ក្នុងគម្ពីរវិមុត្តិមគ្គ បានប្រៀបធៀបថា ការប្រើវិធីអរិយសច្ចៈនេះ មានលក្ខណៈមិនខុសគ្នាទៅនឹងវិធីសាស្ត្រព្យាបាលរបស់គ្រូពេទ្យ ដែលឆ្លាតដូច្នោះដែរ ដែលជាដំបូងគ្រូពេទ្យនោះត្រូវត្រួតពិនិត្យសមុដ្ឋានរបស់រោគជាមុនសិន បន្ទាប់មកទើបត្រួតពិនិត្យរកសារហេតុដែលធ្វើឲ្យកើតរោគ។ ដើម្បីកំចាត់ជម្ងឺនោះ គ្រូពេទ្យក៏ប្រើថ្នាំទៅតាមលក្ខណៈរបស់ជម្ងឺនោះ។ ក្នុងទីនេះ បុគ្គលគប្បីយល់ថា ជម្ងឺប្រៀបបានដូចជាទុក្ខៈ ហេតុនិងបច្ច័យ(របស់ជម្ងឺ) ជាសមុទយៈ។ ការបញ្ចប់នៃជម្ងឺ គឺជានិរោធៈ ហើយថ្នាំព្យាបាលគឺជាមគ្គៈ[៣៦]។ នៅក្នុងព្រះពុទ្ធសាសនាមហាយាន បានថ្វាយព្រះនាមព្រះពុទ្ធថា **ព្រះពុទ្ធភៃសជ្យគុរុ** ប្រែថា **ព្រះពុទ្ធជាគ្រូពេទ្យ** ដែលវប្បធម៌នេះ ក៏បាន សម្តែងចេញជាសិល្បៈព្រះពុទ្ធបដិមាមានគ្រាប់ថ្នាំនៅលើព្រះហស្តដែលដាក់ត្រួតលើគ្នា ទាំងពីរក្នុងឥរិយាបថសមាធិ ដែលគេតែងឃើញនៅក្នុងរចនាបថនាសម័យព្រះបាទជ័យវរ្ម័នទី៧។

[៣៦] គម្ពីរវិមុត្តិមគ្គ បញ្ចឧបាយបរិច្ឆេទ-២ ទំព័រ២៨៩ ការផ្សាយរបស់ពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ព.ស ២៥៥៤



ច្បាប់ធម្មជាតិ ដែលមាននៅក្នុងជីវិតរបស់មនុស្សម្នាក់ៗនេះ មានសក្តានុពលវិឌ្ឍបង្កើតទៅជាច្បាប់សង្គម នៅពេលដែលពួកគេត្រូវរស់ជាមួយគ្នាក្នុងសង្គម ត្រូវរស់នៅជាមួយអ្នកដទៃ ដែលតម្រូវឲ្យម្នាក់ៗត្រូវតែសុខចិត្តឲ្យមានកតិការួមមួយ ដើម្បីការពារ និងអភិវឌ្ឍជីវិត និងសង្គម ឲ្យប្រព្រឹត្តទៅបានស្រួល។

២.២. ច្បាប់គ្រប់គ្រងសង្គមក្នុងពុទ្ធសាសនា

ប្រាំមួយខែបន្ទាប់មក ព្រះសិទ្ធត្ថសមណគោត្តមក៏បានធ្វើមហាសន្និបាតជាផ្លូវការជាមួយនឹងភិក្ខុសង្ឃចំនួន ១២៥០រូប ដើម្បីប្រកាសនូវគោលការណ៍រួម ដែលតម្រូវឲ្យអ្នកដើរតាមការណែនាំរបស់ព្រះអង្គ (សាវ័ក) យកនូវឱវាទដែលអាចចាត់ទុកថាជាច្បាប់សង្គមពិស្តារដំបូងរបស់ពុទ្ធសាសនាយកទៅអនុវត្ត និងប្រកាសដល់មនុស្សជាតិជាសកល។ គោលការណ៍រួមនេះ ព្រះពុទ្ធអង្គហៅថា ឱវាទបាដិមោក្ខ។ ខ្មែរយើងតែងរំលឹកព្រឹត្តិការណ៍នេះជារៀងរាល់ឆ្នាំនៅថ្ងៃពេញបូរមីខែមាឃ (មាឃបូជា) ក្នុងរង្វង់ខែកុម្ភៈ។

ច្បាប់សង្គមជំបូងរបស់ពុទ្ធសាសនា នេះ មានចំនួន ១២ប្រការ៖ ១. មិនត្រូវធ្វើអំពើអាក្រក់ទាំងពួង ២. ត្រូវធ្វើអំពើល្អឲ្យកើតឡើងព្រម ៣. ត្រូវជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់ ៤. ត្រូវមានខន្តី គឺសេចក្តីអត់ធន់ឲ្យខ្ពស់ ៥. ព្រះនិព្វាន ជាធម្មជាតិដ៏ឧត្តមដែល

ត្រូវសម្រេចឲ្យបាន ៦. ជាបព្វជិត ជាសមណៈ មិនត្រូវសម្លាប់ មិនត្រូវបៀតបៀនសត្វដទៃ ៧. មិនត្រូវតិះដៀលអ្នកដទៃ ៨. មិនត្រូវបៀតបៀនអ្នកដទៃ ៩. ត្រូវសង្រួមក្នុងបាតិមោក្ខ ១០. ត្រូវបរិភោគឲ្យស្គាល់ប្រមាណ ១១. ត្រូវដេក និងអង្គុយក្នុងទីដែលស្ងាត់ ១២. ត្រូវអភិវឌ្ឍចិត្តរបស់ខ្លួនឲ្យទៅជាអធិចិត្ត[៣៧]។

1. **សព្វបាបស្ស អករណំ**	1. មិនត្រូវធ្វើអំពើអាក្រក់ទាំងពួង
2. **កុសលស្សូបសម្បទា**	2. ត្រូវធ្វើអំពើល្អឲ្យកើតឡើង
3. **សចិត្តបរិយោទបនំ**	3. ត្រូវជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់
4. **ខន្តិ បរមំ តបោ តីតិក្ខា**	4. ត្រូវមានខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ ដ៏ឧត្តម
5. **និព្វានំ បរមំ វទន្តិពុទ្ធា**	5. ព្រះនិព្វាន ជាធម្មជាតិដ៏ឧត្តមដែលត្រូវសម្រេចឲ្យបាន
6. **ន ហិ បព្វជិតោ បរូបឃាតិ សមណោ ហោតិ បរំ វិហេឋយន្តោ**	6. ជាបព្វជិត ជាសមណៈ មិនត្រូវសម្លាប់ មិនត្រូវបៀតបៀនសត្វដទៃ
7. **អនូបវាទោ**	7. មិនត្រូវតិះដៀលអ្នកដទៃ
8. **អនូបឃាតោ**	8. មិនត្រូវបៀតបៀនអ្នកដទៃ
9. **បាដិមោក្ខេ ច សំវរោ**	9. ត្រូវសង្រួមក្នុងបាតិមោក្ខ
10. **មត្តញ្ញុតា ច ភត្តស្មិំ**	10. ត្រូវបរិភោគឲ្យស្គាល់ប្រមាណ
11. **បន្តញ្ច សយនាសនំ**	11. ត្រូវដេក និងអង្គុយក្នុងទីដែលស្ងាត់
12. **អធិចិត្តេ ច អាយោគោ**	12. ត្រូវព្យាយាមអភិវឌ្ឍចិត្តរបស់ខ្លួនឲ្យទៅជាអធិចិត្ត

ទោះជាយ៉ាងណាក្តី ព្រះសិទ្ធត្ថសមណគោត្តមមិនទាន់បានដាក់ចេញនូវវិន័យ ឬប្រព័ន្ធដាក់ទោសដល់សមាជិក សមាជិកា ដែលស្ម័គ្រចិត្តចូលមកអនុវត្តតាមច្បាប់សង្គមដែលបានចេញ និងទទួលយកជាធរមាននៅថ្ងៃមហាសន្និបាតនេះនៅឡើយទេ។ ព្រះសារីបុត្រ ដែលជាអគ្គសាវ័កស្តាំ (ប្រហាក់ប្រហែលអនុប្រធានាធិបតីទី១) ដែលជាបញ្ញវន្តសង្ឃមួយរូបនាសម័យនោះ ធ្លាប់បានស្នើសុំឲ្យព្រះពុទ្ធអង្គចេញជាវិន័យ ជាច្បាប់ ជាសិក្ខាបទ (អាណាបាតិមោក្ខ[៣៨]) សម្រាប់គ្រប់គ្រងសង្ឃ ព្រោះដោយលោកយល់ឃើញថា ប្រទេសមួយ ឬស្ថាប័នមួយ មិនអាចមិនមានច្បាប់សម្រាប់គ្រប់គ្រងទេ តែត្រូវព្រះពុទ្ធអង្គបដិសេធមិនទាន់បញ្ញត្តសិក្ខាបទ និងដាក់ចេញនូវអាណាបាដិមោក្ខ ដោយផ្តល់ហេតុផលថា៖

---

[៣៧] បិដក ភាគ ៥២ - ទំព័រទី ៦០

[៣៨] អាណាបាតិមោក្ខ ជាអាជ្ញា សេចក្តីបង្គាប់ ពាក្យប្រដៅ អំណាច បញ្ញត្តិ ច្បាប់បញ្ញត្តិ បញ្ញត្តិមានកម្រិត ការគ្រប់គ្រង ការបង្គាប់បញ្ជា សម្រាប់ភិក្ខុសង្ឃ។ អាណាបាតិមោក្ខនេះ ត្រូវសូត្ររំលឹករៀងរាល់កន្លះខែម្តង នៅក្នុងរោងឧបោសថ ដោយមានភិក្ខុសង្ឃមកប្រជុំ ហើយស្តាប់ផ្ទៀងផ្ទាត់ ថាតើខ្លួនបានធ្វើខុសនឹងមាត្រាណាមួយក្នុងចំណោមមាត្រាទាំង ២២០ (សិក្ខាបទ) ដែលមាននៅក្នុងអាណាបាតិមោក្ខ។

ក. ធម៌ទាំងឡាយខ្លះ ដែលជាទីតាំងនៃអាសវៈ (អំពើអាក្រក់) មិនទាន់ប្រាកដចំពោះសង្ឃក្នុងសាសនា។

ខ. សង្ឃពេលនោះ ជាសង្ឃស្ថិតនៅក្នុងរយៈស្ថាបនាពុទ្ធសាសនាជាដំបូងៗ គឺទើបនឹងមានអ្នកស្ម័គ្រចូលមកបួសថ្មី។ ចំនួនអ្នកបួសមានវស្សាច្រើន នៅមិនទាន់មានចំនួនច្រើននៅឡើយ។

គ. ចំនួនព្រះសង្ឃ នៅមានបរិមាណតិចនៅឡើយ។

ឃ. ប្រជាជនទូទៅមិនទាន់មានសទ្ធាច្រើននៅឡើយ ដែលនាំឲ្យលាភសក្ការៈដែលកើតឡើងដល់សង្ឃក៏នៅមានចំនួនតិច។

ង. កិក្ខុសង្ឃនៅមិនទាន់មានពុត (ហ៊ានលបលួចធ្វើអាក្រក់) មិនទាន់មានទោសគួរបារម្ភនៅឡើយ កំពុងនៅមានធម៌បរិសុទ្ធ ឥតទាន់មានពណ៌ខ្មៅសៅហ្មង។

ច. កិក្ខុសង្ឃទាំង ៥០០រូប ដែលនៅជាមួយព្រះពុទ្ធអង្គពេលនោះ សុទ្ធតែជាព្រះអរិយបុគ្គល ដែលយ៉ាងទាបបំផុតក៏បាននូវអរិយគុណកម្រិតទី៤ដែរ គឺបានស្ថានៈជាសោតាបន្នបុគ្គល[៣៩]។

ជារួម ព្រះសង្ឃនាពេលនោះ មិនទាន់មានរូបណាធ្វើខុស ដែលអាចនឹងនាំមកនូវទុក្ខទោសដល់សង្គមសង្ឃ ក៏ដូចជាផលវិបាកដល់សង្គមជាតិ នៅឡើយ[៤០]។ លុះក្រោយមក មានកិក្ខុមួយរូបបានធ្វើខុសយ៉ាងធ្ងន់ធ្ងរ ដែលធ្វើឲ្យប្រជាជនរិះគន់ និងអាប់ឱនដល់កិត្តយសរបស់ពុទ្ធសាសនា ទើបព្រះអង្គហៅប្រជុំកិក្ខុសង្ឃក្នុងចំនួនដ៏ច្រើនមកប្រាប់ថា ព្រះអង្គនឹងរៀបចំជាវិន័យ ជាច្បាប់ ដាក់ចេញដល់កិក្ខុសង្ឃ កុំឲ្យប្រព្រឹត្តល្មើស ហើយបើរូបណាប្រព្រឹត្តល្មើស រូបនោះនឹងត្រូវទទួលទោសច្រើន តិច ទៅតាមទំហំនៃកំហុសដែលបានប្រព្រឹត្តកន្លងហួស។ ព្រះសម្មាសម្ពុទ្ធបានផ្តល់នូវហេតុផល ១០ប្រការ[៤១] ដែលនាំឲ្យព្រះអង្គចេញអាណាបាតិមោក្ខ (ច្បាប់) សម្រាប់គ្រប់គ្រងការប្រព្រឹត្តរបស់សមាជិកសមាជិកា គ្រប់ៗគ្នា ក្នុងមណ្ឌលពុទ្ធសាសនា ដោយមាត្រានីមួយៗ ហៅថាសិក្ខាបទ។ **សិក្ខាបទ** ឬមាត្រានៃច្បាប់សម្រាប់កិក្ខុសង្ឃ បានកើនចំនួនរហូតដល់ ២២០មាត្រា និងសម្រាប់កិក្ខុនីសង្ឃ មានចំនួនដល់ទៅ ៣០៤មាត្រា។ អាណាបាតិមោក្ខ នេះ មានគោលបំណងៈ

---

[៣៩] កម្រិតទី៤ សោតាបន្នបុគ្គល។ កម្រិតតី៣ សកទាគាមិបុគ្គល។ កម្រិតតី២ អនាគាមិបុគ្គល។ កម្រិតតី១ អរហត្តបុគ្គល។

[៤០] បិដក ភាគ ០១ - ទំព័រទី ២៧

[៤១] បិដក ភាគ ០១ - ទំព័រទី ៦៥

១. ដើម្បីបង្កើនសេចក្តីល្អដល់ស្ថាប័នសង្ឃ (សង្ឃសុដ្ឋុតាយ)
២. ដើម្បីឲ្យសង្ឃជាសមាជិក-សមាជិកា អាចរស់នៅដោយប្រកបដោយផាសុកភាព មានសេចក្តីសុខ សប្បាយ ព្រោះស្ថិតនៅក្រោមវិន័យតែមួយ (សង្ឃផាសុតាយ)
៣. ដើម្បីសង្កត់សង្កិនភិក្ខុ-ភិក្ខុនីទាំងឡាយ ដែលមិនអៀនខ្មាសក្នុងការប្រព្រឹត្តខុស មិនអាចនឹងហ៊ានប្រព្រឹត្តខុស ព្រោះមានវិន័យចាំដាក់ទោស ទោះប្រព្រឹត្តខុសដោយគេបានឃើញ ឬមិនបានឃើញក្តី (ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ)
៤. ដើម្បីឲ្យភិក្ខុ-ភិក្ខុនីទាំងឡាយ ដែលជាអ្នកមានសីលជាទីស្រឡាញ់ ហើយមិនដែលប្រព្រឹត្តខុស អាចរស់នៅបានជាសុខស្រួល (បេសលានំ ភិក្ខូនំ ផាសុវិហារាយ)
៥. ដើម្បីរារាំងនូវអាសវធម៌ - គឺកិលេសដែលមាននៅក្នុងសន្តានចិត្ត មិនឲ្យធើបចេញមកខាងក្រៅ តាមរយៈទង្វើ និងការនិយាយ ក្នុងបច្ចុប្បន្នកាល (ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ)
៦. ដើម្បីកម្ចាត់ចោលនូវអាសវធម៌ គឺកិលេសនៅខាងក្រៅ ដែលនឹងកើតមាននៅពេលអនាគត មិនឲ្យចូលមកក្នុងសន្តានចិត្តបាន (សម្បរាយិកានំ អាសវានំ បដិឃាតាយ)
៧. ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាតាមរយៈការប្រព្រឹត្តរបស់ព្រះសង្ឃ ឲ្យកើតសេចក្តីជ្រះថ្លាឡើង (អប្បសន្នានំ បសាទាយ)
៨. ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយក្នុងពុទ្ធសាសនាតាមរយៈការប្រព្រឹត្តរបស់ព្រះសង្ឃ ឲ្យរឹងរឹតតែជ្រះថ្លាថែមទៀត (បសន្នានំ ភិយ្យោភាវាយ)
៩. ដើម្បីឲ្យពាក្យប្រៀនប្រដៅរបស់ពុទ្ធសាសនា តំកល់នៅមាំបានយូរ (សទ្ធម្មដ្ឋិតិយា)
១០. ដើម្បីអនុគ្រោះដល់ព្រះវិន័យ គឺការបង្ហាញពីសារៈសំខាន់នៃវិន័យច្បាប់ដែលត្រូវតែមាន ទោះជានៅក្នុងប្រទេស ឬស្ថាប័ណាក៏ដោយ មិនអាចអត់មានវិន័យ ឬច្បាប់បានទេ (វិនយានុគ្គហាយ)

នៅមួយកន្លែងទៀត ព្រះពុទ្ធអង្គទ្រង់បានសម្តែងអំពីលក្ខណៈ ៨យ៉ាង ដល់ភិក្ខុនី ឈ្មោះ មហាបជាបតីគោតមី សម្រាប់កំណត់ ឬសម្គាល់ថា ធម៌វិន័យរបស់ព្រះអង្គ មានលក្ខ

ណៈបែបណា ដើម្បីឲ្យភិក្ខុ-ភិក្ខុនី អាចធ្វើការឆ្លុះបញ្ចាំងដោយខ្លួនឯងបានថា ធម៌វិន័យនេះ ម្នាក់ៗបានបដិបត្តត្រឹមត្រូវឬទេ[៤២]៖ ធម្មវិន័យនេះ ១. ប្រព្រឹត្តទៅដើម្បីកំចាត់តម្រេក មិនមែនដើម្បីបង្កើតតម្រេកទេ ២. ប្រព្រឹត្តទៅដើម្បីការមិនវិលវល់ក្នុងវដ្តៈ មិនមែនដើម្បីវិលវល់ក្នុងវដ្តៈទេ ៣. ប្រព្រឹត្តទៅដើម្បីការមិនសន្សំកិលេសវដ្តៈ មិនមែនដើម្បីសន្សំកិលេស វដ្តៈទេ ៤. ប្រព្រឹត្តទៅដើម្បីសេចក្តីប្រាថ្នាតិច មិនមែនដើម្បីសេចក្តីប្រាថ្នាច្រើនទេ ៥. ប្រព្រឹត្តទៅដើម្បីសេចក្តីសន្តោស មិនមែនដើម្បីសេចក្តីមិនសន្តោសទេ ៦. ប្រព្រឹត្តទៅដើម្បីការស្ងប់ស្ងាត់ចាកក្រុម-ពួក មិនមែនដើម្បីការច្រឡូកច្រឡំដោយក្រុម-ពួកទេ ៧. ប្រព្រឹត្តទៅដើម្បីប្រារព្ធសេចក្តីព្យាយាម មិនមែនដើម្បីសេចក្តីខ្ជិលច្រអូសទេ ៨. ប្រព្រឹត្តទៅដើម្បីឲ្យគេចិញ្ចឹមបានដោយងាយ មិនមែនដើម្បីគេចិញ្ចឹមបានដោយលំបាក ទេ។

នៅមួយកន្លែងទៀតផងដែរ ព្រះពុទ្ធអង្គបានសម្តែងអំពីលក្ខណៈ ៧យ៉ាង ទៀតនៃធម្មវិន័យ ដល់ភិក្ខុ១រូប ដែលជាឯកទគ្គៈខាងវិន័យ គឺព្រះភិក្ខុឧបាលី សម្រាប់កំណត់ ឬសម្គាល់ថាជាធម៌វិន័យរបស់ព្រះអង្គ[៤៣]៖ ១. ធម៌ទាំងឡាយនេះ នាំឲ្យនឿយណាយដោយដាច់ខាត ២. ធម៌ទាំងឡាយនេះ នាំឲ្យរសាយចិត្ត ៣. ធម៌ទាំងឡាយនេះ នាំឲ្យរលត់ ៤. ធម៌ទាំងឡាយនេះ នាំឲ្យស្ងប់ ៥. ធម៌ទាំងឡាយនេះ នាំឲ្យបានអភិញ្ញា ៦. ធម៌ទាំងឡាយនេះ នាំឲ្យបានត្រាស់ដឹង ៧. ធម៌ទាំងឡាយនេះ នាំឲ្យបានព្រះនិព្វាន។

ទោះជាយ៉ាងណាក្តី អាណាបាតិមោក្ខ ឬច្បាប់គ្រប់គ្រងគណៈសង្ឃនេះ ពុំបានយកទោសដល់អ្នកដែលបានប្រព្រឹត្តកំហុសមុនសិក្ខាបទ (មាត្រា) បានបញ្ញត្តដោយព្រះពុទ្ធអង្គឡើយ (Ex Post Facto Laws) គឺដាក់ទោសតែអ្នកដែលប្រព្រឹត្តកំហុស បន្ទាប់ពីសិក្ខាបទបានបញ្ញត្តរួចហើយតែប៉ុណ្ណោះ (Prospective Law)។

ធម៌ និងវិន័យ ជាតួអង្គយ៉ាងសំខាន់ក្នុងការសម្រេចឲ្យបាននូវអ្វីដែលជាគោលដៅសម្រាប់សង្គមសង្ឃ។ ពាក្យ **ពុទ្ធសាសនា** ដែលប្រើនាពេលបច្ចុប្បន្ននេះ ក្នុងសម័យពុទ្ធកាលសំដៅតែលើពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធតែប៉ុណ្ណោះ។ ចំពោះព្រះពុទ្ធអង្គវិញ ព្រះអង្គប្រើត្រឹមពាក្យ ធម្មវិន័យ ដែលសំដៅលើការគ្រប់គ្រងពុទ្ធសាសនាក្នុងឋានៈជាស្ថាប័នអង្គការ និងការផ្សព្វផ្សាយពុទ្ធសាសនាដែលជាពាក្យប្រៀនប្រដៅ។ សារៈសំខាន់របស់ធម្ម

---

[៤២] ភិក្ខុនីឧបសម្បទានុជាននំ មហាបជាបតីគោតមីវត្ថុ វិនយោចនា រឿងព្រះនាងមហាបជាបតីគោតមី និងការសូមពរ បិដក ភាគ ១១ - ទំព័រទី ២៧៩ (១-វិភាគៈ ២-វិសំយោគៈ ៣-អបចយៈ ៤-អប្បិច្ឆតា ៥-សន្តុដ្ឋី៦-បវិវេកៈ ៧-វិរិយារម្ភៈ ៨-សុភរតា)

[៤៣] សត្តុសាសនសូត្រ ទី៩ បិដក ភាគ ៤៧ - ទំព័រទី ២៥៩ (១-ឯកន្តនិព្វិទា ២-វិរាគៈ ៣-និរោធៈ ៤-ឧបសមៈ-៥-អភិញ្ញា ៦-សម្ពោធៈ ៧-និព្វាន)

វិន័យបានត្រូវព្រះសិទ្ធត្ថសមណគោត្តមលើកឡើងជាចុងក្រោយម្តងទៀតនៅមុនពេលតែបន្តិចដែលព្រះអង្គនឹងទ្រង់បរិនិព្វាន គឺអ្វីដែលព្រះអង្គបានត្រាស់ប្រាប់ព្រះអានន្ទជាលេខាផ្ទាល់ព្រះអង្គ[៤៤] ថា៖ «ម្នាលអានន្ទ ប្រសិនបើអ្នកទាំងឡាយមានសេចក្តីត្រិះរិះយ៉ាងនេះថា ពាក្យប្រៀនប្រដៅដែលមានគ្រូប្រព្រឹត្តកន្លងទៅហើយ (បរិនិព្វានហើយ) គ្រូរបស់យើងឈ្មោះថាមិនមានឡើយ។ សេចក្តីនេះ អ្នកកុំចូលចិត្តយ៉ាងនេះឡើយ។ ម្នាលអានន្ទ **ធម៌ណាក្តី វិន័យណាក្តី ដែលតថាគតសំដែងហើយ បញ្ញត្តហើយ ដល់អ្នកទាំងឡាយ លុះអំណឹះឥតអំពីតថាគតទៅ ធម៌ និងវិន័យនោះ គឺជាគ្រូរបស់អ្នកទាំងឡាយ**[៤៥]។

ធម្មវិន័យ និងនីតិរដ្ឋធម្មវិន័យ គឺជាមូលហេតុចម្បងដែលព្រះពុទ្ធអង្គពុំបានតែងតាំងអង្គណាមួយសម្រាប់តំណាងព្រះអង្គឡើយ គឺមានតែធម្មវិន័យប៉ុណ្ណោះដែលធំជាងអ្វីៗទាំងអស់ទាំងជាធម៌ដែលជាច្បាប់មូលដ្ឋាន និងវិន័យដែលជាច្បាប់សង្គម (Law is supreme: natural and social law)។ បើសិនជាព្រះពុទ្ធអង្គលើកកិក្ខុរូបណាជាអ្នកបន្តវេននោះ ពុទ្ធសាសនាអាចនឹងមិនមានរូបភាពដូចបច្ចុប្បន្នឡើយ ព្រោះការប្រកួតប្រជែងក្នុងការបន្តវេនជាអ្នកដឹកនាំពុទ្ធសាសនា នឹងក្លាយទៅជាវេទិកានយោបាយ ដោយជៀសមិនផុតឡើយ។ ខ្ញុំគិតថា ព្រះពុទ្ធអង្គប្រាកដជាបានជ្រាបក្នុងព្រះទ័យហើយថា ការតែងតាំងអង្គណាមួយជំនួសព្រះអង្គ នឹងនាំមកនូវស្ថានការណ៍ នីតិបុគ្គល (rule of man) ជាជាងនីតិរដ្ឋ (rule of law) ជាពុំខាន។ ដូច្នេះ ការយកធម្មវិន័យជាបន្ទាត់ ជាស្តង់ដា ជាធម្មាធិបតេយ្យ (rule of Dhammaviniya) ផ្តល់នូវឥស្សរភាពក្នុងការប្រតិបត្តតាមបានគ្រប់គ្នា ព្រោះភិក្ខុ-ភិក្ខុនី គ្រប់រូប ទោះជាមានវស្សានៃការបួសប៉ុនណា ឬនាពេលបច្ចុប្បន្នបានទទួលសមណសក្តិប៉ុនណាក្តី ក៏សុទ្ធតែត្រូវស្ថិតនៅក្រោមអំណាចនៃនីតិរដ្ឋធម្មវិន័យដូចៗគ្នា។



[៤៤] ព្រះអានន្ទ ជាលេខាផ្ទាល់ព្រះពុទ្ធ។ ពាក្យដើមគឺ ព្រះអានន្ទជាពុទ្ធុបដ្ឋាក

[៤៥] បិដក ភាគ ១៦ - ទំព័រទី ៣២១

៣. ពុទ្ធសាសនានឹងច្បាប់សង្គម

ក្នុងផ្នែកទី១ អត្ថបទនេះបានជជែកអំពីនិយាមរបស់ពាក្យ ច្បាប់សង្គម (Social Law) ទាំងក្នុងន័យភាសាខ្មែរ និងក្នុងន័យរបស់នីតិកោសលបស្ចឹមប្រទេស ហើយផ្នែកទី ២ ក៏បានព្យាយាមមើលទៅលើវចនៈរបស់ពុទ្ធសាសនា ថាតើមានទស្សនាទានទាក់ទងនឹងច្បាប់សង្គមនៅចំណុចណាខ្លះ។ ក្នុងផ្នែកទី៣នេះ នឹងនិយាយអំពីការយកវចនៈរបស់ព្រះសិទ្ធត្ថសមណគោត្តម ដែលបុរាណាចារ្យបានចារទុកក្នុងគម្ពីរព្រះពុទ្ធសាសនា យកមកអនុវត្តក្នុងជីវិតរបស់ប្រជាពលរដ្ឋខ្មែរទាក់ទងនឹងច្បាប់សង្គមក្នុងទិដ្ឋភាពបច្ចុប្បន្ន។

ដោយហេតុថា ការនិយាយអំពីច្បាប់ផ្សេងៗ ច្បាប់សង្គម និងធម្មវិន័យ(ច្បាប់)ពុទ្ធសាសនា សុទ្ធតែត្រូវការនីតិរដ្ឋទាំងអស់ ដើម្បីទទួលបាននូវការទុកចិត្តពីរដ្ឋ រាស្ត្រ និងបរិស័ទទាំង៤ ដូច្នេះ ការយល់ពីនីតិរដ្ឋ គឺជាខ្លឹមសារនៃច្បាប់ និងការអនុវត្តច្បាប់គ្រប់ប្រភេទនៅក្នុងចំណុចទី៣នៃប្រធានបទនេះតទៅ។

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ ជាការកសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧ ដែលមានកោណចំនួន៥៖ (១) ធានាឱ្យបានកំណើនសេដ្ឋកិច្ច (២) បង្កើតការងារឱ្យបានកាន់តែច្រើន (៣) សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ (៤) បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន (៥) ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គមសេដ្ឋកិច្ច។ ចំណែកនៅក្នុងឯកសារ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាលអាណត្តិទី៧ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត បានមានប្រសាសន៍នៅក្នុងបុព្វកថា ថា៖ **«កម្ពុជាត្រូវការប្រព័ន្ធច្បាប់មួយដែលផ្តែកលើនីតិរដ្ឋ ដើម្បីការពារឯករាជ្យ បូរណភាពទឹកដី ភាពជាម្ចាស់ ការពារសិទ្ធិមនុស្ស និងកម្មសិទ្ធិឯកជន យុត្តិធម៌សង្គម ព្រមទាំងគាំទ្រដល់សេដ្ឋកិច្ចទីផ្សារដែលរស់រវើក ក៏ដូចជាការអភិវឌ្ឍសង្គមសេដ្ឋកិច្ចទាំងមូល។ .....ហើយវប្បធម៌នីតិរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា នឹងមានវិសាលភាពគ្រប ដណ្តប់លើការកសាងប្រព័ន្ធច្បាប់កម្ពុជាទាំងមូល នៅលើមាគ៌ានៃការពង្រឹងអភិបាលកិច្ច និងធានាចីរភាពនៃវប្បធម៌នីតិរដ្ឋ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិផង និងបរិការណ៍ប្រវត្តិសាស្ត្រកម្ពុជាផង»**[៤៦]។ ចំណែកនៅក្នុងឯកសារ **ទស្សនាទានសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា** បានបញ្ជាក់អំពីគោលបំណងចុងក្រោយនៃការក

[៤៦] ឯកសារ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ផ្សព្វផ្សាយនៅខែមេសា ២០២៥

សាងប្រព័ន្ធច្បាប់កម្ពុជា គឺដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា ដែលគោលបំណងនេះ មានសេចក្តីពន្យល់ថា៖ **«បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ សំដៅដល់ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ដោយធានាបាននូវការប្រកាន់ខ្ជាប់ជានិរន្តរ៍នូវការគោរព ប្រតិបត្តិ និងតម្កល់ច្បាប់ជាធំ ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នា និងជំនឿទុកចិត្ត»**[៤៧]។

នីតិរដ្ឋ ជាពាក្យគន្លឹះដ៏សំខាន់ក្នុងការធ្វើឲ្យកើតឡើងនូវជំនឿទុកចិត្តលើច្បាប់ ជំនឿទុកចិត្តលើរាជរដ្ឋាភិបាល និងជំនឿទុកចិត្តលើប្រជាពលរដ្ឋកម្ពុជា ដោយស្មើភាពគ្នា។ ដូច្នេះ នីតិរដ្ឋ (**វិន័យ**) គឺជាដៃគូយុទ្ធសាស្ត្របញ្ចាកោណដែលមានមុំទាំង៥ (**ធម៌**) ដោយមិនអាចខ្វះបាន បីដូចជា **ចិត្តថ្លើម**[៤៨] ដែលជាប្រយោជន៍សម្រាប់រាងកាយ និងជីវិតទាំងមូល។ **យុទ្ធសាស្ត្របញ្ចាកោណទាំងប្រាំមុំ សុទ្ធតែត្រូវការច្បាប់គាំទ្រទាំងអស់** តែបើច្បាប់ទាំងនោះពុំមាននីតិរដ្ឋទេ ច្បាប់នោះក៏នឹងមិនអាចឲ្យផលបានគ្រប់គ្រាន់ទៅលើការអនុវត្តយុទ្ធសាស្ត្រដែលមានមុំទាំង៥ បានល្អដែរ។ ច្បាប់ មិនប្រាកដជាល្អគ្រប់សព្វទេ តែបើនីតិរដ្ឋនៃច្បាប់នោះរឹងប៉ឹង ភាពស្មើគ្នានៅចំពោះមុខច្បាប់ នឹងមានភាពប្រសើរជាមិនខាន។

៣.១. នីតិរដ្ឋតាមន័យាមផ្សេងៗ

ភាសាខ្មែរយើងប្រែពាក្យ "នីតិរដ្ឋ" ពីពាក្យអង់គ្លេសថា Rule of Law តែក្នុងទីនេះ ខ្ញុំសូមប្រែទៅជា "**នីតិកិបាល**" វិញ ព្រោះថា៖

១. តាមព្យញ្ជនៈន័យ ពាក្យថា Rule ប្រែថា ការគ្រប់គ្រង (ជាភាសាខ្មែរ) ឬ អភិបាល (ជាភាសាបាលី)

២. តាមព្យញ្ជនៈន័យ ពាក្យថា Law គឺ ច្បាប់ (ជាភាសាខ្មែរ) ឬ នីតិ (ជាភាសាបាលី)

៣. សំរាប់អ្នកដែលចង់ប្រៀបធៀបភាសាខ្មែរជាមួយនឹងភាសាអង់គ្លេស អាចមានចម្ងល់ថា តើពាក្យ រដ្ឋ ប្រែមកពីពាក្យអ្វី ព្រោះភាសាអង់គ្លេសពុំមានពាក្យ State ដែលស្មើនឹងពាក្យខ្មែរថា **រដ្ឋ** នេះសោះ។ តែសម្រាប់ជាភាសា

[៤៧] Ibid ចក្ខុវិស័យ បេសកកម្មនិងយុទ្ធសាស្ត្រ ទំព័រ ២៧

[៤៨] ចិត្តថ្លើម ជាអង្គប្រកបសំខាន់ក្នុងជំណើរវិថីជីវិតខ្មែរ

> អាឡឺម៉ង់វិញ ពាក្យថា Rechtsstaat[៤៩] ដែលប្រែមកជាភាសាអង់គ្លេសថា Sate of Law ឬ legal state អាចនឹងប្រែជាភាសាខ្មែរដោយត្រង់បានថា នីតិរដ្ឋ ព្រោះ Staat នេះប្រែថារដ្ឋ ឯ Rechts នេះប្រែថា ច្បាប់ នីតិ។ ពាក្យនេះក៏បានវិវត្តទៅជាពាក្យ Rule of Law ដែលអាចប្រែថា " ការគ្រប់គ្រងរបស់ច្បាប់ ឬ **នីតិកិបាល** ជាភាសាបាលី។ ទោះជាយ៉ាងណាក្តី ពាក្យនីតិកិបាល នឹងមិនត្រូវបានប្រើប្រាស់ក្នុងអត្ថបទនេះទេ ដើម្បីជៀសវាងភាពស្រពេចស្រពិល ក្នុងការអានអត្ថបទ។

នីតិរដ្ឋ គឺជាទស្សនាទាន (Concept) និងជាគោលការណ៍ (Principle) ដែលន័យរបស់ពាក្យនេះ មិនអាចកំណត់បានដោយច្បាស់លាស់ ឬនៅក្នុងព្រំដែននៃព្យញ្ជនៈន័យទេ គឺជាអត្ថន័យ។ នីតិរដ្ឋនៃប្រទេសអង់គ្លេស មិនប្រាកដថាដូចគ្នាទៅនឹងនីតិរដ្ឋនៃសហរដ្ឋអាមេរិកទេ ហើយក៏មិនប្រាកដជាអាចយកមកឱ្យពលរដ្ឋកម្ពុជាយល់ថា នីតិរដ្ឋ ឬ Rule of Law នេះ ត្រូវតែមានន័យដូច្នេះ ឬក៏ត្រូវយកមកអនុវត្តយ៉ាងណានោះដែរ។ ដោយងាយយល់ ទោះបីជាខ្មែរ និងបារាំង (បស្ចឹមប្រទេស) ជាមនុស្សជាតិដូចគ្នាក៏ដោយ ក៏ភូមិសាស្ត្រ វប្បធម៌ ចំណេះដឹង និងអាហារ (បាយ - នំបុ័ង) មិនអាចធ្វើឱ្យនីតិរដ្ឋនៃប្រទេសទាំងពីរនេះ ដូចគ្នាទាំងអស់បានទេ។

ក្នុងន័យជាទូទៅ នីតិរដ្ឋ គឺជាគោលការណ៍ស្នើឡើងក្នុងគោលបំណងធ្វើឲ្យទំនាក់ទំនងរវាងអ្នកដឹកនាំ (រដ្ឋាភិបាល) និងអ្នកត្រូវគេដឹកនាំ (ប្រជាពលរដ្ឋ) មានភាពប្រសើរឡើង ដោយឈរនៅលើបន្ទាត់ (Rule) តែមួយ និងស្ថិតនៅក្រោមអំណាចគ្រប់គ្រង (Rule) របស់ច្បាប់តែមួយដូចគ្នា ហើយភាគីទាំងពីរគប្បីមានប្រភពចេញមកពីមូលដ្ឋានមនុស្សដូចគ្នា គឺម្នាក់ៗមានសិទ្ធិជាមនុស្សដូចគ្នា មានសេរីភាពដូចគ្នា និងស្ថិតនៅក្រោមច្បាប់ធម្មជាតិ ៣យ៉ាង ដូចគ្នា គឺ៖ កើត ចាស់ ស្លាប់[៥០]។

---

[៤៩] Wikipedia: The actual expression *Rechtsstaat* appears to have been introduced by Carl Theodor Welcker in ១៨១៣,[៩][90] but it was popularised by Robert von Mohl's book *Die deutsche Polizeiwissenschaft nach den Grundsätzen des Rechtsstaates* ("German Policy Science according to the Principles of the Constitutional State"; ១៨៣២–៣៣). Von Mohl contrasted government through policy with government, in a Kantian spirit, under general rules, https://en.wikipedia.org/wiki/Rechtsstaat#:~:text=The%20actual%20expression%20Rechtsstaat%20appears, Kantian%20spirit%2C%20under%20general%20rules

[៥០] នីតិកិបាលកម្ពុជា: សេចក្តីប្រាថ្នា ការងារ និង ការពិត ហេង មណីចិន្តា ២០២០

៣ក្យថា «ការដែលស្ថិតនៅលើបន្ទាត់តែមួយ» គឺជាសម្មតិកម្មធម្មជាតិរបស់មនុស្សគ្រប់រូប ដែលកើតមកពីផ្ទៃមាតាដូចគ្នា ដូច្នេះ គប្បីមានសិទ្ធិសេរីភាពដូចគ្នាទាំងអស់ មិនថាជនជាតិណាជាជនជាតិណាទេ»។ ការដែលស្ថិតនៅក្រោមអំណាចគ្រប់គ្រងរបស់ច្បាប់តែមួយដូចគ្នា គឺជាសំណើសង្គមដែលផ្អែកលើគំហើញ ពិត ដែលថា ភាគច្រើននៃរដ្ឋដែលកាន់កាប់ដោយរដ្ឋាភិបាល តែងប្រើប្រាស់អំណាចរបស់ខ្លួនរំលោភលើព្រំដែនសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋខ្លួន។ សំណើសង្គមនេះ គឺចង់ឲ្យរដ្ឋាភិបាល (ទោះបីជាខ្លួនមានអំណាចគ្រប់គ្រងពលរដ្ឋ និងអាចធ្វើអ្វីក៏បានក្តី) យកអំណាចប្រតិបត្តិរបស់ខ្លួននោះទៅស្ថិតនៅក្រោមអំណាចរបស់ច្បាប់ ដូចជាពលរដ្ឋទូទៅផងដែរ។ ដូច្នេះ គន្លឹះសំខាន់របស់នីតិរដ្ឋ គឺការកំណត់អំណាចរបស់រដ្ឋាភិបាលឲ្យស្ថិតនៅក្រោមការគ្រប់គ្រងឬក្រោមអំណាចរបស់ច្បាប់ និងជាការព្យាយាមដើម្បីការពារសិទ្ធិនិងសេរីភាពរបស់ពលរដ្ឋឱ្យផុតអំពីការរំលោភបំពាននៃការប្រើអំណាចរបស់រដ្ឋាភិបាល[៥១]។

៣.២. នីតិរដ្ឋតាមពុទ្ធសាសនា និងការអនុវត្ត

នៅក្នុងព្រះសូត្រដែលមានឈ្មោះថា **អធិបតេយ្យសូត្រ**[៥២] ព្រះសម្មាសម្ពុទ្ធបានសំដែងអំពីអធិបតេយ្យភាព ៣យ៉ាង (supremacy) ដូច្នេះគឺ៖

១. **អត្តាធិបតេយ្យ** អធិបតេយ្យអាស្រ័យលើខ្លួន (Supremacy of self)

២. **លោកាធិបតេយ្យ** អធិបតេយ្យអាស្រ័យលើប្រជាជន (Supremacy of the public)

៣. **ធម្មាធិបតេយ្យ** អធិបតេយ្យអាស្រ័យលើធម៌ (Supremacy of the true law)

ក្នុងចំណោមអធិបតេយ្យទាំង៣នេះ ព្រះសម្មាសម្ពុទ្ធទ្រង់លើកទឹកចិត្ត និងសរសើរដល់កិក្ខុអង្គណា ដែលមានធម្មាធិបតេយ្យ នៅក្នុងការបដិបត្តិរបស់ខ្លួន។

ឧទាហរណ៍មួយដ៏ជាក់ស្តែង ក្នុងការអនុវត្តធម្មាធិបតេយ្យក្នុងពុទ្ធសាសនា-- **សមភាពចំពោះមុខច្បាប់** គឺពេលដែលព្រះអានន្ទដែលជាឧបការីរបស់ព្រះសម្មាសម្ពុទ្ធ ជាបញ្ញវន្តលេខ១ខាងធម្មវិនិយ និងជាព្រះអរហន្តទៀតផងនោះ ត្រូវព្រះសង្ឃដែលជាគណៈវិនិយដាក់ទោសដោយមិនមានការយោគយល់ ព្រោះលោកបានធ្វែសប្រហែសក្នុងការងារតួនាទីរបស់លោកចំនួន ៥ករណី។ ថ្វីត្បិតតែព្រះអានន្ទលោកគិតថា ទង្វើរបស់លោក

[៥១] ibid

[៥២] គម្ពីរសុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត បិដកលេខ ៤១ ទំព័រ ១១៣

ដែលបានធ្វើនោះមិនខុសក្តី ក៏លោកទទួលយកនូវកំហុសនោះ ព្រោះលោកជឿថា សេចក្តីសំរេចរបស់គណៈវិន័យតែងមានភាពត្រឹមត្រូវ(ចៅក្រមសង្ឃ)។ ចំណុចមួយទៀតក្នុងព្រះពុទ្ធសាសនា ដែលគួរយកមកធ្វើជាគតិ ក្នុងនីតិវដ្ឋនាបច្ចុប្បន្ននេះ គឺ ព្រះភិក្ខុគ្រប់រូបក្នុងព្រះពុទ្ធសាសនា ទោះជាទើបនឹងបួសបាន១ថ្ងៃ ឬបួសមកហើយ១០០ឆ្នាំក្តី ជាភិក្ខុសាមញ្ញមួយរូប ឬជាសម្តេចអគ្គមហាសង្ឃរាជដែលជាប្រធានសង្ឃជាង ៦ម៉ឺនរូប ក្នុងរាជាណាចក្រកម្ពុជាក្តី ពេលដែលធ្វើខុសក្នុងវិន័យ (ត្រូវអាបត្តិ) សង្ឃ ដែលមានចំនួន **២២៧មាត្រា**នោះ(តាំងពីទោសធំបំផុតគឺត្រូវលាសិក្ខាបទ=បារាជិក រហូតដល់ទោសតូចបំផុត ដែលត្រូវសារភាពប្រាប់ភិក្ខុដទៃទៀត=ទុក្កដ នឹងត្រូវមានទោសដូចគ្នា ហើយត្រូវធ្វើកិច្ចដើម្បីរួចពីទោសនោះដូចគ្នាដែរ ដោយមិនគិតពីលោកិយហានៈ ឬព្រឹទ្ធភាពនៃការបួសមុន ឬយូរជាងឡើយ[៥៣]។

ចំណែកនៅក្នុងចក្កវត្តិសូត្រ[៥៤] ជាសូត្រនិយាយអំពីការគ្រប់គ្រងដែលអាចនាំប្រទេសជាតិឱ្យទៅកាន់វឌ្ឍនភាពដ៏បរិបូណ៌មួយនោះ ព្រះសិទ្ធត្ថសមណគោត្តមបានលើកឡើងពីគោលការណ៍បួនយ៉ាង សំរាប់ឱ្យអ្នកដឹកនាំអនុវត្តតាមគឺ៖

១. **ធម្មាធិបតេយ្យោ** ធម្មិកំ រក្ខាវរណគុត្តិ សំវិទហស្សុ យកធម៌ជាអធិបតី និងចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រង ប្រកបដោយធម៌

២. **មា អធម្មការៈ** បង្ការមិនឱ្យមានអំពើដែលអធម៌ (អំពើខុសច្បាប់) កើតឡើងនៅក្នុងអាណាចក្រ

៣. **ធនានុប្បទានៈ** បែងចែកទ្រព្យសម្បត្តិដល់អ្នកក្រីក្រ និងជួយដល់អាជីវកម្មផ្សេងៗសម្រាប់ចិញ្ចឹមជីវិត

៤. **សមណព្រាហ្មណបរិបុច្ឆាៈ** សាកសួរប្រឹក្សាជាមួយសមណព្រាហ្មណ៍ អំពីគោលការណ៍៣ ខាងលើដែលកំពុងអនុវត្ត

ចំណុចទី១ នៃចក្កវត្តិសូត្រៈ ធម្មាធិបតេយ្យ គ្រាន់តែជាសេចក្តីសង្ខេបនៃការយកធម៌ជាអធិបតីក្នុងការគ្រប់គ្រងប្រទេស ដែលសេចក្តីបរិយាយនៅក្នុងគោលការណ៍ទី១ នៃការដឹកនាំប្រទេសនេះ អ្នកដឹកនាំប្រទេស ឬរដ្ឋាភិបាល ត្រូវរៀបចំខ្លួនឱ្យបានល្អចំពោះ

[៥៣] Ibid ១៨

[៥៤] ចក្កវត្តិសូត្រ បិដក ភាគ ១៨ - ទំព័រទី ១១៧

ច្បាប់ (ធម៌) ដល់ទៅ១០យ៉ាង[៥៥] គឺ (១) អាស្រ័យនូវច្បាប់ (២) ធ្វើសក្ការៈចំពោះច្បាប់ (៣) គោរពច្បាប់ (៤) រាប់អានច្បាប់ (៥) បូជាច្បាប់ (៦) កោតក្រែងច្បាប់ (៧) យកច្បាប់ជាទង់ជ័យ (៨) យកច្បាប់ជាស្តង់ដា[៥៦] (៩) យកច្បាប់ជាអធិបតី និង (១០) ចាត់ចែងនូវការរក្សា ទប់ទល់ គ្រប់គ្រង ប្រកបដោយច្បាប់ដល់៖

ក. អន្តោជន៖ ជនខាងក្នុង មានក្រុមគ្រួសារ និងអ្នកដែលនៅក្រោមឧបការរបស់ខ្លួនផ្ទាល់
ខ. ពលកាយ៖ កងទ័ព យោធា នគរបាល គ្រប់ប្រភេទ
គ. ខត្តិយ៖ ក្រុមគណរដ្ឋមន្ត្រី ឬរដ្ឋាភិបាល
ឃ. អនុយន្ត៖ អ្នកធ្វើការរាជការទាំងឡាយ
ង. ព្រាហ្មណគហបតី៖ ពាណិជករ គ្រូ អ្នកសាសនា ពេទ្យ បញ្ញវន្ត ជាដើម
ច. នេគមជានបទ៖ អ្នកនិគមជនបទ កសិករ កម្មករ
ឆ. សមណព្រាហ្មណ៍៖ ព្រះសង្ឃ បព្វជិតសាសនាទាំងឡាយ
ជ. មិគបក្សី៖ សត្វម្រឹគ និងបក្សីដែលគួរអភិរក្សទាំងឡាយ

ក្នុងន័យនេះ យើងអាចនិយាយថា ធម្មាធិបតេយ្យ ឬអធិបតេយ្យភាពរបស់ច្បាប់ (Supremacy of Law) ធំទូលំទូលាយណាស់ មិនអាចមានអ្នកណារំលោភបានឡើយ។ បុគ្គលទាំង៧ ប្រភេទ (ពី ក ដល់ ឆ) ត្រូវស្ថិតនៅក្រោមអំណាចច្បាប់ដូចគ្នា គឺតាំងពីថ្នាក់កំពូលបំផុតដល់ពលរដ្ឋសាមញ្ញបំផុត។ មិនតែប៉ុណ្ណោះ សូម្បីតែសត្វតិរច្ឆាន និងកន្លែងរស់នៅរបស់សត្វទាំងនោះ ដូចជាព្រៃព្រឹក្សា បឹងទន្លេសមុទ្រជាដើម ក៏ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ច្បាប់ដែរ (ជ)។ ធម្មាធិបតេយ្យ គ្របដណ្តប់ទាំងបុគ្គលដែលគ្រប់គ្រងគេ និងអ្នកដែលត្រូវគេគ្រប់គ្រង។

ពុទ្ធសាសនា បានបង្ហាញឱ្យឃើញនូវការយកចិត្តទុកដាក់លើអធិបតេយ្យភាពរបស់ច្បាប់ ក្នុងការអភិវឌ្ឍប្រទេស។ ទោះជាយ៉ាងណាក្តី នីតិរដ្ឋមិនមែនអាចកើតឡើង

---

[៥៥] ១) ធម្មំយេវ និស្សាយ ២) ធម្មំ សក្ករោន្តោ ៣) ធម្មំ គរុករោន្តោ ៤) ធម្មំ មានេន្តោ ៥) ធម្មំ បូជេន្តោ ៦) ធម្មំ អបចាយមានោ ៧) ធម្មទ្ធជោ ៨) ធម្មកេតុ (យកធម៌ជាស្តង់ដា) ៩) ធម្មាធិបតេយ្យោ ១០) ធម្មិកំ រក្ខាវរណគុត្តឹ សំវិទហស្សុ

[៥៦] នៅក្នុងព្រះសូត្រជាភាសាខ្មែរ ប្រែពាក្យថា ធម្មកេតុ ថា យកធម៌ជាស្ពាន។ តែពាក្យថា កេតុ នេះ ជាផ្កាយទី៩ ក្នុងតារាសាស្ត្រឥណ្ឌា។ វចនានុក្រមខ្មែរ ប្រែថាទង់ផង រស្មីផង។ ខ្ញុំប្រែថា ស្តង់ដា ដោយយកតាមវចនានុក្រមបាលី-អង់គ្លេស ព្រោះពាក្យថា កេតុ នេះ ពុំមានប្រែនៅកន្លែងណាថាជា ស្ពាន ឡើយ។ dhammaketu: Standard of the Law https://dictionary.tamilcube.com/pali-dictionary/ ?term=Dhammaketu

បានដោយងាយៗ ឬក្នុងរយៈពេលដ៏ខ្លីបានទេ ជាពិសេសក្នុងករណីប្រទេសកម្ពុជា ដែលទើបតែក្រេបរសជាតិសន្តិភាពក្នុងរយៈពេលមិនយូរកន្លងមកនេះ។ នីតិរដ្ឋត្រូវរឹងប៉ឹងនៅកម្ពុជា ដើម្បីជួយជាចំណែកដល់បូរណភាពនៃប្រព័ន្ធច្បាប់ ក្នុងការធានាថា ប្រជាពលរដ្ឋ អ្នកដឹកនាំគ្រប់ជាន់ថ្នាក់ និងគ្រប់ក្រសួងស្ថាប័ន ប្រកាន់ខ្ជាប់ជានិច្ចនូវការគោរពប្រតិបត្តិតម្កល់ច្បាប់ជាធំ **ដោយស្មើភាពគ្នា** និងជំនឿទុកចិត្តលើប្រព័ន្ធច្បាប់ដោយអស់ពីចិត្ត[៥៧] ។

សិក្សាលើចក្កវត្តិសូត្រ ដែលជាធម្មនុញ្ញរបស់អ្នកដឹកនាំកំពូល កាលពីសម័យបុរាណ ហើយដែលព្រះសិទ្ធត្ថសមណគោតម ធ្លាប់បានយោនយកកំណើតជាស្តេចចក្កពត្តិ កាលពីអតីតជាតិដ៏យូរលង់មកដែរនោះ ព្រះសូត្របាននិយាមលើការដឹកនាំរបស់អ្នកដឹកនាំថ្នាក់ខ្ពស់ ដូចតទៅ៖

១. ជាស្តេចចក្កពត្តិ ដែលបានអភិសេកត្រឹមត្រូវ សំដៅអ្នកដែលកាន់អំណាចខ្ពស់ជាងគេ ដោយត្រឹមត្រូវតាមច្បាប់ ទទួលស្គាល់និងពេញចិត្តដោយប្រជាជន

២. ជាធម្មិកធម្មរាជ ដឹកនាំប្រកបដោយទសពិធរាជធម៌[៥៨] គឺគុណធម៌១០យ៉ាងរបស់ព្រះរាជាឬថ្នាក់ដឹកនាំ៖

- ២.១. ទាន ជួយសង្គ្រោះដល់អ្នកខ្វះខាត និងអ្នកត្រូវការបច្ច័យទាំងឡាយ ៤
- ២.២. សីល រក្សាសីលជាប់ល្អ ប្រកាន់នៅក្នុងច្បាប់ យកសីលយកច្បាប់ជាធំ
- ២.៣. បរិច្ចាគ លះបង់លោភៈ ទោសៈ មោហៈ ដែលជាសេចក្តីសុខផ្ទាល់ខ្លួន ដើម្បីជាប្រយោជន៍ប្រជារាស្ត្រ និងប្រទេសជាតិ
- ២.៤. មទ្ទវៈ ឥរិយាបថ ព្រឹត្តិកម្ម ចិត្តទន់ភ្លន់ សុភាពរាបសា
- ២.៥. អាជ្ជវៈ ទៀងត្រង់ជាមួយវិជ្ជាជីវៈ មុខការងាររបស់ខ្លួនជាអ្នកដឹកនាំជាន់ខ្ពស់
- ២.៦. តបៈ ដុតកម្តៅអំពើអាក្រក់ទាំងរបស់ខ្លួន និងជនដទៃនៅក្រោមការដឹកនាំឲ្យឆេះក្តៅ មិនអាចប្រព្រឹត្តអំពើអាក្រក់បាន
- ២.៧. អក្កោធនៈ មិនបញ្ចេញកំហឹង ឲ្យអ្នកដទៃបានឃើញ បានដឹង
- ២.៨. អវិហឹសា មិនបៀតបៀនអ្នកដទៃឲ្យបាត់បង់សេចក្តីសុខ ព្រោះតែប្រយោជន៍ខ្លួន

---

[៥៧] ibid ២៦ ទំព័រ ២៧

[៥៨] សូមអានសៀវភៅព្រះបាទធម្មិក រៀបរៀងដោយ ព្រះឥន្ទបញ្ញាភិក្ខុ

២.៩. ខន្តី អត់ធន់ចំពោះកិច្ចការលំបាកគ្រប់ប្រភេទ និងព្យាយាមជានិច្ច មិនលះបង់ចោលកិច្ចការទាំងនោះ

២.១០. **អវិរោធន** មិនប្រព្រឹត្តកំហុសដែលនាំឲ្យកើតទោស នាំឲ្យប្រជារាស្ត្រកើតទុក្ខទោស រិះគន់ចំពោះភាពជាអ្នកដឹកនាំ។

៣. ជាឥស្សរលើផែនដី ដែលមានសមុទ្រទាំង៤ ជាទីបំផុត (ឯករាជ្យបូរណភាពដែនដីគ្រប់ទិស) មិនស្ថិតនៅក្រោមអាណានិគម។

៤. ជាស្តេចដែលឈ្នះសង្គ្រាម[៥៩] (មានសន្តិភាព)។

៥. មានជនបទដល់នូវថិរភាព (សេចក្តីមាំមួន) មានស្ថិរភាព សុវត្ថិភាពគ្រប់ទីកន្លែង។

៦. បរិបូរ ដោយរតនវត្ថុទាំង ៧ប្រការ គឺ៖

៦.១. ចក្កវត្តន៍[៦០] (ចក្រកែវ) យានជំនិះលឿនខ្លាំងបំផុត

៦.២. ហត្ថិវត្តន៍ (ដំរី) មានល្បឿនលឿន

៦.៣. **អស្សវត្តន៍** (សេះ) មានល្បឿនលឿន

៦.៤. មណីវត្តន៍ (កែវមណី) ទ្រព្យធម្មជាតិកម្រនិងថ្លៃ

៦.៥. ឥត្ថីវត្តន៍ (នារីរតន៍) នារីៗស្រស់ស្អាតល្អ

៦.៦. គហបតីវត្តន៍ (នាយឃ្លាំង) ជាពាណិជករល្អ

៦.៧. បរិនាយកវត្តន៍ (នាយពល) នាយករដ្ឋមន្ត្រីល្អ

៧. មានព្រះរាជបុត្រច្រើនជាងពាន់ (មេទ័ពដែលទុកចិត្តបាន) សុទ្ធសឹងតែក្លៀវក្លា អង់អាច អាចសង្កត់សង្កិន នូវសេនារបស់ស្តេចដទៃបាន គឺមានសមត្ថភាពខ្លាំង ពូកែក្នុងការធ្វើសឹកសង្គ្រាម។

៨. ត្រួតត្រា គ្រប់គ្រងផែនដី ដែលមានសាគរជាព្រំប្រទល់នេះ **ដោយធម៌ដ៏ស្មើ** មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធ គ្រប់គ្រងផែនដី១ **(អទណ្ឌេន អសត្ថេន ធម្មេន សមេន)**។

ចំណុចទី៨ ៣ក្យ **ដោយធម៌ដ៏ស្មើ (ធម្មេន សមេន)** បានបញ្ជាក់យ៉ាងច្បាស់អំពីសារៈសំខាន់របស់នីតិរដ្ឋក្នុងការគ្រប់គ្រងផែនដី បើទោះជាស្ថិតនៅក្នុងរបបរាជអាជ្ញាសិទ្ធិក៏ដោយ ក៏ព្រះរាជាផ្តល់នូវ **ភាពស្មើគ្នានៅចំពោះមុខធម៌** គឺមិនមានធម៌ខ្ពស់-ទាប សម្រាប់

[៥៩] បច្ចុប្បន្នអាចមានន័យថា ជាអ្នកដែលឈ្នះការបោះឆ្នោតលើគណបក្សនានា និងទទួលឋានៈជាអ្នកដឹកនាំប្រទេស

[៦០] អ្នកប្រាជ្ញសម័យថ្មីខ្លះយល់ថា ចក្កវត្តន៍ ជាពពួកយាន UFO ព្រោះក្នុងគម្ពីរបាននិយាយថា មានល្បឿនលោះនខ្លាំងណាស់។

មន្ត្រី និងប្រជារាស្ត្រឡើយ។ ទោះជាយ៉ាងណាក្តី សក្តិសិទ្ធិភាព និងប្រសិទ្ធិភាពរបស់នីតិរដ្ឋ ក៏ត្រូវអាស្រ័យជាចាំបាច់លើចំណុចទាំងប្រាំពីរខាងលើ ជួយជ្រោមជ្រែងដែរ៖ ប្រទេសដែលមិនមានសន្តិភាព មានកងទ័ពខ្សោយ មានអ្នកដឹកនាំក្នុងអំណាចមិនច្បាស់លាស់ អ្នកដឹកនាំមិនមានសុខភាព សមត្ថភាព និងគុណធម៌ល្អ ប្រទេសមិនសំបូរធនធានធម្មជាតិដែលមានតម្លៃ ពាណិជករមិនយល់ដឹងច្បាស់ក្នុងពាណិជកម្ម និងរដ្ឋាភិបាលដែលមិនមានប្រសិទ្ធភាព គោលនយោបាយខ្វះភាពទន់ភ្លន់ទាក់ទាញ រួមទាំងកង្វះស្រីស្អាតៗ ផងនោះ កម្រិតអនុវត្តបាននៃនីតិរដ្ឋ ក៏នឹងមិនអាចលូតលាស់ល្អឡើយ។ ដូច្នេះ ជាការចាំបាច់ ដែលរដ្ឋាភិបាលមួយត្រូវបំពេញលក្ខខណ្ឌសម្រាប់នីតិរដ្ឋឲ្យបានគ្រប់គ្រាន់ ទើបច្បាប់សង្គមទាំងឡាយអាចប្រព្រឹត្តទៅដោយរលូន និងអាចបម្រើគោលដៅនៃច្បាប់ទាំងនោះបាន។

ក្នុងពុទ្ធសាសនា អ្វីៗក៏មានសភាពមិនទៀង រួមទាំងអំណាចចក្កវត្តិ ក៏ដូចជាអំណាចនីតិរដ្ឋ។ ជំនាន់ជាបន្តបន្ទាប់នៃចក្កវត្តទី១ ដ៏មានអំណាចកន្លងផុតទៅ ចក្កពត្តិអង្គទី២ ដែលជាព្រះរាជបុត្ររបស់ចក្កពត្តិទី១ មិនអាចរក្សាអំណាចបារមី (ចក្រ) ឲ្យនៅខ្លាំងដូចជាព្រះបិតាបានទេ។ ក្នុងព្រះសូត្រនេះ ព្រះរាជបុត្រត្រូវព្រះបិតា ប្រាប់ឲ្យបំពេញករណីយកិច្ចទាំង ៤យ៉ាង (ចក្កវត្តិធម៌) ដូចដែលបានពោលពីខាងលើ ដើម្បីឲ្យអាណាចក្រចក្រវត្តិអាចពង្រឹងស្ថិរភាព និងការអភិវឌ្ឍទៅមុខបាន។ តាមព្រះសូត្រ អំណាចបារមីចក្កវត្តិភាព មិនមែនកើតឡើងដោយឯកឯង ឬដោយការបន្តសន្តតិវង្ស ដោយសុខស្រួលនោះទេ គឺព្រះរាជាត្រូវកសាងធម៌មានអង្គប្រកបទាំង ១០យ៉ាង ដោយមានធម្មាធិបតេយ្យនៅខាងចុងជាសេចក្តីសង្ខេប និងយកអង្គនីតិរដ្ឋទាំង១០នោះ ទៅអនុវត្តក្នុងការគ្រប់គ្រងប្រជារាស្ត្រឲ្យបានល្អ និងបានបរិបូណ៌។ ចំណុចធម្មាធិបតេយ្យ ត្រូវការការគាំទ្រពីអ្នកដឹកនាំជាខ្លាំង ក្នុងការអនុវត្តច្បាប់ក្រោមនីតិរដ្ឋនេះ គឺ**អ្នកដឹកនាំត្រូវធ្វើជាគម្រូ** ដោយព្រះបាទចក្កវត្តិជាបិតាបានប្រាប់ព្រះរាជបុត្រថា៖

ចំណុចទី២ នៃចក្កវត្តិសូត្រ៖ មាអធម្មការ គឺបង្ការមិនឱ្យមានអំពើដែលអធម៌ (អំពើខុសច្បាប់) កើតឡើងនៅក្នុងអាណាចក្រ។ នេះជាកិច្ចការសំខាន់ទី២ ដែលអ្នកដឹកនាំត្រូវគ្រប់គ្រងផែនដីឲ្យបានល្អ មិនឲ្យកើតអកុសលកម្ម ឧក្រិដ្ឋកម្ម ក្នុងដែនដីរបស់ខ្លួន។ អតីតព្រះបាទចក្កពត្តិអង្គទី១ ក៏បានមានបន្ទូលទៅនឹងព្រះរាជបុត្របន្ថែមថា៖ **ចូរបាកុំធ្វើអកុសលធម៌ក្នុងដែនដីរបស់អ្នកឡើយ។** នេះជាចំណុចសំខាន់ ដែលអ្នកមានអំណាចទាំងឡាយប្រព្រឹត្តអកុសលធម៌ គឺអំពើអាក្រក់ដែលផ្ទុយនឹងច្បាប់តែងតែរកមធ្យោបាយដើម្បីមិនឲ្យនីតិ

រដ្ឋអាចបញ្ចេញអធិបតេយ្យភាពច្បាប់ បូរណភាពច្បាប់បាន។ កាលណាអ្នកដឹកនាំមិននៅក្រោមអធិបតេយ្យភាពនៃច្បាប់ហើយ អ្នករាជការ មន្ត្រី កងទ័ព ពាណិជ្ជករ និងប្រជារាស្ត្រទូទៅ ក៏នឹងព្យាយាមរកល្បិច ឬប្រហោងចន្លោះនៃច្បាប់ (Law Loopholes) ដើម្បីសម្រេចគោលបំណងអកុសលរបស់ខ្លួនផងដើម្បីរួចផុតពីសំណាញ់ច្បាប់ជាពុំខាន។ ភាពជាគម្រូនៃការអនុវត្តច្បាប់ គឺការទទួលយកនីតិរដ្ឋដូចអ្នកដទៃដែរ។

ព្រះសូត្រឈ្មោះ **អធម្មិកសូត្រ**[៦១] បានបង្ហាញពីផលប៉ះពាល់ជាវដ្តៈលើសង្គម (cycle social impact) នៅពេលដែលអ្នកដឹកនាំប្រព្រឹត្តអកុសលធម៌ គឺមិនអាស្រ័យនូវធម៌តែម្យ៉ាង មិនធ្វើសក្ការៈធម៌ មិនគោរពធម៌ មិនរាប់អានធម៌ មិនបូជាធម៌ មិនកោតក្រែងធម៌ មិនយកធម៌ជាទង់ជ័យ មិនយកធម៌ជាស្ពាន[៦២] មិនយកធម៌ជាអធិបតី ទៅលើប្រព័ន្ធទាំងមូលថាៈ


«ម្នាលភិក្ខុទាំងឡាយ សម័យណាពួកព្រះរាជាមិនប្រកបដោយធម៌ សម័យនោះពួកខ្ញុំរាជការក៏មិនប្រកបដោយធម៌ដែរ។ ម្នាលភិក្ខុទាំងឡាយ កាលពួកអ្នករាជការមិនប្រកបដោយធម៌ សម័យនោះពួកព្រាហ្មណ៍ និងគហបតីក៏មិនប្រកបដោយធម៌ដែរ។ កាលពួកព្រាហ្មណ៍ និងគហបតីមិនប្រកបដោយធម៌ហើយ សម័យនោះពួកអ្នកនិគម និងអ្នកជនបទក៏មិនប្រកបដោយធម៌ដែរ។ កាលអ្នកនិគម និងអ្នកជនបទមិនប្រកបដោយធម៌ ព្រះចន្ទ្រ និងព្រះអាទិត្យក៏គោចរទៅមិនស្មើដែរ។ កាលព្រះចន្ទ្រ និងព្រះអាទិត្យ គោចរទៅមិនស្មើ ពួកផ្កាយនក្ខត្តឫក្ស ក៏គោចរទៅមិនស្មើដែរ។ កាលពួកផ្កាយនក្ខត្តឫក្ស គោចរទៅមិនស្មើយប់ និងថ្ងៃ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលយប់ និងថ្ងៃប្រព្រឹត្តទៅមិនស្មើខែ និងកន្លះខែ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលខែ និងកន្លះខែប្រព្រឹត្តទៅមិនស្មើរដូវ និងឆ្នាំ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលរដូវ និងឆ្នាំប្រព្រឹត្តទៅមិនស្មើ ខ្យល់ក៏បក់មិនស្មើដែរ។ កាលខ្យល់បក់មិនស្មើ ខ្យល់បក់ខុសផ្លូវទាំងឡាយ ក៏ប្រព្រឹត្តទៅមិនស្មើដែរ។ កាលខ្យល់បក់ខុសផ្លូវទាំងឡាយ ប្រព្រឹត្តទៅមិនស្មើ ទេវតាទាំងឡាយខឹងសម្បា។ កាលទេវតាទាំងឡាយខឹងសម្បា ភ្លៀងក៏មិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ។ កាលភ្លៀងមិនបង្អុរទឹកភ្លៀងចុះមកដោយប្រពៃ ស្រូវទាំងឡាយក៏ឲ្យផលមិនស្មើល្អ។ ម្នាលភិក្ខុទាំងឡាយ

[៦១] អធម្មិកសូត្រ ទី១០ បិដកភាគ៤២ ទំព័រ ១៨៤

[៦២] យកធម៌ជាស្ពង់ដា


ពួកមនុស្ស កាលបើបរិភោគស្រូវឲ្យផលមិនស្មើ រមែងមានអាយុខ្លី មានសម្បុរអាក្រក់ មានកម្លាំងតិច មានអាពាធច្រើន»។

អធម្មិក (អ្នកដឹកនាំមិនល្អ) មានផលប៉ះទង្គិចជាអវិជ្ជមាន មិនត្រឹមតែលើមន្ត្រីរាជការ និងប្រជារាស្ត្រក្នុងប្រទេសនោះទេ តែសូម្បីធម្មជាតិទាំងឡាយក៏រងផលប៉ះពាល់ដែរ (climate change) ដែលនៅក្នុងនោះ ការប្រែប្រួលបរិយាកាស ប្រព័ន្ធអេកូឡូជី រួមទាំងប្រព័ន្ធតារា (constellations) គឺទាំងព្រះអាទិត្យ ព្រះចន្ទ ផ្កាយនក្ខត្តឫក្ស យប់ ថ្ងៃ ខែ រដូវ ឆ្នាំ ខ្យល់ ទឹកភ្លៀង បានធ្វើឲ្យវិស័យកសិកម្ម ដែលមានសារៈសំខាន់ចំពោះមនុស្សជាតិមានការប្រែប្រួលទាំងបរិមាណនិងគុណភាព (food security and food safety) ដែលនាំឲ្យគុណភាពជីវិតរបស់មនុស្សធ្លាក់ចុះ។ ហេតុការណ៍នេះ នឹងនាំទៅរកអស្ថិរភាពសង្គម ប្រទេសជាតិ និងពិភពលោកជាពិតប្រាកដ។



ពាក្យថា **ទេវតាទាំងឡាយខឹងសម្បា** ជាភាពអវិជ្ជមាន បង្ហាញអំពីភាពមិនប្រក្រតីនៃធម្មជាតិ ដែលដាក់ទោសមកលើសង្គមមនុស្ស បន្ទាប់ពីបានបំផ្លាញអ្វីៗដែលមានប្រយោជន៍គាំទ្រដល់អត្ថិភាពជាមនុស្ស។ ផ្ទុយទៅវិញ ពាក្យថា **ពួកទេវតាក៏មិនខឹងសម្បា** បង្ហាញអំពីការពេញចិត្តរបស់ទេវតា (ធម្មជាតិ) ចំពោះការដឹកនាំរបស់ **ព្រះបាទធម្មិក** (អ្នកដឹកនាំល្អ) ដែលដឹកនាំគ្រប់គ្រងប្រកបដោយធម៌ មានធម្មាធិបតេយ្យ រក្សាគុណភាព

របស់មនុស្ស សង្គម និងធម្មជាតិ បានល្អ ក៏នឹងមានផលប៉ះទង្គិចជាវិជ្ជមាន ទៅលើសង្គមមនុស្ស ទាំងមូល ជាពិតប្រាកដ។



នៅចុងបញ្ចប់នៃព្រះសូត្រ ព្រះសិទ្ធត្ថសមណគោត្តម បានសរុបសេចក្តីថា៖ «បើគោទាំងឡាយ កំពុងឆ្លងទៅ គោមេហ្វូងនាំទៅកាន់ផ្លូវខុសកំពង់ កាលបើគោមេហ្វូង នាំទៅកាន់ផ្លូវខុសកំពង់ ពួកគោទាំងអស់នោះ ក៏នាំគ្នាទៅកាន់ផ្លូវខុសកំពង់ដែរ មានឧបមាយ៉ាងណា ក្នុងពួកមនុស្ស ក៏ដូច្នោះដែរ **អ្នកណាដែលគេសន្មតថាប្រសើរជាងគេ** (ក្សត្រ អ្នកដឹកនាំ អ្នកនយោបាយ) បើអ្នកនោះ ប្រព្រឹត្តមិនត្រូវតាមធម៌ និងបាច់និយាយទៅថ្វីដល់ប្រជាជនដទៃឡើយ **បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកកើតទុក្ខ**។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ កាលបើគោមេហ្វូងនាំទៅកាន់ផ្លូវត្រង់ គោទាំងអស់នោះរមែងទៅកាន់ផ្លូវត្រង់ដែរ។ មានឧបមាយ៉ាងណា ក្នុងពួកមនុស្សក៏ដូច្នោះដែរ អ្នក



ណាដែលគេសន្មតថាប្រសើរជាងគេ បើអ្នកនោះប្រព្រឹត្តតាមធម៌ នឹងបាច់និយាយទៅថ្វីដល់ប្រជាជនដទៃ **បើព្រះរាជាប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកនៅជាសុខ**[៦៣]។

ចំណុចទី៣ នៃចក្កវត្តិសូត្រ (ធនានុប្បទាន)៖ នីតិរដ្ឋក្នុងទស្សនៈនៃព្រះសូត្រត្រូវការបរិយាកាសគោលនយោបាយសង្គមមួយ ដែលបម្រើដល់តម្រូវការរដ្ឋក្នុងលក្ខណៈជារដ្ឋសុខមាលភាព (Welfare State) ដោយព្រះបាទចក្កពត្តិ បានប្រាប់រាជបុត្រថា **ម្នាលបា បើពួកជនណា ដែលស្ថិតក្នុងដែនរបស់អ្នក មិនមានទ្រព្យ អ្នកគប្បីផ្តល់ទ្រព្យដល់ជនទាំងនោះ**។ ទ្រព្យនៅក្នុងទីនេះ មិនមែនត្រឹមតែជាការផ្តល់អំណោយដល់ទុរគតរាស្ត្រទេ គឺសំដៅដល់ការបង្កើតឱកាសការងារ ការផ្តល់ដើមទុនសម្រាប់អាជីវករទាំងឡាយបានប្រកបអាជីវកម្ម បង្កើនកម្លាំងសេដ្ឋកិច្ច ដើម្បីបានបង់ពន្ធចូលរដ្ឋសម្រាប់អភិវឌ្ឍប្រទេស។

ពុទ្ធសាសនាបានពណ៌នាថា **ទ្រព្យមានពីរប្រភេទ** គឺទ្រព្យធម្មតាដែលអាចប៉ះពាល់បាន (hard capitals) និងអរិយទ្រព្យ គឺទ្រព្យខាងក្នុង (soft capitals)។ មិនថាសម័យណាទេ ទ្រព្យខាងក្រៅ ឬទ្រព្យដែលអាចប៉ះពាល់បាន មានតម្លៃអាចយកទៅដូរជារបស់ដទៃទៀត ឬធ្វើពាណិជកម្មបាន សូតញ្ចតែត្រូវទទួលការលើកតម្កើង។ ក្នុងសម័យនេះ មានតាំងពីរូបិយបណ្ណនានាដែលមានតម្លៃ និងធនធានធម្មជាតិមានមាស ប្រាក់ ប្រេង រ៉ែជាដើម។ ក្នុងសម័យពុទ្ធកាល មានរដ្ឋមន្ត្រីមួយរូបបានអួតសរសើរនៅចំពោះព្រះភ័ក្ត្រព្រះសិទ្ធត្ថសមណគោតម អំពីភោគទ្រព្យដែលសម្បូរច្រើនរបស់សេដ្ឋីម្នាក់ ឈ្មោះមិគារសេដ្ឋី ជាចៅរបស់រោហណសេដ្ឋី ថាជាអ្នកស្តុកស្តម្ភ មាសរាប់បានជាសែនទៅហើយ ដោយមិនបាច់ពោលទៅដល់រូបិយវត្ថុ។ ព្រះពុទ្ធអង្គមិនបានបដិសេធអំពីភាពសម្បូរសប្បាយរបស់អ្នកដែលមានភោគទ្រព្យច្រើនឡើយ តែព្រះអង្គបានដាស់តឿនថា ទ្រព្យនុ៎ះមានហានិភ័យ ជារបស់សាធារណៈ ដែលភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិមិនជាទីស្រឡាញ់អាចបំផ្លិចបំផ្លាញបាន។ ព្រះពុទ្ធអង្គ ក៏បានណែនាំឲ្យ ឧគ្គៈរាជមហាមាត្យនោះ យល់ពីគុណតម្លៃនៃទ្រព្យខាងក្នុង ៧យ៉ាង ដែលព្រះអង្គហៅថា **អរិយទ្រព្យ** មាន ៧យ៉ាង ជារបស់មិនសាធារណៈដល់ភ្លើង ទឹក ពួកស្តេច ពួកចោរ និងពួកញាតិមិនជាទីស្រឡាញ់៖ (១) សទ្ធាធនំ ទ្រព្យគឺការជឿជាក់ក្នុងច្បាប់កម្មផល (២) សីលធនំ ទ្រព្យគឺការរក្សាសីល ឬគោរពច្បាប់ (៣) ហិរិធនំ ទ្រព្យគឺការខ្មាសអៀនក្នុងការធ្វើអាក្រក់ (៤) ឱត្តប្បធនំ ទ្រព្យគឺការខ្លាចមានទោសព្រោះធ្វើអាក្រក់ (៥) សុតធនំ ទ្រព្យគឺការសិក្សា


[៦៣] អធម្មិកសូត្រ ទី១០ បិដកភាគ៤២ ទំព័រ ១៨៧

(៦) ចាគធនំ ទ្រព្យគឺការលះបង់ និង(៧) បញ្ញាធនំ ទ្រព្យគឺប្រាជ្ញា។ ព្រះពុទ្ធអង្គបានសរសើរពីអ្នកដែលមានអរិយទ្រព្យ (soft capitals) ទាំងនេះថា៖ «បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ បុគ្គលនោះឯង ឈ្មោះថា មានទ្រព្យច្រើន ដែលអ្នកណាមួយមិនគប្បីផ្ចាញ់បាន ក្នុងទេវលោក និងមនុស្សលោក»។ បុគ្គលណា ទោះស្ត្រីក្តី បុរសក្តី មានទ្រព្យទាំងនេះ អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះថាជាអ្នកមិនទ័លក្រ ការរស់នៅរបស់បុគ្គលនោះមិនសោះសូន្យឡើយ»។


ការផ្តល់នូវធនធានដល់ប្រជារាស្ត្រដើម្បីបរិភោគកុំឲ្យកើតការអត់ឃ្លាន ជាការដោះស្រាយរយៈពេលខ្លី ព្រោះបើបរិភោគអស់ហើយ ក៏នឹងកើតជាការខ្វះខាត ត្រូវផ្គត់ផ្គង់បន្តទៀត ដោយមិនងាយជាច់ឡើយ ដែលលក្ខណៈនេះ ចូលទៅក្នុងលក្ខណៈរដ្ឋសុខមាលភាព។ តែការដែលសង្កត់ទៅលើការផ្តល់ធនធានលើការបណ្តុះបណ្តាលបង្កើនមូលធនមនុស្សសម្រាប់សង្គម និងប្រទេសជាតិ ទើបជាចំណែកមួយនៃនិរន្តរភាពនៃសង្គមសេដ្ឋកិច្ចបាន[៦៤]។

ក្រៅពីមានអរិយទ្រព្យ ដែលផ្តោតលើការពង្រឹងមូលធនមនុស្ស ពលរដ្ឋ ឬប្រជារាស្ត្រ ត្រូវមានកម្លាំងខាងក្នុងរឹងប៉ឹងផងដែរ គឺ៖ (១) សទ្ធាពលៈ ទ្រព្យគឺការមានសទ្ធាជឿជាក់ច្បាស់ក្នុងហេតុផល និងច្បាប់កម្ម។ (២) វីរិយពលៈ កម្លាំងគឺការមានសេចក្តីព្យាយាមមិនបោះបង់ចោលការងារ។ (៣) ហិរិពលៈ កម្លាំងគឺការខ្មាស់ខ្លួនឯងហើយមិនប្រព្រឹត្តអាក្រក់ ទោះជាគេមិនបានឃើញក៏ដោយ។ ឱត្តប្បពលៈ កម្លាំងគឺការកោតក្រែងខ្លាចផលកម្មអាក្រក់ដែលនឹងនាំមកនូវទុក្ខទោសដល់ខ្លួន។ សតិពលៈ កម្លាំងគឺការមានស្មារតីនឹកឃើញជានិច្ច។ សមាធិពលៈ កម្លាំងគឺការមានចិត្តរឹងប៉ឹង មិនងាយរញ្ជួយដោយសារការសាទរឬមាក់ងាយពីអ្នកដទៃ។ បញ្ញាពលៈ កម្លាំងគឺប្រាជ្ញាក្នុងការដោះស្រាយបញ្ហាទៅតាមហេតុផល ដោះស្រាយទៅតាមអរិយសច្ច៤។ ក្នុងទស្សនាទានពុទ្ធសាសនា បដិរូបបទេសវាសកម្ម គឺការកែប្រែទឹកដីមួយឲ្យទៅជាកន្លែងដែលអ្នកណាក៏ចង់រស់នៅ ដែលសំខាន់បំផុត គឺការមានមូលធនមនុស្សច្រើនជាងធនធានមនុស្ស។ ករណីប្រទេសសឹង្ហបុរី និងអ៊ីស្រាអែល ជាឧទាហរណ៍នៃរដ្ឋដែលមានមូលធនមនុស្សច្រើន និងល្អ គឺមានទាំងទ្រព្យ និងមានទាំងកម្លាំង ដែលអាសនាហរណកម្មចូលគ្នារវាងទ្រព្យ និងកម្លាំង បានដូចតទៅ៖

[៦៤] បិដក ភាគ ៤៧ - ទំព័រទី ៦-១១ សំខិត្តធនសូត្រ ទី៥ វិត្ថតធនសូត្រ ទី៦ និងឧគ្គសូត្រ ទី៧



1.	សទ្ធាធនំ	ជំនឿជាទ្រព្យ/កម្លាំង
2.	ហិរិធនំ	ខ្មាសបាបជាទ្រព្យ /កម្លាំង
3.	ឱត្តប្បៈធនំ	ខ្លាចបាបជាទ្រព្យ /កម្លាំង
4.	សីលធនំ	គោរពច្បាប់ជាទ្រព្យ
5.	សុតៈធនំ	ចំណេះដឹងជាទ្រព្យ
6.	ចាគៈធនំ	លះបង់ជាទ្រព្យ
7.	វិរិយពលំ	ព្យាយាមជាកំលាំង
8.	សតិពលំ	សតិជាកំលាំង
9.	សមាធិពលំ	សមាធិជាកំលាំង
10.	បញ្ញាធនំ	បញ្ញាជាទ្រព្យ /កម្លាំង



ចំណុចទី៤ នៃចក្កវត្តិសូត្រ (សមណព្រាហ្មណបរិបុច្ឆា)៖ នីតិរដ្ឋក្នុងទស្សនៈនៃចក្កវត្តិសូត្រ បានដល់ការបើកចំហ ឬផ្តល់លំហសុីវិល (civic space) សម្រាប់ការិះគន់និងផ្តល់មតិយោបល់ ពីសំណាក់ប្រជាពលរដ្ឋ និងរួមដោយការជ្រើសរើសរកមើលបញ្ញវន្តសមណៈអ្នកបួស ដែលមានចំណេះដឹង មានគុណធម៌ មានឯករាជភាព ឲ្យចូលមកវាយតម្លៃលើការអនុវត្តគោលការណ៍ទាំង៣ ខាងលើ និងសុំនូវអនុសាសន៍អំពីសមណៈ និងព្រាហ្មណ៍ ទាំងនោះ សម្រាប់កែលំអចំណុចដែលខ្វះខាត តទៅ (recommendations and adaptions)។ ព្រះបិតាដែលជាអតីតចក្កពត្តិរាជា ទ្រង់បានមានបន្ទូលប្រាប់រាជបុត្រថា៖ «ម្នាលបា បើពួកសមណព្រាហ្មណ៍ណា ស្ថិតក្នុងដែនរបស់អ្នក ជាអ្នករៀរចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ តាំងនៅក្នុងខន្តិ និងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងឲ្យស្ងប់រម្ងាប់ ធ្វើខ្លួនឯងឲ្យរលត់ (ចាករាគាទិក្កិលេស) តែម្នាក់ឯង អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍ទាំងនោះសព្វៗកាល ហើយគប្បីសាកសួរ គប្បីចោទដណ្តឹងថា បពិត្រលោកដ៏ចម្រើន **អ្វីជាកុសល** បពិត្រលោកដ៏ចម្រើន **អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព** អំពើដូចម្តេច ដែលខ្ញុំ**ធ្វើទៅហើយមិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង** មួយទៀត អំពើដូចម្តេច ដែលខ្ញុំ**ធ្វើទៅហើយ ជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង**[៦៥]។ លុះអ្នកបានស្តាប់ពាក្យសមណព្រាហ្មណ៍ទាំងនោះហើយ គប្បីរៀនូវអំពើដែលជាអកុសល ហើយ

[៦៥] អាចថាជា Legal Auditing ? or Rule of law auditing ?

សមាទានប្រព្រឹត្តនូវអំពើដែលជាកុសល[៦៦]។ ម្នាលបា នេះឯង ជាចក្កពត្តិវត្ត ដ៏ប្រសើរ នោះ»[៦៧]។

៣.៣. ការថយចុះ និងការបាត់បង់នីតិរដ្ឋ

ការប្រកាន់យក និងដើរតាមចក្កវត្តិធម៌ ដែលមាននីតិរដ្ឋជាគោលនេះ ព្រះចក្កវត្តិរាជាបានប្រព្រឹត្តតាម អស់វារៈ ៧ជំនាន់ ដោយមិនមានហេតុការណ៍អ្វីកើតឡើងឡើយ។ លុះដល់ស្តេចចក្កពត្តិ ជំនាន់ទី ៨ ព្រះអង្គក៏មានសេចក្តីខ្ជីខ្ជា មិនបានគោរពតាមចក្កវត្តិធម៌ឡើយ ជាពិសេសត្រង់គោលចំណុច ធម្មាធិបតេយ្យ គឺព្រះអង្គគ្រប់គ្រង ដឹកនាំ ដោយតាមតែព្រះទ័យគិតឃើញ។ វិសមភាពសង្គមក៏កើតឡើង ដោយការមិនអើពើដល់គោលការណ៍នីតិរដ្ឋ។ នៅពេលនោះ ក្រុមបុរោហិតក៏ចូលទៅទូលប្រាប់អំពីការខ្វះខាតនូវគោលធម្មាធិបតេយ្យនេះ។ ព្រះអង្គក៏ស្តាប់តាម ហើយប្រកាន់យកធម្មាធិបតេយ្យវិញ។ ព្រះសូត្របាននិទានថា ថ្វីត្បិតតែព្រះអង្គប្រកាន់យកធម្មាធិបតេយ្យហើយក្តី តែព្រះរាជាមិនបានបំពេញគោលការណ៍ទី៣ គឺធនានុប្បទាន បានដល់ការលើកស្ទួយវិស័យឯកជន វិស័យសេដ្ឋកិច្ច និងរៀបប្រព័ន្ធគ្រប់គ្រងប្រទេសឲ្យជារដ្ឋដែលមានសេដ្ឋកិច្ចរឹងប៉ឹងល្អឡើយ។ ពេលនោះឯងដែលការលួច កេងប្រវ័ញ្ច បានកើតឡើង ហើយការដាក់ទោសមិនបានត្រឹមត្រូវ (អគតិ ៤) ដោយប្រើអំពើហឹង្សា ដោយប្រើគ្រឿងសាស្ត្រាវុធ ចំពោះប្រជារាស្ត្រដែលអត់ឃ្លានទាំងនោះ ក៏បាននាំឲ្យមានការបោះបោរដោយហឹង្សាឡើងចំពោះអាជ្ញាធរ។ នីតិរដ្ឋដែលមិនដំណើរការល្អជាបន្តបន្ទាប់ និងកាន់តែថយចុះឡើងៗរហូតដល់គ្មាននីតិរដ្ឋ បាននាំឲ្យកើតទៅជាសង្គ្រាមប្រល័យគ្នាអស់រយៈពេល ៧ថ្ងៃ និងស្លាប់មនុស្សអស់សឹងតែគ្មានសល់។ ដូច្នេះយើងឃើញថា ការបាត់បង់នីតិរដ្ឋ ជាហេតុនាំកើតវិបត្តិសេដ្ឋកិច្ច កើតអំពើហឹង្សា អំពើលួចប្លន់ពុករលួយ ការបំភ្លៃព័ត៌មានគ្រប់យ៉ាង កើតអំពើបះបោរ រហូតដល់កើតទៅជាមហាសង្គ្រាម។

ដំណោះស្រាយ ដើម្បីបន្តនិរន្តរភាពមនុស្សជាតិឡើងវិញ ប្រជាជននៅសល់ពីសង្គ្រាមទាំងប៉ុន្មាន ដែលបានជួបផ្ទាល់នឹងវិនាសកម្មមនុស្សជាតិនោះ ក៏បានធ្វើកិច្ចសន្យាជាមួយគ្នាថា បើចង់បន្តជីវិតមនុស្សជាតិតទៅមុខទៀតនោះ វិធីតែមួយគឺការឈប់ ការវៀរចាក ការសម្លាប់ជីវិតមនុស្សផងគ្នា។ កិច្ចសន្យាសង្គម (social contract) ឬច្បាប់

[៦៦] ជាអនុសាសន៍ និងការរៀបចំកំណែទម្រង់ ទៅតាមអនុសាសន៍ recommendation and adaptation

[៦៧] បិដក ភាគ ១៨ - ទំព័រទី ១២១-១២២

សង្គម[៦៨] (social law) ដំបូងគេបង្អស់ក៏បានកើតឡើង ដែលធ្វើឲ្យកំណើនប្រជាជនកើនជាលំដាប់ ព្រមជាមួយនឹងអាយុខ័យ (life expectancy) របស់មនុស្ស ក៏កាន់តែកើនខ្ពស់ផងដែរ។ ការមិនលួច ការមិនប៉ះពាល់កម្មសិទ្ធិប្តី-ប្រពន្ធ ការមិននិយាយកុហក និងការមិនសេពសុរាគ្រឿងញៀនទាំងឡាយ ក៏កើតឡើងជាបន្តបន្ទាប់។ នេះ អាចជាកំណើតច្បាប់សង្គម ដំបូងគេបង្អស់ ដែលមាននៅក្នុងទស្សនាទានរបស់ពុទ្ធសាសនា ហើយដែលព្រះពុទ្ធអង្គបានកំណត់និយាមច្បាប់សង្គមនេះថាជា សីល៥ ឬនិច្ចសីល ដែលជាច្បាប់សង្គមមូលដ្ឋាន របស់មនុស្សជាតិ និងមិនមែនត្រឹមតែសម្រាប់ពុទ្ធសាសនិកឡើយ (universal social law)។ ខ្ញុំសូមស្រង់ពុទ្ធដិការបស់ព្រះពុទ្ធអង្គ មកដាក់ក្នុងទីនេះដូចតទៅ៖ «..... ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង សត្វអម្បាលនោះ នឹងមានសេចក្តីត្រិះរិះយ៉ាងនេះថា ពួកយើងនេះឯង បានជាដល់នូវការអស់ទៅនៃញាតិជាច្រើនដូច្នេះ ព្រោះហេតុតែកាន់ធម៌ជាអកុសលទាំងឡាយ បើដូច្នោះ មានតែពួកយើងធ្វើកុសលវិញ។ តើគួរធ្វើកុសលដូចម្តេច ណ្តើយចុះ ពួកយើងគួរវៀរចាកបាណាតិបាត (វៀរចាកការសម្លាប់មនុស្ស) ប្រព្រឹត្តសមាទាននូវកុសលធម៌នេះចុះ។ ..... ពួកយើងគួរគប្បីវៀរចាក អទិន្នាទាន (លួច) គួរវៀរចាកកាមេសុមិច្ឆាចារ (ប្រព្រឹត្តខុសក្នុងកាម) គួរវៀរចាកមុសាវាទា (កុហក) គួរវៀរចាកបិសុណាវាចា (ការនិយាយញុះញង់) គួរវៀរចាកផរុសវាចា (ការនិយាយអាក្រក់) គួរវៀរចាកសម្ផប្បលាបៈ (ការនិយាយមិនបានប្រយោជន៍) គួរលះបង់អភិជ្ឈា (ចិត្តចង់តែបានទ្រព្យគេ) គួរលះបង់ព្យាបាទ (ចិត្តព្យាបាទឲ្យគេវិនាស) គួរលះបង់មិច្ឆាទិដ្ឋិចេញ (ការយល់ខុស) គួរលះបង់ធម៌៣ប្រការ គឺអធម្មរាគៈ[១][៦៩] វិសមលោភៈ[១][៧០] មិច្ឆាធម្មៈ[១][៧១] ចេញ បើដូច្នោះ ពួកយើងគួរជាអ្នកគោរពមាតា គោរពបិតា គោរពសមណៈ គោរពព្រាហ្មណ៍ និងជាអ្នកប្រព្រឹត្តកោតក្រែងបុគ្គលជាច្បងក្នុងត្រកូល ពួកយើងគួរនាំគ្នាប្រព្រឹត្តសមាទាននូវកុសលធម៌ទាំងនេះចុះ។ ..... ព្រោះហេតុដែលបានសមាទាននូវកុសលធម៌ទាំងនោះ (កុសលកម្មបថ ១០) សត្វអម្បាលនោះ ចំរើនអាយុ ចម្រើនពណ៌សម្បុរឡើង ហើយ កូនទាំងឡាយរបស់ពួក

---

[៦៨] ជាកិច្ចសន្យាសង្គម ព្រោះបានមូលមាត់សន្យាគ្នាឈប់ប្រព្រឹត្ត។ ជាច្បាប់សង្គម ព្រោះត្រូវអនុវត្ត ដើម្បីទទួលបាននូវសុខុមាលភាពសង្គម ជាមួយគ្នា

[៦៩] អធម្មរាគៈ ត្រេកត្រអាលខុសគន្លងធម៌ គឺមនុស្សមានតម្រេកក្នុងមាតាបិតា ម្តាយធំ ឪពុកធំ ឪពុកមា បងប្អូនបង្កើតតនិងបុត្រធីតាខ្លួន។

[៧០] វិសមលោភៈ ចង់បានហួសប្រមាណ ចង់បានឥតរបប គឺរបស់ដែលមិនគួរខ្លួនបានក៏ចង់បានដែរ នៅស្រុកឯណោះចង់បានរបស់ស្រុកឯណេះ នៅនគរឯណោះចង់បាននគរឯណេះ។

[៧១] មិច្ឆាធម្មៈ ប្រាថ្នាខុសគន្លងធម៌ បានដល់តម្រេករបស់បុរសក្នុងបុរស តម្រេករបស់ស្ត្រីក្នុងស្ត្រី ជាដើម។

មនុស្ស ដែលមានអាយុ១០ឆ្នាំ ក៏មានអាយុ២០ឆ្នាំ អាយុ៤០ឆ្នាំ អាយុ៨០ឆ្នាំឡើងវិញ ជាបន្តបន្ទាប់ រហូតដល់មានអាយុដល់ទៅ ៨ម៉ឺនឆ្នាំ[៧២]»។

៣.៤. ការស្តារ និងបដិរូបនីតិរដ្ឋ

ហេតុអ្វីត្រូវការបដិរូប? សម្តេចតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រីកម្ពុជា បានបញ្ជាក់ពីសារៈសំខាន់នៃការកែទម្រង់នេះយ៉ាងច្បាស់ថា **«កែទម្រង់ គឺរស់ មិនកែទម្រង់ គឺស្លាប់»**។ ជារឿងពិតប្រាកដ មិនអាចប្រកែកបាន!

ជាទូទៅក្នុងពុទ្ធសាសនា អ្វីៗទាំងអស់សុទ្ធតែមិនទៀង មានការប្រែប្រួល មានការផ្លាស់ប្តូរជាប្រចាំ។

ក្នុងភាសាបាលី ពាក្យ អនិច្ចំ ក្នុងពុទ្ធសាសនា ប្រែថា សភាវៈមិនទៀង។ ការប្រែប្រួល ការផ្លាស់ប្តូរនេះ ធ្វើឲ្យកើតសំណឹក ធ្វើឲ្យកើត **រីរូប** (deform) និងឈានទៅរកការទ្រុឌទ្រោមបាក់បែក ធ្លុះធ្លាយ ទាល់តែមិនអាចមានរូបដើមនៅស្ថិតស្ថេរបាន មិនអាចដំណើរការបាន មិនអាចបំពេញមុខងារបាន (dysfunction) បើមិនមានការជួសជុល ឬរៀបចំឡើងវិញទេ (បដិរូប reform)។ ប្រសិនជាបដិរូបហើយ នៅតែមិនអាចដំណើរការបានល្អនោះ **វិធីបដិវត្តន៍** (revolution) ក៏អាចនឹងចូលមកជំនួសប្រព័ន្ធដែលមិនដំណើរការនោះជាមិនខាន។

ឧទាហរណ៍មួយក្នុងពុទ្ធសាសនា៖ បេក្ខជនដែលមានប្រាថ្នានឹងចូលបួសជាបព្វជិត ជាសាមណេរ ត្រូវទទួលយកឱវាទពីព្រះឧបជ្ឈាយ៍ដែលលោកប្រាប់ថា **បដិរូបំ**[៧៣] គឺទទួលយកនូវការបដិរូបខ្លួនពីការរស់នៅបែបគ្រហស្ថ មកជាបែបបព្វជិត ដែលជាភេទអ្នកបួស ដោយគោរពតាមធម៌វិន័យទាំងឡាយដែលព្រះសម្មាសម្ពុទ្ធបានសម្តែងទុក។ កំហុសកន្លងមករបស់អ្នកបួសភាគច្រើន គឺការមិនបានពន្យល់ និងយល់អំពីសារៈសំខាន់នៃការបដិរូបខ្លួនតាមដែលគ្រូឧបជ្ឈាយ៍បានប្រាប់ និងណែនាំឲ្យបានដិតដល់ ច្បាស់លាស់ គឺបដិរូបមិនពេញលេញ មិនគ្រប់គ្រាន់ទៅតាមមាត្រដ្ឋាននៃការបដិរូប ទើបធ្វើឲ្យជីវិតបួសរបស់កិក្ខុ-សាមណេរ ត្រូវបញ្ចប់ និងមិនអាចធ្វើឲ្យគោលបំណងដែលខ្លួនមកសុំបួសបានទទួលជោគជ័យដូចប្រាថ្នា។ បើមិនធ្វើបដិរូបទេ មិនធ្វើកំណែទម្រង់ មិនព្រមកែចិត្ត កែ

---

[៧២] ទំនាក់ទំនងរវាងសីល៥ (ច្បាប់សង្គមមូលដ្ឋាន) នឹងកំណើនអាយុកប្បរបស់មនុស្ស

[៧៣] បិដក ភាគ ០៦ - ទំព័រទី ១៣៨។ សូមអានបន្ថែមសៀវភៅ «គ្រូនឹងសិស្ស» រចនាដោយហេង មណីចិន្តា បោះពុម្ពនាខែឧសភា ឆ្នាំ២០១៥

ផ្នត់គំនិត កែប្រែអាកប្បកិរិយាទេ អ្នកនោះនឹងទទួលនូវក្តីអន្តរាយដោយឆាប់ (អាចសឹក ឬត្រូវចាប់ផ្សឹក) មិនខាន។ យើងអាចនិយាយបានថា៖ «បព្វជិតណាបដិរូបខ្លួន គឺអាចរស់ជាបព្វជិតបាន បើមិនបដិរូបខ្លួន គឺស្លាប់ពីបព្វជិតជាពុំខាន»។

៣.៥. បដិរូបកម្មតាមបែបពុទ្ធសាសនា

បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ ដោយជានាបាននូវការប្រកាន់ខ្ជាប់ជានិរន្តរ៍នូវការគោរព ប្រតិបត្តិ និងតម្កល់ច្បាប់ជាធំ ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នានិងជំនឿទុកចិត្ត[៧៤] ជារឿងមួយដែលអាចសម្រេចបាន ទោះជាត្រូវមានការលំបាក និងឧបសគ្គមការារាំងក៏ដោយ។ នៅក្នុងមង្គលសូត្រ[៧៥] ជាសូត្រនិយាយអំពីសុភមង្គល ដែលកើតមកអំពីការអនុវត្តតាមគោលធម៌ផ្សេងៗ ដែលព្រះពុទ្ធអង្គបានសម្តែងទុកជា ១០គាថា (១០ក្រុម) នោះ ពាក្យថា **កំណែទម្រង់** អាចស្មើនឹងពាក្យថា **បដិរូប** ដោយពាក្យពេញក្នុងព្រះសូត្រគឺ **បដិទេសវាសោ** និយមប្រែថា ការរស់នៅក្នុងប្រទេសដែលសមគួរ[៧៦] ដែលក្នុងទីនេះ ខ្ញុំសុំប្រែថា **ការរស់នៅក្នុងប្រទេសដែលមានការបដិរូបដ៏សមគួរ។** មង្គលសូត្រគាថាទី២៖ បដិរូបទេសវាសោច បុព្វេ ច កតបុញ្ញតា អត្តសម្មា បណីធិ ច ឯតម្មង្គល មុត្តមំ **ការរស់នៅក្នុងប្រទេសមានការបដិរូបដ៏សមគួរ ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន ១ ការដំកល់ខ្លួនដោយប្រពៃ ១ នេះជាមង្គលដ៏ឧត្តម**។ តាមន័យនៃព្រះសូត្រនេះ ការធ្វើបដិរូបប្រទេសមួយ ឬបដិរូបច្បាប់នៃប្រទេសមួយ ត្រូវការយ៉ាងហោចណាស់ គោលឧបត្ថម្ភក៍ពីរដ៏សំខាន់ គឺ **ការដំកល់ខ្លួនដោយប្រពៃ និងការបានធ្វើបុណ្យទុកហើយក្នុងកាលមុន។**

(១) ការរស់នៅក្នុងប្រទេសមានការបដិរូបដ៏សមគួរ បដិរូបទេសវាសោ។ ប្រទេសដែលបានបដិរូបដ៏សមគួរនោះ ក្នុងពុទ្ធសាសនា គឺប្រទេស សង្គម ខេត្ត ប្រជុំជន ដែលប្រជាជនម្នាក់ៗគួររស់នៅ ព្រោះនឹងនាំមកនូវសុភមង្គល។ ក្នុងន័យនេះ បដិរូបទេសវាសៈក៏ជាគោលដៅដែលអ្នកដឹកនាំប្រទេសត្រូវធ្វើបដិរូប ផងដែរ៖ លក្ខណៈ និងគុណសម្បត្តិនៃពាក្យបដិរូបទេសវាស មានសេចក្តីពន្យល់នៅក្នុងគម្ពីរ មង្គលត្ថទីបនី ដូចតទៅ៖

---

[៧៤] Ibid ចក្ខុវិស័យ បេសកកម្មនិងយុទ្ធសាស្ត្រ ទំព័រ ២៧

[៧៥] បិដកលេខ ៥២ ទំព័រ៤

[៧៦] ជាទូទៅ ពាក្យ បដិរូបទេសវាសោ តែងប្រែថា ការនៅក្នុងប្រទេសដ៏សមគួរ តែក្នុងទីនេះ ខ្ញុំប្រែដោយរក្សាសព្ទបដិរូប ឲ្យនៅដដែល។ ដោយពាក្យបដិ ស្មើនឹងប្រឆាំង ផ្ទុយ ឯ រូប: គឺរូប។ ដូច្នេះ បដិរូប គឺផ្ទុយនឹងរូបមុន ដែលប្រហាក់ប្រហែលនឹងពាក្យថា reform គឺធ្វើ form ម្តងទៀត

ប្រទេសដែលមានប្រទេសជិតខាងខ្លួនល្អ ដែលអាចធ្វើពាណិជកម្ម ផ្លាស់ប្តូរវប្បធម៌ ទំនាក់ទំនងគ្នាជាអន្តរជាតិបាន

មានប្រព័ន្ធគមនាគមន៍ផ្លូវទឹក ជាសមុទ្រ ទន្លេ ស្ទឹង បឹងបួរ សម្រួលដល់ពាណិជ្ជកម្មផ្លូវទឹក និងដំណាំកសិកម្ម

មានភ្នំ ព្រៃព្រឹក្សា ប្រព័ន្ធអេកូឡូស៊ីគ្រប់គ្រាន់

មានទីរាបស្មើ អំណោយផលដល់ការដាំដុះដំណាំកសិកម្ម

មានបរិស័ទ ៤៖ មានប្រជាជនគ្រប់វណ្ណៈ ស្មានៈ សម្រាប់បន្តអត្ថិភាព និងវឌ្ឍនភាពនៃប្រទេសជាតិមួយបាន ទៅតាមសមត្ថភាព និងការពេញចិត្តរៀងៗខ្លួន៖

ក្រុមក្សត្រ ជាពួកអ្នកគ្រប់គ្រង អ្នកដឹកនាំ អ្នកនយោបាយ អ្នកការពារប្រទេស។

ក្រុមព្រាហ្មណ៍ ជាពួកបញ្ញវន្ត សាស្ត្រាចារ្យ បព្វជិតអ្នកបួស។

ក្រុមវេស្សៈ ជាអាជីវករ ជាសេដ្ឋការ ជា សេដ្ឋពាណិជ្ជ។

ក្រុមសូទ្រ ជាពលករ-កម្មករ ទូទៅ។

មានការីកដុះដាលខាងផ្នែកជំនឿ សេរីភាពជំនឿ ដែលជួយដល់ការអប់រំចិត្តគំនិតរបស់ប្រជាជន។

មានបុញ្ញកិរិយាវត្ថុ ១០[៧៧]៖ មានប្រជាពលរដ្ឋគ្រប់រូប ចូលរួមក្នុងកិច្ចការអភិវឌ្ឍប្រទេសជាតិ តាមរយៈ៖

ទាន ការមានចិត្តរាប់អានជាមេត្រីនឹងគ្នា ការចែករំលែកគ្នាទៅវិញទៅមកក្នុងសង្គម ការផ្តល់អាហារូបករណ៍ ការវិនិយោគ ដើម្បីកាត់បន្ថយការខ្វះខាតរបស់អ្នកដែលមានសេចក្តីត្រូវការ (ទានម័យ)

សីល ការគោរពសិទ្ធិមនុស្សមូលដ្ឋាន គោរពច្បាប់ កាន់សីល៥ ជាការបង្កើតទំនុកចិត្តរវាងគ្នានឹងគ្នា បង្កើនសិនិទ្ធភាពក្នុងសង្គម

ភាវនា ការអភិវឌ្ឍខ្លួនទាំងខាងផ្លូវកាយ សំដៅការអភិវឌ្ឍកាយសម្បទាឲ្យរឹងប៉ឹងមានសុខភាពល្អ។ ខាងផ្លូវចិត្ត សំដៅការថែទាំសុខភាពផ្លូវចិត្ត ធ្វើសមាធិ មិនឲ្យលោភៈ ទោសៈ មោហៈ មកគ្របដណ្តប់ពេក រហូតកើតជាវិបត្តិផ្លូវចិត្ត ទាំងជាបុគ្គលនិងសង្គម។

អបចាយនៈ សុភាពរាបសារ ឱនលំទោន ការគោរពកោតក្រែងគ្នាទៅវិញទៅមក មិនប្រមាថមើលងាយគ្នាព្រោះអាយុ ចំណេះដឹង គុណធម៌ ជំនឿសាសនា គោលសីលធម៌ប្រចាំជីវិត

---

[៧៧] ន័យសេចក្តីទាញយកពីបុញ្ញកិរិយាវត្ថុ ១០

វេយ្យាវច្ច: ការជួយគ្នាទៅវិញទៅមកពេលមានសេចក្តីត្រូវការ ការចេះធ្វើការងារ រួមគ្នាជាក្រុម ជាធីម ដើម្បីឲ្យកិច្ចការសមូហភាព បានសម្រេចឡើង

បបត្តិទាន ការចែករំលែកសេចក្តីល្អ គុណសម្បត្តិល្អដល់អ្នកដទៃ មិនដណ្តើម យកសេចក្តីល្អតែឯង បែងចែកសេចក្តីសុខដល់សង្គម

បត្តានុមោទនា ត្រេកអររីករាយចំពោះសេចក្តីល្អដែលជនដទៃបានធ្វើចំពោះខ្លួន គេក្តី សង្គមជាតិក្តី។ មិនច្រណែន មិនចំអកចំពោះសេចក្តីល្អទាំងនោះ។

ធម្មស្សវន ពេញចិត្តក្នុងការសិក្សា ស្វែងរកចំណេះដឹងល្អៗ ថ្មីៗ ប្លែកៗជានិច្ច ក្នុងមួយជីវិត ដើម្បីបង្កើនកំពស់កម្រិតសិក្សា ឲ្យកាន់តែប្រសើរឡើង

ការផ្តល់ចំណេះដឹងជាការបន្តវេន ដល់អនុជនជំនាន់ក្រោយ ដោយមិនមានការ លាក់លៀម ព្រោះចង់ឲ្យជំនាន់ក្រោយមានជោគវាសនាប្រសើរជាងខ្លួន

មានទិដ្ឋិត្រង់ មានទស្សនៈជាវិជ្ជមាន មានការយល់ច្បាស់ពីច្បាប់កម្មផលច្បាប់ ធ្វើល្អបានល្អ ធ្វើអាក្រក់បានអាក្រក់ មានហេតុផល យល់ច្បាស់អំពីការរស់ក្នុងវិថីអរិយ សច្ចទាំង៤

ជាប្រទេសដែលប្រជុំដោយអ្នកមានប្រាជ្ញា ទស្សនវិទូ និងគោលធម៌ដែលនាំទៅ រកសេចក្តីរីកចម្រើន ក្នុងនេះគឺសម្បុរទៅដោយគោលការណ៍ហេតុផលក្នុងអរិយសច្ច៤

ជាកន្លែងទាក់ទាញ ថ្វីឲ្យមនុស្សគ្រប់រូបដែលបានមកដល់ហើយ ពេញចិត្ត មាន ការរលឹកចង់ត្រឡប់មកវិញ[៧៨] ព្រោះ៖

មានកន្លែងគួរឲ្យចង់ទស្សនា ដែលនាំឲ្យកើតសេចក្តីសុខ ច្រើនប្រភេទ (ទស្សនា នុត្តរិយៈ)

មានកន្លែងគួរឲ្យចង់ស្តាប់ ទាំងការកំសាន្ត ធម៌អាថ៌ ទស្សនវិជ្ជា ផ្សេងៗ (សវនា នុត្តរិយៈ)

មានកន្លែងដែលអាចធ្វើអាជីវកម្ម វិនិយោគ ដើម្បីបានប្រាក់ភាគចំណេញ (លា ភានុត្តរិយៈ)

មានកន្លែងសិក្សារៀនសូត្រ តាំងពីថ្នាក់ទាប ដល់សាកលវិទ្យាល័យ ដែលអាច បណ្តុះបណ្តាលគុណភាពសិស្សបាន ទាំងចំណេះដឹងនិងជំនាញ (សិក្ខានុត្តរិយៈ)

មានសេវាកម្មល្អ ជាទីទាក់ទាញ និងរីករាយ (បារិចរិយានុត្តរិយៈ)

[៧៨] អត្ថន័យតាម បដិរូបទេសវាសៈ ក្នុងមង្គលត្ថទីបនី និងពីអនុត្តរិយសូត្រ បិដក ភាគ ៤៦ - ទំព័រទី ១០

ជាកន្លែងដែលធ្វើឲ្យគេរលឹករឿយៗ ដូចជាអង្គវត្ត រមណីយដ្ឋាន បុគ្គលដែលសំខាន់ៗ ក្នុងប្រទេសជាដើម (អនុស្សតានុត្តរិយៈ)

(២) ការដំកល់ខ្លួនដោយប្រពៃ (អត្តសម្មាបណីធិ) មានន័យថា បើចង់ធ្វើបដិរូបរឿងអ្វីមួយ ត្រូវតាំងចិត្តឲ្យមាំ ត្រូវមានប្រណិធានខ្ពស់ ថាខ្លួននឹងធ្វើបដិរូបពិតប្រាកដមែន បើទោះជាមានឧបសគ្គអ្វីមករារាំងក៏ដោយ ក៏មិនបោះបង់ចោលការសច្ចាប្រណិធានក្នុងការធ្វើកំណែទម្រង់នេះឡើយ។ **បដិរូបការី** (អ្នកធ្វើបដិរូប អ្នកធ្វើកំណែទម្រង់) ត្រូវតាំងចិត្តឲ្យមុតមាំណាស់ ទើបអាចធ្វើឲ្យនីតិរដ្ឋកើតឡើង អាចធំធាត់លូតលាស់ និងមានអាយុវែងបាន។ **អត្តសម្មាបណីធិ** បើប្រែឲ្យស្រួលស្តាប់ គឺការតាំងប្រណិធានធ្វើខ្លួនឲ្យល្អត្រឹមត្រូវល្មម (សម្មា) ទៅនឹងសេចក្តីត្រូវការលើការកំណែទម្រង់។ ក្នុងព្រះសូត្រ បានណែនាំបដិរូបការីឲ្យធ្វើកិច្ចការបីមុខ ដែលជាមង្គលដំបូង ដែលជាជំនួយដល់ការតាំងប្រណិធានរបស់ខ្លួន ឲ្យកើតសិន គឺ៖ **ទី១**-ការរកបុគ្គល ឬក្រុមជន ដែលជាអ្នកដែលគួរឲ្យគោរពបូជា ជាអ្នកមានអំណាចបារមី ជាអ្នកផ្តល់យោបល់ត្រឹមត្រូវ និងជាអ្នកដែលសុចរិតយុត្តិធម៌ ជាទីរាប់អាន កោតខ្លាចក្នុងសង្គម សម្រាប់ពឹងពាក់ជាបង្អែក។ **ទី១**-គឺសក្ការៈបូជាដល់បុគ្គលដែលគួរបូជា (**បូជា ច បូជនិយានំ**) គឺជាមង្គលដែលត្រូវនៅពីក្រោយខ្នងបដិរូបការីជានិច្ច ជាកល្យាណមិត្ត ជួយឲ្យសម្រេចបាននូវគោលបំណងរបស់បដិរូបកម្ម។ **ទី២**- ការតាំងចិត្ត ការប្តេជ្ញាចិត្ត មិនរាប់រក មិនសេពគប់ ជាមួយបុគ្គលពាល បុគ្គលអាក្រក់ ធម៌ពាល ធម៌អាក្រក់ គឺបុគ្គលដែលមកសេពគប់នឹងអ្នកបដិរូបការី ព្រោះតែសម្លឹងឃើញប្រយោជន៍ ទាំងបច្ចុប្បន្ននិងអនាគត (**អសេវនា ច ពាលានំ**)។ **ទី៣**- ការតាំងចិត្តសេពគប់តែជាមួយបណ្ឌិត អ្នកមានចំណេះដឹង មានការប្រព្រឹត្តល្អ ជាសប្បុរស ជាបណ្ឌិត[៧៩] ជាពហុស្សូត មានការចេះដឹងជ្រៅជ្រះក្នុងកិច្ចការកំណែទម្រង់នោះៗ (បណ្ឌិតានញ្ច សេវនា)។ ទាំង ៣ប្រការនេះ គឺការមិនសេពគប់រាប់រកជាមួយបុគ្គលពាល (ឬធម៌ពាល) ការសេពគប់តែជាមួយបណ្ឌិតសប្បុរស (សប្បុរិសធម៌) និងការរកនូវមនុស្សដែលអាចជាទីពឹងសម្រាប់គាំទ្រការតាំងចិត្តរបស់ខ្លួនដោយត្រឹមត្រូវ ជាបុរេលក្ខខណ្ឌ (precondition) ដំបូងគេ ក្នុងកំណែទម្រង់ ដើម្បីបានទទួលនូវជោគជ័យមួយកម្រិត។

(៣) ភាវៈនៃបុគ្គលមានបុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន (បុព្វេ ច កត បុញ្ញតា) បានដល់អង្គប្រកបទាំងឡាយដែលបានសន្សំទុក ដែលបានត្រៀមទុក សម្រាប់

[៧៩] ៣ក្យថាបណ្ឌិត ក្នុងទីនេះ មិនមែន៣ក្យថា បណ្ឌិតដែលប្រែមកពី៣ក្យថា Doctor នោះទេ

ធ្វើបដិរូបនេះ។ អាចរាប់ចាប់តាំងពីការដឹងអំពីមូលធនមនុស្ស ឋវិកា ហេតុ-ផល ការត្រៀមខ្លួន ពេលវេលា ភាពសមល្មម បុគ្គល និងស្ថាប័ន បរិយាកាសនយោបាយ[៨០] ជាដើម។ ជាភាសាសាមញ្ញ គឺការសម្លឹងមើលថា តើបដិការីខ្លួនឯង និងរដ្ឋាភិបាល មានបារមីចាស់ទុំល្មមនឹងធ្វើបដិរូបនីតិរដ្ឋច្បាប់បានដែរឬទេ។ ក្នុងនេះ **បុណ្យដែលបានធ្វើទុកហើយក្នុងកាលមុន** បានដល់បុញ្ញកិរិយាវត្ថុ ១០យ៉ាង ដែលជាសូចនាករសង្គមសេដ្ឋកិច្ច នយោបាយនៃសង្គមឬប្រទេសនីមួយៗ។ សូមអានចំណុចទី៧ ក្នុងបដិរូបទេសវាសៈ ខាងលើ[៨១]។

គាថាទី៣ នៃមង្គលសូត្រ ជាជំនួយដ៏សំខាន់ក្នុងការធ្វើបដិរូប ដោយផ្តោតលើការបណ្តុះបណ្តាលធនធានមនុស្ស ឲ្យកើតឡើងបានច្រើន សម្រាប់ការបដិរូបជាបន្តបន្ទាប់ព្រោះជាធម្មតា បដិរូបកម្មជាដំណើរការមួយដែលប្រើពេលវេលា និងមូលធនមនុស្សល្អៗជាច្រើនៈ ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ បុគ្គលដែលបានស្តាប់បានរៀនហើយដោយច្រើន១ បុគ្គលដែលមានសិល្ប៍សាស្ត្រគឺសេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្ម១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម» គឺមូលធនមនុស្សដែលប្រកបដោយៈ

១. មានចំណេះដឹងផ្សេងៗដ៏ច្បាស់លាស់(ពាហុសច្ចញ្ច multidisciplinary)
២. មានចំណេះធ្វើ មានភាពស្ទាត់ជំនាញច្បាស់លាស់ គ្រប់ជំនាញ (សិប្បៈ skills)
៣. មានវិន័យក្នុងការរស់នៅ និងក្នុងការងារល្អ (វិនយោ ច សុសិក្ខិតោ discipline, morale, conduct) និង
៤. មានសម្តីពីរោះ ផ្លៀវឆ្លាសក្នុងការនិយាយ និយាយមានហេតុ-ផល (សុភាសិតា ច យា វាចា well-spoken speech)។



[៨០] ន័យយកពីសប្បុរិសធម៌ ៧ៈ ធម្មញ្ញតា អត្ថញ្ញតា អត្តញ្ញតា បមាណញ្ញតា កាលញ្ញតា បរិសញ្ញតា និងបុគ្គលញ្ញតា
[៨១] ibid ៥៣



ច្បាប់សង្គម (social law) ក្នុងពុទ្ធសាសនា ឬនិយាយឱ្យងាយយល់ជាទូទៅ « សង្គមមានច្បាប់ សង្គមត្រូវមានច្បាប់ សង្គមគោរពច្បាប់» ដែលអធិប្បាយមកនេះ ហាក់បីដូចជាការអធិប្បាយអំពី នីតិរដ្ឋ តាមនិយាមផ្សេងៗ (មានដូចជា *Rechtsstaat* នីតិរដ្ឋ; legal state រដ្ឋនីតិ។ state of law រដ្ឋនៃច្បាប់។ state of justice រដ្ឋនៃយុត្តិ ធម៌។ state based on justice and integrity រដ្ឋដែលមានមូលដ្ឋាននៅលើយុត្តិធម៌ និងសុចរិតភាព[៨២]) ដែលអាចរកឃើញបាននៅក្នុងគម្ពីរព្រះត្រៃបិដក ដោយសេចក្តីសង្ខេប។ ការយល់ពីនិយាម ការអនុវត្ត ការថយចុះ និងការបាត់បង់នីតិរដ្ឋ ការស្តារ និងបដិរូបនីតិរដ្ឋ និងបដិរូបកម្មតាមបែបពុទ្ធសាសនា អាចជាកិច្ចការមួយដែលត្រូវសិក្សាឲ្យបានទូលំទូលាយ និងស៊ីជម្រៅ មុននឹងអាចយកទស្សនាទានទាំងនោះ មកបញ្ចូល (mainstream) មកដាក់បញ្ចូល (adopt) ក្នុងដំណើរការបដិរូបកម្មច្បាប់ឆ្ពោះទៅរកបូរណភាពនៃច្បាប់ ដ៏ល្អប្រសើរជាងបច្ចុប្បន្នមួយ។

[៨២] ibid ១៨

សេចក្តីសន្និដ្ឋានលើ ទស្សនាទានពុទ្ធសាសនានឹងច្បាប់សង្គម

ពីទ្រឹស្តី ឆ្ពោះទៅការអនុវត្តជាក់ស្តែង (From Theory to Praxis)

អនិច្ច ការផ្លាស់ប្តូរ គឺជាច្បាប់ធម្មជាតិ ច្បាប់សាកល នៃអត្ថិភាព (entity) ទាំងអស់។ ក្នុងសង្គមមនុស្ស អនិច្ច ជាមេបានៃបដិរូប និងបដិវត្តន៍។ **បដិរូប** ពាក់ព័ន្ធនឹងការធ្វើការផ្លាស់ប្តូរ ឬកែប្រែផ្ទៃក្នុង និងដោយមិនចាំបាច់ដកប្រព័ន្ធដែលមានស្រាប់ទាំងស្រុង។ **បដិវត្តន៍** នៅពេលដែលការផ្លាស់ប្តូរមិនត្រូវបានអនុវត្ត ឬមិនបានទៅឆ្ងាយគ្រប់គ្រាន់ កំណែទម្រង់អាចក្លាយជាកាតាលីករសម្រាប់បដិវត្តន៍ ក៏បាន។ គោលដៅនៃបដិវត្តន៍ ជាធម្មតាគឺជាការផ្លាស់ប្តូរខ្លាំង ឬពេញលេញចំពោះស្ថានភាព រួមទាំងការជំនួសអ្នកទទួលខុសត្រូវដែលមានស្រាប់។ និយាយដោយសាមញ្ញ **បដិរូប និងបដិវត្តន៍** គឺជាសកម្មភាពដែលមនុស្សធ្វើដើម្បីផ្លាស់ប្តូរស្ថាប័ន ប្រព័ន្ធ ឬការអនុវត្តដែលមានស្រាប់ ដោយមានគោលបំណងកែលម្អអត្ថិភាពសង្គមទាំងឡាយ ឬដើម្បីការពារកុំឲ្យសង្គមមួយស្លាប់ ជាពិសេសសង្គមខ្មែរ ប្រទេសខ្មែរ ដូចប្រសាសន៍របស់ **សម្តេចតេជោ ហ៊ុន សែន** ថា **«កែទម្រង់ គឺរស់ មិនកែទម្រង់ គឺស្លាប់»**។ ទោះជាយ៉ាងណាក្តី ក្នុងសៀវភៅ **ការថែរក្សាអំណាច (Power)** ទាំង៤៨ ចំណុច របស់លោក Robert Greene បាននិយាយនៅចំណុចទី ៤៥ ថា៖ «គប្បីនិយាយអំពីសេចក្តីត្រូវការក្នុងការផ្លាស់ប្តូរ ក៏ប៉ុន្តែកុំធ្វើបដិរូបតែម្តងដោយច្រើនឲ្យសោះ» (45: Preach the need to change, but never reform too much at once)។

សម្តេចព្រះមហាឃោសនន្ទ បានមានព្រះបន្ទូលអំពី **«មួយជំហានម្តង មួយជំហានម្តង Step by Step»** នៅក្នុងដំណើរការស្វែងរកសន្តិភាពផ្លូវចិត្ត និងសន្តិភាពប្រទេសជាតិចាប់តាំងពីទសវត្សរ៍ឆ្នាំ ១៩៨០។ បញ្ហានៅត្រង់ថា គេមិនដឹងអំពីល្បឿននៃបដិរូប (ជំហានយឺត ឬជំហានញាប់) ឲ្យប្រាកដប្រជា។

នៅក្នុងបិដក ភាគ ៥៦ ទំព័រទី ២០៨-២០៩ មានព្រះថេរៈជាអរហន្តមួយអង្គព្រះនាម **សម្ភូតត្ថេរ** បានមានថេរដីកាអំពី **ការយល់ច្រឡំរបស់បុគ្គលដែលកិច្ចការខ្លះគួរធ្វើដោយសន្សឹម តែទៅជាប្រញាប់ប្រញាល់ កិច្ចការខ្លះគួរធ្វើដោយប្រញាប់ប្រញាល់ តែទៅជាធ្វើដោយសន្សឹមទៅវិញ**។ លោកថា បុគ្គលនោះរមែងបាននូវសេចក្តីទុក្ខ ព្រោះការចាត់ចែងការងារមិនមាន **យោនិសោមនសិការ** (មិនមែនដោយឧបាយនៃប្រាជ្ញា)។ បុគ្គលនោះ រមែងដល់នូវភាពជាអ្នកមិនមានយសផង បែកចាកពួកមិត្រផង។ ចំណែកបុគ្គលណា ធ្វើកិច្ចការសន្សឹមក្នុងកាលដែលគួរសន្សឹម ប្រញាប់ប្រញាល់ក្នុងកាលដែលគួរប្រញាប់ប្រញាល់ រមែងបានសេចក្តីសុខ ព្រោះមានវិធានការល្អប្រកបដោយយោនិសោមនសិកា

រ:[៨៣] ប្រយោជន៍របស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ខ[៨៤]។ បុគ្គលនោះ រមែងដល់នូវយស និងកេរ្តិ៍ឈ្មោះផង មិនបែកចាកពួកមិត្រផង។ ពាក្យ ការចាត់ចែងការងារល្អ **វិធានការល្អ** (**សំវិធាន**) ប្រកបដោយយោនិសោមនសិការៈ សំដៅទៅលើការចាត់ចែងការងារ គ្រប់គ្រងការងារ ប្រកបដោយប្រាជ្ញា សុចរិតភាព និងមានសតិរលឹកដល់ការធ្វើបដិរូប ដែលមាននៅក្នុងមង្គលសូត្រ និងដែលបានអធិប្បាយរួចមកហើយនៅក្នុងចំណុច ៣.៥. បដិរូបកម្ម តាមបែបពុទ្ធសាសនា។

ការបង្កែបង្កង់ក្នុងការធ្វើបដិរូប ជាញយដង នឹងនាំឲ្យបាត់បង់ទំនុកចិត្ត និងអាចនាំទៅជាអំពើហឹង្សាក្នុងសង្គមជាតិបាន (ករណីប្រទេសឥណ្ឌូនេស៊ី ខែសីហា ២០២៥) ទៅជាកុបកម្មហឹង្សាយោរយៅ (ករណីប្រទេសនេប៉ាល់ ខែកញ្ញា ២០២៥) បដិវត្តន៍ហឹង្សា (ករណីប្រទេសបង់ក្លាដេស ក្នុងខែកក្កដា ២០២៤ Bangladesh July Revolution) ប្រទេសម៉ូរ៉ាកូនៅខែតុលា ជាដើម។

សម្មាបដិរូប ឬការធ្វើបដិរូបឲ្យបានសមស្របទៅនឹងតម្រូវការ និងការផ្តត់ផ្តង់ដល់ដំណើរការបដិរូប ជារឿងសំខាន់។ ពេលវេលា ជារឿងមួយមិនអាចមិនអើពើបានទេ ព្រោះអ្នកទទួលផល (បរិស័ទ) ប្រកបដោយគ្រឿងបង្គុំផ្សេងៗ និងអាយុផ្សេងៗគ្នា។ ឧទាហរណ៍នៃហេតុការណ៍នៅប្រទេសខាងលើ យុវជនជំនាន់ថ្មី Gen Z[៨៥] បានដើរតួយ៉ាងសំខាន់ក្នុងសកម្មភាពផ្លាស់ប្តូរទាំងនោះ។ នៅកម្ពុជាយើង ជំនាន់ Gen Z បើរាប់ពីអាយុ ១៥ឆ្នាំ ដល់ ២៩ឆ្នាំ មានប្រហែលជា ២៦.៧០% ឬប្រមាណ ៤,៥៨៦,៤២៣នាក់នៃប្រជាជនកម្ពុជាសរុប ប្រហែល ១៧,៨៤៧,៩៨១ នាក់[៨៦]។ ស្ថិតិនេះ នេះជាចំនួនមួយដ៏ច្រើន (ជាង ១/៤) ដែលរដ្ឋត្រូវយកចិត្តទុកដាក់ឲ្យបានល្អប្រសើរ។

---


[៨៣] "យោ ទន្ធកាលេ តរតិ តរណីយេ ច ទន្ធយេ អយោនិ សំវិធានេន ពាលោ ទុក្ខំ និគច្ឆតិ តស្សត្ថា បរិហាយន្តិ កាឡបក្ខេវ ចន្ទិមា អាយសក្យញ្ច បប្បោតិ មិត្តេហិ ច វិរុជ្ឈតិ។

"យោ ទន្ធកាលេ ទន្ធេតិ តរណីយេ ច តារយេ យោនិសោ សំវិធានេន សុខំ បប្បោតិ បណ្ឌិតោ តស្សត្ថា បរិបូរេន្តិ សុក្កបក្ខេវ ចន្ទិមា យសោ កិត្តិញ្ច បប្បោតិ មិត្តេហិ ន វិរុជ្ឈតី តិ។


[៨៤] កន្លះខែខាងខ្នើត ដែលព្រះចន្ទមានពន្លឺកាន់តែកើនឡើង ចាប់ពីថ្ងៃ១កើត ដល់១៥កើត

[៨៥] Gen Z ត្រូវបានកំណត់ថាជាអ្នកដែលមានអាយុប្រហាក់ប្រហែលពី ១៣ ដល់ ២៨ឆ្នាំ, https://en.wikipedia.org/wiki/Generation_Z

[៨៦] ស្ថិតិថ្ងៃទី ២៩ កញ្ញា ២០២៥ វេលាម៉ោង ១៦:៤៥ នាទី តាមគេហទំព័រ, https://www.populationpyramid.net/cambodia/២០២៥/



ការពង្រឹងគុណតម្លៃមនុស្ស វប្បធម៌សន្តិភាព និងការចូលរួមអភិវឌ្ឍសង្គម ដែលក្រសួងអប់រំយុវជននិងកីឡា កំពុងដាក់ឲ្យរៀននៅតាមអនុវិទ្យាល័យ វិទ្យាល័យនានា នៅទូទាំងប្រទេសតាំងពីឆ្នាំ ២០១០ មកម្ល៉េះនោះ ជាមេរៀនដ៏ល្អ ដែលអាចនឹងជួយឲ្យកំណែទម្រង់ច្បាប់មានភាពរលូន ដោយមិនបាច់បារម្ភពីកង្វះខាតលើបញ្ហាមូលធនមនុស្ស។ **ទាស់ត្រង់ថា ទាំងគ្រូនិងសិស្ស** ពុំសូវជាបានយកចិត្តទុកដាក់លើកម្មវិធីបង្រៀន រៀនឲ្យសមល្មមទៅនឹងសេចក្តីត្រូវការរបស់ការធ្វើកំណែទម្រង់ ព្រោះគ្រូក៏ពុំសូវបានទទួលការបណ្តុះបណ្តាលឲ្យបានច្រើនលើមុខវិជ្ជាសីលធម៌ ពលរដ្ឋវិជ្ជា ហើយសិស្សជាទូទៅ ភាគច្រើនបារម្ភពីរឿងពិន្ទុរបស់កម្មវិធី STEM ដែលមានសន្ទុះខ្លាំងជាង។



ខ្ញុំសូមបញ្ចប់អត្ថបទ ទស្សនាទានពុទ្ធសាសនា នឹង ច្បាប់សង្គម ត្រឹមនេះ ដោយយកនូវឱវាទរបស់ព្រះបាទទលួនេមិ ជាស្តេចចក្កពត្តិ មានបន្ទូលប្រាប់រាជបុត្រព្រះអង្គ

អំពីចក្កពត្តិវត្ត គឺការប្រព្រឹត្តតាមគោលការណ៍គ្រប់គ្រងប្រទេស ទាំង៤ ដែលបានធ្វើឲ្យប្រទេសជាតិរីកចម្រើនដល់កំពូល ជាប់រហូត ៧ជំនាន់ នោះគឺ (១)អាស្រ័យនូវច្បាប់ ធ្វើសក្ការៈចំពោះច្បាប់ គោរពច្បាប់ រាប់អានច្បាប់ បូជាច្បាប់ កោតក្រែងច្បាប់ យកច្បាប់ជាទង់ជ័យ យកច្បាប់ជាស្តង់ដា យកច្បាប់ជាអធិបតី និង ចាត់ចែងនូវការរក្សា ទប់ទល់ គ្រប់គ្រង ប្រកបដោយច្បាប់ ដល់ប្រជារាស្ត្រ។ (២) បង្ការមិនឱ្យមានអំពើដែលអធម៌កើតឡើងនៅក្នុងរាជាអាណាចក្រ។ ៣) បែងចែកទ្រព្យសម្បត្តិដល់អ្នកក្រីក្រ និងដល់អ្នកប្រកបអាជីវកម្ម។ (៤) សាកសួរប្រឹក្សាជាមួយសមណព្រាហ្មណ៍ អំពីប្រសិទ្ធិភាព និងសក្តិសិទ្ធិភាព នៃគោលការណ៍ទាំង៣ ខាងលើដែលកំពុងអនុវត្ត ទុកជាគតិនៅក្នុងអង្គសិក្ខាសាលាដ៏វិសេសនេះ តទៅ។

សូមអរព្រះគុណ និងអរគុណ!

នត្ថិ សន្តិ បរំសុខំ ពុំមានសេចក្តីសុខមួយណា ប្រសើរជាងសន្តិភាពឡើយ!

បទបដ្ឋាញ្ជៈ ស្តីពីទស្សនាទានពុទ្ធសាសនា និងច្បាប់សង្គម







សាកល្បងឈ្វេងយល់
ទស្សនាទានពុទ្ធសាសនា និង ច្បាប់សង្គម

ថ្ងៃចន្ទ ៦កើត ខែកត្តិក (២៖១២) ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥

បង្ហាញដោយ
ធម្មបណ្ឌិតហេង មណីចិន្តា

មាតិការអត្ថបទ

ទស្សនាទានពុទ្ធសាសនា និង ច្បាប់សង្គម

សេចក្តីផ្តើម 2

១) និយាមពាក្យ ច្បាប់សង្គម 3

- ១.១) ច្បាប់សង្គម តាមព្យញ្ជនៈន័យភាសាខ្មែរ 3
- ១.២) ច្បាប់សង្គម តាមនីតិកោសលបស្ចឹមប្រទេស 4

២) ការអានមើលទស្សនាទានច្បាប់សង្គម ក្នុងពុទ្ធសាសនា 6

- ២.១) ច្បាប់មូលដ្ឋានសម្រាប់សង្គម ក្នុងពុទ្ធសាសនា 6
- ២.២) ច្បាប់គ្រប់គ្រងសង្គម ក្នុងពុទ្ធសាសនា 10

៣) ពុទ្ធសាសនានឹងច្បាប់សង្គម 15

- ៣.១) នីតិវិជ្ជ តាមនិយាមផ្សេងៗ 16
- ៣.២) នីតិវិជ្ជតាមពុទ្ធសាសនា និងការអនុវត្ត 17
- ៣.៣) ការថ្វាយចុះ និងការបាត់បង់នីតិវិជ្ជ 25
- ៣.៤) ការស្តារ និងបដិរូបនីតិវិជ្ជ 26
- ៣.៥) បដិរូបកម្ម តាមបែបពុទ្ធសាសនា 27

សេចក្តីសន្និដ្ឋានលើ ពុទ្ធសាសនានឹងច្បាប់សង្គម 32

- ផ្នែកទី១ អត្ថបទនឹងព្យាយាមនិយាមពាក្យ ច្បាប់សង្គម តាមដែលនីតិកោសលទាំងឡាយបានបញ្ជាញយោបល់ ជាពិសេស ពីបស្ចឹមប្រទេស។
- ផ្នែកទី២ ការសាកល្បងយកនិយាមនៃពាក្យច្បាប់សង្គមនេះ ទៅផ្សារផ្គងនឹងពុទ្ធវចនៈទាំងឡាយដែល (ខ្ញុំ) គិតថា អាចធ្វើដំណើរទៅជាមួយគ្នាបាន។
- ផ្នែកទី៣ ការពិនិត្យទៅលើការអនុវត្តពុទ្ធសាសនធម៌ដែលមានលក្ខណៈជាច្បាប់សង្គម នារយៈកាលកន្លងមក និងអនុសាសន៍ដែលអាចយកទៅធ្វើឲ្យកាន់តែប្រសើរនូវច្បាប់សង្គមក្នុងវិថីជីវិតខ្មែរ ដែលកំពុងរៀបចំធ្វើបច្ចុប្បន្នភាព ដើម្បីបូរណភាពច្បាប់ ដ៏ល្អមួយសម្រាប់កម្ពុជានាសតវត្សរ៍ទី២១ នេះ។

សង្ឃឹមថា អត្ថបទនេះនឹងមានគុណភាវៈជាទៀនមួយដើមតូច ចូលរួមបំភ្លឺអំពីពុទ្ធសាសនាដែលទាក់ទងនឹងច្បាប់សង្គម ដើម្បីជូននីតិកោសលកម្ពុជាទាំងឡាយ ប្រើប្រាស់ក្នុងកំណែទម្រង់ច្បាប់ ដែលរាជរដ្ឋាភិបាលកម្ពុជាកំពុងតែរៀបចំ បានខ្លះជាពុំខាន។ ២

និយាមពាក្យ ច្បាប់សង្គម

១.១) ច្បាប់សង្គម តាមព្យញ្ជនៈន័យ ភាសាខ្មែរ
ជាសមាសនាម ប្រកបដោយពាក្យ ច្បាប់ + សង្គម

- **ច្បាប់** ជានាមសព្ទ ប្រែថាសេចក្តីបញ្ញត្តិ សម្រាប់ឲ្យអ្នកនគរប្រតិបត្តតាម ។ វិន័យ ក្រឹត្យក្រម ក្បួនប្រដៅមនុស្ស ឲ្យប្រព្រឹត្តល្អ ។ បែបយ៉ាង តួយ៉ាង គំរូ ។
- **សង្គម** ជានាមសព្ទ (សំ. បា.) ការជួបជុំគ្នា, ការប្រជុំគ្នា; ការរាប់រកគ្នា, ការប្រមូលរួបរួមផ្តុំមនុស្ស ឬ សត្វទាំងឡាយ។ សង្គមមនុស្ស សង្គមសត្វ ។ (បុំ.) ការជាប់ជំពាក់ សាមគ្គី (ដូចសង្គ) ។ សង្គម ចំណុចប្រសព្វ (Confluence)។ សង្គម សមានច្ឆន្ទ ឆន្ទៈស្មើគ្នា(consociation)។ សង្គម ជួបជំពើប (encounter)។ សង្គម សង្គ្រាម ចម្បាំង ការប្រយុទ្ធ (battle, combat, war) ។ សង្គម ក្នុងន័យដែលប្រែថាសង្គ្រាមនេះ បានបង្ហាញអំពីលក្ខណៈពិតរបស់សង្គមនីមួយៗ ដែលតែងតែមានការប្រកួតប្រជែង ការឈ្លោះប្រកែកគ្នា ការប្រយុទ្ធគ្នា ការធ្វើសង្គ្រាមរវាងគ្នាឯង និងជាមួយអ្នកដទៃជាដើម។
- **ច្បាប់សង្គមៈ** អាចសង្ខេបមកជានិយាមថាៈ សេចក្តីបញ្ញត្តិ វិន័យ ក្រឹត្យក្រម ក្បួនប្រដៅ សម្រាប់ផ្សារភ្ជាប់សង្គមដែលមនុស្សតែងប្រមូលរួបរួមផ្តុំគ្នា ជួបប្រសព្វគ្នា នាំគ្នាប្រតិបត្តតាម ដើម្បីឲ្យកើតការរាប់រកគ្នា មានសាមគ្គី មានសមានច្ឆន្ទ ក្នុងការការពារកុំឲ្យមានការប្រកួតប្រជែង ការឈ្លោះប្រកែក ការប្រយុទ្ធ ការធ្វើសឹកសង្គ្រាម ។

សង្គមប្រកបដោយស្ថាប័ន

1. ស្ថាប័នគ្រួសារ
2. ស្ថាប័នសេដ្ឋកិច្ច
3. ស្ថាប័នការសិក្សា
4. ស្ថាប័នគ្រប់គ្រង
5. ស្ថាប័នសាសនា និង
6. ស្ថាប័នការកំសាន្ត

ត្រូវការច្បាប់ប្រចាំស្ថាប័ន (specific law) ដើម្បីឲ្យស្ថាប័នរបស់ខ្លួនអាចដំណើរការទៅបានដោយរលូន ជាមួយនឹងច្បាប់ប្រចាំស្ថាប័នដទៃៗទៀត ដោយសុខដុមកម្ម ដើម្បីឲ្យសង្គមនោះមានអត្ថិភាព និងការរីកចម្រើន បានយូរ។

និយាមពាក្យ ច្បាប់សង្គម

១.២) ច្បាប់សង្គម តាមនីតិកោសលបស្ចឹមប្រទេស

- ក្នុងសម័យកាលដែលទើបនឹងលូតលាស់ ច្បាប់សង្គម ជាការប្រើប្រាស់យន្តការច្បាប់ដើម្បីដោះស្រាយវិសមភាពសង្គម លើកកម្ពស់ភាពត្រឹមត្រូវ និងធានាឱ្យមានសិនិទ្ធភាពសង្គម នៅក្នុងសង្គមដែលមានភាពសុគស្មាញ និងសង្គមបែបឧស្សាហកម្ម។
- ច្បាប់សង្គម នាពេលនោះ គឺគ្រាន់តែជាទស្សនាទានផ្នែកច្បាប់ ដែលបដិសេធការបែងចែកគ្នាដោយដាច់ខាត រវាងច្បាប់រដ្ឋ (ច្បាប់សាធារណៈ) និងច្បាប់ឯកជន ។
- សតវត្សរ៍ទី២១នេះ **(AI)** «ច្បាប់សង្គម ជាវិស័យដ៏ទូលំទូលាយនៃច្បាប់ នៃគោលការណ៍ និងស្ថាប័នទាំងឡាយ ដែលគ្រប់គ្រងទំនាក់ទំនង និងអន្តរកម្មរវាងបុគ្គលនឹងសង្គម ដោយផ្តោតទៅលើសុខុមាលភាពសង្គម យុត្តិធម៌ និងទ្រព្យសម្បត្តិសមូហភាព។ ច្បាប់សង្គម និយាយអំពីរបៀបដែលសង្គមមួយគួរតែត្រូវបានរៀបចំ ដោយមានចំណងចិទគម្លាតរវាងសេរីភាពបុគ្គល និងទំនួលខុសត្រូវសមូហភាព ដោយការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់វិស័យផ្សេងៗ ដូចជាវិស័យសន្តិសុខសង្គម ពលកម្ម និងជីវិតគ្រួសារ ដែលជារឿយៗ ឆ្លុះបញ្ចាំងពីតម្លៃនៃរដ្ឋសុខុមាលភាព ។
- Social law is a broad field of legal rules, principles, and institutions that govern the relationships and interactions between individuals and society, with a focus on social welfare, justice, and the collective good. It addresses how a society should be organized, aiming to bridge the gap between individual freedoms and collective responsibilities by establishing legal frameworks for areas like social security, labor, and family life, often reflecting the values of the welfare state. (AI)

ទិដ្ឋភាពសង្គម នាសតវត្សរ៍ទី២១ ដែលច្បាប់សង្គមបានរាប់បញ្ចូល៖

A. សិទ្ធិមនុស្ស និងសមភាព
B. សុខមាលភាព និងសន្តិសុខសង្គម
C. ច្បាប់ការងារ និងច្បាប់ទំនាក់ទំនងរវាងនិយោជិត-និយោជក
D. ការទទួលបាននូវសេវាកម្ម សំខាន់ៗ
E. បទបញ្ញត្តិ និងទំនាក់ទំនងសង្គម ។ល។
F. ច្បាប់សង្គម វិវត្តន៍ពីតួនាទីប្រវត្តិសាស្ត្រដែលធ្លាប់បែងចែកដោយដាច់ពីគ្នា រវាងច្បាប់រដ្ឋនឹងច្បាប់ឯកជន ទៅជាក្របខ័ណ្ឌច្បាប់ដែលឆ្លើយតបទៅនឹងបញ្ហានិងសេចក្តីត្រូវការថ្មីផ្សេងៗរបស់សង្គមកាន់តែច្រើន ដូចជាបញ្ហាសាកលភាវូបនីយកម្ម ឌីជីថលភាវូបនីយកម្ម និងវិសមភាពសង្គម ។ល។ ៤

២) ទស្សនាទានច្បាប់សង្គម ក្នុងពុទ្ធសាសនា


- ពាក្យ **ច្បាប់សង្គម** តែម្តង មិនមាននៅក្នុងព្រះត្រៃបិដកទេ
- ព្រះសម្មាសម្ពុទ្ធ មានអតីតភាពមុនត្រាស់ដឹង ព្រះនាម **សិទ្ធត្ថ** ជារជ្ជទាយាទនៃនគរ(ដែន) សក្កៈ ក្នុងឥណ្ឌាបុរាណ (បច្ចុប្បន្នប្រទេសនេប៉ាល់) ជាបញ្ញវន្តមួយរូបដែលមានការចេះដឹង និងជំនាញក្នុងការគ្រប់គ្រងប្រទេស និងអភិវឌ្ឍសង្គម
- រជ្ជទាយាទសិទ្ធត្ថ នឹងត្រូវសោយរាជ្យជំនួសព្រះបិតា តែបានជ្រើសរើសយកការបួសជាបព្វជិត ស្វែងរកការត្រាស់ដឹងជាព្រះពុទ្ធ ជំនួសវិញ។ ក្នុងឋានៈជាអ្នកគ្រប់គ្រងប្រទេសដោយកំណើត និងដោយវណ្ណៈជាក្សត្រ យើងមិនអាចបដិសេធបានទេថា ព្រះសមណគោតម ជាអ្នកដែលមានឯកទេសក្នុងការគ្រប់គ្រងប្រទេសមួយ និងសមត្ថភាពដើម្បីឲ្យប្រទេសមួយនោះទទួលបាននូវស្ថិរភាព និងវឌ្ឍនភាពដោយបរិបូរ ។
- ព្រះអង្គបានយកនូវបទពិសោធន៍ទាំងនោះ មកកែឆ្នៃ បង្កើត និងគ្រប់គ្រងពុទ្ធសាសនា ចំនួន៤៥ឆ្នាំ រហូតដល់ថ្ងៃដែលព្រះអង្គបរិនិព្វាន។ ពុទ្ធសាសនាបានចូលរួមយ៉ាងច្រើន ក្នុងការកែលំអប្រព័ន្ធគ្រប់គ្រង និងការដឹកនាំប្រទេសជាតិនានា (១៦ប្រទេស) នាសម័យនោះ ឲ្យមានភាពប្រសើរឡើង។

ធម្មវិន័យៈ ព្រះសិទ្ធត្ថសមណគោត្តមយកមកដឹកនាំពុទ្ធសាសនា


- **ធម្ម** (ធម៌) គឺជាគោលការណ៍ ជាទ្រឹស្តី ជាទស្សនាទាន ជាវិថីជីវិត ជាមគ្គុទេសក៍ ជាយុទ្ធសាស្ត្រ សម្រាប់ចង្អុលបង្ហាញអ្នកដែលមានបំណងចង់ដើរតាមពុទ្ធសាសនា យកមកធ្វើជាសរណៈ គឺសម្រាប់ដាស់តឿន សម្រាប់រំលឹក នៅពេលជួបនឹងបញ្ហាក្នុងជីវិត **(ធម្មំ សរណំ គច្ឆាមិ)**។
- **ធម៌** ដែលព្រះសមណគោត្តមបានបង្ហាញដល់មនុស្សជាតិជាលើកដំបូងមានឈ្មោះថា ធម្មចក្កប្បវត្តនសូត្រ ដែលបរិយាយអំពីការពិតជាទីបំផុតក្នុងសង្គម ៤យ៉ាង (អរិយសច្ច ៤) ដែលជីវិតមនុស្សម្នាក់ៗ និងសង្គមតែងជួបប្រទះ នោះគឺ**បញ្ហានានា (ទុក្ខសច្ច:)** ដែលតែងកើតមានព្រោះ **មានហេតុផ្សេងៗ (ទុក្ខសមុទយសច្ច:)**។ **សេចក្តីសង្ឃឹម និងជឿថានឹងអាចចេញផុតពីបញ្ហាទាំងនោះបាន (និរោធសច្ច:)** ដោយ **ការអនុវត្តតាមផ្លូវ (មគ្គសច្ច:)** ឲ្យបានត្រឹមត្រូវ **ល្មមទៅនឹងបញ្ហា និងហេតុរបស់បញ្ហាទាំងនោះ។**



សក្តានុពលពីកំណើតរបស់មនុស្ស	
១-ទិដ្ឋិ	១- យល់ឃើញ
២-សង្កប្ប:	២- ត្រិះរិះ
៣-វាចា	៣- និយាយ
៤-កម្មន្ត:	៤- ធ្វើ
៥-អាជីវ:	៥- ចិញ្ចឹមជីវិត
៦-វាយាម:	៦- ព្យាយាម
៧-សតិ	៧- រលឹកត្រូវ
៨-សមាធិ	៨-ដំកល់ចិត្ត



អភិវឌ្ឍសក្តានុពលរបស់មនុស្ស	
១- សម្មាទិដ្ឋិ	១- យល់ឃើញត្រូវ
២- សម្មាសង្កប្ប:	២- ត្រិះរិះត្រូវ
៣- សម្មាវាចា	៣- និយាយត្រូវ
៤- សម្មាកម្មន្ត:	៤- ធ្វើត្រូវ
៥- សម្មាអាជីវ:	៥- ចិញ្ចឹមជីវិតត្រូវ
៦- សម្មាវាយាម:	៦- ព្យាយាមត្រូវ
៧- សម្មាសតិ	៧- រលឹកត្រូវត្រូវ
៨- សម្មាសមាធិ	៨-ដំកល់ចិត្តត្រូវ



លទ្ធភាពទី១ ដំណើរជីវិតដែលគិតតែពីបំពេញចំណង់ចំណូលចិត្ត គិតតែធ្វើខ្លួនឲ្យបានសុខ ឲ្យបានធាត់ធំ សំបូរហូរហៀរ ដោយវត្ថុដែលបម្រើឲ្យភ្នែក ត្រចៀក ច្រមុះ មាត់ រាងកាយ និងចិត្ត។

កាមសុខល្លិកានុយោគ

លទ្ធភាពទី២ គឺដំណើរជីវិតដែលធ្វើបាបខ្លួនឯងដែលតឹងពេក បង្អត់អាហារ តឹងតែងចំពោះខ្លួនឯងពេក ដោយជឿថាការធ្វើបាបខ្លួនឯងឲ្យស្គមស្គាំង ជាការកាត់បន្ថយកិលេសឲ្យអស់ពីខ្លួន

អត្តកិលមថានុយោគ។ ៧

២.២) ច្បាប់គ្រប់គ្រងសង្គម ក្នុងពុទ្ធសាសនា

- ប្រាំមួយខែបន្ទាប់មក ព្រះសិទ្ធត្ថសមណគោត្តម ក៏បានធ្វើមហាសន្និបាតជាផ្លូវការ ជាមួយនឹងភិក្ខុសង្ឃចំនួន ១២៥០ រូប
- ដើម្បីប្រកាសនូវគោលការណ៍រួម ដែលតម្រូវឲ្យអ្នកដើរតាមការណែនាំ (សាវ័ក) របស់ព្រះអង្គ យកនូវឱវាទដែលអាចចាត់ទុកថាជា ច្បាប់សង្គមដំបូងរបស់ពុទ្ធសាសនា យកទៅអនុវត្ត និងប្រកាសដល់មនុស្សជាតិ ជាសកល។
- គោលការណ៍រួមនេះ ព្រះពុទ្ធអង្គហៅថា ឱវាទបាដិមោក្ខ។ ខ្មែរយើងតែងរំលឹកព្រឹត្តិការណ៍នេះជារៀងរាល់ឆ្នាំ នៅថ្ងៃពេញបូរមីខែមាឃ (**មាឃបូជា**) រៀងរាល់ឆ្នាំ គឺស្ថិតនៅក្នុងរង្វង់ខែ កុម្ភៈ
- ទោះជាយ៉ាងណាក្តី ព្រះសិទ្ធត្ថសមណគោត្តម មិនទាន់បានដាក់ចេញនូវវិន័យ ឬប្រព័ន្ធដាក់ទោសដល់សមាជិក-សមាជិកា ដែលស្ម័គ្រចិត្តចូលមកអនុវត្តតាមច្បាប់សង្គមដែលបានចេញ និងទទួលយកជាធរមាន នៅថ្ងៃមហាសន្និបាតនេះនៅឡើយទេ

1. **សព្វបាបស្ស អករណំ**	1. មិនត្រូវធ្វើអំពើអាក្រក់ទាំងពួង
2. **កុសលស្សូបសម្បទា**	2. ត្រូវធ្វើអំពើល្អឲ្យកើតឡើង
3. **សចិត្តបរិយោទបនំ**	3. ត្រូវជម្រះចិត្តរបស់ខ្លួនឲ្យជូរថ្លង់
4. **ខន្តិ បរមំ តបោ តីតិក្ខា**	4. ត្រូវមានខន្តី គឺសេចក្តីអត់ធន់ ជាតបធម៌ ដ៏ឧត្តម
5. **និព្វានំ បរមំ វទន្តិពុទ្ធា**	5. ព្រះនិព្វាន ជាធម្មជាតិដ៏ឧត្តមដែលត្រូវសម្រេចឲ្យបាន
6. **ន ហិ បព្វជិតោ បរូបឃាតិ សមណោ ហោតិ បរំ វិហេឋយន្តោ**	6. ជាបព្វជិត ជាសមណៈ មិនត្រូវសម្លាប់ មិនត្រូវបៀតបៀនសត្វដទៃ
7. **អនូបវាទោ**	7. មិនត្រូវតិះដៀលអ្នកដទៃ
8. **អនូបឃាតោ**	8. មិនត្រូវបៀតបៀនអ្នកដទៃ
9. **បាដិមោក្ខេ ច សំវរោ**	9. ត្រូវសង្រួមក្នុងបាតិមោក្ខ
10. **មត្តញ្ញុតា ច ភត្តស្មឹ**	10. ត្រូវបរិភោគឲ្យស្គាល់ប្រមាណ
11. **បន្តញ្ច សយនាសនំ**	11. ត្រូវដេក និងអង្គុយក្នុងទីដែលស្ងាត់
12. **អធិចិត្តេ ច អាយោគោ**	12. ត្រូវព្យាយាមអភិវឌ្ឍចិត្តរបស់ខ្លួនឲ្យទៅជាអធិចិត្ត

ព្រះសារីបុត្រ អគ្គសាវ័កស្តាំ ជាបញ្ញាវន្តសង្ឃមួយរូបនាសម័យនោះ ធ្លាប់បានស្នើសុំឲ្យព្រះពុទ្ធអង្គចេញជាវិន័យ ជាច្បាប់ ជាសិក្ខាបទ(អាណាបាតិមោក្ខ) សម្រាប់គ្រប់គ្រងសង្ឃ ព្រោះដោយលោកយល់ឃើញថា ប្រទេសមួយ ឬស្ថាប័នមួយ មិនអាចមិនមានច្បាប់សម្រាប់គ្រប់គ្រងទេ តែត្រូវព្រះពុទ្ធអង្គបដិសេធមិនទាន់បញ្ញត្តសិក្ខាបទ និងដាក់ចេញនូវអាណាបាដិមោក្ខ ដោយផ្តល់ហេតុផលថា មិនទាន់ដល់ពេល។

ផលប្រយោជន៍នៃការមានច្បាប់សម្រាប់សង្គម

១. ដើម្បីបង្កើនសេចក្តីល្អដល់ស្ថាប័នសង្ឃ (សង្ឃសុដ្ឋុតាយ)

២. ដើម្បីឲ្យសង្ឃជាសមាជិក-សមាជិកា អាចរស់នៅដោយប្រកបដោយជាសុកភាព មានសេចក្តីសុខ សប្បាយ ព្រោះស្ថិតនៅក្រោមវិន័យតែមួយ (សង្ឃជាសុតាយ)

៣. ដើម្បីសង្កត់សង្កិនភិក្ខុទាំងឡាយ ដែលមិនអៀនខ្មាសក្នុងការប្រព្រឹត្តិខុស មិនអាចនឹងប៉ានប្រព្រឹត្តខុស ព្រោះមានវិន័យចាំដាក់ទោស(ទុម្មង្កូនំ បុគ្គលានំ និគ្គហាយ)

៤. ដើម្បីឲ្យភិក្ខុទាំងឡាយ ដែលជាអ្នកមានសីលជាទីស្រឡាញ់ មិនដែលប្រព្រឹត្តខុស អាចរស់នៅជាសុខស្រួល (បេសលានំ ភិក្ខូនំ ជាសុវិហារាយ)

៥. ដើម្បីរាវាំងនូវអាសវធម៌ - គឺកិលេសដែលមាននៅក្នុងសន្តានចិត្ត មិនឲ្យងើបចេញមកខាងក្រៅតាមទង្វើ និងការនិយាយ ក្នុងបច្ចុប្បន្នកាល (ទិដ្ឋធម្មិកានំ អាសវានំ សំវរាយ)

៦. ដើម្បីកម្ចាត់ចោលនូវអាសវធម៌ គឺកិលេសនៅខាងក្រៅ ដែលនឹងកើតមាននៅពេលអនាគតមិនអាចចូលមកក្នុងសន្តានចិត្តបាន (សម្បរាយិកានំ អាសវានំ បដិឃាតាយ)

៧. ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលមិនទាន់ជ្រះថ្លាក្នុងព្រះពុទ្ធសាសនាតាមរយៈការប្រព្រឹត្តិរបស់ព្រះសង្ឃ ឲ្យកើតសេចក្តីជ្រះថ្លាឡើង (អប្បសន្នានំ បសាទាយ)

៨. ដើម្បីញុំាងបុគ្គលទាំងឡាយ ដែលជ្រះថ្លាស្រាប់ហើយក្នុងពុទ្ធសាសនាតាមរយៈការប្រព្រឹត្តិរបស់ព្រះសង្ឃ ឲ្យរឹងរឹតតែជ្រះថ្លាឡើង (បសន្នានំ ភិយ្យោភាវាយ)

៩. ដើម្បីឲ្យពាក្យប្រៀនប្រដៅរបស់ពុទ្ធសាសនា អាចតំកល់នៅមាំបានយូរ (សទ្ធម្មដ្ឋិតិយា)

១០. ដើម្បីអនុគ្រោះដល់ព្រះវិន័យ គឺការបង្ហាញពីសារៈសំខាន់នៃវិន័យច្បាប់ ដែលត្រូវតែមាន ទោះជានៅក្នុងប្រទេស ឬស្ថាប័នណាក៏ដោយ មិនអាចអត់មានវិន័យ ឬច្បាប់បានទេ (វិនយានុគ្គហាយ)

៣) ច្បាប់សង្គម នីតិរដ្ឋ ពុទ្ធសាសនា

យុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១៖ កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ របស់រាជរដ្ឋាភិបាលកម្ពុជាអាណត្តិទី៧

1. ធានាឱ្យបានកំណើនសេដ្ឋកិច្ច
2. បង្កើតការងារឱ្យបានកាន់តែច្រើន
3. សម្រេចឱ្យបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ
4. បន្តពង្រឹងសមត្ថភាពអភិបាលកិច្ច និងលើកកម្ពស់គុណភាពស្ថាប័ន
5. ធានាឱ្យបាននូវចីរភាពនៃការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

ឯកសារក្របខ័ណ្ឌយុទ្ធសាស្ត្រ កម្មវិធីកែទម្រង់ច្បាប់ របស់រាជរដ្ឋាភិបាលអាណត្តិទី ៧ បុព្វកថា សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន ម៉ាណែត

«កម្ពុជាត្រូវការប្រព័ន្ធច្បាប់មួយដែលផ្អែកលើនីតិរដ្ឋ ដើម្បីការពារឯករាជ្យ បូរណភាពទឹកដី ភាពជាម្ចាស់ ការពារសិទ្ធិមនុស្ស និងកម្មសិទ្ធិឯកជន យុត្តិធម៌សង្គម ព្រមទាំងគាំទ្រដល់សេដ្ឋកិច្ចទីផ្សារដែលរស់រវើក ក៏ដូចជាការអភិវឌ្ឍសង្គម សេដ្ឋកិច្ចទាំងមូល។ .....ហើយវប្បធម៌នីតិរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពគ្របដណ្តប់លើការកសាងប្រព័ន្ធច្បាប់កម្ពុជាទាំងមូល នៅលើមាគ៌ានៃការពង្រឹងអភិបាលកិច្ចនិងធានាចីរភាពនៃវប្បធម៌នីតិរដ្ឋស្របតាមឧត្តមានុវត្តន៍អន្តរជាតិផង និងបរិការណ៍ប្រវត្តិសាស្ត្រកម្ពុជាផង»។

ទស្សនាទានសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា

«ដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា ៖ **ឫណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ** សំដៅដល់ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ដោយធានាបាននូវការប្រកាន់ខ្ជាប់ជានិរន្តរ៍នូវការគោរព ប្រតិបត្តិ និង**តម្កល់ច្បាប់ជាធំ** ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នានិងជំនឿទុកចិត្ត»។

វប្បធម៌នីតិរដ្ឋ

ដូច្នេះ **នីតិរដ្ឋ** (**និន្ទ័យ**) គឺជាដៃគូយុទ្ធសាស្ត្របញ្ចកោណដែលមាន **មុំទាំង៥** (**ឆទ្ធ**) ដោយមិនអាចខ្វះបាន។ យុទ្ធសាស្ត្របញ្ចកោណទាំង ៥មុំ សុទ្ធតែត្រូវការច្បាប់គាំទ្រទាំងអស់ តែបើច្បាប់ទាំងនោះពុំមាននីតិរដ្ឋទេ ច្បាប់នោះក៏នឹងមិនអាចឲ្យផលបានគ្រប់គ្រាន់ នៅពេលអនុវត្តយុទ្ធសាស្ត្រដែលមានមុំទាំង៥នោះ បានល្អដែរ។

៣.១) Rechtsstaat - នីតិរដ្ឋ Rule of Law - នីតិភិបាល

ខ្មែរយើង ប្រែពាក្យ "នីតិរដ្ឋ" ពីពាក្យអង់គ្លេសថា **Rule of Law**

តែក្នុងទីនេះ ខ្ញុំសូមប្រែទៅ**ជា "នីតិភិបាល"**វិញ ព្រោះថា៖

1. តាមព្យញ្ជនៈន័យ ពាក្យថា **Rule** ប្រែថា ការគ្រប់គ្រង (ជាភាសាខ្មែរ) ឬ អភិបាល (ជាភាសាបាលី)
2. តាមព្យញ្ជនៈន័យ ពាក្យថា **Law** គឺ ច្បាប់ (ជាភាសាខ្មែរ) ឬ នីតិ (ជាភាសាបាលី)
3. សំរាប់អ្នកដែលចង់ប្រៀបធៀបភាសាខ្មែរ និងភាសាអង់គ្លេស នឹងមានចម្ងល់ថា តើពាក្យ " រដ្ឋ " ប្រែមកពីពាក្យអ្វី? ព្រោះភាសាអង់គ្លេសពុំមានពាក្យថា "**State**" ដែលស្មើនឹងពាក្យខ្មែរថា រដ្ឋ នេះសោះ
   a) ភាសាអាឡឺម៉ង់ ពាក្យថា **Rechtsstaat** ដែលអាចប្រែមកជាភាសាអង់គ្លេសថា Sate of Law ឬ legal state អាចនឹងប្រែជាភាសាខ្មែរដោយត្រង់បានថា នីតិរដ្ឋ Staat នេះប្រែថារដ្ឋ ឯ Rechts នេះប្រែថា ច្បាប់ នីតិ។
   b) Rechtsstaat, Sate of Law ពាក្យនេះក៏បានវិវត្តទៅជា ពាក្យ Rule of Law ប្រែថា " ការគ្រប់គ្រងរបស់ច្បាប់ ឬ **នីតិភិបាល** ជាភាសាបាលី។ ទោះជាយ៉ាងណាក្តី ពាក្យនីតិភិបាល នឹងមិនត្រូវបានប្រើប្រាស់ក្នុងអត្ថបទនេះទេ ដើម្បីជៀសវាងភាពស្រពេចស្រពិល។

- ក្នុងន័យជាទូទៅ នីតិរដ្ឋ គឺជាគោលការណ៍ស្នើឡើង ក្នុងគោលបំណងធ្វើឲ្យទំនាក់ទំនងរវាងថ្នាក់អ្នកដឹកនាំ (រដ្ឋាភិបាល) និងថ្នាក់អ្នកត្រូវគេដឹកនាំ (ប្រជាពលរដ្ឋ) មានភាពប្រសើរឡើង
- ដោយឈរនៅលើបន្ទាត់ (Rule) តែមួយ និងស្ថិតនៅក្រោមអំណាចគ្រប់គ្រង (Rule) របស់ច្បាប់តែមួយដូចគ្នា ហើយភាគីទាំងពីរ គប្បីមានប្រភពចេញមកពីមូលដ្ឋានមនុស្សដូចគ្នា គឺម្នាក់ៗមានសិទ្ធិជាមនុស្សដូចគ្នា មានសេរីភាពដូចគ្នា និង
- ការប្រកាន់ខ្ជាប់ជានិរន្តរ៍នូវការគោរព ប្រតិបត្តិ និង**តម្កល់ច្បាប់ជាធំ (ធម្មាធិបតី)** ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នានិងជំនឿទុកចិត្ត
- ស្ថិតនៅក្រោមច្បាប់ធម្មជាតិ ៣យ៉ាង ដូចគ្នា ៖ កើត ចាស់ ស្លាប់ ។

៣.២) នីតិរដ្ឋតាមពុទ្ធសាសនា

ព្រះសម្មាសម្ពុទ្ធបានសំដែងអំពី**អធិបតេយ្យភាព** ៣ យ៉ាង នៅក្នុងព្រះសូត្រ ដែលមានឈ្មោះថា **អធិបតេយ្យសូត្រ** ៖

១- អត្តាធិបតេយ្យ អធិបតេយ្យស្ថិតលើខ្លួនឯង (Supremacy of self)

២- លោកាធិបតេយ្យ អធិបតេយ្យស្ថិតលើប្រជាជន (Supremacy of the public)

៣- ធម្មាធិបតេយ្យ អធិបតេយ្យស្ថិតលើធម៌ (Supremacy of the true law)

ព្រះសម្មាសម្ពុទ្ធទ្រង់លើកទឹកចិត្ត និងសរសើដល់ភិក្ខុអង្គណា ដែលមានធម្មាធិបតេយ្យ នៅក្នុងការបដិបត្តិរបស់ខ្លួន។

នៅក្នុងចក្កវត្តិសូត្រ ជាសូត្រនិយាយអំពីការគ្រប់គ្រងដែលអាចនាំប្រទេសឱ្យទៅកាន់វឌ្ឍនភាពដ៏បរិបូណ៌មួយនោះ ព្រះសិទ្ធត្ថសមណគោត្តមបានលើកឡើងពីគោលការណ៍បួនយ៉ាង សំរាប់ឱ្យអ្នកដឹកនាំអនុវត្ត តាមគឺ៖

1) យកធម៌ជាអធិបតី និងចាត់ចែងនូវការរក្សាទប់ទល់ គ្រប់គ្រងប្រកបដោយធម៌ **(ធម្មាធិបតេយ្យោ ធម្មិកំ រក្ខាវរណគុត្តឺ សំវិទហស្សុ)**
2) បង្ការមិនឱ្យមានអំពើដែលអធម៌ (អំពើខុសច្បាប់) កើតឡើង នៅក្នុងអាណាចក្រ **(មា អធម្មការ)**
3) បែងចែកទ្រព្យសម្បត្តិដល់អ្នកក្រីក្រ និងជួយដល់អាជីវកម្មចិញ្ចឹមជីវិត **(ធនានុប្បទាន)**
4) សាកសួរប្រឹក្សាសុំយោបល់ជាមួយសមណព្រាហ្មណ៍ អំពីគោលការណ៍ទាំង៣ ខាងលើដែលកំពុងអនុវត្ត **(សមណព្រាហ្មណបរិបុច្ឆា)**

៣.២) នីតិរដ្ឋតាមពុទ្ធសាសនា និងការអនុវត្ត

ធម្មាធិបតេយ្យ (ធម្មាធិបតី យកច្បាប់ជាធំ) គ្រាន់តែជាសេចក្តីសង្ខេប ១/១០ នៃការយក ធម៌ជាអធិបតី ក្នុងការគ្រប់គ្រងប្រទេស៖

1. អាស្រ័យនូវ**ធម៌** ច្បាប់ (ធម្មំយេវ និស្សាយ)
2. ធ្វើសក្ការៈ ចំពោះច្បាប់ (ធម្មំ សក្ករោន្តោ)
3. គោរពច្បាប់ (ធម្មំ គរុករោន្តោ)
4. រាប់អានច្បាប់ (ធម្មំ មានេន្តោ)
5. បូជាច្បាប់ (ធម្មំ បូជេន្តោ)
6. កោតក្រែងច្បាប់ (ធម្មំ អបចាយមានោ)
7. យកច្បាប់ជាទង់ជ័យ (ធម្មទ្ធជោ)
8. យកច្បាប់ជាស្តង់ដា (ធម្មកេតុ)
9. យកច្បាប់ជាអធិបតី (ធម្មាធិបតេយ្យោ)
10. ចាត់ចែងនូវការការពារ ទប់ទល់ គ្រប់គ្រង ប្រកបដោយច្បាប់ (**ធម្មិកំ**រក្ខាវរណគុត្តិ សំវិទហស្សុ)

10. ចាត់ចែងនូវការការពារ ទប់ទល់ គ្រប់គ្រង **ប្រកបដោយច្បាប់** (**ធម្មិកំ**រក្ខាវរណគុត្តិ សំវិទហស្សុ) ដល់

ក) ជនខាងក្នុង មានក្រុមគ្រួសារ និងអ្នកដែលនៅក្រោមអាណាព្យាបាល (អន្តោជន)

ខ) កងទ័ពគ្រប់ប្រភេទ (ពលកាយ)

គ) ក្រុមគណៈរដ្ឋមន្ត្រី រដ្ឋាភិបាល អ្នកនយោបាយ (ខត្តិយៈ)

ឃ) មន្ត្រីរាជការ (អនុយន្តៈ)

ង) ពាណិជករ គ្រូ អ្នកសាសនា ពេទ្យ បញ្ញវន្ត ជាដើម (ព្រាហ្មណ គហបតី)

ច) អ្នកនិគមជនបទ កសិករ កម្មករ (នេគមជានបទ)

ឆ) ព្រះសង្ឃ បព្វជិតសាសនាទាំងឡាយ (សមណព្រាហ្មណៈ)

ជ) សត្វម្រឹគ បក្សី ព្រៃឈើ សម្បត្តិធម្មជាតិ ដែលគួរអភិរ័ក្ស (មិគបក្សី)

អង្គប្រកប ក្នុងការពង្រឹងធម្មាធិបតេយ្យ

- ពុទ្ធសាសនាបង្ហាញនូវការយកចិត្តទុកដាក់លើអធិបតេយ្យភាពរបស់ច្បាប់ នៅក្នុងការអភិវឌ្ឍប្រទេស។ ទោះជាយ៉ាងណាក្តី
  - នីតិរដ្ឋមិនមែនអាចកើតឡើងបានដោយងាយៗ
  - មិនអាចលុតលាស់ក្នុងរយៈពេលដ៏ខ្លីបានទេ
  - ត្រូវការរដ្ឋាភិបាលដែលមានធម្មិកភាព
  - ត្រូវមានការគាំទ្រពីអង្គប្រកបដទៃទៀត
- ជាពិសេសក្នុងករណីប្រទេសកម្ពុជា ដែលទើបតែក្រេបរសជាតិសន្តិភាពក្នុងរយៈពេលមិនយូរកន្លងមកនេះ។

ត្រូវការរដ្ឋាភិបាលដែលមានធម្មិកភាព

1. ជាស្តេច ដែលបានអភិសេកត្រឹមត្រូវ
2. ជាធម្មិកធម្មរាជ ប្រកបដោយទសពិធរាជធម៌
3. ជាឥស្សរៈលើផែនដី (មានឯករាជ្យ បូរណភាពដែនដី)
4. ជាស្តេចឈ្នះសង្គ្រាម (មិននៅក្រោមអាណានិគម)។
5. មានជនបទដល់នូវចិរភាព (សេចក្តីមាំមួន) មានស្ថិរភាព សុវត្ថិភាពគ្រប់ទីកន្លែង (មានសន្តិភាព)
6. **បរិបូរ ដោយរតនវត្ថុទាំង៧ប្រការ (ធនធនធម្មជាតិ-មូលធនមនុស្ស)**
7. មានព្រះរាជបុត្រច្រើនជាងពាន់ (មេទ័ពដែលទុកចិត្តបាន) ក្លៀវក្លា អង់អាច អាចយកឈ្នះ នូវសេនារបស់ស្តេចដទៃបាន គឺមានសមត្ថភាពខ្លាំងពូកែក្នុងការធ្វើសឹកសង្គ្រាម
8. ត្រួតត្រា គ្រប់គ្រងផែនដី ដែលមានសាគរជាព្រំប្រទល់នេះ **ដោយធម៌ដ៏ស្មើ** មិនបាច់ប្រើអាជ្ញា មិនបាច់ប្រើគ្រឿងសស្ត្រាវុធ គ្រប់គ្រងផែនដី

បរិបូរ ដោយរតនវត្ថុទាំង៧ប្រការ


1. គឺចក្កវត្តន៍ (ចក្រកែវ) យានជំនិះលឿនខ្លាំងបំផុត (យន្តហោះ?)
2. ហត្ថិវត្តន៍ (ដំរី) ល្បឿនលឿន
3. អស្សវត្តន៍ (សេះ) ល្បឿនលឿន
4. មណីវត្តន៍ (កែវមណី) ទ្រព្យធម្មជាតិកម្រនិងថ្លៃ
5. ឥត្ថីវត្តន៍ (នារីរតន៍) នារីៗស្រស់ស្អាតល្អ
6. គហបតីវត្តន៍ (នាយឃ្លាំង) ជាពាណិជករល្អ
7. បរិនាយកវត្តន៍ (នាយពល) នាយករដ្ឋមន្ត្រីល្អ

ចំណុចទី១- ធម្មាធិបតេយ្យ: ត្រូវមានការគាំទ្រពីអង្គប្រកបដទៃទៀត

1. **ធម្មាធិបតេយ្យ**

ត្រូវមានការគាំទ្រពីអង្គប្រកបដទៃទៀត


2. បង្ការមិនឱ្យមានអំពើដែលអធម៌ (អំពើខុសច្បាប់) កើតឡើង នៅក្នុងអាណាចក្រ **(មា អធម្មការ)**
3. បែងចែកទ្រព្យសម្បត្តិដល់អ្នកក្រីក្រ និងជួយដល់អាជីវកម្មចិញ្ចឹមជីវិត **(ធនានុប្បទាន)**
4. សាកសួរប្រឹក្សាសុំយោបល់ជាមួយសមណព្រាហ្មណ៍ អំពីគោលការណ៍ទាំង៣ ខាងលើដែលកំពុងអនុវត្ត **(សមណព្រាហ្មណបរិបុច្ឆា)**




ចំណុចទី២- មា អធម្មិការ

ចូរបាកុំធ្វើអកុសលធម៌ ក្នុងដែនដីរបស់អ្នកឡើយ

ភាពជាគម្រូក្នុងការអនុវត្តធម្មាធិបតេយ្យ យកច្បាប់ជាធំ មាននីតិរដ្ឋបរិបូរណ៍





11/03/2024

១៦

ចំណុចទី៣ (ធនានុប្បទាន)

- នីតិរដ្ឋក្នុងទស្សនៈនៃព្រះសូត្រ ត្រូវការបរិយាកាសគោលនយោបាយសង្គមមួយ ដែលមានលក្ខណៈជាប្រភេទរដ្ឋសុខមាលភាព (Welfare State) ។
- ចក្កវត្តិរាជាបានប្រាប់រាជបុត្រថា **ម្នាលបា បើពួកជនណា ស្ថិតក្នុងដែនរបស់អ្នក មិនមានទ្រព្យ អ្នកគប្បី ផ្តល់ធន (ទ្រព្យ) ដល់ជនទាំងនោះ** ។ ទ្រព្យនៅក្នុងទីនេះ មិនមែនត្រឹមតែជាការផ្តល់អំណោយដល់ទុរគតរាស្ត្រទេ គឺសំដៅដល់ការបង្កើតឱកាសការងារ ការផ្តល់ដើមទុនសម្រាប់អាជីវករទាំងឡាយ បានប្រកបអាជីវកម្ម ដើម្បីបង្កើនកម្លាំងសេដ្ឋកិច្ច និងការបង់ពន្ធចូលរដ្ឋ សម្រាប់អភិវឌ្ឍប្រទេស។ ពុទ្ធសាសនា ផ្តល់សារៈសំខាន់លើ ទុនខាងក្នុង។

ផ្តល់ការវិនិយោគទុនខាងក្នុង (soft capitals) សម្រាប់អាជីវកម្ម ដល់ពលរដ្ឋ

(1) សទ្ធាធនំ ជឿជាក់ក្នុងច្បាប់កម្មផល
(2) សីលធនំ រក្សាសីល គោរពច្បាប់
(3) ហិរិធនំ ខ្មាសអៀនក្នុងការធ្វើអាក្រក់
(4) ឱត្តប្បធនំ ខ្លាចមានទោសព្រោះធ្វើអាក្រក់
(5) សុតធនំ ការសិក្សា
(6) ចាគធនំ ការលះបង់ និង
(7) បញ្ញាធនំ បញ្ញា


ចំណុចទី៤ (សមណព្រាហ្មណបរិបុច្ឆា)


- នីតិរដ្ឋក្នុងទស្សនៈនៃចក្កវត្តិសូត្រ បានដល់ការបើកចំហឬផ្តល់លំហ សម្រាប់ការរិះគន់ពីសំណាក់ប្រជាពលរដ្ឋ (civic space)
- ជ្រើសរើសបញ្ញវន្ត សមណៈអ្នកបួស ដែលមានចំណេះដឹង មានគុណធម៌ មានឯករាជ្យភាព ឲ្យចូលមកវាយតម្លៃលើការអនុវត្តគោលការណ៍ទាំង៣ ខាងលើ
- «ម្នាលបា បើពួកសមណព្រាហ្មណ៍ណា ស្ថិតក្នុងដែនរបស់អ្នក ជាអ្នករៀរចាកសេចក្តីស្រវឹង និងសេចក្តីប្រមាទ តាំងនៅក្នុងខន្តិ និងសោរច្ចៈ តែងទូន្មានខ្លួនឯងតែម្នាក់ឯង ធ្វើខ្លួនឯងឲ្យស្ងប់រម្ងាប់ ធ្វើខ្លួនឯងឲ្យរលត់ (ចាករាគាទិក្កិលេស) តែម្នាក់ឯង
- អ្នកគប្បីចូលទៅរកសមណព្រាហ្មណ៍ទាំងនោះសព្វៗកាល ហើយគប្បីសាកសួរ គប្បីចោទដណ្តឹងថា បពិត្រលោកដ៏ចម្រើន អ្វីជាកុសល បពិត្រលោកដ៏ចម្រើន អ្វីជាអកុសល អ្វីជាអំពើប្រកបដោយទោស អ្វីជាអំពើមិនប្រកបដោយទោស អ្វីគួរសេព អ្វីមិនគួរសេព អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយមិនជាប្រយោជន៍ ជាទុក្ខអស់កាលយូរអង្វែង មួយទៀត អំពើដូចម្តេច ដែលខ្ញុំធ្វើទៅហើយ ជាប្រយោជន៍ ជាសុខអស់កាលយូរអង្វែង ។
- លុះអ្នកបានស្តាប់ពាក្យសមណព្រាហ្មណ៍ទាំងនោះហើយ គប្បីវៀរនូវអំពើដែលជាអកុសល ហើយសមាទានប្រព្រឹត្តនូវអំពើដែលជាកុសល ។ ម្នាលបា នេះឯង ជាចក្កពត្តិវត្ត ដ៏ប្រសើរនោះ» ។ (Recommendation and adoption) ១៧

៣.៣) ការថយចុះ និងបាត់បង់នីតិរដ្ឋ	៣.៤) ការស្តារ និងបដិរូបនីតិរដ្ឋ	៣.៥) បដិរូបកម្ម តាមបែបពុទ្ធសាសនា
• អនិច្ចំ ជារឿងធម្មតា ក្នុងការថយចុះ ឬ កើនឡើង • មិនយកច្បាប់ជាធំ (ធម្មាធិបតេយ្យ) ជាមូលហេតុនៃការធ្លាក់ចុះ • បញ្ហាសេដ្ឋកិច្ច និងវិសមភាពសង្គម ភាពក្រីក្រ • ការរៀបចំគោលនយោបាយកំចាត់ភាពក្រីក្រ មិនបានល្អត្រឹមត្រូវ • ត្រួតត្រា គ្រប់គ្រងផែនដី ដោយធម៌មិនស្មើ ប្រើអំពើ ហឹង្សាជាមធ្យោបាយ • ការបះបោរ ការតតាំងនឹងស្តេចចក្កពត្តិ និងរដ្ឋាភិបាល • បញ្ហាសង្គមកាន់តែកើនឡើង • សង្គ្រាម ការប្រហារគ្នាមិនរើសមុខ រហូតសឹងផុតពូជ	• ប្រជាជននៅសល់ពីសង្គ្រាម មានចំនួនតិច • ដំណោះស្រាយដើម្បីបង្កើនចំនួនមនុស្ស និងអាយុខ្លី គឺធ្វើកិច្ចសន្យាជាមួយគ្នា វៀរចាកឈប់សម្លាប់ជីវិតមនុស្សផងគ្នា។ (social law) • អនុវត្តតាមពាក្យសន្យាសង្គម (social contract) បន្តដោយច្បាប់សង្គម៖ មិនលួច មិនប៉ះពាល់កម្មសិទ្ធិប្តី-ប្រពន្ធ មិននិយាយកុហក មិនសេពសុរាគ្រឿងញៀនទាំងឡាយ ក៏កើតឡើងជាបន្តបន្ទាប់។ នេះ អាចថាជាកំណើតច្បាប់សង្គមដំបូងគេបង្អស់ ដែលមាននៅក្នុងទស្សនាទានរបស់ពុទ្ធសាសនា ហើយដែលព្រះពុទ្ធអង្គបានកំណត់និយាមច្បាប់សង្គមនេះថាជា សីល៥ ឬ និច្ចសីល ដែលជាច្បាប់សង្គមមូលដ្ឋាន របស់មនុស្សជាតិ។	• ហេតុអ្វី បដិរូប? អ្វីៗទាំងអស់សុទ្ធតែមិនទៀង មានការប្រែប្រួល មានការផ្លាស់ប្តូរ ជាប្រចាំ។ ពាក្យ អនិច្ចំ ក្នុងពុទ្ធសាសនា ប្រែថា សភាៈ មិនទៀង។ • ការប្រែប្រួល ការផ្លាស់ប្តូរនេះ ធ្វើឲ្យកើតសំណឹក ធ្វើឲ្យកើតវិរូប (deform) និងឈានទៅរកការទ្រុឌទ្រោមបាក់បែក ធ្លុះធ្លាយ ទាល់តែមិនអាចមានរូបដើមនៅស្ថិតស្ថេរបាន មិនអាចដំណើរការបាន មិនអាចបំពេញមុខងារបាន (dysfunction) • បើមិនមានការជួសជុល ឬរៀបចំឡើងវិញទេ (បដិរូប reform)។ ប្រសិនជាបដិរូបហើយ នៅតែមិនអាចដំណើរការបានល្អនោះ វិធីបដិវត្តន៍ (revolution) ក៏អាចនឹងចូលមកជំនួសប្រព័ន្ធដែលមិនដំណើរការនោះជាមិនខាន។ • ក្នុងពុទ្ធសាសនា បេក្ខជនដែលមានប្រាថ្នានឹងបានហៅៈជាសាមណេរ ត្រូវទទួលយកកិច្ចសន្យាពីព្រះឧបជ្ឈាយ៍ដែលប្រាប់ថា **បដិរូបំ** គឺឲ្យទទួលយកការបដិរូបខ្លួនពីការរស់នៅបែបគ្រហស្ថ មកជាបែបបព្វជិត ដែលជាភេទអ្នកបួស ដោយគោរពតាមធម៌វិន័យទាំងឡាយដែលព្រះសម្មាសម្ពុទ្ធបានសម្តែងទុក។ បើមិនធ្វើបដិរូបទេ មិនធ្វើកំណែទម្រង់ មិនព្រមកែចិត្ត ផ្ទត់ផ្ទង់និត អាកប្បកិរិយាទេ អ្នកនោះនឹងទទួលនូវក្តីអន្តរាយ គឺអាចឆាប់សឹក ឬត្រូវចាប់ផ្សឹក ជាមិនខាន។ ១៨

៣.៥) បដិរូបកម្ម តាមមង្គលសូត្រ

- **បដិរូបទេសវាសោ ច បុព្វេ ច កតបុញ្ញតា អត្តសម្មាបណីធិ ច ឯតម្មង្គលមុត្តមំ។**
- **អសេវនា ចពាលានំ បណ្ឌិតានញ្ច សេវនា បូជា ច បូជនីយានំ ឯតម្មង្គលមុត្តមំ។**
- **ពាហុសច្ចញ្ច សិប្បញ្ច វិនយោ ច សុសិក្ខិតោ សុភាសិតា ច យា វាចា ឯតម្មង្គលមុត្តមំ។**
- កិរិយានៅក្នុងប្រទេសដ៏សមគួរ១ ភាវៈនៃបុគ្គលបានធ្វើបុណ្យទុកហើយក្នុងកាលមុន១ កិរិយាតម្កល់ខ្លួនដោយប្រពៃ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម។
- កិរិយាមិនសេពគប់នូវបុគ្គលពាលទាំងឡាយ១ កិរិយាសេពគប់នូវបុគ្គលជាបណ្ឌិតទាំងឡាយ១ កិរិយាបូជាដល់បុគ្គល ដែលគួរបូជាទាំងឡាយ១ ទាំង៣នេះ ជាមង្គលដ៏ឧត្តម។
- ភាវៈនៃបុគ្គលបានស្តាប់បានរៀនហើយដោយច្រើន១ សិល្ប៍សាស្ត្រ គឺសេចក្តីឆ្លៀវឈ្លាសក្នុងហត្ថកម្មរបស់អ្នកបួស និងគ្រហស្ថ១ វិន័យដែលបុគ្គលសិក្សាដោយប្រពៃ១ វាចាដែលបុគ្គលពោលត្រឹមត្រូវ១ ទាំង៤នេះ ជាមង្គលដ៏ឧត្តម។




កម្ពុជាប្រព័ន្ធច្បាប់មួយដែលផ្អែកលើនីតិរដ្ឋ ដើម្បីការពារឯករាជ្យ បូរណភាពទឹកដីភាពជាម្ចាស់ ការពារសិទ្ធិមនុស្ស និងកម្មសិទ្ធិឯកជន យុត្តិធម៌សង្គម ព្រមទាំងគាំទ្រដល់សេដ្ឋកិច្ចទីផ្សារដែលរស់រវើក ក៏ដូចជាការអភិវឌ្ឍសង្គម សេដ្ឋកិច្ចទាំងមូល។ .....ហើយវប្បធម៌នីតិរដ្ឋរបស់ព្រះរាជាណាចក្រកម្ពុជា និងមានវិសាលភាពគ្របដណ្តប់លើ ការកសាងប្រព័ន្ធច្បាប់កម្ពុជាទាំងមូល នៅលើមាគ៌ានៃការពង្រឹងអភិបាលកិច្ចនិងធានាចីរភាពនៃវប្បធម៌នីតិរដ្ឋ ស្របតាមឧត្តមានុវត្តន៍អន្តរជាតិផង និងបរិការណ៍ប្រវត្តិសាស្ត្រកម្ពុជាផង»។
បុព្វកថាសម្តេចបវរធិបតីហ៊ុន ម៉ាណែត
បទេសនាសោ
រដ្ឋកែទម្រង់ ៥យ៉ាង
សម្តេចធិបតី ហ៊ុន ម៉ាណែត
ឆាមិភាពធ្ងន់ទាំង ៥ ចំណុច៖
១. កំណែទម្រង់រឹតស័ចអាវ៉ាំ
២. ការពង្រឹងរឹតស័ចសុខភិបាល
៣. កំណែទម្រង់រឹតស័ចមុខរបរសាធារណៈ
៤. ការប្រយុទ្ធប្រឆាំងអំពើឆបោក
៥. កំណែទម្រង់លើប្រព័ន្ធច្បាប់ ប្រព័ន្ធតុលាការ
បទេសនាសោ
គោលបំណង
មូលធនមនុស្ស
ចំណេះដឹងច្បាស់លាស់
ជំនាញធ្វើច្បាស់លាស់
វិន័យជីវិត-ការងារល្អ
សម្តីពីរោះ មានហេតុ-ផល
អត្តសម្ភាពណីធិ
តម្កល់ខ្លួនដោយប្រពៃ
បុព្វេកតបុញ្ញតា
មានបុណ្យទុកពីមុនមក
មិនសេពគប់
បុគ្គលពាល
បូជា
បុគ្គលដែលគួរបូជា
សេពគប់
បណ្ឌិត
ទាន
វិនិយោគ
សីល
កាន់សីល កាន់ច្បាប់
ភាវនា
អភិវឌ្ឍ


សេចក្តីសន្និដ្ឋានលើ ពុទ្ធសាសនានឹងច្បាប់សង្គម
ពីទ្រឹស្តី ឆ្ពោះទៅការអនុវត្តជាក់ស្តែង (From Theory to Praxis)

- **ច្បាប់សង្គមៈ** សេចក្តីបញ្ញត្តិ វិន័យ ក្រឹត្យក្រម ក្បួនប្រដៅ សម្រាប់ផ្សារភ្ជាប់សង្គម ដែលមនុស្សតែងជួបប្រសព្វគ្នា ឲ្យនាំគ្នាប្រតិបត្តតាម ដើម្បីឲ្យកើតការរាប់រកគ្នា មានសាមគ្គី មានសមានច្ឆន្ទ ក្នុងការការពារកុំឲ្យមានការប្រកួតប្រជែង ការឈ្លោះប្រកែក ការប្រយុទ្ធ ការធ្វើសឹកសង្គ្រាម ។
- **ច្បាប់សង្គម ជាវិស័យដ៏ទូលំទូលាយនៃច្បាប់** ដែលគ្រប់គ្រងទំនាក់ទំនង និងអន្តរកម្មរវាងបុគ្គលនឹងសង្គម ដោយផ្តោតទៅលើសុខុមាលភាពសង្គម យុត្តិធម៌ និងទ្រព្យសម្បត្តិសមូហភាព។
- **ច្បាប់សង្គម និយាយអំពីរបៀបដែលសង្គមមួយគួរតែត្រូវបានរៀបចំ** ដោយមានបំណងបិទគម្លាតរវាងសេរីភាពបុគ្គល និងទំនួលខុសត្រូវសមូហភាព ដោយការបង្កើតក្របខ័ណ្ឌច្បាប់សម្រាប់វិស័យផ្សេងៗ ដូចជាវិស័យសន្តិសុខសង្គម ពលកម្ម និងជីវិតគ្រួសារ ដែលជារឿយៗ ឆ្លុះបញ្ចាំងពីតម្លៃនៃរដ្ឋសុខុមាលភាព ។
- **ពុទ្ធសាសនា មានទស្សនាទានជាច្រើន** ដែលនិយាយអំពី ច្បាប់ គោលការណ៍ សីល ដើម្បីការពារមិនឲ្យអំពើអាក្រក់ចូលមកយាយីបុគ្គល សង្គម និងធម្មជាតិ។ វិធានការដើម្បីកំចាត់អ្វីដែលជាអកុសល មិនល្អសម្រាប់បុគ្គល សង្គម ធម្មជាតិ។ របៀបអភិវឌ្ឍសមិទ្ធិផលជាប្រយោជន៍ដល់សង្គមផ្សេងៗ និងរបៀបការពារឲ្យសមិទ្ធិផលនោះគង់វង្ស។
- **អនិច្ច បដិរូប បដិវត្តន៍ៈ** គ្រោងសាងសង្គមក្តី ច្បាប់ក្តី និងអ្វីៗទាំងអស់សុទ្ធតែមានបញ្ហា និងការប្រែប្រួល។ បដិរូប ឬកំណែទម្រង់ ជារឿងចាំបាច់ដើម្បីទទួលបាននូវសុភមង្គលមួយដែលប្រាថ្នាចង់បាន។ ភិក្ខុ-សាមណេរ ក្នុងពុទ្ធសាសនា សុទ្ធតែត្រូវធ្វើ បដិរូបជាប្រចាំ។ ២១

សេចក្តីសន្និដ្ឋានលើ ពុទ្ធសាសនានឹងច្បាប់សង្គម
ពីទ្រឹស្តី ឆ្ពោះទៅការអនុវត្តជាក់ស្តែង (From Theory to Praxis)

- **សម្តេចតេជោហ៊ុន សែន៖ «កែទម្រង់ ឆ្ងាស់ មិនកែទម្រង់ ក៏ស្លាប់»**
- **ការបង្អែបង្អង់ក្នុងការធ្វើបដិរូប ជាញយដង** នឹងនាំឲ្យបាត់បង់ទំនុកចិត្ត និងអាចនាំទៅជាអំពើហឹង្សាក្នុងសង្គមជាតិបាន
- **មួយជំហានម្តង មួយជំហានម្តង។ ធ្វើកិច្ចការសន្សឹមក្នុងកាលដែលគួរសន្សឹម ប្រញាប់ប្រញាល់ក្នុងកាលដែលគួរប្រញាប់ប្រញាល់** រមែងបានសេចក្តីសុខ ព្រោះមានវិធានការ ល្អ ប្រកបដោយយោនិសោមនសិការៈ។ ប្រយោជន៍របស់បុគ្គលនោះ រមែងពេញបរិបូណ៌ ដូចជាព្រះចន្ទ្រប៉ែកខាងខ្នើត
- **សម្ផាបដិរូប** ឬការធ្វើបដិរូបឲ្យបានសមស្របទៅនឹងតម្រូវការ និងការផ្គត់ផ្គង់ ដល់ដំណើរការបដិរូប ជារឿងសំខាន់។
- **ការពង្រឹងគុណតម្លៃមនុស្ស វប្បធម៌សន្តិភាព និងការចូលរួមអភិវឌ្ឍសង្គម** នៃកម្មវិធីសិក្សា សីលធម៌-ពលរដ្ឋវិជ្ជា ដើម្បីជួយឲ្យកំណែទម្រង់គន្លឹះជាអាទិភាព ទាំង៨ បានរលូន និងជោគជ័យ
- **បណ្តុះ និងពង្រឹងមូលធនមនុស្ស៖** មូលធនមនុស្សដែលប្រកបដោយ ចំណេះដឹងផ្សេងៗដ៏ច្បាស់លាស់ (ពហុសច្ចញ្ញ multidisciplinary)។ ចំណេះជំនាញធ្វើ ច្បាស់លាស់ (សិប្ប: skills)។ វិន័យក្នុងការរស់នៅ និងក្នុងការងារល្អ (វិនយោ ច សុសិក្ខិតោ discipline, morale, conduct)។ សម្តីពីរោះ ឆ្លៀវឆ្លាសក្នុងការនិយាយពីរោះ មានហេតុ-ផល (សុភាសិតា ច យា វាចា well-spoken speech)
- **អាស្រ័យនូវច្បាប់ ធ្វើសក្ការៈចំពោះច្បាប់ គោរពច្បាប់** រាប់អានច្បាប់ បូជាច្បាប់ កោតក្រែងច្បាប់ យកច្បាប់ជាទង់ជ័យ យកច្បាប់ជាស្តង់ដា យកច្បាប់ជាអធិបតី និង ចាត់ចែងនូវការការពារ ទប់ទល់ គ្រប់គ្រង ប្រកបដោយច្បាប់ ដល់ប្រជារាស្ត្រ។ បង្ការមិនឱ្យមានអំពើដែលអធម៌ កើតឡើង នៅក្នុងរាជាអាណាចក្រ។ បែងចែកទ្រព្យសម្បត្តិ ដល់អ្នកក្រីក្រ និងដល់អាជីវករ។ សាកសួរប្រឹក្សាជាមួយសមណព្រាហ្មណ៍ អំពីប្រសិទ្ធភាព និងសក្តិសិទ្ធិភាព នៃគោលការណ៍ទាំង៣ ។ ២២

សូមអរគុណ


កម្មវិធីសិក្សាពលរដ្ឋវិជ្ជា ទី ១០ ដល់ ១២
១-តម្លៃមនុស្ស
ចំណេះដឹង
Knowledge
ពលរដ្ឋសកម្ម
បំណិន Skill
ឥរិយាបថ
Attitude
២-វប្បធម៌សន្តិភាព
៣-ការចូលរួមអភិវឌ្ឍន៍

២៣

ប្រធានបទទី២
ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេ
ប្រវត្តិដល់បច្ចុប្បន្ន

សម្រាបសម្រួលរួមដោយ ឯកឧត្តមបណ្ឌិត ហែល ចំរើន
រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក គ.ក.ច.
និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម

បញ្ជីឈ្មោះក្រុមសិក្ខាស្រាវជ្រាវ
អនុប្រធានបទស្តីពីច្បាប់ទំនៀមក្នុងសង្គមកម្ពុជា
ឆាសម័យបុរេប្រវត្តិ ហ្វូណន និងចេនឡា

លរ.	គោតនាម និងនាម	វិជ្ជាជីវៈ	ស្ថាប័ន	ការចូលរួម
១	បណ្ឌិត ជុយ ចាន់ធួន	សាស្ត្រាចារ្យ	រាជបណ្ឌិត្យសភាកម្ពុជា	អ្នកសម្រប សម្រួល, ផ្តល់ជាតុចូល និង និពន្ធ
២	ឯកឧត្តម លីវ សុវណ្ណា	អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់	ក្រុមប្រឹក្សាអ្នកច្បាប់	ផ្តល់ជាតុចូល និងនិពន្ធ
៣	ឯកឧត្តម ស៊ីយ៉ុន សុការិទ្ធ	អនុរដ្ឋលេខាធិការ	ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ	ផ្តល់ជាតុចូល
អ្នកសម្របសម្រួលក្រុមស្រាវជ្រាវ				
៤	លោក ម៉ន សុភ័ណ	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ
៥	លោក មាយ សីហា	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ

អនុប្រធានបទស្តីពីច្បាប់ទំនៀមក្នុងសង្គមកម្ពុជា នាសម័យបុរេប្រវត្តិ ហ្វូណន និងចេនឡា

ខ្លឹមសារសង្ខេប

កម្ពុជា ដែលជាប្រទេសដ៏ចំណាស់មួយនៅអាស៊ីអាគ្នេយ៍ ធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសស្តុកស្តម្ភ ប្រុំប្រើង រុងរឿង ធំទូលាយរហូតក្លាយជាអាណាចក្រមួយ ដែលមានសមន្តរដ្ឋចំណុះជាច្រើន។ ដើម្បីរៀបចំ គ្រប់គ្រង និងអភិវឌ្ឍសង្គមមួយ ឱ្យក្លាយជាសង្គម ដែលមានអារ្យធម៌ខ្ពង់ខ្ពស់ឧត្តុង្គឧត្តមបាន ត្រូវមានប្រព័ន្ធច្បាប់មួយប្រកបដោយប្រសិទ្ធភាព។ ប្រព័ន្ធច្បាប់នេះមានប្រភពពីទំនៀមទម្លាប់ប្រពៃណី ជំនឿ សីលធម៌ និងសាសនា។ ច្បាប់ទំនៀមមានប្រភពចេញពីទម្លាប់ ជាប់ជាទំនៀម ចេញពីប្រពៃណីរបស់អ្នកស្រុក ចេញពីសីលធម៌រួមរបស់សង្គម និងចេញពីជំនឿសាសនា។ គ្រួសារជាស្ថាប័នគ្រប់គ្រងសង្គមជាមូលដ្ឋានដំបូងរបស់មនុស្សជាតិ។ គ្រួសារមានភាពតឹងតែង ជាអង្គភាពដែលបានរៀបចំច្បាប់គ្រប់គ្រង ទំនោរទៅលើការរក្សាសុខុមាលភាពរបស់សមាជិករបស់ខ្លួន ប្រឆាំងនឹងភ្នាក់ងារខាងក្រៅណាមួយ ជាផ្លូវការ ឬមិនផ្លូវការ ហើយប្រហែលជាការការពារតែមួយគត់នៃផលវិបាកប្រឆាំងនឹងការកេងប្រវ័ញ្ចគ្មានដែនកំណត់នៃវណ្ណៈ។ ដើម្បីឱ្យមានគំនិតខ្លះៗអំពីការរៀបចំសង្គមនិងច្បាប់នៃសង្គម ដែលកំពុងសិក្សា គេអាចបន្តសួរសំណួរត្រឹមត្រូវអំពីទិដ្ឋភាពផ្សេងទៀតនៃសង្គមនោះ។ ឧទាហរណ៍ ក្រុមដែលបានរៀបចំជាអ្វីដែលហៅថា **ក្រុមសង្គម** ចេញពីសង្គមអ្នកចិញ្ចឹមជីវិតដោយការបរបាញ់ និងការប្រមូលអាហារ(ឬរកអាហារ) និងបន្តដំណើរទៅមុខជានិច្ច មិនដែលនៅកន្លែងមួយយូរល្មម នឹងសង់ទីប្រជុំជន ឬទីក្រុងនោះទេ ទាំងចំនួនប្រជាជនរបស់ពួកគេមិនគ្រប់គ្រាន់ ឬអង្គការសង្គម និងសេដ្ឋកិច្ចរបស់ពួកគេមានភាពស្មុគស្មាញ។ ដូច្នេះ វាគ្មានន័យទេក្នុងការរំពឹងថា នឹងស្វែងរកទីក្រុង ឬទីប្រជុំជនក្នុងចំណោមសង្គមបែបនេះ។ ប៉ុន្តែដូចគ្នានេះដែរ គេត្រូវសិក្សាពីអ្វី ដែលក្រុមសង្គមបង្កើតឡើង តាមរបៀបនៃរចនាសម្ព័ន្ធ ហើយស្វែងយល់ថា តើដានទាំងនេះអាចបន្សល់ទុកអ្វីខ្លះ នៅក្នុងកំណត់ត្រាបុរាណវិទ្យាសង្គម។ អ្នកសង្កេតការណ៍សម័យថ្មី ជាទូទៅមើលស្រាលសមត្ថភាពរបស់សង្គមសាមញ្ញ ជាឧទាហរណ៍ការជឿដែលអ្នកបុរាណវត្ថុវិទូភាគច្រើនធ្លាប់បានធ្វើថា ប្រព័ន្ធរៀបចំសង្គមតាមការដឹកនាំជាច្បាប់សង្គមដំបូងៗ ដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ថានីយបន្ទាយគូនៅអាស៊ីអាគ្នេយ៍ដំបូង ការរៀបចំទីក្រុងនិងប្រព័ន្ធប្រឡាយទឹកនៃនគរភ្នំ ការរៀបចំកំពែងក្រុងសម្ភុរៈ ក្រុងឥសានបុរៈនៃនគរចេនឡា ពិសេសនៅកម្ពុជា ការរៀបចំវិមានដ៏ល្បីល្បាញនៃ Stonehenge

នៅភាគខាងត្បូងប្រទេសអង់គ្លេស អាចត្រូវបានសាងសង់ដោយ អ្នកមានបទពិសោធពី អរិយធម៌នៃ Mycenae នៅក្នុងប្រទេសក្រិក។ ឧទាហរណ៍ទាំងនេះ បង្ហាញពីក្រមច្បាប់ ដឹកនាំ និងរៀបចំសង្គមរបស់មនុស្ស នៅសម័យបុរេប្រវត្តិសាស្ត្រ។

ដូច្នេះយើងចាប់ផ្តើមនៅក្នុងប្រធានបទ ច្បាប់ទំនៀមក្នុងសង្គមកម្ពុជានា សម័យបុរេប្រវត្តិ ហ្វូណន និងចេនឡានេះ ជាមួយនឹងសំណួរ "តើសង្គមកម្ពុជាត្រូវ បានរៀបចំយ៉ាងដូចម្តេច?" ហើយបន្តនៅក្នុងវគ្គជាបន្តបន្ទាប់ ដើម្បីពិចារណាអំពីប រិស្ថាន និងរបបអាហារ មុនពេលងាកទៅរកឧបករណ៍ បច្ចេកវិទ្យា ទំនាក់ទំនង ការ ផ្លាស់ប្តូរសង្គម របៀបដែលមនុស្សគិត និង វិធីដែលមនុស្សរីវត្តនិងធ្វើអាណានិគមលើ ពិភពលោក ដែលហៅថានរវិទ្យាជីវសាស្ត្រ និងចំនួនប្រជាជន។ នៅក្នុងវគ្គបន្តបន្ទាប់ យើងសួរថា "ហេតុអ្វីបានជាអ្វីៗមានរូបសណ្ឋានសង្គមដូច្នេះ?" និង "ហេតុអ្វីបានជាសង្គម ពួកគេផ្លាស់ប្តូរ?" តាមរបៀបខ្លះ ទាំងអស់នេះគឺជាសំណួរ ដែលគួរឱ្យចាប់អារម្មណ៍បំផុត ក្នុងការសិក្សាប្រព័ន្ធសង្គមច្បាប់ ដោយសម័យបុរេប្រវត្តិ មិនទាន់មានភស្តុតាងអក្សរនៅ ឡើយ អ្វីៗត្រូវអាស្រ័យលើមុខវិទ្យា បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា និងនរវិទ្យា។ នៅក្នុង ប្រវត្តិសាស្ត្ររបស់បុរាណវត្ថុវិទ្យាអាមេរិក លោកGordon Willey និងលោក Jeremy Sabloff បានប្រកែកថា នៅក្នុងទសវត្សរ៍ឆ្នាំ ១៩៦០ បុរាណវត្ថុវិទ្យាបានផ្លាស់ប្តូរពី សម័យកាល ដែលខ្វល់ខ្វាយជាមួយនឹងការចាត់ថ្នាក់ ការពិពណ៌នា និងមុខងារនៃវត្ថុ ហើយបានចូលដល់សម័យពន្យល់ពីសង្គម និងច្បាប់មនុស្សជាតិ។ ការពន្យល់ពិត ប្រាកដ ត្រូវបានមើលឃើញដោយមនុស្សជាច្រើនថា ជាគោលដៅកណ្តាលនៃការ ស្រាវជ្រាវបុរាណវិទ្យាសង្គម។

សម័យបុរេប្រវត្តិ ជាសម័យស្ថាប័ននយោបាយ និងច្បាប់ ស្ថិតនៅក្នុងយុគ សម័យងងឹត មានលក្ខណៈដើមដំបូងខ្លាំងណាស់។ សហគមន៍មនុស្សភូមិតូចៗ នីមួយៗ ឯករាជ្យពីការគ្រប់គ្រងខាងក្រៅ ប៉ុន្តែសិទ្ធិអំណាចនយោបាយមានភាពតឹងរ៉ឹង ដូច្នេះវានឹងមិនច្រើនពេកទេ ក្នុងការនិយាយថា រដ្ឋស្ទើរតែមិនមានទាល់តែសោះ។ Basileus ឬអ្នកគ្រប់គ្រង គឺមិនមានច្រើនជាងមេដឹកនាំកុលសម្ព័ន្ធទេ។ គាត់មិនអាច បង្កើត ឬអនុវត្តច្បាប់ ឬគ្រប់គ្រងយុត្តិធម៌បានទេ។ គាត់មិនបានទទួលប្រាក់កម្រៃអ្វីទេ ហើយត្រូវធ្វើស្រែចម្ការចិញ្ចឹមជីវិត ដូចពលរដ្ឋដទៃទៀត។ ជាក់ស្តែងមុខងារតែមួយគត់ របស់គាត់ គឺយោធា និងបព្វជិត។ ទ្រង់បញ្ជាទ័ពក្នុងសម័យសង្គ្រាម ហើយថ្វាយយញ្ញ បូជា ដើម្បីរក្សាព្រះនៅក្នុងសហគមន៍។ ទោះបីជាសហគមន៍តូចៗនីមួយៗ មានក្រុម

ប្រឹក្សាអភិជន និងក្រុមអ្នកចម្បាំងក៏ដោយ ស្ថាប័នទាំងពីរនេះ មិនមានសមាជិកភាពច្បាស់លាស់ ឬហាន:ជាសរីរាង្គនៃរដ្ឋាភិបាលនោះទេ។ ការកិច្ចរបស់អ្នកដឹកនាំពីអតីតកាល គឺផ្តល់ដំបូន្មាន និងជួយអ្នកគ្រប់គ្រង និងរារាំងពីការដណ្តើមអំណាចផ្តាច់ការ។ មុខងារចុងក្រោយគឺផ្តល់សច្ចាប័ន លើសេចក្តីប្រកាសសង្គ្រាម និងយល់ព្រមដល់ការបង្កើតសន្តិភាព។ ស្ទើរតែគ្មានករណីលើកលែង ទំនៀមទម្លាប់បានជំនួសច្បាប់ ហើយការគ្រប់គ្រងយុត្តិធម៌ មានលក្ខណ:ឯកជន។ សូម្បីតែអំពើឃាតកម្មដោយចេតនា ក៏ត្រូវទទួលទោស តែពីក្រុមគ្រួសារជនរងគ្រោះតែប៉ុណ្ណោះ។ ខណ:ពេលដែលវាជាការពិតដែលពេលខ្លះវិវាទ ត្រូវបានបញ្ជូនទៅអ្នកគ្រប់គ្រងដើម្បីដោះស្រាយ ប៉ុន្តែគាត់បានធ្វើសកម្មភាព នៅក្នុងករណីបែបនេះ គ្រាន់តែជាអាជ្ញាកណ្តាល មិនមែនជាចៅក្រមទេ។ តាមពិតទៅ មនសិការនយោបាយរបស់មនុស្សសម័យបុរេប្រវត្តិសាស្ត្រ មានការវិវត្តតិចតួចណាស់ ដែលពួកគេមិនមានគំនិតបែបជារដ្ឋាភិបាល ឬជាភ្នាក់ងារ ដែលមិនអាចខ្វះបាន សម្រាប់ការថែរក្សាសណ្តាប់ធ្នាប់សង្គមនោះទេ។ ជាឧទាហរណ៍នៅក្នុងសង្គមក្រិចអ្នកស្រាវជ្រាវបង្ហាញថា៖ នៅពេលដែល Odysseus ដែលជាអ្នកគ្រប់គ្រងនៅ Ithaca បានអវត្តមានអស់រយ:ពេលម្តែឆ្នាំ ហើយគ្មានអ្នកស្នងរាជ្យទេ ត្រូវបានតែងតាំងជំនួសហើយមិនមានសម័យប្រជុំរបស់ក្រុមប្រឹក្សា ឬសភា ត្រូវបានធ្វើឡើងទេ។ គ្មាននរណាម្នាក់គិតថា ការព្យួរដោយគ្មានអ្នកដឹកនាំសង្គម(រដ្ឋាភិបាល)ទាំងស្រុង សូម្បីតែមួយរយ:ពេល ជាយូរមកហើយនោះ គឺជាបញ្ហាសំខាន់ណាស់របស់សង្គមនោះទេ។

នៅចុងសម័យបុរេប្រវត្តិសាស្ត្រកម្ពុជា សញ្ញាណនៃរដ្ឋបានកកើតរួចហើយ (មានទឹកដីច្បាស់លាស់ មានប្រជាជនរស់នៅជាអចិន្ត្រៃយ៍ និងមានអង្គការចាត់តាំងនយោបាយសម្រាប់ការពារ គ្រប់គ្រង និងដឹកនាំប្រជាជននិងទឹកដីរបស់ខ្លួន)។ វិស័យកសិកម្មមានការរីកលូតលាស់ដោយមានការគិតគូរអំពីនយោបាយទឹក(ស្នាមព្រែកជីកបរមបុរាណនិងគូទឹកនៃបន្ទាយគូឬភូមិមូល)។ វិស័យសិប្បកម្មក៏មានការរីចម្រើនដែរ តាមរយៈការធ្វើទូកស្លាលោហធាតុ ធ្វើឧបករណ៍សម្រាប់ប្រើប្រាស់ និងធ្លាក់គ្រឿងអលង្ការជាបន្តោង កងដៃ ការ ទំហូ ក្រវិល អង្កាំ ត្បាញសំពត់សម្រាប់ស្លៀក។ នាសម័យនោះ ខ្មែរយើងមានជំនឿមានទំនៀមទម្លាប់ មានសីលធម៌ផ្ទាល់ខ្លួន និងបានទទួលឥទ្ធិពលវប្បធម៌ពីឥណ្ឌា។ ទោះបីជាពុំមានភស្តុតាងបញ្ជាក់ថា ច្បាប់ទំនៀមរបស់សង្គមកម្ពុជានាពេលនោះមានច្បាប់ទំនៀមអ្វីខ្លះក្តី ក៏យើងអាចសន្និដ្ឋានបានថា ដោយសារការវិវត្តពីការរស់នៅបែបកុលសម្ព័ន្ធទៅជាការគ្រប់គ្រងបែបរដ្ឋ មានសន្តិសុខ មានការរីកចម្រើនដោយមាន

នយោបាយទឹក កសិកម្មរីកលូតលាស់ សិប្បកម្មចម្រុះ ជាច់ខាតត្រូវមានច្បាប់ទំនៀមសម្រាប់គ្រប់គ្រងទើបអាចរក្សាស្ថិរភាពសង្គមរហូតមកដល់សម័យហ្វូណន។

សម័យហ្វូណន របបនយោយបាយនៅកម្ពុជាគឺរាជាធិបតេយ្យ ដែលអនុវត្តនយោបាយដឹកនាំតាមបែបឥណ្ឌា។ អធិរាជអាណាចក្រហ្វូណន(អាណាចក្រភ្នំ) និយមធ្វើនយោបាយពង្រីកទឹកដី ដោយព្រះរាជាលើកទ័ពវាយយកបានរដ្ឋជាច្រើនដាក់ជារដ្ឋចំណុះឬសាមន្តរដ្ឋ។ នាសម័យនោះមានទំនាក់ទំនងការទូតជាមួយប្រទេសចិន។ មានប្រព័ន្ធបង់ពន្ធជារជូនរាជការជាមាស ប្រាក់ ត្បូង គជ់ ឬគ្រឿងក្រអូបផ្សេងៗ។ វិស័យពាណិជ្ជកម្ម កម្ពុជាបានធ្វើទំនាក់ទំនងផ្នែកពាណិជ្ជកម្មជាមួយចិន ឥណ្ឌា រ៉ូម៉ាំង និងពែរ្ស។ វិស័យកសិកម្ម ដោយសារការអនុវត្តនយោបាយទឹកទទួលបានជោគជ័យ ធ្វើឱ្យវិស័យកសិកម្មមានការរីកលូតលាស់ខ្លាំងណាស់។ អ្នកស្រុកចេះជីកព្រែកខ្នាត់ខ្នែងដែលបន្សល់ទុកដល់សព្វថ្ងៃត្រង់កម្ពុជាក្រោមភាគខាងលិច។ ព្រែកជីកនេះ ក្រៅពីបំពេញនាទីជាប្រព័ន្ធស្រោចស្រព បានដើរតួនាទីសម្រាប់បង្ហូរទឹកជំនន់ទន្លេមេគង្គ សម្រាប់លាងបន្សាបជាតិអំបិល សម្រាប់នាំយកដីល្បាប់មានជីជាតិ និងជាផ្លូវគមនាគមន៍ផងដែរ។ គេធ្វើស្រូវមួយឆ្នាំបានបីដង។ ក្រៅពីធ្វើស្រែ មានការដាំក្រូច ទទឹម អំពៅ ស្លា។ល។ វិស័យរ៉ែ គេឃើញមានរ៉ែមាស ប្រាក់ ទង់ដែង សំណបាហាំង និងពេជ្រ។ ម៉្យាងទៀតអ្នកស្រុកបុិនប្រសប់ណាស់ក្នុងរបរធ្វើជាងមាសឬប្រាក់ សូនរូប ត្បាញសូត្រចរបាប់ ស្លកែវ ។ល។ ចំពោះប្រព័ន្ធសង្គមកិច្ច មានការរៀបចំកសាងបូជនីយដ្ឋានសាសនានានា សាងសង់ផ្លូវ ជីកស្រះទឹករួម និងជីកប្រឡាយជាដើម សម្រាប់ប្រើប្រាស់ជាផលប្រយោជន៍រួម។ សម័យនោះនៅនិយមស្រីជាធំ(មេនិយម) គឺគេទុកស្រីជាធំក្នុងគ្រួសារផងនិងក្នុងសង្គមផង ស្រីត្រូវទៅចូលស្តីដណ្តឹងប្រុស។ នៅពេលមនុស្សស្លាប់ គេលែងយកសពដាក់ក្នុងក្រឡយកទៅកប់ទៀតហើយ ដោយអនុវត្តតាមវិធីបួនយ៉ាងគឺយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី យកសពទៅចោលក្នុងទឹកទន្លេ យកសពទៅកប់ និងយកសពទៅបូជាប្រមូលធាតុដាក់ក្នុងកោដ្ឋ១បិទជិត ហើយយកទៅបោះចោលក្នុងទឹកទន្លេ។ គេកាន់ទុក្ខដោយកោរសក់និងពុកមាត់។ ប្រជាជននៅប្រតិបត្តិពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង ហើយទោះបីព្រះមហាក្សត្របានប្រតិបត្តិព្រហ្មញ្ញសាសនាក្តី ក៏ព្រះអង្គបានបើកសិទ្ធិសេរីភាពពេញលេញដល់ប្រជាជនក្នុងការជ្រើសរើសជំនឿសាសនាដែរ។ ខ្មែរយើងបុិនប្រសប់ក្នុងការបន្សុីគ្នារវាងអរិយធម៌បរទេសជាមួយជំនឿ ទំនៀមទម្លាប់ប្រពៃណីក្នុងស្រុក ដើម្បីរក្សានូវអត្តសញ្ញាណខ្មែរនិងមានលក្ខណៈរួមមួយ ដែលសង្គមទាំងមូលទទួលយកបាន។ យើងអាចមានទំនៀមសម្រាប់រៀបចំរដ្ឋនិងគ្រប់គ្រងជារាជ

ធានី ជាសាមន្តរដ្ឋចំណុះ ច្បាប់ទំនៀមសម្រាប់ប្រមូលនិងបែងចែកពន្ធដារ និងច្បាប់ទំនៀមសម្រាប់រក្សាសណ្តាប់ធ្នាប់សាធារណៈ និងសន្តិសុខសង្គម។ ច្បាប់ទំនៀមទាំងនោះអាចមានប្រភពពីជំនឿ ទំនៀមទម្លាប់ សីលធម៌ សាសនា ជាពិសេសព្រះរាជអាជ្ញា (ព្រះរាជបញ្ញា) របស់ព្រះមហាក្សត្រ។ ការដោះស្រាយវិវាទ អ្នកស្រុកហ្វូណនចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរកសេចក្តីពិត។ កាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេព្តា រួចគេអង្វរសូមឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះទៅចែកឱ្យពួកខ្ញុំបម្រើនៅក្នុងផ្ទះឱ្យបរិភោគ ក្នុងមាត់ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែង ហើយវាមិនអាចទំពារបាយផង ឯមាត់របស់ជនទៀងត្រង់បាយនោះរអិលទៅក្នុងមាត់យ៉ាងស្រួល។ ម៉្យាងទៀតបើកាលណាមានជនជាប់ចោទ គេឱ្យជននោះអត់បាយ ៣ថ្ងៃ រួចគេតម្រូវឱ្យលូកយកវត្ថុផ្សេងៗ ចេញពីទឹកកំពុងពុះ ឬកាន់ពូថៅឬច្រវាក់ដុតក្រហមដើរ៧ជំហាន បើមានកំហុសមែនដៃរបស់ជននោះត្រូវរលាករលួយ ផ្ទុយទៅវិញបើគ្មានកំហុសគ្មានអ្វីទាំងអស់។ នេះជាការដោះស្រាយវិវាទពឹងពាក់លើអំណាចធម្មជាតិ។ ពេលនោះមិនទាន់មានគុកដាក់មនុស្សទេ។ ជនឧក្រិដ្ឋត្រូវបោះឱ្យក្រពើដែលគេចិញ្ចឹមនៅក្នុងប្រឡាយជុំវិញទីក្រុង ឬសត្វសាហាវដែលគេចិញ្ចឹមដាក់ក្នុងទ្រង់ពិសេស។ បើរយៈពេល៣ថ្ងៃសត្វសាហាវទាំងនោះមិនស៊ី គេឱ្យរួចខ្លួន។ យើងអាចសន្និដ្ឋានបានថា នាសម័យនោះមានច្បាប់ទំនៀមកំណត់អំពីទោសធ្ងន់ ទោសស្រាល (បទឧក្រិដ្ឋឬមជ្ឈិម) មានបុគ្គលដែលមានសមត្ថកិច្ចសម្រេចដាក់ទោសឧក្រិដ្ឋជន។

សម័យចេនឡា របបនយោបាយមិនខុសគ្នាជាមួយសម័យហ្វូណនទេ គឺជារបបរាជាធិបតេយ្យ ដែលអនុវត្តនយោបាយតាមបែបឥណ្ឌាដែរ។ ចាប់តាំងពីរជ្ជកាលព្រះបាទឦសានវរ្ម័នទៅ រាជធានីតាំងនៅឦសានបុរ ហើយមានប្រជាជនរស់នៅចំនួន ២០ ០០០គ្រួសារ។ នៅកណ្តាលក្រុងមានសាលប្រជុំធំមួយជាទីដែលព្រះមហាក្សត្រទ្រង់ព្រះប្រទានសវនាការ និងប្រជុំមន្ត្រី សេនាបតី។ ក្រៅពីរាជធានី នៅមានក្រុងចំនួន ៣០ទៀត។ ក្រុងនីមួយៗមានច្រើនគ្រួសារ ហើយត្រួតត្រាដោយអភិបាលម្នាក់។ ក្នុង៣ថ្ងៃម្តង ព្រះរាជាតែងយាងទៅកាន់សាលប្រជុំ។ មន្ត្រីជាន់ខ្ពស់មាន៥នាក់ និងមានមន្ត្រីតូចតាចច្រើនណាស់។ ទី១មានងាររហៅតាមចិនថា Kou-ling ទី២ Sing-kao-ping ទី៣ Po-hoto-ling ទី៤ Cho-mo-ling ទី៥ Jan-lo-leou។ រហូតមកដល់ពេលនេះ គេមិនទាន់រកឃើញថា គោរមងារដែលហៅតាមចិននេះ ត្រូវនឹងពាក្យខ្មែរដំនាន់នោះថាយ៉ាងម៉េចនៅឡើយទេ។ ឯពួកមន្ត្រីតូចតាចវិញ មានចំនួនច្រើនណាស់។ ក្នុងចំណោមមន្ត្រីជាន់ខ្ពស់ទាំង៥នាក់ មានម្នាក់ជាមន្ត្រីទទួលបន្ទុកពន្ធអាករ និងម្នាក់ទៀតទទួលបន្ទុកជាមន្ត្រី

យមរាជ(ខាងយុត្តិធម៌)។ ចំពោះនយោបាយក្រៅប្រទេស ចេនឡានៅរក្សាទំនាក់ទំនងផ្នែកការទូតជាមួយប្រទេសចិន និងរក្សានយោបាយក្រៅប្រទេសក្នុងវិស័យពាណិជកម្មដូចអាណាចក្រហ្វូណនដែរ។ ប្រព័ន្ធពន្ធដារជូនរាជការត្រូវយកជាមាស ប្រាក់ ត្បូង គជ់ គ្រឿងក្រអូបផ្សេងៗ ឬបង់ពន្ធដារជាកសិផល។ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរឹងរឹតតែប្រសើរឡើងថែមទៀត ជាហេតុញុំាងឱ្យមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងញុំាងឱ្យកសិកម្មមានការចម្រើនលូតលាស់ជាលំដាប់។ ប្រព័ន្ធសង្គមកិច្ចកាន់តែរីកចម្រើន។ បន្ថែមលើការលើកលែងពន្ធដារចំពោះបូជនីយ៍ដ្ឋានសាសនាដើម្បីបន្ថយបន្ទុកចំណាយ មានការរៀបចំគោលនយោបាយបែងចែកដីឱ្យប្រជាជន ការទទួលស្គាល់កម្មសិទ្ធិដីធ្លីរបស់ប្រជាជន និងជាពិសេសការដាក់ទានដីដល់ជនក្រីក្រ។ ទំនៀមទម្លាប់មានការផ្លាស់ប្តូរពីសម័យហ្វូណនខ្លះៗ។ គេនិយមរាប់ញាតិដោយយកខ្សែតាមម្តាយ។ ពួកប្រុសៗទៅដណ្តឹងស្រី។ នៅពេលរៀបការរួច កូនប្រុសបានទទួលមត៌កពីឪពុកម្តាយបង្កើតរបស់ខ្លួន ហើយបែកផ្ទះទៅនៅដោយឡែក។ ដល់ពេលឪពុកម្តាយស្លាប់ ពួកកូនដែលនៅលីវ អាចទទួលយកមត៌កដែលនៅសេសសល់ទាំងអស់។ ប៉ុន្តែប្រសិនបើកូនទាំងនោះមានប្តីប្រពន្ធហើយបានទទួលមត៌ករួចហើយ នោះទ្រព្យសម្បត្តិដែលនៅសេសសល់ត្រូវបញ្ចូលក្នុងឃ្លាំងជាតិ។ ក្នុងពិធីបុណ្យសព កូនទាំងឡាយរបស់សពអត់បាយ៧ថ្ងៃ ត្រូវកោរសក់ ហើយត្រូវយំស្រែកយ៉ាងខ្លាំង។ ក្រុមគ្រួសារនៃសព ដោយរួមនិងព្រះភិក្ខុ និងភិក្ខុនីបានធ្វើក្បួនដង្ហែរ ដោយមានច្រៀង(ប្រហែលសូត្រធម៌) និងលេងភ្លេងផង។ សពគេបូជាក្នុងប៉ាឆា សង់ដោយឈើក្រអូបរួចគេរើសធាតុដាក់ក្នុងកោដ្ឋមាស ឬប្រាក់យកទៅទម្លាក់ចោលក្នុងទឹក។ ប្រជាជននៅបន្តគោរពប្រតិបត្តិពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនា។ ឯច្បាប់ទំនៀមក៏មានការរីកចម្រើនដែរ។ យើងអាចសន្និដ្ឋានបានថា មកដល់សម័យចេនឡានេះ សង្គមកម្ពុជាមានច្បាប់ទំនៀមជាច្រើនវិស័យ (រដ្ឋបាល មុខងារសាធារណៈ ពន្ធដារ ម៉ែតក ព្រហ្មទណ្ឌ)។ រីឯការដោះស្រាយវិវាទមិនសូវខុសពីសម័យហ្វូណនទេ តែក្នុងចំណោមមន្ត្រីជាន់ខ្ពស់នៅអមព្រះមហាក្សត្រទាំង៥នាក់ មានមន្ត្រីជាន់ខ្ពស់ម្នាក់ជាមន្ត្រីយមរាជ(យុត្តិធម៌)ដែលបញ្ជាក់បានថា មានការរៀបចំរចនាសម្ព័ន្ធសម្រាប់ស្វែងរកយុត្តិធម៌ជូនប្រជាជនដែរ។ ព្រះមហាក្សត្រជើរតួនាទីជាអ្នកកាត់ក្តីចុងក្រោយ។

ជំពូកទី១.
សេចក្តីផ្តើម

សង្គមគឺជាការប្រមូលផ្តុំមនុស្សដែលរស់នៅរួមគ្នា ដោយមានការប្រាស្រ័យទាក់ទងគ្នា និងការចែករំលែកធនធាន ចំណេះដឹង បទពិសោធជាមួយគ្នាទៅវិញទៅមក។ ដើម្បីធានាឱ្យសង្គមមានសន្តិសុខ រីកចម្រើន និងនិរន្តរភាព ចាំបាច់ត្រូវមានវិធានរួមសម្រាប់គ្រប់គ្រងសង្គមនោះ។ វិធានទាំងនេះអាចជាច្បាប់ទំនៀម វិន័យ គោលនយោបាយ ឬសីលធម៌ដែលមានតួនាទីរារាំង និងដោះស្រាយបញ្ហាដែលកើតមានក្នុងសង្គម។

នៅក្នុងប្រវត្តិសាស្ត្រពិភពលោក សង្គមតែងតែមានការប្រែប្រួលទៅតាមសម័យកាលនីមួយៗ។ សង្គមខ្លះមានវឌ្ឍនភាព លូតលាស់ ធំធាត់រហូតកកើតបានជារដ្ឋ ជាចក្រភព។ តែក៏មានសង្គមខ្លះមានការវិវត្តទៅរកការរលំរលាយ បាត់បង់ទាំងស្រុង។ ការរីកចម្រើន ឬការបាត់បង់ អាស្រ័យទៅលើកត្តាជាច្រើន ក្នុងនោះប្រសិទ្ធភាពនៃវិធានសម្រាប់គ្រប់គ្រងសង្គមជាកត្តាដ៏សំខាន់មួយដែរសម្រាប់កំណត់ជោគវាសនារបស់សង្គម។

ដោយឡែកសង្គមកម្ពុជា ដែលជាប្រទេសដ៏ចំណាស់មួយនៅអាស៊ីអាគ្នេយ៍ ធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសស្តុកស្តម្ភ ប្តុំប្តើង រុងរឿង ធំទូលាយរហូតក្លាយជាអាណាចក្រមួយ ដែលមានសមន្តរដ្ឋចំណុះជាច្រើន ហើយពេលខ្លះចុះដុនដាប បែកបាក់រហូតសឹងតែបាត់ឈ្មោះពីផែនទីពិភពលោក។ ដូច្នេះការសិក្សាស្រាវជ្រាវអំពីសង្គមកម្ពុជាដើម្បីស្វែងរកគុណសម្បត្តិ និងគុណវិបត្តិនៃការគ្រប់គ្រង ពិតជាមានសារៈសំខាន់ណាស់ ជាពិសេសក្នុងបរិបទសង្គមសម័យថ្មី ដែលពេបប្រទះនឹងកត្តាប្រឈមជាច្រើនដូចជា ការកើនឡើងនៃប្រជាជន ការហូរចូលនូវវប្បធម៌បរទេស ការធ្វើសកលភាវូបនីយកម្មផ្នែកពាណិជ្ជកម្ម និងការផ្លាស់ប្តូរនៃបច្ចេកវិទ្យា បានធ្វើឱ្យប្រព័ន្ធគ្រប់គ្រងសង្គមកាន់តែមានភាពស្មុគស្មាញ។

នៅក្នុងរបាយការណ៍ស្រាវជ្រាវនេះ យើងខ្ញុំផ្តោតលើច្បាប់ទំនៀមក្នុងសង្គមកម្ពុជានាសម័យបុរេប្រវត្តិ សម័យហ្វូណន និងសម័យចេនឡា។ ការសិក្សាអំពីច្បាប់ទំនៀមក្នុងសម័យទាំងបីនេះ ពិតជាជួបការលំបាកយ៉ាងខ្លាំង ពីព្រោះកង្វះខាតឯកសារសម្រាប់សិក្សា។ ការសិក្សាប្រវត្តិសាស្ត្រក្នុងសម័យទាំងបីនេះភាគច្រើនពឹងផ្អែកលើឯកសាររបស់ចិន ទីតាំងបុរេប្រវត្តិសាស្ត្រ វត្ថុបានពីការធ្វើកំនាយ និងសិលាចារឹក ដែលមានតិចតួចប៉ុណ្ណោះ។

ការសិក្សាអំពីច្បាប់ទំនៀមក្នុងសង្គមកម្ពុជា គឺសិក្សាអំពីវិធានសម្រាប់គ្រប់គ្រង និងដឹកនាំ រួមមានរចនាសម្ព័ន្ធរបស់សង្គម (រដ្ឋបាល សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌) និងច្បាប់ទំនៀម(ច្បាប់និងយន្តការដោះស្រាយវិវាទក្នុងសង្គម) នាសម័យកាលទាំងបីខាងលើ។

តាមនិយមន័យអក្សរសាស្ត្រ ពាក្យថា "ទំនៀម" ជាបវេណី សណ្តាប់ធ្នាប់ ទម្លាប់ ឬបែបបទ។ ច្បាប់ទំនៀមជាច្បាប់ ឬវិធានទាំងឡាយ ដែលបានកើតចេញពីទម្លាប់ជាប់ជាទំនៀម ជាប្រពៃណីរបស់អ្នកស្រុក ដ៏យូរលង់ណាស់មកហើយ។[៨៧]

គ្រួសារជាស្ថាប័នគ្រប់គ្រងសង្គមជាមូលដ្ឋាន ដំបូងរបស់មនុស្សជាតិ ។ គ្រួសារមានភាពតឹងតែង ជាអង្គភាពដែលបានរៀបចំច្បាប់គ្រប់គ្រង ទំនោរទៅលើការរក្សាសុខុមាលភាពរបស់សមាជិករបស់ខ្លួន ប្រឆាំងនឹងភ្នាក់ងារខាងក្រៅណាមួយ ជាផ្លូវការ ឬមិនផ្លូវការ ហើយប្រហែលជាការការពារតែមួយគត់ នៃផលវិបាកប្រឆាំងនឹងការកេងប្រវ័ញ្ចគ្មានដែនកំណត់នៃវណ្ណៈ។

ដើម្បីឱ្យមានគំនិតខ្លះៗ អំពីការរៀបចំសង្គម និងច្បាប់នៃសង្គម ដែលកំពុងសិក្សា គេអាចបន្តសួរសំណួរត្រឹមត្រូវអំពីទិដ្ឋភាពផ្សេងទៀតនៃសង្គមនោះ។ ឧទាហរណ៍ ក្រុមដែលបានរៀបចំជាអ្វីដែលហៅថា **ក្រុមសង្គម** ចេញពីសង្គមអ្នកចិញ្ចឹមជីវិតដោយការបរបាញ់ និងការប្រមូលអាហារ(ឬរកអាហារ) និងបន្តដំណើរទៅមុខជានិច្ច មិនដែលនៅកន្លែងមួយយូរល្មមនឹងសង់ទីប្រជុំជន ឬទីក្រុងនោះទេ ទាំងចំនួនប្រជាជនរបស់ពួកគេមិនគ្រប់គ្រាន់ ឬអង្គការសង្គម និងសេដ្ឋកិច្ចរបស់ពួកគេមានភាពស្មុគស្មាញ។ ដូច្នេះ វាគ្មានន័យទេក្នុងការរំពឹងថា នឹងស្វែងរកទីក្រុង ឬទីប្រជុំជនក្នុងចំណោមសង្គមបែបនេះ។ ប៉ុន្តែដូចគ្នានេះដែរ គេត្រូវសិក្សាពីអ្វីដែលក្រុមសង្គមបង្កើតឡើង តាមរបៀបនៃរចនាសម្ព័ន្ធ ហើយស្វែងយល់ថា តើជានទាំងនេះអាចបន្សល់ទុកអ្វីខ្លះ នៅក្នុងកំណត់ត្រាបុរាណវិទ្យាសង្គម។ អ្នកសង្កេតការណ៍សម័យថ្មី ជាទូទៅមើលស្រាលសមត្ថភាពរបស់សង្គមសាមញ្ញ ជាឧទាហរណ៍ ការជឿ ដែលអ្នកបុរាណវត្ថុវិទូភាគច្រើនធ្លាប់បានធ្វើ ថាប្រព័ន្ធរៀបចំសង្គមតាមការដឹកនាំជាច្បាប់សង្គមដំបូងៗ ពិសេសនៅកម្ពុជា មានការកសាងហេដ្ឋារចនាសម្ព័ន្ធ ស្ថានីយបន្ទាយគូនៅអាស៊ីអាគ្នេយ៍ដំបូង ការរៀបចំទីក្រុង និងប្រព័ន្ធប្រឡាយទឹកនៃនគរភ្នំ ការរៀបចំកំពែងក្រុងសម្ភបុរៈ ក្រុងឥសានបុរៈនៃនគរចេ

[៨៧] ទស្សនវិជ្ជាច្បាប់ខ្មែរបែបទំនៀម ទំព័រទី១៧ (ឯកឧត្តម ស៊ាង ផល្លា "អត្តសញ្ញាណនៃវប្បធម៌ច្បាប់និងយុត្តិធម៌ខ្មែរ")។

នឡា ការរៀបចំវិមានដ៏ល្បីល្បាញនៃ Stonehenge នៅភាគខាងត្បូងប្រទេសអង់គ្លេស អាចត្រូវបានសាងសង់ដោយអ្នកមានបទពិសោធពីអរិយធម៌នៃ Mycenae នៅក្នុងប្រទេសក្រិក។ ឧទាហរណ៍ទាំងនេះ បង្ហាញពីក្រមច្បាប់ដឹកនាំ និងរៀបចំសង្គមរបស់មនុស្ស នៅសម័យបុរេប្រវត្តិសាស្ត្រ។

ដូច្នេះយើងចាប់ផ្តើមនៅក្នុងប្រធានបទ ច្បាប់ទំនៀមកម្ពុជា សម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា នេះ ជាមួយនឹងសំណួរ "តើសង្គមកម្ពុជាត្រូវបានរៀបចំយ៉ាងដូចម្តេច?" ហើយបន្តនៅក្នុងវគ្គជាបន្តបន្ទាប់ ដើម្បីពិចារណាអំពីបរិស្ថាន និងរបបអាហារមុនពេលងាកទៅរកឧបករណ៍ និងបច្ចេកវិទ្យា ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គម របៀបដែលមនុស្សគិត វិធីដែលមនុស្សវិវត្តនិងធ្វើអាណានិគមលើពិភពលោក ដែលហៅថានរវិទ្យាជីវសាស្ត្រ និងចំនួនប្រជាជន។ នៅក្នុងវគ្គបន្តបន្ទាប់ យើងសួរថា "ហេតុអ្វីបានជាអ្វីៗមានរូបសណ្ឋានសង្គមដូច្នេះ?" និង "ហេតុអ្វីបានជាសង្គមពួកគេផ្លាស់ប្តូរ?" តាមរបៀបណាខ្លះ ទាំងអស់នេះគឺជាសំណួរ ដែលគួរឱ្យចាប់អារម្មណ៍បំផុត ក្នុងការសិក្សាប្រព័ន្ធសង្គមនិងច្បាប់ ដោយសម័យបុរេប្រវត្តិ មិនទាន់មានកស្តូតាងអក្សរនៅឡើយ អ្វីៗត្រូវអាស្រ័យលើមុខវិទ្យា បុរាណវត្ថុវិទ្យា ជាតិពន្ធុវិទ្យា និងនរវិទ្យា។ នៅក្នុងប្រវត្តិសាស្ត្ររបស់បុរាណវត្ថុវិទ្យាអាមេរិក លោក Gordon Willey និងលោក Jeremy Sabloff បានប្រកែកថា នៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០ បុរាណវត្ថុវិទ្យាបានផ្លាស់ប្តូរពីសម័យកាល ដែលខ្វល់ខ្វាយជាមួយនឹងការចាត់ថ្នាក់ ការពិពណ៌នា និងមុខងារនៃវត្ថុ ហើយបានចូលដល់សម័យពន្យល់ពីសង្គម និងច្បាប់មនុស្សជាតិ។ ការពន្យល់ពិតប្រាកដ ត្រូវបានមើលឃើញដោយមនុស្សជាច្រើនថា ជាគោលដៅកណ្តាលនៃការស្រាវជ្រាវបុរាណវិទ្យាសង្គម។

សម័យបុរេប្រវត្តិ ជាសម័យស្ថាប័ននយោបាយ និងច្បាប់ ស្ថិតនៅក្នុងយុគសម័យងងឹត មានលក្ខណៈដើមដំបូងខ្លាំងណាស់។ សហគមន៍មនុស្ស ភូមិតូចៗនីមួយៗ ឯករាជ្យពីការគ្រប់គ្រងខាងក្រៅ ប៉ុន្តែសិទ្ធិអំណាចនយោបាយមានភាពតឹងរឹង ដូច្នេះវាមិនខុសទេ ក្នុងការនិយាយថា រដ្ឋស្ទើរតែមិនមានទាល់តែសោះ។ អ្នកគ្រប់គ្រងគឺមិនមានតែមេដឹកនាំកុលសម្ព័ន្ធទេ។ គាត់មិនអាចបង្កើត ឬអនុវត្តច្បាប់ ឬគ្រប់គ្រងយុត្តិធម៌បានទេ។ គាត់មិនបានទទួលប្រាក់កម្រៃអ្វីទេ ហើយត្រូវធ្វើស្រែចម្ការចិញ្ចឹមជីវិតដូចពលរដ្ឋដទៃទៀត។ ជាក់ស្តែងមុខងារតែមួយគត់របស់គាត់ គឺអ្នកប្រើកម្លាំងការពារ និងបព្វជិត។ មេកុលសម្ព័ន្ធ ជាអ្នកបញ្ជាទ័ពក្នុងពេលមានសង្គ្រាម ហើយថ្វាយយញ្ញបូជា ដើម្បីរក្សាព្រះនៅក្នុងសហគមន៍។ ទោះបីជាសហគមន៍តូចៗនីមួយៗ មានក្រុម

ប្រឹក្សាអភិជន និងក្រុមអ្នកចម្បាំងក៏ដោយ ស្ថាប័នទាំងពីរនេះ មិនមានសមាជិកភាពច្បាស់លាស់ ឬហាន:ជាសរីរាង្គនៃរដ្ឋាភិបាលនោះទេ។ ការកិច្ចរបស់អ្នកដឹកនាំពីអតីតកាល គឺផ្តល់ដំបូន្មាន និងជួយអ្នកគ្រប់គ្រង និងរារាំងពីការដណ្តើមអំណាចផ្តាច់ការ។ មុខងារចុងក្រោយគឺផ្តល់សច្ចាប័ន លើសេចក្តីប្រកាសសង្គ្រាម និងយល់ព្រមដល់ការបង្កើតសន្តិភាព។ ស្ទើរតែគ្មានករណីលើកលែង ទំនៀមទម្លាប់បានជំនួសច្បាប់ ហើយការគ្រប់គ្រងយុត្តិធម៌មានលក្ខណៈឯកជន។ សូម្បីតែអំពើឃាតកម្មដោយចេតនា ក៏ត្រូវទទួលទោស តែពីក្រុមគ្រួសារជនរងគ្រោះតែប៉ុណ្ណោះ។ ខណៈពេលដែលវាជាការពិតដែលពេលខ្លះវិវាទត្រូវបានបញ្ជូនទៅអ្នកគ្រប់គ្រងដើម្បីដោះស្រាយ ប៉ុន្តែគាត់បានធ្វើសកម្មភាព នៅក្នុងករណីបែបនេះ គ្រាន់តែជាអាជ្ញាកណ្តាល មិនមែនជាចៅក្រមទេ។ តាមពិតទៅ មនសិការនយោបាយរបស់មនុស្សសម័យបុរេប្រវត្តិសាស្ត្រ មានការវិវត្តតិចតួចណាស់ ដែលពួកគេមិនមានគំនិតបែបជារដ្ឋាភិបាល ឬជាភ្នាក់ងារ ដែលមិនអាចខ្វះបាន សម្រាប់ការថែរក្សាសណ្តាប់ធ្នាប់សង្គមនោះទេ។ ជាឧទាហរណ៍នៅក្នុងសង្គមក្រិចអ្នកស្រាវជ្រាវបង្ហាញថា នៅពេលដែល Odysseus ដែលជាអ្នកគ្រប់គ្រងនៅ Ithaca បានអវត្តមានអស់រយៈពេលម្តៃឆ្នាំ ហើយគ្មានអ្នកស្នងរាជ្យទេ ត្រូវបានតែងតាំងជំនួស ហើយមិនមានសម័យប្រជុំ របស់ក្រុមប្រឹក្សា ឬសភា ត្រូវបានធ្វើឡើងទេ។ គ្មាននរណាម្នាក់គិតថា ការព្យួរដោយគ្មានអ្នកដឹកនាំសង្គម (រដ្ឋាភិបាល) ទាំងស្រុង សូម្បីតែមួយរយៈពេល ជាយូរមកហើយនោះ គឺជាបញ្ហាសំខាន់ណាស់របស់សង្គមនោះទេ។

ជំពូកទី២.
សម័យបុរេប្រវត្តិសាស្ត្រ

ជាទូទៅអ្នកប្រាជ្ញបានធ្វើការបែងចែកកាលប្រវត្តិសាស្ត្រជាពីរផ្នែកធំៗ៖ សម័យបុរេប្រវត្តិសាស្ត្រសំដៅលើសម័យកាលមិនទាន់មានឯកសារសំណេរ។ សម័យប្រវត្តិសាស្ត្ររាប់ចាប់ពីពេលមានអក្សរសម្រាប់កត់ត្រាពីព្រឹត្តិការណ៍នានា ដែលកើតឡើងក្នុងសង្គម។

សម្រាប់ប្រទេសកម្ពុជា មានការខ្វែងគំនិតគ្នាចំពោះការកំណត់កាលបុរេប្រវត្តិសាស្ត្រខ្មែរ។ លោកបណ្ឌិត មីលែលត្រាណេ បានអះអាងថា "បុរេប្រវត្តិសាស្ត្រខ្មែរចាប់ផ្តើមឡើងតាំងពីប្រមាណ ៦៨០ ០០០ឆ្នាំ មុនគ្រិស្តសករាជ"។ លោក ត្រឹង ងា បានអះអាងថា "បុរេប្រវត្តិសាស្ត្រខ្មែរចាប់ពីប្រមាណ ៤ ២៩០ឆ្នាំមុនគ្រិស្តសករាជ រហូតដល់ប្រហែលជាឆ្នាំ៥២ នៃគ្រិស្តសករាជ"។[៨៨] ការកំណត់យកសម័យបុរេប្រវត្តិសាស្ត្រកម្ពុជាចាប់ផ្តើមពីឆ្នាំ៤ ២៩០ឆ្នាំមុនគ្រិស្តសករាជ អាចប្រហែលជាពឹងផ្អែកលើព័ត៌មានតាមរយៈកំណាយផ្នែកបុរាណវិទ្យាក្នុងស្ថានីយបុរេប្រវត្តិសាស្ត្រ **"ល្អាងស្ពាន-បាត់ដំបង"** ដែលជាស្ថានីយបុរេប្រវត្តិសាស្ត្រចាស់ជាងគេរបស់ពួកមន-ខ្មែរ។

២.១. ក្រុមមនុស្សដំបូងៗនៅកម្ពុជា

២.១.១. ក្រុមមនុស្សរស់នៅស្ថានីយហោលខាល

ក្នុងឆ្នាំ១៩៦៣ លោក **សូរ៉ាំង** (E. Saurin) បានធ្វើការកត់សម្គាល់នូវវប្បធម៌យុគថ្មបំបែក (Pebble Culture) ដែលចេញពីកម្ពស់ដី (Terrass) ដែលមានរលកពី ៤០ម៉ែត្រ ទៅ៤៥ម៉ែត្រ ខ្ពស់ជាងទឹកសមុទ្រ នៅភាគខាងកើតទន្លេមេគង្គ ចន្លោះខេត្តស្ទឹងត្រែង និងស្រុកស្ទួល ខេត្តក្រចេះ ដែលមានរយៈចម្ងាយប្រហែល ២០០គ.ម ក្នុងនោះមានស្ថានីយឆែប ស្រែឫស្សី ស្រែស្បូវ ត្រង់ចំណុចគីឡូម៉ែត្រលេខ៣៣៥, ៣២៥, ២៨០ (គឺជាលេខបង្គោលគីឡូម៉ែត្រចន្លោះពីខេត្តក្រចេះ ទៅខេត្តស្ទឹងត្រែង) កន្ទួត ព្រៃកទេ ខ្សឹម និងស្ទួល[៨៩]។ ការរកឃើញទីតាំងផលិតឧបករណ៍ថ្ម ពពួកថ្មបំបែក (galets

[៨៨] សៀវភៅប្រវត្តិសាស្ត្រកម្ពុជា (វង់ សុធារ៉ា និង ណុប សុខា) ទំព័រទី១០។

[៨៩] The locations of Pebble-culture sites noted by E. Saurin, ១៩៦៣, quoted from, "Prehistoric Research in Cambodia during the Last Ten Years", Cécile and Roland Mourer, *Asian Perspectives*, Volume XIV, ១៩៧៣, pp. ៣៥-៣៦.

aménagé) ជាច្រើនកន្លែង ពពួកឧបករណ៍ថ្ម មានមុខពីរ (éclats à taille) និងពពួកថ្មដែលកើតពីឈើ (bois silicifièr)[៩០] ហើយដែលជាប្រភេទឧបករណ៍ថ្មទាំងនោះមានអាយុកាល ប្រហែល ៦០០ ០០០ ឆ្នាំមុនគ.ស។ លោកបានពិនិត្យសាឡើងវិញនៅឆ្នាំ ១៩៦៦ និងគូសបញ្ជាក់ថា នៅទីនោះមានសំណល់វប្បធម៌ ទាក់ទងនឹងភាគខាងដើមនៃយុគថ្មបំបែក។ នោះជាលើកទីមួយហើយ ដែលលោកបានឃើញប្រភេទថ្មបំបែកក្នុងតំបន់នោះ។ លោក **សូរ៉ាំង** (E. Saurin) បានរកឃើញថ្មបំបែកមួយចំនួនស្ថិតនៅវាលល្បាប់ទន្លេមេគង្គ ដែលដុំថ្មទាំងនោះមានស្លាកស្នាមបំបែក លោកបានសន្និដ្ឋានថា រាល់ថ្មបំបែកទាំងនោះ ប្រហែលមានទំនាក់ទំនងទៅនឹងវប្បធម៌នៃយុគថ្មបំបែកជាប្រាកដ[៩១]។

នៅចុងឆ្នាំ១៩៩៦ ការសិក្សាថ្មីរបស់និស្សិតមហាវិទ្យាល័យបុរាណវិទ្យា ក្នុងនោះក៏មានអ្នកនិពន្ធផងដែរ បានចុះទៅស្រាវជ្រាវដល់ស្ថានីយផ្ទាល់តែម្តង ដោយបានពិនិត្យឃើញថា រាល់បំណែកថ្មដែលប្រមូលបានពីស្ថានីយកន្លួត ធ្វើឱ្យយើងពិបាកធ្វើការសន្និដ្ឋានថាតើវាកើតឡើងដោយស្នាដៃមនុស្ស ឬដោយធម្មជាតិជាអ្នកបង្កើត ព្រោះហេតុថារាល់បំណែកថ្មដែលប្រមូលបានទាំងនោះ នៅមានសភាពដើមបែបធម្មជាតិច្រើនជាង។ ម៉្យាងវិញទៀតប្រភេទថ្ម ដែលយើងប្រមូលបានទាំងនោះជាប្រភេទដុំគ្រួសធំៗ (Pebble) ហើយគ្រួសនេះមាន នៅតំបន់ខ្ពង់រាប និងភ្នំក្នុងដែនដីចាស់របស់ប្រទេសកម្ពុជាចន្លោះជ្រលងទន្លេមេគង្គចាប់ពីស្រុកស្នួលក្នុងខេត្ត ក្រចេះ ឆ្ពោះទៅជើង។

ប្រភេទពូថៅថ្មបំបែកមួយដុំ បានប្រទះឃើញនៅស្ថានីយភូមិរលួច ក្បែរស្ពានស្វាយយូ ដោយក្រុមស្រាវជ្រាវ ដែលដឹកនាំដោយលោក **ជុច ភឿន ហ្គឺត** និង **បាបាវ៉ា អាល់ប្រិច** (Gerd and Babara Albrecht)ព្រមទាំងអ្នកនិពន្ធ ផងដែរ នៅដើមឆ្នាំ១៩៩៦ នោះ។ ជាប្រភេទថ្មដែលកើតពីឈើ (bois silicifièr) ពូថៅថ្ម នេះមានស្លាកស្នាមមុខបំបែកនៅទាំងសងខាង ហើយត្រូវបានសន្និដ្ឋានថា ជាប្រភេទឧបករណ៍ពូថៅថ្មដែលផលិតនៅនឹងកន្លែងបន្សល់ពីសម័យយុគថ្មបំបែកនៅក្នុងស្ថានីយនោះ។ រហូតមកដល់សព្វថ្ងៃនេះ មានកស្តុតាងតិចតួចនៅឡើយ ដែលបញ្ជាក់អំពីភាគខាងដើមនៃសង្គមវប្បធម៌ថ្មបំបែក និងសម័យយុគថ្មបំបែកនៅកម្ពុជា។ ទោះបីការសិក្សាអំពីយុគសម័យថ្មបំបែកនៅមានកម្រិត ក៏អ្នកនិពន្ធគាំទ្រ និងលើកទឹកចិត្តដល់ការសិក្សាបន្តនៅ

[៩០] យើងបានជួបប្រទះឧបករណ៍របៀបនេះជាច្រើនកន្លែងនៅប្រទេសកម្ពុជា ក្នុងនោះមានឧបករណ៍មួយដែលយើងបានរកឃើញនៅ ស្ពានស្វាយយូ ក្នុងខេត្តក្រចេះ ដោយអ្នកនិពន្ធនៅឆ្នាំ១៩៩៧។

[៩១] *Asian Perspectives*, volume IX, ១៩៦៦.

តំបន់ស្ថានីយ ដែលមានស្រាប់និងជំរុញឱ្យមានការរុករកស្ថានីយថ្មីៗបន្ថែមទៀត ព្រមទាំងស្វែងរកកាលបរិច្ឆេទឱ្យបានច្បាស់លាស់សម្រាប់យុគថ្មបំបែកនៅកម្ពុជា។

២.១.២. ក្រុមមនុស្សរស់នៅស្ថានីយរូងភ្នំ

កំណាយនៅល្អាងស្ពានស្រទាប់ក្រោមបង្អស់ ជាស្រទាប់ទី១ អាយុកាល៦៨០០ឆ្នាំ មុនគ្រិស្តសករាជ ស្ថិតនៅក្នុងសម័យ Hoabinhian[៩២]។ សម័យនេះ ជាសម័យកាលនៃអរិយធម៌អ្នកប្រមាញ់ និងបេះផ្លែឈើ។ គេបានរកឃើញកុលាលភាជន៍ ជាដំបូងនៅស្រទាប់ទី២ អាយុកាល៤៣០០ឆ្នាំ មុនគ្រិស្តសករាជ ដែលនេះប្រហែលជាសំណល់របស់អ្នកធ្វើស្រែចំការនៅក្នុងប្រទេសកម្ពុជា។ ស្រទាប់ទី៣ អាយុ២០០០ឆ្នាំ មុនគ្រិស្តសករាជ និងស្រទាប់ទី៤ មានអាយុ៥០០ឆ្នាំមុនគ្រិស្តសករាជ ស្ថិតនៅក្នុងសម័យកាល នៃការធ្វើដំណាំស្រូវ។ ស្រទាប់លើបង្អស់អាយុកាល៨០០ឆ្នាំ នៃគ្រិស្តសករាជ ដែលកាលបរិច្ឆេទប្រហែលនឹងដើមសម័យអង្គរដែរ។

អំពីស្ថានីយយុគថ្មរំលីង នៅភ្នំល្អាងខេត្តកំពត កំណាយនៅក្នុងរូងភ្នំនោះបានកំណត់ទីតាំងរណ្តៅរបស់ល្អាង ដោយដាក់លេខកូដពី C-៥៧ ដល់ C-៦២bis[៩៣] ហើយមានទីតាំងជាច្រើនទៀត ដែលលោកបានកំណត់ផងដែរ។ នៅទីនោះបានរកឃើញ ការផលិតឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម (L'industrie lithique) របស់មនុស្សរស់នៅក្នុងរូងភ្នំសម័យបុរាណ ពិសេសក្នុងយុគថ្មរំលីងជាច្រើន ហើងត្រូវបានអ្នកស្រាវជ្រាវកំណត់ថា ជាសង្គមក្នុងយុគថ្មរំលីង ដែលមនុស្សចេះផ្សាំងសត្វ ដាំស្រូវ និងដោះដូរអាហារ។

២.២. រចនាសម្ព័ន្ធគ្រប់គ្រងសង្គម

២.២.១. ទម្រង់នៃការគ្រប់គ្រង

តើនៅសម័យបុរេប្រវត្តិសាស្ត្រ កម្ពុជាមានរចនាសម្ព័ន្ធគ្រប់គ្រងជារដ្ឋហើយឬនៅ?

នៅពេលមិនទាន់មានសង្គមជាតិ និងមិនទាន់មានរចនាសម្ព័ន្ធត្រឹមត្រូវ ដែលយើងហៅថា "**រដ្ឋ**" នោះ បុព្វបុរសខ្មែរស់នៅជាលក្ខណៈគ្រួសារសម្ព័ន្ធ ហើយមានការពង្រីកគ្រួសារ ដែលជាហេតុបណ្តាលឱ្យមនុស្សមានទំនាក់ទំនងក្នុងញាតិសន្តានរបស់ពួកគេ។ លើសពីនេះទៅទៀត ដោយសារការរស់នៅមិនអាចផ្តាច់ចេញពីទំនាក់ទំនងរវាងគ្នា

[៩២] ហូអាប៊ីនៀន (Hoabinhian) ជាអរិយធម៌មួយនៃវៀតណាមខាងជើង ក្នុងយុគថ្មបំបែក។

[៩៣] ជាឈ្មោះល្អាងដែលលោក កាបូណែល បានដាក់ឈ្មោះឱ្យ។

នឹងគ្នា ខ្មែរចេះចងក្រងប្រមូលគ្នាបង្កើតឱ្យក្លាយមកជាកុលសម្ព័ន្ធ។ ដោយសារប្រទេសកម្ពុជានាសម័យនោះមានផ្ទៃដីដ៏ធំទូលំទូលាយ គឺលាតសន្ធឹងយ៉ាងធំល្វឹងល្វើយ ជាហេតុធ្វើឱ្យក្រុមមនុស្សដែលរស់នៅជាកុលសម្ព័ន្ធមានជាច្រើនក្រុម។ នៅពេលមានការឯកភាពរវាងសមាជិកក្រុមនីមួយៗបានត្រឹមត្រូវហើយ បញ្ហានៃការរស់នៅបានលេចឡើងជាបាតុភូតនានា ដែលកើតពីមនុស្សនិងកើតពីធម្មជាតិ រួមផ្សំកម្រិតយល់ដឹងដែលចេះតែកើនឡើនជាលំដាប់ បានបង្កឱ្យមនុស្សបង្កើតបាននូវប្បធម៌ផ្ទាល់ដោយឡែករបស់កុលសម្ព័ន្ធនីមួយៗ គឺមានតាំងពីទំនៀមទម្លាប់ ជំនឿ ប្រពៃណីផ្សេងៗជាដើម។ ដោយមានការយល់ដឹងកាន់តែខ្ពស់ឡើងនោះ ក្រុមកុលសម្ព័ន្ធទាំងអស់ បានបន្តការពង្រីកអំណាចរៀងៗខ្លួន តាមរយៈការធ្វើសង្គ្រាមឈ្លានពានគ្នាទៅវិញទៅមក ដើម្បីពង្រីកក្រុមកុលសម្ព័ន្ធរឹតតែមានទំហំធំឡើងៗ និងមានចំនួនសមាជិកក៏កាន់តែច្រើនឡើងៗ។ ការរស់នៅសម័យបុរេប្រវត្តិសាស្ត្រតាមបែបជាកុលសម្ព័ន្ធ ក៏ចងក្រងបានក្លាយមកជាសហគមន៍ ជាសង្គម ជារដ្ឋ។

យោងតាមការស្រាវជ្រាវរបស់បុរាណវត្ថុវិទូ ស្ថានីយបន្ទាយគូឬភូមិមូល គឺជាកន្លែងរស់នៅរបស់សហគមន៍មនុស្សនាយុគលោហៈ (ស្ថានីយបុរេប្រវត្តិសាស្ត្រ)។ លក្ខណៈទូទៅនៃស្ថានីយបន្ទាយគូឬភូមិមូលនេះជាទីទួលមានផ្ទៃរាបស្មើ ដែលមានរាងមូលនិងមានវិដ្ឋមាត្រពី ២០០ ទៅ៣០០ ម៉ែត្រ។ ជាទូទៅវង់មណ្ឌលនេះមានផ្លូវចេញចូល២ មានទំនប់ព័ទ្ធជុំវិញ និងមានប្រឡាយខាងក្នុង និងខាងក្រៅទំនប់ ឬជាប់នឹងប្រភពទឹកជានិច្ច។ បើតាមបុរាណវត្ថុវិទូនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ស្ថានីយបន្ទាយគូឬភូមិមូលនីមួយៗអាចមានអាយុកាលជាង ៤ ០០០ ឆ្នាំ ហើយត្រូវបានគេប្រសិទ្ធនាមឱ្យថា "អារ្យធម៌មេមត់"។ ការសិក្សាស្រាវជ្រាវនៃវប្បធម៌ភូមិមូលនៅកម្ពុជាដោយលោកបារីស ម៉ាលើរ៉ និងការសិក្សាថ្មីៗដោយនិស្សិតនៃមហាវិទ្យាល័យបុរាណវិទ្យា ជំនាន់ទី ៦ បានឱ្យដឹងថាជនជាតិខ្មែរនាសម័យបុរេប្រវត្តិសាស្ត្របានបង្កើតនូវស្ថាបត្យកម្ម ផ្ទាល់របស់ខ្លួនដោយប្រើដី និងឈើជាវត្ថុធាតុដើម ដើម្បីសាងសង់ជាផ្ទះសម្បែង ស្រុក ភូមិ ដោយមានកំពែងមូលមានគូទឹកជុំវិញ ដើម្បីការពារទល់នឹងសត្វសាហាវ ឬកុលសម្ព័ន្ធដទៃទៀត នៅពេលកើតសង្គ្រាម។ ភូមិនេះជាលំនៅឋានរបស់សហគមន៍ខ្មែរបុរាណ ដែលមានកំពែងដីកំពស់ ១,៨០ ម៉ែត្រហ៊ុមព័ទ្ធជុំវិញ ។

បណ្ឌិត **ជា មុនីឫទ្ធិ** ក្នុងសៀវភៅ "ទស្សនវិជ្ជានាសម័យហ្វូណន" បានសរសេរថា "ការរស់នៅមានការរៀបចំយ៉ាងហ្មត់ចត់ ដូចដែលលោកបានរកឃើញ គឺមានកំពែង

រាងមូលព័ទ្ធជុំវិញ (វិមាត្រប្រហែល២០០ម៉ែត្រ) ដែលត្រូវបានគេហៅថា**បន្ទាយគូ ឬភូមិមូល** មានអាយុកាលប្រហែល ២ ០០០ឆ្នាំ មុនគ្រិស្តសករាជ បញ្ជាក់ថា ការរស់នៅពេលនោះមានលក្ខណៈជាកុលសម្ព័ន្ធ"។

នៅចុងនៃបុរេប្រវត្តិសាស្ត្រកម្ពុជា ព្រះនាង លីវ យី បានលើកទ័ពទៅច្បាំងជាមួយព្រះបាទ ហ៊ុន ទៀន ដែលជាជនបរទេស។ ព្រះបាទ ហ៊ុន ទៀន បានច្បាំងឈ្នះព្រះនាង លីវ យី ហើយបានឡើងសោយរាជ្យបង្កើតបានជាបឋមក្សត្រនៃរដ្ឋហ្វូណន។[៩៤]

លោក អាដេម៉ារ ឡឺក្លែរ ក្នុងសៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា" បានសរសេរថា "ព្រះនាង លីវ យី ជាស្តេចសោយរាជ្យដំបូងនៅនគរគោកធ្លក។ ព្រះរាជាទី២ គឺព្រះបាទ ហ៊ុន ទៀន..... "។

សរុបមកយើងអាចសន្និដ្ឋានបានថា នៅចុងសម័យបុរេប្រវត្តិសាស្ត្រកម្ពុជា សញ្ញាណនៃរដ្ឋបានកកើតរួចហើយ (មានទឹកដីច្បាស់លាស់ មានប្រជាជនរស់នៅជាអចិន្ត្រៃយ៍ និងមានអង្គការចាត់តាំងនយោបាយសម្រាប់ការពារ គ្រប់គ្រង និងដឹកនាំប្រជាជននិងទឹកដីរបស់ខ្លួន)។ បើផ្អែកលើសៀវភៅប្រវត្តិសាស្ត្រប្រទេសកម្ពុជារបស់លោក អាដេម៉ារ ឡឺក្លែរ ទម្រង់នៃការគ្រប់គ្រងចុងសម័យបុរេប្រវត្តិសាស្ត្រកម្ពុជា គឺរបបរាជានិយម (មានស្តេចសោយរាជ្យ) រួចទៅហើយ។[៩៥]

សម័យបុរេប្រវត្តិ ជាសម័យស្ថាប័ននយោបាយ និងច្បាប់ ស្ថិតនៅក្នុងយុគសម័យងងឹត មានលក្ខណៈដើមដំបូងខ្លាំងណាស់។ សហគមន៍មនុស្សភូមិតូចៗនីមួយៗ ឯករាជ្យពីការគ្រប់គ្រងខាងក្រៅ ប៉ុន្តែសិទ្ធិអំណាចនយោបាយមានភាពតឹងរ៉ឹង ដូច្នេះវានឹងមិនច្រើនពេកទេ ក្នុងការនិយាយថា រដ្ឋស្ទើរតែមិនមានទាល់តែសោះ។ អ្នកគ្រប់គ្រង គឺមិនមានតែមេដឹកនាំកុលសម្ព័ន្ធទេ។ គាត់មិនអាចបង្កើត ឬអនុវត្តច្បាប់ ឬគ្រប់គ្រងយុត្តិធម៌បានទេ។ គាត់មិនបានទទួលប្រាក់កម្រៃអ្វីទេ ហើយត្រូវធ្វើស្រែចម្ការចិញ្ចឹមជីវិត ដូចពលរដ្ឋដទៃទៀត។ ជាក់ស្តែងមុខងារតែមួយគត់របស់គាត់ គឺអ្នកប្រើកម្លាំងការពារ និងបព្វជិត។ មេកុលសម្ព័ន្ធ ជាអ្នកបញ្ជាទ័ពក្នុងពេលមានសង្គ្រាម ហើយថ្វាយយញ្ញបូជា ដើម្បីរក្សាព្រះធ្វើអំពើល្អក្នុងសហគមន៍។ ទោះបីជាសហគមន៍តូចៗនីមួយៗ មានក្រុមប្រឹក្សាអភិជន និងក្រុមអ្នកចម្បាំងក៏ដោយ ស្ថាប័នទាំងពីរនេះ មិនមានសមាជិកភាពច្បាស់លាស់

[៩៤] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា) ទំព័រទី៨៤។
[៩៥] សៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (អាដេម៉ារ ឡឺក្លែរ) ទំព័រទី៨៤។

ឬឋានៈជាសរីរាង្គនៃរដ្ឋាភិបាលនោះទេ។ ភារកិច្ចរបស់អ្នកដឹកនាំពីអតីតកាល គឺផ្តល់ជំបូន្មាន និងជួយអ្នកគ្រប់គ្រង និងរារាំងពីការដណ្តើមអំណាចផ្តាច់ការ។ មុខងារចុងក្រោយគឺផ្តល់សច្ចាប័ន លើសេចក្តីប្រកាសសង្គ្រាម និងយល់ព្រមដល់ការបង្កើតសន្តិភាព។ ស្ទើរតែគ្មានករណីលើកលែង ទំនៀមទម្លាប់បានជំនួសច្បាប់ ហើយការគ្រប់គ្រងយុត្តិធម៌ មានលក្ខណៈឯកជន។ សូម្បីតែអំពើឃាតកម្មដោយចេតនា ក៏ត្រូវទទួលទោសតែពីក្រុមគ្រួសារជនរងគ្រោះតែប៉ុណ្ណោះ។ ខណៈពេលដែលវាជាការពិត ដែលពេលខ្លះវិវាទ ត្រូវបានបញ្ជូនទៅអ្នកគ្រប់គ្រងដើម្បីដោះស្រាយ ប៉ុន្តែគាត់បានធ្វើសកម្មភាព នៅក្នុងករណីបែបនេះ គ្រាន់តែជាអាជ្ញាកណ្តាល មិនមែនជាចៅក្រមទេ។ តាមពិតទៅ មនសិការនយោបាយរបស់មនុស្ស សម័យបុរេប្រវត្តិសាស្ត្រ មានការវិវឌ្ឍន៍តិចតួចណាស់ ដែលពួកគេមិនមានគំនិតបែបជារដ្ឋាភិបាល ឬជាភ្នាក់ងារ ដែលមិនអាចខ្វះបាន សម្រាប់ការថែរក្សាសណ្តាប់ធ្នាប់សង្គមនោះទេ។ ជាឧទាហរណ៍នៅក្នុងសង្គមក្រិច អ្នកស្រាវជ្រាវបង្ហាញថា៖ នៅពេលដែល Odysseus ដែលជាអ្នកគ្រប់គ្រងនៅ Ithaca បានអវត្តមានអស់រយៈពេលម្ភៃឆ្នាំ ហើយគ្មានអ្នកស្នងរាជ្យទេ ត្រូវបានតែងតាំងជំនួស ហើយមិនមានសម័យប្រជុំ របស់ក្រុមប្រឹក្សា ឬសភា ត្រូវបានធ្វើឡើងទេ។ គ្មាននរណាម្នាក់គិតថា ការព្យួរដោយគ្មានអ្នកដឹកនាំសង្គម(រដ្ឋាភិបាល)ទាំងស្រុង សូម្បីតែមួយរយៈពេល ជាយូរមកហើយនោះ គឺជាបញ្ហាសំខាន់ណាស់របស់សង្គមនោះទេ។

២.២.២.លំនាំដើមនៃជីវិតសង្គម និងសេដ្ឋកិច្ច

គំរូនៃជីវិតសង្គម និងសេដ្ឋកិច្ចគឺសាមញ្ញ ហើយអស្ចារ្យណាស់ សម្រាប់មនុស្សសម័យបុរេប្រវត្តិសាស្ត្រ។ ទោះបីជាសំឡេងទូទៅនៃសង្គម ដែលបានបង្ហាញនៅក្នុងវីរភាព គឺមានលក្ខណៈបែបអភិជនក៏ដោយ តាមពិតមិនមានការបែងចែកថ្នាក់តឹងរឹងនោះទេ។ ការងារដោយដៃមិនត្រូវបានគេចាត់ទុកថា ថោកទាបទេ ហើយជាក់ស្តែងមិនមានអ្នកក្រឬអ្នកមាននោះទេ។ ថាមានជាកម្លាំង(កម្មករ)ពឹងផ្អែកខ្លះ ដែលធ្វើការនៅលើទឹកដី នៃពួកអភិជន(ជនពូកែ ឬជាជនដែលត្រូវបានគោរព) ហើយបម្រើពួកគេ ជាអ្នកចម្បាំងដ៏ស្មោះត្រង់ ហាក់ដូចជាច្បាស់លាស់ពីវីរភាព ប៉ុន្តែពួកគេហាក់ដូចជាអ្នកបម្រើជាជាងទាសករ។ ទាសករភាគច្រើនជាស្ត្រី ធ្វើការជាអ្នកបម្រើ អ្នកកែច្នៃត្បាញវែ អ្នកធ្វើក្អមឆ្នាំង ឬស្រីស្នំ។ មនុស្សជាច្រើនគឺជាឈ្លើយសឹកសង្គ្រាម ប៉ុន្តែពួកគេហាក់ដូចជាមិនត្រូវបានប្រព្រឹត្តអាក្រក់នោះទេ។ កសិកម្ម និងការចិញ្ចឹមសត្វ (ពាហនៈ) គឺជាមុខរបរមូលដ្ឋានរបស់មនុស្សមានសេរីភាព។ លើកលែងតែសិប្បកម្មជំនាញមួយចំនួនដូចជា

ជាងរទេះ ជាងដាវ ជាងមាស និងជាងស្មូន នោះគ្មានជំនាញខាងការងារសោមញ្ញទេ។ ភាគច្រើន គ្រួសារនីមួយៗ ធ្វើឧបករណ៍ផ្ទាល់ខ្លួន ត្បាញសំលៀកបំពាក់ផ្ទាល់ខ្លួន និងចិញ្ចឹមសត្វជាអាហារផ្ទាល់ខ្លួន។ រហូតមកដល់ពេលនេះ នៅសម័យបុរេប្រវត្តិសាស្ត្រនេះ ធ្វើការជាអ្នកជួញដូរ ដែលពួកគេមិនមានពាក្យ "ឈ្មួញ" នៅក្នុងភាសារបស់ពួកគេទេ ហើយការដោះដូរគឺជាវិធីសាស្ត្រតែមួយគត់ នៃការផ្លាស់ប្តូរទំនិញរវាងគ្នា ដែលត្រូវបានអនុវត្ត។

២.២.៣. ធម្មជាតិនៃសង្គមនិងមាត្រដ្ឋាននៃសង្គម (Establishing the nature and scale of the society)

ជំហានដំបូងនៃបុរាណវិទ្យាសង្គម ឬសង្គមសម័យបុរេប្រវត្តិសាស្ត្រគឺ ជាក់ស្តែងណាស់ តែអ្នកសិក្សាច្បាប់សង្គមច្រើនតែត្រូវបានគេមើលរំលង។ វាគឺជាការចោទសួរថា ៖ តើច្បាប់ក្នុងសង្គមបុព្វកាលជាអ្វី? អ្នកណាជាអ្នកកាន់ច្បាប់ គាំពារច្បាប់ និងអ្នកណាជាអ្នកអនុវត្តច្បាប់? តើអ្វីទៅជាច្បាប់ក្នុងសម័យបុរេប្រវត្តិសាស្ត្រ? តើច្បាប់សម័យបុរេប្រវត្តិមានអ្វីជាទឡ្ហីករណ៍ បើសង្គមសម័យបុរេប្រវត្តិគ្មានអក្សរជាសំណេរផងនោះ? តើសង្គមបុព្វកាលជាអ្វី? តើទំហំនៃអង្គភាពសង្គមធំបំផុតនោះគឺជាអ្វី? ហើយតើសង្គមបែបណា, ក្នុងន័យទូលំទូលាយសង្គមបានកើតរបៀបណា?

ជាក់ស្តែងមិនងាយស្រួលឆ្លើយនូវសំណួរទាំងនេះទេ, វាចាំបាច់ត្រូវសួរដោយប្រុងប្រយ័ត្ននូវអ្វីដែលយើងចង់សំដៅទៅលើអង្គភាពសង្គមធំជាងគេ ដែលយើងនឹងហៅថាអង្គការសង្គម។ ការសិក្សានេះត្រូវរំពឹងទាំងស្រុងទៅលើនរវិទ្យា ជាតិពន្ធុវិទ្យា និងបុរាណវិទ្យា។ ពាក្យសង្គមមិនសំដៅលើមាត្រដ្ឋានជាក់លាក់ណាមួយ ឬភាពស្មុគស្មាញនៃអង្គការនោះទេ។ វាអាចអនុវត្តផងដែរចំពោះ ទីតាំងស្នាក់នៅនៃ ក្រុមអ្នកប្រមាញ់បេះផ្លែឈើ ភូមិអ្នកធ្វើកសិកម្ម ឬអាណាចក្រដ៏អស្ចារ្យ។ អង្គការគឺជានយោបាយឯករាជ្យ ឬអង្គភាពសង្គមស្វយ័ត ដែលអាចនៅក្នុងករណីនៃសង្គមស្មុគស្មាញ ដូចជាសង្គមរដ្ឋ រួមបញ្ចូលសមាសធាតុតិច ឬច្រើន។ ដូច្នេះហើយ នៅក្នុងពិភពទំនើបរដ្ឋប្រជាជាតិស្វយ័តអាចត្រូវបានបែងចែកទៅជាស្រុក ឬតំបន់, ប្រទេស, ដែលនីមួយៗអាចមានទីក្រុង និងភូមិជាច្រើន។ រដ្ឋទាំងមូលគឺជាអង្គការ។ នៅចុងម្ខាងទៀតនៃមាត្រដ្ឋាន ក្រុមតូចមួយនៃក្រុមអ្នកប្រមាញ់និងបេះផ្លែឈើ អាចធ្វើការសម្រេចចិត្តដោយខ្លួនឯង ហើយមិនមានលំដាប់អំណាចខ្ពស់ ក្រុមនោះក៏បង្កើតជាអង្គការមួយដែរ។ ពេលខ្លះសហគមន៍អាចរួមគ្នាបង្កើតសហព័ន្ធមួយ ហើយយើងត្រូវសួរថា តើសហគមន៍ទាំងនោះនៅតែជាអង្គការស្វយ័តដែរឬ

ទេ ឬថាតើសហព័ន្ធទាំងមូលឥឡូវនេះ ជាអង្គការធ្វើការសម្រេចចិត្តប្រកបដោយប្រសិទ្ធភាព ចំណុចទាំងនេះមិនទាន់ជាផ្នែកបុរាណវិទ្យាត្រូវសិក្សានៅឡើយទេ៖ ទោះយ៉ាងណា ពួកគេបង្ហាញពីសារៈសំខាន់នៃការដឹងយ៉ាងច្បាស់អំពីអ្វីដែលយើងចង់ដឹងអំពីច្បាប់សង្គមអតីតកាល។

ទាក់ទងនឹងការស្រាវជ្រាវក្នុងវិស័យនេះ ជារឿយៗសំណួរត្រូវបានឆ្លើយយ៉ាងល្អបំផុត ពីការសិក្សាអំពីការតាំងទីលំនៅ ទាំងនៅក្នុងលក្ខខណ្ឌនៃមាត្រដ្ឋាន និងធម្មជាតិនៃស្ថានីយ និងនៅក្នុងទំនាក់ទំនងរវាងពួកគេ តាមរយៈការវិភាគគំរូនៃលំនាំលំនៅឋាន (settlement pattern)។ ប៉ុន្តែយើងមិនត្រូវភ្លេចកំណត់ត្រា ដែលសរសេរនោះទេ សង្គមមួយចេះអក្សរ និងប្រើការសរសេរ រឿងព្រេងប្រជាប្រិយ(ប្រពៃណីផ្ទាល់មាត់) និងជាតិពន្ធុបុរាណវិទ្យា ការសិក្សាពីទស្សនៈបុរាណវិទ្យានៃសង្គមបច្ចុប្បន្ន អាចមានតម្លៃស្មើភាពគ្នាក្នុងការវាយតម្លៃលក្ខណៈ និងមាត្រដ្ឋាននៃសង្គមដែលកំពុងពិនិត្យ។

ជាដំបូង ទោះជាយ៉ាងណា យើងត្រូវការកម្រិតឯកសារយោង ការចាត់ថ្នាក់សម្មតិកម្មនៃសង្គម ដែលត្រូវសាកល្បងគំនិតរបស់យើង។

២.២.៤. ចំណាត់ថ្នាក់នៃសង្គម (Classification of Societies)

គឺជាការសិក្សាអំពីការវិវត្តរបស់សង្គមមនុស្ស ចាប់ផ្តើមតាំងពីជីវិតដំបូងៗរបស់មនុស្ស រស់នៅលើផែនដី។ អ្នកជំនាញខាងផ្នែកនរវិទ្យាជនជាតិអាមេរិក Elman Service បានបង្កើតការចាត់ថ្នាក់នៃសង្គមមានចំនួនបួន ដែលអ្នកបុរាណវត្ថុវិទូជាច្រើនបានរកឃើញថាមានប្រយោជន៍។ ភ្ជាប់ជាមួយសង្គមទាំងនេះ តាមរយៈកស្តុតាងប្រភេទនៃទីតាំងស្ថានីយជាក់លាក់ និងលំនាំនៃការតាំងទីលំនៅរបស់មនុស្ស។

ក. ក្រុម គឺជាសង្គមខ្នាតតូច នៃអ្នកប្រមាញ់ និងអ្នកបេះផ្លែឈើ ជាទូទៅមានមនុស្សតិចជាង ១០០ នាក់ ដែលផ្លាស់ទីតាមរដូវដើម្បីស្វែងរកធនធានស្បៀងអាហារព្រៃ (គ្មានផ្ទះសម្បែង)។ ក្រុមអ្នកប្រមាញ់ និងអ្នកបេះផ្លែឈើ នៅមានសព្វថ្ងៃនេះដូចជា Hadza នៃប្រទេសតង់ហ្សានី ឬសាននៃអាហ្វ្រិកខាងត្បូង។ សមាជិកក្រុម ជាទូទៅគឺសាច់ញាតិ ទាក់ទងនឹងតំណពូជ ឬអាពាហ៍ពិពាហ៍។ ក្រុម ខ្វះអ្នកដឹកនាំផ្លូវការ, សេដ្ឋកិច្ចមិនគួរឱ្យកត់សម្គាល់មានភាពមិនខុសគ្នាក្នុងចំណោមសមាជិករបស់ពួកគេទេ។

ក្រុម បង្កើតឡើងដោយ បណ្តុំចល័តអ្នកប្រមាញ់ និងអ្នកបេះផ្លែឈើច្រើនរូប, ទីតាំងស្ថានីយរបស់ពួកគេភាគច្រើនជាជំរុំកាន់កាប់តាមរដូវកាល, ជាស្ថានីយតូចៗ។ ក្នុង

ចំណោមនោះមានកស្តុតាងដូចជាកន្លែងសម្លាប់សត្វ ឬកន្លែងក្លាសសត្វ ទីតាំងដែលមានឋនិកសត្វធំៗត្រូវបានសម្លាប់ ហើយជួនកាលត្រូវបានគេក្លាសសត្វនៅកន្លែងបរបាញ់តែម្តង, កន្លែងដែលឧបករណ៍ត្រូវបានផលិតឡើង ឬសកម្មភាពជាក់លាក់ផ្សេងៗទៀត។ ដំរុំពួកគេអាចផ្តល់កស្តុតាងនៃលំនៅឋានដែលមិនសូវសំខាន់ ឬជម្រកបណ្តោះអាសន្ន, រួមជាមួយនឹងកំទេចកំទីនៃការកាន់កាប់លំនៅឋាន។

កំឡុងសម័យយុគថ្មបំបែក (Paleolithic មុន ១២ ០០០ ឆ្នាំមុន) ទីតាំងស្តានីយបុរាណវត្ថុភាគច្រើនហាក់ដូចជាអនុលោមតាមប្រភេទមួយ ឬផ្សេងទៀតនៃប្រភេទទាំងនេះ - ទីតាំងស្តានីយជាជំរុំ, កន្លែងសម្លាប់សត្វ, កន្លែងធ្វើការ - ហើយអ្នកបុរាណវត្ថុវិទូជាធម្មតាសន្មតថា សង្គមក្នុងយុគថ្មបំបែក(Paleolithic) ភាគច្រើនមនុស្សត្រូវបានរៀបចំជាក្រុមតូចៗ។ ជាតិពន្ធុបុរាណវិទ្យា (Ethnoarchaeology) បានយកចិត្តទុកដាក់យ៉ាងខ្លាំង ចំពោះការសិក្សាអំពីក្រុមអ្នកប្រមាញ់ និងអ្នកបេះផ្លែឈើ, ផ្តល់នូវការយល់ដឹងជាច្រើន ដែលទាក់ទងនឹងអតីតកាលដ៏ឆ្ងាយ។

ខ. កុលសម្ព័ន្ធ (**Tribes**) ជាទូទៅមានទំហំធំជាងក្រុម, ប៉ុន្តែកម្រមានចំនួនមនុស្សច្រើនជាងពីរ ឬបីពាន់នាក់ ហើយរបបអាហារ ឬការចិញ្ចឹមជីវិតរបស់ពួកគេ គឺពឹងផ្អែកភាគច្រើនលើរុក្ខជាតិដាំដុះ និងចិញ្ចឹមសត្វ។ ជាធម្មតា ពួកគេមានការតាំងទីលំនៅ ហើយជាកសិករ, ប៉ុន្តែពួកគេអាចជាអ្នកពនេចរតាមរដូវកាល, អាស្រ័យលើរបបអាហារចល័ត ផ្អែកលើការទាញផលពីការចិញ្ចឹមសត្វ។ ជាទូទៅពួកគេទាំងនេះគឺជាសង្គមពហុសហគមន៍, ជាមួយសហគមន៍នីមួយៗ រួមបញ្ចូលទៅក្នុងសង្គមធំ តាមរយៈទំនាក់ទំនងញាតិមិត្ត។ ទោះបីយ៉ាងណាក៏ដោយកុលសម្ព័ន្ធខ្លះមានមន្ត្រី និងមាន «ទីប្រជុំជន» ឬអាសនៈរបស់អង្គការចាត់តាំង, តែនៅខ្វះមូលដ្ឋានសេដ្ឋកិច្ចចាំបាច់ សម្រាប់ការប្រើប្រាស់អំណាចប្រកបដោយប្រសិទ្ធភាព។

ការតាំងទីលំនៅ ជាធម្មតាសម្រាប់កុលសម្ព័ន្ធ គឺជាផ្នែកមួយនៃលំនៅឋានកសិកម្ម ដែលបានតាំងទីលំនៅជាបណ្តុំ ឬភូមិ។ លក្ខណៈពិសេសនៃកុលសម្ព័ន្ធ គឺគ្មានការត្រួតត្រាលើការតាំងទីលំនៅណាមួយរបស់ក្រុមគេ ឬត្រួតត្រាអ្នកដទៃក្នុងតំបន់នោះទេ។ ផ្ទុយទៅវិញ អ្នកបុរាណវត្ថុវិទូរកឃើញកស្តុតាងដោយឡែក ផ្ទះដែលកាន់កាប់ជាអចិន្ត្រៃយ៍ ឬសម្រាប់ភូមិអចិន្ត្រៃយ៍។ ភូមិបែបនេះអាចត្រូវបានបង្កើតឡើង ដោយបណ្តុំនៃផ្ទះឯករាជ្យ ឬផ្ទះដាច់មួយៗនៃគ្រួសារ ដូចកសិករដំបូងគេនៃមនុស្សរស់នៅក្នុងស្តានីយបន្ទាយគូក្នុងប្រទេសកម្ពុជា ហើយក៏ដូចនៅជ្រលង Danube នៅអឺរ៉ុប ៤៥០០ មុនគ.ស.

ឬពួកវាអាចជាចង្កោម នៃអគារដែលជាក់ជាក្រុមជាមួយគ្នា - អ្វីដែលគេហៅថារចនាសម្ព័ន្ធប្រមូលផ្តុំ(agglomerate), ឧទាហរណ៍ពួក Pueblos នៃភាគនិរតីអាមេរិក, និងភូមិកសិកម្មដំបូង ឬទីក្រុងតូចមួយនៃ Çatal Hüyük, ៧០០០ ឆ្នាំមុនគ្រិស្តសករាជ ដែលបច្ចុប្បន្នជាប្រទេសទួរគី។

គ. មេកន្ត្រាញ Chiefdoms សង្គមចាប់ផ្តើមមានចំណាត់ថ្នាក់ នៃភាពខុសគ្នាក្នុងសង្គមរវាងមនុស្ស និងមនុស្ស។ ពូជពង្សផ្សេងៗគ្នា ត្រូវបានចាត់ថ្នាក់លើកិត្យានុភាព និងត្រកូលជាន់ខ្ពស់ ជាតំណាងសង្គមទាំងមូល ដែលគ្រប់គ្រងដោយមេមួយរូប(ជាក្រុមដែលទាមទារតំណពូជពីបុព្វបុរស)។ កិត្យានុភាព និងឋានន្តរស័ក្តិ កំណត់ដោយភាពជិតស្និទ្ធិជាមួយនឹងមេ ហើយមិនមានការបែងចែកជាថ្នាក់ពិតប្រាកដទេ។ តួនាទីរបស់មេកន្ត្រាញគឺសំខាន់ណាស់។ ជាញឹកញាប់ ពួកគេមានជំនាញផ្នាល់ក្នុងស្រុកនៅក្នុងផលិតផលសិប្បកម្ម ហើយអាកររនៃអាហារ និងគ្រឿងឧបភោគបរិភោគ ត្រូវបង់តាមកាលកំណត់ជាកាតព្វកិច្ចជូនមេកន្ត្រាញ។ គាត់ប្រើអាកទាំងនេះដើម្បីឱ្យអ្នករក្សារបស់ខ្លួន ហើយអាចប្រើអាករសម្រាប់ការចែកចាយឡើងវិញចំពោះតម្រូវការរបស់ខ្លួន។ អំណាចជាទូទៅមាននៅមជ្ឈមណ្ឌល, ជាទូទៅគឺប្រាសាទ, លំនៅឋានរបស់មេ និងអ្នករក្សារបស់គាត់, និងអ្នកជំនាញសិប្បកម្ម។ មេកន្ត្រាញ Chiefdoms មានទំហំខុសៗគ្នា ប៉ុន្តែជាទូទៅមានចន្លោះពី ៥០០០ ទៅ ២០ ០០០ នាក់។

លក្ខណៈពិសេសមួយនៃមេកន្ត្រាញ គឺអត្ថិភាពនៃពិធីសាសនាមានជាអចិន្ត្រៃយ៍ និងជាមជ្ឈមណ្ឌលពិធីដែលដើរតួជាចំណុចកណ្តាលសម្រាប់នយោបាយទាំងមូល។ មេកន្ត្រាញនេះមិនមានជាមជ្ឈមណ្ឌលទីក្រុងអចិន្ត្រៃយ៍ទេ មិនមានការិយាធិបតេយ្យ ដូចដែលបានឃើញនៅក្នុងសង្គមរដ្ឋទេ។ ប៉ុន្តែមេកន្ត្រាញ បានផ្តល់ការចង្អុលបង្ហាញអំពីស្ថានីយខ្លះមានសារៈសំខាន់ជាងកន្លែងផ្សេងទៀត(ឋានានុក្រមស្ថានីយ)។ លក្ខណៈចំណាត់ថ្នាក់ផ្នាល់ខ្លួននៃសង្គមមេកន្ត្រាញ គឺអាចមើលឃើញតាមវិធីផ្សេងៗ ដូចជាការតាំងទីលំនៅ ជាឧទាហរណ៍ នៅក្នុងផ្នូរ មានវត្ថុដ៏សម្បូរបែប ដែលជារឿយៗអមជាមួយការបញ្ចុះសពរបស់មេដឹកនាំដែលបានស្លាប់។

ឃ. រដ្ឋដំបូង Early States ទាំងនេះរក្សានូវលក្ខណៈពិសេសជាច្រើនរបស់មេក្រុម ឬមេកន្ត្រាញ ប៉ុន្តែអ្នកគ្រប់គ្រង (ប្រហែលជាស្តេច ឬជួនកាលជាមហាក្សត្រី) មានសិទ្ធិអំណាចច្បាស់លាស់ក្នុងការបង្កើតច្បាប់ និងពង្រឹងអំណាចពួកគេដោយការប្រើកងទ័ពឈរជើងការពារ។ សង្គមលែងពឹងផ្អែកទាំងស្រុងលើទំនាក់ទំនង

ញាតិមិត្ត៖ ឥឡូវនេះសង្គមត្រូវបានបែងចែកទៅជាថ្នាក់ផ្សេងៗគ្នា។ ជាកម្មករ ជាអ្នកកសិកម្ម ឬអ្នកបម្រើ និងអ្នករស់នៅទីក្រុង អ្នកក្រីក្រ ជាវណ្ណៈទាបបំផុត។ ជាមួយអ្នកជំនាញខាងសិប្បកម្មខាងលើ, ពួកអាចារ្យ និងញាតិសន្តានរបស់ចៅហ្វាយនាយនៅតែជាវណ្ណៈដដែល។ មុខងាររបស់អ្នកគ្រប់គ្រង ច្រើនតែញែកចេញពីមុខងាររបស់មេសាសនា៖ វិមានឬវាំងត្រូវបានសម្គាល់ខុសពីប្រាសាទ។ សង្គមត្រូវបានចាត់ទុកថាជាទឹកដី ដែលគ្រប់គ្រងដោយត្រកូលអ្នកគ្រប់គ្រង និងមានប្រជាជនរស់នៅជាអ្នកជួលដែលមានកាតព្វកិច្ចបង់ពន្ធ។ រាជធានីកណ្តាលមានការគ្រប់គ្រងការិយាធិបតេយ្យរបស់មន្ត្រី។ គោលបំណងសំខាន់មួយរបស់ពួកគេគឺ ប្រមូលចំណូល(ជាញឹកញាប់នៅក្នុងទម្រង់នៃពន្ធនិងថ្លៃសេវា) ហើយចែកចាយចំណូលនោះដល់រដ្ឋាភិបាល កងទ័ព និងអ្នកជំនាញសិប្បកម្ម។ រដ្ឋដំបូងៗជាច្រើនបានបង្កើតប្រព័ន្ធចែកចាយឡើងវិញដ៏ស្មុគស្មាញដើម្បីគាំទ្រសេវាកម្មសំខាន់ៗទាំងនេះ។

សង្គមរដ្ឋសម័យបុរាណជាទូទៅ បង្ហាញពីគំរូនៃការតាំងទីលំនៅទីក្រុងដើរតួយ៉ាងសំខាន់។ ទីក្រុង ជាធម្មតាជាមជ្ឈមណ្ឌលប្រជាជនដ៏ធំ (ជារឿយៗមានប្រជាជនច្រើនជាង ៥០០០នាក់) ជាមួយនឹងអគារសាធារណៈសំខាន់ៗ រួមទាំងប្រាសាទ និងកន្លែងធ្វើការសម្រាប់ការិយាធិបតេយ្យរដ្ឋបាល។ ជាញឹកញយ មានឋានានុក្រមនៃការតាំងទីលំនៅច្បាស់លាស់ ដោយមានរាជធានីជាមជ្ឈមណ្ឌលសំខាន់ និងជាមួយសាខា ឬមជ្ឈមណ្ឌលប្រចាំតំបន់ព្រមទាំងភូមិក្នុងតំបន់។

២.៣. សម័យប្រវត្តិសាស្ត្រ

២.៣.១. ស្ថានីយភូមិស្នាយ

ស្ថានីយភូមិស្នាយ ជាស្ថានីយបុរេប្រវត្តិសាស្ត្រដ៏សំខាន់មួយរបស់ខ្មែរ និងជាស្ថានីយមួយដ៏សំខាន់នៅក្នុងតំបន់ដែរ។ ក៏អាចប្រៀបធៀបជាមួយនឹងស្ថានីយយុគដៃកលក្ខណៈដោយឡែករបស់ស្ថានីយភូមិស្នាយមានសាស្ត្រាវុធច្រើន ដែលតាមរយៈនេះយើងអាចសន្និដ្ឋានបានថា ជាស្ថានីយបង្ហាញពីឋានៈក្នុងសង្គម និងការបែងចែកមុខងារ និងវណ្ណៈ តាមរយៈសញ្ញាស័ក្តិ និងសព្វាវុធដែលយើងបានរកឃើញ កប់នៅជាមួយសាកសព។ ម៉្យាងវិញទៀត ប្រសិនបើយើងពិនិត្យទៅលើកុលាលភាជន៍វិញ មានលក្ខណៈនិងទ្រង់ទ្រាយស្រដៀងគ្នានឹងកុលាលភាជន៍នៅស្ថានីយអង្គរបុរីដែលស្ថានីយ នោះស្ថិតនៅជើមសតវត្សរ៍នៃសហវត្សរ៍ដំបូង ដែលបង្ហាញពីពាណិជ្ជកម្ម និងការជួញដូរ ភស្តុតាង

ក្នុងស្ថានីយនេះ អាចបញ្ជាក់ថា ជាសង្គមមានច្បាប់ទម្លាប់ មានអ្នកគ្រប់គ្រង និងមានការគោរពច្បាប់សង្គម និងច្បាប់សាសនា។

២.៣.២. ស្ថានីយសំរោងសែន

ការរកឃើញស្ថានីយសំរោងសែន នាំឱ្យមានការជជែកគ្នាមិនចេះចប់ទៅលើវត្ថុសិល្បៈបុរាណ នៅតំបន់អាស៊ីនេះ។ លោក **នូលេ** និងលោក **កាតៃហាក់** (J. Noulet & E. Catailhac) បានភ្ជាប់អាយុកាលរបស់ស្ថានីយសំរោងសែនទៅនឹង *យុគសំរឹទ្ធ* វិញ។ ផ្ទុយទៅវិញ នៅក្នុងឆ្នាំ១៨៨២ លោក **ហ្វុស** (E. Fuchs) បានធ្វើការពិសោធស្រាវជ្រាវទៅលើដីទន្លេមេគង្គ និងទន្លេសាប បានឱ្យដឹងថា ស្ថានីយនេះប្រហែលជាស្ថិតនៅក្នុងសតវត្សរ៍ទី១ ឬទី២ មុនគ្រិស្តសករាជប៉ុណ្ណោះ។ ការសិក្សារបស់លោក **លី វណ្ណា** នៅពេលថ្មីៗ (Ly Vanna, ១៩៩៩) បានបញ្ជាក់ឱ្យដឹងថាក្នុងជម្រៅពី៨០ស.ម ទៅ១០០ ស.ម ស្ថានីយនេះ មានអាយុកាល ក្នុងកំឡុងសតវត្សរ៍ទី១៤ ឬទី១៥ នៃគ្រិស្តសករាជ ហើយស្រទាប់នេះប្រហែលជាការជីកកកាយ ដោយអ្នកស្រុកដើម្បីរកសំបកលៀសទៅធ្វើកំបោរ[៩៦]។ ចំណែកឯក្នុងជម្រៅដីប្រមាណជា៤ម៉ែត្រ ដែលមិនមានការរំខាននោះ ការធ្វើកាលបរិច្ឆេទបានបង្ហាញនូវលទ្ធផល ដែលមានអាយុកាល៤០០០ឆ្នាំ។ សំអាងលើឧបករណ៍ធ្វើអំពីសំរឹទ្ធ ដែលប្រមូលបានពីរណ្តៅកំណាយ លោកបានបែងចែកស្រទាប់ដីក្នុងរណ្តៅកំណាយរបស់លោកដែលមានជម្រៅជាង៤ម៉ែត្រនោះចេញជាបីស្រទាប់ធំផ្សេងៗគ្នា។ ស្រទាប់ក្រោមជាស្រទាប់បុរេ-សំរឹទ្ធ (Pre-Bronze phase) ស្រទាប់កណ្តាលជាស្រទាប់សំរឹទ្ធ (Bronze phase) និងស្រទាប់ខាងលើជាស្រទាប់លោហៈ (Iron phase)។ វិធីកំណត់កាលបរិច្ឆេទហៅថា AMS (Accelerator Mass Spectrometry) បានបញ្ជាក់ថា ក្នុងជម្រៅដី៤ម៉ែត្រ មានអាយុពី ២២០៥ ទៅ ១៨៨៧ មុនគ្រីសសករាជ[៩៧] (២២០៥-១៨៨៧ B.C) ត្រូវគ្នានឹងកំឡុង៤១៥៤ ទៅ ៣៨៣៦មុនឆ្នាំបច្ចុប្បន្ន (៤១៥៤-៣៨៣៦ B.P)។ ចំពោះសហគមន៍មនុស្ស ដែលរស់នៅលើស្ថានីយនេះគឺជាអ្នកប្រមាញ់ បេះផ្លែឈើ នេសាទ ដាំស្រូវ និងជាសហគមន៍កុលសម្ព័ន្ធមានមេដឹកនាំ ហើយអ្នកស្រុកទាំងនោះប្រហែលមានទំនាក់ទំនងនឹងសម័យ

[៩៦] អ្នកស្រុកសំរោងសែនមានរបេះដើករកសម្បកលៀសយកទៅលក់តាំងពីសម័យមុនអាណានិគមបារាំងរហូតមក ដោយគេយកសម្បកលៀសនេះទៅធ្វើជាកំបោរស្រាប់ពិសាជាមួយស្លា និងម្ហូ។

[៩៧] លី វណ្ណា សៀវភៅថ្នាក់បណ្ឌិត *The Archaeology of Shell Matrix Sites In the Central Floodplan of the Tonle Sap River, Central Cambodia*, Sophia University, Japan ២០០២, p.២០៦,។

អង្គរ (Ly Vanna, ២០០២, p. ២០៩)។ លោកបានចាត់ស្ថានីយនេះជាស្ថានីយយុគលោហៈមួយយ៉ាងសំខាន់នៅក្នុងតំបន់។

២.៣.៣. ស្ថានីយបន្ទាយគូ

សព្វថ្ងៃនេះអ្នកនិពន្ធបានរកឃើញស្ថានីយបន្ទាយគូនៅកម្ពុជា៣៨ទីតាំង និងនៅវៀតណាមខាងត្បូង២៦ទីតាំង ស្ថានីយបន្ទាយគូទាំងនោះជាទូទៅ មានអង្កត់ផ្ចិតប្រមាណជា២៥០ម៉ែត្រទៅ ៣០០ម៉ែត្រ និងទំហំពី៤ហិចតា ទៅ៦ហិចតា។ ក្នុងនោះមានស្ថានីយបន្ទាយគូពីរដែលមានទំហំខុសធម្មតា ដែលមានអង្កត់ផ្ចិតតូចបំផុត ១១០ ម៉ែត្រ គឺស្ថានីយងឺ ដែលមានទំហំប្រហែលជា១ហិកតា ហើយស្ថានីយដែលធំបំផុតនោះគឺស្ថានីយត្របែក ដែលមានអង្កត់ផ្ចិតរហូតដល់៤៤៧ម៉ែត្រ មានទំហំប្រហែល១៦ហិកតា។ វិសាលភាពវិដ្ឋមាត្ររបស់ស្ថានីយបន្ទាយគូ បញ្ជាក់ពីទំហំស្ថានីយ ជាភស្តុតាងនៃការស្ថាបនា ដែលត្រូវការកម្លាំងពលកម្មជាច្រើន សម្រាប់បញ្ចប់ការងារកសាងស្ថានីយនីមួយៗ ។

ដូច្នេះប្រព័ន្ធរដ្ឋបាលមួយដ៏ចាំបាច់ ត្រូវការមេដឹកនាំត្រឹមត្រូវក្នុងការចាត់ចែង កសាងស្ថានីយនីមួយៗ។ ប្រសិនបើយើងមើលស្ថានីយឡុកតាន់២ (Loctan ២) មានទំហំ ១០ហិកតា និងស្ថានីយត្របែក ដែលមានទំហំជាង១៥ ហិកតានោះវិញ យើងឃើញថា រយៈពេលនៃការសាងសង់ស្ថានីយនីមួយៗ ត្រូវការយ៉ាងតិចបំផុតក៏ពីរខែដែរ ។ ការដឹកនាំស្ថាបនាស្ថានីយទាំងអស់នេះប្រាកដជាមានមេក្រុម ឬមេកុលសម្ព័ន្ធ ដែលសព្វថ្ងៃយើងអាចហៅថាជាប្រមុខរដ្ឋក៏បាន។

ចំពោះការរស់នៅរបស់មេក្រុមនេះ យើងមិនអាចសន្និដ្ឋានបានថា នៅស្ថានីយណាមួយបានទេដោយប្រភេទរូបសាស្ត្រស្ថានីយមានលក្ខណៈដូចៗគ្នាទាំងអស់។ ស្ថានីយមួយចំនួនមានរូបសាស្ត្រល្អចម្លែក ដោយមានកំពែងខ្ពស់ល្អ បាតគូជ្រៅ បរិវេណខាងក្នុងមានរាងជាបាតខ្ទះ។ ស្ថានីយមួយចំនួនតាំងទីនៅលើកំពូលរបស់ខ្ពង់រាបខ្ពស់ៗ ដែលមានដូចជា ស្ថានីយធួនស្នួល លំពែង១ ឡុកតាន់២ (Loctan ២)ហើយដែលសព្វថ្ងៃនេះ វានៅតែរក្សាបានភាពល្អដដែល បើយើងឈរពីលើស្ថានីយទាំងនោះ យើងអាចមើលឃើញនូវទិដ្ឋភាព ដ៏ស្រស់ស្អាតរបស់ទេសភាពនៅជុំវិញស្ថានីយ។

បន្ទាយគូបានបង្ហាញឱ្យឃើញនូវច្រកចេញចូលរហូតដល់ប្រាំពីរបែបខុសៗគ្នា ដែលស្ថានីយនីមួយៗ មានច្រកមួយ ឬពីរ។ ច្រកធំជាច្រកសំខាន់ សម្រាប់ការចេញចូលទូទៅ ឯច្រកតូចអាចជាច្រកសម្រាប់សត្វពាហនៈចេញចូល។ របកគំហើញវត្ថុសិល្បៈជា

ច្រើនប្រភេទ ត្រូវបានប្រទះឃើញនៅលើស្តានីយបន្ទាយគូ ដែលមានដូចជា កុលាលភាជន៍ និងឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម បញ្ជាក់ឱ្យឃើញថា សហគមន៍មនុស្ស ដែលរស់នៅក្នុងស្តានីយទាំងនោះ មានបច្ចេកទេសវិវត្តក្នុងការកសាងសហគមន៍របស់ខ្លួននៅក្នុងតំបន់ដោយមានទំនាក់ទំនងផ្នែកៈ

ក. លក្ខណៈសង្គម

ការធ្វើកសិកម្មនៅស្តានីយបន្ទាយគូ ដែលជាស្រូវភ្នំ ឬស្រូវចម្ការបានបន្សល់នូវភស្តុតាងតាមរយៈបំណែកកុលាលភាជន៍ គឺជាសក្ខីភាពនៃសង្គមដែលមានការរីកចម្រើន និងមានរចនាសម្ព័ន្ធដឹកនាំត្រឹមត្រូវ ហើយមានរបាយប្រជាជនច្រើន (Agricultural Cultural communities are generally permanent, with high population densities)។ មានហានៈក្នុងសង្គម ដែលបញ្ជាក់តាមប្រព័ន្ធកសាងស្តានីយនោះតែម្តងដោយស្តែងលើវិសាលភាពនៃការសាងសង់ស្តានីយធំៗទាំងនោះ។ ប្រសិនបើពុំមានអ្នកដឹកនាំដែលជាស្តេច ឬមេកន្ត្រាញទេនោះ ស្តានីយបន្ទាយគូមិនអាចកសាងបានរហូតដល់រាប់សិបនោះដែរ។ អ្នកនិពន្ធលើកសក្ខីកម្មខាងលើមកបង្ហាញដើម្បីគូសបញ្ជាក់នូវសម្មតិកម្មខាងដើមថា ស្តានីយបន្ទាយគូ គឺជាសណ្ឋាននៃការរៀបចំសហគមន៍នៃការកសាងរដ្ឋដំបូងៗ ដែលបានចាប់កំណើតនៅតំបន់ឥណ្ឌូចិន ជាពិសេសនៅកម្ពុជា តាំងពីប្រមាណ ២០០០ឆ្នាំ មុនសករាជ។

ខ. កសិកម្ម និងហត្ថកម្ម

តឹកតាងនៃការដាំស្រូវ ត្រូវបានឃើញយ៉ាងច្បាស់នៅលើបំណែកកុលាលភាជន៍ ។ យើងឃើញ ស្លាកស្នាមគ្រាប់ស្រូវ ដែលមនុស្សនៅក្នុងអរិយធម៌នេះបានបន្សល់ទុក។ យើងអាចសន្និដ្ឋានបានថា ជាប្រភេទស្រូវបុកដាំ (ប្រភេទស្រូវបុកដាំនៅតំបន់ខ្ពង់រាបដែលមានរហូតដល់សព្វថ្ងៃ) វាមិនមែនស្រូវស្រែទេ ក៏ប៉ុន្តែដោយសំណល់សម្បកអង្កាម ដែលនៅលាយជាមួយនឹងដីឥដ្ឋសម្រាប់ធ្វើក្អមឆ្នាំងនោះ វាមានសភាពរួញទៅតាមទំហំនៃដីឥដ្ឋនៅពេលដុត។ ម៉្យាងទៀតប្រសិនបើយើងមើលទៅលើច្រកចេញចូលរបស់ស្តានីយ ដែលជាទូទៅឃើញថា ស្តានីយមួយមានច្រកចេញ-ចូលចំនួនពីរ ដោយច្រកមួយឆ្ពោះទៅរកប្រភពទឹក និងច្រកមួយទៀតឆ្ពោះទៅទីវាលរបស់ខ្ពង់រាប ដែលអាចឱ្យយើងសន្និដ្ឋានបានថា ជាច្រកចេញចូលសម្រាប់ធ្វើកសិកម្ម ឬទំនាក់ទំនងផ្សេងៗ។

ប្រសិនបើយើងមើលស្ថានភាពបច្ចុប្បន្ននេះវិញឃើញថា ប្រជាជនដែលរស់នៅក្នុងតំបន់ខ្ពង់រាប គេដាំស្រូវចម្ការ ដែលជាប្រភពស្រូវសម្រាប់ទ្រទ្រង់ជីវិតរបស់ពួកគេ

ប្រចាំឆ្នាំ ហើយប្រហែលប្រជាជននៅទីនោះសព្វថ្ងៃបានបន្តប្រពៃណីដាំស្រូវភ្នំតាំងពីអតីតកាលមក។

ក្រៅពីដំណាំស្រូវ សត្វស្រុកប្រហែលជាត្រូវបានចិញ្ចឹមដូចគ្នានេះដែរ។ រហូតមក ដល់បច្ចុប្បន្ននេះ មិនឃើញមានស្លាកស្នាមសំណល់ឆ្អឹង ស្នែងសត្វ ឬសារធាតុសរីរាង្គអ្វីផ្សេងទៀតបន្សល់ទុកឡើយ ដោយសារសមាសធាតុដីនៅលើស្ថានីយទាំងនោះសម្បូរជាតិអាស៊ីតខ្លាំង ដែលមានpH≤៤។ ប៉ុន្តែយើងអាចសន្និដ្ឋានបានថា ប្រហែលជាមានការចិញ្ចឹមសត្វជាក់នៅក្នុងគូ ដោយយើងឃើញថា បាតគូទំនងជាកន្លែងចិញ្ចឹម ឬជាក្រោលគោ ក្របី ឬក៏ជ្រូកច្រើនជាង។ ព្រោះថា គូ មិនមែនជាប្រឡាយសម្រាប់ផ្ទុកទឹកទេ តែវាអាចប្រើសម្រាប់បង្ហូរទឹកនៅពេលរដូវវស្សាកុំឱ្យជន់លើផ្ទៃស្ថានីយ។

ឧបករណ៍ដីដុត ដែលយើងអាចសម្គាល់ថា «ខ្នារ» ជាប្រភេទឧបករណ៍សម្រាប់ផលិតអំបោះ ត្រូវបានរកឃើញនៅក្នុងស្ថានីយបន្ទាយគូ ដែលសបញ្ជាក់ឱ្យឃើញថា សហគមន៍មនុស្សនាពេលនោះ មានបច្ចេកទេសចេះត្បាញអំបោះ។ ថ្វីបើយើងមិនឃើញមានអំបោះឬក្រណាត់ នៅក្នុងស្ថានីយក៏ដោយ តែការរកឃើញ «ខ្នារ» បានបង្ហាញឱ្យយើងឃើញថា សហគមន៍នោះជាក្រុមមនុស្ស ដែលមានអរិយធម៌ខ្ពស់ មានសម្លៀកបំពាក់ត្រឹមត្រូវ ។

តាមរយៈកំណាយបុរាណវិទ្យា យើងបានជួបប្រទះកុលាលភាជន៍ជាច្រើន ហើយដែលវាមានប្រភេទ និងទម្រង់ខុសៗពីគ្នា ព្រមទាំងក្បាច់លម្អផ្សេងៗជាច្រើនទៀត។ កុលាលភាជន៍ទាំងនោះ គឺជាឧបករណ៍ចាំបាច់សម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ។ ចំពោះនៅក្នុងពេលបច្ចុប្បន្ននេះវិញ ក៏យើងឃើញមានការផលិតក្អម ឆ្នាំង នៅក្នុងខេត្ត និងតំបន់មួយចំនួនក្នុងប្រទេសកម្ពុជា ដោយនៅប្រើបច្ចេកទេសបុរាណដូចជា ក្លឹង ស្លឹកក សម្រាប់ស្មូនក្អម ឆ្នាំងទាំងនោះដែរ។ យើងបានប្រទះឃើញក្លឹងមួយចំនួន នៅក្នុងស្ថានីយបន្ទាយគូ ដែលសបញ្ជាក់ឱ្យឃើញថា ពួកគេជាអ្នកស្មូនដ៏ពូកែ។ ជាងនេះទៅទៀតរាល់ស្ថានីយបន្ទាយគូទាំងអស់ កុលាលភាជន៍ត្រូវបានប្រទះឃើញច្រើនជាងឧបករណ៍ថ្ម។

ជំនីកពស្លាក់ ឬដឹងពស្លាក់ ដែលជាឧបករណ៍ប្រើប្រាស់ធ្វើអំពីថ្ម ត្រូវបានឃើញនៅរាយប៉ាយលើគ្រប់ស្ថានីយបន្ទាយគូ ដែលយើងស្គាល់បានថា ជាប្រភេទពូថៅថ្មនៅសម័យនោះ ហើយដែលបច្ចុប្បន្ននេះ អ្នកស្រុកក្នុងតំបន់មួយចំនួនយល់ថាជាកាំរន្ទះ ឬផ្លែរន្ទះ។ កស្តុតាងដែលបន្សល់ទុកទាំងនេះ ប្រាកដណាស់ថា វាជាប្រភេទឧបករណ៍ថ្មរំលីង ដែលមនុស្សរស់នៅលើស្ថានីយបន្ទាយគូបានផលិតសម្រាប់ប្រើនៅក្នុងជីវភាពប្រចាំថ្ងៃរបស់ពួកគេ។ ពូថៅថ្មធម្មតា ពូថៅថ្មមានស្មា ថ្មសំលៀង និងផ្លែដឹង បានបង្ហាញថា បុព្វការីជនទាំង

នោះមានភាពប៉ិនប្រសព្វនៅក្នុងការផលិតឧបករណ៍ប្រើប្រាស់ទាំងនោះសម្រាប់ប្រកបរបរកសិកម្ម។ ម៉្យាងទៀត សំណល់អង្កាមនៅលើកុលាលភាជន៍ បញ្ជាក់ឱ្យឃើញយ៉ាងច្បាស់ថា អរិយធម៌នេះមានប្រពៃណីដាំស្រូវជាយូរលង់ណាស់មកហើយ។

គ. គមនាគមន៍

ប្រហែលសត្វពាហនៈ ជាមធ្យោបាយមួយយ៉ាងសំខាន់សម្រាប់គមនាគមន៍ និងរបរកសិកម្ម នាសម័យកាលនោះ។ ក្រៅពីនេះប្រភពទឹកដែលមានព្រែកឆ្លង ទន្លេចាំ(ឬទន្លេចាម ឬទន្លេដុងណាយ)ដែលហូរចាក់ទៅ ទន្លេសៃហ្គន(ទន្លេព្រៃនគរ) ប្រហែលជាប្រភពដ៏សំខាន់មួយទៀតសម្រាប់គមនាគមន៍ ។ ផ្លែពន្លាក ប្រហែលជាឧបករណ៍ មួយសំខាន់ប្រើសម្រាប់កាប់ ឬចាំងឈើធ្វើទូក ក៏ប៉ុន្តែយើងមិនមានស្លាកស្នាមរបស់ទូក ឬក្បូន សម្រាប់ធ្វើការបញ្ជាក់នោះទេ។ ទំនាក់ទំនងពីតំបន់មួយទៅតំបន់មួយ ពីស្ថានីយមួយទៅស្ថានីយមួយ ត្រូវបានធ្វើ ប្រហែលដោយមធ្យោបាយប្រើសត្វពាហនៈ ទូក ឬក្បូននេះឯង សម្រាប់ដោះដូរទំនិញ ជាមួយសហគមន៍ដទៃទៀតនៅក្នុងតំបន់។

ឃ. ពាណិជ្ជកម្ម

បទពិសោធនៃការប្រើផេះឈើចដោយមិនមានអំបិល ជារឿងមួយសំខាន់របស់អ្នកស្រុកភ្នំ នៅតំបន់ខ្ពង់រាបខាងកើតទន្លេមេគង្គ ប៉ុន្តែផេះឈើចនេះមិនគ្រប់គ្រាន់ ហើយក៏មិនអាចជួយឱ្យក្រុមមនុស្សនាសម័យកាលនោះមានសុខភាពល្អទេ។ ជំនួញអំបិលប្រហែលជាមានរវាងអ្នកដែលរស់នៅឆ្ងាយពីសមុទ្រ និងអ្នកនៅជិតសមុទ្រ។ យើងបានប្រទះឃើញកុលាលភាជន៍ ដែលគេប្រើសម្រាប់ផលិតអំបិល នៅតាមស្ថានីយមួយចំនួនក្បែរសមុទ្រប្រទេសវៀតណាម។

ម៉្យាងទៀតការដោះដូររបស់របរផ្សេងៗទៀតដូចជាត្រី និងគ្រឿងលម្អ ប្រហែលជាត្រូវធ្វើទំនាក់ទំនងទៅនឹងទន្លេសាប ឬទន្លេមេគង្គ ដែលជាប្រភពត្រីដ៏សំខាន់ជាយូរលង់ណាស់មកហើយ។ វាអាចពាក់ព័ន្ធទៅនឹងស្ថានីយនៅសួង នៅពាមជាំង ដែលអាចធ្វើដំណើរឆ្លងទន្លេមកស្ថានីយចម្ការអណ្តូង។ ម៉្យាងទៀតចលនាទឹកសមុទ្រប្រហែលជាមានការប្រែប្រួលខ្លាំង (ដោយសំអាងលើការស្រាវជ្រាវអំពីកម្ទេចកំណនៅបាតទន្លេសាប បានបញ្ជាក់ថាប្រហែល៥៥០០ ឆ្នាំមុនបច្ចុប្បន្ន (BP) ទន្លេមេគង្គបាននាំកម្ទេចកំណមកចាក់

នៅបឹងទន្លេសាប)[៩៨] ។ កត្តាទាំងនេះបញ្ជាក់ឱ្យដឹងថាកំពស់ផ្ទៃទឹកសមុទ្រប្រហែលជានៅខ្ពស់នៅឡើយ ដែលធ្វើអោយវិស័យគមនាគមន៍តាមផ្លូវទឹកក្លាយជារឿងសំខាន់មួយ។

កងធ្វើអំពីកែវ និងអង្កាំ មិនអាចថាជាការផលិតនៅលើស្ថានីយបន្ទាយគូបានទេ ការពិសោធទៅលើកងធ្វើអំពីកែវនាំឱ្យយើងសន្និដ្ឋានបានថា ទំនាក់ទំនងពាណិជកម្ម ប្រាកដជាមានជាមួយមនុស្សនៅតំបន់ផ្សេង ដែលអាចមកពីតំបន់បី ដែលគេចាត់ទុកជាមជ្ឈមណ្ឌលផលិតកែវមុនដំបូង ហើយបាននាំចូលមកក្នុងតំបន់អាស៊ីអាគ្នេយ៍ ទីមួយនៅប្រទេសឥណ្ឌា ទីពីរនៅប្រទេសចិន និងទីបីនៅតំបន់មេឌីទែរ៉ានេ។ តាមលទ្ធផលនៃការពិសោធទៅលើកងធ្វើអំពីកែវ ដែលបានមកពីកំណាយស្ថានីយក្រែក៥២/៦២ ឃើញថាមានសមាសធាតុស្រដៀងគ្នាទៅនឹងបំណែកកងធ្វើអំពីកែវផលិតនៅប្រទសឥណ្ឌា (លោក គ្លូវើ និងលោក ហោន ឌែសុន ១៩៩៥)។

នេះជាសក្ខីកម្មមួយ អាចសន្និដ្ឋានថា បុព្វការីជនដែលរស់នៅលើស្ថានីយបន្ទាយគូ មានទំនាក់ទំនងពាណិជ្ជកម្មជាមួយនឹងបរទេស។

១. ឧបករណ៍សិល្បៈ

ឧបករណ៍សិល្បៈថ្មសំឡេងបានរកឃើញជាច្រើននៅលើស្ថានីយបន្ទាយគូ នៅឡុកនិញ និងនៅស្ថានីយហ្គ្រូសលីយេ។ អត្ថបទរបស់លោក ចច. កុងឌូមីណាស់ (G.Condominas)បាន ផ្តល់ព័ត៌មានថា ការផលិតថ្មសំឡេងគឺយកតាមគំរូអរិយធម៌បាក់សូនៀន (Basonien) ឬក៏ក្នុងសម័យដើមនៃយុគថ្មរំលើង (Neolithic Time) នៅឧបទ្វីបឥណ្ឌូចិន។ បន្ទះថ្មសំឡេងមានរាងទ្រវែង គឺជាឧបករណ៍តន្ត្រីមួយប្រភេទនៅដើមសម័យយុគថ្មរំលើង។ វាអាចបញ្ជាក់ឱ្យយើងដឹងថាអរិយធម៌មេមត់បានរក្សាប្រពៃណីសិល្បៈរបស់ខ្លួនជាយូរអង្វែងណាស់មកហើយ។

សរុបការសិក្សាស្ថានីយបន្ទាយគូទាំងនោះ បានផ្តល់ឱ្យយើងយល់ថែមទៀតនូវការកត់សម្គាល់អំពីការតាំងទីលំនៅក្នុងតំបន់ដ៏សំបូរបែប ដែលមនុស្សសម័យមុននៅតំបន់នោះបានកសាងឡើង។ លក្ខខណ្ឌធម្មជាតិក្នុងតំបន់ មានលក្ខណៈអំណោយផលដល់ការរស់នៅរបស់មនុស្សទីនោះ គ្មានព្យុះ គ្មានទឹកជំនន់ ដូចតំបន់ដីសណ្តមេគ

[៩៨] Allen & Unwin: However, *recent long-term sedimentation studies show that net sedimentation within the lake proper has been in the range of 0.9-0.9៦ mm/year since ca. ៥៥00 years before present (BP)*, The Mekong: Sydney, ២0000.

ង្គក្រោមទេ។ មានសីតុណ្ហភាពក្តៅសើមទៀងទាត់ មានប្រព័ន្ធទន្លេ ព្រៃក បឹងត្រពាំង ខ្ទាត់ខ្ទែង មានជ្រលងភ្នំ ទំនាបតូចៗ និងជាតំបន់ដីក្រហមសម្បូរដីជីជាតិ នាំឱ្យមាន រុក្ខជាតិ និងសត្វព្រៃជាច្រើន។ ប៉ុន្តែលក្ខខណ្ឌអំណោយផលរបស់ធម្មជាតិ ក៏បានផ្តល់ នូវផលវិបាកខ្លះៗដល់ការរស់នៅរបស់មនុស្សដែរ ជាពិសេសនៅសម័យមុន ដូចជាព្រៃ ក្រាស់នាំឱ្យមានការពិបាកនៅក្នុងការធ្វើដំណើរ មានសត្វព្រៃសាហាវ ដែលជាការគំរាម កំហែងដល់អាយុជីវិតអ្នករស់នៅទីនោះ។ ការសង់កំពែងជាសក្តិកម្ម ដែលបុព្វបុរសធ្វើ ដើម្បីការពារសត្វសាហាវ មិនមែនសម្រាប់ការពារសត្រូវឡើយ ដោយស្ថានភាពកំពែង នៃស្ថានីយបន្ទាយគូទាំងនោះមានភាពងាយស្រួលចូលពីខាងក្រៅ ដូច្នេះនៅលើកំពូល កំពែងប្រហែលត្រូវបានធ្វើជារបងការពារ។

ដើម្បីស្ថិរភាព និងការរីកចម្រើនរបស់ខ្លួន មនុស្សសម័យមុនបានកសាងទី ជម្រកបន្ទាយគូនេះឡើង សម្រាប់ងាយស្រួលក្នុងការការពារខ្លួន ងាយស្រួលដល់ការ ប្រាស្រ័យទាក់ទងគ្នាក្នុងកុលសម្ព័ន្ធ ក៏ដូចជារៀបចំ ការបរបាញ់ បេះផ្លែឈើ និងធ្វើ កសិកម្មជាដើម។ ដោយហេតុនេះហើយ ស្ថានីយបន្ទាយគូភាគច្រើនត្រូវបាន កសាង ឡើងមានលក្ខណៈប្រមូលផ្តុំជាក្រុម ដែលនៅក្នុងក្រុមនីមួយៗ មានទីតាំងស្ថិតនៅមិន ឆ្ងាយប៉ុន្មានពីគ្នា។ ទាំងនេះវាឆ្លុះបញ្ចាំងឱ្យឃើញយ៉ាងច្បាស់ថា នៅសម័យមុនមនុស្ស ដែលរស់នៅក្នុងស្ថានីយទាំងនោះចេះសាមគ្គីគ្នា ជួយការពារគ្នាក្នុងសង្គម ដែលឆ្លុះបញ្ចាំ ងឱ្យឃើញនូវអរិយធម៌មួយដ៏ពិសេសនៅក្នុងតំបន់។

ការរៀបចំនិងស្ថាបនាស្ថានីយ ដោយមានអ្នកដឹកនាំ ការធ្វើកសិកម្ម ហត្ថកម្មនៃ ការផលិតកុលាលភាជន៍ (ភាជន៍សម្រាប់ផលិតអំបិល) ផ្លែពន្លាកសម្រាប់ផលិតសង្ហារឹម ផ្សេងៗ (អាចជាឧបករណ៍សម្រាប់ចាំងទូក បម្រើគមនាគមន៍ជើងទឹក) កូនខ្លឹងបង្ហាញ ការផលិត សម្លៀកបំពាក់ កងដែលជាអលង្ការសម្រាប់បង្ហាញពីឋានៈយសក្នុងសង្គម ឧបករណ៍ថ្ម សំឡេង ដែលជាឧបករណ៍តន្ត្រីបញ្ជាក់អំពីសិល្បៈក្នុងសង្គម។

ភស្តុតាងទាំងអស់នេះអាចបញ្ជាក់ថា មនុស្សដែលរស់នៅលើស្ថានីយបន្ទាយគូ នៃអរិយធម៌មេមត់នេះ បានចាប់ផ្តើមរៀបចំសហគមន៍នៃការកសាងរដ្ឋដំបូងៗរបស់ខ្លួន មានរបៀបចាត់ចែង និងគ្រប់គ្រងការងារច្បាស់លាស់។ កត្តាទាំងអស់ដែលបានបង្ហាញ ក្នុងអត្ថបទស្រាវជ្រាវនេះ អ្នកនិពន្ធសន្និដ្ឋានថា ស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ គឺជា សណ្ឋានរដ្ឋដំបូងៗ ដែលកើតមានមុនសម័យប្រវត្តិសាស្ត្រ ពោលគឺរដ្ឋដែលកើតមានមុន សម័យនគរភ្នំ ឬហ្វូណន (អង្គរបុរី) នៅកម្ពុជាយើង។

ការស្រាវជ្រាវនេះនៅមានកម្រិត ដោយសារតែអ្នកនិពន្ធមិនមានលទ្ធភាពគ្រប់គ្រាន់ដើម្បីធ្វើកំណាយបុរាណវិទ្យា នៅលើទីតាំងដទៃទៀតនៃស្ថានីយបន្ទាយគូនៅកម្ពុជា និងនៅវៀតណាម ។ ម៉្យាងវិញទៀត ការសិក្សាលម្អិតទៅលើសំណល់វត្ថុបុរាណ និងការកំណត់កាលបរិច្ឆេទតាមវិធីសាស្ត្រកាបូន-១៤ (C-១៤) មិនទាន់អាចធ្វើបានច្រើនស្ថានីយ។ ដូច្នេះអ្នកនិពន្ធសូមផ្តល់ជាយោបល់ឱ្យមានការស្រាវជ្រាវបន្តឱ្យកាន់តែស៊ីជម្រៅជាងនេះទៀត ជាពិសេសគួរយកបច្ចេកទេសវិទ្យាសាស្ត្រទំនើប ដែលស្របទៅនឹងការរីកចម្រើននាពេលបច្ចុប្បន្ន ដូចជាការពិសោធកាបូន-១៤ (C-១៤) ដើម្បីឱ្យដឹងអាយុកាលរបស់ស្ថានីយ ឱ្យបានជាក់លាក់ និងគួរធ្វើការសិក្សាបន្ថែមដោយផ្តោតទៅលើកុលាលភាជន៍ បរិស្ថាន និងកំណាយបុរាណវិទ្យាឱ្យបានច្រើនស្ថានីយបន្ទាយគូទាំងនោះ។

២.៣.៤. ស្ថានីយព្រែកឆ្លូង (លោកសាស្ត្រាចារ្យ ត្រឹង ថា)

នេះជាស្ថានីយថ្មរំលីងមួយទៀតដែលលោក B.P.Groslier បានរកឃើញនៅព្រែកឆ្លូង (ស្រុកមេមត់ខែត្រកំពង់ចាម) នៅឆ្នាំ១៩៦២ (១០)។ ជាយូរមកហើយលោក Groslier បានសិក្សាពីលើយន្តហោះនូវស្នាដៃធ្វើពីដីមានរាងមូល ដែលនៅរាយប៉ាយ ចាប់តាំងពីឡាបានសៀកដល់ឡុកនិញ (LocNinh) ក្នុងប្រទេសវៀតណាមខាងត្បូង ដោយឆ្លងកាត់តាមមេមត់ បានសេចក្តីថា ស្នាដៃទាំងនោះស្ថិតនៅក្នុងតំបន់ដីក្រហមនៃចម្ការកៅស៊ូធំៗ។

មានសញ្ញានិងសម្មតិកម្មជាច្រើនបានស្របគ្នា ជាហេតុនាំអោយលោក Groslier ជឿថាទីកន្លែងទាំងនោះជាទីលំនៅរបស់ជនជាតិខ្មែរដើម ។ ដូច្នេះ ដើម្បីធ្វើការបញ្ជាក់ពីគំនិតនេះ នៅឆ្នាំ១៩៦២ លោក Groslier បានជ្រើសរើសយកទីកន្លែងមួយនៅព្រែកឆ្លូងដើម្បីធ្វើកំណាយ ព្រោះកន្លែងនោះស្ថិតនៅចំកណ្តាលប្រព័ន្ធទាំងមូល។ ក្នុងការរុករកនេះ លោក Groslier បានរកឃើញរបស់ធ្វើពីថ្មនិងគ្រឿងចានឆ្នាំងមួយចំនួនធំ។ វត្ថុទាំងនោះបានបង្ហាញឱ្យឃើញថា នៅត្រង់កន្លែងដែលជាជំរំការពារយ៉ាងមាំមួននោះមានមនុស្សរស់នៅ ដោយមានការរៀបចំយ៉ាងហ្មត់ចត់ហើយ។ ជំរំដែលលោក Groslier បានសិក្សាមានកំពែងរាងមូលព័ទ្ធជុំវិញ (វិដ្ឋមាត្រជាង២០០ម.)ហើយមានផ្លូវចូលពីរ។ អាយុនៃជំរំមានប្រហែលពី១ ៥០០ ដល់៥០០ ឆ្នាំ មុនគ.ស.។ ប្រដាប់ប្រដាដែលធ្វើពីថ្មរំលីងមានរាងប្លែកៗខ្លះ មានរាងជាពងខ្លះ មានរាងជាចតុមុម យកលំនាំតាមរបស់ដែលធ្វើពីលង្ហិនដំបូង។ គ្រឿងចានឆ្នាំងមានរាងច្រើនបែបយ៉ាង ហើយមានក្បាច់រចនាល្អវិចិត្រ ប៉ុន្តែក្រោយមកបែរជាមានសភាពគ្រោតគ្រាតគ្មានលម្អអ្វីសោះ។ វត្ថុ

ទាំងអស់នេះគេចាត់ទុកថាជាស្នាដៃរបស់ជនជាតិខ្មែរដើម មុនពេលដែលជនជាតិនេះចុះមករស់នៅត្រង់វាលទំនាបនៃទន្លេមេគង្គ និងមុនពេលដែលបានទទួលអរិយធម៌ឥណ្ឌា។

២.៤. ប្រព័ន្ធសេដ្ឋកិច្ច

នៅសម័យបុរេប្រវត្តិសាស្ត្រ មនុស្សចេះបរបាញ់សត្វ ផ្សាំងសត្វ ធ្វើស្រែ នេសាទ ដាំថ្នាំសម្រាប់ជក់ និងបានប្រើប្រាស់វត្ថុផ្សេងៗពីលោហៈធាតុដូចជា កាក់ បន្ទោង កងដៃ ការ ទំហូ ក្រវិល អង្កាំ ត្បាញសំពត់សម្រាប់ស្លៀក ចេះប្រើឧករណ៍ភ្លេង ចេះប្រើទូក ចេះគូរគំនូរលម្អដោយប្រើពណ៌លើកុលាលភាជន៍និងរូងភ្នំ។ ចាប់ផ្តើមដំបូងមនុស្សចេះយករូងភ្នំជាលំនៅឋាន និងរស់នៅក្នុងជីវភាពជាអ្នកបរបាញ់ និងបេះផ្លែឈើស្រាប់នៅក្នុងព្រៃ។ ពេលក្រោយមក មនុស្សរស់នៅលើតំបន់ខ្ពង់រាប គេចេះធ្វើភូមិដ្ឋានផ្តុំគ្នា ដោយមានលើកកំពែងខ្ពស់ព័ទ្ធបិទបាំងភូមិ និងរស់នៅតាមរបៀបសេដ្ឋកិច្ចប្រមាញ់ផងនិងដាំដុះផង។ ពេលរស់នៅតំបន់វាលទំនាបដូចជានៅសំរោងសែន ម្លូព្រៃ គេចេះសង់ផ្ទះលើកជាជន្លល់ ផ្សាំងសត្វ នេសាទ និងដាំដុះ គឺធ្វើកសិកម្មដើម្បីរក្សាស្បៀងបម្រុង។ គេចេះធ្វើស្រែវស្សាដោយមានគំនិតធ្វើនយោបាយទឹក(ស្នាមព្រែកជីកបរមបុរាណនិងបន្ទាយគូឬភូមិមូល)។ ចេះប្រើគោ ក្របីសម្រាប់ជួយជាកម្លាំងអូសទាញ ចេះប្រើទូកធ្វើនាវាចរណ៍ និងចេះស្លលោហធាតុធ្វើឧបករណ៍សម្រាប់ប្រើប្រាស់។[៩៩]

សរុបមកប្រព័ន្ធសេដ្ឋកិច្ចនាសម័យបុរេប្រវត្តិសាស្ត្រកម្ពុជា វិស័យកសិកម្មមានការរីកលូតលាស់ដោយមានការគិតគូររៀបចំនយោបាយទឹក (ស្នាមព្រែកជីកបរមបុរាណនិងគូទឹកនៃបន្ទាយគូឬភូមិមូល)។ វិស័យសិប្បកម្មក៏មានការរីចម្រើនដែរ ដូចជាធ្វើទូក ស្លលោហធាតុធ្វើឧបករណ៍សម្រាប់ប្រើប្រាស់ និងឆ្លាក់គ្រឿងអលង្ការជាបន្ទោង កងដៃ ការ ទំហូ ក្រវិល អង្កាំ ត្បាញសំពត់សម្រាប់ស្លៀកជាដើម។ យើងពុំទាន់មានកស្តុតាងអំពីការធ្វើពាណិជ្ជកម្មនៅឡើយ។

២.៥. ជំនឿ ទំនៀមទម្លាប់ និងសាសនា

នាសម័យបុរេប្រវត្តិសាស្ត្រ ខ្មែរមានជំនឿហើយ។ ជំនឿនេះជាមធ្យោបាយធ្វើឱ្យខ្មែរមានសាមគ្គីធម៌។ ជំនឿញុំាងឱ្យមនុស្សដឹងបុណ្យ ដឹងបាប ស្គាល់សេចក្តីល្អ សេចក្តី

[៩៩] សៀវភៅប្រវត្តិសាស្ត្រកម្ពុជា (វង់ សុធារ៉ា និងណុប សុខា) ទំព័រ១៣ និងទំព័រ១៤។

អាក្រក់ ដែលបង្កើតបានជាសីលធម៌រួមមួយ។ សម័យនោះ ខ្មែរជឿលើព្រលឹង (ជីវចលនិយម) ដែលជឿថា វត្ថុ ទីកន្លែង រុក្ខជាតិ ធម្មជាតិ សំណង់ ឬអ្វីៗទាំងអស់នៅជុំវិញខ្លួនសុទ្ធសឹងមានវិញ្ញាណឬព្រលឹង។ គេជឿថាមនុស្សស្លាប់ទៅមិនសាបសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិជាថ្មីទៀត។ **អ្នកតា** ជាព្រលឹងនៃជនដែលស្លាប់ទៅហើយ តែនៅថែរក្សាមើលសុខទុក្ខដល់កូនចៅតទៅទៀត។ ដើម្បីគោរព**អ្នកតា** គេយកដុំថ្មទៅដាក់តម្កល់ហើយគោរពជាអ្នកតា។ ម្យ៉ាងទៀតនៅភូមិមូលខ្លះ គេបានរកឃើញបង្គោលថ្មនៅចំកណ្តាលភូមិ ជាហេតុនាំឱ្យគេជឿថា បង្គោលនោះទាក់ទងទៅនឹងជំនឿលើអ្នកតាម្ចាស់ស្រុក។ ជំនឿលើអ្នកតានេះ បានបន្សល់ទុករហូតដល់សព្វថ្ងៃ។

នាសម័យនោះ មនុស្សស្លាប់គេយកសពទៅដាក់ក្នុងក្រឡដោយអង្គុយ ដោយដាក់ដង្វាយផ្សេងៗមានរបស់របរប្រើប្រាស់ គ្រឿងអលង្ការ និងម្ហូបអាហារជាមួយ ហើយយកទៅកប់។ នេះបញ្ជាក់ពីជំនឿលើព្រលឹង និងបង្ហាញពីសីលធម៌ក្នុងទម្លាប់ ដឹងគុណដឹងទោស និងគោរពដល់អ្នកដែលបានស្លាប់ទៅ។ នាសម័យនោះ សង្គមកម្ពុជាបានលើកស្ត្រីជាធំ។ ផ្តល់តួនាទីដល់ព្រះនាង លីវ យី ឱ្យសោយរាជ្យនិងដឹកនាំនគរគោកធ្លក គឺជាកស្តុតាង។

ប្រហែល៣០០ឆ្នាំ មុនរជ្ជកាលព្រះរាជិនី លីវ យី អារិយធម៌ឥណ្ឌាបានចូលមកកម្ពុជាជាមួយពុទ្ធសាសនា។ ប្រជាជនខ្មែរមានសេចក្តីជ្រះថ្លាចំពោះអមតធម៌ បានពង្រីកអរិយធម៌ប្រកបដោយសីលធម៌និងមនុស្សធម៌ដែលមានស្រាប់មកហើយនោះ ឱ្យអរិយធម៌នេះរឹតតែមានគុណភាពប្រសើរវិសេសតាមពុទ្ធធម៌កើតជាពុទ្ធនិយមឡើងក្នុងអរិយធម៌ខ្មែរមុនគេបំផុត។[900] នេះសបញ្ជាក់បានថា នាសម័យនោះ សង្គមកម្ពុជាបានទទួលឥទ្ធិពលពុទ្ធសាសនាពីឥណ្ឌា។

សរុបមក នាសម័យបុរេប្រវត្តិសាស្ត្រ ខ្មែរយើងមានជំនឿ មានទំនៀមទម្លាប់មានសីលធម៌ផ្ទាល់ខ្លួន និងបានទទួលឥទ្ធិពលពុទ្ធសាសនាពីឥណ្ឌា។

ខ្មែរហៅប្រទេសកម្ពុជានៅសម័យដំបូងថាគោកធ្លក សព្វថ្ងៃនៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ ជាអតីតរាជធានីមួយដ៏ចំណាស់មួយរបស់ខ្មែរនៅសម័យមុនអង្គរ គឺសម័យនគរភ្នំ ឬសម័យហ្វូណន។ ទីក្រុងបុរាណនេះ មានទីក្រុងកំពង់ផៃមួយទៀតនៅភាគខាងត្បូងក្រុងនគរភ្នំ ប្រមាណជា៦៥គ.ម. តាមរយៈផ្លូវទឹកដែលជាព្រែកជីក កំពង់

[900] សៀវភៅ "ទស្សនវិជ្ជាបុរេប្រវត្តិ ហ្វូណន ចេនឡា" (លោកជំទាវបណ្ឌិតសភាចារ្យ ខ្លូត ធីតា) ទំព័រ៩៣

ផែនោះមានឈ្មោះថាអូរកែវ។ បច្ចុប្បន្ន អូរកែវស្ថិតក្នុងទឹកដីកម្ពុជាក្រោម (វៀតណាមភាគខាងត្បូង)។ នគរភ្នំឬហ្វូណន ជាឈ្មោះអាណាចក្របុរាណ ដែលមានកស្តុតាងបញ្ជាក់ក្នុងឯកសាររបស់ជនជាតិចិនថា ជារដ្ឋដំបូងគេក្នុងអាស៊ីបូព៌ាដែលទទួលឥទ្ធិពលពីវប្បធម៌ឥណ្ឌា។ រាជធានីខ្មែរសម័យហ្វូណនឬសម័យនគរភ្នំ ពិតជានៅអង្គរបុរី ខេត្តតាកែវសព្វថ្ងៃនេះ ដែលមានឈ្មោះជាភាសាសំស្ក្រឹតថា នរវរនគរ ដែលជាទីកន្លែងចាប់កំណើតនៃអារ្យធម៌ខ្មែរ សម័យនគរភ្នំ។ អរិយធម៌នគរភ្នំ (ហ្វូណន) ត្រូវបានបង្ហាញដោយអ្នកដំណើរជនជាតិឥណ្ឌាក្នុងស.វ ទី១ នៃគស បានបញ្ជាក់ថា ជារាជាណាចក្រមានក្រុងព័ទ្ធដោយកំពែង មានប្រព័ន្ធបង់ពន្ធដារ មានការនាំចូលទំនិញមានតម្លៃ និងមានអក្សរប្រើរបៀបហិណ្ឌូ។ វប្បធម៌របស់អាណាចក្រភ្នំគឺជាល្បាយនៃជំនឿ ជាមួយនឹងជំនឿឥណ្ឌាដើម។ នគរនេះត្រូវបានគេនិយាយថាមានឥទ្ធិពលយ៉ាងខ្លាំងដោយវប្បធម៌ឥណ្ឌា មានការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋមួយច្បាស់លាស់។ ប្រើអក្សរសំស្ក្រឹត គឺជាអក្សរផ្លូវការនៃអាណាចក្រភ្នំ មានសាសនាហិណ្ឌូជាកស្តុតាងនៃការប្រតិបត្តិ និងបន្ទាប់មកចាប់ពីសតវត្សទីប្រាំ គេឃើញមានកស្តុតាងព្រះពុទ្ធសាសនា បានចូលមកផងដែរ។ កំណត់ត្រាក្នុងសង្គមនគរភ្នំ បង្ហាញថាមានការយកប្រាក់ពន្ធ សង្គមត្រូវបង់ពន្ធជាប្រាក់មាស គុជខ្យង និងឈើក្រអូប ជាដើម។ ជនជាតិចិនពីរូបគឺ *កាងតៃ និង ជូយីង* បានរាយការណ៍ថា អាណាចក្រភ្នំ បានអនុវត្តទោសដោយតុលាការត្រូវបានគេបង្ហាញតាមរយៈការកាត់ក្តី មានវិធីសាស្ត្រជាច្រើនដូចជា ការយកច្រវាក់ដែកមួយក្រហមក្តៅ យកចិញ្ចៀនមាស និងស៊ុតពីក្នុងទឹកក្តៅ បរិភោគស្រូវ...។ កស្តុតាងខាងបុរាណវត្ថុភាគច្រើនទាក់ទងទៅនឹងកំណត់ត្រារបស់ប្រទេសចិន។ ចិនដែលបានរៀបរាប់អាណាចក្រភ្នំជាមនុស្សដែលរស់នៅលើផ្ទះសសរ ដាំដុះស្រូវ។

២.៦. សិលាចារឹកនៅអង្គរបុរី

លោកសាស្ត្រាចារ្យបណ្ឌិត វ៉ង់ សុធាវ៉ា បានបោះពុម្ពសៀវភៅដែលមានចំណងជើងថា សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ ភាគទី១, ឆ្នាំ២០០៣, ទំព័រទី៣៧ នៃមាតិកា នៅស្រុកអង្គរបុរី ខេត្តតាកែវ៖ ទួលវត្តគំនូរ, ឃុំព្រែកផ្ដោល, ចំនួន៩ផ្ទាំង។ ក្នុងអត្ថបទសិលាចារឹកវត្តគំនូរ K.៥៥៧ និង K.៦០០ នៅក្នុងស្រុកអង្គរបុរី ខេត្តតាកែវ លោកបានសរសេរថា៖ គេបានចុះបញ្ជីសិលាចារឹកទួលវត្តគំនូរពីរលេខខុសគ្នាដូចបានបង្ហាញខាងលើ ដោយយកបំណែកដែលមានសល់អក្សរ៣ បន្ទាត់ខាងចុង បោះពុម្ពផ្សាយឡើងវិញ នៅក្នុង Corpus (pl. XIII) របស់លោក លូ ហ្វីណូត ក្រោម ឈ្មោះ "ទួលវត្ត

គំនូរ" ក្នុងកម្រងឯកសារស៊េរីក្រោមចំណងជើងថា សិលាចារឹកកម្ពុជា (Inscriptions du Cambodge) តាមពិតបំណែកនេះជាផ្នាំងទិសខាងត្បូង នៃសិលាចារឹកទួលវត្តគំនូរ ដែលចារលើថ្មរាងស៊ីឡាំងធំមួយ កម្ពស់០,៨ម. និងជ្រុងបណ្តោយប្រវែង១,២ម.។ លោកម៉ូហ្សេបានផ្តាមសិលាចារឹកនេះ កាលពីឆ្នាំ១៩៣៥ នៅត្រើយខាងស្តាំនៃស្ទឹងអង្គរបុរី លើទួលវត្តគំនូរសព្វថ្ងៃ ចំណែកផ្នាំងខាងជើង និងខាងកើត នៅមានសភាពល្អអាចអានបានទាំងអស់ រីឯផ្នាំងខាងលិចវិញ ត្រូវបាត់អក្សរអស់ទាំងស្រុង ឃើញថាខូចខាតធ្ងន់ធ្ងរជាងផ្នាំងខាងត្បូងទៅទៀត គេបានយកផ្នាំងសិលាចារឹកដើមពីកន្លែងដើម មកទុកនៅសារមន្ទីរភ្នំពេញមួយរយៈ ហើយសព្វថ្ងៃនេះវាត្រូវគេរក្សាទុកនៅមន្ទីរអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប អំឡុងពេលប៉ុន្មានឆ្នាំមុននេះ មាននិស្សិតជាច្រើនក្រុម និងមុខជំនាញបានធ្វើការផ្តិតចម្លងទុកជាឯកសារ ក្នុងចំណោមនោះក៏មានក្រុមយើងជាអ្នកនិពន្ធនេះផងដែរ។

អត្ថបទត្រូវបានចារឹកជាភាសាខ្មែរ ចុះកាលបរិច្ឆេទ ឆ្នាំ៥៣៣សក: ឬ ៦១២គស។

(ចំណាំ៖ លោក សឺដែស ថា ត្រូវនឹងគ.ស.៦១១ ។ តែបើយើងគិតអំពីខែ និងថ្ងៃ (១៣កើត ខែមាឃ) ដែលគេចារឹក ឃើញថា គេតោងយកឆ្នាំនោះបូកនឹង៧៩ឆ្នាំវិញ ដើម្បីគណនារកកាលបរិច្ឆេទជាគ.ស.ឱ្យបានត្រឹមត្រូវ។ ពីព្រោះ៖ ពេលវេលាចែកឆ្នាំនៃសក: ឬមហាសករាជនៅរវាងពាក់កណ្តាលខែមីនា គឺយឺតជាងគ.ស.បីខែកន្លះប្រាយ ។ ហេតុនេះគេមិនអាចបូកនឹង៧៨ឆ្នាំបានឡើយ ។)

បរិយាយអំពីខ្ញុំបម្រើ ឬ អ្នកបម្រើការព្រះ ដីស្រែ និងសត្វពាហន: ដោយឡែកអ្នកបម្រើទាំងអស់នោះមានបញ្ជាក់ពីមុខការអាជីពរៀងៗខ្លួន មានអ្នករាំ អ្នកចម្រៀង តន្ត្រីករ ដែលស្ទើរតែទាំងអស់មានបញ្ជាក់ឈ្មោះជាភាសាសំស្ក្រឹត មានអ្នកបម្រើក្នុងអាសន: ព្រះ និងអ្នកធ្វើស្រែជាច្រើននាក់ ចំពោះអ្នកធ្វើអំណោយ មានឈ្មោះជាភាសាខ្មែរ គឺម្រតាញ អន្តារ អាចារ្យកន្ទិន និងបោញ ឧយហើយព្រះ ដែលពួកគេមានសទ្ធាជ្រះថ្លាធ្វើអំណោយជូន មាននាមខុសៗគ្នា ដូចជានៅផ្នាំងខាងជើង បញ្ជីឈ្មោះអ្នកបម្រើ នៅខាងដើមអត្ថបទគេបានថ្វាយចំពោះព្រះ(ទេវី) នាម «ល្បោញ កម្រតាង អញ» ដែលគួរតែត្រូវនឹងព្រះទេវីសរស្វតី បញ្ជីបន្ទាប់មកជាអ្នកបម្រើ ដែលគេ ថ្វាយចំពោះព្រះ «មហាគណបតី» (គឺព្រះគណេស)។ ចំណែកផ្នាំងខាងកើតជាបញ្ជីរាយនាមអ្នកបម្រើសម្រាប់ថ្វាយព្រះមួយអង្គ ដែលរួមគ្នាហៅថា «វៈកម្រតាងអញកម្រតាងតំរៅ» និងព្រះមួយអង្គទៀតដែលគេបញ្ជាក់នៅបន្ទាត់ខាងក្រោមបំផុតនាម «មណីស្វរៈ»។ សម្រាប់បំណែកនៃផ្នាំងខាងត្បូងបន្សល់តែឈ្មោះអ្នកបម្រើប៉ុណ្ណោះ។

កំពង់ផៃអូរកែវ ប្រហែលជាកំពង់ផៃដែលជនជាតិរ៉ូមស្គាល់ថាជា Kattigara Kirti-nagara "ទីក្រុងដ៏ល្បីល្បាញ" ឬជាផ្នែកមួយនៃនគរមានកេរ្តិ៍ឈ្មោះល្បីល្បាញ។ Kattigara គឺជាឈ្មោះដែលត្រូវបានផ្តល់ឱ្យដោយ Ptolemy ក្នុងសតវត្សទី២ នៃគ.ស។ អ្នកភូមិសាស្ត្រអាឡិចសាន់ឌឺ ក្លូឌាស តូលេមី (Claudius Ptolemy)ទៅកាន់ជីនៅច្រាំងខាងកើតបំផុត វាជាកំពង់ផៃសំខាន់នៃនគរសម័យមុនអង្គរ ដែលមានទីតាំងនៅកន្លែងមួយឥឡូវនេះហៅថា អូរកែវ។

ជាសរុប នគរភ្នំជារដ្ឋប្រទេសខ្មែរដំបូងដែលមានរចនាសម្ព័ន្ធសង្គមមានស្តេចសោយរាជ្យ ជាច្រើនតំណ តាំងពីមុនគ្រិស្តសករាជ អាចចាប់តាំងពីសតវត្សទី២ ឬទី៣ មុនគ្រិស្តសករាជ ក៏សឹងមាន។ សំណង់ស្ថាបត្យកម្ម ៖ កំពែងក្រុងអូរកែវ ព្រែកជីកបុរាណជាច្រើន សំណង់ប្រាសាទបុរាណជាច្រើន នៅជាកស្តុតាង។ សាសនា ៖ លទ្ធិព្រហ្ម ញ្ញ សិវលិង្គ សាសនាទ្រូនី។ ពាណិជ្ជកម្ម៖ កាក់ រ៉ូមាំង កំពង់ផៃអូរកែវ ការយកពន្ធអាករ ...។ សិប្បកម្ម៖ មានពុម្ពផៃលោហៈ កុលាលភាជន៍ ផលិតឥដ្ឋ។ កសិកម្ម៖ សាបព្រួស១ ឆ្នាំប្រមូលផល៣ឆ្នាំ... ទាំងនេះបង្ហាញថា នគរភ្នំជារដ្ឋស៊ីវិល័យដំបូងរបស់ខ្មែរនៅជាប់ឆ្នេរ មានឥទ្ធិពលគ្របដណ្តប់នៅមួយភាគធំនៃប៉ែកខាងត្បូងជ្រោយដីគោកនៅអាស៊ីអាគ្នេយ៍។

២.៧. សីលធម៌-យុត្តិធម៌

យោងតាមឯកសាររបស់សាស្ត្រាចារ្យ វង់ សុធារ៉ា ឯកសារចិនបាននិយាយអំពីអ្នកស្រុកហ្វូណាននិយមយុត្តិធម៌ និងសច្ចធម៌។ គេអាចធ្វើឱ្យមនុស្សមានសីលធម៌ប្រកបដោយប្រសិទ្ធភាព ដោយការប្រើយុទ្ធវិធីបែបចិត្តសាស្ត្រមួយ ធ្វើឱ្យអ្នកមានកំហុសខ្លាចទារុណកម្មមិនហ៊ានប្រព្រឹត្តនូវកំហុស។ នៅក្នុងជីវភាពរស់នៅគេចាត់ទុកដៃស្តាំជាដៃបរិសុទ្ធ ឯដៃឆ្វេងជាដៃមិនបរិសុទ្ធ។ រាល់ព្រឹកគេលុបលាងមុខចាក់ធ្មេញ អានសៀវភៅសូត្រធម៌ដោយស្ងាធ្យាយ។ នៅក្នុងសិលាចារឹកថា គេនិយមរាប់ញាតិដោយគេយកខ្សែស្រឡាយតាមម្តាយ។ ប៉ុន្តែក៏មានកំណត់ត្រាខ្លះរបស់ចិន បានបង្ហាប់អ្នកស្រុកហ្វូណានដែលថា ពេលធ្វើដំណើរចូលចិត្តសៀតអាវុធនៅនឹងចង្កេះ ហើយបើមានរឿងទាស់ទែងគ្នាបន្តិចបន្តួច ចូលចិត្តប្រឈោះ កាប់ចាក់គ្នាភ្លាមៗដៃរ។

ក្នុងករណីរកយុត្តិធម៌ គេបានតម្រូវឱ្យជនជាប់ចោទ សាកល្បងលូកក្នុងវត្តុរាវដាំពុះ, កាន់ដែកដុតក្តៅដើរឱ្យបាន៧ដំហាន, ស៊ីបាយពំនូតដែលគេបានសែកមន្តគាថា រួចដាក់តម្កល់មួយយប់នៅទេវស្ថាន, ដាក់ឱ្យសត្វស៊ី មាន ក្រពើ ឬខ្លា រួចចាំមើលបាតុភូតកើតឡើងបន្ទាប់ពីអនុវត្តន៍តាមវិធាន។ បើមិនរលាកដៃ មិនមានឈាមហូរចេញពីមាត់ ឬ

រឹងមាត់និយាយមិនរួច សត្វមិនស៊ីទេ គេចាត់ទុកជនសង្ស័យនោះគ្មានកំហុស។ ចិនថា ថ្វីបើគេប្រើវិធីពិសោធន៍បែបនេះ តែអ្នកស្រុកនេះចេះមន្តអាគមឆើតណាស់ ជនល្មើសកម្រមានសំណាងបានរួចខ្លួនឡើយ។

យោងតាមសៀវភៅប្រវត្តិសាស្ត្រ លោក ដាវីដ ឆាន់លឺ ទំព័រ២៩ នៅប្រទេសកម្ពុជាក្នុងសម័យមុនអង្គរ ហាក់បីដូចជាសញ្ញាណនៃកម្មសិទ្ធិដីធ្លីដែលគេអាចជាវបាន មិនបានចាក់ឫសដូចសញ្ញាណនៃសិទ្ធិប្រើប្រាស់ដីធ្លីទេ។ ដីធ្លីទាំងឡាយណាដែលគេទុកចោលមិនដាំដុះក្នុងរយៈពេលបីឆ្នាំ ក្លាយជាកម្មសិទ្ធិរបស់រដ្ឋវិញ។ ដោយសន្មតព្រះរាជាជាម្ចាស់ដីទាំងអស់ក្នុងព្រះរាជអាណាចក្រ ដែលមានន័យថា ទ្រង់អាចប្រទានដីជារង្វាន់ឱ្យគេបានប្រើប្រាស់ដីនោះ។ សិលាចារឹកជាភាសាខ្មែរជាច្រើននៅសម័យអង្គរ បានរៀបរាប់ពីរឿងជម្លោះដ៏ស្មុគស្មាញអំពីបញ្ហាសិទ្ធិកាន់កាប់ដីធ្លី និងកម្លាំងពលកម្ម ។

យោងតាមសៀវភៅប្រវត្តិសាស្ត្រ លោក ដាវីដ ឆាន់លឺ ទំព័រ៣១ ប៉ុន្តែកស្តុតាងអាចធ្វើឱ្យគិតថា សង្គមបុរេអង្គរនោះ គឺជាការប្រមូលផ្តុំរវាងអ្នកដឹកនាំនិងបក្សពួកដែលកាន់កាប់ទឹកដីតាមតំបន់ និងកាន់កាប់តួនាទីផ្សេងៗក្នុងសង្គម ហើយអ្វីៗទាំងនេះ គេរៀបចំទៅតាមទីតាំងកណ្តាលនិង តំបន់ជុំវិញ ស្របតាមទស្សនៈរបស់ឥណ្ឌាអំពី «មណ្ឌល»។ ដោយហេតុថា មានមជ្ឈមណ្ឌលចំនួនច្រើន បានជាប្រទេសកម្ពុជាជារដ្ឋវិមជ្ឈការ។ អ្វីដែលយើងចង់ហៅសង្គមនោះ បែងចែកជាផ្នែកតូចៗ ហើយ « សង្គម» ជាការផ្តុំគ្នានៃផ្នែកទាំងនេះ ដែលមានភាពឯកច្ឆន្ទពីគ្នា ឬក៏មានការពាក់ព័ន្ធនឹងគ្នាតែម្តងម្កាល ។

២.៨. ច្បាប់ទំនៀមសម្រាប់គ្រប់គ្រងសង្គម

២.៨.១. ច្បាប់ទំនៀម

យើងពុំមានកស្តុតាងឬសំណេរណាមួយមកបញ្ជាក់ថា នាសម័យបុរេប្រវត្តិសាស្ត្រកម្ពុជា យើងមានច្បាប់ឬវិធានសម្រាប់រៀបចំនិងគ្រប់គ្រងសង្គមឡើយ។ ប៉ុន្តែដោយសារនាសម័យបុរេប្រវត្តិសាស្ត្រនេះ សញ្ញាណនៃរដ្ឋបានកកើតរួចទៅហើយ។ លើសពីនេះ ខ្មែរយើងមានជំនឿ មានទំនៀមទម្លាប់ មានសាសនា និងមានសីលធម៌ផ្ទាល់ខ្លួនដែលជាមូលដ្ឋានគ្រឹះសម្រាប់រៀបចំជាវិធានរួមសម្រាប់ប្រតិបត្តិ។ ដូច្នេះ សង្គមខ្មែរនាសម័យនោះពិតជាមានច្បាប់ទំនៀមសម្រាប់រៀបចំរដ្ឋនិងគ្រប់គ្រងសង្គមឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ

ការរីកចម្រើន និងស្ថិរភាព។ ច្បាប់ទំនៀមទាំងនោះអាចមានប្រភពពីជំនឿ ទំនៀមទម្លាប់ សាសនា និងសីលធម៌សង្គមនេះឯង។

ជាក់ស្តែងការរៀបចំបន្ទាយគូឬកូមិមូលនីមួយៗ និងការរស់នៅជាកុលសម្ពន្ធរួមគ្នា ត្រូវមានច្បាប់ទំនៀមសម្រាប់គ្រប់គ្រង ទើបអាចរួបរួមគ្នាសាងសង់បានជាសំណង់នេះ និងរក្សាបាននូវសណ្តាប់ធ្នាប់និងស្ថិរភាពនៃការរស់នៅជាសង្គម។ បើគ្មានច្បាប់ទំនៀមរួមណាមួយសម្រាប់គ្រប់គ្រងទេ គេមិនអាចប្រមូលផ្តុំកម្លាំងលើកដីធ្វើកំពែង ជីកប្រឡាយទឹកជុំវិញកំពែង មិនអាចការពារសមាជិកកុលសម្ព័ន្ធពីការយាយីនិងឈ្លានពានពីសត្វសាហាវនិងក្រុមកុលសម្ព័ន្ធផ្សេងទៀត ហើយក៏មិនអាចរួមរស់ជាក្រុម ជាកុលសម្ព័ន្ធបានយូរអង្វែងឡើយ។

ការរៀបចំជារដ្ឋមួយបានត្រូវតែមានច្បាប់ទំនៀមសម្រាប់គ្រប់គ្រង។ បើគ្មានច្បាប់ទំនៀមទេ មិនអាចបង្កើតជានគរគោកធ្លកដែលមានសណ្តាប់ធ្នាប់និងស្ថិរភាពបានឡើយ។

សម័យហ្វូណន និងសម័យចេនឡាដែលមានអរិយធម៌រុងរឿង គឺបានទទួលមរតកពីសម័យបុរេប្រវត្តិសាស្ត្រ ដូចគ្នានិងសម័យអង្គរដែលបានទទួលសមិទ្ធផលជាមរតកនៃសម័យហ្វូណននិងសម័យចេនឡា ទើបក្លាយជាសម័យកាលដ៏រុងរឿងថ្កុំថ្កើងបំផុតរបស់កម្ពុជា។ ទាញចេញពីសម្មតិកម្មនេះ យើងអាចសន្និដ្ឋានបានថា ច្បាប់ទំនៀមដែលមានក្នុងសម័យហ្វូណន មានប្រភពចេញពីច្បាប់ទំនៀមនាសម័យបុរេប្រវត្តិសាស្ត្រ គ្រាន់តែអាចធ្វើការកែសម្រួលផ្លាស់ប្តូរស្របតាមការវិវត្តនៃសង្គមប៉ុណ្ណោះ។ ដូច្នេះសម័យបុរេប្រវត្តិសាស្ត្រនេះ ពិតជាមានច្បាប់ទំនៀមដែលមានប្រភពចេញពីទម្លាប់ជាប់ជាទំនៀមជាប្រពៃណីរបស់អ្នកស្រុក និងមានប្រភពចេញពីសាសនាសម្រាប់គ្រប់គ្រងសង្គម។

២.៨.២. យន្តការដោះស្រាយវិវាទ

ការរួមរស់ជាសង្គម ចៀសពុំផុតពីការកើតជាជម្លោះ កើតជាទំនាស់ កើតជាវិវាទឡើយ។ បើមានជម្លោះ មានទំនាស់ ឬមានវិវាទកើតឡើង ហើយគ្មានយន្តការនិងច្បាប់ឬវិធានដោះស្រាយទេ សង្គមនោះក៏មិនអាចមានសណ្តាប់ធ្នាប់ មានសន្តិសុខ និងមានស្ថិរភាពដែរ។ ដូច្នេះយើងអាចសន្និដ្ឋានថា នាសម័យកាលនោះមានបុគ្គល(អាចជាមេកន្ត្រាញនៃកុលសម្ព័ន្ធឬព្រះមហាក្សត្រ) និងយន្តការដោះស្រាយវិវាទជាមិនខាន។ ប៉ុន្តែគួរឱ្យសោកស្តាយដែលពុំមានភស្តុតាងបន្សល់ទុក សម្រាប់ធ្វើការសិក្សាស្រាវជ្រាវលើយន្តការដោះស្រាយវិវាទក្នុងសម័យកាលនោះបាន។

ជំពូកទី ៣.
សម័យហ្វូណន

ប្រវត្តិសាស្ត្រកម្ពុជាសម័យហ្វូណនចាប់ផ្តើមនៅឆ្នាំ៥២នៃគ្រិស្តសករាជ ដល់ឆ្នាំ ៥៥០នៃគ្រិស្តសករាជ គឺចាប់រាប់ពីរជ្ជកាលព្រះបាទ ហ៊ុន ទៀន-លីវ យី។ តាមឯកសារ ដែលបានកត់ត្រា ក្នុងសម័យនេះមានព្រះមហាក្សត្រចំនួន១៤ អង្គសោយរាជ្យ។

៣.១. រចនាសម្ព័ន្ធគ្រប់គ្រងសង្គម

៣.១.១. ទម្រង់នៃការគ្រប់គ្រង

សម័យហ្វូណន របបនយោយបាយនៅកម្ពុជាគឺរាជាធិបតេយ្យ ដែលអនុវត្ត នយោបាយដឹកនាំតាមបែបឥណ្ឌា។ អធិរាជអាណាចក្រហ្វូណន(អាណាចក្រភ្នំ) និយម ធ្វើនយោបាយពង្រីកទឹកដី ដោយព្រះរាជាលើកទ័ពវាយយកបានរដ្ឋជាច្រើនដាក់ជារដ្ឋ ចំណុះឬសាមន្តរដ្ឋ។ ដោយហេតុនេះ គេនិយាយថា អាណាចក្រហ្វូណនជាអធិរាជាណា ចក្រ ហើយព្រះរាជាមានឋានៈជាមហារាជ។ រដ្ឋដែលស្ថិតក្រោមអំណាចគ្រប់គ្រងរបស់ អាណាចក្រហ្វូណនសុទ្ធតែមានស្តេចសោយរាជ្យ ប៉ុន្តែស្តេចទាំងនោះជាសាមន្តរាជ របស់អធិរាជាអាណាចក្រហ្វូណន ហើយត្រូវលើកសួយសារអាករមកថ្វាយមហារាជជា រៀងរាល់ឆ្នាំ។[909] ព្រះរាជាមានឋានន្តរនាមជា "ក្រុងវ្នំ" ព្រោះយកតាមភ្នំដែលព្រះអង្គ យាងឡើងទៅធ្វើសក្ការបូជាចំពោះព្រះមហេស្វរ និងតម្កល់លិង្គព្រះគិរិស (ឈ្មោះព្រះ ឥសូរដែលសណ្ឋិតនៅលើភ្នំនោះ)។ ដោយហេតុនេះព្រះអង្គមានឋានៈជាតំណាងអទិ ទេព ដូច្នេះហើយបានជាអំណាចរបស់ព្រះអង្គទូលំទូលាយណាស់ (ម្ចាស់ទឹកដី ម្ចាស់ លើប្រជានុរាស្ត្រ)។

ចំពោះនយោបាយក្រៅប្រទេស អាណាចក្រហ្វូណនមានទំនាក់ទំនងជាមួយ ប្រទេសមួយចំនួនដូចជាឥណ្ឌា ចិន ជាដើម។ ដោយឡែកនយោបាយក្រៅប្រទេសក្នុងវិ ស័យពាណិជកម្ម គឺបើកចំហដើងមេយដោយឱ្យបរទេសចូលមកធ្វើពាណិជ្ជកម្មជាមួយ អ្នកស្រុកដោយសេរី។

សម័យកាលនោះមានប្រព័ន្ធបង់ពន្ធជារួចហើយ។ អ្នកស្រុកត្រូវបង់ពន្ធជារជូន រាជការជាមាស ប្រាក់ ត្បូង គុជ ឬគ្រឿងក្រអូបផ្សេងៗ។

---

[909] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា)"។

៣.១.២. ប្រព័ន្ធសេដ្ឋកិច្ច

សកម្មភាពសេដ្ឋកិច្ចចម្បងនៅសម័យហ្វូណនគឺ កសិកម្មនិងពាណិជ្ជកម្ម។ វិស័យកសិកម្មមានការរីកលូតលាស់ខ្លាំងណាស់។ នេះដោយសារការអនុវត្តនយោបាយទឹកទទួលបានជោគជ័យ។ អ្នកស្រុកចេះជីកព្រែកខ្វាត់ខ្វែងដែលបន្សល់ទុកដល់សព្វថ្ងៃនៅត្រង់កម្ពុជាក្រោមភាគខាងលិច។ ព្រែកជីកនេះ ក្រៅពីបំពេញនាទីជាប្រព័ន្ធស្រោចស្រពបានដើរតួនាទីសម្រាប់បង្ហូរទឹកជំនន់ទន្លេមេគង្គ ទៅលាងបន្សាបជាតិអំបិលលើដីសម្រាប់នាំយកដីល្បាប់មានជីជាតិ និងជាផ្លូវគមនាគមន៍ផងដែរ។ តាមឯកសារចិននិយាយថា គេធ្វើស្រូវមួយឆ្នាំបានបីដង។ ក្រៅពីធ្វើស្រែ មានការដាំក្រូច ទទឹម អំពៅ ស្លា។ល។

វិស័យពាណិជ្ជកម្មក៏មានការរីកលូតលាស់ផងដែរ។ កស្តុតាងគេបានរកឃើញស្នាមកំពង់ផៃសមុទ្រយ៉ាងធំមួយគឺកំពង់ផៃអូកែវ។ គេសន្និដ្ឋានថា កំពង់ផៃនេះជាកំពុងផៃអន្តរជាតិ ពីព្រោះផ្អែកលើកំណាយនៅតំបន់នោះបានរកឃើញវត្ថុផ្សេងៗដែលមកពីប្រទេសឆ្ងាយៗដូចជា ចក្រភពរ៉ូម៉ាំង ចក្រភពអ៊ីរ៉ង់ ឥណ្ឌា។ ដូច្នេះនៅសម័យនោះ អ្នកស្រុកហ្វូណនបានធ្វើជំនួញជាមួយប្រទេសនានាដូចជាចិន ឥណ្ឌា រ៉ូម៉ាំង និងពែរ្ស។ តាមកំណត់ត្រាចិនថា នៅស្រុកនេះ ស្រីៗពូកែរកស៊ីណាស់។ ទំនិញដែលគេលក់ដូរច្រើនជាមាស ប្រាក់ សំពត់ព្រៃ គ្រឿងកែវ ។ល។

ឯកសារចិនបាននិយាយថា អាណាចក្រហ្វូណនជាកន្លែងកើតមាស ប្រាក់ ទង់ដែង សំណបាហាំង គ្រឿងក្រអូប ភ្លុកដំរី និងពេជ្រ។ ពេជ្រគេមុជទៅរកនៅបាតសមុទ្រ ហើយមានភាពរឹងណាស់យកដែកដំមិនខូចទេ តែខូចដែកវិញ។ ម៉្យាងទៀតអ្នកស្រុកប៉ិនប្រសប់ណាស់ក្នុងរបរធ្វើជាងមាសឬប្រាក់ សូនរូប ត្បាញសូត្រចរបាប់ ស្លៃកែវ ។ល។

ផ្អែកលើឯកសារនេះ យើងអាចវាយតម្លៃបានថា នាសម័យនោះ វិស័យរ៉ែ និងសិប្បកម្មក៏មានការរីកចម្រើនផងដែរ។

៣.១.៣. ប្រព័ន្ធសង្គមកិច្ច

នាសម័យនោះ មានការយកចិត្តទុកដាក់លើប្រព័ន្ធសង្គមកិច្ចផងដែរ តាមរយៈការផ្តល់ជាព្រះរាជទ្រព្យនិងថ្វាយជាជីធ្លី ជាទ្រព្យសម្បត្តិផ្សេងៗ ជាខ្ញុំបម្រើ ដល់បូជនីយដ្ឋានសាសនានានា ការសាងសង់ផ្លូវ ការជីកស្រះទឹករួម និងជីកប្រឡាយជាដើម សម្រាប់បម្រើផលប្រយោជន៍សាធារណៈ។

ជាក់ស្តែងសិលាចារឹកវ៉ូកាញ់(Ka៧៤)ជាភាសាសំស្ក្រឹត ដែលជាសិលាចារឹកមានចំណាស់ជាងគេ នាចុងសតវត្សរ៍ទី២ ដើមសតវត្សរ៍ទី៣នៃគ្រិស្តសករាជ បកប្រែជាភាសាខ្មែរ *"ព្រះរាជាប្រទេសខ្មែរមួយអង្គព្រះនាមព្រះបាទស្រីមារៈ(គ្រីមារ) ជារាជកុល (ព្រះបាទហ្វាន់ចេម៉ាន់) ក្នុងសម័យនគរភ្នំ(ហ្វូណន) ទ្រង់ជាពុទ្ធមាមកជន ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ហើយទ្រង់ត្រាស់បង្គាប់ឱ្យចារឹកទុក ព្រោះទ្រង់ជ្រាបច្បាស់នូវដំណើរអន្ទោលស្លាប់កើតនៃសត្វលោកក្នុងវាលវដ្តសង្សារ(គតាគតិ) ទ្រង់មានមេត្តាជ្រាលជ្រៅចំពោះសត្វលោក ហើយបង្គាប់ឱ្យចំណាយព្រះរាជទ្រព្យ ធ្វើជាប្រយោជន៍ដល់សាធារណជនទូទៅ ឱ្យសមតាមព្រះរាជបំណងដែលទ្រង់មានព្រះទ័យប្រកបដោយមេត្តាករុណាប្រាថ្នាចង់ដោះទុក្ខសត្វដែលកំពុងតែហែលឆ្លងកាត់សមុទ្រសោតរ គឺសង្សារវដ្តៈ"* សិលាចារឹកនេះបញ្ជាក់អំពីទឹកព្រះទ័យរបស់ព្រះមហាក្សត្រអនុគ្រោះ អាណិតអាសូរ ជួយសង្រោះសត្វលោកចេញពីសង្សារវដ្ត ដោយបានចំណាយព្រះរាជទ្រព្យសម្រាប់បម្រើផលប្រយោជន៍ទូទៅរបស់សាធារណជន។

៣.១.៤. ជំនឿ ទំនៀមទម្លាប់ និងសាសនា

តាមឯកសារចិនបាននិយាយថា អ្នកស្រុកហ្វូណនសង់ផ្ទះខ្ពស់ផុតពីដីប្រក់ស្លឹកចាកដែលដុះនៅមាត់សមុទ្រ ហើយមានការតុបតែង។ ផ្ទះទាំងនោះសុទ្ធតែសង់ពីឈើដែលគេកាប់យកមកពីព្រៃ មានរបងព័ទ្ធជុំវិញ ហើយផ្តុំគ្នាជាភូមិមានពី៥០ ទៅ ៦០ផ្ទះ មានស្រះមួយសម្រាប់យកទឹកប្រើប្រាស់រួមគ្នា។ មនុស្សអាណាចក្រហ្វូណនគ្មានគំនិតរញ៉ៃមរញ៉ាំ ត្រង់ណាស់មិនចេះលួចទេ (ឯកសារខ្លះថាមានចិត្តលោភលន់) មានការបិនប្រសប់ ហើយខិលព្រោះចូលចិត្តចាប់យកមនុស្សនៅក្រុងជិតខាងដែលមិនព្រមគោរពរាប់អានខ្លួនមកធ្វើជាខ្ញុំកំដរ។ នៅពេលទំនេរគេចូលចិត្តលេងប្រជល់មាន់និងប្រជល់ជ្រូក។

សម័យនោះនៅនិយមស្រីជាធំ (មេនិយម) នៅឡើយ គឺគេទុកស្រីជាធំក្នុងគ្រួសារផង និងក្នុងសង្គមផង។ ក្នុងការរៀបការ ស្រីត្រូវទៅចូលស្តីដណ្តឹងប្រុស។ នៅពេលមនុស្សស្លាប់ គេលែងយកសពដាក់ក្នុងក្រឡយកទៅកប់ទៀតហើយ ដោយអនុវត្តតាមវិធីបួនយ៉ាងគឺ យកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី យកសពទៅចោលក្នុងទឹកទន្លេ យកសពទៅកប់ និងយកសពទៅបូជាប្រមូលធាតុដាក់ក្នុងកោដ្ឋ១បិទជិតហើយយកទៅបោះចោលក្នុងទឹកទន្លេ។ គេកាន់ទុក្ខដោយកោរសក់និងពុកមាត់។

ប្រជាជននៅប្រតិបត្តិពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង។ នាសម័យនោះអាណាចក្រហ្វូណន ទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងចំនួន២ លើក នៅដើមសត

វត្សរ៍ទី១ និងដើមសតវត្សរ៍ទី៥។[១០២] យើងសង្កេតឃើញថា ទោះបីព្រះមហាក្សត្របានប្រតិបត្តិព្រហ្មញ្ញសាសនាក្តី ក៏ព្រះអង្គបានបើកសិទ្ធិសេរីភាពពេញលេញដល់ប្រជាជនក្នុងការជ្រើសរើសជំនឿសាសនាដែរ។

លោក អាដេម៉ា ឡឺក្លែរ បានសរសេរថា "ប្រទេសឥណ្ឌាជាប្រភពនៃពួកអ្នកផ្សព្វផ្សាយអារ្យធម៌ដែលបាននាំយកព្រហ្មញ្ញសាសនាមកកាន់កោះជ្វា និងកន្លែងជាច្រើនទៀតនៃឥណ្ឌូចិន ប្រហែលនៅឆ្នាំ៧៨ នៃគ្រិស្តសករាជ។[១០៣]

ទោះបីជាកម្ពុជាបានទទួលឥទ្ធិពលអរិយធម៌ពីបរទេសក្តី ក៏ខ្មែរយើងបានកែច្នៃសម្របសម្រួលរវាងអរិយធម៌បរទេសជាមួយជំនឿ ទំនៀមទម្លាប់ប្រពៃណីរបស់អ្នកស្រុកក្នុងគោលបំណងរក្សានូវអត្តសញ្ញាណខ្មែរ។ ជាក់ស្តែងក្នុងវិស័យសាសនា សង្គមកម្ពុជាមានភាពបិនប្រសប់ក្នុងការបន្សុីគ្នារវាងសាសនានានា ជាពិសេសរវាងពុទ្ធសាសនា និងព្រហ្មញ្ញសាសនាឱ្យមានលក្ខណៈរួមមួយ ដែលសង្គមទាំងមូលទទួលយកបាន និងពុំមានការបែកបាក់សង្គមធ្ងន់ធ្ងរឡើយ។

៣.២. ច្បាប់ទំនៀមសម្រាប់គ្រប់គ្រងសង្គម

៣.២.១. ច្បាប់ទំនៀម

ដើម្បីគ្រប់គ្រង និងរក្សាអាណាចក្រដ៏ធំល្វឹងល្វើយទាំងមូលឱ្យមានសណ្តាប់ធ្នាប់ សន្តិសុខ រីកចម្រើន និងស្ថិរភាពបានត្រូវមានច្បាប់ទំនៀមប្រកបដោយប្រសិទ្ធភាព។

តាមកំណត់ត្រាចិនបាននិយាយថា អ្នកស្រុកសម័យហ្វូណនបង់ពន្ធដារជូនរាជការជាមាស ប្រាក់ ត្បូង គជ់ ឬគ្រឿងក្រអូបផ្សេងៗ។ ប្រព័ន្ធពន្ធដារនេះជំរុញឱ្យអាណាចក្រហ្វូណនមានលទ្ធភាពពង្រីកទឹកដី។ ដើម្បីកំណត់អត្រាពន្ធដារ ប្រមូលពន្ធដារ គ្រប់គ្រងនិងបែងចែកប្រាក់ពន្ធ និងចាត់វិធានការចំពោះអ្នកមិនព្រមបង់ពន្ធដារ ត្រូវមានច្បាប់ទំនៀមក្នុងវិស័យពន្ធដារមួយច្បាស់លាស់។

ទោះជាយើងពុំមានភស្តុតាងឬសំណេរណាមួយមកបញ្ជាក់ថា នាសម័យហ្វូណនយើងមានច្បាប់ សម្រាប់រៀបចំ និងគ្រប់គ្រងសង្គមក៏ដោយ ក៏យើងអាចវាយតម្លៃបានថាសង្គមខ្មែរនាសម័យនោះពិតជាមានច្បាប់ទំនៀមសម្រាប់រៀបចំរដ្ឋ និងគ្រប់គ្រងសង្គមឱ្យ

[១០២] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា) ទំព័រទី៩៥។

[១០៣] សៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (អាដេម៉ារ ឡឺក្លែរ) ទំព័រទី៣៩ ដើងទំព័រទី៦១។

មានសណ្តាប់ធ្នាប់ សន្តិសុខ អភិវឌ្ឍន៍ និងស្ថិរភាព។ ច្បាប់ទំនៀមទាំងនោះអាចមានប្រភពពីជំនឿ ទំនៀមទម្លាប់ សីលធម៌ សាសនា ជាពិសេសព្រះរាជអាជ្ញា (ព្រះរាជបញ្ជា) របស់ព្រះមហាក្សត្រ។

៣.២.២. យន្តការដោះស្រាយវិវាទ

តាមឯកសារចិនបាននិយាយថា "**អ្នកស្រុកហ្វូណនចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរកសេចក្តីពិត**"។ កាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេព្តារួចគេអង្វរសូមឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះទៅចែកឱ្យពួកខ្ញុំបម្រើនៅក្នុងផ្ទះឱ្យបរិភោគ ក្នុងមាត់ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែង ហើយវាមិនអាចទំពារបាយផង ឯមាត់របស់ជនទៀងត្រង់បាយនោះរអិលទៅក្នុងមាត់យ៉ាងស្រួល។ ម៉្យាងទៀត បើកាលណាមានជនជាប់ចោទ គេឱ្យជននោះអត់បាយ៣ថ្ងៃ រួចគេតម្រូវឱ្យលូកយកវត្ថុផ្សេងៗចេញពីទឹកកំពុងពុះ ឬកាន់ពូថៅឬច្រវាក់ដុតក្រហមដើរ៧ជំហាន បើមានកំហុសមែនដៃរបស់ជននោះត្រូវរលាករលួយ ផ្ទុយទៅវិញ បើគ្មានកំហុសគ្មានអ្វីទាំងអស់។ យើងជឿថា វិធីនេះអនុវត្តតែចំពោះការដោះស្រាយវិវាទក្រៅប្រព័ន្ធយុត្តិធម៌ផ្លូវការប៉ុណ្ណោះ។ នេះជាវិធីរកយុត្តិធម៌ដោយពឹងផ្អែកលើអំណាចធម្មជាតិ។

ឯកសារចិននិយាយទៀតថា "ពេលនោះមិនទាន់មានគុកដាក់មនុស្សទេ។ ជនឧក្រិដ្ឋត្រូវបោះឱ្យក្រពើដែលគេចិញ្ចឹមនៅក្នុងប្រឡាយជុំវិញទីក្រុង ឬសត្វសាហាវដែលគេចិញ្ចឹមដាក់ក្នុងទ្រុងពិសេស។ បើរយៈពេល ៣ថ្ងៃ សត្វសាហាវទាំងនោះមិនស៊ី គេឱ្យរួចខ្លួន។" ផ្អែកលើកំណត់ត្រានេះ យើងអាចធ្វើការសន្និដ្ឋានបានថា នាសម័យនោះ ពិតជាមានច្បាប់ទំនៀមក្នុងវិស័យព្រហ្មទណ្ឌកំណត់អំពីប្រភេទទោសធ្ងន់ ឬទោសស្រាល (បទឧក្រិដ្ឋឬមជ្ឈិម) និងមានបុគ្គលឬស្ថាប័នចោទប្រកាន់ និងដាក់ទោសចំពោះឧក្រិដ្ឋជន។ ប៉ុន្តែគួរឱ្យសោកស្តាយដោយយើងពុំមានកំណត់ត្រាអំពីប្រភេទច្បាប់ និងអ្នកមានអំណាចសម្រេចដាក់ទោស។

ជំពូកទី៤.
សម័យចេនឡា

ប្រវត្តិសាស្ត្រកម្ពុជាសម័យចេនឡាចាប់ផ្តើមនៅឆ្នាំ៥៥០នៃគ្រិស្តសករាជ ដល់ឆ្នាំ ៨០២នៃគ្រិស្តសករាជ។ តាមឯកសារដែលបានកត់ត្រា ក្នុងសម័យនេះមានព្រះមហាក្សត្រចំនួន២៦ អង្គសោយរាជ្យ។

៤.១. រចនាសម្ព័ន្ធគ្រប់គ្រងសង្គម

៤.១.១. ទម្រង់នៃការគ្រប់គ្រង

សម័យចេនឡា របបនយោយបាយមិនខុសគ្នាជាមួយសម័យហ្វូណនទេ គឺជារបបរាជាធិបតេយ្យ ដែលអនុវត្តនយោបាយតាមបែបឥណ្ឌាដែរ។ អាណាចក្រហ្វូណនបានបែកបាក់ ហើយបង្កើតបានជាចេនឡាដីគោក និងចេនឡាដីទឹក។

ចាប់តាំងពីរជ្ជកាលព្រះបាទឦសានវរ្មនទៅរាជធានីតាំងនៅឦសានបុរ ហើយមានប្រជាជនរស់នៅចំនួន២០ ០០០គ្រួសារ។ នៅកណ្តាលក្រុងមានសាលប្រជុំធំមួយ ជាទីដែលព្រះមហាក្សត្រទ្រង់ព្រះប្រទានសវនាការ និងប្រជុំមន្ត្រីសេនាបតី។ ក្រៅពីរាជធានីនៅមានក្រុងចំនួន៣០ទៀត។ ក្រុងនីមួយៗមានច្រើនគ្រួសារ ហើយត្រួតត្រាដោយអភិបាលម្នាក់។ ក្នុង៣ថ្ងៃម្តង ព្រះរាជាតែងយាងទៅកាន់សាលប្រជុំ។ មន្ត្រីជាន់ខ្ពស់មាន៥នាក់ ទី១ មានងារហៅតាមចិនថា Kou-ling ទី២ Sing-kao-ping ទី៣ Po-hoto-ling ទី៤ Cho-mo-ling ទី៥ Jan-lo-leou។ រហូតមកដល់ពេលនេះ គេមិនទាន់រកឃើញថាតើរមងារដែលហៅតាមចិននេះត្រូវនឹង៣ក្យខ្មែរជំនាន់នោះថាយ៉ាងម៉េចនៅឡើយទេ។ ឯពួកមន្ត្រីតូចតាចវិញមានចំនួនច្រើនណាស់។[904] ព្រះបាទឦសានវរ្មន សោយរាជ្យឆ្នាំ៦១៦ដល់ឆ្នាំ៦៣៧នៃគ្រិស្តសករាជ។

ប៉ុន្តែលោក អាដេម៉ា ឡឺក្លែរ បានធ្វើការបកស្រាយលើហាន:របស់មន្ត្រីជាន់ខ្ពស់ដូចតទៅ *"គេអាចកំណត់ឃើញយ៉ាងច្បាស់នូវឈ្មោះពិតប្រាកដរបស់ហាន:នីមួយៗ ដែលចិនបំភ្លៃខុសជាខ្លាំង ដូចជាផ្ទួតទួទឹង ពហុទេពឬពហុទេវ:, ចេម៉ាលីង ត្រូវនឹង យោមរាជ, ហាន:ទីមួយសំដៅយកមន្ត្រីទទួលបន្ទុកពន្ធអាករ, ហាន:ទី២ សំដៅយកមន្ត្រីយុត្តិធម៌។"*[905]

---

[904] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា) ទំព័រទី១២៧។

[905] សៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (អាដេម៉ារ ឡឺក្លែរ) ទំព័រទី៣៩ ដើងទំព័រទី១៣។

ផ្អែកតាមកំណត់ត្រាខាងលើ អាចឱ្យយើងធ្វើការវាយតម្លៃបានថា ក្នុងកិច្ចការដ្ឋបាលនារជ្ជកាលនេះ មានការបែងចែកការគ្រប់គ្រងរដ្ឋបាលដែនដីច្បាស់លាស់ មានការបែងចែកមុខងាររបស់មន្ត្រីឱ្យទទួលខុសត្រូវ និងគ្រប់គ្រងតាមវិស័យ(យ៉ាងហោចៗវិស័យ) ដែលក្នុងនោះមានវិស័យពន្ធដារ និងវិស័យយុត្តិធម៌ផងដែរ។

សិលាចារឹកខ្មែរ (ប្រាសាទយាយព័ន្ធ) បានសរសើរគោលនយោបាយរបស់ព្រះបាទឦសានវម៌្មទី១ បានបង្កើតឡើងដោយឈរលើគោលការណ៍៣យ៉ាងនៃអំណាចរបស់ព្រះអង្គ។ យើងរកមិនឃើញថា តើគោលការណ៍៣យ៉ាងនោះមានអត្ថន័យយ៉ាងណាឡើយ ពីព្រោះសិលាចារឹកនេះពុំបានអត្ថាធិប្បាយលម្អិតអំពីខ្លឹមសារនៃគោលការណ៍ទាំង៣នេះឡើយ។ ប៉ុន្តែយើងអាចវាយតម្លៃបានថា ព្រះមហាក្សត្រអង្គនេះ បានរៀបចំ និងដាក់ចេញនូវគោលនយោបាយដើម្បីដឹកនាំព្រះនគរ ធ្វើឱ្យមានភាពល្បីល្បាញ និងកោតសរសើរពីរនគរផ្សេងៗ។ ខាងក្រោមនេះជាខ្លឹមសារបកប្រែពីសិលាចារឹកនេះ៖

១. ព្រះស្រីប្រហសិតេស្វរអង្គនោះ រមែងមានជ័យជម្នះ...ព្រះរូបរាង្គកាយរបស់ព្រះស្រីប្រហសិតេស្វរអង្គនោះទ្រង់មានពន្លឺភ្លឺចែងចាំង ដូច្នេះឯងទើបពោលថា ផែនដីនៅក្នុងសមុទ្រមាស (ពណ៌ក្រហមដូចមាស)។

២. ស្តេចផែនដីអង្គនោះ ព្រះអង្គមានព្រះកិត្តិសព្ទល្បីល្បាញ ព្រះអង្គជាប់ព្រះញាតិវង្សខាងសូរ្យវង្ស ព្រះអង្គប្រដូចទៅនឹងដួងព្រះអាទិត្យនៅលើអាកាសវេហាដោយហោចទៅសូម្បីតែព្រះអង្គគង់នៅក្នុងកណ្តាលមណ្ឌល (រាជមន្ទីរ) ក៏ដោយ ក៏ព្រះអង្គទ្រង់មានកំដៅ (អំណាច) មិនមានបុគ្គលណាអាចទប់ទល់បានឡើយ។

៣. នរណាដែលបានគយគន់ឃើញហើយនូវព្រះវរបុកាយ ដែលមានរូបឆោមលោមពណ៌ល្អស្រស់ឆើតឆាយ ដោយហោចទៅសូម្បីតែនាងរតិ ក៏បានភ្ញាក់ដឹងខ្លួនហើយបានពោលពាក្យដូច្នេះថា ឱហ្ន៎ ស្មានអញជាស្ត្រីមេម៉ាយយូរហើយទេតើ តែវាដូចជាមិនពិតនោះទេ។

៤. ស្រីតរុណ្យកញ្ញា (ស្រីក្រមុំព្រហ្មចារីយ៍) រមែងមិនហ៊ានចោមរោមជុំជិតព្រះអង្គនោះទេ បើទោះបីជាព្រះអង្គកំពុងនៅវ័យកំលោះ មានកាមរូប (ល្អស្រស់ឆើតឆាយ) ក៏ដោយ ដោយសារតែព្រះអង្គពេញចិត្តតែចំណេះវិជ្ជាមួយមុខប៉ុណ្ណោះ ដោយព្រឹទ្ធាចារ្យទាំងឡាយបានបរិភោគ (អាស្រ័យហើយ) រីករាយពេញចិត្ត។

៥. ស្វយំ=ខ្លួនឯង..បិយៈ=សេចក្តីពេញចិត្ត ...កត្តវត៌=មានសេចក្តីគោរព..សូរិកិៈ=ដោយព្រះអាទិត្យទាំងឡាយ។

៦. ព្រះរាជាអង្គណាទ្រង់បរិបូណ៌ដោយរត្នសម្បត្តិទាំងឡាយច្រើនប្រការ ដូចទៅនឹងមហាសមុទ្រ បាតា=ការពារដោយស្តេចភ្នំ។

៧. ព្រះអង្គមិនមានបុគ្គលណាប្រៀបប្រដូចបាន ភាពដែលមាននៅក្នុងស្ត្រី ឬទ្រព្យសម្បត្តិដ៏ល្អប្រសើរទាំងអស់ស្ថិតនៅក្បែរព្រះអង្គបាន ត្បិតថាព្រះអង្គទ្រង់ប្រព្រឹត្តតែអំពើល្អដ៏សុក្រឹត...ក្នុងកិត្តិគុណប៉ុណ្ណោះ។

៨. ព្រះអង្គ (ព្រះបាទឦសានវម្ម៌ទី១) មានមូល (ឫសគល់) ដ៏រឹងមាំក្រៃលែង មានបែកមែកសាខា មានដុះត្រួយពន្លកច្រើន ដោយបានការស្រោចស្រពដោយទឹកមន្ត្រមានផ្លែផ្កាច្រើន នេះជាដើមជ័យព្រឹក្សរីកលូតលាស់ដុះដាលលើផែនដីទ្រង់។

៩. ស្ថិតនៅក្នុងចំណោមបុគ្គលដែលប្រព្រឹត្តអំពើសុចរិតទាំងឡាយ បុគ្គលអ្នកគោរព និងដឹងគុណចំពោះគ្រូបាធ្យាយ ព្រះអង្គ (ព្រះបាទឦសានវម្ម៌ទី១) ជាបុគ្គលទី១ មានប្រក្រតីប្រព្រឹត្តសុចរិត មានកតិ្តភាពចំពោះគ្រូបាធ្យាយ ទោះបីទ្រង់មានអំណាចធំក៏ពិតមែនក៏ដោយ។ ព្រះអង្គបានពង្រីកដែនវិស័យរបស់ទ្រង់ឱ្យធំទូលាយជាងគ្រូទាំងឡាយរបស់ទ្រង់ទៅទៀត។

១០. សាធុសប្បុរសជនទាំងឡាយដ៏ច្រើន ពោលសរសើរទ្រង់ថា ព្រះអង្គ (ព្រះបាទឦសានវម្ម៌ទី១) មិនត្រឹមតែជាទីជ្រកអាស្រ័យបណ្តាជនប៉ុណ្ណោះទេ ព្រះអង្គមិនប្រព្រឹត្តដោយនូវទោសទាំងឡាយ ដោយទ្រង់ប្រដូចនូវការសេពគប់នូវទោស (អំពើបាប) នេះថាជាសត្រូវរបស់ទ្រង់។

១១. វ៉-អង្គនា= រូបរាងកាយទាំងឡាយដ៏ល្អប្រសើររបស់ទ្រង់ កាលមើលនូវរូបល្អសោភានៃព្រះអង្គដែលមានរូបស្រស់ស្អាត នឹកក្នុងចិត្តថា គ្រាន់តែក្រលែកមើលមួយប៉ប្រិចភ្នែក ដូចជាចាប់បានសត្រូវទៅហើយ។

១២. ព្រះសិរីយសដ៏ល្អបរិសុទ្ធឥតមន្ទិលសៅហ្មងដ៏ធំ មានច្រើនអនេកវាប់មិនអស់ ព្រះធាតា (ទេពបង្កើតលោក) ទ្រង់មានព្រះតម្រិះតូចចិត្តថា ផែនដីដែលទ្រង់គ្រប់គ្រងនេះតូចពេកណាស់។

១៣. អកិយានេ រជសា= នៅពេលចូលទៅក្បែរព្រះរាជា ធូលីដីហុយទ្រលោមមកលើផែនដី ដែលបង្កើតឡើងដោយកងទ័ពរបស់ទ្រង់ បង្កើតបានជាភាពងងឹតខ្ពួលខ្មាញ់ បានបង្ហាញអំពីភាពខុសប្លែកគ្នារវាងសត្វ។

១៤. គោលនយោបាយរបស់ព្រះអង្គ (ព្រះបាទឦសានវរ្ម៌ទី១) បានបង្កើតឡើងដោយ គោលការណ៍៣យ៉ាង នៃអំណាចរបស់ព្រះអង្គ បានធ្វើឱ្យព្រះរាជាក្រៅដែនអាណាចក្រ (បរទេស) ពេញចិត្ត (សាទរជាមួយគោលនយោបាយ) និងដួលរលំអំណាច បើទោះបីជាគេមានឫសគល់រឹងមាំនៅក្នុងដែនដីរបស់គេក៏ដោយ។

១៥. ព្រះអង្គទ្រង់ព្រះតម្រិះនូវអត្ថប្រយោជន៍ ដោយការប្រព្រឹត្តដ៏ឧត្តមរបស់ទ្រង់ ដោយព្រះអង្គបានបង្កើតប្រយោជន៍ដល់អ្នកដទៃ ដូចជាការបង្ហាញនូវគុណធម៌។

១៦. អំណាចដែលបានកំណត់ថាជាបឋមជនជាដើម និងជនដទៃ វាមានលក្ខណៈអស្ចារ្យណាស់ ទោះបីជាវាមិនគួរឱ្យជឿក៏ដោយ តែបានបង្ហាញឱ្យគេឃើញយ៉ាងច្បាស់អំពីតម្លៃក្នុងពេលប្រយុទ្ធ។

១៧. ជាប្រក្រតី ពន្លឺភ្លើងបានភ្លឺផ្លេកចែងចាំងភ្លឺឡើង ជាគ្រឿងរណ្តាប់ដោយរត្នាលង្ការ ប្រដាប់នៅលើព្រះភ្នែងសិរសាចុះមកក្រោមរបស់ព្រះមហាក្សត្រ បានភ្លឺជះចែងចាំងរស្មីភ្លឺត្រចះត្រចង់ មានពណ៌ល្អចម្រុះពណ៌ជះទៅលើព្រះបាទាទាំងគូដែលល្អបរិសុទ្ធឥតសៅហ្មង។

ចំពោះនយោបាយក្រៅប្រទេស ចេនឡានៅរក្សាទំនាក់ទំនងផ្នែកការទូតជាមួយប្រទេសចិន និងអនុវត្តនយោបាយក្រៅប្រទេសក្នុងវិស័យពាណិជកម្មដូចអាណាចក្រហ្វូណនដែរ។

សម័យកាលនោះមានប្រព័ន្ធបង់ពន្ធជារដូចសម័យហ្វូណនដែរ ដោយប្រជាជនត្រូវបង់ពន្ធជូនរាជការជាមាស ប្រាក់ ត្បូង គជ់ គ្រឿងក្រអូបផ្សេងៗ ឬបង់ពន្ធជារជាកសិផល។

៤.១.២. ប្រព័ន្ធសេដ្ឋកិច្ច

សង្គមកម្ពុជាធ្លាប់ទទួលបានជោគជ័យក្នុងនយោបាយទឹកតាំងពីសម័យអាណាចក្រភ្នំ(ហ្វូណន) មក ម្ល៉េះ។ ចូលមកដល់សម័យចេនឡា នយោបាយទឹកមានសភាពរឹងរឹតតែប្រសើរឡើងថែមទៀត ជាហេតុញុំាងឱ្យមានការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹង និងញុំាងឱ្យកសិកម្មមានការចម្រើនលូតលាស់ជាលំដាប់។ ឧ. ក្រុងឦសានបុរៈត្រូវបានក

សាងនៅក្បែរស្ទឹងសែន ឯទឹកស្ទឹងនោះត្រូវបង្ហូរចូលក្នុងស្រះព័ទ្ធជុំវិញ និងក្នុងអាងទឹកឯទៀតៗក្នុងផ្ទៃក្រុង ធ្វើដូច្នេះ គេអាចមានទឹកប្រើប្រាស់គ្រប់គ្រាន់ ហើយមានលទ្ធភាពពង្រីកដីដាំដំណាំទៀតផង។[១០៦]

ចំពោះវិស័យពាណិជ្ជកម្ម សិប្បកម្ម និងរ៉ែ គេពុំឃើញមានឯកសារណានិយាយថា មានការប្រែប្រួល ឬកែប្រែខុសពីសម័យហ្វូណនឡើយ។ ដូច្នេះយើងអាចសន្និដ្ឋានបានថា វិស័យទាំងនេះនៅបន្តអនុវត្តដូចសម័យហ្វូណនដែរ។

៤.១.៣. ប្រព័ន្ធសង្គមកិច្ច

មកដល់សម័យនេះ គេឃើញមានសិលាចារឹកជាច្រើនបានចារឹកអំពីការបរិច្ចាគទាន និងព្រះរាជទ្រព្យនិងជាដីធ្លី ជាទ្រព្យសម្បត្តិផ្សេងៗ ជាខ្ញុំបម្រើដល់បូជនីយដ្ឋានសាសនានានា សម្រាប់បម្រើជាប្រយោជន៍រួមរបស់ សង្គម។ នៅតាមទីតាំងបូជនីយដ្ឋានសាសនាទាំងអស់ ត្រូវបានលើកលែងពន្ធដារទាំងស្រុង។ ជាក់ស្តែង សិលាចារឹក (ប្រាសាទយាយព័ន្ធ)ក៏បានលើកអំពីគុណធម៌របស់ព្រះបាទឦសានវរ្ម័នទី១ ដែលទ្រង់បានគិតគូរដល់សង្គមកិច្ច *"ស្លោកទី១៥.ព្រះអង្គទ្រង់ព្រះតម្រិះនូវអត្ថប្រយោជន៍ ដោយការប្រព្រឹត្តដ៏ឧត្តមរបស់ទ្រង់ ដោយព្រះអង្គបានបង្កើតប្រយោជន៍ដល់អ្នកដទៃ ដូចជាការបង្ហាញនូវគុណធម៌។"*

លើសពីនេះ មានសិលាចារឹកមួយចំនួនបានលើកឡើងអំពីគោលនយោបាយបែងចែកដីឱ្យប្រជាជន ការទទួលស្គាល់កម្មសិទ្ធិដីធ្លីរបស់ប្រជាជន និងជាពិសេសការដាក់ទានដីដល់ជនក្រីក្រ។

៤.១.៤. ជំនឿ ទំនៀមទម្លាប់ និងសាសនា

មនុស្សនៅសម័យនោះមានមាឌតូច ហើយសម្បុរខ្មៅដូចមនុស្សនៅសម័យអាណាចក្រហ្វូណនដែរ ប៉ុន្តែស្រីៗភាគច្រើនមានសម្បុរស (នេះប្រហែលជាមកពីនៅក្នុងម្លប់មិនចេញប្រកបការងារខាងក្រៅដូចប្រុសៗទេដឹង?)។ ទាំងប្រុស ទាំងស្រីសុទ្ធតែបួងសក់ ហើយពាក់រយ៉ាថែមទៀត។ ឯកសារចិនបានបញ្ជាក់ទៀតថា ពួកនេះមានគំនិតវាងវៃ ហើយមានមាឌមាំមួនទៀតផង។ គេចាត់ទុកដៃស្តាំថាបរិសុទ្ធ ឯដៃឆ្វេងថាមិនបរិសុទ្ធ។ រៀងរាល់ព្រឹកគេតែងធ្វើការលប់លាង ចាក់ធ្មេញ រួចអានសៀវភៅ ឬសូត្រធម៌។ មុនពេល

[១០៦] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា) ទំព័រទី១២៨។

ទទួលទានអាហារ គេតែងធ្វើការលប់លាងសាជាថ្មី លុះទទួលទានរួចហើយ គេចាក់ធ្មេញ ហើយគេសូត្រធម៌ថែមទៀត។ ក្នុងម្ហូបអាហារ គេចូលចិត្តប្រើទឹកដោះគោ ស្ករគ្រាប់ល្អិតបាយ millet (?)។[១០៧]

គេនិយមរាប់ញាតិដោយយកខ្សែតាមម្តាយ។ ក្នុងរឿងជ្រើសរើសគូស្រករ គឺពួកប្រុសៗទៅដណ្តឹងស្រី។ ត្រង់នេះឃើញថា មានការវិវត្តប្លែកពីសម័យហ្វូណនដែលពួកស្រីៗទៅដណ្តឹងប្រុស។ លុះពិធីមង្គលការចប់ កូនប្រុសទទួលមត៌កពីឪពុកម្តាយបង្កើតរបស់ខ្លួន ហើយបែកផ្ទះទៅនៅដោយឡែក។ ដល់ពេលឪពុកម្តាយស្លាប់ ពួកកូនដែលនៅលីវ អាចទទួលយកមត៌កដែលនៅសេសសល់ទាំងអស់។ ប៉ុន្តែប្រសិនបើកូនទាំងនោះមានប្តីប្រពន្ធហើយបានទទួលមត៌ករួចហើយ នោះទ្រព្យសម្បត្តិដែលនៅសេសសល់ត្រូវបញ្ចូលក្នុងឃ្លាំងជាតិ។

ក្នុងពិធីបុណ្យសព កូនទាំងឡាយរបស់សពអត់បាយ៧ថ្ងៃ ត្រូវកោរសក់ ហើយត្រូវយំស្រែកយ៉ាងខ្លាំង។ ក្រុមគ្រួសារនៃសព ដោយរួមនិងព្រះភិក្ខុ និងភិក្ខុនីបានធ្វើក្បួនដង្ហែរ ដោយមានច្រៀង (ប្រហែលសូត្រធម៌) និងលេងភ្លេងផង។ សពគេបូជាក្នុងប៉ាឆាសង់ដោយឈើក្រអូប រួចគេរើសធាតុដាក់ក្នុងកោដ្ឋមាស ឬប្រាក់យកទៅទម្លាក់ចោលក្នុងទឹក។ អ្នកក្រប្រើកោដ្ឋដីមានលាបពណ៌ផ្សេងៗ។ មានខ្លះគ្រាន់តែយកសពទៅដាក់ចោលក្នុងព្រៃស្មសានឱ្យសត្វស៊ី។

ប្រជាជននៅបន្តគោរពប្រតិបត្តិពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង។ នៅចុងសតវត្សរ៍ទី៧ នៃគ្រិស្តកាល ប្រទេសឥណ្ឌាមានឥទ្ធិពលយ៉ាងខ្លាំងមកលើឥណ្ឌូចិន ព្រោះថា បណ្តាក្រុមឧបនិវេសន៍ដែលនាំយកអារ្យធម៌មកផ្សព្វផ្សាយនៅទីនេះបន្តិចម្តងៗ គឺក្រុមឧបនិវេសន៍ហិណ្ឌូ ហើយរាជវង្សស្តេចដែលសោយរាជ្យនៅទីនេះ សុទ្ធតែជាប់អម្បូរក្សត្រិយ៍ ឬព្រាហ្មណ៍ និងម៉្យាងទៀតសាសនាដែលគេគោរពគឺព្រហ្មញ្ញសាសនា ឬពុទ្ធសាសនា។ ពាក្យថា "វ៉ឺន" មានន័យថា អ្នកការពារដែលព្រះរាជាប្រកាន់យកនៅពេលឡើងសោយរាជ្យនៅកម្ពុជា ក៏ដូចជានៅចាម្ប៉ា ជាហានៈដែលស្តេចហិណ្ឌូខ្លះប្រកាន់យកនៅឥណ្ឌាភាគខាងត្បូង។ ច្បាប់ទម្លាប់ ប្រពៃណីដែលគេអនុវត្ត សុទ្ធតែមានប្រភពចេញមកពីឥណ្ឌា។[១០៨]

---

[១០៧] សៀវភៅ "ប្រវត្តិសាស្ត្រខ្មែរ-ភាគ១ (ត្រឹង ងា) ទំព័រទី១២៥។

[១០៨] សៀវភៅ "ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (អាដេម៉ារ ឡឺរ៉ែរ) ទំព័រទី៣៩ ដើងទំព័រទី៦៣។

៤.២. ច្បាប់ទំនៀមសម្រាប់គ្រប់គ្រងសង្គម

៤.២.១. ច្បាប់ទំនៀម

នៅសម័យនោះ អ្នកស្រុកត្រូវបង់ពន្ធដារជូនរាជការជាមាស ប្រាក់ ស្បូង គជ់ គ្រឿងក្រអូបផ្សេងៗ ឬបង់ពន្ធជាកសិផល។ ដើម្បីកំណត់អត្រាពន្ធដារ ប្រមូលពន្ធដារ គ្រប់គ្រងនិងបែងចែកពន្ធដារ និងចាត់វិធានការចំពោះអ្នកមិនព្រមបង់ពន្ធដារ ត្រូវមានច្បាប់ទំនៀមក្នុងវិស័យពន្ធដារនេះ។

មកដល់សម័យនេះ យើងមានកស្តុតាងបញ្ជាក់អំពីសញ្ញាណនៃវាក្យសព្ទសម្រាប់ប្រើក្នុងច្បាប់ ហើយមានលក្ខណៈជាបញ្ញត្តិឬជាអាជ្ញាខ្លះៗហើយ។ ក្រៅពីច្បាប់ទម្លាប់ដែលមានប្រភពចេញពីសាសនា ទំនៀមទម្លាប់ យើងមានសិលាចារឹកបានចារឹកអំពីសញ្ញាណនៃបទប្បញ្ញត្តិ ដូចជាពាក្យ **"អាជ្ញា"** ពាក្យ **"ទណ្ឌកម្ម"** ពាក្យ **"ពិន័យ"**។ សិលាចារឹកទាំងនោះ[១០៩]រួមមាន៖

១. សិលាចារឹកKa៤៩ នៅស្រុកកំពង់ត្របែក ជាភាសាសំស្ក្រឹត កាលបរិច្ឆេទថ្ងៃទី២៨ ខែធ្នូ ឆ្នាំ ៦៦៤ នៃគ្រិស្តសករាជ។ អត្ថបទបកប្រែជាភាសាខ្មែរបានរំឭកឡើងវិញនូវព្រះរាជអាជ្ញា(របស់ព្រះបាទជ័យវរ្ម័ទី១) ដែលអត្ថបទសំស្ក្រឹតបានពណ៌នារួចស្រេចហើយនូវខសំខាន់ៗនៅក្នុងស្លោកទី៦ និងទី៧ គឺនិយាយពីការយល់ព្រមផ្តល់នូវសិទ្ធិស្របច្បាប់ដល់បោញ សុកកីរតិ ទៅលើការគ្រប់គ្រងអំណោយបុណ្យទាំងឡាយរបស់តាមីងទាំងពីរអង្គដែលថ្វាយដល់ព្រះ គឺប្រហែលជាព្រះពុទ្ធ។ ***ស្លោកទី១៥-១៧. អ្នកណាដែលរាំងខ្ទប់ទីនេះ អ្នកណាដែលលួចរបស់របរនៅទីនេះ អ្នកណាដែលសុំយករបស់របរពីទីនេះ អ្នកណាដែល....បំបាត់ និងរាំងដល់អគារនៅទីនេះ អ្នកណាដែលហៅអ្នកបក់(ផ្តិត)ជកយកចេញពីទីនេះ អ្នកណាដែលប្រើប្រាស់អ្វីៗទាំងអស់នេះសោត អ្នកនោះកន្លងនឹងព្រះរាជអាជ្ញារបស់ព្រះរាជា អ្នកនោះនឹងត្រូវជាក់ទណ្ឌកម្ម។*** សិលាចារឹកនេះ បានបង្ហាញពីប្រភេទល្មើសដែលនឹងទទួលទណ្ឌកម្ម។ ប៉ុន្តែយើងមិនដឹងថា តើត្រូវទទួលទណ្ឌកម្មប្រភេទណា។

២. សិលាចារឹកKa៤៤ នៅខេត្តកំពត ជាពីរភាសាគឺភាសាខ្មែរនិងភាសាសំស្ក្រឹត កាលបរិច្ឆេទឆ្នាំ៦៧៤ នៃគ្រិស្តសករាជ។ អត្ថបទបកប្រែជាភាសាខ្មែរ (ស្លោកទី៤-១៣.

[១០៩] សៀវភៅ "សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ" (វង់ សុធារ៉ា)។

អ្នកទាំងឡាយដែលគេហៅថា "សំបោល"នោះឯង អ្នកទាំងឡាយដែលគៃបន្លំយកថ្លៃពន្ធប្រចាំឆ្នាំនៅទីនេះ អ្នកដែលសុំអ្វីៗនៅទីនេះពីចៅអធិការ អ្នកដែលទារយកទ្រនាប់ឃោសនានេះទីនេះ អ្នកដែលចាប់រទេះទូក គោ ក្របី ខ្ញុំបម្រើនៅទីនេះ អ្នកដែលលួចយកឆ័ត្រជាទីសក្ការៈដែលគេរក្សាទុក ធ្វើនំបិតនៅក្នុងបរិវេណទីធ្លារបស់ព្រះ អ្នកបួសនៅទីនេះដែលបានធ្វើការបូជាចំពោះព្រះអ្នកបួសដែលបួសនៅលើភ្នំរបស់ព្រះនេះ អស់សត្វទាំងឡាយដែលរស់នៅទីនេះ ពុំមែនជាផលរបស់ (ឬជាផ្លែផ្កាចេញពី) អ្នកផ្តល់ដង្វាយនិច្ចកាល ពីស្រុងទាំងឡាយដែលជាស្រុកចំណែរបស់ព្រះ សម្រាប់ជាការបូជាចំពោះព្រះ អ្នកណាដែលសុំរបស់ទាំងនេះ អ្នកណាដែលរាំងខ្ទប់ទីនេះ អ្នកណាដែលប្រើប្រាស់របស់ទាំងអម្បាលនេះសោត អ្នកនោះកន្លងនឹងព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ ហើយពួកគេនឹងត្រូវជាប់ទណ្ឌកម្ម។) សិលាចារឹកនេះ បានបង្ហាញពីប្រភេទល្មើសដែលនឹងទទួលទណ្ឌកម្ម។ ប៉ុន្តែយើងមិនដឹងថា តើត្រូវទទួលទណ្ឌកម្មប្រភេទណាដែរ។

៣. សិលាចារឹកKa១២ នៅទួលអង្គសង្គ្រាម ភូមិអង្គសង្គ្រាម ឃុំជង្រុក ស្រុកគងពិសី ខេត្តកំពង់ស្ពឺ ជាអក្សរនិងភាសាខ្មែរសម័យមុនអង្គរសតវត្សរ៍ទី៦-៧នៃគ្រិស្តសករាជ។ អត្ថបទបកប្រែជាភាសាខ្មែរ "**ព្រះរាជបញ្ជាព្រះមហាក្សត្រ (ប្រើ)ឱ្យស្រុកបុទោកនេះជល់ *ម្រតាញកម្រតាង ច្រង្កោស* ហើយនៅទីនេះដែរ(មាន)ស្រុក(និង)ប្រមាន(នៅទី)នេះ។ (ចំពោះ)អ្នកណាដែលធ្វើឱ្យខូចខាត(ផ្នាំងចារឹក)នេះ(នឹង)ត្រូវប្តឹង(ឱ្យ)បង់មាសចំនួនមួយកដ្តិ។**" សិលាចារឹកនេះ បានបង្ហាញពីប្រភេទល្មើសដែលបានកម្រិតទណ្ឌកម្មដែលត្រូវពិន័យជាមាសមួយកដ្តិ[990]។

ដូច្នេះយើងអាចសន្និដ្ឋានបានថា មកដល់សម័យចេនឡានេះ សង្គមកម្ពុជាមានច្បាប់ទំនៀមសម្រាប់គ្រប់គ្រងប្រទេសជាច្រើនវិស័យរួចហើយ គ្រាន់តែពុំមានបន្សល់ទុកឯកសារសំណេរគ្រប់ជ្រុងជ្រោយ។ ច្បាប់ទំនៀមទាំងនោះអាចមានសញ្ញាណនៃច្បាប់ទំនៀមក្នុងកិច្ចការរដ្ឋបាល-នគរូបនីយកម្ម (បែងចែកដែនដី) កិច្ចការពន្ធដារ កិច្ចការមត៌ក កិច្ចការព្រហ្មទណ្ឌជាដើម។

[990] ឯកតារង្វាស់ទម្ងន់នៅសម័យបុរាណដែលខ្មែរយកតាមថ្នា។ ១កដ្តិស្មើ ០,១៤៥ក្រាម(សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ (វ៉ង់ សុធារ៉ា)ទំព័រ១៧៥)។

៤.២.២. យន្តការដោះស្រាយវិវាទ

មកដល់សម័យនេះ សង្គមកម្ពុជានៅតែ "ប្រើវិធីអស្វាឃ្យដើម្បីរកសេចក្តីពិត" ដូចសម័យហ្វូណនដដែល ពីព្រោះយើងឃើញថា វិធីសាស្ត្រនេះនៅប្រើដល់សម័យអង្គរ[999]។

ឯកសារចិនបាននិយាយថា នៅកណ្តាលក្រុងមានសាលប្រជុំធំមួយជាទីដែលព្រះមហាក្សត្រទ្រង់ព្រះប្រទានសវនាការ។ ក្នុង៣ថ្ងៃម្តង ព្រះរាជាតែងយាងទៅកាន់សាលប្រជុំនោះ។ មានមន្ត្រីជាន់ខ្ពស់ចំនួន ៥នាក់នៅអមព្រះមហាក្សត្រ ដែលក្នុងនោះមានមន្ត្រីយមរាជ (យុត្តិធម៌) ផងដែរ។ ចំណុចនេះបញ្ជាក់បានថា នាសម័យនោះមានកំណត់ទីតាំងសម្រាប់ទទួលបណ្តឹង និងធ្វើសវនាការ មានរចនាសម្ព័ន្ធ និងមានព្រះមហាក្សត្រសម្រាប់ស្វែងរកយុត្តិធម៌ជូនប្រជាជនដែរ។ ព្រះមហាក្សត្រជើរតួនាទីជាអ្នកកាត់ក្តីចុងក្រោយ។

៤.២.៣. សីលធម៌សង្គមសម័យចេនឡា

សីលធម៌ និងច្បាប់សង្គមសម័យចេនឡា មានសភាពមិនសូវខុសគ្នានឹងសម័យនគភ្នំឡើយ។ សង្គម ស្ថិតក្រោមព្រះរាជា ព្រះអង្គជាអ្នកកាន់ច្បាប់ រួមជាមួយនឹងព្រាហ្មណ៍បុរោហិត មានន័យថាជាច្បាប់សង្គម និងច្បាប់សាសនា។ យើងមិនឃើញមានភស្តុតាងច្បាប់សង្គមដែលចារជាសិលាចារឹកនោះទេ ប៉ុន្តែយើងឃើញមាន ការបង្គាប់បញ្ជាតាមបែបសាសនា ដោយការដាក់បណ្តាសារដល់ជនទាំងឡាយ ដែលធ្វើវិនាសកម្មនានាលើប្រាសាទ និងសាសនា។ ជាឧទាហរណ៍ សិលាចារឹកក្នុងសម័យសម្ភុរៈ (ប្រាសាទត្រពាំងប្រីយ) ដែលសាស្ត្រាចារ្យបណ្ឌិត ធុយ ចាន់ធួន ទើបរកឃើញក្នុងឆ្នាំ២០១៩នេះ សាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា ថាសិលាចារឹកនេះគឺចារក្នុងកំឡុងសតវត្សទី៧ នៃគ្រិស្តសករាជ ជាភាសាខ្មែរសុទ្ធ បានចារថា៖

សេចក្តីប្រែសម្រួល

(១-២) (នេះ)គឺរណ្តាប់បូជារបស់ម្រេតាញសីលចាន់ចំពោះអាស្រមនិងព្រះគម្ពែងអញ្ជស្រីព្រឹទ្ធស្វរ (ស្រីព្រឹទ្ធស្វរៈ)។

[999] កំណត់ហេតុរបស់ ជីវ តាក្វាន់ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា។

(២-៦) (សម្រាប់)បុណ្យទាំងបួនមាន ស្លាបស្មែង អង្គរពាលិះ ប្រេង២ចន្ទរ។ សម្រាប់ថ្ងៃសីល ថ្ងៃថ្វាយផ្កាមាន អង្គរបលិះ ប្រេងចន្ទន៍១ចន្ទរ ស្លាបដំបរ កន្លែងគ្រប់យ ជ្ញ១ គឺសម្រាប់ចតុមាស(បួនខែ)ប៉ុណ្ណោះ។

(៦-១១) ខ្ញុំបម្រើ ស្រែ ច្បារដំណាំ គោ គឺថ្វាយជាចតុជាតកដល់អាស្រម។ រណ្តាប់បូជាដល់អាស្រមមានស្រូវ១កញ្ជើ សម្លបផ្នែក(មុខ) ស្លាបដំបរ សម្លៀក១យៅ។

(១១-១៥) អ្នកណាដែលយក(ទ្រព្យទាំងនេះ) អ្នកណាដែលរារាំង អ្នកណា ដែលបំផ្លាញ គឺអ្នកនោះលន្លឹងក្នុងនរក២៧ជាន់ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែ មាន។

(១៥-២១) អ្នកសិងកំឡុង(ទីនោះ) គឺម្រតាញជាបំនួសរស់នៅអាស្រម ម្រតា ញជាផ្ទុះ អ្នកជាប្រធានស្រុក ដែលពុំពោលប្រាប់ដល់អ្នកដែលដកយក(ទ្រព្យទាំងនោះ) ចេញពីព្រះ ចេញពីប្រាសាទ (និង)អ្នកដែលមកការារាំង ក៏ធ្លាក់ទៅនរកដែរ។

ទេពអង្គនេះត្រូវនឹងពាក្យហៅក្នុងសិលាចារឹកខ្មែរសម័យមុនអង្គរថា «ព្រះចស៊ិ»។

ចតុជាតក = គ្រឿងដង្វាយដែលមានបួនមុខ។

ដរាបណាព្រះចន្ទ្រនិងព្រះអាទិត្យនៅតែមាន ដរាបនោះអ្នកទាំងនោះនៅតែលន្លឹង ក្នុងនរកនោះពុំលែង។

សិង = ស្នាក់នៅរៀបចំបូជាពិធីកម្មផ្សេងៗក្នុងប្រាសាទឬអាស្រម។

ម្រតាញផ្ទុះ = បព្វជិតប្រោសព្រំជម្រះមន្ទិល...។

សេចក្តីសន្និដ្ឋាន

ពីសម័យកាលមួយទៅសម័យកាលមួយ ជំនឿ ទំនៀមទម្លាប់ សាសនារបស់ប្រជាជនកម្ពុជាមានការប្រែប្រួលតិចតួចបំផុត។ ពោលគឺសង្គមកម្ពុជាបានថែរក្សាវប្បធម៌ និងអត្តសញ្ញាណរបស់ខ្លួនជានិច្চកាល។ ក្នុងសៀវភៅ "ប្រវត្តិសាស្ត្រកម្ពុជា" របស់ វង់ សុធារ៉ា និង ណុប សុខា ទំព័រទី១៤ (បើផ្អែកតាមជំនឿ ប្រពៃណីទំនៀមទម្លាប់ និងផ្នត់គំនិត រួមទាំងការអះអាងរបស់អ្នកប្រាជ្ញបារាំងថា ***"សង្គមខ្មែរក្នុងរយៈពេលរាប់ពាន់ឆ្នាំរហូតដល់ការមកដល់របស់បារាំង មានការផ្លាស់ប្តូរ ឬប្រែប្រួលតិចតួចណាស់"***.....)។

ចំណុចពិសេសរបស់សង្គមកម្ពុជា ទោះសង្គមកម្ពុជាបានទទួលឥទ្ធិពលអរិយធម៌ពីបរទេស ជាពិសេសពីឥណ្ឌាក្តី ក៏សង្គមកម្ពុជាបានធ្វើជាតូបនីយកម្មឱ្យមានលក្ខណៈជាខ្មែរ ដោយសម្របសម្រួលជាមួយជំនឿ ប្រពៃណីទំនៀមទម្លាប់ និងសីលធម៌របស់ខ្មែរ ក្នុងគោលបំណងរក្សាវប្បធម៌ និងអត្តសញ្ញារបស់ខ្លួន។ ជាក់ស្តែងដូចជាស្ថាបត្យកម្ម សំណង់ប្រាសាទ ចម្លាក់ សិល្បៈ អក្សរជាដើម។ ចំពោះវិស័យសាសនា សង្គមកម្ពុជាមានភាពបិនប្រសប់ក្នុងការបន្សុំគ្នារវាងសាសនានានា ជាពិសេសរវាងពុទ្ធសាសនា និងហិណ្ឌូសាសនាឱ្យមានលក្ខណៈរួមមួយដែលសង្គមទាំងមូលទទួលយកបាន។ បន្ថែមពីនេះ ទោះជាសង្គមកម្ពុជាមានការបែងចែកវណ្ណៈជាបួន(ក្សត្រ មន្ត្រី អ្នកមាន អ្នកក្រ) ដូចសង្គមឥណ្ឌាក្តី ក៏សង្គមកម្ពុជាមិនប្រកាន់ឬរើសអើងវណ្ណៈដូចសង្គមឥណ្ឌាឡើយ។ ទោះបីសង្គមកម្ពុជាមានការផ្លាស់ប្តូរពីលើកស្រីជាធំ ជាអ្នកដឹកនាំក្នុងគ្រួសារ និងសង្គមជាតិ(មេនិយម) មកឱ្យបុរសដឹកនាំវិញក្តី ក៏សង្គមកម្ពុជានៅតែផ្តល់តម្លៃដល់ស្ត្រីក្នុងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ និងគ្រួសារដែរ។ គោលការណ៍មិនរើសអើងវណ្ណៈសង្គមជំនឿសាសនា និងភេទនេះ មិនត្រឹមតែផ្តល់សេចក្តីសុខសន្តិភាពនិងរក្សាបានសណ្តាប់ធ្នាប់សង្គមសម្រាប់កម្ពុជាប៉ុណ្ណោះទេ ថែមទាំងបានក្លាយជាគោលការណ៍សកលយកទៅតាក់តែងជាច្បាប់អន្តរជាតិទៀតផង។

បូជនីយដ្ឋាននៃសាសនាមិនមែនត្រឹមតែជាទីកន្លែងសម្រាប់គោរពបូជាក្នុងវិស័យសាសនាប៉ុណ្ណោះទេ វាក៏បានដើរតួនាទីដ៏សំខាន់សម្រាប់ប្រព័ន្ធគាំពារសង្គម តាមរយៈការទុកជាទីកន្លែងសម្រាប់ផ្តល់នូវការទូន្មានអប់រំដល់មនុស្ស(ផ្លូវចិត្តនិងចំណេះដឹង) និងជាទីកន្លែងសម្រាប់ការបរិច្ចាគទ្រព្យធន និងការផ្តល់ទានដល់អ្នកក្រីក្រថែមទៀត។ ជាក់ស្តែងវត្តអារាមក្នុងព្រះពុទ្ធសាសនាបានដើរតួនាទីបន្ថែមជាកន្លែងរក្សាទុកអក្សរសា

ស្ត្រខ្មែរ គម្ពីរ ក្បួនខ្នាត ជាសាលារៀន ជាកន្លែងសម្រាប់ស្នាក់អាស្រ័យរបស់ដូនជី តាជី (ដែលពេលខ្លះពួកគាត់គ្មានទីពឹង គ្មានកូនចៅ)ជាដើម។

ទោះជានៅសម័យបុរេប្រវត្តិសាស្ត្រ សម័យហ្វូណន និងសម័យចេនឡា ពុំមានឯកសារបញ្ជាក់ថាមានច្បាប់ ឬវិធានសរសេរច្បាស់លាស់សម្រាប់គ្រប់គ្រងសង្គមដូចសម័យទំនើបក្តី ក៏ការគ្រប់គ្រងសង្គមនាសម័យទាំងនោះបានផ្អែកលើច្បាប់ទំនៀមដែលបានកើតចេញពីទម្លាប់ជាប់ជាទំនៀមជាប្រពៃណីរបស់អ្នកស្រុក ចេញពីសីលធម៌ ចេញពីវិធានសីលធម៌ និងចេញពីព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ។

សរុបមក មរតកដែលបន្សល់ទុកពីសម័យបុរេប្រវត្តិសាស្ត្រ សម័យហ្វូណន និងសម័យចេនឡា ក្រៅពី បានបន្សល់ទុកនូវមូលដ្ឋានគ្រឹះសម្រាប់បង្កើតអរិយធម៌អង្គរ(ជំនឿទំនៀមទម្លាប់ សាសនា និងច្បាប់ទំនៀម) ក៏បានបន្សល់ទុកនូវអត្តសញ្ញាណជាតិ គឺគោលការណ៍មិនរើសអើង និងការធ្វើសុខដុមនីយកម្មជំនឿ និងសាសនា ប្រកបដោយវប្បធម៌សន្តិភាពនិយមរហូតដល់សព្វថ្ងៃ។ ដោយឡែកចំពោះច្បាប់ទំនៀម ពុំមានកំណត់ត្រាច្បាស់លាស់នៅឡើយ។

អនុសាសន៍

ឆ្លៀតក្នុងឱកាសនេះ យើងខ្ញុំសូមកោតសរសើរដោយសុទ្ធចិត្ត និងដោយការគោរព ចំពោះគំនិតផ្តួចផ្តើម និងឆន្ទៈដ៏មោះមុតរបស់ **ឯកឧត្តម ឥន្ទ្រី ឥសរុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** ដែលបានរៀបចំឱ្យមានការសិក្សាស្រាវជ្រាវក្នុងវិស័យច្បាប់យ៉ាងស៊ីជម្រៅ និងនៅគ្រប់សម័យកាលនៃប្រវត្តិសាស្ត្រកម្ពុជា ឈានទៅរកការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា ក្នុងគោលបំណងសម្រេចបានចក្ខុវិស័យ "**គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ជានិម្មាបករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល**"។

ទោះបីជារបាយការណ៍ស្រាវជ្រាវរបស់យើងខ្ញុំ ពុំទាន់បានផ្តល់ជាធាតុចូលគ្រប់ជ្រុងជ្រោយ សម្រាប់កំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជាក្តី ក៏យើងខ្ញុំពិតជាមានមោទកភាពណាស់ ដែលបានចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវនេះ។ យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅថ្នាក់ដឹកនាំនៃ **គ.ក.ច**. និងថ្នាក់ដឹកនាំនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. ដែលបានផ្តល់ឱកាសដល់យើងខ្ញុំក្នុងការចូលរួមក្នុងគម្រោងសិក្សាស្រាវជ្រាវនេះ។ យើងខ្ញុំសូមជូនអនុសាសន៍ដូចក្រោម៖

១. ដោយសារឯកសារដែលសរសេរអំពីប្រវត្តិសាស្ត្រកម្ពុជា និងឯកសារពាក់ព័ន្ធនឹងច្បាប់ផ្សេងទៀត ច្រើនតែនិពន្ធ និងចងក្រងជាភាសាបារាំង គួរបញ្ញវន្តដែលមានចំណេះដឹងជ្រាលជ្រៅក្នុងភាសាបារាំង ធ្វើការបកប្រែមកជាភាសាខ្មែរដើម្បីជួយសម្រួលដល់អ្នករៀនសូត្រ និងអ្នកស្រាវជ្រាវនានា ដែលមិនចេះភាសាបារាំង។

២. ដោយសាររហូតមកដល់សម័យបារាំងចូលមកកម្ពុជាហើយ ទំនៀមទម្លាប់ប្រពៃណី ជំនឿរបស់ខ្មែរយើងមិនសូវជាប្រែប្រួល ដូច្នេះគប្បីសិក្សាចងក្រងអំពីទំនៀមទម្លាប់ប្រពៃណី ជំនឿ និងរឿងនិទានរបស់ខ្មែរ ដែលនៅសេសសល់នៅតាមជនបទ ជាពិសេសជនជាតិភាគតិច ដែលនៅរក្សាទំនៀមទម្លាប់ ជំនឿដើមនៅឡើយ ចងក្រងគម្ពីរឬសាស្ត្រាស្លឹករឹតនានា ដែលរក្សាទុកនៅតាមវត្តអារាម។ យើងខ្ញុំក៏បានដឹងថា កន្លងមកមានការចងក្រងជាច្រើនរួចហើយ។ ចេញពីរឿងប្រជាប្រិយនានា ចេញពីជំនឿ ទំនៀមទម្លាប់ខុសៗគ្នា ពីស្រុកមួយទៅស្រុកមួយ អាចឱ្យយើងរកឃើញ និងបានដឹងអំពីច្បាប់ទម្លាប់ខ្លះៗដែរ។

៣. ទំនៀមទម្លាប់មួយចំនួនដែលល្អៗ គួរផ្សព្វផ្សាយ និងលើកទឹកចិត្តឱ្យបន្តអនុវត្ត។ ឧ. ការស្រុះស្រួលសាមគ្គីគ្នា ជួយគ្នាទៅវិញទៅមកពេលមានបុណ្យទានម្តងៗ ការរៀបចំពិធីបុណ្យរួម (ដូចជាបុណ្យភូមិ) ការប្រវាស់ដៃគ្នា ការពឹងពាក់គ្នានៅពេលមានការលើកផ្ទះ(សង់ផ្ទះ)។ល។

៤. ជំរុញ និងរកមូលនិធិសម្រាប់ការស្រាវជ្រាវលើមូលដ្ឋានវប្បធម៌ បុរេប្រវត្តិសាស្ត្រ និងប្រវត្តិសាស្ត្រជាតិឱ្យបានទូលំទូលាយ។

៥. ផ្តល់ការគាំទ្រ រាល់ការបោះពុម្ព ចងក្រងក្រម ច្បាប់... និងជំរុញធ្វើឱ្យមានការធ្វើសិក្ខាសាលាថ្នាក់ជាតិ តំបន់ អន្តរជាតិឱ្យបានច្រើន។

គន្ថនិទ្ទេស

អាដេម៉ា ឡឺក្លែរ. ២០០៥. *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា*. បកប្រែ ទេព ម៉េងឃាន ហៅ ទី ឃាយុ. ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា។

អេង សុត. ២០០៩. *ឯកសារមហាបុរសខ្មែរៈរាជពង្សាវតារខ្មែរ*. ភ្នំពេញ៖ ក្រសួងអប់រំ យុវជន និងកីឡា។

វង់ សុធារ៉ា និងណុប សុខា. *ប្រវត្តិសាស្ត្រខ្មែរៈសម្រាប់សិក្សាថ្នាក់មូលដ្ឋាន*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

វង់ សុធារ៉ា. ២០០៣. *សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ*. ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ត្រឹង ងា. ១៩៧៣. *ប្រវត្តិសាស្ត្រខ្មែរ*. ភ្នំពេញ។

ត្រឹង ងា. ១៩៧៤. *អរិយធម៌ខ្មែរ*. ភ្នំពេញ។

Chandler, David. *ប្រវត្តិសាស្ត្រខ្មែរ*. បកប្រែ ជិន ចន្ធា, ប្រាក់ សុវណ្ណារ៉ា, ម៉ម វណ្ណារី និង សេង សាត. ភ្នំពេញ៖ Westview Press។

ជីវ តាក្វាន់. ១៩៧៣. *កំណត់ហេតុរបស់ ជីវ តាក្វាន់៖ អំពីប្រពៃណីនៃអ្នកស្រុកចេនឡា*. បកប្រែ លី ធាមតេង. ភ្នំពេញ។

រាជរដ្ឋាភិបាលកម្ពុជា. ២០២៥. *កម្រងឯកសារសិក្សាសាកល្បងអំពីទស្សនវិជ្ជាច្បាប់ខ្មែរ បែបទំនៀម*. ព្រះរាជាណាចក្រកម្ពុជា៖ វេទិកាជំនុំច្បាប់ខ្មែរ។

ធុយ ចាន់ធួន. ២០២៤. *បុរាណវិទ្យាខ្មែរ*. ភ្នំពេញ។

ធុយ ចាន់ធួន. ២០០២. *បុរេប្រវត្តិសាស្ត្រខ្មែរ៖ ស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់*. ភ្នំពេញ៖ ពុទ្ធសាសនបណ្ឌិត្យ។

ខ្លូត ធីតា. ២០១៨. *ទស្សនវិជ្ជាប្រវត្តិសាស្ត្រខ្មែរសម័យបុរេប្រវត្តិ នគរភ្នំ និងចេនឡា*. ភ្នំពេញ៖ រាជបណ្ឌិត្យសភា។

ជា មុនីឫទ្ធិ. ២០១២. *ទស្សនវិជ្ជាខ្មែរសម័យហ្វូណន*. ភ្នំពេញ៖ រាជ្យបណ្ឌិត្យសភាកម្ពុជា។

ទាវ ឆែសុក. ១៩៧១. *សិក្សាវប្បធម៌-អរិយធម៌៖ ខ្មែរ-ឥណ្ឌា*. ភ្នំពេញ។

មីសែល ត្រាណេ និងធន ហ៊ុន. *ការគ្រប់គ្រងរដ្ឋនាសម័យមហានគរ៖ សតវត្សរ៍ទី៩ ដល់ទី១៣ នៃគ.ស.* ភ្នំពេញ៖ សាកលវិទ្យាល័យកម្ពុជា។

ពៅ សារឿន. ២០២១. *ប្រវត្តិស្ថាប័នខ្មែរ.* ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

សុខ ប៊ុនធឿន. ២០១៤. *ប្រព័ន្ធច្បាប់ខ្មែរ៖ និក្ខេបបទបណ្ឌិតនីតិសាស្ត្រ.*ភ្នំពេញ៖ រាជបណ្ឌិត្យសភាកម្ពុជា។

Bruno Bruguier និង Juliette Lacroix. ២០០៩. *មគ្គុទ្ទេសក៍បុរាណវិទ្យាកម្ពុជាភាគទី១៖ ភ្នំពេញ និងបណ្តាខេត្តភាគខាងត្បូង* ។

Lunet de Lajonquière. *បញ្ជីសាវរពើភ័ណ្ឌពិពណ៌នាអំពីប្រាសាទនៅកម្ពុជា*, ១៩១១. Paris។

ម៉ៅ ឈាងឡែង. ២០០៦. *ស្ថានីយអង្គរបុរី*។

George Coedès. ១៩៦៦. *សិលាចារឹកនៃប្រទេសកម្ពុជា*, ភាគទី៨, K. ១-៩។

ស៊ន សំណាង ២០២១ ឯកសារបង្រៀន។

George Coedès, ១៩៦៥. *The Indianized States of Southeast Asia* ។

បញ្ជីឈ្មោះក្រុមសិក្ខាស្រាវជ្រាវ
អនុប្រធានបទស្តីពីរចនាសម្ព័ន្ធរដ្ឋបាលនិងទិដ្ឋភាពទូទៅ
នៃការប្រើប្រាស់ច្បាប់ក្នុងសម័យអន្តរ

លរ.	គោតនាម និងនាម	វិជ្ជាជីវៈ	ស្ថាប័ន	ការចូលរួម
១	សាស្ត្រាចារ្យបណ្ឌិត វង់ សុធារ៉ា	ប្រធានដេប៉ាតឺម៉ង់ ប្រវត្តិវិទ្យា	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	អ្នកសម្រប សម្រួល, ផ្តល់ជាតុចូល និង និពន្ធ
២	ឯកឧត្តម ស៊ាង ផល្លា	អនុរដ្ឋលេខាធិការ និងជាប្រធានលេខាធិការដ្ឋាន	ក្រុមប្រឹក្សានីតិកម្ម	ផ្តល់ជាតុចូល
៣	ឯកឧត្តមបណ្ឌិត មាយ ប៊ូរ៉ា	ប្រធានវិទ្យាស្ថានភាសាជាតិ	រាជបណ្ឌិត្យសភាកម្ពុជា	ផ្តល់ជាតុចូល
៤	ឯកឧត្តម អ៊ឹម សុខរិទ្ធី	ប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ	អាជ្ញាធរជាតិអប្សរា	ផ្តល់ជាតុចូល និងនិពន្ធ
៥	ឯកឧត្តម ហ៊ុន ឈុនតេង	ជំនួយការសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងជាសាស្ត្រាចារ្យជំនួយ	សាកលវិទ្យាល័យភូមិន្ទភ្នំពេញ	ផ្តល់ជាតុចូល និងនិពន្ធ
អ្នកសម្របសម្រួលក្រុមស្រាវជ្រាវ				
៦	លោក ម៉ន សុភ័ណ	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ
៧	លោក មាយ សីហា	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ

បញ្ជីអក្សរកាត់

ល.រ.	អក្សរកាត់	អត្ថន័យ
១	ខ.ក.	ខ្មែរកណ្តាល
២	ខ.ច.	ខ្មែរចាស់
៣	គ.ស.	គ្រិស្តសករាជ
៤	ប.ម.ន.	បច្ឆាមរណនាម
៥	បា.	ភាសាបាលី
៦	បា.សំ.	ភាសាបាលីនិងសំស្ក្រឹត
៧	ស.វ.	សតវត្សរ៍
៨	សំ.	ភាសាសំស្ក្រឹត

អនុប្រធានបទស្តីពីរចនាសម្ព័ន្ធរដ្ឋបាលនិងទិដ្ឋភាពទូទៅនៃការប្រើប្រាស់ច្បាប់ក្នុងសម័យអង្គរ

ខ្លឹមសារសង្ខេប

ប្រព័ន្ធច្បាប់នៃចក្រភពខ្មែរសម័យអង្គរ (សតវត្សរ៍ទី៩ ដល់ទី១៥) គឺជាការរួមបញ្ចូលគ្នារវាងគោលការណ៍ច្បាប់ឥណ្ឌាបុរាណ (ដូចជា ធម្មសាស្ត្រ និងច្បាប់មនុ) អំណាចដ៏ខ្ពង់ខ្ពស់របស់ព្រះមហាក្សត្រ និងទំនៀមទម្លាប់ក្នុងស្រុក ដែលបង្កើតបានជា***ប្រព័ន្ធច្បាប់កូនកាត់ (ច្បាប់ហិណ្ឌូ-ខ្មែរ)*** ដែលមានលក្ខណៈទំនៀមដ៏ស្មុគស្មាញ និងមានប្រសិទ្ធភាពអនុវត្តក្នុងសង្គមខ្មែរបុរាណ។ ***គម្ពីរធម្មសាស្ត្រ*** ត្រូវបានប្រើជាក្រមច្បាប់ និងក្រមសីលធម៌ដ៏សំខាន់ ប្រៀបដូចជា ***«ក្បាល»*** ដឹកនាំនៃរដ្ឋ សម្រាប់ផ្តល់ក្របខ័ណ្ឌនីតិរដ្ឋ ក្រមសីលធម៌ និងការអនុវត្តច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌ ចំណែកឯ ***គម្ពីរអេថ៌សាស្ត្រ*** ត្រូវបានប្រើជាក្បួនយុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋ រដ្ឋបាល យោធា សេដ្ឋកិច្ច និងការទូតសម្រាប់គ្រប់គ្រង និងពង្រីកនគរ។

ទិដ្ឋភាពប្រើប្រាស់ច្បាប់ក្នុងការងារយុត្តិធម៌៖ ច្បាប់មិនមែនជាក្រមច្បាប់ចងក្រងតែមួយទេ តែជាការរួមបញ្ចូលគ្នានៃ***គោលការណ៍គ្រឹះពីឥណ្ឌា (ច្បាប់មនុ ធម្មសាស្ត្រ ទណ្ឌនីតិ), ច្បាប់ផ្អែកលើអំណាចព្រះមហាក្សត្រ (ព្រះរាជក្រឹត្យ)*** និង***ការអនុវត្តតាមទំនៀមទម្លាប់ក្នុងស្រុក***។ តាមសិលាចារឹក K.១៦១ ព្រះបាទសូរ្យវរ្ម៌ទី១ (សូរ្យវរ្ម៌នទី១) ប្រៀបធៀបគម្ពីរព្រះធម្មសាស្ត្រប្រដូចនឹង ***«ក្បាល»*** រីឯគម្ពីរដទៃទៀតដូចជាផ្នែកដទៃនៃរាងកាយ ពោលគឺជាក្បាលនៃរដ្ឋ ដែលផ្តល់នូវក្រមសីលធម៌ ច្បាប់សង្គម ច្បាប់តុលាការ និងទោសទណ្ឌ។ ច្បាប់មនុ ជំពូកទី៨ និងទី៩ ផ្តល់គោលការណ៍នីតិសាស្ត្រ (វិវាទផ្លូវច្បាប់ 18 ប្រភេទ) និងច្បាប់គ្រួសារ (មរតក, អាពាហ៍ពិពាហ៍, កាតព្វកិច្ចស្ត្រី)។

ទិដ្ឋភាពទូទៅនៃប្រព័ន្ធតុលាការ៖ ស្ថាប័នតុលាការមានឈ្មោះថា «សភា», «ព្រះសភា» ឬ «សភាស្ថាន» ដោយមានបីកម្រិតគឺ ព្រះសភាស្រុក (ថ្នាក់ទី១ ជាន់ទាប សាលាជម្រះក្តីថ្នាក់ស្រុក) ព្រះសភាវិស័យ (ថ្នាក់ទី២ ជាន់ខ្ពស់ ទំនងជាសាលាជម្រះក្តីថ្នាក់តំបន់) និងព្រះសភានគរ (ថ្នាក់ទី៣ ជាន់ខ្ពស់ តុលាការកំពូលដែលព្រះមហាក្សត្រគ្រប់គ្រង និងទ្រង់ជាចៅក្រម)។ គម្ពីរព្រះធម្មសាស្ត្រ និងច្បាប់មនុ ជាមូលដ្ឋានគ្រឹះនៃនីតិវិធីតុលាការ ដោយមន្ត្រីសំខាន់ៗមានដូចជា សភាបតី (ប្រធានតុលាការ) គុណទោសទស៊ី (ព្រះអាជ្ញា) និង ស្មូតព្រះធម្មសាស្ត្រ (អ្នកជំនាញច្បាប់) ហើយព្រះមហាក្សត្រ «ព្រះគម្ពែងផ្នែកក្រោម» ជាចៅក្រមចុងក្រោយ។ វិវាទភាគច្រើន ដែលមាននិយាយក្នុងសិលា

ចារឹកគឺជារឿង វិវាទដីធ្លី ក្រៅពីនេះមាន ទំនាស់បំណុល ពាណិជ្ជកម្ម សហាយស្មន់ និង ឃាតកម្ម។ ដំណើរការកាត់ក្តីចាប់ផ្តើមពី វាទ (ប្តឹង) រហូតដល់ សភានិណ៌ាយ (សាលក្រម) ហើយការប្តឹងបន្តអាចឡើងដល់ព្រះសភានគរ។ សាក្សីត្រូវបានអនុញ្ញាតឱ្យចូលរួមដោយមិនរើសអើងវណ្ណៈ (ខុសពីឥណ្ឌា) ដោយត្រូវស្បថជាមុន។ ការដាក់ទោស (និណ៌ាយ/និណ្ឌាយ) មានបួនកម្រិតគឺ ១. ឧត្តមសាហ ២. មហាបាតក ៣. បាតក និង ៤. ឧបបាតក ស្របតាមច្បាប់មនុ។ ទណ្ឌកម្មរួមមាន ការពិន័យជាវត្ថុ (បលមាស) ការដាក់ទ្រុង «ចាបិបញ្ជរ» ឬទោសធ្ងន់ធ្ងរ (ដូចជា កាត់ច្រមុះ គាបក្បាល ឬប្រហារជីវិតដោយកប់នៅទ្វារលិចក្រុង)។ ចំពោះបុព្វជិត (ព្រាហ្មណ៍) ច្បាប់តម្រូវឱ្យដាក់ទោស ដោយការនិរទេស ការបាត់បង់កិត្តិយស និងទ្រព្យសម្បត្តិ និងមិនដាក់ទោសលើរូបរាងកាយទេ។

ច្បាប់ប្រើប្រាស់ក្នុងវិស័យពន្ធដារ៖ គោលការណ៍ពន្ធដារមានចែងក្នុងគម្ពីរព្រះធម្មសាស្ត្រ និងអថ៌សាស្ត្រ ដោយកំណត់ថាការយកពន្ធអាករជាសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះមហាក្សត្រ (ក្នុងនាមជាម្ចាស់ផែនដី) ភ្ជាប់ទៅនឹងកាតព្វកិច្ចការពារប្រជារាស្ត្រពីសត្រូវផ្ទៃក្នុង និងខាងក្រៅ។ គោលការណ៍សីលធម៌ នៃការប្រមូលពន្ធតម្រូវឱ្យមានអត្រាពន្ធសមរម្យ (មិនតឹងរ៉ឹងជ្រុល) ដោយមានអត្រាខ្ពស់បំផុត 1/៦ និងទាបបំផុត 1/12 នៃទិន្នផល (ជាពិសេសស្រូវ និងផលិតផលកសិកម្ម)។ គោលការណ៍នេះត្រូវបានប្រៀបធៀបនឹង ***«ឃ្មុំបឺតផ្កា»*** និង ***«កូនគោបៅដោះ»*** ធ្វើយ៉ាងណាមិនឱ្យផ្តាខូចខាតឬងាប់ និងធ្វើឱ្យមេគោបាក់កម្លាំង។ របបពន្ធក្នុងសម័យអង្គរគឺជាប្រព័ន្ធផ្អែកលើ ការទូទាត់ជាវត្ថុ មិនមែនប្រាក់កាសទេ ដោយប្រជាជនបង់ជាទំនិញ ឬផលិតផល (មាស ប្រាក់ ស្រូវ ក្រណាត់ ។ល។)។ ប្រភេទពន្ធសំខាន់ៗរួមមាន ពន្ធលើដីធ្លី ដីកសិកម្ម ពន្ធលើពាណិជ្ជកម្មឬពន្ធគយ ពន្ធលើមុខរបរ ជ្លៀជីវៈ និងជាពិសេសគឺ ពន្ធកម្លាំងពលកម្ម។ កម្លាំងពលកម្ម ***«ថ្វាយព្រះរាជកាយ្យ»*** (បង់ឬផ្តល់កម្លាំងពលកម្មជូនរាជការ) គឺជាកាតព្វកិច្ចដែលប្រជាជនត្រូវផ្តល់ដល់រាជការ ដោយត្រូវបានប្រើប្រាស់សម្រាប់ការងារសាធារណៈ (សាងសង់ប្រាសាទ ផ្លូវ ថ្នល់ ធារាសាស្ត្រ ។ល។) ក្នុងពេលសន្តិភាព និងសម្រាប់កិច្ចការយោធា (កំណែនកងទ័ព) ក្នុងពេលមានចម្បាំង។

ច្បាប់ប្រើប្រាស់លើសុខាភិបាលនៅសម័យអង្គរ៖ ក្នុងរជ្ជកាលព្រះបាទជ័យវរ្ម័នទី ៧ ប្រព័ន្ធសុខាភិបាលដែលទទួលបានការឧបត្ថម្ភពីរាជការទាំងស្រុង ត្រូវបានបង្កើតឡើងយ៉ាងទូលំទូលាយ ដោយព្រះអង្គមានទស្សនថា ***«រោគាផ្លូវចិត្ត មានសេចក្តីឈឺចាប់ខ្លាំងជាងរោគដែលកើតមានក្នុងរាងកាយ ឯសេចក្តីទុក្ខរបស់រាស្ត្រ គឺជាសេចក្តីទុក្ខនៃមេដឹកនាំ***

ទាំងឡាយ, សូម្បីសេចក្តីទុក្ខនោះ មិនមែនជាសេចក្តីទុក្ខផ្ទាល់ខ្លួនក៏ដោយ» ។ ព្រះអង្គ បានបង្កើតបណ្តាញមន្ទីរពេទ្យចំនួន 102កន្លែង ទូទាំងចក្រភពខ្មែរ ដែលត្រូវបានអ្នក ស្រាវជ្រាវចាត់ទុកថាជា ***«ប្រព័ន្ធដែលឧបត្ថម្ភដោយរាជការលើកដំបូងគេរបស់ពិភពលោក»*** ក្នុងសម័យកាលនោះ។ ***ធម្មនុញ្ញនៃមន្ទីរពេទ្យ*** មានចារនៅលើសិលាចារឹកតម្កល់ នៅតាមមន្ទីពេទ្យ និងមានបង្ហាញពីរចនាសម្ព័ន្ធអង្គការលេខស្តង់ដារ ដោយក្នុងនោះមាន **វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឱសថការី និងបុគ្គលិកជំនួយផ្សេងទៀត** ជាសរុបប្រហែល ៩០ - ៩៨ នាក់ បម្រើការនៅមន្ទីរពេទ្យតែមួយ។ អ្វីដែលគួរកត់សម្គាល់បំផុត គឺមន្ទីរពេទ្យ ទាំងនោះបានផ្តល់ ការព្យាបាល និងថែទាំសុខភាពដោយឥតគិតថ្លៃ ដល់ប្រជាជនគ្រប់រូប ព្រមទាំងមានការបូកបញ្ចូលការធ្វើរោគវិនិច្ឆ័យតាមសាសនា (តម្កល់ព្រះបដិមា ព្រះពុទ្ធ ស្តេចជ្នាំ «កៃសជ្ញគុរុ») ផងដែរ។

យុទ្ធសាស្ត្រចម្បាំង និងវិស័យការទូតសម័យអង្គរ៖ កិច្ចការយោធា និងការទូត ត្រូវបានអនុវត្តតាមក្បួនក្នុងគម្ពីរ ***អថ៌សាស្ត្រ***របស់កៅដិល្យ។ ក្រៅអំពីក្បួនគ្រប់គ្រងរដ្ឋ រដ្ឋ បាល និងសេដ្ឋកិច្ច អថ៌សាស្ត្រ មានមុខងារជាក្បួនបង្ហាញការរៀបចំកងទ័ពដ៏រឹងមាំ និង ផែនការយុទ្ធសាស្ត្រនគរ។ យុទ្ធសាស្ត្រចម្បាំង ផ្តោតលើការរៀបចំកងទ័ពរឹងមាំ (កងទ័ព ថ្មើរជើង កងទ័ពសេះ កងទ័ពដំរី កងទ័ពកស្តុភារ និងបូកទាំងកងទ័ពជើងទឹក ដែលខ្មែរ បង្កើតផ្ទាល់) ការប្រើប្រាស់យុទ្ធវិធី (ព្យុហ) សង្គ្រាមចិត្តសាស្ត្រ សង្គ្រាមចារកម្ម («គូឈ បុរុស») និងសង្គ្រាមឡោមព័ទ្ធ «អរោធ»។ ចំណែកឯ យុទ្ធសាស្ត្រការទូត វិញ គឺត្រូវបាន ប្រើប្រាស់ជាឧបករណ៍យុទ្ធសាស្ត្រដើម្បីចៀសវាងសង្គ្រាម ឬត្រៀមខ្លួនច្បាំងប្រកបដោយ ប្រសិទ្ធភាព។ យុទ្ធសាស្ត្រទាំងនោះរួមមាន វិធី ផ្សះផ្សា (សម) ការផ្តល់ អំណោយ (ទាន) ការប្រើប្រាស់ ទ្រឹស្តីប្រព័ន្ធមណ្ឌល (ចងសម្ព័ន្ធមិត្តជាយុទ្ធសាស្ត្រ) យុទ្ធសាស្ត្រ បំបែកបំបាក់ (ភេទ) និងការប្រើប្រាស់បេសកជនទូត ជាភ្នាក់ងារប្រមូលព័ត៌មានសម្ងាត់។ ទាំងការងារយោធា និងការទូត គឺមានគោលដៅសម្រេចបាននូវស្ថិរភាពនគរ និងការ ពង្រីកអំណាចចក្រភព។

សរុបមក ច្បាប់សម័យអង្គរបានបង្ហាញពីភាពបិនប្រសប់ក្នុងការប្រើប្រាស់គោល ការណ៍ដ៏ខ្ពង់ខ្ពស់ពីឥណ្ឌា (ដូចជា ធម្មសាស្ត្រ និង អថ៌សាស្ត្រ) មកសម្របទៅនឹងតម្រូវ ការជាក់ស្តែងរបស់សង្គមខ្មែរ រួមទាំងការបង្កើតប្រព័ន្ធរដ្ឋបាលរឹងមាំ យុត្តិធម៌ យោធា ប្រព័ន្ធសុខាភិបាលសាធារណៈទំនើប និងជាពិសេសបង្កើតបាននូវប្រព័ន្ធច្បាប់ខ្មែរបុរាណ មួយ ដែលមានលក្ខណៈដ៏ទំនើប និងស្របស្រួលជាមួយសង្គមខ្មែរនាសម័យកាលនោះ។

សេចក្តីផ្តើម

ការសិក្សាអំពីច្បាប់របស់រដ្ឋបុរាណនៅអាស៊ីអាគ្នេយ៍ដោយផ្អែកលើកស្តុតាងសិលាចារឹក បានលើកមកជជែកពិភាក្សាក្នុងរង្វង់អ្នកសិក្សាស្រាវជ្រាវយ៉ាងទូលាយលើការបង្កើតរដ្ឋឥទ្ធិពលឥណ្ឌា រចនាសម្ព័ន្ធសង្គមនយោបាយរបស់រដ្ឋដំបូងៗទាំងនោះ។ លោក ហ្សក សេដែស ដែលជាអ្នកសិក្សាត្រួសត្រាយផ្លូវដំបូងគេ បានចាត់ទុកថាទំនៀមច្បាប់ខ្មែរ មានឥទ្ធិពលគំនិតឥណ្ឌានីយកម្មលកើតមកពីការផ្សាយឥទ្ធិពលសាសនានិងច្បាប់ឥណ្ឌា ជាពិសេសគឺគម្ពីរ ***«ធម្មសាស្ត្រ»*** (សំ.; បា.សំ. ធម្មសាស្ត្រ) ដែលជាមូលដ្ឋានគ្រឹះក្នុងភាពជាព្រះរាជានិងសិទ្ធិអំណាចផ្លូវច្បាប់នាសម័យអង្គរ (Cœdès, 1968, pp. 16, 254)។ សេចក្តីអះអាងនេះ ពឹងផ្អែកសំខាន់លើតឹងតាងដែលបន្សល់ទុកពីសម័យបុរាណ ដូចជាសិលាចារឹក សាសនា វត្ថុបុរាណនានា ដែលបង្ហាញអំពីឥទ្ធិពលឥណ្ឌាតាមរយៈសាសនា និងភាសាសំស្ក្រឹត។ ទាំងនេះជារូបភាព ដែលអាចបង្ហាញថាសង្គមអាស៊ីអាគ្នេយ៍បុរាណ ជាពិសេសខ្មែរ ទទួលឥទ្ធិពលពីឥណ្ឌា និងជារដ្ឋឥណ្ឌានីយកម្ម។ អ្នកស្រាវជ្រាវក្រោយៗមក ជាពិសេសលោក ម៉ែឃើល វីកឃើរី បានបដិសេធនឹងគំនិតឥណ្ឌានីយកម្ម ដោយអះអាងថាព័ត៌មានក្នុងសិលាចារឹកខ្មែរអាចបង្ហាញថាច្បាប់និងការយកពន្ធជាដើម គឺឆ្លុះបញ្ចាំងការយកចិត្តទុកដាក់របស់អ្នកស្រុកអាយ ដូចជាការគ្រប់គ្រងដីធ្លី កាតព្វកិច្ចពន្ធកម្លាំងពលកម្ម និងបញ្ហាជម្លោះលើព្រំប្រទល់ដីជាដើម។ លោកពន្យល់ថាការអនុវត្តទាំងនេះ ចាក់ឫសក្នុងរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចខ្មែរច្រើនជាងទទួលយកមកពីឥណ្ឌាទាំងស្រុង (Vickery, 1998)។ គំនិតជាមូលដ្ឋានសំខាន់ទាំងពីរនេះ អាចឱ្យយើងសង្កេតឃើញជាកណ្តាលថា សង្គមខ្មែរ ក៏ដូចជាសង្គមបុរាណនៅអាស៊ីអាគ្នេយ៍ បានធ្វើសមាហរណកម្មគំនិតដែលមាននៅក្នុងស្រុកនិងគំនិតដែលបានមកពីឥណ្ឌា។ ជាតុច្បាប់សំខាន់ៗនៅក្នុងគម្ពីរធម្មសាស្ត្រ ដែលមានប្រភពមកពីឥណ្ឌា បានបង្ហាញក្នុងទម្រង់ជាវាក្យសព្ទ, ការអនុវត្តទោស, ព័ត៌មានបង្ហាញពីការគោរព ការសិក្សារៀនសូត្រ និងអ្នកមានវិជ្ជាស្ទាត់ជំនាញខាងគម្ពីរនេះ អាចបញ្ជាក់ពីឥទ្ធិពលនេះបាន ខណៈដែលព័ត៌មានក្នុងសិលាចារឹកក៏បានបង្ហាញពីទម្រង់របស់ច្បាប់តាមបែបអ្នកស្រុកអាយផ្ទាល់។

ដំណើរវិវត្តនៃច្បាប់ខ្មែរ គឺស្ថិតនៅចន្លោះរវាងឥណ្ឌានិងបស្ចិមប្រទេស ដែលឧបករណ៍ច្បាប់ពីខាងក្រៅទាំងនេះហាក់ក្លាយជាបន្ទាត់ក្រិតមួយ។ ច្បាប់ទំនើបក្នុងប្រទេសកម្ពុជាបច្ចុប្បន្ន ទទួលឥទ្ធិពលពីបស្ចិមប្រទេស ខុសប្លែកពីច្បាប់សម័យបុរាណដែលទទួលឥទ្ធិពលមកពីឥណ្ឌា។ ហេតុដូច្នេះហើយ ទើបនៅក្នុងការពិនិត្យលើទំនាក់ទំនងរវាងច្បាប់ក្នុងសង្គមបុរាណ និងសង្គមបច្ចុប្បន្ន មានបញ្ហាលំបាកដែលចោទឡើង។ ចំពោះពាក្យ ***«ច្បាប់»***

មិនមាននិយមន័យតែមួយដូចគ្នានៅក្នុងវប្បធម៌ ភាសា និងពេលវេលាផ្សេងគ្នានោះទេ (Davis & Lustig, 2023, p. 239)។ ជាក់ស្តែងក្នុងភាសាខ្មែរ បើគិតពីន័យជាតិសព្ទរបស់ពាក្យ ***«ច្បាប់»*** គឺកម្លាយចេញមកពីពាក្យឫស ***«ចាប់»*** ដែលសំដៅដល់ការចាប់ឱ្យអនុវត្តតាម និងជាក់ពិន័យចំពោះអំពើដែលសង្គមយល់ថាខុសប្រក្រតី មិនតាមទម្លាប់ដែលសង្គមយល់ស្របព្រមទាំងប្រតិបត្តិរៀងមក (ស៊ីយ៉ុន, ២០២៤)។

ច្បាប់ខ្លះមានលក្ខណៈត្រឹមជាការទូន្មានផ្នែកសីលធម៌ប៉ុណ្ណោះ ដូចជា ច្បាប់ប្រុសច្បាប់ស្រី ច្បាប់ប្រដៅកូនចៅ។ល។ នៅមានបច្ចេកសព្ទដទៃទៀតក្នុងភាសាខ្មែរ ដែលគ្របដណ្តប់លើច្បាប់ផង និងក្រៅដែននៃច្បាប់បច្ចុប្បន្នផង។ ដូច្នេះហើយ ការពិនិត្យមើលលើច្បាប់សម័យបុរាណ ជាពិសេសសម័យអង្គរដែលជាអារ្យធម៌ជាប់ទាក់ទងនឹងសាសនា មិនអាចកាត់ផ្តាច់ច្បាប់ចេញពីសាសនា ក្រុមរាជវង្សកាន់អំណាច និងអង្គការលេខនៃប្រព័ន្ធគ្រប់គ្រងនាសម័យនោះបានទេ (Hooker, 1978, p. 98)។ ចំពោះព្រះបន្ទូល ព្រះរាជបញ្ជា ឬពាក្យបុរាណហៅថា **«ព្រះសាសន៍»** របស់ព្រះមហាក្សត្របង្ហាញពីបទបញ្ញត្តិច្រើនជាងអំណាចច្បាប់នៅក្នុងទិដ្ឋភាពច្បាប់សម័យទំនើប។ ប៉ុន្តែយ៉ាងនេះក្តី ក្នុងសម័យបុរាណ ព្រះសាសន៍ ឬព្រះបន្ទូលគឺជាច្បាប់ (Lingat, 1949)។ សិលាចារឹកនៅសម័យមុនអង្គរ បង្ហាញពីព្រះរាជអាជ្ញាឬព្រះរាជតម្រាស់របស់ព្រះមហាក្សត្រ តែងបញ្ញត្តិថានរណាដែលល្មើសនឹងព្រះរាជបញ្ជា អ្នកនោះនឹងត្រូវទទួលទោសទណ្ឌ។

ច្បាប់ខ្មែរបុរាណ (សម័យមុនអង្គរ-អង្គរ) ពិបាកនឹងឆ្លុះបញ្ចាំងរកលក្ខណៈជាខ្មែរឱ្យបានធំទូលាយណាស់ ដោយសារតែពុំមានសល់ក្បួនច្បាប់ទាំងនោះផង និងសិលាចារឹកពុំសូវបង្ហាញឱ្យឃើញចំណុចទាំងនោះផង។ ហេតុដូច្នេះហើយ ទើបគេច្រើនតែមើលក្បួនច្បាប់ពីឥណ្ឌា តាមរយៈឥទ្ធិពលចម្លាក់ និងព័ត៌មានក្នុងសិលាចារឹកជាដើម មកឆ្លុះបញ្ចាំងព្រមទាំងបង្ហាញឱ្យឃើញថាច្បាប់ពីបុរាណហាក់ទទួលឥទ្ធិពលមកពីក្រៅទាំងស្រុង។ យ៉ាងនេះក្តី ច្បាប់ខ្មែរពិតជាមិនអាចប្រកែកបានថាមិនទទួលឥទ្ធិពលច្បាប់ពីឥណ្ឌាប្រាកដមែន។ ទាំងច្បាប់បែបខ្មែរ និងច្បាប់ទទួលឥទ្ធិពលពីឥណ្ឌា មិនមានរូបភាព ខ្លឹមសារ ដូចគ្នាទៅនឹងអត្ថបទឬបែបបទច្បាប់នៅសង្គមលោកខាងលិចនោះទេ។ ដូច្នេះហើយទើបគេយល់ថា គេយល់ថាអត្ថបទពីបុរាណតាមរយៈសិលាចារឹករបស់សង្គមអាស៊ីអាគ្នេយ៍ រួមទាំងកម្ពុជា គឺជាអត្ថបទច្បាប់ (Hooker, 1978)។ អត្ថបទទាំងនោះបង្ហាញអំពី អ្នកគ្រប់គ្រង និងអ្នកដែលត្រូវគ្រប់គ្រង (Lingat, 1949)។ សម័យបុរាណមានសញ្ញាណច្បាប់តិចតួចជាងបទបញ្ញត្តិការអនុវត្តបែបប្រពៃណី កាតព្វកិច្ចសីលធម៌ដែលចង់ភ្ជាប់នឹងសាសនា វណ្ណៈ និងឋានៈសង្គ

ម។ ទំនួលខុសត្រូវបុគ្គល គឺជាបញ្ហាសីលធម៌ សីលធម៌ ឬសាសនា ព្រោះវាក៏ជាប់ទាក់ទងនឹង 'ផ្លូវច្បាប់' ដែរ។ លើសពីនេះ កាតព្វកិច្ចរបស់បុគ្គលម្នាក់ៗប្រែប្រួលយ៉ាងទូលំទូលាយទៅតាមស្ថានភាព។ កាតព្វកិច្ចផ្លូវច្បាប់ទាំងអស់មិនត្រូវបានអនុវត្តលើបុគ្គលគ្រប់រូបដូចគ្នានោះទេ ប៉ុន្តែអាស្រ័យលើជាតិសាសន៍ ភេទ វណ្ណៈ និងសាសនា (Lingat, 1949)។ សកម្មភាពសេដ្ឋកិច្ច សូម្បីតែការទិញដូរដីធ្លីជាដើម ក៏ជាប់ទាក់ទងនឹងវិស័យច្បាប់ដែរ (Lustig, 2009)។ នៅក្នុងសិលាចារឹកខ្មែរ មានបង្ហាញច្រើនអំពីការលើកលែងពន្ធដល់សហគមន៍ និងក្រុមមន្ត្រីដែលចុះអនុវត្តការប្រមូលពន្ធផង។ សម័យអង្គរ ប្រហែលជាពុំមានបែងចែកច្បាប់ដាច់ដោយឡែក ជាច្បាប់ស៊ីវិលនិងច្បាប់ព្រហ្មទណ្ឌដូចសម័យបច្ចុប្បន្នទេ។

អ្នកស្រាវជ្រាវយល់ថាច្បាប់របស់ខ្មែរនិងសង្គមអាស៊ីអាគ្នេយ៍ពីបុរាណ មានឥទ្ធិពលពីឥណ្ឌា ដោយឈរលើមូលដ្ឋានសាសនា។ ពាក្យ ***«ច្បាប់»*** ត្រូវនឹងពាក្យសំស្ក្រឹតថា ***«ធម៌»*** ដែលជាប់ទាក់ទងនឹងវណ្ណៈនិងវ័យ។ យ៉ាងនេះក្តី ពាក្យ ***«ធម៌»*** ក្នុងភាសាសំស្ក្រឹតមានន័យធំទូលាយជាងពាក្យ ***«ច្បាប់»*** ឬ ***«នីតិ»*** ក្នុងសម័យបច្ចុប្បន្ន។ គម្ពីរច្បាប់នៅឥណ្ឌាមានដូចជាធម៌សូត្រ ធម្មសាស្ត្រ មានវធម្ម៌សាស្ត្រ និងមនុស្មឹតិ (មនស្មឹតិ = ច្បាប់មនុ) (Davis & Lustig, 2023)។ ច្បាប់មនុ មានសៀវភៅ១២ក្បាល ចែងពីច្បាប់សង្គម សាសនា (ការប្រតិបត្តនិងកិច្ចពិធី) ទំនាក់ទំនងបុគ្គល នយោបាយ សង្គ្រាម ព្រមទាំងការគ្រប់គ្រងវិស័យយុត្តិធម៌ផង។ ច្បាប់ទាំងនេះឆ្លុះបញ្ចាំងពីច្បាប់សម័យទំនើបដូចជា ច្បាប់ស៊ីវិល កិច្ចសន្យា ព្រហ្មទណ្ឌ ទ្រព្យសម្បត្តិ គ្រួសារ និងប្រព័ន្ធតុលាការផង (Lingat, 1949, 1973, pp. 77–87)។

ចំណែកឯ អថ៌សាស្ត្រ របស់ព្រាហ្មណ៍កៅដិល្យ ជាភស្តុតាងកាន់តែទូលាយទាក់ទងនឹងច្បាប់នៃការគ្រប់គ្រងរដ្ឋ ដែលជាប់ទាក់ទងនឹងព្រះរាជាគ្រប់គ្រង និងនីតិវិធីច្បាប់ (Olivelle, 2013, p. 29)។ ភស្តុតាងឥទ្ធិពលច្បាប់ពីឥណ្ឌានៅក្នុងសង្គមខ្មែរបុរាណដែលមានចំណាស់ជាងគេ គឺមានសរសេរក្នុងសិលាចារឹកអង្គជំនីក K.៥៣ (ឆ្នាំ ៦៦៧) ដែលបង្ហាញពីមន្ត្រី២រូបរបស់ព្រះបាទស្រីភវរ៉ម្ម៌ទី១ (ភវរ៉ន្ទ្រវរ្ម៌ទី១) មានជំនាញខាងធម្ម៌សាស្ត្រ និងអថ៌សាស្ត្រ។ គម្ពីរទាំងនេះ បានបង្ហាញក្នុងសិលាចារឹកក្នុងរាជ្យព្រះរាជាក្រោយៗមកទៀតដូចមានក្នុងសិលាចារឹកព្រៃប្រាសាទ K.២៧៩ ដែលជាសិលាចារឹកនិយាយអំពីយសោធរាស្រមក្នុងរាជ្យព្រះបាទស្រីយសោវ៌ម្ម៌ទេវទី១ (យសោវរ្ម៌ន្ទ្រទី១)។


តឹកតាងគួរឱ្យចាប់អារម្មណ៍មួយទៀត នៅក្នុងសិលាចារឹកប្រាសាទព្រះខ័នកំពង់ស្វាយ K.១៦១ ព្រះបាទស្រីសូរ្យវ៌ម្ម៌ទេវទី១ (សូរ្យវរ្ម៌ន្ទ្រទី១) បានប្រដូចគម្ពីរព្រះធម្ម៌សាស្ត្រ

ទៅនឹងក្បាល និងគម្ពីរវិទ្យាដទៃទៀតដូចនឹងផ្នែកផ្សេងៗនៃសរីរាង្គ (Lingat, 1949, pp. 77–87, 1973; Sahai, 1970, pp. 9–38) ដែលអាចឆ្លុះបញ្ចាំងសារៈសំខាន់របស់គម្ពីរព្រះធម្មសាស្ត្រនិងសង្គម។ មនុស្សពុំអាចរបស់បានដោយឥតក្បាល ដូចនឹងរដ្ឋដែលមិនអាចដំណើរការបានដោយឥតច្បាប់ គឺគម្ពីរព្រះធម៌សាស្ត្រ ដែលជាច្បាប់កំពូលរបស់រដ្ឋសម័យនោះ។

១. ក្បួនច្បាប់ប្រើប្រាស់សម្រាប់រៀបចំរាជធានីនៃចក្រភពខ្មែរ

តំបន់អង្គរ ជាតំបន់ដែលមានភូមិសាស្ត្រពិសេស ស្របតាមក្បួនរៀបចំក្រុងតាមប្រពៃណីវប្បធម៌ឥណ្ឌា ដែលខ្មែរបានទទួលឥទ្ធិពល ហើយយកមកប្រើប្រាស់សម្រាប់រៀបចំក្រុង ភូមិស្រុកនិងផ្ទះសម្បែងជាដើម។ ចំណុចភូមិសាស្ត្រពិសេសនោះមាន ភ្នំគូលែននៅខាងជើង ទីធ្លាសម្រាប់កសាងក្រុងនៅកណ្តាល និងទន្លេសាបនៅខាងត្បូង។ ការជ្រើសរើសនេះ គឺតម្រូវតាមក្បួនលោកធាតុវិទ្យា (Cosmology) ដែលភ្នំព្រះសុមេរុនៅខាងជើង (ខ្មែរមានភ្នំគូលែន រីឯឥណ្ឌាមានភ្នំហិមពាន្ត) ជម្ពូទ្វីបនៅកណ្តាល (អង្គរនៅខ្មែរ ឧបទ្វីបឥណ្ឌានៅឥណ្ឌា) និងមហាសមុទ្រនៅខាងត្បូង (ទន្លេសាបនៅខ្មែរ មហាសមុទ្រនៅឥណ្ឌា)។ ទីតាំងដែលបានជ្រើសរើស ជាតំបន់មានស្រទាប់ដីរឹងមាំ មិនស្រុត មិនរអិល មិនញ័រ ដែលជាមូលដ្ឋានគ្រឹះដើម្បីទ្រទ្រង់ទម្ងន់របស់ប្រាសាទរាប់លានតោន។ ម្យ៉ាងទៀតក៏ជាតំបន់មានអាងទឹកធម្មជាតិសម្រាប់ស្រោចស្រព នោះគឺភ្នំគូលែនដែលជាអាងទឹកស្ថិតនៅខាងលើ ព្រមទាំងមានសណ្ឋានដីទេរក្នុងជម្រាលទាប ចុះពីជើងមកត្បូងពោលគឺពីភ្នំគូលែន ចុះមកទន្លេសាប។

រូប ១. ភូមិសាស្ត្ររាជធានីនៅតំបន់អង្គរ



ប្រភព៖ ផុន តារា មន្ត្រីអាជ្ញាធរជាតិអប្សរា

២. ទ្រឹស្តីនយោបាយដែលឆាំឱ្យខ្មែរនៅសម័យអង្គរចម្រុងចម្រើនរុងរឿង

២.១. ភ្ជួនរាជមណ្ឌលតាមច្បាប់អថ៌សាស្ត្រ

ប្រព័ន្ធរាជមណ្ឌល (Mandala System) ក្នុងសម័យអង្គរ គឺជាគំរូនយោបាយដែលបានប្រើដើម្បីគ្រប់គ្រង ចក្រភពខ្មែរ។ ***«មណ្ឌល»*** (Mandala) ជាពាក្យសំស្ក្រឹតដែលមានន័យថា ***«វង្វង់»*** ឬ ***«បរិវេណ»*** ហើយត្រូវបានអ្នកប្រវត្តិសាស្ត្រលោកខាងលិចនាចុងសតវត្សរ៍ទី២០ យកមកសិក្សាដើម្បីវិភាគអំពីប្រព័ន្ធនយោបាយនៅអាស៊ីអាគ្នេយ៍សម័យបុរាណ ដោយសារតែប្រព័ន្ធនេះមានភាពខុសប្លែកពីគំនិតនៃ ***«រដ្ឋជាតិ»*** (Nation-State) ដែលមានព្រំដែនកំណត់ច្បាស់លាស់។ ប្រព័ន្ធរាជមណ្ឌល គឺជាបណ្តុះនៃគំនិតទស្សនៈដ៏មានសារៈសំខាន់ ដែលចក្រភពខ្មែរបានអនុវត្តគ្រប់គ្រងអំណាចក្នុងរយៈពេលជាច្រើនសតវត្ស។ ជាប្រព័ន្ធដែលមានលក្ខណៈ វិមជ្ឈការ ផ្អែកលើ ទំនាក់ទំនងផ្ទាល់ខ្លួន រវាងមេដឹកនាំ និងមិនផ្អែកលើ ដែនដីកំណត់ច្បាស់លាស់ ដូចរដ្ឋសម័យទំនើបនោះទេ។ ប្រព័ន្ធនេះបានផ្តល់នូវភាពបត់បែននិងភាពប្រាកដនិយមសម្រាប់ការគ្រប់គ្រងនយោបាយនៅទូទាំងអាស៊ីអាគ្នេយ៍ដែលមានវប្បធម៌ចម្រុះនិងភូមិសាស្ត្រលំបាកក្នុងការគ្រប់គ្រង។

នាសម័យបុរាណ ខ្មែរបានទទួលយកនូវប្រព័ន្ធគ្រប់គ្រងរដ្ឋតាមបែបឥណ្ឌា គឺប្រព័ន្ធ ***«មណ្ឌល»*** ឬ ***«រាជមណ្ឌល»*** (Mandala System) ដែលមានរាជអំណាចកណ្តាលមួយ (អង្គរ) និងមានរាជអំណាចរណប (សាមន្តរាជ) ប្រមាណ២៣ (Sahai, 1970)។ រាជមណ្ឌលមានរចនាសម្ព័ន្ធដូចខាងក្រោម៖

រាជអំណាចកណ្តាល ឬ អំណាចមជ្ឈិម៖ សំដៅដល់នគរ ឬ ព្រះមហាក្សត្រដ៏ខ្លាំងមាំមួយអង្គ កាន់អំណាចនៅចំណុចកណ្តាលនៃមណ្ឌល។ អំណាចកណ្តាលធ្វើឱ្យនគររណបព្រមនៅចំណុះ រក្សារាជអំណាចនគរចំណុះនោះឱ្យនៅដដែល និងធ្វើឱ្យគេពេញចិត្តរួមរស់ក្នុងប្រព័ន្ធ។

វិសាលភាពនៃឥទ្ធិពលត្រួតត្រា៖ អំណាចកណ្តាលគ្របដណ្តប់លើស្តេចនគររណប(សាមន្តរាជ) ក្នុងវង្វង់នៃឥទ្ធិពលដែលអាចគ្រប់គ្រងបាន។

ប្រព័ន្ធសួយសារអាករ៖ នគរតូចៗដែលជាដែនរណបដែលនៅជុំវិញអំណាចកណ្តាល បានទទួលស្គាល់អធិបតេយ្យភាពរបស់ខ្លួនជារដ្ឋចំណុះ ហើយតាមទម្លាប់ត្រូវផ្តល់

សួយសារអាករប្រចាំឆ្នាំ និងត្រូវមានភក្តីភាពជាមួយអំណាចកណ្តាល។ អំណាចកណ្តាលមានកាតព្វកិច្ចការពារ ទំនុកបម្រុង និងផ្តល់សិទ្ធិអំណាចឱ្យគ្រប់គ្រង និងចាត់ចែងគ្រប់គ្រងតាមរបបរបស់ខ្លួន។

ទំនាក់ទំនងរវាងនគរកណ្តាលនិងនគរណាប៖ ស្មោះត្រង់និងភក្តីភាពជាទម្លាប់ដឹកនាំចម្បង ដោយទទួលខុសត្រូវគ្រប់គ្រងរដ្ឋដោយខ្លួនឯង ព្រមទាំងបង្កើននិងជំរុញទំនាក់ទំនងសម្ព័ន្ធភាពនិងកាតព្វកិច្ចទទួលខុសត្រូវ។

រក្សាស្វ័យភាពនៅមូលដ្ឋានជាសំខាន់៖ រាជអំណាចរណបដែលបង់សួយសារអាករ អាចរក្សាបាននូវឯករាជ្យភាពរបស់ខ្លួន និងស្វ័យភាពការចាត់ចែងគ្រប់គ្រងកិច្ចការផ្ទៃក្នុងរបស់ខ្លួន។

២.២. ធនធានមនុស្ស

ប្រព័ន្ធបណ្តុះបណ្តាលមនុស្សខ្មែរបុរាណមានកំណើតប្រមាណជិតពីរពាន់ឆ្នាំមកហើយ។ ប្រវត្តិនៃការអភិវឌ្ឍនិងការរៀបចំបណ្តុះបណ្តាលចំណេះដឹងរបស់កម្ពុជា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធនឹងអន្តរកម្មរវាងវប្បធម៌ឥណ្ឌា និងវប្បធម៌ខ្មែរដើម។ ភស្តុតាងបុរាណវិទ្យា និងសិលាចារឹក បង្ហាញពីការរៀបចំលម្អិតនៃកន្លែងរៀនសូត្រ ដែលពិតជាមជ្ឈមណ្ឌលអប់រំដ៏ខ្ពស់ ដែលមានសាលបង្រៀន បណ្ណាល័យ និងកន្លែងស្នាក់នៅរបស់គ្រូនិងសិស្ស។

ភស្តុតាងនៃការបណ្តុះបណ្តាលមនុស្សសម័យបុរាណ ជាកញ្ចក់ឆ្លុះបញ្ចាំងពីភាពរុងរឿងរបស់កម្ពុជា ដែលបានផលិតវរជនឆ្នើមៗលើគ្រប់វិស័យ។ ការងារបណ្តុះបណ្តាលមានឫសគល់នៅក្នុងក្បួនច្បាប់បុរាណ ព្រហ្មញ្ញសាសនា ព្រះពុទ្ធសាសនា អត្ថបទទស្សនវិជ្ជា និងប្រពៃណីវប្បធម៌សាសនាព្រាហ្មណ៍និងព្រះពុទ្ធសាសនា ដែលបង្កើតជាមូលដ្ឋាននៃចំណេះដឹងទូទៅ និងបង្កើតឱ្យមានវិជ្ជាសំខាន់ជាច្រើន ដូចជា គណិតវិទ្យា តារាសាស្ត្រ វេជ្ជសាស្ត្រ ទស្សនវិជ្ជា អក្សរសិល្ប៍ ស្ថាបត្យកម្ម នគរោបនីយកម្ម វិស្វកម្ម នយោបាយ ការទូត សិល្បៈចម្បាំងជាដើម។

២.៣. ធនធានសេដ្ឋកិច្ច

សេដ្ឋកិច្ចនៃចក្រភពខ្មែរ (សតវត្សទី ៩-១៥) គឺជាប្រព័ន្ធទំនើបមួយដែលទ្រទ្រង់អំណាចនិងនាំនគរឱ្យរុងរឿង។ វាជាប្រព័ន្ធចលករមួយ មិនមែនពឹងផ្អែកតែលើកសិកម្ម ដូចដែលគេគិតស្មានដូចនគរនានាបានទទួលឥទ្ធិពលឥណ្ឌានោះទេ។ ប្រព័ន្ធ

នេះ រួមផ្សំគ្នាយ៉ាងសកម្មរវាងការងារកសិកម្ម សិប្បកម្ម(ទម្រង់កំណើតឧស្សហកម្ម) និងពាណិជ្ជកម្ម។

២.៣.១. ទិដ្ឋភាពសំខាន់ៗនៃសេដ្ឋកិច្ចអង្គរ

កសិកម្មជាគ្រឹះប្រៀបដូចគល់ឈើធំមួយ៖ ស្រែចម្ការ គឺជាឆ្អឹងខ្នងសម្រាប់ទ្រទ្រង់ចិញ្ចឹមជីវភាពខ្លួន។ កសិកម្មដំណើរការបានអាស្រ័យលើប្រព័ន្ធធារាសាស្ត្រ និងភូមិសាស្ត្រអំណោយផលរបស់តំបន់មួយ។ ប្រព័ន្ធទឹកសំខាន់របស់កម្ពុជា គឺបណ្តាញព្រែកធម្មជាតិជាច្រើន និងការជីកផ្លូវទឹកភ្ជាប់បណ្តាញជាមួយប្រព័ន្ធទន្លេ និងស្ទឹងធំៗទាំងប៉ុន្មានដែលកកើតដោយធម្មជាតិ។ បណ្តាញធារាសាស្ត្របែបនេះ ធ្វើឱ្យចក្រភពមានលទ្ធភាពបង្កើនផលិតបានច្រើនដងក្នុងមួយឆ្នាំ សម្រាប់ទ្រទ្រង់ប្រជាជនដ៏ច្រើន និងបង្កើតជាមូលដ្ឋានសម្រាប់ការធ្វើពាណិជ្ជកម្ម ប្រព័ន្ធធារាសាស្ត្រនៅតាមរាជធានីនិងក្រុងនានារបស់ចក្រភពខ្មែរ មិនមែនបម្រើការងារកសិកម្មសម្រាប់ចិញ្ចឹមចក្រភពទាំងមូលទេ តែអាចបម្រើការងារកសិកម្មទ្រទ្រង់មនុស្សរស់នៅក្នុងរាជធានីបានខ្លះ។ ឯប្រព័ន្ធធារាសាស្ត្រក្នុងក្រុងមានសារៈសំខាន់ខ្លាំងសម្រាប់បម្រើរចនាសម្ព័ន្ធនៃនគរោបនីយកម្ម។

ធនធានធម្មជាតិ៖ មហាអំណាចពីរនៅក្នុងតំបន់អាស៊ីបុរាណ គឺចក្រភពចិននិងឥណ្ឌា បានចូលមកទឹកដីកម្ពុជាបុរាណ គ្មានអ្វីក្រៅពីស្វែងរកធនធានធម្មជាតិនោះទេ។ ធនធានទាំងនោះមានដូចជា៖ គ្រឿងទេស រុក្ខជាតិឱសថ ក្រមួន ភ្លុកដំរី កុយរមាស ជំរុក្ខជាតិផ្សេងៗ សត្វស្អែកសត្វ ខ្លឹមច័ន្ទន៍ក្រស្នា ក្រញូង និងរោមស្លាបបក្សីល្អៗ មានរោមត្រយ៉ងខៀវជាដើម។

សិប្បកម្មរីកចម្រើន៖ សិប្បកម្មគឺជាទម្រង់កំណើតនៃឧស្សហកម្មបច្ចុប្បន្ន ដែលចក្រភពខ្មែរមានមជ្ឈមណ្ឌលផលិតកម្មលោហធាតុក្នុងតំបន់ដ៏សំខាន់ អំបិល និងកុលាលភាជន៍ជាដើម។ កស្តុតាងបុរាណវិទ្យាបង្ហាញពីស្តានីយស្លដែកស្ទើរតែពេញខេត្តព្រះវិហារ កំពង់ធំ ឧត្តរមានជ័យ និងសៀមរាប។ ផលិតកម្មកុលាលភាជន៍មានស្ទើរតែគ្រប់តំបន់ពាសពេញអាណាចក្រ។ ផលិតកម្មអំបិលមាននៅតំបន់នគរាជសីមា ជុំវិញក្រុងកិមាយ។ ផលិតកម្មទាំងនេះ បង្ហាញពីកម្រិតបរិមាណលើសពីការចិញ្ចឹមជីវិតជាមូលដ្ឋាន។

បណ្តាញពាណិជ្ជកម្មទូលំទូលាយ៖ កម្ពុជាមានទីតាំងយុទ្ធសាស្ត្រនៅលើបណ្តាញដួញដូរផ្លូវសមុទ្ររវាងលោកខាងលិចភ្ជាប់មកលោកខាងកើត (East-West Economic Corridors) ។ នេះជាសក្តានុពលភូមិសាស្ត្រ ដែលផ្តល់លទ្ធភាពឱ្យកម្ពុជាបានចូលរួមយ៉ាងសកម្មក្នុងពាណិជ្ជកម្មទាំងក្នុងតំបន់និងពិភពលោក ដើម្បីអភិវឌ្ឍ

អំណាចសេដ្ឋកិច្ចរបស់ខ្លួន។ ព្រះមហាក្សត្រអង្គរ មិនត្រឹមតែពឹងផ្អែកលើធនធានកសិកម្មប៉ុណ្ណោះទេ ប៉ុន្តែលោកក៏បានបង្កើតបណ្តាញគមនាគមន៍ផ្លូវគោក និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ ដើម្បីតភ្ជាប់នឹងបណ្តាញផ្លូវសមុទ្រលិចកើតដ៏សំខាន់នេះ សម្រាប់បើកមុខចក្រភពចូលក្នុងជំនួញពាណិជ្ជកម្មជាមួយពិភពខាងក្រៅ។ វិស័យនេះបង្កើនប្រភពចំណូលច្រើនសម្រាប់ខ្មែរ ហើយក៏ជាផ្នែកសំខាន់មួយនៃនយោបាយរបស់អង្គរផងដែរ។

អំណាចកណ្តាលអង្គរបានចាប់ផ្តើមគោលនយោបាយពាណិជ្ជកម្មនេះពីសតវត្សទី១០ និងសម្រេចបានគោលបំណងនេះនៅសតវត្សទី១១។ ចាប់ពីរជ្ជកាលព្រះបាទស្រីសូរ្យវរ្ម៌ទី១ (សូរ្យវរ្ម៌ទី១ គ.ស. ១០០២-១០៥០) នាសតវត្សរ៍ទី១១ ចក្រភពខ្មែរបានចាប់ផ្តើមពង្រីក អំណាចរបស់ខ្លួនទៅទិសខាងលិចពាសពេញអាងទន្លេមេណាមនិងឆ្ពោះទៅកាន់តំបន់ប្លរដីក្រា (KRA) នៃឧបទ្វីបម៉ាឡាយូ។ អធិបតេយ្យភាពអង្គរដែលត្រូវបានដាក់លើទឹកដីលពបុរី បាននាំបណ្តាញពាណិជ្ជកម្មលើដីគោករបស់ខ្លួនឱ្យចូលទៅដល់ពាណិជ្ជកម្មអន្តរជាតិនៅតាមប្របបណ្តោយឆ្នេរនៃប្រទេសថៃភាគខាងត្បូងបច្ចុប្បន្ន។ ទីនោះហើយ ដែលបាននអនុញ្ញាតឱ្យខ្មែរមានទំនាក់ទំនងផ្ទាល់ជាងមុនជាមួយផ្លូវពាណិជ្ជកម្មអន្តរជាតិ ជាមួយចិននៅខាងកើត ក៏ដូចជាទីផ្សារលោកខាងលិចពែរ្ស និងឥណ្ឌាផងដែរ។

ប្រព័ន្ធយកពន្ធ៖ ចក្រភពអង្គរបានអនុវត្តប្រព័ន្ធពន្ធដារ ដើម្បីធានាថាធនធានហូរពីបណ្តានគរណាបចំណុះខ្លួន។ ប្រព័ន្ធយកពន្ធដានេះ គឺជាផ្នែកសំខាន់មួយដែលទ្រទ្រង់អំណាច និងភាពរុងរឿងនៃចក្រភពនេះ។ តាមរយៈការប្រមូលធនធានពីប្រជាជនរដ្ឋាភិបាលអង្គរអាចកសាងហេដ្ឋារចនាសម្ព័ន្ធដ៏មហិមា ថែរក្សារដ្ឋបាលនិងកងទ័ព ហើយធ្វើឱ្យចក្រភពនេះក្លាយជាមហាអំណាចក្នុងតំបន់។ ទម្រង់នៃពន្ធដា៖

- **ពន្ធលើដីធ្លី៖** នេះទំនងជាទម្រង់ពន្ធដាសំខាន់មួយ ដោយសារកសិកម្មជាមូលដ្ឋានគ្រឹះនៃសេដ្ឋកិច្ចអង្គរ។ ប្រជាកសិករត្រូវបង់ផលដំណាំមួយចំណែក ឬទិន្នផលកសិកម្មផ្សេងទៀតទៅឱ្យរដ្ឋ ឬមន្ត្រីមូលដ្ឋាន។
- **ពន្ធលើផលិតផល៖** ក្រៅពីដំណាំ ប្រហែលជាមានពន្ធលើផលិតផលផ្សេងទៀតដូចជា ត្រី សត្វព្រៃ ឬទំនិញដែលផលិតដោយសិប្បករ។
- **ពន្ធលើកម្លាំងពលកម្ម៖** ប្រជាជនអាចត្រូវតម្រូវឱ្យបម្រើការងារសាធារណៈដូចជាការសាងសង់ប្រាសាទ ទំនប់ទឹក ផ្លូវថ្នល់ ឬកិច្ចការផ្សេងៗទៀត

សម្រាប់រដ្ឋជំនួសឱ្យការបង់ពន្ធជាប្រាក់ ឬវត្ថុ។ កម្លាំងពលកម្មនេះមានសារៈសំខាន់ណាស់សម្រាប់ការកសាងហេដ្ឋារចនាសម្ព័ន្ធដ៏ធំសម្បើមក្នុងសម័យអង្គរ។

- **ពន្ធលើពាណិជ្ជកម្ម៖** ពាណិជ្ជករទាំងក្នុងស្រុក និងក្រៅស្រុកប្រហែលជាត្រូវបង់ពន្ធលើទំនិញដែលពួកគេធ្វើពាណិជ្ជកម្ម។ នេះអាចរួមបញ្ចូលពន្ធគយសម្រាប់ទំនិញនាំចូល និងនាំចេញ។

៣. ចនាសម្ព័ន្ធរដ្ឋបាលសម័យបុរាណ

តាមក្បួនឥណ្ឌាសមាសធាតុរដ្ឋ ដែលហៅតាមភាសាសំស្ក្រឹតថា **សប្តប្រកឹតិ**, **សប្តាង្គ** ឬ **រាជ្យាង្គ** របស់ព្រាហ្មណ៍កៅដិល្យ ចែងថារដ្ឋមួយត្រូវមានអង្គប្រកបចំនួន៧៖ **ស្វាមី** (ព្រះមហាក្សត្រ) **អាមាត្យ** (អាមាត្យមុខមន្ត្រី) **ជនបទ** (ទឹកដី និងពលរដ្ឋ) **ទុគ៌** (ក្រុងមានបន្ទាយឬកំពែងរឹងមាំ) **កោស** (ឃ្លាំងទ្រព្យឬសេដ្ឋកិច្ច) **ទណ្ឌ** (កងទ័ពនិងច្បាប់) និង **មិត្រ** (សម្ព័ន្ធមិត្តនិងការទូត) (Kaur, 2010)។ ច្បាប់នេះ មានអ្នកស្រាវជ្រាវយល់ថាប្រហែលជាបានប្រើប្រាស់ក្នុងប្រទេសកម្ពុជាពីសម័យមុនអង្គរ និងមានភស្តុតាងច្បាស់លាស់នៅសម័យអង្គររហូតមកដល់សម័យកណ្តាល (វង់, ២០១២; Sahai, 1970)។

យោងតាមការសិក្សារបស់លោក សាហៃ សច្ចិទានន្ទ បានបែងចែករចនាសម្ព័ន្ធរដ្ឋបាលខ្មែរសម័យបុរាណជា៣ធំៗ៖ ព្រះមហាក្សត្រ រដ្ឋបាលកណ្តាល និងរដ្ឋបាលខេត្ត (Sahai, 1970)។ ឈរលើការសិក្សារបស់លោក យើងនឹងសង្ខេបចំណុចសំខាន់ៗ ដោយភ្ជាប់បន្ថែមនូវភស្តុតាងគាំទ្រដកចេញពីសិលាចារឹកនានាផង ដើម្បីជាព័ត៌មាននិងការយល់ដឹងទូលាយពីសម័យអង្គរ។

៣.១. ព្រះមហាក្សត្រ

នាសម័យអង្គរ ព្រះមហាក្សត្រ គឺជាស្តេចចក្រពត្តិ ប្រកាន់នូវលិទ្ធិទេវរាជ។ យោងតាមសិលាចារឹកស្តុកកក់ធំ K.២៣៥ ព្រះបាទស្រីជ័យវរ្ម៌ទេវទី២ (ជ័យវរ្ម័នទី២) បានប្រតិស្ឋាននូវ «ព្រះគម្ពែងជគតដ៏រាជ» (ខ.ច. ព្រះកម្រតេង៑ជគត្តរាជ, សំ. ទេវរាជ) និងធ្វើពិធីសាសនាធំមួយ (ខ.ច. ហៅថា វិធីលេហ) ដើម្បីឱ្យប្រទេសកម្ពុជាកុំបីចំណុះជ្វា និងមានព្រះមហាក្សត្រតែមួយអង្គគត់ជាស្តេចចក្រពត្តិ (Aymonier, 1901;

Chakravarti, 1978; Cœdès & Dupont, 1943; Finot, 1915; Sak-Humphry, 2005)។

អំណាចព្រះមហាក្សត្រ ជាអំណាចកំពូល ដែលព្រះអង្គកាន់កាប់លើវិស័យនយោបាយ សេដ្ឋកិច្ច សាសនា តុលាការ និងយោធា។ ព្រះអង្គឡើងគ្រងរាជ្យដោយពេញច្បាប់ស្របតាមលទ្ធិទេវរាជ ដែលទំនៀមនេះបានពង្រឹងនិងថែរក្សាអំណាចរបស់ព្រះមហាក្សត្រ។ នៅក្នុងជំនឿសាសនានិងប្រពៃណីខ្មែរ ព្រះមហាក្សត្រជារូបស្នងព្រះអាទិទេពគ្រប់គ្រងផែនដី ដែលមានទម្រង់ពាក់កណ្តាលទេព និងពាក់កណ្តាលមនុស្ស។ ទ្រឹស្តីមនោគមវិជ្ជានេះ បានធ្វើឱ្យព្រះមហាក្សត្រមានអំណាចកំពូលស្របតាមច្បាប់សាសនា បន្ថែមលើច្បាប់ជាទំនៀមទម្លាប់ដទៃទៀត។

ព្រះមហាក្សត្រក៏ជាចៅក្រមកំពូល ដែលជាប្រធានព្រះសភានគរ គឺជាអ្នកសម្រេចយុត្តិធម៌ចុងក្រោយ ពីលើស្ថាប័នតុលាការពីរថ្នាក់នៅខាងក្រោម។ គួរបញ្ជាក់ផងដែរថាតុលាការសម័យបុរាណមាន៣កម្រិត៖ ព្រះសភាស្រុក ព្រះសភាវិស័យ និងព្រះសភានគរ។ នៅក្នុងប្រព័ន្ធរដ្ឋបាលសម័យបុរាណ នៅក្នុងកម្រិតនៃការងារនីមួយៗ មានមន្ត្រី ៤ ថ្នាក់៖ ថ្នាក់ឯក ថ្នាក់ទោ ថ្នាក់ត្រីណី និងថ្នាក់ចត្វារី។ ប្រព័ន្ធបែបនេះនៅរក្សាជាបន្តបន្ទាប់រហូតមកដល់សម័យកណ្តាល និងបាត់បង់នៅក្នុងសម័យទំនើបក្នុងរចនាសម្ព័ន្ធរដ្ឋបាលទូទៅ ប៉ុន្តែនៅបន្តប្រើក្នុងរចនាសម្ព័ន្ធរាជគណៈក្នុងស្ថាប័នព្រះសង្ឃនាពេលបច្ចុប្បន្ន។

បន្ថែមពីនេះ ព្រះមហាក្សត្រទ្រង់ជាអគ្គមេបញ្ជាការយោធា ដែលព្រះអង្គទ្រង់បញ្ជានិងដឹកនាំកងទ័ពផ្ទាល់ក្នុងគ្រប់សមរភូមិចម្បាំងការពារនិងការពង្រីកទឹកដី។ ចម្លាក់នៅលើជញ្ជាំងរបៀងនៃប្រាសាទអង្គរវត្ត បាយ័ន្ត និងបន្ទាយឆ្មារ បានបង្ហាញអំពីសកម្មភាពព្រះមហាក្សត្រក្នុងការយោងចេញដឹកនាំនិងបញ្ជាទ័ពដោយផ្ទាល់ព្រះអង្គ។ ចម្លាក់និងសិលាចារឹកខ្លី (K.២៩៨-២ និង K.២៩៨-១៧) នៅរបៀងខាងត្បូង ចំហៀងខាងលិចប្រាសាទអង្គរវត្ត បានបង្ហាញពីព្រះបាទស្រីសូរ្យវរ្ម៌ទេវទី២ (សូរ្យវរ្ម៌ទី២) ទ្រង់គង់នៅលើភ្នំសិវបាទសណ្តាប់មន្ត្រីថ្វាយរបាយការណ៍កងទ័ព និងយាងដឹកនាំបញ្ចុះពលដោយផ្ទាល់ព្រះអង្គ។ ដូចគ្នាដែរ ចម្លាក់នៅប្រាសាទបាយ័ន្ត និងប្រាសាទបន្ទាយឆ្មារ បង្ហាញពីព្រះរាជសកម្មភាពរបស់ព្រះបាទស្រីជ័យវរ្ម៌ទេវទី៧ (ជ័យវរ្ម៌ទី៧) ក្នុងការដឹកនាំទ័ព។

រូប ២. ចម្លាក់ព្រះបាទស្រីសូរ្យវរ្ម៌ទេវទី២ (សូរ្យវរ្ម័នទី២) គង់សណ្តាប់ឫបាយការណ៍និងធ្វើពិធីបញ្ចុះពលនៅភ្នំសិវបាទ



ប្រភព៖ របៀងខាងត្បូង ចំហៀងខាងលិច ប្រាសាទអង្គរវត្ត ស.វ.ទី១២

ព្រះមហាក្សត្រ ទ្រង់គ្រប់គ្រងលើវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងវិស័យការងារទូតផង។ ព្រះអង្គគ្រប់គ្រងព្រះឃ្លាំង (រតនគារជាតិ) ត្រួតពិនិត្យគ្រប់គ្រងជាពិសេសលើការប្រមូលនិងលើកលែងពន្ធ ការគ្រប់គ្រងព្រមទាំងចាត់ចាត់ចែងធនធានហរិញ្ញវត្ថុ និងការងារទំនាក់ទំនងការទូត។ សិលាចារឹកប្រាសាទបន្ទាយស្រី K.៥៦៩.២ បានបង្ហាញពី ខ្លោញពលត្រីបដាក ជាឈ្មួញក្នុងព្រះឃ្លាំងធំ បានក្រាបបង្គំទូលសុំព្រះបាទមហាបរមសៅគតបទ (ប.ម.ន. ព្រះបាទជ័យវរ្ម័នទី៧) ដកលង្ហៅ(លង្ហិន/ស្ពាន់) ដើម្បីដកអុសថ្វាយទៅប្រាសាទបន្ទាយស្រីនេះ (Finot et al., ១៩២៦, pp. ៧៩–៨២; Pou, ២០០១, pp. ១៦៦–១៧១)។ ព្រះមហាក្សត្រចាត់ចែងមូលនិធិនានាសម្រាប់ដំណើរការរបស់ប្រាសាទ អាស្រម និងមន្ទីរពេទ្យ ព្រមទាំងកសាងហេដ្ឋារចនាសម្ព័ន្ធនានាដូចជាស្ពានថ្ម ជាដើម។ ព្រះបាទស្រីយសោវរ្ម៌ទេវទី១(យសោវរ្ម័នទី១) បានកសាងអាស្រមចំនួន១០០ ពាសពេញផ្ទៃប្រទេស សម្រាប់ជាទីគោរពសក្ការៈ អប់រំបណ្តុះបណ្តាល និងទទួលអ្នកដំណើរមកស្នាក់(Chea et al., ២០២៣)។ ចំណែកឯក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម៌ទេវទី៧ (ជ័យវរ្ម័នទី៧) ព្រះអង្គនិងព្រះនាងឥន្ទ្រទេវី បានកសាងហេដ្ឋារចនាសម្ព័ន្ធមានដូចជាផ្លូវ

ថ្នល់ធំៗ ស្ពាន សាលាសំណាក់ មន្ទីរពេទ្យ និងមជ្ឈមណ្ឌលអប់រំយ៉ាងច្រើននិងសម្បើមជាងរាជ្យមុនៗ។

៣.២. រដ្ឋបាលកណ្តាល

៣.២.១. ឋានានុក្រមព្រះរាជវចូរានុវចូរ្យ

នៅក្នុងក្រុមគ្រួសាររាជវង្ស មិនខុសពីមន្ត្រីជាន់ខ្ពស់នោះទេ ត្រូវបានបែងចែកជាឋានានុក្រម ដោយផ្អែកលើឋានន្តរនាមជាក់លាក់ជាច្រើន សម្រាប់រាជបុត្រ មានដូចជា៖

ព្រះកម្រតែងអញយុវរាជ	ជារាជទាយាទ
ព្រះកម្រតែងអញ	ដូចមន្ត្រីថ្នាក់ទី១
ព្រះកំស្តែងអញ	ដូចមន្ត្រីថ្នាក់ទី២
ម្រតាញខ្លោញ	ដូចមន្ត្រីថ្នាក់ទី៣
ម្រតាញ	ដូចមន្ត្រីថ្នាក់ទី៤
ស្តែង/ស្តេញអញ	ដូចមន្ត្រីជាអ្នកបួស
លោញ	ដូចមន្ត្រី ឬអកិជនបុរសទូទៅ

ចំណែកព្រះមហេសី, ស្វាមិនី, ទេវី, រាជបុត្រី ឬស្នំវិញទទួលបានឋានានុក្រមតាមឋានន្តរនាមពីធំមកតូចដូចជា៖

តាញកម្រតែងអញ	ជាអគ្រមហេសី
កម្រតែងអញ	ជាអគ្រមហេសី ឬ មហេសី ឬអគ្រស្វាមិនី, (អគ្រទេវី)
កនិហ្យង/កន្ត្រងកម្រតែងអញ	ជារាជិនី, ឬ ជាភគិនីព្រះមហាក្សត្រ
កំស្តែងអញ	ជាស្វាមិនី, ទេវី
ស្តែងអញ	ជារាជបុត្រី
តែង	ជារាជបុត្រី

ឋានៈសមាជិករាជវង្សនៅកម្រិតឋានន្តរនាមនីមួយៗ មិនមានការបែងចែកជា៤ថ្នាក់គឺ ថ្នាក់ឯក ថ្នាក់ទោ ថ្នាក់ត្រី និងថ្នាក់ចត្វា ដូចពួកមន្ត្រីនោះទេ (Vong ២០១៦)។ ប៉ុន្តែ នៅក្នុងឋានន្តរនាមនីមួយៗ ពួកគេត្រូវបានទទួលឋានៈទាបខ្ពស់ខុសគ្នាដោយសារមានបរមេនាមខ្លីឬកាន់តែវែង។ ក្រុមរាជវង្សានុវង្ស គឺជាក្រុមមានតួនាទីសំខាន់ៗនិងបម្រើការជាមន្ត្រីជាន់ខ្ពស់នៅក្នុងការគ្រប់គ្រងរដ្ឋបាល និងក្នុងសង្គម។ ជាក់ស្តែង មានព្រះអង្គ

ម្ចាស់ឋាន:ខ្ពស់និងកណ្តាលខ្លះ បានកាន់កាប់តំណែងសំខាន់ៗនៅក្នុងរដ្ឋាភិបាល, គ្រប់គ្រងខេត្តចំណុះ ឬអ្នកការទូតនៅប្រទេសក្រៅ។

៣.២.២. មន្ត្រីផ្នែកស៊ីវិល

ព្រះមហាក្សត្របានតែងតាំងបណ្តាញមន្ត្រីដើម្បីជួយគ្រប់គ្រងរាជការ។ មន្ត្រីមាន ៥ថ្នាក់ ដឹកនាំដោយមន្ត្រីជាន់ខ្ពស់ម្នាក់ជាអាមាត្យាធិបតី ឬមហាអាមាត្យ ឬមហាសេនាបតី ដែលប្រដូចនឹងនាយករដ្ឋមន្ត្រីនាពេលបច្ចុប្បន្ន។

- **ថ្នាក់ឯក៖** មានគ្រឿងសម្គាល់ឋានានុក្រមដោយមធ្យោបាយធ្វើដំណើរអង្រឹងស្នែងមាស១ បាំងដោយក្លស់ដងមាស៤។
- **ថ្នាក់ទោ៖** មានគ្រឿងសម្គាល់ឋានានុក្រមដោយមធ្យោបាយធ្វើដំណើរអង្រឹងស្នែងមាស១ បាំងដោយក្លស់ដងមាស២។
- **ថ្នាក់ត្រី ៖** មានគ្រឿងសម្គាល់ឋានានុក្រមដោយមធ្យោបាយធ្វើដំណើរអង្រឹងស្នែងមាស១ បាំងដោយក្លស់ដងមាស១។
- **ថ្នាក់ចត្វា៖** មានគ្រឿងសម្គាល់ឋានានុក្រមដោយមធ្យោបាយធ្វើដំណើរ ពុំមានអង្រឹងស្នែង បាំងដោយក្លស់ដងមាស១។
- **ថ្នាក់បញ្ចា៖** មានគ្រឿងសម្គាល់ឋានានុក្រមដោយមធ្យោបាយធ្វើដំណើរ ពុំមានអង្រឹងស្នែង បាំងដោយក្លស់ដងប្រាក់១។

៣.២.៣. មន្ត្រីក្នុងព្រះបរមរាជវាំង

ក្រុមមន្ត្រីសំខាន់មួយក្រុមទៀត គឺក្រុមមន្ត្រីព្រះបរមរាជវាំងដែលមាននាទីគ្រប់គ្រងព្រះបរមរាជវាំង ពិធីរាជវង្ស និងទំនាក់ទំនងការទូត។ ក្រុមមន្ត្រីទាំងនោះមានដូចជា៖

- **រាជកុលមហាមន្ត្រី៖** ទទួលបន្ទុកការងាររាជវាំងនិងព្រះញាតិវង្ស ដែលសម័យក្រោយមក យើងស្គាល់ជា ***«ឧកញ៉ាមហាមន្ត្រី»***។
- **ព្រះគ្រូ៖** ព្រះរាជគ្រូ ទទួលបន្ទុកបង្ហាត់បង្រៀនស្តេច និងព្រះញាតិវង្ស។ (ខ.ច. ព្រះគុរុ)។
- **ព្រះបណ្ឌិត៖** ជាព្រាហ្មណ៍មាននាទីសំខាន់ក្នុងកិច្ចពិធីបូជាហោមនិងយជ្ញ ក៏ប្រហែលមានតួនាទីសំខាន់មួយទៀតគឺជាទីប្រឹក្សាផង។ (ខ.ច. ព្រះបន្ទិត K. ២០៦)។
- **បុរោហិត** ឬ **រាជបុរោហិត៖** ព្រាហ្មណ៍ទទួលរៀបចំពិធីសាសនា។

- **ហោតរ៖** អាចារ្យព្រាហ្មណ៍មាននាទីសំខាន់រៀបចំពិធីសម្រាប់ព្រះមហាក្សត្រ។
- **រាជប្រត្យយ ឬ ប្រត្យយ៖** ព្រះរាជតំណាងឬមន្ត្រីជំនិតព្រះរាជាទទួលការងារកំណត់ព្រំដី និងការងារប្រកាសរាជបញ្ញតិ រាជប្រកាស រាជសារ។ល។
- **ខ្លោញសណ្តាប់៖** មន្ត្រីតំណាងព្រះមហាក្សត្រចូលរួមក្នុងសាវនាការកាត់ក្តី។ (ខ.ច. ខ្លោញ្ជិសន្តប៊ិ)។

៣.២.៤. មន្ត្រីផ្នែកសាសនា

ព្រាហ្មណ៍ជាន់ខ្ពស់ (ព្រះរាជគ្រូ រាជហោតា) មានតួនាទីយ៉ាងសំខាន់លើសពីក្នុងពិធីសាសនា ជាទីប្រឹក្សា ជាជំនួយការរបស់ព្រះមហាក្សត្រ ជាស្ថាបត្យករ/វិស្វករ អ្នកតារាសាស្ត្រ។ល។ លោកដឹកនាំស្នើរគ្រប់គម្រោងសំណង់ធំប្រចាំរាជការនីមួយៗ។ ចំណេះដឹងរបស់ព្រាហ្មណ៍ជារឿយៗ ត្រូវបានបន្តពីជំនាន់មួយទៅជំនាន់មួយ។

៣.២.៥. មន្ត្រីប្រដាប់អាវុធ

ក្រុមមន្ត្រីប្រដាប់អាវុធ មានចំនួន៣ផ្នែកធំៗ៖

- **កងទ័ព៖** មហាសេនាបតី (មេទ័ពប្រចាំនគរ) សេនាបតីកណ្តាលពល (មេទ័ពតាមតំបន់) សេនាបតី (ឧត្តមសេនីយ) ខ្លោញពល ពលាធិបតី ពល។
- **អាវុធហត្ថ ៖** សញ្ជក/អ្នកសញ្ជក។ អ្នកសញ្ជក ជាពាក្យទូទៅហៅក្រុមប្រដាប់អាវុធ មាននាទីច្បាំងនិងថែរក្សាការពារ។ មេទ័ពរហូតដល់កូនទ័ពហៅថា អ្នកសញ្ជក ដូចគ្នា។
- **ក្រុមប្រហែល**នគរបាល**សព្វថ្ងៃ៖** តម្រួច (សព្វថ្ងៃក្លាយមកជាតម្រួត) សវ៉ាធិការិន (អធិការនគរបាល) ខ្លោញមុខ ខ្លោញការ្យ ។

៣.២.៦. មន្ត្រីផ្នែកតុលាការ

«សភា» នាសម័យបុរាណ សំដៅដល់តុលាការក្នុងពេលបច្ចុប្បន្ន។ ក្រុមមន្ត្រីផ្នែកតុលាការមានតួនាទីខាងរក្សាច្បាប់ និងសណ្តាប់ធ្នាប់ ព្រមទាំងដោះស្រាយវិវាទក្តីក្តាំនានា។ សូមអានបន្ថែមអំពីការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការនាសម័យបុរាណនៅក្នុងចំណុច ០។ ខាងក្រោមនេះជាមន្ត្រីសំខាន់ៗក្នុងតុលាការ៖

- **សភាបតី** ឬ **សភានាយក** ជាប្រធានស្ថាប័នតុលាការ។
- **សភាជន** ជាមន្ត្រីបម្រើការនៅរ្រះសភា។

- **ចារ** ជាមន្ត្រីមានការកិច្ចដើរសង្កេតពេលមានរឿងក្តី។
- **វង្វាង** ជាមន្ត្រីថ្នាកទាបបម្រើការផ្ទៀងផ្ទាត់ពិនិត្យការងាររឿងក្តីតាមទីតាំងកើតរឿង។
- **វ្យវហារាធិការី** ជាមន្ត្រីថ្នាក់ខ្ពស់ទទួលបន្ទុកវិវាទ (រឿងក្តី)នីមួយៗ។ (សំ. វ្យវហារាធិការិន៑)
- **គុណទោសទ៌សី** ជាមន្ត្រីវិនិច្ឆ័យគុណទោស មានមុខងារប្រៀបដូចនឹងព្រះអាជ្ញា។ (សំ. គុណទោមទគ៌ិន៑)
- **ខ្លោញកូតាស** ជាមន្ត្រីលេខាធិការ ជាអ្នកបួស ប្រៀបដូចនឹងនាយកក្រឡាបញ្ជី។
- **ស្នូតធម្ម៌សាស្ត្រ** ជាមន្ត្រីតុលាការ ដែលមានការកិច្ចសូតគម្ពីរធម្មសាស្ត្រ នៅពេលបញ្ចប់រឿងក្តី, ពិធីការប្រគល់អំណោយផ្សេងៗ, ឬ ពិធីសប្បុរសធម៌នានា
- **សភាសត** ជាមន្ត្រីអាជ្ញាសាលា ដែលមានការកិច្ចគ្រប់គ្រងរបៀបវារៈ និងសណ្តាប់ធ្នាប់ក្នុងសាលសវនាការ។
- **ធម្មាធិការណបាល ឬ ធ្មាំតុលាការ** ជាមន្ត្រីថែរក្សាស្ថាប័នតុលាការ

៣.២.៧. មន្ត្រីព្រះឃ្លាំង

ក្រុមមន្ត្រីព្រះឃ្លាំង មានទទួលការងារខាងហិរញ្ញកិច្ច និងទទួលបន្ទុកធនធានសេដ្ឋកិច្ច ដែលមានដូចជា៖

- **ខ្លោញគ្លាង/ឃ្លាំង៖** ប្រហែលប្រធានហិរញ្ញវត្ថុថ្នាក់ស្រុក។
- **ម្រតាញឃ្លាំង៖** ប្រហែលប្រធានហរិញ្ញវត្ថុតាមខេត្ត។
- **ម្រតាញខ្លោញឃ្លាំង៖** ប្រហែលប្រធានរតនគារជាតិ។
- **កម្រតែងអញឃ្លាំង៖** ប្រហែលរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។
- **ធ្មាំព្រះបញ្ជី៖** មន្ត្រីទទួលបន្ទុកកត់ត្រា ចុះបញ្ជី និងគ្រប់គ្រងថែរក្សាបញ្ជីទ្រព្យរបស់ប្រាសាទ ឃ្លាំងជាដើម។ (ខ.ច. ថ្មាំព្រែះបាញ្ជី)។

៣.២.៨. មន្ត្រីផ្នែកពន្ធអាករ

ក្រុមមន្ត្រីត្រួតពិនិត្យពន្ធដារ មាននាទីជាចម្បងលើផលិតផលកសិកម្ម(អង្គរ) និងទំនិញផ្សេងទៀត ព្រមទាំងពន្ធលើកម្លាំងពលកម្ម។ ក្រុមមន្ត្រីទាំងនោះមានដូចជា៖

- **ខ្លោញស្រែ៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធស្រែ។ (ខ.ច. ខ្លោញ៊ស្រែ ខ្លោញ៊ព្រីហិ)
- **ខ្លោញសណ្តែក៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធសណ្តែក។ (ខ.ច. ខ្លោញ៊សន្តែក៏/សន្តាក៏)
- **ខ្លោញល្ង៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធល្ង។ (ខ.ច. ខ្លោញ៊ល្ងោ)
- **ខ្លោញក្រមួន៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធក្រមួន។ (ខ.ច. ខ្លោញ៊កល្ម្ន៊/កល្ម្នាន៊)
- **ខ្លោញប្រេង៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធប្រេងធញ្ញជាតិ។ (ខ.ច. ខ្លោញ៊បយ៉្យ៊ង ខ្លោញ៊ចញ្ច្រល)
- **កំស្តេងត្រួតអំបិល៖** មន្ត្រីមានតួនាទីធំលើការត្រួតពិនិត្យនិងគ្រប់គ្រងប្រមូលពន្ធអំបិល។ (ខ.ច. កំស្តេង៊ត្រ្ចៃអំប្យល៊)
- **ខ្លោញមុខ៖** មន្ត្រីជាប្រធានផ្នែកកិច្ចការអ្វីមួយ។
- **ខ្លោញការ៖** មន្ត្រីជាប្រធានខាងប្រមូលពន្ធពលកម្មឬកំណែនកម្លាំងដើម្បីបម្រើរាជការក្នុងវិស័យផ្សេងៗ។ (ខ.ច. ខ្លោញ៊កាយ៉្ង)
- **ឆ្មាំព្រះបញ្ជី៖** មន្ត្រីទទួលបន្ទុកកត់ត្រា ចុះបញ្ជី និងគ្រប់គ្រងថែរក្សាបញ្ជីទ្រព្យរបស់ប្រាសាទ ឃ្លាំងជាដើម។ (ខ.ច. ច្មាំព្រះបាញ្ជី)

៣.២.៩. មន្ត្រីផ្នែកដីធ្លី

ដីធ្លី មានសារៈសំខាន់សម្រាប់ការតាំងទីរស់នៅ សាងសង់ និងធ្វើកសិកម្ម។ ក្រុមមន្ត្រីទទួលបន្ទុកផ្នែកដីធ្លី មានដូចជា៖

- **មហាស្រេស្ដី៖** ប្រហែលរដ្ឋមន្ត្រីក្រសួងសុរិយោដី។
- **ស្រេស្ដី៖** ប្រធានសុរិយោដីខេត្តខណ្ឌ។
- **វ៉ាបារ ៖** មន្ត្រីទទួលបន្ទុកកំណត់ព្រំដី និងការងារប្លង់ដី។

៣.៣. រដ្ឋបាលដែនដី

រដ្ឋបាលខេត្តសម័យអង្គរ បែងចែកជា ***«ប្រមាណ»*** (សតវត្សទី៩) ក្រោយមកជា ***«វិស័យ»*** (ចាប់ពីសតវត្សទី១០)។ ចក្រភពខ្មែរ មានប្រហែល ២៣ខេត្ត ដែលជាសាមន្តរាជចំណុះ។ រដ្ឋបាលដែនដី ចែកជា ៣ថ្នាក់៖

- **ប្រមាណ ឬ វិស័យ៖** មន្ត្រីទទួលខុសត្រូវហៅ «ខ្លោញវិស័យ»។

- **ស្រុក៖** មន្ត្រីទទួលបន្ទុកហៅ «ខ្លោញស្រុក»។
- **គ្រាម (ភូមិ)៖** អ្នកទទួលខុសត្រូវហៅ «គ្រាមព្រឹទ្ធ» ជាមេភូមិ ឬចាស់ស្រុក។
- **តម្រួចព្រះរាជការ្យៈ** មន្ត្រីការងាររក្សាសន្តិសុខ ប្រហែលដូចគ្នានឹងនគរបាល។ (ខ.ច. តម្រួចប្រៃរាជកាយ្យ)។
- ក្រៅពីនេះមានបែងចែកជាតំបន់រដ្ឋបាល៣បន្ថែមទៀត៖
- **សតគ្រាម៖** ១០០ភូមិ ដែលមានមន្ត្រីទទួលបន្ទុកមានឋានៈជា «កម្រងតេងអញសតគ្រាម»។ (K.២០៧, គ.ស.១០៤២, ព្រះកម្រតេង៑អញ្ជិគតគ្រាម)។
- **ទសគ្រាម៖** ១០ភូមិ ដែលមានមន្ត្រីទទួលបន្ទុកជា «វាបទសគ្រាម»។ (K.៥៩៨, គ.ស.១០៨៤/១០៨៥, វាប៑ទគគ្រាម)។
- **បញ្ចគ្រាម៖** ៥ភូមិ ដែលមានមន្ត្រីទទួលបន្ទុកជា «វាប» និងមាននាទីជា «ស្មៅ»។ (K.២២១, គ.ស.១០១១, វាប៑អម្ងួតស្មៅបញ្ចគ្រាម)។

៤. ទ្រឹស្តីគ្រប់គ្រងរដ្ឋ

៤.១. រាជមណ្ឌល ឬ មណ្ឌល

ក្បួន ***«រាជមណ្ឌល»*** ឬ ***«មណ្ឌល»*** ជាទ្រឹស្តីស្នូលនៃកិច្ចការរដ្ឋ ដែលអ្នកគ្រប់គ្រងនគរខ្មែរសម័យអង្គរ បានប្រតិបត្តិខ្ជាប់ខ្ជួន។ ក្បួននេះផ្តល់ដំបូន្មានដល់អ្នកគ្រប់គ្រងនគរ សិក្សាអំពីភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រយុទ្ធសាស្ត្រដែលមានណែនាំយ៉ាងសង្ខេបថា «អ្នកជិតខាងរបស់យើងគឺជាសត្រូវជាធម្មតារបស់យើង ហើយអ្នកជិតខាងដែលជាសត្រូវរបស់យើង ត្រូវតែជាមិត្តរបស់យើងវិញ»។

«មណ្ឌល» មានន័យដើមសំដៅដល់រង្វង់។ ***«រាជមណ្ឌល»*** គឺជាក្បួនរបៀបរង្វង់ដូច «ប្រព័ន្ធចងសម្ព័ន្ធរដ្ឋជារង្វង់» (circle of states) ដែលជាគំនិតដ៏សំខាន់មួយនៃយុទ្ធសាស្ត្រនយោបាយឥណ្ឌាបុរាណ។ ***«រាជមណ្ឌល»*** ជាប្រព័ន្ធគ្រប់គ្រងបែបរមែជ្ឈការនាសម័យបុរាណ ដែលក្បួននេះមាននិយាយនៅក្នុងគម្ពីរអរ៑ថ៑សាស្ត្រ (Arthashastra) តាក់តែងនៅចន្លោះរវាងសតវត្សរ៍ទី៤ មុនគ្រិស្តសករាជ ដល់សតវត្សទី២ នៃគ្រិស្តសករាជ។ ទ្រឹស្តីនៃក្បួននេះផ្តល់ឱ្យអ្នកគ្រប់គ្រងនគរយល់ដឹងអំពីទំនាក់ទំនងការទូតរវាងរដ្ឋនិងរដ្ឋ និងការបង្កើតគោលនយោបាយការបរទេស ដោយផ្អែកលើទីតាំងភូមិសាស្ត្រនៃនគរមួយ និងអន្តរកម្មរបស់ខ្លួនជាមួយរដ្ឋជិតខាង។

ចំពោះនគរខ្មែរ យើងឃើញក្បួនរាជមណ្ឌលមានប្រើប្រាស់យ៉ាងទូលំទូលាយ តាំងតែងពីសម័យហ្វូណានមកម្ល៉េះ។ សិលាចារឹក K.១៤២៦ ដែលបានរកឃើញនៅក្រុងកំពង់ផែអន្តរជាតិអូរកែវ (Oc-Eo) នគរហ្វូណាន មាននិយាយអំពីធាតុនៃក្បួនរាជមណ្ឌលក្នុងគម្ពីរអេចំសាស្ត្រនេះ (ឆោម, ២០២៤) នៅក្នុងរាជ្យព្រះបាទស្រីជ័យវម្ម៌ទី១ (ជ័យវរ្ម័នទី១) ដែលព្រះអង្គបានឡើងគ្រោងរាជ្យនៅឆ្នាំ៦៥៤ ដល់ឆ្នាំ៦៩៤ (Chhom et al., 2025)។ ចំណេរក្រោយមកទៀត នៅចុងសតវត្សទី៨ ព្រះបាទស្រីជ័យវម្ម៌ទី២ (ជ័យវរ្ម័នទី២) ក៏បានប្រើប្រាស់ក្បួនក្នុងគម្ពីរអេចំសាស្ត្រនេះ ដើម្បីបង្រួមបង្រួមនគរតូចៗបានសម្រេច ហើយបង្កើតបានជាចក្រភពអង្គរតមក។

គំនិតស្នូលនៃទ្រឹស្តីរាជមណ្ឌលនេះ គឺទូន្មានព្រះរាជាឬអ្នកដឹកនាំថាគួរមើលរដ្ឋជិតខាងខ្លួនមានធម្មជាតិជាសត្រូវ និងអាចមានសក្តានុពលជាសម្ព័ន្ធមិត្តដែរ។ មូលដ្ឋានសំខាន់នៃសម្ព័ន្ធភាពជាយុទ្ធសាស្ត្រនិងការបង្កឹតបង្កំបែបការទូត ត្រូវប្រើគោលការណ៍ ***«សត្រូវរបស់សត្រូវ គឺជាមិត្តរបស់យើង»***។

ក្បួន ***«រាជមណ្ឌល»*** ជាប្រព័ន្ធនៃសាមន្តរដ្ឋឬសាមន្តរាជចំនួន១២ដែលរៀបចំជារង្វង់ចំណុះឱ្យ ***«វិជិគីសុ»*** (សំ. វិជិគីឥ) គឺព្រះរាជាកណ្តាល ឬស្តេចដែលដណ្តើមយកជ័យបាន។ ប្រព័ន្ធដែលមានធាតុទាំង១២ មានដូចខាងក្រោម៖

១. **វិជិគីសុ៖** ព្រះរាជាកណ្តាល ជាស្តេចចក្រពត្តិ ដែលមានបំណងពង្រីកអំណាចនិងគ្រប់គ្រងដែនដទៃ។
២. **អរិ៖** សត្រូវ គឺដែនក្បែរខាង។
៣. **មិត្រ៖** សម្ព័ន្ធមិត្ត គឺដែនជាសត្រូវនៃដែនក្បែរខាងរបស់ខ្លួន។
៤. **អរិមិត្រ៖** សត្រូវដែលជាដែនជិតខាងនៃដែនជាសម្ព័ន្ធមិត្ត គឺសម្ព័ន្ធមិត្តរបស់សត្រូវនិងជាសត្រូវរបស់ **វិជិគីសុ**។
៥. **មិត្រមិត្រ៖** មិត្ររបស់សម្ព័ន្ធមិត្ត គឺដែនជិតខាងរបស់**អរិមិត្រ** គឺជាសម្ព័ន្ធមិត្តរបស់**មិត្រ** និងមានសក្តានុពលជា**មិត្ត**របស់**វិជិគីសុ**។
៦. **អរិមិត្រមិត្រ៖** សម្ព័ន្ធមិត្តរបស់សម្ព័ន្ធមិត្តសត្រូវ គឺដែនក្បែរខាងរបស់**មិត្រមិត្រ** ដែលជាសម្ព័ន្ធមិត្តរបស់**អរិមិត្រ** និងជាសត្រូវរបស់**មិត្រ**។
៧. **បាស្ខិគ្រាហ៖** សត្រូវនៅដែនក្រៅ គឺដែននៅចុងនៃដែនរបស់**វិជិគីសុ** ដែលជាដែនអាចមានការគំរាមកំហែង។

៨. **អាក្រាន្ត៖** សម្ព័ន្ធមិត្តជែនក្រៅ គឺជែននៅជាប់**បាស្និគ្រាហ**ដែលអាចជួយដល់**វិជិគីសុ**បាន។


៩. **បាស្និគ្រាហសារ៖** សម្ព័ន្ធមិត្តរបស់សត្រូវនៅជែនក្រៅ គឺជែនជាប់នឹង**អាក្រាន្ត** និងជាសម្ព័ន្ធមិត្តរបស់**បាស្និគ្រាហ**។

១០. **អាក្រាន្តសារ៖** សម្ព័ន្ធមិត្តរបស់សម្ព័ន្ធមិត្តជែនក្រៅ គឺជែនជាប់នឹង**បាស្និគ្រាហសារ** និងជាសម្ព័ន្ធមិត្តរបស់**អាក្រាន្ត**។

១១. **មជ្ឈម៖** ជែនរបស់ស្តេចគង់នៅកណ្តាល គឺជែនស្ថិតនៅចន្លោះរវាង **វិជិគីសុ** និង **អរិ** ដែលមានឥទ្ធិពលលើ **វិជិគីសុ** និង **អរិ**។

១២. **ឧទាសីន៖** ជែនរបស់ស្តេចអព្យាក្រឹត្យ ជាស្តេចដែលមានអំណាចនិងស្ថិតនៅជែនឆ្ងាយ មិនខ្វាយខ្វល់នឹងជម្លោះរវាង **វិជិគីសុ** និង ជែនជិតខាងដទៃទៀត ប៉ុន្តែអាចនឹងលូកដៃក្នុងករណីជម្លោះនោះគំរាមកំហែងឬប៉ះពាល់ដល់ផលប្រយោជន៍ជែនខ្លួន។

រូប ៣. ប្រព័ន្ធគ្រប់គ្រងរង្វង់នៃប្រព័ន្ធ «រាជមណ្ឌល»



ប្រភព៖ គេហទំព័រ Electronic Journal of Social and Strategic Studies

៤.២. សប្តប្រក្រឹតិ (សប្តប្រកৃតি)

សប្តប្រាក្រឹត្យ (ធម្មជាតិ៧យ៉ាង) ឬ សប្តាង្គ (អង្គទាំង៧) ឬក៏ រាជ្យាង្គ (អង្គរបស់រាជ្យ) គឺជាអង្គនៃរាជ្យឬអង្គរបស់រាជការ ដែលជាធាតុសំខាន់នៃរដ្ឋមួយក្នុងទ្រឹស្តីដឹកនាំរដ្ឋរបស់ឥណ្ឌាដែលមានឥទ្ធិពលមកលើប្រទេសកម្ពុជាសម័យបុរាណ។ ទ្រឹស្តីនេះមានចែងក្នុងគម្ពីរអេចិ៍សាស្ត្ររបស់ព្រាហ្មណ៍ឈ្មោះ កៅដិល្យ ឬ ចាណាក្យ ដែលជាទីប្រឹក្សារបស់ព្រះបាទចន្ទ្រគុប្តនៃអាណាចក្រមៅរ្យ ប្រទេសឥណ្ឌា (Kaur, ២០១០)។ ទ្រឹស្តីនេះមានឥទ្ធិពលមកលើប្រទេសកម្ពុជាតាំងពីសម័យមុនអង្គរមកម្ល៉េះ ដ្បិតតាមព័ត៌មានសិលាចារឹកបានបង្ហាញថាមន្ត្រីរបស់ព្រះបាទភវវរ្ម៌ (ភវវរ្ម័ន) និងមហេន្ទ្រវរ្ម៌ (មហេន្ទ្រវរ្ម័ន) ឈ្មោះ ***«ជម៌ទេព»*** និង ***«សិង្ហទេព»*** គឺជាអ្នកមានចំណេះដឹងខ្លាំងពូកែខាងគម្ពីរ ***«ជម៌សាស្ត្រ»*** និង ***«អេចិ៍សាស្ត្រ»*** (Barth, 1885, pp. 64–72)។ យ៉ាងនេះក្តី កស្តុតាងក្នុងសិលាចារឹកបង្ហាញច្បាស់នៅសម័យអង្គរ (Sahai, 1970) និងកាន់តែច្បាស់បំផុតនៅសម័យកណ្តាល តាមរយៈសិលាចារឹកនគរវត្តលេខ៣ (IMA3) ដែលមានបង្ហាញពាក្យ ***«សប្តប្រាក្រឹត្យ»*** នេះ (វង់, ២០១២, p. ២៧-២៩)។ នៅក្នុងការគ្រប់គ្រងរដ្ឋសម័យបុរាណ អង្គនៃរាជការសំដៅទៅលើ ធាតុសំខាន់ៗ ចំនួន៧ ឬសមាសភាពទាំង៧ ដែលគោលការណ៍គ្រឹះដើម្បីបង្កើតបានជារដ្ឋមួយប្រកបដោយអធិបតេយ្យ និងដំណើរការបានល្អ។ អង្គទាំង៧ សម្រាប់រដ្ឋ មានដូចជា៖

១. **ស្វាមី** (ព្រះមហាក្សត្រ)៖ ព្រះមហាក្សត្រជាអគ្គប្រមុខ ជាអ្នកកាន់កាប់អំណាចកំពូលទាំងបី (នីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ) និងជាមេបញ្ជាការកងទ័ពផ្ទាល់។ ក្នុងសម័យបុរាណ ជាពិសេសសម័យអង្គរ ព្រះមហាក្សត្រត្រូវបានគេចាត់ទុកជា ទេវរាជ។ រដ្ឋមួយត្រូវមានព្រះមហាក្សត្រ ឬអ្នកដឹកនាំដែលមានប្រាជ្ញាឈ្លាសវៃក្នុងការដឹកនាំ និងយល់ដឹងពីសិល្បៈនៃការគ្រប់គ្រងរដ្ឋ។

២. **អាមាត្យ** (អាមាត្យមុខមន្ត្រី)៖ មន្ត្រីឈ្លាសវៃជាប្រធានសម្រេចកិច្ចរាជការសំដៅលើក្រុមមន្ត្រីធំៗ (នាម៉ឺន) ដែលមានចំណេះដឹង និងបទពិសោធក្នុងការជួយព្រះមហាក្សត្រក្នុងការគ្រប់គ្រង កសាង និងការពារប្រទេស។ រដ្ឋត្រូវមានអាមាត្យមុខមន្ត្រីដែលមានការអប់រំខ្ពស់ ដែលអាចគ្រប់គ្រងរដ្ឋបាល ប្រកបដោយប្រសិទ្ធភាព និងយុត្តិធម៌។

៣. **ជនបទ** (ទឹកដី និងពលរដ្ឋ)៖ រដ្ឋចាំបាច់ត្រូវមានទឹកដី និងប្រជារាស្ត្រ ដែលមានចំណេះដឹងផ្នែកកសិកម្ម នគរូបនីយកម្ម និងសិប្បកម្ម បានរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច។

៤. **ទុគ៌** (ក្រុងមានបន្ទាយរឹងមាំ)៖ រដ្ឋត្រូវមានហេដ្ឋារចនាសម្ព័ន្ធរឹងមាំ គឺការមានបន្ទាយការពារ និងរាជធានីដែលមានទីតាំងភូមិសាស្ត្រល្អ មានការរៀបចំច្បាស់លាស់ (ដូចជារាជធានីអង្គរធំដែលរៀបចំដូចក្រឡាចត្រង្គ) រៀបចំតាមក្បួននាំឱ្យនគរមានមង្គល។ ដូច្នេះរដ្ឋរឹងមាំត្រូវមានការកែចម្រើនផ្នែកវិស្វកម្ម និងស្ថាបត្យកម្ម ដែលអាចសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងថែទាំបន្ទាយការពារជាតិ។

៥. **កោស** (ឃ្លាំងទ្រព្យ ឬសេដ្ឋកិច្ច)៖ រដ្ឋមួយត្រូវមានសេដ្ឋកិច្ចរឹងមាំនិងបរិបូរណ៍ គឺសំដៅដល់ផ្នែកហិរញ្ញវត្ថុ និង ធនធាន គ្រប់គ្រាន់របស់រដ្ឋ ដូចជា មាស ប្រាក់ និងទំនិញផ្សេងៗ ដែលធានាដល់ការចំណាយលើកិច្ចការរដ្ឋ ការកសាងហេដ្ឋារចនាសម្ព័ន្ធ (ដូចជាប្រព័ន្ធធារាសាស្ត្រ និងប្រាសាទ) និងការចិញ្ចឹមកងទ័ព។ រដ្ឋត្រូវតែមានសកម្មភាពសេដ្ឋកិច្ច ពាណិជ្ជកម្ម និងការគ្រប់គ្រងហិរញ្ញវត្ថុ ដើម្បីបង្កើនធនធានរបស់រដ្ឋ។

៦. **ទណ្ឌ** (កងទ័ព និងច្បាប់)៖ រដ្ឋចាំបាច់ត្រូវមានកម្លាំងទ័ពខ្លាំងពូកែ ពោលគឺមានកម្លាំងយោធាដែលរៀបចំបានល្អតាមក្បួនច្បាប់ មានមេទ័ពជំនាញចេញច្បាំងមានក្បួនយុទ្ធសាស្ត្រ ដើម្បីការពារអធិបតេយ្យភាពទឹកដី និងពង្រីកឥទ្ធិពលនគរ។ វិស័យអប់រំបានបណ្តុះបណ្តាលកងទ័ពឱ្យមានវិន័យ និងយុទ្ធសាស្ត្រ រីឯអ្នកច្បាប់វិញ ត្រូវបានបង្រៀនឱ្យយល់ដឹងពីគោលការណ៍យុត្តិធម៌។

៧. **មិត្រ** (សម្ព័ន្ធមិត្ត និងការទូត)៖ រដ្ឋត្រូវមានទំនាក់ទំនងល្អ ការទូត និងសម្ព័ន្ធមិត្តជាមួយប្រទេសជិតខាង ឬប្រទេសដទៃទៀត ដើម្បីរក្សាសន្តិសុខ និងផលប្រយោជន៍ជាតិ ព្រមទាំងត្រូវមានអ្នកការទូតដែលមានចំណេះដឹងផ្នែកភាសា និងវប្បធម៌ ដែលនាំឱ្យមានទំនាក់ទំនងល្អជាមួយរដ្ឋដទៃ។

៤.៣. ទេវរាជ

«ទេវរាជ» ជាបច្ចេកសព្ទមួយយ៉ាងសំខាន់ដែលអ្នកស្រាវជ្រាវកន្លងមកនិងបច្ចុប្បន្ន នៅតែជជែកពិភាក្សាយ៉ាងផុសផុល។ ទេវរាជ គឺជា លទ្ធិសាសនា (ឬការគោរព)

ដែលមិនមែនជាច្បាប់សុទ្ធសាធ។ ប៉ុន្តែខ្មែរបុរាណ បានប្រើប្រាស់រួមផ្សំទ្រឹស្តីសាសនានេះ ដើម្បីគ្រប់គ្រងនគរ ដែលនាំចក្រភពខ្មែរចម្រុងចម្រើន។ លទ្ធិនេះបានបង្ហាញផ្លូវថា ព្រះមហាក្សត្រជាអ្នកគ្រប់គ្រងចក្រវាល ប្រៀបដូចរូបស្នងព្រះអាទិទេព ព្រះឥសូរ ឬ ព្រះវិស្ណុ។ ពោលគឺព្រះរាជា ជាតំណាងជាព្រះអាទិទេពរស់នៅលើផែនដី ដោយសារព្រះអង្គមានតួនាទីជា «សាវ័ក» របស់អាទិទេពលើផែនដី។ ទោះបីជាលទ្ធិសាសនាក៏ដោយ ក៏គោលគំនិតនេះ បានប្រើប្រាស់ ដើម្បីផ្តល់ភាពស្របច្បាប់សាសនាចំពោះព្រះរាជា ដែលធ្វើឱ្យអំណាចរបស់ព្រះអង្គរឹងមាំ និងមានឯកភាពជាតិ។

យោងតាមសិលាចារឹកស្តុកកក់ធំសរសេរនៅសតវត្សរ៍ទី១១ អ្នកស្រាវជ្រាវយល់ថា ***«ទេវរាជ»*** ជាលទ្ធិដែលបានទទួលឥទ្ធិពលពីឥណ្ឌា ចាប់ផ្តើមប្រើប្រាស់នៅក្នុងរាជការនៃចក្រភពខ្មែរ ក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័ទី២ (ជ័យវរ្ម័នទី២) នៅដើមសតវត្សទី៩។ ថ្មីៗនេះ មានអ្នកស្រាវជ្រាវបារាំង (ÉRIC BOURDONNEAU) ដែលជាអ្នកជំនាញប្រវត្តិសាស្ត្រសម័យកោះកេរបានពន្យល់ថា លទ្ធិទេវរាជ ប្រហែលជាប្រតិបត្តិក្នុងរាជការខ្មែរដំបូងនៅសតវត្សទី១០ ក្នុងរាជ្យព្រះបាទជ័យវរ្ម័ទី៤ (ជ័យវរ្ម័នទី៤) ដែលជាក្សត្របានកសាងរាជធានីកោះកេរ។ ចំណែកលោក ក្លូដ ហ្សាក់ បានពន្យល់ថា ទេវរាជ គឺជាអាទិទេពដែលជាស្តេចនៃទេព ឬអាទិទេព, មិនមែនជានាមតំណាងដោយមនុស្ស ឬស្តេចទេ។ ទំនងពាក្យនេះ ត្រូវបានខ្មែរបុរាណព្យាយាមបកប្រែពីភាសាខ្មែរចាស់ថា «កម្រតេងជគត តរាជ» (គម្តែង ជគត់ ដ៏រាជ) ដែលគាត់បកប្រែថា អម្ចាស់នៃលោកជាច្បងលើគេ។ ពីព្រោះ នៅលើសិលាចារឹកផ្នែកភាសាខ្មែរមានប្រើតែបច្ចេកពាក្យ កម្រតេងជគតតរាជ ចំណែកនៅលើសិលាចារឹកសំស្ក្រឹតវិញ មានប្រើតែបច្ចេកពាក្យ «ទេវរាជ» ដើម្បីពណ៌នាអំពីអាទិទេព ឬ ប្រតិមាអាទិទេព ដែលព្រាហ្មណ៍ ហិរណ្យទាម ប្រតិស្ថានឡើងសម្រាប់ព្រះអធិរាជ ឬស្តេចចក្រពត្តិ ជ័យវរ្ម័ទី២ គោរពបូជា ដែលមានព្រាហ្មណ៍សិរីកៃវល្យជារាជគ្រូ និងសមាជិកបំនួសក្នុងគ្រួសារគាត់ជាអ្នកថែរក្សា សូត្រធម៌ និងថ្វាយវត្ថុសក្ការៈទៀងទាត់។ ដូច្នេះ កម្រតេងជគតតរាជ ឬ ទេវរាជ គឺជាប្រតិមាអាទិទេពដ៏សំខាន់បំផុតសម្រាប់ព្រះចក្រពត្តិ ឬអធិរាជត្រូវគោរពបូជានិច្চកាល។ គំនិតនេះត្រូវបានលោក ម៉ៃឃើល វិកឃើរី គាំទ្រយ៉ាងមុតមាំ(Vickery ២០០០) ហើយក៏មានខ្លឹមសារស្របគ្នាជាមួយការពន្យល់របស់អ្នកស្រី ពៅ សាវរស (ក្រេតី សីហា ២០០៣) ផងដែរ។ ប៉ុន្តែ លោកស្រីបានបន្ថែមថា នៅឥណ្ឌាបុរាណ បច្ចេកពាក្យ ទេវរាជ ត្រូវបានគេយល់ថា មានន័យពីរ គឺអាទិទេពច្បងគេ និងស្តេច(មនុស្ស)ជាអាទិទេព។ ប្រហែល ដោយហេតុនេះហើយ ទើបធ្វើឱ្យមានការយល់មិនដាច់ស្រេច ដោយអ្នកប្រាជ្ញដែលបានសិក្សាផ្ទាល់ផង និងដោយអ្នកអាន

អ្នកសិក្សាទូទៅផងរហូតមកដល់ពេលនេះ។ ទោះបី គេសង្កេតឃើញថា ព្រះអធិរាជអង្គរមិនបានចាត់ទុកខ្លួនព្រះអង្គជាទេព ឬ អាទិទេពក្តី។ ពីព្រោះ ព្រះអង្គមិនហ៊ានកសាងរាជវាំងពីឥដ្ឋ ឬពីថ្មសម្រាប់គង់នៅ ដូចប្រាសាទឥដ្ឋ និងថ្ម ដែលព្រះអង្គបានស្ថាបនាថ្វាយជាជម្រកដល់អាទិទេពក្តី។

៤.៣.១. តើអ្វីទៅជាលទ្ធិទេវរាជ និងនាំឱ្យចក្រភពខ្មែរចម្រុងចម្រើនរបៀបណា

«ទេវរាជ» អាចចាត់ទុកជាលទ្ធិមួយដែលមានកំណើតនៅប្រទេសឥណ្ឌាបុរាណ សំដៅលើជំនឿនៃគំនិតថា ព្រះមហាក្សត្រមានកំណើតពាក់កណ្តាលទេពនិងពាក់កណ្តាលមនុស្ស ដែលគេហៅតាមខ្មែរបុរាណថា *«កម្រតែងជាគតតរាជ (ស្តេចទ្រង់ជាអាទិទេពមើលការខុសត្រូវលើផែនដី)»*។ ទេវរាជ អ្នកស្រាវជ្រាវច្រើនប្រែជាភាសាអង់គ្លេសថា *«God-King»* មានន័យថាស្តេច គឺជាទេពដែលរស់នៅលើផែនដី ដែលជាតំណាងឱ្យទេពក្នុងព្រហ្មញ្ញសាសនា គឺព្រះឥសូរ ឬព្រះនារាយណ៍។

ក. ប្រភពនិងដំណើរវិវត្តន៍

«ទេវរាជ» ជាបញ្ញត្តិដែលមានទំនាក់ទំនងជាប់នឹងសញ្ញាណស្តេចចក្រពត្តិ ឬស្តេចចក្ររបស់ឥណ្ឌា។ គំនិតដ៏សំខាន់ស្តីពីព្រះរាជាជាស្តេចគ្រប់គ្រងផែនដីទាំងមូលនេះបានផ្តល់ជាមូលដ្ឋានយ៉ាងសំខាន់ដល់ការបង្កើតជា ទេវរាជ។ លទ្ធិនេះទទួលឥទ្ធិពល និងបង្កើតឡើងចេញពីការផ្សំគ្នារវាងព្រហ្មញ្ញសាសនា និងពុទ្ធសាសនារបស់ឥណ្ឌានៅក្នុងអាណាចក្រខ្មែរ និងអាស៊ីអាគ្នេយ៍ ដែលទំនងជាណែនាំដោយព្រាហ្មណ៍របស់ឥណ្ឌានៅក្នុងរាជការខ្មែរ។

ខ. គោលបំណងនិងសារៈសំខាន់

«លទ្ធិទេវរាជ» មានគោលបំណងនិងសារៈសំខាន់មួយចំនួនដូចខាងក្រោម៖

- **ភាពស្របច្បាប់ខាងនយោបាយ ឬនីត្យានុកូលកម្មនយោបាយ៖** គោលគំនិតទេវរាជ បានផ្តល់សិទ្ធិស្របច្បាប់តាមសាសនាចំពោះអំណាចរបស់ព្រះមហាក្សត្រ ដែលធ្វើឱ្យអំណាចរបស់ព្រះអង្គ និងសិទ្ធិរបស់រាជវង្សក្នុងការគ្រងរាជ្យកាន់តែរឹងមាំ។
- **សណ្តាប់ធ្នាប់សង្គម៖** តាមរយៈការលើកតម្កើងព្រះមហាក្សត្រជាអាទិទេពតាមលទ្ធិសាសនានេះ តម្រូវឱ្យប្រជារាស្ត្រផ្តល់បំពេញកាតព្វកិច្ច និងភក្តី

ភាពខ្ពស់បំផុត ដែលគោរពសណ្តាប់ធ្នាប់ឋានានុក្រម និងជួយរក្សាស្ថិរភាពសង្គម។

- **ប្រមូលប្រភពធនធាន៖** ឋានៈរបស់ព្រះមហាក្សត្របានអនុញ្ញាតឱ្យព្រះអង្គអាចប្រមូលកម្លាំងប្រជារាស្ត្រដើម្បីធ្វើការងារសាធារណៈទ្រង់ទ្រាយធំៗ និងគម្រោងដ៏មហិមា នានា ដូចជា ប្រព័ន្ធធារាសាស្ត្រ និងការសាងសង់ប្រាសាទធំៗ ព្រមទាំងកម្លាំងការពារជាតិជាដើម។
- **រក្សាសុខដុមរមនីយកម្មចក្រវាឡ៖** សណ្តាប់ធ្នាប់សង្គមដែលកំណត់ដោយអាទិទេពនេះ ជាកត្តាចាំបាច់ដើម្បីរក្សាសុខដុមរមនីយកម្មនៃចក្រវាឡ។ រាល់ការប៉ុនប៉ងជំទាស់អំណាចរបស់ព្រះមហាក្សត្រ ត្រូវបានចាត់ទុកថាជាការបំផ្លាញសណ្តាប់ធ្នាប់នេះ។

គ. ការបញ្ជាក្យ

«ទេវរាជ» តែងតែភ្ជាប់នឹងទេពអង្គណាមួយក្នុងព្រហ្មញ្ញសាសនា ដែលភាគច្រើនគេជឿថាតំណាងដោយសិវលិង្គតម្កល់ក្នុងប្រាសាទភ្នំណាមួយ។ ព្រាហ្មណ៍ជាន់ខ្ពស់ធ្វើពិធីដ៏ឱឡារិកនិងអាថ៌កំបាំងដើម្បីផ្តល់ភាពជាទេពចំពោះព្រះរាជាជាអ្នកគ្រប់គ្រងតាមរយៈព្រះសិវលិង្គ។ ចំណែកឯការថែរក្សាការពារព្រះសិវលិង្គជាប់ទាក់ទងនឹងការរក្សាសុខសុវត្ថិភាពនិងភាពរីកចម្រើនរបស់ព្រះនគរ។

ឃ. នីត្យានុកូលភាពនិងសិទ្ធិអំណាចអាធិទេព

ព្រះរាជាដែលជាទេពតំណាងឱ្យព្រះឥសូរឬព្រះនារាយណ៍គង់ព្រះជន្មលើផែនដី ដូច្នេះព្រះអង្គមានភាពស្របច្បាប់ដែលមិនអាចប្រកែកបាននៅក្នុងការគ្រប់គ្រង។ ទេវរាជជាតំណាងឱ្យលោកធាតុនៅលើផែនដី ហើយព្រះរាជបញ្ញាគឺជាអំណាចរបស់ទេព ដែលជាច់ខាតអ្នកនៅក្រោមបញ្ញាត្រូវតែលុះតាមអាជ្ញានិងស្មោះត្រង់ជានិច្ច។ ប្រព័ន្ធជំនឿនេះបានកាត់បន្ថយសក្តានុពលនៃការប្រឆាំង ព្រមទាំងពង្រឹងអំណាចគ្រប់គ្រងលើអាណាប្រជានុរាស្ត្រ។

ង. មជ្ឈការអំណាចនិងរដ្ឋបាល

«ទេវរាជ» ជាលទ្ធិដែលនាំទៅរកការគ្រប់គ្រងបែបមជ្ឈការ។ ព្រះរាជាដែលជាសម្មតិទេព ព្រះអង្គជាអ្នកមានអំណាចខ្ពស់បំផុតលើគ្រប់វិស័យដូចជានយោបាយ សាសនា សេដ្ឋកិច្ច និងសង្គម។ រាជកិច្ចទាំងឡាយរៀបចំឡើងដើម្បីបម្រើដល់គោលបំណងរបស់

លទ្ធិទេវរាជ ដែលមានមន្ត្រីជាអន្តរការីនិងអនុវត្តនូវព្រះរាជបញ្ជារបស់សម្មតិទេព។ ការសាងសង់ប្រាសាទធំៗ ឧទ្ទិសថ្វាយដល់ព្រះមហាក្សត្រ និងអាទិទេពដែលពាក់ព័ន្ធ ដូចជាប្រាសាទអង្គរវត្ត មិនត្រឹមតែជាមជ្ឈមណ្ឌលសាសនាប៉ុណ្ណោះទេ ថែមទាំងជានិមិត្តសញ្ញាដ៏មានអានុភាពនៃព្រះរាជអំណាច និងតួនាទីមជ្ឈការរបស់ព្រះរាជានៅក្នុងចក្រវាឡ។

ច. ការប្រមូលផ្តុំធនធានមនុស្សនិងកម្លាំងពលកម្ម

ក្នុងហានៈជាព្រះសម្មតិទេព ជាហេតុដែលអាចជួយសម្រួលដល់ការរៀបចំកៀរគរធនធានមនុស្សនិងធនធានសម្ភារៈយ៉ាងច្រើនសម្រាប់គម្រោងនានា។ អាណាប្រជានុរាស្ត្រត្រូវមានកាតព្វកិច្ច ក្នុងការចូលរួមចំណែកជាកម្លាំងពលកម្ម និងធនធានក្នុងការសាងសង់និងថែទាំប្រាសាទ ប្រព័ន្ធធារាសាស្ត្រ និងការងារសាធារណៈផ្សេងទៀតជាទម្រង់បម្រើដល់ទេវរាជ។ គម្រោងទាំងនេះមិនត្រឹមតែពង្រឹងហេដ្ឋារចនាសម្ព័ន្ធនិងវិបុលភាពសេដ្ឋកិច្ចរបស់ព្រះនគរប៉ុណ្ណោះទេ ថែមទាំងបានពង្រឹងអំណាច និងកិត្យានុភាពរបស់ព្រះមហាក្សត្រផង។

ឆ. ការបដិបត្តិសាសនានិងកិច្ចពិធី

ការបដិបត្តិសាសនានិងកិច្ចពិធី គឺជាស្នូលនៃលទ្ធិទេវរាជ។ ការបដិបត្តិទាំងនេះតែងធ្វើដោយព្រាហ្មណ៍ជាន់ខ្ពស់ដែលពង្រឹងនូវទំនាក់ទំនងរវាងទេវភាពរបស់ព្រះរាជានិងភាពស្របច្បាប់ឬនីត្យានុកូលភាពនៅក្នុងក្រសែភ្នែករបស់អាណាប្រជានុរាស្ត្រ។ ការថែរក្សាការពារព្រះសិវលិង្គនិងវត្ថុសក្ការៈដទៃទៀតដែលមានទំនាក់ទំនងនឹងទេវរាជ បានក្លាយជាទិដ្ឋភាពនៃការគ្រប់គ្រង ដែលគេជឿថាធ្វើឡើងដើម្បីធានាបាននូវភាពរុងរឿងនិងសន្តិសុខនៃព្រះនគរ។

ជ. ការថែរក្សាសណ្តាប់ធ្នាប់សង្គម

មនោគមវិជ្ជាទេវរាជ បានពង្រឹងហានានុក្រមក្នុងសង្គមដែលមានស្រាប់។ ព្រះរាជាជាទេពដែលបានកាន់កាប់អំណាចកំពូលនៃសង្គម ដែលមានពួកក្រុមជាន់ខ្ពស់និងវណ្ណៈសង្គមដទៃទៀតកាន់កាប់អំណាចនៅថ្នាក់ក្រោមៗ។ សណ្តាប់ធ្នាប់នៃសង្គមដែលរៀបចំដោយព្រះសម្មតិទេព បង្ហាញពីការថែរក្សាភាពសុខដុមរមនារបស់ពិភពលោក ហើយការបង្កបញ្ហាប្រឈមនឹងអំណាចរបស់ព្រះអង្គ ត្រូវចាត់ទុកថាជាការរំខានឬធ្វើឱ្យខូចខាតដល់សណ្តាប់ ឬរបៀបរៀបរយរបស់សង្គមដែរ។

គោលគំនិតទេវរាជ បានផ្តល់ក្របខ័ណ្ឌដ៏ទូលំទូលាយមួយសម្រាប់ការគ្រប់គ្រងនគរ។ ទេវរាជ ជាក្បួនច្បាប់ចងភ្ជាប់ជំនឿសាសនា ជាមួយអំណាចនយោបាយ ដែលថ្វាយព្រះមហាក្សត្រនូវអំណាចស្របច្បាប់ ដើម្បីរៀបចំរដ្ឋបាលគ្រប់គ្រងចក្រភពខ្មែរឱ្យមានលក្ខណៈកណ្តាល កេណ្ឌធនធាន និងរក្សាសណ្តាប់ធ្នាប់សង្គម តាមរយៈជំនឿលើព្រះអង្គដែលជាព្រះរស់នៅលើផែនដី។ មនោគមវិជ្ជានេះបានដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ និងស្ថិរភាពនៃចក្រភពធំៗដែលបានរីកចម្រើនក្នុងសម័យកម្ពុជាបុរាណ។ គួរកត់សម្គាល់ថា ទោះបីជាគោលគំនិតទេវរាជ មានឫសគល់យ៉ាងរឹងមាំនៅក្នុងគំនិតនយោបាយ និងសាសនារបស់ឥណ្ឌាក៏ដោយ ក៏ការអនុវត្តតាមដ៏ល្អិតល្អន់ កើតមានតែនៅប្រទេសកម្ពុជា និងអាស៊ីអាគ្នេយ៍។ នៅប្រទេសឥណ្ឌាផ្ទាល់ ដែលជាប្រភពដើមនៃទ្រឹស្តីនយោបាយនេះ ក៏មិនបានវិវឌ្ឍទៅជាលទ្ធិដែលត្រូវបានធ្វើឱ្យមានលក្ខណៈផ្លូវការដូចដែលបានឃើញនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ដូចជាកម្ពុជានិងជ្វានោះទេ។

៤.៣.២. តើលទ្ធិទេវរាជបានបម្រើប្រយោជន៍យ៉ាងណាដល់ប្រជាជន?

លទ្ធិទេវរាជ ដែលផ្តោតសំខាន់ទៅលើសិទ្ធិអំណាច និងភាពស្របច្បាប់របស់ព្រះរាជាលើអំណាចមជ្ឈការ អាចបម្រើផលប្រយោជន៍ដល់អាណាប្រជានុរាស្ត្រក្នុងប្រទេសកម្ពុជាសម័យបុរាណតាមមធ្យោបាយដូចខាងក្រោម៖

ក. រក្សាសណ្តាប់ធ្នាប់ស្ថិរភាព

ហានៈជាព្រះសម្មតិទេព បានជួយដល់ការពង្រឹងអំណាច និងច្បាប់ដែលព្រះរាជាបានចាត់ចែង។ កត្តានេះអាចនាំឱ្យសង្គមមានស្ថេរភាពនិងសណ្តាប់ធ្នាប់ច្រើនជាងមុន កាត់បន្ថយជម្លោះ និងអសន្តិសុខដែលនឹងជះឥទ្ធិពលជាអវិជ្ជមានដល់ជីវិតប្រចាំថ្ងៃរបស់ប្រជាជនទូទៅ។ អំណាចនេះអាចជំរុញឱ្យមានការអនុវត្តច្បាប់បានប្រសើរជាងមុន និងការពារព្រះរាជាណាចក្រពីការគំរាមកំហែងពីខាងក្រៅ ដោយធានាបាននូវសន្តិភាព និងនាំឱ្យសហគមន៍រីកចម្រើន។

ខ. កិច្ចការសាធារណការ

ព្រះសម្មតិទេព មានសិទ្ធិអំណាចក្នុងការប្រមូលផ្តុំមនុស្សយ៉ាងច្រើនសម្រាប់គម្រោងធំៗ ដូចជាប្រព័ន្ធធារាសាស្ត្រ ការកសាងប្រាសាទ និងហេដ្ឋារចនាសម្ព័ន្ធជាដើម។ គម្រោងទាំងនេះ ក្រៅពីបង្ហាញពីអំណាចព្រះរាជា ក៏អាចផ្តល់នូវសារៈសំខាន់ដល់ជីវភាព

រស់នៅរបស់ប្រជាជនដូចជាទឹកសម្រាប់កសិកម្ម ដែលជាសក្តានុពលនាំទៅរកការប្រមូលផលកាន់តែប្រសើរ និងលើកកម្ពស់ជីវភាពរស់នៅ។ ការសាងសង់ប្រាសាទ និងបូជនីយដ្ឋានសាសនាដែលភ្ជាប់ទៅនឹងលទ្ធិទេវរាជ ក៏អាចផ្តល់នូវកម្លាំងស្មារតីនិងជំនឿ ព្រមទាំងជាចំណុចប្រមូលផ្តុំសហគមន៍សម្រាប់មនុស្សទូទៅផង។

គ. ការចាត់ចែងសិល្បៈនិងវប្បធម៌

ប្រភពធនធាននិងស្ថិរភាពបានដែលផ្តល់ដោយនូវអំណាចរបស់ព្រះរាជា អាចជំរុញនូវការអភិវឌ្ឍផ្នែកសិល្បៈ វប្បធម៌ និងចំណេះវិជ្ជាទាំងឡាយ។ ផលប្រយោជន៍ទាំងនេះប្រហែលជាមិនអាចបានដល់អាណាប្រជានុរាស្ត្រភ្លាមៗនោះទេ ប៉ុន្តែបរិយាកាសនៃការរីកសុះសាយនៃវប្បធម៌អាចផ្តល់នូវលក្ខណៈអត្តសញ្ញាណនិងមោទនភាពនៃព្រះនគរ។

ឃ. អំណាចនិងការគ្រប់គ្រងសីលធម៌

ទេវរាជ ច្រើនតែបង្ហាញពីកម្រិតនៃទំនួលខុសត្រូវផ្នែកសីលធម៌។ មនោគមវិជ្ជាទេវរាជបានជំរុញឱ្យព្រះរាជាប្រព្រឹត្តនិងអនុវត្តព្រះរាជសកម្មភាពដោយយុត្តិធម៌ និងដើម្បីផលប្រយោជន៍របស់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ ដែលជាការឆ្លុះបញ្ចាំងឱ្យឃើញនូវឋានៈជាទេព។

បុព្វហេតុសំខាន់បំផុតនៃលទ្ធិទេវរាជ គឺដើម្បីបង្រួបបង្រួមអំណាច និងតួនាទីរបស់អ្នកគ្រប់គ្រងនៅក្នុងឋានានុក្រមសង្គម។ ការផ្តោតលើផលប្រយោជន៍របស់អាណាប្រជានុរាស្ត្រ ជាចំណុចសំខាន់បន្ទាប់។ អំណាចដ៏ធំសម្បើមដែលប្រមូលផ្តុំនៅក្នុងកណ្តាប់ដៃព្រះសម្មតិទេព ក៏អាចនាំទៅរកការស្វែងរកផលចំណេញ និងការគៀបសង្កត់ប្រសិនបើអ្នកគ្រប់គ្រងមិនមានចិត្តសប្បុរស។ ទ្រឹស្តីនេះផ្ទាល់ មិនបានធានាអភិបាលកិច្ចល្អនោះទេ។ ធនធាននិងកម្លាំងពលកម្មដែលប្រមូលបានសម្រាប់គម្រោងធំៗ ជួនកាលអាចការចំណាយខ្លាំងចំពោះអាណាប្រជានុរាស្ត្រ ដែលអាចត្រូវបានទទួលរងនូវពលកម្មដោយបង្ខំ ឬបង់ពន្ធធ្ងន់។ នៅក្នុងខ្លឹមសារដែលគោលគំនិតទេវរាជ បម្រើជាចម្បងលើការលើកតម្កើងអ្នកគ្រប់គ្រងនោះ វាអាចរួមចំណែកដោយប្រយោលដល់សង្គមដែលមានស្ថិរភាព វិបុលភាព និងវប្បធម៌ដ៏សម្បូរបែប ដោយផ្តល់អត្ថប្រយោជន៍មួយចំនួនដល់អាណាប្រជានុរាស្ត្រ។ ទោះជាយ៉ាងណាក៏ដោយ អត្ថប្រយោជន៍ទាំងនេះច្រើនតែជាប់ទាក់ទងនឹងសកម្មភាពរបស់អ្នកគ្រប់គ្រងបុគ្គល ហើយមិនមែនជាគោលបំណងសំខាន់នៃទ្រឹស្តីនោះទេ។

៥. ទិដ្ឋភាពច្បាប់ប្រើប្រាស់តាមស្ថាប័ននិងវិស័យពាក់ព័ន្ធ

៥.១. ច្បាប់ប្រើប្រាស់ក្នុងវិស័យពន្ធដារ

គម្ពីរព្រះធម្មសាស្ត្រ មាននិយាយពីពន្ធអាករយ៉ាងលម្អិត ដែលជាមូលដ្ឋានគ្រឹះនៃប្រព័ន្ធរដ្ឋបាល និងហិរញ្ញវត្ថុរបស់រាជាណាចក្រខ្មែរ រួមទាំងចក្រភពអង្គរផងដែរ។ នៅក្នុងគម្ពីរព្រះធម្មសាស្ត្រ មិនត្រឹមតែអនុញ្ញាតឱ្យមានការយកពន្ធប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានកំណត់គោលការណ៍សីលធម៌សម្រាប់ការប្រមូលពន្ធ ដើម្បីធានាបាននូវតុល្យភាពរវាងអំណាចរបស់ព្រះមហាក្សត្រ និងសុខុមាលភាពរបស់ប្រជារាស្ត្រ។ គោលការណ៍ទាំងនេះហើយដែលបានក្លាយជាមូលដ្ឋាននៃប្រព័ន្ធពន្ធអាកររនៅក្នុងចក្រភពខ្មែរ។

ព្រះធម្មសាស្ត្រ ជាពិសេស គម្ពីរសាស្ត្រប៉ែលបុរាណផ្សេងៗ ដូចជា *មនុស្ស្ម្រិ* និង *អថ៌សាស្ត្រ* របស់កៅដិល្យ បានកំណត់អំពីគោលការណ៍សំខាន់ៗនៃការយកពន្ធដូចខាងក្រោម៖

៥.១.១. សិទ្ធិ និងភារកិច្ចរបស់ព្រះមហាក្សត្រ

ច្បាប់ព្រះធម្មសាស្ត្របានចែងថា ការយកពន្ធអាករ គឺជាសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះមហាក្សត្រក្នុងនាមជាម្ចាស់ផែនដី។ ការយកពន្ធ គឺដើម្បីធានានូវលទ្ធភាពរបស់រដ្ឋាភិបាលក្នុងការគ្រប់គ្រងប្រទេស។ ការយកពន្ធត្រូវបានភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹង កាតព្វកិច្ច របស់ព្រះមហាក្សត្រក្នុងការការពារប្រជារាស្ត្រពីសត្រូវផ្ទៃក្នុង និងខាងក្រៅ។ បើព្រះមហាក្សត្រមិនបានបំពេញកាតព្វកិច្ចការពារទេនោះ ប្រជារាស្ត្រមានសិទ្ធិឈប់បង់ពន្ធ។

ក. គោលការណ៍នៃអត្រាពន្ធសមរម្យ

ព្រះធម្មសាស្ត្របានសង្កត់ធ្ងន់លើការយកពន្ធដោយយុត្តិធម៌ និងមិនតឹងរ៉ឹងជ្រុលហួសហេតុ។ អត្រាពន្ធដែលខ្ពស់បំផុត គឺ១/៦លើផលិតផលទទួលបានផលល្អ ហើយអត្រាទាបចំនួន១/១២ លើផលិផលដែលទទួលបានតិច ឬចំណូលរបស់ប្រជារាស្ត្រ (ជាពិសេសស្រូវ និងផលិតផលកសិកម្ម)។ ការអនុវត្តគោលការយកពន្ធនេះតម្រូវតាមទម្លាប់ប្រពៃណី ដ៏ល្បីល្បាញថា ដែលព្រះមហាក្សត្របានអនុវត្តក្នុងការប្រមូលពន្ធដូចជា៖

- **ឃ្មុំបីតផ្កា៖** ដែលបីតយកលំអងផ្កាបន្តិចម្តងៗ ដោយមិនធ្វើឱ្យផ្កាខូចខាត។
- **កូនគោបៅដោះ៖** បៅបន្តិចម្តងៗ ដោយមិនធ្វើឱ្យមេវាហត់នឿយបាក់កម្លាំង។

ខ. ប្រភេទពន្ធសំខាន់ៗ

ធម្មសាស្ត្របានចែងអំពីពន្ធជាច្រើនប្រភេទ ដែលត្រូវបង់ជាទំនិញ ឬសេវា ក្នុងនោះមាន៖

- **ពន្ធលើដីធ្លី/កសិកម្ម៖** ជាប្រភពចំណូលដ៏ធំបំផុត ដែលត្រូវបង់ជាស្រូវ។
- **ពន្ធលើពាណិជ្ជកម្ម៖** ពន្ធគយ និងអាករលើការជួញដូរទំនិញ។
- **ពន្ធលើមុខរបរ/វិជ្ជាជីវៈ៖** លើសិប្បករ ឈ្មួញ ឬអ្នករកស៊ីដទៃទៀត។
- **កម្លាំងពលកម្ម៖** ការកេណ្ឌកម្លាំងពលកម្មពីប្រជារាស្ត្រដើម្បីធ្វើការងារសាធារណៈដូចជាការសាងសង់ ឬបម្រើកងទ័ព។

៥.១.២. ពន្ធកសិកម្ម

របបពន្ធអាករក្នុងចក្រភពខ្មែរ គឺជាប្រព័ន្ធពន្ធមូលដ្ឋានលើផលិតផលឬទិន្នផល និងកម្លាំងពលលកម្ម (Barter and Service-based System)។ ចំពោះប្រភេទមន្ត្រីគ្រប់គ្រងនិងអនុវត្តការប្រមូលពន្ធ សូមមើលចំណុច ។ របបពន្ធអាករសម័យអង្គរ មានលក្ខណៈខុសប្លែកពីប្រព័ន្ធពន្ធសព្វថ្ងៃដាច់ស្រឡះដូចខាងក្រោម៖

- **ការទូទាត់ជាវត្ថុ (មិនមែនជាប្រាក់កាស)៖** ចក្រភពខ្មែរមិនបានប្រើរូបិយប័ណ្ណជាមូលដ្ឋានទេ។ ពន្ធអាករត្រូវបានបង់ជាទំនិញ ឬ ផលិតផល ដូចជា៖ មាស ប្រាក់ កំណាត់ (ក្រណាត់) ស្រូវ ប្រេង សត្វពាហនៈ ជាដើម។ សួយសារអាករ ពីបណ្តារដ្ឋចំណុះ (សម្ភារៈមានតម្លៃ ឬផលិតផលក្នុងស្រុករបស់ខ្លួន) ឬក៏វត្ថុ ផលិតផលកសិកម្ម រុក្ខផល ឬផលិតឧស្សាហកម្ម ដូចជាអំបិល ដែក ឬកុលាលភាជន៍។ល។
- **ការយកពន្ធផ្អែកលើទិន្នផល ឬផលិតផល៖** ការបង់ពន្ធជារឧស់បំផុត១/៦ និងតិចបំផុត១/១២ នៃផលិតផលនានា។
- **សិទ្ធិរបស់ព្រះមហាក្សត្រ៖** ការយកពន្ធអាករ គឺជាសិទ្ធិពិសិដ្ឋរបស់ព្រះមហាក្សត្រដែលជាម្ចាស់ផែនដី។ ព្រះរាជាប្រើប្រាស់ធនធានទាំងនេះដើម្បីគ្រប់គ្រងអាណាចក្រ ផ្តល់រង្វាន់ដល់មន្ត្រីស្មោះត្រង់ ថែទាំប្រព័ន្ធធារាសាស្ត្រ និងជាពិសេសគឺដើម្បីសាងសង់ប្រាសាទ និងសំណង់សាធារណៈធំៗ។
- **ការកេណ្ឌកម្លាំងពលកម្ម៖** ក្រៅពីពន្ធជាទំនិញ ព្រះមហាក្សត្រក៏មានសិទ្ធិកេណ្ឌពលកម្ម ពីប្រជារាស្ត្រសម្រាប់បម្រើការងារសំណង់ (សាងសង់ប្រាសាទ) និងកិច្ចការយោធាផងដែរ។

- **ការគ្រប់គ្រងរដ្ឋបាល៖ ប្រព័ន្ធ**រដ្ឋបាលត្រូវបានរៀបចំឡើងដើម្បីកែលម្អការប្រមូលពន្ធ និងសេវា ជាពិសេសនៅតាមខេត្តឆ្ងាយៗ។ ព្រះរាជាផ្សេងៗគ្នាបានធ្វើកំណែទម្រង់រដ្ឋបាលដើម្បីប្រមូលពន្ធបានកាន់តែប្រសើរ។

៥.១.៣. ពន្ធកម្លាំងពលកម្ម

នៅក្នុងការសិក្សារបស់លោក **សាហៃ សច្ចិទានន្ទ** បានបង្ហាញថានាសម័យអង្គរ មានការងារជាកាតព្វកិច្ចមួយប្រភេទ ដែលយើញមានពាក្យសរសេរក្នុងសិលាចារឹកថា ***«រាជការយ៉ា»***ឬ ***«រាជ្យការយ៉ា»***(K.៦៨២) មានសេចក្តីថា ***«កម្លាំងពលកម្មរបស់រាជការ»***និងមានឃ្លា ***«ថ្វៃព្រះរាជការយ៉ា»***(បង់ឬផ្តល់កម្លាំងពលកម្មជូនរាជការ) (Sahai, ១៩៧០)។ តាមអ្នកស្រាវជ្រាវប្រវត្តិសាស្ត្រនិងអារ្យធម៌ខ្មែរ នៅសម័យបុរាណ មនុស្សទូទៅក្នុងព្រះនគរត្រូវមានកាតព្វកិច្ចផ្តល់កម្លាំងពលកម្មរបស់ខ្លួនមួយរយៈពេល (មិនដឹងរយៈពេលប៉ុន្មានឱ្យប្រាកដ) ជូនរាជការ។ ប្រភេទការងារ ***«រាជការ»***ប្រហែលត្រូវនឹងប្រភេទការងារបម្រើរដ្ឋ ដែលត្រូវនឹង ***«កំណែន»***និង ***«កាតព្វកិច្ចកងទ័ព»***។ នៅលើចម្លាក់ររបៀងខាងត្បូង ចំហៀងខាងលិចនៃប្រាសាទអង្គរវត្ត មានចម្លាក់និងអក្សរចារឹក (K.២៩៨-២៨) បញ្ជាក់ពីអ្នករាជការភាគប្រមាញ់ជើងឆាល់ បានដឹកនាំទ័ពកំណែនពួកសង្សាំកុក ចេញឆ្ការព្រៃ ដើម្បីនាំទ័ពរបស់ព្រះបាទស្រីសូរ្យវរ្ម៌ទេវទី២ (សូរ្យវរ្ម៌ទី២) ដែលធ្វើព្យុហយាត្រាចុះពីភ្នំសិវបាទ។ ចំណុចត្រង់នេះ អាចបញ្ជាក់បានថា ពួកទ័ពសង្សាំកុក ជាក្រុមមនុស្សចំណុះឱ្យអំណាចខ្មែរ និងត្រូវជាប់កាតព្វកិច្ចថ្វាយកម្លាំងពលកម្មដល់រាជការ។

ក- កាតព្វកិច្ចពលកម្ម

ក្នុងពេលនគរសោន្តត្រាណ កម្លាំងពលកម្មផ្តល់ដោយរាស្ត្រ ត្រូវរាជការយកទៅប្រើប្រាស់ជាកម្លាំងពលកម្មសម្រាប់គម្រោងការងារសាធារណៈ ផ្លូវថ្នល់ ស្ពាន និងប្រព័ន្ធធារាសាស្ត្រ សម្រាប់ការសាងសង់ប្រាសាទធំៗរបស់រាជការជាដើម។ កម្លាំងពលកម្មនេះ មានសារៈសំខាន់ចំពោះវិស័យសេដ្ឋកិច្ច ដែលចាំបាច់សម្រាប់ការទ្រទ្រង់គម្រោងការងាររបស់រាជការ ដូចជា វិស័យកសិកម្ម ហេដ្ឋរចនាសម្ព័ន្ធសាធារណៈ មន្ទីរពេទ្យ សាលាអប់រំ។ល។

ខ- កាតព្វកិច្ចបម្រើកងទ័ព

បើនាពេលនគរមានចម្បាំង រាជការបានប្រើកម្លាំងដែលផ្តល់ដោយរាស្ត្រ សម្រាប់ការងារកងទ័ព។ កម្លាំងរាស្ត្រគឺជាកាតព្វកិច្ចបម្រើរាជការ ដែលអាចយកមកជួយការងារ

កងទ័ព ក្នុងកិច្ចការពារនិងរក្សាសណ្តាប់ធ្នាប់ចក្រភព។ យោងតាមតម្រូវការរបស់រាជការ ប្រជាជនត្រូវបានកេណ្ឌនៅពេលចាំបាច់ក្នុងពេលនគរមានសឹកសង្គ្រាម។

កាតព្វកិច្ចចំពោះព្រះមហាក្សត្រ រួមទាំងកាតព្វកិច្ចពលកម្មនិងកាតព្វកិច្ចយោធា គឺជាកាតព្វកិច្ចជាមូលដ្ឋានរបស់ប្រជាជនទូទៅ ដើម្បីចូលរួមការពារព្រះមហាក្សត្រ និង ស្ថិរភាពនៃចក្រភព។ ឃ្លា ***«ថ្វាយព្រះរាជ្យការ»*** នៅក្នុងសិលាចារឹក បានបង្ហាញថាប្រជាជន បានផ្តល់កាតព្វកិច្ចពលកម្ម ជាប្រភពកម្លាំងពលកម្មចម្បងសម្រាប់យោធា។ ក្នុងសម័យ សន្តិភាព កម្លាំងពលកម្មទាំងនោះ ប្រហែលបានប្រើក្នុងវិស័យកសិកម្មក្រៅរដូវ និង គម្រោងសាងសង់នានារបស់ជាតិ។

សរុបមក សេវាជាកាតព្វកិច្ចនេះ ពេលស្រុកសាន្តត្រាណ រាជការប្រើកាតព្វកិច្ច ពលកម្មផ្តោតលើការសាងសង់ និងហេដ្ឋារចនាសម្ព័ន្ធ។ រីឯពេលចម្បាំង កម្លាំងពលកម្ម នេះ បានក្លាយកាតព្វកិច្ចយោធាផ្តោតលើសង្គ្រាមនិងការពារជាតិ។ លើសពីនេះ រាជការ បានប្រភពកម្លាំងប្រជាជនទូទៅ ដ៏មានមានសារៈសំខាន់ចំពោះដំណើរការអភិវឌ្ឍន៍ និង ការពង្រីកចក្រភពខ្មែរបុរាណ។

៥.២. ច្បាប់ប្រើប្រាស់លើសុខាភិបាលនៅសម័យអង្គរ

នៅក្នុងរាជ្យព្រះបាទស្រីជ័យវរ្ម័ទេវទី៧ (ជ័យវរ្ម័នទី៧) បានបង្កើតប្រព័ន្ធសុខាភិ បាល មួយដែលមានមន្ទីរពេទ្យចំនួន១០២ នៅក្នុងចក្រភពខ្មែររួមទាំងអំណាចកណ្តាល និងសាមន្តរាជក្នុងប្រព័ន្ធមណ្ឌល។ វិស័យសុខាភិបាលក្នុងរាជ្យរបស់ព្រះអង្គ ជាប្រព័ន្ធ បានទទួលការឧបត្ថម្ភពីរាជការអង្គរទាំងស្រុង។

ការសិក្សាស្រាវជ្រាវថ្មីៗនេះ បានបង្ហាញថា «លទ្ធផលមិនអាចប្រកែកបាន នោះគឺថាចក្រភពខ្មែរ ជាពិសេសក្នុងរជ្ជកាលព្រះបាទស្រីជ័យវរ្ម័ទេវទី៧ (ជ័យវរ្ម័នទី ៧) (ចុងសតវត្សទី ១២ ដល់ដើមសតវត្សទី ១៣) បានបង្កើតបណ្តាញមន្ទីរពេទ្យដ៏ ទំនើបនិងលក្ខណៈទូលំទូលាយ ដែលតំណាងឱ្យការរីកចម្រើនដ៏សំខាន់មួយនៅក្នុងការ ថែទាំសុខភាពសាធារណៈ»។

សិលាចារឹកប្រាសាទតាព្រហ្ម និងភស្តុតាងបុរាណវិទ្យា បានឱ្យយើងដឹងថា ព្រះបាទស្រីជ័យវរ្ម័ទេវទី៧ (ជ័យវរ្ម័នទី៧) បានបង្កើតបណ្តាញមន្ទីរពេទ្យចំនួន**១០២** ទូ ទាំងចក្រភពខ្មែរ។ នេះបង្ហាញពីការប្តេជ្ញាចិត្តដ៏សំខាន់របស់រដ្ឋចំពោះសុខុមាលភាពរបស់ ប្រជាជនរបស់ខ្លួន ទូទាំងរាជមណ្ឌល។ មន្ទីរពេទ្យទាំងនេះ មាននៅតាមទីប្រជុំ ក្រុង

ហើយច្រើនតែស្ថិតនៅក្បែរផ្លូវធំៗ។ នៅតាមដងផ្លូវធំៗ ក្នុងរវាងប្រមាណ៤០គីឡូម៉ែត្រ មានមន្ទីរពេទ្យមួយ (អ៊ឹម et al., ២០២១) ពោលគឺ៖

- បើសែងអ្នកជំងឺ ដោយថ្មើរជើងត្រូវប្រើជិតមួយថ្ងៃ
- បើបរទេះគោចំណាយពេលជិត៣ម៉ោង
- បើបរទេះសេះ អាចចំណាយពេលជិត២ម៉ោង
- បើជិះសេះ ត្រូវប្រហែលមួយម៉ោងកន្លះ
- បើជិះដំរី ត្រូវប្រើពេលជាង២ម៉ោង។ល។

៥.២.១. ធម្មនុញ្ញនៃមន្ទីរពេទ្យ

នៅតាមមន្ទីរពេទ្យនីមួយៗមានតម្កល់សិលាចារឹកគោលមួយ ដែលមានចែងជាបញ្ញតិដូចៗគ្នា (Barth, 1903; Chea et al., 2023; Cœdès, 1940; Finot, 1903; Honda, 1965; Rethy et al., 2023)។ សិលាចារឹក ទាំងនេះបានបង្ហាញពីអ្វីដែលជាគោលការណ៍សំខាន់ៗនៃប្រព័ន្ធសុខាភិបាលសាធារណៈរបស់ព្រះអង្គ ដែលអាចចាត់ទុកជា ***«ធម្មនុញ្ញ»*** ឬ ***«គោលការណ៍ប្រតិបត្តិ»*** របស់មន្ទីរពេទ្យ ដូចខាងក្រោម៖

ក. ជំនួយឧបត្ថម្ភពីរាជការ៖ សិលាចារឹក និងការរកឃើញផ្នែកបុរាណវិទ្យាបង្ហាញថា មន្ទីរដំណើរការរបស់ពេទ្យទាំងនេះបានទទួលការឧបត្ថម្ភពីរាជការ។ ព្រះមហាក្សត្រផ្ទាល់បានបង្ហាញពីការព្រួយបារម្ភយ៉ាងខ្លាំងចំពោះសុខភាពរបស់ប្រជានុរាស្ត្រ ដោយទ្រង់មានបន្ទូលយ៉ាងដូច្នេះ *«រោគាផ្លូវចិត្ត មានសេចក្តីឈឺចាប់ខ្លាំងជាងរោគដែលកើតមានក្នុងរាងកាយ ឯសេចក្តីទុក្ខរបស់រាស្ត្រ គឺជាសេចក្តីទុក្ខនៃមេដឹកនាំទាំងឡាយ, សូម្បីសេចក្តីទុក្ខនោះ មិនមែនជាសេចក្តីទុក្ខផ្ទាល់ខ្លួនក៏ដោយ»*។ រាជការបានផ្តល់ធនធាន រួមទាំងបុគ្គលិក និងឱសថ ដល់មន្ទីរពេទ្យទាំងនេះ។ ដោយសារឱសថធម្មជាតិ មន្ទីរពេទ្យនីមួយៗត្រូវឡើងមកបើកយកថ្នាំពីព្រះរាជឃ្លាំងនៅរាជធានី នៅរៀងរាល់ខែមីនា ខែមិថុនា និងខែកញ្ញា (៤ខែម្តង)។ ឱសថខ្លះនាំមកពីប្រទេសឥណ្ឌា ខ្លះមកពីប្រទេសចិន ខ្លះផលិតតាមសាមន្តរាជ និងខ្លះទៀតដាំក្នុងបរិវេណមន្ទីរពេទ្យផ្ទាល់។

ខ. រចនាសម្ព័ន្ធអង្គការលេខរបស់មន្ទីរពេទ្យ៖ យោងតាមធម្មនុញ្ញដែលចារនៅលើសិលាចារឹកតម្កល់ក្នុងប្រាសាទរបស់មន្ទីរពេទ្យនីមួយៗ មានរចនាសម្ព័ន្ធស្តង់ដារតែមួយ និងបុគ្គលិកយ៉ាងច្រើន ដឹកនាំដោយនាយកម្នាក់បានតែងតាំងដោយព្រះមហាក្សត្រ។ មន្ទីពេទ្យនីមួយៗមាន៖ **វេជ្ជបណ្ឌិត គិលានុបដ្ឋាយិកា ឱសថការី និងបុគ្គលិក**

ជំនួយផ្សេងទៀត ដែលបង្ហាញពីប្រព័ន្ធរៀបចំបានល្អសម្រាប់ការថែទាំអ្នកជំងឺ។ មានមនុស្សប្រហែល ៩០-៩៨ នាក់ បម្រើការនៅមន្ទីរពេទ្យតែមួយ។

គ. ការប្រតិបត្តិវិស័យវេជ្ជសាស្ត្រប្រកបដោយវិទ្យាសាស្ត្រ៖ ដោយប្រើប្រាស់ឱសថបុរាណ ប្រព័ន្ធនេះក៏បានបញ្ចូលការអនុវត្តដែលអាចចាត់ទុកថាជាទម្រង់ដំបូងនៃការធ្វើរោគវិនិច្ឆ័យផ្នែកវេជ្ជសាស្ត្រ ដូចជា **ការពិនិត្យជីពចរអ្នកជំងឺ** ជាដើម។ ឱសថតែងមានសារធាតុរួមផ្សំដូចជា ទឹកឃ្មុំ ប៊ឺរ (ទឹកដោះគោខាប់) ប្រេង និងស្ករត្នោ ព្រមទាំងមានការប្រើប្រាស់គីមីសាស្ត្រ វេជ្ជសាស្ត្រ (medical alchemy) បន្ថែមដែរ។

ឃ. ការរួមបញ្ចូលជាមួយរបៀបធ្វើរោគវិនិច្ឆ័យតាមសាសនា៖ ក្នុងបរិវេណមន្ទីរពេទ្យនីមួយៗ **ប្រាសាទមួយ** ដែលផ្សាភ្ជាប់ទំនាក់ទំនងយ៉ាងជិតស្និទ្ធរវាងវេជ្ជសាស្ត្រ និងស្មារតីនៅក្នុងសង្គមអង្គរ។ ប្រាសាទមានតម្កល់ព្រះបដិមា ព្រះពុទ្ធស្តេចថ្នាំ១ «ភៃសជ្ជគុរុ» ។ បើពេទ្យវិជ្ជសាស្ត្ររកវោគវិនិច្ឆ័យពុំឃើញ ឬព្យាបាលមិនសះស្បើយ ឬចិត្តសាស្ត្រអ្នកជំងឺ អាចារ្យបម្រើក្នុងប្រាសាទនឹងរៀបចំការងារធ្វើរោគវិច្ឆ័យតាមប្រពៃណីសាសនា។

ង. ការព្យាបាលនិងថែទាំសុខភាពដោយឥតគិតថ្លៃ៖ មន្ទីរពេទ្យទាំងនោះបានផ្តល់ **ការព្យាបាល ការថែទាំសុខភាពដោយឥតគិតថ្លៃពីរដ្ឋ** ដល់គ្រប់មនុស្សក្នុងសង្គមនៅក្នុងចក្រភព។ នេះគឺជាគំនិតផ្តួចផ្តើមដ៏គួរឱ្យកត់សម្គាល់មួយសម្រាប់សម័យកាលនោះ ដែលបង្ហាញពីការប្តេជ្ញាចិត្តចំពោះសុខុមាលភាពសាធារណៈ ដែលមិនដែលកើតមាននៅទីដទៃ ក្នុងពិភពលោកនៅសម័យដូចគ្នា។ លើសពីនេះ មន្ទីរពេទ្យតែងផ្តល់ចំណីអាហារដល់អ្នកទុគ៌ត និងផ្តល់កន្លែងស្នាក់នៅបណ្តោះអាសន្ន ជូនអ្នកជាច់សង្វែង។ល។

ច. ការផ្សេរចំណេះដឹង៖ ប្រព័ន្ធនេះក៏អាចជួយសម្រួលដល់ **ការផ្សេរចំណេះដឹងផ្នែកវេជ្ជសាស្ត្រ** តាមរយៈវិស័យអប់រំបណ្តុះបណ្តាលរបស់អង្គរដោយមានសក្តានុពល និងការផ្សព្វផ្សាយការអនុវត្តផ្នែកវេជ្ជសាស្ត្រទូទាំងចក្រភព។

ជាសរុបមក តាមភស្តុតាងដែលបានលើកឡើងមកខាងលើ អ្នកស្រាវជ្រាវមានទស្សនយ៉ាងច្បាស់អំពីប្រព័ន្ធសុខាភិបាលរបស់អង្គរគឺជា ***«ប្រព័ន្ធដែលឧបត្ថម្ភដោយរាជការនេះ មានលើកដំបូងគេរបស់ពិភពលោក»***។ វាគឺជាប្រព័ន្ធមានភាពលំបាកនិងស្មុគស្មាញក្នុងការគ្រប់គ្រង តែជាក់ស្តែងប្រព័ន្ធនេះបានបង្កើតឡើងដោយព្រះបាទស្រីជ័យវរ្ម័នទេវទី៧ (ជ័យវរ្ម័នទី៧) ប្រកបដោយប្រសិទ្ធភាពដែលជាសមិទ្ធិផលដ៏អស្ចារ្យមួយរបស់ពិភពលោកនាសម័យកាលនោះ។ ចំណុចនេះជាការបង្ហាញពីការប្តេជ្ញាចិត្តចំពោះសុខភាពសាធារណៈ និងកម្រិតនៃអង្គការចាត់តាំងមួយ ដែលទំនងជាមិនមានគូប្រៀបនៅទី

ជំទៃទៀតរបស់ពិភពលោកក្នុងអំឡុងចុងសតវត្សទី១២ និងដើមសតវត្សទី១៣។ ប្រព័ន្ធនេះបានផ្តល់កម្រិតនៃការព្យាបាលនិងថែទាំសុខភាពដ៏សំខាន់ដល់ប្រជាជននៃចក្រភពខ្មែរដ៏ធំល្វឹងល្វើយ នៅអាស៊ីអាគ្នេយ៍ និងផ្តល់ជាមេរៀនបទពិសោធដូនដល់ប្រវត្តិសាស្ត្រមនុស្សជាតិយើងនេះ។

រូប ៤. ចម្លាក់បង្ហាញពីទិដ្ឋភាពមន្ទីរពេទ្យលើចម្លាក់ចញ្ចាំងប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ និងដើមស.វ.ទី១៣



រូប ៥. ចម្លាក់ស្នង់ជីពចរ លើហោជាងប្រាសាទលាក់នាង (ក្បែរប្រាសាទកែវ) និងចម្លាក់សម្រាលកូននាប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ និងដើមស.វ.ទី១៣





៥.៣. ទិដ្ឋភាពទូទៅនៃប្រព័ន្ធតុលាការ

ការដោះស្រាយវិវាទនៅតាមប្រព័ន្ធតុលាការ ជាកម្មវត្ថុសំខាន់មួយដែលមានបង្ហាញនៅក្នុងអត្ថបទសិលាចារឹកខ្មែរ ជាពិសេសគឺផ្នែកអត្ថបទភាសាខ្មែរបុរាណ និងភាគច្រើនស្ថិតនៅរវាងស.វ.ទី១០ ដល់ទី១១។ កន្លងមកមានការសិក្សាច្រើនរបស់អ្នកស្រាវជ្រាវអន្តរជាតិផ្តោតទៅលើបញ្ហានេះ។ មានការសិក្សាចុងក្រោយមួយរបស់លោក សួង សុខរ៉ូ (២០១៨, ២០១៥) មានលក្ខណៈលម្អិតនិងក្បោះក្បាយដែលមានសេចក្តីសង្ខេបដូចខាងក្រោម។

៥.៣.១. រចនាសម្ព័ន្ធតុលាការ

នៅសម័យបុរាណផ្នែកទាក់ទងនឹងតុលាការ គឺគេបង្ហាញដោយពាក្យថា **សភា, ព្រះសភា** និង **សភាស្ថាន**។ ពាក្យ ***«សភា»*** សំដៅដល់ទីជំនុំកាត់ក្តី ដែលពាក្យនេះក្លាយមកជា ***«សុភ»*** និង ***«សូភា»*** នាសម័យក្រោយៗមក ដែលជាប់ទាក់ទងនឹងវិស័យតុលាការ។ ចំពោះ ***«ព្រះសភា»*** ឬ ***«សភាស្ថាន»*** មានបីកម្រិតគឺ ព្រះសភាស្រុក ព្រះសភាវិស័យ និងព្រះសភានគរ។

- **ព្រះសភាស្រុក** (ខ.ច. ព្រះសភាស្រុក៑) សម្តៅលើតុលាការដែលគ្រប់គ្រងក្នុងតំបន់រដ្ឋបាលនៅកម្រិតមូលដ្ឋានហៅថា ***«ស្រុក»***។
- **ព្រះសភាវិស័យ** (ខ.ច. ព្រះសភាវិមយ) ជាតុលាការដែលគ្រប់គ្រងតំបន់រដ្ឋបាលកម្រិតទី២។ ចំពោះ ***«វិស័យ»*** ជាពាក្យសម្គាល់តំបន់ ឬដែនដីដែលមានវិសាលភាពធំជាងស្រុក ហើយទំនងជាអាចមានវិសាលភាពស្មើ ឬធំជាងខេត្តបច្ចុប្បន្នផង។
- **ព្រះសភាប្រាសាទ** ជាតុលាការនៅតាមទេវស្ថាន ឬប្រាសាទធំតូច នៅតាមខេត្តក្រៅក្នុងចក្រភព។ ចៅអធិការប្រាសាទ (ខ្លោញរ្នំ/ក្នំ) ជាច្រើន ជាព្រះសភាបតី ក្នុងជួររដ្ឋមន្ត្រីកម្រិតទី១, ទី២, ទី៣ និងទី៤ នៃរាជការមជ្ឈិមនិងខេត្តស្រុក។ អាទិទេព ឬប្រាសាទតូចធំជាច្រើន ត្រូវបានព្រះអធិរាជប្រគល់ភូមិស្រុក និងខេត្តចំណុះ ដែលបានន័យថា ប្រជារាស្ត្រនៅដែនដីទាំងនោះ ត្រូវនាំគ្នាបង់ពន្ធឱ្យអាទិទេព ឬប្រាសាទ និងនៅក្រោមការគ្រប់គ្រងរបស់ចៅអធិការប្រាសាទ។ ដែនដីទាំងនោះ តែងទទួលបាននូវបុព្វសិទ្ធិមិនចំណុះឱ្យរដ្ឋបាលដែនដីខេត្ត(វិស័យ)។

- **ព្រះសភានគរ** ជាតុលាការកំពូលប្រចាំប្រទេសទាំងមូលមានអំណាចធំជាងគេបង្អស់ និងជាកន្លែងសម្រេចក្តីចុងក្រោយនៃដំណើរការតុលាការ។ ព្រះមហាក្សត្រក៏ជាអ្នកគ្រប់គ្រងព្រះសភានគរដែរ។

ក្នុងរចនាសម្ព័ន្ធតុលាការ មានក្រុមមនុស្ស២ក្រុម គឺក្រុមទី១ ជាអ្នកដែលមានតួនាទីច្បាស់លាស់លើផ្នែកនីមួយៗនៅក្នុងរចនាសម្ព័ន្ធតុលាការ និងក្រុមទី២ ជាក្រុមអ្នកពាក់ព័ន្ធ ប៉ុន្តែពុំមានតួនាទីជាក់ប្រាកដនោះទេ។

ចក្រវត្តិ / ព្រះអធិរាជ							
តុលាការនគរ/រាជវាំង			**វិស័យ/ខេត្តលេខ១/ស្តេចត្រាញ់**			**ប្រាសាទ/ខ្លោញ្ជ្រុំ-ភ្នំ**	
វិស័យ/ខេត្តក្នុង	វិស័យ/ខេត្តក្នុង	រាជសវនាការ	ខេត្តលេខ ២	ខេត្តលេខ ៣	ខេត្តលេខ ៤	ខេត្តច្រើន	អន្ទាយ
សភាវិស័យ	សភាវិស័យ	សភាបតី	សភាវិស័យ	សភាវិស័យ	សភាវិស័យ	សភាវិស័យ	
សភាស្រុក	សភាស្រុក		សភាស្រុក	សភាស្រុក	សភាស្រុក	សភាស្រុក	

៥.៣.១.១. ទម្រង់នៃស្ថាប័នតុលាការ

- **សភាបតី៖** ជារដ្ឋមន្ត្រីយុត្តិធម៌, ជាប្រធានតុលាការ ឬជាមេចៅក្រម ដែលមានតួនាទីក្នុងការស្វែងរកយុត្តិធម៌ឱ្យអធិករណ៍ ដែលបានប្តឹង។ ជាធម្មតាសភាបតីដែលទទួលបន្ទុកដោះស្រាយបណ្តឹងរបស់អធិករណ៍(អចិ ឬដើមចោទ និងប្រត្យចិ ឬចុងចោទ) ក្រោមបញ្ជារបស់ព្រះមហាក្សត្រ ឬអធិរាជ ឬចៅហ្វាយខេត្ត (ខ្លោញ/ប្រធានវិមយ) ពួកគេអាចត្រឹមធ្វើសេចក្តីសន្និដ្ឋានចំពោះរឿងក្តីដែលត្រូវបានរកឃើញការពិតទាំងនោះប៉ុណ្ណោះ។ ចំពោះការសម្រេចសេចក្តីធំជាងគេចុងក្រោយ ត្រូវស្ថិតក្នុងដៃរបស់ចៅហ្វាយខេត្ត ឬព្រះអធិរាជ។ ចំណែក ឋានានុក្រមរបស់សភាបតី ខ្ពស់ ឬទាប ត្រូវអាស្រ័យលើកត្តាពីរយ៉ាងឋានន្តរនាមគោល នៅខាងដើមនៃឈ្មោះ តាមលំដាប់លើខ្សែឈរ និងនាមប្បញ្ញត្តិ ឬឋានន្តរនាមនៅខាងចុងនៃនាមប្បញ្ញត្តិ ព្រមទាំងលេខលំដាប់ក្នុងជួរនោះ ដែលត្រូវបានបញ្ជាក់ជាថ្នាក់ទី១ (ឯក) ថ្នាក់ទី២ (ទោ) ថ្នាក់ទី៣ (ត្រីណី) ឬ ថ្នាក់ទី៤ (ចត្វារី) ដែលជាឋានៈទាបជាងគេនៅក្នុងលំដាប់ជួរ ។
- **សភាចារ៖** ជាអ្នកចុះស៊ើបអង្កេតរឿងក្តីអ្វីមួយដល់ទីកន្លែងផ្ទាល់។

- **សភាជន៖** ជាងារហៅសម្គាល់សមាជិករបស់សភាតុលាការ ឬមន្ត្រីបម្រើការនៅព្រះសភា។
- **សភាសត៖** ជាសមាជិកសភាកាន់អំណាចគ្រប់គ្រងសណ្តាប់ធ្នាប់សាលាក្តី និងតួនាទីជាអ្នកវាយតម្លៃប៉ាន់ប្រមាណទំហំរឿងក្តី។
- **ខ្លោញ្ញសណ្តាប់៖** មន្ត្រីតំណាងព្រះមហាក្សត្រចូលរួមក្នុងសវនាការ (ខ.ច. ខ្លោញ្ញសំតប៊/សំតាប)។
- **គុណទោស ឬគុណទោសទស៌ី៖** ជាអ្នកត្រួតពិនិត្យពីគុណនិងទោស ល្អនិងអាក្រក់ និងមានមានមុខងារប្រៀបដូចនឹងព្រះអាជ្ញា។ (ខ.ច. គុណទោមទគិ; សំ. គុណទោមទគិនិ)។
- **វ្យវហារាធិការី៖** ជាមន្ត្រីថ្នាក់ខ្ពស់ទទួលបន្ទុកវិវាទ (រឿងក្តី)នីមួយៗ។ (សំ. វ្យវហារាធិការិនិ)។
- **រង្វាង៖** ជាតម្រួតឬល្បាត និងជាអ្នកឃ្លាំមើលរឿងរ៉ាវសព្វបែបយ៉ាងដល់ទីកន្លែងផ្ទាល់។ រង្វាងជាអ្នកសួរដេញដោលរកឬសគល់ដើមហេតុនៃទំនាស់។
- **ស្មូតព្រះធម្មសាស្ត្រ៖** ជាមន្ត្រីទទួលកិច្ចការងារខាងក្បួនច្បាប់។ ស្មូត្រឬអ្នកសូត្រធម្មសាស្ត្រ ជាអ្នកមានចំណេះដឹងខ្ពង់ខ្ពស់ស្ទាត់ជំនាញខាងវិទ្យាធម្មសាស្ត្រនិងខាងវោហាសាស្ត្រ។
- **គម្តែងផ្នែក្រោម៖** ជារហ័ស្សនាម ឬសព្វនាមសម្តៅលើអង្គព្រះមហាក្សត្រផ្ទាល់។ នៅក្នុងតុលាការនគរ ឬរាជវាំង ព្រះមហាក្សត្រជាចៅក្រមជម្រះក្តីធំជាងគេ និងជាធម្មតាព្រះអង្គជាចៅក្រមសម្រេចក្តីចុងក្រោយគេបង្អស់នៅរាជវាំង ឬតុលាការនគរ (ខ.ច. ព្រែកម្រតេង៑ផ្នែករៅ)។

មុខងារ ៖ សភាបតី, គុណទោសទស៌ី, សភាសត, វ្យវហារាធិការី, ស្មូតព្រះធម្មសាស្ត្រ, រង្វាង, ចារ, ធម្មាធិករណបាល, ...				
ឋានន្តរនាមលំដាប់ខ្សែឈរ	**លំដាប់ឋានៈមន្ត្រីនៅលើខ្សែដេក**			
ព្រែកម្រតេងអញ (គ្រី).....	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)
ព្រែកំស្តេងអញ(គ្រី)....	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)
ម្រតាញខ្លោញ(គ្រី)....	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)
ម្រតាញ (គ្រី).....	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)
ស្តេង	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)
វាប	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)

លោញ	ថ្នាក់ទី១(នាឯក)	ថ្នាក់ទី២(នាទោ)	ថ្នាក់ទី៣(នាត្រីណី)	ថ្នាក់ទី៤(នាចត្វារី)

តារាងបង្ហាញពីឋានានុក្រម ឬ លំដាប់ឋានៈរបស់មន្ត្រីយុត្តិធម៌ និងមន្ត្រីមុខងារផ្សេងទៀតនៅសម័យអង្គរ។

៥.៣.១.២. សមាសភាពនៃស្ថាប័នពាក់ព័ន្ធ

ក្រុមមនុស្សខាងក្រោមនេះ ពុំមាននាទីអ្វីប្រាកដនៅក្នុងតុលាការឡើយ ប៉ុន្តែមានពេលខ្លះក៏អាចរួមចំណែកសម្រួលដំណើរការរបស់តុលាការដែរនៅពេលគេត្រូវការដែរ។ អ្នកទាំងនោះរួមមាន៖

- **រាជកុលមហាមន្ត្រី៖** ជាមន្ត្រីធំមានការៈមើលការខុសត្រូវរបៀបវិន័យរបស់ព្រះញាតិវង្ស
- **ព្រះរាជគ្រូ៖** ជាគ្រូរបស់ព្រះមហាក្សត្រដែលមានចំណេះដឹងជ្រៅជ្រះហើយបង្រៀនវិជ្ជាច្រើនបែបយ៉ាងដល់ព្រះមហាក្សត្រ។ (ខ.ច. ព្រះគុរុ)
- **ស្រែស្តី៖** ជាមន្ត្រីខាងការងារគ្រប់គ្រងដីធ្លី ភូមិបាល និងប្រហែលជាអ្នកត្រួតការងារសុរិយោដីតាមតំបន់នីមួយៗក្នុងនគរផង ។ (សំ. ក្សេត្រិន, បា. សេដ្ឋី)
- **ខ្លោញភូតាស៖** ជាមន្ត្រីបួសមានឋានៈមួយក្នុងតុលាការដែរ ដែលយើងមានពត៌មានមិនទាន់គ្រប់គ្រាន់ ដើម្បីកំណត់អត្តសញ្ញាណច្បាស់លាស់។ យោងតាមសិលាចារឹកមួយចារនៅឆ្នាំ៩៩២ នៃគ.ស. (Sahai 1970:85) ខ្លោញភូតាសម្នាក់ជាមន្ត្រីចុះបញ្ជីទេវទ្រព្យ ដើម្បីទប់ស្កាត់ការលួចពីប្រាសាទ។ បើតាមលោក Bruno Dagens (Dagens 2003:105) ***«ភូតាស»*** ប្រហែលមានតួនាទីកត់ត្រាបញ្ជី ដូចគ្នានឹងការងារ ***«ក្រឡាបញ្ជី»***។ សិលាចារឹកស្តុកកក់ធំ K.២៣៥D ភូតាស ជាអ្នកបួសពីរូបនៅខេត្តជើងភ្នំ ត្រូវបានស្តេងអញ សិខា សុំព្រះរាជានុញ្ញាតយកមកធ្វើជំនួយការក្នុងការកសាងព្រះ និងប្រាសាទ ព្រមទាំងបុរីនៅស្តុកកក់ធំ ភទ្របត្តនៈ ថ្វាយដល់រាជគ្រូព្រះបាទយសោវម៌្មទី១ ដែលមាននាម ស្តេងអញវាមសិវ ឬ ព្រះកម្រតេងសិវាស្រម (ក្មេង) និងត្រូវជាគ្រូរបស់ស្តេងអញ សិខានោះផងដែរ (វង់ សុធារ៉ា ២០១៦) ។ ពីបើយោងតាមច្បាប់នគរសៀម (១៨០៥) បានប្រើពាក្យខ្មែរបុរាណ ***«ភូតាស»*** នេះទៅប្រើបន្ត ដោយសរសេរជា ***«ភូដាដ»*** សំដៅមន្ត្រីហែរហមព្រះមហាក្សត្រ ជាអ្នកអនុវត្តច្បាប់ ភ្ជាប់នឹងតុលាការ។ ***«ភូដាដ»***

ដើរតួជាអ្នកជំនួយ ឬរណបចៅក្រមស៊ើបអង្កេត មានសិទ្ធិកាន់កាប់ពន្ធនាគារ និងកត់ត្រាបញ្ហាផ្សេងទាក់ទងនឹងការងារតុលាការ។

- **ឆ្មាំព្រះបញ្ជី៖** ជាមន្ត្រីថ្នាក់ខ្ពស់ប្រៀបនឹងនាយកក្រឡាបញ្ជី។

៥.៣.២. ប្រតេទវិវាទ

«ព្យវហារ» «វាទ» «អបវាទ» និង *«វិវាទ»* ជាពាក្យគន្លឹះសំខាន់ក្នុងការបង្ហាញពីរឿងរ៉ាវទំនាស់ក្តីក្តាំដែលមានក្នុងអត្ថបទសិលាចារឹក។ ឯវិវាទភាគច្រើនដែលនិយាយក្នុងសិលាចារឹកភាសាខ្មែរ សឹងតែជារឿងវិវាទដីធ្លី ដូចជាការដេរណ្តើមគ្នាធ្វើជាម្ចាស់កម្មសិទ្ធិលើដីណាមួយ, ការចោទប្រកាន់ពីការបោះបង្គោលព្រំដីបំពានលើដីអ្នកដទៃ, ការលួចដក ឬកម្ទេចបង្គោលព្រំដីចោលជាដើម។ ក្រៅពីនេះមានវិវាទដទៃទៀតដូចជា៖ ទំនាស់ទាក់ទងនឹងបំណុល និងការជំពាក់, រឿងបញ្ញើ និងការបញ្ចាំ, ទំនាស់ទាក់ទងនឹងជំនួញដែលគ្មានច្បាប់កម្មសិទ្ធិ, ការទាមទារយកសម្បត្តិដែលជាអំណោចមកវិញ, ទំនាស់ក្នុងសហគមន៍អ្នកជំនួញ, ការមិនគោរពតាមកតព្វកិច្ចរបស់ខ្លួន, ការបដិសេធមិនព្រមទទួលយកការព្រមព្រៀងទិញនិងលក់, ទំនាស់ទាក់ទងនឹងជម្លោះរវាងចៅហ្វាយនាយនឹងអ្នកនៅក្រោមបង្គាប់, ជម្លោះទាក់ទងក្នុងការកំណត់យកទ្រព្យសម្បត្តិជាកម្មសិទ្ធិ, ទំនាស់ទាក់ទងនឹងការនិយាយបង្ខូចកេរ្តិ៍ឈ្មោះអ្នកដទៃ, ការលួចកេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ, ករណីចោរប្លន់និងឃាតកម្ម, ករណីសាយស្មន់, ទំនាស់ទាក់ទងនឹងការទទួលទ្រព្យសម្បត្តិមរតកនិងទំនាស់ទាក់ទងនឹងល្បែងនិងការភ្នាល់ជាដើម។

យោងតាមកំណត់ត្រារបស់បេសកទូតចិន លោក ជីវ តាក្វាន់ របៀបដោះស្រាយក្តីនាសម័យអង្គរមានពីររបៀប គឺការដោះស្រាយតាមតុលាការ និងការដោះស្រាយតាមរបៀបជំនឿ។ របាយការណ៍នេះ ស៊ីគ្នានឹងរឿងព្រេងរបស់ខ្មែរនានា ដែលអ្នកស្រុកធម្មតាមានជម្លោះក្តីក្តាំអាចចូលគាល់ដល់ព្រះមហាក្សត្រ ដើម្បីសុំការកាត់ក្តី។ រឿងព្រេងនានា ក៏បានបង្ហាញអំពីវិធីកាត់ក្តីតាមរយៈចាស់ព្រឹទ្ធាចារ្យក្នុងភូមិស្រុក មន្ត្រីមូលដ្ឋានជាសេដ្ឋី ឬក៏លោកសុភា(សភា)ជាដើម ដែលបង្ហាញពីភាពស្របគ្នានឹងទិន្នន័យសិលាចារឹកដែរ។

៥.៣.៣. សាក្សីក្នុងពេលជំនុំក្តី

នៅគ្រប់វិវាទនិងថ្នាក់នៃសភា ត្រូវមានសាក្សី។ ខ្មែរខុសពីស្រុកឥណ្ឌា ត្រង់មនុស្សគ្រប់វណ្ណៈអាចធ្វើជាសាក្សីបាន តែនៅស្រុកឥណ្ឌាវណ្ណៈសូទ្រ (ថ្នាក់ទាប) មិន

អាចជាសាក្សីទេ។ សាក្សីពេលនិយាយបង្ហាញចំពោះព្រះសភា ត្រូវស្បថជាមុន។ មនុស្ស មួយចំនួនដែលមាននាទីក្នុងតុលាការក្នុងនាមជាសាក្សីដឹងឮ មានដូចជា៖

- **ព្រាហ្មណ៍៖** ជាបុគ្គលសំខាន់ក្នុងសាសនា។ ព្រាហ្មណ៍ជាអ្នកចេះដឹងក្បួន ច្បាប់កិច្ចពិធីសព្វបែបយ៉ាង ហើយព្រាហ្មណ៍ជាបុគ្គលបរិសុទ្ធគួរជាទីគោរព។
- **គ្រាមព្រឹទ្ធ៖** ជាចាស់ទុំ ចាស់ព្រឹទ្ធាចារ្យក្នុងភូមិឬហៅថា *«ចាស់ស្រុក»* ជា អ្នកដែលមានចំណេះដឹងនិងដឹងរឿងរ៉ាវច្រើនជាងគេនៅក្នុងភូមិស្រុក។
- **ខ្លោញស្រុក** និង **ខ្លោញវិស័យ៖** អ្នកទាំងពីរនេះ អាចប្រៀបប្រដូចចៅហ្វាយ ស្រុក និងចៅហ្វាយខេត្តសព្វថ្ងៃ។

៥.៣.៤. ដំណើរការកាត់ក្តី (*គតិវ្យវហារ*)

នៅក្នុងដំណើរកាត់ក្តីតាមប្រព័ន្ធតុលាការសម័យបុរាណ ចាប់ផ្តើមដំបូងដោយ **វាទ** (ប្តឹង) > **ឧត្តរ** (ព្រះសភាឆ្លើយតប) > **ក្រឹត្យាបាទ** (ដំណើរកាត់ក្តី) > **និណ៌ាយ** (វិនិច្ឆ័យទោស) > **សភានិណ៌ាយ** (សភាចេញសាលក្រម)។ បើមានការមិនយល់ព្រម *«បដិសេធ»* ត្រូវប្តឹងបន្តពីព្រះសភាស្រុក ទៅព្រះសភាវិស័យ ហើយអាចឡើងដល់ព្រះ សភានគរ។

៥.៣.៥. អំពីទោស

«និណ្ណាយ» ឬ *«និណ៌ាយ»* ជាពាក្យប្រើសំដៅដល់ការដាក់ទោស ការកាត់ទោស ឬ ចេញសាលក្រម។ តាមទិន្នន័យសិលាចារឹកគេឃើញមានទោស ៤កម្រិត ដែលតាមទ្រឹស្តី មកពីឥណ្ឌា ត្រូវមាន៥កម្រិត។ ទោសទាំងនោះពាក់ព័ន្ធនឹងទោសតាមច្បាប់លោក និង ច្បាប់សាសនា។ មានទោស ៣ មានចែងក្នុងច្បាប់មនុរបស់ឥណ្ឌា គឺ ឧបបាតក បាតក និង មហាបាតក។

- **កណ្តាក ៖** ទោសកំហុសស្រាលៗជាងគេ ដែលប្រហែលគ្រាន់តែ ត្រូវទទួល ការព្រមាន ឬពិន័យជាទ្រព្យក្នុងចំនួនតិចតួច។
- **ឧបបាតក ៖** ទោសស្រាល សម្រាប់បទល្មើសប្រមាថកាតទានគ្រូបាអាចារ្យ ប្រមាថស្ត្រី មិនគោរពបូជាសាសនា មិនគោរពពាក្យសន្យា កុហកបោក ប្រាស មើលងាយបន្ទោកប្រពន្ធកូនខ្លួន លួចមាសប្រាក់ស្រូវអង្ករនិងទ្រព្យ អ្នកដទៃ មិនសងបំណុលគេជាដើម។

- **បាតក ៖** ទោសមធ្យម មិនមានចែងច្បាស់លាស់អំពីបទចោទដែលត្រូវទទួលទោសនេះ។
- **មហាបាតក ៖** ជាទោសធ្ងន់ជាងគេ សម្រាប់បទល្មើសលួចប្លន់ កាប់សម្លាប់សហាយស្មន់អន្ទកជាមួយភរិយាម្ចាស់ឯងជាដើម។
- **ឧត្តមសាហ ៖** ទោសប្រព្រឹត្តកន្លងព្រះរាជបញ្ញត្តិ ឬព្រះរាជអាជ្ញា ជាទោសធ្ងន់ក្នុងឥហលោក និងត្រូវធ្លាក់នរកអាប៉ពាន់ជាតិក្នុងបរលោក។

៥.៣.៦. ការពិន័យ និងទណ្ឌកម្ម

ការពិន័យ និង **ទណ្ឌកម្ម** ទាំងក្នុងផ្លូវច្បាប់ក្តី ទាំងក្នុងផ្លូវជំនឿសាសនាក្តី មានគោលបំណងសំខាន់ គឺដើម្បីស្តារនូវសណ្តាប់ ច្បាប់ ទំនៀមទម្លាប់ ដែលខូចខាតដោយសារការបំពានផ្សេងៗ (ស៊ីយ៉ុន, ២០២៤)។ ចំពោះរឿងពិន័យនិងទណ្ឌកម្មនេះមានព័ត៌មានតិចតួចបំផុតតាមរយៈសិលាចារឹក ដ្បិតរឿងនេះហាក់ជារឿងដែលគេដឹងឮជាទូទៅនាសម័យនោះរួចហើយ ឬមានចែងច្បាស់លាស់នៅក្នុងច្បាប់សម្រាប់អនុវត្តរួចទៅហើយ។ តាមរយៈសិលាចារឹកលលៃ បង្ហាញថាការពិន័យត្រូវគិតជា ***«បលមាស»*** (១បលមាសស្មើ ២,៤៨៨តម្លឹង)។ តាមការស្រាវជ្រាវមួយចំនួនទៀតបង្ហាញថា ការពិន័យនៅសម័យអង្គរត្រូវបង់ដោយសត្វពាហនៈ សម្លៀកបំពាក់ ឬក្រណាត់ផ្សេងៗ ស្រូវ អង្គរ មាស ប្រាក់ ភ្លុក ដំរីឈើ និងគ្រឿងទេសនានា។

ទោសស្រាលអាចទទួលទណ្ឌកម្មត្រឹមទះកំផ្លៀង ឬវាយនឹងរំពាត់។ ចំណែកទណ្ឌកម្មចំពោះទោសធ្ងន់ជាងនេះបន្តិច គឺយកទៅដាក់ទ្រុង (ខ.ច. ចាបិបញ្ជរ = ចាប់ដាក់ទ្រុង)។ ខ្មែរសម័យបុរាណប្រហែលមិនទាន់មានគុកទេ ព្រោះមិនមានភស្តុតាងក្នុងសិលាចារឹកនិងចម្លាក់ ប៉ុន្តែតាមលោក ជីវ តាក្វាន់ ថាមានបន្ទប់ងងឹតសម្រាប់ឃុំឃាំង។

ទណ្ឌកម្មដែលទុកថាធ្ងន់ធ្ងរ គឺការកាត់ ឬឆូតមាត់ ដៃជើង គាបក្បាលជាដើម។ លោក ជីវ តាក្វាន់ និយាយថា អ្នកមានទោសធ្ងន់គេមិនចាប់ចងយកទៅប្រហារជីវិតទេ គេគ្រាន់តែនាំចេញទៅតាមទ្វារខាងលិចក្រុង ហើយឱ្យជីករណ្តៅកប់អ្នកទោសនោះនិងយកដុំថ្មកប់គ្របពីលើ។

គួរសម្គាល់ថាព្រះញាតិវង្ស មន្ត្រី អ្នកជំនួញ បុព្វជិត ដែលមានឋានៈក្នុងសង្គមកាន់តែខ្ពស់ បើមានទោសនឹងទទួលធ្ងន់ជាងរាស្ត្រប្រជាធម្មតា។

រូប ៦. ចម្លាក់មនុស្សជាប់ទ្រុង មកពីប្រាសាទបន្ទាយឆ្មារ ចុងស.វ.ទី១២និងដើមស.វ.ទី១៣



ប្រភព៖ ចាន់ អឿន, ២០២៥

៥.៤. ទិដ្ឋភាពប្រើប្រាស់ច្បាប់ក្នុងការងារយុត្តិធម៌

ប្រព័ន្ធតុលាការខ្មែរបុរាណ គឺមិនមានក្រមច្បាប់តែមួយដែលត្រូវបានចងក្រងដូចសម័យទំនើបនោះទេ។ ផ្ទុយទៅវិញ វាជាប្រព័ន្ធមួយដែលត្រូវបានអនុវត្តដោយផ្អែកលើការរួមបញ្ចូលគ្នានៃគោលការណ៍ច្បាប់សំខាន់ៗជាច្រើន។ ប្រព័ន្ធតុលាការខ្មែរបុរាណគឺជាការរួមបញ្ចូលគ្នា នៃគោលការណ៍គ្រឹះពីឥណ្ឌា អំណាចព្រះមហាក្សត្រ និង ទំនៀមទម្លាប់ក្នុងស្រុក ដើម្បីបង្កើតប្រព័ន្ធច្បាប់មួយដ៏ស្មុគស្មាញ និងមានប្រសិទ្ធភាពសម្រាប់រក្សាសណ្តាប់ធ្នាប់នគរ។

៥.៤.១. គោលការណ៍គ្រឹះពីឥណ្ឌា

ច្បាប់ខ្មែរបុរាណ បានឥទ្ធិពលយ៉ាងខ្លាំងពីគំនិតច្បាប់របស់ឥណ្ឌា តាមរយៈសាសនាព្រាហ្មណ៍។ គោលការណ៍សំខាន់ៗដែលបានយកមកប្រើគឺ៖

- **ច្បាប់មនុ ឬ មនុស្សតិ៖** មិនមែនជាក្រមច្បាប់ដែលតម្រូវឱ្យអនុវត្តតាមត្រង់ៗនោះទេ ប៉ុន្តែវាត្រូវបានចាត់ទុកជា មូលដ្ឋានគ្រឹះខាងច្បាប់ និងសីលធម៌

ដែលបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើការបង្កើតប្រព័ន្ធច្បាប់នៅក្នុងតំបន់អាស៊ីអាគ្នេយ៍ រួមទាំងប្រទេសកម្ពុជា។

- **ធម្មសាស្ត្រ៖** នេះជាមូលដ្ឋានគ្រឹះនៃច្បាប់ដែលផ្តោតលើសីលធម៌ គុណធម៌ និងកាតព្វកិច្ចសង្គមរបស់មនុស្សម្នាក់ៗ។
- **ទណ្ឌនីតិ៖** នេះជាគោលការណ៍នៃការប្រើប្រាស់អំណាច និងការដាក់ទណ្ឌកម្មរបស់ស្តេច ដើម្បីរក្សាសណ្តាប់ធ្នាប់ និងយុត្តិធម៌។

៥.៤.២. ច្បាប់ផ្អែកលើអំណាចព្រះមហាក្សត្រ

ព្រះមហាក្សត្រខ្មែរគឺជាប្រភពច្បាប់ដ៏ខ្ពស់បំផុត និងជាអ្នកអនុវត្តចុងក្រោយ។ ព្រះរាជក្រឹត្យ (បញ្ញត្តិរបស់ស្តេច) ដែលត្រូវបានកត់ត្រានៅលើសិលាចារឹក ក៏ជាទម្រង់នៃច្បាប់ផងដែរ។ ព្រះរាជក្រឹត្យទាំងនេះអាចពាក់ព័ន្ធនឹងបញ្ហាផ្សេងៗដូចជា៖

- ការគ្រប់គ្រងដីធ្លី និងការបែងចែកធនធាន។
- ការដាក់ទណ្ឌកម្មលើបទល្មើសជាក់លាក់។
- ការលើកលែងពន្ធ និងការតាំងសិទ្ធិពិសេស។

៥.៤.៣. ការអនុវត្តតាមទំនៀមទម្លាប់

ក្រៅពីច្បាប់ជាលាយលក្ខណ៍អក្សរដែលបានមកពីគំនិតឥណ្ឌា និងព្រះរាជក្រឹត្យ តុលាការខ្មែរបុរាណក៏បានប្រើប្រាស់ ទំនៀមទម្លាប់ប្រពៃណី ដែលមានតាំងពីយូរលង់មកហើយ ដើម្បីដោះស្រាយវិវាទតូចតាច ជាពិសេសនៅតាមសហគមន៍មូលដ្ឋាន។ នេះបង្ហាញថា ប្រព័ន្ធច្បាប់មិនត្រឹមតែពឹងផ្អែកលើគោលការណ៍ធំៗប៉ុណ្ណោះទេ ប៉ុន្តែក៏បានរួមបញ្ចូលទាំងប្រាជ្ញាប្រចាំថ្ងៃរបស់សង្គមផងដែរ។

៥.៤.៤. ភស្តុតាងពីសិលាចារឹក

សិលាចារឹកដែលបានរកឃើញតាមប្រាសាទជាច្រើន បានផ្តល់កស្តុតាងដ៏រឹងមាំអំពីការអនុវត្តច្បាប់ទាំងនេះ។ ឧទាហរណ៍ សិលាចារឹកបានរៀបរាប់អំពីការកាត់ក្តី និងការដាក់ទោសចំពោះបទល្មើសផ្សេងៗ។ លើសពីនេះ ការប្រើប្រាស់ ការកាត់សេចក្តីដោយការតាមទំនៀមទម្លាប់ដូចជាការដើរលើភ្លើង ឬការចាប់ដៃកន្តៅ គឺជាការអនុវត្តដែលបានមកពីឥទ្ធិពលច្បាប់ឥណ្ឌា។

ទោះបីជាអ្នកគ្រប់គ្រងខ្មែរមិនបានចម្លងច្បាប់ឥណ្ឌាមកប្រើទាំងស្រុងក៏ដោយ ក៏រាជការខ្មែរបានស្រូបយកគោលការណ៍សំខាន់ៗ និងបានបញ្ចូលទៅក្នុងប្រព័ន្ធច្បាប់ និង

នយោបាយរបស់ខ្លួន។ នៅសម័យអង្គរ ព្រះមហាក្សត្រខ្មែរបានទទួលឋានៈជា ***«ទេវរាជ»*** ហើយមានតួនាទីថែរក្សា ***«ធម៌»*** ក្នុងនគរ។ ភារកិច្ចនេះគឺស្របទៅនឹងគំនិត ទណ្ឌនីតិ ដែលចែងថា ព្រះរាជាត្រូវប្រើអំណាចរបស់ខ្លួនដើម្បីរក្សាសណ្តាប់ធ្នាប់ និងយុត្តិធម៌។ សិលាចារឹកខ្មែរជាច្រើនបានបង្ហាញពីកស្តុតាងនៃការអនុវត្តច្បាប់ទាំងនេះ។ ឧទាហរណ៍ សិលាចារឹកខ្លះបានរៀបរាប់អំពីការដាក់ទណ្ឌកម្មលើអ្នកដែលរំលោភបំពានលើដីធ្លី សាសនា ឬទ្រព្យសម្បត្តិព្រះមហាក្សត្រ ដែលបង្ហាញពីការអនុវត្តច្បាប់ដាក់ទោសដូចមានចែងក្នុង ធម្មសាស្ត្រ។

ការអនុវត្តការកាត់សេចក្តីខ្លះបានប្រើប្រាស់វិធីតាមជំនឿ សាសនា ដូចជាតម្រូវឱ្យជនសង្ស័យការដើរលើភ្លើងឆ្សួង ឬការដាក់ដៃក្នុងទឹកក្តៅ គឺជារបៀបមួយនៃការអនុវត្តច្បាប់ដែលផ្អែកលើ ***«គំនិតសច្ចៈ»*** និង ***«វិសោធន»*** (សំ. វិគោធន = ការបន្សុទ្ធ) ដូចគ្នានឹងទំនៀមស្រុកឥណ្ឌាដែរ។ គំនិតពីគម្ពីរវេទ និងបុរាណ បានជ្រាបចូលទៅក្នុងសង្គមខ្មែរតាមរយៈរឿងនិទាន ពិធីសាសនា និងសិល្បៈ។ នេះបានជួយពង្រឹងគោលការណ៍សីលធម៌ និងសង្គម ដែលគាំទ្រដល់ប្រព័ន្ធច្បាប់ផងដែរ។

៥.៤.៥. គម្ពីរព្រះធម្មសាស្ត្រ

«ធម្មសាស្ត្រ» គឺជាគម្ពីរស្តីពីច្បាប់ក្នុងព្រហ្មញ្ញសាសនា។ គម្ពីរនេះ ខ្មែរទទួលយកមកសិក្សា និងប្រើប្រាស់នៅក្នុងសង្គមខ្មែរ ដោយលើកជាគម្ពីរសេក្ការៈ ដោយហៅជា ***«ព្រះធម៌សាស្ត្រ»*** (ខ.ច. ព្រះធម្មគាស្ត្រ) សម័យកណ្តាលហៅជា ***«ក្រមព្រះធម្មសាស្ត្រ»*** (ខ.ក. ក្រំមព្រះធម្មសាត្រ) ដែលស្តែងពីការគោរពនិងលើកតម្កើងគម្ពីរនេះ។

គម្ពីរព្រះធម្មសាស្ត្រ មានសារៈសំខាន់ខ្លាំងណាស់ នៅក្នុងការអនុវត្តច្បាប់និងការគ្រប់គ្រងប្រទេសកម្ពុជានាសម័យបុរាណ។ គម្ពីរនេះ ប្រដូចជាក្បាលរបស់មនុស្សយ៉ាងដូច្នោះ។ ប្រសិនបើមនុស្សពុំមានក្បាល គឺពុំអាចនឹងរស់រានមានជីវិត គឺដូចជារដ្ឋមួយបើគ្មានច្បាប់ ក៏នឹងពុំអាចដំណើរការទៅមុខបានដែរ។ យោងតាមសិលាចារឹកប្រាសាទព្រះខ័នកំពង់ស្វាយ K.១៦១ ព្រះបាទស្រីសូរ្យវរ្ម៌ទី១(សូរ្យវរ្ម៌នទី១) បានប្រដូចគម្ពីរសំខាន់ៗក្នុងព្រហ្មញ្ញសាសនាទៅនឹងសរីរាង្គរបស់មនុស្ស។ ព្រះអង្គប្រដូច គម្ពីរភោស្យដូចនឹងជើង គម្ពីរកាព្យដូចនឹងដៃ ទស័នទាំង៦ដូចនឹងឥន្ទ្រិយគឺរូបកាយ រីឯគម្ពីរធម្មសាស្ត្រជាដើមដូចនឹងក្បាល (Finot, ១៩០៤)។

រូប ៧. សម្រង់សិលាចារឹក ប្រាសាទព្រះខ័នកំពង់ស្វាយ K.១៦១



រូបភាព៖ វិទ្យាស្ថានសាលាបារាំងចុងបូព៌ា (EFEO)

ព្រះរាជា ដែលជាអ្នកដឹកនាំកំពូលរបស់ប្រទេស ក៏ត្រូវសិក្សានិងមានចំណេះខាងវិជ្ជាផ្សេងៗ ដែលក្នុងនោះក៏មានសិក្សាអំពីគម្ពីរធម្មសាស្ត្រនេះជាចាំបាច់ដែរ។ នៅក្នុងសិលាចារឹកប្រាសាទស្តុកកក់ធំ K.២៣៥ (ស.វ.ទី១១) បានបង្ហាញថាព្រះបាទស្រីឧទយាទិត្យវរ្ម័ទេវទី២ (ឧទយាទិត្យវរ្ម័នទី២) បានរៀនវិជ្ជា និងគម្ពីរនានាដែលក្នុងនោះមានគម្ពីរធម្មសាស្ត្រ ពីព្រះគ្រូទ្រង់គឺធូលីជើងព្រះគម្តែងអញស្រីជយេន្ទ្រវរ្ម័។ ព្រាហ្មណ៍ ជាមនុស្សសំខាន់ក្នុងការសិក្សា បណ្តុះបណ្តាល ផ្សព្វផ្សាយ និងអនុវត្តនូវក្បួនច្បាប់ក្នុងគម្ពីរព្រះធម្ម៌សាស្ត្រនេះ តាំងពីសម័យមុនអង្គររហូតមកដល់សម័យកណ្តាល។

ផ្អែកតាមព័ត៌មានក្នុងសិលាចារឹកអង្គជំនីក K.៥៣ (គ.ស. ៦៦៧) នៅខេត្តព្រៃវែង បង្ហាញថា មន្ត្រី២នាក់របស់ព្រះបាទស្រីភវវរ្ម័ទី១ (ភវវរ្ម័នទី១) មានជំនាញខាងធម្ម៌សាស្ត្រ និងអាថ៌សាស្ត្រ (Barth, 1885, pp. 64–72)។ ពួកព្រាហ្មណ៍ និងមន្ត្រី ដែលមានចំណេះដឹងខាងផ្នែកធម្ម៌សាស្ត្រ ដើរតួនាទីសំខាន់ក្នុងការអនុវត្តច្បាប់ក្នុងគម្ពីរព្រះធម្ម៌សាស្ត្រ។ មានតួនាទីម្យ៉ាងហៅថា «ស្មូត្រព្រះធម្ម៌សាស្ត្រ» គឺជាអ្នកដែលមានចំណេះជ្រៅជ្រះខាងព្រះធម្ម៌សាស្ត្រ និងជាអ្នកផ្ទៀងផ្ទាត់ដំណើររឿងនានាលុះតាមគម្ពីរនេះ។ ***«ស្មូត្រព្រះធម្ម៌សាស្ត្រ»*** ជាមនុស្សមានតួនាទីនៅក្នុងដំណើរកាត់ក្តី វាស់វែងនិងបោះបង្គោលព្រំដីជាដើម។ សិលាចារឹកក្រឡាញ់ធំ K.៦៧ (ស.វ. ១០-១១) នៅខេត្តព្រៃវែង បង្ហាញពីព្រះគម្តែងអញរុទ្រោជាអ្នកសូត្រព្រះធម្ម៌សាស្ត្រថ្នាក់ទី២ (Cœdès, 1964, pp. 23–25)។ សិលាចារឹកប្រាសាទត្រពាំងរុន K.៥៩៨ (គ.ស. ១០៨៥/១០៨៥) ម្រតាញខ្លោញស្រីរាជសំកល្បជាអ្នកសូត្រព្រះធម្ម៌សាស្ត្រ (Finot, 1928, pp. 58–80; Pou, 2001, pp. 230–239)។

ចំណែកឯសិលាចារឹកប្រាសាទបាសែត K.២០៧ (គ.ស.១០៤៣) នៅខេត្តបាត់ដំបង បានបង្ហាញពីព្រះគម្តែងអញវិទ្យាស្រមជាអ្នកសូត្រព្រះធម្ម៌សាស្ត្រ មានតួនាទីសំខាន់ក្នុងក្រុមមនុស្សចុះទៅវាស់វែង និងសង់គោលដីទាំងប្រាំបីទិស ដែលគេបានទិញថ្វាយ

ចំពោះប្រាសាទបាសែត (Cœdès, 1951, pp. 16–24)។ នៅក្នុងសិលាចារឹកប្រាសាទគោកពោធិ៍ K.៨១៤ (គ.ស.១០០៤) បានបង្ហាញពីមន្ត្រីពីរបេគឺ ម្រតាញស្រីប្រឹថិវិន្ទ្រោបកល្ប និងម្រតាញស្រីរាជោបកល្ប គឺជាអ្នកសូត្រព្រះធម្មសាស្ត្រ ដែលស្ថិតនៅក្នុងក្រុមមនុស្សចូលរួមក្នុងដំនុំនៃដំណើរទិញដីរបស់ខ្លោញពលត្រពាំងព្រាហ្មណ៍ (Cœdès & Dupont, 1937)។ សិលាចារឹកកំពែងណៃ K.៣៧៤ (គ.ស.១០៤២/១០៤៣) បង្ហាញពីព្រះគម្ពែងអញសិខរេ ជាអ្នកសូត្រព្រះធម្មសាស្ត្រ បានចូលរួមនៅក្នុងការជាវដី សង់គោលដី (Cœdès, 1954, pp. 251–253)។ សិលាចារឹកត្រពាំងដូនមាស K.៨៤៣ (គ.ស.១០២៥) ព្រះមហាក្សត្របានត្រាស់បង្គាប់ប្រើមន្ត្រីទាំងឡាយ ក្នុងនោះមានម្រតាញខ្លោញស្រីវិជយេន្ទ្របណ្ឌិតជាអ្នកសូត្រព្រះធម្មសាស្ត្រនៅឯឥសូរបុរ(ប្រាសាទបន្ទាយស្រី) ឱ្យចូលរួមក្នុងដំណើរចុះសង់គោលដីប្រគល់ឱ្យស្តែងអញស្តុកចិញ្ចាញជាព្រះរាជប្រទាន (Cœdès, 1964, pp. 109–119)។

នៅក្នុងសិលាចារឹកបន្ទាយស្រី K.៥៦៩-២ (គ.ស. ១៣០៦) បានបង្ហាញអំពីតួនាទីរបស់គម្ពីរធម្មសាស្ត្រនៅក្នុងការដោះស្រាយបញ្ហា។ ដំណើររឿងនៅក្នុងសិលាចារឹកនេះកើតមានតាំងពីរាជ្យព្រះបាទស្រីជ័យវម្ម៌ទី៧ (ជ័យវរ្ម័នទី៧) មកម្ល៉េះ។ មានមន្ត្រីម្នាក់ជាខ្លោញពល ឈ្មោះ ត្រីបដាក ដែលជាឈ្មួញនៅព្រះឃ្លាំងធំ (ខ.ច. ឡាងរុង) បានក្រាបបង្គំទូលថ្វាយព្រះរាជាស្នើដកទង់ដែងនៅព្រះឃ្លាំងយកទៅទិញអុស ប៉ុន្តែវណ្ណៈអ្នកបម្រើនៅប្រាសាទបានកាត់អុសផ្តល់ជូន ដោយពុំបានដកទង់ដែងពីព្រះឃ្លាំងរុងឡើយ។

លុះមកដល់រាជ្យព្រះបាទស្រីន្ទ្រវម្ម៌ទៅ (ស្រីន្ទ្រវរ្ម័ន គ.ស.១២៩៥-១៣០៧) ទើបពិនិត្យសើរើរឿងក្តីនេះ ដោយមានព្រះគម្ពែងអញស្រីរាជេន្ទ្របណ្ឌិតជាសភាបតី (ប្រធានតុលាការ) ព្រះគម្ពែងអញគុណទោស(អ្នកវិនិច្ឆ័យគុណទោស) និងភូតាស(រាជលេខាធិការ) ទាំង៤ គម្ពែងអញបណ្ឌិត ព្រឹទ្ធាចារ្យផង មូលមតិគ្នាជាឯកច្ឆន្ទបង្គាប់ឱ្យធ្វើតាមព្រះធម្មសាស្ត្រ។ នៅខាងចុងអត្ថបទសិលាចារឹកបានបញ្ជាក់ថា ព្រះបាទស្រីន្ទ្រវម្ម៌ទៅ និងព្រះអគ្គមហេសី ជាអ្នកការពារអាណាប្រជានុរាស្ត្រ និងជាអ្នកគាំពារនូវអំពើបុណ្យទាំងឡាយតាមឆន្ទៈនៃព្រះធម្មសាស្ត្រ (វង់, ២០២១, pp. ៣៨៤-៣៨៥; Pou, 2001b, pp. 166–171)។

៥.៤.៦. ច្បាប់សម្រាប់បព្វជិត

៥.៤.៦.១. គម្ពីរព្រះធម្មសាស្ត្រ (អនុវត្តចំពោះបព្វជិតសាសនា)

នៅសម័យបុរាណ ច្បាប់ដែលប្រើដើម្បីដោះស្រាយបទល្មើសរបស់ពួកបុព្វជិតសាសនាព្រហ្មញ្ញ (ព្រាហ្មណ៍) មានលក្ខណៈពិសេស និងខុសពីជនទូទៅ។ ការអនុវត្ត

នេះ គឺផ្អែកលើគម្ពីរព្រះធម្មសាស្ត្រ ដែលជាក្រមច្បាប់ និងក្រមសីលធម៌ដ៏សំខាន់របស់ឥណ្ឌាបុរាណ។

ច្បាប់បុរាណបានបង្ហាញថា ទោះបីជាព្រាហ្មណ៍មានអំណាច និងឋានៈខ្ពស់ក៏ដោយ ពួកគេនៅតែមិនរួចផុតពីការដាក់ទោសឡើយ។ ប៉ុន្តែការដាក់ទោសនោះ គឺផ្តោតលើការដកហូតកិត្តិយស និងឋានៈសង្គម ជាជាងការធ្វើទារុណកម្មផ្នែករាងកាយ ស្របតាមទស្សនៈដែលចែងក្នុងគម្ពីរព្រះធម្មសាស្ត្រ។ ខាងក្រោមនេះជាគោលការណ៍ច្បាប់សំខាន់ៗ ចំពោះព្រាហ្មណ៍។ នៅក្នុងប្រព័ន្ធវណ្ណៈ ពួកព្រាហ្មណ៍ត្រូវបានចាត់ទុកថាជាវណ្ណៈខ្ពស់បំផុត និងមានឋានៈដ៏ពិសិដ្ឋ។ ដូច្នេះ គម្ពីរធម្មសាស្ត្រ បានចែងថា ព្រះរាជាមិនត្រូវដាក់ទោសរាងកាយ ឬទោសប្រហារជីវិតលើពួកគេឡើយ ទោះបីជាពួកគេបានប្រព្រឹត្តបទឧក្រិដ្ឋធ្ងន់ធ្ងរក៏ដោយ។ ហេតុផលគឺដោយសារតែខ្លួនប្រាណរបស់ព្រាហ្មណ៍ត្រូវបានចាត់ទុកថាពិសិដ្ឋ និងមិនអាចរំលោភបំពានបាន។ ជំនួសឱ្យការដាក់ទោសរាងកាយ ពួកគេនឹងត្រូវទទួលទណ្ឌកម្មផ្លូវចិត្ត និងសង្គម ដែលត្រូវបានចាត់ទុកថាជាការដាក់ទោសដ៏ធ្ងន់ធ្ងរជាង។ ទម្រង់ទណ្ឌកម្មទាំងនោះមានដូចជា៖

- **ការនិរទេស៖** នេះគឺជាទោសមួយដ៏ធ្ងន់បំផុតសម្រាប់ព្រាហ្មណ៍។ ការនិរទេសចេញពីនគរ គឺស្មើនឹងការបាត់បង់ឋានៈ សិទ្ធិ និងទំនាក់ទំនងសង្គមទាំងអស់របស់ពួកគេ។
- **ការបាត់បង់សិទ្ធិ៖** ពួកព្រាហ្មណ៍មានទោសត្រូវបានហាមឃាត់មិនឱ្យធ្វើពិធីសាសនា ឬកាតព្វកិច្ចបូជាផ្សេងៗរបស់ពួកគេ។
- **ការបាត់បង់កិត្តិយស៖** ពួកព្រាហ្មណ៍អាចនឹងត្រូវដកហូតទ្រព្យសម្បត្តិ ឬរងការអាម៉ាស់ជាសាធារណៈ ដូចជាការកោរសក់ (ដែលជាការបំបាត់និមិត្តសញ្ញានៃភាពបរិសុទ្ធរបស់ពួកគេ)។
- **ការពិន័យ៖** ក្នុងករណីខ្លះ ពួកព្រាហ្មណ៍អាចនឹងត្រូវបង់ប្រាក់ពិន័យខ្ពស់ជាងវណ្ណៈដទៃទៀតសម្រាប់កំហុសដូចគ្នា។

៥.៤.៦.២. គម្ពីរវេទ

គេមិនបានយកមកប្រើប្រាស់ដោយផ្ទាល់ជាក្រមច្បាប់ ដើម្បីដោះស្រាយរឿងក្តីនោះទេ ប៉ុន្តែគម្ពីរនេះគឺជា **មូលដ្ឋានគ្រឹះ** និងជាប្រភពនៃគំនិតទាំងអស់។ គម្ពីរវេទ គឺជាបណ្តុំនៃគម្ពីរបុរាណបំផុត និងដ៏ពិសិដ្ឋបំផុតនៃសាសនាព្រាហ្មណ៍-ហិណ្ឌូ។ ខ្លឹមសាររបស់វាភាគច្រើនផ្តោតលើចម្រៀងសរសើរអាទិទេព ពិធីសាសនា ព្រមទាំងទស្សនវិជ្ជា

សាសនា។ វេទជាគោលការណ៍ណែនាំខាងសីលធម៌ និងជំនឿប៉ុណ្ណោះ មិនមែនជាបញ្ជីនៃបទល្មើស ឬទោសទណ្ឌជាក់លាក់ដូចទៅនឹងច្បាប់នោះទេ។

៥.៤.៦.៣. គម្ពីរបុរាណ

មិនមែនជាក្រមច្បាប់ដើម្បីកាត់ក្តីនោះទេ ប៉ុន្តែវាមានតួនាទីសំខាន់ខ្លាំងណាស់ក្នុងការអនុវត្តគោលការណ៍ **ធម៌** ទៅក្នុងសង្គម។ គម្ពីរ **បុរាណ** គឺជាឧបករណ៍ដ៏មានប្រសិទ្ធភាពសម្រាប់ **ការអប់រំសីលធម៌** ដល់ប្រជាជនទូទៅ។ វាបានធ្វើឱ្យគំនិតដ៏ស្មុគស្មាញនៃគម្ពីរធម្មសាស្ត្រក្លាយទៅជាងាយស្រួលយល់តាមរយៈការនិទានរឿង។

ការបង្រៀនអំពីធម៌៖ ជំនួសឱ្យការចែងអំពីច្បាប់ត្រង់ៗ គម្ពីរ **បុរាណ** បានបង្ហាញពីគំនិតនៃ **ធម៌** តាមរយៈរឿងរ៉ាវ។ ឧទាហរណ៍ វាបានរៀបរាប់អំពីស្តេចដែលប្រព្រឹត្តអំពើល្អ ហើយទទួលបានលទ្ធផលល្អ ឬស្តេចដែលប្រព្រឹត្តអំពើអាក្រក់ ហើយត្រូវទទួលកម្មផល។

ការលើកតម្កើងយុត្តិធម៌៖ រឿងនិទានទាំងនោះបានបង្ហាញថា **ទណ្ឌនីតិ** របស់ព្រះមហាក្សត្រ គឺចាំបាច់ដើម្បីរក្សាសណ្តាប់ធ្នាប់ និងថែរក្សា **ធម៌** នៅក្នុងនគរ។ ប្រជាជនបានយល់ពីសារៈសំខាន់នៃច្បាប់តាមរយៈការរៀនសូត្រពីវីរបុរស និងស្តេចក្នុងរឿងព្រេង។

នៅក្នុងបរិបទប្រទេសកម្ពុជាបុរាណ ព្រះរាជាខ្មែរក៏បានទទួលយកនូវរឿងនិទានពីគម្ពីរ **បុរាណ** នេះផងដែរ។ កស្តុតាងចំណាស់ជាងគេ បង្ហាញវត្តមានគម្ពីរនេះ រួមនឹងគម្ពីររាមាយណៈ និងមហាភារត នៅក្នុងសិលាចារឹកវាលកន្ទួល K.៣៥៩។ ចម្លាក់នៅតាមជញ្ជាំងប្រាសាទអង្គរវត្ត ដែលពណ៌នាពីរឿងរាមាយណៈ និងមហាភារតៈ ក៏ជាឧទាហរណ៍ដ៏ល្អមួយ។ រឿងទាំងនេះមិនមែនជាច្បាប់ទេ ប៉ុន្តែវាបានជួយពង្រឹងកម្លាំងចិត្ត និងតម្លៃសីលធម៌ ដែលគាំទ្រដល់ប្រព័ន្ធច្បាប់ និងការគ្រប់គ្រងរបស់ស្តេច។ ដូច្នេះ គម្ពីរ **បុរាណ** មិនត្រូវបានអនុវត្តជាផ្លូវការដូចក្រមច្បាប់ទេ ប៉ុន្តែវាបានដើរតួនាទីយ៉ាងសំខាន់ជាឧបករណ៍វប្បធម៌ និងសីលធម៌ ដែលបានជួយបង្រៀន និងពង្រឹងគំនិតនៃយុត្តិធម៌ដល់មនុស្សគ្រប់រូប។

៥.៤.៧. ច្បាប់សម្រាប់ជនស៊ីវិល និងកងទ័ព

ធម្មសាស្ត្រ និង ច្បាប់មនុ (មនុស្មៃតិ) បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងប្រព័ន្ធច្បាប់នៃចក្រភពខ្មែរ និងជា***មូលដ្ឋានគ្រឹះនៃទស្សនវិជ្ជានីតិវជ្ជ***។ ព្រះមហាក្សត្រប្រើប្រាស់គោលការណ៍ទាំងនេះ (រួមជាមួយនឹង រាជប្រវេណី និង ជំនឿប្រពៃណីខ្មែរ) ដើម្បីបង្កើតជាប្រព័ន្ធយុត្តិធម៌មួយ ដែលបានទទួលស្គាល់ដោយសាសនា និងរាជការ។ ធម្មសាស្ត្រ

បានរួមបញ្ចូលគ្នារវាងគោលការណ៍ខាងសាសនា សីលធម៌ និងនីតិរដ្ឋ ដែលផ្តល់ជាក្របខ័ណ្ឌច្បាប់ទាំងមូលសម្រាប់គ្រប់គ្រងសង្គម ចាប់ពីការរស់នៅផ្ទាល់ខ្លួន រហូតដល់ការកាត់ក្តីនៅក្នុងតុលាការ។

៥.៤.៨. អំពីធម្មសាស្ត្រ

ធម្មសាស្ត្រមិនមែនជាក្រមច្បាប់តែមួយគត់ទេ ប៉ុន្តែជាបណ្តុំនៃអត្ថបទ ដូចជាគម្ពីរស្មឹតិ (ស្មូតិ) ដែលពន្យល់អំពី ធម៌ (Dharma) ពោលគឺ ច្បាប់ សីលធម៌ និងការកិច្ចរបស់មនុស្សក្នុងសង្គម។ ធម្មសាស្ត្រ ជាទូទៅមានគោលការណ៍ច្បាប់សំខាន់ៗចំនួនបីផ្សេងគ្នា៖

ក. ក្រមសីលធម៌ និងការប្រព្រឹត្តប្រចាំថ្ងៃ៖ បញ្ជាក់អំពីកាតព្វកិច្ចរបស់មនុស្សម្នាក់ៗទៅតាមឋានៈសង្គម (វណ្ណៈ) និង វ័យ(ដំណាក់កាលនៃជីវិត ដូចជាសិក្សា គ្រប់គ្រងគ្រួសារ និងបួស)។ ច្បាប់អាពាហ៍ពិពាហ៍ និយាយអំពីរបៀបរៀបអាពាហ៍ពិពាហ៍ សិទ្ធិ និងកាតព្វកិច្ចរបស់ប្តីនិងប្រពន្ធ។ បទបញ្ញត្តិស្តីពីការរក្សាអនាម័យខ្លួនប្រាណ និងបរិស្ថាន (ពិធីជម្រះបាប) និងរបៀបប្រតិបត្តិ និងធ្វើបុណ្យផ្សេងៗដើម្បីរក្សាសណ្តាប់ធ្នាប់សង្គម និងសាសនា។

ខ. ច្បាប់ និងនីតិវិធីតុលាការ៖ ផ្តោតលើ ទំនាក់ទំនងរវាងមនុស្ស និងការដោះស្រាយវិវាទផ្លូវច្បាប់។ នេះគឺជាផ្នែកដែលពាក់ព័ន្ធនឹងតុលាការផ្ទាល់ ដែលមាននិយាយអំពីមូលដ្ឋានបណ្តឹង ការកំណត់អំពីមូលហេតុទាំង១៨ សម្រាប់ការប្តឹងផ្តល់ (ដូចជាជម្លោះកម្មសិទ្ធិដីធ្លី ការជំពាក់បំណុល ការបោកប្រាស់ ការលួច ការរំលោភលើកិច្ចសន្យា ការសហាយស្មន់ និងបទល្មើសព្រហ្មទណ្ឌផ្សេងៗទៀត)។ របៀបនៃការជំនុំជម្រះក្តី កស្តុតាងដែលត្រូវប្រើប្រាស់ (ដូចជាសាក្សី ឯកសារ ស្បថ ឬការធ្វើទារុណកម្មដើម្បីស៊ើបអង្កេត)។ របៀបនៃការស្នងមរតក ការលក់ទិញ ការចែកទ្រព្យសម្បត្តិ និងសិទ្ធិកាន់កាប់ដីធ្លី ព្រមទាំងតួនាទីរបស់ព្រះមហាក្សត្រដែលជាចៅក្រមកំពូល បានបញ្ជាក់ពីភារកិច្ចរបស់ព្រះមហាក្សត្រក្នុងការអនុវត្តច្បាប់ និងតួនាទីរបស់ព្រះអង្គក្នុងការផ្តល់យុត្តិធម៌។

គ. ទោសទណ្ឌ និងការលោះបាប៖ បានផ្តោតលើ ការដាក់ទណ្ឌកម្ម និងការលោះបាប បន្ទាប់ពីមានការប្រព្រឹត្តខុស។ ប្រភេទបទល្មើស ត្រូវបានកំណត់អំពីបទល្មើសធ្ងន់ និងស្រាល (ដូចជា មហាបាប) និងផលវិបាកនៃការប្រព្រឹត្តបទល្មើសទាំងនោះ។ ទម្ងន់ទោសទណ្ឌ បានបញ្ជាក់ពីរបៀបនៃការដាក់ទោស (សំ. ទណ្ឌ) តាមលក្ខណៈសមាមាត្រទៅនឹងអំពើដែលបានប្រព្រឹត្ត ព្រមទាំងមាននិយាយពីរបៀបនៃការធ្វើពិធីសាសនា

ឬការបូជាដើម្បីលាងបាប ឬកំហុសដែលបានប្រព្រឹត្ត ដើម្បីឱ្យជនល្មើសអាចត្រឡប់ចូលសង្គមបានវិញ។

៥.៤.៩. អំពីច្បាប់មនុ

ច្បាប់មនុ ឬ មនុធម្មសាស្ត្រ គឺជាគម្ពីរ ធម្មសាស្ត្រ ដ៏ល្បីល្បាញបំផុតរបស់ឥណ្ឌាបុរាណ ដែលបានចែងអំពីគោលការណ៍នៃធម៌ ឬច្បាប់សីលធម៌។ គម្ពីរនេះបានកំណត់លម្អិតអំពីកាតព្វកិច្ចរបស់ស្តេច របស់ប្រជាពលរដ្ឋ របៀបនៃការដោះស្រាយវិវាទ និងការដាក់ទណ្ឌកម្មលើបទល្មើសផ្សេងៗ។ ច្បាប់មនុដើរតួជាឯកសារយោង និងជាប្រភពអំណាចសម្រាប់គោលការណ៍ច្បាប់។ អ្នកគ្រប់គ្រង និងពួកបព្វជិតព្រាហ្មណ៍ ដែលជាទីប្រឹក្សាច្បាប់នឹងប្រើប្រាស់គំនិតក្នុងច្បាប់មនុ ដើម្បីបង្កើតច្បាប់ ព្រះរាជក្រឹត្យ ឬកាត់សេចក្តីតាមករណីជាក់ស្តែង។ យើងមានកស្តុតាងខ្លះដែលបញ្ជាក់ថាព្រះរាជាខ្មែរបានប្រើច្បាប់មនុត្រង់ជំពូកទី៨ និងទី៩ក្នុងការងារយុត្តិធម៌សម័យអង្គរ ដូចជា៖ ការដាក់ទោសដោយផ្អែកលើហានៈសង្គម, តួនាទីរបស់ព្រះមហាក្សត្រជាអ្នកអនុវត្តច្បាប់, ការយល់ដឹងអំពីយុត្តិធម៌ និងអំពើល្អ ព្រមទាំងបានបញ្ចូលទៅក្នុងប្រព័ន្ធច្បាប់របស់ខ្មែរសម័យក្រោយៗដែរ។

ជំពូកទី៨ និងទី៩ នៃគម្ពីរនេះ មានលក្ខណៈសំខាន់បំផុតចំពោះតួនាទីជាក្រមច្បាប់ និងក្រមសីលធម៌សង្គម។ ជំពូកទាំងពីរនេះផ្តោតជាចម្បងលើ នីតិសាស្ត្រ ច្បាប់រដ្ឋប្បវេណី (ស៊ីវិល) និងច្បាប់ព្រហ្មទណ្ឌ ព្រមទាំងច្បាប់គ្រួសារ។

ក. ជំពូកទី៨៖ យុត្តិធម៌របស់ព្រះមហាក្សត្រ និង វិវាទផ្លូវច្បាប់

ជំពូកទី ៨ មានចំណងជើងថា ***«វ្យវហារធម៌»*** (ច្បាប់ស្តីពីការប្រតិបត្តិ) ដែលបានគូសបញ្ជាក់ពីកាតព្វកិច្ចរបស់ព្រះមហាក្សត្រក្នុងការគ្រប់គ្រងយុត្តិធម៌ និងផ្តល់នូវក្រមច្បាប់លម្អិត។ ជំពូកនេះជាប្រភពដ៏សំខាន់សម្រាប់ការយល់ដឹងពីនីតិសាស្ត្រហិណ្ឌូបុរាណ។ តួនាទីរបស់ព្រះមហាក្សត្របានចែងថា ព្រះមហាក្សត្រត្រូវតែជាអ្នកផ្តល់យុត្តិធម៌ដោយត្រួតពិនិត្យលើដំណើរការផ្លូវច្បាប់ទាំងអស់។ ព្រះអង្គត្រូវបានណែនាំឱ្យតែងតាំងព្រាហ្មណ៍ដែលចេះដឹងជាចៅក្រមដើម្បីជួយព្រះអង្គ។ អត្ថបទបានសង្កត់ធ្ងន់ថា កាតព្វកិច្ចចម្បងរបស់ព្រះមហាក្សត្រគឺការពារប្រជារាស្ត្រ និងធានាការអនុវត្តធម៌។

ការវិវាទទាំង១៨ ប្រភេទ បានរាយបញ្ជីនិងរៀបរាប់លម្អិតពីវិវាទផ្លូវច្បាប់ជាក់លាក់ចំនួន ១៨ ដែលត្រូវបានគេស្គាល់ថាជា ***«ច្បាប់ទាំង ១៨ ប្រភេទ»*** (សំ. អច្តាទគវ្យវ

ហារបទ)។ ច្បាប់ទាំងនេះ គ្របដណ្តប់លើបញ្ហាផ្លូវច្បាប់រដ្ឋប្បវេណី និងព្រហ្មទណ្ឌយ៉ាងទូលំទូលាយ រួមមាន៖

- បំណុល និងការឱ្យខ្ចី (សំ. ឫណាទាន)។
- បញ្ចាំ និងប្រាក់កក់ (សំ. និក្សេប)។
- ការលក់ដោយគ្មានសិទ្ធិជាម្ចាស់ (សំ. អស្វាមិវិក្រយ)។
- វិវាទភាពជាដៃគូ (សំ. សម្ភូយសមុត្ថាន)។
- ការមិនបង់ប្រាក់ឈ្នួល (សំ. វេតនាទាន)។
- វិវាទព្រំប្រទល់ (សំ. សីមាវិវាទ)។
- បរិហារកេរ្តិ៍ការវាយដំ និងលួច (សំ.វាក្ប្រារុបេយ, ទណ្ឌបារុឞ្យ, ស្តេយ)។

ចំពោះករណីកស្តុតាង និងសាក្សី បានផ្តល់នូវច្បាប់ស្តីពីរបៀបដំណើរការនីតិវិធីផ្លូវច្បាប់ រួមទាំងតួនាទីរបស់សាក្សី ប្រភេទកស្តុតាងផ្សេងៗ និងការស្បថ។ វាក៏បញ្ជាក់អំពីថាតើសក្តីកម្មបែបណាដែលត្រូវបានទទួលយក និងរបៀបដែលចៅក្រមគួរដោះស្រាយសក្តីកម្មដែលផ្ទុយគ្នា។

ករណីទោសទណ្ឌ (សំ. ទណ្ឌ) ជាផ្នែកដ៏សំខាន់មួយនៃជំពូកទី៨ បានបរិយាយអំពីគំនិតនៃទោសទណ្ឌ ដែលមានបង្ហាញពីប្រព័ន្ធពិន័យជាប្រាក់ និងទោសទណ្ឌលើរាងកាយ ដែលជារឿយៗអាចប្រែប្រួលទៅតាមវណ្ណៈសង្គម(សំ. វណ៌) នៃទាំងជនល្មើស និងជនរងគ្រោះ។ ឧទាហរណ៍ ជនវណ្ណៈទាបដែលប្រមាថព្រាហ្មណ៍នឹងប្រឈមមុខនឹងទោសទណ្ឌធ្ងន់ធ្ងរជាងព្រាហ្មណ៍ដែលប្រព្រឹត្តបទល្មើសដូចគ្នាប្រឆាំងនឹងជនវណ្ណៈទាប។

ខ. ជំពូកទី៩៖ ច្បាប់គ្រួសារ និងកិច្ចការក្នុងស្រុក

ជំពូកទី ៩ មានចំណងជើងថា «ស្ត្រីធម៌ប្រករណ» (ផ្នែកស្តីពីកាតព្វកិច្ចរបស់ស្ត្រី) ដែលផ្តោតលើកិច្ចការក្នុងស្រុក និងបញ្ហាគ្រួសារ។ ផ្នែកនេះជាការពង្រីកក្របខ័ណ្ឌច្បាប់ ដើម្បីគ្របដណ្តប់លើទំនាក់ទំនងអាពាហ៍ពិពាហ៍ កាតព្វកិច្ចរបស់ស្ត្រី ច្បាប់ស្តីពីមរតក និងតួនាទីរបស់វណ្ណៈសង្គមផ្សេងៗ។

ខ១. តួនាទី និង កាតព្វកិច្ចរបស់ស្ត្រី៖ ជំពូកនេះមានសារសំខាន់ដោយសារនិយាយអំពីឋានៈរបស់ស្ត្រី ដែលបានចែងថាស្ត្រីត្រូវតែត្រូវបានការពារដោយឪពុករបស់នាងក្នុងវ័យកុមារ ដោយស្វាមីរបស់នាងក្នុងវ័យក្មេង និងដោយកូនប្រុសរបស់

នាងក្នុងវ័យចំណាស់ ដោយបន្ថែមថាស្ត្រីមិនគួរមានឯករាជ្យដោយខ្លួនឯងឡើយ។ ជំពូកនេះ គឺជាការពិភាក្សាអំពីកាតព្វកិច្ចរបស់ភរិយាចំពោះស្វាមី និងគ្រួសាររបស់ស្ត្រី។

ខ២. អាពាហ៍ពិពាហ៍ និង អំពើផិតក្បត់៖ បានគូសបញ្ជាក់ពីច្បាប់សម្រាប់អាពាហ៍ពិពាហ៍ និងរាយបញ្ជីទោសទណ្ឌជាក់លាក់សម្រាប់ការប្រព្រឹត្តអំពើផិតក្បត់។ ភាពធ្ងន់ធ្ងរនៃទោសទណ្ឌសម្រាប់ការផិតក្បត់ គឺអាស្រ័យលើវណ្ណៈរបស់បុរស និងស្ត្រីដែលពាក់ព័ន្ធ។

ខ៣. មរតក និង ការស្នងតំណែង៖ ជំពូកនេះលម្អិតអំពីច្បាប់មរតក ដោយបញ្ជាក់ពីរបៀបបន្តកេរ្តិ៍មរតក ទ្រព្យសម្បត្តិ ពីឪពុកបុរស បែងចែកក្នុងចំណោមកូនប្រុសរបស់ខ្លួន ហើយក៏បាននិយាយអំពីសិទ្ធិរបស់ភរិយា និងកូនស្រីក្នុងការបែងចែកទ្រព្យសម្បត្តិគ្រួសារ។

ខ៤. កាតព្វកិច្ចជាក់លាក់តាមវណ្ណៈ៖ ត្រង់នេះផ្តល់នូវក្របខ័ណ្ឌច្បាប់ទូទៅជំពូកទី៩ រួមបញ្ចូលបទបញ្ញត្តិផ្លូវច្បាប់ និងសង្គមជាក់លាក់សម្រាប់វណ្ណៈទាំងបួន ជាពិសេសទាក់ទងនឹងជីវិតគ្រួសារ មុខរបរ និងអាកប្បកិរិយារបស់ខ្លួន។ លើសពីនេះក៏មានដំណោះស្រាយនូវបញ្ហាដែលទាក់ទងនឹងវណ្ណៈចម្រុះ ដែលត្រូវបានចាត់ទុកថាបានកើតឡើងពីអាពាហ៍ពិពាហ៍ឆ្លងវណ្ណៈ។

៥.៥. យុទ្ធសាស្ត្រចម្បាំងនិងវិស័យការទូតសម័យអង្គរ

ខ្មែរបុរាណបានប្រើប្រាស់ក្បួនយុទ្ធសាស្ត្រក្នុងគម្ពីរ *«អថ៌សាស្ត្រ»* ដែលបង្កើតដោយព្រាហ្មណ៍ឥណ្ឌាបុរាណជាមន្ត្រីជាន់ខ្ពស់ឈ្មោះ *«កៅដិល្យ»* ឬ *«ចាណាក្យ»*។ *«អថ៌សាស្ត្រ»* បានផ្តល់ចំណេះដឹងយ៉ាងទូលំទូលាយ អំពីកិច្ចការចម្បាំង និងការងារទូត។ គម្ពីរនេះជាក្បួនបង្ហាញការរៀបចំកងទ័ពជើរឹងមាំ រៀបចំផែនការជាយុទ្ធសាស្ត្រ ការងារប្រមូលព័ត៌មានសម្ងាត់ប្រកបដោយប្រសិទ្ធភាព និងការប្រើប្រាស់កម្លាំង ព្រមទាំងក្បួនការងារទូតដោយប៉ិនប្រសប់ដើម្បីសម្រេចបានគោលបំណងរបស់អ្នកគ្រប់គ្រងនគរ។

៥.៥.១. យុទ្ធសាស្ត្រចម្បាំង

ក. របៀបរៀបចំកងទ័ពរឹងមាំ

រចនាសម្ព័ន្ធកងទ័ព៖ តាម អថ៌សាស្ត្រ កងទ័ពរៀបចំជា ៥ក្រុមផ្សេងគ្នា ប៉ុន្តែខ្មែរបុរាណបានបន្ថែមកងទ័ពមួយក្រុមទៀតគឺ *«កងទ័ពជើងទឹក»* (រចនាសម្ព័ន្ធទ័ពទាំងនេះមានបង្ហាញជារូបភាពលើប្រាសាទអង្គរវត្ត បាយ័ន្ត និងបន្ទាយឆ្មារ)។ កងទ័ពទាំងនោះ

មាន៖ កងទ័ពថ្មើរជើង កងទ័ពរទេះ កងទ័ពសេះ កងទ័ពដំរី កងទ័ពកស្តុការ (ដឹកជញ្ជូនស្បៀង) និងកងទ័ពជើងទឹក (ខ្មែរសម័យអង្គរបង្កើតខ្លួនឯង)។

ក១. របៀបជ្រើសរើសនិងការបង្វឹក៖ ក្បួនបានសង្កត់ធ្ងន់លើសារៈសំខាន់នៃការជ្រើសរើសពលទាហានដែលស្មោះត្រង់និងមានសមត្ថភាព ព្រមទាំងផ្តល់ការបណ្តុះបណ្តាលយ៉ាងម៉ត់ចត់លើជំនាញយោធាផ្សេងៗ និងការប្រើប្រាស់អាវុធយុទ្ធោបករណ៍នានា។

ក២. ការថែទាំបីបាច់និងបំប៉នស្មារតី៖ អចិសាស្ត្រ បានលម្អិតអំពីតម្រូវការនៃការផ្តល់អាហារូបត្ថម្ភត្រឹមត្រូវ ការទូទាត់ប្រាក់បៀវត្សរ៍ទាន់ពេលវេលា និងការរក្សាបំពាក់បំប៉នស្មារតីរបស់កងទ័ពតាមរយៈភាពគំរូជាអ្នកដឹកនាំល្អ និងផ្តល់រង្វាន់។

ខ. យុទ្ធសាស្ត្រ និងកលយុទ្ធយោធា (យុទ្ធវិធី)

ខ១. ការរៀបចំក្បួនយុទ្ធសាស្ត្រ៖ អ្នកគ្រប់គ្រងកងទ័ពត្រូវសិក្សាវាយតម្លៃដោយប្រុងប្រយ័ត្នអំពីកម្លាំងនិងចំណុចទន់ខ្សោយរបស់សត្រូវ ស្ថានភាពភូមិសាស្ត្រទឹកដីនិងពេលវេលា ព្រមទាំងពិនិត្យមើលធនធានផ្ទាល់ខ្លួន មុនពេលចូលធ្វើសង្គ្រាម។ ត្រូវរៀបចំលើកធ្វើផែនការយុទ្ធសាស្ត្រ និងគោលដៅចម្បាំងទុកជាមុន។

ខ២. ការរៀបចំក្បួនកងទ័ពចេញប្រយុទ្ធ (ព្យុហ)៖ រៀបចំទម្រង់ក្បួនទ័ពតម្រូវតាមស្ថានភាពភូមិសាស្ត្រទឹកដី និងក្បួនទប់ទល់នឹងការរៀបចំទ័ពរបស់សត្រូវ។ ទម្រង់ទាំងនេះមានគោលបំណងបង្កើនប្រសិទ្ធភាពចម្បាំង និងការពារភាពងាយរងគ្រោះ។

ខ៣. កលយុទ្ធវាយប្រហារនិងការពារ៖ យុទ្ធសាស្ត្រវាយប្រហារពីខាងមុខ ចលនាវាយពីចំហៀង និងការវាយប្រហារដោយមិនឱ្យដឹងខ្លួនមុន។ របៀបរៀបចំលម្អិតអំពីយុទ្ធសាស្ត្រការពារខ្លួន ដូចជាការពង្រឹងទីតាំងឈរជើង និងការប្រើប្រាស់ស្ថានភាពភូមិសាស្ត្រទឹកដីឱ្យមានប្រយោជន៍ជាដើម។

ខ៤. សង្គ្រាមចិត្តសាស្ត្រ៖ ចលនាយោសនាធ្វើឱ្យសត្រូវបាក់ស្មារតីនិងទឹកចិត្ត ការផ្សព្វផ្សាយពាក្យចចាមអារ៉ាម និងការប្រើប្រាស់ល្បិចបោកបញ្ឆោត។

គ. សង្គ្រាមចារកម្ម៖

គ១. រៀបចំបណ្តាញចារកម្មដ៏ទូលំទូលាយ៖ បណ្តាញចារកម្ម (គូឈបុរុស) ដែលរៀបចំបានល្អ ដើម្បីប្រមូលព័ត៌មានសម្ងាត់អំពីកម្លាំង ភាពទន់ខ្សោយ គោលដៅនិងចលនាទ័ពរបស់សត្រូវ។

គ២. រៀបចំឱ្យមានប្រភេទចារកម្មផ្សេងៗ៖ ប្រភេទចារកម្ម រួមទាំងអ្នកដែលក្លែងខ្លួនជាអ្នកបួស ឈ្មួញ សិប្បករ និងសូម្បីតែស្ត្រី ដែលប្រតិបត្តិការទាំងនៅក្នុងទឹកដីរបស់អ្នកគ្រប់គ្រងខ្លួនឯង និងនៅក្នុងទឹកដីសត្រូវ។

គ៣. ឈ្លបស៊ើបយកការណ៍សម្ងាត់៖ ព័ត៌មានដែលប្រមូលបានដោយចារកម្មមានសារៈសំខាន់សម្រាប់ការបង្កើតយុទ្ធសាស្ត្រយោធា ការវាយតម្លៃ ការគំរាមកំហែង និងការផ្សាយឱ្យមានជម្លោះក្នុងចំណោមជួរកងទ័ពសត្រូវ។

ឃ. យុទ្ធសាស្ត្រសង្គ្រាមឡោមព័ទ្ធ (អវរោធ)

ឃ១. របៀបរៀបចំបន្ទាយរឹងមាំ (ទុគ៌)៖ រៀបចំសាងសង់ ការថែទាំ និងការការពារបន្ទាយ។ បន្ទាយមានសារៈសំខាន់សម្រាប់ការការពារទីតាំងយុទ្ធសាស្ត្រ និងជាទីបញ្ជាការរាល់ប្រតិបត្តិការយោធា។

ឃ២. វិធីសាស្ត្រនៃការឡោមព័ទ្ធ៖

- ***ការវាយប្រហារដោយផ្ទាល់៖*** ការកម្ចាត់ការការពាររបស់សត្រូវដោយកម្លាំងទល់មុខ។
- ***ការបិទផ្លូវ៖*** ការកាត់ផ្តាច់ការផ្គត់ផ្គង់ស្បៀង ដើម្បីធ្វើឱ្យអ្នកការពារអត់ឃ្លាន។
- ***ការជីកកកាយជញ្ជាំង៖*** ការជីកផ្លូវក្រោមដីដើម្បីធ្វើឱ្យរលំរលាយបន្ទាយ។
- ***ការប្រើប្រាស់គ្រឿងចក្រឡោមព័ទ្ធ៖*** ការប្រើប្រាស់គ្រឿងយុទ្ធោបករណ៍ដើម្បីទម្លុះជញ្ជាំងបន្ទាយ និងវាយប្រហារអ្នកការពារលើបន្ទាយ។

ឃ៣. ការការពារប្រឆាំងនឹងការឡោមព័ទ្ធ៖ រៀបចំការស្តុកទុកជាក់និងការផ្គត់ផ្គង់ស្បៀង ការថែរក្សានិងការការពារប្រព័ន្ធការពារឱ្យបានរឹងមាំ និងរៀបចំប្រព័ន្ធវាយប្រហារបកវិញ។

៥.៥.២. យុទ្ធសាស្ត្រការទូត

ការងារទូតមានតួនាទីសំខាន់និងជាការងារពហុមុខ។ ជាឧបករណ៍យុទ្ធសាស្ត្រដើម្បីសម្រេចគោលបំណងរបស់អ្នកគ្រប់គ្រងនគរ ដែលជាជម្រើសប្រសើរជាងជម្លោះប្រដាប់អាវុធ ប៉ុន្តែក៏ជាធាតុសំខាន់ក្នុងការត្រៀមខ្លួន ក្នុងការធ្វើសង្គ្រាមប្រកបដោយប្រសិទ្ធភាព ជាយថាហេតុ។

ក. ការចារឹកតិចតួនាទីក្នុងសង្គ្រាម៖

ក១. ទំនាក់ទំនងរវាងរដ្ឋ៖ ជាគោលនយោបាយការបរទេស សម្រាប់គ្រប់គ្រងទំនាក់ទំនងជាមួយរដ្ឋជិតខាង ដើម្បីការបង្កើតសម្ព័ន្ធភាព និងដើម្បីព្រៃកសត្រូវ ដ៏មានសក្តានុពល។

ក២. ការចរចា និងសន្ធិសញ្ញា៖ ជាយុទ្ធសាស្ត្រសម្រាប់ប្រើប្រាស់យុទ្ធវិធីនៃការបង្កើតឱ្យសន្ធិសញ្ញា និងការចរចា ដើម្បីសម្រេចគោលដៅនយោបាយ និងយោធា រួមទាំងការជានាសន្តិភាព ឬការបង្កើតសម្ព័ន្ធភាពសម្រាប់ច្បាំងជាមួយអ្នកទី៣។

ក៣. តួនាទីនៃបេសកជន ឬអ្នកការទូត៖ បេសកជនបានដើរតួនាទីយ៉ាងសំខាន់ក្នុងការបញ្ជូនសារ ការចរចាសម្ព័ន្ធភាព និងការប្រមូលព័ត៌មានសម្ងាត់នៅក្នុងរាជការនគរបរទេស។

ខ. ការចារឹកជាយុទ្ធសាស្ត្រដើម្បីចៀសវាងសង្គ្រាម៖

ខ១. មធ្យោបាយការទូតចាំបាច់៖ វិធីផ្សះផ្សា (សំ. សម) និងការផ្តល់អំណោយ (សំ. ទាន) ជាវិធានការដំបូងដើម្បីគ្រប់គ្រងទំនាក់ទំនងជាមួយរដ្ឋដទៃទៀត និងការពារជម្លោះកុំឱ្យកើតឡើង។

ខ២. រក្សាសន្តិភាព៖ អ្នកគ្រប់គ្រងនគរដ៏ឈ្លាសវៃ គួរតែខិតខំរក្សាសន្តិភាព និងស្ថិរភាព តាមរយៈប្រើប្រាស់យុទ្ធសាស្ត្រចរចាដ៏ប៉ិនប្រសប់ និងប្រើយុទ្ធសាស្ត្រចងសម្ព័ន្ធភាព ដ្បិតសង្គ្រាមជាការខាតបង់ដែលត្រូវចំណាយតម្លៃខ្ពស់ និងមានហានិភ័យជាប់ជាប្រចាំ។

ខ៣. ផលប្រយោជន៍ការងារទូត៖ អាចប្រើប្រាស់ដើម្បីវាយតម្លៃចំណាប់អារម្មណ៍និងសមត្ថភាពរបស់នគរជិតខាង ដែលអនុញ្ញាតឱ្យអ្នកគ្រប់គ្រងធ្វើការសម្រេចចិត្ត ដោយមានទិន្នន័យត្រឹមត្រូវអំពីការគំរាមកំហែងពីខាងក្រៅ និងរកសម្ព័ន្ធភាពដ៏មានសក្តានុពល។

គ- ការបង្កើតសម្ព័ន្ធភាព និងការស្វែងរកការគាំទ្រ៖

គ១. ទ្រឹស្តីប្រព័ន្ធមណ្ឌល៖ ជាចំណុចកណ្តាលនៃយុទ្ធសាស្ត្រការទូតបុរាណ។ ទ្រឹស្តីនេះជាការយល់ដឹងអំពីបណ្តាញទំនាក់ទំនងដ៏ស្មុគស្មាញរវាងនគរជិតខាង និងការបង្កើតសម្ព័ន្ធភាពជាយុទ្ធសាស្ត្រជាមួយអ្នក ដែលស្ថិតក្នុងទីតាំងភូមិសាស្ត្រជាមួយសម្ព័ន្ធ

មិត្ត។ ឧទាហរណ៍៖ ចងសម្ព័ន្ធភាពជាមួយនគរនៅជាប់គ្នាដែលខ្សោយជាងខ្លួន (នគរចាម្ប ឬដៃរៀត) តែត្រូវចងមិត្តជាមួយនគរនៅជាប់បន្តពីនគរទី១ ដែលខ្លាំងជានគរនេះ (ក្រុងចិន)។

គ២. ឧបករណ៍ចម្បងនៃយុទ្ធសាស្ត្រការទូត៖ សម្រាប់ការបង្កើតសម្ព័ន្ធភាព ដើម្បីធានាការគាំទ្រផ្នែកយោធា និងការដាក់ឱ្យសត្រូវជ៏មានសក្តានុពលនៅឯកោ ដែលជាជំនួយរៀបចំសន្ធិសញ្ញា និងកិច្ចព្រមព្រៀង ប្រកបដោយសារៈសំខាន់សម្រាប់ការកំណត់លក្ខខណ្ឌនៃចំណង់សម្ព័ន្ធភាព ព្រមទាំងកាតព្វកិច្ចការពារគ្នាទៅវិញទៅមក។

ឃ. យុទ្ធសាស្ត្របំបែកបំបាក់ដើម្បីគ្រប់គ្រង

ឃ១. ការបង្កើតជម្លោះបំបែកបំបាក់ (ភេទ)៖ ជាយុទ្ធសាស្ត្រការទូតដ៏សំខាន់មួយ បង្កសកម្មភាពក្នុងចំណោមសម្ព័ន្ធមិត្តរបស់សត្រូវ ឬនៅក្នុងនគរសត្រូវខ្លួនឯង តាមរយៈការសាបព្រោះការសង្ស័យ ការញុះញង់ឱ្យមានការបះបោរ ឬការកេងប្រវ័ញ្ចលើជម្លោះដែលមានស្រាប់ អ្នកគ្រប់គ្រងអាចធ្វើឱ្យសមត្ថភាពរបស់សត្រូវក្នុងការធ្វើសង្គ្រាមចុះខ្សោយយ៉ាងមានប្រសិទ្ធភាព។

ឃ២. យុទ្ធសាស្ត្រទូតមុនពេល ឬអំឡុងពេលមានជម្លោះគ្នា៖ ការងារទូតតាមរយៈការប្រើប្រាស់បេសកជន ភ្នាក់ងារសម្ងាត់ដោយប៊ិនប្រសប់ ធ្វើឱ្យអស្ថិរភាពផ្ទៃក្នុងរបស់គេ និងការគាំទ្រពីខាងក្រៅរបស់សត្រូវចុះខ្សោយ។

ង. ការប្រមូលព័ត៌មានសម្ងាត់តាមរយៈបេសកជន

ង១. ការងាររបស់បេសកជនទូត (ទូត/Duta)៖ មិនត្រឹមតែជាអ្នកនាំសារប៉ុណ្ណោះទេ តែក៏ជាអ្នកប្រមូលព័ត៌មានសម្ងាត់ដ៏សំខាន់ផងដែរ។ បេសកជនជាអ្នកសង្កេតមើលកម្លាំង ភាពទន់ខ្សោយ ការត្រៀមខ្លួនខាងយោធា និងកិច្ចការផ្ទៃក្នុងរបស់សត្រូវ ដោយផ្តល់ព័ត៌មានសំខាន់សម្រាប់ការធ្វើផែនការជាយុទ្ធសាស្ត្រ។

ង២. លក្ខណៈសម្បត្តិ និងការកិច្ចរបស់បេសកជន៖ ជាតួនាទីក្នុងការស្វែងយល់អំពីសម្ព័ន្ធមិត្ត យល់ដឹងអំពីស្ថានភាពនយោបាយ និងការរាយការណ៍ត្រឡប់មកវិញជូនអ្នកគ្រប់គ្រងនគរ។

ច. ការប្រើប្រាស់ការទូតជាឧបករណ៍អំឡុងពេលសង្គ្រាម

សូម្បីតែក្នុងអំឡុងពេលមានជម្លោះយ៉ាងសកម្ម ការងារការទូតនៅតែមានសារៈសំខាន់។ ពេលគឺប្រើប្រាស់ការងារទូត ដើម្បីចរចាការបញ្ឈប់ចម្បាំង ការដោះដូរអ្នក

ទោស ឬសូម្បីតែស្វែងរកលក្ខខណ្ឌសន្តិភាពនៅពេលដែលពេលវេលាសមស្រប។ ការប្រើប្រាស់ការងារទូត ដើម្បីកៀរគរការគាំទ្រពីនគរអព្យាក្រឹត្យ ឬដើម្បីបញ្ចុះបញ្ចូលគេកុំឱ្យចូលរួមជាមួយសត្រូវ។

រូប ៨. ចម្លាក់ព្រះបាទស្រីសូរ្យវម្ម៌ទេវទី២ (សូរ្យវ៌្មនទី២) ធ្វើពិធីបញ្ចុះពលនៅភ្នំសិវបាទ ស.វ.ទី១២




ប្រភព៖ របៀងខាងត្បូង ចំហៀងខាងលិច ប្រាសាទអង្គរវត្ត

រូប ៩. ចម្លាក់កងទ័ពព្រះបាទស្រីសូរ្យវម្ម៌ទេវទី២ (សូរ្យវ៌្មនទី២) ស.វ.ទី១២



ប្រភព៖ ចម្លាក់លើជញ្ជាំងប្រាសាទអង្គរវត្ត

រូប ១០. ចម្លាក់កងទ័ពជើងទឹកនៅប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣



ប្រភព៖ ចម្លាក់លើជញ្ជាំងប្រាសាទបាយ័ន្ត

រូប ១១. ចម្លាក់ព្រះមហាក្សត្រទតការហាត់សមយុទ្ធនៅប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣



ប្រភព៖ ចម្លាក់លើជញ្ជាំងប្រាសាទបាយ័ន្ត

រូប ១២. ចម្លាក់កងទ័ពកសុការ (ជីកជញ្ជួនស្បៀង) នៅប្រាសាទបាយ័ន្ត ចុងស.វ.ទី១២ ដើមស.វ.ទី១៣



ប្រភព៖ ចម្លាក់លើជញ្ជាំងប្រាសាទបាយ័ន្ត

៦. សេចក្តីសន្និដ្ឋាន

ច្បាប់សម័យអង្គរ កើតបានមកពីការរួមបញ្ចូលគ្នានៃឥទ្ធិពលឥណ្ឌា និងប្រពៃណីខ្មែរ។ ប្រព័ន្ធច្បាប់នៃចក្រភពខ្មែរសម័យអង្គរ (សតវត្សរ៍ទី៩ ដល់ទី១៥) គឺជាការសម្របសម្រួលដ៏ប៉ិនប្រសប់មួយរវាង គោលការណ៍ច្បាប់ឥណ្ឌាបុរាណ (ធម្មសាស្ត្រ) និងទំនៀមទម្លាប់សង្គមខ្មែរ ដែលមានស្រាប់។ វិធីសាស្ត្រនេះបានបង្កើតជាប្រព័ន្ធច្បាប់មួយដែលមានលក្ខណៈបត់បែន និងស៊ីជម្រៅ ហៅថា ច្បាប់ចម្រុះ ឬ ច្បាប់ហិណ្ឌូ-ខ្មែរ។

ចក្រភពខ្មែរបានទទួលយកធម្មសាស្ត្រ (Dharmaśāstra) ជាពិសេស ច្បាប់មនុ (Manusmṛti) ជាមូលដ្ឋានគ្រឹះនៃទស្សនវិជ្ជានីតិរដ្ឋ។ ធម្មសាស្ត្របានផ្តល់ជាគោលការណ៍ទេវរាជ ដែលជាមូលដ្ឋានគ្រឹះសម្រាប់ការគ្រប់គ្រងដោយព្រះមហាក្សត្រ (រាជធម៌) ។ ព្រះរាជាត្រូវបានគេលើកតម្កើងជា ទេវរាជ ដែលត្រូវមានការកិច្ចរក្សាសណ្តាប់ធ្នាប់សង្គម និងយុត្តិធម៌ (Dharma)។ ធម្មសាស្ត្របានផ្តល់ក្របខ័ណ្ឌនីតិវិធីជាមូលដ្ឋានគ្រឹះសម្រាប់នីតិវិធីតុលាការ (វ្យវហារៈ) ដូចជាប្រភេទនៃវិវាទ (បំណុល ទ្រព្យសម្បត្តិ) របៀបស៊ើបអង្កេត និងការប្រើប្រាស់កស្តុតាង។ គោលការណ៍ក្រមសីលធម៌ បានកំណត់អំពីសីលធម៌ ភារកិច្ចក្នុងគ្រួសារ និងការដាក់ទោស ចំពោះបទល្មើសធ្ងន់ៗ។

ក្បួនពីដើមពីឥណ្ឌាតែបានសម្របតាមប្រពៃណីខ្មែរ។ ទោះបីមានការទទួលឥទ្ធិពលពីឥណ្ឌាក៏ដោយ ក៏ច្បាប់ទាំងនោះមិនត្រូវបានចម្លងទាំងស្រុងនោះទេ។ ព្រះមហាក្សត្រខ្មែរបានសម្របសម្រួល និងដាក់បញ្ចូលប្រពៃណីរបស់ខ្លួនទៅក្នុងប្រព័ន្ធច្បាប់។ អាទិភាពនៃរាជបវេណី ដែលបានអនុវត្តច្បាប់នៅខ្មែរមិនមែនផ្អែកតែលើអត្ថបទសាសនាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងលើ ទំនៀមទម្លាប់ និង រាជបវេណី ដែលបានចាក់ឫសគល់ក្នុងសង្គមខ្មែរតាំងពីយូរយារណាស់មកហើយ។ អំណាចកណ្តាល ព្រះមហាក្សត្រជាអ្នកសម្រេចចុងក្រោយលើរឿងក្តីសំខាន់ៗ និងការដាក់ទោសធ្ងន់ធ្ងរ គឺស្ថិតនៅក្រោម ព្រះរាជបញ្ជា ផ្ទាល់របស់ព្រះមហាក្សត្រ។ នេះធ្វើឱ្យអំណាចស្តេចខ្មែរមានលក្ខណៈដាច់ខាតហួសពីដែនកំណត់នៃគម្ពីរធម្មសាស្ត្រសុទ្ធសាធ។ ការដាក់ទោសទណ្ឌមួយចំនួនដូចដែលបានពិពណ៌នានៅក្នុងកំណត់ហេតុរបស់អ្នកដំណើរចិន (ជីវ តាក្វាន់) គឺមានលក្ខណៈសាហាវ ឬ ប្រហែលជាខុសប្លែក ពីការអនុវត្តដោយផ្ទាល់ក្នុងប្រទេសឥណ្ឌាដើម។ ឧទាហរណ៍៖ ការកាត់ច្រមុះ ម្រាមដៃ ឬការគាបជើងលើករណីសាហាយស្មន់ ដែលអាចជាការអនុវត្តតាមទំនៀមទម្លាប់ខ្មែរ។

ច្បាប់សម័យអង្គរគឺជា ប្រព័ន្ធច្បាប់កូនកាត់ ដែលប្រើប្រាស់ធម្មសាស្ត្រ ជាគ្រឹះសីលធម៌ និងរដ្ឋបាល ប៉ុន្តែត្រូវបានអនុវត្ត និងកែប្រែដោយ ព្រះរាជអំណាច និងប្រពៃណីក្នុងស្រុក។ នេះធានាបានថា នគរមានសណ្តាប់ធ្នាប់ រដ្ឋបាលរឹងមាំតាមលំនាំឥណ្ឌា ក្នុងពេលជាមួយគ្នានោះក៏រក្សាបាននូវអត្តសញ្ញាណ និងសណ្តាប់ធ្នាប់សង្គមរបស់ខ្មែរ។

គន្ថនិទ្ទេស

ឆោម គន្ធា. (២០២៤). *សិលាចារឹកនៃរាជ្យព្រះបាទជ័យវរ្ម័ទី១ នៅដែនដីសណ្តែកន្លេមគង្គ*. បាឋកថាសាធារណៈសារមន្ទីរជាតិកម្ពុជា, ភ្នំពេញ. https://www.youtube.com/watch?v=kvumRMlibyY&t=3266s។

វង់ សុធារ៉ា. (២០២១). *សិលាចារឹកកម្ពុជាសម័យអង្គរ*។

វង់ សុធារ៉ា. (២០១២). *សិលាចារឹកនៃប្រទេសកម្ពុជាសម័យកណ្តាល*. នគរវត្ត។

ស៊ីយ៉ុន សុការិទ្ធ. (២០២៤). *ទោសទណ្ឌនៅកម្ពុជាសម័យបុរាណតាមរយៈសិលាចារឹកនិងចម្លាក់*។

សួង សុខរ៉ូ. (២០១៨). របៀបដោះស្រាយវិវាទក្នុងសង្គមខ្មែរនាអតីតកាល. ព្រឹត្តិបត្រសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ៖ កម្រងអត្ថបទស្រាវជ្រាវប្បធម៌ខ្មែរ, ២១-៦៣។

សួង សុខរ៉ូ. (២០១៥). *របៀបដោះស្រាយវិវាទក្នុងសង្គមខ្មែរនាអតីតកាល* [សារណាថ្នាក់បរិញ្ញាបត្រ]. សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ។

អ៊ឹម សុខវិទ្ធី, អ៊ា ដារិទ្ធ, ខៀវ ច័ន្ទ, ស្រ៊ុន តិច, ហេង ថាន, & គឹម សំណាង. (២០២១). បណ្តាញគមនាគមន៍នៃចក្រភពខ្មែរ៖ករណីផ្លូវបុរាណពីអង្គរទៅកិមាយ. ព្រះនគរ, ៣, ១២៩-១៥៨។

អាំង ជូលាន. (២០២៥). *ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអង្គរ (មូលដ្ឋានរៀននិងស្រាវជ្រាវ)*. យសោធរ។

Aymonier, É. (1901). La stèle de Sdok Kâk Thom. *Journal Asiatique*, *9*(17), 5–52.

Barth, A. (1885). *Inscriptions sanscrites du Cambodge*. Imprimerie nationale.

Barth, A. (1903). Les doublets de la stèle de Say-Fong. *Bulletin de l'École française d'Extrême-Orient*, *3*(3), 460–466. https://www.persee.fr/doc/befeo_0336-1519_1903_num_3_1_1239

Chakravarti, A. (1978). *The Sdok Kak Thoṃ Inscription: A study in Indo-Khmèr civilization*. Sanskrit College.

Chea, S., Estève, J., Soutif, D., & Swenson, E. (2023). Āśramas, shrines and royal power. In *The Angkorian World*. Taylor & Francis.

Chhom, K., Goodall, D., & Griffiths, A. (2025). A Buddhist Procession Inaugurated in a 7th-century Inscription from Óc Eo (K. 1426) and the Ancient Toponym Tamandarapura. *The Journal of the Siam Society*, *113*(1), 141–164.

Cœdès, G. (1940). II. Études cambodgiennes. *Bulletin de l'École française d'Extrême-Orient*, *40*(2), 315–349. https://doi.org/10.3406/befeo.1940.4797

Cœdès, G. (1942) "L'Édits de Jayavarman VII." Inscriptions du Cambodge, vol. 2. Hanoi: École Française d'Extrême-Orient.

Cœdès, G. (1951). *Inscriptions du Cambodge* (EFEO, Vol. 3). Editions de Boccard.

Cœdès, G. (1954). *Inscriptions du Cambodge* (EFEO, Vol. 6, p. 269).

Cœdès, G. (1964). *Inscriptions du Cambodge* (EFEO, Vol. 7). École Française d'Extrême-Orient.

Cœdès, G. (1968). *The indianized states of Southeast Asia* (W. F. Vella, Ed.; S. B. Cowing, Tran.). Australian National University Press.

Cœdès, G., & Dupont, P. (1937). Les inscriptions du Pràsàt Kôk Pô. *Bulletin de l'École française d'Extrême-Orient*, *37*(2), 379–413.

https://www.persee.fr/doc/befeo_0336-1519_1937_num_37_1_5358

Cœdès, G., & Dupont, P. (1943). Les stèles de Sdŏk Kăk Thom Phnom Sandak et Práah Vihār. *Bulletin de l'École française d'Extrême-Orient*, *43*(1), 56–154.

Davis, T., & Lustig, E. (2023). Angkorian Law and Land. In *The Angkorian World* (pp. 237–253). Routledge.

Finot, L. (1903). Notes d'épigraphie, II : L'inscription sanskrite de Say-Fong. *Bulletin de l'Ecole française d'Extrême-Orient*, *3*, 18–33. https://www.persee.fr/doc/befeo_0336-1519_1903_num_3_1_1187

Finot, L. (1904). Notes d'épigraphie, VII : L'inscription de Práḥ Khan. *Bulletin de l'Ecole française d'Extrême-Orient*, *4*(3), 672–679.

Finot, L. (1915). Notes d'épigraphie, XVI : L'inscription de Sdok Kak Thom. *Bulletin de l'École française d'Extrême-Orient*, *15*(2), 53–106.

Finot, L. (1928). Nouvelles inscriptions du Cambodge. *Bulletin de l'École française d'Extrême-Orient*, *28*(1), 43–80. https://doi.org/10.3406/befeo.1928.3116

Finot, L., Parmentier, H., & Goloubew, V. (1926). *Le temple d'Içvarapura (Bantāy Srĕi, Cambodge)*. G. Vanoest.

Honda, M. (1965). The SAY-FONG Inscription Of Jayavarman VII. *印度學佛教學研究 = Journal of Indian and Buddhist Studies = Indogaku Bukkyōgaku Kenkyū*, *14*(1).

Hooker, M. B. (1978). *A Concise Legal History of South-East Asia*. Clarendon Press.

Kaur, K. (2010). Kautilya: Saptanga Theory of State. *The Indian Journal of Political Science*, *71*(1), 59–68.

Lingat, R. (1949). L'influence juridique de l'Inde au Champa et au Cambodge d'après l'épigraphie. *Journal Asiatique*, *137*, 273–290.

Lingat, R. (1973). *The Classical Law of India*. University of California Press.

Lustig, E. J. (2009). Money doesn't make the world go round: Angkor's non-monetisation. In D. Wood (Ed.), *Research in Economic Anthropology* (pp. 165–199). Emerald Group Publishing Ltd.

Olivelle, P. (2013). *King, Governance and Law in Ancient India: Kauṭilya's Arthaśāstra: A New Annotated Translation*. Oxford University Press.

Pou, S. (2001). *Nouvelles inscriptions du Cambodge, volumes II et III*. École française d'Extrême-Orient.

Rethy, C., Evans, D., Kunthea, C., Pisith, P., & Sharrock, P. D. (2023). Education and Medicine at Angkor. In *The Angkorian World*. Routledge.

Sahai, S. (1970). *Les institutions politiques et l'organisation administrative du Cambodge Ancien (VI-XIII siècles)*. Ecole Française d'Extreme-Orient.

Sak-Humphry, C. (2005). *The Sdok Kak Thom inscription (K. 235): With a grammatical analysis of the Old Khmer text* (Buddhist Institute). Buddhist Institute.

Vickery, M. (1998). *Society, economics and politics in pre-Angkor Cambodia: The 7th-8th centuries*. The Centre for East Asian Cultural Studies for Unesco, The Toyo Bunko.

Vong Sotheara. (2016). *Hierarchy in Ancient Cambodia: the study on title nouns.* Ph.D Thesis (Area Studies), Sophia University.

បញ្ជីឈ្មោះក្រុមសិក្ខាស្រាវជ្រាវ
អនុប្រធានបទស្តីពីច្បាប់កម្ពុជាសម័យកណ្តាល (មជ្ឈិមសម័យ)

លរ.	គោតនាម និងនាម	វិជ្ជាជីវៈ	ស្ថាប័ន	ការចូលរួម
១	ឯកឧត្តម ពៅ សារឿន	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់	ក្រុមប្រឹក្សាអ្នកច្បាប់	អ្នកសម្រប សម្រួល, ផ្តល់ជាតុចូល និង និពន្ធ
២	ឯកឧត្តមបណ្ឌិត សឿន សុភ័ណ	សាកលវិទ្យាធិការរង	សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច	ផ្តល់ជាតុចូល
៣	ឯកឧត្តម សួង សុខរ៉ូ	ជំនួយការសម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី និងជានាយកប្រតិបត្តិនៃអង្គការផ្សព្វផ្សាយវប្បធម៌ខ្មែរ យសោធរ	អង្គការផ្សព្វផ្សាយវប្បធម៌ខ្មែរ យសោធរ	ផ្តល់ជាតុចូល និងនិពន្ធ
អ្នកសម្របសម្រួលក្រុមស្រាវជ្រាវ				
៤	លោក ម៉ន សុភ័ណ	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ
៥	លោក មាយ សីហា	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួល និងបច្ចេកទេសអត្ថបទ

អនុប្រធានបទ
ស្តីពីច្បាប់កម្ពុជាសម័យកណ្តាល (មជ្ឈិមសម័យ)

ខ្លឹមសារសង្ខេប

ការសិក្សាស្រាវជ្រាវនេះបានផ្តល់នូវការវិភាគយ៉ាងល្អិតល្អន់ទៅលើប្រព័ន្ធច្បាប់ និងយុត្តិធម៌កម្ពុជានាសម័យកណ្តាល ការសិក្សានេះបង្ហាញឱ្យឃើញថា ប្រព័ន្ធច្បាប់កម្ពុជានាសម័យនោះ ជាប្រព័ន្ធច្បាប់បុរាណ ឬច្បាប់ទំនៀម ដែលត្រូវបានបង្កើតឡើងដើម្បីរក្សាស្ថិរភាពសង្គមក្នុងបរិបទ នៃវិបត្តិផ្នែកនយោបាយក្រោយសម័យអង្គរ។ ប្រព័ន្ធច្បាប់ និងយុត្តិធម៌នៅសម័យនោះមិនត្រូវបានកំណត់ដោយអំណាចរដ្ឋតែឯកឯងនោះទេ តែជាការរួមបញ្ចូលគ្នារវាង ច្បាប់ នយោបាយ វប្បធម៌ ទំនៀមទំលាប់ ជំនឿ និងឥទ្ធិពលសៀម (ថៃឡង់ដ៍) - យួន (វៀតណាម)។ ប្រព័ន្ធច្បាប់កម្ពុជាក្នុងសម័យកណ្តាល ត្រូវបានកែលម្អ បង្កើត និងដំណើរការដោយអន្លើ ក្រោមការដឹកនាំរបស់ព្រះរាជាខ្មែរជាច្រើនអង្គ ជាពិសេសក្នុងរាជ្យព្រះជៃជេដ្ឋាទី៣ ដែលទ្រង់បានកែលម្អ និងបង្កើតច្បាប់បានច្រើនជាងរាជ្យព្រះរាជាអង្គផ្សេង។ ក្រោយការដួលរលំរាជធានីលង្វែក កម្ពុជាបន្តធ្លាក់ទន់ខ្សោយ និងស្ថិតក្រោមឥទ្ធិពលសៀម និងយួន ម្លោះហើយការអនុវត្តប្រព័ន្ធច្បាប់ខ្មែរនាសម័យកណ្តាល ដំណើរការទៅស្ថិតក្រោមភាពទន់ខ្សោយផ្នែកនយោបាយ និងបាត់បង់អធិបតេយ្យភាពមួយផ្នែក និងត្រូវប្រឈមមុខនឹងសម្ពាធពីខាងក្រៅ ពោលគឺ សៀម និងយួន។ ភាពចុះខ្សោយនេះបាននាំឱ្យមានឥទ្ធិពលពីសៀម និងយួន មកលើការតាក់តែង និងខ្លឹមសារនៃ ក្រមច្បាប់ខ្មែរ ជាពិសេសគឺឥទ្ធិពល សៀម ដែលបង្ហាញពីការសម្របខ្លួនរបស់ខ្មែរទៅនឹងអំណាចក្នុងតំបន់។ ទោះជាយ៉ាងណាក៏ដោយ ច្បាប់ខ្មែរនៅតែរក្សាគុណតម្លៃនិងស្មារតីដើមរបស់ខ្លួន ក្នុងការកសាងច្បាប់ និងអនុវត្តតាមប្រព័ន្ធយុត្តិធម៌តាមទំនៀមបុរាណ ដែលមានភាតព្វកិច្ចច្បាស់លាស់ក្នុងការរក្សាសណ្តាប់ធ្នាប់ក្នុងព្រះនគរ និងការពារផលប្រយោជន៍របស់រាជវង្សានុវង្ស។ ការអនុវត្តន៍ច្បាប់ត្រូវបានកំណត់ដោយគោលការណ៍នៃការថ្លឹងថ្លែងកម្រិតទោសកំហុស យ៉ាងម៉ឺងម៉ាត់ ដោយភ្ជាប់នឹងជំនឿលើកម្មផល ដែលតម្រូវឱ្យអ្នកកាត់ក្តីអនុវត្តដោយយុត្តិធម៌បំផុត។ ការបំពានលើគោលការណ៍នេះអាចនាំឱ្យអ្នកកាត់ក្តីទទួលកម្មផលអាក្រក់ផងដែរ ដែលបង្ហាញពីការផ្សារភ្ជាប់គ្នារវាងអំណាចតុលាការ និងក្រមសីលធម៌សាសនា។

ចំពោះទោសទណ្ឌ មានលក្ខណៈចម្រុះ និងតឹងរ៉ឹងបំផុត ដោយមានការប្រើប្រាស់ឧបករណ៍ធ្វើទារុណកម្មជាក់ស្តែង និងទោសប្រហារជីវិតដ៏សាហាវ។ ទណ្ឌកម្មធ្ងន់ៗរួមមាន វាយព្រាត់លួស (គិតជាដំណំ) ឡើងឈើអណ្តោត (អង្គុយលើបង្គោលស្រួច) វះមាត់ (ចំពោះទោសក្បត់) និងទោសប្រហារជីវិតដោយដោត។ ក្រៅពីការឈឺចាប់ផ្លូវកាយ ក៏មានទណ្ឌកម្មដែលផ្តោតលើការបំផ្លាញកិត្តិយសរបស់ជនល្មើសផងដែរ ដូចជាការវាយបណ្តើរនិងស្រែកអារក្រោស ដើម្បីដាក់ទណ្ឌកម្មលើឋានៈសង្គម និងកេរ្តិ៍ឈ្មោះរបស់ជនល្មើស។ ទោះជាយ៉ាងណាក៏ដោយ ប្រព័ន្ធនេះមានភាពបត់បែនខ្ពស់តាមរយៈយន្តការសម្រាលទោស ដែលអនុញ្ញាតឱ្យជនល្មើស រំលោះទោស ឬសុំអភ័យទោស ដោយបង់ជាប្រាក់ពិន័យ/ជំនួន ដែលចំនួនត្រូវបានកំណត់យ៉ាងជាក់លាក់ទៅតាមបណ្តាសក្តិរបស់ជនរងគ្រោះ ឬមន្ត្រីពាក់ព័ន្ធ។ លើសពីនេះ អភ័យឯកសិទ្ធិពិសេស ត្រូវបានផ្តល់ជូនដល់ ព្រះសង្ឃ និង ពលព្រះ ព្រោះព្រះសាសនា ត្រូវបានលើកតម្កើងថាមានតេជៈស្មើស្តេចផែនដី ដែលបញ្ជាក់ពី ឧត្តមភាពរបស់សាសនាលើច្បាប់រដ្ឋ។

នៅក្នុងនីតិវិធីនៃការកាត់ក្តី តុលាការត្រូវគោរពគោលការណ៍ច្បាប់ក្នុងការកាត់ក្តី ប៉ុន្តែនៅពេលមានស្ថានភាពភស្តុតាងនិងមនុស្សទាល់ច្រក តុលាការបានអនុវត្តការដោះស្រាយវិវាទតាមបែបជំនឿ ដែលជាជម្រើសចុងក្រោយ។ នីតិវិធីទាំងនេះរួមមាន ស្បថធឹកទឹកធម្មារម្យ ស្បថអារកមាន់ ស្បថអកអង្ករ និងដេកក្នុងសីមា ដែលសុទ្ធសឹងពឹងផ្អែកលើការវិនិច្ឆ័យពីកម្លាំងជំនឿ។ ជាក់ស្តែង ព្រះពុទ្ធ ទេព ព្រះធរណី ព្រះភ្លើង អ្នកតា និងអមនុស្ស មានព្រាយ និងបិសាចជាដើម ត្រូវបានអញ្ជើញឱ្យមកធ្វើជាសាក្សី ដើម្បីផ្តល់សច្ចភាពដាច់ខាត ដែលមនុស្សមិនអាចផ្តល់បានឡើយ។ ការទទួលស្គាល់អំណាចវិញ្ញាណក្នុងការវិនិច្ឆ័យនេះ បានបង្ហាញថា ប្រព័ន្ធយុត្តិធម៌ខ្មែរនាសម័យកណ្តាលមានទស្សនៈមួយដែលថា យុត្តិធម៌ពេញលេញ ទាមទារទាំងការវិនិច្ឆ័យរបស់មនុស្ស និងការកាត់ក្តីពីអំណាចដ៏ពិសិដ្ឋ។

សរុបសេចក្តីមក ប្រព័ន្ធច្បាប់កម្ពុជានាសម័យកណ្តាល គឺជាប្រព័ន្ធច្បាប់ទំនៀមបុរាណ ដែលត្រូវបានសង្គមខ្មែរប្រើប្រាស់តំណរមកតាំងពីបុរាណកាល ដោយផ្អែកគោលការណ៍ច្បាប់តឹងរ៉ឹងរបស់រដ្ឋ មានភាពបត់បែនតាមបរិបទសង្គម អំណាច សីលធម៌ទំនៀមទម្លាប់ និងជំនឿរបស់មេដឹកនាំនិងប្រជារាស្ត្រ ដើម្បីរក្សាលំនឹងសង្គម និងជំនឿចិត្តលើប្រព័ន្ធយុត្តិធម៌ដ៏ពិសិដ្ឋ៕

ជំពូកទី១
ស្ថានភាពទូទៅក្នុងសម័យកណ្តាល

សម័យកណ្តាល (ឆ្នាំ១៤៣១ - ១៨៦៣) គឺជាដំណាក់កាលដ៏វឹកវរ និងជូរចត់បំផុតមួយក្នុងប្រវត្តិសាស្ត្រខ្មែរ ដែលផ្ទុយស្រឡះពីសម័យអង្គរដ៏រុងរឿង។ ក្នុងសម័យអង្គរ អំណាចកណ្តាលរបស់ព្រះមហាក្សត្រត្រូវបានបង្រួបបង្រួមយ៉ាងរឹងមាំ លើមូលដ្ឋាននៃច្បាប់ព្រហ្មញ្ញសាសនា (ធម្មសាស្ត្រ) និង រាជបញ្ញត្តិ (អំណាចនៃទេវរាជា) ដែលធានានូវ ***"នីតិរដ្ឋ"*** មួយដ៏មានប្រសិទ្ធភាពក្នុងការគ្រប់គ្រងមហាអាណាចក្រ និងការអនុវត្តគម្រោងការណ៍ធំៗ របស់ព្រះរាជា។ ប៉ុន្តែបន្ទាប់ពីការដួលរលំនៅចុងសម័យអង្គរ និងជាពិសេសក្រោយការបោះបង់ចោលរាជធានីអង្គរនៅឆ្នាំ១៤៣១ ដោយសារកត្តានានា និងការគំរាមកំហែងពីសៀម។ រាជធានីខ្មែរត្រូវបានផ្លាស់ប្តូរទៅកាន់តំបន់ផ្សេងៗ ដូចជាទួលបាសាន ចតុមុខ លង្វែក ឧដុង្គ និងភ្នំពេញ-ចតុមុខ ដែលនាំឱ្យ អំណាចកណ្តាលនៃរាជាធិបតេយ្យធ្លាក់ចុះយ៉ាងគំហុក។ ការបាក់បែកអំណាចនេះបានធ្វើឱ្យ ប្រព័ន្ធច្បាប់ដើមដែលធ្លាប់ចាក់ឫសគល់ក្នុងជំនឿទេវរាជា និងការគ្រប់គ្រងរដ្ឋដ៏រឹងមាំរបស់អង្គរ ត្រូវបានស្រុតចុះ និងរលាយបាត់បង់ទាំងស្រុង ឬចុះខ្សោយខ្លាំង ដោយសារក្រមច្បាប់ចាស់ៗ និងឯកសារនីតិសាស្ត្រ ជាច្រើនត្រូវបានបាត់បង់ ឬត្រូវសត្រូវដុតបំផ្លាញក្នុងសង្គ្រាម។

អស្ថិរភាពដែលជាលក្ខណៈស្នូលនៃសម័យកណ្តាលបានផ្តើមចេញពី ទំនាស់ផ្ទៃក្នុង និងវិបត្តិស្នងរាជ្យនៃរាជវង្សានុវង្សរបស់ខ្មែរផ្ទាល់ ដែលបង្ហាញយ៉ាងច្បាស់ថា ***គ្មាននីតិវិធីច្បាស់លាស់*** ឬ ***ច្បាប់កំពូល*** ណាមួយអាចធានាដល់ការផ្លាស់ប្តូរអំណាចប្រកបដោយសន្តិវិធីឡើយ។ ភាពខ្វះខាតនៃច្បាប់ស្នងរាជ្យនេះបានបើកផ្លូវឱ្យព្រះអង្គម្ចាស់ និងមន្ត្រីជាន់ខ្ពស់នានាបង្កើត ***"វប្បធម៌នយោបាយពឹងបរទេស"*** ដោយរត់ទៅសុំអន្តរាគមន៍យោធាពីប្រទេសជិតខាង ពោលគឺសៀម និង យួន។ ទាំងសៀម និងយួនបានឆ្លៀតឱកាសនេះធ្វើការ ត្រួតត្រាបែងចែក លើកម្ពុជា ដោយសៀមបានកាន់កាប់ខេត្តនៅភាគខាងលិច រួមមានបាត់ដំបង និងសៀមរាប ក្រោមការគ្រប់គ្រងផ្ទាល់តាមរយៈមន្ត្រីចំណុះរបស់ខ្លួន តាំងពីចុងសតវត្សរ៍ទី១៨ និងដើមសតវត្សរ៍ទី១៩ ខណៈដែលយួនបានវាតទីយកដែនដីកម្ពុជាក្រោមបន្តិចម្តងៗ ដោយប្រើប្រាស់យុទ្ធសាស្ត្រអន្តោប្រវេសន៍ និងរហូតដល់ការអនុវត្ត ***"យួនូបនីយកម្ម"*** នាសតវត្សរ៍ទី១៩ ដែលជាការប៉ុនប៉ងរំលាយអត្តសញ្ញាណជាតិ និងរចនាសម្ព័ន្ធរដ្ឋបាលខ្មែរតែម្តង។ ក្នុងស្ថានភាពនេះ ប្រទេសខ្មែរបានក្លាយជា ***"រដ្ឋចុះខ្សោយ"*** និងជាសមរភូមិប្រយុទ្ធគ្នារវាងមហាអំណាចទាំងពីរ ដែលធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាត្រូវបាន

បំផ្លាញ ហេដ្ឋារចនាសម្ព័ន្ធបាក់បែក និងប្រជាជនរងទុក្ខវេទនាពីការជម្លៀស ការកាប់សម្លាប់ និងការអត់ឃ្លាន។

ផលប៉ះពាល់ដ៏ធំបំផុតទៅលើ ប្រព័ន្ធច្បាប់ខ្មែរ គឺការរលាយបាត់នូវប្រព័ន្ធនីតិសាស្ត្របុរាណ និងការបាត់បង់ឯកសារច្បាប់ខ្មែរ។ ការអនុវត្តច្បាប់នៅសម័យកណ្តាលមិនមែនផ្អែកលើ គោលការណ៍យុត្តិធម៌ទេ ប៉ុន្តែផ្អែកលើអំណាច កម្លាំង និងផលប្រយោជន៍នយោបាយរបស់មហាអំណាចត្រួតត្រា។ ជាលទ្ធផល ប្រព័ន្ធនីតិប្រតិបត្តិខ្មែរបានបែកខ្ញែក ទៅជាបំណែកៗតាមតំបន់ដែលត្រូវទទួលរងឥទ្ធិពលនិងអនុវត្តិច្បាប់បរទេស ដូច្នេះហើយនៅតំបន់ភាគខាងលិច រចនាសម្ព័ន្ធតុលាការ ឋានន្តរស័ក្តិមន្ត្រី និងការអនុវត្តច្បាប់រដ្ឋបាលមានភាពស្រដៀងគ្នា ឬចម្លងតាមប្រព័ន្ធច្បាប់សៀម (ដែលអ្នកសិក្សាខ្លះសន្មតថាជាច្បាប់ធម្មសាស្ត្រដែលបានកែសម្រួល) ខណៈដែលនៅតំបន់ភាគខាងត្បូងដែលស្ថិតក្រោមការត្រួតត្រារបស់យួន រដ្ឋបាលតុលាការខ្មែរត្រូវបានលុបចោល ហើយត្រូវបានជំនួសដោយប្រព័ន្ធច្បាប់ និងយុត្តិធម៌របស់រាជវង្សង្វៀន។ ភាពមិនច្បាស់លាស់នេះបានធ្វើឱ្យច្បាប់រដ្ឋបាល និងច្បាប់តុលាការរបស់ខ្មែរនៅរាជធានីឧដុង្គមិនអាចដំណើរការបានពេញលេញលើដែនដីរបស់ខ្លួនឯងឡើយ។ ដូច្នេះ ភាពវឹកវរនៃសម័យកណ្តាល គឺជាវិបត្តិរចនាសម្ព័ន្ធនីតិសាស្ត្រ ដែលបានធ្វើឱ្យកម្ពុជាគ្មានសមត្ថភាពគ្រប់គ្រងប្រទេសដោយច្បាប់ឯករាជ្យខ្លួនឯង ហើយជាកត្តាចម្បងដែលរុញច្រានព្រះមហាក្សត្រខ្មែរ ព្រះបាទនរោត្តម ឱ្យសម្រេចចិត្តចុះហត្ថលេខាទទួលយកអាណាព្យាបាលបារាំង នៅឆ្នាំ១៨៦៣ ដើម្បីរួចផុតពីការត្រួតត្រា និងការបែងចែកទឹកដីខ្មែររវាងសៀម និងយួន។

១.១. ទំនាក់ទំនងរវាង ខ្មែរ - សៀម និង ខ្មែរ - យួន

ទំនាក់ទំនងរវាង ខ្មែរ - សៀម និង ខ្មែរ - យួន ក្នុងសម័យកណ្តាលនេះ ត្រូវបានគេចាត់ទុកថាជាសម័យងងឹតរបស់កម្ពុជា កម្ពុជាក្លាយជារដ្ឋចុះខ្សោយ ក្រោមឥទ្ធិពលរបស់ប្រទេសមហាអំណាចទាំងពីរ ពោលគឺ សៀម និងយួន។ ការប្រជែងឥទ្ធិពលគ្នារវាង សៀម និងយួន លើប្រទេសខ្មែរ បាននាំទៅពើបប្រទះប្រយុទ្ធគ្នាដើម្បីដណ្តើមឥទ្ធិពលលើប្រទេសខ្មែរ លើទឹកដីខ្មែរផ្ទាល់ ដែលបង្កវិនាសកម្មយ៉ាងធ្ងន់ធ្ងរដល់ប្រជារាស្ត្រខ្មែរ។ កម្ពុជាបានបាត់បង់អធិបតេយ្យភាព ហើយត្រូវបានគេប្រៀបធៀបថាជា "កូន" ដែលមាន "សៀមជាឪពុក" និង យួន "ជាម្តាយ" ដែលតែងតែទាញទ្បើងទាញចុះ និងគ្មានស្តេរភាព។

១.១.១. ទំនាក់ទំនងនយោបាយ និងយុទ្ធសាស្ត្រ

សម័យកណ្តាល ត្រូវបានអ្នកប្រវត្តិសាស្ត្រខ្លះហៅថា "សម័យដ៏ខ្មៅងងឹត" សម្រាប់កម្ពុជា ដោយសារតែប្រទេសត្រូវបាត់បង់អធិបតេយ្យភាពស្ទើរទាំងស្រុង ហើយក្លាយជាសមរភូមិសឹកសង្គ្រាម រវាងសៀមនិងយួនប្រយុទ្ធដណ្តើមឥទ្ធិពលគ្នា។

ក. ឥស្សរធម៌នយោបាយពឹងបរទេស និងភាពចលាចល

ជម្លោះដណ្តើមរាជ្យ៖ បន្ទាប់ពីការបាត់បង់រាជធានីអង្គរ (ឆ្នាំ១៤៣១) និងលង្វែក (ឆ្នាំ១៥៩៤) រាជវង្សខ្មែរបានចុះខ្សោយ។ ភាពគ្មាននីតិវិធីច្បាស់លាស់ក្នុងការឡើងគ្រងរាជ្យបានធ្វើឱ្យរាជវង្សបែកបាក់។ ព្រះអង្គម្ចាស់ខ្មែរ ឬសូម្បីតែមន្ត្រីជាន់ខ្ពស់ តែងតែរត់ទៅពឹងពាក់កងទ័ពសៀម ឬកងទ័ពយួន ដើម្បីគាំទ្រការឡើងសោយរាជ្យរបស់ខ្លួន។

ការបាត់បង់ស្វ័យភាព៖ ព្រះមហាក្សត្រដែលឡើងសោយរាជ្យដោយមានការជួយជ្រោមជ្រែងពីសៀម ឬយួន ត្រូវតែធ្វើជារដ្ឋចំណុះ ដោយថ្វាយសួយសារអាករ និងអនុញ្ញាតឱ្យប្រទេសជាឪពុកធម៌នោះ (សៀមជាឪពុក យួនជាម្តាយ) ជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង។

សមរភូមិខ្មែរ-សៀម-យួន៖ ទឹកដីខ្មែរបានក្លាយជាសមរភូមិ ប្រយុទ្ធដោយផ្ទាល់រវាងកងទ័ពសៀមនិងកងទ័ពយួន (ឆ្នាំ១៨៤០-១៨៤៥) ដែលបានធ្វើឱ្យប្រទេសខ្មែរឆេងការបំផ្លិចបំផ្លាញយ៉ាងខ្លាំង និងប្រជារាស្ត្រឆេងទុក្ខវេទនា ឆេងការដុតបំផ្លាញផ្ទះសម្បែង រាំងស្ទះការងារស្រែចំការ រហូតដល់ស្លាប់ដោយសារសង្គ្រាមនេះ និងភាពអត់ឃ្លាន។

ខ. ការបាត់បង់ទឹកដី និងការផ្លាស់ប្តូរប្រជាសាស្ត្រ

ការរុលចូលរបស់យួន (នយោបាយវាតទី)៖ តាមរយៈការរៀបអភិសេករវាងព្រះបាទជ័យជេដ្ឋាទី២ ជាមួយបុត្រីស្តេចយួន ព្រះនាមអង្គចូវ យួនត្រូវបានអនុញ្ញាតឱ្យតាំងទីលំនៅ និងបង្កើតគ្រឹះស្ថានជំនួញ (ក្រសួងគយ) នៅតំបន់ភាគខាងត្បូងខ្មែរ (ព្រៃនគរ កំពង់ក្របី) នៅឆ្នាំ១៦២៣។ នេះជាការបើកផ្លូវឱ្យយួនរុលចូលកាន់កាប់បន្តិចម្តងៗនូវដែនដីកម្ពុជាក្រោមទាំងមូល ជាពិសេសនៅសតវត្សរ៍ទី១៧ និងទី១៨។

ការរឹបអូសរបស់សៀម៖ សៀមបានកាន់កាប់ខេត្តនានានៅភាគខាងលិចជាបន្តបន្ទាប់។ នៅក្នុងឆ្នាំ១៨៤៧ ពេលដែល ព្រះបាទអង្គអេង ត្រូវឡើងសោយរាជ្យក្រោមការគាំទ្ររបស់សៀម សៀមបានកាត់យកខេត្តបាត់ដំបង និងសៀមរាប ទៅគ្រប់គ្រងផ្ទាល់ ដាក់ឱ្យចៅពញាអភ័យភូបេត ជាអភិបាលកម្ពុជាក្រោមការគ្រប់គ្រងរបស់សៀម។

នយោបាយ "យួនូបនីយកម្ម" (Vietnamization)៖ នៅដើមសតវត្សរ៍ទី១៩ ជាពិសេសក្នុងរជ្ជកាល អធិរាជមិញម៉ាង យួនបានព្យាយាមរំលាយអត្តសញ្ញាណជាតិខ្មែរ ដោយដាក់ឈ្មោះតំបន់ខ្មែរទៅជាខេត្តយួន បង្ខំឱ្យមន្ត្រីខ្មែរស្លៀកពាក់តាមរបៀបយួន ប្រើប្រាស់រដ្ឋបាលយួន និងបង្រៀនភាសាយួន។

១.១.២. ឥទ្ធិពលលើប្រព័ន្ធច្បាប់ និងរដ្ឋបាលខ្មែរ

ផលវិបាកនៃការជ្រៀតជ្រែកនេះបានធ្វើឱ្យប្រព័ន្ធច្បាប់ខ្មែរ និងប្រព័ន្ធរដ្ឋបាលដែលធ្លាប់មានមូលដ្ឋានលើរាជក្រឹត្យ រាជអាជ្ញា និងច្បាប់ទំនៀមខ្មែរ បានធ្លាក់ចុះខ្សោយ និងទទួលឥទ្ធិពលពីសៀម និងយួន។

ក. ការចុះខ្សោយនៃប្រព័ន្ធនីតិរដ្ឋ

ការបាត់បង់ក្រមច្បាប់ចាស់៖ ក្រោយការដួលរលំនិងបែកបាក់រាជធានីជាច្រើនលើកគិតចាប់ពីក្រោយសម័យអង្គរ ឯកសារនានា (រួមទាំងក្រមច្បាប់ដើម) ត្រូវបានបាត់បង់ និងវិនាស ដោយកត្តាការប្រមូលយកឯកសារ ការកៀរយកមនុស្ស និងការដុតបំផ្លាញ ក្រោមថ្វីដៃសៀម និងយួន។ ទោះបីមានការព្យាយាមចងក្រងឡើងវិញនូវក្រមច្បាប់ ក្នុងរាជ្យក្នុងរាជ្យព្រះមហាក្សត្រខ្មែរក្រោយៗ និងជាពិសេសក្នុងរាជ្យព្រះជ័យជេដ្ឋាទី ៣ ដែលទ្រង់បានកសាងឡើងវិញនូវក្រមច្បាប់ខ្មែរច្រើន ក៏ទំនងក្រមច្បាប់ថ្មីទាំងនោះមានលក្ខណៈពុំដូច និងពេញលេញដូចទៅនឹងក្រមច្បាប់ខ្មែរពីបុរាណឡើយ។

អវត្តមាននីតិវិធីឡើងរាជ្យ៖ ការដណ្តើមរាជ្យគ្នាយ៉ាងអាណាធិបតេយ្យរវាងរាជវង្សានុវង្ស បង្ហាញឱ្យឃើញថា គ្មាននីតិវិធីច្បាស់លាស់ ឬគ្មានច្បាប់កំពូលណាមួយដែលអាចទប់ស្កាត់ជម្លោះផ្ទៃក្នុងនេះបានឡើយ។

ខ. ឥទ្ធិពលច្បាប់ និងរដ្ឋបាលសៀម

ឥទ្ធិពលសៀមលើរដ្ឋបាលខ្មែរនៅសម័យឧដុង្គគឺមានទំហំធំធេង ជាពិសេសផ្នែករដ្ឋបាលតុលាការ និងឋានន្តរស័ក្តិ។

រចនាសម្ព័ន្ធឋានន្តរស័ក្តិ៖ ឋានន្តរស័ក្តិមន្ត្រីខ្មែរមួយចំនួននៅសម័យនេះ ដែលជាប្រព័ន្ធរដ្ឋបាល ចតុស្តម្ភ រួមមាន ឧកញ៉ាយមរាជ ឧកញ៉ាវាំង ឧកញ៉ាក្រឡាហោម ឧកញ៉ាចក្រី ត្រូវបានគេជឿថាបានទទួលឥទ្ធិពល និងភាពស្រដៀងគ្នាខ្លាំងពីប្រព័ន្ធឋានន្តរស័ក្តិរបស់សៀមសម័យអយុធ្យា សម័យក្រុងធនបុរី និងសម័យក្រុងទេពមហានគរ។

ការអនុវត្តច្បាប់៖ នៅក្នុងតំបន់ភាគខាងលិច មានខេត្តបាត់ដំបង និងសៀមរាប ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់របស់សៀម ការអនុវត្តច្បាប់រដ្ឋបាល យុត្តិធម៌ និងការកាត់ក្តីបានប្រើប្រាស់ប្រព័ន្ធសៀម ដែលជាហេតុធ្វើឱ្យប្រព័ន្ធច្បាប់ខ្មែរបែកខ្ញែកគ្នាតាមតំបន់។

គ. ការគ្រប់គ្រងផ្ទាល់ និងការរំលាយច្បាប់ខ្មែរដោយយួន

វប្បធម៌នយោបាយពឹងបរទេស បាននាំមនូវផលវិបាកផ្នែកនយោបាយ ទំនាស់ក្នុងរាជ្យវង្សានុវង្ស និងសង្គ្រាមរ៉ាំរ៉ៃ។ ការលូកដៃចូលរបស់យួនក្នុងកិច្ចការផ្ទៃក្នុងរបស់ខ្មែរ ធ្វើឱ្យអំណាចយួនលើប្រទេសខ្មែរសង្កត់ខ្មែរកើខ្លួនលែងរួច ម្ល៉ោះហើយ រដ្ឋអំណាចយួនកាន់តែយោរយៅក្នុងគោលដៅយួនូបនីយកម្ម រំលាយវប្បធម៌ខ្មែរ រំលាយរដ្ឋបាល និងច្បាប់ខ្មែរ ធ្វើយ៉ាងណាឱ្យប្រព័ន្ធដើមរបស់ខ្មែររលាយ និងដាក់ជំនួសវិញនូវប្រព័ន្ធយួន។

ការលុបបំបាត់រដ្ឋបាលខ្មែរ៖ ក្នុងពេលយួនធ្វើយួនូបនីយកម្ម ពួកគេបានលុបចោលរដ្ឋបាលខេត្តខ្មែរ ហើយបញ្ចូលទៅក្នុងប្រព័ន្ធខេត្តរបស់យួនផ្ទាល់។ យួនបានដាក់មន្ត្រីយួនឱ្យគ្រប់គ្រងផ្ទាល់ និងជំនួសឱ្យមន្ត្រីខ្មែរ ដោយរំលាយស្ថាប័នគ្រប់គ្រងរបស់ខ្មែរ។

ការរងទុក្ខរបស់ពលរដ្ឋ៖ ក្នុងសម័យ "តែអុង" ឬសម័យដែលយួនគ្រប់គ្រងតំបន់កណ្តាលខ្លះ ប្រជាជនខ្មែរត្រូវបានធ្វើទុក្ខបុកម្នេញយ៉ាងខ្លាំង ដូចជាការកប់មនុស្សទាំងរស់ដើម្បីធ្វើជើងចង្រ្កានជាំតែឱ្យមេទ័ពយួនឈ្មោះ អុង ដែលបានក្លាយជាជំណាល "តែអុង" ការនេះបង្ហាញថា ច្បាប់ និងយុត្តិធម៌ខ្មែរ ត្រូវបានជាន់ឈ្លី ដោយអំណាចឈ្លានពានរបស់យួន។

សរុបមក ទំនាក់ទំនងខ្មែរ សៀម និងយួននៅសម័យកណ្តាល មិនមែនគ្រាន់តែជាបញ្ហានយោបាយ និងសង្គ្រាមប៉ុណ្ណោះនោះទេ តែវាជាកត្តាដែលបាននាំទៅរកការបំផ្លាញនូវអធិបតេយ្យភាពច្បាប់ និងរចនាសម្ព័ន្ធរដ្ឋបាលរបស់ខ្មែរ ដែលជាមូលហេតុធ្វើឱ្យកម្ពុជាពិបាកស្តារអភិវឌ្ឍខ្លួនឡើងវិញ រហូតដល់សម័យអាណ្យាបាល - អាណានិគមបារាំង។

១.២. ការរៀបចំប្រទេសជាតិឡើងវិញ

១.២.១. នយោបាយក្នុងប្រទេស

១.២.១.១. ការរៀបចំរាជធានី

ព្រះរាជា ដែលសោយរាជ្យបន្តបន្ទាប់គ្នាទ្រង់បានគង់នៅទួលបាសាន (ស្រីសន្ធរ) មួយរយៈពេលខ្លី និងបន្ទាប់មកទៀតបោះទីតាំងនៅក្នុងរាជធានី ៣ សំខាន់ គឺ និង

ភ្នំពេញចតុម្មុខ រាជធានីលង្វែក និងរាជធានីឧដុង្គ។ តាមព័ត៌មានដែលឯកសារផ្សេងៗ បានផ្តល់ និងតាមដែលយើងពិនិត្យសព្វថ្ងៃនេះ ឃើញថាទីតាំងនៃរាជធានីទាំងនោះ សុទ្ធតែជាចំណុចយុទ្ធសាស្ត្រដែលមានប្រជារាស្ត្រច្រើន ស្ថិតនៅជិតទន្លេ បឹង និងព្រៃ សម្រាប់ការពារខ្លួនបានស្រួល។ ម្យ៉ាងទៀតរាជធានីនីមួយៗ សុទ្ធតែមានកំពែង និងគូ ឬ អូរព័ទ្ធជុំវិញ ហើយបន្ទាយ មានឫស្សីច្រើនកន្លែងសម្រាប់ការពារទៀតផង។

រាជធានី ភ្នំពេញចតុម្មុខ (ទី១) ដែលត្រូវបានបង្កើតឡើងដោយ ព្រះបាទពញាយ៉ាត នៅគ្រិស្តសតវត្សរ៍ទី១៥ មានទីតាំងភូមិសាស្ត្រដ៏ល្អឥតខ្ចោះ និងមានលក្ខណៈពិសេសប្លែកពីគេ គឺស្ថិតនៅត្រង់ទន្លេចតុម្មុខ។ "ចតុម្មុខ" មានន័យថា "មុខបួន" សំដៅដល់ទីប្រសព្វដ៏ធំនៃទន្លេបួនខ្សែគឺ៖ ទន្លេមេគង្គលើ ទន្លេមេគង្គក្រោម ទន្លេសាប និងទន្លេបាសាក់។ ទីតាំងនេះត្រូវបានជ្រើសរើសជាទីតាំងយុទ្ធសាស្ត្រ ដោយសារតែជាតំបន់ដីទួលខ្ពស់ត្រើយខាងលិចទន្លេ ដែលចៀសផុតពីគ្រោះទឹកជំនន់ធំ (ដែលធ្លាប់បង្ខំឱ្យព្រះអង្គផ្លាស់រាជធានីពីទួលបាសាន)។ លក្ខណៈភូមិសាស្ត្រនេះបានផ្តល់អត្ថប្រយោជន៍ដ៏ធំធេងទាំងផ្នែក យុទ្ធសាស្ត្រការពារ និងផ្នែកសេដ្ឋកិច្ចពាណិជ្ជកម្ម ដោយសារជាមជ្ឈមណ្ឌលដឹកជញ្ជូន និងទីផ្សារកណ្តាលដ៏សំខាន់ ភ្ជាប់ពីតំបន់ខាងលើទៅតំបន់ខាងក្រោម និងចេញទៅសមុទ្រ។ លើសពីនេះ រាជធានីនេះក៏ត្រូវបានសាងសង់ឡើងនៅក្បែរ ភ្នំតូច មួយគឺ វត្តភ្នំដូនពេញ (បច្ចុប្បន្ន វត្តភ្នំ) ដែលបានក្លាយជាចំណុចកណ្តាលខាងជំនឿ និងវប្បធម៌។

រាជធានីលង្វែក ជាអតីតរាជធានីរបស់កម្ពុជានាសម័យកណ្តាល ដែលត្រូវបានជ្រើសរើសនិងកសាងធ្វើជារាជធានី ដោយព្រះបាទអង្គចន្ទទី១ ដោយសារទីតាំងនេះមានលក្ខណៈភូមិសាស្ត្រដ៏រឹងមាំ និងមានយុទ្ធសាស្ត្រក្នុងការការពារ។ ទីក្រុងនេះមានទីតាំងស្ថិតនៅចម្ងាយប្រមាណ ៤០គីឡូម៉ែត្រ ភាគឦសាននៃរាជធានីភ្នំពេញបច្ចុប្បន្ន ស្ថិតនៅក្នុងស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង ដែលស្ថិតនៅត្រើយខាងលិចនៃទន្លេសាប។ លក្ខណៈពិសេសនៃទីតាំងនេះគឺស្ថិតនៅចន្លោះផ្លូវទឹកយុទ្ធសាស្ត្រដ៏សំខាន់ ដោយនៅភាគខាងត្បូងភ្ជាប់ទៅនឹងតំបន់ចតុម្មុខ (ភ្នំពេញ) និងនៅភាគខាងជើងភ្ជាប់ទៅបឹងទន្លេសាប និងតំបន់អង្គរ។ ទីតាំងនេះជាចំណុច ផ្លូវបំបែក ឬចំណុចប្រសព្វ ដែលសាកសមនឹងឈ្មោះថា "លង្វែក" ឬ "ល្វែក" ដែលផ្តល់ភាពងាយស្រួលទាំងផ្លូវគោក និងផ្លូវទឹក។ ទីក្រុងលង្វែកត្រូវបានកសាងឡើងជារាងចតុកោណ (បណ្តោយប្រហែល ៣ គីឡូម៉ែត្រ និងទទឹង ២ គីឡូម៉ែត្រ) ព័ទ្ធជុំវិញដោយកំពែងដីដ៏មាំមួននិងគូទឹកជាច្រើនជាន់ ក៏ដូចជារបងឫស្សីក្រាស់ៗ ដែលបានបង្កើតជាឧបសគ្គធម្មជាតិ និងសិប្បនិម្មិតដ៏រឹងមាំបំផុតសម្រាប់ទប់ទល់នឹង

ការឈ្លានពានពីខាងក្រៅ។ សរុបមក ភូមិសាស្ត្រលង្វែកត្រូវបានគេចាត់ទុកជាតំបន់យុទ្ធសាស្ត្រការពារ ដ៏ល្អបំផុតដោយមានបឹង ទន្លេ និងព្រៃឈើជាខែលធម្មជាតិ ហើយអាចគ្រប់គ្រងលើផ្លូវពាណិជ្ជកម្មតាមដងទន្លេបានយ៉ាងមានប្រសិទ្ធភាព។

រាជធានីឧដុង្គ ដែលជាអតីតរាជធានីនៃព្រះរាជាណាចក្រកម្ពុជានាសម័យក្រោយអង្គរ (ឆ្នាំ១៦១៨-១៨៦៦) ត្រូវបានកសាងឡើងនៅលើទីតាំងភូមិសាស្ត្រដ៏មានយុទ្ធសាស្ត្រមួយ ដែលមានចម្ងាយប្រមាណ ៤០ គីឡូម៉ែត្រ ភាគពាយព្យនៃរាជធានីភ្នំពេញបច្ចុប្បន្ន។ ភូមិសាស្ត្រនៃទីក្រុងនេះមានលក្ខណៈពិសេស ដោយសារទីក្រុងទាំងមូលត្រូវបានកសាង និងអភិវឌ្ឍដោយយក ភ្នំឧដុង្គ (ឬ ភ្នំព្រះរាជទ្រព្យ) ជាចំណុចកណ្តាល។ ភ្នំនេះដើរតួជាកន្លែងស័ក្តិសិទ្ធិសម្រាប់តម្កល់ព្រះចេតិយរបស់ព្រះមហាក្សត្រខ្មែរ ហើយផ្តល់នូវលទ្ធភាពការពារ និងទិដ្ឋភាពដ៏ល្អសម្រាប់មើលទៅបរិវេណជុំវិញ។ តំបន់ជុំវិញភ្នំភាគច្រើនជា ដីវាលទំនាប ដែលមានដីជាតិល្អ សម្បូរទៅដោយវាលស្រែ និងបណ្តាញទឹកធម្មជាតិ ដែលងាយស្រួលសម្រាប់ការដាំដុះ និងទ្រទ្រង់ជីវភាពប្រជារាស្ត្រក្នុងទីក្រុង។ ក្រៅពីនេះ ឧដុង្គក៏មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយ ទន្លេសាប នៅប៉ែកខាងកើត ដែលមានកំពង់ផែដ៏សំខាន់ឈ្មោះ កំពង់ហ្លួង សម្រាប់ធ្វើពាណិជ្ជកម្ម និងទំនាក់ទំនងជាមួយរាជធានីលង្វែកចាស់ និងបណ្តាប្រទេសជិតខែ្ទៀត។ ទីតាំងរួមរបស់ឧដុង្គគឺស្ថិតនៅក្នុងតំបន់ក្បែរព្រំប្រទល់នៃខេត្តកំពង់ស្ពឺ ខេត្តកណ្តាល និងខេត្តកំពង់ឆ្នាំងបច្ចុប្បន្ន ដែលបង្ហាញពីតួនាទីជាមជ្ឈមណ្ឌលតភ្ជាប់ដ៏សំខាន់មួយក្នុងប្រវត្តិសាស្ត្រខ្មែរ។

១.២.១.២. ការរៀបចំរដ្ឋបាលកណ្តាល

ដោយហេតុថាព្រះរាជា ជាប្រភពនៃអំណាចទាំងឡាយ ហើយពួកបរិវាររបស់ព្រះអង្គសុទ្ធតែជារាជវង្សានុវង្ស និងមន្ត្រីជាន់ខ្ពស់ផងនោះ គេអាចយល់បានថា ពួកបរិវារនេះហើយ ជាអ្នកញុំាងឱ្យរដ្ឋបាលកណ្តាលអាចប្រព្រឹត្តទៅបានដោយរលូន។ ដូចយើងបានរៀបរាប់រួចមកហើយ អំពីព្រះរាជបរិវារយើញថាបន្ទាប់ពីស្តេចទ្រង់រាជ្យមក មានឧកយោរាជ ឧបរាជ ឬមហាឧបរាជ ព្រះវររាជមាតា វររាជអយ្យកា ចៅហ្វាទឡ្ហៃ និងមន្ត្រីជាន់ខ្ពស់ ៤រូប ដែលគេនិយាយហៅថា *"ចតុស្តម្ភ"* គឺ៖

ឧកញ្ញាយមរាជ (រដ្ឋមន្ត្រីក្រសួងយុត្តិធម៌)
ឧកញ្ញាក្រឡាហោម (រដ្ឋមន្ត្រីក្រសួងទំពជើងទឹក)
ឧកញ្ញាវាំង (រដ្ឋមន្ត្រីក្រសួងព្រលបរមរាជវាំង)
ឧកញ្ញាចក្រី (រដ្ឋមន្ត្រីខាងទំពជើងគោក)

ដូច្នេះចៅហ្វាទឡ្ហៈ និងមន្ត្រីជាន់ខ្ពស់ទាំង ៤រូបនេះ ប្រៀបបាននឹងគណៈរដ្ឋមន្ត្រីសព្វថ្ងៃ ដែលពីដើមគេនិយមហៅថា "សេនាបតី"។ មន្ត្រីជាន់ខ្ពស់ទាំង ៥រូបនេះគេហៅថា មន្ត្រីសម្រាប់ឯក គឺជាមន្ត្រី ដែលត្រូវឡើងទៅព្រះមហាក្សត្រ។ មន្ត្រីទាំងនេះ មានមុខងារញុំាងឱ្យរដ្ឋបាលកណ្តាលអាចប្រព្រឹត្តទៅផង ហើយមានអំណាចត្រួតត្រាលើខេត្តដែលខ្លួនគ្រប់គ្រងផង។

ក្រៅពីនេះមាន **មន្ត្រីសំរាប់ឆោ** ត្រូវឡើងទៅព្រះឧកញោរាជ
មន្ត្រីសំរាប់ត្រី ត្រូវឡើងទៅព្រះឧបរាជ ឬមហាឧបរាជ
មន្ត្រីសំរាប់ចត្វា ឡើងទៅព្រះវររាជមាតា ឬព្រះវររាជអយ្យការ។

មន្ត្រីទាំង៤សំរាប់នេះ លើកលែងចៅហ្វាទឡ្ហៈចេញ ដែលមានឋានន្តរសក្តិជាសម្តេចចៅពញា សុទ្ធតែមានឋានន្តរសក្តិ ជាឧកញ៉ាសក្តិ ១០ហ៊ូពាន់ (ហ៊ូពាន់៖ពាក្យសៀមមានន័យថាក្បាលពាន់ គឺទំព១០០០នាក់ ដែលនៅក្រោមបង្គាប់របស់មន្ត្រីណាម្នាក់)។ ក្រៅពីមន្ត្រីជាន់ខ្ពស់ទាំងប៉ុន្មានដូចរៀបរាប់ រួចមកហើយនេះ គេ ឃើញមានមន្ត្រីជាន់កណ្តាល និងជាន់ទាបជាច្រើនទៀត ដែលមានឋានន្តរសក្តិ ដូចតទៅ៖

ព្រះ មានសក្តិ ៦ហ៊ូពាន់
ហ្លួង មានសក្តិ ៥ហ៊ូពាន់
ឃុនម៉ឺន មានសក្តិ ៤ហ៊ូពាន់
ឧកម៉ឺន មានសក្តិ ៣ហ៊ូពាន់
ចម៉ឺន មានសក្តិ ២ហ៊ូពាន់
ម៉ឺន មានសក្តិ១ហ៊ូពាន់

ចំណែកឯខ្ញុំរាជការ ដែលមិនទាន់បានទទួលយសសក្តិនៅឡើយទេនោះឱ្យហៅថា នាយ ។

១.២.១.៣. ការបែងចែករដ្ឋបាលដែនដី/រដ្ឋបាលភូមិភាគ

នៅសម័យនេះប្រទេសខ្មែរយើងលែងជាមហាអំណាចខាងទឹកដីទៀតហើយ ទឹកដីជាន់ក្រៅ ដូចជាសុខោទ័យ ស្រីអយុធ្យា លពបុរី គោត្របុរ (កិម៉ាយ) ត្រូវបាត់បង់អស់ហើយឯប្រទេសសាមន្តរដ្ឋ ដូចជា ចម្ប៉ា អាណ្ណាម ជ្វា និងមន ក៏លែងមានទៀតដែរ។ ព្រំដែនខាងជើងរបស់ខ្មែរ ធ្លាក់មកត្រឹមទន្លេមូល ឬនៅលើនេះបន្តិចជាប់នឹងប្រទេសលាវ។

ព្រំដែនខាងលិចទល់នឹងបស្ចិមបុរី និងរយ៉ង ខាងពាយ័ព្យទល់នឹងនាងរង និងនគរាជ ខាងកើតទល់នឹងប្រទេសចម្ប៉ា ខាងត្បូងទល់នឹងសមុទ្រចិន និងឈូងសមុទ្រសៀម។

បើតាមរាជវង្សាវតាព្រះរាជាណាចក្រខ្មែរ សម័យនោះ មានប្រមាណជា ៧០ខេត្ត គឺលង្វែក អម្រិន្ទបុរ ក្រគរ គ្រង ពោធិសាត់ បាត់ដំបង ឬស្សីសាញ តាមសីមា មង្គលបូរី រយ៉ង សុរិន្ទ សិង្គារ កំពង់សៀម ស្ទឹងត្រែង ជើងព្រៃ គោកសេះ អន្លង់រាជ ព្រំទេព ព្រៃក្តី ស្នោង ជីក្រែង រលួស សៀមរាប កំពង់ស្វាយ ម្លូព្រៃ ជាំក្សាន្ត ត្នោត ទឹកជោរ សៀមបូក សម្បុកសម្បូណ៌ ក្រចេះ ឆ្លូង ត្បូងទទឹងថ្ងៃ ព្រៃវែង ត្បូងឃ្មុំ រំដួល ស្វាយទាប រោងដំរី ព្រៃនគរ លង់ហោ ជើងបាដែន សំរោងទង បាទី លើកដែក កំពត កំពង់សោម ទឹកខ្មៅ ពាម មេសា ព្រះត្រពាំង ក្រមួនស និងដូនណៃ ។ល។

គួរកត់សំគាល់ថាក្នុងចំណោមខេត្តទាំងប៉ុន្មាននេះ ខេត្តខ្លះនៅមានឋានៈជាខេត្ត រហូតមកដល់សព្វថ្ងៃនេះ ដូចជា ពោធិសាត់ បាត់ដំបង ស្ទឹងត្រែង សៀមរាប ក្រចេះ ព្រៃវែង ។ល។ ឯខេត្តខ្លះទៀត ធ្លាក់ឋានៈមកជាស្រុកវិញ ដូចជា មង្គលបូរី ស្នោង ជីក្រែង រលួស ទឹកជោរ ។ល។ ឯខេត្តខ្លះទៀត ត្រូវបាត់ឈ្មោះរលាយចូលនឹងខេត្តឯទៀតអស់ទៅ។

ខេត្តនីមួយៗ ត្រូវបែងចែក ជាស្រុក ហើយស្រុកនីមួយៗ ត្រូវបែងចែកជាឃុំ និងភូមិជាច្រើនទៅទៀត។ ប៉ុន្តែខេត្តជាច្រើន ត្រូវបានប្រមូលផ្តុំជាតំបន់ធំៗ ដែលគេឱ្យឈ្មោះថា ***"ដែនជី"***។ ក្នុងដែនជីនីមួយៗ មានស្តេចក្រាញ់មួយអង្គឈរត្រួតត្រា ដួនកាលហៅថាស្តេចត្រាញ់ក៏បាន ពាក្យនេះ ទំនងជាក្លាយមកពីពាក្យបុរាណម្រតាញ ដែលមានប្រើក្នុងសិលាចារឹកខ្មែរ។ ស្តេចក្រាញ់មួយអង្គៗ មាននាទីគ្រប់គ្រងតំបន់ផង ហើយមាននាទីគ្រប់គ្រងខេត្តរបស់ខ្លួនផ្ទាល់ផង។ បើតាមឯកសាររាជពង្សាវតាខ្មែរក្នុងរជ្ជកាលព្រះបាទធម្មរាជាទី១ មានការតែងតាំងស្តេចក្រាញ់ ៥អង្គគឺ៖

ពញាតេជោ ចៅហ្វាយស្រុកខេត្តកំពង់ស្វាយ១
ពញាសួគ៌ាលោក ចៅហ្វាយស្រុកខេត្តពោធិសាត់១
ពញាស្រីធម្មាតេជោ ចៅហ្វាយស្រុកខេត្តបាភ្នំ១
ពញាពិស្ណុលោក ចៅហ្វាយស្រុកខេត្តទ្រាំង១
ពញាអរជូន ចៅហ្វាយស្រុកខេត្តត្បូងឃ្មុំ១

ដូចបានពោលមកហួចខាងលើនេះ យើងឃើញថាក្នុងខេត្តនីមួយៗ មានមន្ត្រីជាន់ខ្ពស់ម្នាក់ឈរ ត្រួតត្រា។ មន្ត្រីនេះគេនិយមហៅថា ***"ចៅហ្វាយស្រុក"*** ឧទាហរណ៍មន្ត្រីឈរត្រួតត្រាខេត្តទ្រាំងគេ ហៅថា ***"ចៅហ្វាយស្រុកខេត្តទ្រាំង"*** ជាដើម។ តាមប្រកពារាជពង្សាវ

តាខ្មែរដដែលគេ ដឹងថាចៅហ្វាយស្រុក សុទ្ធតែមានសក្តិ១០ ឬ៩ហ៊ូពាន់ពីបុរាណរៀងមក តាំងឡើងសុទ្ធតែជា ***សម្តេចចៅពញា*** ព្រោះ ចៅហ្វាយ ស្រុកទាំងនោះ សុទ្ធតែជាប់ព្រះញាតិនៃព្រះរាជា តែក្រោយមកចៅហ្វាយស្រុកទាំងនោះ ច្រើនតែពុំសូវគោរព កោតខ្លាច ***សេនាបតី*** ទើបត្រូវទម្លាក់មកនៅត្រឹមតែ ***ចៅពញា***។

គួរគប្បីជ្រាបដែរថា ***ចៅពញា*** នេះក៏ជាឋានន្តរសក្តិរបស់បុត្រស្តេចទ្រង់រាជ្យដែរ ដូចជា៖ ចៅពញាដាំខាត់រាជា ចៅពញាចន្ទរាជា ចៅពញាអន ចៅពញាញោម ។ល។ បើចៅហ្វាយស្រុកណា ដែលមានសក្តិ៨ ឬ៩ហ៊ូពាន់ ត្រូវតាំងជា ***ពញា*** ។

ខេត្តនីមួយៗ ត្រូវបែងចែកជាច្រើនស្រុក ដែលគ្រប់គ្រងដោយ ***មេស្រុក*** ហើយស្រុកនីមួយៗ ទំនងជាត្រូវចែកជាឃុំ ជាភូមិ ដែលមានមេឃុំ និងមេភូមិ ជាអ្នកគ្រប់គ្រង។

១.២.២. ទំនាយក្រៅប្រទេស

នៅគ្រានោះខ្មែរ មិនទាន់មានកង្វល់នៅតាមព្រំដែនខាងកើតនៅឡើយទេ ព្រោះប្រទេសចម្ប៉ា កំពុងជាប់ច្បាំងជាមួយយួនពួកង្វៀង ដែលបានលេបទឹកដីរបស់រាជាណាចក្រនេះបន្តិចម្តងៗ ហើយក្រោយមកពួកអាណ្ណាម បានជ្រៀតចូលប្រទេសខ្មែរតាមការស្នើរបស់ព្រះរាជាខ្មែរ ក្រោយៗទៀត។ ប៉ុន្តែនៅតាម ព្រំដែនខាងលិចព្រះរាជាខ្មែរ ត្រូវព្យាយាមវាយរំដោះទឹកដី ដែលត្រូវបានបាត់បង់ទៅតាំងពីសតវត្សទី១៣ រៀងមក។ ក្នុងគោលបំណងនេះហើយ ដែលព្រះស្រីរាជា ព្រះចន្ទរាជា ព្រះបរមរាជាទី៤ និងព្រះសត្ថាទី ១ បានលើកទ័ពទៅវាយលុករហូតដល់រាជធានីស្រីអយុធ្យា ២លើក គឺនៅឆ្នាំ១៥៥៧ និងឆ្នាំ១៥៦៩ និងពេលនោះភូមា បានវាយយកនិងដាក់ប្រទេសសៀមជាចំណុះអស់រយៈពេលជាច្រើនឆ្នាំទៀតផង ហើយស្តេចខ្មែរ ចេះឆ្លៀតឱកាស ដែលសត្រូវកំពុងតែទន់ខ្សោយ ក៏លើកទ័ពទៅវាយយកបន្ថែមទៀត ហើយអាចរំដោះយកបានទឹកដីដែលបាត់បង់មួយចំនួនមកវិញ។

ត្រង់ចំណុចនេះ ឯកសារអឺរ៉ុបនិយាយថាខ្មែរ បានធ្វើសម្ព័ន្ធមិត្តជាមួយភូមា ដើម្បីវាយសៀម ប៉ុន្តែឯកសារខ្មែរ មិនបាននិយាយដល់រឿងនេះទេ។ ប្រភពអឺរ៉ុបដដែលបានបន្ថែមថា ក្រោយមកខ្មែរបានងាកទៅចងសម្ព័ន្ធមេត្រីជាមួយសត្រូវរបស់ខ្លួនវិញ(សន្ធិសញ្ញាខ្មែរ-សៀមឆ្នាំ១៥៧៤ ឬឆ្នាំ១៥៧៦ព្រះសត្ថាទី១ បញ្ជាឱ្យស្រីសុរិយោពណ៌ លើកទ័ពទៅជួយសៀមវាយឈ្នះភូមា) ប៉ុន្តែមិនបានផលល្អ ព្រោះក្រោយពីបានរំដោះខ្លួនពីចំណុះភូមាមក សៀម តែងលើកទ័ពចូលមកវាយខ្មែរជាញឹកញាប់ដោយចោទថា ខ្មែរមិនរក្សាពាក្យសច្ចៈ។ ការពិតសៀម ធ្វើនេះក្នុងន័យពង្រីកទឹកដីរបស់គេតែប៉ុណ្ណោះ។ ម្លោះ

ហើយនៅចំពោះមុខ គ្រោះថ្នាក់ ដែលតែងតែគំរាមកំហែងមកលើប្រទេសជាតិ ព្រះរាជាខ្មែរ ចាប់ពីព្រះសត្ថាទី១ រៀងមក បានងាកទៅរកជំនួយពីពួកព័រទុយហ្គាល ហើយក្រោយមកពី ពួកអេស្ប៉ាញទៀត។ ព្រះអង្គទ្រង់ បានយកចិត្ត អ្នកផ្សាយសាសនាអឺរ៉ុបយ៉ាងខ្លាំង ដើម្បីឱ្យ ពួកគេជួយធ្វើអន្តរាគមន៍សុំជំនួយទ័ពមកប្រឆាំងនឹងសៀម។ ព្រះអង្គទ្រង់ បានសន្យាថា នឹងបើកសិទ្ធិឱ្យពួកនេះផ្សាយសាសនាគ្រិស្តគ្រប់ទិសក្នុងព្រះរាជាណាចក្រ ហើយព្រះអង្គ ជួយសង់ព្រះវិហារ និងផ្តល់ទេយ្យទាន មានអង្គរ ជាដើមដល់ពួកនេះ។ ពួកអេស្ប៉ាញ នៅ ក្រុងម៉ានីល មានបំណងមកតាំងអាណាព្យាបាលលើប្រទេសខ្មែរ ហើយបានបញ្ជូនទ័ព និង អ្នកផ្សាយសាសនា មកប្រទេសខ្មែរជាច្រើនលើក តែពុំបានសំរេចដូចប្រាថ្នាទេ។

នៅទីបំផុតព្រះស្រីសុរិយោពណ៌ ដែលត្រូវទ័ពសៀមចាប់នាំយកទៅក្រុងអយុធ្យា បានត្រលប់ចូលមកប្រទេសខ្មែរវិញដោយនាំយកឥទ្ធិពលរបស់សៀមមកផ្សាយទៀតផង។

គួរគប្បីបញ្ជាក់ថាពួកសៀម ដែលកាន់ព្រះពុទ្ធសាសនា ដូចខ្មែរដែរនោះ បាន ប្រឆាំងយ៉ាងខ្លាំង ចំពោះការប៉ុនប៉ងផ្សាយសាសនារបស់ជនជាតិអឺរ៉ុប ជាពិសេសក្នុង រជ្ជកាលរបស់ព្រះនរេសួរ។

១.៣. ប្រភពច្បាប់ខ្មែរ

ទោះបីលទ្ធិទេវរាជ ត្រូវខ្មែរបោះបង់ចោលជាស្ថាពរតាំងពីបដិវត្តន៍នាយត្រសក់ ផ្អែមមកម្ល៉េះ ក៏ដោយ ក៏ព្រះមហាក្សត្រខ្មែរ នៅមានលក្ខណៈពិសិដ្ឋ ពុំមានជនណាល្មើស បានឡើយ ដែលគេនិយមហៅថា ព្រះសម្មតិទេព គឺថាជាជនខ្ពង់ខ្ពស់ផុតគេ ឬក៏ជាទេវតា ដោយសន្មត់ក្នុងចំណោមមនុស្ស ជាប្រជានុរាស្ត្ររបស់ព្រះអង្គ។ លក្ខណៈពិសិដ្ឋរបស់ព្រះ មហាក្សត្រខាងលើនេះ គឺបានមកពីពិធីរាជាភិសេក ឡើងសោយរាជសម្បត្តិ។ ពាក្យស្លោក នេះខ្មែរពីបុរាណលោក បានប្រើជាហូរហែរៀងមកមានភស្តុតាងក្នុងសិលាចារឹកជាដើម តែលោកសរសេរថា ***ស្វេយ*** ទៅវិញ (ស្វេយវៈធម្មរាជ្យសិលាចារឹកប្រាសាទរលួស ឆ្នាំ ១០៤៩)។ គួរគប្បីជ្រាបថា ក្សត្រអង្គណា ដែលមិនទាន់បានរៀបអភិសេក ហើយគ្រាន់ តែបានទទួលរាជសម្បត្តិគ្រប់គ្រងអាណាប្រជានុរាស្ត្រជាបណ្តោះអាសន្ននោះ តាមក្បួន លោក ឱ្យហៅថា ***គ្រងរាជសម្បត្តិ*** ដូចជាករណីរបស់ ព្រះបរមរាជាទី២ ចៅពញាយ៉ាត កាលដែលវាយរំដោះបានរាជធានីអង្គរពីកណ្តាប់ដៃទ័ពសៀម និងព្រះចន្ទរាជា កាលដែល មិនទាន់ច្បាំងឈ្នះស្តេចកន ជាស្ថាពរនៅឡើយ។ ម្យ៉ាងទៀត ប្រសិនបើអភិសេកក្នុងពេល ធ្វើសង្គ្រាម លោកឱ្យហៅថា ***សង្គ្រាមាភិសេក*** ហើយប្រសិនបើអភិសេក ក្រោយបង្ក្រាបខ្មាំង សត្រូវឱ្យរាបទាប លោកឱ្យហៅថា ***ប្រាប្តាភិសេក*** ទៅវិញ។

ត្រង់នេះគួរគប្បីជ្រាបថា ក្សត្រដែលអាចអភិសេកឡើងសោយរាជ្យពេញលក្ខណៈជា ព្រះមហាក្សត្រ បានលុះណាតែមានគ្រឿងសំរាប់រាជ្យ គឺព្រះខាន់រាជ្យ១ ព្រះលំពែងជ័យ១ និងគ្រឿងព្រះបញ្ចាក្សត្រ។ ប៉ុន្តែបើតាមឯកសារខ្លះគេ បញ្ចូលព្រះខាន់រាជ្យ ឬព្រះខាន់ជ័យនេះ ទៅក្នុងចំណោមគ្រឿងបញ្ចាក្សត្រវិញ ដែលគេហៅថា បញ្ចកុធភ័ណ្ឌ ឬរាជកុធភ័ណ្ឌ គឺ៖

១. ព្រះមកុដ
២. ព្រះវាលវីជនី (ផ្លិតធ្វើដោយរោមសត្វពណ៌ស)
៣. ព្រះខាន់រាជ្យ
៤. ស្វេតច្ឆត្រ
៥. ព្រះសុវណ្ណបាទុកា (ស្បែកជើងមាស)

ប្រភពដដែលបាននិយាយទៀតថា កាលនឹងស្តេច ចេញទៅធ្វើរាជសង្គ្រាម ក៏ត្រូវយកព្រះខាន់ ជាប់នឹងព្រះអង្គទៅជាដំរាប តែមិនមែនយកទៅប្រើកាប់សម្លាប់ផ្តេសផ្តាសដូចអាវុធឯទៀតទេ លុះត្រាតែ សត្រូវជាមេទ័ព ឬក្សត្រ ដែលអង់អាចចូលមកដល់ទីបព្រះអង្គ ត្រូវប្រើព្រះខាន់នេះ ប្រហារឱ្យវិនាសទៅ រួមសេចក្តីទៅថា ត្រូវតែសំលាប់ដោយកិត្តិយស។ ទោះបីចាប់ពីរជ្ជកាលព្រះបាទត្រសក់ផ្អែមតមកខ្មែរយើង កាន់ភ្ជាប់តែព្រះពុទ្ធសាសនាហិនយានក៏ដោយតែព្រះខាន់រាជ្យ និងគ្រឿងបញ្ចាក្សត្រ ត្រូវបានពួកបាគូជា អ្នកថែរក្សាយ៉ាងតឹងរឹង និងមានកិច្ច ធ្វើពិធីបូជាជារៀងរាល់ខែផង។ ពួកបាគូនេះ ជាកូនចៅមានតំណវង្សពី ពួកព្រាហ្មណ៍បុរោហិត គឺពួកព្រាហ្មណ៍ ដែលមានភារៈប្រារព្ធរាជពិធីផ្សេងៗក្នុងរាជវាំងនាសម័យអង្គរ ដែលព្រះរាជាខ្មែរភាគច្រើននិយមរាប់អានសាសនាព្រាហ្មណ៍ជាងព្រះពុទ្ធសាសនា។

តាមរាជពង្សាវតារខ្មែរថា កាលដែលស្តេចកន មានជ័យជំនះ ហើយសម្តេចឥសីកទ្ធ បានយកព្រះខាន់រាជ្យ ព្រះលំពែងជ័យ និងគ្រឿងបញ្ចាក្សត្រ ទៅលាក់ទុកក្នុងរន្ធនៃប្រហោងដើមចំបក់មួយនៅក្នុងព្រៃ។ លុះស្តេចកន ទទួលអភិសេកឡើងសោយរាជ្យ ព្រះអង្គទ្រង់ឱ្យគេដើរកគ្រឿងសម្រាប់រាជ្យទាំងនោះនៅគ្រប់ទិសទី តែរកមិនឃើញសោះ។ ចំណែកឯ ព្រះចន្ទរាជា កាលដែលនាហ្មឺនសព្វមុខមន្ត្រី សូមយាងព្រះអង្គ ទទួលប្រាប្តាភិសេកឡើងសោយរាជ្យសម្បត្តិនោះ ព្រះអង្គទ្រង់ ប្រកែកព្រោះរកគ្រឿងសម្រាប់

រាជ្យមិនទាន់ឃើញ។ បើតាមរាជពង្សាវតាខ្មែរថា គ្រឿងទាំងនោះគេ អាចរកឃើញឡើងវិញដោយសារតែក្រឡាពស[១១២] ម្នាក់ ដេកយល់សប្តិឃើញគេមកប្រាប់ឱ្យទៅយក។

រួមសេចក្តីមកយើងឃើញថា ស្តេច ដែលសោយរាជ្យ មានគ្រឿងសម្រាប់រាជ្យ ដូចបានពោលខាងលើនេះទើបមានលក្ខណៈជាស្តេច ទ្រង់រាជ្យពេញលេញស្របតាមច្បាប់។ ដោយហេតុនេះ ក្នុងគ្រាអាសន្នបើទោះបីមានគ្រោះថ្នាក់យ៉ាងណាក៏ដោយ ក៏ពួកព្រាហ្មណ៍បាគូ សេវកាមាត្យ ត្រូវខំរំដោះគ្រឿងសម្រាប់រាជនេះ ឱ្យបាន ជាឧទាហរណ៍ដូចកាលពីឆ្នាំ១៣៥២ នៅពេលដែលសៀម វាយបែបរាជធានីអង្គរក្នុងរជ្ជកាលព្រះបាទលំពង់រាជានោះ ពួករាជគ្រូបុរោហិត បាននាំយកគ្រឿងសម្រាប់រាជ វាយទម្លាយទ័ពសៀមរត់រួចចេញទៅ។ ដូច្នេះយើងឃើញថា អំណាចរបស់ព្រះរាជាស្ថិតនៅលើព្រះរាជពិធីរាជាភិសេក១ និងលើគ្រឿងសំរាប់រាជ្យ១។

ដោយសារព្រះរាជពិធីអភិសេកនេះ ព្រះរាជា ក៏មានឋានៈជាម្ចាស់ជីវិតលើត្បូងមានសិទ្ធិឱ្យស្លាប់ ឬឱ្យរស់លើសព្វសត្វនៅលើផែនដី បានសេចក្តីថា ព្រះអង្គ ជាចៅក្រមម្នាក់ អាចវិនិច្ឆ័យទោសកំហុសជាយថាហេតុ ប៉ុន្តែក្នុងករណីចុងក្រោយនេះ ក៏ដូចជា ក្នុងករណីឯទៀតៗដែរ ព្រះអង្គ ត្រូវប្រកបដោយទសពិធរាជធម៌ មានទាន សីល ជាដើម។

ច្បាប់ និងអំណាចទាំងឡាយ មានប្រភពចេញមកពីព្រះរាជា។
ព្រះអង្គ ជាអ្នកតាក់តែងច្បាប់ ប៉ុន្តែជាច្បាប់សាធារណៈប៉ុណ្ណោះ។

ដូច្នេះទោះបីជាព្រះរាជា ជាប្រភពនៃច្បាប់គ្រប់បែបយ៉ាង កាន់កាប់អំណាចគ្រប់ប្រភេទក៏ដោយ ក៏ពុំបានសេចក្តីថា ព្រះអង្គ ជាអ្នកកាន់អំណាចផ្តាច់ការទេ។ ផ្ទុយទៅវិញ ព្រះអង្គ ត្រូវប្រកបទៅ ដោយសីលធម៌ឱ្យបរិបូរណ៍ និងគោរពច្បាប់ថែមទៀតផង។ ការដែលមានព្រះរាជាខ្លះ ដូចជា ចៅពញាអន និងចៅពញាញោម ពុំគោរពក្រិត្យវិន័យសម្រាប់ស្តេចទ្រង់រាជ្យ ហើយបែរជាប្រព្រឹត្តអំពើអបាយមុខ រំលោភ លើរូបប្រពន្ធ កូនអ្នកជនៃ បណ្តាលឱ្យមានភាពវឹកវរពេញផ្ទៃប្រទេស នោះគឺជាអំពើ ពុំសមរម្យរបស់អ្នកដឹកនាំជាតិដែលត្រូវមានករណីកិច្ចមើលសុខទុក្ខលើអាណាប្រជានុរាស្ត្រ។

[១១២]ពួកស្នងពួកស្តប្ញជាមន្ត្រីសំគ្គិតូច

ជំពូកទី២
ការអនុវត្តន៍ច្បាប់សៅសម័យកណ្តាល

នៅសម័យកណ្តាលយើងឃើញថា ការអនុវត្តច្បាប់បានប្រព្រឹត្តទៅមានលក្ខណៈស្រដៀងគ្នានឹងសម័យអង្គរ និងសម័យមុនអង្គរនៅឡើយទេ ដែលមានលក្ខណៈដូចជា បន្តជំនំជំរះក្តីដោយឈរលើគោលការណ៍សាសនា រួមមានព្រហ្មណ៍ និងពុទ្ធសាសនា បន្តជំនំជំរះក្តីដោយឈរលើគោលការណ៍ជំនឿ ទំនៀមទម្លាប់ពីបុរាណ និងបន្តជំនំជំរះក្តីដោយឈរលើគោលការណ៍នៃព្រះរាជបញ្ជារបស់ព្រះរាជា ប៉ុន្តែដំណើរការប្រព្រឹត្តទៅនៃការអនុវត្តច្បាប់នៅសម័យកណ្តាល មានលក្ខណៈប្រសើជាងនៅសម័យមុនៗផងដែរ ព្រោះគេអនុវត្តន៍តាមព្រះរាជក្រម ដែលបានកំណត់ពីបទល្មើស និងការដាក់ទោសទណ្ឌជាដើម។

២.១. ដោះស្រាយវិវាទតាមផ្លូវតុលាការ

ប្រភពដែលយកមកសិក្សាពាក់ព័ន្ធរឿងតុលាការសម័យកណ្តាលគឺ «ច្បាប់» និង «ក្រម»។ ច្បាប់និងក្រមនោះសោតភាគច្រើនជាងគេគឺចារនៅក្នុងរាជ្យព្រះបាទជៃជេដ្ឋាទី ៣ នាចុងសតវត្សទី១៧ នៃគ្រិស្តសករាជ។ តាមពិតទៅច្បាប់នៅសម័យកណ្តាលមានមកតាំងពីចុងសតវត្សទី១៥ នៃគ្រិស្តសករាជមកម្លេះ ឧទាហរណ៍យើងឃើញមានច្បាប់មួយចារនៅក្នុងឆ្នាំ១៤១២ នៃមហាសករាជ ត្រូវនឹងឆ្នាំ១៤៩០ នៃគ្រិស្តសករាជ គឺ «ច្បាប់ព្រះក្រោត»។ ក្រោយមកទៀតដល់ពាក់កណ្តាលទីមួយនៃសតវត្សទី១៧ នៃគ្រិស្តសករាជ ទើបមានច្បាប់និងក្រមចំនួនបីទៀត ទី១ គឺ «ព្រះរាជក្រិតប្រាភ្នាភីសេក» (Braḥ rājakrit prābhḍābhisaek) ដែលនិយាយពីពិធីបរមរាជាភិសេករបស់ព្រះមហាក្សត្រីបីអង្គក្នុងអត្ថបទតែមួយ គឺព្រះស្រីសុរិយោពណ៌ (គ.ស. ១៦១៣) ព្រះជ័យជេដ្ឋាទី២ (គ.ស. ១៦១៨) និងព្រះស្រីធម្មរាជា (គ.ស.១៦២៩) ទី២ គឺ «ក្រមចោរ» ចារនៅឆ្នាំ១៦២១ នៃគ្រិស្តសករាជ ក្នុងរាជ្យព្រះជ័យជេដ្ឋាទី២ និងច្បាប់ទី៣ គឺ «ច្បាប់ក្រមស្រុក៨ប្រការ» ចារនៅឆ្នាំ១៥៤៦ នៃមហាសករាជ ត្រូវនឹងឆ្នាំ១៦២៤ នៃគ្រិស្តសករាជ ក្នុងរាជ្យព្រះជ័យជេដ្ឋាទី២ដូចគ្នា[១១៣]។ លុះចំណេរក្រោយមកដល់ចុងសតវត្សទី១៧ នៃគ្រិស្តសករាជ ក្នុងរាជ្យព្រះបាទជ័យជេដ្ឋាទី៣ ហាក់មានចលនាមួយគួរឱ្យកត់សម្គាល់ គឺមានការតាក់តែងច្បាប់ច្រើនប្រការលើសពីរាជ្យស្តេចមុនៗ ហើយក្រោយពីរាជ្យព្រះជៃជេដ្ឋាទី៣ទៅ អត្ថបទច្បាប់ក៏ពុំសូវមានដែរ ដរាបដល់ចុងសតវត្សទី១៩ នៃគ្រិស្តសករាជ ក្រោយបារាំងចូលមក

[១១៣] សូមមើល Mikaelian ២០០៦: ៣៦-៣៧។

ធ្វើអាណាព្យាបាលខ្មែរបន្តិចទើបមានការបោះពុម្ពច្បាប់ខ្មែរលើក្រដាសសៀវភៅដែលនាំចូលមកពីអឺរ៉ុប ហើយភាគច្រើនក្នុងរាជ្យព្រះបាទនរោត្តមនាឆ្នាំ១៨៩១ នៃគ្រិស្តសករាជ នៅរោងពុម្ពប្រូតិកតូរ៉ា។ នៅចន្លោះពេលពីរាជ្យព្រះជ័យជេដ្ឋាទី៣ ដល់រាជ្យហ្លួងនរោត្តមពុំមែនមានន័យថាលែងមានការគាក់តែងច្បាប់ទេ ប្រហែលជាមានដៃរតែពុំសេសសល់ដល់សព្វថ្ងៃ។ មូលហេតុដែលបាត់បង់មានច្រើនប្រការ គឺថាក្នុងប្រវត្តិសាស្ត្រសម័យកណ្តាលខ្មែរកើតកលយុគវឹកវរនឹងសង្គ្រាមជាមួយស្រុកជិតខាងច្រើនលើកច្រើនសារ។ នៅពេលខ្មែរធ្វើសង្គ្រាមចាញ់ដៃគេ ពួកនោះប្រមូលអស់ទាំងមនុស្សទាំងមនុស្សអ្នកចេះដឹង ទ្រព្យសម្បត្តិរួមទាំងគម្ពីរក្បួនច្បាប់នានាផងយកទៅស្រុកគេ។ ឯនៅសេសសល់ច្រើនតែរក្សានៅនឹងព្រះសង្ឃតាមវត្តអារាមនានា។ លុះដល់ព្រះសង្ឃសុគតទៅជួនកាលគេដុតទាំងក្បួនច្បាប់អម្បាលនោះទៅជាមួយសពព្រះសង្ឃទៀត។ ឯមួយភាគទៀតក៏ពុកផុយខូចខាតតាមកាលវេលា ព្រោះសំណេរចារលើស្លឹករឹត ឬស្លឹកត្នោតជាប្រភេទសាត្រា ក្រាំងគម្ពីរជាដើមមិនអាចស្ថិតស្ថេរយូរអង្វែងឡើយពិសេសមិនអាចធន់នឹងអាកាសធាតុក្តៅសើម។ ចំណែកការអន្តរាយដ៏គំហុករបស់ក្បួនច្បាប់មួយចន្លោះកាលទៀតនោះគឺការដុតបំផ្លាញដោយពួកខ្មែរក្រហមដែលកាន់អំណាចចន្លោះឆ្នាំ១៩៧៥ ដល់ ១៩៧៩ ដែលធ្វើឱ្យក្បួនច្បាប់ខ្មែរកាន់តែហោចទៅ។ សព្វថ្ងៃក្បួនច្បាប់ដែលសេសសល់ មួយភាគរក្សាទុកនៅបណ្ណាល័យជាតិបារាំង និងមួយភាគទៀតទាំងអត្ថបទដើមនិងអត្ថបទចម្លងឡើងវិញលើក្រដាស មានរក្សាទុកនៅបណ្ណាសារដ្ឋានជាតិ វិទ្យាស្ថានពុទ្ធិសាសនបណ្ឌិត សាលាបារាំងចុងបូព៌ា និងមានខ្លះទៀតរក្សានៅតាមវត្ត។ នេះបើយើងនិយាយពីគម្ពីរ ក្បួន ច្បាប់ក្រម និងសាត្រាទូទៅ។

ដូចនិយាយមកពីខាងដើមច្បាប់ទាក់ទងនឹងកិច្ចការតុលាការនៅសម័យកណ្តាលដែលសេសសល់មកដល់សព្វថ្ងៃ ភាគច្រើនចារក្នុងរាជ្យព្រះជ័យជេដ្ឋា ហើយច្បាប់និងក្រមដែលខ្ញុំយកធ្វើជាគោលក្នុងការសិក្សានេះមានដូចជា៖

ឈ្មោះច្បាប់	កាលបរិច្ឆេទជា គ.ស.	រាជ្យ
ច្បាប់ក្រមស្រុក៨ប្រការ	១៦២៤	ព្រះជ័យជេដ្ឋាទី២
សាត្រាប្រាំធ្នានសាកៅ	១៦៩៣?	ព្រះជ័យជេដ្ឋាទី៣
សាត្រាប្រាំធ្នានស្បថ	១៦៩៣?	ព្រះជ័យជេដ្ឋាទី៣
សាត្រាប្រណិធានចាប់ឆ្នោត	១៦៩៣?	ព្រះជ័យជេដ្ឋាទី៣
ច្បាប់ទំនឹមពីបុរាណ	១៦៩១?	ព្រះជ័យជេដ្ឋាទី៣

ឈ្មោះច្បាប់	កាលបរិច្ឆេទជា គ.ស.	រាជ្យ
	១៧០៤?	
ច្បាប់សារពើល្បែងភ្នាល់គ្នា	១៦៩៣?	ព្រះជ័យជេដ្ឋាទី៣
ច្បាប់ក្រមស្រុកព្រះដៃជេស្តា	១៦៩៣	ព្រះជ័យជេដ្ឋាទី៣
មាត្រាច្បាប់សារពើគុណ	១៦៩៣	ព្រះជ័យជេដ្ឋាទី៣
ច្បាប់សំពៅ	១៦៩៣	ព្រះជ័យជេដ្ឋាទី៣
ច្បាប់ក្រមសុភាធិបតី	១៦៩៣	ព្រះជ័យជេដ្ឋាទី៣
ច្បាប់សង្ឃរី	?	ព្រះជ័យជេដ្ឋាទី៣
ក្រមប្រដៅចៅក្រម	១៦៩៣	ព្រះជ័យជេដ្ឋាទី៣
ក្រមពលទេព	១៦៩៣?	ព្រះជ័យជេដ្ឋាទី៣
ក្រមពួក	១៦៩៧	ព្រះជ័យជេដ្ឋាទី៣
ច្បាប់ឃុនសាឡា១៤សន្លឹក	១៧២៣	ព្រះសត្ថាទី២

បើនិយាយពីសិលាចារឹក នៅសម័យកណ្តាលមានសិលាចារឹកប្រមាណជាង១៤០ផ្ទាំង។ ប៉ុន្តែសិលាចារឹកទាំងនោះសឹងតែនិយាយពីរឿងធ្វើបុណ្យក្នុងព្រះពុទ្ធសាសនាដើម្បីសន្សំកុសលមគ្គផលទុកទៅជាតិមុខដូចជាប្រោសខ្ញុំ សាងព្រះប្រតិមាអំពីមាស ប្រាក់ជាដើម ដ្បិតពេលនោះព្រះពុទ្ធសាសនាថេរវាទកំពុងមានឥទ្ធិពលខ្លាំងលើប្រជាជនខ្មែរ និងជនជាតិឯទៀតនៅក្នុងតំបន់ដូចជា សៀម លាវ និងភូមា។ ស្ទើរតែគ្មានអត្ថបទទាក់ទងនឹងច្បាប់ក្រមណាមួយដែលចារលើផ្ទាំងថ្មក្រៅតែអំពីរឿងបុណ្យកុសលក្នុងព្រះពុទ្ធសាសនាឡើយ។ ប្រការនេះមិនគួរឱ្យឆ្ងល់ទេ ព្រោះច្បាប់ក្រមគេចារលើវត្ថុស្រាលជាក្រាំង ជាសាស្ត្រា ពីស្លឹករិត ឬស្លឹកត្នោត បើពុំនោះសោតគេចារលើបន្ទះលោហៈស្រាលៗព្រោះគេងាយស្រួលក្នុងការចែកចាយផ្សាយបន្តចម្លងយកទៅរៀនសូត្រ ខុសពីរឿងបុណ្យកុសលដែលគេចារលើផ្ទាំងថ្មតម្កល់ក្នុងទីណាមួយដើម្បីទុកជាតឹកតាងបង្ហាញពីអំពើជាកុសលរបស់គេ។ ម្យ៉ាងថ្មអាចគង់វង្សនៅយូរអង្វែងឧបមានឹងបុណ្យដែលគេបានធ្វើ ហើយហុចផលឱ្យគេជាអង្វែងកាលដូច្នោះដែរ។ ព្រះពុទ្ធសាសនា នាសម័យកណ្តាលប្តុំប្តើងណាស់ទាំងក្សត្រនិងរាស្ត្រច្រើនប្រាថ្នាផ្សារភ្ជាប់ជីវិតទៅនឹងសាសនាព្រះតថាគត។ ដូច្នោះហើយឥទ្ធិពលព្រះពុទ្ធសាសនាបន្តិចម្តងៗបានជ្រាបចូលទៅក្នុងវិស័យច្បាប់ក្រមតុលាការ។ ទ្រឹស្តីក្នុងព្រះពុទ្ធសាសនាគឺការប្រកាន់យកធម៌អហិង្សា មានចិត្តសណ្តោសប្រោសប្រណី។ ដោយសារហេតុនេះ នៅសម័យកណ្តាលបានបញ្ជាក់យ៉ាងច្បាស់ពីគោលបំណងនៃការ

បង្កើតនិងអនុវត្តច្បាប់ គឺថាការតាក់តែង និងការអនុវត្តច្បាប់ពុំមែនចង់ដាក់ទោសរាស្ត្រឱ្យ រាស្ត្របែកបាក់ ផ្ទុយទៅវិញគឺប្រាថ្នាឱ្យរាស្ត្ររស់នៅបានសុខជានឹងគ្នា។ ទស្សនៈនេះ នាំឱ្យ ទៅដល់ការកែប្រែធ្វើវិសោធនកម្មច្បាប់ចាស់នៅក្នុងរាជ្យព្រះបាទដែដេដ្ឋាមានការកែប្រែ ច្បាប់ចាស់ឡើងវិញដោយព្រះអង្គយល់ថាច្បាប់អំពើដើមនោះពុំគួរ ហៅអធម៌សប្បុរស បង្កើតជាអកុសល តឹងរឹងហួសពេកចំពោះរាស្ត្រ។ ទើបព្រះអង្គត្រាស់លើត្បូងអស់ពួក ចៅក្រម នាម៉ឺន ឧកញ៉ា នូវអស់

មន្ត្រី កវី បណ្ឌិត ព្រឹទ្ធាចារ្យផងឱ្យជំនុំឱ្យខានចោលចេញនូវច្បាប់អំពើមុនដែលធ្ងន់ ហួសពេក។ សេចក្តីនេះពោលនៅក្នុងក្រមសារពើគុណ និងច្បាប់ក្រមសុភាធិបតី។ ដូច្នេះ យើងឃើញថាការកែប្រែច្បាប់ចាស់អាចដោយសារសម័យកាលសង្គមផ្លាស់ប្តូរ ហើយ ចំណុចខ្លះដែលចែងនៅក្នុងច្បាប់ចាស់ពីបុរាណហួសសម័យកាលប្រើទៀតលែងបាន។

ជាទូទៅសង្គមណាក៏ដូចគ្នា ការតាក់តែងច្បាប់គឺមានបំណងធ្វើយ៉ាងណាឱ្យ មនុស្សក្នុងសង្គមអាចរស់នៅប្រាស្រ័យទាក់ទងគ្នាដោយសុខសន្តិភាពក្រោមអំណាច ច្បាប់តែមួយ និងចៀសវាងទប់ស្កាត់រាល់ជម្លោះទាស់ទែងក្តីក្តាំផ្សេងៗ។ បើនិយាយពីការ បង្កើតច្បាប់នាសម័យកណ្តាលឃើញថាមានពីស្ថានភាព គឺ ស្ថានភាពទី១ គឺអស់អ្នករាជ ការធំតូចជំនុំគ្នាជាមុនធ្វើសេចក្តីព្រាងច្បាប់ដោយលើកយកស្ថានទម្ងន់ទោសនីមួយៗមក ពិចារណាថ្លឹងថ្លែង និងកំណត់ក្រយ៉ាពិន័យយ៉ាងកណ្តាល គឺថាមិនឱ្យធ្ងន់ជ្រុលពេកនិង មិនឱ្យស្រាលហួសពេក។ បើការកំណត់ក្រយ៉ាពិន័យនោះសមរម្យល្មមតាមទោសកំហុស និងមានការយល់ស្របឯកភាពគ្នាហើយ ទើបគេកត់ត្រាសេចក្តីនោះទុកជាច្បាប់ប្រើប្រាស់ តទៅ។ ឯស្ថានភាពទី២ គឺថាច្បាប់អនុម័តដោយយោងលើស្ថានភាពជាក់ស្តែងនៃទោស កំហុសណាមួយដែលបានកើតឡើងហើយ។ ឧទាហរណ៍ បើមាននរណាម្នាក់បានប្រព្រឹត្ត កំហុស ហើយគេយកទៅធ្វើក្តីនៅសាលាជំនុំ អ្នកសភាតុលាការជំនុំពិចារណាសេចក្តីនោះ ថាត្រូវដាក់ទោសទណ្ឌតាមរបៀបណាមួយ ឬត្រូវបង់ក្រយ៉ាពិន័យប៉ុន្មានៗដូច្នោះ។ ក្រោយជំនុំសេចក្តីនោះចប់ ស្មៀនអ្នកកត់ត្រាក៏តោងកត់ត្រារាល់រឿងហេតុយ៉ាង ក្បោះក្បាយនិងចំនួនក្រយ៉ាពិន័យដែលបង់ប៉ុន្មានៗនោះទុក ប្រយោជន៍បើថ្ងៃក្រោយមាន កើតហេតុដូចគ្នា សភាតុលាការនឹងកាត់សេចក្តីនោះឱ្យដូចដែលនោះឯងឬតជារឿងដែល ធ្លាប់មានហើយ។ ប្រការទី២នេះមានឧទាហរណ៍ច្រើននៅក្នុងច្បាប់ក្រមនានា ហើយដែល រឹតតែច្បាស់ជាងគេគឺ «ច្បាប់ទំនឹមពីបុរាណ» ដែលព្រះដែដេដ្ឋាត្រាស់បង្គាប់ឱ្យឧកញ៉ាសូ ភាធិបតីទៅក្រាបទូលសួរពីព្រះមាតាជាសម្តេចព្រះទាវអំពីទំនឹមព្រះរាជក្រិតបុរាណដើម្បី

កត់ត្រាទុកជាច្បាប់តំណរពាជ្យតទៅ។ ថ្វីបើច្បាប់មានហើយក៏ពិតមែន តែក្នុងជីវិតប្រាស្រ័យទាក់ទងគ្នាប្រចាំថ្ងៃគេនៅតែមិនអាចបញ្ចៀសទំនាស់ទាស់ទែងដែលកើតមានឡើងបាន។ ជាក់ស្តែងតាមរយៈអត្ថបទច្បាប់និងក្រមផ្សេងៗនាសម័យកណ្តាល យើងឃើញមានវិវាទច្រើនប្រការដែលគេកត់ត្រាចូលក្នុងច្បាប់។ វិវាទកើតឡើងនាសម័យកណ្តាលនឹងរៀបរាប់បង្ហាញក្នុងចំណុចបន្ត។

២.១.១. ប្រភេទវិវាទ

វិវាទដែលកត់ត្រាក្នុងច្បាប់និងក្រមទាំងឡាយគឺជាវិវាទដែលកើតមានជាទូទៅនៅក្នុងសង្គម គឺក្នុងជីវភាពប្រចាំថ្ងៃរបស់មនុស្ស។ ទំនាស់ខ្លះអាចទុកថាជារឿងដ៏សាមញ្ញបំផុត។ នៅទីនេះខ្ញុំមិនបែងចែកវិវាទទាំងនោះតាមប្រព័ន្ធសព្វថ្ងៃឡើយ មានន័យថាខ្ញុំពុំចាត់ថ្នាក់ថាប្រភេទវិវាទណាចូលក្នុងបទព្រហ្មទណ្ឌ ឬប្រភេទណាជារដ្ឋប្បវេណីឡើយដោយហេតុថាកាលពីសម័យនោះដំណើរការក្តីរបស់តុលាការប្រព្រឹត្តទៅក្នុងទម្រង់តែមួយដោយពុំមានការបែងចែកអ្វីឡើយ។ បើមានក្តីក្តាំ តុលាការកាត់ទោសតាមភាពជាក់ស្តែងឬកាត់តាមច្បាប់ដែលជាទម្លាប់តមក។ សព្វថ្ងៃ ច្បាប់មានការបែងចែកជាប្រភេទដូជាក្រមព្រហ្មទណ្ឌ រដ្ឋប្បវេណី ច្បាប់ភូមិបាល ច្បាប់ឯកព័ន្ធភាព ។ល។ រីឯក្នុងអត្ថបទច្បាប់ គេធ្វើការបែងចែកជាគន្លឹ ជំពូក ផ្នែក មាត្រា របៀបនៃការរៀបចំនេះ គឺយកតាមរបៀបរបស់អឺរ៉ុប។ ម្លោះហើយអំពីប្រភេទទោសនេះខ្ញុំនឹងបង្ហាញដោយសរុបបញ្ចូលគ្នាតែម្តង។ ប្រភេទវិវាទនៅសម័យកណ្តាលយើងឃើញមានច្រើនប្រការដូចជា៖

- វិវាទទាក់ទងនឹងរឿងដីធ្លី ជម្លោះដណ្តើមគ្នាធ្វើជាម្ចាស់កម្មសិទ្ធលើដីណាមួយ
- វិវាទទាក់ទងនឹងបញ្ញើនិងការបញ្ចាំ
- វិវាទពីសារពើល្បែងភ្នាល់នានា
- អំពើសហាយស្មន់អន្ទកររវាងប្រុសនិងស្រី ចៅហ្វាយនាយនិងខ្ញុំបម្រើ រវាងសាច់សាររលោហិតនឹងគ្នា
- អំពើចោរកម្ម លួច ឆក់ ប្លន់
- ការជេរប្រទេចផ្តាសារប្រមាថកាតទានដាក់គ្នា
- ការប្រព្រឹត្តអំពើហិង្សា វាយ កាប់ ចាក់ សម្លាប់គ្នា
- អ្នកមានអំណាចព្រហើនកោងកាចរំលោភលើអ្នកទន់ខ្សោយ
- ការមិនកោតក្រែងអំណាចព្រះរាជាអ្នកជាអម្ចាស់ជីវិតលើត្បូង
- បំផ្លាញធ្វើឱ្យខូចខាតសម្បត្តិសាធារណ

- រុករានទន្ទ្រានចូលក្នុងរបងផ្ទះអ្នកដទៃតាមទំនើងចិត្ត
- អ្នករុករានទន្ទ្រានចូលក្នុងរបងរាំងខុសច្បាប់
- អ្នកលបលួចសម្ព័ន្ធស្នេហាជាមួយស្រីស្នំក្រមការក្នុងវាំង
- អំពើបំពានលើត្រណមអ្នកដទៃ
- បេះបោចផ្លែឈើបន្លែបង្ការច្បារដំណាំអ្នកដទៃ
- ដេញគោក្របីដំរីសេះសព្វសារពើសត្វចិញ្ចឹមឱ្យចូលលុកលុយស្រែចម្ការច្បារដំណាំគេ
- កុហកបោកបញ្ឆោទប្រវ័ញ្ចទ្រព្យគេ
- លាក់បំពួនកូន ប្រពន្ធគេ លាក់ខ្ញុំគេទុកប្រើខ្លួនឯង
- វិវាទទាក់ទងរឿងបំណុល បុល ខ្ចី ចងការ
- ការរៀបអាពាហ៍ពិពាហ៍ជាមួយសាច់ញាតិឯង ជាមួយគ្រូឬសាច់ញាតិគ្រូ ជាមួយក្តៅម្រាក់ ឬសាច់ញាតិរបស់ក្តៅម្រាក់ជាដើម
- លួចរបស់ទ្រព្យក្នុងវត្ត ឬរំលាយព្រះពុទ្ធរូប
- ការកាប់សម្លាប់គ្នាដោយចោទថាជាអាបឬធ្មប់
- អំពើជុតផ្ទះសម្បែង ចំបើង របងផ្ទះ សម្រះនានា
- អំពើបំផ្លាញ ចោះទូក ពន្លិចទូកគេឱ្យលិចលង់ក្នុងទឹក
- ដាក់ថ្នាំបំពុលគេក្នុងអាហារ ស្រា ទឹក
- អ្នកព្រះសង្ឃឈ្លោះទាស់ប្រវាយប្រកាប់ប្រចាក់គ្នាជាមួយគ្រហស្ថ
- ជុតខ្មោច កប់ខ្មោច លើភូមិលើស្រែគេ
- កាប់ឈើរលំលើស្រែគេ។
- និយាយដើម បង្កាច់បង្ខូច អាក្រោសកេរ្តិ៍គេឱ្យអាស្រូវជាដើម។ល។ អំពើទាំងអម្បាលនេះសុទ្ធសឹងជាវិវាទក្តីក្តាំដែលបានកើតឡើង ហើយដែលបានកត់ត្រាចូលក្នុងច្បាប់និងក្រមនានា។

២.១.២. អ្នកមានតួនាទីក្នុងតុលាការ

មកដល់សម័យកណ្តាលយើងមើលឃើញថាមានចំណុចផ្លាស់ប្តូរច្រើនប្រការ។ ឧទាហរណ៍ងារមន្ត្រីអ្នករាជការបម្រើការទូទៅនិងក្នុងវិស័យតុលាការស្ទើរទាំងអស់បានផ្លាស់ប្តូរ។ ងារមន្ត្រីនៅសម័យកណ្តាលភាគច្រើនផ្តើមដោយពាក្យថា «ឧកញ៉ា» «នាម៉ឺន» និង «ចៅពញ្ញា» ជាដើម ។

ចំពោះគោរម្យងារមន្ត្រីដែលធ្វើការពាក់ព័ន្ធនឹងតុលាការកាលពីសម័យបុរាណ បានបាត់បង់ទៅនៅសម័យណ្តាលភាគច្រើន ប៉ុន្តែក៏មានងារខ្លះនៅរក្សាដដែលដូចជា «រាជអាជ្ញា» និង «ព្រះសភាជាដើម» ហើយអ្នកដែលជាអង្គចៅក្រមសំខាន់តាំងពីបុរាណ តួយ៉ាងដូចជាអង្គព្រះមហាក្សត្រ ក៏នៅតែសំខាន់ដដែលមកដល់សម័យកណ្តាល។ អ្វីដែលយើងឃើញប្លែកគឺថានៅសម័យបុរាណពុំបានបែងចែកមន្ត្រីឱ្យកាន់ក្តីតាមប្រភេទវិវាទទេ។ ប៉ុន្តែដោយឡែកតាម «ច្បាប់ក្រមសុភាធិបតី» របស់ព្រះជ័យជេដ្ឋា នាសម័យកណ្តាលបានបែងចែកមន្ត្រីឱ្យកាន់ក្តីជាចៅក្រមទៅតាមជំពូកផ្សេងៗនៃទំនាស់។ ជួនកាលមន្ត្រីម្នាក់មើលការខុសត្រូវលើវិវាទច្រើនជំពូក។ដូច្នេះខាងក្រោមនេះ គឺជាសមាសភាពអ្នកមាននាទីចាំបាច់ក្នុងកិច្ចការតុលាការនាសម័យកណ្តាល ដែលមានជាអាទិគឺ ៖

ក. អាជ្ញា

ន័យដើមបង្អស់របស់ពាក្យថា «អាជ្ញា» គឺមានន័យថាអំណាច ការគ្រប់គ្រង ពាក្យបង្គាប់បញ្ជា ច្បាប់បញ្ញត្តិដែលដាក់មកឱ្យធ្វើតាម។ ប៉ុន្តែពាក្យនេះក៏សម្តៅទាំងអ្នកដែលទទួលអំណាចពីរាជការបានជាមន្ត្រីបម្រើការក្នុងតុលាការជាដើមផង។ អាជ្ញាមានច្រើនប្រភេទដូចជា អាជ្ញាកត់ពន្ធ អាជ្ញាកែនបរ អាជ្ញាសាលា អាជ្ញាហ្លួងជាដើម[១១៤]។ នៅទីនេះយើងនិយាយតែពីអាជ្ញាមួយគត់ គឺអាជ្ញាដែលជាអ្នកបម្រើការក្នុងតុលាការ។ អាជ្ញានេះ គឺជាបេសកជនដែលទទួលអំណាចពីព្រះរាជាដើម្បីបំពេញកិច្ចការជាអ្នកសម្របសម្រួល ឬជាតំណាងកណ្តាលរវាងអំណាចកំពូល និងអំណាចភូមិភាគ[១១៥]។ នៅក្នុងច្បាប់ក្រមស្រុកព្រះជ័យជេស្ដាមានការបែងចែកអាជ្ញាជាបីលំដាប់ថ្នាក់គឺ៖

១. ដើមអាជ្ញា
២. កណ្តាលអាជ្ញា
៣. ចុងអាជ្ញា[១១៦]។

អាជ្ញាដែលទទួលអំណាចពីព្រះរាជាមានសិទ្ធិធំសម្បើមអាចបង្គាប់បញ្ជាលើអ្នកឯទៀតដូចជាចៅហ្វាយស្រុកជាដើម។ អ្នកណាដែលល្មើសព្រើលបំពានមិនកោតខ្លាចអំណាចអាជ្ញា អ្នកនោះនឹងត្រូវពិន័យ។ ប៉ុន្តែនៅក្នុងច្បាប់ដដែលក៏បញ្ជាក់ដែរថាអាជ្ញាពុំ

---

[១១៤] នេះជាសេចក្តីពន្យល់ក្នុងវចនានុក្រមខ្មែររបស់វិទ្យាស្ថានពុទ្ធិសាសនបណ្ឌិតឆ្នាំ ១៩៦៧។
[១១៥] សូមមើល ជា ឡាលីន ២០១០: ៦០។
[១១៦] *ច្បាប់ក្រមស្រុកព្រះជ័យជេស្ដា* ច្បាប់ដើម, បន្ទាត់ ៣៧-៥៤។

មែនមានសិទ្ធិគ្រប់យ៉ាងអាចលូកដៃជ្រៀតជ្រែកក្នុងកិច្ចការអ្នកដទៃ ឧទាហរណ៍ គឺពុំអាចទៅដណ្តើមក្តីពីគេមកកាន់ខ្លួនឯងបានឡើយ ទោះបីអ្នកនោះកាត់ពុំដាច់ស្រេចក៏ដោយ។

នៅពេលមានវិវាទក្តីក្តាំកើតឡើង អាជ្ញាជាអ្នកមាននាទីទៅប្រកោះហៅគូក្តីទាំងសងខាងមកសាលាជំនុំ[១១៧]។ ចំពោះអ្នកដែលជាអាជ្ញានោះសោតពុំចាំបាច់តម្រូវលើមនុស្សម្នាក់ដដែលទេ។ អ្នកឯទៀតដែលទទួលបញ្ជាឱ្យទៅប្រកោះហៅគូក្តីមក ឬនាំសារពីព្រះរាជា ពីសម្តេចព្រះមាតាជាសម្តេចព្រះទាវជាដើមក៏ហៅថា «អាជ្ញា» មួយពេលដែរ ហើយក្នុងកំឡុងពេលដែលអ្នកនោះដើរតួជាអាជ្ញានាំពាក្យពីព្រះរាជា ឬព្រះមាតាឱ្យទៅនាំគូក្តីមកជំនុំ ហើយបើអាជ្ញាពុំទាន់បានរ៉ាយរ៉ាប់ពីព្រះបន្ទូលផងទេស្រាប់តែមានអ្នកឯណាមកជេរប្រទេចផ្តាសារដាក់អាជ្ញានោះ អ្នកនោះឯងនឹងមានទោសពីបទជេរអាជ្ញាលើព្រះបន្ទូលត្រូវពិន័យជាជាច់ខាត។ សេចក្តីនេះមានចែងជាឧទាហរណ៍នៅក្នុងច្បាប់ទំនឹមពីបុរាណ ត្រង់ទំនឹម១៤ រាជព្រះជ័យជេដ្ឋាទី៣។

> *មានជំនឹម១៤ កាលរាជព្រះរាជឱង្ការព្រះជ័យជេដ្ឋា កាលនោះសម្តេចព្រះនារព្រះកន្ទោជប្រើចៅពញាស្នាជិបតីឱ្យជាអ្នកក្តីទៅជួនឧកញ៉ាវង្សាជិបតីឱ្យជំនុំ។ លុះចៅពញាស្នាជិបតីជាអ្នកក្តីនោះមកដល់ឧកញ៉ាវង្សាជិបតីហើយ ចៅពញាថ្លែងព្រះបន្ទូលថាព្រះបន្ទូលឱ្យជួនអ្នកក្តីមកឧកញ៉ាឱ្យឧកញ៉ាជំនុំ។ ឧើបឧកញ៉ាឧទ្ធលព្រះបន្ទូលហើយឱ្យស្មាន់ចៅពញាជាអាជ្ញាស៊ី ហើយឧកញ៉ាជំនុំក្តីនោះ។ ឧើបចៅពញាស្នាជិបតីធ្វើយថាស់ពាក្យឧកញ៉ាៗជេរចៅពញាថាស្រម៉ីញស្នែស្នោ។ ឯចៅពញាអាក់ក្តីនឹងឧកញ៉ាថាម្តេចអ្នកជេរអញលើព្រះបន្ទូល [...]។*

ខ.ចៅហ្វាយស្រុក

ចៅហ្វាយស្រុកជាមន្ត្រីម្នាក់ដែលទទួលបន្ទុកគ្រប់គ្រងដែនដីរដ្ឋបាលមួយផ្នែកហៅថា «ស្រុក»។ មកដល់សម័យកណ្តាល ប្រពន្ធ័នៃការបែងចែកដែនដីរដ្ឋបាលឃើញកាន់តែច្បាស់ឡើង។ ស្រុកនៅសម័យកណ្តាលប្រហែលមានន័យស្មើនឹងខេត្តសព្វថ្ងៃ ស្រុកមួយគ្រប់គ្រងដោយចៅហ្វាយស្រុកម្នាក់។ ក្នុង «ច្បាប់ក្រមស្រុកព្រះជ័យជេស្ត» បង្ហាញយើងឱ្យដឹងពីច្បាប់ទម្រង់សក្តិរបស់ចៅហ្វាយស្រុក។ ចៅហ្វាយស្រុកដែលមាន

[១១៧] សូមមើលឧទាហរណ៍ក្នុង *ច្បាប់ទំនឹមពីបុរាណ* ត្រង់ទំនឹម១៨។

ឈ្មោះក្នុងច្បាប់នេះទាំងអស់ចំនួន៣០ ប៉ុន្តែចៅហ្វាយស្រុកសំខាន់និងមានសក្តិធំជាងគេ មានចំនួន៥គឺ ចៅហ្វាយស្រុកសន្ទុក ចៅហ្វាយស្រុកទ្រាំង ចៅហ្វាយស្រុកត្បូងឃ្មុំ ចៅហ្វាយស្រុកពោធិសត្វ និងចៅហ្វាយស្រុកបាភ្នំ។ ដែនដីរដ្ឋបាលទាំងប្រាំគឺជាដែនដីរដ្ឋបាលសំខាន់ជាងគេនៅសម័យនោះ ឯសក្តិរបស់ចៅហ្វាយស្រុកទាំងប្រាំនាក់នោះគឺចំនួន ១០ហ៊ិចតា។ ចំណែកស្រុកឯទៀត ចៅហ្វាយស្រុកមានសក្តិពី៨ហ៊ិចតា ៧ហ៊ិចតា រៀងមកដល់ទាបជាងគេគឺ ៦ហ៊ិចតា។

តាមច្បាប់ក្រមស្រុក ការជ្រើសរើសចៅហ្វាយស្រុកនីមួយៗពុំមែនដោយការតែងតាំងពីព្រះមហាក្សត្រតែមួយអង្គឯងឡើយ។ ផ្ទុយទៅវិញគឺត្រូវមានការជំនុំពិចារណាពីអស់មន្ត្រី ឧកញ៉ា ពញាជាមុនទើបឡើងក្រាបទូលព្រះមហាក្សត្រជាក្រោយ។ បើព្រះមហាក្សត្រសព្វព្រះរាជហឫទ័យទើបតែងតាំងជាចៅហ្វាយស្រុកសក្តិ ៦ហ៊ិចតា។ បើចៅហ្វាយស្រុកធ្វើការល្អរាស្ត្រចូលចិត្ត ឯរាជការក៏បានដឹង ទើបចៅហ្វាយស្រុកនោះលើកឡើងឱ្យបានសក្តិ ៨ហ៊ិចតា ឬរហូតដល់សក្តិ ១០ហ៊ិចតា។

សម្រង់ឃ្លាក្នុង «ច្បាប់ក្រមស្រុកព្រះឥយជេស្ដា» ៖

១៦៧. [...] បើនឹងចិញ្ចឹមឱ្យជាចៅហ្វាយស្រុក នុះឱ្យមន្ត្រីធំដំនុំពិចារណា

១៦៨. និងរកឧកញ៉ា ពញ្ញា ព្រះឯណានឹងឱ្យជាចៅហ្វាយស្រុកក្តី បើចានស្រែចហើយ ក្រាបពិតទូល

១៦៩. បើសព្វព្រះរាជហឫទ័យព្រមនឹងឱ្យចៅជាចៅហ្វាយស្រុកសាក់ ៦ហ៊ិចតាជាដើមបើ

១៧០. បើអស់រាស្ត្រចំណុះស្រុកចូលចិត្ត ហើយរាជការក៏ចានផង ឌើបយកចៅហ្វាយស្រុកនោះឯងចិញ្ចឹមលើកឡើង

១៧១. ឱ្យជាចៅហ្វាយស្រុកសក្តិ៨ហ៊ិចតាលើសនឹងដើម។ បើរាស្ត្រចំណុះស្រុកចូលចិត្ត ហើយរាជការក៏

១៧២. ចានដឹងឌើបឱ្យយកចៅហ្វាយស្រុកនោះឯង ចិញ្ចឹមលើកឡើងឱ្យជាចៅហ្វាយស្រុកសក្តិ១០

១៧៣. ហ៊ិចតាលើសនឹងដើម។ [...]

នៅក្នុងវិស័យតុលាការ ចៅហ្វាយស្រុកដែលបានទទួលការតែងតាំងរួចហើយអាចមានសិទ្ធិក្នុងការដោះស្រាយរឿងក្តីផ្សេងៗរបស់រាស្ត្រចំណុះស្រុកខ្លួន ហើយពុំអាច

មាននរណានឹងមកជ្រៀតជ្រែកការងារ ដណ្តើមក្តីពីចៅហ្វាយស្រុកបានឡើយ។ អត្ថន័យនេះ មានចែងដូចខាងក្រោម៖

៣៣៧. មួយសោតជាព្រះចាឧបរមបពិត្រចិញ្ចឹមជាចៅហ្វាយស្រុក និងចានអប្បការជំយដោយ
៣៣៨. ព្រះរាជជានពិសេសក្តីធំដូច្នេះឯង និងចានផ្តត់ផ្តង់ព្រះរាជ ការកុំឱ្យមានអាជ្ញាជង
៣៣៩. មកយកក្តីអ្នកអំពីចៅហ្វាយស្រុកចូលទៅឡើយ ទោះចៅហ្វាយស្រុកជំនុំសារពើ
៣៤០. ក្តីអ្វីៗបើពុំជាច់ស្រែច ឱ្យកត់ដោយដំណើរសេចក្តីទោះឱ្យ ជាំទៅក្រោម
៣៤១. ចូលជល់ល្អងចូលីព្រះចាឧ...

ចៅហ្វាយស្រុកសក្តិ ១០ហ៊ូពាន់មាននាទីមើលខុសត្រូវច្បាប់ក្រមទាំងឡាយឱ្យច្បាស់លាស់ត្រឹមត្រូវ ចៀសវាងមានភ្លាំងភ្លាត់នាំកើតសៅហ្មងដល់រាស្ត្រនិងកើតក្តៅក្រហាយដល់ផ្នែក្រោមផង។ ចៅហ្វាយស្រុកក៏មានសិទ្ធិអំណាចតាក់តែងច្បាប់ (អាជ្ញា) សម្រាប់ប្រើប្រាស់ក្នុងស្រុករបស់ខ្លួនបានប្រសិនបើច្បាប់នោះពុំឃ្លាតចាកពីច្បាប់រាជការ។

ឧទាហរណ៍ ៖

២២៧. [...] ព្រះបន្ទូលពិសេសត្រាស់ឱ្យមកតម្កល់ទុកលើ
២២៨. ត្បូងចៅហ្វាយស្រុក ១០ហ៊ូពាន់ ឱ្យពិនិត្យជិតជុំអស់រាជ ការផងចាំងចូងចូចក្រែមច្បាប់ ហើយឱ្យចៅ
២២៩. ហ្វាយស្រុកកត់ត្រាបញ្ជីអស់រាស្ត្រចំណុះស្រុកឱ្យដឹង អ្នកជា ព្រៃជារដៅកំម្ងោះ មហាតដៅ ពលបម្រើស
២៣០. ដៅខ្ញុំកេចាំងចូង ទោះឰ្យឰ្យាយ លីវ ឃ្លាល ពិការ ចាស់ជរា ក្តី ឱ្យដឹងដោយដំពូកចៅហ្វាយជាយ
២៣១. ឌីឌៃៗឱ្យសព្វគ្រប់ ...។

.....

២៤៣. [...] ដំណើរអំពីនេះដៅបើចៅហ្វាយស្រុកឌឹងតែងអាជ្ញា

២៤៤. ឱ្យបរចាប់ភស្តុចំណុះស្រុក មកប្រើធ្វើព្រះរាជការ ជាំជព្ជជឱ្យមែនជឺជច្បាប់

២៤៥. តែជព្រះរាជការនោះហើយ ព្រះចាជអ្នកជាអម្ចាស់(ពុំ)ឱ្យ មានក្តីឡើយ។

ក្នុងករណីមានចោរកម្មលួចឆក់ប្លន់កាប់សម្លាប់ ឬមានអ្នកឯណាមករុករាតត្បាត ធ្វើទុក្ខបុកម្នេញរាស្ត្រចំណុះស្រុកដោយប្រការផ្សេងៗ គឺចៅហ្វាយស្រុកនោះឯងត្រូវ សង្កាតរកចាប់មនុស្សកំណាចដៃលមករុកគួនរាតត្បាតនោះ ឱ្យបានយកមកធ្វើទោសតាម ដោយធ្ងន់ស្រាល ឧបមាដូចឪពុកម្តាយចិញ្ចឹមរក្សាកូន។

១៦៣. [...] ហើយបើមានមនុស្សកំណាច ការចចេញទៅរៃភត ត្បាតយក ទ្រព្យរបស់

១៦៤. លក់ក្នៃធ្វើឧក្ខបុកបិនអស់រាស្ត្រចំណុះស្រុកក្តីចេញទៅ ជាចោរលួចប្លន់ចាញ់

១៦៥. ការប់ចាក់សម្ចាប់អស់រាស្ត្រចំណុះស្រុកនោះក្តី ឱ្យចៅ ស្រុកឯជឺខ្ចីឃ្នាតសង្ខាត

១៦៦. ទំរកមនុស្សចោរកំណាចនេះឱ្យឃើញ ហើយឱ្យយក មកធ្វើនោស ដោយទៅនោស ច្ងន់ ស្រាល

១៦៧. ជូចអាពុកម្តាយចិញ្ចឹមកូន។...

ការៈពាក់ព័ន្ធនឹងវិស័យតុលាការគឺជាចំណែកមួយក្នុងកិច្ចការដៃលចៅហ្វាយ ស្រុកត្រូវបំពេញ។ ក្រៅពីនោះយើងឃើញថាចៅហ្វាយស្រុកមានភាតព្វកិច្ចច្រើនជំពូក ទៀត ដៃលត្រូវធ្វើក្នុងប្រយោជន៍រាជការផង និងរាស្ត្រចំណុះស្រុកផង។ ការទាំងនោះ ដូចជាចាំជួយជាស់តឿនក្រើនរំឮករាស្ត្រចំណុះស្រុកផង ឱ្យខិតខំបំពេញការងារខ្លួន។ បើអ្នកឯណាធ្វើស្រែឱ្យខំសង្កាតធ្វើស្រែ អ្នកឯណាជាអ្នកចម្ការឱ្យសង្កាតខំធ្វើចម្ការ អ្នក ឯណាធ្វើជំនួញឱ្យសង្កាតខំជួញ រីអ្នកឯណាធ្វើអ្វីឱ្យខំសង្កាតធ្វើការនោះ។ ចៅហ្វាយ ស្រុកខ្លួនឯងត្រូវឱ្យដឹងបុណ្យដឹងបាប កុំឱ្យប្រមាថព្រះសាសនាព្រះតថាគត គ្រូបាធ្យាយ ឪពុកម្តាយ ចាស់ទុំ ហើយកុំឱ្យលួចប្លន់កឹបកេងទ្រព្យគេឡើយ។ ចៅហ្វាយ ស្រុកជាគ្រូអស់រាស្ត្រចំណុះស្រុក និងជាម្តាយឪពុករបស់រាស្ត្រផង គោងឱ្យចេះគន់ មើលការក្រការងាយ ឱ្យដឹងកម្សត់រាស្ត្រ ឱ្យប្រណីអស់រាស្ត្រកូនចៅ។ មួយសោត ចៅហ្វាយស្រុកត្រូវឱ្យចេះដាស់តឿនអស់ពួករាជការភ្នាក់ងារយុនពួក ភ្នាក់ងារសង្ឃរី

កុដុម្ពី ពន្ធសួយដើងកបផងទាំងឡាយឱ្យខ្មីខ្មាតគិតគូរប្រមូលពន្ធអាករថ្វាយអ្នកជាអម្ចាស់តាមដោយច្បាប់កំណត់។ ក្នុងវិស័យសាសនា ចៅហ្វាយស្រុកត្រូវចេះរក្សាការពារព្រះវិហារ វត្តអារាម សាលាផងនានា ហើយត្រូវប្រាប់អ្នកព្រះសង្ឃ ចៅគូ ឱ្យសង្វាតសូត្រមន្តសំពះព្រះជម្រះអាបត្តិ រក្សាសីលកុំបីឱ្យខាន។ ឯសាមណេរឱ្យផ្សំសីលថ្ងៃ៧កុំលែងឡើយ។ នេះហៅផ្តត់ផ្តង់ព្រះសាសនារក្សាផ្នែក្រោមឱ្យសុខសួស្តីស្រឹមង្គលដល់អ្នកជាអម្ចាស់ផង។ បើមានសឹកសង្គ្រាមលើកមក ឱ្យចៅហ្វាយស្រុកចេញទៅទ័ពបន្ទាយហើយឱ្យទៅមើលជាស់តឿនប្រទល់លីវឱ្យចូលមកជូនស្បៀងកុំឱ្យយូរឡើយ។ សេចក្តីទាំងអម្បាលដែលពោលមកនេះសឹងស្រង់ចេញពីច្បាប់ក្រមស្រុកព្រះជ័យជេស្ត។

នេះតារាងលំដាប់ទម្រង់សក្តិរបស់ចៅហ្វាយស្រុក

ឈ្មោះចៅហ្វាយស្រុក	ឈ្មោះស្រុក	ទម្រង់សក្តិ
ឧកញ៉ាតេជោ	ចៅហ្វាយស្រុកសន្ទុក	១០ហ៊ិចតាឯក
ឧកញ៉ាពិស្ណុលោក	ចៅហ្វាយស្រុកទាំង	១០ហ៊ិចតាឯក
ឧកញ៉ាអរជូន	ចៅហ្វាយស្រុកថ្ងឹងឃ្មុំ	១០ហ៊ិចតាឯក
ឧកញ៉ាសួគ៌ាលោក	ចៅហ្វាយស្រុកពោធិសត្វ	១០ហ៊ិចតាឯក
ឧកញ៉ាធម្មាតេជោ	ចៅហ្វាយស្រុកបាភ្នំ	១០ហ៊ិចតាឯក
ឧកញ៉ានគរ	ចៅហ្វាយស្រុកនគរ	៩ហ៊ិចតា
ឧកញ៉ាឧទ័យធីរាជ	ចៅហ្វាយស្រុកសំរោងទង	៩ហ៊ិចតា
ឧកញ៉ាសេនាធីបតី	ចៅហ្វាយស្រុកព្រះត្រពាំង	៩ហ៊ិចតា
ឧកញ៉ានារាធីបតី	ចៅហ្វាយស្រុកសម្បូណ៌	៩ហ៊ិចតា
ពញាធីរាជវង្សា	ចៅហ្វាយស្រុកបាទី	៨ហ៊ិចតា
ពញាមហាធីរាជ	ចៅហ្វាយស្រុកសន្ទរ	៨ហ៊ិចតា
ពញារាជាស្មត់	ចៅហ្វាយស្រុកបរិបូរណ៌	៨ហ៊ិចតា
ពញារាជាកីមុន	ចៅហ្វាយស្រុកគោកសេះ	៨ហ៊ិចតា
ចៅពញារាជាស្នេហា	ចៅហ្វាយស្រុកភ្នំពេញ	៧ហ៊ិចតា
ចៅពញាយោធាធីរាជ	ចៅហ្វាយស្រុក បន្ទាយមាស	៧ហ៊ិចតា
ចៅពញាឥន្ទសេនា	ចៅហ្វាយស្រុកលង្វែក	៧ហ៊ិចតា
ចៅពញាសេនាបតី	ចៅហ្វាយស្រុកបាត់ដំបង	៧ហ៊ិចតា

ឈ្មោះចៅហ្វាយស្រុក	ឈ្មោះស្រុក	ទម្រង់សក្តិ
ព្រះសេនាធីរាជ	ចៅហ្វាយស្រុកសម្បុក	៦ហ៊ូពាន់
ព្រះសូរិន្ទធីបតី	ចៅហ្វាយស្រុកព្រៃក្របាស	៦ហ៊ូពាន់
ព្រះស្រីវីសាក់	ចៅហ្វាយស្រុកព្រៃវែង	៦ហ៊ូពាន់
ព្រះយសតេជោ	ចៅហ្វាយស្រុករលៀប្អៀរ	៦ហ៊ូពាន់
ព្រះយោធាធីបតី	ចៅហ្វាយស្រុកកំពង់សោម	៦ហ៊ូពាន់
ព្រះរាជតេជោ	ចៅហ្វាយស្រុកព្រៃក្តី	៦ហ៊ូពាន់
ព្រះសេនាសង្គ្រាម	ចៅហ្វាយស្រុកក្រគរ	៦ហ៊ូពាន់
ព្រះមនោសង្គ្រាម	ចៅហ្វាយស្រុកក្រង	៦ហ៊ូពាន់
ព្រះយោធាសង្គ្រាម	ចៅហ្វាយស្រុកខ្លុង	៦ហ៊ូពាន់
ព្រះជ័យតេជោ	ចៅហ្វាយស្រុកជើងព្រៃ	៦ហ៊ូពាន់
ព្រះធីកតេជោ	ចៅហ្វាយស្រុកបាជ័យ	៦ហ៊ូពាន់
ព្រះរាមតេជោ	ចៅហ្វាយស្រុកស្ទឹងត្រែង	៦ហ៊ូពាន់
ព្រះលីចក្រី	ចៅហ្វាយស្រុករំដួល	៦ហ៊ូពាន់

គួរបញ្ជាក់ថា «ច្បាប់ឃុនសាឡា» ដែលចារក្នុងរាជ្យព្រះបាទសត្ថាទី២ ឆ្នាំ១៦៤៥ នៃមហាសករាជ បានបញ្ជាក់ពីសិទ្ធិអំណាចជាអទិភាពរបស់មន្ត្រីទាំងឡាយដែលមានសក្តិគិតតាមចំនួនហ៊ូពាន់។ សក្តិហ៊ូពាន់នេះចែកជា «ហ៊ូពាន់ក្នុង» និង «ហ៊ូពាន់ក្រៅ»។ បើមន្ត្រីណាមានអំណាចស្មើគ្នា ឧទាហរណ៍សក្តិ១០ហ៊ូពាន់ដូចគ្នា បើម្នាក់១០ហ៊ូពាន់ក្នុង និងម្នាក់១០ហ៊ូពាន់ក្រៅ នោះមន្ត្រី១០ហ៊ូពាន់ក្នុងមានអំណាចធំជាង គោងអ្នក១០ហ៊ូពាន់ក្រៅគោរពកោតខ្លាច បើដើរជួបគ្នាត្រូវមន្ត្រីសក្តិ១០ហ៊ូពាន់ក្រៅចៀសឱ្យមន្ត្រី១០ហ៊ូពាន់ក្នុងទៅ។ ប៉ុន្តែក្នុងករណីដែលមន្ត្រីនោះមានសក្តិស្មើគ្នាគោងចៀសគ្នាតាមដោយចាស់ក្មេង។ សេចក្តីនេះមានពោលដូចតទៅ៖

> [...] ជាច្បាប់បម្រើជាមឺនជាន់ខ្ពស់ បើសក្តិ៨ហ៊ូពាន់ឱ្យចៀស១០ហ៊ូពាន់ បើសក្តិ៦ហ៊ូពាន់ឱ្យចៀស៨ហ៊ូពាន់ បើសក្តិ៤ហ៊ូពាន់ឱ្យចៀស៦ហ៊ូពាន់ បើសក្តិ២ហ៊ូពាន់ក្រៅឱ្យចៀស៦ហ៊ូពាន់ក្នុង បើសក្តិ៣ហ៊ូពាន់ក្រៅឱ្យចៀស៣ហ៊ូពាន់ក្នុង បើកំណើះរាជានុកុលនិងខាងខ្ញុំឱ្យចៀសមានជាសក្តិ៦ហ៊ូពាន់។

[...] មួយសោតសក្តិពី១០ហ៊ុំពាន់ក្រោឱ្យចៀស១០ហ៊ុំពាន់ក្នុង ៨ ហ៊ុំពាន់ក្រោឱ្យចៀស៨ហ៊ុំពាន់ក្នុង ៦ហ៊ុំពាន់ក្រោឱ្យចៀស៦ ហ៊ុំពាន់ក្នុង ២ហ៊ុំពាន់ក្រោឱ្យចៀស២ហ៊ុំពាន់ក្នុង។ មួយសោត ជាមឺនក្នុងនិងជាមឺនក្នុង ជាមឺនក្រោនិងជាមឺនក្រោ សក្តិ១០ ហ៊ុំពាន់និង១០ហ៊ុំពាន់ សក្តិ៨ហ៊ុំពាន់និង៨ហ៊ុំពាន់ សក្តិ៦ហ៊ុំពាន់ និង៦ហ៊ុំពាន់ សក្តិ២ហ៊ុំពាន់និង២ហ៊ុំពាន់ សក្តិ៣ហ៊ុំពាន់និង៣ ហ៊ុំពាន់ឱ្យចៀសគ្នាដោយចាស់ក្មេង។ ឯព្រៃជារនាំងផ្តាសឱ្យចៀស កំណេ្ចះរាជានុកុល។ ដោះឧកញ៉ាពញាព្រះក្តី បើដើរមានជារ ផលពលរយ បើនរណាដើរពាលល្មមផងល្មមវាយចានហោង។ បើ ដើរឥតសណ្តាប់ បើគេដើរពាល់ឥតក្តីឲ្បើយ បើដេពោលវាយដំគេ ពុំចានឲ្បើយ ច្បាប់ឱ្យឧកញ៉ាភំងធ្វើជារនេះហោង។ [...]

គ. ចៅក្រម

ចៅក្រមមកពីពាក្យថា «ចៅ» និង «ក្រម»។ ***ចៅ*** នៅទីនេះជាពាក្យផ្តើមហៅទៅ នរណាដែលជាចៅហ្វាយនាយ ជាម្ចាស់ ជាធំ ឬជាអ្នកដែលមានបុណ្យសក្តិដូចជាហៅ ព្រះមហាក្សត្រ «ព្រះចៅក្រុងកម្ពុជា» ហៅពួកមន្ត្រី «ចៅមឿង» «ចៅបាន» «ចៅពញា» «ចៅហ្លួង»...ជាដើម។ ចំណែកឯពាក្យ «ក្រម» ជាពាក្យដើមចេញពីភាសាសំស្ក្រឹតមាន ន័យថា លំដាប់ ក្បួន បែប របៀប វិន័យ ប្រពៃណី ច្បាប់ និងអំណាចជាដើម។ ដូចច្នេះ ពាក្យ «ចៅក្រម» មានន័យសម្តៅដល់អ្នកមានអំណាចខាងច្បាប់ អ្នកដែលជាម្ចាស់នៃ ច្បាប់ អ្នកទ្រទ្រង់ច្បាប់ ជាដើម។ មកដល់បច្ចុប្បន្ននេះ ***ចៅក្រម*** សម្តៅលើមន្ត្រីមួយពួក ដែលជាអ្នកកាន់ក្តី អ្នកដោះស្រាយវិវាទក្តីក្តាំទាំងឡាយ ដោយយោងទៅលើច្បាប់ក្រមជា ធំ។ នៅសម័យកណ្តាលពាក្យ ***ចៅក្រម*** ជួនកាលជំនួសដោយពាក្យថា «សុភា» ឬ «សភា»។ នៅក្នុង «សាត្រាកឹងកន្ត្រែ» ដែលជាកម្រងរឿងនិទានទាក់ទងនឹងតុលាការ គេហៅតួអង្គ ទន្យាយដែលជាកំពូលអ្នកកាត់ក្តីដ៏ត្រឹមត្រូវប្រកបដោយប្រាជ្ញារៀងរៃថា «សុភាទន្យាយ» ។ ពាក្យទាំងពីរនេះមានន័យពុំខុសគ្នាទេ សុភាទន្យាយគឺចៅក្រមទន្យាយនោះឯង។ ដូច្នេះសារុបមកពាក្យ ចៅក្រម សុភា ឬសភា តុលាការ និងពាក្យថាអ្នកកាត់ក្តីគឺអាស្រ័យ លើការនិយមប្រើប៉ុណ្ណោះ ឯខ្លឹមសារគឺតែមួយ។

នៅសម័យកណ្តាលពុំបានកំណត់ថាទាល់តែនរណាម្នាក់មានជំនាញឯកទេស ខាងច្បាប់ទើបធ្វើជាចៅក្រមកាត់ក្តីបានឡើយ។ ផ្ទុយទៅវិញមន្ត្រីរាជការសំខាន់ៗស្ទើរតែ

ទាំងអស់រាប់តាំងពីចៅហ្វាយស្រុករហូតដល់មន្ត្រីចតុស្តម្ភសឹងធ្វើជាចៅក្រមកាត់ក្តីជូនរាស្ត្របាន។ មន្ត្រីធំភាគច្រើនមានងារជា «ឧកញ៉ា» ហើយងារឧកញ៉ាទាំងនោះមានឧទាហរណ៍ជាអាទិគឺ៖ *ឧកញ៉ាតេជោ ឧកញ៉ាពិស្ណុលោក ឧកញ៉ាអរជុន ឧកញ៉ាសូរគ៌ាលោក ឧកញ៉ាធម្មាតេជោ ឧកញ៉ារាំង ឧកញ៉ាយមរាជ ឧកញ៉ាចក្រី ឧកញ៉ាក្រឡាហោម ឧកញ៉ាមហាមន្ត្រី ឧកញ៉ាមហាទ័ព ឧកញ៉ាចៅហ្វា ឧកញ៉ាព្រះស្តេច ឧកញ៉ាជ័រុងសេនា (តម្រង់សេនា?) ឧកញ៉ាសួស្តីឆ្វេងស្តាំ ឧកញ៉ាធម្មឧទ័យ ឧកញ៉ាពលទេព ឧកញ៉ាវង្សាអគ្គរាជ ឧកញ៉ាជ័រុងឆ្វេងស្តាំ ឧកញ៉ាទេពនាយក ឧកញ៉ាធម្មាធិរាជ ឧកញ៉ាមន្ត្រីស្នេហា ឧកញ៉ាទេពស្មត់ ឧកញ៉ារាជាធូបែសឆ្វេងស្តាំ ឧកញ៉ារាជតេជៈ ឧកញ៉ាសូភាធិបតី ឧកញ៉ាសូភាមន្ត្រី ឧកញ៉ាវង្សាធិបតី ឧកញ៉ារាជនិវេស ឧកញ៉ាកាម្មាធិបតី ។ល។* ឧកញ៉ាដែលរៀបរាប់ឈ្មោះមកនេះភាគច្រើនរាជការចាត់តាំងឱ្យធ្វើជាចៅក្រមទទួលខុសត្រូវដោះស្រាយវិវាទតាមប្រភេទផ្សេងៗរៀងៗខ្លួន។ នៅក្នុងច្បាប់ «ក្រមសុភាធិបតី» តែងក្នុងរាជ្យព្រះជ័យជេដ្ឋាទី៣ (១៦៩០-១៦៩៥) បានបែងចែកភ្នាក់ងារចៅហ្វាយជំនុំក្តី (ឧកញ៉ា) ទាំងនោះជា ១១ជំពូក។ លុះក្រោយមកក្នុង «ច្បាប់ឃុនសាឡា» ដែលតែងក្នុងរាជ្យព្រះបាទសត្ថាទី ២ (១៧២២-១៧២៩) មានចំនួន ១៤សន្លឹកក៏បានលើកមកនិយាយដូចគ្នា។

សេចក្តីចែងពីភ្នាក់ងារចៅហ្វាយជំនុំក្តីទាំង១១ជំពូកនៅក្នុងច្បាប់ទាំងពីនេះមានដូចជាខាងក្រោម ៖

> ១. សេចក្តីចោរលួចប្លន់ចាញ់ចាក់ការប់សម្ងាប់ ឫយប្លន់ការប់យកទ្រព្យរបស់ក្តី លបលួចរបស់កេក្តី ម្ចែងត្រាក្តី ទ្រុស្តក្បត់ព្រះចាងអ្នកជាអម្ចាស់ក្តី ចោរលួចអុជផ្ទះរកស្តុងជ ឬចំបើង ឬរបងសម្រាស់ ឬសារពើរបស់អ្វីៗក្តី អស់ចាំងនេះសឹងត្រូវឧកញ៉ាយមរាជឬ[៩១៨] ឧកញ៉ាវង្សាអគ្គរាជជាចៅហ្វាយជាហានជំនុំ។
>
> ២. ឯសេចក្តីអស់ជំពូកស្រីអ្នកក្នុងវាំង ឬសេចក្តីអាប ឬសេចក្តីស្រីមានថ្នាំបំពុលមនុស្សជងក្តី មានថ្នាំអំពើមួចៗក្តី នេះសឹងត្រូវឧកញ៉ាវាំងឬឧកញ៉ាធម្មាធិរាជ[៩១៩] ជាឃុនភ្នាក់ងារជំនុំ។

---

[៩១៨] «នូវ» ទីនេះស្មើពាក្យថា «និង»។

[៩១៩] ក្នុង *ច្បាប់ឃុនសាឡា* សរសេរថា «ឧកញ៉ាធម្មាធិបតីទៅវិញ»។

៣. ឯសេចក្តីចោរលួចគូក ចំហូរគូក[១២០] អុំគូកចុះជ្បើជ័ជុលគ្នា លិចលុជ័ក្តី (ចោះលិច) លជ័មានតេស្រែជ័ក្តី ក្រែពើទាំមានតេការួចក្តី ចូលខ្វីគូកតេក្តី អស់ចាំជ័នេះត្រូវមុខជារឧកញ៉ាក្រែឧប្បាហោមគូវឧកញ៉ារាជតេជះជាចៅហ្វាយអង្គរក្សជំនុំ។

៤. ឯសេចក្តីលួចជំរី បរជំរីជាន់ស្រូវ ឧម្ងាយរបជ័ កាច់របជ័ក្តី បរជំរីបំរេចឈើក្នុជ័ភូមិក្តី បរជំរីបណ្តោញតេក្តី បរកន្ជ័សារពើការតេក្តី ចោះចោរចាញ់ ចាក់ កាប់ សម្ងាប់ជំរីក្តី ចោះមនុស្សជជ័ជុតភ្លើជ័ព្រៃនេះហេលជំរីតេអ្នកក្នុជ័ប្រកាំក្តី ចោះមន្ត្រីគូវមេជ័ព មេកជ័ ច្បាំជ័ចានជំរីលាក់បំពួនក្តី ចោះជំរីសត្វព្រាត់[១២១] តេចាប់យកលាក់ចាំជ័ក្តី ចោះលក់ជំរី ឱញជំរី ខ្វីជំរីតេថៅឱ្យស្ងាប់ ជាពិការក្តី ចោះជំរីស្រុកគ្មេចមានតេជាក់ចានក្តី ជំរីស៊ីស្រូវតេក្តី ចោះអ្នកជជ័ជិះជំរីពុំធ្វើក្រិតជារាស្ត្រជ្បើយ ធ្វើជូចជាព្រះចាជអ្នកជាអម្ងាស់ក្តី ចោះមនុស្សជជ័លក់ជំរី ចាញ់ជំរីយកភ្ងុក ចោះចោរលួចស្តាន់ រមាំជ ជ្ងូកត្រូវអជ្ញាក់ត្រូវអង្គប់តេក្តី តេចាញ់ត្រូវបូសក្តី ឆ្កែតេទាំក្តី ចោះសេចក្តីធ្មប់ក្តី[១២២] ជាក់ស្នេហ៍ស្រីក្តី ចោះប្រុសមានថ្នាំបំពុលស្រីប្រុសជជ័ក្តី អស់ចាំជ័នេះសឹជ័ត្រូវមុខជារឧកញ៉ាចក្រី ឧកញ៉ារាជនិវេសជាចៅហ្វាយជំនុំ។

៥. ឯសេចក្តីចោរលួចអ្នកព្រះពុទ្ធរំលាយ កាប់ដើមព្រះស្រីរតន៍មហាពោធិហើយចោជអ្នកព្រះសង្ឃក្តី ចោះព្រះសង្ឃឧ្វ ត្រហស្តប្រឈ្មោះប្រភាយត្រូវព្រះសង្ឃ ចោះព្រះសង្ឃ កិក្ខុសាមណេរឈ្មោះប្រភាយគ្នាក្តី ព្រះសង្ឃពុំកាន់ដោយក្រិតព្រះ

---

[១២០] ពាក្យ «ចំហូរ» នេះបើតាមវចនានុក្រមខ្មែរបស់វិទ្យាស្ថានពុទ្ធិសាសនបណ្ឌិតមានន័យថាសេចក្តីបោកបញ្ឆោទ ឬគម្រោមកំហែង។ ប្រសិនបើប្រែដូច្នេះ «ចំហូរទូក» នៅទីនេះឃើញថាឆ្គងមិនស្របន័យគ្នាសោះ។ តែបើតាមអង្កេតរបស់ខ្ញុំលើពាក្យ «ចំហូរ» នេះក្នុងបរិបទផ្សេងទៀត ខ្ញុំយល់ថា *ចំហូរ* គឺការធ្វើឱ្យខូចខាត បំផ្លិចបំផ្លាញ ធ្វើឱ្យបែកបាក់ខ្ទេចខ្ទី ឬធ្វើឱ្យអាស្រូវកេរ្តិ៍ឈ្មោះជាដើម។ ឧទាហរណ៍ ចំហូរដំរី ចំហូចរទេះ ចំហូរគោ ចំហូរសេះ ចំហូរឈ្មោះ...ជាដើមសឹងជាពាក្យដែលប្រទះក្នុងសាស្ត្រាសម័យកណ្តាល។

[១២១] សព្វថ្ងៃសរសេរថា «ខ្ចាត់ព្រាត់»។

[១២២] ចំណុចនេះនិយាយតែក្នុងច្បាប់ *យុនសាឡា* ប៉ុណ្ណោះ ឯច្បាប់ *ក្រមសុភាធិបតី* ឥតនិយាយដល់រឿងធ្មប់នេះទេ។

វិន័យអ្នកព្រះពុទ្ធឲ្បើយ ក្បត់ព្រះសាសនាបរាជិកក្តី សម្ព័ន្ធ
ន៏ជមេសិការក្តី សម្ព័ន្ធន៏ជសារពើសត្វក្តី ចោះជាចោរលួចប្លន់
សម្ងាប់មនុស្សឲ្យសារពើសត្វក្តី ពុំកាន់ដោយក្រិតវិន័យ ចោះ
ត្រហស្តវាយម្តាយឪពុកប្រមាថមេថា ដេវាយដំម្តាយមីន
ឪពុកមា ជីដូន ជីតា ចោសខ្ញែះរាជ អម្ពន ពានជុន[123] ខ្ញុំប្រុស
និន៏ម្ងាស់ស្រី ពានជុននឹន៏ម្តាយមីន៏ជាបង ជាប្អូន កូនក្មួយ ចៅ
ត្រួវជាសាច់ (ញាតិ) និន៏អម្ងាស់ ជាម្តាយមីន៏ ជាបង ជាប្អូន
បង្កើត ជីដូនមួយ ជីចួតមួយក្តី ចោះខ្ញុំកេជាវប្រម៉ាត់[124] ជាអន្ត
ការនឹន៏ស្រីអ្នកជាគ្រៅអំពីសាច់នឹន៏អម្ងាស់ក្តី ចោះមនុស្សដន៏
សម្ព័ន្ធន៏ជសារពើសត្វក្តី ចោះជាចោរកាស់កំណាប់កេ កាស់ព្រះ
ចេតិយ កាស់សីមាក្តី ចោសចាំន៏អស់នេះសឹន៏ត្រួវមុខជារ
ឧកញ៉ាព្រះស្តេចឲ្យឧកញ៉ាចម្មាឧន៏យជំនុំ។

៦. ឯសេចក្តីជណ្តើមភូមិ ជណ្តើមស្រែ សែន៏ខ្មោចដៅជុតដៅកប់
លើភូមិស្រែកេក្តី ដៅកាប់ឈើរំលំលើភូមិកេក្តី លើស្រូវស្រែកេ
ក្តី ចោះចោរលួចសារពើដំណាំ អង្កាល់ រនាស់ ស្នាច ត្រដោក
ខ្សែ កេក្តី ចោះលួចបើកឆឹកអំពីស្រែ ត្រពាំន៏ជកេក្តី ចោះលួច
ស្រូវកេ បរាជេះលើស្រូវកេ ចោះក្រុបីស៊ីស្រូវកេ ត្រាំក្នុន៏ស្រូវកេ
ក្តី ចោះក្រុបីជល់សារពើដំណាំកេក្នុន៏ច្បារកេក្តី ចោះចោរលួច
ក្រុបី ឆ្កែ ជ្រូក មាន់ ជា កេក្តី ចោះចោរលួចរជេះក្តី ទ្រូ លាយ
លាន់ជន៏ជាំន៏ឲ្បាយក្តី សេចក្តីអស់ជាំន៏នេះត្រួវឧកញ៉ាពល
ដេពធ្វេន៏ស្តាំឲ្យឧកញ៉ាដេពជាយកជាឃុនភ្នាក់ជារជំនុំ។

៧. ឯសេចក្តីចោរលួចសេះ ចាញ់ ចាក់ កាប់សេះកេក្តី បរជាន់កេ
ក្តី បរាជេះពុំត្រួវនឹន៏សក្តិយសក្តី ចំហូរសេះកេក្តី ក្រុបីជល់
សេះកេក្តី ចោះដឹកសេះ បរសេះជាន់ស្រូវ ចន៏សេះឱ្យស៊ីស្រូវ
ជនៀលក្នុន៏ស្រូវកេ ចាប់សេះសត្វព្រាត់ (ខ្ចាត់ព្រាត់) ក្តី មេន៏ព
មេកន៏ច្បាំន៏សឹកចានសេះលាក់បំពួនក្តី អស់ជាំន៏នេះត្រួវមុខ

---

[123] អំពីទោសទាំងនេះ *ជ្រេះរាជ, អម្ពន, ពានជុន* នឹងពន្យល់នៅត្រង់ចំណុច ២.៥ អំពីទោស។

[124] ដូចគ្នាដែរ ជាវប្រម៉ាត់ ជាប្រភេទទោសដែលនឹងនិយាយនៅត្រង់ចំណុច២.៥។

ជារឧកញ៉ាដ៏រុងធ្វើដស្តាំឲ្យរឧកញ៉ាមន្ត្រីស្នេហាជាឃុនក្នាក់ជាសេះជំនុំ[១២៥]។

៨. ឯសេចក្តីចោលួចគោព្រោះ លួចគោកូនចាដៅស្រុកគ្រោក្តី គោះចោរលួចគោ រនេះ ដៅក្នុងព្រះរាជធានីក្តី គោះចំហ្យរគោក្នា គោះចាញ់ ចាក់ កាប់គោក្នុងព្រះរាជធានីក្តី អស់សេចក្តីចាំងអម្បាលនេះត្រូវចៅហ្វាយគោធ្វើដស្តាំឲ្យរឧកញ៉ាដេពស្នត់ជាឃុនក្នាក់ជារជំនុំ។

៩. ឯសេចក្តីចៅហ្វាយកាំភ្លោះ ចៅហ្វាយពល ប្រចាប់កាំភ្លោះ ប្រចាប់ពល យកមកជំនុំចែកភ្នែកមេភ្នែកចា យកកាំភ្លោះយកពលចាត់ជាព្រៃជារក្តី គោះគេលក់ពល បំចាត់កាំភ្លោះក្តី អស់សេចក្តីចាំអនេះត្រូវឧកញ៉ារាជាធូបែសធ្វើដស្តាំឲ្យរឧកញ៉ាសួស្តីធ្វើដស្តាំជាចៅហ្វាយសួស្តីជំនុំ[១២៦]។

១០. ឯសេចក្តីសម្បត្តិ បើកេរ្តិ៍ព្រះចាឧអ្នកជាអម្ចាស់ឱ្យយសឱ្យសក្តិឥតជារាជការ គោះឱ្យជាព្រះពញា ជាឧកញ៉ា គោះឃុនណាដ៏ស្រី។ ព្រះចាឧជាអម្ចាស់ឱ្យយសឱ្យសក្តិយ្យរហឹមច្បើដកាល់ក្តី ឱ្យជាដំណាវក្តី អស់ចាំដនេះបើស្ងាប់ដៅសឹដឱ្យកមរតកជាដថ្ងាយ។ បើអស់បដ៏ប្អូនកូនក្មួយដណ្តើមខ្ញុំកំដរឲ្យរអស់សារពើរបស់សម្បត្តិដោយញាតិប្រុសស្រី គោះត្រូវឧកញ៉ាមហាមន្ត្រីឲ្យរឧកញ៉ាមហាដេពឲ្យរឧកញ៉ាមន្ត្រីអជ្ញិតជាអាជ្ញាព្រះរាជភេដ៏ជំនុំ។

១១. បើសេចក្តីប្រកៀកប្រកាប់ប្រចាក់ភ្នាដណ្តើមស្រីជាអន្តរាក្តីត្រូវឧកញ៉ាយមរាដឲ្យរឧកញ៉ាសុភាធិបតីជំនុំ។ បើសេចក្តីចោរប្លន់កាប់អ្នកព្រះសង្ឃត្រូវមុខជាឧកញ៉ាយមរាដឲ្យរឧកញ៉ាព្រះស្តេចជំនុំ។

---

[១២៥] នៅចំណុចទី៧នេះបើផ្ទៀងផ្ទាត់ច្បាប់ទាំងពីរគឺ *យុនសាឡា* និង *ក្រមសុភាធិបតី* ឃើញថាច្បាប់ឃុនសាឡានិយាយបាត់ច្រើនប្រការពុំក្បោះក្បាយដូចក្រមសុភាធិបតីឡើយ។

[១២៦] សេចក្តីនៅក្នុងជំពូកនេះ ក្រមសុភាធិបតី និយាយតែឧកញ៉ារាជាធូបែសឆ្វេងស្តាំប៉ុណ្ណោះជាអ្នកជំនុំ។ តែនៅក្នុងច្បាប់ឃុនសាឡាមានដល់ទៅពីរនាក់គឺឧកញ៉ារាជាធូបែសឆ្វេងស្តាំផង និងឧកញ៉ាសួស្តីឆ្វេងស្តាំផង។

នៅទីបំផុតនៃច្បាប់ក្រមសុភាធិបតីបានបង្ហាញពីប្រភេទវិវាទមួយចំនួនទៀតក្រៅអំពីវិវាទដែលបែងចែកទៅតាមភ្នាក់ងារទាំង១១ជំពូកនោះ ហើយដែលជាការៈរបស់ឧកញ៉ាសុភាធិបតីនិងឧកញ៉ាសុភាមន្ត្រីជំនុំដោះស្រាយដែលមានសេចក្តីដូចតទៅ៖

> បើសេចក្តីឈ្លោះប្រកែកប្រកាយប្រកាប់ប្រចាក់ក្នាក្តី ភៃតត្បាតយកសារពើរបស់គេក្តី ចាប់ប្រពន្ធកូនគេក្តី ជេរពោលត្មេះគេក្តី ជេរវាយលើអាជ្ញារាជាព្រះបន្ទូលក្តី ត្មេះតេះដៀលព្រះចំណាំក្តី ជួលខ្វីចង់ការប្រវ័ញ្ចក្តី ជិតប្តី លួចប្រពន្ធ លួចមេខា កន្ទុំជាតិលួចប្តី ជាំពន្លិត់ប្រពន្ធកូនខ្ញុំគេ ពន្លិត់កូនប្រពន្ធឪខ្ញុំគេដៅលក់ក្តី វាយមហាត វាយពល ប្រើមហាត ប្រើពលឱ្យពិការឱ្យស្លាប់ក្តី សេចក្តីមហាតនិងព្រៃជារដណ្តើមរបស់សម្បត្តិក្តី បុលជំពាក់ទ្រព្យដៅវិញដៅមកក្តី ដោះយកសារពើគុណាក្តី សេចក្តីលួចខ្វីក្នាក្តី ជាំការប្រពន្ធកូនចៅខ្ញុំគេក្តី ហែការបង់ ចូលក្នុងរបង់ ឡើងលើផ្ទះចាប់ប្រពន្ធកូនចៅគេក្តី ហៅក្នាធឹកស្រាប្រវាយនឹងដំបង ពួនដំស្លាប់ក្តី រស់ក្តី ធ្វើកលបំភូតក្នាក្តី សេចក្តីជាក់ជាំកូនចៅឱ្យមានប្តីប្រពន្ធក្តី យកកូនគេជាកូនធម៌ក្តី ដោះសារពើអ្វីៗក្តី ក្រៅអំពីចៅហ្វាយជាំង១១ជំពូកនេះហើយសឹងត្រូវឧកញ៉ាសុភាធិបតីឬឧកញ៉ាសុភាមន្ត្រីឱ្យយកឱ្យអូសឱ្យកោះមកជំនុំ។ ដោះសារពើសេចក្តីគ្រប់អស់ក្នាក់ជារជំនុំរង់ពុំអស់ពុំហើយឱ្យក្រាបទូលជាំសេចក្តីដោះដៅសាលាបញ្ជាន់សឹងឱ្យឧកញ៉ាសុភាធិបតីឬឧកញ៉ាសុភាមន្ត្រីជាក្នាក់ជារឃុនសាលាជំនុំសេចក្តីតាមដោយឆ្ងន់ស្រាលដោះហោង។

នៅក្នុងច្បាប់នានាដែលនិយាយពាក់ព័ន្ធនិងចៅក្រមជំនុំក្តីតែងតែនិយាយរឭកជារឿយៗអំពីកាតព្វកិច្ច ក្រមសីលធម៌ និង អាកប្បកិរិយារបស់ចៅក្រមដែលត្រូវបំពេញឱ្យខាងតែបាន។ ដើម្បីបំពេញមុខងាររបស់ខ្លួនក្នុងការផ្តល់យុត្តិធម៌ អ្នកកាត់ក្តីទាំងឡាយត្រូវវៀរចាកអគតិធម៌ផងទាំងឡាយ ហើយត្រូវតម្កល់ចិត្តឱ្យនឹងស្មើកុំឱ្យអស់ចៅក្រមផងលោភោ ទោសោ កយា មោហោ និងឆន្ទាឡើយ ឱ្យតម្រង់ចិត្តដោយនូវក្តីបួនប្រការ។

- **លោភោ** គឺចៅក្រមត្រូវវៀរចាកអគតិដោយសារការលោភលន់។

- **ឧបោសោ** គឺចៅក្រមត្រូវរៀបចាកសេចក្តីលម្អៀងដោយការស្អប់ក្រោធ ចង់កំនុំ។
- **ភយា** គឺត្រូវរៀបចាកសេចក្តីលម្អៀងដោយការភ័យខ្លាច។
- **មោហោ** គឺចៅក្រមត្រូវចៀសវាងអតតិចាំងឧប្បាយដែលកើតដោយភាពល្ងិតល្ងង់ ឬសេចក្តីវង្វេងជាដា។
- **ឆន្ទា** គឺចៅក្រមត្រូវប្រកាន់ចិត្តជាកណ្តាលមិនលម្អៀងព្រោះសេចក្តីស្រលាញ់ពេញចិត្តលើភាគីណាមួយឡើយ[១២៧]។

ឯសេចក្តី៤ប្រការដែលជាលក្ខណៈរបស់ចៅក្រមត្រូវតាំងចិត្តប្រតិបត្តិឱ្យខ្ជាប់ខ្ជួននោះមានចែងក្នុងច្បាប់ «ប្រដៅចៅក្រម» រាជ្យព្រះជ័យជេដ្ឋទី៣ និងច្បាប់ «ឃុនសាឡា» របស់ព្រះបាទសត្ថាទី២។ ចៅក្រមទាំងឡាយបើនឹងពិចារណាសារពើសេចក្តីអស់អ្នកផងគោងស្គាល់សេចក្តីទាំង៤ជំពូក ១ហៅមន្ទលេន ១ហៅសេនបទ ១ហៅមន្ទកដ ១ហៅសីហាលោ។

- ជាហៅ «**មន្ទលេន**» ឱ្យជំនុំពិចារណាសេចក្តីគេនោះសព្វឹមៗ ឧបមាបីដូចឆឹកស្វឹងហូរស្មោះចូលត្រពាំងស្រះផង់ពុំដែលវិលវល់ឡើយ ឱ្យកសព្វឹមសេចក្តីនោះ ឱបនឹងឃើញសេចក្តីនោះហោង់។
- ជាហៅ «**សេនបទ**» ឱ្យពិចារណាសេចក្តីគេបីដូចខ្វែងជាបសត្វផង់ចាំងឧប្បាយនោះវាសម្តៅក្រចកក្រចៅចាប់ខ្ជាប់កុំឱ្យប្រែច្រាលចានឡើយ។ បើចៅក្រមស្តាប់ពាក្យត្រង់ណាឱ្យកត់ពាក្យនោះឱ្យខ្ជាប់ខ្ជួចវាប្រែច្រាលក្រឡាស់ពាក្យនោះវិញ។
- ជាហៅ «**មន្ទកដ**» ឱ្យពិចារណាសេចក្តីនោះបីដូចកង្កែបលោត។ កាលណាវាលោតនោះវាមើលមើលឆ្វេងស្តាំហើយឱបវាលោតទៅទៀត។ ឱ្យចៅក្រមផង់ស្តាប់សេចក្តីពាក្យគេថ្លែងនោះ ហើយឱ្យកត់ពាក្យដើម ពាក្យកណ្តាល ពាក្យចុង់ចុងឱ្យខ្ជាប់ហើយឱបនឹងឃើញសេចក្តីនោះហោង់។

[១២៧] នេះជាសេចក្តីពោលក្នុង *ក្រមប្រដៅចៅក្រម* ឆ្នាំ១៦១៥ស.ក.ត្រូវនឹងឆ្នាំ១៦៩៣ រាជ្យព្រះជ័យជេដ្ឋាទី៣។

- ជាហៅ «**សីហាសោ**» ឱ្យពិចារណាសេចក្តីដោះលែមដឹងជាខុស ជាត្រូវហើយឱ្យចៅក្រមជនជំយកអំណាចធ្វើជាធំពន្លឹកដូចរាជសីហាប្រើអំណាចសន្លប់សត្វម្រឹកបក្បីជន។ នេះក្រែងអ្នកក្តីដោះប្រែប្រែកែកប្រកួតវិញ នើបឱ្យចៅក្រមយកឮវាក្យរាជាសីហាសោស្រដីទៅអ្នកដែលរឹងរូសដោះឯងឱ្យវាចាញ់ហើយនើបបង្គាប់តាមច្បាប់ហោង។

ក្រៅពីសេចក្តីដែលនិយាយរៀបរាប់ពីគុណសម្បត្តិ កាតព្វកិច្ច ក្រមសីលធម៌និងសេចក្តីរំឭកជាស់តឿនចៅក្រមឱ្យប្រតិបត្តិតាមគន្លងសីលធម៌ច្បាប់ក្រមត្រឹមត្រូវហើយ ក្នុងច្បាប់ទាំងនោះសោតក៏បង្ហាញឱ្យយើងដឹងពីទោសទាំងឡាយរបស់ចៅក្រមដែលកាត់ក្តីខុសពុំដោយនូវច្បាប់ក្បួន។ ចៅក្រមអគតិពុំប្រកបដោយសុភវិនិច្ឆ័យកាត់ក្តីលម្អៀងនាំទុក្ខដល់រាស្ត្របង្កើតក្តៅក្រហាយដល់ផ្នែក្រោម រមែងត្រូវទទួលទណ្ឌកម្មហើយនឹងបានធ្លាក់ទៅនរកពុំលែងឡើយ។ សព្វថ្ងៃនៅលើជញ្ជាំងខាងក្នុងបន្ទប់សាវនាការនៃសាលាយុត្តិធម៌ដែលបច្ចុប្បន្នជាបន្ទប់បណ្ណាល័យនៃក្រសួងយុត្តិធម៌មានស្លាកមួយដែលចារឹកក្រោមទម្រង់អក្សរខ្មែរកណ្តាលហើយដែលសម្រួលជាខ្មែរសព្វថ្ងៃថា «អ្នកដែលលុះដោយអគតិ៤បទគឺដូចញុំាងនូវទ្រនិចត្រាជូឱ្យល្បៀងចុះ អ្នកនោះនឹងត្រូវទោសទណ្ឌកម្មក្នុងឥហាលោកនិងបរលោក[១២៨]»។

នៅក្នុងច្បាប់ «ក្រមពួក» ចែងក្នុងឆ្នាំ១៦១៩ នៃមហាសករាជ រាជ្យព្រះបាទជ័យជេដ្ឋាទី៣ បញ្ជាក់ថា ក្នុងករណីរកឃើញថាចៅក្រមកាត់ក្តីលម្អៀងពុំត្រូវតាមច្បាប់ចៅក្រមនោះនឹងត្រូវទម្លាក់ជារាស្ត្រវិញ។

> មាត្រា១ ឧរអ្នកជនជំមានសារតើសេចក្តីដៅជំនុំនឹងចៅក្រមមានពាក្យថាចៅក្រមពុំត្រជំជាន់ឫកស្បើជ ឱ្យចៅក្រមក្រោយជំនុំឱ្យចៅក្រមដើម បើរកដៅឃើញថាជាពិតត្រជំជាន់ឫកស្បើជពិតកេថាចានហោង។ ឯសេចក្តីដោះឱ្យចៅក្រមក្រោយជំនុំហើយឱ្យបន្តចៅក្រមដើមដោះជារាស្ត្រវិញហោង។ បើរកដៅពុំដូចអ្នកក្តីថាឡើយ ចៅក្រមដោះត្រជំពុំជាន់ឫកស្បើជឡើយ ព្រះក្រែត្តិការថាឱ្យយកពីចៅក្រមពិជ័យ ឯសេចក្តីដោះឱ្យកាត់ជាចាញ់កេហោងជ្បិតសេចក្តីដោះពិតជាតាមនឹងចានឈ្នះសេចក្តីហេតុ

[១២៨] សូមមើល ហ៊ែល ចំរើន ២០០៩: ២៩៦។

ចៅក្រមត្រង់ពិតនើបនេះពាបហរាមុខឱ្យអ្នកក្តីនោះចាញ់ចៅក្រម ហើយចាញ់ជាំជ័ក្តីឯជ័ដោជ័ហោជ័[១២៩]។

នៅក្នុងច្បាប់ «ក្រមសារពើគុណ» មានមាត្រមួយចែងថា ចៅក្រមទទួលក្តីគេស្រាប់តែមានហេតុអាសន្ន ទោះបីភ្លើងឆេះផ្ទះ លិចទូក មានសឹកសង្គ្រាមមកដល់ ចៅក្រមរត់ចោលផ្ទះ ហើយបាត់កំណត់ពាក្យ រឿងក្តីនោះទុកថាអសារបង់ទៅ។ អ្នកក្តីទាំងពីរពុំឱ្យបង្គាប់កត់វិញឡើយ ដ្បិតគេជឿថាទេវតាមានទិព្វចក្ខុពុំឱ្យអ្នកទាំងពីរជោក្តីផងគ្នាឡើយ។ បើចៅក្រមឯណាធ្វើក្តីនោះវិញ ចៅក្រមនោះជាអ្នកបំបែករាស្ត្រមានទោសលើទម្ងន់ផ្ទៃក្រោម។

> មាត្រាមួយសោត ជោះបីអ្នកជ័ជាំជ័ពួជ័មានសេចក្តី មានសារពើសេចក្តីជ័ក្នាប្តីជ័ចៅក្រមមានកំណត់ពាក្យដៅដៃចៅក្រម ជោះបីចៅក្រមជោះខុសជឹជ័ព្រះចាជជាអម្ងាស់ឱ្យរឹបចាត់កំណាត់ពាក្យពីចៅក្រមក្តី ជោះមានភ្លើជ័ឆេះផ្ទះចៅក្រមហើយឆេះជាំជ័កំណាត់ពាក្យក្តី ជោះលជ័ទូកចៅក្រមហើយចាត់ជាំជ័កំណាត់ពាក្យក្តី ជោះមានសឹកផ្ទៃក្រោមកង្វល់ហើយចៅក្រមជោះរត់ចោលផ្ទះហើយចាត់ជាំជ័កំណាត់ពាក្យក្តី ជោះព្រះច្បាប់ពុំឱ្យចៅក្រមបង្គាប់ អស់ចៅក្រមជាំជ័សង្ហាជ័កត់ពាក្យជំនុំបំបែកជាជំឱ្យចានជាលក់ឆ្នៃក្នាឡើយ ឱ្យចៅក្រមបង្គាប់សុក្ខតិកុំមជាំជ័ជ័ក្នាជាលាជ័សាជចៅក្រមដោយជូរច្បាប់ហោជ័ ហេតុអស់ជេញ្ញាជាលោកបើកជិព្វចក្ខុមកពុំឱ្យអ្នកជាំជ័ជេះជាក្តីជ័ក្នាសៅហ្មជ័ឡើយ។ ចៅក្រមឯណាទិតទំបង្គាប់ឱ្យកត់ពាក្យវិញជៀតបំបែកឱ្យចានលក់ឆ្នៃក្នា ហើយឧកចៅក្រមជោះឯជ័ជាអ្នកបំបែកភាស្ត្រមានជោសលើជម្ងន់ផ្ទៃក្រោមហោជ័ បើមានសេចក្តីជ័ជ័ក្នាជណ្តើមសម្បាច់ ជោះបើអស់អ្នកក្តីជាំជ័សង្ហាជ័សើរើជៅឡើជ ជោះឱ្យចៅក្រមបង្គាប់ឱ្យកត់ចំណាំអស់របស់ជាំជ័សង្ហាជ័ ឌើបឱ្យចៅក្រមចែកចានហោជ័។

ចំណែកនៅក្នុងច្បាប់ «សងគ្រី ឬសង្ឃរី» មានមាត្រាមួយដែលចែងដំបូងគេបង្អស់ថា កាលបើអ្នកណាមានទោស ត្រូវបង់ក្រយាពិន័យប៉ុន្មានៗក្តី ឯក្នុងច្បាប់ពុំឱ្យ

---

[១២៩] *ក្រមពួក* ទំ.១៣-១៤។

ប្រណីដល់ជននោះឡើយ ហើយបើចៅក្រមមានចិត្តសណ្តោសប្រណីឯងយល់ជាចៅក្រមនោះល្មើសច្បាប់ព្រះក្រិត្តិការ ត្រូវឱ្យចៅក្រមនោះបង់ក្រយាពិន័យជំនួសនូវទ្រព្យគេនោះ១ជា១០។

> មាត្រា១សោត បើអ្នកឈ្លោយកជាំជ័បជ័ជាំជ័ម្ខួនបង្ក្លើតជាប្រពន្ធ ជាំជ័ពីរក្តី នោះយកបជ័ខាជ័ប្រពន្ធអាពុកក្តី នោះយកជាំជ័ម្តាយមីជ័ យកក្មួយបង្ក្លើតក្តី នោះយកជាំជ័ម្តាយជាំជ័កូនធ្វើកូនចុជ័បង្ក្លើតជាប្រពន្ធក្តី នោះយកជាំជ័ជីដូនជាំជ័ចៅបង្ក្លើតជាប្រពន្ធក្តី នោះសុំកូនគេពីតូចទ្រព្យឪកដោះ កាត់សុក ឧកឈ្មោះធ្វើជាកូនហើយវិលមកយកជាប្តីប្រពន្ធវិញ បើកូនដើមកូនជម៌យកគ្នាជាប្តីប្រពន្ធក្តី ហើយកូនដើមកូនជម៌ទៅយកជីតា ជីដូន មា ម្តាយមីជ័បង្ក្លើតនឹជ័អាពុកជម៌ម្តាយជម៌ក្តី អស់ទោសជាំជ័អម្បាលនោះនោះញាតិខាជ័ប្តីក្តីខាជ័ប្រពន្ធក្តី សឹជ័ត្រូវទោសជាជម្ងន់ឱ្យរឹបទ្រព្យរបស់ហើយលក់ជាច់សុរិលបជំនិម្ងយតួកុំប្រណីឡើយ ហើយ[?]ចេញ បើចិត្តវាស្វាហិចស្វាហាវត្រឹមអត្ថការនឹជ័គ្នាទេ ឱ្យលក់ជាច់សុរិលបជំនិម្ងយតួកុំរឹប (ទ្រព្យរបស់) បើមែនដូច្នោះហើយ ចៅក្នាក់ជារលុកលោះលារប្រណីឯជ័ត្រូវចៅក្រមក្នាក់ជារនោះសជ័ព្រះរាជទ្រព្យ បើលោះក្រយាពិន័យនូវទ្រព្យរបស់អម្បាលដែលនោះតាំជ័ជា១០ឱ្យចៅក្រមក្នាក់ជារនោះសជ័។

ចំណែកឧទាហរណ៍មួយទៀតទាក់ទិននឹងរឿងចៅក្រមដែលជំនុំក្តីគេខុសហើយទទួលពិន័យខ្លួនឯង គឺរឿងចិនខ្វីបៀរហ្លួងពីអ្នកឃ្លាំងដែលរឿងនេះសោតជារឿងមួយតែយើញចារនៅក្នុងច្បាប់ពីរផ្សេងគ្នា។ ច្បាប់ទី១គឺ «ច្បាប់ទំនឹមពីបុរាណ» ត្រង់ទំនឹម១៥ និងច្បាប់មួយទៀតគឺ «ច្បាប់សារពើល្បែងភ្នាល់គ្នា» ត្រង់សន្លឹកទី៤៣ បន្ទាត់២០៤ ដល់ ២១៩។ សេចក្តីក្នុងច្បាប់ទាំងពីរនិយាយពីចិនម្នាក់ទៅខ្វីបៀពីអ្នកឃ្លាំង ឯអ្នកឃ្លាំងនោះយកបៀហ្លួងឱ្យទៅ។ ក្រោយមកបៀនោះបាត់ ព្រះអង្គជ្រាបឱ្យអ្នកឃ្លាំងនោះសងថ្លៃបៀរ។ ទើបអស់ជំនុំទៅសួរអ្នកផ្សារពីថ្លៃបៀរក្រែតើប៉ុន្មាន។ ទើបគេប្រាប់ថាបៀរនោះថ្លៃបាត ៥ ក៏មាន បាត១០ ក៏មាន។ អស់អ្នកជំនុំកាត់ថ្លៃបៀនោះជាបាត១០ ហើយទ្វេឡើង១ ជា ១០ ត្រូវជាប្រាក់ជឹង១ តម្លឹង៥ ឱ្យអ្នកឃ្លាំងសង។ គាប់ជួនឧកញ៉ាក្រឡាហោមឡើងគាល់ស្តេច ព្រះអង្គទ្រង់សួរទៅឧកញ៉ាថាតើបៀថ្លៃប៉ុន្មាន? ឧកញ៉ាក្រឡាហោមទូលវិញថាបៀ

រាស្ត្របាត១០ បៀរហ្លួងថ្លៃតម្លឹង៥។ ព្រះអង្គឮហើយខ្ចាល់ឱ្យអាជ្ញាទៅប្រាប់ចៅក្រមឱ្យ គិតក្រយ៉ាពិន័យម្តងទៀត។ ទើបចៅក្រមទាំងនោះគិតក្នុងថ្លៃបៀហ្លួងតម្លឹង៥ ទ្វេមួយជា ១០ ត្រូវជាតម្លឹង៥០ លើសអំពីមុន។ អ្នកឃ្លាំងពុំសុខចិត្តឡើយ ឡើងក្រាមទូលដល់ស្តេច។ ព្រះអង្គមានព្រះបន្ទូលថា ចៅក្រមឥតពិចារណា គិតខុសខ្លួនឯងហើយរើសេចក្តីបង្គាប់ដោយចិត្តឯង ត្រូវឱ្យកាត់អណ្តាត។ ព្រះអង្គអនុគ្រោះឱ្យត្រឹមចៅក្រមទាំងនោះរកប្រាក់បង់ក្រយ៉ាពិន័យជួសគេពុំឱ្យកាត់អណ្តាតឡើយ។

> មានជំនឹម១៤ កាលព្រះអង្គតជំនៅបង្ហាយជំនោះ មានចិន១ស្គាល់តម្ងែចឃ្លាំងមកខ្វីបៀអ្នកឃ្លាំង១ឱ្យបៀហ្លួង។ បៀនោះចាត់។ ព្រះអង្គជ្រាបជាបៀនោះចាត់ឱបឱ្យចៅក្រមជំនុំ។ លុះចៅក្រមជំនុំពិចារណាយល់ថាស់អ្នកឃ្លាំងនោះខុសឱ្យបៀទ្រជំនៅចិនពុំចានក្រាបទូលឱ្យជ្រាបឡើយយល់ជាតាក់តែងឯង។ ឱបអស់ជំនុំឡើងក្រាបទូលដោយទោស ហើយព្រះអង្គពុំឱ្យពិន័យជាតាក់តែងនោះឡើយ ឱ្យសងតែថ្ងៃបៀ។ ឱបអស់ជំនុំចុះទៅឯសាលា ហើយអស់ជំនុំឱ្យទៅជណ្តើងចិនឯផ្សារ ឯថ្ងៃបៀរក្រែតើប៉ុន្មាន។ ឱបអស់ចិនផ្សារ ថាឯថ្ងៃបៀរនោះចាត៤ក៏មានចាត១០ក៏មាន។ ឱបអស់ជំនុំកាត់ថ្ងៃបៀទ្រជំនោះចាត១០ហើយទ្វេឡើង១ជា១០ត្រូវជាច្រាក់ជីង១តម្លឹង៤ហើយឡើងមកក្រាបទូលជ្រាបហើយចុះទៅឱ្យធ្វើសំបុត្រឱ្យអ្នកឃ្លាំងរកច្រាក់ជីង១តម្លឹង៤ថ្វាយ។ លុះឧកញ៉ាក្រែឌ្បាហោមឡើងទៅតាស់ ក្សត្រមានព្រះបន្ទូលត្រាស់ជណ្តើងឧកញ៉ាក្រែឌ្បាហោមថាបៀតើថ្ងៃប៉ុន្មាន។ ឱបឧកញ៉ាក្រែឌ្បាហោមថាឯថ្ងៃបៀរក្រែនោះចាត១០ឯថ្ងៃបៀរហ្លួងថ្ងៃតម្លឹង៤។ ឱបព្រះអង្គខ្ចាល់ឱ្យអាជ្ញាទៅជណ្តើងចៅក្រមឱ្យអស់ចៅក្រមគិតក្រយ៉ាពិន័យវិញទៀត។ ឱបអស់ចៅក្រមចាំងនោះគិតក្នុងថ្ងៃបៀហ្លួងតម្លឹង៤ទ្វេ១ជា១០នោះត្រូវជាតម្លឹង៤០ឱ្យដូងអ្នកឃ្លាំង១ពុំឧទ្ធូលឡើយ។ អ្នកឃ្លាំងឡើងក្រាបទូល ឱបហ្លួងមានព្រះបន្ទូលថាចៅក្រមឥតពិចារណាគិតខុសឯងហើយតើងឱ្យម្តេចទៅតេវិញទៀតកុំឱ្យឧទ្ធូលឡើយ។ ចៅក្រមរើបង្គាប់ឯងត្រូវឱ្យកាត់អណ្តាតឱបឱ្យឧទ្ធូល។ ឱបមានព្រះបន្ទូលឱ្យត្រូវចៅក្រម

អស់ចាំដនោះត្រូវក្រែយ៉ាពិដ័យតាដកេដីដ៏ឯតម្ងឹដ៏ឥ។ ឌើបអស់ដំនុំ
ត្រប់ភ្នារកច្រាក់ដីដ៏ឯតម្ងឹដ៏ឥឡើដថ្ងាយ។ ឯអ្នកឃ្លាំដក៏យក
ច្រាក់ដីដ៏ឯតម្ងឹដ៏ឥដៅឱ្យចៅក្រមថ្ងាយព្រមត្រូវជាច្រាក់តម្ងឹដ៏ឥ០
ហោដជាស្មរេច។ ឌើបព្រះអង្គប្រដៅអស់ចៅក្រមថាដំនុំសេចក្តី
មុខក្រោយឱ្យពិនិត្យពិគ្រោះឱ្យថែចាំដូចឧកញ៉ាក្រែឍ្យាហោម។

សេចក្តីពោលរៀបរាប់ទាំងអម្បាលនេះសុទ្ធសឹងជាគុណសម្បត្តិ និងគុណវិបត្តិរបស់ចៅក្រមជំនុំក្តីដែលចែងទុកក្នុងច្បាប់ក្រមនានា។

ឃ. ព្រះមហាក្សត្រ

យើងឃើញថាព្រះមហាក្សត្រមានចំណែកធំមួយពាក់ព័ន្ធនឹងកិច្ចការតុលាការតាំងតែពីសម័យបុរាណមកម្លេះ ព្រះអង្គគឺជាចៅក្រមកំពូលសម្រេចក្តីចុងក្រោយបង្អស់។ មកដល់សម័យកណ្តាលយើងឃើញតែតែច្បាស់ទៅទៀតអំពីព្រះរាជកិច្ចរបស់ព្រះមហាក្សត្រក្នុងការងារតុលាការ។ រាល់ការជំនុំក្តីក្តាំរបស់ចៅក្រមពុំដាច់ស្រេច ចៅក្រមទាំងនោះរមែងឡើងក្រាបទូលព្រះករុណាទ្រង់ជ្រាប និងសុំឱ្យព្រះអង្គជួយព្រះតម្រិះពិចារណារឿងនោះផង។ មានឧទាហរណ៍ច្រើនណាស់នៅក្នុងក្រមនិងច្បាប់នានា ដែលនិយាយពីព្រះរាជកិច្ចព្រះបាទអ្នកជាអម្ចាស់ទាក់ទងនឹងវិស័យយុត្តិធម៌។ បើយើងមើលត្រឹមកម្រងរឿងព្រេងទាក់ទងនឹងរឿងតុលាការនៅក្នុងច្បាប់មួយហៅថា «សាត្រាកឹងកន្ត្រែ» ក៏ល្មមយើងយល់ដែរពីព្រះរាជកិច្ចព្រះមហាក្សត្រក្នុងការជួយឱ្យមានយុត្តិធម៌ដល់រាស្ត្រ។ ព្រះអង្គទទួលក្តីពីចៅក្រមមកជំនុំនៅពេលចៅក្រមទាល់ដោះស្រាយពុំដាច់ស្រេច ឬជួនកាលអ្នកក្តីទាំងសងខាងពុំព្រមល្មមសុខចិត្តនឹងសេចក្តីវិនិច្ឆ័យរបស់ចៅក្រម ពួកគេក៏អាចឡើងទៅក្រាបទូលព្រះរាជាសុំឱ្យព្រះអង្គជួយកាត់សេចក្តីម្តងទៀតដែរ។ ស្ទើរតែគ្រប់រឿងក្តីមិនថាតូច ឬធំសុទ្ធតែអាចឡើងប្តឹងសុំព្រះរាជវិនិច្ឆ័យសម្រេចពីព្រះមហាក្សត្រ ហើយដែលគេជឿថាព្រះអង្គអាចផ្តល់យុត្តិធម៌ពិតប្រាកដឥតលម្អៀងដោយអគតិទាំងឡាយ។ ម្យ៉ាងព្រះមហាក្សត្រទ្រង់មានព្រះចិន្តាល្អិតល្អន់មានមេត្តាធម៌ មុននឹងសម្រេចព្រះទ័យវិនិច្ឆ័យរឿងអ្វីមួយទ្រង់ពិចារណាថ្លឹងថ្លែងដ្បិតបើទោសតូចល្មមទ្រង់ឱ្យកាត់ចោលចេញហើយសម្រួលឱ្យសុខជានឹងគ្នា។ បើជាមានទោសត្រូវពិន័យក៏តោងពិន័យដោយនូព្រះច្បាប់។ ព្រះមហាក្សត្រទ្រង់ជាអ្នករក្សាធម៌មានទសពិធរាជធម៌១០ប្រការរក្សាឃុំគ្រងផែនដីឱ្យសន្តិភាពកុំឱ្យរង្គោះរង្គើ។ ឯច្បាប់ដែលនឹងតែងមកក៏ពុំមែនចង់ដាក់ទោសរាស្ត្រ ប្រើអំណាចលើរាស្ត្រផងទាំងឡាយរបស់ព្រះអង្គឡើយ។ ដោយ

ហេតុគំនិតនៃការប្រកាន់ទសពិធរាជធម៌ និងការប្រតិបត្តិធម៌នេះ ទើបព្រះមហាក្សត្រមានព្រះនាមថា «ស្រីធម្មរាជា» ហើយពិសេសនៅសម័យកណ្តាលនាមនេះប្រើហៅទៅព្រះមហាក្សត្រជាច្រើនអង្គ។ ឧទាហរណ៍ «សម្តេចព្រះរាជឱង្ការព្រះជ័យជេស្តារាម្មាឥសូរបរមសូរិន្ទកូវមិនរាជេនធិរាជបរមខត្តិជាតិសុរិយោវង្សពង្សកម្ពុជាធិបតីស្រីធម្មរាជាមហាចក្រពត្រាធិរាជមហាមហិនបថៃរសរវរសូរិនតេជោជ័យត្រៃរតន៍ម្កុដវិសុទ្ធមុនីព្រះស្រីបរមទេព្វារជន្យារសន្ធបរមបធម្មកាគរាជាធិរាជបរមបពិត្រ»[១៣០]។

ភាគច្រើននៃច្បាប់និងក្រមនានាតែងពោលបញ្ជាក់ថា គឺព្រះរាជាអង្គឯងដែលត្រាស់បង្គាប់អស់នាមុីន មន្ត្រី សេនាបតី និងអស់ចៅក្រមផងឱ្យតាក់តែងច្បាប់ឡើង ឬជួនកាលឱ្យកែប្រែច្បាប់ចាស់ដែលយល់ថាពុំគាប់ប្រសើរ។ គោលបំណងគឺថាកុំឱ្យមានមន្ទិលសៅហ្មងដល់អស់ប្រជានុរាស្ត្រព្រមទាំងជាតិសាសន៍ដទៃដែលរស់នៅក្រោមម្លប់បារមីរបស់ព្រះអង្គមានកួយ ពរ៍...ជាដើមដូចសេចក្តីពោលៈ

> *ស្តេចកដំឭងដ៏បដ្ឋាយស្រះកែវមួយអន្ទើហើយ មានមហារាជគ្រូឲ្យសមណាព្រាហ្មណាចារ្យបរិចាល ឲ្យរាជបុរោហិតសំរិទ្ធិ ឲ្យព្រះរដ្ឋអគ្គសាមន្តិរាជ ឲ្យរាជមន្ត្រីចតុស្តម្ភក្រមការ ការីបណ្ឌិតត្រីទ្ធាចារីជដ៏កាល់ហ្មោជាប្រក្រតី ដោយឲ្យព្រះបរមីពិសេស ឌើបស្តេចទ្រង់ឲ្យព្រះបរមសុចរិត ពិចិត្រពិចិន្តែឲ្យព្រះឥឭញ្ញាណឈ្វេងយល់កុំឱ្យឡៃក្រោមកើតកោលាហល ព្រះអគ្គជម្ភល់ឱ្យបរិបូរណ៌ស្ថិតស្ថេរចេរកាលដ៏លុងដៅ កុំឱ្យសៅហ្មងឆ្គងចិត្តប្រជារស្ត្រជាសការកួយព័រជង ហើយឌើបព្រះចាឧបរមជាថបរមបពិត្រឌើកព្រះឥស្សឥឭថ្ងៃមានព្រះបន្ទូលព្រះរាជឱង្ការបរមសាភេះនេះ។*

ក្នុងព្រះរាជកិច្ចដើម្បីរក្សាសុខសន្តិភាពដល់ប្រជារាស្ត្រក្នុងនគរ ផ្តល់យុត្តិធម៌ក្នុងផ្នែកតុលាការ ព្រះមហាក្សត្រខ្មែរភាគច្រើននៅសម័យកណ្តាលប្រតិបត្តិតាមគន្លងទ្រឹស្តីរបស់ព្រះពុទ្ធសាសនា។ ព្រោះថាបើយើងពិនិត្យឱ្យមែនទែនទៅព្រះពុទ្ធសាសនារួមចំណែកយ៉ាងធំក្នុងការធ្វើឱ្យស្រុកទេសមានភាពនឹងនស្ងប់សុខដោយការជឿលើទ្រឹស្តី «*បុណ្យ*» និង «*បាប*»។ កាលបើមនុស្សទាំងឡាយមិនប្រព្រឹត្តិសាងអំពើបាបដូចជាការបៀតបៀនគ្នាឈ្លោះប្រមាថ កាប់សម្លាប់ លួចឆក់ប្លន់គ្នាជាដើម មនុស្សទាំងអស់ក៏រស់នៅជាមួយគ្នា

---

[១៣០] សេចក្តីស្រង់ចេញពី *ក្រមសារពើគុណ* បោះពុម្ពឆ្នាំ១៨៩១, រោងពុម្ពប្រូតិកតូរ៉ា, ទំព័រទី១។

ដោយសុខសប្បាយ។ រីឯពួករចៅក្រមដែលប្រកាន់ធម៌សុចរិតមិនលម្អៀង មិនស៊ីសំណូក សូកប៉ាន់កាត់បង្វិលក្តីគេពីត្រូវទៅខុសជាហេតុនាំឱ្យមានបាបកម្មទេ នោះយុត្តិធម៌ច្បាស់ជាកើតមានដល់រាស្ត្រប្រជាជាក់ជាមិនខាន។ ដោយហេតុនេះព្រះរាជាតែងលើកតម្កល់ព្រះសាសនាឱ្យថ្កុំថ្កើងហួសប្រមាណហើយតែងដាក់ទោសដល់អ្នកណាដែលមើលងាយប្រមាថព្រះសាសនាតថាគត។ ឯការដែលព្រះមហាក្សត្រប្រតិបត្តិតាមទ្រឹស្តីព្រះពុទ្ធសាសនា ដំបូងបង្អស់ដែលព្រះអង្គត្រូវមានគឺមិនអ្វីក្រៅតែពីការប្រកាន់យកទសពិធរាជធម៌ឡើយ។ ធម៌១០ប្រការនេះមានជាអាទិ៍៖ ១. ទាន ២. សីល ៣. បរិច្ចាគ ៤. អជ្ជវៈ ៥. មទ្ទវៈ ៦. តបៈ ៧. អក្កោធនៈ ៨. អវិហិង្សា ៩. ខន្តី និង ១០. អវិរោធនៈ។ ឯទានគឺការឱ្យទាន សីលគឺការឱ្យសីល បរិច្ចាគគឺការធ្វើអំណោយសព្វបែបយ៉ាង អជ្ជវៈគឺសេចក្តីស្មោះត្រង់ មទ្ទវៈគឺភាពទន់ភ្លន់រាបសា តបៈគឺការកាន់ខ្ជាប់ប្រតិបត្តិតាមសីលវិន័យ អក្កោធនៈគឺភាពមិនក្រោធខឹងមិនគំគួន អវិហិង្សាគឺការមិនប្រព្រឹត្តិហិង្សា ខន្តីគឺការអត់ធ្មត់អំណត់ និង អវិរោធនៈគឺមានចិត្តរឹងមាំមិនចាកគន្លងធម៌[១៣១]។

ចំណែកក្នុងជីវភាពប្រចាំថ្ងៃ ច្បាប់ព្រះក្រិត្តិការចារក្នុងក្រមសារពើគុណនិយាយអំពីព្រះមហាក្សត្រដែលសោយរាជ្យគ្រប់គ្រងផែនដីរក្សារាស្ត្រគប្បីប្រតិបត្តិព្រះកាយតាមពុតសត្វ៨ជំពូក។

«នេះជូវស្រែដីព្រះក្រិត្តិការ»

ច្បាប់ក្បត្រាជិបតីប្រើរពីជ័ត្រាប់ពុតសត្វ៨ជំពូក ជំពូក១ គឺរាជសីហ៍ ១គឺកោ ១គឺក្អែក ១គឺមាន់ ១គឺរាជហង្ស ១គឺស្នាត ១គឺអក ១គឺខ្លា។ ជាពុតរាជសីហ៍នោះកាលរាជសីហ៍ចេញចៅបរិភោគ រាជសីហ៍នោះស្រែកមានសម្រែកនោះមួយយោជន៍ ចម្ងាយចេញពុសម្ងៃជ័នោះហើយឆើបដើរចៅ។ នោះសត្វជ័ពុបើពុំចៀសចេញឡើយ រាជសីហ៍នោះចាប់សត្វនោះស៊ីឥតចាបឡើយ នោះចាបក្តីមាន

[១៣១] សូមអានបន្ថែម ៖
- មាក់ ព្រេន ១៩៥៧: ១៤៣។
- ងិន កេន ២០០៥: ១៦-១៧។
- យូ នួន ២០០១: ២។
- ខ្លូត ធីតា ២០០២: ៥១៥-៥១៨។
- ហេង មណីចិន្តា ១៩៩៩: ៨៦។

> តែ[?][១៣២]។ ស្តេចជាដៅត្រាប់ដោះធ្វើក្រិត្តិការជាកំហិតប្តីជ័ច្រាប់ មនុស្សជ័ជាំជ័ឧប្បាយ ដោះមនុស្សជ័ខុសឲ្យកំហិតដោះឱ្យធ្វើ ដោសឲ្យដោសនេះហោជ័។ ជាពុតគោដោះកេឌីមហើយ កេដុកសារពើរបស់ទ្រព្យអម្បាលចានក្តីសឹជ័អង្សោតឧម្ងប់លុះអស់កម្ចាំជ័ ឯជ័ឥតបើខ្លឹលឌ្បើយ ឌីស្តេចជាឲ្យត្រាប់ពុតគោដោះដោះមានឧម្ងប់ ក្រិតបីជាឧម្ងប់ស្តេចសារពើក្តី ឆ្នៃក្រោមក្តី ឧម្ងប់រាស្ត្រក្តី[១៣៣]។

សេចក្តីក្នុងច្បាប់នេះពុំបានរៀបរាប់ឱ្យអស់អាថ៌សេចក្តីអំពីពុតសត្វនីមួយៗ ដែលព្រះមហាក្សត្រគួរគប្បីយកតម្រាប់តាមឡើយ។ ប៉ុន្តែទោះយ៉ាងនេះក្តីលក្ខណៈរបស់សត្វនីមួយៗ ក៏យើងអាចពិចារណាបានខ្លះៗដែរ។ ឯសម្រែកចេញពីរាជសីហ៍ទំនងឧបមានឹងច្បាប់ដែលផ្សព្វផ្សាយខ្ចរខ្ចាយសាយភាយទៅទូទាំងព្រះនគរឱ្យអស់រាស្ត្រផងបានដឹងនិងចៀសវាងជាច់ខាតនូវអំពើទាំងឡាយណាដែលខុសឆ្គងនឹងច្បាប់នោះ។ បើជនឯណារឹងទទឹងមិនស្តាប់បញ្ញត្តិរមែងមានទោសជាក់ជាពុំខាន ប្រៀបដូចរាជសីហ៍ស្រែកឱ្យសត្វម្រឹកទាំងឡាយខ្លបខ្លាចចៀសចេញឆ្ងាយ បើនៅរឹងមិនចៀសចេញទេ នោះនឹងត្រូវរាជសីហ៍ស៊ីជាក់ពុំលែងឡើយ។ ឯឧបមាត្រាប់ពុតគោនោះ គឺថាព្រះមហាក្សត្រត្រូវទទួលបន្ទុកធ្ងន់ស្រាលគ្រប់បែបយ៉ាងក្នុងកិច្ចការដឹកនាំប្រទេសជាតិប្រៀបបាននឹងគោដែលផ្ទុករបស់ទ្រព្យធ្ងន់យ៉ាងណាក៏តែដឹកមិនចេះខ្ជិល។ ឯត្រាប់តាមសត្វមាន់គឺទំនងជាមាន់មេការកូនទាំឡាយពីសត្រូវមិនឱ្យជួបអន្តរាយដូចស្តេចការពាររាស្ត្រពីខ្មាំងខាងក្រៅកុំឱ្យមកបុកបិនបង្ខិនបង្ហោចបង្កទុក្ខទោសដល់រាស្ត្រក្នុងព្រះនគរដែលចំណុះក្រោមបារមីព្រះអង្គឡើយ។ ឯពុតសត្វទាំងអម្បាលទៀតដូចជាក្អែក រាជហង្ស ត្មាត អក ខ្លា ជាដើមគប្បីយើងសាកល្បងពិចារណាតាមដោយទំនងទៅចុះ។

២.១.៣. អ្នកមានឆន្ទៈជាយថាហេតុក្នុងតុលាការ

ក. សម្តេចព្រះឆាវ

ជាទូទៅពាក្យ «សម្តេចព្រះទាវ» ច្រើនជាព្រះគោរម្យងាររហៀទៅព្រះរាជមាតារបស់ព្រះមហាក្សត្រ។ បើតាមលោក អាដេម៉ា ឡឺក្លែរ (Adhémar Leclère) គាត់ប្រែពាក្យ *សម្តេចព្រះទាវ* ជាភាសាបារាំងថា «Reine-Mère» ដែលមានន័យថា «ព្រះវរ

---

[១៣២] ពាក្យបន្ទាប់មិនដឹងថាជាពាក្យអ្វីឡើយ ដ្បិតនៅក្នុងច្បាប់សរសេរដៃពុំសូវច្បាស់ពិបាកអានយល់ថាជាពាក្យអ្វីប្រាកដ។
[១៣៣] សេចក្តីស្រង់ចេញពី *ក្រមសារពើគុណ* ទំព័រ៣៩-៤០។

មាតា ឬសម្តេចម៉ែ» ដូច្នេះតែម្តង។ ប៉ុន្តែបើតាមការអង្កេត សម្តេចព្រះទាវក៏អាចជាម្តាយមីង ឬម្តាយធំរបស់ស្តេច (ព្រះមាតុច្ឆា) ឬជាជីដូនរបស់ស្តេច (ព្រះអយ្យកា)[១៣៤]។ តាមពិតទៅព្រះរាជមាតា ឬសម្តេចព្រះទាវពុំមាននាទីអ្វីចាំបាច់នៅក្នុងតុលាការឡើយ។ មានន័យថាព្រះអង្គពុំកាន់ការផ្នែកណាមួយក្នុងរចនាសម្ព័ន្ធរបស់តុលាការទេ។ ប៉ុន្តែនៅក្នុងរឿងខ្លះក៏យើងឃើញព្រះវត្តមានរបស់សម្តេចព្រះទាវដែរ។ ឧទាហរណ៍គឺក្នុងពេលតាក់តែងច្បាប់ «ទំនឹមពីបុរាណ» (ព្រះវត្តមានព្រះអង្គនៅពេលនោះ ព្រោះព្រះអង្គជាចាស់ទុំធ្លាប់បានដឹងឮសេចក្តីច្បាប់អំពីដើមមក ទើបនៅពេលមានការជំនុំបង្កើតច្បាប់ថ្មី គេទៅក្រាបទូលសួរដំណើរពីបុរាណនោះដូចម្តេច)។ សេចក្តីពោលដើមដំបូងបង្អស់នៃច្បាប់នេះ គឺប្រាប់ពីឆ្នាំខែ *(សព្ភមស្ដុ មង្គលពហុលចេស្ដាជ័យយាតិរេក១៦១៤សក្ក មមែនក្សត្រ ចតុទស ១ កើត អាសាឍមាសា អាទិត្យវារ សាសនាមន្តីរ)* បន្ទាប់មក គឺព្រះនាមរបស់ព្រះមហាក្សត្រ *(ព្រះបាទសម្តេចព្រះរាជឱង្ការព្រះជ័យជេស្ឋារាម្មាឥសូរបរមសូរិន្ទរាជាធិរាជអធិបតីបរមនាថបរមបពិត្រ)* ហើយទើបរៀបរាប់សាច់រឿងថា ស្តេច (ព្រះជ័យជេដ្ឋា) ទ្រង់មានព្រះបន្ទូលត្រាស់ប្រើឧកញ៉ាសូកាធិបតីទៅក្រាបទូលសួរទំនឹមច្បាប់ពីបុរាណអំពីសម្តេចព្រះរាជមាតាជាសម្តេចព្រះទាវ *(អ្នកជាអម្ចាស់ស្តេចគង់ចំពោះព្រះភ័ក្ត្របូព៌ទិសមានព្រះបន្ទូលត្រាស់ប្រើឧកញ៉ាសូកាធិបតីទៅក្រាបទូលសួរច្បាប់ទំនឹមព្រះរាជក្រិតព្រះរាជសាសន៍អំពីសម្តេចព្រះរាជមាតាជាសម្តេចព្រះទាវ (ថា) ព្រះបរមបពិត្រចង់ជ្រាបអំពីអង្គព្រះពហុសក្ត នឹងទុកជាច្បាប់តំណរាជរៀងទៅហោង...)*។ ក្រៅអំពីនេះយើងនៅឃើញពាក្យកាព្យប្រមាណ៤ឈ្នះទៀតដែលចារក្នុងច្បាប់ពោលសរសើរសម្តេចព្រះរាជមាតាជាសម្តេចព្រះទាវថា៖

យើងដឹងសរសើរ	*ដំណាលដំណើរ*	*ទំនឹមផងណា*
អំពីសម្តេច	*ព្រះរាជមាតា*	*ព្រះអង្គជាតិជា*
	ព្រះនារកន្ទោង។	
ព្រះអង្គគ្រាបច្បាប់	*ជ្រាបដោយសណ្តាប់*	*ទំនឹមទំនង*
ព្រះជាតិសក្តិ	*ជាតិជាក់ហ្មត់ហ្មង*	*គឺកមាសដោះហោង*

[១៣៤] សូមមើលបន្ថែម :

- Aymonier 1900: 61។
- Leclère 1894: 52។
- Mikaelian 1997- 1998: 114។
- *Ibid.,* 2006: 686។

ពុំឆ្គងឆ្ងើយដែ។

ដើមវាជបុត្រា *ត្រប់ត្រងសីមា* *សោយរាជ្យប្រពៃ*
ត្រាស់ប្រើឧកញ៉ា *សូភាធិបតី* *ដៅត្រាបទូលពៃ*
អង្គព្រះហ្វសក្តិ។

ព្រះអង្គចង់ត្រាប *ពុំឱ្យខ្ពស់ទាប* *ទ្រង់ស្រាលលើកជាក់*
ឱ្យចាជារស្តែរម្យ *សុខសមត្រជាក់* *ខ្មែរខ្លាចអាណាក់*
ក្នុងរាជធានី។

ទាំងនេះជាឧទាហរណ៍បញ្ជាក់ថាសម្តេចព្រះទាវពេលខ្លះក៏បានរួមចំណែកមួយក្នុងវិស័យតុលាការដែរ។ ព្រះអង្គប្រៀបបាននឹងអ្នកប្រឹក្សាច្បាប់ ពិសេសច្បាប់បុរាណអំពីមុនដែលទ្រង់គង់ទាន់។ ជួនកាលទៀតសម្តេចព្រះទាវក៏អាចមានអំណាចបង្គាប់បញ្ជាឱ្យមន្ត្រីណាម្នាក់ជំនុំក្តីរឿងណាមួយដែរ។ ដូចមាននិយាយនៅទំនឹម១៤ *«មានទនឹម១៤ កាលរាជ្យព្រះរាជឱង្កាវព្រះជ័យជេស្ឋា កាលនោះសម្តេចព្រះទាវព្រះកន្លោងប្រើចៅពញាស្នាធិបតីឱ្យនាំអ្នកក្តីទៅជូនឧកញ៉ាវង្សាធិបតីឱ្យជំនុំ...»*។ នៅក្នុងក្រមនិងច្បាប់នានាយើងពុំដែលប្រទះថាសម្តេចព្រះទាវទទួលជំនុំក្តីជាចៅក្រមដោយអង្គឯងឡើយ លើកលែងតែក្នុងរឿងមួយប៉ុណ្ណោះដែលរឿងនោះស្ថិតនៅក្នុងកម្រងរឿងទាក់ទងនឹងតុលាការហៅថា **«សាត្រាកឹងកន្ត្រែ»**។ រឿងដែលនិយាយនេះមានចំណងជើងថា *«ឈ្នួញម្នាក់មានដើមទុនតែ១ហួង»*។ សាច់រឿងនិយាយអំពីវិវាទរវាងបុរសពីរនាក់ដែលទាស់គំនិតគ្នារឿថ្លៃឈ្នួលឆ្លងស្ទឹង។ ទោះបើចៅក្រមរហូតដល់ព្រះមហាក្សត្រកាត់ក្តីយ៉ាងណាក៏គូក្តីពុំសុខចិត្ត ទើបព្រះមហាក្សត្រថ្វាយក្តីទៅព្រះរាជមាតាឱ្យជួយជំនុំពិចារណាទើបបានសុខចិត្ត[១៣៥]។

ដូច្នេះសារុបមកបើទោះបីពេលខ្លះយើងឃើញថាសម្តេចព្រះទាវមានចំណែកខ្លះៗក្នុងតុលាការក៏ពិតមែន ប៉ុន្តែជាការចៃដន្យ ឬជាយថាហេតុប៉ុណ្ណោះដ្បិតព្រះអង្គពុំមានកាតព្វកិច្ចបំពេញកិច្ចការជាចៅក្រមជំនុំក្តី ឬជាភ្នាក់ងារណាមួយជាអចិន្ត្រៃក្នុងរចនាសម្ព័ន្ធតុលាការឡើយ។

ខ. អ្នកកណ្តាល

អ្នកកណ្តាល ឬជួនកាលគេហៅអ្នកនេះថា «អាជ្ញាកណ្តាល» ផងក៏បាន។ អ្នកកណ្តាលជាភ្នាក់ងារមិនអចិន្ត្រៃ ទទួលបញ្ជាម្តងម្កាលពីចៅក្រមឱ្យទៅអង្កេតរឿងក្តីអ្វីមួយ

[១៣៥] សូមអាន ហ៊ែល ចំរើន ២០០៩- ២០១០: ១១៣។

ឬជាអ្នកដែលទៅសួរកសាក្សីបន្ទាល់មកក្នុងអង្គជំនុំក្តីនៅសាលា។ អ្នកកណ្តាលមិនមាននាទីជាប់ជួនក្នុងតុលាការទេ ដ្បិតយើញថាទាល់តែមានទំនាស់ក្តីក្តាំហើយគេចាំបាច់ត្រូវមានអ្នកកណ្តាល ទើបគេរើសរកអ្នកណាម្នាក់មកតាំងជាអ្នកកណ្តាល។ អ្នកនោះត្រូវតែជាអ្នកមានចិត្តទៀងត្រង់សុភាពរាបសា។ អ្នកកណ្តាលអាចជាអាចារ្យណាម្នាក់ឬជាចាស់ទុំអ្នកមានធម៌បរិសុទ្ធដែលគេឯងគោរពរាប់អាន។ ហេតុដូច្នេះហើយនៅពេលដែលគេត្រូវការសាក្សីបន្ទាល់គឺគេឱ្យអ្នកកណ្តាលលនោះឯងជាអ្នកទៅរកបន្ទាល់ជាមួយសាច់ញាតិណាម្នាក់របស់គូក្តី ព្រោះគេមិនទុកចិត្តឱ្យអ្នកក្តីទៅរកបន្ទាល់ ឬសាក្សីខ្លួនឯងឡើយដោយខ្លាចថាអ្នកក្តីនោះនិយាយបញ្ចុះបញ្ចូលបន្ទាល់កណ្តាលផ្លូវនាំឱ្យបន្ទាល់ឆ្លើយពុំត្រង់ ពុំត្រឹមត្រូវពិតប្រាកដ។ ដោយហេតុថាអ្នកកណ្តាលជាអ្នកទៀងត្រង់មានធម៌ប្រាកដ ទើបនៅពេលធ្វើកិច្ចពិធីចាំបាច់ទាក់ទងនឹងការស្បថស្បែរកខុសត្រូវក្នុងពេលមានវិវាទក្តីក្តាំជាដើម គឺអ្នកកណ្តាលនោះឯងជាអ្នកទទួលដឹកនាំកិច្ចពិធីនោះ។ ឯកិច្ចការដែលអ្នកកណ្តាលទទួលខ្លួនទៅរកបន្ទាល់សាក្សី និងជាអ្នកដឹកនាំធ្វើកិច្ចពិធីស្បថស្បែនោះ យើងឃើញមាននិយាយនៅក្នុង «**ក្រមពួក**»[១៣៦] និង «**ច្បាប់ទំនឹមពីបុរាណ**» ត្រង់ទំនឹម១៧។

ការអង្កេតមួយទៀត គឺថាកាលបើចៅក្រមប្រើអ្នកកណ្តាលចេញទៅយកអ្នកក្តី ឬទៅយកសាក្សីបន្ទាល់មកក្នុងសាលាជំនុំ គោងចៅក្រមនោះចេញថ្លៃជើងការឱ្យអ្នកកណ្តាលនោះផង។ ឯច្បាប់អំពីថ្លៃជើងការអ្នកកណ្តាលនេះមានចែងនៅក្នុង «**ក្រមសារពើគុណ**» ដូច្នេះថា *«[...] នេះច្បាប់សំណាលជើងអ្នកកណ្តាលទៅយកអ្នកក្តី ចេញពីឧដុង្គ ឮដំយទៅដល់ភ្នំពេញ បាទ១ ទៅដល់បាទី បាទ២ ព្រៃក្របាស់ បាទ៣ ទៅដល់ទ្រាំង បាទ៤ ឯអស់ស្រុកលោកឱ្យគិតដោយចម្ងាយដូច្នេះហោង [...]»*[១៣៧]។

ក. សាក្សី ឬបន្ទាល់

នៅពេលជំនុំក្តីពុំចាំបាច់ត្រូវតែមានសាក្សីឬបន្ទាល់គ្រប់ពេលវេលាទេ។ រឿងខ្លះចៅក្រមហៅគូក្តីទាំងសងខាងមកជំនុំតែម្តង។ ប៉ុន្តែក្នុងករណីដែលគូក្តីណាកើតទុក្ខពុំសុខចិត្តទាមទារឱ្យមានសាក្សីដឹងឮ ទើបអង្គជំនុំបញ្ជូនអ្នកកណ្តាលឱ្យទៅនាំអ្នកបន្ទាល់នោះមក។ ចៅក្រមអាចឱ្យអ្នកកណ្តាលទៅយកនរណាម្នាក់មកជាបន្ទាល់ឆ្លើយក្តីបានទាល់តែគូក្តីសងខាងសុខចិត្តរៀងខ្លួនថាអាចយកបានទើបចៅក្រមសម្រេចយកបុគ្គលនោះជា

---

[១៣៦] សូមអាន *ក្រមពួក* សន្លឹក៤៨-៥១។

- Mikaelian 2006: 170។

[១៣៧] *ក្រមសារពើគុណ* បោះពុម្ពឆ្នាំ១៨៩១, រោងពុម្ពប្រូតិតូរ៉ា, ទំ.២៣។

បន្ទាល់បាន។ ប្រសិនបើអ្នកកណ្តាលទៅយកបន្ទាល់នោះមកហើយ ឯអ្នកក្តីថាបន្ទាល់នោះពុំសុទ្ធ ពុំទៀងត្រង់ នោះឱ្យចៅក្រមពិចារណាវិញទៀត ដ្បិតគេពុំសុខចិត្តនឹងបន្ទាល់នោះឡើយ។ ដូច្នេះហើយមុនសម្រេចចិត្តយកបុគ្គលណាជាបន្ទាល់គោងចៅក្រមសួរអ្នកក្តីសងខាងជាមុន។ ឧទាហរណ៍ក្នុងទំនឹម១៧នៃច្បាប់ទំនឹមពីបុរាណនិយាយពីរឿងក្តីមួយដែលចៅពញារត្នសេនាបាត់គោហើយទៅឃើញគោនោះនៅនឹងចៅពញាបរនាយកហើយក៏មានការប្តឹងប្តល់គ្នា។ ក្តីនេះឡើងក្រាបទូលដល់ព្រះមហាក្សត្រ ហើយព្រះអង្គដាក់ឱ្យសាលាជំនុំពិចារណា។ ទើបអស់ជំនុំពិចារណាយកចៅពញាដ៏រុងរកក្តីជាបន្ទាល់ ហើយសួរទៅចៅពញាទាំងពីរថាល្មមព្រមចូលចិត្តឬទេ? អ្នកចៅពញាទាំងពីរយល់ព្រមតាមចៅក្រមជំនុំ ទើបចៅក្រមចាប់ផ្តើមពិចារណាក្តីនោះបាន[១៣៨]។ នេះជាឧទាហរណ៍នៃបន្ទាល់ដែលអាចហៅឱ្យមកបំភ្លឺបានភ្លាមៗ។ មានបន្ទាល់ខ្លះទៀតទាល់តែឆ្លងកាត់ការធ្វើពិធីស្បថស្បែសច្ចាប្រណិធានមានគ្រឿងរណ្តាប់ អង្ករ ទៀន ប្រាក់បាទ ជាដើមជាមុនសិនទើបអាចក្លាយជាបន្ទាល់ឱ្យគេបាន។ ឯការរើសបន្ទាល់នោះសោតក៏ពុំមែនចេះតែរើសយកតាមចិត្តចង់ឬតាមការស្នើសុំពីភាគីទំនាស់ទេ។ ដើម្បីជ្រើសរើសបានគេគោងពិចារណាល្អិតល្អន់ទាំងគុណសម្បត្តិរបស់បុគ្គលនោះផងនិងទាំងទំនាក់ទំនងរវាងអ្នកបន្ទាល់ជាមួយគូក្តីផង។ លក្ខណៈរបស់សាក្សីឬបន្ទាល់យើងរកឃើញនៅក្នុងច្បាប់ពីរគឺ «**ច្បាប់យុនសាឡា**» និង «**ក្រមសារពីគុណ**»។ បើយើងបូកបង្រួមសេចក្តីនៃច្បាប់ទាំងពីរបញ្ចូលគ្នាមកយើងឃើញថាអ្នកដែលអាចយកជាបន្ទាល់បាននិងអ្នកដែលមិនអាចយកជាបន្ទាល់បានមានដូចខាងក្រោម[១៣៩]៖

បុគ្គលដែលអាចយកជាបន្ទាល់បាន៖

- កិក្ខុប្រុស
- កិក្ខុស្រី
- សាមណេរប្រុស
- សាមណេរស្រី
- បុគ្គលស្រលាញ់ទាន

---

[១៣៨] *ច្បាប់ទំនឹមពីបុរាណ* ទំនឹម១៧, សន្លឹកទី២២។

[១៣៩] សូមអាន :

- *ច្បាប់យុនសាឡា*, សន្លឹកទី១៧។
- *ក្រមសារពីគុណ*, ទំព័រ១២។

- បុគ្គលស្រលាញ់សីល
- បុគ្គលចម្រើនភាវនា
- បុគ្គលខ្មាសបាប
- បុគ្គលលោះលែងបាប
- អ្នកមានពាក្យសត្យ។

បុគ្គលមិនអាចធ្វើសាក្សីបាន៖

- បុគ្គលជាសាច់ញាតិ ជាសម្លាញ់ម្ខាងៗនឹងគូក្តី
- បុគ្គលជាអ្នករស់នៅភូមិផងជាមួយគូក្តី
- បុគ្គលជាទោស ជាសម្ពប់នឹងអ្នកម្ខាងៗក្តី
- បុគ្គលជាអ្នកក្រក្សត់
- អ្នកផឹកស្រា កូតករកុហក មាយាទកាន់បាបពុំដឹងបុណ្យ
- ក្មេងពុំទាន់ដឹងក្តី
- ចាស់វង្វេងក្តីស្តីពុំដឹងខុសត្រូវ
- អស់ពួកមហាត ពល ខ្ញុំគេ ជំពាក់ទ្រព្យគេ
- បុគ្គលបាបអធម៌
- អ្នកលួចប្លន់ជាដើម។

រីចៅក្រមជំនុំក្តីគោងពិនិត្យពិចារណាលើលក្ខណៈរបស់បន្ទាល់ទាំងនោះឱ្យត្រឹមត្រូវដោយនូវច្បាប់ជាមុនសិនទើបឱ្យយកជាបន្ទាល់បាន។ ថាបើចៅក្រមជំនុំក្តីរើសរកបន្ទាល់ឯណាប្រាសចាកធម៌ដែលជាលក្ខណៈប្រសើររបស់បន្ទាល់ ចៅក្រមនោះរមែងបានទៅនរកពុំលែងឡើយ។

២.១.៤. រៀបដំណើរការក្តី

ដំណើរការប្រព្រឹត្តិទៅនៃតុលាការសម័យកណ្តាលមានមូលដ្ឋានសំខាន់ៗដូចជា ការទទួលបណ្តឹងពីគូក្តី ការសាកសួរនិងការពិសោធន៍ ការស្វែងរកសាក្សីឬបន្ទាល់ ការបង្គាប់ក្តីនិងចុងក្រោយគឺការសម្រេចដាក់ទោសទណ្ឌផ្សេងៗទៅតាមកំហុសជនដែលបានប្រព្រឹត្តិ។

ក. ទទួលបណ្តឹងពីគូក្តី

ជនទាំងឡាយណាដែលមានវិវាទកើតទុក្ខពុំសុខចិត្តចង់ប្តឹងទៅចៅក្រមក៏គោងមានជំនួនគំនាប់ផ្ទាប់ដៃបន្តិចបន្តួចជូនទៅចៅក្រមផង។ ឯគំនាប់ដៃនោះមានជា

ឧទាហរណ៍ដូចជា អង្គរ ស្លាម្ល ស្រា ជាដើម[១៤០]។ ឯចៅក្រមដែលនឹងទទួលបណ្តឹងយកមកជំនុំជម្រះ ក៏ពុំអាចទទួលគ្រប់តែពាក្យបណ្តឹង ឬពីគ្រប់អ្នកមកប្តឹងដែរ។ ឧទាហរណ៍ លោកមិនឱ្យចៅក្រមទទួលបណ្តឹងពីកូនទាំងឡាយណាដែលមានចិត្តសាហិចសាហាយ កំណាចយោយៅប្តឹងឱ្យប្រកោះឪពុកម្តាយបង្កើត ទាំងម្តាយមីង ជីដូនជីតា បងថ្លៃ បងបង្កើត ម្តាយក្មេក ឪពុកក្មេកជាដើម ដ្បិតឪពុកម្តាយជាអ្នកមានគុណធ្ងន់។ បើមានកូនកំណាចណាមកប្តឹង ឱ្យចៅក្រម (ពិសេសភ្នាក់ងារសង្ឃរី) ពិន័យកូនដែលកំណាចនោះជាប្រាក់តម្លឹង១៥ ជី១។ បើប្តឹងឱ្យប្រកោះត្រូវជាជីដូនមួយបង្កើត នោះឱ្យពិន័យជាប្រាក់តម្លឹង១២ បាទ២ ជី១។ បើប្តឹងឱ្យប្រកោះត្រូវជាជីទួតមួយ ត្រូវឱ្យពិន័យតម្លឹង៩ បាទ២ ជី ១។ បើជាជីលួតមួយ ត្រូវពិន័យតម្លឹង៣ បាទ២ ជី១[១៤១]។ ដូច្នេះយើងឃើញថាបុគ្គលដែលប្តឹងសាច់សារលោហិតខ្លួនឯងនឹងត្រូវទោសវិញពុំខាន។ ឯការដែលថា ចៅក្រមមិនអាចទទួលបណ្តឹងពីគ្រប់មនុស្សគ្រប់គ្នាបាននោះ គឺថាបុគ្គលខ្លះមានសតិវិប្បល្លាសមិនដឹងខុសត្រូវនិយាយយកសេចក្តីពុំបាន ចាស់អាយុច្រើនវង្វេងវង្វាន់ស្មារតី ក្មេងអាយុតិចស្តីស្តាប់យកសេចក្តីជាជាក់ប្រាកដពុំបាន មនុស្សភ្នែកខ្វាក់ ត្រចៀកថ្លង់ជាដើមសឹងតែជាអ្នកដែលពុំអាចយកជាប្រមាណបាន។ ដូច្នេះលោកកុំឱ្យទទួលជំនុំក្តីអ្នកទាំងអម្បាលនេះឡើយ។ បើជារឿងចាំបាច់ណាស់ត្រូវឱ្យស៊ើបសួរសាក្សីពេជ្ញាណឱ្យច្បាស់ការសិន បើល្មមព្រមទទួលយកមកជំនុំបានទើបឱ្យចៅក្រមជំនុំក្តីនោះ។ មួយទៀតឋានៈជាខ្ញុំគេដែលមានមន្ទិលជាប់ខ្លួនមិនបរិសុទ្ធ បើរត់ចេញពីផ្ទះហើយមកប្តឹងម្ចាស់ឯង ចៅក្រមពុំគួរបើកទទួលកាត់ក្តីនោះឡើយ ថាបើចៅក្រមណាទទួលយកក្តីនោះមានកាន់ ហើយបើចាញ់គេចៅក្រមនោះត្រូវពិន័យជួសតួខ្ញុំគេនោះឯង។ ករណីមួយទៀត គឺថាបណ្តឹងរឿងក្តីតែមួយមិនអាចប្តឹងទៅសាលាជំនុំពីរបានឡើយ[១៤២]។

ខ. សាកសួរនិងពិសោធន៍

នៅពេលមានអ្នកណាចង់មកប្តឹងចៅក្រម នោះចៅក្រមតម្រូវឱ្យអ្នកដើមចោទនិងចុងចម្លើយកត់ពាក្យប្តឹងទាំងអម្បាលនោះមកឱ្យចៅក្រម។ ពុំនោះសោតសាលាជំនុំ

---

[១៤០] សូមអានឧទាហរណ៍ក្នុងទំនឹម២៩នៃ *ច្បាប់ទំនឹមពីបុរាណ*។

[១៤១] សូមអាន *ច្បាប់សង្ឃរី* សន្លឹកទី១៨។

[១៤២] សេចក្តីនេះដ្បិតពុំឃើញមានចែងក្នុងក្រមនិងច្បាប់នានាចន្លោះស.វ.ទី១៥-១៨ក្តី តែដែលយើងឃើញលេចឡើងដំបូងគឺក្នុង «*ក្រមទទួលបណ្តឹង*» របស់ព្រះបាទអង្គឌួងនាពាក់កណ្តាលស.វ.ទី១៩ ហើយយើងហ៊ានសន្និដ្ឋានថាប្រការនេះច្បាស់តមកពីបុរាណមិនខាន ព្រោះជារឿងក្នុងករណីចាំបាច់តែមួយដូចគ្នាមិនថាសម័យបុរាណឬសម័យក្រោយមកទៀតឡើយ។

គោងមានស្មៀនម្នាក់ជាអ្នកកត់ពាក្យ។ នៅពេលគូក្តីម្ខាងៗ បរិយាយពាក្យប្តឹង អ្នកស្មៀនត្រូវស្តាប់ឱ្យច្បាស់ និងកត់ឱ្យអស់អាថ៌សេចក្តីគេ ចៀសវាងមានអ្នកក្តីណាពុំទៀងត្រង់វេះវៀនក្រឡាស់សម្តីវិញសជាខ្មៅ។ បើក្នុងកំឡុងពេលប្តឹងចៅក្រម ហើយចៅក្រមឱ្យស្មៀនកត់ពាក្យតាមដំណើរហើយ ស្រាប់តែដល់ថ្ងៃជុំនំអ្នកក្តីខាងណាឆ្លើយខុសពាក្យដើមដែលបានកត់នោះទុកជាចាញ់គេបាន។ មួយទៀតបើអ្នកដើមចោទៗចុងចម្លើយពីរឿងអ្វីមួយ (ឧទាហរណ៍ចោទរឿងលួចរបស់ទ្រព្យ) ឯចុងចម្លើយនោះបែរជាឆ្លើយបង្វែងខុសសេចក្តីដែលគេកំពុងចោទ នោះទុកថាចុងចម្លើយនោះខុសពិតដ្បិតពុំហ៊ានឆ្លើយនឹងគេខំតែបង្វៀងទៅរឿងឯណាផ្សេងវិញ ត្រូវឱ្យទទួលពិន័យតិចច្រើនតាមដោយនូវទោសនោះឯង[១៤៣]។

ឯចៅក្រមបើនឹងសាកសួរឬពិសោធន៍ក្តីគេអាចជ្រើសរើសពិធីច្រើនរបៀបតាមស្ថានភាពជាក់ស្តែង។ ជួនកាលចៅក្រមត្រូវឱ្យសួរ ឬពិសោធន៍ក្តីគេនោះដោយសុភាពអត់ធ្មត់ធ្វើដោយសន្សឹមៗ ដើម្បីឱ្យបានដឹងដល់ឬសគល់នៃរឿងវ៉ាវរិវាទនោះពិតប្រាកដនឹងបានកាត់ក្តីនោះឱ្យដោយយុត្តិធម៌ត្រឹមត្រូវ។ ប៉ុន្តែពេលខ្លះទៀត បើមានគូវិវាទម្ខាងណាមានៈរឹងរូសប្រទូសរាយព្រហើនកោងកាចដាក់ចៅក្រមនិយាយពុំស្តាប់ខំណាស់តែនឹងប្រកែកតវ៉ា នោះចៅក្រមអាចប្រើអំណាចសង្កត់សួរកឬសគល់ដើមចមនៃរឿងហេតុនោះបានឥតទាស់ខុសនឹងព្រះក្រិត្តិការឡើយ។ ចំណែកក្នុងកំឡុងពេលពិសោធន៍ពិចារណាជម្រះក្តីលើរឿងអ្វីមួយដូចជារឿងទ្រព្យសម្បត្តិ គោក្របី ដំរី សេះ សារពើអ្វីៗក្តី បើចៅក្រមពុំទាន់កាត់ឱ្យជ្រះស្រឡះ ហើយបើអ្នកក្តីនោះស្លាប់អស់ ឯទ្រព្យជាជម្លោះនោះត្រូវបានទៅចៅក្រម១ភាគ បានទៅអ្នករក្សា១ភាគ និងយកជាទ្រព្យហ្លួង២ភាគ[១៤៤]។

ឃ. ស្វែងរកបន្ទាល់សាក្សី

ការស្វែងរកសាក្សីពុំមែនជារឿងចាំបាច់ត្រូវធ្វើដោយខានពុំបានក្នុងពេលជម្រះក្តីឡើយ ព្រោះសាក្សីជាចំណែកក្រៅប៉ុណ្ណោះ។ រឿងខ្លះពុំចាំបាច់មានសាក្សីមកជួយបំភ្លឺក៏អង្គជំនុំអាចដំណើរការក្តីបានដែរ។ សាក្សីនេះមានវត្តមាននៅពេលចៅក្រមទាល់ឬនៅពេលគូក្តីទាមទារស្នើទៅចៅក្រមសុំយកនរណាម្នាក់មកជួយអះអាង។ តែបើសិនអង្គជំនុំជម្រះសេចក្តីសម្រេចឱ្យមានសាក្សីហើយ ពេលនោះពាក្យសម្តីរបស់សាក្សីទាំងអស់ជា

---

[១៤៣] សូមអានឧទាហរណ៍ទំនឹម១៩នៃ *ច្បាប់ទំនឹមពីបុរាណ*។

[១៤៤] សូមអានឧទាហរណ៍ក្នុង «ក្រមសារពើគុណ», ១៨៩១, ទំ.២៧-២៨។

រឿងសំខាន់ដែលអាចឱ្យចៅក្រមយកមកវិនិច្ឆ័យក្តីបាន។ បើសាក្សីស្រដីពុំត្រូវរឿងជាមួយដើមបណ្តឹងឬចុងចម្លើយ ឧទាហរណ៍បើដើមបណ្តឹងឬចុងចម្លើយនិយាយពីគោ ចំណែកសាក្សីនិយាយឯស្វាទៅវិញ លោកទុកថាពុំទៀងត្រង់ឱ្យកាត់សេចក្តីជាចាញ់គេ។ មួយវិញទៀតបើសាក្សីនិយាយហួសពីពាក្យរបស់ដើមបណ្តឹងឬចុងចម្លើយ សាក្សីនោះទុកថាកុហកបោកប្រាស់ពុំសុទ្ធនិយាយបំភ្លើសតាមចិត្តឯង ដូច្នេះអង្គចៅក្រមក៏កាត់សេចក្តីនោះថាជាចាញ់គេដែរ។ ក្នុងករណីត្រូវការចាំបាច់អ្នកសាក្សីឬបន្ទាល់នោះ គេត្រូវឱ្យអ្នកបន្ទាល់នោះស្បថទទួលបណ្តាសារសាត្រាប្រណិធានជាមុនសិនទើបឱ្យជាបន្ទាល់សាក្សីបាន ហើយបើសាក្សីនោះមិនទាន់ស្បថទទួលបណ្តាសារនៅឡើយ បើសាក្សីនោះនិយាយអ្វីៗក្តីទោះត្រូវគ្នានឹងពាក្យដើមរបស់អ្នកប្តឹងក្តី អ្នកចុងចម្លើយក្តី ពុំឱ្យយកពាក្យសាក្សីនោះមកកាត់សេចក្តីថាជាចាញ់ជាឈ្នះបានឡើយ។ រីឯកិច្ចការចាត់តាំងអ្នកទៅកោះហៅសាក្សីមកនោះ គេមិនឱ្យអ្នកកណ្តាលទៅតែឯងឡើយ គឺត្រូវឱ្យមានគ្នាពីរទៅបីនាក់ហើយសឹងជាអ្នកចេះសំបុត្រខ្ជាប់ដូចគ្នាផង ចៀសវាងអ្នកកណ្តាលត្រូវគ្នានឹងសាក្សីសមគំនិតគ្នាបំភ្លៃសេចក្តីគេសឱ្យជាខ្មៅនាំឱ្យចៅក្រមកាត់ក្តីខុសកើតក្តៅក្រហាយដល់រាស្ត្រចង្រៃដល់ផ្ទៃក្រោមហើយនាំឱ្យមានបាបធ្លាក់នរកចតុរាបាយផង[១៤៥]។

ឃ. បង្គាប់ក្តី

ការបង្គាប់ក្តីធ្វើឡើងក្រោយពេលដែលចៅក្រមស៊ើបសួរនិងកត់ត្រាច្បាស់នូវរឿងហេតុរបស់ដើមបណ្តឹងនិងចុងចម្លើយ។ ចៅក្រមជំនុំក្តីបើនឹងបង្គាប់ក្តីគេត្រូវឱ្យតាមលំអានច្បាប់ព្រះក្រិត្តិការ។ ឯច្បាប់បង្គាប់ក្តីនោះមានបីប្រការដូចមានចែងក្នុង «*ច្បាប់ឃុនសាឌ្ឃា*» និងក្នុង «*ក្រមប្រដៅចៅក្រម*»។

១. ហៅ «ឧិត្តា» : ឱ្យបង្គាប់ក្តីនោះបីដូចភ្ងៀងហូរចុះពីស្ថានខ្ពស់ ហើយសឹងហូរចុះទៅស្ថានជាបនោះហោង។

២. ហៅ «ចិត្តា» : ឱ្យបង្គាប់ក្តីតាមដោយទូរគន្ធត្រូបកចិត្តអ្នកក្តីនោះហោង គឺឱ្យបង្គាប់កាត់សេចក្តីគេបីដូចអ្នកបរនេះតាមដោយទូរគន្ធផ្លូវរៀចផ្លូវត្រង់នោះហោង។

[១៤៥] សូមអាន *ច្បាប់ឃុនសាឌ្ឃា* សន្លឹកទី២១។

៣. ហៅ «ទ្វារតា» : ឱ្យបង្ហាប់ក្តីគេបីដូចមនុស្សដៅក្នុងព្រៃនគរធានីដើរចេញចូលព្រៃនគរនោះសឹងដើរតាមដោយងួចច្រោះទ្វារព្រៃនគរនោះហោង ពុំដែលចៀសក្រៅអំពីទ្វារព្រៃនគរនោះឡើយ។

ក្រៅអំពីសេចក្តីច្បាប់បង្គាប់ក្តីបីប្រការនេះ នៅពេលបង្គាប់ក្តី ចៅក្រមគោងប្រតិបត្តិឱ្យខ្ជាប់នូវលក្ខណៈ៤ដំពូក គឺ *មន្ទរលេន សេនបទ មន្ទកដ សីហរោ* ដូចបាននិយាយរួចមកហើយនៅចំនុចខាងលើ អំពី «ចៅក្រម»។

៦. ការសម្រេចជាក់ពិន័យនិងទោសទណ្ឌា

នេះជាចំណុចចុងក្រោយបង្អស់ក្នុងដំណើរការកាត់ក្តី។ ការពិន័យនិងដាក់ទោសទណ្ឌាគឺអនុឡោមទៅតានស្ថានទម្ងន់ទោសរបស់អ្នកប្រព្រឹត្ត។

២.១.៥. អំពីទោស

នៅក្នុងសិលាចារឹកសម័យបុរាណប្រភេទទោសដែលយើងឃើញឈ្មោះមានដូចជា ឧបបាតក បាតក មហាបាតក និងឧត្តមសាហ។ លុះមកដល់សម័យកណ្តាលនៅក្នុងច្បាប់និងក្រមនានា យើងប្រទះឈ្មោះទោសមានច្រើនប្រភេទខុសៗគ្នាតាំងពីកម្រិតស្រាលដល់កម្រិតធ្ងន់។ ទោសទាំងនោះមានដូចខាងក្រោម៖

ទោសសាក្តី៖ ពាក្យថា «សា» មានន័យថាធ្វើឱ្យត្រលប់វិញ សាមកវិញ ក្រឡាស់ឱ្យផ្លាស់ពីម្ខាងទៅម្ខាងជាដើម។ «សាក្តី» គឺសម្តៅលើការធ្វើឱ្យរឿងក្តីក្រឡាស់ច្រាសចុះឡើង។ អ្នកដើមចោទៗចុងចម្លើយថាបានប្រព្រឹត្តខុសរឿងអ្វីមួយ ឯចុងចម្លើយថាខ្លួនពុំបានប្រព្រឹត្តរឿងនោះទេ គឺអ្នកដើមចោទខ្លួនឯងវិញទេដែលប្រព្រឹត្តរឿងដែលចោទនោះ។ ឧទាហរណ៍ បុគ្គល «ក» ដឹងថាបុគ្គល «ខ» ជាចោរ ជាអាប ជាធ្មប់ ឬបុគ្គល «ខ» នោះជំពាក់ទ្រព្យឯងតែពុំបានទៅប្តឹងចៅក្រមឱ្យដឹងឮឡើយ។ លុះចំណេរក្រោយមកបុគ្គល «ខ» នោះមានក្តីជាមួយបុគ្គល «ក» ប្តឹងចៅក្រមថាអ្នក «ក» នោះជាចោរ ជាអាប ជាធ្មប់ឬជំពាក់ទ្រព្យខ្លួនទៅវិញ ទើបបុគ្គល «ក» ខំតវ៉ាប្រកែកថាអ្នក «ខ» ទៅវិញទេដែលជាចោរ ជាអាប ជាធ្មប់ ដ្បិតខ្លួនដឹងឃើញរហើយ។ ប្រសិនបើដូច្នេះ គឺបុគ្គល «ក» នោះឯងមានទោសឈ្មោះថា «**សាក្តី** » ឱ្យកាត់ជាចាញ់គេ ឱ្យពិន័យតាមសេចក្តីដែលគេប្តឹងមុន ដ្បិត

ខ្លួនដឹងយូរហើយខំលាក់ពុំប្តឹងចៅក្រមឡើយបណ្តោយឱ្យទោសនោះធ្លាប់បកមកលើអាត្មាឯង[១៤៦]។

ទោសមជ្ឈឹម៖ ជាទោសទាំងឡាយណាដែលពាក់ព័ន្ធនឹងការសម្ព័ន្ធមេត្រីរវាងសាច់សាររលោហិតខ្លួនឯងត្រឹមខ្សែជីទួតមួយ។ ឧទាហរណ៍ បើអ្នកឯណាយកជីតា ជីដូន ទីទួតមួយបង្កើតក្តី ទោះយកម្តាយមីង ចៅ ក្មួយជីទួតមួយបង្កើតក្តី សាច់ថ្លៃក្តី ទោះយកបងថ្លៃ ប្អូនថ្លៃជីទួតមួយបង្កើតក្តី ខាងសាច់ថ្លៃក្តី អស់ទោសទាំងនោះសឹងកាត់ដោយ *ទោសមជ្ឈឹម*[១៤៧]។

ទោសលហុ៖ ទោសនេះជាទោសស្រាលជាងទោសមជ្ឈឹម។ ឯអំពើដែលចាត់ចូលជាបទលហុគឺជនទាំងឡាយណាដែលទៅស្មន់អន្ធករឬយកសាច់សាររលោហិតគិតត្រឹមជីលួតមួយរបស់ខ្លួនធ្វើជាប្តីប្រពន្ធ[១៤៨]។

ទោសជ្រៃរាជ៖ ជាទោសដែលអ្នកផងទាំងឡាយណាទៅយកស្រីទាំងបងទាំងប្អូនបង្កើតជាប្រពន្ធ ទោះយកបងហើយមានកូនលែងគ្នាឬស្លាប់ក្តីហើយវិលទៅយកប្អូនជាប្រពន្ធទៀតក្តី ទោះម្តាយមីងទៅយកក្មួយឯងក្តី ទោះអ្នកផងសុំកូនគេពីតូចមកមកធ្វើជាកូនឯង លុះធំឡើងវិលទៅយកកូននោះជាប្តីប្រពន្ធវិញក្តី ទាំងអស់នេះហៅជ្រៃរាជ[១៤៩]។

ទោសជងជាំ៖ ជាទោសដែលបងទៅយកប្អូនឯងជាប្តីជាប្រពន្ធ ឬប្អូនទៅយកបងឯងជាប្តីជាប្រពន្ធ[១៥០]។

ទោសសលវលជំ៖ អ្នកប្រព្រឹត្តអំពើដែលចាត់ចូលក្នុងទោសសល់វល់ធំគឺអ្នកទាំងឡាយណាដែលទៅបួសជាភិក្ខុឬសាមណេរនៅក្នុងវត្តជិតភូមិឬឆ្ងាយពីភូមិក្តីឥតមានបងប្អូនសន្តានព្រៀងលាន តែមានអ្នករក្សាចង្ការតែងផ្តត់ផ្គង់ស្បង់ចីពរ គ្រឿងបរិភោគគ្រប់បែបយ៉ាង បើអ្នកនោះសឹកទៅយកមេចង្ការដែលតែងផ្តត់ផ្គង់នោះជាប្រពន្ធក្តី យកម្តាយបង្កើតក្តី យកជីដូន ម្តាយមីង យកបងប្អូនកូនក្មួយចៅបង្កើតក្តី សាច់ថ្លៃរបស់មេនោះក្តីពុំបានឡើយ។ រីអ្នកឯណាមានកូនយកទៅបំបួសនឹងគេក្តី ទោះសឹកមកវិញក្តី អ្នកបំបួសនោះស្លាប់ក្តី ទោះបីធ្វើបាន១ថ្ងៃ ២ថ្ងៃ ឬ១ខែ ២ខែក្តី នោះមាត្រាទុកថាជាសិស្សបាន។ បើ

---

[១៤៦] សូមអានបន្ថែមឧទាហរណ៍ក្នុងមាត្រា១នៃ *ច្បាប់ឃុនសាឡា* សន្លឹកទី១៥។

[១៤៧] ច្បាប់សង្ឃរី សន្លឹកទី៤។

[១៤៨] *Ibid.,*

[១៤៩] *Ibid.,*

[១៥០] *ច្បាប់សង្ឃរី* សន្លឹកទី៦។

គ្រូនោះទៅយកម្តាយសិស្សបង្កើតក្តី បងសិស្ស ប្អូនសិស្សក្តី ម្តាយមីង ក្មួយ បងថ្លៃ ប្អូនថ្លៃ ជីដូន ចៅ ម្តាយក្មេកនឹងសិស្សក្តី អស់ទាំងនេះរាប់ចូលជាទោសហៅ «*សល់វល់ធំ*»[១៥១]។

ទោសជាវប្រមាត់៖ គឺទោសដែលអស់ពួកខ្ញុំបម្រើទាំងឡាយណាយកម្ចាស់ឯងជាប្រពន្ធក្តីជាប្តីក្តី។ ទោះកាលអ្នកនោះធ្លាប់ជាខ្ញុំបម្រើគេ ដល់កាលមានទ្រព្យមកលោះដោះខ្លួនរួចចេញអំពីម្ចាស់នោះ ហើយវិលមកយកម្ចាស់ឯងជាប្រពន្ធក្តី ជាប្តីក្តី ទោះយកម្តាយបងប្អូនបង្កើត ម្តាយមីង ក្មួយ ចៅ បងថ្លៃ ម្តាយក្មេកម្ចាស់ស្រីឯងក្តី ទោះខ្ញុំគេជាអន្ធករនិងស្រីអ្នកជាក្តី អស់អំពើទាំងនេះហៅ «*ជាវប្រមាត់*» សឹងត្រូវទោសទាំងអស់គ្នាអ្នកដែលប្រព្រឹត្ត ដ្បិតលោកថាវានោះបង្កាច់កេរ្តិ៍ស្រីផងទាំងផ្តាស[១៥២]។

ទោសពានជុន[១៥៣]៖ គឺជាទោសដែលអ្នកទាំងឡាយណាជាអ្នកជាហើយទៅស្មន់អន្ធករជាមួយខ្ញុំគេគ្រប់ជំពូក ទោះខ្ញុំអ្នកទាំងពួងក្តី ទោះខ្ញុំនាមីនមុខមន្ត្រីជំទាវខុនណាងក្តី សឹងត្រូវទោសពានជុនទាំងអស់[១៥៤]។ បើអ្នកឯណាមានងារជាខ្ញុំគេក្តី ជាបំរោសគេក្តី អាយ័តគេក្តី ទៅលបលួចឡើងចាប់កូនក្រមុំគេ នោះហៅពានជុន ឱ្យពិន័យដោយនូវបណ្តាសក្តិមេបាកុំប្រណីឡើយ។ តែបើប្រុសនោះជាអ្នកជាសឹងស្មើគ្នា ឱ្យព្រះសភាយកមកផ្សំផ្គុំគ្នា។ បើម្តាយឪពុកមិនពេញចិត្តឱ្យឡើងទូលដល់ព្រះករុណាស្តេចផែនដីជ្រាប[១៥៥]។ រីបើម្ចាស់ខឹងនឹងខ្ញុំហើយគុំវាយវានោះ ខ្ញុំនោះកាន់ជាវកាន់លំពែងធ្នូស្នានឹងបាញ់ចាក់កាប់អ្នកម្ចាស់នោះវិញសឹងហៅពានជុនដូចគ្នា។ ទោសពានជុននេះឱ្យសម្លាប់បាន។ បើរាស្ត្រឱ្យប្តឹងនាមីនទើបសម្លាប់បាន។ ទោះមន្ត្រីឱ្យទូលស្តេចទើបសម្លាប់បាន[១៥៦]។

ទោសអម្ពន៖ អំពីទោសនេះយើងគ្រាន់តែដឹងថាជាទោសដែលពាក់ព័ន្ធនឹងរឿងសម្ព័ន្ធរវាងប្រុសនិងស្រីដូចទោសទាំងប៉ុន្មានខាងលើដែរ ប៉ុន្តែសេចក្តីលម្អិតថាដូចម្តេចទៀតឥតបើដឹងឡើយ ព្រោះនៅក្នុងសាត្រាយើងឃើញតែឈ្មោះហៅក្នុងចង្កោមទោសស្រដៀងគ្នា។ ឧទាហរណ៍ជ្រះរាជអម្ពនពានជុន[១៥៧]។

---

[១៥១] *Ibid.*, សន្លឹកទី ៧-៨។

[១៥២] *Ibid.*, សន្លឹកទី ១៧។

[១៥៣] ក្នុងសាត្រាខ្លះសរសេរថា «ពានជុន» ដូច្នេះ។

[១៥៤] *Ibid.*,សន្លឹកទី១៧។

[១៥៥] *ក្រមសារពើគុណ* សន្លឹកទី៨។

[១៥៦] *ច្បាប់ក្រមស្រុក៨ប្រការ* សន្លឹកទី១៧។

[១៥៧] *ច្បាប់ក្រមសុភាជិបតី*, សាត្រាដើម សន្លឹកទី៤៤។

ទោសបារាក្រមៈ ជាទោសដែលឃើញមានចែងតែនៅក្នុងច្បាប់ក្រមសុកាធិបតី ឯច្បាប់នឹងក្រមដទៃទៀតពុំឃើញមាននិយាយដល់ទោសនេះឡើយ។ ទោសបារាក្រមនេះពុំដឹងថាកាត់ថ្លៃក្រយ៉ាពិន័យប៉ុន្មានទេ ដ្បិតពុំមាននិយាយនៅក្នុងច្បាប់ ខុសពីទោសដទៃទៀតដែលសុទ្ធសឹងបញ្ជាក់ថាត្រូវបង់ក្រយ៉ាពិន័យប៉ុន្មានៗតាមទោសហើយដែលយើងនឹងឃើញនៅចំណុចក្រោយបន្តទៅទៀតនេះ។ ឧទាហរណ៍ដែលនិយាយអំពីទោសបារាក្រមគឺថាបើសិនមាននរណាទាល់លំបាកទៅយកប្រាក់គេតិចច្រើនហើយយកប្រពន្ធកូន ចៅ ខ្ញុំ ឬយកខ្លួនឯងទៅបញ្ចាំបម្រើទ្រព្យគេតែពុំទាន់ជាខ្ញុំដាច់ថ្លៃ នោះម្ចាស់ទ្រព្យពុំអាចប្រើគេក្នុងបទបារាក្រមឡើយ។ ឯអំពើហៅថាបារាក្រមនោះមាន ៖ ប្រើគេឱ្យជីកបង្គន់ សង់បង្គន់ កាន់ទឹកទៅបង្គន់ កាន់ថង់ កាន់ខ្សៀ កាន់ស្បែកជើង តាំងយូ ជាដើម។ ទោះបើម្ចាស់នោះខឹងនឹងខ្ញុំនោះណាស់ហើយវាយនឹងថង់ វាយច្រកឃ្នាង កាប់នឹងកង្វៃរ ចាក់នឹងជន្លួញ វាយនឹងរំពាត់សេះរំពាត់ក្របី វាយនឹងខ្សែ វាយនឹងអង្រែ វាយនឹងចន្លោះ វាយនឹងអង្កត់អុស ទោះបោកនឹងស្បែកជើង វាយនឹងវែកបាយវែកសម្ល ទោះចាក់ទឹកលើក្បាល ទោះយកកក់យកធ្យូងមកប្រឡាក់មុខប្រឡាក់មាត់ប្រឡាក់ខ្លួនក្តី អស់ទោសទាំងនេះសឹងហៅបារាក្រមធ្វើតាមចិត្តខឹងពុំបានឡើយ។ ម្យ៉ាងទៀតទោះមាននរណាស្លាប់ក្នុងផ្ទះទោះម្តាយឪពុក ប្រពន្ធកូន ទោះម្ចាស់នោះស្លាប់ក្តី នឹងឱ្យខ្ញុំនោះកោរសក់ក្តី យំក្តី ឱ្យចំអាសទឹកខ្មោច លាងជើងខ្មោច បិទមុខបិទភ្នែកខ្មោចក្តី នឹងឱ្យរុំសពកៀសជើងត្បូង ឱ្យកាន់ទង់ព្រលឹង កាន់ជើងជ្រវ ទូលខ្សែភ្លាំង ប្រាយលាជ អស់អំពើទាំងនឹងសឹងឱ្យធ្វើពុំបានឡើយ។ ទោះបើមានបំណងផ្សំផ្គុំរៀបការខ្ញុំនោះនឹងកូនចៅផងខ្លួនក៏ពុំបានព្រោះខ្ញុំនោះពុំទាន់អស់ថ្លៃនៅជាព្រៃហ្លួងនៅឡើយ។ មួយសោតអ្នកម្ចាស់ទ្រព្យពុំអាចប្រើខ្ញុំនោះឱ្យទៅប្រព្រឹត្តអំពើទាំងឡាយដូចជា ប្រើឱ្យទៅលួចប្លន់ កាប់សម្លាប់បំពុលគេ ជាដើម។ បើគេចាប់បានឱ្យពិន័យម្ចាស់ទ្រព្យពុំឱ្យពិន័យខ្ញុំនោះឡើយ ហើយម្ចាស់ទ្រព្យនោះជាប់ទោសហៅបារាក្រម[១៥៨]។

ទោសទម្ងន់ផ្នែកក្រោមៈ ជាទោសដែលល្មើសលើព្រះបញ្ញត្តិរបស់ព្រះមហាក្សត្រ។ ឧទាហរណ៍បើនរណាម្នាក់ឬមន្ត្រីណាមួយចង់ធ្វើអ្វីមួយហើយ បើព្រះមហាក្សត្រពុំបើកឱ្យឡើយនៅរឹងចចេសធ្វើឱ្យខាងតែបាន អ្នកនោះនឹងត្រូវទោសទម្ងន់ផ្នែកក្រោម[១៥៩]។

---

[១៥៨] *ច្បាប់ក្រមសុកាធិបតី*, សាត្រាដើម សន្លឹក១៧-១៨។

[១៥៩] សូមអាន*ច្បាប់ក្រមស្រុកព្រះវិហារដេស្ត*, បន្ទាត់២៤៨ និង Mikaelian ២០០៦: ៧៤១។

ទោសរបឹបហ្លួង៖ ជាទោសត្រូវឱ្យរឹបយកអស់សម្បត្តិទ្រព្យទាំងអស់រួមមាន គោ ក្របី ស្រែ ចម្ការ ផ្ទះសម្បែង រទេះ រនាស់ ខ្ញុំបម្រើប្រុសស្រីទាំងឡាយផង។ សម្បត្តិដែលរឹបពីអ្នកទោសទាំងនោះត្រូវយកទៅដាក់ក្នុងព្រះឃ្លាំងទុកជាទ្រព្យហ្លួង។ អ្នកដែលជាប់ទោសរបឹបហ្លួង គឺអ្នកណាដែលជាអាប ជាធ្មប់ ស្រីផើមឥតប្តី និងអ្នកប្រព្រឹត្តអំពើដែលរាប់ចូលក្នុងប្រភេទជ្រៃរាជ ដាវប្រមាត់ អម្ពន ពានជុន សល់វល់ធំជាដើម[១៦០]។

ទោសតាសករ៖ អ្នកមានទោសហៅតាសករគឺអ្នកដែលជាចោរលួចយប់លួចថ្ងៃ។

ទោសពាតាសករ៖ គឺទោសចំពោះពួកចោរប្លន់យប់ប្លន់ថ្ងៃ។

ទោសពាន្ធិយុង៖ គឺពួកចោរប្លន់យប់សម្លាប់គេ។

ទោសពាហន្ធិយុង៖ ទោសនេះយើងឃើញមានតែឈ្មោះនិងចំនួនពិន័យប៉ុណ្ណោះ ឯសេចក្តីដូចម្តេចទៀតពុំដឹងឡើយ។

ទោសបូពាន្ធិយុង៖ គឺពួកចោរប្លន់យប់ហើយអុជផ្ទះគេ សម្លាប់គេ កាប់គេ ហើយចាប់ទាំងមនុស្សទៅផង។

ទោសហាន្ធិយុង៖ គឺពួកចោរប្លន់កណ្តាលព្រៃ ឬប្លន់ស្រុកគេដទៃទាំងកណ្តាលថ្ងៃ។

ទោសឧទុម្ពរ៖ គឺទោសអ្នកលបលួចស្មន់អន្ធករជាមួយប្រពន្ធគេ។

ទោសពាឧទុម្ពរ៖ គឺទោសអ្នកលួចនាំប្រពន្ធគេរត់ទៅស្រុកដិតធ្លាយ[១៦១]។

ទោសអហំការ៖ ពាក្យថា «អហំការ» មានន័យថាដាច់ខាត ម៉ឺងម៉ាត់ ប្រាកដប្រជា។ ឯទោសអហំការគឺទោសទាំងឡាយណាដែលមិនអាចលើកលែងបន្លប់បន្តយអធ្យាស្រ័យ ឬអភ័យឱ្យបាន។ បើជនណាត្រូវទោសអហំការ នោះត្រូវពិន័យតាមច្បាប់កំណត់ពុំឱ្យប្រណីឡើយ ទោះអ្នកនោះមានគុណសម្បត្តិនឹងរាជការក៏ដោយ។ អំពើដែលចាត់ចូលជាទោសអហំការគឺអំពើទាំងឡាយណាដែលជាការប្រមាថពាយងាយព្រះចេស្តាព្រះមហាក្សត្រមានចិត្តធំចង់ល្បងចង់ប្រគួតប្រជែងវិទ្ធអំណាចតេជៈនឹងព្រះចេស្តា។ បើអស់ពួកមន្ត្រីធ្វើអ្វី សម្រេចអ្វីចិត្តឯងពុំពិតទូលព្រះករុណាទ្រង់ជ្រាប ទាំងនេះសឹងហៅល្មើសចិត្តធំរំលងលើបារមីព្រះកម្រតេងផ្ទៃក្រោមនឹងត្រូវទោសអហំការ។ ឯការពិន័យខុស

---

[១៦០] សូមមើលឧទាហរណ៍នៅតារាងពិន័យ។

[១៦១] ក្នុងចំណោមទោសទាំង៨ចាប់ពី តាសករ ដល់ទោស ៣ឧទុម្ពរ សុទ្ធតែស្រង់ចេញពី *ច្បាប់ក្រមស្រុក៨ប្រការ* សន្លឹកទី ១៣។

គ្នាពីមន្ត្រីទៅរាស្ត្រ។ នៅក្នុង «ច្បាប់ឃុនសាឡា» បញ្ជាក់ថាទោសត្រូវពិន័យអហំការនេះមានតែព្រះអង្គទ្រង់រាជ្យ (ព្រះមហាក្សត្រ) ជាអម្ចាស់ផ្ទៃក្រោមប៉ុណ្ណោះដែលមានសិទ្ធិអំណាចអាចដាក់ទោសមនុស្សផងទាំងឡាយឱ្យត្រូវទោសអហំការបាន។ ឯព្រះអង្គយោរាជទាំងបី អស់ព្រះអង្គជាសម្តេចព្រះមាតុឡ្ហា សម្តេចព្រះទាវ សម្តេចព្រះមាតុច្ឆា សម្តេចព្រះរាម សម្តេចព្រះអនុជ សម្តេចព្រះរាជបុត្រីបុត្រាសម្តេចព្រះភ័ក្ខនិយោ ព្រះកក្តិនិយា សម្តេចព្រះរាជនុតោ ព្រះរាជនុតា ពុំមានក្រយ៉ាពិន័យអាចពិន័យមនុស្សមានទោសដល់ឧត្តុងសក្តិនិងដល់អហំការឡើយ[១៦២]។

ទោសសម្លាប់បង់ ឬសម្លាប់ស្នងអាយុ៖ ជាទោសដាច់ខាតត្រូវតែសម្លាប់អ្នកទោសនោះចោល។ ពាក្យថា «សម្លាប់បង់» គឺសម្លាប់អ្នកទោសចោលព្រោះគេបានប្រព្រឹត្តកំហុសធ្ងន់ធ្ងរមិនអាចលើកលែងបាន។ ឯពាក្យថា «សម្លាប់ស្នងអាយុ» គឺសម្លាប់អ្នកទោសនោះដោយសារអ្នកនោះបានសម្លាប់គេដោយចិត្តពាលកំណាចយោឃៅ ដូច្នេះត្រូវតែសម្លាប់ជននោះឱ្យស្លាប់ដៃរទើបស្មើគ្នា។ ឧទាហរណ៍ជនដែលមានទោសត្រូវសម្លាប់បង់ឬសម្លាប់ស្នងអាយុមាន ៖ អស់ស្រីជាប្រពន្ធចិត្តពាលជេររំលើកកេរ្តិ៍ប្តី ទៅប្តឹងចៅក្រមឱ្យប្រកោះប្តី វាយប្តីឱ្យមានស្លាកស្នាមជាំជាំ ទោះប្រពន្ធនោះជេរដល់ម្តាយប្តី វាយធាក់កាប់សម្លាប់ប្តីដោយប្រការអ្វីក្តី បើទោះប្តីនោះមិនពុំប្តឹងចៅក្រមក៏ដោយក៏ត្រូវឱ្យភ្នាក់ងារទៅចាប់មេស្រីកំណាចនោះមកឱ្យខ្ជាប់ហើយយកព្រាត់ត្របែងកសម្លាប់ចោល។ ឯទ្រព្យចែកជា៣ភាគ ២ភាគបានប្តី ១ភាគបានប្រពន្ធ។ ឯភាគបានប្រពន្ធនោះត្រូវរឹបយកជាទ្រព្យហ្លួង។ បើមេនោះប្រមាថតែមាត់ទេ ឱ្យលក់ជាប្រាក់ជីង១តម្លឹង៥កុំប្រណីឡើយដ្បិតជេរប្រមាថប្តីទុកស្មើប្រមាថឪពុកម្តាយ[១៦៣]។ ឧទាហរណ៍មួយទៀតនៅក្នុងច្បាប់ទំនឹមពីបុរាណត្រង់ទំនឹម២១និយាយអំពីចោរលួចគាស់ទ្វារព្រះវិហារលួចយកព្រះពុទ្ធរូបមាសច្រើនអង្គទៅរំលាយលក់យកប្រាក់។ រឿងនេះក្រោយមកគេតាមទាន់ប្តឹងចៅក្រមឱ្យជំនុំក្តី។ ឯចោរនោះសោតត្រូវព្រះចៅឱ្យនាំយកទៅធ្វើទោសអាំងរោលសម្លាប់បង់សៀត។ ចំពោះទោសអ្នកដែលសម្លាប់គេហើយត្រូវភ្នាក់ងារចាប់យកទៅសម្លាប់ស្នងអាយុគេវិញ មានឧទាហរណ៍និយាយក្នុងទំនឹម១៦នៃច្បាប់ទំនឹមពីបុរាណដែលមានសេចក្តីសង្ខេបដូច្នេះថា ៖ ចៅសមទៅចាប់អាងួនជាធ្មប់ ទៅចាប់មេសន់ជាអាប។ ចៅសមចាប់បានសុទ្ធ

---

[១៦២] សូមអាន *ច្បាប់ឃុនសាឡា* សន្លឹកទី២៤ និងអានឧទាហរណ៍បន្ថែមអំពីទោសអហំការក្នុង *ច្បាប់ទំនឹមពីបុរាណ* ត្រង់ទំនឹម១៤, ១៨និង២០។

[១៦៣] សូមអាន *ច្បាប់សង្ឃរី* សន្លឹកទី២៥។

ជាធ្មប់នឹងអាបស្រេចហើយក៏សម្លាប់ធ្មប់អាបនោះចោលដោយចិត្តឯងរួចរឹបយករបស់អាបធ្មប់នោះទៀត។ ទើបឈ្មោះចៅសួសជាឃុនណាងទៅប្តឹងសម្តេចព្រះទាវ។ ឯសម្តេចព្រះទាវក៏ទូលព្រះរាជបុត្រតាមដំណើរនោះ ទើបព្រះអង្គឱ្យប្រកោះចៅសមហើយរឹបទ្រព្យនិងខ្ញុំចៅសមបីនាក់ផង រួចទើបព្រះអង្គដាក់សេចក្តីឱ្យឧកញ៉ាយមរាជដំនុំ។ ចៅក្រមយល់ថាចៅសមនោះព្រហើនកំណាចហ៊ានសម្លាប់អាបធ្មប់ចិត្តឯងមិនឱ្យចៅក្រមដំនុំហើយរឹបទ្រព្យគេទុកខ្លួនឯងមិនយកទៅថ្វាយហ្លួង អំពើនេះយល់ជាខុសណាស់ត្រូចឱ្យសម្លាប់ចៅសមនោះស្នងអាយុគេវិញហើយរឹបទ្រព្យចៅសមនោះទាំងអស់ផង។

ឧទាហរណ៍មួយទៀតនៅក្នុងច្បាប់ក្រមស្រុកព្រះដៃដេដ្ឋា។ ចាប់ពីបន្ទាត់៣៤៣ដល់៣៤៦ពោលថា បើពលព្រះបាទអ្នកជាអម្ចាស់នូវអស់ព្រះអង្គផង បើវាចេញទៅជាចោរលួចព្រពន្ធគេក្តី ទោះវាលួចប្លន់យកទ្រព្យរបស់គេហើយវាវាយដំបាញ់ចាក់កាប់សម្លាប់ម្ចាស់ទ្រព្យឬប្តីនោះស្លាប់ ទោះជារបួសទេក្តី ឱ្យសម្លាប់វានោះបង់សៀតទៅហោង។

២.១.៦ ការពិន័យនិងទណ្ឌកម្ម

ក. ការពិន័យ

យើងត្រូវបែងចែកការពិន័យទៅលើមនុស្ស៣ក្រុមគឺ ក្រុមព្រះញាតិវង្ស ក្រុមមន្ត្រីនិងរាស្ត្រសាមញ្ញ។ បំពោះក្រុមព្រះញាតិវង្សនិងក្រុមមន្ត្រី ការបែងចែកក្រយ៉ាពិន័យត្រូវប្រព្រឹត្តទៅក្នុងទម្រង់ពីរផ្សេងទៀត។ ទី១គឺការពិន័យនៅពេលដែលព្រះញាតិវង្សនិងក្រុមមន្ត្រីប្រព្រឹត្តកំហុស។ ឯទី២គឺពិន័យចំពោះជនទូទៅដែលខុសនឹងព្រះញាតិវង្សឬពួកមន្ត្រី ឧទាហរណ៍រាស្ត្រប្រមាថមើលងាយព្រះរាជវង្សនិងពួកមន្ត្រីជាដើម។ ការពិន័យនៅសម័យកណ្តាលគឺអាស្រ័យទៅតាមប្រភេទនិងកម្រិតសក្តិទៀត។ ប្រភេទសក្តិទាំងនោះហៅថា «ព្រះជាតិសក្តិ» រួមមាន ៖ ព្រះពហុសក្តិ បុរាណសក្តិ រាជសក្តិ ពិភពសក្តិ និងឧត្តុង្គសក្តិ។

ពហុសក្តិ៖ សម្តៅពួកនាម៉ឺនដែលជាប់ខ្សែរាជវង្ស។ ចំនួនទឹកមាសដែលត្រូវពិន័យគឺជីង៣តម្លឹង១៧ហើយគិតជាទ្វេគុណ ត្រីគុណ ឬចតុគុណតាមដោយនូវទោសធ្ងន់ស្រាល។ ទោសដែលអាចពិន័យអង្គពហុសក្តិមានជាអាទិគឺ ខឹងនឹងខ្ញុំជេរត្មិះតេះដៀលដល់ម្ចាស់ចៅហ្វាយគេ លួចលបស្មន់អន្ធករនឹងប្រពន្ធគេនៅក្បែរវាំង ជេរប្រមាថអាជ្ញាព្រះមហាក្សត្រលើព្រះបន្ទូល លួចស្មន់អន្ធករនឹងខ្ញុំហ្លួង វាយមហាតហ្លួង មានព្រះបន្ទូលពិសេសទៅជនណាមួយហើយ ជននោះមិនចេញមកទទួលព្រះបន្ទូល អស់អ្នកមានអំណាច ឬចៅហ្វាយនាយណាប្រើអ្នកដែលជាជំពូកបម្រើសឱ្យកាន់ជាវកាន់លំពែង ទៅដណ្តឹងកូនគេ

គេប្រាប់ថាមានប្តីហើយពុំស្តាប់នៅប្រឹងទៅដណ្តើងជាគម្រប់៣ដើង ទាំងអស់នេះសឹងត្រូវទោសឱ្យពិន័យអង្គពហុសក្តិជាទ្វេរគុណ ត្រីគុណ ចតុគុណ[១៦៤]។

បុរាណសក្តិ៖ គឺនាមុឺនដែលមានត្រកូលជាមន្ត្រីតគ្នាមកទើបព្រះរាជទានឱ្យបានជាមន្ត្រីតទៅទៀត។ ឯចំនួនក្រយ៉ាពិន័យមិនដឹងថាមានចំនួនប៉ុន្មានឡើយឯច្បាប់ពុំមាននិយាយ។

រាជសក្តិ៖ គឺអ្នកដែលបានឡើងជាមន្ត្រីដោយសារព្រះមហាក្សត្រព្រះរាជទាន។ ឯក្រយ៉ាពិន័យក៏ពុំដឹងដូចគ្នា។

ពិភពសក្តិ៖ គឺពួកជនទាំងឡាយដែលបានឡើងជានាមុឺនដោយសារមន្ត្រីធំ ឬតពីដូនតាមកពុំដែលបានជាមន្ត្រី តែមានចិត្តឈឺឆ្អាលព្រះរាជាផ្ទៃក្រោម។ ឯក្រយ៉ាពិន័យក៏ពុំមាននិយាយក្នុងច្បាប់។

ឧត្តុង្គសក្តិ៖ ប្រហែលពុំសម្តៅទៅលើសក្តិមន្ត្រីទេ តែប្រហែលសម្តៅលើកម្រិតពិន័យប៉ុណ្ណោះ។ ឧទាហរណ៍ ពិន័យឧត្តុង្គសក្តិស្មើនឹងប្រាក់ជីង២២។ បើពួកមន្ត្រីធ្វើខុសហើយពិន័យដល់ឧត្តុង្គសក្តិអាចដកជារាស្ត្រវិញ និងពិន័យជាប្រាក់ជីង២២នោះផង។

តារាងពិន័យព្រះជាតិសក្តិ

ព្រះជាតិសក្តិទឹកមាស១ជា១០						
ជនត្រូវពិន័យ	ប្រភេទសក្តិ	ចំនួន	ទំហំទោស			អហំការ
			ទ្វេរគុណ	ត្រីគុណ	ចតុគុណ	
រាស្ត្រ+មន្ត្រី	ពហុសក្តិ	ជីង២៣ តម្លឹង១៧	ជីង៧ តម្លឹង១៤	ជីង១១ តម្លឹង១១	ជីង១៥ តម្លឹង៨	ជីង៥៣
	ឧត្តុង្គសក្តិ	ជីង២២	X	X	X	
ព្រះវររាជបិតានិងមហា	ពហុសក្តិ	ជីង២៣ តម្លឹង១៧	X	X	X	គ្មាន
	ឧត្តុង្គសក្តិ	ជីង២២	X	X	X	

[១៦៤] សូមមើលឧទាហរណ៍ក្នុង៖
- *ច្បាប់ទំនឹមពីបុរាណ* ត្រង់ទំនឹម៧, ៨, ៩, ១០, ២២ និង២៤។
- *ច្បាប់ក្រមស្រុកព្រះវិជ័យជ័យ* បន្ទាត់២៥៦-២៥៧
- *ក្រមសារពើគុណ* សន្លឹកទី៥។

ព្រះជាតិសក្តិទឹកមាស១ជា១០						
ជនត្រូវពិន័យ	ប្រភេទសក្តិ	ចំនួន	ទំហំទោស			អហំការ
			ទ្វេគុណ	ត្រីគុណ	ចតុគុណ	
ឧបរាជទាំង៣						
សម្តេចព្រះអយ្យកោ	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះមាតុលា	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះទាវ	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះរាម	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះអនុជ	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះរាជបុត្រ និងព្រះរាជបុត្រី	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
ព្រះរាជានាតុនិងព្រះរាជានាតា	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	
សម្តេចព្រះភគនិយោ និងសម្តេច	ពហុសក្តិ	ជីង២ តម្លឹង៤	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	ជីង៤ តម្លឹង១៦	គ្មាន
	ឧត្តុង្គសក្តិ	គ្មាន	X	X	X	

ព្រះជាតិសក្តិទឹកមាស១ជា១០						
ជនត្រូវពិន័យ	ប្រភេទសក្តិ	ចំនួន	ទំហំទោស			អហំការ
			ទ្វេគុណ	ត្រីគុណ	ចតុគុណ	
ព្រះភគនិយា						

សេចក្តីនេះចែងនៅក្នុងច្បាប់ក្រមស្រុកព្រះជ័យជេដ្ឋាដែលមានខ្លឹមសារដូច្នេះ៖

[...] មាត្រា១ ជាច្បាប់ព្រះមហាក្សត្រាធិរាជឱ្យចៅក្រមជជ្ជឹជ័

១៥. ព្រះជាតិសក្តិ ព្រះអង្គទ្រង់ព្រះរាជាអម្ចាស់ផ្ទៃក្រោមនោះ ព្រះជាតិសក្តិឧកមាស១ជា១០

១៦. អង្គព្រះពហុសក្តិច្រាក់ជីជ័៣តម្លឹជ័១៧ ឱ្យពិន័យជាហ្នឹងនិជ័ រាស្ត្រជ័មានទោស

១៧. ខុសដោយជ្ងូវជ្ងន់ស្រាល ឱ្យពិន័យទ្វេកុណាត្រូវជាច្រាក់ជីជ័ ៧តម្លឹជ័១៤ ឱ្យពិន័យ

១៨. ត្រីកុណាត្រូវជាច្រាក់ជីជ័១១តម្លឹជ័១១ ឱ្យពិន័យចតុកុណាត្រូវ ជាច្រាក់ជីជ័១៤

ចំព័រជី២

១៩. តម្លឹជ័៨ ឱ្យពិន័យដល់ឧជុដ្ឋសក្តិត្រូវជាច្រាក់ជីជ័២២ ហើយ ឱ្យពិន័យដល់អាហាំការត្រូវ

២០. ជាច្រាក់ជីជ័៤៣ ឯសម្តេចព្រះវររាជបិតា និជ័សម្តេចព្រះ មហាឧបរាជជាំជ័បីព្រះអង្គ

២១. នោះមានកជ័យាមជំរី (ចជ័រុជ័) នោះឧកមាស១ជាឯជ័ ព្រះព ហុសក្តិជីជ័៣តម្លឹជ័១៧

២២. ឱ្យពិន័យដោយជ្ងូវនោះជ្ងន់ស្រាល ទ្វេកុណា ត្រីកុណា ចតុ កុណា ឧជុដ្ឋសក្តិជីជ័២២

២៣. ពុំមានអហំការឡើយ។ ឯសម្តេចព្រះអយ្យកោ និជ័សម្តេច ព្រះមាតុលា និជ័សម្តេច

២៤. ព្រះជាវ និជ័សម្តេចព្រះរាម និជ័សម្តេចព្រះអនុជ និជ័សម្តេច ព្រះរាជបុត្រ និជ័

២៥. សម្តេចព្រះរាជបុត្រី និង៍សម្តេចព្រះកកនិយោ និង៍សម្តេចព្រះកកនិយា និង៍សម្តេច

២៦. ព្រះរាជាតុ និង៍សម្តេចព្រះរាជាតាក្រៅអំពីព្រះអង្គ៌ាំង៍បីនោះព្រះជាតិសក្តិ

២៧. ១ជា៧ អង្គ៌ព្រះពហុសក្តិ៌ី៍ង៍២តម្ងឹ៍ង៍៤ ឱ្យពិន៍យដោយន្ងវ ដោសចូន់ស្រាល

២៨. ខ្វេកុណា ត្រីកុណា ចតុកុណា ត្រូវជាច្រាក់ី៍ង៍៤តម្ងឹ៍ង៍១៦ពុំ៍ង៍ឧជុង្គ៌សក្តិឡើយ។

២៩. បើអស់ព្រះអង្គ៌ាំង៍នោះ កង៍ក្នុង៍ព្រះរាជាំង៍ស្តេចទ្រង៍ំរាជ្យ និង៍ព្រះអង្គ៌ាំង៍បីក្តី កង៍ក្នុង៍

៣០. ព្រះរាជាំង៍ សម្តេចព្រះវរបិតាក្តី និង៍សម្តេចព្រះវររាជមាតាក្តីនិង៍សម្តេច

៣១. ព្រះមហាឧបរាជក្តី នោះឱ្យឈកព្រះអង្គ៌ទ្រង៍ំរាជ្យ និង៍ព្រះអង្គ៌ាំង៍បីឱ្យពិន៍យ១កុណា

៣២. ខ្វេកុណា ត្រីកុណា ចតុកុណាក្តី ឯក្រយាពិន៍យាំង៍អំចាលនេះ បើអស់ចៅក្រមយកសេច

៣៣. ក្តីឡើង៍ក្រាបទូលថា បើព្រះអង្គ៌ទ្រង៍ំរាជ្យ និង៍សម្តេចព្រះវររាជបិតា និង៍

៣៤. សម្តេចព្រះវររាជមាតា និង៍សម្តេចព្រះមហាឧបរាជតាមតែព្រះអង្គ៌ាំង៍នេះដោយន្ងវ

៣៥. ព្រះជាតិសក្តិព្រះអង្គ៌ាំង៍នោះហោង៍។ [...]

នៅក្នុងច្បាប់ទំនឹមពីបុរាណត្រង់ទំនឹម១៥បានបង្ហាញអំពីចំនួនក្រយ៉ាពិន័យក្នុងខ្សែរាជវង្សចំពោះអំពើប្រព្រឹត្តទ្រព្យហ្លួងឬទ្រព្យរាជការសាធារណៈ។

តារាងពិន័យចំពោះអំពើប្រព្រឹត្តទ្រព្យហ្លួងក្នុងព្រះឃ្លាំង

ព្រះគោរម្យងារ	ចំនួនពិន័យ
ព្រះឧបយោរាជ	គុណ ១ ជា ៩ (1x9)
សម្តេចព្រះទាវ	គុណ ១ ជា ៨ (1x8)
សម្តេចព្រះមាតុលា	គុណ ១ ជា ៨ (1x8)

សម្តេចសព្វព្រះអង្គ	គុណ ១ ជា ៧ (១x៨)

*បើប្រវ័ញ្ចទ្រព្យហ្លួងក្នុងព្រះឃ្លាំងចំនួនប៉ុន្មានៗក្តីឱ្យគិតគូរគុណតាមចំនួនដូចកំណត់ខាងលើ។

ចំណែកអ្នកផងទាំងឡាយណាដែលមានចិត្តសាហិចសាហាយព្រហើនពុំកោតខ្លាចអំណាចព្រះចេស្តាហ៊ានមើលងាយព្រះបាទអ្នកជាអម្ចាស់ព្រមទាំងព្រះញាតិវង្សនិងមន្ត្រីផង ត្រូវពិន័យដោយច្បាប់ដូច្នេះ[១៦៥] ៖

ព្រះគោរម្យងារ	**ចំនួនពិន័យ**
ព្រះបន្ទូល (ព្រះមហាក្សត្រ)	ជីង ១០
ព្រះឧបរាជ	ជីង ១០
ព្រះឧភយោរាជ	ជីង ៦ តម្លឹង ១០
ព្រះសាត្រា (បុត្រ)	ជីង ៩
ព្រះមាតុច្ឆា	ជីង ៨
ព្រះវង្សរាជរុង	ជីង ៦
ព្រះអង្គកែវ	ជីង ៦
អ្នកចៅហ្វាយសម្តេចចៅពញាជិតនិងពោធិ	ជីង ៥
មន្ត្រីចតុស្តម្ភ ១០ ហ៊ូពាន់ ក្នុង	ជីង ៥
មន្ត្រីចតុស្តម្ភ ១០ ហ៊ូពាន់ ក្រៅ	ជីង ៣ តម្លឹង ១២
មន្ត្រី ៩ ហ៊ូពាន់ ក្នុង និង ក្រៅ	ជីង ៣ តម្លឹង ១០
មន្ត្រី ៨ ហ៊ូពាន់ ក្នុង និង ក្រៅ	ជីង ១ តម្លឹង ៥
មន្ត្រី ៧ ហ៊ូពាន់ ក្នុង និង ក្រៅ	ជីង ៣ តម្លឹង ៧
មន្ត្រី ៦ ហ៊ូពាន់ ក្នុង និង ក្រៅ	ជីង ៣ តម្លឹង ៧
មន្ត្រី ៥ ហ៊ូពាន់ ក្នុង និង ក្រៅ	ជីង ៣ តម្លឹង ២
មន្ត្រី ៤ ហ៊ូពាន់	ជញ្ជីង ៣
មន្ត្រី ៣ ហ៊ូពាន់	ជញ្ជីង ? តម្លឹង ២
មន្ត្រី ២ ហ៊ូពាន់	ជញ្ជីង ២ តម្លឹង ២
មន្ត្រី ១ ហ៊ូពាន់	ជញ្ជីង ១ តម្លឹង ៤

[១៦៥] សេចក្តីស្រង់ចេញពី *ច្បាប់ក្រមស្រុកជប្រការ* សន្លឹកទី១៦, បន្ទាត់១៣៥-១៣៧ ឬសូមអាន Mikaelian ២០០៦: ៤៥៦។

* ទាំងនេះសឹងជាមន្ត្រីមានយសសក្តិ។ បើមន្ត្រីណាពុំទាន់មាននាមពិសេសឱ្យពិន័យត្រឹម **តម្លឹង៧**។

នៅក្នុង «ច្បាប់ក្រុមស្រុកព្រះជ័យជេដ្ឋា» និយាយពីចំនួនដែលត្រូវពិន័យដល់ជនទាំងឡាយដែលមិនគោរពកោតខ្លាចអាជ្ញា។ សេចក្តីនោះមានដូចតទៅ៖

៤១. [...] បើជាស់ខុសឆ្គង

៤២. ដេរវាយអាជ្ញាក្តី ដេរពោល ដំវាយកូនចៅគេក្តី ដេរវាយខ្ញុំកំដរគោ

៤៣. ក្រែបីចោះឆ្អែចាស់ដើងអង្គើរគេក្តី យល់អាជ្ញាមកហើយធ្វើសាហាវនឹងអាជ្ញា

៤៤. ពុំគោតពុំខ្ចាចអាជ្ញាបម្រើក្តី ដោះឱ្យពិន័យអង្គពហុសក្តិជាច្រាក់ជីង៤ កណ្តាលអាជ្ញាជា

៤៥. ច្រាក់តម្លឹង១៥ ជូនអាជ្ញាពុសត្រឿង ដើមអាជ្ញាដោះបញ្ចៀសបង្វែងចម្អាក់ចម្ការ ឱ្យអាជ្ញា

៤៦. ឱ្យពិន័យជាច្រាក់ជីង៦តម្លឹង៧ កណ្តាលអាជ្ញាពុះត្រឿងដើមអាជ្ញា ជូនអាជ្ញាជាច្រាក់តម្លឹង

៤៧. ១០ ចាន ៧ នេះហៅក្រមពហុសក្តិ ដល់អង្គើរហន្ទយំ។ មាត្រា ១ ជាក់អាជ្ញាពី

៤៨. លើរនេះក្តី ពីលើទូកក្តី ឱ្យពិន័យជាច្រាក់ជីង៣ ដល់ថ្ងារព្រះរាជកំង៍ត្រូវបុពាន្ធិយំ

៤៩. ដល់មុខព្រះលានត្រូវជាន្ធយំ បើជាហ្មឺនត្រូវក្រែយាពិន័យបុរាណាសក្តិដល់ថ្ងាស

៥០. ជាហ្មឺនដោះពិន័យជារាជសក្តិដល់ចៅមឿង ឱ្យពិន័យដោយពិភពសក្តិជាច្រាក់ជីង១៥

៥១. រាជសក្តិជាច្រាក់ជីង៧ តម្លឹង១០ ពិភពសក្តិជាច្រាក់ជីង១៥ ដល់ព្រះសុភាចានស្វាក

៥២. ពិចារណាឱ្យពិន័យដោយរាជសក្តិដល់ព្រះសុភាឥតស្វាក ពិចារណាឱ្យពិន័យដោយពិភព សក្តិ។

៤៣. ដល់សុការស្រុកឱ្យពិចារណាដោយយសសក្តិជាច្រាក់ដី ជ័រតម្លឹជ័ង៧ចាន៦ កណ្តាល

៤៤. អាជ្ញាពុះត្រឿង ដើមអាជ្ញា(ចុងអាជ្ញា) ពុះត្រឿង កណ្តាល អាជ្ញាជាច្រាក់៦ចាន៣ស្លឹង៦

តារាងទម្រង់សក្តិមន្ត្រី និងចំនួនពិន័យក្នុងច្បាប់ក្រមស្រុកព្រះជ័យជេដ្ឋា

ទម្រង់សក្តិ	ចំនួនពិន័យ			
	ជីង	តម្លឹង	បាទ	ស្លឹង
សក្តិ ១០ ហ៊ូពាន់ឯក	៣	៧	X	៣
សក្តិ ១០ ហ៊ូពាន់ទោ	៣	X	៣	៣
សក្តិ ១០ ហ៊ូពាន់ត្រី	១	១៨	X	៩
សក្តិ ១០ ហ៊ូពាន់ចត្វា	១	១២	X	៩
សក្តិ ៩ ហ៊ូពាន់ឯក	១	១២	X	X
សក្តិ ៩ ហ៊ូពាន់ទោ	១	១១	X	X
សក្តិ ៩ ហ៊ូពាន់ត្រី	១	១០	X	៧
សក្តិ ៩ ហ៊ូពាន់ចត្វា	១	៩	X	X
សក្តិ ៨ ហ៊ូពាន់ឯក	១	៩	X	៣
សក្តិ ៨ ហ៊ូពាន់ទោ	១	៨	X	៦
សក្តិ ៨ ហ៊ូពាន់ត្រី	១	៧	X	X
សក្តិ ៨ ហ៊ូពាន់ចត្វា	១	៦	X	X
សក្តិ ៧ ហ៊ូពាន់ឯក	១	៧	X	៣
សក្តិ ៧ ហ៊ូពាន់ទោ	១	៦	X	៩
សក្តិ ៧ ហ៊ូពាន់ត្រី	១	៦	X	៥
សក្តិ ៧ ហ៊ូពាន់ចត្វា	១	៥	X	៦
សក្តិ ៦ ហ៊ូពាន់ឯក	១	៥	៥	X
សក្តិ ៦ ហ៊ូពាន់ទោ	១	៥	X	៣
សក្តិ ៦ ហ៊ូពាន់ត្រី	១	៣	X	៩

ទម្រង់សក្តិ	ចំនួនពិន័យ			
	ជីង	តម្លឹង	បាទ	ស្លឹង
សក្តិ ៦ ហ៊ូពាន់ចត្វា	១	X	X	៩
សក្តិ ៥ ហ៊ូពាន់ឯក	១	២	X	X
សក្តិ ៥ ហ៊ូពាន់ទោ	១	២	X	៦
សក្តិ ៥ ហ៊ូពាន់ត្រី	១	១	X	៣
សក្តិ ៥ ហ៊ូពាន់ចត្វា	១	X	X	៩
សក្តិ ៤ ហ៊ូពាន់ឯក	១	X	X	X
សក្តិ ៤ ហ៊ូពាន់ទោ	X	១៩	X	៦
សក្តិ ៤ ហ៊ូពាន់ត្រី	X	១៨	X	៣
សក្តិ ៤ ហ៊ូពាន់ចត្វា	X	១៨	X	៣
សក្តិ ៣ ហ៊ូពាន់ឯក	X	១៧	X	៩
សក្តិ ៣ ហ៊ូពាន់ទោ	X	១៧	X	X
សក្តិ ៣ ហ៊ូពាន់ត្រី	X	១៦	X	៦
សក្តិ ៣ ហ៊ូពាន់ចត្វា	X	១៥	X	៣
សក្តិ ២ ហ៊ូពាន់ឯក	X	១៥	X	៦
សក្តិ ២ ហ៊ូពាន់ទោ	X	១៤	X	៧
សក្តិ ២ ហ៊ូពាន់ត្រី	X	១៤	X	X
សក្តិ ២ ហ៊ូពាន់ចត្វា	X	១៣	X	៦
សក្តិ ១ ហ៊ូពាន់ឯក	X	១៣	៣	X
សក្តិ ១ ហ៊ូពាន់ទោ	X	១២	X	៣
សក្តិ ១ ហ៊ូពាន់ត្រី	X	១១	X	៩
សក្តិ ១ ហ៊ូពាន់ចត្វា	X	១១	X	X
សក្តិ ១ ហ៊ូបាកឯក	X	៩	X	១០
សក្តិ ១ ហ៊ូបាកទោ	X	៨	X	X
សក្តិ ១ ហ៊ូបាកត្រី	X	៦	៣	X

ទម្រង់សក្តិ	ចំនួនពិន័យ			
	ជីង	តម្លឹង	បាទ	ស្លឹង
សក្តិ ១ ហ៊ូបាកចគ្វា	X	៦	X	X
សក្តិ ១ ហ៊ូសីឮឯក	X	៤	៣	X
សក្តិ ១ ហ៊ូសីឮទោ	X	៤	១	X
សក្តិ ១ ហ៊ូសីឮត្រី	X	៣	៣	X
សក្តិ ១ ហ៊ូសីឮចគ្វា	X	៣	១	X

នៅក្នុងច្បាប់ក្រមស្រុក៨ប្រការរបស់ព្រះជ័យជេដ្ឋាទី២ ចាប់ពីបន្ទាត់១៤៦ដល់ ១៥៣ និយាយអំពីការពិន័យចំពោះជនដែលប្រមាថមើលងាយហៅគោរម្យងាររគេពុំត្រូវ តាមឋានានុក្រមឋានៈយសសក្តិរបស់គេ។ សេចក្តីក្នុងច្បាប់នេះពោលថា « *១សោតនា អ្នកផងមើលងាយពុំកោតគេជា**ចៅ**ថាគេជា**អាវ**ឱ្យព្រះសូភាពិន័យតម្លឹង៣ គេជា**នាហ៊ីន**ហៅ គេថា**ចៅ**ឱ្យព្រះសូភាពិន័យតម្លឹង៥ គេជា**ព្រះ**ហៅគេ**នាហ៊ីន**ឱ្យពិន័យតម្លឹង៦ គេជា**ពញា** ហៅគេជា**ព្រះ**ឱ្យពិន័យតម្លឹង៧ គេជា**ឧកញ៉ា**ហៅគេជាចៅ**ពញា**ឱ្យពិន័យតម្លឹង៨ [គេជា] **ចៅហ្វា**ហៅគេចៅ**ពញា**ឱ្យពិន័យតម្លឹង៩ គេជា**ព្រះអង្គកែវ**ហៅគេជាចៅហ្វាឱ្យពិន័យតម្លឹង ១០ គេជា**ព្រះវង្ស**មានងាររហៅជា**ព្រះអង្គកែវ**កុំឱ្យពិន័យឡើយ។ មួយនីសោតទោះបើជា ពញាព្រះហ៊ីនអ្នកជារាជការ បើហៅពុំត្រូវនឹងព្រះច្បាប់ឡើយឱ្យពិន័យបន្តយចុះពីឧកញ៉ា មានងារនោះតម្លឹង១ហោង។* » […]

តារាងពិន័យតាមទោស

ប្រភេទទោស	ចំនួនពិន័យ		ផ្សេងៗ	ប្រភព
	កម្រិតស្រាល	កម្រិតធ្ងន់		
សាក្តី	X	X	ពិន័យតាមសេចក្តីដែលគេប្តឹង	ច្បាប់ឃុនសាឡា សន្លឹកទី១៥
មជ្ឈឹម	លក់តម្លឹង៧	លក់តម្លឹង១៥	X	ច្បាប់សង្ឃរី សន្លឹកទី៥
លហុ	លក់តម្លឹង៣ បាទ២	លក់តម្លឹង៧ បាទ២	X	ច្បាប់សង្ឃរី សន្លឹកទី៥

ប្រភេទទោស	ចំនួនពិន័យ		ផ្សេងៗ	ប្រភព
	កម្រិតស្រាល	កម្រិតធ្ងន់		
ជ្រៃរាជ	X	X	លក់ដាច់សុរិលបង់និងរឹបទ្រព្យ	ច្បាប់សង្ឃរី សន្លឹកទី៥
ជងដាំ	X	ពិន័យតម្លឹង១៥	X	ច្បាប់សង្ឃរី សន្លឹកទី៦
សល់វល់ធំ	X	X	លក់ដាច់សុរិលបង់ រឹបទ្រព្យ និងសងខ្វាត់ព្រះឃ្លាំង១ជា៥	ច្បាប់សង្ឃរី សន្លឹកទី៧
ដាវប្រមាត់	X	X	លក់ដាច់សុរិលបង់និងរឹបទ្រព្យ	ច្បាប់សង្ឃរី សន្លឹកទី១៧
ពានជុន	X	សម្លាប់បង់	ពិន័យដាច់សុរិលបង់ ឱ្យស្លៀកស្បែបណ្តើរផ្សារ៣ថ្ងៃ	-ច្បាប់សង្ឃរី សន្លឹកទី១៧ -ក្រមសុភាធិបតី សន្លឹកទី៤៤
អម្ពន	X	X	X	ក្រមសុភាធិបតី សន្លឹកទី៤៤
បារាក្រម	X	X	ពិន័យដោយនូវស្ថានទម្ងន់ទោស	ក្រមសុភាធិបតី សន្លឹកទី១១ ២១
ទម្ងន់ផ្ទៃក្រោម	X	សម្លាប់បង់	X	ក្រមស្រុកព្រះដៃជេស្ឋ បន្ទាត់ ២៤៨
របឹបហ្លួង	X	X	រឹបអស់ទ្រព្យ	ច្បាប់សង្ឃរី សន្លឹកទី៤ ៦ ៧ ១៧
តាសករ	ដំរាយធ្វើក្តី៥ ហត្ថ	X	ពិន័យចតុគុណ	ក្រមស្រុក៨ ប្រការ សន្លឹកទី១៣

ប្រភេទទោស	ចំនួនពិន័យ		ផ្សេងៗ	ប្រភព
	កម្រិតស្រាល	កម្រិតធ្ងន់		
ពាតាសករ	ធ្វើក្តី៧ហត្ថ	X	ពិន័យចតុគុណ	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
ពាន្ធិយុង	ធ្វើក្តី១១ហត្ថ ចំអាម១	សម្លាប់បង់	ពិន័យចតុគុណ	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
បូពាន្ធិយុង	X	សម្លាប់បង់	ពិន័យចតុគុណ	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
ហាន្ធិយុង	ធ្វើក្តី១២ហត្ថ	សម្លាប់បង់	X	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
ពហាន្ធិយុង	ធ្វើក្តី១១ហត្ថ	X	X	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
ឧទុម្ពរ	ធ្វើក្តី៩ហត្ថ	X	ពិន័យចតុគុណ	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
ពឧទុម្ពរ	ធ្វើក្តី១១ហត្ថ	X	X	ក្រមស្រុក៨ប្រការ សន្លឹកទី១៣
អហំការ	ជីង៣ តម្លឹង ១៧ (រាស្ត្រ)	ជីង៣ តម្លឹង ១៧ (មន្ត្រី)	X	- ច្បាប់ទំនឹមពីបុរាណ ទំនឹម ១៤ ១៨ ២០ - ច្បាប់ឃុនសាឡា សន្លឹកទី២៤

ប្រភេទទោស	ចំនួនពិន័យ		ផ្សេងៗ	ប្រភព
	កម្រិតស្រាល	កម្រិតធ្ងន់		
				- ច្បាប់ក្រមស្រុកព្រះដៃជេស្ឋ បន្ទាត់១៩

* មួយសោតនានឹងកាត់ថ្លៃអ្នកផង ហៅ ៖

- ជាច់សុរិល = តម្លឹង ៣៣។
- ផុតសុរឹល = តម្លឹង ៣៣ បាទ ៣។
- សុរិលបង់ = តម្លឹង ៣ បាទ ១[១៦៦]។

ខ. ប្រភេទទណ្ឌកម្ម

ទណ្ឌកម្មដែលយើងដឹងតាមរយៈអត្ថបទច្បាប់និងក្រមនានាឃើញថាមានច្រើនរបៀបណាស់ ហើយប្រភេទឧបករណ៍ដែលគេប្រើសម្រាប់ធ្វើទោសទណ្ឌនោះក៏មានច្រើនប្រភេទទៅទៀត។ ប៉ុន្តែយ៉ាងណាការសម្រេចដាក់ទណ្ឌកម្មលើរាងកាយអ្នកទោសនោះក៏ពុំមែនចេះតែធ្វើទៅទេ។ បើតាមសេចក្តីដែលនិយាយក្នុងច្បាប់នោះយើងអាចយល់បានថាតុលាការមានការថ្លឹងថ្លែងកម្រិតទោសកំហុសរបស់អ្នកទោសជាមុនសិន មុននឹងសម្រេចថាត្រូវដាក់ទណ្ឌកម្មប្រភេទណា។ ដ្បិតបើទោសគេតិចតួចតុលាការមិនអាចដាក់ទណ្ឌកម្មគេក្នុងកម្រិតធ្ងន់ដែរ ព្រោះទីមួយគឺខុសនឹងព្រះក្រិត្តិការច្បាប់ដែលកំណត់មក ឯទីពីរសោតនៅក្នុងរឿងបុណ្យបាប បើធ្វើទោសគេធ្ងន់ហួសប្រមាណនឹងអ្វីដែលគេប្រព្រឹត្ត គឺថាអស់ចៅក្រមទាំងនោះកំពុងនាំគ្នារកផ្លូវទៅនរកដោយសារតែការអាងអំណាចមានចិត្តកំណាចយោយៅអមនុស្សធម៌។ ទោះបីច្បាប់តាក់តែងមកពុំមែនចង់ដាក់ទោសរាស្ត្រធ្វើបាបសង្កត់សង្កិនរាស្ត្រឱ្យរាស្ត្រក្តៅក្រហាយ តែច្បាប់ក៏ពុំអាចមានមេត្តាធម៌សណ្តោសប្រោសប្រណីដល់អ្នកដែលព្រហើនកោងកាចធ្វើតាមអំពើចិត្តបានដែរ ពុំនោះសោតស្រុកទេសនឹងមានតែភាពវឹកវរឥតសណ្តាប់ មនុស្សមិនអាចស្រុះស្រួលរស់នៅជាមួយគ្នាបាន។ ដូច្នេះច្បាប់ត្រូវតែដាក់ទោសពិរុទ្ធជនទាំងឡាយឱ្យរាងចាលកុំឱ្យធ្លាប់តែខុស ប៉ុន្តែត្រូវពិនិត្យឱ្យ

[១៦៦] *ច្បាប់ក្រមស្រុក៨ប្រការ* សន្លឹកទី២២។

ពិតនឹងច្បាប់ នឹងស្ថានទម្ងន់ទោសរបស់គេ។ នៅសម័យកណ្តាលប្រភេទទណ្ឌកម្ម និងឧបករណ៍ដែលគេយកមកប្រើមានជាអាទិ៍៖

ចងឃ្នង ឬច្រកឃ្នង៖ ឃ្នងជាប្រភេទឧបរណ៍មា្យងធ្វើពីកំណាត់ឈើ ឬ ឬស្សី ពីរដែលមានកាំទទឹងដូចកាំជណ្តើរ ឃ្នងមានខ្លី មានវែង។ ឃ្នងខ្លីអាចដាក់បានមនុស្សម្នាក់ ឯឃ្នងវែងអាចដាក់បានចាប់ពី២ ទៅ ៥នាក់។ គេដាក់ក្បាលអ្នកជាប់ចោទចូលក្នុងប្រឡោះកំណាត់ឈើឬឫស្សី ហើយគេដាក់កាំបញ្ចូលដោយបោះស្នៀតយ៉ាងណែនឱ្យជាប់ក្បាលអ្នកនោះនៅចន្លោះកាំនោះឯង។ អ្នកជាប់ឃ្នងត្រូវពឹងគេពីឱ្យក្រៅជួយទើបរួច[១៦៧]។ ជាទូទៅយើងសង្កេតឃើញថាគេប្រើឃ្នងគឺនៅពេលដែលគេចាប់អ្នកទោសបណ្តើរយកទៅសាលាជំនុំក្តី។ ចំនែកពេលខ្លះគេយកឃ្នងទៅដាក់ជាទារុណកម្មឱ្យនៅជាប់៥ថ្ងៃឬ៧ថ្ងៃទើបដោះចេញ។ យើងមិនដឹងថាឃ្នងមានប្រមាណប្រភេទឡើយ តែបើតាមឃើញឈ្មោះក្នុងច្បាប់គឺមានឃ្នងពីរប្រភេទ។ ១ហៅ «ឃ្នងក្អែក» និងមួយទៀតហៅ «ឃ្នងក្អែកក្រួច»។ ឃ្នងទាំងពីរមិនដឹងថារូបរាងពិតប្រាកដនោះយ៉ាងដូចម្តេចទេ។ តែបើពិនិត្យលើឈ្មោះខ្ញុំសន្និដ្ឋានថា ឃ្នងក្អែក ទំនងហៅឃ្នងដែលធ្វើពីឈើឬឫស្សីដែលមានបោះកាំទទឹងនោះឯងដូចដែលនិយាយមកពីខាងលើ ដ្បិតអ្វីដែលខ្វែងគ្នា កាត់គងគ្នាមួយបណ្តោយមួយទទឹងយើងហៅថា «ខ្វែងជើងក្អែក»។ ចំណែកឃ្នងក្អែកក្រួច ប្រហែលសម្គាល់លើឃ្នងម្យ៉ាងទៀតដែលធ្វើពីបន្ទះក្តារមានប្រឡោះសម្រាប់បញ្ចូលក្បាលហើយបិទកៀបត្រឹមក ឯដៃទាំងសងខាងត្រូវលើកឡើងលើអមសងខាងក្បាលក្នុងប្រឡោះដូចគ្នាដែលបិទកៀបត្រឹមកដៃ។ រីដែលហៅថា «ក្អែកក្រួច» គឺទម្រង់ចតុកោណស្មើស្រួចចុងសងខាង។

ជាក់ខ្នោះ ឬបោះខ្នោះ៖ ខ្នោះជាឈ្មោះឧបករណ៍មា្យងធ្វើពីឈើ ឬដែកសម្រាប់ភ្ជាប់ជើងឬដៃ។ ខ្នោះមានខ្នោះដៃ និងខ្នោះជើង។ តែនៅសម័យបុរាណប្រហែលមានតែខ្នោះជើងទេក៏មិនដឹង។ បានជាថាដូច្នេះព្រោះបើតាមរូបថត (រូបអ្នកទោសជាប់ខ្នោះ) ដែលសល់តាំងពីសម័យអាណាព្យាបាលបារាំងមកគឺកំឡុងចុងសតវត្សទី១៩ ឬដើមទីសតវត្សទី ២០ ហើយក៏ដោយ យើងឃើញថាអ្នកទោសទាំងនោះសឹងជាប់ខ្នោះជើង ឥតបើឃើញនរណាមួយជាប់ខ្នោះដៃឡើយ។ ខ្នោះដៃទំនងមាននៅសម័យក្រោយនេះទេ។ អ្នកដែលគេចាប់យកមកបោះខ្នោះច្រើនជាអ្នកដែលបង្ករជម្លោះប្រព្រឹត្តហិង្សាវាយដំច្រំធាក់កាប់សម្លាប់

[១៦៧] សូមអាន តូច ឈួង ១៩៩៤: ៧៦។

គ្នា ឬកូនកំណាចវាយដំឪពុកម្តាយ ប្រមាថកាតទានជីដូនជីតា ម្តាយមីងឪពុកមាខ្លួនឯង អ្នកឥតសាសនាជេរវាយអ្នកព្រះសង្ឃមានសីល ឬពុំនោះសោតគឺអស់ពួកចោរប្លន់ទ្រព្យដុតផ្ទះគេ។ ពួកនេះកាលណាគេចាប់បានគេដាក់ខ្នោះកុំឱ្យរត់រួច ទើបនាំទៅសាលាធ្វើក្តី។ ឯខ្នោះនោះសោតជួនកាលគេដាក់ម្នាក់មួយដាច់ដោយឡែកពីគ្នា ឯមួយបែបទៀតបើមានអ្នកទោសច្រើនគេដាក់ខ្នោះរៀងខ្លួនហើយទើបយកខ្សែឬច្រវាក់តភ្ជាប់គ្នាពីម្នាក់ទៅម្នាក់ទៀតជាជួរ។ ខ្នោះជើងគេមិនធ្វើឱ្យជាប់គ្នាដូចរបៀបខ្នោះដៃសព្វថ្ងៃទេ គឺថាពីរង្វង់ជើងម្ខាងទៅជើងម្ខាងទៀតគេតខ្សែច្រវាក់ល្មមឱ្យអ្នកនោះអាចឈានដើរបានជំហានខ្លីៗ។

ដាក់ច្រវាក់៖ ការដាក់ច្រវាក់ក៏ជាវិធីមួយបែបទៀតដើម្បីបង្ខាំងអ្នកទោសកុំឱ្យលួចរត់ទៅណាបាន។ មានរបៀបមួយហៅថា «ខួងក»។ គេធ្វើកងដៃកដាក់កអ្នកទោសមិនឱ្យដោះបាន។ គេយកច្រវាក់មួយខ្សែល្មមភ្ជាប់កងកអ្នកទោសម្នាក់ទៅកងកអ្នកទោសម្នាក់ទៀត។ អ្នកទាំងពីរត្រូវទៅណាមកណាទាំងពីរនាក់ជាមួយគ្នា ទោះបីត្រូវទៅបន្ទោបង់ក៏ដោយ។ គេប្រើអ្នកទោសរបៀបនេះឱ្យសែងឈើ រែកទឹក ពុះអុស ជាដើម។ ជួនកាលយើងត្រូវទោសតែគ្មានគូ គេដាក់ច្រវាក់ម្ខាងឱ្យជាប់យើង តែចុងម្ខាងទៀតគេភ្ជាប់ជុំដៃកមួយមានទម្ងន់៧គីឡូក្រាម ដែលពេលទៅណាមកណាត្រូវលើកយួរជុំដៃកនោះឡើង[១៦៨]។

បំពាក់ជាលភ្នែកក្រួច៖ សព្វថ្ងៃដែលយើងហៅថា «ជាល» គឺយើងសម្តៅលើវត្ថុម្យ៉ាងដែលត្បាញដោយបន្ទោះមានក្រឡាប្រហោងទម្រង់ភ្នែកក្រួចដូចក្រឡាសំណាញ់។ ឯបន្ទោះនោះជួនកាលជាបន្ទះឫស្សី ឬជួនកាលទៀតជាសសៃដៃកលួសទំហំប៉ុនសសៃធូប។ ចំពោះពាក្យ «ជាល» នេះនិងឧបករណ៍ដែលគេហៅ អាចខុសគ្នាពីតំបន់មួយទៅតំបន់មួយ។ ចំណែកឯជាលភ្នែកក្រួចដែលជាគ្រឿងដាក់ក្តីអ្នកទោសនោះ មិនដឹងថាមានរូបរាងដូចម្តេច ហើយគេប្រើបំពាក់អ្នកទោសយ៉ាងណាឡើយ។ យើងគ្រាន់តែដឹងថាមានប្រភេទឧបករណ៍នេះគេប្រើនៅសម័យកណ្តាល។

ចងឈើរនោល៖ ជាប្រភេទទណ្ឌកម្មម្យ៉ាងនៅសម័យកណ្តាល តែដូចគ្នាដែរយើងមិនអាចដឹងបានថាឈើរនោលនោះមានរូបរាងដូចម្តេច ហើយដំណើរការដែលគេចងឈើរនោលនោះដាក់អ្នកទោសក៏មិនដឹងថាប្រព្រឹត្តទៅយ៉ាងដូចម្តេចដែរ។

ខ្ឌីងឈើអណ្តោត ឬឈើរនោយ៖ លោក អាដេម៉ាឡ្វីក្លែ ប្រៃពាក្យ «រនោយ» ជាភាសាបារាំងថា «Pieu» ដែលមានន័យសម្តៅលើ «បង្គោលឈើឬសសរ» ជាដើម

[១៦៨] សូមអាន តូច ឈួង ១៩៩៤: ៨០។

(LECLÈRE A. ១៨៩៨: ១០៧)។ ដើម្បីធ្វើទុក្ខអ្នកទោសឱ្យឈឺចាប់វេទនា គេដាំបង្គោល ឬសសរមួយដើមដែលនៅខាងចុងបង្គោលនោះគេសម្រួចឱ្យស្រួច។ គេយកបន្ទះក្តារមួយបន្ទះចោះប្រហោងកណ្តាលហើយយកទៅស៊កនៅចុងបង្គោល។ បន្ទាប់មកទើបគេឱ្យអ្នកទោសឡើងទៅលើបង្គោលអង្គុយលើក្តារនោះដោយដាក់គូទឱ្យចំសម្រួចឈើ។ ឯចុងបង្គោលច្បាស់តែនឹងមុតគូទអ្នកនោះពុំខាន។ គេឱ្យអ្នកនោះអង្គុយ១ថ្ងៃប្រហែល ១០ម៉ោង ហើយរយៈពេល២ ទៅ ៣ថ្ងៃ[១៦៩]។

ជាក់ទ្រុង៖ នៅក្នុងច្បាប់និយាយថាអ្នកទោសខ្លះត្រូវឱ្យយកទៅឃុំក្នុងទ្រុង។ ប៉ុន្តែយើងមិនដឹងថាទ្រុងជាក់ស្តែងសម័យនោះទំហំប៉ុណ្ណា ហើយអាចដាក់មនុស្សបានប៉ុន្មាននាក់ទេ។

ចងចង់ បាញ់ចង់ វាយចង់៖ «ចង់» ជាឈ្មោះឧបករណ៍ម្យ៉ាងដែលគេប្រើសម្រាប់ជាគ្រឿងដាក់ក្តីអ្នកទោសផង និងប្រើជាអាវុធផងក៏បាន។ នៅសម័យកណ្តាលគេប្រើចង់ដាក់ទណ្ឌកម្មអ្នកទោសមានបីរបៀបគឺ «ចងចង់» «បាញ់ចង់» និង «វាយចង់»។ ដូចមានឧទាហរណ៍៖

> ច្បាប់ចំនឹមពីបុរាណ (ចំនឹម២៤): [...] ខើបអកហ្វូដកុំចរសីល និដអស់កូនជារដេញតាមចៅចាប់មេសុកចដចង់វាយល្អិតល្អន់ចៅក្នុដស្រូវចៅចន្ទ។ ខើបចៅចន្ទស្រដីអង្វរយាត់កុំឱ្យចាប់ក្នុដស្រូវជ្បិតស្រូវកំពុដផ្ទៃ [...]។
>
> ច្បាប់ក្រមស្រុកព្រះនៃដេស្ដា: ១១១ [...] បើមានអាជ្ញាចេញមកបេរាតត្បាតយកបស់ (១១២) ខ្លួឡតេ ឱ្យចាប់ប្រគោះឱ្យខ្ជាប់ឱ្យអស់ជំនុំពិចារណា បើវាកាចមែនឱ្យធ្វើដោយខ្លួ (១១៣) ចោសចូដស្រាលល្មមចដចង់ ច្រកឃ្នាដ ចាញ់ ចាក់ កាប់ ដោតឱ្យវាកោតខ្លាចវាដចាលកុំឱ្យ (១១៤) មនុស្សដដែលដច្រាណាធ្វើខុក្ខាស្តែដដ។ [...]

ឯការដែលថា «ចង់» ជាប្រភេទអាវុធនោះគឺយើងមើលឧទាហរណ៍ក្នុងទំនឹម២៥ នៃច្បាប់ទំនឹមពីបុរាណ៖

---

[១៦៩] សូមអាន Mikaelian ២០០៦: ៧៣៩។

> [...] ចៅកេមពុំឱ្យខ្ញុំឯងឆ្លើយមកយកឯងបំភេសព្រះនន្ទចូមែសជាបង ឈ្មោះអាណីឱ្យចៅព្រះស្វសប្រើខ្ពក់ខ្ពាន់ចៅហោង។ ចៅកេមពុំច្រាប់ព្រះស្វសជាព្រះអាជ្ញាថាជាដំពូកបំភេសឆ្លើយ។ ឱើបព្រះស្វសយកចូលចៅ**កាន់ថង**កាន់ជារដើរតាមដល់ទ្វារព្រះរាជវាំង [...]។

ត្រង់នេះយើងឃើញថា «ថង់» រាប់ចូលក្នុងជំពូកអាវុធមានដាវ លំពែង កាំបិតជាដើម។ ចំពោះពាក្យថា «វាយថង់» លោក Mikaelian G. ពន្យល់ថាគឺជាការវាយដោយទម្ងន់និងដោយហិង្សាបំផុត ដោយវាយនឹងកែងដៃ ឬក្ពួយដៃ[១៧០]។

កៀបក្បាល៖ ការកៀបក្បាលនេះច្រើនធ្វើជាញឹកញាប់នៅពេលសួរចម្លើយពិសេសចំពោះអ្នកទោសណាដែលរឹងរូសមាន:ខ្លាំងពេកសួរពុំស្តី និយាយគំហកគំរោះទ្រគោះបោះបោកឈ្លើយពាលពុំកោតញញើតចៅក្រម។ នៅក្នុង «សាត្រាកឹងកន្ត្រែ» ដែលជាកម្រងរឿងនិទានពាក់ព័ន្ធនឹងតុលាការ មានរឿងមួយនិយាយពីស្វាលួចម្ដុដស្តេចទៅពាក់លេងហើយយកទៅលាក់ទុកបាត់។ ស្តេចសង្ស័យថាចៅនេសាទជាចោរលួចក៏បញ្ជាឱ្យគេកៀបក្បាលសួរចម្លើយ។ ចៅនោះឈឺខ្លាំងពេកក៏ឆ្លើយដាក់សេដ្ឋី។ ស្តេចឱ្យកៀបសេដ្ឋីទៀត។ ឯសេដ្ឋីសោតក៏ឆ្លើយបន្តដាក់បុរោហិត។ ទីបំផុតទើបគេដឹងថាស្វាជាអ្នកលួចម្ដុដស្តេច[១៧១]។ រឿងនេះជ្បិតតែជារឿងនិទាន តែមានចំនុចដែលអាចយល់ពីទិដ្ឋភាពសង្គម។ ជាក់ស្តែងដូចជាការសួរចម្លើយដោយការកៀបនេះជាដើម។ លោក **តូច ឈួង** បង្ហាញសេចក្តីប្រហែលគ្នានេះនៅក្នុងអត្ថបទរបស់លោកដូច្នេះថា ៖ បើអ្នកចុងចោទរឹងទទឹងខ្លាំងគ្មានវិធីសារភាព គេប្រើគំនាបម្យ៉ាងហៅ «គំនាបស្លាស្លឹង» ដែលមានរូបរាងដូចគំនាបគាបត្នោត។ គេយកស្លាស្លឹង គឺគ្រាប់ស្លាស្ងួតទាំងមូលយកមកដាក់ត្រង់សៀតផ្ដាមួយម្ខាង ហើយគេដាក់គំនាបពីលើស្លានោះ។ គេកៀបបន្តិចម្ដងៗពីតិចទៅខ្លាំង។ អ្នកស្ងួតត្រង់ដែលមិនអាចឆ្លើយសារភាពបានមុខជាត្រូវគេកៀបរហូតដល់លៀនគ្រាប់ភ្នែកឬសន្លប់មិនខានឡើយ។ តែអ្នកដែលស្គាល់អំណាចគំនាបនេះមុខជាឆ្លើយដាក់គេដាក់ឯងយកឬចខ្លួនមិនខានឡើយ[១៧២]។

វាយនឹងរំពាត់៖ អ្នកដែលត្រូវទោសវាយត្រឹមរំពាត់ (ទំនងរំពាត់ផ្តៅធម្មតា) គឺជាទោសកម្រិតស្រាលបំផុត អាចថាការពិន័យនេះគ្រាន់តែជាការប្រៀនប្រដៅប៉ុណ្ណោះ។ អ្នក

---

[១៧០] *Ibid.*, p.៧៤១។

[១៧១] *Ibid.*, p.៧៤១។

[១៧២] សូមអាន តូច ឈួង ១៩៩៤: ៧៧។

ត្រូវវាយនឹងរំពាត់មិនមានបង់ពិន័យទៀតទេ។ ឯចំនួនរំពាត់ដែលដឹងមកតិចបំផុត១០០ រំពាត់។

វាយក៉ាះ ជាការវាយម្យ៉ាងទៀតដោយប្រើរំពាត់ដៃរតែមានសភាពធ្ងន់ធ្ងរជាងធម្មតា។ ការវាយនេះគេតម្រូវឱ្យអ្នកទោសអង្គុយលើកំណល់មួយ។ គេចាប់ចងជើងចងដៃភ្ជាប់នឹងបង្គោលមួយ។ តាមធម្មតាគេច្រើនតែចងមេដៃនិងមេជើង។ បន្ទាប់មកគេចងចង្កេះដោយខ្សែវែងឬដោយច្រចាក់ភ្ជាប់ទៅនឹងបង្គោលមួយទៀតនៅខាងក្រោយ។ គេដកកំណល់អង្គុយចេញធ្វើឱ្យអ្នកទោសអណ្តែតប៉ែលប៉ោលៗ។ គេវាយអ្នកទោសយ៉ាងខ្លាំងៗ ឱ្យស្នាមរំពាត់ស្របៗគ្នាជានិច្ច។ បើកាលណាវាយឱ្យមានស្នាមរំពាត់ខ្វែងគ្នា អ្នកវាយត្រូវមានទោសយកទៅវាយម្តងវិញ។ ក្នុងការវាយនេះ បើវាយ៣០រំពាត់គេថាមួយ «យក់»។ នៅពេលវាយអ្នកទោសរើបានតែក្បាលនិងកបន្តិចៗប៉ុណ្ណោះ។ បីថ្ងៃក្រោយមកគេចាប់អ្នកទោសដដែលមកវាយម្តងទៀត គេហៅថា «វាយបកក្រមរ»[១៧៣]។

វាយព្រាត់លួស ជាទណ្ឌកម្មស្ថិតនៅក្នុងដំពូកវាយដៃរតែហាក់ដូចជាធ្ងន់ជាងគេ ព្រោះមិនមែនវាយនឹងរំពាត់ផ្តៅធម្មតាឡើយ តែវាយនឹងព្រាត់ ហើយព្រាត់នោះសោតជាព្រាត់វែញពីខ្សែលួស។ ការវាយព្រាត់លួសគេគិតជាចំនួនហៅថា «ដំណំ»[១៧៤]។ ឧទាហរណ៍វាយព្រាត់លួស១០០ដំណំ។ ទោសដែលត្រូវគេវាយព្រាត់លួសមានដូចជា: អ្នកដែលលួចលាក់ខ្ទុំហ្លួង បម្រោស មហាត ពល កម្លោះ លីវ ឃ្លាល ជាដើមមិនឱ្យគេដឹង មិនឱ្យគេកត់ចូលបញ្ជីជាដើម។ ឧទាហរណ៍មួយទៀតគឺពួកពលព្រះមហាក្សត្រឬពលរបស់ព្រះអង្គឯទៀត បើពួកពលអស់នោះចេញទៅលួចប្លន់ទ្រព្យគេ បើគេទាន់ចាប់បានឱ្យវាយពួកនោះ១០០ដំណំ[១៧៥]។

បាញ់ នៅក្នុងច្បាប់ខ្លះគ្រាន់តែនិយាយថាឱ្យយកអ្នកទោសទៅបាញ់ តែពុំបញ្ជាក់ថាបាញ់នឹងអ្វីឡើយ។ យើងដឹងថាឧបករណ៍ប្រើសម្រាប់បាញ់មានច្រើនប្រភេទដូចជា: កាំភ្លើង កាំភ្លើងបាញ់សត្វ ចំពាមកៅស៊ូ ស្នា ធ្នូ...។ ក្នុងចំណោមប្រភេទនៃទោសបាញ់មានប្រភេទមួយនោះហៅថា «បាញ់សណ្តោត» គឺជាការបាញ់ដោយគ្រាប់ព្រួញតូចៗទៅលើខ្លួនអ្នកទោស។ គ្រាប់ព្រួញតូចៗនោះឯងហៅថា «សណ្តោត»។ គេចងអ្នកទោសជាប់នឹងបង្គោលមួយដែលដាំជាប់នឹងដីហៅថា «រនោយ»។ បន្ទាប់មកគេយកប្រភេទល្អីឬកញ្ជើ

---

[១៧៣] *Ibid.*, ៧៨។

[១៧៤] សូមមើល Mikaelian ២០០៦: ៧៤១។

[១៧៥] សូមមើល *ច្បាប់ក្រមស្រុកព្រះរំដេះស្នា* បន្ទាត់២៣២, ៣៤៩។

មកគ្របក្បាលអ្នកទោស ព្រោះគេបាញ់ឱ្យត្រូវតែខ្លួនប៉ុណ្ណោះឥតបាញ់ក្បាលទេ។ អ្នកត្រូវគេបាញ់មានការឈឺចាប់ឈាមស្រោចជោគពេញខ្លួន។ ទោសបាញ់សណ្តោតកម្រិតស្រាលត្រឹម២០សណ្តោត ឯធ្ងន់ដល់១០០សណ្តោត[១៧៦]។

វាសធ្នូ៖ ទណ្ឌកម្មប្រភេទនេះឃើញមានតែឈ្មោះ ឧទាហរណ៍នៅក្នុងច្បាប់សង្ឃវិសន្លឹកទី១១ ប៉ុន្តែមិនដឹងថាដំណើរវាសធ្នូនោះយ៉ាងដូចម្តេចក៏ទេ។ ឯច្បាប់ឯទៀតក៏ពុំឃើញនិយាយដល់ជាហេតុនាំឱ្យយើងគ្មានពត៌មាន។

កាប់ក្បាល៖ ទណ្ឌកម្មកាប់ក្បាលនេះពុំមែនកាប់នឹងកាំបិត ពូថៅ ដាវ លំពែងឱ្យស្លាប់ឡើយ តែគេកាប់នឹងចម្រៀកឫស្សី។ គេដាក់ក្បាលអ្នកទោសចូលក្នុងប្រឡោះចម្រៀកឫស្សីពីរ បន្ទាប់មកប្រហែលគេយកអន្លូងឫអ្វីមួយទៅដំពីលើឱ្យមុតក្បាលចេញឈាម។ ក្បាលដែលមុតនោះនៅពេលជាវិញនឹងមានស្នាមរង្វង់ដូចរណ្តៅ។ ហេតុដូច្នេះហើយទើបចំនួនដែលគេកាប់ក្បាលនោះគេគិតជា «រណ្តៅ»។ ឧទាហរណ៍ កាប់ក្បាល១០រណ្តៅ[១៧៧]។

ដោត៖ ដោតជាទណ្ឌកម្មមួយធ្ងន់នៅក្នុងក្រុមនៃទោសប្រហារជីវិត មានន័យថាអ្នកដែលគេយកទៅប្រហារជីវិតអាចយកទៅកាប់ចោល ឬយកទៅដោត។ អ្នកទោសទាំងនោះច្រើនស្ថិតនៅក្នុងជំពូកទោសពន្ធយុង បូពន្ធយុង និង ហាន្ធិយុង។ ការដោតនោះ គឺទំនងយកលំពែង ពុំនោះសោតដើមឫស្សីសម្រួចចុងឱ្យស្រួច ហើយចាប់អ្នកនោះចងក្តួរបន្ទាប់មកយកដើមឫស្សី ឬលំពែងបុកទំលុះពីទ្វារធំឱ្យធ្លាយចេញតាមមាត់។

កាត់អវៈវៃ៖ នៅក្នុងច្បាប់និងក្រមសម័យកណ្តាលពុំមាននិយាយដល់ចំណុចនេះទេ។ តែយើងជឿថាទារុណកម្មបែបនេះច្បាស់ជាមាន។ បានជាហ៊ានអះអាងដូច្នេះដ្បិតយោងលើឧទាហរណ៍តាំងពីសម័យបុរាណមក។ នៅសម័យបុរាណដូចបាននិយាយរួចមកហើយ មានអ្នកទោសខ្លះគេយកទៅកាត់ម្រាមដៃម្រាមជើង កាត់ច្រមុះជាដើម ហើយមិនឱ្យចូលក្នុងរបងរាជធានីផង។ លុះមកដល់ស.វទី១៩ហើយក្តីពិសេសក្នុងរាជហ្លួងនរោត្តមមានការគាក់តែងក្រមមួយហៅថា «ក្រមក្បត់សឹក»។ ក្រមនេះបោះពុម្ពនៅរោងពុម្ពប្រូតិតូរ៉ាឆ្នាំ១៨៩១។ មានមាត្រាមួយនិយាយថា «*ទោះអ្នកផងកន្លងព្រះរាជអាជ្ញា ព្រះរាជបញ្ញត្តិ និងព្រះរាជកំណត់បទព្រះអយ្យការ ព្រះរាជប្រកាសប្រការម្តេចក្តី ជាចោរប្លន់ផ្ទះសម្បែង*

[១៧៦] សូមមើល Aymonier ១៩០០: ៨៨។

[១៧៧] សូមមើល Janneau ១៨៧០: ១០៨។

កំហែងយកទ្រព្យគេដោយអំណាចក្តី ធ្វើវិទ្យាគមសណ្តំបំពុលហើយយកទ្រព្យគេក្តី វាយដណ្តើមយកទ្រព្យគេក្តី លួនលបលួចយកទ្រព្យគេក្តី បញ្ឆោទមុសាវាទព្រះបាទព្រះបរមបពិត្រជាអម្ចាស់លើត្បូង អ្នកធ្វើអំពើទាំងនេះលោកឱ្យត្រូវទោសកម្មករណ៍១១ប្រការដែលបែងចែកជាមជ្ឈឹមទោស ជាលហុទោស» ។ ទោស១១ប្រការមាន៖

ប្រការ១ គឺឱ្យវាយនឹងរំពាត់ផ្តៅ។
ប្រការ១ គឺឱ្យកាត់ម្រាមដៃ។
ប្រការ១ គឺឱ្យកាត់ម្រាមជើង។
ប្រការ១ គឺឱ្យកាត់ម្រាមដៃទាំងសងខាង កាត់ម្រាមជើងទាំងសងខាង។
ប្រការ១ គឺឱ្យកាត់ម្រាមត្រចៀកទាំងសងខាង ។
ប្រការ១ គឺឱ្យកាត់ច្រមុះបង់។
ប្រការ១ គឺឱ្យកាត់ម្រាមត្រចៀកទាំងសងខាង ហើយឱ្យកាត់ច្រមុះបង់។
ប្រការ១ គឺឱ្យកាត់មាត់ វះមាត់បង់។
ប្រការ១ គឺឱ្យកាត់ក្បាលបង់។

ប្រការ១ គឺឱ្យចង៥ប្រការទុកនៅក្នុងគុក គួរឱ្យធ្វើទោសដោយប្រការឯណាក៏ឱ្យធ្វើទោសតាមព្រះរាជអាជ្ញាដែលសម្តេចព្រះមហាក្សត្រខត្តិយវង្សទ្រង់ត្រាព្រះរាជក្រិត្តការជាព្រះរាជកំណត់បទព្រះអយ្យការដោយនៃមាត្រាទុកមកនេះចុះ[១៧៨]។

ដូច្នេះយើងឃើញថាទណ្ឌកម្មប្រភេទនេះច្បាស់ជាមានមកតៗគ្នាតាំងពីសម័យបុរាណរហូតមកដល់សតវត្សទី១៩។

ទះមាត់ និងវះមាត់៖ ទោសត្រឹមទះមាត់គឺជាទោសស្រាលជាងគេ ឯធ្ងន់ជាងនោះគឺវះមាត់។ អ្នកដែលគេចាប់ទះមាត់គឺអ្នកដែលឈ្លើយពាលា ស្តោះទឹកមាត់ដាក់ជើងគេ ឬស្តោះដាក់ក្បាលគេ (សេចក្តីចែងក្នុងច្បាប់ក្រមស្រុក៨ប្រការ)។ ឯអ្នកដែលគេចាប់វះមាត់គឺអ្នកដែលក្បត់ប្រទូស្តនឹងព្រះមហាក្សត្រ។ ប្រការមួយក្នុងចំណោមប្រការទាំង២១នៃក្រមក្បត់សឹកចែងថាបើអ្នកណាមានចិត្តទ្រនង់អង់អាចពុំខ្លាចព្រះតេជៈ មានៈខ្លាំងតាំងខ្លួនជាធំធិតក្បត់ប្រទូស្តរាយនឹងអង្គមហាក្សត្រ ឱ្យចាប់អ្នកនោះមកយកពន្លាកមុតដាប់វះ

[១៧៨] សូមមើល *ក្រមក្បត់សឹក* សន្លឹកទី៩-១១ និង ហ៊ែល ចំរើន ២០០៩-២០១០: ៤០៣-៤០៤។

មាត់ដល់គុម្ពត្រចៀកទាំងសងខាង ហើយយកតម្ពក់ថ្ពក់មាត់ឱ្យហាទុកឱ្យឈាមហូរចេញពេញមាត់[១៧៩]។

វាយបណ្តើរនិងរំស្រែកអាក្រោស៖ ទណ្ឌកម្មនេះហាក់មិនធ្ងន់ធ្ងរប៉ុន្មានលើរាងកាយក៏ពិតមែន តែវាទាក់ទងនឹងរឿងអាសោចកេរ្តិ៍ ដ្បិតគេវាយហើយស្រែកអាក្រោសរំលើកទោសឱ្យអ្នកផងដឹងសុះសាយទូទាំងស្រុក ពុំនោះសោតគេវាយបណ្តើរជុំផ្សារទៀត។ ឧទាហរណ៍នៃអ្នកដែលត្រូវទោសប្រភេទនេះមានជាអាទិ ៖ ចោរលួចម្រ័ក្ស លួចកំបោរគេទាំងក្អមទាំង៣ង បើគេចាប់បានឱ្យយកម្រ័ក្សឬកំបោរមកលាបខ្លួនមុខមាត់ក្បាលប្រឡាក់ពាសពេញ ហើយទើបវាយបណ្តើរជុំស្រុកឬផ្សារបាន៧ជុំ[១៨០]។ មួយសោត បើប្រុសស្រីឯណាជាអ្នកជាហើយទៅស្មន់អន្ធករនឹងខ្ញុំគេ នោះឱ្យភ្នាក់ងារចាប់អានោះមេនោះធ្វើក្តី ឱ្យស្លៀកស្បែបណ្តើរកណ្តាលផ្សារ៣ថ្ងៃ[១៨១]។ រីបើអ្នកជានិងអ្នកជាឈ្លោះគ្នាវាយដំគ្នា បើអ្នកជាឱ្យខ្ញុំជេរម្តាយគេ លោកឱ្យពិន័យអ្នកជានោះ។ បើមិនបានប្រើទេ ខ្ញុំនោះជេរចិត្តឯង ក៏អ្នកជាជាម្ចាស់ត្រូវពិន័យដែរ។ ទោះបីអ្នកជាបង្គាប់ពុំស្តាប់ខំតែជេរគេឱ្យវាយបណ្តើរផ្សារ៣ជុំកុំប្រណីឡើយ។ ចំណែកស្រីដែលប្តីទើបស្លាប់ពុំទាន់ធ្វើបុណ្យហើយលួចទៅស្មន់អន្ធករ លោកឱ្យស្រីនោះពាក់ខោលរួចកាត់សក់ដើងកញ្ជើហើយឱ្យស្លៀកសំពត់ស្មើជង្គង់បណ្តើរអាក្រោសវាយនឹងព្រាត់ជុំផ្សារ៣ថ្ងៃ[១៨២]។

ទណ្ឌកម្មច្រើនប្រការរួមគ្នា៖ មានអ្នកទោសខ្លះតម្រូវឱ្យដាក់ទណ្ឌកម្មច្រើនប្រការរួមគ្នា។ ឧទាហរណ៍ អ្នកដែលជេរប្រមាថឪពុកម្តាយជីដូនជីតាម្តាយមីងឪពុកមាបង្កើតឯងទោះម្តាយក្មេកឪពុកក្មេកបងថ្លៃជីដូនជីតាក្មេកជាដើម លោកឱ្យចាប់អ្នកនោះមកធ្វើក្តីដាក់ទ្រុង ច្រកឃ្នាង ដាក់ខ្នោះ ឱ្យរឹបទ្រព្យថ្វាយហ្លួង ហើយឱ្យចងឈើរនោលបំពាក់ជាលក្នែកក្រួច ហើយឱ្យវាស៧ឆ្នូ ឱ្យបាញ់ឈើសណ្តោត ហើយឱ្យលក់បញ្ចុះសំពៅ[១៨៣]។ ចំណែកឧទាហរណ៍មួយទៀតគឺពួកពលព្រះបាទអ្នកជាអម្ចាស់និងអស់ព្រះអង្គផង បើវាចេញទៅជាចោរលួចប្រពន្ធគេក្តី បើវាលួចប្លន់វាយ កាប់ ចាក់ អ្នកផ្ទះនូវម្ចាស់ទ្រព្យគ្រាន់

---

[១៧៩] *Ibid.*,

[១៨០] សេចក្តីចារក្នុង *ច្បាប់ក្រមស្រុក៨ប្រការ* សន្លឹក១៩-២០។

[១៨១] សេចក្តីចារក្នុង *ច្បាប់សង្ឃរី* សន្លឹកទី១៧។

[១៨២] សេចក្តីចារក្នុង *ក្រមសារពើគុណ* សន្លឹកទី៩និងទី៣២។

[១៨៣] សូមមើល *ច្បាប់សង្ឃរី* សន្លឹកទី១១។

តែរបួសពុំដល់ស្លាប់ទេ ឱ្យចាប់វានោះមកបាញ់១០០សណ្តោត បណ្តើរក្រវែល ហើយឱ្យវាយ១០០ដំណាំ រួចកាប់ក្បាល១០០រណ្តៅនិងធ្លាក់ជាពលដដែល[១៨៤]។

២.១.៧ ការសុំអភ័យ និងការរំលោះទោស

ចំពោះកំហុសធ្ងន់ខ្លះយើងអាចសុំការអភ័យទោសពីគេបានបើគេព្រមសុខចិត្តដោយជូនជំនួនជាប្រាក់ ស្លាម្ល ឬចំណីចំណុកផ្លែឈើផ្សេងៗទៅគេ។ ក្នុងករណីខ្លះទៀត ទោះបើគេប្តឹងទៅសាលាជំនុំរួចហើយក្តី ហើយចៅក្រមជំនុំសម្រេចថាត្រូវផ្តន្ទាទោសដោយប្រការផ្សេងៗ យើងក៏នៅតែអាចយកប្រាក់ទៅបង់ឱ្យគេជួយសម្រាលទោសនោះបាន។ ប៉ុន្តែបើទោសយើងធ្ងន់ណាស់នឹងអនុគ្រោះឱ្យពុំបាន យើងក៏មិនអាចយកប្រាក់បង់រំលោះទោសនោះបានដែរ។ ឧទាហរណ៍ទាំងនេះយើងឃើញចែងនៅក្នុងច្បាប់ក្រមស្រុកព្រះជ័យជេដ្ឋា។ ឯចំនួននៃរបស់ជាជំនួនជូនគេនោះ ក៏មានកម្រិតទៅតាមបណ្តាសក្តិគេដែរ។ ជាក់ស្តែងឧបមាថាបើមានខ្ញុំណាម្នាក់កាចស្អប់ម្ចាស់ឯងហើយទៅពានរាំងហែករបងគេចូល ទោះចូលតាមទ្វារខាងលិច ខាងកើត ឯជើង ឯត្បូងក្តី ត្រូវឱ្យម្ចាស់ខ្ញុំនោះទៅស្មាលាទោសគេតាមដោយនូវបណ្តាសក្តិនៃម្ចាស់របងនោះ។

តារាងកំណត់ចំនួនជំនួនត្រូវបង់ស្មាលាទោសគេតាមបណ្តាសក្តិ

សក្តិម្ចាស់របង	**ចំនួនជំនួន**
សក្តិ ១០ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ តម្លឹង ៤
សក្តិ ៨ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ តម្លឹង ៣
សក្តិ ៦ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ តម្លឹង ៣
នាយសក្តិ ៦ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ បាទ ៦
សក្តិ ៥ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ បាទ ៥
សក្តិ ៤ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ តម្លឹង ១
សក្តិ ៣ឬ២ ហ៊ូពាន់	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ បាទ ១
សក្តិ ១ ហ៊ូបាក ឬ ១ ហ៊ូសីព	ស្លាម្ល ចំណី ផ្លែឈើ ប្រាក់ ស្លឹង ២
សក្តិ ១ ហ៊ូពាន់	ប្រាក់ បាទ ១

[១៨៤] សូមអាន *ច្បាប់ក្រមស្រុកព្រះជ័យជេដ្ឋា* បន្ទាត់៣៤៣-៣៥០។

*បន្ទាប់ពីម្ចាស់ខ្ទុំនោះទៅស្មាលាទោសគេហើយ ឱ្យចៅក្រមចាប់ខ្ទុំកំណាចនោះមកវាយព្រាត់លួសបាន៤០ដំណំ ហើយកាប់ក្បាល៥រណ្តៅទើបបើកទៅឱ្យម្ចាស់នោះហោង[១៨៥]។

ចំណែកការសុំអភ័យមួយទៀតគឺថាបើអ្នកផងទាំងពួងខុសនឹងចៅហ្វាយក្តី នឹងសម្តេចចៅពញាក្តី នឹងឧកញ៉ាជេតក្តី បើអស់ចៅក្រមផងនឹងបង្គាប់ឱ្យសូមទោសគេ នោះត្រូវបង់ជាប្រាក់ដូចនេះ៖

បណ្តាសក្តិ	**ប្រាក់ត្រូវបង់**
សម្តេចចៅពញា	ប្រាក់តម្លឹង ៣៤ អំពីនោះ ជីង ១ តម្លឹង ៤
ឧកញ៉ាជេត	ប្រាក់តម្លឹង ៣៤ អំពីនោះ ជីង ១ តម្លឹង ៤
ចៅហ្វាយ (?)	ប្រាក់តម្លឹង ៣៤ អំពីនោះ ជីង ១ តម្លឹង ៤
នាហ៊ឺនសក្តិ១០ហ៊ូពាន់និងចតតុស្តម្ភ	ប្រាក់តម្លឹង ៣០ អំពីនោះ ជីង ១ តម្លឹង ៤ និង តម្លឹង ១២
នាហ៊ឺនសក្តិ ៩ ហ៊ូពាន់	ប្រាក់ ជីង ១ តម្លឹង ៤ អំពីនោះ តម្លឹង ១២
នាហ៊ឺនសក្តិ ៨ ហ៊ូពាន់	ប្រាក់ ជីង ១ តម្លឹង ៤ អំពីនោះ តម្លឹង ៦
នាហ៊ឺនសក្តិ ៧ ហ៊ូពាន់	ប្រាក់ តម្លឹង ១២ អំពីនោះ តម្លឹង ៦
នាហ៊ឺនសក្តិ ៦ ហ៊ូពាន់	ប្រាក់ តម្លឹង ១២ អំពីនោះ តម្លឹង ៣
នាហ៊ឺនសក្តិ ៤ ២ និង១ ហ៊ូពាន់	ប្រាក់ តម្លឹង ៦ អំពីនោះ តម្លឹង ៣ បាទ ៦

(សេចក្តីចម្លងពី ច្បាប់ក្រមស្រុកព្រះជ័យជេស្ឋា បន្ទាត់ទី ៥០៥-៥១៧)។

ឯការលោះទោសវិញយើងមានពត៌មានតិចតួច ហើយទោសឬទណ្ឌកម្មដែលគេលោះនោះមានឧទាហរណ៍តែចំពោះការវាយ បាញ់ និងកាប់ក្បាលតែប៉ុណ្ណោះ។ ការលោះនោះគឺ បើវាយម្តងលោះជាប្រាក់បាទ២ បាញ់ម្តងលោះជាប្រាក់បាទ២ កាប់ក្បាលម្តងលោះជាប្រាក់តម្លឹង៤[១៨៦]។

២.១.៨. អ្នកដែលច្បាប់អនុគ្រោះ

សាមញ្ញជនទាំងឡាយបើធ្វើខុសរមែងត្រូវទោសតាមច្បាប់ពុំលែងឡើយ។ ប៉ុន្តែមានបុគ្គលខ្លះរាប់ថាជាករណីពិសេសដែលច្បាប់តែងអនុគ្រោះឱ្យ។ ជាក់ស្តែងគឺព្រះ

[១៨៥] សូមអាន *ច្បាប់ក្រមស្រុកព្រះជ័យជេស្ឋា* បន្ទាត់៤១១-៤២២។
[១៨៦] សូមអាន *ច្បាប់ក្រមស្រុកព្រះជ័យជេស្ឋា* បន្ទាត់៣៥៨-៣៥៩។

សង្ឃ។ នេះពុំមែនមានន័យថាព្រះសង្ឃអាចរួចខ្លួនបានគ្រប់រឿងនោះទេ។ បើព្រះសង្ឃខុសណាស់ ប្រព្រឹត្តអំពើជាទោសនាំឱ្យដាច់អបត្តិពិសេសអំពើជាបរាជិកជំពូក[១៨៧] ព្រះសង្ឃនោះច្បាស់ត្រូវភ្នាក់ងារសង្ឃរឹចាប់ផ្សឹកហើយដាក់ទោសតាមកំហុស។ ប៉ុន្តែយើងសម្គាល់ឃើញថាក្រៅពីអំពើជាបរាជិក៤ប្រការ បើព្រះសង្ឃខុសក្នុងផ្លូវលោកធម្មតា ច្បាប់តែងលើកលែងដល់ព្រះសង្ឃនោះ នឹងលក់ព្រះសង្ឃនោះឱ្យពេញថ្លៃដូចអ្នកផង ដាក់ព្រះសង្ឃក្នុងទោសអហំការក្តីពុំបានឡើយ ដ្បិតអ្នកព្រះសង្ឃជាអ្នកប្រតិបត្តិធម៌តម្កល់តម្កើងព្រះសាសនាព្រះស្រីរត្នឱ្យរុងរឿង។ ម្យ៉ាងព្រះសាសនាព្រះស្រីរត្នេនោះកាត់ថ្លៃស្មើហ្លួងមានតេជៈស្មើស្តេចផែនដីនឹងប្រមាថពុំបាន។ បើអ្នកឯណាប្រមាថព្រះសង្ឃទុកស្មើប្រមាថព្រះសាសនាព្រះតថាគតនាំអន្តរាយដល់ផ្ទៃក្រោម។

ក្រៅអំពីព្រះសង្ឃ មនុស្សមួយជំពូកទៀតក៏ច្បាប់តែងអនុគ្រោះឱ្យដែរ។ អ្នកទាំងនោះគឺអ្នកដែលស្ថិតនៅក្នុងជំពូកនៃពលព្រះ កំឡោះព្រះ ញោមព្រះ បំរោសព្រះជាដើម។ អ្នកទាំងនេះបានការលើកលែងទោសព្រោះខ្លួនបានភ្ជាប់និស្ស័យទៅនឹងព្រះសាសនា។ ទោះបីបើខុសគេចោមចាប់បាន បើគេដឹងក៏គង់គេលែងទៅវិញ។ បើអ្នកនោះជាចោរ ជាអាប ជាធ្មប់ ជាខ្មាំងម្តេចក្តី លោកមិនឱ្យសម្លាប់ ឱ្យលែងទៅវិញ ឬពុំនោះសោតឱ្យបំបរបង់ទៅនៅស្រុកនិគមជនបទឆ្ងាយ ហើយគេមិនអាចប្រើអ្នកនោះឱ្យឃ្វាលគោក្របីឬកិច្ចការសារពើក្រៅអំពីការដែលចម្រើនដល់ព្រះសាសនាដូចជាថែទាំវត្ត ធ្វើការសង់ព្រះវិហារ រក្សាព្រះចេតិយ ព្រះស្រីមហាពោធិជាដើម។ ទោះបើមានអ្នកឯណាមកយកបំរោសព្រះពលព្រះ កំឡោះព្រះ ញោមព្រះ ទៅប្រើក្នុងប្រយោជន៍ខ្លួនពុំបានឡើយ។ កាលដែលមានទោសហើយគេលែងឱ្យទៅលំនៅដើមវិញដោយហេតុគេយល់ថាគេបានធ្វើអំពើចម្រើនដល់សាសនានាំអាត្មាទៅសួគ៌ា។ ទោះបីមានទោសត្រូវពិន័យខ្លះ ក៏ប្រាក់ពិន័យនោះយកដាក់ជាទ្រព្យសាសនា មិនអាចយកជាទ្រព្យហ្លួងបានឡើយនាំឱ្យអន្តរាយ។ ហើយម្យ៉ាងបើអ្នកទាំងនោះមានកូនមានចៅក្តី កូនចៅទាំងនោះសឹងជាទ្រព្យព្រះ ជាអ្នករក្សាការព្រះ

---

[១៨៧] បរាជិក៤ជំពូករបស់ព្រះសង្ឃគឺ ៖

១. ការសេពមេធន: បើភិក្ខុសេពមេធនធម៌តាមទ្វារទាំង៣គឺទ្វារមាត់ ទ្វារនោម ទ្វារជុះ ជាមួយស្រីតូចធំ មានជីវិតក្តី ទោះស្លាប់ក្តី ប្រុសក្តី សត្វតិរច្ឆានក្តី ទោះសត្វស្លាប់ក្តី សូម្បីប្រមាថប៉ុនសំជីលូក៏ដាច់សីលហៅបរាជិក។

២. ការលួចទ្រព្យគេ: ភិក្ខុលួចបំបាត់ទ្រព្យគេ ទោះលួចខ្លួនឯងក្តី ប្រើគេក្តី ទោះប្រាក់ត្រឹម១បាទក្តី ច្រើនលើសនោះក្តី ភិក្ខុនោះដាច់សីលហៅបរាជិក។

៣. ការសម្លាប់ជីវិត: ទោះសម្លាប់មនុស្សមានជីវិត ទោះសម្លាប់សត្វក្តី ទោះប្រើគេឲ្យសម្លាប់ក្តី ទោះធ្វើថ្នាំពិសបំបាត់ខ្សែឲ្យស្លាប់កូនក្នុងពោះក្តី ភិក្ខុនោះដាច់សីលហៅបរាជិក។

៤. ការអួតអាង: បើភិក្ខុអួតមគ្គអួតផង ខ្លួនមិនបាន មិនដល់ថាខ្លួនបានដល់ក្តី ភិក្ខុនោះដាច់សីលជ្បិតកុហកហៅបរាជិក។

សាសនាតទៅឥតបើហ្លួងក្តី រាជវង្សក្តី អស់មុខមន្ត្រីសេនាបតីឯណាយកពួកគេចេញពីសាសនាព្រះស្រីរតន៍បានឡើយ។ បើអ្នកឯណាអាងអំណាចមកស្រដីយកអ្នកនោះធ្វើជាខ្ញុំក្តី ឬហេតុផ្សេងៗម្តេចក្តី អ្នកនោះនឹងបានទៅសោយទុក្ខនៅនរកពុំលែងឡើយ។

ដូច្នេះសារុបមកយើងឃើញថា អ្នកដែលច្បាប់ច្រើនអនុគ្រោះឱ្យគឺជាអ្នកដែលបានផ្សារភ្ជាប់ខ្លួនទៅនឹងសាសនា ហើយព្រះសាសនានោះទៀតគេលើកតម្កល់តម្កើងខ្ពស់ហួសប្រមាណមិនអាចនឹងមានអ្នកឯណាបំពារបំពានបានឡើយ។ ប្រមាថព្រះសាសនាស្មើប្រមាថស្តេចផែនដី ព្រោះសាសនាកាត់សក្តិស្មើហ្លួង។

២.២. ការដោះស្រាយវិវាទតាមបែបជំនឿ

នៅក្នុងសង្គមនីមួយៗតែងតែមានច្បាប់រៀងៗខ្លួន។ ច្បាប់នេះគាក់តែងមកគឺដើម្បីឱ្យមនុស្សក្នុងសង្គមនោះគោរពតាម មានន័យថាមនុស្សទាំងអស់ត្រូវស្ថិតនៅក្រោមអំណាចច្បាប់តែមួយ។ កាលណាមានបញ្ហាជម្លោះក្តីក្តាំនឹងគ្នា មានការគាបសង្កត់សង្កិនរំលោភបំពារបំពានលើគ្នា ឬការចោទប្រកាន់គ្នាទៅវិញទៅមកក្នុងរឿងអ្វីមួយ គេតែងរត់ទៅរកច្បាប់ឱ្យជួយដោះស្រាយ។ ប៉ុន្តែតើគេអាចជឿទុកចិត្តបានទេថា ច្បាប់នឹងផ្តល់យុត្តិធម៌ដល់មនុស្សគ្រប់គ្នាបានឥតខ្ចោះ ឥតមានលម្អៀង? ចុះប្រសិនបើគេមិនទុកចិត្តការសម្រេចរបស់ភ្នាក់ងារតុលាការ តើគេនឹងទៅរកផ្លូវណាបន្ត? ចម្លើយគឺមិនអ្វីក្រៅតែពីការរត់ទៅរកខាងផ្លូវជំនឿឡើយ (និយាយនេះក្នុងបរិបទសង្គមខ្មែរនិងសង្គមមួយចំនួនដទៃទៀត) ព្រោះគេជឿជាក់ថាមានកម្លាំងពិសេសនៃធម្មជាតិ ព្រលឹងវិញ្ញាណបុព្វបុរសបារមីសក្តិសិទ្ធិទាំងឡាយដទៃទៀតអាចជួយផ្តល់យុត្តិធម៌ ឬផ្តល់ការវិនិច្ឆ័យយ៉ាងពិតប្រាកដដល់គេបាន។ ការណ៍នេះមើលទៅហាក់ដូចជាផ្ទុយគ្នាស្រឡះ ព្រោះម្យ៉ាងជាជំនឿ ឯម្យ៉ាងទៀតជាច្បាប់។ ប៉ុន្តែពុំដូច្នោះទេ ដ្បិតបើពិនិត្យមើលឱ្យច្បាស់ទៅជំនឿរមែងផ្សារភ្ជាប់ជាមួយនិងច្បាប់ រហូតពេលខ្លះជំនឿជ្រាតចូលទៅក្នុងច្បាប់ ហើយក្លាយទៅជាទម្លាប់ ហើយទម្លាប់នោះយូរទៅក្លាយជារឿងដែលច្បាប់ទទួលស្គាល់ថែមទៀត។ មានន័យថាសូម្បីតែពេលខ្លះតុលាការក៏យកកិច្ចពិធីក្នុងជំនឿមកអនុវត្តក្នុងពេលជំនុំជម្រះក្តីដែរ។ បើនិយាយពីសង្គមខ្មែរជំនឿនិងការអនុវត្តដូចសេចក្តីរៀបរាប់នេះ មានយូរណាស់មកហើយ។ គេបានឃើញកស្តុតាងជាលាយល័ក្ខណ៍អក្សរច្បាស់គឺនៅសតវត្សទី៦តាមកំណត់ហេតុរបស់ជនជាតិចិន ដែលមកបំពេញបេសកម្មនៅស្រុកហ្វូណន ហើយដែលអ្នកស្រាវជ្រាវយល់ថាហ្វូណនជាអាណាចក្រដំបូងនៃបុព្វបុរសខ្មែរ។ របាយការណ៍សំខាន់ៗដែលនិយាយពាក់ព័ន្ធនិងរឿងនេះ មានរបាយការណ៍ Siao Tsen Hien របាយការណ៍

របស់ Tai Ping របាយការណ៍ Leang Chou និងរបាយការណ៍ពិសេសមួយទៀតគឺរបស់អ្នកការទូត **ជីវតាក្វាន់** នាសតវត្សទី១៣។ របាយការណ៍ទាំងនេះសុទ្ធតែបញ្ជាក់ពីភាពអស្ចារ្យនៃការពិសោធន៍រកខុសត្រូវនៅពេលមានវិវាទក្តីក្តាំរបស់អ្នកស្រុកហ្វូណន និងចេនឡា។ ចំណែកប្រភពជាសិលាចារឹក រហូតដល់សតវត្សទី១០ ទើបយើងឃើញមានភស្តុតាងខ្លះៗ និយាយពាក់ព័ន្ធរឿងនេះ។

២.២.១. ការស្បថនិងប្រភេទសម្បថ

នៅសម័យកណ្តាលការស្បថស្បែរមានច្រើនបែបយ៉ាងហើយដែលសម្បថទាំងនោះគេយកមកធ្វើជាមធ្យោបាយមួយក្នុងដំណើរការជំនុំជម្រះក្តីរកខុសត្រូវឱ្យគូវិវាទ។ ប៉ុន្តែក្នុងចំណោមប្រភេទសម្បថទាំងនោះ មានសម្បថខ្លះយើងស្គាល់បានត្រឹមតែឈ្មោះប៉ុណ្ណោះ ឯដំណើរកិច្ចពិធីប្រព្រឹត្តទៅដូចម្តេចយើងនៅខ្វះព័ត៌មាននៅឡើយ។ ដូច្នេះយើងត្រូវបន្តកិច្ចការស្រាវជ្រាវទៅទៀតដើម្បីឱ្យបានយល់រំពឹងឆ្ងាយ។ ការស្បថនិងប្រភេទនៃសម្បថនៅសម័យកណ្តាលមានជាឧទាហរណ៍ដូចជា៖

ស្បថប្រណិធាន៖ គឺនៅពេលគេស្បថគេត្រូវសូត្រតាមក្បួនសត្រាមួយដែលគេតែងហើយស្រែចហៅថា «សាស្ត្រាប្រណិធាន»។ ខ្លឹមសារនៅក្នុងសាស្ត្រាប្រណិធាននោះគេសូត្រហៅអស់ពពួកទេព្តាអារក្សអ្នកតាបង់បត់ខ្មោចព្រាយធំតូចពីគ្រប់ទិសទីមកធ្វើជាអធិបតី និង ជាសាក្សីដឹងឮផង ហើយគេជាក់ទំនាយផ្តាសាដល់ជនដែលប្រព្រឹត្តខុសនោះច្រើនប្រការ គួរឱ្យភ័យរន្ធត់ល្មមតែអ្នកដែលដឹងខ្លួនថាខុសតក់ស្លុតក្តមាហើយអាចនឹងសារភាពពាក់កណ្តាលទីផង ក៏សឹងបាន[១៨៨]។

ស្បថលាងខ្លួន៖ សម្បថនេះគេធ្វើនៅពេលមាននរណាម្នាក់បាត់របស់ហើយរកមុខអ្នកលួចពិតប្រាកដនោះពុំឃើញឡើយ គ្រាន់តែមានការសង្ស័យលើជនម្នាក់ទៀត។ គេពុំប្តឹងភ្នាក់ងារឱ្យចាប់ជំនុំអ្វីឡើយ ហើយក៏ពុំបានទាមទារឱ្យសងរបស់មកវិញដែរ។ ប៉ុន្តែអ្នកដែលគេសង្ស័យនោះមានចិត្តរអៀសខ្លួនឯង ចង់បង្ហាញថាខ្លួនត្រង់ពិតឥតបើជាចោរលួច

---

[១៨៨] សូមអាន ៖

- *សាស្ត្រាប្រាំធ្នាន (ប្រណិធាន) សាកៅ* (ច្បាប់ដើម), កូដ B.៣៩.៤, SA។
- *សាស្ត្រាប្រណិធានស្បថ* (ច្បាប់ដើម),, កូដ B.៣៩.៤, SA។
- ព្រាប ចាន់ម៉ារ៉ា, *សាស្ត្រាប្រណិធាន*, កម្រងអត្ថបទក្នុងបណ្តាញព័ត៌មានវប្បធម៌ខ្មែរ, ២០១២, www.khmerenaissance.info (ជំពូក៦ លេខរៀងទី៣៤)។

ទ្រព្យរបស់គេនោះឡើយ ហើយដើម្បីកុំឱ្យម្ចាស់នោះមានសៅហ្មងឆ្គងចិត្តគិតផ្តាសលើខ្លួន និងដើម្បីបង្ហាញថាខ្លួនបរិសុទ្ធក៏ស៊ូសុខចិត្តទៅស្បថឱ្យម្ចាស់ទ្រព្យនោះអស់ចិត្ត។

ស្បថតំណាំង៖ «តំណាំង» គឺការតាំងដោយមានអ្វីមួយជាតំណាង ជាកស្តុតាង ឬ ជាជំនួស។ នៅក្នុងច្បាប់សម័យកណ្តាល ប្រភេទសម្បថនេះមានតែឈ្មោះតែគ្មានសេចក្តីបរិយាយឱ្យយើងដឹងពីកិច្ចពិធីឡើយ។ ប៉ុន្តែបើតាមលោក Grégory .M ពន្យល់ថា ស្បថតំណាំងគឺជាប្រភេទស្បថជំនួស។ ការស្បថនេះគេយកចម្លើយសាក្សីជាសំខាន់ ហើយដែលគេរើសមកពីខាងក្រុមចុងចោទឬជនសង្ស័យ។ អ្នកដែលត្រូវស្បថគឺជាអ្នកតំណាងក្រុម។ លទ្ធផលយ៉ាងដូចម្តេចគឺអាស្រ័យលើសាក្សីដែលជាអ្នកស្បថនោះឯង[១៨៩]។

ស្បថបង្ខូត៖ ជាប្រភេទសម្បថមួយទៀតដែលគេធ្វើសម័យកណ្តាល ប៉ុន្តែយើញមានតែឈ្មោះហៅ ឯដំណើរធ្វើដូចម្តេចនោះ ពុំឃើញមាននិយាយឡើយ។

ស្បថបង្កៀរ៖ យើងគ្រាន់តែដឹងខ្លះៗថាគេធ្វើពិធីស្បថបង្កៀតនៅព្រះវិហារ នៅខ្ទមអ្នកតា ណាមួយ ឬធ្វើនៅផ្ទះចៅក្រមក៏បាន។ ឯថ្ងៃខែឬពេលវេលាស្បថគឺចៅក្រមនោះឯងជាអ្នកកំណត់។ ក្រោយស្បថគេចាំឃ្លាំមើលអ្នកក្តីទាំងសងខាង។ បើវេលារំលងទៅឥតមានកើតហេតុភេទអ្វីទេ ទុកថាអ្នកនោះគ្មានទោសគ្មានកំហុស។ ផ្ទុយទៅវិញបើមានជម្ងឺដំកាត់ឬមានហេតុភេទអ្វីៗកើតឡើងក្តីក្នុងអំឡុងពេលដែលចៅកក្រមកំណត់នោះអាចកាត់ថាជាចាញ់ជាឈ្នះបាន។

ស្បថផឹកទឹកធម្មារម្យ៖ ទឹកធម្មារម្យជាទឹកសម្បថម៉្យាងដែលគេធ្វើដោយមានកិច្ចប្រសិទ្ធិបញ្ចុះអាគមផ្សេងៗ សម្រាប់ទុកឱ្យគូក្តីអ្នកមានទំនាស់ផឹក។ ការស្បថផឹកទឹកធម្មារម្យគេធ្វើនៅពេលដែលទាល់ច្រករកចាញ់ឈ្នះពុំឃើញ ដ្បិតគេបានពិសោធន៍គូក្តីហើយដោយប្រការផ្សេងៗ ឧទាហរណ៍ឱ្យដេកក្នុងសីមាជាដើម (រឿងនេះនឹងនិយាយនៅចំណុច គ.៣) ប៉ុន្តែគូក្តីទាំងសងខាងសុខជាធម្មតាពុំឃើញមានកើតហេតុភេទអ្វីជាសម្គាល់ល្មមឱ្យចៅក្រមជំនុំយល់អ្នកណាខុសអ្នកណាត្រូវបានឡើយ។

២.២.២. ការចាប់ឆ្នោត

ក្រៅពីស្បថគេមានវិធីមួយទៀតដើម្បីផ្សងរកអ្នកដែលប្រព្រឹត្តខុស នោះគឺតាមរយៈការចាប់ឆ្នោត។ ឆ្នោតដែលគេធ្វើពិធីផ្សងចាប់នៅពេលនោះមិនដឹងថាជាសន្លឹកឆ្នោតឬ

[១៨៩] សូមអាន MIKAELIAN, G., *op. cit.*, ២០០៦, ទំព័រ ៧៣៥។

ជាអ្វីប្រាកដឡើយ។ ប៉ុន្តែលោក Goégory M. ថាជាសន្លឹកឆ្នោតដែលមានសរសេរឈ្មោះអ្នកក្តីទាំងសងខាង[១៩០]។ នៅពេលគេចាប់ឆ្នោតនោះហាក់ដូចជាស្ថិតនៅលើព្រេងសំណាងដូច្នោះ ព្រោះបើគេចាប់ចំឈ្មោះណា ឈ្មោះនោះគេទុកថាជាអ្នកចាញ់។ ការប្រកាន់ចាប់ឆ្នោតធ្វើឡើងដោយមានកិច្ចពិធីត្រឹមត្រូវ មានការចូលរួមពីភ្នាក់ងារចៅក្រម មានសាក្សីមានអ្នកកណ្តាលជាដើម។ ក្នុងកំឡុងពេលធ្វើកិច្ចចាប់ឆ្នោត គេត្រូវប្រយ័ត្នប្រយែងឃ្លាំងមើលកិរិយារបស់អ្នកក្តី បើឃើញខុសប្រក្រតីដូចជាធ្វើឱ្យរលំទៀនឬរលំដមជាដើម គេទុកថាអ្នកនោះចាញ់គេពិត[១៩១]។ មួយទៀតអំពើដែលគេអាចសម្គាល់ថាអ្នកក្តីណាមួយមានពុត ដូចជាអង្គុយចុះហើយក្រោកឈរវិញ ឬអង្គុយយកមេជើងច្រត់កន្ទេល កេះក្រចក ប្រែគូទជាដើម។ បើមានអ្នកធ្វើអំពើដូច្នេះគេពុំឱ្យចាប់ឆ្នោតឡើយ ឱ្យកាត់ជាឈ្នះជាចាញ់ពេលនោះតែម្តង[១៩២]។

២.២.៣. ការពិសោធន៍ដោយប្រការផ្សេងទៀត

ដេកក្នុងសីមា៖ ដំណើរកិច្ចនោះគឺថាគេរើសរកពេលាឱ្យគូក្តីទាំងសងខាងដេកក្នុងសីមា នៅថ្ងៃ៤ឬថ្ងៃ៧ (កើត ឬ រោច?)។ ពេលនោះគេចាំបាច់ត្រូវរកអ្នកកណ្តាលណាម្នាក់ដែលស្លូតត្រង់បរិសុទ្ធមកជាដំណាង។ គេត្រូវរៀបចំគ្រឿងរណ្តាប់ផ្សេងៗ។ បន្ទាប់មកទើបហៅគូក្តីសងខាងមកឱ្យទូលផ្សងប្រណិធានបាន៣ដង។ ចប់ទៅទើបអ្នកកណ្តាលសូត្រប្រណិធានពីដើមដល់ចប់និងចាប់ពាត់សីមា។ គេត្រូវឱ្យគូក្តីស្លៀកសំពត់សនិងស្លៀកថានបំពង់ស រួចអ្នកកណ្តាលគោងពិនិត្យមើលបើគូក្តីខាងណាមានលាក់កណ្តាញ់ស្វាហោម ប្រទាលគាថា ខ្សែបាស ខ្នាច់ក្រវាត់ចង្កេះ សៀតធ្មេញ សៀតសក់ នោះទុកជាចាញ់គេ។ បើគ្មានឃើញអ្វីទេទើបគេឱ្យអ្នកក្តីនោះដេកក្នុងសីមាហ៊ុមម្នាក់ឯង។ បើដេកស្ងៀមដល់ព្រឹក៣ថ្ងៃ ៤ថ្ងៃ ឬ៧ថ្ងៃ កាត់ថាឈ្នះក្តីនោះបាន។ តែបើដេកពុំលក់ ក្រហល់ក្រហាយអន្ទះអន្ទែងកើតខ្លាចមមើមមាយដេកពុំបានកើតរោគរមាស់ដំបៅ

---

[១៩០] MIKAELIAN, G., *op. cit.,* ២០០៦, ទំព័រ ៧៣៥។

[១៩១] សូមមើល ៖

- *ក្រមព្រហ*, បន្ទាត់៦៣១ដល់៦៥៩ (ច្បាប់ដើម), ប្រអប់សម្គាល់ ៤៥៤, បណ្ណាសារជាតិក្រុងភ្នំពេញ។
- *ច្បាប់ទំនឹមពីបុរាណ,* ទំនឹម៣៤, *op. cit.,*។

[១៩២] *ក្រមសារពើគុណ* សន្លឹកទី៣១ (ច្បាប់ដើម), ប្រអប់សម្គាល់ B.៤៥៣, បណ្ណាសារជាតិក្រុងភ្នំពេញ។

អ្វីក្តី ឱ្យអ្នកកណ្តាលកត់ពាក្យទុកជាចាញ់គេ ហើយឱ្យចៅក្រមកាត់ក្រយាពិន័យតាមដោយនូវធ្ងន់ស្រាលតាមច្បាប់នោះបាន[១៩៣]។

បោះក្នុងទឹក: ចំពោះការពិសោធន៍ដោយចាប់មនុស្សបោះចូលទឹកគឺគេធ្វើចំពោះតែអ្នកដែលគេសង្ស័យថាជាអាបប៉ុណ្ណោះ ព្រោះគេជឿថាអាបមានខ្លួនស្រាលបើកាលណាបោះទៅអណ្តែតគេយល់ថាជាអាបពិត។ នៅពេលគេសង្ស័យជនណាម្នាក់ថាជាអាប គេត្រូវរកមេមត់បញ្ជូលរូបឱ្យទាយមើល បើមេមត់នោះទាយចំឈ្មោះបុគ្គលនោះហើយ ទើបគេចាប់មនុស្សនោះបោះក្នុងទឹកពិសោធន៍ចំនួន៣ដង។ បើលិចម្តងអណ្តែត២ដង ឬបើលិច២ដងអណ្តែតម្តងក្តីត្រូវឱ្យគិតបង់ក្រយាពិន័យតាមដោយលិចអណ្តែតប៉ុន្មានៗដងនោះឯង។ ឧទាហរណ៍គឺបើអណ្តែត២ដងលិចម្តងឱ្យបែងក្រយាពិន័យជា៣ភាគ។ បើលិច២ដងអណ្តែតម្តងឱ្យបែងជាភាគ៣ ភាគ១បានទៅអណ្តែត ភាគ២បានទៅលិច។ តែបើអណ្តែត៣ដងឱ្យពិន័យដាច់សុរិលបង់។ ជាទូទៅបើរកឃើញថានរណាម្នាក់ជាអាបឬជាធ្មប់គេច្រើនតែសម្លាប់បង់ចោលតែម្តង[១៩៤]។ បើពុំដូច្នោះទេគេដាក់ទោសរបឹបរឹបយកអស់ទាំងអម្បាលទ្រព្យសម្បត្តិមានមាសប្រាក់គោក្របីស្រែចម្ការខ្ញុំប្រុសស្រីទាំងឡាយផងទុកជាទ្រព្យហ្លួង[១៩៥]។ មានម៉្យាងទៀតគឺគេឱ្យព្រះសូកាចាប់ធ្វើក្តីពីរថ្ងៃហើយទើបនាំចេញទៅស្រែកអារក្រោសបាន៣ថ្ងៃរួចឱ្យកាប់សម្លាប់ចោលមិនឱ្យប្រណីឡើយ[១៩៦]។

២.២.៤. ប្រតេចសម្បថដែលនៅតជល់សព្វថ្ងៃ

តាមពិតទៅគោលបំណងនៃការសិក្សាប្រធានបទនេះគឺផ្តោតទៅលើសម័យបុរាណ (អតីតកាល)។ ប៉ុន្តែខ្ញុំយល់ថាមិនគួរបើរំលងមិនមើលមកសម័យបច្ចុប្បន្នសោះក៏មិនកើត ដ្បិតសព្វថ្ងៃយើងក៏ពុំមែនជាច់ចេញពីបុរាណសុទ្ធដែរ។ បើលើកតែរឿងសម្បថមកនិយាយ ឃើញថាពីដើមគេជឿខ្លាំងណាស់ លុះមកដល់ឥឡូវក៏គេនៅតែជឿដដែល។ មានន័យថាជំនឿប្រភេទនេះតគ្នាមកឥតដាច់។ ដូច្នេះហើយខ្ញុំយល់ថាការពិចារណាពីបច្ចុប្បន្នក៏ជាផ្នែកមួយនាំឱ្យយើងយល់ដល់បុរាណវិញខ្លះដែរ។ នៅទីនេះយើងលើកតែរឿងសម្បថមួយប្រភេទគត់មកនិយាយនោះគឺសម្បថក្នុងក្រមខ័ណ្ឌនៃខ្លឹមសារយុត្តិធម៌។

---

[១៩៣] *ច្បាប់ក្រមសុកាធិបតី* (ច្បាប់ដើម), កូដ ០២៨៣, EFEO, Paris។

[១៩៤] *Ibid.,* សន្លឹកទី៣៤, ៣៥, ៤០។

[១៩៥] *ច្បាប់ទំនឹមពីបុរាណ,*ទំនឹម១៥, *op. cit.,*។

[១៩៦] *ច្បាប់ក្រមស្រុក៨ប្រការ,* សន្លឹកទី១១, *op. cit.,* ។

ឯសម្បថប្រការផ្សេងពីនេះយើងឥតបើលើកយកមកបរិយាយទេ។ កិច្ចស្បថ និង ប្រភេទសម្បថដែលគេនៅធ្វើដល់សព្វថ្ងៃមានដូចជា៖

ស្បថផឹកទឹកព្រះ៖ «ទឹកព្រះ» ជាទឹកមួយផ្ទិលដែលព្រះង្ឃបានប្រសិទ្ធិបញ្ចុះអាគម ហើយយកទៅដាក់ផ្សងនៅមុខព្រះពុទ្ធរូប។ នៅពេលស្បថគេឱ្យអ្នកក្តីទាំងសងខាងផឹកទឹកព្រះនោះ។ នៅពេលគូក្តីផឹកទឹកសម្បថនោះហើយ អាចារ្យសួរទៅក្តីទាំងសងអំពីរសជាតិទឹកនោះ។ បើម្នាក់ឆ្លើយថាទឹកនោះសាបធម្មតា ឯម្នាក់ទៀតផឹកហើយឆ្លើយថាទឹកនោះប្រៃ អ្នកដែលថាទឹកនោះប្រៃជាអ្នកចាញ់ក្តីគេ ដ្បិតខ្លួនមានពុតពិតទើបធ្វើឱ្យទឹកប្តូររសពីសាបទៅប្រៃ។ គេជឿថាឪពុកម្តាយកើតក្តីឈានដល់ស្បថឯអ្នករងគ្រោះគឺកូនជាន់ក្រោយដែលកើតមកហើយមិនគ្រប់លក្ខណៈហៅថា «សម្បថស៊ី»[១៩៧]។

ស្បថអារកមាន់ ឬ មូលកមាន់៖ សម្បថនេះគេច្រើនតែធ្វើនៅនឹងខ្នមអ្នកតា។ អ្វីដែលចាំបាច់បំផុតសម្រាប់កិច្ចស្បថនេះគឺសត្វមាន់រស់។ អ្នកជាដើមបណ្តឹងត្រូវកាន់យកមាន់មួយក្បាលមក ឬជួនកាលទាំងពីរនាក់ដើមបណ្តឹងនិងចុងចម្លើយកាន់មាន់ម្នាក់មួយ។ បើពេលស្បថនោះមានអាចារ្យគឺអាចារ្យនោះត្រូវសូត្រសាត្រាប្រណិធានសម្បុងសង្រួងបួងសួងហៅអស់ទេពនិករមកជួយជាសាក្សីដឹងឮរឿងក្តីអ្នកទាំងពីរនេះ ហើយជួយឱ្យផ្តន្ទាជនណាដែលខុសពិត។ បន្ទាប់ពីអាចារ្យសូត្រហើយគេឱ្យអ្នកក្តីធ្វើសច្ចាតែរៀងខ្លួន។ លុះសច្ចាចប់សព្វគ្រប់ទើបគេចាប់មាន់ទាំងរស់នោះមកអារកដួនក៏មូលកមាន់នេះហើយបោះចូលទៅក្នុងខ្នមអ្នកតា។ បើចំពោះដើមចោទ ពេលមូលកមាន់បោះចូលទៅនោះ គេពោលថាបើចុងចម្លើយនោះបំពានសម្បថឱ្យស្លាប់ដូច

មាន់។ ឯចុងចម្លើយវិញក៏ដូចគ្នាពេលបោះទៅបណ្តើរនិយាយបណ្តើរថាបើខ្លួននិយាយមិនពិតសូមឱ្យស្លាប់វេទនា តែបើខ្លួនត្រង់ពិតហើយដើមចោទនោះមកចោទបំពានឱ្យអ្នកដើមចោទស្លាប់ក្អែកស្រស់បង់សៀតវេទនាដូចខ្មោចមាន់នោះឯងរួមទាំងគ្រួសារញាតិការផង[១៩៨]។

ស្បថអកអង្គរ៖ ការស្បថនេះគឺគេឱ្យគូក្តីទាំងសងខាងអកអង្គរម្នាក់មួយក្តាប់រួចទំពារ បន្ទាប់មកទើបឱ្យស្តោះចេញមកវិញ។ គេវិនិច្ឆ័យថាអ្នកណាខុសអ្នកណាត្រូវឈ្នះចាញ់ដូចម្តេចអាស្រ័យនៅលើកាកអង្គរដែលស្តោះចេញមកនោះ។ គេជឿថាបើអ្នកខុស

---

[១៩៧] បទសម្ភាសន៍ជាមួយលោកអាចារ្យ ហាត នៅភូមិបត់ ស្រុកអង្គរជុំ ខេត្តសៀមរាប ថ្ងៃទី២ខែមិនាឆ្នាំ២០១៥។

[១៩៨] បទសម្ភាសន៍ជាមួយលោកអាចារ្យអ្នករៀបចំកិច្ចនៅវត្តប្រាង្គក្បែរជើងភ្នំឧដុង្គ ថ្ងៃ៣ខែមករាឆ្នាំ២០១៥។

ពិតប្រាកដ ពេលស្តោះអង្ករចេញមកអង្ករនោះនឹងស្ងួតចៃសគ្មានសើមឬជាប់ស្អិតទឹកមាត់ទេ។ តែបើអ្នកត្រង់ពិតស្តោះមកអង្ករនោះនឹងសើមពោពេញដោយទឹកមាត់ ហើយអ្នកនោះឯងទុកថាឈ្នះគេ។ ក្នុងករណីបើអ្នកទាំងសងខាងស្តោះមកអង្ករសើមមានជាប់ទឹកមាត់ដូចគ្នាទុកថាស្មើគ្នា គេសម្រួលឱ្យជាគ្នាវិញដូចដើម[១៩៩]។

ស្បថហុតឈាមឆ្កែខ្មៅ៖ សម្បថប្រភេទនេះច្រើនធ្វើនៅពេលមានជម្លោះចោទប្រកាន់គ្នាម្ខាងៗថាជាគ្រូធ្មប់។ គេយល់ឈាមរបស់សត្វឆ្កែដែលមានសម្បុរខ្មៅមានអានុភាពអាចឱ្យគេវែកមុខរកជនណាដែលគេចោទប្រកាន់ថាជាធ្មប់ពិតប្រាកដ ព្រោះនៅពេលផឹករួចនឹងមានប្រតិកម្មផ្សេងៗឱ្យគេសម្គាល់[២០០]។

២.២.៥. សាក្សីក្នុងជំនឿ

របៀបនៃការដោះស្រាយវិវាទនៅក្នុងសង្គមខ្មែរមានពីរទម្រង់សំខាន់ គឺទី១ ប្រព្រឹត្តទៅតាមបែបបទរដ្ឋបាលតុលាការទូទៅអនុឡោមតាមច្បាប់ដែលបានកំណត់ស្រេច និង១ទៀតគឺការដោះស្រាយតាមបែបជំនឿ។ ដូច្នេះយើងឃើញថាសាក្សីឬបន្ទាល់ក៏មានពីរទម្រង់ដែរ។ ឧទាហរណ៍បើគេធ្វើក្តីតាមដំណើររបស់តុលាការធម្មតា នោះសាក្សីពេជញ្ញាណក៏ជាសាក្សីរស់មានន័យថាជាមនុស្សធម្មតា។ ចំណែកឯមួយបែបទៀតបើគេប្រព្រឹត្តទៅតាមផ្លូវជំនឿផ្អែកលើអំណាចអភិធម្មជាតិ នោះសាក្សីបន្ទាល់ក៏ជាសាក្សីដែលប្រកបដោយវិទ្វិតេជៈអស្ចារ្យខ្ពង់ខ្ពស់ហួសផុតពីវិស័យមនុស្សដែរ។ សាក្សីនៅក្នុងជំនឿមានពួកអមនុស្ស (ទាំងល្អ និង អាក្រក់) ទេពនានា ព្រះ វត្ថុសក្តិសិទ្ធិទាំងពួងជាដើម ។ ជាទូទៅយើងមើលឃើញថាគេមិនប្រកាន់ថាសាក្សីទាំងនោះ ស្ថិតនៅក្នុងជំពូកនៃក្រុមល្អ ឬអាក្រក់យ៉ាងណាទេ ទោះបើព្រាយបិសាចណាក៏ដោយឱ្យតែគេអាចពឹងពាក់អាស្រ័យបាន នោះគេអញ្ជើញហៅមកជាសាក្សីទាំងអស់។ ឯសាក្សីសំខាន់ៗនៅក្នុងក្របខណ្ឌនៃ

---

[១៩៩] បទសម្ភាសន៍ជាមួយលោកអាចារ្យ ធិ នៅភូមិប្រាសាទចារ, ខេត្តសៀមរាប។

[២០០] សម្បថមួយប្រភេទនេះប្រហែលមានដោយកម្រប៉ុណ្ណោះមិនទូលំទូលាយគេឯងដឹងឮ ឬ ស្គាល់ជាទូទៅឡើយ ដ្បិតតាមការស្រាវរបស់ខ្ញុំកន្លងមក ខ្ញុំបានសាកសួរនាំអ្នកស្រុកជាច្រើនកន្លែង ប៉ុន្តែគ្មានអ្នកណាដឹងរឿងប្រភេទសម្បថនេះទេ។ កាលដែលខ្ញុំលើកយករឿងស្បថមួយប្រភេទនេះមកនិយាយព្រោះធ្លាប់មានហេតុការពិតមួយកើតឡើងនៅកំលុងឆ្នាំ ២០០០ នៅភូមិក្រាំងទ្រា, ស្រុកកណ្តាលស្ទឹង, ខេត្តកណ្តាល។ អ្នកនិពន្ធខ្លួនឯងបានសង្កេតផ្ទាល់ក្នុងជម្លោះនេះ។ ពេលនោះមានមនុស្ស២ក្រុមឈ្លោះប្រកែកគ្នា យ៉ាងខ្លាំង។ ក្រុមមួយចោទបុរសម្នាក់ថាជាធ្មប់ ឯក្រុមមួយទៀតចោទបុរសម្នាក់ថាជាគ្រូអាគម ចេះធ្វើអំពើដាក់មនុស្ស។ បុរសដែលគេចោទថាជាធ្មប់ប្រកែកថាខ្លួនជាមនុស្សសាមញ្ញធម្មតាពុំដែលបានរៀនវិជ្ជាអាគមអ្វីឡើយ។ ដើម្បីបញ្ជាក់ភាពល្អបរិសុទ្ធគាត់សូមស្បថហុតឈាមឆ្កែខ្មៅ។ ដោយសារជម្លោះមានសភាពខ្លាំងក្លាពេក ហេតុដូច្នោះនៅពេលគេរៀបចំធ្វើពិធីស្បថខាងកម្លាំងសមត្ថកិច្ចក៏ចុះមកជួយអន្តរាគមសម្រួលអធិករណ៍នោះទៅ។

ជំនឿដែលគេតែងនិយមហៅរកមកជាបន្ទាល់មាន៖ **ព្រះពុទ្ធ អ្នកតា អមនុស្សផ្សេងៗមានព្រាយ បិសាចជាដើម ព្រះធរណី ព្រះភ្លើង**។ល[២០១]។

ជាសេចក្តីសារុប ការដោះស្រាយវិវាទក្នុងសង្គមខ្មែរទោះបីមានច្បាប់តុលាការក៏ពិតមែន ប៉ុន្តែតុលាការមិនបានដាច់ស្រឡះពីជំនឿឡើយ។ ច្បាប់នឹងជំនឿតែងនៅជាប់គ្នាជានិច្ចហើយបំពេញសេចក្តីត្រូវការឱ្យគ្នាទៅវិញទៅមកព្រោះ**មនុស្សតែងមានជំនឿ**។

[២០១] សូមអានបន្ថែម ៖

- ANG, C., *Les êtres surnaturels dans la religion populair khmère*, Cedoreck, Paris, 1986។
- *Ibid., Hommes et terre*, Reyum, Phnom-Penh, 2000. (Publié également en versions khmère et en anglaise).

សេចក្តីសន្និដ្ឋាន

ប្រព័ន្ធច្បាប់កម្ពុជា ដែលសង្គមខ្មែរនាសម័យកណ្តាលបានអនុវត្តគឺជាប្រព័ន្ធច្បាប់មួយផ្សារភ្ជាប់គ្នារវាង ច្បាប់ ប្រព័ន្ធតុលាការ អំណាចរដ្ឋ ទំនៀមទម្លាប់ សាសនា និងជំនឿ។ ការសិក្សាប្រព័ន្ធច្បាប់កម្ពុជាក្នុងសម័យកណ្តាល បង្ហាញថា៖

ស្ថានភាពនយោបាយខ្មែរក្រោយសម័យអង្គរ៖ ក្រោយការដួលរលំនៃអាណាចក្រអង្គរដ៏រុងរឿង កម្ពុជាបានធ្លាក់ក្នុងស្ថានភាពនយោបាយទន់ខ្សោយ និងភាពផុយស្រួយផ្ទៃក្នុងអធិបតេយ្យភាព។ ការផ្លាស់ប្តូរទីតាំងរាជធានីញឹកញាប់ បញ្ហាជម្លោះផ្ទៃក្នុង និងការប្រឈមមុខនឹងសម្ពាធពី សៀម និង យួន បានធ្វើឱ្យរដ្ឋអំណាចខ្មែរត្រូវតស៊ូយ៉ាងលំបាកក្នុងការរក្សានូវអំណាច និងស្ថេរភាពផ្ទៃក្នុង។ ប្រការនេះ បានបង្កលក្ខខណ្ឌឱ្យព្រះរាជាខ្មែរធ្វើការកែលម្អ និងកសាងប្រព័ន្ធច្បាប់ឡើងវិញ និងមានប្រសិទ្ធភាព ដើម្បីធានាសណ្តាប់ធ្នាប់សង្គមក្នុងព្រះនគរ។

ឥទ្ធិពលសៀម យួន មកលើប្រព័ន្ធច្បាប់ខ្មែរ៖ ភាពចុះខ្សោយផ្ទៃកនយោបាយនិងបញ្ហាផ្ទៃក្នុងរបស់ខ្មែរ បានបណ្តាលឱ្យឥទ្ធិពលរបស់សៀម និងយួន ជ្រៀតចូលយ៉ាងជ្រៅទៅក្នុងរាជ្យសំណាក់ខ្មែរនិងរចនាសម្ព័ន្ធរដ្ឋ រួមទាំងប្រព័ន្ធច្បាប់ផងដែរ។ ឥទ្ធិពលអំណាចនិងគោលគំនិតមួយចំនួនពីប្រទេសជិតខាង បានបង្ហាញថា ប្រព័ន្ធច្បាប់ខ្មែរនាសម័យកណ្តាលទទួលរងឥទ្ធិពលពីទំនៀមទម្លាប់ និងការគ្រប់គ្រងរដ្ឋបាលរបស់សៀម និងយួន ដែលជាលទ្ធផលនៃការសម្របខ្លួនរបស់រដ្ឋអំណាចខ្មែរ ដើម្បីឆ្លើយតបទៅនឹងសម្ពាធនយោបាយ។ ទោះបីជាយ៉ាងណាក៏ដោយ ប្រព័ន្ធច្បាប់ខ្មែរនៅតែត្រូវបានកែលម្អ និងកសាងឡើងផ្អែកលើគោលគំនិតរបស់ក្រមច្បាប់ចាស់តាំងពីបុរាណ ដើម្បីបម្រើផលប្រយោជន៍និងរក្សាអត្តសញ្ញាណខ្មែរតាមដែលអាចធ្វើទៅបាន។

ស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាសម័យកណ្តាល៖ ប្រព័ន្ធច្បាប់កម្ពុជានាសម័យកណ្តាល ត្រូវបានកែលម្អ និងកសាងឡើងដោយផ្អែកលើក្រមច្បាប់ចាស់ ដែលបានបន្សល់ទុកតាំងពីបុរាណ និងចំណេះដឹងពីក្រុមមេដឹកនាំ ដែលបានចេះចាំពីបុព្វបុរសតគ្នារៀងមក។ ច្បាប់ខ្មែរនាសម័យនោះ ចែងច្បាស់លាស់ពីការអនុវត្តប្រព័ន្ធយុត្តិធម៌ ប្រភេទបទល្មើស និងទោសទណ្ឌ។ វត្តមាននៃចៅក្រម និងភ្នាក់ងារតុលាការ បានបញ្ជាក់ថារដ្ឋអំណាចខ្មែរបានខិតខំកសាងរចនាសម្ព័ន្ធតុលាការរឹងមាំ ទោះបីស្ថិតក្នុងវិបត្តិនយោបាយក៏ដោយ។ ការអនុវត្តច្បាប់មិនត្រឹមតែជាការអនុវត្តអំណាចរដ្ឋទេ តែជាការប្រកាន់ខ្ជាប់នូវក្រមសីលធម៌ ដែលផ្សារភ្ជាប់ទៅនឹងជំនឿបុណ្យបាប។

ការអនុវត្តច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅសម័យកណ្តាល៖ ការអនុវត្តច្បាប់ត្រូវបានធ្វើឡើងយ៉ាងម៉ឺងម៉ាត់និងតឹងរឹង ក្នុងគោលបំណងចម្បងគឺរក្សាសណ្តាប់ធ្នាប់សង្គម និងធ្វើជាគំរូព្រមានដល់អ្នកផង។ មន្ត្រីក្នុងប្រព័ន្ធយុត្តិធម៌ គេឃើញមានអាជ្ញាជាអ្នកនាំអាជ្ញាព្រះរាជាក្នុងកិច្ចការតុលាការ រីឯមន្ត្រីមានងារជាឱកញ៉ា ពញា ចៅពញា និងព្រះ រហូតដល់មន្ត្រីចតុស្តម្ភសុទ្ធសឹងតែជាចៅក្រមដែលបែងចែកឱ្យកាត់ក្តីទៅតាមដំពូកនៃប្រភេទរឿងក្តី ចៅហ្វាយស្រុកជាចៅក្រមកាត់ក្តីដូចទៅនឹងចៅក្រមនៃសាលាដំបូងបច្ចុប្បន្ន មន្ត្រីចតុស្តម្ភទំនងជាចៅក្រមដូចទៅនឹងចៅក្រមនៃសាលាឧទ្ធរណ៍បច្ចុប្បន្ន ហើយព្រះរាជាគឺជាចៅក្រមចុងក្រោយប្រៀបដូចនឹងចៅក្រមនៃតុលាការកំពូលនាពេលបច្ចុប្បន្នផងដែរ។ ចៅក្រម ត្រូវតែមានការប្រុងប្រយ័ត្នខ្ពស់ក្នុងការថ្លឹងថ្លែងកម្រិតទោសកំហុស ដើម្បីចៀសវាងការដាក់ទោសធ្ងន់ធ្ងរហួសហេតុ ឬកាត់ក្តីខុស ដែលអាចនាំឱ្យបំពានលើព្រះក្រឹត្យិការ និងបង្កឱ្យមានកម្មផលមិនល្អដល់ខ្លួនឯង។

នីតិវិធីនៃការកាត់ក្តីនៅសម័យកណ្តាល៖ នីតិវិធីតុលាការនាសម័យកណ្តាលបង្ហាញឱ្យឃើញពីប្រព័ន្ធយុត្តិធម៌មួយដែលមានលក្ខណៈផ្លូវការ ដែលទាមទារនូវគុណធម៌និងការគោរពវិន័យ ពីគូក្តីយ៉ាងតឹងរឹង។ នីតិវិធីដំណើរការចាប់ផ្តើមដោយការទទួលបណ្តឹងបុគ្គលជាដើមបណ្តឹងត្រូវមាន ***ជំនួនគំនាប់ផ្ចាប់ដៃ*** ដូចជាអង្គរ ស្រា ស្លាម្ហូ ជាដើម ជូនចៅក្រម មុននឹងបណ្តឹងត្រូវបានពិចារណា។ ច្បាប់បានដាក់លក្ខខណ្ឌយ៉ាងម៉ត់ចត់ទៅលើគូក្តី ដោយហាមឃាត់ដាច់ខាត ការប្តឹងផ្តល់ឪពុកម្តាយ ឬសាច់សាររលោហិតជិតស្និទ្ធ ហើយដាក់ពិន័យយ៉ាងធ្ងន់ធ្ងរដល់ ***កូនកំណាច*** ដែលហ៊ានប្រព្រឹត្តបែបនេះ។ លើសពីនេះ តុលាការបដិសេធទទួលបណ្តឹងពីបុគ្គលដែលមាន សតិវិប្បលាស ចាស់ជរាវង្វេង ក្មេងអាយុតិច ឬអ្នកដែលមានពិការភាពរាងកាយ លើកលែងតែមានការស៊ើបសួរពេជ្ឈញាណច្បាស់លាស់។ ក្នុងដំណាក់កាល ***សាកសួរ និងពិរោធន៍*** តុលាការផ្តល់តម្លៃខ្ពស់លើភាពត្រឹមត្រូវនៃពាក្យបណ្តឹងដើម ដែលបានកត់ទុកដោយស្មៀន។ គូក្តីណាដែលឆ្លើយ ***ខុសពីពាក្យដើម*** ឬ ***ឆ្លើយបង្វែង*** សេចក្តីដែលគេកំពុងចោទ នឹងត្រូវទុកជា ចាញ់ក្តី និងត្រូវពិន័យ។ ចៅក្រមមានអំណាចក្នុងការជ្រើសរើសវិធីសាស្ត្រសាកសួរដោយអាចប្រើទាំងភាព ***សុភាពអត់ធ្មត់*** ឬ ***អំណាចសង្កត់*** ទៅលើអ្នកដែលរឹងរូស ដើម្បីស្វែងរកឫសគល់នៃរឿងហេតុ។ ចំណែកការស្វែងរកបន្ទាល់សាក្សី មិនមែនជារឿងចាំបាច់ក្នុងគ្រប់ករណីឡើយ តែបើមានការនិយាយរបស់សាក្សីត្រូវតែ ត្រូវរឿង នឹងពាក្យដើមរបស់គូក្តី បើនិយាយហួស ឬខុសរឿង នឹងត្រូវទុកថា កុហកបោកប្រាស់ ហើយនាំឱ្យចាញ់គេ។ អ្វីដែលសំខាន់បំផុតគឺសាក្សីត្រូវស្បថទទួលបណ្តាសារសោត្រាប្រណិធានជាមុនសិន ទើបពាក្យសម្តីអាចយកជា

ការបាន ហើយការកោះហៅសាក្សីបន្ទាល់ត្រូវតែមានគ្នាច្រើនជាអ្នកចេះសំបុត្រ អមអ្នកកណ្តាល ដើម្បីទប់ស្កាត់ការសមគំនិតបំភ្លៃការពិត។ ដូច្នេះ នីតិវិធីតុលាការនេះ គឺជាប្រព័ន្ធនីតិវិធីផ្លូវការតឹងរ៉ឹងមួយ ដែលទាមទារសុចរិតភាព និងក្រមសីលធម៌ខ្ពស់របស់គូក្តី រួមទាំងការប្រយ័ត្នប្រយែងយ៉ាងខ្លាំងចំពោះ ភាពមិនទៀងត្រង់នៅក្នុងការកាត់ក្តី។

ការដោះស្រាយវិវាទតាមបែបជំនឿ៖ ចំណុចពិសេសនិងលេចធ្លោបំផុតនៃប្រព័ន្ធយុត្តិធម៌ខ្មែរ គឺការដោះស្រាយវិវាទដោយជំនឿ។ ការដោះស្រាយវិវាទតាមបែបជំនឿ ត្រូវបានប្រើជាមធ្យោបាយចុងក្រោយ ប្រសិនបើរឿងក្តីដើរដល់ផ្លូវទល់ច្រកពុំដឹងខុសត្រូវ ឬគ្មានបន្ទុកភស្តុតាងច្បាស់លាស់ គេត្រូវយកជំនឿមកដោះស្រាយរឿងក្តី ដើម្បីស្វែងរកសច្ចភាពដាច់ខាត។ នីតិវិធីទាំងនេះមានលក្ខណៈជា នីតិអច្ចរិយៈ ដូចជា ស្បថផឹកទឹកធម្មារម្យ ស្បថអារកមាន់ ស្បថអកអង្គរ (វិនិច្ឆ័យតាមកាកអង្គរស្ងួត/សើម) ស្បថលាងខ្លួន ស្បថបង្កៀរ និង ដេកក្នុងសីមា ជាដើម។ ព្រះពុទ្ធ ទេព ព្រះធរណី ព្រះភ្លើង អ្នកតា និង អមនុស្ស មានព្រាយ និងបិសាចជាដើម ត្រូវបានអញ្ជើញឱ្យមកធ្វើជាសាក្សី និងអាជ្ញាកណ្តាល ដែលបញ្ជាក់ថា អំណាចវិញ្ញាណត្រូវបានទទួលស្គាល់ថាមានតម្លាភាពជាងសក្តីកម្មមនុស្ស។

ទោស និងទណ្ឌកម្ម៖ ទោស និងទណ្ឌកម្ម ត្រូវបានរៀបចំឡើងជាផ្លូវការយ៉ាងម៉ឺងម៉ាត់ មានលក្ខណៈតឹងរឹង និងដាច់ខាត។ ***ទណ្ឌកម្មផ្លូវកាយដ៏សាហាវ*** រួមមានការប្រើឧបករណ៍ធ្វើទារុណកម្មជាច្រើនប្រភេទ ដូចជា ច្រកឃ្នាង វាយព្រត់លួស (គិតជាដំណំ) ឡើងឈើអណ្តោត វះមាត់ កាប់ក្បាល (គិតជារណ្តៅ) និងទោសប្រហារជីវិត ដោយកាប់ចោល ឬដោត។ ***ទណ្ឌកម្មបំផ្លាញកិត្តិយស*** រួមមាន វាយបណ្តើរ និងស្រែកអាក្រោស ដែលផ្តោតលើការដាក់ទណ្ឌកម្មទៅលើ ឋានៈសង្គម និងកេរ្តិ៍ឈ្មោះរបស់ជនល្មើស។

យន្តការសម្រាលទោស និងអភ័យឯកសិទ្ធិ៖ ***យន្តការសម្រាលទោស*** ជនល្មើសអាចរំលោះទោស ឬសុំអភ័យទោស ដោយបង់ជាប្រាក់ពិន័យ ឬជំនួន ដែលចំនួនត្រូវបានកំណត់តាមបណ្តាសក្តិរបស់ជនរងគ្រោះ (ឧទាហរណ៍ សក្តិ ១០ ហ៊ូពាន់ តម្រូវឱ្យបង់ប្រាក់តម្លឹង ៤)។ យន្តការសម្រាលទោសនេះ ផ្តល់នូវភាពបត់បែន និងអនុញ្ញាតឱ្យទ្រព្យសម្បត្តិមានតួនាទីក្នុងការសម្រាលទោស។ ***អភ័យឯកសិទ្ធិពិសេស*** ព្រះសង្ឃ និងពលព្រះ ទទួលបានការអនុគ្រោះ ស្ទើរតែដាច់ខាតពីទោសផ្លូវលោក ព្រោះព្រះសាសនាត្រូវបានលើកតម្កើងស្មើស្តេចផែនដី។ ប្រការនេះ បង្ហាញឱ្យឃើញថា ឧត្តមភាពនៃសាសនានិងព្រះរាជា មានអភ័យឯកសិទ្ធិពិសេសរួចផុតពីអំណាចច្បាប់ ដែលបង្ហាញពីឥទ្ធិពលដ៏ជ្រាលជ្រៅរបស់សាសនាលើច្បាប់រដ្ឋ។

តាមរយៈការសិក្សា គេអាចសន្និដ្ឋានជារួមបានថា ប្រព័ន្ធច្បាប់កម្ពុជានាសម័យកណ្តាល គឺជាប្រព័ន្ធច្បាប់ទំនៀមបុរាណ ផ្អែកលើទម្លាប់ស្រុក ទំនៀមទំលាប់ សាសនា និងជំនឿរបស់ខ្មែរ ដែលត្រូវបានសង្គមខ្មែរប្រើប្រាស់តំណមកតាំងពីបុរាណកាល ដោយគោរពគោលការណ៍ច្បាប់យ៉ាងតឹងរ៉ឹងរបស់រដ្ឋ មានភាពបត់បែនតាមបរិបទសង្គម អំណាច សីលធម៌ ទំនៀមទម្លាប់ និងជំនឿ ដើម្បីរក្សាលំនឹងសង្គម និងជំនឿចិត្តលើប្រព័ន្ធយុត្តិធម៌ដ៏ពិសិដ្ឋ។

គន្ថនិទ្ទេស

១. មណ្ឌលស្រាវជ្រាវឯកសារ និងបណ្ណាល័យ

- បណ្ណាសារជាតិ, ភ្នំពេញ។
- បណ្ណាល័យជាតិ, ភ្នំពេញ។
- បណ្ណាល័យសាលាបារាំងចុងបូព៌ា (EFEO), ភ្នំពេញ (វត្តឧណ្ណាឡោម) ។
- បណ្ណាល័យវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។
- បណ្ណាល័យសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។
- បណ្ណាល័យសារមន្ទីជាតិ, ភ្នំពេញ។
- បណ្ណាល័យមជ្ឈមណ្ឌលវប្បធម៌បារាំង (Institut Français du Cambodge), ភ្នំពេញ។

២. ទេបសាយអ៊ីនធើណេត

- www.Yosothor.org
- www.Khmerenaissance.info
- http://aefek.free.fr
- http://persee.fr
- http://www.khmermanuscripts.org

៣. សារត្រាបុរាណ

ក្រមពួក, ប្រអប់សម្គាល់ ៤៥៤, ប.ណ.ជ., ភ្នំពេញ។
ច្បាប់ក្រមពលទេព១ខ្សែ, ប្រអប់សម្គាល់ ១០៤, d, លេខ ៥៦, ប.ណ.ជ., ភ្នំពេញ។
ក្រមសារពើគុណ, ប្រអប់សម្គាល់ B.453, ប.ណ.ជ., ភ្នំពេញ។
ក្រមក្បត់សឹក, ប្រអប់សម្គាល់……?, ភ្នំពេញ។
ច្បាប់សំពៅ, កូដ I.132/C.54, BnF.
ច្បាប់សារពើល្បែងភ្នាល់គ្នា, កូដ I.132/C.54, BnF.
ច្បាប់ក្រមពលទេព, កូដ I.429, BnF.
ច្បាប់ក្រមស្រុកផ្សេងៗ, កូដ I.429, BnF.
ច្បាប់សាក្សីពិសោធន៍, កូដ d.895.v.2, nº 145 (239) , EFEO- FEMC.
ក្រមប្រដៅចៅក្រម, កូដ 003.V.2-PP.00.03.01, EFEO-FEMC.
រាជក្រិតក្រមពលទេព, កូដ 001.V.2-PP.00.03.01, nº 01 (01), EFEO-FEMC.

ក្រមពលទេព, កូដ d.893.V.2, nº 145 (239), EFEO- FEMC.
ច្បាប់ក្រមសុភាធិបតី, កូដ O283, EFEO.
ច្បាប់ទំនីមពីបុរាណ, កូដ P23/P111, EFEO.
ច្បាប់ឃុនសាឡា, កូដ P25/P219, EFEO.
ច្បាប់ក្រមស្រុកព្រះជៃជេស្ដា, កូដ P29/P115, EFEO.
សាស្ត្រាប្រាំធ្នាន (ប្រណិធាន) សារកៅ, កូដ B.39.4, SA.
សាស្ត្រាប្រណិធានស្បថ, កូដ B.39.4, SA.
ច្បាប់សង្ឃរី, កូដ ...?, nº 17.
សារតាវត្តសម្បក, ឯកសារលេខ៦៩៤, FAL.

៤. ឯកសារពិគ្រោះទូទៅ

កុយ នាម ២០០២, *ដំណើរការក្តីនៃតុលាការកម្ពុជា*, អង្គការមូលនិធិអាស៊ី, ភ្នំពេញ។

ខេង សុខឡេង ២០១៤, *ពាណិជ្ជកម្មខ្មែរនាសតវត្សទី១៧*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី២២ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ខ្លូត ធីតា ២០០២, *ការស្វែងយល់អំពីរបត់ព្រះពុទ្ធសាសនានៅក្នុងសង្គមខ្មែរ*, វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។

គឹម មិញ ១៩៩៥, *បញ្ហាដីធ្លីតាមរយៈសិលាចារឹក*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី២ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ឃីង ហុកឌី ២០០៧, *បណ្តាំតាមាស*, បណ្ណាគារអង្គរធំ, ភ្នំពេញ។

ងិន កេន ២០០៥, *ទសពិធរាជធម៌*, វត្តពោធិវង្ស (ប្រទេសបារាំង)។

ធាយ ដាវីន ២០១២, *ការពិចារណារលើពាក្យជម័*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី២០ សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ជេត ចន ២០០២, *រូបតួអង្គក្នុងរឿងរាមកេរ្តិ៍*, រៃយ៉ំ, ភ្នំពេញ។

ជា ឡាលីន ២០១០, *ការសិក្សាអត្ថន័យច្បាប់ខ្មែរនាឆ្នាំ១៦៩៣តាមរយៈច្បាប់ក្រមស្រុករបស់ព្រះបាទជ័យជេដ្ឋាទី៣ (១៦៧៥-១៧០៦)*, សារណាបញ្ចប់បរិញ្ញាបត្រ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ។

ឈឹម ក្រសេម, ចាប ពិន ១៩៦៨, *ព្រះរាជពិធីទ្វាទសមាស (ភាគ១)*, ពុទ្ធសាសនបណ្ឌិត, ភ្នំពេញ។

ដេវិឌ ឆាណ្ឌលែរ ២០០៩, *ប្រវត្តិសាស្ត្រខ្មែរ*, ចេញផ្សាយលើកទី៣ជាភាសាខ្មែរ, មជ្ឈមណ្ឌលខេមរសិក្សា, ភ្នំពេញ។

តូច ឈួង ១៩៩៤, *បាត់ដំបងសម័យលោកម្ចាស់*, មជ្ឈមណ្ឌលឯកសារស្រាវជ្រាវអារ្យធម៌ខ្មែរ, ភ្នំពេញ។

ត្រឹង ងា ១៩៧៣, *ប្រវត្តិសាស្ត្រខ្មែរ (ភាគ១-២)*, ភ្នំពេញ។

ទុយ លីដា ២០០៦, *បញ្ហាគុណភាពសម័យបុរាណ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១៣ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

ធន់ ហ៊ុន ២០០៤, *កម្រងកំណាព្យបុរាណ*, ភ្នំពេញ។

ពៅ សារវេស ១៩៨៤, *សិលាចារឹកនគរវត្ត* ,មជ្ឈមណ្ឌលស្រាវជ្រាវអារ្យធម៌, បារីស។

ព្រាប ចាន់ម៉ារ៉ា ២០១២, *សាត្រាប្រណិធាន*, កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, www.khmerenaissance.info (ជំពូក៦ លេខរៀងទី៣៤)។

មាស សុភាព ២០០៧, *ពរ និងបណ្តាសាក្នុងសិលាចារឹក*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១៥ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

មាក់ ព្រេន ១៩៥៧, *លោកន័យសាស្ត្រ*, បណ្ណាគារ គីម គី, ភ្នំពេញ។

យឹម ម៉ានី ២០០៤, *តួនាទីភ្លើងក្នុងអារ្យធម៌ខ្មែរ*, សារណាបញ្ចប់បរិញ្ញាបត្របុរាណវិទ្យាជំនាន់ទី១១ នៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ, ភ្នំពេញ។

យូ នួន ២០០១, *ទសពិធរាជធម៌*, បោះពុម្ពដោយសហរដ្ឋអាមេរិក។

លី ជាមតេង ១៩៧៣, *អំពីប្រពៃណីអ្នកស្រុកចេនឡា*, បកប្រែផ្ទាល់ពីឯកសារដើមភាសាចិននៃ កំណត់ហេតុរបស់ជីវតាក្វាន់, បោះពុម្ពលើកទី៣ ភ្នំពេញ។

លី សុវីរ ២០០៤, *ពិធីចាប់ឆ្នោតស្តាប់ទេសន៍មហាជាតក*, ភ្នំពេញ។

វង់ សុធារ៉ា ២០០៣, *សិលាចារឹកនៃប្រទេសកម្ពុជាសម័យមុនអង្គរ*, ភ្នំពេញ។

សាន ផល្លា ២០០៧, *គំនូរនៅតាមវត្ត*, រៃយ៉ំ, ភ្នំពេញ។

ហេង មណីចិន្តា ១៩៩៩, *ព្រះបាទធម្មិក,* បោះពុម្ពលើកទី៤ផ្សាយ, ការផ្សាយរបស់ព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍, អន្លង់វិល, ភ្នំពេញ។

ហ៊ែល ចំរើន ២០០៩-២០១០, *មរតកយុត្តិធម៌ខ្មែរ*, រោងពុម្ពភ្នំពេញ, ភ្នំពេញ។

ឡុង សៀម ២០០០, *សិក្សាកថាសិលាចារឹករកឃើញថ្មីរបស់សូរ្យវរ្ម័នទី១*, កាសាវិទ្យានឹងសិលាចារឹក, រាជបណ្ឌិតសភាកម្ពុជា, ភ្នំពេញ។

អាដេម៉ា ឡឺក្លែរ ២០០៥, *ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ចាប់តាំងពីសតវត្សទី១នៃគ្រិស្តសករាជរហូតមក*, ប្រែជាភាសាខ្មែរដោយ ទេព ម៉េងឃាង, មជ្ឈមណ្ឌលឯកសារកម្ពុជា, ភ្នំពេញ។

អេង សុត ១៩៩១, *ឯកសារមហាបុរសខ្មែរ, ព្រះរាជពង្សាវតាខ្មែរតាមសាស្ត្រាស្លឹករឹតពិតឥតក្លែងក្លាយ*, បោះពុម្ពឡើងវិញ (ភាគ៥), ភ្នំពេញ។

អាំង ជូលាន ២០១៣, *មូលដ្ឋានរៀនខ្មែរបុរាណ*, យសោធរផ្សព្វផ្សាយវប្បធម៌ខ្មែរ, ភ្នំពេញ។

២០០៤, *ព្រះលឹង្គ*, រៃយ៉ំ, ភ្នំពេញ។

២០០០, *មនុស្សនិងដី*, រៃយ៉ំ, ភ្នំពេញ។

អាំង ជូលាន, ព្រាប ចាន់ម៉ារ៉ា, ស៊ុន ចាន់ជឹប ២០១៤, *ដំណើរជីវិតមនុស្សខ្មែរមើលតាមពិធីឆ្លងវ័យ* (ផ្សាយលើកទី២), យសោធរផ្សព្វផ្សាយវប្បធម៌ខ្មែរ, ភ្នំពេញ។

អាំង ជូលាន, ស៊ីយ៉ុន សុភារិទ្ធ ២០១១, *ស្បថ*, កម្រងអត្ថបទក្នុងបណ្តាញពត៌មានវប្បធម៌ខ្មែរ, www.khmerenaissance.info (ជំពូក៤ លេខរៀងទី៤២)។

នាយកដ្ឋានវប្បធម៌ ២០០៣, របាយការណ៍: *ពីជីវស្បថរបស់អ្នកភូមិនគរក្រៅនៅវត្តតាកាំ*, ក្រុមសិក្សាសង្គម។

២០១៥,ប្រវត្តិស្ថាប័នខ្មែរ,ពៅ សារឿន

ANG, Chouléan 1986*, Les êtres surnaturels dans la religion populair khmère*, Cedoreck, Paris.

1987-90, « Le sacré au féminin », *Seksa Khmer* nº 13-10, Cedoreck, Paris : p. 3-30,

1995, « Le sol et l´encêtre, L´amorphe et l´anthropomorphe », [*in*]

JA, Tome 283, numéro 1. p.213-238.

2000, *Hommes et terre*, Reyum, Phnom-Penh (publié également en versions khmère et anglaise).

2012, « Est-ce si surnaturel ? », *Péninsule* n.65, p. 81-99.

AU, Chhieng 1953, *Catalogue du fonds khmer*, Bibliothèque Nationale, Paris.

1969, « Études de philologie indo-khmère. V : à propos de la statue dite du ‘roi lépreux’ » [*in*] *JA*, année 1968, p. 185-201.

AYMONIER, Etienne 1989-1900, « Les inscriptions modernes d'Angkor Vat, Preah Peân Bakkan et la Grande Inscription », [*in*] *JA*, nov.-déc. 1899, p. 453-529, janv.-fév. 1900, p.143-175.

1900-1904, *Le Cambodge*, vol. I. *Le Royaume actuel*, vol. II. *Les provinces siamoises*, Vol. III. *Le groupe d'Angkor et l'histoire*, Ernest Leroux, Paris.

AUGUSTE, Pavie 1903, *Contes populaires du Cambodge, du Laos et du Siam*, Bnf, Paris. BARTH, Auguste et BERGAIGNE, Abel

1885-1889, *Inscriptions sanscrites de Champā et du Cambodge*, Paris. B.P., Groslier

2006, *Angkor and Cambodia in the sixteenth century, According to Portuguese and Spanish sources*, translate by Michael Smithies, Orchid Press, Bangkok, Thailand.

BRUNO, Dagens 2003, *Les Khmers*, Belles Lettre, Paris.

CARBONNEL, Roseline Octobre 1981, *Étude du* Sástrá kön kantrai, Mémoire de D.E.A, Université Paris VII.

1979, *Le Sástrá kön kantrai*, Mémoire pour le Diplôme de l'École Pratique des Hautes Études, IV^{e} section, Histoire et Philologie, Paris – Sorbonne.

COEDÈS, George 1937, Inscriptions du Cambodge, Vol I, EFEO, Hanoi-Paris.
1942, Inscriptions du Cambodge, Vol II, EFEO, Hanoi-Paris.
1951, Inscriptions du Cambodge, Vol III, EFEO, Hanoi-Paris.
1952, Inscriptions du Cambodge, Vol IV, EFEO, Hanoi-Paris.
1953, Inscriptions du Cambodge, Vol V, EFEO, Hanoi-Paris.
1954, Inscriptions du Cambodge, Vol VI, EFEO, Hanoi-Paris.
1964, Inscriptions du Cambodge, Vol VII, EFEO, Hanoi-Paris.
1954, La stèle de Tuol Rolom Tim, Essai d'interprétation par la langue Bhanar d'un texte juridique khmèr du Xe Siècle, [*in*] *JS,* CCXLII, p.49-67.

DAVID P., Chandler July 1974, « Royally Sponsored Human Sacrifices in nineteenth Century Cambodia: the cult of nak tā Me Sa (Hahisāsuramardini) at Ba Phnom », [in] *JS*, volume 62, part 2.

ELLUL, Jean 1983, *le coutumier rituel des capteurs d'éléphants de l'Ouest du Cambodge*, Thèse de Doctorat de l'EHESS. Paris,

FINOT, Louis 1928, « Nouvelles inscriptions du Cambodge », BEFEO Tome XXVIII, p. 43-80.

GOUR, Claude-Gilles 1965-1966, *Institutions constitutionnelles et politiques du Cambodge,* Les systèmes de droit contemporain, Dalloz, Paris.

HARRIS, Peter 2007, *Zhou Daguan. A record of Cambodia. The Land and its people*, translated with an introduction and notes by, Chiang Mai, Silkworm Book.

HINÜBER, Oskar von 1995, « Buddhist Law according to Theravada-Vinaya » [*in*] *Journal of the International Association of Buddhist Studies*, volume 18, number 1, p. 7-45.

HUXLEY, Andrew 1996, *Thai Law: Buddhist law. Essays on the Legal History of Thailand, Laos and Burma*, White Orchid Press, Bangkok.

HEL, Chamroeun Août 2006, *Les conflits foncier au Cambodge, Contribution à la connaissance du droit de propriété cambodgien*, Thèse pour le doctorat en droi, Universite Paris 1 Pontéon Sorbonne.

IMBERT, Jean 1967, *Histoire des institutions khmères*. Annales de la Faculté de Droit de Phnom Penh.

1894, *Recherches sur la législation criminelle des Cambodgiens*, Paris, Augustin Challamel.

1898, *Les codes cambodgiens*, 2 tomes, Ernest Leroux, Paris,

ISHIZAWA, Yoshiaki 1984, « Court and Lawsuits in Cambodia of the Angkor Period », [*in*] *Journal of Oriental,* Research, Kyoto University.

1985, « The Juridical System in Angkorian Cambodia », [*in*] *Journal of Sophia Asian Studies*, Sophia University.

JENNEAU, Gustave 1870, *Manuel pratique de langue cambodgienne, contenant de nombreuses listes de mots usuels groupé par catégories, des dialogues applicables aux circonstances ordinaires de la vie pratique, et une carte politique du royaume de khmer*, Saigon, Imprimerie impériale.

KHIN, Sok 1988, *Chronique Royales du Cambodge (De Bañā Yāt à la prise de Lanvaek de 1417 à 1595*), BEFEO, Paris.

1998, « L´esclavage au Cambodge à l´époque moyenne à traverse les codes, les inscriptions modernes d´Angkor et les chronique royales », [*in*] *Formes extrêmes de dépendance. Contributions à l´étude de l´esclavage en Asie du Sud-Est*, (sous la direction de Georges CONDOMINAS), Paris, EHESS.

LINGAT, Robert 1929, « Note sur la révision des lois siamoises » [*in*] *JSS*, XXIII, p. 19-27.

1947-1950, « La conception du droit dans l´Indochine hinayaniste » [*in*] *BEFEO*, tome XXXXIV, fasc. 2, p.163-188.

1949, *Les ordalies au Siam*, Saigon, L'Éducation.

1949, « L'influence juridique de l'Inde au Champa et au Cambodge d'après l'épigraphie » [*in*] *JA*, n°2, p. 273-290.

1964, « La preuve dans l'ancien droit siamois » [*in*] *La preuve. Recueils de la Société Jean Bodin*, Tome XVIII, p. 397-418.

1973, *A Concise Legal History of South-East-Asia*, Oxford, the Clarendon Press.

1986, *The Laws of Southeast-Asia. Volume I: The Pre-Modern Texts*. Butterworth & co.

Juin 2005, *Pour un droit comparé indochinois*, (réimpression d'un article de 1955 avec une présentation d'Antoine Fontaine) [*in*] *Aseanie* n°15, p. 125-160. HOOKER Michael Barry.

LECLERE, Adhémard 1890, *Recherches sur la législation cambodgienne (droit privé)*, Paris, Augustin Challamel.

1894, « Droit cambodgien » [*in*] *Nouvelle revue historique de droit français et étranger*, janv.-fév, p. 1-32.

1894, « Droit cambodgien. Étude sur le régime des biens entre époux, les donations et les successions au Cambodge » [*in*] *Nouvelle revue historique de droit français et étranger*, p. 68-95.

1894, *Recherches sur le droit public des Cambodgiens*, Paris, Augustin Challamel.

1894, *Droit cambodgien (le régime de la communauté dans le mariage, les successions, les donations)*, Paris, Augustin Challamel.

1898, *Recherches sur les origines brahmaniques des lois cambodgiennes,* Paris, Ernest Leroux.

MAK, Phoun 1989, « La frantière enter le Cambodge et le Vietnam du XVIIe siècle à l'institution du protectorat francais présentée à

traverse les chronique royales khmères », [*in] Les frontières du Vietnam. Histoire des frontières de la Péninsuls indochinoise*, Paris. 1995, *Histoire du Cambodge de la fin du XVIe siècle*, EFEO, Paris. p.136-155.

MIKAELIAN, Grégory 1997-1998*, Mémoire Le Kram Sruk de Chey Chettha III, édition critique d'un code institutionnel khmer du 17è siècle*, sous la direction de M. Denis CROUZET, Université Paris IV- Sorbonne nouvelle.

1999 (1), « La gestion administrative du royaume khmer d'après un code institutionnel du XVII^{e} siècle » [*in*] *Péninsule* n° 38, p. 65-167.

Octombre 2006, *Recherches sur l'histoire du fonctionnement politique des royautés post-Angkoriennes (c.1600-c.1720)*, Thèse de doctorat d'histoire moderne, Université Paris IV- Sorbonne nouvelle.

Juin 2009, *La royauté d'Oudong. Réformes institutionnelles et crise du pouvoir dans le pays khmer du XVII^{e} siècle,* Paris, Presses Universitaires de la Sorbonne (PUPS).

MESTIER DU BOURG, Hubert de (Date) « Le procès dans l'ancien droit khmer », [*in*] *JA*, n°256, p.37-53.

NEPORT, Jacques 1983, introduction à « Le cycle de SII THANONSAY ou variations sur le thème du bouffon royal » [*in*] *Péninsule* n° 6-7, p. 7-14.

1986, introduction à *Le roman cambodgien du lièvre*, Paris, CEDORECK.

PAUL, Péllio 1902, « Mémoire sur les coutumes du Cambodge» [*In*] *BEFEO*, Tome 2, p. 123-177 POU, Saveros

1981, « La littératures didactique Khmère : Les CPĀP' », [*in*] *JA*, Tome CCLXIX, p.200-213.

1982, *Rāmakerti II* , EFEO, Paris.

1983, « Dharma and trivarga in the Khmer Language » [*in*] *ºtam , Dr. Babu Ram Saksena Felicitation Volume*, XI-XV, ed. by J.P. SINHA, Lucknow, p. 289-297.

1984, *Nouvelles Inscriptions du Cambodge, Vol I*, CNRS, Paris.

2001, *Nouvelles Inscriptions du Cambodge, Vol II-III*, *EFEO*, Paris.

2009, « *Satya*, *śapatha* et *sáksí* dans la culture khmère », [*in*] *JA*, t. 297, nº 2, p. 399-421.

2011, *Nouvelles Inscriptions du Cambodge, Vol IV*, *EFEO*, Paris.

REID, Anthony 1988, *Southeast Asia in Age of Commerce 1450-1680*, New Haven and London, Yale University Press, Volume 1.

R.P., Kangle 1965, *The Kauṭilīya Arthaśāstra*, Part III, Delhi.

SHYTOV, Alexander [2000 ? Non précisé], *Thai Folktales Law,* Chiang Mai, ACTS.

SAHAI, Sachchidanand, 1970, « Les institutions politiques et L´oganisation administrative du Cambodge ancien (VI-XIII Siècle) », BEFEO, Volume LXXV, Paris.

August 1976, « The Judicial System in Ancient Cambodia » [*in*] *The South East Asian Review,* vol. I, nº1, p. 79-100.

THOMPSON, Ashley 2004, « The Suffering of the Kings : Substitute Bodies, Healing, and Justice in Cambodia » [*in*] *History, Buddhism and New Religious Movements in Cambodia*, E. GUTHRIE and J. MARSTON éds., University of Hawaï Press, Honolulu, p. 91-112.

TAUPIN, Jean 1886, « Études sur la littérature khmère. Une douzaine d´équitables jugements du Boddhisatva » [*in*] *B.S.E.I.*, 2ème semestre, p. 15-31.

VICKERY, Theodore Michael 1977*, Cambodia after Angkor*, The chronicular evidence for the volume 1, published on demand by University Microfilms International, U.S.A-London, England.

1984, « Prolegomena to Methods for Using the Ayutthaya Laws as Historical Source Material » [*in*] *JSS*, 72, p. 37-58.

៥. ឥចនានុក្រម

ជួន ណាត ២០០៨ ,*វចនានុក្រមខ្មែរ* ,ពុទ្ធសាសនបណ្ឌិត,ភ្នំពេញ។

ឡុង សៀម ២០០០, *វចនានុក្រមខ្មែរបុរាណ ស.វ.ទី៦-៨*, រាជបណ្ឌិតសភាកម្ពុជា, ភ្នំពេញ។

PHILIP N., Jenner 2009, *A dictionary of pre-Angkorian Khmer*, edited by Doug Cooper. Bangkok, Thailand.

PHILIP N., Jenner 2011, *A dictionary of Middle Khmer*, edited by Doug Cooper. Bangkok, Thailand.

POU, Saveros 1992, *Dictionnaire Vieux Khmer-Français-Anglais*, Cedoreck, Paris.

បញ្ជីឈ្មោះក្រុមសិក្ខាស្រាវជ្រាវអនុប្រធានបទ
ស្តីពីប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប (១៨៦៣ ដល់បច្ចុប្បន្ន)

លរ.	គោតនាម និងនាម	វិជ្ជាជីវៈ	ស្ថាប័ន	ការចូលរួម
១	ឯកឧត្តមបណ្ឌិត មាស បូរ៉ា	រដ្ឋលេខាធិការ	លេខាធិការដ្ឋានកិច្ចការព្រំដែន	អ្នកសម្របសម្រួល, ផ្តល់ធាតុចូលនិងនិពន្ធ
២	ឯកឧត្តម ស សាមីឌី	រដ្ឋលេខាធិការ	ក្រសួងមុខងារសាធារណៈ	ផ្តល់ធាតុចូល
៣	ឯកឧត្តម លី តៃសង	សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងប្រធានគ្រប់គ្រង	ក្រុមហ៊ុនមេធាវី HBS	ផ្តល់ធាតុចូល
៤	លោក ហ៊ឹប ណារិទ្ធិ វេស៍	ប្រធានមជ្ឈមណ្ឌលជាតិមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា	មជ្ឈមណ្ឌលជាតិមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា	ផ្តល់ធាតុចូល
៥	លោក ប៊ុន ឃូឌី	នាយកគ្រប់គ្រង	ការិយាល័យមេធាវី ប៊ុន និងសហការី	ផ្តល់ធាតុចូល
៦	លោក ភិន សុវត្ថិ	នាយកគ្រប់គ្រង	ការិយាល័យមេធាវី អេស.ឌី.អេស.	ផ្តល់ធាតុចូល
អ្នកសម្របសម្រួលក្រុមស្រាវជ្រាវ				
៧	លោក ម៉ន សុភ័ណ	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួលនិងបច្ចេកទេសអត្ថបទ
៨	លោក មាឃ សីហា	អ្នកជំនាញការច្បាប់	គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់	សម្របសម្រួលនិងបច្ចេកទេសអត្ថបទ

អនុប្រធានបទ
ស្តីពីប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប (១៨៦៣ ដល់បច្ចុប្បន្ន)

ខ្លឹមសារសង្ខេប

អត្ថបទនៃរបាយការណ៍នេះ គឺជាលទ្ធផលនៃការពិនិត្យមើលប្រព័ន្ធច្បាប់សម័យទំនើប (១៨៦៣ ដល់បច្ចុប្បន្ន) ដោយឆ្លុះនឹងធាតុផ្សំចម្បងនៃប្រព័ន្ធច្បាប់ ដែលមានដូចជាប្រភពនៃច្បាប់ រចនាសម្ព័ន្ធនៃ តុលាការ ឋានុក្រមនៃច្បាប់ នីតិវិធីនៃការធ្វើច្បាប់ ការបកស្រាយនិងការអនុវត្តច្បាប់ ។ល។ ដោយសារតែមានកង្វះខាតឯកសារពាក់ព័ន្ធជាពិសេសក្នុងសម័យកាលពីឆ្នាំ១៨៦៣ ដល់ ឆ្នាំ១៩៧៩ ក្រុមការងារមិនបានពិនិត្យមើលខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តនីមួយៗ បានស៊ីជម្រៅ ដើម្បីអាចកំណត់អំពីគុណភាពនៃខ្លឹមសារច្បាប់នោះថាស្ថិតក្នុងប្រព័ន្ធច្បាប់អ្វីទេ។

លទ្ធផលបានបង្ហាញថា ទោះបីមានការដឹងជាទូទៅថា កម្ពុជាប្រកាន់យកប្រព័ន្ធច្បាប់ស៊ីវិល តាមបែបប្រព័ន្ធច្បាប់បារាំង ក៏**គ្រាន់តែជាលក្ខណៈជាទម្រង់ (ច្បាប់ជាលាយលក្ខណ៍អក្សរ) និងយន្តការដោះស្រាយជម្លោះ រីឯប្រព័ន្ធច្បាប់អង់គ្លូសាក់សុង** ក៏មិនទាន់បានចាក់គ្រឹះរឹងមាំផងដែរ។ ចាប់ពីឆ្នាំ២០០៧ ទើបទម្រង់ និងខ្លឹមសារ នៃប្រព័ន្ធច្បាប់ស៊ីវិល ចូលមកតាមរយៈជំនួយសរបស់ប្រទេសជប៉ុនលើគម្រោងអភិវឌ្ឍក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី និងជំនួយរបស់ប្រទេសបារាំងលើគម្រោងអភិវឌ្ឍក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ (សមាសភាគផ្សំរវាងប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង)។ ក្រោមកម្មវិធីជំនួយនេះ ដោយសារលទ្ធភាពនៃការទទួលយក ឬការខកខានអភិវឌ្ឍច្បាប់ បន្ទាប់ពីរបបការបំផ្លាញប្រព័ន្ធច្បាប់ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ និងការជ្រៀតចូលដោយប្រព័ន្ធច្បាប់សង្គមនិយមក្នុងរយៈពេលជាង១០ឆ្នាំ ដែលចាក់ឫសគល់ដ៏មាំក្នុងចិត្តគំនិតរបស់អ្នកអនុវត្តច្បាប់ (១៩៧៩-១៩៩៣)។

ក្រោយមក ជាពិសេសឆ្នាំ១៩៩៣ ធាតុផ្សំនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បានជ្រៀតចូលបន្តិចម្តងៗក្នុងវិស័យជាច្រើនដូចជាពាណិជ្ជកម្ម តាមរយៈជំនួយបច្ចេកទេសច្បាប់ (អ្នកជំនាញការ ឬប្រទេសផ្តល់ជំនួយប្រកាន់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង) និងការ

ចូលជាភាគីរបស់កម្ពុជាក្នុងកិច្ចព្រមព្រៀង ឬជាសមាជិកអង្គការអន្តរជាតិ។ ធាតុផ្សំច្បាប់បុរាណក្នុងសម័យកណ្តាលនៃច្បាប់កម្ពុជា ក៏មានវត្តមានជាកម្រ និងត្រូវបានគិតគូរដាក់បញ្ចូលទៅក្នុងប្រពន្ធច្បាប់កម្ពុជាសព្វថ្ងៃដែរ។ អ្នកសិក្សាស្រាវជ្រាវច្បាប់ជំនាន់ក្រោយមួយចំនួនក៏ទទួលបានការបណ្តុះបណ្តាលនៅក្នុងប្រទេសប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ ស្របពេលគ្នានេះ និន្នាការនៃការប្រើប្រាស់យុត្តិសាស្ត្រក៏កើតមាន ទោះបីមិនក្នុងលក្ខណៈជាខ្សែសង្វាក់។

ច្បាប់ខ្លះជាទម្រង់នៃប្រព័ន្ធអង់គ្លូសាក់សុង (ឈ្មោះចំណងជើងមាត្រា) ខ្លះទម្រង់ជាក្រមបែបប្រព័ន្ធច្បាប់ស៊ីវិល ក៏ប៉ុន្តែនៅតែខ្វះខាតនូវខ្លឹមសារលម្អិត ដែលចង់មិនចង់ ទុកច្រកឲ្យចៅក្រមបកស្រាយច្បាប់។ ខណៈដែលអ្នកអនុវត្តខ្លះ មានផ្នត់គំនិតតាមប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់សង្គមនិយម។ ទីនេះ ប្រព័ន្ធច្បាប់កម្ពុជាប្រឈមនឹងបញ្ហាថាខ្លឹមសារច្បាប់តាមលំនាំប្រព័ន្ធអង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការដោះស្រាយ ឬអនុវត្ត តាមប្រព័ន្ធច្បាប់ស៊ីវិលទៅវិញ។

ជាសរុប ប្រព័ន្ធច្បាប់កម្ពុជាស្ថិតនៅក្នុងសភាពមិនច្បាស់លាស់ និងគ្មាននូវភាពពិតប្រាកដ (Unique) ដែលត្រូវការឲ្យមានការកសាងប្រព័ន្ធមួយមានភាពជាក់លាក់សម្រាប់កម្ពុជា។

«ប្រព័ន្ធច្បាប់ស៊ីវិលចាប់តាំងពីឆ្នាំ១៨៦៣ មិនបានចាក់ឫសរឹងមាំក្នុងប្រព័ន្ធច្បាប់កម្ពុជា ក្រៅពីទម្រង់ច្បាប់ជាលាយលក្ខណ៍អក្សរ និងការបង្កើតយន្តការអនុវត្ត ដោយសារកត្តាគម្លាតវេលានៃរបបដឹកនាំនយោបាយ។ ផ្នត់គំនិតនៃការអនុវត្តច្បាប់តាមបែបសង្គមនិយម បានចាក់ឫសរឹងមាំក្រោយឆ្នាំ១៩៧៩។ ក្រោយឆ្នាំ១៩៩៣ ខ្លឹមសារនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បានជ្រៀតចូលក្នុងប្រព័ន្ធច្បាប់កម្ពុជានាំឲ្យមានការអះអាងថាប្រព័ន្ធច្បាប់កម្ពុជា មានខ្លឹមសារតាមលំនាំប្រព័ន្ធច្បាប់អង់គ្លូសាក់សុង រីឯយន្តការអនុវត្តតាមបែបប្រព័ន្ធច្បាប់ស៊ីវិល។»

ផ្នែកចុងក្រោយនៃអត្ថបទ បានដាក់ចេញនូវអនុសាសន៍មួយចំនួន។ ក្រុមការងារស្រាវជ្រាវ សូមធ្វើការខន្តីអភ័យទោសចំពោះកង្វះខាត និងរង់ចាំទទួលនូវការរិះគន់ប្រកបដោយការស្ថាបនា ដើម្បីជាមូលដ្ឋានស្រាវជ្រាវលម្អិតជាបន្ត។

ជំពូកទី១
សេចក្តីផ្តើម

នៅពេលបរិយាយអំពីប្រព័ន្ធច្បាប់ គេត្រូវដឹងអំពីនិយមន័យ ប្រភេទ និងសមាសភាគនៃប្រព័ន្ធច្បាប់ និងថាតើប្រទេសនេះ ប្រកាន់យកប្រព័ន្ធច្បាប់អ្វី ប្រព័ន្ធច្បាប់ស៊ីវិល ឬប្រព័ន្ធប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ កម្ពុជា ជារដ្ឋមួយបានចាប់កំណើតជាយូរមកហើយ ពោលគឺនាដើមគ្រឹស្តសករាជ ដែលពីមុននគរកម្ពុជាមានឈ្មោះថា ***«ហ្វូណន»***។ ការដឹកនាំរដ្ឋនាសម័យកាលនោះ គឺអនុវត្តប្រព័ន្ធគ្រប់គ្រងរដ្ឋតាមបែបឥណ្ឌាបុរាណ ***«រាជ្យមណ្ឌល»*** និងអនុលោមតាមវិធានមួយចំនួន ដែលគេហៅថា ***«អាជ្ញា ឬរាជ្យអាជ្ញា»*** និងមានគម្ពីច្បាប់ ***«ធម្មសាស្ត្រ និងអាថ៌សាស្ត្រ»*** និងសម័យកាលក្រោយមកទៀតឃើញមាន ***«ច្បាប់ទំនៀមបុរាណ ដែលគេសន្និដ្ឋានថាមានប្រភពពីព្រះធម្មសាស្ត្រ»*** ទោះបីមិនមានទម្រង់ ឬប្រព័ន្ធជាក់លាក់ក្តី។

អត្ថបទសិក្សាស្រាវជ្រាវខ្លីនេះ ផ្តោតលើប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប ដោយគិតចាប់ពីឆ្នាំ១៨៦៣ ដល់បច្ចុប្បន្ន ដែលក្នុងអំឡុងពេលនៃសម័យកាលប្រវត្តិសាស្ត្រនេះ មានរបបដឹកនាំនយោបាយជាច្រើន និងអនុវត្តិប្រព័ន្ធច្បាប់រៀងៗខ្លួន។ លទ្ធផលនៃការស្រាវជ្រាវខាងក្រោមនេះ គឺនៅមិនទាន់បានសិក្សាលម្អិតនិងស៊ីជម្រៅ ដោយសារកត្តាពេលវេលា និងកង្វះនូវប្រភពឯកសារមួយចំនួនផងដែរ។

សម័យកាលនីមួយៗ នឹងត្រូវបានសិក្សាលើសមាសភាគនៃប្រព័ន្ធច្បាប់ ស្ថាប័នច្បាប់ យន្តការធ្វើច្បាប់ ការដោះស្រាយជម្លោះ អត្ថបទ ច្បាប់ ព្រមទាំងខ្លឹមសារនៃច្បាប់មួយចំនួនផង។[202] ធាតុផ្សំទាំងនេះ នឹងត្រូវបានឆ្លុះឆ្លើយជាមួយនឹងរដ្ឋធម្មនុញ្ញនៃរបបនីមួយៗចន្លោះឆ្នាំ១៨៦៣ ដល់បច្ចុប្បន្ន។

ក្រុមស្រាវជ្រាវនឹងវាយតម្លៃថា ***តើកម្ពុជាអនុវត្តប្រព័ន្ធច្បាប់អ្វី*** ហើយប្រភេទនៃប្រព័ន្ធច្បាប់ដែលបានអនុវត្តនោះបានប្រែប្រួលដែរឬទេ និងជាចុងក្រោយថា ***តើស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជាមានលក្ខណៈយ៉ាងដូចម្តេចនាពេលបច្ចុប្បន្ន***។

[202] Luka Burazin, "Legal systems as abstract artifacts", 2022, p.2, Legal Systems as Abstract Artifacts by Luka Burazin :: SSRN។

លទ្ធផលការសិក្សានេះ ត្រូវបានរំពឹងថា នឹងត្រូវបានគេយកទៅពិចារណាដើម្បីកសាងប្រព័ន្ធច្បាប់មួយ ទោះបីមិនទាំងស្រុង ក៏ប៉ុន្តែជាផ្នែកមួយក្នុងការឆ្ពោះទៅរកការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា។

ជំពូកទី២.
ប្រព័ន្ធច្បាប់និងការវិវត្តពីឆ្នាំ១៨៦៣ ដល់បច្ចុប្បន្ន

ប្រព័ន្ធច្បាប់ ផ្តុំឡើងពីពាក្យ ***«ប្រព័ន្ធ»*** និង ***«ច្បាប់»***។ ក្នុងន័យសាមញ្ញ ***«ប្រព័ន្ធ»*** មានបង្គប់នូវចង្កោម ឬការប្រមូលផ្តុំ ប្រទាក់ក្រឡាគ្នា រីឯពាក្យ ***«ច្បាប់»*** សំដៅជាចម្បងក្នុងន័យចង្អៀត ជាលិខិតបទដ្ឋានគតិយុត្តធ្វើឡើងដោយអំណាចនីតិប្បញ្ញត្តិ។ ប្រព័ន្ធច្បាប់ មានសមាសភាគ៖ ការតាក់តែង ការអនុវត្ត និងបកស្រាយច្បាប់ ព្រមទាំងយន្តការនៃការតាក់តែង ការអនុវត្ត និងការបកស្រាយច្បាប់។ ក្នុងពេលមានជម្លោះផ្លូវច្បាប់ តើគេត្រូវយកយន្តការណាដោះស្រាយ។ ជាមួយគ្នានេះដែរ ប្រព័ន្ធច្បាប់ក៏ពាក់ព័ន្ធនឹងខ្លឹមសារនៃច្បាប់ ដែលទាមទារនូវការពិនិត្យមើលខ្លឹមសារជាក់ស្តែងដើម្បីវាយតម្លៃ អំពីប្រភេទនៃប្រព័ន្ធច្បាប់។

តាមខ្លឹមសារនេះ រដ្ឋធម្មនុញ្ញនៃប្រទេសនីមួយៗ មានចែងអំពីធាតុផ្សំមួយចំនួនខាងលើ។ ដើម្បីកំណត់អំពីប្រព័ន្ធច្បាប់នៃប្រទេសមួយបាន គេត្រូវពិនិត្យមើលច្បាប់រដ្ឋធម្មនុញ្ញនៃប្រទេសនោះ។

២.១. សម័យអាណាព្យាបាលបារាំង ១៨៦៣ ដល់ ១៩៥៣

ក្នុងឆ្នាំ១៨៦៣ ព្រះរាជាណាចក្រកម្ពុជា និងបារាំងបានចុះសន្ធិសញ្ញាអាណាព្យាបាល ក្នុងបំណងជួយការពារកម្ពុជាពីការទន្ទ្រានពីប្រទេសក្បែរខាង។[២០៣] ក្រោយមកក្នុងឆ្នាំ១៨៨៤ តាមសន្ធិសញ្ញាឆ្នាំ១៨៨៤ កម្ពុជាលែងមានឯករាជ្យភាព ដោយសារកិច្ចការបរទេសត្រូវបានធ្វើឡើងដោយប្រទេសបារាំងជាតំណាង។[២០៤] ក្រោមការគ្រប់របស់បារាំងជិតមួយសតវត្ស រហូតដល់ឆ្នាំ១៩៥៣ ទើបកម្ពុជាទទួលបានឯករាជពេញលេញពីប្រទេសបារាំង។

បារាំងបានគ្រប់គ្រងដឹកនាំកម្ពុជា តាមវិធាន និងប្រព័ន្ធច្បាប់របស់ខ្លួន។ ចាប់ពីពេលនោះ កំណើតនៃច្បាប់ជាលាយលក្ខណ៍អក្សរតាមបែបបារាំងបានចាប់ផ្តើម[២០៥] ដោយហេតុថា ជនជាតិខ្មែរ មានប្រើវិធានសរសេរដែលជាច្បាប់ខ្មែរបុរាណមានលក្ខណៈមិន

---

[២០៣] *សន្ធិសញ្ញារវាងព្រះចៅអធិរាជបារាំងនិងព្រះមហាក្សត្រខ្មែរសន្ធិសញ្ញា ឧត្តុង*, ចុះថ្ងៃទី ១១ខែសីហាឆ្នាំ១៨៦៣ ដើម្បីកំណត់លក្ខខណ្ឌអាណាព្យាបាលបារាំង លើប្រទេសកម្ពុជា ; *"Traité conclu à Oudon le 11 août 1863, réglant les conditions du Protectorat Français au Cambodge"*, Bulletin du Cambodge, Année 1884 N° 1, p.3.

[២០៤] *អនុសញ្ញារវាងបារាំងនិងកម្ពុជា*, ចុះថ្ងៃទី ១៧ ខែមិថុនា ឆ្នាំ ១៨៨៤ ; *"Convention entre la France et le Cambodge, le 17 juin 1884, pour régler les rapports respectifs des deux pays"*.

[205] Bibliothèque de l'Association Henri Capitant, *"Histoire du Cambodge"*, 2016, p.13

ទំនើប និងគោរពនូវវិធានទំនៀមទំលាប់ជាង។[២០៦] គណៈកម្មការរៀបចំច្បាប់មួយ ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជប្បញ្ញត្តិរបស់ព្រះបាទនរោត្តម ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩០១ ស្តីពីការបង្កើតគណៈកម្មការចម្រុះកម្ពុជា-បារាំង ដើម្បីបង្កើតក្រមច្បាប់ខ្មែរ។[២០៧]

មូលបទនៃព្រះរាជប្បញ្ញត្តិបានចែងថា ***«ហេតុផលដើម្បីកែសម្រួលអត្ថបទច្បាប់កំពុងនៅជាធរមាន (សំដៅដល់អត្ថបទច្បាប់ពីបុរាណ) គឺដើម្បីផ្សាភ្ជាប់តម្រូវការបច្ចុប្បន្នជាមួយនឹងប្រពៃណីនៃព្រះរាជាណាចក្រយើង»*** ។ យោងតាមមូលបទនៃព្រះរាជប្បញ្ញត្តិនេះ ***«អត្ថបទច្បាប់ពីបុរាណ»*** គឺមិនមានភាពពេញលេញ ពិបាកយល់ និងពេលខ្លះមានភាពផ្ទុយគ្នា ហើយបានដាក់ទោសទណ្ឌដែលមិនសមរម្យ។ ចំណែកឯនីតិវិធីបណ្តឹងមានរយៈពេលវែង អូសបន្លាយពេល និងថ្លៃ ធ្វើឱ្យប៉ះពាល់ដល់ជីវភាពរបស់ពលរដ្ឋ។

រយៈពេល១០ឆ្នាំ បន្ទាប់ពីព្រះរាជប្បញ្ញត្តិឆ្នាំ១៩០១ គឺនៅឆ្នាំ១៩១១ ព្រះបាទស៊ីសុវត្ថិ និង Résident Supérieur Ernest Outrey បានចុះហត្ថលេខាលើ ***ក្រមព្រហ្មទណ្ឌ*** ***ក្រមនីតិវិធីព្រហ្មទណ្ឌ*** និង ***ក្រមស្តីអំពីការរៀបចំតុលាការ*** ហើយចូលជាធរមាននៅឆ្នាំ១៩១២។[២០៨]

ក្នុងការគាក់តែងក្រមរដ្ឋប្បវេណីខ្មែរទំនើប បារាំងបានបង្កើតគណៈកម្មការចំនួន៥ ជាបន្តបន្ទាប់ ដើម្បីសិក្សាស្វែងយល់ពីសង្គមខ្មែរឱ្យបានច្បាស់ និងដើម្បីពិនិត្យមើលច្បាប់រដ្ឋប្បវេណីខ្មែរ ធ្វើយ៉ាងណាឱ្យសមស្របតាមបរិបទជាក់ស្តែងនៃសង្គមខ្មែរ។ កិច្ចការងារនេះ សម្រេចបានជាស្ថាពរនៅឆ្នាំ១៩២០ មានក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី និងការរៀបចំសាលាជំរះក្តីរដ្ឋប្បវេណី ដែលត្រូវបានប្រកាសឱ្យប្រើ។[២០៩] ក្រមរដ្ឋប្បវេណី មានចែងអំពីការគ្រប់គ្រងទ្រព្យសម្បត្តិឯកជន (ដី) អត្រានុកូលដ្ឋាន ។ល។[២១០] ក្រមនេះមាន

---

[២០៦] Bibliothèque de l'Association Henri Capitant, *"Histoire du Cambodge"*, 2016, p.13. ដូចគ្នាដែរ Béactrice Balivet, *"Introduction au droit cambodgien"* , Presses Universitaires du Cambodge 2005, p.12-13។ ក្នុងឆ្នាំ១៨៩៨ ច្បាប់សម័យមុនចំនួន៣៩ បានសរសេរដោយផ្ទាល់ដៃជាភាសានិងអក្សរខ្មែរ, វេទិកាជំនុំច្បាប់ខ្មែរ, កម្រងឯកសារសិក្សាសាកល្បងអំពីទស្សនវិជ្ជាច្បាប់ខ្មែរបែបទំនៀម, ២០២៥, ទំ. ៨។

[207] Sally Frances Low, *"Colonial law making : Cambodia under the French, Sally Frances Low"*, NUS Press [2024] Asian Studies Association, p.77.

[208] Bibliothèque de l'Association Henri Capitant, *"Histoire du Cambodge"*, 2016, p.15

[២០៩] គណៈកម្មការទាំង៥នេះ ត្រូវបានបង្កើតឡើងជាបន្តបន្ទាប់តាមព្រះរាជានុក្រឹត្យចំនួន៥ ដូចតទៅ៖ ព្រះរាជានុក្រឹត្យពីរចេញនៅឆ្នាំ១៩១២, ព្រះរាជានុក្រឹត្យឆ្នាំ១៩១៣, ព្រះរាជានុក្រឹត្យ១៩១៨ និងព្រះរាជានុក្រឹត្យ១៩១៩។

[210] Sally Frances Low, Colonial Law Making, Cambodia under the French, 2024, p.93.

១៣៦៥ មាត្រា មានបញ្ញត្តិអំពីច្បាប់ និងអនុភាពនៃច្បាប់ គន្លឹចំនួន៣ទៀតគឺ បញ្ញត្តិអំពីបុគ្គល (គន្លឹទី១) អំពីទ្រព្យ (គន្លឹទី២) និង អំពីកាតព្វកិច្ច (គន្លឹទី៣)។[២១១]

ជាលទ្ធផលគិតចាប់ពីឆ្នាំ១៨៨១ ក្រមចំនួន៣៩ ក្នុងចំណោម៥២ក្រមត្រូវបានផ្សព្វផ្សាយ។[២១២] ក្រមទាំងនេះ ត្រូវបានគេមើលឃើញថាជាកម្រងសេចក្តីរបស់ព្រះមហាក្សត្រ នាពេលសម្រេចក្តីក្នុងព្រះរាជសវនាការសាធារណៈ ហើយយកមកចងក្រងរៀបជាបណ្តុំ។[២១៣]

គេមិនបានដឹងជាក់លាក់អំពីនីតិវិធីធ្វើច្បាប់ ឬស្ថាប័នណាផ្តួចផ្តើមធ្វើច្បាប់ទេ ក៏ប៉ុន្តែអនុលោមតាមច្បាប់រដ្ឋធម្មនុញ្ញដំបូងរបស់កម្ពុជាឆ្នាំ១៩៤៧ (យកលំនាំតាមច្បាប់ធម្មនុញ្ញបារាំងឆ្នាំ១៩៤៦)[២១៤] មានចែងអំពីការបែងចែកអំណាច ដែលនេះបង្ហាញថាសភាជាស្ថាប័នរៀបចំធ្វើច្បាប់ ហើយព្រះមហាក្សត្រ ជាអ្នកឡាយព្រហស្តលេខាប្រកាសឲ្យប្រើច្បាប់។[២១៥]

យន្តការដោះស្រាយជម្លោះ៖ បារាំងបានបង្កើតស្ថាប័នតុលាការ និងព្រៃកយុត្តាធិការតុលាការជា ៣ផ្នែក ដោយផ្អែកទៅតាមជាតិសាសន៍។ ទី១. តុលាការសម្រាប់ជនជាតិបារាំង សម្រាប់ដោះស្រាយវិវាទដែលពាក់ព័ន្ធនឹងពលរដ្ឋបារាំងដែលរស់នៅក្នុងប្រទេសកម្ពុជា។ ទី២. តុលាការសម្រាប់ជនជាតិខ្មែរ សម្រាប់ដោះស្រាយវិវាទរវាងពលរដ្ឋខ្មែរនិង ទី៣. តុលាការចម្រុះ (Mixed Court)[២១៦] សម្រាប់ដោះស្រាយវិវាទរវាងពលរដ្ឋបារាំង/អឺរ៉ុប

---

[211] Sok Siphana, *"Analyse de la dualité juridique au Cambodge"*, Thèse de doctorat en droit international, le 27 juin 2022, p.38 ; Béactrice Balivet, *"Introduction au droit cambodgien"* , Presses Universitaires du Cambodge 2005, p.16

[212] Sok Siphana, *"Analyse de la dualité juridique au Cambodge"*, Thèse de doctorat en droit international, le 27 juin 2022, p.37 ; Béactrice Balivet, *"Introduction au droit cambodgien"* , Presses Universitaires du Cambodge 2005, p.14

[២១៣] Sok Siphana, *"Analyse de la dualité juridique au Cambodge"*, Thèse de doctorat en droit international, le 27 juin 2022, p.37។ សូមមើលកម្រងច្បាប់ខ្មែរតាមបែបបារាំង (ភាគ១និងភាគ២), ក្រុមប្រឹក្សានីតិកម្ម, ២០២៥។

[214] Sally Frances Low, Colonial Law Making, Cambodia under the French, 2024, p. 177.

[២១៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មាត្រា៣៦។

[២១៦] «Mixed Court» ឬ «តុលាការចម្រុះ», មាត្រា៧នៃសន្ធិសញ្ញាបារាំង ខ្មែរឆ្នាំ១៨៦៣ បានចែងថា តុលាការនេះកាត់ក្តីលើវិវាទរវាងពលរដ្ឋបារាំងនិងខ្មែរ។ ប៉ុន្តែក្រោយមកតាមរយៈព្រះរាជប្បញ្ញត្តិចុះថ្ងៃទី១ ខែមេសា ឆ្នាំ១៨៧៣ កំណែទម្រង់តុលាការចម្រុះនេះសំដៅលើវិវាទកើតឡើងរវាងពលរដ្ឋបារាំង/អឺរ៉ុប ជាមួយនឹងពលរដ្ឋខ្មែរ។ ក្នុងព្រះរាជប្បញ្ញត្តិនោះដែរ ព្រះបាទនរោត្តមបញ្ញត្តិបន្ថែមថា ចំពោះពលរដ្ឋជនជាតិអាស៊ី នឹងត្រូវស្ថិតក្រោមយុត្តាធិការតុលាការកម្ពុជាជាអ្នកកាត់ក្តី។ រហូតដល់ឆ្នាំ១៨៩៧ " Mixed Court" ឬ "តុលាការចម្រុះ" ត្រូវបានរំសាយចោល ហើយជនជាតិវៀតណាម និងជនជាតិចិនត្រូវចាត់ទុកជាជនបរទេស ហើយដាក់ស្ថិតក្រោមយុត្តាធិការរបស់បារាំង ប៉ុន្តែប្រើច្បាប់អាណ្ណាមនៃកូសាំងស៊ីន។ សូមមើល Sally Frances Low, *"Colonial law making : Cambodia under the French, Sally Frances Low"*, NUS Press [2024] Asian Studies Association, p.70-73

ជាមួយនឹងពលរដ្ឋខ្មែរ។[២១៧] គួរកត់សម្គាល់ថា ក្នុងករណីដែលពលរដ្ឋខ្មែរ មានវិវាទជាមួយបារាំង ឬប្តឹងបារាំង គឺត្រូវទៅប្តឹងនៅតុលាការសម្រាប់ជនជាតិបារាំង (បារាំងជាអ្នកកាត់ក្តី)។

នៅឆ្នាំ១៨៩៧ ***«Sala Outor»*** ឬ ***«សាលាឧទ្ធរណ៍»*** ត្រូវបានបង្កើតឡើង ក្រោមព្រះរាជប្បញ្ញត្តិចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧។ នៅឆ្នាំ១៩១២ ***«Sala Vinichhay»*** ឬ ***«សាលាវិនិច្ឆ័យ»*** (តុលាការកំពូល) បង្កើតឡើងនៅឆ្នាំ១៩១២។ ក្នុងឆ្នាំ១៩១២ នេះដដែល ***«Sala Okret»*** ឬ ***«សាលាឧក្រិដ្ឋ»*** ត្រូវបានបង្កើតឡើងសម្រាប់កាត់ក្តីរឿងព្រហ្មទណ្ឌ។ នៅឆ្នាំ១៩២២ បារាំងបានបង្កើតសាលាដំបូងចំនួន១៤ (*សាលាដំបូង ចំនួន១៣ នៅតាមបណ្តាខេត្ត និង សាលាលុយុតចំនួន១នៅភ្នំពេញ*) ដាក់ក្រោមអង្គតុលាការ ហើយលុបចោលតុលាការខេត្ត (Provincial Court) ចំនួន៥១ចោលដែលមានពីមុន។

នៅឆ្នាំ១៩២៣ ***«Sala Kromchot»*** ឬ ***«សាលាក្រមឈុត»*** ត្រូវបានបង្កើតឡើងមួយឆ្នាំមុនក្រមព្រហ្មទណ្ឌថ្មីផ្សព្វផ្សាយនៅឆ្នាំ១៩២៤ ភ្ជាប់ជាមួយនឹងសាលាឧទ្ធរណ៍។ ឆ្នាំ១៩៣២ វិជ្ជាជីវៈស្មាក្តី (មេធាវី) ត្រូវបានបង្កើត។[២១៨] បន្ទាប់មកនៅឆ្នាំ១៩៣៣ ***«Sala Krom Viveat»*** ឬ ***«សាលាក្រមវិវាទ»*** ដែលជាអង្គរដ្ឋបាល ត្រូវបានបង្កើតតាមរយៈព្រះរាជប្បញ្ញត្តិឆ្នាំ១៩៣៣ ដើម្បីដោះស្រាយលើវិវាទរដ្ឋបាល។ រីឯមូលដ្ឋានរបស់តុលាការក្នុងការកាត់សេចក្តីគឺផ្អែកទៅតាមក្រម និងច្បាប់សរសេរ ខណៈស្ថាប័នមានសមត្ថកិច្ចក្នុងការកាត់រឿក្តីរវាងពលរដ្ឋខ្មែរ គឺតុលាការខ្មែរជាអ្នកមានសមត្ថកិច្ចពេញលេញក្នុងការកាត់សេចក្តី។

ទិន្នន័យសំណុំរឿងចន្លោះឆ្នាំ១៩២៤ ដល់ ១៩២៦ និងឆ្នាំ១៩៣៦ ដល់ ១៩៣៩ បង្ហាញថាតុលាការសម័យនោះ មានសាលាវិនិច្ឆ័យ សាលាចោទប្រកាន់ (mises en accusation) សាលាដំបូង(ក្នុង១៤ខេត្ត) និងសាលាឧទ្ធរណ៍។[២១៩]

កំណត់សំគាល់: តាមសម្រង់ខាងលើ មានការទទួលស្គាល់ថា មុនសម័យអាណាព្យាបាលបារាំងចាប់ពីឆ្នាំ១៨៦៣ កម្ពុជាមានច្បាប់ ឬទំនៀមទម្លាប់ ក៏ប៉ុន្តែមិនមានការចងក្រងជាប្រព័ន្ធ ទើបជម្រុញឲ្យមានការតាក់តែងចងក្រងដោយបារាំង ហើយឆ្លៀតឱកាសនោះបារាំង បានដាក់បញ្ញត្តិមួយចំនួនក្នុងប្រព័ន្ធច្បាប់កម្ពុជា ជាពិសេសវិស័យស៊ីវិល (ពាណិជ្ជកម្ម ឬគ្រួសារ)។ ក្នុងសម័យនោះ ជាទូទៅគេហៅថាក្រម ដែលមានប្រមាណ

---

[២១៧] មាត្រា៧, *"សន្ធិសញ្ញារវាង ព្រះចៅអធិរាជបារាំង និង ព្រះមហាក្សត្រខ្មែរសន្ធិសញ្ញាឧត្តុង"*, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដើម្បីកំណត់លក្ខខណ្ឌអាណាព្យាបាលបារាំងលើប្រទេសកម្ពុជា។

[218] Bar Association of the Kingdom of Cambodia, Legal Profession in Cambodia, 2005, p. 14.

[219] Sally Frances Low, Colonial Law Making, Cambodia under the French, 2024, pp.138-139.

ជិត៥០ ទោះបីជាក្រមខ្លះមិនមានលក្ខណៈលម្អិត។ ច្បាប់រដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ មុនឯករាជ្យឆ្នាំ១៩៥៣ បានបង្ហាញថា សភាជាអ្នកធ្វើច្បាប់ក្នុងចំណោមអំណាចទាំងបី។ ច្បាប់ក៏តម្រូវឲ្យមានបោះពុម្ពក្នុងរាជកិច្ចដែរ។

យន្តការដោះស្រាយជម្លោះ មានបីកម្រិតលើវិស័យព្រហ្មទណ្ឌ និងស៊ីវិល និងមានការញែកសមត្ថកិច្ចអាស្រ័យទៅតាមជម្លោះរវាងជនជាតិខ្មែរ ឬបារាំង។ នេះកើតមុនសម័យឯករាជ្យ។ ឆ្នាំ១៩៣២ វិជ្ជាជីវៈស្មាក្តី ត្រូវបានបង្កើត និងពង្រឹងជាបន្តបន្ទាប់ក្នុងឆ្នាំ១៩៥១។

២.២. សម័យសង្គមរាស្ត្រនិយម ១៩៥៣ ដល់ ១៩៧០

ឆ្នាំ១៩៥៣ ព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យ។ ព្រះមហាក្សត្រ បានចាប់ផ្តើមកែសម្រួលច្បាប់ឲ្យមានលក្ខណៈខ្មែរ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧ ត្រូវបានរៀបចំឡើង ទោះបីជាយ៉ាងនេះក្តី គ្រាន់តែកែសម្រួលខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧។

ក្រមពាណិជ្ជកម្មឆ្នាំ១៩៥០ ត្រូវបានធ្វើវិសោធនកម្មត្រង់ផ្នែកទី២ ស្តីអំពីក្រុមហ៊ុនពាណិជ្ជកម្ម ដើម្បីដំរុញការអនុវត្តរបស់ក្រុមហ៊ុន។ ដូចគ្នាដែរ ក្នុងដំណាក់កាលនេះ ក៏ជាសក្តីភាពនៃការអភិវឌ្ឍវិស័យការងារ តាមរយៈការប្រកាសឱ្យប្រើក្រមការងារ (Code de travail) នៅឆ្នាំ១៩៦០។ ក្នុងសម័យសង្គមរាស្ត្រនិយម កម្ពុជាបានចាប់ផ្តើមមានទំនាក់ទំនងជាមួយស្ថាប័នអន្តរជាតិ ដោយបានចូលជាភាគីសន្ធិសញ្ញាអន្តរជាតិមួយចំនួនពាក់ព័ន្ធនឹងច្បាប់សមុទ្រក្នុងឆ្នាំ១៩៥៨។ ឆ្នាំ១៩៦៩ កម្ពុជាក៏បានចូលជាសមាជិកនៅក្នុងអង្គការពលកម្មអន្តរជាតិ (ILO/OIT) និងបានផ្តល់សច្ចាប័នលើអនុសញ្ញាលេខ៤ ស្តីពីការងារពេលយប់របស់ស្ត្រី អនុសញ្ញាលេខ៦ ស្តីពីការងារពេលយប់របស់មនុស្សក្នុងវិស័យឧស្សាហកម្ម អនុសញ្ញាលេខ១៣ ស្តីពីសំណកាបូណាត និង អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧ ចែងថា ច្បាប់ជាសេចក្តីសំដែងឆន្ទៈរបស់ប្រជាជាតិ[២២០]។ សភា (អំណាចនីតិបញ្ញត្តិ) ព្រះមហាក្សត្រ គណៈរដ្ឋមន្ត្រី សមាជិកនៃរដ្ឋសភា និងសមាជិកនៃក្រុមប្រឹក្សារាជអាណាចក្រ មានសិទ្ធិផ្តើមគំនិតតែងច្បាប់។[២២១] មិនមានព័ត៌មានស្តីពីនីតិវិធីតាក់តែងលិខិតបទដ្ឋានគតិយុត្តទេក៏ប៉ុន្តែតាមរដ្ឋធម្មនុញ្ញ ក្រុមប្រឹក្សាព្រះរាជអាណាចក្រពិនិត្យ ហើយឲ្យយោបល់ លើសេចក្តីព្រាងច្បាប់និងសេចក្តីស្នើច្បាប់

[២២០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា១៧។
[២២១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា២២។

ដែលរដ្ឋសភាបានបញ្ចេញមតិយល់ព្រម។ ព្រះមហាក្សត្រ ទ្រង់ប្រកាសឲ្យប្រើច្បាប់ទាំងឡាយ[២២២] ក្រោយឆ្លងនីតិវិធីដូចមានកំណត់ក្នុងមាត្រា ៨៣ រួចរាល់។ រដ្ឋសភាត្រូវពិភាក្សាសេចក្តីព្រាងច្បាប់ ដោយបើកចំហដល់មហាជនលើកលែងសម្រេចប្រជុំជាសំងាត់។ ពាក្យរាយការណ៍ក្នុងកិច្ចប្រជុំចំហ ត្រូវចុះក្នុងរាជកិច្ច[២២៣]ត្រូវបោះពុម្ពក្នុងរាជកិច្ច។[២២៤]

ច្បាប់ដែលត្រូវបានរៀបចំមានដូចជា ក្រមព្រហ្មទណ្ឌឆ្នាំ១៩៥៥ ដែលត្រូវបានកែសម្រួលក្នុងឆ្នាំ១៩៥៦ (មាន៥៤០មាត្រា) ច្បាប់ហាមឃាត់ល្បែងស៊ីសងឆ្នាំ១៩៥៥[២២៥] ច្បាប់ស្តីពីការបំបិទផ្ទះបនស្រីពេស្យាឆ្នាំ១៩៦១[២២៦] ក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ និងច្បាប់ស្តីពីការបាត់សញ្ជាតិឆ្នាំ១៩៦៨។[២២៧]

សាលាជំរះក្តីគ្រប់ជាន់ ជាអង្គនៃអំណាចតុលាការ[២២៨]។ តុលាការមានក្រុមប្រឹក្សាជាន់ខ្ពស់ ដែលធានាវ៉ាប់រងលើវិន័យនៃចៅក្រម៖ *ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការដោយអនុលោមតាមច្បាប់ ត្រូវធានារ៉ាប់រងចំពោះវិន័យនិងឥស្សរភាពនៃចៅក្រម*។[២២៩] តាមរយៈនេះ តុលាការសឹក ដែលជាតុលាការពិសេស ត្រូវបានបង្កើតក្នុងឆ្នាំ១៩៥៩។ តុលាការរាស្ត្រ ត្រូវបានបង្កើតក្នុងឆ្នាំ១៩៦៤ មានសមត្ថកិច្ចពិនិត្យមើលសំណុំរឿងពុករលួយជាដើម។[២៣០]

សាលាក្តីចែកជាសាលាក្តីជាន់ទាប រួមមាន ១.សាលាលហុ ២. សាលាលហុមានសមត្ថកិច្ចធំទូលាយ ៣. សាលាស៊ើបសួរនិងទី៤សាលាដំបូង) និងសាលាក្តីជាន់ខ្ពស់ រួមមាន ១. សាលាឧក្រិដ្ឋ ២. សាលាក្រុមចោទនិងទី៣ សាលាវិនិច្ឆ័យ។[២៣១]

---

[២២២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា៣៦។

[២២៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា៧២។

[២២៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា១៩។

[២២៥] វ៉ែត កាលីន និងកុល ស្រីមាន អំពើសញ្ជរកម្ម ឆ្នាំ២០១៧, ទំ.៧។

[២២៦] វ៉ែត កាលីន និងកុល ស្រីមាន អំពើសញ្ជរកម្ម ឆ្នាំ២០១៧, ទំ.៧។

[២២៧] វ៉ែត កាលីន និងកុល ស្រីមាន អំពើសញ្ជរកម្ម ឆ្នាំ២០១៧,ទំ.៧។

[២២៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា២៤។

[២២៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧, មាត្រា១១៤។

[២៣០] ទី សុផល, របបសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) https://online.fliphtml5.com/kthii/jvik/#p=1 (Accessed on ៨ Oct ២០២៥)។

[២៣១] ហ៊ែល សុំដា របៀបរៀបចំខាងតុលាការនៅសម័យសង្គមរាស្ត្រនិយម ១៩៥៣-១៩៧០, ទំ. ៥៩៧។

កំណត់សំគាល់៖ តាមខ្លឹមសាររដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧ យន្តការតាក់តែងច្បាប់មានភាពជាក់លាក់ខ្លះ តាំងពីការផ្តួចផ្តើមរហូតដល់ច្បាប់ត្រូវបានបោះពុម្ពក្នុងរាជកិច្ច។ ក្នុងដំណើរនេះ សាធារណជនអាចចូលរួមបានក្នុងករណីមិនមែនជាការប្រជុំរៀបចំច្បាប់ជាសម្ងាត់។ ក្នុងសម័យនោះ ច្បាប់ក៏មានរាប់បញ្ចូលនូវសមាសភាគច្បាប់អន្តរជាតិ។

យន្តការដោះស្រាយជម្លោះ ហាក់មិនមានអ្វីប្លែកខុសពីយន្តការចន្លោះឆ្នាំ១៩៤៧ ដល់១៩៥៣ ដោយគ្រាន់តែបន្ថែមតុលាការរាស្ត្រនិងតុលាការពិសេស។ អ្វីជាការកត់សំគាល់ មានការបង្កើតនូវ ក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការ ដើម្បីធានានូវការគោរពក្រមសីលធម៌របស់ចៅក្រម។

២.៣. សម័យសាធារណរដ្ឋខ្មែរ ១៩៧០ ដល់ ១៩៧៥

ក្រោយពីឆ្នាំ១៩៥៣ ដូចដែលបានបង្ហាញខាងលើ ប្រព័ន្ធច្បាប់កម្ពុជា លែងស្ថិតក្នុងដៃអាណាព្យាបាលហើយ។ នេះក្នុងន័យថា កម្ពុជាជាអ្នកសម្រេចប្រភេទនៃប្រព័ន្ធច្បាប់។ ក្រៅពីមិនបានបន្ថែមច្បាប់មួយចំនួន ថ្នាក់ដឹកនាំរវល់ខ្វល់និងការកសាងសេដ្ឋកិច្ច ស្របពេលប្រឈមនឹងនិន្នាការរបត់នៃនយោបាយការបរទេសមកលើការដឹកនាំកម្ពុជា។ ចលនាកំមុយនីស្ត និងសេរី (ប្រជាធិបតេយ្យ) កើតមានក្នុងកម្ពុជា បង្កជាស្ថានភាពតានតឹងប្រឈមគ្នានៃមេដឹកនាំ។ ចុងបញ្ចប់នាំទៅរកការធ្វើរដ្ឋប្រហារក្នុងឆ្នាំ១៩៧០។ ចាប់ពីពេលនេះមក របបដឹកនាំនៅកម្ពុជា ជារបបសាធារណរដ្ឋ ខុសពីប្រព័ន្ធដឹកនាំបែបសភានិយមពីមុន។ របបនេះ យកលំនាំតាមសហរដ្ឋអាម៉េរិក។ នេះឆ្លុះបញ្ចាំងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៧២[២៣២] ដែលបង្កប់នូវការប្រែប្រួលលើធាតុផ្សំនៃប្រព័ន្ធច្បាប់ រាប់តាំងពីស្ថាប័នធ្វើច្បាប់និងរបៀបរៀបចំច្បាប់។

អំណាចគ្រប់យ៉ាងចេញពីរាស្ត្រនិងមានអំណាចបីប្រភេទ គឺនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងអំណាចតុលាការ[២៣៣]។ ច្បាប់ជាការសំដែងនៃឆន្ទៈជាតិ[២៣៤]។ អំណាចផ្តើមធ្វើច្បាប់មិនខុសពីសម័យមុន។ រដ្ឋាភិបាល សមាជិកសហសភា ជាអ្នកផ្តើមគំនិតបង្កើតច្បាប់[២៣៥]។ បន្ថែមពីលើនេះ ក្រុមប្រឹក្សារដ្ឋ ក៏ចូលរួមក្នុងកិច្ចតាក់តែងច្បាប់ផង

---

[២៣២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា១។ Nop Kanharith, legal development in Cambodia before and after Japanese Assistance, Microsoft Word - Legal and Judicial Development.doc, p.1.

[២៣៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៣។

[២៣៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៦៥។

[២៣៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៦៦។

ដែរ[២៣៦]។ ដោយសារជារបបប្រធានាធិបតី ដូចនេះ អត្ថបទច្បាប់ដែលសហសភា បានអនុម័តជាស្ថាពរ ត្រូវបញ្ជូនទៅប្រធានាធិបតីចុះហត្ថលេខា។[២៣៧] ច្បាប់នោះ ត្រូវចុះក្នុងរដ្ឋកិច្ច ត្រូវផ្សព្វផ្សាយជ្រួតជ្រាបទូលំទូលាយជាទីបំផុត។ រដ្ឋាភិបាល មានភារៈចុះផ្សាយច្បាប់ក្លាម។ ច្បាប់មួយត្រូវកំណត់បែបបទនៃការផ្សាយច្បាប់និងបទបញ្ជានានា និងការផ្សាយកិច្ចព្រមព្រៀងអន្តរជាតិ។[២៣៨]

បន្ថែមលើការយោងដល់កិច្ចព្រមព្រៀង ខុសពីសម័យកាលមុន រដ្ឋធម្មនុញ្ញ បានចែងជាលើកដំបូងពាក់ព័ន្ធច្បាប់អន្តរជាតិ ដោយចែងថា ប្រធាននាធិបតី មានសិទ្ធិចុះហត្ថលេខាលើសន្ធិសញ្ញា អនុសញ្ញា និងផ្តល់សច្ចាប័នដោយអាស្រ័យលើការអនុម័តដោយសហសភា (សភានិងព្រឹទ្ធសភា)៖ *ប្រធានាធិបតីនៃសាធារណៈរដ្ឋ ចុះហត្ថលេខាលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិ ហើយអោយសច្ចាប័នលើឯកសារទាំងនេះ ដោយអាស្រ័យការអនុម័តិនៃសហសភា*[២៣៩]។

សម្រាប់យន្តការនៃការដោះស្រាយជម្លោះ ខ្លឹមសារក៏មានបទប្បញ្ញតិថ្មីនិងខុសគ្នាដែរ។ យន្តការមានភាពជាក់លាក់និងមានច្រើនប្រភេទ។ តុលាការការពារសិទ្ធិប្រជាពលរដ្ឋទាំងអស់។[២៤០] ប្រជាពលរដ្ឋទាំងអស់ មានសិទ្ធិប្តឹងតវ៉ាប្រឆាំងជាសាធារណ ឲ្យតែក្នុងទម្រង់អហិង្សា[២៤១]។ អំណាចនេះ ត្រូវប្រគល់ដល់តុលាការកំពូលនិងសាលាជំរះក្តីគ្រប់ជាន់ថ្នាក់។[២៤២] ការកាត់ក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមប្រជារាស្ត្រនិងតាមនីតិក្រម។[២៤៣] ចៅក្រមជំរះក្តីនិងចៅក្រមអយ្យការ មានលក្ខន្តិកៈដោយឡែកពីគ្នា ដែលខាងក្រោយនេះស្ថិតនៅក្រោមការត្រួតត្រានៃរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។[២៤៤] រីឯចៅក្រមជំរះក្តី ស្ថិតនៅក្រោមតុលាការកំពូល។[២៤៥] មានឧត្តមក្រុមប្រឹក្សាតុលាការ ទទួលភារៈដាក់ពិន័យលើចៅ

---

[២៣៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា១០៤។
[២៣៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៧១។
[២៣៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៧៣។
[២៣៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៣៨។
[២៤០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៦។
[២៤១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩។
[២៤២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៨១។
[២៤៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៨០។
[២៤៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៨៣ និង៨៥។
[២៤៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៨៤។

ក្រម[២៤៦] ហើយក្រុមប្រឹក្សានេះស្ថិតក្រោមអធិបតីនៃប្រធានាធិបតី[២៤៧]។ ក្រៅពីតុលាការធម្មតា មានការបង្កើតតុលាការជាន់ខ្ពស់ សម្រាប់ជំនុំជម្រះប្រធានាធិបតី៖ *តុលាការជាន់ខ្ពស់ មានអំណាចជំនុំជម្រះប្រធានាធិបតីនៃសាធារណៈរដ្ឋ អនុប្រធានាធិបតីនៃសាធារណរដ្ឋ សមាជិករដ្ឋាភិបាល សមាជិកសហសភា សមាជិកតុលាការធម្មនុញ្ញនិងសមាជិកតុលាការកំពូលពីបទឧក្រិដ្ឋនិងមជ្ឈិម ដែលបានប្រព្រឹត្តក្នុងពេលបំពេញមុខងាររៀងៗខ្លួន*[២៤៨]។ តុលាការធម្មនុញ្ញមានសមត្ថកិច្ច បកស្រាយជាចុងក្រោយនៃបទប្បញ្ញត្តិធម្មនុញ្ញ[២៤៩] ច្បាប់ដែលត្រូវបានប្រកាសថាមិនត្រឹមត្រូវតាមធម្មនុញ្ញ មិនអាចប្រកាសឲ្យប្រើនិងអនុវត្ត។[២៥០] សម្រាប់វិវាទរដ្ឋបាល ក្រុមប្រឹក្សារដ្ឋជាតុលាការកាត់ក្តី។[២៥១]

កំណត់សំគាល់៖ របៀបរបបនៃការតាក់តែងច្បាប់ មានលក្ខណៈខុសគ្នាបន្តិចដោយសារជារបបសាធារណរដ្ឋ ដែលមានប្រធានាធិបតី។ ប្រធានាធិបតី ជាអ្នកប្រកាសចុះហត្ថលេខាប្រកាសឲ្យប្រើច្បាប់។ ច្បាប់ក្នុងន័យនោះ ក៏មានធាតុផ្សំនៃច្បាប់អន្តរជាតិ (សន្ធិសញ្ញា) ដែលប្រធានាធិបតី ជាអ្នកចុះហត្ថលេខា។ ជាលើកទីមួយ ដែលមានបទប្បញ្ញត្តិគន្លឹះពាក់ព័ន្ធនឹងច្បាប់អន្តរជាតិក្នុងរដ្ឋធម្មនុញ្ញ។

យន្តការដោះស្រាយជម្លោះ មានលក្ខណៈប្លែកខុសពីសម័យមុន ដោយសារមានតុលាការសម្រាប់វិនិច្ឆ័យលើកំហុសរបស់ប្រធានាធិបតី។ ពិសេសជាងនេះទៀត មានតុលាការធម្មនុញ្ញ ដែលមានសមត្ថកិច្ច បកស្រាយរដ្ឋធម្មនុញ្ញ (នេះជាធាតុផ្សំមួយនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង)។

២.៤. សម័យកម្ពុជាប្រជាធិបតេយ្យ ១៩៧៥ ដល់ ១៩៧៩

ក្រុមខ្មែរក្រហមបានទទួលបានជ័យជំនះក្នុងឆ្នាំ១៩៧៥ និងបានបង្កើតរបបកម្ពុជាប្រជាធិបតេយ្យជារបបសង្គមនិយម ឈានឆ្ពោះទៅរបបកំមុនីស្ត[២៥២]។ របបនេះ មាន

---

[២៤៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩១។
[២៤៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩០។
[២៤៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩៧។
[២៤៩]រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩៥។
[២៥០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា៩៥។
[២៥១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧២, មាត្រា១០៤។
[252] Jörg Menzel, "Cambodian Law: Some Comparative and International Perspectives," in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), 484, https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf

បង្កើតរដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦ បានបង្កើតសភាប្រជាជនតុលាការ ក៏ប៉ុន្តែជាក់ស្តែង មិនមានដំណើរការទេ។ ក្រៅពីមិនបានរៀបចំច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត របបនេះមិនទទួលបន្តអនុវត្តច្បាប់ក្នុងសម័យមុន និងថែមទាំងបានបំផ្លាញប្រព័ន្ធច្បាប់ទៀត។[២៥៣]

រដ្ឋធម្មនុញ្ញបានចែងថា រដ្ឋកម្ពុជាជារដ្ឋឯករាជ្យ ជារបស់ប្រជាជន កម្មករ...មានឈ្មោះជាផ្លូវការថាកម្ពុជាប្រជាធិបតេយ្យ[២៥៤]។ អំណាចធ្វើច្បាប់ជាអំណាចរបស់សភាតំណាងប្រជាជន កម្មករ ។[២៥៥] សភាតំណាងប្រជាជនមានភារៈសំរេចច្បាប់ៈ *សភាតំណាងប្រជាជន មានភារៈសំរេចច្បាប់និងកំនត់មាគ៌ានយោបាយផ្សេងៗក្នុងប្រទេសនិងក្រៅប្រទេសរបស់កម្ពុជាប្រជាធិបតេយ្យ*។[២៥៦] *រីឯរដ្ឋាភិបាល ជាអង្គការមានភារកិច្ចអនុវត្តច្បាប់ រដ្ឋាភិបាល ជាអង្គការមានភារកិច្ចអនុវត្តច្បាប់និងអនុវត្តមាគ៌ានយោបាយទាំងអស់របស់សភាតំណាងប្រជាជនកម្ពុជា...*។[២៥៧] តុលាការជារបស់ប្រជាជន មានគ្រប់ជាន់ថ្នាក់ជ្រើសរើសនិងតែងតាំងដោយសភាតំណាងប្រជាជន។[២៥៨]

២.៥. សម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ១៩៧៩ ដល់ ១៩៨៩

ក្រោយពីរបបកម្ពុជាប្រជាធិបតេយ្យបរាជ័យ របបសាធារណរដ្ឋប្រជាមានិតកម្ពុជាត្រូវបានបង្កើតឡើងក្នុងឆ្នាំ១៩៧៩។ របបនេះ បានដាក់ចេញនូវរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១។ ច្បាប់រងេតទ្ធិពលពីរបបកំមុនីស្តសហភាពសូវៀត។ អ្វីគួរឲ្យកត់សំគាល់ ទ្រព្យសម្បត្តិឯកជន មិនត្រូវបានទទួលស្គាល់។ អចលនៈវត្ថុ ដូចជាដី ជាសម្បត្តិរបស់រដ្ឋ។

ប្រទេសកម្ពុជា មានឈ្មោះជាផ្លូវការថាសាធារណរដ្ឋប្រជាមានិតកម្ពុជា[២៥៩]។ សេដ្ឋកិច្ចជាតិស្ថិតនៅក្រោមការគ្រប់គ្រងរបស់រដ្ឋ។[២៦០] ទ្រព្យសម្បត្តិជាកម្មសិទ្ធិរបស់រដ្ឋ

---

[253] Dolores A. Donovan, Rebuilding Cambodia: Human Resources, Human Rights and Law (Cambodia: Building a Legal System from Scratch),1992, p. 445; Dolores A. Donovan, Cambodia: Building a Legal System from Scratch, 27 INT'L L. 445 (1993) https://scholar.smu.edu/til/vol27/iss2/8; Basil Fernando, Problem Facing the Cambodian Legal System, 1998, p. 102.

[២៥៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦, មាត្រា១។

[២៥៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦, មាត្រា៥។

[២៥៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦,មាត្រា៧។

[២៥៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦, មាត្រា៨។

[២៥៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៧៦, មាត្រា៩។

[២៥៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា១។

[២៦០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា១១។

មានដីធ្លី...[២៦១] ពលរដ្ឋមានសិទ្ធិពេញទីក្នុងការប្រើប្រាស់និងមានសិទ្ធិមរតកលើដី ដែលរដ្ឋប្រគល់អោយ។[២៦២]

ស្រដៀងនឹងសម័យកាលមុន រដ្ឋសភាជាអង្គភាពតែមួយគត់ ដែលមានសិទ្ធិធ្វើច្បាប់។[២៦៣] មានស្ថាប័នជាច្រើន ដូចជា ក្រុមប្រឹក្សារដ្ឋ[២៦៤] ក្រុមប្រឹក្សារដ្ឋមន្ត្រី[២៦៥] គណៈកម្មការនានារបស់រដ្ឋសភា....មានសិទ្ធិធ្វើសេចក្តីព្រាងច្បាប់។[២៦៦] ក្រុមប្រឹក្សារដ្ឋ ត្រូវប្រកាសជាសាធារណៈឲ្យប្រើច្បាប់ ដែលរដ្ឋសភាបានអនុម័តរួច ។[២៦៧] ក្រុមប្រឹក្សារដ្ឋ ជាអង្គការអចិន្ត្រៃយ៍របស់រដ្ឋសភា ក្រៅពីប្រកាសច្បាប់មានសិទ្ធិបកស្រាយច្បាប់ និងចេញក្រឹត្យ-ច្បាប់ និងក្រឹត្យ។[២៦៨] តាមខ្លឹមសារនេះ ខុសពីសម័យមុនដែលប្រកាន់របបរាជានិយម មានព្រះមហាក្សត្រឡាយព្រះហស្តលេខា ក្រុមប្រឹក្សារដ្ឋទទួលភារៈនេះ។ វាជាលើកទីមួយក្នុងរដ្ឋធម្មនុញ្ញ ដែលចាប់ផ្តើមលឺពាក្យ ***«ក្រឹត្យ»*** ក្នុងប្រភេទនៃលិខិតបទដ្ឋានគតិយុត្ត។ តាមរយៈការស្រាវជ្រាវជាបឋម ក្នុងសម័យសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមានយ៉ាងតិចច្បាប់ចំនួន១០ និងក្រឹត្យច្បាប់ចំនួន២២ ត្រូវបានរៀបចំឡើង។

បន្ថែមពីលើនេះ រដ្ឋសភាមានភារកិច្ចត្រួតពិនិត្យការអនុវត្តន៍រដ្ឋធម្មនុញ្ញ និងការអនុវត្តច្បាប់ អោយសច្ចាប័ន ឬលុបចោលសន្ធិសញ្ញាអន្តរជាតិ ក្នុងករណីដែលក្រុមប្រឹក្សារដ្ឋជូនរដ្ឋសភាសំរេច[២៦៩]។ តាមមាត្រា៦០ ការងារអោយសច្ចាប័នត្រូវបានផ្ទុកផ្តាក់ដល់ក្រុមប្រឹក្សារដ្ឋ។

ក្រុមប្រឹក្សារដ្ឋមន្ត្រី គឺជារដ្ឋាភិបាល មានភារកិច្ចអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យ-ច្បាប់ អនុសញ្ញាទាំងឡាយ ផ្តាកការអនុវត្ត កែប្រែ ឬលុបចោលអនុសញ្ញា និងសេចក្តី

---

[២៦១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា១៤។
[២៦២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា១៥។
[២៦៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៤៥។
[២៦៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៥៩។
[២៦៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៦៦។
[២៦៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៥៣។
[២៦៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៥៥។
[២៦៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៦០។
[២៦៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៤៨។

ណែនាំមិនសមស្របរបស់រដ្ឋមន្ត្រី។ មាត្រា៦៦៖ [២៧០] រដ្ឋធម្មនុញ្ញជាច្បាប់កំពូលដែលច្បាប់ទាំងអស់ត្រូវស្របតាម[២៧១]។

ការជំរះក្តី ស្ថិតនៅក្នុងដៃតុលាការ ដែលមានសាលាជំរះក្តីនិងអយ្យការ[២៧២] ។ ក្រៅពីតុលាការធម្មតា មានតុលាការយោធា។ តុលាការពិសេស ក៏អាចត្រូវបានបង្កើតផងដែរដោយក្រុមប្រឹក្សារដ្ឋ ដើម្បីជំនុំជំរះរឿងដែលមានលក្ខណៈពិសេស[២៧៣]។ ការជំរះក្តីត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់។ ក្នុងដំណើរការសកម្មភាពតុលាការ មានទីប្រឹក្សាប្រជាជន ដែលមានសិទ្ធិស្មើនឹងចៅក្រម។[២៧៤] អនុលោមតាមខ្លឹមសារនេះ ឆ្នាំ១៩៨២ តុលាការខេត្ត ត្រូវបានបង្កើតឡើងនិង តុលាការកំពូលត្រូវបានបង្កើតក្នុងឆ្នាំ១៩៨៧។

កំណត់សំគាល់៖ ឆ្លងកាត់របបសាធារណរដ្ឋ រួចធ្លាក់ចូលក្នុងរបបសង្គមនិយមដែលប្រព័ន្ធច្បាប់ ត្រូវបានបំផ្លាញចោលទាំងស្រុង របបក្រោយឆ្នាំ១៩៧៩ ជារបបសង្គមនិយម ដែលកាន់តែចាកឆ្ងាយពីប្រព័ន្ធច្បាប់នៃសម័យអាណាព្យាបាល។ ពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ (ក្រៅអំពីសមត្ថកិច្ចធ្វើច្បាប់) ច្បាប់រដ្ឋធម្មនុញ្ញ បានចែងជាក់លាក់ជាងៈ រដ្ឋាភិបាលជាអង្គអនុវត្តច្បាប់ រដ្ឋធម្មនុញ្ញ និងសន្ធិសញ្ញា រីឯរដ្ឋសភា ជាអង្គត្រួតពិនិត្យលើការអនុវត្តច្បាប់ និងបកស្រាយច្បាប់ផងដែរ។ ច្បាប់មានរដ្ឋធម្មនុញ្ញ ដែលជាច្បាប់កំពូល។ គួរឲ្យកត់សំគាល់ផងដែរថា ក្នុងប្រព័ន្ធច្បាប់ យើងចាប់ផ្តើមលឺពាក្យ ***«ក្រឹត្យ»***។

ចំពោះយន្តការដោះស្រាយជម្លោះវិញ ក្រៅពីតុលាការធម្មតា មានតុលាការយោធា និងតុលាការពិសេស។ តុលាការខេត្ត និងកំពូលត្រូវបានបង្កើតក្នុងឆ្នាំ១៩៨២ និង១៩៨៨ ដោយច្បាប់ និងក្រឹត្យច្បាប់ របស់រាជរដ្ឋាភិបាល។

២.៦. សម័យរដ្ឋកម្ពុជា ១៩៨៩ ដល់ ១៩៩៣

របបសាធារណរដ្ឋប្រជាមានិតកម្ពុជា មានសន្តិភាពផ្ទៃក្នុង ក៏ប៉ុន្តែនៅមានសង្គ្រាមតាមបណ្តាព្រំដែនជាមួយកងកម្លាំងនៃរបបកម្ពុជាប្រជាធិបតេយ្យ។ ឆ្នាំ១៩៩១ ក្រោយពីមានការជ្រោមជ្រែងពីប្រទេសជាមិត្ត កិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ត្រូវបានចុះ

[២៧០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៦៦។
[២៧១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៩១។
[២៧២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៧៩។
[២៧៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៨០។
[២៧៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨១, មាត្រា៨២។

ហត្ថលេខា។ ខ្លឹមសារនៃកិច្ចព្រមព្រៀង ក្រៅពីបានចែងបញ្ចប់សង្គ្រាម បានដាក់បញ្ចូលធាតុផ្សំប្រជាធិបតេយ្យនិងសិទ្ធិមនុស្ស។ របបរដ្ឋកម្ពុជា ត្រូវបានបង្កើតឡើង ជាមួយការអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ ដោយគ្រាន់តែកែសម្រួលបន្ថែមខ្លឹមសារមួយចំនួនលើរដ្ឋធម្មនុញ្ញឆ្នាំ១៩៨១។[២៧៥]

តាមខ្លឹមសារនៃមាត្រា១ ប្រទេសកម្ពុជាមានឈ្មោះជាផ្លូវការគឺ រដ្ឋកម្ពុជា។ រដ្ឋកម្ពុជាអនុវត្តរបបនយោបាយពហុបក្ស។[២៧៦] ពលរដ្ឋកម្ពុជា មានសិទ្ធិពេញទីក្នុងការកាន់កាប់និងប្រើប្រាស់ដីធ្លី[២៧៧]។ ប្រជាពលរដ្ឋ មានសិទ្ធិជាច្រើនប្រភេទ ដូចជាសិទ្ធិការពារខ្លួនតាមផ្លូវតុលាការ ហើយទោសប្រហារជីវិតត្រូវបំបាត់ចោល [២៧៨]។

រដ្ឋសភាជាអង្គការតែមួយគត់ដែលមានសិទ្ធិធ្វើច្បាប់[២៧៩]។ គណៈកម្មាធិការអចិន្ត្រៃយ៍នៃរដ្ឋសភា មានសិទ្ធិផ្តើមធ្វើសេចក្តីព្រាងច្បាប់។[២៨០] មានស្ថាប័នជាច្រើន ដូចជា ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី គណៈកម្មការនានារបស់រដ្ឋសភា ប្រធានតុលាការប្រជាជនកំពូល .....មានសិទ្ធិធ្វើសេចក្តីព្រាងច្បាប់ជូនរដ្ឋសភា។[២៨១] ច្បាប់ដែលត្រូវបានអនុម័តដោយរដ្ឋសភា ត្រូវចុះក្នុងរាជកិច្ច និងផ្សព្វផ្សាយនៅទូទាំងប្រទេស។[២៨២] ក្រុមប្រឹក្សារដ្ឋមន្ត្រី ធ្វើសេចក្តីព្រាងច្បាប់និងសេចក្តីព្រាងផ្សេងៗ ជូនរដ្ឋសភា[២៨៣]។

ក្រុមប្រឹក្សារដ្ឋ ប្រកាសឲ្យប្រើច្បាប់និងចេញក្រឹត្យ។ វាអាចជាក្រឹត្យតែងតាំងសមាជិករដ្ឋសភា ក្រឹត្យប្រកាសឲ្យប្រើច្បាប់ ឬឲ្យសច្ចាប័នលើសន្ធិសញ្ញានិងអនុសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាល ក្រោយពីរដ្ឋសភាបានអនុម័ត។[២៨៤] ក្នុងសម័យកាលនេះ មានការផ្តល់សច្ចាប័នលើសន្ធិសញ្ញាមួយចំនួនជាពិសេស សន្ធិសញ្ញាពាក់ព័ន្ធនឹងសិទ្ធិមនុស្ស។

---

[275] Hap Phalthy, Introduction to Cambodian Law, 2022, p. 5.
[២៧៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា១។
[២៧៧] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៤។
[២៧៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៣៥។
[២៧៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៤៥។
[២៨០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៤៩ ស្តួន២ថ្មី។
[២៨១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៥៣។
[២៨២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៥៥។
[២៨៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៦៦។
[២៨៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៦០ថ្មី។

ក្រុមប្រឹក្សារដ្ឋ មានការកិច្ចអនុវត្តរដ្ឋធម្មនុញ្ញ ច្បាប់ ក្រឹត្យ អនុសញ្ញាទាំងឡាយ ផ្អាកការអនុវត្ត កែប្រែ ឬលុបចោលអនុសញ្ញា និងសេចក្តីណែនាំមិនសមស្របរបស់រដ្ឋមន្ត្រី។[២៨៥]

បន្ថែមពីអំណាចធ្វើច្បាប់ រដ្ឋសភាមានអំណាចអនុម័តឬកែប្រែរដ្ឋធម្មនុញ្ញនិងច្បាប់នានា ពិនិត្យការអនុវត្តរដ្ឋធម្មនុញ្ញ និងការអនុវត្តច្បាប់បង្កើតឬលុបចោលតុលាការប្រជាជនកំពូល... អនុម័តឬលុបចោលសន្ធិសញ្ញា អនុសញ្ញាអន្តរជាតិរបស់រដ្ឋាភិបាល[២៨៦] ។ សមត្ថកិច្ចបកស្រាយច្បាប់ ជារបស់គណៈកម្មាធិការអចិន្ត្រៃយ៍រដ្ឋសភា។[២៨៧] ច្បាប់ ក្រឹត្យ-ច្បាប់ ក្រឹត្យ អនុក្រឹត្យ ប្រកាស និងសេចក្តីសម្រេចទាំងឡាយរបស់ស្ថាប័ន ...ត្រូវស្របនឹងរដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជា។[២៨៨]

ពលរដ្ឋមានសិទ្ធិប្តឹងបរិហារ ប្តឹងតវ៉ា ឬប្តឹងទាសំណង ជួសជុលការខូចខាត ដែលបណ្តាលមកពីអំពើខុសច្បាប់ច្បាប់របស់អង្គការរដ្ឋ...[២៨៩]។ ការជំរះក្តីស្ថិតនៅក្នុងដៃតុលាការដែលមានសាលាជំរះក្តីនិងអយ្យការ[២៩០]។ ក្រៅពីតុលាការធម្មតា មានតុលាការយោធា។ តុលាការពិសេស ក៏អាចត្រូវបានបង្កើតផងដែរ ដោយក្រុមប្រឹក្សារដ្ឋ ដើម្បីជំនុំជំរះរឿងដែលមានលក្ខណៈពិសេស[២៩១]។ ការជំរះក្តី ត្រូវធ្វើឡើងដោយអនុលោមតាមច្បាប់។ ក្នុងដំណើរការសកម្មភាពតុលាការ មានទីប្រឹក្សាប្រជាជនដែលមានសិទ្ធិស្មើនឹងចៅក្រម ។[២៩២]

កំណត់សំគាល់៖ ក្រុមប្រឹក្សារដ្ឋនិងសភា មានសិទ្ធិរៀបចំច្បាប់ ដែលនឹងអនុម័តដោយសភា និងប្រកាសឲ្យប្រើដោយក្រុមប្រឹក្សារដ្ឋ។ ស្ថាប័នក្រោយនេះ ជាអ្នកអនុវត្តច្បាប់ដែលត្រួតពិនិត្យដោយសភា។ គណៈកម្មាធិការអចិន្ត្រៃយ៍សភា ជាអ្នកមានសមត្ថកិច្ចបកស្រាយច្បាប់។ ក្នុងសម័យនេះ គេលឺពាក្យ ***«អនុក្រឹត្យ»*** និង ***«ប្រកាស»***។ មានតុលាការយោធា ឬតុលាការពិសេស ដែលអាចត្រូវបានបង្កើតដោយក្រុមប្រឹក្សារដ្ឋ ដែលអាចត្រូវបានរំលាយវិញដោយរដ្ឋសភា។

---

[២៨៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៦៦។
[២៨៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៤៨ថ្មី
[២៨៧]រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៤៩ ស្តួន២ថ្មី។
[២៨៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៩២។
[២៨៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៣៩។
[២៩០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៧៩។
[២៩១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៨០។
[២៩២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩, មាត្រា៨២។

២.៧. ព្រះរាជាណាចក្រកម្ពុជា ១៩៩៣ ដល់បច្ចុប្បន្ន

ឆ្នាំ១៩៩៣ កម្ពុជាបានបោះឆ្នោត បង្កើតនូវរបបរាជាណាចក្រកម្ពុជាទី២ និងអនុម័តរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ ខ្លឹមសារនៃរដ្ឋធម្មនុញ្ញនេះ ទទួលឥទ្ធិពលពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៥៧។ រដ្ឋធម្មនុញ្ញ ទទួលស្គាល់លិទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស ទទួលស្គាល់ទ្រព្យសម្បត្តិឯកជន។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានមូលដ្ឋានពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៨៩ និងទទួលបានកែសម្រួល ជាច្រើនដងមកដល់ពេលនេះ (ដូចជាពាក់ព័ន្ធនឹងអំណាចធ្វើច្បាប់ចូលរួមដោយព្រឹទ្ធសភា)។[២៩៣]

២.៧.១. យន្តការនិងដំណើរការនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត

ច្បាប់ជាលាយលក្ខណ៍អក្សរនេះ ត្រូវបានរៀបចំតាក់តែង ក្នុងទម្រង់ជាសេចក្តីស្នើច្បាប់ ឬសេចក្តីព្រាងច្បាប់។[២៩៤] រដ្ឋសភា មានអំណាចនីតិបញ្ញត្តិ[២៩៥]រួមជាមួយនឹងព្រឹទ្ធសភា[២៩៦]។ ពាក់ព័ន្ធនឹងគោលការណ៍ឬវិធានជួយគាំទ្រកិច្ចការងារតាក់តែងលិខិតបទដ្ឋានគតិយុត្ត ក្នុងឆ្នាំ២០១៣ រាជរដ្ឋាភិបាលបានដាក់ចេញនូវសារាចរលេខ០៣ សរចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៣ ស្តីពីការអនុវត្តគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្ត ក្រោយមកត្រូវបានជំនួសដោយអនុក្រឹត្យលេខ១៧០ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០២៤ ស្តីពីគោលការណ៍ណែនាំស្តីពីនីតិវិធីនិងវិធាននៃការតាក់តែងសេចក្តីព្រាងច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត។

សម្រាប់ដំណើរការនៃការតាក់តែង សភាអាចស្នើច្បាប់ រីឯរាជរដ្ឋាភិបាលអាចរៀបចំសេចក្តីព្រាងច្បាប់។[២៩៧] ក្រសួងជំនាញក្រោមរដ្ឋាភិបាល អាចរៀបចំសេចក្តីព្រាងច្បាប់ ពិភាក្សានិងប្រជុំផ្ទៃក្នុងក្រសួង រួចបញ្ជូនមកទីស្តីការគណៈរដ្ឋមន្ត្រី

---

[២៩៣] រដ្ឋធម្មនុញ្ញឆ្នាំ ១៩៩៣, មាត្រា ២៦ ថ្មី។ Hor Peng, the Development of the Constitutional Law of the Kingdom of Cambodia, p. 15 in Perspectives on Cambodian Constitutional Law, 2020 (ថាទទួលឥទ្ធិពលពីរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧)។

[២៩៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៩១ថ្មី។

[២៩៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៩០ថ្មី(២)។

[២៩៦] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៩, មាត្រា៩៩ថ្មី។

[២៩៧] រដ្ឋធម្មនុញ្ញកម្ពុជា១៩៩៣, មាត្រា៩១ថ្មី។

ជាមួយនឹងសេចក្តីព្រាងច្បាប់ ព្រមទាំងឯកសារពាក់ព័ន្ធមួយចំនួនដូចជាសេចក្តីថ្លែងហេតុ (គោលបំណងនិងប្រយោជន៍ទទួលបានពីការអនុវត្តច្បាប់)។

ក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គមកិច្ចនិងវប្បធម៌ (ក.ស.វ) នៃទីស្តីការគណៈរដ្ឋមន្ត្រីនឹងពិនិត្យមើលសេចក្តីព្រាង ដោយផ្តោតលើជ្រុងសេដ្ឋកិច្ចនិងសង្គម ខណៈដែលក្រុមប្រឹក្សាអ្នកច្បាប់នឹងប្រជុំផ្ទៃក្នុងផងដែរ ផ្តោតលើទិដ្ឋភាពច្បាប់។ ជាបន្ទាប់ ទីស្តីការគណៈរដ្ឋមន្ត្រី នឹងរៀបចំកិច្ចប្រជុំជំនាញបច្ចេកទេស ដែលមានការចូលរួមពីក្រុមប្រឹក្សាទាំងពីរ និងតំណាងក្រសួងសាមីនៃសេចក្តីព្រាងច្បាប់ មុននឹងប្រជុំអន្តរក្រសួង។

កិច្ចប្រជុំអន្តរក្រសួង ចូលរួមដោយក្រសួងស្ថាប័នជាច្រើន ដែលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ និងដឹកនាំដោយតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីពិនិត្យខ្លឹមសារឲ្យបានរួចរាល់មុននឹងដាក់ឆ្លងប្រជុំពេញអង្គនៃគណៈរដ្ឋមន្ត្រី។ ក្នុងអំឡុងពេលនៃកិច្ចប្រជុំអន្តរក្រសួងនេះ សម្រាប់ច្បាប់ខ្លះ អាចមានបញ្ហាជាន់សមត្ថកិច្ច។ ក្នុងករណីនេះ កិច្ចប្រជុំអន្តរក្រសួងចង្អៀត ដឹកនាំដោយតំណាងទីស្តីការគណៈរដ្ឋមន្ត្រី ចូលរួមដោយក្រសួងពាក់ព័ន្ធផ្ទាល់ នឹងត្រូវបានរៀបចំ។ ក្រោយកិច្ចប្រជុំនេះ និងជាករណីកម្រ អាចមានកិច្ចប្រជុំត្រួតពិនិត្យចុងក្រោយ មុននឹងចូលកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ ក្រោយពីគណៈរដ្ឋមន្ត្រីអនុម័ត សេចក្តីព្រាងនឹងបញ្ជូនទៅរដ្ឋសភា ដើម្បីបន្តនីតិវិធីពិនិត្យ ពិភាក្សាលើសេចក្តីព្រាងច្បាប់ និងបន្តបញ្ជូនទៅព្រឹទ្ធសភា។

នៅខណៈនេះ ប្រសិនបើសេចក្តីព្រាងច្បាប់ស្ថិតក្នុងប្រភេទច្បាប់ ដែលត្រូវឆ្លងការត្រួតពិនិត្យធម្មនុញ្ញភាព (ច្បាប់ស្តីពីការរៀបចំអង្គការ) ត្រូវឆ្លងកាត់ក្រុមប្រឹក្សាធម្មនុញ្ញ មុននឹងព្រះមហាក្សត្រឡាយព្រហស្តលេខា ចូលជាធរមាន និងអាចអនុវត្តបាន។ ច្បាប់អនុម័តដោយសភាទាំងពីរ នឹងត្រូវប្រកាសឲ្យប្រើដោយព្រះមហាក្សត្រ និងត្រូវចុះក្នុងរាជកិច្ចនិងផ្សព្វផ្សាយនៅទូទាំងប្រទេស[២៩៨]។

សេចក្តីព្រាងច្បាប់ ក្នុងករណីខ្លះ ត្រូវបានរៀបចំដោយអ្នកជំនាញការជាតិឬអន្តរជាតិ តាមរយៈគម្រោងជំនួយហិរញ្ញវត្ថុសម្រាប់រៀបចំសេចក្តីព្រាងច្បាប់។ ក្រសួងសាមីអាចបង្កើតក្រុមការងាររៀបចំសេចក្តីព្រាងច្បាប់ ធ្វើការងារជាមួយអ្នកជំនាញការ។ ក្រុមការងារនេះ ជាចម្បងដឹកនាំ និងចូលរួមប្រជុំផ្ទៃក្នុងផ្តល់យោបល់ លើសេចក្តីព្រាងច្បាប់ដោយអ្នកជំនាញ រួចបញ្ជូនទៅទីស្តីការគណៈរដ្ឋមន្ត្រី។ មុននឹងបញ្ជូនមកទីស្តីការគណៈ

[២៩៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៩៣ថ្មី។

រដ្ឋមន្ត្រី សេចក្តីព្រាងច្បាប់ត្រូវបានឆ្លងកាត់ប្រជុំពិគ្រោះយោបល់ផងដែរ ចូលរួមដោយអង្គការសង្គមស៊ីវិលឬវិស័យឯកជន។ ទោះបីជាយ៉ាងនេះក្តី វាមិនមានលក្ខណៈទូទៅនិងទូលំទូលាយឡើយ។

សម្រាប់សេចក្តីព្រាងច្បាប់អនុម័តឲ្យកម្ពុជាចូលជាភាគីសន្ធិសញ្ញាណាមួយ ដំណើរមិនខុសគ្នា ដែលជាទូទៅចាប់ផ្តើមពីក្រសួងសាមី ជាអ្នកចុះហត្ថលេខាលើសន្ធិសញ្ញា។[២៩៩] ទោះបីជាយ៉ាងនេះក្តី ដំណើរការនិងរយៈពេលនៃកិច្ចក្នុងដំណាក់កាលនីមួយៗ មិនស្មុគ្រស្មាញនិងមានរយៈពេលខ្លី ដោយសារ សេចក្តីព្រាងច្បាប់នេះ មានតែប៉ុន្មានមាត្រាតែប៉ុណ្ណោះ។[៣០០]

រដ្ឋធម្មនុញ្ញជាច្បាប់កំពូល[៣០១] មានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ជាច្រើន ត្រូវបានរៀបចំឡើង រហូតដល់ឆ្នាំ២០០៧ មានក្រមរដ្ឋប្បវេណី ក្រមព្រហ្មទណ្ឌឆ្នាំ ២០១០ ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ ត្រូវបានអនុម័ត។ ឆ្នាំ២០២៤ កម្ពុជាមានក្រមស្តីពីបរិស្ថាននិងធនធានធម្មជាតិ។ តាមទិន្នន័យ មានច្បាប់សរុបប្រមាណ៧០០ ដែលក្នុងនោះ មានច្បាប់សារធាតុមានជាង៣០០។ ជារួម ក្នុងដំណើរតាក់តែងច្បាប់ តាំងពីការចាប់ផ្តើមរហូតដល់ច្បាប់ត្រូវបានអនុម័តជាស្ថាពរ ឆ្លងកាត់កិច្ចប្រជុំផ្ទៃក្នុង ខាងក្រៅ តូចឬធំ និងបង្កើតឯកសារជាច្រើន ដូចជាកំណត់ត្រាកិច្ចប្រជុំពិភាក្សាច្បាប់ជាដើម។ ច្បាប់ខ្លះ បានចំណាយពេលយូរ (ជួនកាល១០ឆ្នាំក៏មាន) មុននឹងត្រូវបានអនុម័ត។ ក្នុងរយៈពេល៣២ឆ្នាំ (១៩៩៣-២០២៥) ជាមធ្យម មានច្បាប់ប្រហែល ២០ ត្រូវបានអនុម័តក្នុងមួយឆ្នាំ។

ច្បាប់ ក៏រួមមានបញ្ជូលនូវអនុសញ្ញានិងសន្ធិសញ្ញាអន្តរជាតិ ដែលរដ្ឋសភាអនុម័តយល់ព្រមឬលុបចោល។[៣០២] ព្រះមហាក្សត្រ ទ្រង់ឡាយព្រហស្តលេខាលើសន្ធិសញ្ញា ហើយប្រទានសច្ចាប័ន[៣០៣] ខណៈរាជរដ្ឋាភិបាលក៏អាចចុះកិច្ចព្រមព្រៀងបានដែរ[៣០៤]។ តាមការអង្កេតជាបឋម មានសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងទ្វេភាគី ៣ក់ព័ន្ធ

---

[២៩៩] ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ២០១៨, មាត្រា១៧។

[៣០០] ច្បាប់ស្តីពីការអនុម័តយល់ព្រមលើពិធីសារទីមួយ...សមាគមប្រជាជាតិអាស៊ីអាគ្នេយ៍និងជប៉ុន ឆ្នាំ ២០២០(មានតែ ៣ មាត្រា)។

[៣០១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១៥២ថ្មី (ពី)។

[៣០២] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៥០ថ្មី (២)។

[៣០៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា២៦ថ្មី។

[៣០៤] ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ២០១៨, មាត្រា៤៧។

គ្រប់វិស័យ ដែលកម្ពុជាបានចូលជាភាគីប្រមាណជិត ៣០០។ ច្បាប់អន្តរជាតិ ត្រូវបានទទួលស្គាល់ដោយរដ្ឋធម្មនុញ្ញ[៣០៥] នឹងត្រូវបានរាប់បញ្ចូលជាច្បាប់ជាតិ។[៣០៦] ក្នុងន័យនេះ វិធានសន្ធិសញ្ញាអាចត្រូវបានអនុវត្តផ្ទាល់[៣០៧]។ ទោះបីជាយ៉ាងនេះក្តី មិនមានបទប្បញ្ញត្តិច្បាស់លាស់ចែង ក្នុងឋានានុក្រម សន្ធិសញ្ញាស្ថិតនៅទាបជាងរដ្ឋធម្មនុញ្ញ ក៏ប៉ុន្តែស្ថិតនៅខ្ពស់ជាងច្បាប់ធម្មតា។

កំណែទម្រង់ច្បាប់នៅកម្ពុជាមានចាប់តាំងពីឆ្នាំ១៩៩៦ ដោយមានផែនការកែទម្រង់ច្បាប់។ មានយុទ្ធសាស្ត្រចំនួន៧ ក្នុងនោះមាន ការទទួលបានព័ត៌មានច្បាប់គឺជាគោលដៅទី៣នៃយុទ្ធសាស្ត្រ។[៣០៨] ក្នុងអាណត្តិទី៧ នៃរដ្ឋសភា ចាប់ពីឆ្នាំ២០២៣ មក កម្ពុជាបានបង្កើតគណៈកម្មការធិការដឹកនាំការកែទម្រង់ច្បាប់ ដែលជាយន្តការសម្របសម្រួលមួយ ពាក់ព័ន្ធនឹងការគាក់តែងច្បាប់។[៣០៩] យើងរំពឹងថា ក្រុមប្រឹក្សានឹងបង្កើតគោលការណ៍ណែនាំបន្ថែម ជាពិសេសពាក់ព័ន្ធនឹងការគាក់តែងខ្លឹមសារសារធាតុនៃច្បាប់។

រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ផងដែរ លើការវាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្ត (RIA) តាមរយៈការបង្កើតនូវគណៈកម្មការដឹកនាំកែទម្រង់វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តជាច្រើនឆ្នាំមកហើយ និងត្រូវបានកែសម្រួលក្នុងឆ្នាំ២០២៤។[៣១០]

២.៧.២. យន្តការដោះស្រាយជម្លោះ

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បង្កើតនូវក្រុមប្រឹក្សាធម្មនុញ្ញ[៣១១]។ បន្ថែមពីលើនេះ រដ្ឋធម្មនុញ្ញបានចែងអំពីការបែងចែកអំណាច ដោយផ្តល់អំណាចដល់តុលាការនិច្ឆ័យ

---

[៣០៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៣១។

[៣០៦] សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំលេខ៩២ ឆ្នាំ២០០៧។ Taing Ratna et al., Annotated Constitution of the Kingdom of Cambodia, 2017, ទំ. 23។

[307] ECCC, Supreme Court Chamber, Decision on Objections to Document Lists (full reasons) 13 December 2015, F26/12. para. 34.

[308] Kong Phallack, Overview of the Cambodian Legal and judicial system, pp. 19-20 in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf

[៣០៩] ព្រះរាជក្រឹត្យលេខនស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការធិការដឹកនាំការកែទម្រង់ច្បាប់។

[៣១០] សេចក្តីសម្រេចលេខ ១១ សសរ ស្តីពីការបង្កើតគណៈកម្មការដឹកនាំកែទម្រង់វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តឆ្នាំ២០២៤។

[៣១១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, ជំពូកទី១២ថ្មី។

សេចក្តី លើបញ្ហាទូទៅ សូម្បីវិទេរដ្ឋបាល។[៣១២] តុលាការសម្រេចសេចក្តីមានបីកម្រិត៖ តុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង។[៣១៣] តុលាការត្រូវអនុវត្តកិច្ចការអនុលោមតាមច្បាប់។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ពិនិត្យលើពិន័យដល់ចៅក្រម[៣១៤]។ ចាប់ពីឆ្នាំ ២០២០ សាលាឧទ្ធរណ៍តំបន់ចំនួន៣ ត្រូវបានបង្កើតឡើង (សាលាឧទ្ធរណ៍តំបន់ភ្នំពេញ , សាលាឧទ្ធរណ៍តំបន់បាត់ដំបង និងសាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ)។ ប្រជាពលរដ្ឋមានសិទ្ធិធ្វើបណ្តឹងតវ៉ាដើម្បីទាមទារសំណងពីការខូចខាតបង្កដោយអង្គការរដ្ឋ។[៣១៥]

ដំណើរការនៃស្ថាប័នវិជ្ជាជីវៈមេធាវី បានចាប់ផ្តើមដំណើរការ។ ឆ្នាំ១៩៩៩ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានបង្កើត ហើយគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវបានបង្កើតក្នុងឆ្នាំដដែល។ ជាបន្តបន្ទាប់ តុលាការជំនាញត្រូវបានស្នើបង្កើត ផ្អែកតាមច្បាប់ស្តីពីមជ្ឈត្តករពាណិជ្ជកម្ម។[៣១៦] ក្រុមប្រឹក្សាអាជ្ញាកណ្តាល ត្រូវបានបង្កើតឡើងអនុលោមតាមមាត្រា៣០៩ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។[៣១៧] ថ្មីៗនេះ ក្រសួងយុត្តិធម៌បានដឹកនាំកិច្ចការងារដោះស្រាយជម្លោះក្រៅប្រព័ន្ធតុលាការ។[៣១៨] អាជ្ញាធរដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការត្រូវបានបង្កើត ដោយព្រះរាជក្រឹត្យលេខ១១២៣ ឆ្នាំ ២០២៣។

ពាក់ព័ន្ធការបកស្រាយច្បាប់ មិនមានលិខិតបទដ្ឋានណាមួយចែងនៅឡើយ។ ក្រុមប្រឹក្សារធម្មនុញ្ញ មានអំណាចបកស្រាយច្បាប់។[៣១៩] ការអនុវត្តច្បាប់ មិនទាន់ត្រូវបានធ្វើឡើងជាទូទៅ ដោយធ្វើឡើងដោយក្រសួងសាមីដែលផ្តួចផ្តើមធ្វើច្បាប់។ មិនមានក្រសួងណាមួយទទួលបន្ទុកផ្សព្វផ្សាយច្បាប់ជាទូទៅ ក្រៅពីផ្សព្វផ្សាយច្បាប់ក្នុងរាជកិច្ច។[៣២០]

---

[៣១២]រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៥១ថ្មី។

[៣១៣] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១២៨ថ្មី។

[៣១៤] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១៣៣ថ្មី។

[៣១៥] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៣៩។

[៣១៦] ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ឆ្នាំ២០០៦។

[317] Kong Phallack, Overview of the Cambodian Legal and judicial system, p. 12 in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf

[318] មានតាំងពីឆ្នាំ១៩៧0 សូមមើល Kong Phallack, Overview of the Cambodian Legal and judicial system, pp. 13 in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf

[៣១៩] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១៣៦ថ្មី។

[៣២០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា៩៣ថ្មី។

កំណត់សំគាល់៖ ចាប់តាំងពីឆ្នាំ១៩៩៣ យន្តការធ្វើច្បាប់មានភាពជាក់លាក់និងជារចនាសម្ព័ន្ធ។ ក្រៅពីបរិមាណច្បាប់ដែលត្រូវបានធ្វើឡើង មានលិខិតបទដ្ឋានគតិយុត្តជាច្រើនប្រភេទ និងស្ថិតតាមលំដាប់លំដោយឋានានុក្រម ចាប់ផ្តើមពីរដ្ឋធម្មនុញ្ញដែលជាច្បាប់កំពូល បន្តដោយច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល បទបញ្ជា សារាចរណែនាំ ប្រកាស សារាចរណែនាំរបស់ក្រសួង ដីការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ។ ព្រះរាជក្រឹត្យ អនុក្រឹត្យ សារាចរណែនាំ ប្រកាស អាចត្រូវបានដាក់ចេញដើម្បីជួយដល់ការអនុវត្តច្បាប់ឬបំភ្លឺខ្លឹមសារច្បាប់។[៣២១]

ច្បាប់ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តដទៃទៀត ត្រូវបានតម្រូវបានបោះពុម្ពក្នុងរាជកិច្ច។ អំណាចទាំងបីត្រូវបានបែងចែក ដែលចង់មិនចង់ អំណាចនីតិប្រតិបត្តិជាអង្គអនុវត្តច្បាប់ ហើយក្រុមប្រឹក្សាធម្មនុញ្ញ ជាអង្គបកស្រាយច្បាប់និងរដ្ឋធម្មនុញ្ញ។

យន្តការដោះស្រាយជម្លោះមានសំបូរបែប។ តុលាការធម្មតា សូម្បីជាន់ទាបក៏អាចពិចារណាវិវាទរដ្ឋបាលផងដែរ។

២.៧.៣. ការសំយោគចរិត និងប្រភេទនៃប្រព័ន្ធច្បាប់កម្ពុជា

ចាប់តាំងពីឆ្នាំ១៨៦៣ ដល់ឆ្នាំ១៩៩៣ (១៣០ឆ្នាំ) កម្ពុជាបានឆ្លងកាត់ ៧របប ហើយដែលរបបខ្លះរងឥទ្ធិពលនៃប្រព័ន្ធច្បាប់ខុសគ្នា អាស្រ័យទៅតាមនិន្នាការឬរបបដឹកនាំ។ ជាក់ស្តែង ក្នុងសម័យអាណាព្យាបាលរបស់បារាំង (១៨៦៣-១៩៥៣) ចង់មិនចង់ កម្ពុជាទទួលរងនូវប្រព័ន្ធច្បាប់ស៊ីវិលសម័យសាធារណៈរដ្ឋ (១៩៧០-១៩៧៥) តិចឬច្រើនទោះបីមិនមានការអនុវត្ត គឺរងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងប្រព័ន្ធច្បាប់សង្គមនិយមក្នុងរបបសាធារណៈរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩០)។

ឥទ្ធិពលឬការទទួលយកជាក់ស្តែងនៃប្រព័ន្ធច្បាប់មកក្នុងកម្ពុជា វាអាស្រ័យលើរយៈពេលនៃរបប ឬលទ្ធភាពនៃការអនុវត្តតាមជាតុផ្សំនៃប្រព័ន្ធច្បាប់។ ជាក់ស្តែងក្រោមរបបអាណាព្យាបាល ប្រហែលមួយរយឆ្នាំ កម្ពុជារងឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិលចាប់ផ្តើមពីសកម្មភាពចងក្រងនិងធ្វើច្បាប់ជាលាយលក្ខណ៍អក្សរ។ ខណៈក្នុងរបបសាធារណរដ្ឋ ដែលគេអាចនិយាយថាប្រកាន់នូវប្រព័ន្ធប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បែរជាមិនបានទទួលការអនុវត្តជាក់ស្តែង ដោយសារកត្តាសង្គ្រាម និងវិបត្តិផ្ទៃក្នុង រារាំងមិនឲ្យមានការកសាងច្បាប់ទម្លាប់ច្រើន។ ងាកបន្តមើលរបបកម្ពុជាប្រជាធិបតេយ្យវិញ បន្ត

[៣២១] ក្រុមប្រឹក្សានីតិកម្ម, ចក្ខុវិស័យនិងយុត្តិសាស្ត្រក្រុមប្រឹក្សានីតិកម្ម, ២០២២ ទំ.៣០៩។

ពីសម័យសាធារណរដ្ឋឆ្នាំ១៩៧៥ ការអភិវឌ្ឍច្បាប់ មិនមានទាល់តែសោះ ផ្ទុយទៅវិញ បែរជាលុបចោលនូវប្រព័ន្ធច្បាប់ទាំងស្រុង។ ជាសរុប ១០ឆ្នាំនៃរបបទាំងពីរនេះ មិនមានការអភិវឌ្ឍប្រព័ន្ធច្បាប់អ្វីនោះទេ។

យន្តការនិងស្ថាប័នកសាងច្បាប់ ទោះបីមានការប្រែប្រែតិចតួចក្តី ក៏សភា (សហសភា) នៅតែដើរតួ និងជាអង្គនៃអំណាចនីតិបញ្ញត្តិ។ ប្រភេទច្បាប់ មានក្រម ច្បាប់ ក្រឹត្យ-ច្បាប់ និងក្រឹត្យជាដើម។ ក្រៅពីច្បាប់ជាតិ ក៏មានការយោងដល់ច្បាប់អន្តរជាតិ ទោះបីជាផ្លូវការ មានចែងយោងក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៧២។ តាមសម័យកាលនីមួយៗ ការរៀបចំច្បាប់មានតិចឬច្រើន ទោះបីជាយ៉ាងនេះក្តី ជាសរុប មិនមានច្បាប់ច្រើន ត្រូវបានរៀបចំនិងអនុម័តប្រសិនបើធៀបនឹងចំនួនច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជានៅពេលនេះ។

កម្ពុជាបានកសាងច្បាប់ទម្លាប់ជាច្រើន គ្រប់វិស័យ។ ច្បាប់ខ្លះមានលក្ខណៈខ្លីខ្លះមានទម្រង់ជាក្រមលម្អិត។ ខ្លឹមសារសារធាតុនៃច្បាប់ក៏មានបង្កប់ធាតុផ្សំនៃច្បាប់កម្ពុជាសម័យកណ្តាល មុនឆ្នាំ១៨៦៣ ដូចជា ការផ្សះផ្សារជម្លោះដោយចាស់ព្រឹទ្ធាចារ្យ លោកសង្ឃ។[៣២២]

ក្រុមស្រាវជ្រាវ មិនបានដឹង (អាចមាន)អំពីលិខិតបទដ្ឋានគតិយុត្តឬយន្តការត្រួតពិនិត្យនីត្យានុកូលភាពនៃច្បាប់។ ដូចគ្នានេះដែរ ដោយសារពេលវេលាមានកម្រិត ក្រុមការងារ មិនបានពិនិត្យមើលខ្លឹមសារជាក់ស្តែងនៃច្បាប់ដើម្បីវាយតម្លៃ អំពីគុណភាពនៃច្បាប់។ ក្រុមការងាររំពឹងថា នឹងមានការសិក្សាស្រាវជ្រាវលើបញ្ហាទាំងនេះនៅពេលខាងមុខ។

ច្បាប់និងសន្ធិសញ្ញា ត្រូវបានតម្រូវឲ្យចុះក្នុងរដ្ឋ (រាជ)កិច្ច ហើយការអនុវត្តស្ថិតនៅក្នុងដៃរបស់រដ្ឋាភិបាល ឬក្រុមប្រឹក្សារដ្ឋមន្ត្រី ក្រោមការត្រួតពិនិត្យរបស់សភា ឬក្រុមប្រឹក្សារដ្ឋ។ សម្រាប់ការបកស្រាយវិញ ក្រុមប្រឹក្សារដ្ឋ (សភា) និងក្នុងឆ្នាំ១៩៩៣ ក្រុមប្រឹក្សាធម្មនុញ្ញជាអ្នកបកស្រាយច្បាប់។

យន្តការដោះស្រាយជម្លោះ: ចាប់តាំងពីឆ្នាំ១៨៦៣មក លើកលែងរបបកម្ពុជាប្រជាធិបតេយ្យចេញ យន្តការដោះស្រាយជម្លោះ មិនមានអ្វីខុសគ្នាខ្លាំង ក្រៅតែចំនួនឬប្រភេទនៃការដោះស្រាយជម្លោះ។ របត់ខុសគ្នា គឺការបង្កើតនូវតុលាការធម្មនុញ្ញ ក្នុង

[322] Dolores A. Donovan, Cambodia: Building a Legal System from Scratch, 27 INT'L L. 454 (1993) https://scholar.smu.edu/til/vol27/iss2/8

សម័យសាធារណៈរដ្ឋ ដែលខុសពីសម័យ១៩៩៣ មានតែក្រុមប្រឹក្សាធម្មនុញ្ញ។ និយាយជាសរុប យន្តការដោះស្រាយជម្លោះមានច្រើនបែប និងតាមវិស័យ។

ប្រព័ន្ធច្បាប់កម្ពុជា: សំណួរអាចត្រូវបានសួរថា តើប្រព័ន្ធច្បាប់កម្ពុជាជាប្រព័ន្ធស៊ីវិល ឬប្រព័ន្ធច្បាប់អ្វី។ សម្រាប់ការសន្និដ្ឋានថា កម្ពុជាតាំងពីឆ្នាំ១៨៦៣ មកអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលនៃប្រទេសបារាំង ឬយ៉ាងណានោះ ជាដំបូង វាទាមទារឲ្យយើងស្គាល់ធាតុផ្សំចម្បងនៃប្រព័ន្ធច្បាប់ស៊ីវិល។

អត្ថបទសូមបង្ហាញអំពីធាតុផ្សំនៃប្រព័ន្ធច្បាប់ស៊ីវិលដោយប្រៀបធៀប នឹងធាតុផ្សំនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ហើយចុងបញ្ចប់នៃផ្នែកនេះ ក៏នឹងបង្ហាញអំពីការវិវឌ្ឍនិងការប្រែប្រួលនៃប្រព័ន្ធស៊ីវិលឡងដែរ:

ក. ការរៀបចំច្បាប់និងខ្លឹមសារនៃច្បាប់

លរ.	ប្រព័ន្ធច្បាប់ស៊ីវិល	ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង
១	**ក.** ផ្តោតលើច្បាប់ជាលាយលក្ខណ៍អក្សរក្នុងទម្រង់ជាក្រម ចែងលម្អិតជាមួយចេតនាដោះស្រាយលើគ្រប់បញ្ហាដែលអាចកើតឡើង។ ក្នុងន័យនេះ មិនផ្តល់ឆន្ទានុសិទ្ធិច្រើនដល់ចៅក្រមក្នុងការបកស្រាយ។[៣២៣] **ខ.** ខ្លឹមសារបទប្បញ្ញត្តិច្បាប់ ត្រូវមានភាពជាក់លាក់និងច្បាស់លាស់ អនុលោមតាមគោលការណ៍នីត្យានុកូលភាព។ **គ.** ច្បាប់ត្រូវបានតាក់តែងឡើង តាមនីតិវិធីឬដំណាក់កាលច្បាស់លាស់ ដោយអង្គភាពទទួលខុសត្រូវជាក់លាក់។ សភាជាអ្នកធ្វើច្បាប់ ចៅក្រមត្រូវបានរំពឹងថាដឹងច្បាប់ និងមានតួនាទីបកស្រាយច្បាប់។ រដ្ឋាភិបាល ទទួលខុសត្រូវក្នុង	**ក.** មិនផ្តោតសំខាន់លើច្បាប់ជាលាយលក្ខណ៍អក្សរ(ចៅក្រមបង្កើតច្បាប់)។ក្នុងករណីមានច្បាប់ ជាច្បាប់តាមវិស័យ មិនលម្អិតច្រើនផ្តល់ឆន្ទានុសិទ្ធិដល់ចៅក្រមច្រើនក្នុងការបកស្រាយ។ **ខ.** ភាពមិនជាក់លាក់ពេកមិនតម្រូវពីព្រោះចៅក្រមមានឆន្ទានុសិទ្ធិច្រើនក្នុង ការបកស្រា យ។ **គ.** ចៅក្រមដើរតួផងដែរ ក្នុងការធ្វើច្បាប់ដោយបង្កើតជាយុត្តិសាស្ត្រ (precedent)។ **ឃ.** ច្បាប់ត្រូវបានរៀបចំ ដោយយោងលើច្បាប់បង្កើតដោយចៅក្រម។

[323] Eva Steiner, French Law, A comparative approach, 2010, p. 37.

លរ.	ប្រព័ន្ធច្បាប់ស៊ីវិល	ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង
	ការអនុវត្តច្បាប់ ដែលនេះស្របតាមគោលការណ៍បែងចែកអំណាចកំណត់ក្នុងរដ្ឋធម្មនុញ្ញ និងដែលជាធាតុផ្សំជាក់លាក់ នៃប្រព័ន្ធស៊ីវិលឡ។ **ឃ**. សាស្ត្រាចារ្យ និងសាកលវិទ្យាល័យដើរតួនាទីខ្លាំងក្នុងការកសាងទ្រឹស្តីច្បាប់។ **ង**. មានខ្លឹមសារពន្យល់លើខ្លឹមសារច្បាប់ (explainatory note)។ **ច**. សន្និសញ្ញា (ច្បាប់អន្តរជាតិ) ក្រោយពេលផ្តល់សច្ចាប័ន ជាផ្នែកនៃច្បាប់ជាតិ និងអាចត្រូវបានអនុវត្តដោយផ្ទាល់ដោយតុលាការ។	**ង**. រដ្ឋាភិបាល ផ្តល់សច្ចាប័នលើសន្ធិសញ្ញា។ ច្បាប់អន្តរជាតិនឹងជាផ្នែកនៃច្បាប់ជាតិ និងអាចអនុវត្តដោយផ្ទាល់បានក្រោយពីសភា ធ្វើច្បាប់ជាក់ជាផ្នែកនៃច្បាប់ជាតិ (transformation act)។

ខ. យន្តការដោះស្រាយជម្លោះនិងវិធានន៍តិវិធី

លរ	ប្រព័ន្ធច្បាប់ស៊ីវិល	ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង
១	**ក**. តុលាការមានសមត្ថកិច្ចដោយឡែកៗ។[៣២៤] **ខ**. ជាទូទៅមានវិធាននីតិវិធីជាក់លាក់។ ក្នុងបញ្ហាព្រហ្មទណ្ឌ យើងឃើញមានភាពខុសគ្នាច្រើនរវាងប្រព័ន្ធច្បាប់ទាំងពីរនេះ៖ ១. ស៊ើបអង្កេតដោយចៅក្រមស៊ើបអង្កេត។[៣២៥] ២. មិនមាន jury។ ៣. មិនមានយន្តការ guilty plea ។ ៤. មេធាវីមិនអាចស៊ើបអង្កេតដោយ	**ក**.តុលាការមានសមត្ថកិច្ចទូទៅជាក់ស្តែងអាចដោះស្រាយលើគ្រប់បញ្ហា(ច្បាប់ឯកជនឬសាធារណៈ)[៣២៦]។ **ខ**. ក្នុងដំណើរការក្តីព្រហ្មទណ្ឌ៖ ១. មាន jury។ ២. មិនមានចៅក្រមស៊ើបអង្កេត។ ការស៊ើបអង្កេតជាចម្បងដោយនគរបាល។ ៣. មានយន្តការ guilty plea។[៣២៧] ៤. គ្រាន់តែជាជនរងគ្រោះ មិនមានតួនាទីនិង

[324] Dr. Vivienne O'Connor, Practitioner's guide to common law and civil law, 2015, p. 15.
[325] Abraham S. Goldstein and Martin Marcus, inquisitorial, 1977, p. 250.
[326] Mathias Siems, Comparative Law, 2014, p. 49.
[327] J.R. Spencer, European Criminal Procedure, 2006, p. 163.

លរ	ប្រព័ន្ធច្បាប់ស៊ីវិល	ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង
	ខ្លួនឯង។ ៥. តួនាទីនិងសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី។ ៦.ចៅក្រមសវនាការដើរតួចម្បងក្នុងពេលសវនាការ។ **គ.** តុលាការកំពូល មិនមានសិទ្ធិបកស្រាយធម្មនុញ្ញ។ **ឃ.** មិនមានបទល្មើសច្បាស់អំពីការប្រមាថតុលាការ។	សិទ្ធិច្រើន។ ៥. ក្នុងពេលសវនាការចៅក្រមដើរតួជាអាជ្ញាកណ្តាល។[៣២៨] ៦. មេធាវីអាចស៊ើបអង្កេតនិងបង្កើតសំណុំរឿងខ្លួនឯង។ គ.តុលាការកំពូលមានសិទ្ធិបកស្រាយរដ្ឋធម្មនុញ្ញ។ **ឃ.** មានបទល្មើសស្តីពីការប្រមាថតុលាការ (contempt of court)

កំណត់សំគាល់

ជាការពិត មានភាពខុសគ្នាជាច្រើនទៀតរវាងធាតុផ្សំនៃប្រព័ន្ធច្បាប់ទាំងពីរ ដូចជាក្នុងវិស័យរដ្ឋប្បវេណី (កិច្ចសន្យា)។ ប៉ុន្តែការសិក្សា មិនធ្វើការសិក្សាលម្អិតពីភាពខុសគ្នារវាងប្រព័ន្ធច្បាប់ទាំងពីរនេះទេ។ ភាពខុសគ្នាក្នុងតារាងប្រៀបធៀបខាងលើ គឺជាធាតុផ្សំដើម។ ការធ្វើសមាហរណកម្មច្បាប់ក្នុងបរិបទសកលភាវូបនីយកម្មនាពេលបច្ចុប្បន្ន ប្រព័ន្ធទាំងពីររងនូវការកែសម្រួលគួរឲ្យកត់សំគាល់ ជាពិសេសដោយប្រទេស ដែលជាមេនៃប្រព័ន្ធច្បាប់ទាំងពីរនេះ ជាពិសេសក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ដើម្បីសម្របខ្លួននឹងនិន្នាការសកល ក៏ដូចជាការធានាសិទ្ធិសេរីភាព និងនាំមកនូវភាពរីកចំរើនផ្នែកសេដ្ឋកិច្ចនិងសង្គម[៣២៩]។ សូមមើលឧទាហរណ៍ខាងក្រោម៖

- **ក.** ប្រទេស Austria បានលុបចោទចៅក្រមស៊ើបអង្កេត[៣៣០]
- **ខ.** ប្រទេសអាឡឺម៉ង់ព្រមទាំងបារាំង បានប្រើយុត្តិសាស្ត្រជាច្រើន (Case law)
- **គ.** ប្រទេសអ៊ីតាលី បានប្រកាន់យកប្រព័ន្ធ Jury
- **ឃ.** ប្រទេសខ្លះយកយន្តការ Guilty plea។

[328] Evode KAYITANA, the accusatorial and Inquisitorial models of criminal procedure: a historical and comparative approach, 3(2) AJLHR, 2019, p. 188.
[329] Scott N. Carlson, Introduction to civil law legal systems, 2009, p. 15.
[330] J.R. Spencer, European Criminal Procedure, 2006, p. 12.

ង. ប្រទេសអង់គ្លេស ក៏ងាកមករក codification ហើយដែរ ទោះបីមិនទាន់ទូលំទូលាយ។

ច. នីតិវិធីព្រហ្មទណ្ឌក្នុងប្រទេស ដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលមួយចំនួន បានធ្វើសវនាការតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុងអនុញ្ញាតឲ្យមានការសួរតទល់ទូលំទូលាយ (Cross-examination)។

សន្និដ្ឋាន

ការសន្និដ្ឋានជាបឋម និងជារួមនេះ ទំនងជាការសន្និដ្ឋានត្រឹមត្រូវ ហើយការសិក្សាថ្មី អាចគ្រាន់តែគាំទ្រលើអំណះអំណាងទាំងនេះ។ តាមរយៈការពិភាក្សាខាងលើ គេអាចសន្និដ្ឋានបានថា ***«ប្រព័ន្ធច្បាប់កម្ពុជា ជាចម្បង ជាប្រព័ន្ធច្បាប់ស៊ីវិល ដែលរងឥទ្ធិពលពីប្រព័ន្ធច្បាប់របស់បារាំងតាំងពីឆ្នាំ១៨៦៣ រហូតដល់ពេលបច្ចុប្បន្ន»*** ។ ***ការសន្និដ្ឋាននេះ ផ្អែកតាមទម្រង់នៃច្បាប់ (ច្បាប់ជាលាយលក្ខណ៍អក្សរ) និងយន្តការនៃការដោះស្រាយជម្លោះ ដែលត្រូវបានបង្កើតនិងប្រើប្រាស់កន្លងមក។*** ឥទ្ធិពលនៃប្រព័ន្ធច្បាប់ ដែលបានផ្លាស់ប្តូរនិងប្រែប្រួលតាមសម័យកាលដូចបានអះអាងខាងលើ មិនបាននាំឲ្យប្រព័ន្ធនេះចាកឆ្ងាយពីប្រព័ន្ធច្បាប់ស៊ីវិលនោះទេ។ ការអះអាងដូចនេះ ដោយសារថា៖

ទី១. កម្ពុជានៅតែនិយមច្បាប់ជាលាយលក្ខណ៍អក្សរ (មានច្បាប់ និងក្រមជាច្រើន)

ទី២. ចៅក្រមជាមន្ត្រីរាជការ។ ដើម្បីចូលប្រកបត្រូវការប្រឡងចូលរៀននិងធ្វើកម្មសិក្សា។ ចៅក្រម បកស្រាយច្បាប់អនុលោមតាមច្បាប់ និងមិនប្រើយុត្តិសាស្ត្រ

ទី៣. ច្បាប់ត្រូវបានតាក់តែងឡើង តាមនីតិវិធីជាក់លាក់ ដោយអង្គភាពមានសមត្ថកិច្ចរៀងៗខ្លួន។

ជាង១០០ឆ្នាំ (១៨៦៣ ដល់ឆ្នាំ ១៩៧០) ប្រព័ន្ធច្បាប់ស៊ីវិលរបស់បារាំងគ្រាន់តែ***បានជ្រៀតចូលជាទម្រង់ និងយន្តការដោះស្រាយជម្លោះ***។ ពីឆ្នាំ១៩៧០ ដល់ ២០០៧ (ជាង៣៧ឆ្នាំ) (លើកលែងក្រមរដ្ឋប្បវេណី) ប្រព័ន្ធច្បាប់ផ្សេងចូលមកក្នុងប្រព័ន្ធច្បាប់កម្ពុជា។ ចាប់ពីឆ្នាំ២០០៧ មក ទោះបីមានទម្រង់ជាច្បាប់និងក្រមមួយចំនួន ខ្លឹមសារនៃច្បាប់ភាគច្រើនមិនលម្អិត ដែលមិនត្រូវនឹងនិយមន័យចង្អៀតនៃពាក្យ ***«ក្រម»***។

ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី យកលំនាំតាមច្បាប់របស់ជប៉ុន រីឯក្រមព្រហ្មទណ្ឌ យកលំនាំតាមក្រមព្រហ្មទណ្ឌរបស់បារាំង និងក្រមនីតិវិធីព្រហ្មទណ្ឌ យកលំនាំចម្រុះរវាងប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ ចាប់ពីឆ្នាំ ១៩៩៣ ខ្លឹមសារក្នុងច្បាប់ជាច្រើនផ្សេងទៀត មានខ្លឹមសារនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង នៅខាងក្នុងច្បាប់នោះ។ ធាតុផ្សំនៃប្រព័ន្ធច្បាប់កម្ពុជាមុនឆ្នាំ១៨៦៣ មានចែងជាអន្លើក្នុងច្បាប់មួយចំនួនក្នុងបរិមាណតិចតួច។

ប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ននេះគឺជា ***ទម្រង់ប្រព័ន្ធច្បាប់ស៊ីវិល ក៏ប៉ុន្តែខ្លឹមសារមួយចំនួនជាប្រព័ន្ធច្បាប់អង់គ្លូសាក់សុង***។ ប្រព័ន្ធច្បាប់កម្ពុជាស្ថិតនៅក្នុងសភាពមួយមិនច្បាស់ និងខុសប្លែកធ្ងាយពីប្រពៃណីនៃប្រទេសនេះ និងខ្វះឯកត្តភាព (unique) នៃប្រព័ន្ធច្បាប់របស់ខ្លួន។

ជំពូកទី៣.
ការវាយតម្លៃអំពីស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

៣.១. ច្បាប់

ក្នុងពេលបច្ចុប្បន្ននេះ កម្ពុជាមានលិខិតបទដ្ឋានគតិយុត្តជាច្រើនប្រភេទ មានរដ្ឋធម្មនុញ្ញ ច្បាប់ (ក្រម) អនុក្រឹត្យ ប្រកាស ដីកា...។ ឋានានុក្រមនៃច្បាប់ត្រូវបានចែងយ៉ាងច្បាស់។[៣៣១] ទិន្នន័យ ប្រហាក់ប្រហែល អាចមានសរុបប្រហែល ៧០០ ច្បាប់ ដែលមានច្បាប់សារធាតុ (មិនមែនច្បាប់ស្តី ពីនីតិវិធី) តាមវិស័យជាង៣០០ (បរិស្ថាន, គ្រឿងញៀន, យុត្តិធម៌អនីតិជន...)។ អ្វីជាការកត់សំគាល់ក្នុងទីនេះផងដែរ ប្រសិនបើធៀបក្នុងសម័យមុន មានកំណើនក្រម ហើយច្បាប់តាមវិស័យមួយចំនួន ទោះបីជា មិនក្នុងទម្រង់ក្រម ក៏មានលក្ខណៈលម្អិតគួរសម។[៣៣២] ចំនួននេះកើនឡើងច្រើន ក្នុងរយៈពេល ៣២ (១៩៩៣-២០២៥) បើធៀបនឹងរយៈពេល ១០០ឆ្នាំ (១៨៦៣-១៩៥៣) ដែលមាន[៣៣៣] លិខិតបទដ្ឋានគតិយុត្តប្រហែល ៥០។ ច្បាប់អន្តរជាតិ ក៏មានសន្ទុះច្រើន ខុសសម័យមុន។ ក្រោយឆ្នាំ១៩៩៣ កម្ពុជា បានចូលជាភាគី ឬជាសមាជិកអង្គការអន្តរជាតិក្នុងទម្រង់ ពហុភាគីឬទ្វេភាគី ក្នុងវិស័យជាច្រើនជាងមានប្រមាណ៣០០ សន្ធិសញ្ញាឬកិច្ចព្រមព្រៀង (មិនមានទិន្នន័យជាក់លាក់ និងយន្តការគ្រប់គ្រងមានប្រសិទ្ធភាព)។

យោងលើការដាក់ចំណងជើង តាមមាត្រា និងខ្លឹមសារខ្លី ច្បាប់ខ្លះមានទម្រង់នៃច្បាប់នៃប្រព័ន្ធប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ ទោះបីជាក្រម ក្នុងទម្រង់ប្រព័ន្ធច្បាប់ស៊ីវិលក្តី ក៏មិនទាន់មានភាពលម្អិតនោះដែរ ក្នុងន័យថាមានវិស័យតូចៗជាច្រើនក្នុងក្រមក៏ប៉ុន្តែមិនបានបង្ហាញលម្អិត។ នេះឆ្លុះបញ្ចាំងតាមរយៈតម្រូវការនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តបន្ថែមដើម្បីអនុវត្ត (ច្បាប់ចង្អុលឲ្យបង្កើតលិខិតបទដ្ឋានគតិយុត្ត) តម្រូវក្នុងក្រមក៏ដូចជាច្បាប់ដទៃទៀត។ នេះជាកត្តាមួយ ដែលនាំឲ្យច្បាប់មួយចំនួនចូលជាធរមាន មិនអាចត្រូវបានអនុវត្តបានភ្លាម ឬអនុវត្តបានពេញលេញដោយរងចាំនូវលិខិតបទដ្ឋានគតិយុត្តដទៃទៀត។

---

[៣៣១] ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ២០១៨, មាត្រា១៧។

[៣៣២] ច្បាប់ស្តីពីភូមិបាលកម្ពុជា ឆ្នាំ២០០១។

[៣៣៣] សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខបច្ចេកវិទ្យាឆ្នាំ២០២៥។

ទោះបីទម្រង់នៃច្បាប់ (ច្បាប់ជាលាយលក្ខណ៍អក្សរ) និងយន្តការ ជាប្រព័ន្ធច្បាប់ស៊ីវិល មានតែក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី (តាមលំនាំប្រទេសជប៉ុន) និងក្រមព្រហ្មទណ្ឌ (យកលំនាំតាមបារាំង) និង នីតិវិធីព្រហ្មទណ្ឌយកលំនាំតាមច្បាប់បារាំងរួមផ្សំធាតុផ្សំនៃច្បាប់អន្តរជាតិ ឬប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (សិទ្ធិទទួលបានការជូនដំណឹងបទចោទ, សិទ្ធិសួរតទល់, សិទ្ធិទទួលបានការពិនិត្យមើលភាពស្របច្បាប់នៃការឃុំខ្លួន)។

ខ្លឹមសារនៃច្បាប់មួយចំនួន ជាពិសេសពាក់ព័ន្ធពាណិជ្ជកម្ម ដូចជាច្បាប់សហគ្រាសពាណិជ្ជកម្ម មានខ្លឹមសារ ជាគម្រូនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងបន្ថែមដោយច្បាប់មួយចំនួន ត្រូវបានធ្វើឡើងតម្រូវដោយសន្ធិសញ្ញាឬកិច្ចព្រមព្រៀងអន្តរជាតិដែលកម្ពុជាជាភាគី ដូចជាច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ ច្បាប់ស្តីពីប្រកាសនីយបត្រកម្ម ជាដើម។ នេះដោយសារ មានការជួយតាមរយៈជំនួយធ្វើច្បាប់របស់ប្រទេសប្រកាន់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង[៣៣៤] ឬត្រូវទទួលយកនូវប្រភេទច្បាប់ណាមួយ ដោយសារតម្រូវតាមសន្ធិសញ្ញា ឬកិច្ចព្រមព្រៀងដែលកម្ពុជាចូលជាភាគី។

ពាក់ព័ន្ធនឹងខ្លឹមសារច្បាប់នេះដែរ ចង់មិនចង់ ពិតនឹងមិនមានសង្គតិភាពខ្លះសូម្បីក្នុងលិខិតបទដ្ឋានគតិយុត្តតែមួយ និងក៏មានសង្គតិភាពរវាងខ្លឹមសារ ពាក្យពេចន៍ (និយមន័យ) នៃជីកា ប្រកាស រហូតដល់ខ្លឹមសារនៃអនុក្រឹត្យ តាមឋានានុក្រម។ នេះដោយសារ មិនមានយន្តការត្រួតពិនិត្យនីត្យានុកូលភាពជាទៀងទាត់និងខ្សែសង្វាក់។ ជាក់ស្តែង ប្រកាស ត្រូវរៀបចំធ្វើឲ្យក្រសួងសាមី និងមិនឆ្លងកាត់យន្តការ ត្រួតពិនិត្យខាងក្រៅ។ ជាសរុប យើងអាចសន្និដ្ឋានថា ក្នុងពេលបច្ចុប្បន្ន មានការរីកចំរើនច្រើនលើបរិមាណនៃច្បាប់ ក៏ប៉ុន្តែគុណភាពនៃបទប្បញ្ញត្តិឬនៃច្បាប់ទាំងមូលនៅជាបញ្ហាចម្បង។

ខាងក្រោមនេះ ជាស្ថានភាពនៃខ្លឹមសារច្បាប់ (បានពីការពិនិត្យលើខ្លឹមសារច្បាប់មួយចំនួន) សម្រាប់ជាការពិចារណាវិភាគ៖

១. ក្នុងច្បាប់តែមួយមានធាតុផ្សំប្រព័ន្ធច្បាប់ស៊ីវិលនិងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ៖ ក្រុមហ៊ុនមានអត្ថិភាពលុះត្រាចុះបញ្ជី (ស៊ីវិលឡ) ក្នុងឯកសារចុះបញ្ជី ត្រូវនិយាយអំពីដើមទុន ប្រភេទនៃភាគហ៊ុន សិទ្ធិនិងការកម្រិតសិទ្ធិ(ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង) (ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, មាត្រា ៩១,៩៣,៩៧និង៩៨)។

[334] Kong Phallack, Overview of the Cambodian Legal and Judicial System, p. 8.

២. យន្តការអនុវត្ត៖ ភាគីទទួលទ្រព្យធានា (secured party) អាចទទួលបានទ្រព្យ ដោយ មិនចាំបាច់ឆ្លងនីតិវិធីតុលាការ (ប្រព័ន្ធច្បាប់ស៊ីវិល) ភាគីអាចអនុវត្តយកទ្រព្យបាន ជាការឆ្លើយតបប្រសិនបើភាគី ដទៃបំពានកិច្ចសន្យា។ ប្រសិនកូនបំណុលជំទាស់ទើបទាមទារការបញ្ជាក់ពីតុលាការ (Law on Secured Transactions)។

៣. បណ្តឹងស្តីពីការក្ស័យធន អាចត្រូវបានធ្វើឡើងដោយកូនបំណុល, ម្ចាស់បំណុល, នាយក ឬព្រះរាជអាជ្ញា (មាត្រា៨ នៃច្បាប់ស្តីពីការក្ស័យធន) ក៏ប៉ុន្តែ សម្រាប់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង អ្នកដែលអាចដាក់បណ្តឹងបានទូលាយជាង។

ជាការកត់សំគាល់ពាក់ព័ន្ធនឹងក្របខណ្ឌច្បាប់ពាណិជ្ជកម្មកម្ពុជា ក្នុងទម្រង់ប្រព័ន្ធច្បាប់ស៊ីវិលមាន៖ ការចងក្រង ការចុះបញ្ជី ភាពតឹងរឹងក្នុងផ្នែកនីតិវិធី និងមានដាក់បញ្ចូលនូវធាតុផ្សំនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង (នវានុវត្ត) ក្នុងច្បាប់ដើម្បីឲ្យមានការទទួលស្គាល់ និងអនុវត្តបាន សម្រាប់អ្នកវិនិយោគិន និងម្ចាស់បំណុលបរទេស។

៤. ច្បាប់ចំនួន៣ យ៉ាងតិច ដែលត្រូវបានរៀបចំតម្រូវតាមកិច្ចព្រមព្រៀងអន្តរជាតិពាក់ព័ន្ធនឹងពាណិជ្ជកម្ម និងដែលមានធាតុផ្សំនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង តាមរយៈការចូលរួមយោបល់ពីអ្នកជំនាញនៃប្រទេស ហ្វីលីពីន ម៉ាឡេស៊ី សហរដ្ឋអាមេរិក នូវែលហ្សេឡង់ ASEAN និង WIPO (ច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា ច្បាប់ស្តីពីការការពារអ្នកប្រើប្រាស់ និងច្បាប់ស្តីពីការប្រកួតប្រជែង) ដែលយកលំនាំតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ មានសំណួរអាចត្រូវបានសួរថា តើអនុវត្តវិធានការបណ្តោះអាសន្នដូចម្តេចក្នុងច្បាប់ស្តីពីកម្មសិទ្ធិបញ្ញា, តើត្រូវធ្វើឡើងតាមនីតិវិធីរក្សាការពារចែងក្នុងក្រមរដ្ឋប្បវេណីរបៀបណា, តើអ្វីទៅជាជំនួញមិនត្រឹមត្រូវ (unfair trade) ដែលពាក្យនេះយកពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុង?

ប្រការនេះចង់មិនចង់ នឹងបើកផ្លូវទូលាយឲ្យចៅក្រមបកស្រាយខ្លឹមសារច្បាប់។ គួរឱ្យកត់សំគាល់ផងដែរ វាហាក់បីដូចជា និន្នាការប្រកាន់យុត្តិសាស្ត្រផងដែរ ប្រសិនបើពិនិត្យមើលរបៀបដែលមជ្ឈត្តការការងារ ក្រុមប្រឹក្សាធម្មនុញ្ញ និងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាធ្វើការងារ។

៥. និយមន័យក្នុងច្បាប់៖ មានច្បាប់ជាច្រើនដែលផ្តល់និយមន័យលើពាក្យតែមួយដូចជា «នីតិបុគ្គល» ដែលមានខ្លឹមសារខុសគ្នា បន្ថែមបន្ថយ និងក្នុងករណីខ្លះផ្ទុយគ្នា (ច្បាប់ស្តីពីគ្រប់គ្រងខេត្ត ក្រុង ច្បាប់ស្តីពីភូមិបាល និងច្បាប់ស្តីពីពន្ធដារ)។ ច្បាប់ស្តីពីការគ្រប់គ្រងខេត្តចែងថា ***នីតិបុគ្គលនៃនីតិសាធារណៈ (Public Legal Entity) គឺជាក្រុមមនុស្សដែលច្បាប់បានអនុញ្ញាតឱ្យ ធ្វើសកម្មភាព ដូចជាបុគ្គល ដើម្បីជាផល***

ប្រយោជន៍សាធារណៈ ។ ខណៈច្បាប់ស្តីពីភូមិបាលចែងថា ***នីតិបុគ្គល ក្រុមមនុស្សដែលច្បាប់ទទួលស្គាល់ថាជាបុគ្គលដែរ តែជាទៃពីសមាជិកនៃខ្លួន***។ ឧទាហរណ៍ ពុទ្ធិកសមាគម ជានីតិបុគ្គល ក្រុមហ៊ុនក៏ជានីតិបុគ្គលដែរ។ ***នីតិបុគ្គលនៃនីតិសាធារណៈ*** ៖ ក្រុមរាជការសាធារណៈ។ ឧទាហរណ៍ រដ្ឋ ខេត្ត ឃុំ ឬគ្រឹះស្ថានសាធារណៈ ដូចជាសាកលវិទ្យាល័យជាដើម។ ***នីតិបុគ្គលនៃនីតិឯកជន*** ៖ សមាគម ក្រុមហ៊ុន ក្រុមមូលនិធិ។

៦. ខ្លឹមសារមិនច្បាស់ ៖ ក្រមព្រហ្មទណ្ឌឆ្នាំ២០១០ ចែងតែបទល្មើសមានបីប្រភេទ (លហុ មជ្ឈិម និងបទឧក្រិដ្ឋ) រីឯច្បាប់ស្តីពីការបង្ក្រាបអំពើហិង្សាក្នុងគ្រួសារ មានបទល្មើសមជ្ឈិមធ្ងន់(មាត្រា១៧) និងមិនបានផ្តល់អត្ថន័យឡើយ។

៧. ខ្លឹមសារផ្ទុយគ្នា ៖ ក្រមព្រហ្មទណ្ឌ ចែងនូវការបន្ថយទោសពាក់កណ្តាលជាស្វ័យប្រវត្តិ ដល់អនីតិជន ទោះបីប្រព្រឹត្តបទល្មើសប្រភេទអ្វីក៏ដោយ។ ក៏ប៉ុន្តែច្បាប់ស្តីពីការគ្រប់គ្រងគ្រឿងញៀន ចែងបដិសេធការបន្ថយទោស ក្នុងករណីអនីតិជនប្រព្រឹត្តិបទគ្រឿងញៀន (មាត្រា៣២)។

៨. ក្រៅពីច្បាប់ មានលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ជាច្រើនទៀត ដូចជាអនុក្រឹត្យ និងប្រកាសរបស់ក្រសួង ដែលអាចមានច្រើនពាន់។ ខ្លឹមសារនៃប្រកាស ចង់មិនចង់ អាចមានខ្លឹមសារផ្ទុយនឹងលិខិតបទដ្ឋានគតិយុត្តខ្ពស់ជាង និងមានការប្រើប្រាស់ពាក្យ មិនមានភាពស៊ីសង្វាក់គ្នា។

៩. ច្បាប់ភាគច្រើន (លើកលែងក្រមនីតិវិធីព្រហ្មទណ្ឌ....) ចែងខ្លឹមសារនិរាករណ៍ទូទៅ ឬដោយតុណ្ហីភាព) ដែលនាំឲ្យសាធារណជនពិបាកដឹងថា អ្វីជាខ្លឹមសារពិតដែលត្រូវបាននិរាករណ៍។ បន្ថែមពីលើនេះ ច្បាប់មួយចំនួនផងដែរ មានចែងអំពីបទប្បញ្ញត្តិការប្រកាសច្បាប់ជាការប្រញាប់។

១០. ខ្លឹមសារពន្យល់ច្បាប់ ៖ ភាគច្រើននៃច្បាប់ មិនត្រូវបានធ្វើការពន្យល់ខ្លឹមសារទេ មានតែកំណត់តាមមាត្រានីមួយៗ លើក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ស្តីពីការបង្ក្រាបអំពើហិង្សាក្នុងគ្រួសារ និងច្បាប់ស្តីពីការបង្ក្រាបអំពើកេរ្តិ៍ឈ្មោះ។ ពាក់ព័ន្ធនឹងចំណុចនេះ រាជរដ្ឋាភិបាល តាមរយៈអនុក្រឹត្យ សារាចរ ឬប្រកាសរបស់ក្រសួង អាចដាក់ចេញគោលការណ៍ណែនាំក្នុងការអនុវត្តច្បាប់។ ជាក់ស្តែងកន្លងមកមាន អនុក្រឹត្យ[៣៣៥] ក៏

[៣៣៥] អនុក្រឹត្យលេខ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥។

ដូចជា ប្រកាសលេខ០៣៧ (ឆ្នាំ២០០២) របស់ក្រសួងសុខាភិបាលស្តីពីការណែនាំអនុវត្តច្បាប់រំលូតកូន។ សារាចរលេខ០១៧ (ឆ្នាំ២០២៥) របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុស្តីពីការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥។

សម្រាប់នីតិវិធីនិងយន្តការរៀបចំច្បាប់ វាមានលក្ខណៈជាក់លាក់ និងជារចនាសម្ព័ន្ធជាច្រើន។ វាអាចជាលើកទី១ ដែលកម្ពុជាមានលិខិតបទដ្ឋានណែនាំអំពីការតាក់តែងនិងត្រូវបានធ្វើការកែសម្រួល ក្នុងឆ្នាំ២០២៤។ ទោះបីជាយ៉ាងនេះ ការណែនាំជាខ្លឹមសារសារធាតុ នៅមិនទាន់មាននៅឡើយ។

ការបោះពុម្ពផ្សាយក្នុងរាជកិច្ចមានសន្ទុះផុសផល ក៏ប៉ុន្តែ ការផ្សព្វផ្សាយច្បាប់ជាក់ស្តែងដល់អ្នកពាក់ព័ន្ធនិងសាធារណជននៅមានកម្រិត។ ក្នុងន័យថា ចំនួនច្បាប់ដែលត្រូវបានផ្សព្វផ្សាយ មានចំនួនតិចតួច ហើយក្រសួងសាមី ផ្សព្វផ្សាយតែច្បាប់ក្នុងសមត្ថកិច្ចរបស់ខ្លួន។ ក្រុមការងារស្រាវជ្រាវ ដែលជាអ្នកជំនាញច្បាប់ និងធ្លាប់ចូលរួមរៀបចំច្បាប់ ហ៊ានអះអាងថា ទិន្នន័យច្បាប់ ជាពិសេស ខ្លឹមសារមួយណាត្រូវបានកែប្រែ ឬមួយណាត្រូវបាននិរាករណ៍ គឺជាបញ្ហាមួយត្រូវដោះស្រាយជាបន្ទាន់ ដោយសារ វាប្រទាក់ក្រឡា ជាមួយការយល់ដឹងច្បាប់ អនុវត្តច្បាប់និងតាមដានការអនុវត្តច្បាប់។

៣.២. ការអនុវត្តច្បាប់

ក្រុមការងារស្រាវជ្រាវអាចវាយតម្លៃបានថា (មិនពិចារណាលើភាពមិនស៊ីសង្វាក់រវាងបទប្បញ្ញត្តិនៃច្បាប់) ការអនុវត្តច្បាប់នៅប្រឈមបញ្ហាច្រើន យន្តការនៃការបកស្រាយមិនមានភាពជាក់លាក់។ ខណៈជាមួយការរំពឹងថា ចៅក្រមអាចជួយបំភ្លឺបញ្ហាច្បាប់ តាមរយៈការអនុវត្តនូវច្បាប់ក្នុងសំណុំរឿង សាលក្រមនិងសាលដីកា មិនត្រូវបានផ្សព្វផ្សាយទូលំទូលាយ។

រដ្ឋធម្មនុញ្ញ ចែងថាក្រុមប្រឹក្សាធម្មនុញ្ញមានអំណាចបកស្រាយច្បាប់ និងរដ្ឋធម្មនុញ្ញ ក្រៅពីនេះ មិនមានលិខិតបទដ្ឋានគតិយុត្តចង្អុលថា ស្ថាប័នណាទៀតមានអំណាចបកស្រាយច្បាប់ ឬចែងអំពីវិធីសាស្ត្រនៃការបកស្រាយច្បាប់។ មិនមានការចូលរួមពីបញ្ញវន្តច្បាប់ល្បីៗចូលរួមជាទ្រឹស្តីច្បាប់ (បទអត្ថាធិប្បាយច្បាប់) ដែលតាមចរិតនៃប្រព័ន្ធច្បាប់ស៊ីវិល បញ្ញាវន្តបានដើរតួនាទីសំខាន់ បើប្រៀបធៀបនឹងបញ្ញវន្តក្នុងប្រទេសប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។

ការអនុវត្តប្រឈមនឹងឧបសគ្គជាច្រើន កើតចេញពីភាពមិនស៊ីសង្វាក់គ្នារវាងបទប្បញ្ញត្តិ ខ្លឹមសារម្តងតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ម្តងតាមប្រព័ន្ធច្បាប់ស៊ីវិល (ប្រធានសក្តិ)[៣៣៦]។ បន្ថែមពីលើនេះ ខ្លឹមសារនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការអនុវត្ត តាមបែបប្រព័ន្ធច្បាប់ស៊ីវិល។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បង្កើតយន្តការជាច្រើន ក្នុងនោះមានយន្តការអនុវត្តច្បាប់ ក៏ប៉ុន្តែដោយសារឥទ្ធិពលនៃរបបកម្ពុជាប្រជាធិតេយ្យ (បាត់ទំនុកចិត្តលើច្បាប់ និងការបំផ្លាញទាំងស្រុងនៃប្រព័ន្ធច្បាប់)[៣៣៧] ប្រព័ន្ធច្បាប់សង្គមនិយម មានអាយុ១០ឆ្នាំ (១៩៧៩-១៩៨៩) បានបង្កើតនូវផ្នត់គំនិតអនុវត្តច្បាប់ តាមបែបសង្គមនិយម លុបលើច្បាប់ជាទម្រង់ប្រព័ន្ធច្បាប់ស៊ីវិល។ ខណៈដែលអ្នកច្បាប់ អ្នកអនុវត្តច្បាប់ បច្ចុប្បន្ន ទទួលបានការបណ្តុះបណ្តាលផ្នត់គំនិតស្តីពីខ្លឹមសារច្បាប់ឬវិធីសាស្ត្រគតិយុត្តនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។ នេះជាបញ្ហាលំបាកបន្ថែមពីលើយន្តការអនុវត្ត ឬដោះស្រាយជម្លោះតាមទម្រង់ប្រព័ន្ធច្បាប់ស៊ីវិល កើតចេញពីជម្លោះនៃការបកស្រាយឬអនុវត្តខ្លឹមសារប្រព័ន្ធច្បាប់អង់គ្លូសាក់សុង។

សម្រាប់ការអនុវត្តច្បាប់អន្តរជាតិវិញ គិតតាំងពីឆ្នាំ១៨៦៣ មកដល់ពេលនេះ ខណៈដែលចំនួនកិច្ចព្រមព្រៀងឬសន្ធិសញ្ញា ដែលកម្ពុជាមានចំនួនច្រើន ការអនុវត្តនៅតែឆ្លុះលើទិដ្ឋភាពទឹកនិងប្រេង។ នេះ ក្នុងន័យថា មិនបានអនុវត្តជាក់ស្តែងពេញលេញ (give effect to international law) ក្នុងខណៈសកលភាវូបនីយកម្ម ដែលច្បាប់អន្តរជាតិដើរតួ និងគ្រប់គ្រងលើទំនាក់ទំនងរវាងរដ្ឋនិងរដ្ឋ រដ្ឋនិងឯកជន ឬរដ្ឋនិងអង្គការអន្តរជាតិ។

៣.៣. យន្តការនៃការដោះស្រាយជម្លោះ

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានបង្កើតក្រុមប្រឹក្សាធម្មនុញ្ញ។ បន្ថែមពីលើនេះ រដ្ឋធម្មនុញ្ញបានចែងអំពីការបែងចែកអំណាច ដោយផ្តល់អំណាចតុលាការវិនិច្ឆ័យសេចក្តី លើបញ្ហារដ្ឋបាល។[៣៣៨] តុលាការសម្រេចសេចក្តី មានបីកម្រិត គឺតុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង។

---

[336] Dr. sc. Caslav Pejovic, Civil Law and Common Law: Two Different paths leading to the same goal, PPP. God 40 (2001) 155, p.14.
[337] Victoria Amann-Lasnier, Overview of the Cambodian History, Governance and Legal Sources, 2019, p. 6.
[៣៣៨] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១២៨ថ្មី។

ដំណើរការនៃស្ថាប័នវិជ្ជាជីវៈមេធាវី បានចាប់ផ្តើមដំណើរការ។ ឆ្នាំ១៩៩៥ ច្បាប់ស្តីពីលក្ខន្តិកៈមេធាវីត្រូវបានអនុម័ត។ ជាបន្តបន្ទាប់ គុណាការជំនាញ ត្រូវបានស្នើឲ្យបង្កើត[៣៣៩] (ក្រុមប្រឹក្សាអាជ្ញាកណ្តាល)[៣៤០]។ ពាក់ព័ន្ធការបកស្រាយច្បាប់ មិនមានលិខិតបទដ្ឋានណាមួយចែងនៅឡើយ។ ក្រុមប្រឹក្សាធម្មនុញ្ញបកស្រាយច្បាប់។[៣៤១]

តាមរយៈការពិភាក្សាលើសមាសភាគនៃប្រព័ន្ធច្បាប់ រួមមានយន្តការធ្វើច្បាប់ យន្តការដោះស្រាយជម្លោះ វិធាន និងនីតិវិធី។ គេអាចវាយតម្លៃជាបឋមអំពីប្រព័ន្ធច្បាប់កម្ពុជាបានថា មិនទាន់មានភាពជាក់លាក់ (unique) របស់ខ្លួននៅឡើយ។ ប្រព័ន្ធច្បាប់ស៊ីវិលដែលទទួលយក តាមរយៈអាណានិគមបារាំងនៅតែជាធាតុចម្បងជាទម្រង់ និងយន្តការដោះស្រាយជម្លោះ ក្នុងប្រព័ន្ធច្បាប់ខ្មែរ និងជាប្រព័ន្ធច្បាប់ស៊ីវិលបែបបុរាណ (មិនមានការកែទម្រង់)[៣៤២]។ ធាតុផ្សំនៃវិធានច្បាប់បុរាណ កាន់តែថមថយ ឬរីឯសមាសភាគថ្មីនៃប្រព័ន្ធអង់គ្លូសាក់សុង បានជៀតចូលក្នុងប្រព័ន្ធច្បាប់កម្ពុជាតាមរយៈការផ្តល់ជំនួយ និងការចូលរួមក្នុងយន្តការសកលភារូបនីយកម្ម[៣៤៣] បង្កជាភាពស្រពេចប្រពិលនាំឲ្យពិបាកអនុវត្តច្បាប់ (ខ្លឹមសារប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល)។

សម្រាប់ចំណុចខ្លាំងនៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន គឺមានភាពសម្បូរបែបនៃលិខិតបទដ្ឋានគតិយុត្តទាំងជាតិ និងអន្តរជាតិ យន្តការដោះស្រាយជម្លោះច្រើន វិធីសាស្ត្រនៃការតាក់តែង និងយន្តការនៃការធ្វើច្បាប់មានភាពប្រាកដប្រជាជាងមុន។ ទោះបីជាយ៉ាងនេះក្តី យន្តការអនុវត្តច្បាប់ ត្រួតពិនិត្យការអនុវត្តច្បាប់ គ្រប់គ្រងច្បាប់ពាក់ព័ន្ធសង្គតិភាព និងគុណភាពបទប្បញ្ញត្តិច្បាប់គឺជាបញ្ហានៅឡើយ។ បន្ថែមពីលើនេះ ការមិនទាន់កែសម្រួលប្រព័ន្ធច្បាប់ស៊ីវិលឲ្យសមស្របតាមការវិវត្ត ដូចអះអាងខាងលើ គឺចំណុចខ្សោយមួយ។

គុណសម្បត្តិនិងគុណវិបត្តិ: ប្រព័ន្ធច្បាប់ស៊ីវិលដែលកម្ពុជាទទួលរងឥទ្ធិពលពីបារាំងនៅតែស្ថិតនៅជាចម្បងក្នុងផ្នត់គំនិតអ្នកច្បាប់ខ្មែរ និងមានលាយបញ្ចូលនូវភាពចម្រុះនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដែលអាចអះអាងថា សមស្របនឹងនិន្នាការច្បាប់ក្នុង

---

[៣៣៩] សូមមើលលេខយោងទី១១៩ ខាងលើ។

[៣៤០] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១២៨ថ្មី។

[៣៤១] រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣, មាត្រា១១៧។

[342] Clauspeter Hill, Constitutionalism in the Southeast Asia, 2008, Jogre Menzel, Cambodia-From civil war to a constitution to constitutionalism? in p. 61.

[343] Kathryn E. Neilson, Q.C. they killed all the lawyers, Rebuilding the Judicial system in Cambodian, 1996, pp.10-11.

ពិភពលោក។ ទន្ទឹមនឹងនេះ ភាពចម្រុះ ក៏នឹងជាគុណវិបត្តិដែលពិបាកដល់ការអនុវត្ត។ ក្នុងន័យថា ខ្លឹមសារសារធាតុនៃច្បាប់ខ្លះ ជាទម្រង់ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការអនុវត្ត គឺក្នុងទម្រង់ជាប្រព័ន្ធច្បាប់ស៊ីវិល។

ប្រព័ន្ធច្បាប់អ្វីសមស្របសម្រាប់កម្ពុជា៖ ចុងក្រោយ ដោយសារតែការទទួលរងឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិល យូរយោរមកហើយ (១៦២ឆ្នាំ) ខ្លឹមសារនៃប្រព័ន្ធច្បាប់ស៊ីវិលនៅតែជាចម្បងក្នុងប្រព័ន្ធដឹកនាំកម្ពុជា។ ប្រព័ន្ធច្បាប់ដ៏សមស្របសម្រាប់កម្ពុជា គឺជា***ប្រព័ន្ធច្បាប់ចម្រុះ ស្របតាមសម័យកាល មានជាតុផ្សំដើមនៃច្បាប់កម្ពុជាសម័យបុរាណ (ស្របបរិបទក្នុងស្រុក) និងមានសុខុដុមនីយកម្មរវាងខ្លឹមសារនៃច្បាប់និងយន្តការអនុវត្ត***។ បន្ថែមពីលើនេះ ប្រព័ន្ធច្បាប់ដែលសមស្រប គឺជួយជម្រុញអនុវត្តយ៉ាងណាឲ្យមានលក្ខណៈមេត្រីជាមួយវិធានច្បាប់អន្តរជាតិ។

សេចក្តីសន្និដ្ឋាន

តាមរយៈការពិភាក្សាលើសមាសភាគនៃប្រព័ន្ធច្បាប់ រួមមានយន្តការធ្វើច្បាប់ យន្តការដោះស្រាយជម្លោះ វិធាន និងនីតិវិធី។ គេអាចវាយតម្លៃជាបឋមអំពីប្រព័ន្ធច្បាប់កម្ពុជាបានថា មិនទាន់មានភាពជាក់លាក់ (unique) របស់ខ្លួននៅឡើយ។ ប្រព័ន្ធច្បាប់ស៊ីវិលដែលទទួលយកតាមរយៈអាណានិគមបារាំងនៅតែ ជាធាតុចម្បងក្នុងប្រព័ន្ធច្បាប់ខ្មែរ។ ធាតុផ្សំនៃវិធានបុរាណកាន់តែថមថយ ឬរីឯសមាសភាគថ្មីនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បានចូលក្នុងប្រព័ន្ធច្បាប់កម្ពុជា តាមរយៈការផ្តល់ជំនួយ និងការចូលរួមក្នុងយន្តការសកលភាវូបនីយកម្ម ដែលបង្កជាភាពស្រពេចប្រពិល នាំឲ្យពិបាកអនុវត្តច្បាប់ (ខ្លឹមសារប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល)។

អនុសាសន៍

ក. ជាដំបូង ក្រៅអំពីគោលការណ៍ណែនាំស្តីពីទម្រង់នៃច្បាប់ គួរមានគោលការណ៍ណែនាំស្តីពីការតាក់តែងខ្លឹមសារសារធាតុនៃច្បាប់។

ខ. គួរតែមានការសិក្សាលំអិត តាមលំដាប់លំដោយកាលបរិច្ឆេទ ច្បាប់តាមវិស័យនីមួយៗ ដូចជាវិស័យរ៉ែ ដោយក្តោបលើលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ ការវិវត្តិ ខ្លឹមសារនិរាករណ៍ ដើម្បីជាការបន្សុំបញ្ចូលគ្នា (benchmark) សម្រាប់ការរៀបចំលិខិតបទដ្ឋានគតិយុត្ត វាយតម្លៃសេចក្តីព្រាងច្បាប់ថ្មី មានចែងជាន់អ្វីខ្លះ ខ្វះខាតអ្វីខ្លះ ផ្ទុយនឹងបទប្បញ្ញត្តិអ្វីខ្លះ ព្រមទាំងត្រូវនិរាករណ៍បទប្បញ្ញត្តិអ្វីខ្លះ។

គ. ពាក្យពេចន៍ដែលប្រើ ព្រមទាំងការកំណត់និយមន័យនៃពាក្យក្នុងច្បាប់ ពិតជាសំខាន់ជាពិសេស ពាក្យពេចន៍ ពាក់ព័ន្ធការកំណត់វិសាលភាពនៃច្បាប់ ឬសមត្ថកិច្ចនៃស្ថាប័នអនុវត្តច្បាប់។ ក្នុងន័យនេះ តារាងសន្ទានុក្រមនៃច្បាប់ទាំងអស់ ពីមុនសេចក្តីព្រាងច្បាប់ គួរត្រូវបានចងក្រងនិងសិក្សា សម្រាប់ជាជំនួយក្នុងការរៀបចំខ្លឹមសារនៃពាក្យពេចន៍។ តើគួរផ្តល់និយមន័យលើពាក្យអ្វី ខ្លឹមសារនៃពាក្យពេចន៍ផ្ទុយគ្នាដែរឬទេ។

ឃ. ចំណុច**ខ** និង **គ** ខាងលើ អាចពិបាកសម្រេចបាន ឬក៏អាចបង្កការពន្យារពេលក្នុងការសម្រេចធ្វើច្បាប់ឲ្យបានឆាប់ ក៏ប៉ុន្តែគេគួរចងចាំថា វានឹងនាំឲ្យការតាក់តែងច្បាប់ និងការផ្តល់យោបល់ច្បាប់ បានល្អគ្រប់ជ្រុងជ្រោយ អាចអនុវត្តទៅបានរលូន មិននាំឲ្យមានការកែសម្រួលច្បាប់ញឹកញាប់ (ក្រោយពេលអនុវត្ត) ប៉ះដល់ភាពជាក់លាក់នៃច្បាប់ក៏ដូចជាគោលការណ៍នៃភាពអាចប្រមើលមើលលើច្បាប់ (foreseeability) ក្នុងចំណោមសាធារណជន។

ង. ជាសត្យានុម័ត វាមិនអាចទៅរួចទេ ដែលនឹងមានច្បាប់មានគុណភាពល្អឥតខ្ចោះ ដោយសារអ្នកធ្វើច្បាប់មិនមែនជាទេវតា។ វានៅតែមានចន្លោះខ្វះខាត ភាពមិនច្បាស់លាស់ ដែលតម្រូវឲ្យមានការបកស្រាយច្បាប់។ ក្នុងន័យនេះ គួរតែមាន៖

> **ង.១.** លិខិតបទដ្ឋានគតិយុត្ត ឬសេចក្តីណែនាំស្តីពីការបកស្រាយច្បាប់ (ប្រទេសខ្លះក្នុងតំបន់អាស៊ាន ក៏មានដែរ) ក្នុងនោះសង្កត់ធ្ងន់លើទំនាក់ទំនងរវាងច្បាប់មុន និងច្បាប់អនុម័តតាមក្រោយ ច្បាប់ទូទៅនិងច្បាប់ពិសេស ក៏ដូចជាបញ្ហានិរាករណ៍។

ង.២. កំណត់ត្រានៃកិច្ចប្រជុំតាំងពីសេចក្តីព្រាងដំបូងនៅក្នុងកម្រិតក្រសួងសាមី ដល់ការពិភាក្សារបស់ព្រឹទ្ធសភា ឬក្នុងពេលអំឡុងក្រុមប្រឹក្សាធម្មនុញ្ញ (ករណីច្បាប់មួយចំនួន) គួរចងក្រងទុកតាមលំដាប់លំដោយ ច្បាស់លាស់ងាយរកបានដើម្បីជួយក្នុងការបកស្រាយ ដោយសារតាមរយៈឯកសារទាំងនោះ គេអាចដឹង សំយោគដឹងអំពីចេតនានៃអ្នកតាក់តែងច្បាប់ និងអត្ថន័យនៃពាក្យដែលជាកម្មវត្ថុនៃការបកស្រាយ និងក៏អាចជួយក្នុងការធ្វើខ្លឹមសារពន្យល់ស្តីពីច្បាប់ផងដែរ។

ង.៣. ឯកសារដទៃទៀតក៏សំខាន់ដែរសម្រាប់ជួយក្នុងការបកស្រាយច្បាប់ ដូចជា កំណត់ត្រាស្តីពីមាត្រានីមួយៗ (commentary) ឬ កំណត់ពន្យល់ (explanatory note) ដែលអ្នកតាក់តែងច្បាប់នៃប្រទេសក្នុងប្រព័ន្ធច្បាប់ស៊ីវិលត្រូវធ្វើភ្ជាប់នឹងសេចក្តីព្រាងច្បាប់ (ជាទម្លាប់ពីបុរាណនៃប្រព័ន្ធច្បាប់ស៊ីវិល)។ អត្ថបទទាំងនេះ ជារួម នឹងឲ្យអ្នកអានដឹងអំពីប្រវត្តិនៃការតាក់តែងច្បាប់ ខ្លឹមសារនៃមាត្រាច្បាប់ ពាក្យពេចន៍ជាដើម។

ង.៤. ពាក់ព័ន្ធនឹងការកាត់តែង ការអនុវត្តច្បាប់ឬការបកស្រាយច្បាប់ផងដែរ បទប្បញ្ញត្តិស្តីពីអវិសាន្តប្បញ្ញត្តិ គួរត្រូវសរសេរឲ្យបានជាក់លាក់ ជាអតិបរមា ប្រសិនបើអាចធ្វើបាន។

ង.៥. ជាចុងក្រោយ យន្តការតាមដាននិងសិក្សាការស្រាវជ្រាវអំពីការអនុវត្តច្បាប់រឹតតែសំខាន់ ដើម្បីដឹងថា មានបញ្ហាយល់ដឹងអំពីខ្លឹមសារច្បាប់ ឬការបកស្រាយដែរឬទេ?។ ក្នុងន័យនេះ អំណាចទាំងបី ជាពិសេសតុលាការ គួរធ្វើការងារប្រាស្រ័យទាក់ទងឲ្យបានឆាប់រហ័សទៀងទាត់ជាមួយរដ្ឋសភា ដើម្បីធ្វើការកែសម្រួល ឬធ្វើច្បាប់ថ្មីប្រសិនបើចាំបាច់។

ច. ទោះបីជាច្បាប់ (ក្រម) តាមប្រព័ន្ធច្បាប់ស៊ីវិលមិនលម្អិតពេកក្តីក៏ ប៉ុន្តែក៏មិនត្រូវខ្លីដោយរុញចង្អុលចែងក្នុងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់ច្រើន។ ដោយសារទម្រាំ

នឹងដាក់ចេញនូវឯកសារទាំងនោះដើម្បីអនុវត្តច្បាប់ វាចំណាយពេលវេលាយូរ។[៣៤៤] បន្ថែមពីលើនេះ ដើម្បីធានាប្រសិទ្ធភាព ឬសង្គតិភាពរវាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្រោមច្បាប់នេះ សេចក្តីព្រាងនៃលិខិតខាងក្រោយនេះ គួរត្រូវបានដាក់រួមជាមួយនឹងសេចក្តីព្រាងច្បាប់ ដើម្បីពិនិត្យផ្តល់យោបល់រួមគ្នា។

ឆ. ទោះបីជាប្រកាសក្តី ក៏គួរមានការត្រួតពិនិត្យនីតិានុកូលភាពជាមុន មុននឹងដាក់ចេញឲ្យអនុវត្តជាពិសេស ប្រកាស ឬលិខិតបទដ្ឋានគតិយុត្តដទៃទៀត ដែលបំភ្លឺបញ្ហាច្បាប់។ ក្នុងន័យនេះ យន្តការនៃការពង្រឹងការអនុវត្តការត្រួតពិនិត្យនីតិានុកូលភាពនៃច្បាប់ គួរត្រូវបានរៀបចំ។

ជ. នៅពេលធ្វើច្បាប់ ការពិចារណាគួរថ្លឹងថ្លែងលើខ្លឹមសារនៃធាតុផ្សំនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង អាចអនុវត្តបានទេក្នុងយន្តការអនុវត្ត ឬដោះស្រាយជម្លោះ ក្នុងទម្រង់ជាប្រព័ន្ធច្បាប់ស៊ីវិល។

ឈ. ការបោះពុម្ពនិងផ្សព្វផ្សាយច្បាប់ ដែលជាផ្នែកមួយនៃការចូលរួមឲ្យអនុវត្តច្បាប់ប្រកបដោយប្រសិទ្ធភាព គួរត្រូវបានពង្រឹងឲ្យបានទូលំទូលាយ ជាទៀងទាត់និងរចនាសម្ព័ន្ធ។ ការផ្សព្វផ្សាយសាលក្រម សាលដីកា ក៏ជាការងារមួយដែរ ប្រសិនបើគេសិក្សាអំពីការអនុវត្តរបស់ប្រទេសបារាំង (យោងលើយុត្តិសាស្ត្រអន្តរជាតិ) និងទម្រង់ច្បាប់កម្ពុជា ជាក្រម ក៏ប៉ុន្តែមិនលម្អិត ឬខ្លឹមសារ (ខ្លឹមសារតាមលំនាំនៃប្រព័ន្ធប្រព័ន្ធច្បាប់អង់គ្លូសាក់សុង) បើកច្រកឲ្យតុលាការបកស្រាយ។

[៣៤៤] ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ទាមទារចេញនូវអនុក្រឹត្យ១ និងប្រកាសចំនួន៤។ ច្បាប់ស្តីពីលក្ខន្តិក:ចៅក្រម ទាមទារអនុក្រឹត្យចំនួន២ និងប្រកាសចំនួន៤។ ច្បាប់ស្តីពីការរៀបចំអង្គតុលាការ ទាមទារអនុក្រឹត្យចំនួន៩ និងប្រកាស១។

គន្ថនិទ្ទេស

១. សន្ធិសញ្ញា

សន្ធិសញ្ញារវាង ព្រះចៅអធិរាជបារាំង និង ព្រះមហាក្សត្រខ្មែរសន្ធិសញ្ញាឧត្តុង, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដើម្បីកំណត់លក្ខខណ្ឌអាណាព្យាបាលបារាំង លើប្រទេសកម្ពុជា ; "*Traité conclu à Oudon le 11 août 1863, réglant les conditions du Protectorat Français au Cambodge*", Bulletin du Cambodge, Année 1884 N° 1។

អនុសញ្ញារវាងបារាំងនិងកម្ពុជា, ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ; *"Convention entre la France et le Cambodge, le 17 juin 1884, pour régler les rapports respectifs des deux pays"*។

២. ច្បាប់

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅរបស់គណៈរដ្ឋមន្ត្រីឆ្នាំ២០១៨។

ច្បាប់ស្តីពីភូមិបាលកម្ពុជា ឆ្នាំ២០០១។

សេចក្តីព្រាងច្បាប់ស្តីពីសន្តិសុខបច្ចេកវិទ្យាឆ្នាំ២០២៥។

ច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម ឆ្នាំ២០០៦។

សេចក្តីសម្រេចក្រុមប្រឹក្សាធម្មនុញ្ញឆ្នាំលេខ៩២ ឆ្នាំ២០០៧។

ព្រះរាជក្រឹត្យលេខនស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈឆ្នាំ២០២៤ ស្តីពីការបង្កើតគណៈកម្មការធិការដឹកនាំការកែទម្រង់ច្បាប់។

អនុក្រឹត្យលេខ១១១ ស្តីពីការអនុវត្តច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៥។

សេចក្តីសម្រេចលេខ១១ សសរ ស្តីពីការបង្កើតគណៈកម្មការដឹកនាំកែទម្រង់វាយតម្លៃលើផលប៉ះពាល់នៃលិខិតបទដ្ឋានគតិយុត្តឆ្នាំ២០២៤។

ECCC, Supreme Court Chamber, Decision on Objections to Document Lists (full reasons) 13 December 2015, F26/12.

៣. សៀវភៅ

ហ៊ីង ធីឬទ្ធិ, ប្រជុំអត្ថបទច្បាប់របស់ទីស្តីការរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ឆ្នាំ១៩៨១ លេខ១ ដល់ឆ្នាំ១៩៨៩ លេខ៧ និង កម្រងឯកសារច្បាប់-សារាចររបស់តុលាការ-ក្រសួងយុត្តិធម៌១៩៨០-២០០៧ , ២០០៨។

វេទិកាជំនុំច្បាប់ខ្មែរ, កម្រងឯកសារសិក្ខាសាកល្បងអំពីទស្សនវិជ្ជាច្បាប់ខ្មែរបែបទំនៀម, ២០២៥។

ប្រជុំរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ ១៩៤៧ ដល់១៩៩៣។

ក្រុមប្រឹក្សានីតិកម្ម, ចក្ខុវិស័យនិងយុត្តិសាស្ត្រក្រុមប្រឹក្សានីតិកម្ម, ២០២២។

កម្រងច្បាប់ខ្មែរតាមបែបបារាំង (ភាគ១និងភាគ២), ក្រុមប្រឹក្សានីតិកម្ម, ២០២៥។

Bibliothèque de l'Association Henri Capitant, *"Histoire du Cambodge"*, 2016។

Béactrice Balivet, *"Introduction au droit cambodgien"*, Presses Universitaires du Cambodge 2005។

Eva Steiner, French Law, a comparative approach, 2010។

John Bell et al., Principles of French Law, 2nd ed., 2007។

Penelope Nicholson et al., Examining Practice, Interrogating Theory: Comparative Legal Studies in Asia, 2008។

Eva Steiner, French Law, A comparative approach, 2010។

Mathias Siems, Comparative Law, 2014។

J.R. Spencer, European Criminal Procedure, 2006។

Sally Frances Low, Colonial Law Making, Cambodia under the French, 2024។

Bar Association of the Kingdom of Cambodia, Legal Profession in Cambodia, 2005 ។

៤. អត្ថបទស្រាវជ្រាវ

វ៉ែត កាលីន និងកុល ស្រីមាន អំពើសញ្ជរកម្ម ឆ្នាំ២០១៧។

ហ៊ែល សុំផា របៀបរៀបចំខាងតុលាការនៅសម័យសង្គមរាស្ត្រនិយម ១៩៥៣-១៩៧០។

ទី សុផល, របបសង្គមរាស្ត្រនិយម (១៩៥៥-១៩៧០) https://online.fliphtml5.com/kthii/jvik/#p=1 (Accessed on 8 Oct 2025)។

Sok Siphana, *"Analyse de la dualité juridique au Cambodge"*, Thèse de doctorat en droit international, le 27 juin 2022។

Luka Burazin, "Legal systems as abstract artifacts", 2022, p.2, Legal Systems as Abstract Artifacts by Luka Burazin :: SSRN។

Hor Peng, ed., perspectives on Cambodian Constitutional Law, 2020។

Dolores A. Donovan, Cambodia: Building a Legal System from Scratch, 27 INT'L L. 445 (1993) https://scholar.smu.edu/til/vol27/iss2/8។

Jörg Menzel, "Cambodian Law: Some Comparative and International Perspectives," in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), 484, https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf។

Jogre Menzel, Cambodia-From civil war to a constitution to constitutionalism? p. 61 in Clauspeter Hill, Constitutionalism in the Southeast Asia, 2008។

Kathryn E. Neilson, Q.C. they killed all the lawyers, Rebuilding the Judicial system in Cambodian, 1996។

Dr. sc. Caslav Pejovic, Civil Law and Common Law: Two Different paths leading to the same goal, PPP. God 40 (2001) 155។

Victoria Amann-Lasnier, Overview of the Cambodian History, Governance and Legal Sources, 2019។

Evode KAYITANA, the accusatorial and Inquisitorial models of criminal procedure: a historical and comparative approach, 3(2) AJLHR, 2019។

Scott N. Carlson, Introduction to civil law legal systems, 2009។

Dr. Vivienne O'Connor, Practitioner's guide to common law and civil law, 2015។

Abraham S. Goldstein and Martin Marcus, inquisitorial, 1977។

Hor Peng, the Development of the Constitutional Law of the Kingdom of Cambodia, p. 15 in Perspectives on Cambodian Constitutional Law, 2020។

Taing Ratna et al., Annotated Constitution of the Kingdom of Cambodia, 2017។

Kong Phallack, Overview of the Cambodian Legal and judicial system, pp. 13 in *Introduction to Cambodian Law*, ed. Hor Peng, Kong Phallack, and Jörg Menzel (Cambodia: Konrad-Adenauer-Stiftung, 2012), https://fian-ch.org/content/uploads/PengPhallackMenzel-intro-Cambodian-law.pdf ។

Nop Kanharith, legal development in Cambodia before and after Japanese Assistance, Microsoft Word - Legal and Judicial Development.doc។

Basil Fernando, Problem Facing the Cambodian Legal System, 1998។

Hap Phalthy, Introduction to Cambodian Law, 2022។

ឧបសម្ព័ន្ធ៖ តារាងធាតុផ្សំនៃប្រព័ន្ធច្បាប់កម្ពុជាតាមសម័យកាល

ល.រ	សម័យកាល	ប្រភេទច្បាប់ឬក្រម	ស្ថាប័នធ្វើច្បាប់	ស្ថាប័នប្រកាសឱ្យប្រើច្បាប់	ស្ថាប័នអនុវត្តច្បាប់	ស្ថាប័នត្រួតពិនិត្យច្បាប់	ស្ថាប័នបកស្រាយច្បាប់	យន្តការដោះស្រាយវិវាទ
១	អាណានិគមបារាំង (១៨៥៣ - ១៩៥៣)	- សន្ធិសញ្ញា/ អនុសញ្ញា - រដ្ឋធម្មនុញ្ញ - ព្រះរាជក្រម - ព្រះរាជបញ្ញត្តិ - ព្រះរាជប្រកាស - ច្បាប់ ក្រម	- ព្រះមហាក្សត្រខ្មែរ - សភា (រដ្ឋធម្មនុញ្ញ ១៩៤៧) - គណៈរដ្ឋមន្ត្រី (រដ្ឋធម្មនុញ្ញ ១៩៤៧) ក្រុមប្រឹក្សាព្រះរាជាណាចក្រ(រដ្ឋធម្មនុញ្ញ ១៩៤៧)	- ព្រះមហាក្សត្រខ្មែរ	- អាជ្ញាធរបារាំង	ក្រុមប្រឹក្សាព្រះរាជាណាចក្រ(រដ្ឋធម្មនុញ្ញ ១៩៤៧)		- សាលាវិនិច្ឆ័យ (តុលាការកំពូល) - សាលាចោទប្រកាន់ - សាលាឧទ្ធរណ៍ - តុលាការខេត្ត/ សាលាដំបូង - សាលាឧក្រិដ្ឋ - សាលាក្រមឈុតសាលាក្រមវិវាទ
២	សង្គមរាស្ត្រនិយម (១៩៥៣ - ១៩៧០)	- រដ្ឋធម្មនុញ្ញ - ព្រះរាជក្រម - ព្រះរាជក្រឹត្យ - ក្រឹត្យ - ច្បាប់ ក្រម	- រដ្ឋសភា - គណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាព្រះរាជាណាចក្រ	ព្រះមហាក្សត្រ	- រដ្ឋាភិបាល	ក្រុមប្រឹក្សាព្រះរាជាណាចក្រ		- សាលាវិនិច្ឆ័យ - សាលាចោទ - សាលាឧក្រិដ្ឋ - សាលាដំបូង - សាលាស៊ើបសួរសាលាលហុ

ល.រ	សម័យកាល	ប្រភេទច្បាប់ឬក្រម	ស្ថាប័នធ្វើច្បាប់	ស្ថាប័នប្រកាសឱ្យប្រើច្បាប់	ស្ថាប័នអនុវត្តច្បាប់	ស្ថាប័នត្រួតពិនិត្យច្បាប់	ស្ថាប័នបកស្រាយច្បាប់	យន្តការដោះស្រាយវិវាទ
៣	សាធារណរដ្ឋខ្មែរ (១៩៧០ - ១៩៧៥)	- រដ្ឋធម្មនុញ្ញ - ក្រឹត្យ ច្បាប់	- រដ្ឋាភិបាល សហសភា	ប្រធានាធិបតី	រដ្ឋាភិបាល	តុលាការធម្មនុញ្ញ	- តុលាការធម្មនុញ្ញ	- តុលាការជាន់ខ្ពស់ - តុលាការជាន់ទាប ក្រុមប្រឹក្សារដ្ឋ (វិវាទរដ្ឋបាល)
៤	កម្ពុជាប្រជាធិបតេយ្យ (១៩៧៥ - ១៩៧៩)	- រដ្ឋធម្មនុញ្ញ ច្បាប់	- រដ្ឋាភិបាល សភាតំណាងប្រជាជនកម្ពុជា		រដ្ឋាភិបាល			- តុលាការ
៥	សាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៨៩)	- រដ្ឋធម្មនុញ្ញ - ច្បាប់ ក្រឹត្យ	រដ្ឋសភា	- ប្រធានក្រុមប្រឹក្សារដ្ឋមន្ត្រី	- ក្រុមប្រឹក្សារដ្ឋ - រដ្ឋសភា	- ក្រុមប្រឹក្សារដ្ឋ	- ក្រុមប្រឹក្សារដ្ឋ	- តុលាការកំពូល - តុលាការខេត្ត - តុលាការយោធា - ក្រុមប្រឹក្សារដ្ឋ

ល.រ	សម័យកាល	ប្រភេទច្បាប់ឬក្រម	ស្ថាប័នធ្វើច្បាប់	ស្ថាប័នប្រកាសឱ្យប្រើច្បាប់	ស្ថាប័នអនុវត្តច្បាប់	ស្ថាប័នត្រួតពិនិត្យច្បាប់	ស្ថាប័នបកស្រាយច្បាប់	យន្តការដោះស្រាយវិវាទ
៦	រដ្ឋកម្ពុជា (១៩៨៩ - ១៩៩៣)	- រដ្ឋធម្មនុញ្ញ - ច្បាប់ - ក្រឹត្យ - អនុក្រឹត្យ ប្រកាស	- រដ្ឋសភា - ក្រុមប្រឹក្សារដ្ឋ ក្រុមប្រឹក្សារដ្ឋមន្ត្រី	- ក្រុមប្រឹក្សារដ្ឋ	- ក្រុមប្រឹក្សារដ្ឋ - រដ្ឋសភា	- រដ្ឋសភា	- រដ្ឋសភា	- តុលាការជាន់ខ្ពស់ - តុលាការជាន់ទាប - តុលាការយោធា តុលាការពិសេស
៧	ព្រះរាជាណាចក្រកម្ពុជា (១៩៩៣-បច្ចុប្បន្ន)	- រដ្ឋធម្មនុញ្ញ - ព្រះរាជក្រម - ព្រះរាជក្រឹត្យ - ក្រម - ច្បាប់ - ក្រឹត្យ - អនុក្រឹត្យ -	- រដ្ឋសភា - ព្រឹទ្ធសភា - រាជរដ្ឋាភិបាល	- ព្រះមហាក្សត្រ	- រាជរដ្ឋាភិបាល	- រដ្ឋសភា - ព្រឹទ្ធសភា - ក្រុមប្រឹក្សាធម្មនុញ្ញ -	- ក្រុមប្រឹក្សាធម្មនុញ្ញ	- តុលាការកំពូល - សាលាតំបូង - សាលាឧទ្ធរណ៍ - តុលាការយោធា - .....

ការសិក្សាសង្ខេបនៃប្រធានបទទី២
ស្តីពីប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន

ដឹកនាំសម្របសម្រួលការតាក់តែងដោយឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក គ.ក.ច. និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម និងចូលរួមតាក់តែងដោយសមាសភាពនៃក្រុមការងារទទួលបន្ទុកប្រធានបទទី២

សេចក្តីផ្តើម

"សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា" ជាសិក្ខាសាលាលើកទីមួយដែលមានកម្រិតទូលំទូលាយ គ្របដណ្តប់វិសាលភាពនៃការពិចារណា លើប្រព័ន្ធច្បាប់ធំៗ ទាំងអស់នៅលើសកលលោក ទាំងស៊ីវិលឡ័រ ទាំងខម្មិនឡ័រ ទាំងព្រហ្មញ្ញសាសនា ហិណ្ឌូឡ័រ ក៏ដូចជាព្រះពុទ្ធសាសនា ទាំងក្នុងបរិបទជាតិ ទាំងក្នុងបរិបទអន្តរជាតិ។ ទន្ទឹមនេះ គិតចាប់ពីទទួលបាននូវឯករាជ្យ រហូតមកដល់ពេលនេះ, កម្មវិធីនេះ ជាលើកទីមួយនៅក្នុងប្រវត្តិសាស្ត្រកម្ពុជា ដែលមានការជួបជុំគ្នានៅ ក្នុងកម្រិតទាំងនីតិសាស្ត្រ ទាំងទស្សនៈវិជ្ជា ទាំងប្រវត្តិសាស្ត្រ ទាំងយុទ្ធសាស្ត្រ ទាំងធម្មសាស្ត្រ។ ដូច្នេះ សិក្ខាសាលានេះ ជាកិច្ចការដ៏ក្រៃ ហើយជ្រៅទៅក្នុងទស្សនវិជ្ជា ក្នុងការពិចារណា ក្នុងការត្រិះរិះរកសេចក្តីពិត និងសេចក្តីបរិសុទ្ធ នៅក្នុងប្រព័ន្ធច្បាប់ ទាំងក្នុងវិស័យច្បាប់ស៊ីវិលឡ័រ ទាំងក្នុងវិស័យច្បាប់ខម្មិនឡ័រ។

សម្រាប់ប្រធានបទទី២ **"ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន"**, ការស្វែងយល់អំពីប្រព័ន្ធច្បាប់កម្ពុជា ពីសម័យបុរេប្រវត្តិ ដល់សម័យបច្ចុប្បន្ន ជាអម្រែកមួយដ៏ធ្ងន់ ដ្បិតការវិវត្តនៃប្រព័ន្ធច្បាប់កម្ពុជា គ្របដណ្តប់រយៈពេលជាង ២៣ន់ឆ្នាំ។ ដោយឡែក ប្រធានបទស្រាវជ្រាវនេះ ត្រូវបានរៀបចំឡើងក្នុងក្របខ័ណ្ឌនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ដែលត្រូវបានកំណត់ទុកជាចក្ខុវិស័យរបស់ខ្លួនថា "ជានិម្មាបនកររនៃប្រព័ន្ធច្បាប់កម្ពុជាផង និងជានម្មាបនកររនៃវប្បធម៌នីតិរដ្ឋផង ដែលឈរលើគុណតម្លៃជាប្រវត្តិសាស្ត្ររបស់កម្ពុជា ហើយនិងផ្អែកលើគុណតម្លៃសកល"។ ដូច្នេះ ការសិក្សាស្រាវជ្រាវនេះ ចូលរួមចំណែកសម្រេចបាននូវគោលដៅជាសារវន្តពីរ ដូចតទៅ៖

ទី១. បូរណភាពនៃប្រព័ន្ធច្បាប់ ពោលគឺភាពពេញលេញទាំងខាងក្នុង ទាំងខាងក្រៅ

ទី២. វប្បធម៌នីតិរដ្ឋ ពោលគឺច្បាប់មិនត្រឹមតែសរសេរតែប៉ុណ្ណោះទេ តែត្រូវផ្សារភ្ជាប់ចូលជ្រៅទៅក្នុងឥរិយាបថរបស់ប្រជាពលរដ្ឋ របស់ថ្នាក់ដឹកនាំក្នុងសង្គម។

ក្នុងន័យនេះ ការប្រមើលមើលអំពីប្រព័ន្ធច្បាប់កម្ពុជា ពីសម័យបុរេប្រវត្តិ ដល់សម័យបច្ចុប្បន្ន ចៀសមិនផុតអំពីតម្រូវឱ្យអត្ថបទនេះ ធ្វើការពិពណ៌នាខ្លះ មុននឹងឈានចូលដល់ការវិភាគ សំយោគ និងសន្និដ្ឋាន។ ហេតុដូច្នេះ អត្ថបទស្រាវជ្រាវលើកឡើងក្នុងមាតិកាទី១ អំពីទស្សនទានជាប្រវត្តិសាស្ត្រនៃព្រះធម្មសាស្ត្រកម្ពុជា ដែលផ្តោតសំខាន់ទៅតាមកាលប្បវត្តិពីសម័យមុនអង្គរ (រួមបញ្ចូលសម័យបុរេប្រវត្តិ សម័យហ្វូណន និងសម័យចេនឡា) សម័យអង្គរ និងសម័យក្រោយអង្គរ មុនពេលដែលកម្ពុជាទទួលនូវអាណាព្យាបាលបារាំង ដែលអាចចាត់ទុកថាជាសម័យមុនទំនើប។

បន្ទាប់ពីការប្រមើលជាទស្សន:អំពីប្រព័ន្ធច្បាប់ក្នុងសម័យកាលនីមួយៗ ដោយកម្រិតត្រឹមតែជាទស្សនាទាន ដែលទាញចេញពីការស្វែងយល់តាមបែបទស្សនវិជ្ជា អត្ថបទនេះ នឹងបោះដំហាន ការពិចារណា ទៅកាន់ការប្រមើលមើលអំពីទស្សនាទាននៃការធ្វើទំនើបការរៀបនីយកម្មប្រព័ន្ធច្បាប់កម្ពុជាក្នុងមាតិកាទី២ ដែលចាប់ផ្តើមពីការដាក់អាណាព្យាបាលបារាំង រហូតមកដល់បច្ចុប្បន្ន ដែលផ្តោតសំខាន់ទៅលើការធ្វើទំនើបកម្មបែបបារាំង ការប្រមើលមើលអំពីគុណតម្លៃទំនើបនិងគុណតម្លៃទំនៀម និយាយសាមញ្ញ និយាយម្យ៉ាងទៀតថាគុណតម្លៃប្រវត្តិសាស្ត្រនិងគុណតម្លៃសកល ទាំងភាសាផង ទាំងទស្សនវិជ្ជាផង។

ក្នុងមាតិកាទី៣ ក្នុងក្របខ័ណ្ឌទស្សនាទានទំនើបការរៀបនីយកម្មខាងលើនេះ អត្ថបទនេះ នឹងបង្ហាញជាសង្ខេបនូវការសាកល្បងប្រមូលយកច្បាប់ដែលមានជាធរមានបច្ចុប្បន្ន តាំងពីឆ្នាំ១៩៩៣ មកដល់ពេលបច្ចុប្បន្ន ពោលគឺយកច្បាប់ទាំងអស់ជាធរមានមកធ្វើការវិភាគសាកល្បង ដោយប្រើទស្សនវិជ្ជា និងតក្កវិជ្ជាគតិយុត្ត ដើម្បីធ្វើចំណាត់ថ្នាក់គតិយុត្ត (Typologie Juridique) ឱ្យទៅតាមជំពូក និងតាមវិស័យ ដោយផ្អែកលើចំណេះវិជ្ជាសាកល តាមបែបបារាំង ជាអភិក្រមពីលើ ចុះក្រោម ដើម្បីរកចំណុចកណ្តាលមួយ ឬវិធីសាស្ត្រ ដើម្បីធានាបាននូវភាពពេញលេញ ឯកសណ្ឋាន និងអត្តសញ្ញាណរបស់ប្រព័ន្ធច្បាប់កម្ពុជា។ ការធ្វើចំណាត់ថ្នាក់នេះ នឹងនាំឱ្យយល់អំពីកង្វះចន្លោះ សង្គតិភាព និងអសង្គតិភាព នៃក្របខ័ណ្ឌគតិយុត្តជាធរមាន ដែលជាមូលដ្ឋានចូលរួមចំណែកក្នុងការរៀបចំប្រព័ន្ធច្បាប់កម្ពុជា ឱ្យមានឯកសណ្ឋានភាពផង ឯកអត្តសញ្ញាណផង ហើយនឹងមានបូរណភាពផង ក្នុងគោលដៅធានាការអនុវត្តប្រព្រឹត្តទៅ ប្រកបដោយធម៌ ដែលស៊ីចង្វាក់គ្នាទាំងក្នុងស្ថាប័នមួយ ទៅកាន់ស្ថាប័នមួយទៀត ក៏ដូចជានៅក្នុងស្ថាប័នរដ្ឋ ជាមួយនឹងស្ថាប័នឯកជន។ ទន្ទឹមនេះ មាតិកានេះ ក៏បង្ហាញអំពីជាការសាកល្បងត្រួសត្រាយផ្លូវ ឬ មាគ៌ាដើម្បីឆ្ពោះទៅកាន់ការកសាងនូវប្រព័ន្ធច្បាប់កម្ពុជាមួយ ដែលមានអត្តសញ្ញាណរបស់ខ្លួន

ហើយមានលក្ខណៈពេញលេញ ជាប្រព័ន្ធច្បាប់មួយដែលមិនមានការឆកល្វែងនៃច្បាប់ដែលជាប្រភពនៃការរើសអើងសិទ្ធិរបស់ពលរដ្ឋ។ មាគ៌ាទាំងនោះ រួមមានជាសាវន្តចំនួន ៣ គឺ ទី១. នីតិនិពន្ធវិជ្ជា (Législistique) ដែលជាវិទ្យាសាស្ត្រផង ជាសិល្ប៍សាស្ត្រផង ក្នុងការនិពន្ធច្បាប់, ទី២. នីតិក្រមវិជ្ជា (Codistique) ដែលជាការប្រមូលផ្តុំនៅបទបញ្ញតិទាំងឡាយក្នុងវិស័យតែមួយចងក្រងឱ្យទៅជាក្រម និងទី៣. ព័ត៌មានវិទ្យានីតិកម្ម ដែលជាការប្រើប្រាស់បច្ចេកវិទ្យាសម្រាប់គាំទ្រដល់ការងារនីតិកម្ម។

១. ទស្សនាទានជាប្រភពិសាស្ត្រ នៃព្រះធម្មសាស្ត្រកម្ពុជា

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា យើង បានគូសបញ្ជាក់នៅថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ កន្លងទៅ ក្នុងឱកាសដែល **សម្តេចមហាបវរធិបតី** បានប្រកាសដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្រស្តីពីការកែទម្រង់ច្បាប់ថា ព្រះរាជាណាចក្រកម្ពុជា មានច្បាប់សម្រាប់គ្រប់គ្រងនគរយ៉ាងជាក់លាក់ ដែលជាច្បាប់កំពូល សូម្បីតែព្រះមហាក្សត្រក៏ត្រូវតែគោរពតាមផងដែរ។ ច្បាប់នោះ មានឈ្មោះថា **ក្រមព្រះធម្មសាស្ត្រ**។

ក្នុងន័យនេះ តាមការស្រាវជ្រាវ គេសង្កេតឃើញនូវតឹកតាងជាប្រវត្តិសាស្ត្រជាច្រើន ដែលបង្ហាញអំពីឥទ្ធិពលរបស់ក្រមព្រះធម្មសាស្ត្រ លើវប្បធម៌និងប្រព័ន្ធច្បាប់កម្ពុជាចាប់តាំងពីសម័យមុនអង្គរ និងបន្តរហូតដល់សម័យអង្គរ ហើយជាពិសេសនៅសម័យក្រោយអង្គរ ឬសម័យកណ្តាល ជាសម័យដែលក្រមព្រះធម្មសាស្ត្រមានរូបរាងពិតប្រាកដឡើង និងជាមូលដ្ឋានគ្រឹះនៃអភិបាលកិច្ច និងការគ្រប់គ្រងសណ្តាប់ធ្នាប់ក្នុងសង្គម។

១.១. សម័យមុនអង្គរ (សម័យបុរេប្រវត្តិ ហ្វូណន និងចេនឡា)

១.១.១. ច្បាប់ មានសណ្ឋានជាទំនៀមទំលាប់ និងជំនឿ

នៅសម័យមុនអង្គរ នាសម័យបុរេប្រវត្តិ, ស្ថានីយ៍បុរេប្រវត្តិជាច្រើន បានគូសបញ្ជាក់ថា សង្គមកម្ពុជាដឹកនាំបែបកុលសម្ព័ន្ធខ្លះ បែបជាមេកន្ត្រាញ ទៅតាមរចនាសម្ព័ន្ធជាមណ្ឌលកណ្តាល ឬក៏ជាបន្ទាយគូ ឬភូមិមូល ស្រដៀងនឹងទស្សនាទាននៃពាក្យ ចៅគូ ឬក៏បាគូ ដែលជាគ្រូ ឬជាអ្នកដឹកនាំ។

នៅសម័យមុនអង្គរ ច្បាប់ មានសណ្ឋានជាទំនៀមទំលាប់ ជាជំនឿ ជារបៀប ជាសាសនា ពោល ការគ្រប់គ្រងទំនាក់ទំនងសង្គមប្រចាំថ្ងៃ គឺមានប្រភពចេញពីទំនៀមទម្លាប់និងជំនឿសាសនា។ ជាពិសេស ជំនឿដើមដំបូងរបស់យើង គឺជំនឿអរូបិយ (Animism)

ដែលជាជំនឿលើព្រលឹង អ្នកតា ព្រៃ និងភ្នំ។ ជំនឿទាំងនេះ នៅតែរក្សាឥទ្ធិពលរបស់ខ្លួន រហូតដល់បច្ចុប្បន្ន បើទោះបីជាកម្ពុជា បានទទួលនូវឥទ្ធិពលចេញអំពីព្រហ្មញ្ញសាសនា និងពុទ្ធសាសនា ទាំងពុទ្ធសាសនាហីនយាន ទាំងមហាយាន ទាំងពេជ្រយាន ឬវជ្រយាន ក៏ជំនឿទាំងអស់នេះ មិនទាន់បាត់បង់ដែរ។ ជាឧទាហរណ៍ នៅរៀងរាល់ពេលដែលមានសំណង់កើតឡើង នៅលើផែនដីនេះ សុទ្ធតែមានព្រលឹងទាំងអស់។ ជាក់ស្តែង រៀងរាល់ពេលសង់រោងការ ពេលប្រជាពលរដ្ឋតែងរៀបចំពិធីពិធីសែនព្រេននានា ពិសេសពិធីសែនក្រុងពាលី។ ការគោរពអ្នកតា ការគោរពក្រុងពាលី ព្រះភូមិ ព្រះធរណី នាងគង្គីង ទាំងអស់នេះសុទ្ធតែជាសញ្ញានៃការគោរពម្ចាស់ទឹកម្ចាស់ដី អ្នកតាទឹក អ្នកតាព្រៃ ភ្នំ ប្រឹក្សា ស្នឹងបឹងបួរ ទន្លេ ខេត្ត ស្រុក ភូមិ ឃុំ រហូតដល់ជំនាងផ្ទះ។ ជំនឿនេះ អាចចាត់ទុកជា Loi Cosmique ឬជា Ordre Cosmique ជាច្បាប់ទេវតា ឬក៏ជាច្បាប់នៃលោកធាតុ ឬក៏ជាច្បាប់នៃធម្មជាតិ ដែលមិនមានចែងនៅក្នុងលិខិតជាលាយលក្ខណ៍អក្សរក៏ពិតមែន ប៉ុន្តែយើងម្នាក់ៗ តែងតែគោរព តែងតែមិនហ៊ានរំលង ដោយគិតថាបើសិនជារំលង នឹងត្រូវទទួលបាននូវការដាក់ទណ្ឌកម្ម ដោយប្រការណាមួយ នៅក្នុងអារម្មណ៍របស់យើងទាំងអស់គ្នា។

១.១.២. ច្បាប់ឯឱអតិបាលកិច្ច

នៅក្នុងសម័យហ្វូណន អ្នកស្រុកនៅហ្វូណន តែងតែគោរពជំនឿទាំងអស់នេះ រហូតទៅដល់ការកាត់ក្តីនានា ឬការផ្តល់យុត្តិធម៌ប្រព្រឹត្តទៅ ដោយពឹងផ្អែកទៅលើជំនឿមួយចំនួនផងដែរ។ តាមរយៈសិលាចារឹក នៅក្នុងរជ្ជកាលព្រះបាទភវវរ្ម័នទី១ ព្រះអង្គមានមន្ត្រីដែលជាទីប្រឹក្សា ច្រើនរូប ដែលមានចំណេះជំនាញ និងប្រាជ្ញាញាណជ្រៅជ្រះក្នុងគម្ពីរធម្មសាស្ត្រ (Dhammasastra) និងគម្ពីរអឋ៌សាស្ត្រ (Arthasastra)។ គម្ពីរធម្មសាស្ត្រមានអត្ថិភាពតាមរយៈសិលាចារឹក រហូតមកដល់សម័យក្រោយអង្គរ។ រីឯគម្ពីរអឋ៌សាស្ត្រហាក់ពុំមានគឺកតាងដែលនៅសេសសល់។ អ្វីដែលនៅសេសសល់ គឺហាក់មានតែមួយគត់នៅក្នុងភាសាដែលប្រជាពលរដ្ឋប្រើជាប្រចាំថ្ងៃ ដែលលោកតា លោកយាយ ទៅវត្តទៅវា តែងតែលើកឡើងផ្តាំកូន ផ្តាំចៅ ថាគាត់ទៅរៀនធម៌ រៀនអាឋ៌ "អាឋ៌" ហ្នឹង គឺ អឋ៌សាស្ត្រ។

ការកកើតនគរភ្នំ ក៏ប្រព្រឹត្តទៅតាមរបៀបជាសម័យបុរេប្រវត្តិដែរ។ ទំនើបកម្ម ពី "បន្ទាយគូរ" ឬពី "ភូមិមូល" មកកាន់ជា "មណ្ឌល" ដែលតាមភាសាបាលី មណ្ឌល: ប្រែថា កណ្តាល ឬក៏ជាមជ្ឈមណ្ឌល។ របៀបនៃការរៀបចំនគរ ក៏យកមណ្ឌលកណ្តាល ធ្វើជាគោល។ ប្រាង្គប្រាសាទអង្គរវត្តក៏យើងមានប្រាសាទនៅកណ្តាល ជាគោល ដែលយើងឱ្យ

ឈ្មោះថា "រាជមណ្ឌល" ឬក៏ជាមជ្ឈមណ្ឌល។ រីឯការគ្រប់គ្រងរដ្ឋបាលដែនដី ក៏ប្រើប្រាស់ទស្សនវិជ្ជានេះផងដែរ ដែលមានរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន។

១.១.៣. សណ្តាប់ធ្នាប់សង្គម និងការផ្តល់យុត្តិធម៌

ស្ថាប័នយុត្តិធម៌ ក៏ប្រើប្រាស់ទស្សនវិជ្ជានៃកណ្តាលនេះ យកមកផ្តល់យុត្តិធម៌ផងដែរ។ គេសង្កេតឃើញមានគោលការណ៍មួយចំនួន ដែលបានដកស្រង់ចេញពីការសិក្សាស្រាវជ្រាវ នៃសម័យមុនអង្គរ គឺមានការមិនរើសអើងវណ្ណៈនៅក្នុងសង្គម ដោយប្រជារាស្ត្រអាចថាមានវណ្ណៈទៅតាមលទ្ធភាពជីវភាព រួមមានក្សត្រ មន្ត្រី អ្នកមាន អ្នកក្រ ពាណិជ្ជករ សិប្បករ ជាដើម។ ប៉ុន្តែអ្នកទាំងនោះ ហាក់បីដូចជារស់នៅ ប្រកបដោយសុខដុមរមនា គោរពតាមសណ្តាប់ធ្នាប់សាធារណៈ ដោយមិនមានជាទំនាស់ទាស់ទែងគ្នាទេ។ រីឯសាសនាក៏មានច្រើន មានទាំងព្រហ្មញ្ញសាសនា ទាំងព្រះពុទ្ធសាសនាមហាយាន ទាំងជំនឿអរូបិយក៏នៅជាមួយគ្នាបាន។ រីឯការផ្លាស់ប្តូរពីបុរសនិងស្ត្រីជាធំ នៅក្នុងការដឹកនាំគ្រួសារនិងសង្គម , ពេលខ្លះក៏យើងបានប្រើពាក្យថាមេ ពេលខ្លះក៏យើងប្រើពាក្យថាបា ប៉ុន្តែមេ និងបា ថ្វីត្បិតតែធំដូចគ្នា ប៉ុន្តែក៏ធំខុសកាលទេស:នឹងគ្នា ទៅតាមការវិវត្តន៍នៃទស្សន:មាតាធិបតេយ្យ ឬបិតាធិបតេយ្យ។ យើងនិយាយភាសាបារាំងថា "Patrie" មកពីបារាំងប្រកាន់យកបិតាធិបតេយ្យ ប៉ុន្តែយើងបកប្រែជាភាសាខ្មែរថាជា "មាតុភូមិ" មិនមែនជា "បិតុភូមិ" ទេ។

សម្រាប់ការកាន់កាប់ដីធ្លី, អ្នកប្រាជ្ញលើលោកនេះ ជាពិសេសអ្នកអាណានិគមបារាំង តែងគិតថាខ្មែរយើងមិនមានកម្មសិទ្ធិដីធ្លីទេ។ ដោយឡែក សិលាចារឹកវិទ្យា បានបង្ហាញឱ្យឃើញថា ព័ត៌មានជាច្រើនណាស់ពី ៥០% ចេញពីសិលាចារឹក គឺចែងអំពីវិវាទដីធ្លី ដែលបញ្ជាក់អំពីអាទិភាពនៃកម្មសិទ្ធិដីធ្លីនៅកម្ពុជា។ ហើយជាពិសេស ការកសាងប្រាង្គប្រាសាទនានា ក៏ជាការកសាងដែលប្រព្រឹត្តទៅតាមរបៀបជាព្រលឹង ជាដួងវិញ្ញាណ ជាទស្សនវិជ្ជា ជានយោបាយដឹកនាំប្រទេស ជាសង្គម និងជាសេដ្ឋកិច្ច។

១.២. សម័យអង្គរ

១.២.១. លទ្ធិទេវរាជ

ក្នុងសម័យអង្គរ, ព្រះមហាក្សត្រព្រះបាទជ័យវរ្ម័នទី២ ដែលលោកបានកសាងចក្រភពអង្គរ នាឆ្នាំ៨០២ នៅលើភ្នំមហិន្ទ្របព៌ត (ភ្នំគូលែន), ព្រះអង្គបានឧប្បត្តិក នូវលទ្ធិមួយ សម្រាប់ប្រមែប្រមូលស្តេចត្រាញ់នៅជុំវិញនគរ ឱ្យក្លាយទៅជាស្តេចចំណុះរបស់ខ្លួន ដើម្បីឱ្យស្តេចទាំងអស់គ្នាចំណុះព្រះអង្គ។ ក្នុងន័យនេះ លទ្ធិទេវរាជ (Devaraja)

ត្រូវបានបង្កើតឡើង ដើម្បីធានានូវការបង្រួបបង្រួមជំនឿ សាសនា ស្មារតី ព្រលឹង និងវិញ្ញាណរបស់ស្តេច មន្ត្រី និងប្រជារាស្ត្រ នៅតាមតំបន់នីមួយៗ ឱ្យវិលជុំវិញព្រះមហាក្សត្រ ព្រះបាទជ័យវរ្ម័នទី២ ដែលជាស្ថាបនិកដើមដំបូងនៃអាណាចក្រអង្គរ។ ផ្អែកតាមគោលនយោបាយនេះ បើកាលណាស្តេចត្រាញ់ទាំងឡាយណា មិនតតាំង ហើយសុខចិត្តធ្វើជាស្តេចចំណុះឱ្យអង្គព្រះ, ព្រះអង្គទុករក្សាតំណែងនៅដដែល ប៉ុន្តែត្រូវមានសួយសាអាករ ហើយត្រូវស្ថិតនៅក្រោមឱវាទរបស់ព្រះអង្គ។ ប៉ុន្តែ បើសិនជាស្តេចត្រាញ់ទាំងឡាយណា មិនព្រមចំណុះ គឺត្រូវកាត់ក្បាល។ ហេតុដូច្នេះហើយ បានជាការកសាងអាណាចក្រអង្គរ នៅឆ្នាំ៨០២ ជាបន្តបន្ទាប់មក គឺប្រព្រឹត្តទៅដោយរលូនល្អ ទាំងស្មារតី ព្រលឹង វិញ្ញាណ ជំនឿ និងសាសនា។ ផ្អែកតាមលិទ្ធិទេវរាជ ព្រះមហាក្សត្រគឺជាស្តេចនៃទេវតា ឬជាសម្មទិទេព ពោលគឺជាអាទិទេពដោយការសម្មត់។

អាស្រ័យហេតុនេះ លិទ្ធិទេវរាជ គឺជាការបង្រួបបង្រួមនូវជំនឿ សាសនា ទស្សនវិជ្ជា និងនយោបាយនៃការដឹកនាំប្រទេស ដើម្បីធានាថាប្រភពអំណាច ត្រូវបានបង្កើតឡើងប្រកបដោយភាពត្រឹមត្រូវ មានមូលដ្ឋានរឹងមាំ គាំទ្រដោយប្រជារាស្ត្រ ដោយមន្ត្រី ដើម្បីរក្សាអំណាច ការពារទឹកដី និងប្រជារាស្ត្រ។ អំណាចនេះ ជាអំណាចតាមច្បាប់ផង ហើយដើម្បីកសាងច្បាប់សម្រាប់តាំងអំណាចផង។ អំណាចទាំងអស់នេះ គឺពឹងផ្អែកទៅលើគុណជាតិនិងគុណធម៌របស់ព្រះមហាក្សត្រ ដែលព្រះអង្គបំពេញនូវតប:ធម៌ កម្មដ្ឋាន និងបំពេញនូវប្រាជ្ញាបារមិតារបស់ព្រះមហាក្សត្រ ដើម្បីបំពេញព្រះពោធិសម្ភារ របស់ព្រះអង្គ។ ដូច្នេះ ទស្សនវិជ្ជានេះ មិនអាចស្វែងយល់តាមន័យជាទស្សនវិជ្ជាលោកខាងលិច ដែលអាចសម្គាល់ជាពាក្យថា "ធម្មវិជ្ជា" ពោលគឺមិនមែនជាវិជ្ជាដែលបានកម្រិតត្រឹមតែប្រាជ្ញាត្រិះរិះ ពិចារណាបែបឈ្លាសវៃប៉ុណ្ណោះទេ តែជាវិជ្ជាដែលចូលទៅក្នុងថ្នាក់ភាវនា ដើម្បីអាចយល់អំពីខ្លឹមសារនៃច្បាប់ពីបរមបុរាណរបស់ខ្មែរបាន។

១.២.២. ព្រះធម្មសាស្ត្រ ជាច្បាប់កំពូល

ទោះបីជាយ៉ាងណាក៏ដោយ ជាទស្សនវិជ្ជាច្បាប់ យើងឃើញថាព្រះធម្មសាស្ត្រ ជាច្បាប់កំពូល ដែលត្រូវការពារនិងគោរពប្រតិបត្តិដោយព្រះមហាក្សត្រ ដែលព្រះអង្គតម្កល់លើព្រះសិរសារបស់ព្រះអង្គ។ នៅក្នុងក្រមព្រះធម្មសាស្ត្រ គឺមានចែងអំពីសិល្ប៍សាស្ត្រផង និងអំពីវិទ្យាសាស្ត្រនៃការដឹកនាំប្រទេសផង ដោយពុំមែនជាបទបញ្ញត្តិដែលត្រូវចែង ឬជាមាត្រាដែលលើកឡើង ដើម្បីយកមកកាន់ក្តី ឱ្យរឿងណាមួយទេ។ ប៉ុន្តែគឺជា មាគ៌ា សម្រាប់

ដឹកនាំប្រទេស ធានាសណ្តាប់ធ្នាប់នៅក្នុងក្រឡាផ្ទៃក្រោម (ពីបុរាណ ៣ក្យ "ក្រឡាផ្ទៃក្រោម" ប្រែថា ផែនដី រីឯ ក្រឡាផ្ទៃលើ គឺឋានព្រហ្ម)។

ទន្ទឹមនេះ ក្រមព្រះធម្មសាស្ត្រ ក៏លើកឡើងអំពីសីលធម៌ និងយុត្តិធម៌ សម្រាប់ធានាសណ្តាប់ធ្នាប់នៅក្នុងសង្គម។ ក្បួនច្បាប់នានាដែលមានជាច្រើន អាចប្រៀបប្រដូចទៅនឹងអាវុធរបស់មនុស្ស។ ដោយឡែក សម្រាប់ក្រមព្រះធម្មសាស្ត្រ គឺតម្កល់លើព្រះសិរសារបស់ព្រះរាជា ជាច្បាប់កំពូលដែលព្រះអង្គត្រូវការពារនិងគោរពប្រតិបត្តិ ដោយហេតុថា ដើម្បីមានធម្មានុរូបភាព ដើម្បីមានគុណធម៌ជាមហាក្សត្រ, ព្រះអង្គចាំបាច់ត្រូវតែគោរពច្បាប់ ដែលជារាជធម៌ ឬក៏ទសពិធរាជធម៌ ដើម្បីធ្វើជាមហាកុសល ជាសេចក្តីទំនុកបម្រុង តាមបែបព្រលឹង តាមបែបស្មារតីដល់ប្រជានុរាស្ត្រ។ បើកាលណាមហាក្សត្រឃ្លាតចាកចេញពីព្រះទសពិធរាជធម៌ហើយ ប្រជារាស្ត្រនឹងរងទុកសោក។ ការទ្រទ្រង់ព្រះធម៌ មិនមែនត្រឹមតែជាការធានា នូវភាពស្របច្បាប់ ឬភាពត្រឹមត្រូវនៃការដឹកនាំរបស់ព្រះមហាក្សត្រតែប៉ុណ្ណោះទេ តែថែមទាំងជាគំរូ និងជាប្រផ្នូលល្អ សម្រាប់ប្រជារាស្ត្រក្នុងការប្រកបរបរស្រែចម្ការ។

ធម: ឬធម៌ ត្រូវបានប្រៀបប្រដូចទៅនឹង "គោឧសភរាជ" ជួនកាលគេហៅថាជា "ព្រះធម៌" ជួនកាលគេហៅថាជា "ព្រះគោ" ឬក៏ជា "ព្រះច្បាប់"។ នៅក្នុងរជ្ជកាលរបស់ព្រះបាទសុរិយោវរ្ម័នទី១ និងទី២ ដែលជាមហាក្សត្រក្លាហានវាងវៃ និងដែលមានរជ្ជកាលយូរឆ្នាំ, ព្រះអង្គតែងតែលើកឡើង អំពីការបន្តរជ្ជកាលរបស់ព្រះអង្គ ចេញពីកលិយុគនិងសង្គ្រាម។ ពេលដែលប្រទេសជាតិមានសង្គ្រាម គឺបាត់បង់អស់ច្បាប់ ដែលធ្វើឱ្យព្រះគោបាត់អាវុធ: ពោលគឺបាត់ជើងអស់ សល់តែជើងមួយ មិនអាចឈរបាន។ ប៉ុន្តែដោយសារតែអម្រិតជាតិ និងគុណជាតិ នៃតបធម៌ របស់មហាក្សត្រក្លាហានវាងវៃទាំងនោះ ព្រះអង្គបានឧប្បត្តិក ធ្វើឱ្យព្រះគោ មានជើង មានអាវុធ:ពេញបរិបូរឡើងវិញ និងមានកម្លាំងខ្លាំងក្លា ដែលចង់គូសបញ្ជាក់អំពីវោហាសាស្ត្រនៃសិលាចារឹក ក្នុងខ្លឹមសារថា ប្រទេសគ្រប់គ្រងដោយច្បាប់តឹងរឹងត្រឹមត្រូវ ខុសប្លែកអំពីប្រទេសជាតិ ដែលបានធ្លាប់ឆ្លងកាត់ពីកលិយុគនិងសង្គ្រាម។

សិល្បៈសាស្ត្រនិងវិទ្យាសាស្ត្រនៃការដឹកនាំរបស់ព្រះមហាក្សត្រនេះ គឺពឹងផ្អែកទៅលើគម្ពីរក្នុងព្រហ្មញ្ញសាសនាផង ក្នុងពុទ្ធសាសនាផង។ ព្រហ្មញ្ញសាសនា មានទស្សនវិជ្ជានិងវិធីសាស្ត្រ នៃការបដិបត្តិស្រដៀងគ្នា ជាមួយនឹងព្រះពុទ្ធសាសនាមហាយាន ដោយព្រះមហាក្សត្របំពេញនូវតបធម៌ ក្នុងគោលដៅគ្រប់គ្រងចិត្តរបស់ខ្លួនបាន ពោលគឺធ្វើជាម្ចាស់

លើខ្លួនឯង ឬធ្វើជាម្ចាស់លើកិលេសចិត្ត រួមានរាគៈ ទោសៈ និងមោហៈ។ នេះជាគុណជាតិ ឬជាគុណធម៌ដ៏កំពូល របស់ព្រះមហាក្សត្រធំៗ ដែលអាចប្រើវិជ្ជាកម្មដ្ឋានសម្រាប់គ្រប់គ្រងចិត្តរបស់ខ្លួន ឬសំលៀងចិត្ត តម្រង់រកប្រាជ្ញាសម្រាប់យកមកដឹកនាំប្រទេស។ ក្នុងន័យនេះ ការផ្តល់នូវយុត្តិធម៌ ក៏ត្រូវវាចាក នូវសេចក្តីលម្អៀងទាំងបួនប្រការ គឺ៖

- ឆន្ទាគតិ លម្អៀងព្រោះស្រលាញ់ ជាប់ជំពាក់នឹងប្រយោជន៍គ្នា
- ទោសាគតិ លម្អៀងព្រោះតែស្អប់ គុំគួន ខឹងសម្បារ
- ភ័យាគតិ លម្អៀងព្រោះតែកីខ្លាច កោតក្រែងអំណាច និង
- មហាគតិ សេចក្តីលម្អៀងព្រោះតែងងឹតងងល់ វង្វេង គ្មានវិជ្ជា។

អគតិទាំង ៤ ប្រការនេះ មិនអាចបដិបត្តិចៀសវាងបាន ដោយត្រឹមតែការត្រិះរិះពិចារណាទេ គឺត្រូវយកទៅបដិបត្តិនៅក្នុងបរមត្ថសច្ច តាមរយៈវិបស្សនាកម្មដ្ឋាន តាមបែបព្រហ្មញ្ញសាសនាផង តាមបែបពុទ្ធសាសនាមហាយានផង។ ហេតុដូច្នេះបានជាគេឃើញមានរូបសំណាកព្រះបាទជ័យវរ្ម័នទី៧ ព្រះអង្គទ្រង់គង់សមាធិ ដែលមានអ្នកប្រាជ្ញមួយចំនួនតែងតែគិតថាព្រះអង្គ ជាព្រះអរហន្ត។

ដោយឡែក អច់សាស្ត្រគឺជាគម្ពីរក្បួនខ្នាតមួយ ដែលលើកឡើងអំពីសេដ្ឋកិច្ចជាតិ, របៀបនៃការដឹកនាំប្រទេស, ការទូត និងនយោបាយ ដើម្បីធានាទំនុកបម្រុងឱ្យធម្មសាស្ត្រអាចស្ថិតនៅជាធរមានរឹងមាំបាន ដែលយើងតែងប្រើក្នុងភាសាបច្ចុប្បន្នថាជា នីតិរដ្ឋ។

ជាក់ស្តែង ការកសាងប្រាសាទប្រព្រឹត្តទៅ ប្រកបទៅដោយវិធីសាស្ត្រនិងយុទ្ធសាស្ត្រច្បាស់លាស់ ជានគរូបនីយកម្មជំនាន់នោះ។ ប្រាសាទ ក៏ជាមូលដ្ឋានសេដ្ឋកិច្ច ពីព្រោះនៅរៀងរាល់ពេលដែលសង់ប្រាសាទ ជាស្ថាបត្យកម្ម ត្រូវពឹងផ្អែកលើទឹកវិលជុំវិញ ដើម្បីគាំទ្រដល់សំណង់ស្ថាបត្យកម្មប្រាសាទផង និងជាទីសម្រាប់បង្ហូរទឹកទៅដល់ស្រែចម្ការជុំវិញប្រាសាទនីមួយៗ សម្រាប់ទ្រទ្រង់ជីវភាពប្រាសាទផង។ ហេតុដូច្នេះ នៅក្នុងខែខ្នើតមានអ្នកកាន់វេន មួយវេន, ខែរនោច មានអ្នកកាន់វេន មួយវេន សម្រាប់មកថែរក្សាប្រាសាទ នាំយកនូវផលានុផលចេញពីស្រែចម្ការរណបប្រាសាទ យកមកថ្វាយប្រាសាទ។ រីឯប្រាសាទមានបទបញ្ជាផ្ទៃក្នុងរបស់ប្រាសាទនីមួយៗ ច្បាស់លាស់។ ជាក់ស្តែង សម្រាប់មន្ទីរពេទ្យរបស់ព្រះបាទជ័យវរ្ម័នទី៧, ការទទួលយកអ្នកជំងឺមិនត្រូវរើសអើង គឺត្រូវតែមានស្មើភាព ហើយត្រូវទទួលយកទាំងអស់ ប្រកបដោយមេត្តា ករុណា និងព្រហ្មវិហារធម៌។ ហើយជាពិសេស នៅក្នុងប្រាសាទនានា មិនអនុញ្ញាតឱ្យជនណាប្រព្រឹត្តអំពើល្មើសបានឡើយ។ បើទោះបីជាមានជនល្មើស ហ៊ានឈានជើងចូលទៅក្នុងប្រាសាទ មន្ត្រី

ក្រមការ ក្រុមព្រះនគរបាលនានា មិនអាចចូលទៅចាប់ជនល្មើសចេញពីក្នុងប្រាសាទបានទេ។ អ្នកដែលអាចចូលក្នុងប្រាសាទហើយ គឺទោះបីជាចោរ ក៏មិនមានអ្នកណាអាចមានសិទ្ធិចាប់ដែរ។ រីឯ អំណោយទានទាំងឡាយដែលថ្វាយចំពោះប្រាសាទ ជាច់ខាតមិនអាចដកយកវិញបានទេ ទោះបីជាទាយាទរបស់អ្នកធ្វើទាននោះ ជាកូន ជាចៅតពូជពង្សវង្សត្រកូលប្រាំពីរសន្ដានចុះទៅក្រោមទៀត ក៏មិនអាចដកបានដែរ។ អ្នកដែលដកយក នូវអំណោយទានថ្វាយប្រសាទមកវិញ នឹងធ្លាក់នរក មិនតិចជាង ៣២ ជាន់ឡើយ។ នេះជាជំនឿផង ជាច្បាប់ផង ហើយជាការបដិបត្តិនៅក្នុងប្រាសាទនីមួយៗផង។

១.២.៣. ព្រះមហាក្សត្រ ជាចៅក្រមកំពូល និងជាប្រភពនៃយុត្តិធម៌

សម័យអង្គរថ្វីត្បិតតែយើងមិនបានរកឃើញនូវសិលាចារឹក ដែលចារឹកអំពីខ្លឹមសារល្អិតល្អន់អំពីក្រមព្រះធម្មសាស្ត្រ ប៉ុន្តែគេសង្កេតឃើញពីការអនុវត្តក្រមព្រះធម្មសាស្ត្រពោលគឺការអនុវត្តច្បាប់នៅក្នុងការដោះស្រាយវិវាទដោយព្រះមហាក្សត្រ។ មានវិវាទដីធ្លីច្រើនដែលព្រះមហាក្សត្រ ព្រះអង្គកាត់សេចក្ដីឱ្យអាណាប្រជានុរាស្ត្រ។

ជាក់ស្តែងដូចជាមានករណីវិវាទនៅសម័យអង្គរ ដែលគ្រូភ្លេងទាស់ជាមួយចៅហ្វាយស្រុក។ ចៅហ្វាយស្រុក ឬក្លាញស្រុក ទាស់ជាមួយគ្រូភ្លេង លើដីស្រែមួយកន្លែង។ ចៅហ្វាយស្រុកទៅក្ជូរស្រែលើដីរបស់គ្រូភ្លេង។ សភាចៅក្រមនៅថ្នាក់ក្រោម បានសម្រេចឱ្យចៅហ្វាយស្រុកឈ្នះ។ គ្រូភ្លេង ក៏ឡើងមកក្រាបបង្គំទូលព្រះមហាក្សត្រ, ព្រះមហាក្សត្របានត្រាស់បង្គាប់ឱ្យឧកញ៉ាសុភាធិបតីចុះទៅពិនិត្យ ឃើញថាដីស្រែនោះជាដីស្រែរបស់គ្រូភ្លេង។ រីឯចៅហ្វាយស្រុក ក៏បានសារភាពថាគាត់ច្រឡំជើងស្រែ។ ក្នុងន័យនេះ ព្រះមហាក្សត្រ បានចេញព្រះរាជសារ ឱ្យចារឹកនៅលើថ្មនៅជាប់ជាមួយដីស្រែហ្នឹង។ ជាធម្មតាដីស្រែខ្លះ បើតូចបោះបង្គោល ៤ ទិស បើធំបោះបង្គោល ៨ ទិស រួមជាមួយសាលាចារឹកដែលចារឹកអំពីព្រះរាជសាសន៍របស់ព្រះមហាក្សត្រ នៅក្នុងការធានានូវសិទ្ធិ (ពីដើមមិនមានប្រើពាក្យ "កម្មសិទ្ធិ" ទេ មានតែពាក្យ "សិទ្ធិ" លើដីធ្លី) រហូតដល់ព្រះច័ន្ទ្រាទិត្យគង់នៅជាធរមានដរាបណាព្រះចន្ទនិងព្រះសូរិយារះក្នុងចក្រវាលនេះ ដីស្រែទាំងអស់នេះនៅរក្សាការពារជូនដល់គ្រូភ្លេង។ ដោយឡែក នៅពេលដែលមានការផ្លាស់ប្តូររជ្ជកាលនីមួយៗ ម្ចាស់ស្រែធំៗ តែងតែទៅក្រាបបង្គំទូលព្រះមហាក្សត្រ ដើម្បីសុំព្រះរាជទានលើដីស្រែជាថ្មី ដើម្បីជានានិរន្តរភាពរបស់ដីស្រែ ឆ្លងកាត់រាជបល្ល័ង្ក។ ហេតុដូច្នេះបានជានៅក្នុងច្បាប់នាសម័យក្រោយអង្គរ នៅរៀងរាល់ពេលដែលមានការផ្លាស់ប្តូរព្រះមហាក្សត្រ រឿងក្តីទាំងឡាយដែល

មិនទាន់ជម្រះ នៅតាមសាលាជម្រះក្តី សាលាបញ្ជាន់សឹង សាលាឧទ្ធរណ៍ សាលនុគុណ នានា គឺត្រូវបិទចោលទាំងអស់ មិនត្រូវលើកមកជម្រះ នៅក្នុងរដ្ឋកាលថ្មីឡើយ លើកលែងតែរឿងវិវាទមួយគត់ គឺរឿងវិវាទដីធ្លី កេរ្តិ៍អាករស្រែចម្ការរបស់ប្រជារាស្ត្រ។

ដូច្នេះហើយ អត្ថិភាពនៃច្បាប់នៅសម័យអង្គរ គឺអាចលាតត្រដាង តាមរយៈរឿងរ៉ាវ ដែលចារឹកនៅលើសិលា តាមសិលាចារឹកវិទ្យា (Épigraphie) ដែលមិនមែនជាអត្ថបទជាក់ស្តែង ដែលអាចលើកយកនូវមាត្រាណាមួយ មកប្រៀបធៀបទេ។ ជាវិទ្យាសាស្ត្រនៃការស្រាវជ្រាវ គេមិនធ្វើការអះអាងថាធម្មសាស្ត្រដែលអាចរកបានពីក្រមមនុនាពេលបច្ចុប្បន្ននេះ ជាក្រមព្រះធម្មសាស្ត្ររបស់សម័យអង្គរនោះទេ។ ទន្ទឹមនេះ គេសង្កេតឃើញមានសញ្ញាណខុសប្លែកគ្នាមួយចំនួន រវាងប្រព័ន្ធច្បាប់ឥណ្ឌា ដែលមហាក្សត្រមិនមែនជាចៅក្រមកំពូល រីឯសម្រាប់ប្រវត្តិសាស្ត្រខ្មែរយើង តាំងពីបុរាណកាលរៀងមក ព្រះមហាក្សត្រគឺជាចៅក្រមកំពូល ដែលតំណាងឱ្យព្រះសម្មទិទេព ឬសម្មទិវាជជាព្រះពោធិសត្វ ដែលកាត់សេចក្តីប្រកបដោយសុគតិគមនំ ពីឥធលោក ដល់បរលោក។

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

១.៣.១. ក្រមច្បាប់ខ្មែរពីបុរាណ

នៅសម័យក្រោយអង្គរ (សម័យកណ្តាល) ព្រះធម្មសាស្ត្រ មានរូបរាងពិតប្រាកដឡើង តាមរយៈ **ព្រះករុណាព្រះបាទអង្គឌួង** ដែលព្រះអង្គបានសោយរាជសម្បត្តិ ហើយមានព្រះរាជតម្រិះគិតគូរចងក្រងច្បាប់ ដោយយកលំនាំភាគច្រើនចេញពីច្បាប់របស់**ព្រះបាទជ័យជេដ្ឋាទី១** និង**ព្រះបាទជ័យជេដ្ឋាទី៣** នាដើមសតវត្សទី១៧ ហើយត្រូវបាន **ព្រះករុណាព្រះបាទនរោត្តម** ប្រមូលចងក្រងច្បាប់ទាំងអស់នោះ ដោយចម្លងចេញពីសាស្ត្រាស្លឹករឹត និងយកមកដាក់បោះពុម្ពជាសៀវភៅ នៅក្នុងរោងពុម្ពប្រូតិកតុរ៉ាអាណាព្យាបាលបារាំង។

ទោះបីជាយ៉ាងណាក៏ដោយ ព្រះធម្មសាស្ត្រ នៅតែជាច្បាប់កំពូលរបស់ព្រះមហាក្សត្រ ដែលគ្រប់ច្បាប់ទាំងអស់ ត្រូវតែអនុលោមតាមក្រមព្រះធម្មសាស្ត្រ។ តាមរយៈនេះ ច្បាប់នាសម័យក្រោយអង្គរ (សម័យកណ្តាល) ដែលនៅសេសសល់ ត្រូវបានប្រមូលចងក្រងជាកម្រងច្បាប់ខ្មែរពីបុរាណចំនួន ៤ ភាគ ដែលត្រូវបានចងក្រងឡើងអស់រយៈពេលជាងមួយទសវត្សរ៍កន្លងមកនេះ ក្រោមការផ្តួចផ្តើមគំនិតដ៏ខ្ពង់ខ្ពស់របស់ **សម្តេចសេដ្ឋវិទូ ភក្តី គាត ឈន់** អតីតឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងត្រូវបាន

បន្តគម្រោងនេះដោយ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រោមការគាំទ្រ ទំនុកបម្រុង ការសម្រេចដ៏ខ្ពង់ខ្ពស់ពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ហើយបន្តដល់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ដែលបន្តការគាំទ្រគម្រោងនេះ រហូតមកដល់បច្ចុប្បន្ន។ កម្រងច្បាប់ខ្មែរពីបុរាណ រួមមាន ៨៣ ក្រម/ច្បាប់ ដូចជា៖

១-ក្រំមព្រះធម្មសាត្រ	២-ក្រំមលក្ខណឥន្ធកាស
៣-ក្រំមទំរុងស័ក្ខតិ៍	៤-ក្រំមក្បដ្ឋសិក់
៥-ក្រំមមុណ្ឌីរបាល	៦-ក្រំមអាជ្ញាលួង
៧-ក្រំមព្រះធម្មនុញ	៨-ក្រំមត្រលាការ
៩-ក្រំមសាកសីពីសោធន៍	១០-ក្រមកាត់សំនួនកាត់សាក្សី
១១-ក្រំមទ៏ទួលកាត់បន្តឹង	១២-ក្រំមអញ្ញមញ្ញបដិភាស
១៣- ក្រំមឧទ្ធរ៍	១៤- ក្រំមព្រំហ្មទណ្ឌ
១៥- ក្រំមចោរកំម្ម	១៦-ក្រំមព្រះរាជក្រិតសំយ៉ារី
១៧-ក្រំមទស់កិរីយា	១៨- ក្រំមមរដក់
១៩-ក្រមសារពើគុណ	២០-ក្រំមពហុលទេព្វ
២១-ក្រំមសែះ	២២-ក្រំមពួក
២៣-ក្រំមវិវាទ	២៤-ក្រំមបៀរ
២៥-ក្រំមបំណុល់	២៦-ល័ក្ខណៈទាសកម្មករ
២៧-ក្រំមសួស្តីបនជូនព្រៃយ	២៨-ក្រមព្រះរាជខណ្ឌ
២៩-ច្បាប់ទុំនីមព្យីបូរ៉ាន	៣០-ច្បាប់ក្រំមចក្រីយ៍
៣១-ព្រះធម្មសាត្រ	៣២-ច្បាប់រាជនីតិសាស្ត្រ
៣៣-ព្រះរាជក្រឹត្យ នៃមហាក្សត្រាធិរាជ	៣៤-ក្រឹត្យព្រះវររាជមាតា
៣៥-ក្រឹត្យព្រះអគ្គមហេសី	៣៦-ក្រឹត្យឧបរាជ
៣៧-ក្រឹត្យបុរោហិត	៣៨-ក្រឹត្យពលទេព
៣៩-ក្រឹត្យសារថី	៤០-ក្រឹត្យសេដ្ឋី
៤១-ក្រឹត្យឃុនឃ្លាំង	៤២-ក្រឹត្យឆ្មាំទ្វារ
៤៣- ក្រឹត្យនាងសុវណ្ណបុប្ផា	៤៤- ទសមិត្តធម៌
៤៥- លក្ខណៈអាជ្ញាហ្លួង	៤៦-ច្បាប់ក្រមស្រុកព្រះជ័យចេស្តា

៤៧-ច្បាប់ក្រមចៅហ្វាយស្រុក	៤៨- ច្បាប់ក្រមព្រះនគរបាល
៤៩-ច្បាប់អាណាចក្រ	៥០-ក្រមសុភាធិបតី (I)
៥១-ក្រមសុភាធិបតី (II)	៥២-ច្បាប់ក្រមស្រុក ៩ ប្រការ
៥៣-ក្រមប្រដៅចៅក្រម (I)	៥៤-ក្រមប្រដៅចៅក្រម (II)
៥៥-ច្បាប់កុលបន្ទប់ សភៅវិលេខ១	៥៦-ច្បាប់កុលបន្ទប់ សភៅវិលេខ២
៥៧-ច្បាប់កុលបន្ទប់ សភៅវិលេខ៣	៥៨-ច្បាប់កុលបន្ទប់ព្រះរាជសាស្ត្រ
៥៩-ច្បាប់កុលបន្ទប់	៦០-ច្បាប់ព្រះរាជសាស្ត្រ
៦១-ច្បាប់សារពើគុណ	៦២-ច្បាប់ឃុនសាលា
៦៣-លក្ខណៈល្មើសព្រះរាជបញ្ញត្តិ	៦៤-លក្ខណៈប្តីប្រពន្ធ
៦៥-ច្បាប់ក្រមសួស្តីចែកពល	៦៦-ច្បាប់ក្រមសួស្តីប្រចាប់ពល
៦៧-លក្ខណៈខ្ចុំលួចទ្រព្យ ម្ចាស់ទ្រព្យ	៦៨-លក្ខណៈរុករានទី
៦៩-លក្ខណៈទទួលទិញបញ្ចាំទ្រព្យ	៧០-ច្បាប់ក្រមដំរី
៧១-ច្បាប់សំពៅ	៧២-ច្បាប់សារពើល្បែងភ្នាល់គ្នា
៧៣-លក្ខណៈកំហែង, លក្ខណៈភ្នាល់	៧៤- ក្រមស័ក្តិនិងលក្ខណៈវិវាទគ្នា
៧៥- លក្ខណៈវិវាទ	៧៦-លក្ខណៈវិវាទសង្សការី
៧៧-ក្បួនព្រះរាជសព្ទ	៧៨- ក្បួនរាជាភិសេក
៧៩-ច្បាប់ប្រាប្តាភិសេក	៨០-ច្បាប់ទ្វាទសមាស

៨១-ច្បាប់ធ្វើពិធីត្រុដិចង្រ្កានទ្វាទសមាស ៨២-ព្រះរាជក្រឹត្យគ្មានចំណងជើងនិងមិនចប់ ៨៣-គម្ពីរត្រៃភូមិ។

១.៣.២. ការតាក់តែងច្បាប់មុនៗ

យ៉ាងណាក៏ដោយ បើយើងពិនិត្យមើលទៅលើក្រំមព្រះធម្មសាស្ត្រ របៀបនៃការតាក់តែងមិនដូចទៅនឹងការតាក់តែងច្បាប់នាពេលបច្ចុប្បន្នឡើយ។ ច្បាប់/ក្រំមខ្មែរពីបុរាណ ត្រូវបានតាក់តែងឡើងដោយពុំមានបែងចែកជាមាត្រា ឬជំពូកឡើយ គ្រាន់ជាការពណ៌នា និងបែងចែកជាសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។ រីឯការតាក់តែងច្បាប់ត្រូវបានដឹកនាំដោយព្រះមហាក្សត្រដោយផ្ទាល់ បន្ទាប់ពីដាក់ត្រាស់បង្គាប់ឱ្យឧកញ៉ាណាម្នាក់ដែលរៀបចំច្បាប់ ជាអាទិ៍ឧកញ៉ាសុភាធិបតីជាដើម ដែលត្រូវបានសន្មតថាជាព្រះឃ្លាំងច្បាប់ ហើយបានយកមកប្រជុំជួបជុំនៅមុខមន្ត្រីសេនាបតី ព្រាហ្មណ៍បុរោហិត សម្តេចព្រះសង្ឃរាជ ដើម្បីធ្វើការសម្រេចសេចក្តី។

បទប្បញ្ញត្តិដើមដំបូងបង្អស់នៃក្រមព្រះធម្មសាស្ត្រ គឺចែងអំពីអគតិធម៌ទាំង ៤ ប្រការ គឺ ឆន្ទាគតិ ទោសាគតិ ភយាគតិ និងមោហាគតិ។ ការដែលលុះដោយអគតិធម៌ទាំង ៤ ប្រការនេះ អ្នកកាត់សេចក្តីទាំងឡាយនឹងទទួលបាននូវឥស្សរិយយស និងបរិវារយសរលាយសាបសូន្យទៅ ដូចជាព្រះចន្ទចរក្នុងថ្ងៃចាស់រនោច តាំងពីខែ១រោច ដល់១៥រោច ដែលងងឹតឈឹង។ រីឯអ្នកពិភាក្សាត្រាសេចក្តីទាំងឡាយណា ដែលវៀរចាកបានល្អនូវអគតិធម៌ទាំង ៤ ប្រការនេះ នឹងទទួលបាននូវឥស្សរិយយសនិងបរិវារយស ចេះតែភ្លឺថ្លាទៅប្រៀបដូចជាព្រះចន្ទចរក្នុងថ្ងៃចាស់ខ្នើត ពី១កើត ដល់ ១៥កើត ពោលគឺដូចពេញបូណ៌មីរះភ្លឺថ្លាពណ្ណរាយ។

ចំពោះក្រំមព្រះធម្មសាស្ត្រ មិនត្រូវបានចែងជាមាត្រាសម្រាប់កំណត់អំពីទោសទណ្ឌណាមួយឡើយ តែគឺជាសំណុំនៃច្បាប់ ដែលបញ្ញត្តអំពីច្បាប់ដែលត្រូវតាក់តែងជាបន្តទៀត ដែលប្រៀបដូចជារដ្ឋធម្មនុញ្ញនាពេលបច្ចុប្បន្ននេះដែរ។ ក្នុងន័យនេះទើបក្រំមព្រះធម្មសាស្ត្រ ចែងជាបញ្ញត្តិចុងក្រោយថា មានមូលគតិ និងសាខាគតិ។ ចំពោះមូលគតិសំដៅទៅលើច្បាប់ដែលបញ្ញត្តចែងជាក់លាក់ជាឈ្មោះច្បាប់នៅក្នុងក្រមព្រះធម្មសាស្ត្រ។ រីឯសាខាគតិ មិនមែនជាឈ្មោះច្បាប់ទេ តែជាព្រះរាជសាសន៍ ជាព្រះរាជអាជ្ញា ជាព្រះរាជាបញ្ញត្តិ ជាព្រះរាជាកំណត់ របស់ព្រះមហាក្សត្រ ដែលព្រះអង្គទំនុកបម្រុងរាជាប្រពៃណីជាទីសុខក្សេមក្សាន្ត ញ៉ាំងប្រជារាស្ត្រ ឱ្យមានជីវភាពធូរធារតាមរយៈការចេញព្រះរាជសាសន៍ តាមព្រះរាជនយោបាយនៃការដឹកនាំប្រទេស តាមកាលៈទេសៈនីមួយ ៗ ធ្វើឱ្យព្រះនគរព្រះអង្គមានសេចក្តីសុខចម្រើនក្សេមក្សាន្ត ជាឧត្តមប្រយោជន៍ដល់ប្រជារាស្ត្រ ដោយអនុលោមតាមមាគ៌ាគ្រឹះនៃព្រះធម្មសាស្ត្រ។

១.៣.៣. សញ្ញាណ នៃយុត្តិធម៌

ក្រំមនានា ក្រៅពីក្រំមព្រះធម្មសាស្ត្រ ក៏ចែងអំពីសញ្ញាណនៃយុត្តិធម៌ផងដែរ ដូចជាក្រំមត្រលាការ, ក្រំមសាកសីពីសោធន៍, ក្រំមមុណ្ឌីរបាល, ក្រំមលក្ខណឥន្ទភាស ជាដើម។ ចំពោះ ក្រំមលក្ខណឥន្ទភាស គឺជាក្រមដែលចែងអំពីក្រមសីលធម៌របស់អ្នកកាត់សេចក្តីនិងខ្លឹមសារនៃអគតិធម៌ទាំង ៤ ប្រការ។ ក្រៅពីនេះ យើងមានសាស្ត្រាកឹងកន្ត្រៃ ដែលតែងតែលើកឡើងពីការកាត់សេចក្តីទាំង ៥៣ រឿង ដោយចៅក្រម ហើយចៅក្រមតែងតែកាត់សេចក្តីដោយមានជំនួយពីខាងក្រៅ រហូតទៅដល់គាល់ព្រះមហាក្សត្រ ដើម្បីកាត់សេចក្តី ប្រកបដោយសុចរិតយុត្តិធម៌។

រីឯ ក្រមសីលធម៌របស់អ្នកកាត់សេចក្តី តម្រូវឱ្យអ្នកកាត់សេចក្តីទាំងឡាយត្រូវ ព្យាយាមឱ្យបានសមប្រកបដោយសុគតិធម៌ ៤ ប្រការគឺ៖

- **សុចរិតយុត្តិធម៌៖** ក្នុងការកាត់សេចក្តី បើសិនបើចៅក្រម មិនប្រកបសុចរិត មិនមានទេយុត្តិធម៌។ ហេតុនេះហើយ ក្រំមព្រះធម្មសាស្ត្រចែងជាបឋម បញ្ញត្តិ អំពីក្រមសីលធម៌របស់អ្នកកាត់សេចក្តីគឺអគតិធម៌ទាំង ៤ប្រការ។
- **បញ្ញត្តិគារវោ៖** គឺត្រូវគោរពបទប្បញ្ញត្តិច្បាប់។
- **សមទណ្ឌោ៖** គឺការនិច្ឆ័យផ្តន្ទាទោសមស្របទៅតាមកំហុស។
- **បញ្ញាវុធនិច្ឆ័យ៖** គឺការកាត់សេចក្តី ដោយប្រើប្រាស់បញ្ញាញាណ។

ទន្ទឹមនឹងនេះ ច្បាប់ខ្មែរពីបុរាណ ក៏បានកំណត់នូវវិធីសាស្ត្រក្នុងការរកយុត្តិធម៌ ផងដែរ។ ព្រះមហាក្សត្រខ្មែរមិនត្រឹមតែចែងអំពីបញ្ញត្តិដែលត្រូវគោរពនោះទេ ថែមទាំង ចែងអំពីសិល្ប៍សាស្ត្រក្នុងការសម្រេចសេចក្តីផងដែរ ដែលសម្តេចព្រះសង្ឃរាជ **ជួន ណាត** ព្រះអង្គបានយកសាស្ត្រាពណ៌ខ្មៅ យកមកចម្លងទុក នៅក្នុងវចនានុក្រមខ្មែរ និងដាក់ ឈ្មោះថា "ល្បិចចៅក្រម"។ ប្រសិនបើយើងពិនិត្យនៅក្នុងវចនានុក្រមខ្មែរ យើងនឹងពិនិត្យ ឃើញពាក្យល្បិចចៅក្រម ដែលរួមមាន មន្ទរលេន សេនបទ មណ្ឌុកដ សីហលោ ជាសិល្ប៍ សាស្ត្រ ចិត្តសាស្ត្រ វោហារសាស្ត្ររបស់អ្នកកាត់សេចក្តី ដើម្បីស្ទាបស្ទង់ចិត្តរបស់គូក្តី គូវិវាទ រកសេចក្តីពិត ទើបផ្តល់យុត្តិធម៌បាន។ ចំពោះវិធីសាស្ត្រ "មន្ទរលេន" ប្រៀបប្រដូចទៅនឹង ទឹកហូរវិញៗ ការស៊ើបអង្កេត រករឿងហេតុ សេចក្តីពិត នៅក្នុងអង្គសេចក្តី រឿងរ៉ាវទំនាស់ គឺត្រូវប្រព្រឹត្តទៅដោយសន្សឹមៗ។ ប៉ុន្តែក្នុងករណីរបៀបសន្សឹមៗ ដូចទឹកហូរវិញៗ មិន មានប្រសិទ្ធភាពទេ គឺយើងប្រើវិធីសាស្ត្រទីពីរ គឺ "សេនបទ" គឺប្រៀបប្រដូចនឹងឥរិយាបទ របស់ខ្លែងឆាបកូនមាន់ គឺត្រូវស្ងាត់ រហូតដល់ពេលត្រូវធ្វើសកម្មភាព គឺត្រូវធ្វើឱ្យបានឆាប់ ចាប់ឱ្យបានយកជាការពិត (វិធីក្លែង)។ ចំពោះវិធីសាស្ត្រ "មណ្ឌុកដ" ជាវិធីត្រាប់តាម កង្កែបលោត មិនមែនធ្វើសន្សឹមៗទេ គឺត្រូវធ្វើឈប់ ធ្វើឈប់ ទៅតាមជំហានរបស់កង្កែប លោតជាដំណាក់ៗ។ បើសិនបើវិធីសាស្ត្រទី៣ មិនមានប្រសិទ្ធភាពទេ គឺប្រើវិធីសាស្ត្រ "សីហលោ" គឺសម្លុតកំហែងឱ្យស្លុតហើយទទួលយកការពិត ដោយសារតែអ្វីៗមានភាព ច្បាស់លាស់អស់ហើយ។

លក្ខណៈសម្បត្តិរបស់ចៅក្រម ឬនិយាយម្យ៉ាងទៀតថា លក្ខណៈសម្បត្តិរបស់ អ្នកពិភាក្សាសេចក្តី មាន ៣ប្រការ ដែលមានលក្ខណៈសម្បត្តិ ដូចខាងក្រោម៖

- **ចៅក្រម** គឺសំដៅទៅលើអ្នកដែលកាន់ច្បាប់។ អ្នកកាត់សេចក្តីទាំងឡាយ រហតដល់ព្រះមហាក្សត្រ ចាំបាច់ត្រូវតែចេះច្បាប់ ហើយក៏ត្រូវនមស្ការក្រំម ព្រះធម្មសាស្ត្រ នៅរៀងរាល់ល្ងាចជាកាតព្វកិច្ចផងដែរ។ ព្រះរាជកិច្ចរបស់ ព្រះមហាក្សត្រនៅពេលល្ងាច ក្រោយពីស្តាប់ភ្លេងហើយ គឺត្រូវនមស្ការក្រំម ព្រះធម្មសាស្ត្រ។
- **សុភា** ក៏ជាអ្នកកាត់សេចក្តីផងដែរ ដែលបច្ចុប្បន្ននេះ យើងប្រើពាក្យសុភា ខ្លះ ពាក្យសភាខ្លះ។ សុភាគឺជាអ្នកពិភាក្សាត្រាសេចក្តីទាំងឡាយ ចាំបាច់ ត្រូវតែមានសំដីពិរោះពិសា ទទួលយកនូវទំនាស់ ពាក្យបណ្តឹង ពាក្យចោទ ពាក្យឆ្លើយរបស់គូវិវាទទាំងឡាយ ដោយធ្វើឱ្យវិវាទធំ ឱ្យនៅរួមស្ងួចតូច រឹង រឿងដែលតូច ឱ្យវាអស់រឿង ដោយមិនចាំបាច់កាត់សេចក្តីឡើយ។
- **ត្រឡាការ** គឺសំដៅទៅលើការដែលអ្នកពិភាក្សាត្រាសេចក្តី ត្រូវតែប្រកាន់ ខ្លួននៅជាកណ្តាល ប្តឹងថ្លែងភាគីទាំងសងខាង ដែលត្រូវរៀបចាកនូវអគតិ ធម៌ទាំង ៤ ប្រការ។

ក្រៅពីការគោរពនូវក្រមសីលធម៌របស់ចៅក្រម និងកាតព្វកិច្ចត្រូវនមស្ការក្រំម ព្រះធម្មសាស្ត្រ ចៅក្រម ក៏ដូចជាមន្ត្រីរាជការទាំងឡាយ ត្រូវកាន់សីលប្រាំ ចាំសីលប្រាំបី និងមានព្រហ្មវិហារធម៌ផងដែរ។ ចំពោះព្រះមហាក្សត្រ អាចមានលក្ខណៈតឹងរ៉ឹងជាង ចៅក្រមធម្មតា ពោលត្រូវមានទសពិធរាជធម៌ រួមមាន៖ ទាន, សីល, បរិច្ចាគ, អាជីវៈ មទ្ទវៈ, តបៈ, អក្កោធនៈ អវិហិង្សា, ខន្តី និងអវិរោធនៈ។

១.៣.៤. សញ្ញាណ នៃបទដ្ឋានគតិយុត្ត

ច្បាប់ខ្មែរពីបុរាណ ពេលខ្លះមានលក្ខណៈជាច្បាប់បង្គាប់ ពេលខ្លះត្រូវបាន តាក់តែងឡើងក្រោមទម្រង់ជាច្បាប់ទូន្មាន។ ចំពោះច្បាប់បង្គាប់ មានលក្ខណៈចាប់បង្ខំឱ្យ អនុវត្ត និងមាននូវទណ្ឌកម្មផងដែរ ក្នុងករណីប្រព្រឹត្តខុស ដែលមានចរិតលក្ខណៈ ដូច ទៅនឹងច្បាប់ក្នុងពេលបច្ចុប្បន្នផងដែរ។

តួយ៉ាងនៅច្បាប់ទុំនីមព្យីបូរ៉ាន៖ ទំនឹមទី២០ ពាក់ព័ន្ធអំពើត្បូកព្រះសិរសារបស់ ព្រះសង្ឃ ជាការប្រមាថព្រះសង្ឃផង ជាការប្រមាថព្រះពុទ្ធសាសនាផង ត្រូវមានទោស ១៥០ រំពាត់ និងរឹបអូសទ្រព្យសម្បត្តិទាំងអស់ ហើយបង្គាប់ឱ្យទូលដៃជើងតាមជើងដំរី។ ចំពោះ សារពើទ្រព្យដែលបានបូជាថ្វាយព្រះរតនត្រ័យហើយ ពុំអាចយកវិញបានឡើយ។

ចំពោះក្រមក្បត់សឹក ចែងថាជាប្រពៃណីក្សត្រ ទ្រង់ព្រះបញ្ញតចាត់ទោសដោយគួរនឹងកម្ម។ តាមច្បាប់បុរាណទោសមាន ៣ ប្រការ រួមមានឧក្រិដ្ឋទោស គរុទោស និងលហុទោស។ ដោយសារវាមានលក្ខណៈធ្ងន់ពេក ទើបព្រះមហាក្សត្រ ក្នុងរជ្ជកាលព្រះបាទអង្គឌួង ព្រះអង្គកែសម្រួលទោស ៣ប្រការនេះ មកជាទោស ៥ ប្រការវិញ រួមមានឧក្រិដ្ឋទោស មហានទោស គរុទោស មជ្ឈិមអទោស និងលហុទោស ដើម្បីជួយសម្រាល ដល់ការផ្តល់យុត្តិធម៌ ចំពោះប្រជានុរាស្ត្រ។

រីឯអ្នកកាត់សេចក្តី ប្រជារាស្ត្រ មន្ត្រីទាំងឡាយ ដែលស្វាមីភក្ត្រឈ្នះអស់សង្គ្រាម ពេលដែលជង្ហែព្រះមហាក្សត្រទៅច្បាំង សឹកសត្រូវនៅក្នុងសមរភូមិ គឺត្រូវទទួលបានរង្វាន់។ បើសិនជាខ្ញុំគេ ឬជាទាសករ ពេលត្រឡប់មកវិញ គឺត្រូវបានរួចមកជាអ្នកជាវិញ។ ផ្ទុយទៅវិញ បើគេចរេះពីសង្គ្រាម ដោយចោលស្តេចឱ្យសត្រូវ ត្រូវកាត់ក្បាលនៅលើសមរភូមិ។ ការណ៍នេះ បានជាតាំងពីសម័យអង្គរ មកដល់សម័យក្រោយអង្គរ មានមន្ត្រីមួយរូបដែលទទួលបាននូវភារៈក្នុងការវាយតម្លៃ អំពីគុណនិងទោសរបស់មន្ត្រីរាជការ។ នៅសម័យអង្គរ មន្ត្រីនេះ ត្រូវបានឱ្យឈ្មោះថា "គុណទោសទស៊ី" គឺជាអ្នកដែលពិនិត្យនិងវាយតម្លៃអំពីគុណនិងទោសរបស់មន្ត្រីរាជការ។ ចំពោះអ្នកដែលមានគុណបំណាច់ គឺត្រូវផ្តល់បំណាច់ ដូចជាផ្តល់នូវកន្ទោមាស គ្រែស្នែងជាដើម ដែលព្រះរាជទានទាំងអស់នេះ នៅពេលមន្ត្រីរូបនោះស្លាប់ទៅ ត្រូវបង្វិលមកឱ្យព្រះរាជឃ្លាំងវិញ ដោយមិនអាចបន្តជាកេរ្តិ៍មរតកបានទេ។ ផ្ទុយទៅវិញ មន្ត្រីដែលធ្វើខុស ត្រូវមានទោស។ ចំពោះសម័យក្រោយអង្គរវិញ នៅក្នុងក្រមមុណ្ឌីរបាល បានបញ្ញត្តអំពីនាមរបស់មន្ត្រី ដែលមានភារៈមើលការខុសត្រូវលើមន្ត្រីគ្រប់ទាំងអស់ក្នុងរាជបល័ង្ក។ មន្ត្រីរូបនេះ គឺជាមហាមន្ត្រីតាងព្រះនាមព្រះឱស្ឋរបស់ព្រះមហាក្សត្រ ដោយមានភារៈមើលកិច្ចការខុសត្រូវបន្ទាប់ពីព្រះមហាក្សត្រ ដែលមានឈ្មោះថា "អធិបតីសិរីរាជមន្ទីរបាល" ដែលជាក់ទណ្ឌកម្មចំពោះមន្ត្រីធ្វើខុស និងលើកផ្តល់នូវគុណបំណាច់ដល់មន្ត្រីដែលមានគុណបំណាច់ធំ។

រីឯនៅក្នុងក្រំមព្រះធម្មនុញ្ញ ក៏បានបញ្ញត្តពាក់ព័ន្ធនឹងខ្ញុំរាជការដែលគ្មានសាលាដំនុំ មិនអាចធ្វើជាចៅក្រម ចៅក្រសួងត្បូងការបានទេ មិនអាចយករឿងទំនាស់យកទៅកាត់សេចក្តីនៅផ្ទះចៅក្រមបានទេ ត្រូវតែមានសាលាបញ្ជាន់សិង្ហដើម្បីធ្វើការ។ ក្រំមព្រះធម្មនុញ្ញ បញ្ញត្តនូវការបែងចែកអំពីមុខក្រសួង តាមមុខងារ និងការពិភាក្សារួមក្រសួង ប្រសិនជារឿងវិវាទនោះ មានទំនាក់ទំនងជាមួយសមត្ថកិច្ច ឬក៏មុខការរបស់ក្រសួងត្បូង

ការច្រើន ដូចជា សមត្ថកិច្ចលើកម្មវត្ថុវិវាទពាក់ព័ន្ធជាមួយនឹងការលួច គឺក្រុមព្រះនគរបាល, ការលួចទ្រព្យព្រះមហាក្សត្រ គឺក្រុមព្រះអាជ្ញាហ្លួង។

ដើមព្រះធម្មសាស្ត្រ៖ ក្នុងរជ្ជកាលមុន ខ្វះការថែរក្សា និង ចម្លងកាត់ប្លែងតាមអំពើចិត្តដោយមនុស្សទុច្ចរិត ទើបតែងថ្មី ដោយហេតុទាំងពីរប្រការនេះ សម្រាប់ទុកជាមូលធម្ម ដែលព្រះមនោសារាចារ ឬព្រះមនោសារឥសី បានសម្តែងទុកជា បុរេចរឹក ដូចតទៅ៖

“ភ្លើងរំលាយកប្ប ឆេះរាលដាលដល់ឋានព្រហ្ម៖ ភ្លើងឆេះដល់ត្រឹមណា ទឹកលិចដល់ត្រឹមនោះ។ យូរមកខ្យល់បក់ ទឹកស្រកស្រុត ទាបចុះ ពពុះទឹកខនខាប់កើតជាផែនកែវ ប៉ុនចក្រវាឡ ជាបន្តបន្ទាប់ជាច្រើនលានយោជន៍ រហូតដល់បង្កើតបានជាផែនដីកើតធំឡើងទៅជាចក្រវាឡយើងនេះ ឈ្មោះថា មង្គលចក្រវាឡ ដ្បិតនៅសិរសាផែនដីមានឈូក ១ គុម្ព ដុះត្រង់ឡើង មានទង១ ផ្កាបែកជា ៥ ជាសញ្ញានៃការត្រាស់ដឹងរបស់ព្រះពុទ្ធ ៥ អង្គ នៅដើមកទ្រកប្បនេះ។ ព្រហ្ម ចុះមកបង្កើតជាមនុស្ស មានវិវាទគ្នា ព្រះបរមពោធិសត្វ ត្រូវបានប្រជាជន តាំងជាព្រះបាទសម្តេចព្រះមហាសម្មតិរាជ។ មានមហាព្រហ្ម ១ អង្គ (ព្រហ្មទេវៈ) ចុតចុះមកក្នុងត្រកូលមហា មាត្យ ជាខ្ញុំ ព្រះបាទសម្តេចព្រះមហាសម្មតិរាជ លុះវ័យ ១៥ ឆ្នាំ តាងតំណែងបិតា ឃើញសត្វមានទុក្ខលំបាក វិវាទទាស់គ្នា មានចិត្តចង់ឱ្យព្រះមហាក្សត្រ តាំងក្នុងទសពិធរាជធម៌ ក៏ឥស្សរិយយស លាទៅបួសជាតាបសឥសី។ មានកាលភ្លៀងធំ នាងទេពគន្ធបកិណ្ណាវី ទៅជ្រកសំណាក់ នៃព្រហ្មទេវៈឥសី មានចិត្តប្រតិព័ទ្ធ បានបុត្រ២អង្គ៖ ចៅកទ្ធរកុមារ និង ចៅមនោសារកុមារ។ ទាំងពីរបួសជាឥសី សម្រេចបានអភិញ្ញាណ ៥ និងអដ្ឋសមាបត្តិ ៨។ ព្រះកទ្ធរតាបស ហៅទៅកាន់កន្លាប់ចក្រវាឡ ចម្លងគម្ពីរអោគមវេទ ថ្វាយមហាក្សត្រ ក្លាយជារាជគ្រូ។ ព្រះមនោសារតាប ជាអាមាត្យជំក្នុងទីសុភាជំនុំពិភាក្សាសេចក្តី។ គ្រានោះ បុរស ២ នាក់ធ្វើចម្ការត្រសក់ជិតខាងគ្នា ពូនដីខ្ពស់ឡើងជាព្រំចម្ការខណ្ឌកណ្តាល កុំឱ្យច្រឡំគ្នា រីឯ ត្រសក់ដុះលូតលាស់បោះទង ឆ្លងព្រំទៅមកប្រសព្វគ្នា មានផ្លែ បេះកើតវិវាទគ្នា នាំគ្នាទៅប្តឹងព្រះមនោសារអាមាត្យ។ ព្រះមនោសារអាមាត្យ៖ ចម្ការត្រសក់មានព្រំខណ្ឌកណ្តាលហើយ បើត្រសក់ផ្លែនៅក្នុងចម្ការអ្នកណា ឱ្យជារបស់អ្នកនោះ។ កាត់ក្តីមិនយុត្តិធម៌ បុរសមិនសុខចិត្តទៅប្តឹងព្រះមហាក្សត្រ ត្រាស់បង្គាប់រាជ្យអាមាត្យ១ទៀត ទៅពិចារណាមើលទងត្រសក់ ហើយទ្រង់បណ្តាំថា ឱ្យលើកទងត្រសក់នោះដាក់មកតាមគល់ ហើយបង្គាប់ឱ្យបេះផ្លែត្រសក់តាមគល់។ បុរសពេញចិត្ត សរសើរព្រះប្រាជ្ញាញាណ រីឯ ព្រះមនោសារអាមាត្យ ត្រូវត្មៃតិះដៀល ដោយល្បែងអគតិ ៤ ប្រការមាន មោហាគតិ កើតធម្មសង្វេគ

ស្មុតចិត្ត ខ្មាសរាស្ត្រ ទៅបួសជាឥសី ដូចដើមវិញ សម្រេចបាន អភិញ្ញាណ ៥ និងអដ្ឋ សមាបត្តិ ៨ ប្រជារាស្ត្រក៏ត្រេកអរឡើងវិញ ។ មនោសារតាបស មានចិត្តចង់ឱ្យព្រះមហា ក្សត្រទ្រង់ទសពិធរាជធម៌ ក៏ហោះទៅកំពែងចក្រវាឡ បានឃើញគម្ពីរព្រះធម្មសាស្ត្រ តាម ស្នាមលក្ខណៈអក្សរប្រាកដ មានបរិមណ្ឌលតួនីមួយៗ ប៉ុនដំរីសារ។ ព្រះមនោសារឥសី កំណត់ក្តចកត់សម្គាល់រាល់តួចាំបាន ហើយវិលត្រឡប់មកតែងឡើងជាគម្ពីរព្រះធម្ម សាស្ត្រ ថ្វាយព្រះបាទសម្តេចព្រះមហាសម្មតិរាជ ដោយសច្ចធម៌។ ព្រះបាទសម្តេចព្រះ មហាសម្មតិរាជ ស្តេចសោយរាជសម្បត្តិ កំចាត់ភ័យ នៃប្រជាជន ជាសុខសោកិនី ស្តេច តាំងក្នុងធម៌ទសពិធ ១០ ប្រការ ទ្រង់នូវបញ្ចសីល ឧបោសថសីល ទ្រង់ព្រះករុណានុ គុណ ដល់សត្វលោកផងមិនរើសមុខ ហើយទ្រង់ព្រះឧស្សាហ៍នមសិការ នូវគម្ពីរព្រះធម្ម សាស្ត្រ ជានីតិក្នុងព្រះអង្គ ទ្រង់ប្រព្រឹត្តក្នុងធម៌ ៤ ប្រការ ៖

១. ពិចារណាជ្រាបសេចក្តីខុស ត្រូវ នៃអ្នកដែលធ្វើឱ្យជាប្រយោជន៍និងមិនជា ប្រយោជន៍ដល់ព្រះអង្គ
២. ទំនុកបម្រុងផ្គងផ្តើមកុលបុត្រ ដែលរក្សាសីលសត្យ
៣. ប្រមូលព្រះរាជទ្រព្យក្នុងព្រះរាជធានី ត្រូវដោយគន្លងធម្ម
៤. រក្សាខបខណ្ឌសីមាមហានគរ និងអាណាប្រជានុរាស្ត្រ ឱ្យសុខសប្បាយ ក្សេមក្សាន្ត ដោយយុត្តិធម៌។

២. ទស្សនាទានទំនើបភាគូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា

២.១. ការធ្វើទំនើបភាគូបនីយ៍កម្មតាមបែបបារាំង

ក្រោយពីការដាក់អាណានិគមបារាំង, ប្រទេសកម្ពុជា បានរៀបចំជាប្រព័ន្ធច្បាប់ ប្រព័ន្ធតុលាការ និងបានបង្កើតរដ្ឋធម្មនុញ្ញនៅឆ្នាំ១៩៤៧។ ការធ្វើទំនើបកម្មប្រព័ន្ធច្បាប់ កម្ពុជាតាមលំអានបារាំងរួមមាន៖

- ការបង្កើតគណៈកម្មការចម្រុះកម្ពុជា-បារាំងដើម្បីបង្កើតក្រមច្បាប់ខ្មែរ (១១ សីហា ១៩០១)
- ក្រមនីយកម្មតាមលំអានបារាំងត្រូវបានរៀបចំរួមមាន ក្រមព្រហ្មទណ្ឌ ក្រម នីតិវិធីព្រហ្មទណ្ឌ ក្រមស្តីពីការរៀបចំតុលាការ (១៩១២)

- វិធីសាស្ត្រនៃការរៀបចំក្រមរដ្ឋប្បវេណីយកតាមលំអានបារាំង៖ បង្កើតគណៈកម្មការចំនួន៥ ចុះប្រមូល ពិនិត្យនិងចងក្រងរៀបចំជាក្រមរដ្ឋប្បវេណីសម័យទំនើប (១៩២០)
- ការបង្កើតស្ថាប័នតុលាការឱ្យមានជារចនាសម្ព័ន្ធរឹងនៅតាមបណ្តាខេត្ត (១៩២២)
- យន្តការនៃការដោះស្រាយជម្លោះមាន៣កម្រិត៖ សាលាដំបូង សាលាឃុត ឬសាលាឧទ្ធរណ៍ និងសាលានិច្ឆ័យឬតុលាការកំពូល។ វិវាទរដ្ឋប្បវេណីព្រហ្មទណ្ឌនិងរដ្ឋបាលត្រូវបានបែងចែកដាច់ពីគ្នា តាមរយៈការបង្កើតសាលាឧក្រិដ្ឋ (១៩១២)និងសាលាក្រមឈុត (១៩២៣) សម្រាប់វិវាទព្រហ្មទណ្ឌ និងសាលាក្រមវិវាទ (១៩៣៣) សម្រាប់វិវាទរដ្ឋបាល។

២.២. គុណតម្លៃទំនើបនិងគុណតម្លៃទំនៀម ៖ តាសាច្បាប់ និងទស្សនវិជ្ជាច្បាប់

២.២.១. ទស្សនាទាន និងការវិវត្ត

ការសិក្សាស្វែងយល់ពីទស្សនវិជ្ជានៃគុណតម្លៃ ត្រូវបានទស្សនវិទូលោកខាងលិចសិក្សានិងបង្កើតនូវគំហើញទ្រឹស្តីជាច្រើនបន្តបន្ទាប់មកទល់បច្ចុប្បន្ននេះ។ នៅក្នុងទស្សនវិជ្ជាបុរាណ ឬបែបក្លាសិក គុណតម្លៃត្រូវបានផ្សារភ្ជាប់ជាមួយនឹងទ្រឹស្តី ឬគោលលទ្ធិនៃគុណធម៌ (aretē) និងភាពល្អ (agathon)។ សម្រាប់ប្លាតុង (Plato) ភាពល្អ គឺជាទម្រង់ដ៏ខ្ពង់ខ្ពស់បំផុត ដែលជាមូលដ្ឋានគ្រឹះនៃចំណេះដឹងនិងយុត្តិធម៌។ អារីស្តូត (Aristotle) បានយកគោលលទ្ធិនេះទៅលម្អិតនៅក្នុងក្រមសីលធម៌ Nicomachean (ក្រមសីលធម៌ដែលកំណត់ថាធម្មជាតិនៃសកម្មភាពនិងសីលធម៌របស់មនុស្សគឺជាឫសគល់នៃទស្សនាទានសុភមង្គល) ដែលផ្សារភ្ជាប់គុណតម្លៃជាមួយនឹងគោលបំណង (telos) នៃសកម្មភាពរបស់មនុស្ស។

សម្រាប់ទ្រឹស្តីទស្សនវិជ្ជាសម័យកណ្តាលនិងសម័យទំនើប ទ្រឹស្តីគុណតម្លៃ បានវិវត្តនិងផ្លាស់ប្តូរជាបន្តបន្ទាប់។ ទស្សនវិទូ Immanuel Kant បានបែងចែករវាងវត្ថុដែលមានតំលៃ និងរបស់ដែលមានភាពថ្លៃថ្នូរ។ សម្រាប់ទស្សនវិទូ Kant គុណតម្លៃផ្នែកសីលធម៌កើតចេញពីស្វ័យភាព និងសមត្ថភាពក្នុងការធ្វើសកម្មភាពស្របតាមច្បាប់សកលដោយមានកាតព្វកិច្ចសីលធម៌ជាមូលដ្ឋាន។ ទស្សនវិទូ Nietzsche បានលើកឡើងជា

ទ្រឹស្តីគុណតម្លៃថា ជាការវាយតម្លៃឡើងវិញនៃគុណតម្លៃទាំងអស់ ដោយបដិសេធនូវ ហានានុនៃទ្រឹស្តីសីលធម៌ដែលមិនផ្លាស់ប្តូរ តែឱ្យតម្លៃលើភាពច្នៃប្រឌិតដែលជាប្រភពនៃគុណតម្លៃថ្មី។

នៅសតវត្សទី២០ លោក Max Scheler និងលោក Nicolai Hartmann បានបង្កើតនូវទ្រឹស្តី axiology (ទ្រឹស្តីទូទៅ ឬវិទ្យាសាស្ត្រស្តីពីគុណតម្លៃ) ដែលជាការសិក្សាទស្សនវិជ្ជានៃគុណតម្លៃ។ លោក Scheler បានធ្វើការចាត់ថ្នាក់គុណតម្លៃតាមហានានុក្រមពីផ្នែកអារម្មណ៍ ទៅផ្នែកវិញ្ញាណ ដោយបានលើកនូវទេឡ្លីករណ៍បញ្ជាក់ថាគុណតម្លៃមានអត្ថិភាពដោយឯករាជ្យដោយផ្អែកលើអារម្មណ៍និងយោបល់ផ្ទាល់ខ្លួន ដែលជាប្រធាន។ ចំណែក លោក John Dewey នៅក្នុងការអនុវត្តជាក់ស្តែងបានចាត់ទុកគុណតម្លៃថាជាមុខងារ និងបរិបទ ដែលកើតឡើងតាមរយៈបទពិសោធន៍សង្គម និងការកសាងសង្គមឡើងវិញ។ លោក John Dewey ក៏បានលើកឡើងថា ការវិនិច្ឆ័យអំពីគុណតម្លៃ គឺជាវិនិច្ឆ័យអំពីលក្ខខណ្ឌ និងលទ្ធផលនៃវត្ថុវិស័យភាព ដែលគេបានជួបប្រទះ។ ការវិនិច្ឆ័យនេះ គួរតែកម្រិតនូវចនាសម្ព័ន្ធនៃតម្រូវ (សេចក្តីប្រាថ្នា) សេចក្តីស្រឡាញ់ និងការសប្បាយរីករាយ។

លោក Baruch Spinoza (ឆ្នាំ១៦៣២ ដល់ឆ្នាំ១៦៧៧) បានលើកឡើងថា យើងគ្រប់គ្នាមិនមែនចង់បានវត្ថុមួយ ពីព្រោះតែវាល្អនោះទេ តែវាល្អពីព្រោះយើងចង់បានវា ឬត្រូវការវា។

តាមរយៈទ្រឹស្តីទាំងឡាយរបស់ទស្សនវិទូ គេអាចធ្វើបែងចែកទ្រឹស្តីទាំងនោះជា ៣ ធំៗ រួមមានៈទ្រឹស្តីទំនាក់ទំនង, ទ្រឹស្តីបវានុម័ត (the Objective Theory), ទ្រឹស្តីអត្តនោម័តិ (the Subjective Theory)។ សម្រាប់ទ្រឹស្តីទំនាក់ទំនង (The Relational Theory)ៈ គុណតម្លៃមិនមែនជាសម្បត្តិទាំងស្រុងរបស់អ្វីមួយ ឬរបស់អំពើណាមួយទេ ហើយវាក៏មិនមែនជាការបង្កើតទាំងស្រុងរបស់មនុស្សដែរ។ អត្ថិភាពនៃគុណតម្លៃតម្រូវឱ្យមានកត្តាបីៈ ១. មនុស្សដែលជាអ្នកជ្រើសរើសយកអ្វីមួយ ដូចជា វត្ថុ គំនិត មនុស្ស អំពើស្ថានភាព។, ២. អ្វីមួយដែលគេចូលចិត្ត ឬត្រូវការ។ , ៣. បរិបទ ឬកាលៈទេសៈ ដែលក្នុងនោះការវាយតម្លៃកើតមានឡើង។ រីឯ ទ្រឹស្តីបវានុម័ត (Objective Theory)ៈ គុណតម្លៃ គឺជាសម្បត្តិ ឬគុណភាពពិតរបស់វត្ថុវិស័យភាព (វត្ថុ គំនិត មនុស្ស អំពើ...)។ មិនមែនចំណាប់អារម្មណ៍របស់មនុស្សទេដែលបង្កើតគុណតម្លៃ។ វត្ថុ ឬសកម្មភាពដែលល្អ ឬត្រឹមត្រូវ មិនមែនពីព្រោះតែយើងវិនិច្ឆ័យថាវាល្អនោះទេ ប៉ុន្តែពីព្រោះតែនៅក្នុងវត្ថុឬសកម្មភាព នោះមានគុណភាព ពេលដែលយើងបានជួបប្រទះ ពិនិត្យ ឃើញថាវាមានប្រយោជន៍ និងគួរ

ឱ្យចង់បាន។ ចំពោះ ទ្រឹស្តីអត្តនោម័តិ (Subjective Theory)៖ គុណតម្លៃមិនមែនជាអ្វីមួយជាក់លាក់ទេ ពោលគឺវាប្រែប្រួលទៅតាមបុគ្គលនីមួយៗ ឬក្រុមនីមួយៗ។

ផ្អែកតាមទ្រឹស្តីទស្សនវិជ្ជាទូទៅនៃទស្សនាទានគុណតម្លៃ ទ្រឹស្តីទស្សនវិជ្ជាច្បាប់នៃទស្សនាទានគុណគម្លៃច្បាប់ ក៏ត្រូវបានវិវត្តជាបន្តនៅក្នុងការសិក្សាទស្សនវិជ្ជាច្បាប់ផងដែរ។ ទ្រឹស្តីទស្សនវិជ្ជាច្បាប់នៃទស្សនាទានគុណ គម្លៃច្បាប់ មានទំនាក់ទំនងផ្សារភ្ជាប់ឫសគល់ទស្សនវិជ្ជានៃច្បាប់ធម្មជាតិ (Droit Naturel)៖ ប្រទេសក្រិកបុរាណ (ប្រហែលសតវត្សទី ៥-១ មុនគ.ស)ទស្សនវិទូល្បីៗ៖

- អារីស្តូត (Aristotle)៖ ច្បាប់ជាការសំដែងមតិនៃយុត្តិធម៌ ច្បាប់របស់មនុស្សគួរតែឆ្លុះបញ្ចាំងពីហេតុផល និងប្រយោជន៍រួម។
- ស៊ីសេរ៉ូ (Cicero)៖ ច្បាប់មានឫសគល់នៅក្នុងហេតុផលជាសកល គ្មានទីបញ្ចប់។ គុណតម្លៃនៃយុត្តិធម៌ និងសមភាពគឺជាមូលដ្ឋានគ្រឹះនៃច្បាប់។

ការវិវត្តទ្រឹស្តីទស្សនវិជ្ជាសម័យកណ្តាល៖ (សតវត្សទី ១១-១៥ គ.ស.)៖ ទស្សនវិទូ៖ ថូម៉ាស អាគីណាស (Thomas Aquinas)៖ ច្បាប់មានសុពលភាពប្រសិនបើវាស្របនឹងច្បាប់អាទិទេព និងច្បាប់ធម្មជាតិ។ កំណត់ភាពខុសគ្នារវាង៖ Lex aeterna កំណត់នូវគុណតម្លៃសីលធម៌ជាសកល និងLex humana (ច្បាប់មនុស្ស)៖ បទដ្ឋានត្រូវបានចងក្រងដែលឆ្លុះបញ្ចាំងពីគុណតម្លៃ។

ការវិវត្តទ្រឹស្តីទស្សនវិជ្ជាសម័យទំនើប (សតវត្សទី១៧-១៩ គ.ស)៖ ទស្សនវិទូល្បីៗ ដូចជា៖

- លោក Hugo Grotius (១៥៨៣–១៦៤៥)៖ ច្បាប់ធម្មជាតិដែលមិនទាក់ទងនឹងទ្រឹស្តីសាសនា និងកំណត់គុណតម្លៃសង្គមជាប្រភពនៃច្បាប់។
- Jean-Jacques Rousseau (១៧១២–១៧៧៨)៖ ទ្រឹស្តីកិច្ចសន្យាសង្គម, ច្បាប់មានប្រភពមកពីឆន្ទៈរួម និងគុណតម្លៃសង្គម។
- Jeremy Bentham, John Austin៖ ទ្រឹស្តី Legal positivism, បានជំទាស់នឹងយុត្តិកម្មផ្អែកលើសីលធម៌ ដោយកំណត់ថា "ច្បាប់ជាបញ្ជា មិនមែនជាគុណតម្លៃទេ"។

សញ្ញាណនៃ **"គុណតម្លៃច្បាប់"** ត្រូវបានលេចឡើងនៅចុងសតវត្សទី១៩ និងដើមសតវត្សទី២០ ទន្ទឹមនឹងការកកើតឡើងនូវទ្រឹស្តី "axiology" ជាទ្រឹស្តីសិក្សាពីទស្សនវិជ្ជាតម្លៃ។ គុណតម្លៃច្បាប់ផ្សារភ្ជាប់ទំនាក់ទំនងជាមួយសង្គមរស់នៅរបស់មនុស្ស តាមរយៈគុណតម្លៃសង្គម (Social Values) និងទ្រឹស្តីច្បាប់ធម្មជាតិ (Natural Law)។ នៅក្នុងទ្រឹស្តីច្បាប់ធម្មជាតិ គុណតម្លៃច្បាប់ ដូចជាគោលការណ៍យុត្តិធម៌, សមធម៌ និងសេចក្តីថ្លៃថ្នូររបស់មនុស្ស ជាដើម គឺជាការឆ្លុះបញ្ចាំងពីគោលការណ៍សីលធម៌ជាសកល។ ការណ៍នេះ មានលក្ខណៈផ្ទុយគ្នាជាមួយនឹងទ្រឹស្តីច្បាប់វិជ្ជមាន (Legal Positivism) ដែលទស្សនវិទូដូចជាលោក John Austin និងលោក Hans Kelsen ផ្តោតលើសុពលភាពនៃច្បាប់ ដែលចេញដោយរដ្ឋ ហើយកំណត់និយមន័យច្បាប់ថាជាសំណុំវិធានដែលបង្កើតឡើងដោយរដ្ឋ ដោយមិនគិតពីគោលការណ៍សីលធម៌ឡើយ។

លោក Christophe Grzegorczyk បានកំណត់នូវសញ្ញាណតម្លៃច្បាប់ថា **"សំណុំនៃបទដ្ឋានដែលផ្តល់អត្ថន័យដល់ប្រព័ន្ធច្បាប់"**។ ក្នុងន័យនេះ ច្បាប់មិនត្រឹមតែជាការប្រមូលផ្តុំនៃវិធានប៉ុណ្ណោះទេ ប៉ុន្តែជាប្រព័ន្ធមួយដែលបង្ហាញ និងបន្តនូវគុណតម្លៃ ឬគោលដៅជាក់លាក់មួយចំនួន ដូចជាយុត្តិធម៌ សមភាព សេរីភាព ឬសណ្តាប់ធ្នាប់សង្គមជាដើម។ បទដ្ឋានទាំងនេះ គឺជាគុណតម្លៃនៃច្បាប់ (valeurs de droit) ដែលបង្ហាញនូវរបៀបដែលច្បាប់ត្រូវបានសរសេរតាក់តែង បកស្រាយ និងអនុវត្ត។

គុណតម្លៃច្បាប់ អាចត្រូវបានកំណត់ជា ២ ប្រភេទ ធំៗ ដូចខាងក្រោម៖

- **គុណតម្លៃជាសកល៖** គឺជាគុណតម្លៃដែលត្រូវបានកំណត់ថាមានលក្ខណៈថេរ ជាប់ខាត និងមានសមស្របសម្រាប់គ្រប់សម័យកាល និងសង្គមមនុស្សទាំងអស់ ដោយមិនគិតពីវប្បធម៌ សម័យកាល ឬប្រព័ន្ធច្បាប់ឡើយ។ ឫសគល់ទស្សនវិជ្ជា មានឫសគល់នៅក្នុងទ្រឹស្តីច្បាប់ធម្មជាតិ (Droit naturel) កំណត់នូវសច្ចភាពសីលធម៌ និងគុណតម្លៃដែលមាននៅក្នុងធម្មជាតិ និងហេតុផលរបស់មនុស្ស។ ទស្សនវិទូ ដូចជា Aristotle, Thomas Aquinas, Immanuel Kant និង Michel Villey ចាត់ទុកគុណតម្លៃជាសកលថាជាការបង្ហាញពីយុត្តិធម៌ សេចក្តីថ្លៃថ្នូរ ឬសណ្តាប់ធ្នាប់សីលធម៌សមហេតុផល (rational moral order)។
- **គុណតម្លៃតាមសម័យកាល (Valeur temporelle)៖** ជាគុណតម្លៃដែលអាស្រ័យលើបរិបទប្រវត្តិសាស្ត្រ វប្បធម៌ នយោបាយ ឬសេដ្ឋកិច្ចរបស់សង្គម

ណាមួយ។ គុណតម្លៃនេះវិវត្តទៅតាមពេលវេលា និងឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរ សង្គម គោលការណ៍រួមនៃសង្គម (Collective Conciousness) និង លក្ខខណ្ឌនយោបាយ។ ឫសគល់ទស្សនវិជ្ជា មានឫសទស្សនវិជ្ជា មានឫស គល់នៅក្នុង Legal Realism (Réalisme juridique) និង Legal Positivism (Positivisme juridique)។ ទស្សនវិទូ Hans Kelsen, Raymond Saleilles និង Jean Carbonnier បានទទួលស្គាល់ថា ច្បាប់ត្រូវតែសម្របខ្លួនទៅនឹង ការផ្លាស់ប្តូរគុណតម្លៃរបស់សង្គម។

២.២.២. ដំណាក់កាលនៃការផ្លាស់ប្តូរគុណតម្លៃ ទៅបទដ្ឋានគតិយុត្ត

នៅក្នុងទស្សនវិជ្ជាច្បាប់ ទ្រឹស្តីនៃគុណតម្លៃ បានចូលរួមចំណែកជាមូលដ្ឋាន សម្រាប់ការរៀបចំក្របខ័ណ្ឌច្បាប់ និងការកំណត់នូវព្រំដែននៃការអនុវត្តសិទ្ធិ។ យោង តាមលោក Gustav Radbruch ច្បាប់ត្រូវបានរៀបចំឡើងដោយផ្អែកលើគុណតម្លៃជា មូលដ្ឋានគ្រឹះចំនួនបី រួមមានគោលការណ៍យុត្តិធម៌ ភាពប្រាកដប្រជានៃច្បាប់ (legal certainty) និងការប្រើប្រាស់ (utility)។ ស្រដៀងគ្នានេះដែរ លោក Lon L. Fuller (១៩៦៩) បានកំណត់នូវទស្សនាទានច្បាប់ថា ច្បាប់បង្កប់នូវគុណតម្លៃផ្នែកសីលធម៌ ដូចជា គោលការណ៍យុត្តិធម៌ គោលការណ៍សង្គតិភាព និងគោលការណ៍បដិការ។ សម្រាប់ លោក Ronald Dworkin (១៩៧៧) គោលការណ៍សមភាពចំពោះមុខច្បាប់ ឬ សិទ្ធិទទួលបានសេចក្តីថ្លៃថ្នូរ គឺជាគុណតម្លៃសីលធម៌ ដែលត្រូវដាក់បញ្ចូលទៅក្នុង ក្របខ័ណ្ឌច្បាប់ ដោយការបកស្រាយច្បាប់។

នៅពេលដែលសង្គមមួយចាប់រីកចម្រើនលូតលាស់ និងកាន់តែមានភាពស្មុគ្រ ស្មាញ មនុស្សនៅក្នុងសង្គម ចាប់ផ្តើមយកគោលការណ៍សីលធម៌, ទ្រឹស្តីច្បាប់ធម្មជាតិ, ប្រពៃណីទំនៀមទម្លាប់ មករៀបចំជាវិធានសម្រាប់គ្រប់គ្រងសង្គមនោះ។ ដំណាក់កាល នៃការផ្លាស់ប្តូរគុណតម្លៃ ទៅបទដ្ឋានគតិយុត្ត មិនមានការកំណត់ជាដំណាក់កាល ច្បាស់លាស់នោះទេ និងប្រែប្រួលទៅតាមទស្សនាទានផ្សេងៗគ្នារបស់ទស្សនវិទូ។ តាម ទស្សនលោក Jean-Baptiste Jacob (សៀវភៅ La valeur en droit, ២០២១) បានកំណត់អំពីដំហាននៃការវិវត្ត ដោយចាប់ផ្តើមចេញពីសំណុំនៃគំនិត ឬទស្សនៈរបស់ ទស្សនវិទូ ហើយក្រោយមកបន្ទាប់ពីមានការទទួលស្គាល់និងទទួលយកនូវសំណុំគំនិត ឬទស្សនៈនោះ វាចាប់ផ្តើមវិវត្តទៅជាគុណតម្លៃ ដែលមនុស្សនៅសង្គមមួយផ្តល់នូវតម្លៃ។

គុណតម្លៃគ្រឹះមួយចំនួន បានឆ្លងការវិវត្តជាច្រើនសម័យកាល ចាប់តាំងពីការកកើតជាគំនិត ទ្រឹស្តីនានារបស់ទស្សនវិទូ រហូតក្លាយជាគោលការណ៍ត្រូវបានដាក់បញ្ចូលទៅក្នុងបទដ្ឋានគតិយុត្ត ដែលបានបន្តអត្ថិភាពពីសម័យបុរាណ មកដល់បច្ចុប្បន្ន រួមមាន៖ គោលការណ៍សេរីភាព, គោលការណ៍សមភាពចំពោះមុខច្បាប់, គោលការណ៍នីតិរដ្ឋ, គោលការណ៍ប្រជាធិបតេយ្យ, គោលការណ៍យុត្តិធម៌, គោលការណ៍ស្មើភាពចំពោះមុខច្បាប់, គោលការណ៍ការពារនិងគោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស, គោលការណ៍សេរីភាពបុគ្គល, គោលការណ៍នៃសិទ្ធិរស់រានមានជីវិតគោលការណ៍ប្រយោជន៍សាធារណៈ ជាដើម។

២.៣. ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

ចាប់តាំងពីឆ្នាំ១៩៩៣ មកដល់បច្ចុប្បន្ន ប្រទេសកម្ពុជា មានច្បាប់សរុបចំនួនប្រមាណ ៦៧៥ ច្បាប់។ ក្នុង ៦៧៥ ច្បាប់នេះ គឺមានច្បាប់ជាសារវន្តប្រមាណ ២៤១។ តាមការសិក្សាពីឧត្តមានុវត្តន៍បារាំង នីតិអាចបែងចែកជាសាខាធំៗចំនួន២គឺ នីតិសាធារណៈ និងនីតិឯកជន។ ដោយឡែកសម្រាប់កម្ពុជា ស្របតាមការវិវត្តន៍ដ៏លឿនរហ័សនៃពិភពលោកសម័យបច្ចេកវិទ្យា ៥.០ នីតិថ្មីមួយបានលេចរូបឡើងដែលអាចមិនស្ថិតក្នុងការបែងចែកនីតិបែបប្រពៃណីតាមលំអានបារាំង។ នីតិនោះ គឺនីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។ ក្នុងន័យនេះ សរុបជារួមសម្រាប់បរិបទកម្ពុជា សាខានៃនីតិមានចំនួន៣ធំៗគឺ ទី១). នីតិសាធារណៈ ទី២). នីតិឯកជន និងទី៣). នីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និងអាចបែងចែកជាវិស័យនៃនីតិចំនួន១៥ គឺ ១). នីតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២). នីតិរដ្ឋបាលសាធារណៈ ៣). នីតិអន្តរជាតិ ៤). នីតិអប់រំ ៥). នីតិសុខាភិបាល ៦). នីតិរបបសន្តិសុខសង្គម ៧). នីតិវប្បធម៌ ៨). នីតិបរិស្ថាន ៩). នីតិសន្តិសុខ ១០). នីតិការពារជាតិ និង១១). នីតិព្រហ្មទណ្ឌ ១២). នីតិរដ្ឋប្បវេណី ១៣). នីតិ៣ណិជ្ជកម្ម ១៤). នីតិការងារ និង ១៥). នីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។

ជាការសិក្សាបឋម គោលការណ៍គតិយុត្តសរុបដែលទាញចេញពីនីតិទាំង១៥ខាងលើ មានចំនួន ៧០ គោលការណ៍ ដូចខាងក្រោម៖

១. គោលការណ៍គ្រឹះក្នុងនីតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (៦គោលការណ៍)៖

- គោលការណ៍គ្រឹះនៃសេរីភាពសេដ្ឋកិច្ច (សេរីភាពក្នុងការប្រកបវិជ្ជាជីវៈ) ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទមានសិទ្ធិជ្រើស

រើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម (មាត្រា៣៦ វាក្យខណ្ឌ១នៃរដ្ឋធម្មនុញ្ញ)។

- គោលការណ៍នៃការអន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារ ជាគោលការណ៍ដែលយកតាមលំអានបារាំងតែក៏មាន រំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ការរៀបចំនិងការប្រព្រឹត្តទៅនៃប្រព័ន្ធសេដ្ឋ-កិច្ចមានកំណត់ក្នុងច្បាប់(មាត្រា ៥៦នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋយកចិត្តទុដាក់ជួយដោះស្រាយមធ្យោបាយផលិតការពារថ្លៃផលិតផល ជូនកសិករ សិប្បករ និងជួយរកទីផ្សារលក់ផលិតផល (មាត្រា៦២នៃរដ្ឋ-ធម្មនុញ្ញ)។ រដ្ឋយកចិត្តទុកដាក់គ្រប់គ្រងទីផ្សារ ជួយឱ្យជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានកម្រិតសមរម្យ (មាត្រា៦៣នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍នៃការការពារសណ្តាប់ធ្នាប់សេដ្ឋកិច្ច៖ រដ្ឋបង្ការការធ្វើឱ្យខូចខាតដល់សេដ្ឋកិច្ចជាទូទៅ តាមរយៈការកំណត់ពីវិធានការត្រួតពិនិត្យ បង្ការ ទប់ស្កាត់ បង្ក្រាបនិងលុបបំបាត់ការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម (មាត្រា ១ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់និងហិរញ្ញប្បទានភេរវកម្ម)។
- គោលការណ៍សមភាពនិងមិនរើសអើង៖ ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា (មាត្រា៣៦ វាក្យខណ្ឌ ២ នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍នៃការការពារប្រតិបត្តិករសេដ្ឋកិច្ច ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិច្បាប់កម្ពុជា។ មាត្រា ១ នៃច្បាប់ស្តីពីឧបាស្រ័យពាណិជ្ជកម្មមានគោលបំណង ការពារនិងដោះស្រាយផលប៉ះពាល់ជាអវិជ្ជមាន ចំពោះឧស្សាហកម្មកម្ពុជាបណ្តាលមកពីការធ្វើពាណិជ្ជកម្មនាំចូលដោយមិនស្មោះត្រង់ និងការនាំចូលដោយគំហុកដោយប្រើប្រាស់វិធានការឧបាស្រ័យពាណិជ្ជកម្ម។ មាត្រា១នៃច្បាប់ស្តីពីការប្រកួតប្រជែងកំណត់អំពីសកម្មភាពដែលរារាំង រឹតត្បិតឬបង្ខូចដល់ការប្រកួតប្រជែងក្នុងគោលបំណងលើកទឹកចិត្តឱ្យមានទំនាក់ទំនងធុរកិច្ចដោយស្មើភាពនិងស្មោះត្រង់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច ជំរុញឱ្យមានការបង្កើតធុរកិច្ចថ្មីៗ។
- គោលការណ៍គ្រឹះនៃថវិកា៖ ថវិកាត្រូវមានគោលការណ៍គ្រឹះ១០ (មាត្រា៤ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ)។

២. គោលការណ៍គ្រឹះក្នុងនីតិរដ្ឋបាលសាធារណៈ (៤គោលការណ៍)៖

- គោលការណ៍នីត្យានុកូលភាពរដ្ឋបាល ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ រដ្ឋធម្មនុញ្ញជាច្បាប់កំពូល។ ច្បាប់និងសេចក្តីសម្រេចទាំងឡាយនៃស្ថាប័នរដ្ឋនានាត្រូវស្របនឹងរដ្ឋធម្មនុញ្ញជាដាច់ខាត (មាត្រា១៥២ថ្មីនៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍ប្រតិតុល្យការអំណាច ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ អំណាចបែងចែកដាច់ពីគ្នារវាងអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិនិងអំណាចតុលាការ (មាត្រា៥១ថ្មីនៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍រដ្ឋបាលឯកភាព ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញនិងស្មារតីនៃប្បញ្ញត្តិកម្ពុជាដែរ។ ទឹកដីនៃព្រះរាជាណាចក្រកម្ពុជាចែកជា រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ (មាត្រា១៤៥ថ្មីនៃរដ្ឋធម្មនុញ្ញ)។ រដ្ឋបាលឯកភាព សំដៅដល់ការពង្រឹងអង្គឯកភាពរបស់រដ្ឋដើម្បីសម្របសម្រួលនូវសកម្មភាពរដ្ឋបាលសាធារណៈនៅក្នុងដែនដីរបស់ខ្លួន (មាត្រា៨នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។
- គោលការណ៍គណនេយ្យភាព ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញនិងស្មារតីនៃប្បញ្ញត្តិកម្ពុជាដែរ។ អំណាចទាំងអស់ជារបស់ប្រជាពលរដ្ឋ។ ប្រជាពលរដ្ឋប្រើអំណាចរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាលនិងសាលាជម្រះក្តី (មាត្រា៥១ ថ្មីនៃរដ្ឋធម្មនុញ្ញ)។ ក្រុមប្រឹក្សានៃរដ្ឋបាលថ្នាក់ក្រោមជាតិត្រូវមានគណនេយ្យភាពដោយផ្ទាល់ចំពោះប្រជាពលរដ្ឋទាំងអស់អំពីជម្រើសអាទិភាពដើម្បីធ្វើសេចក្តីសម្រេច ធានាបានការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន (មាត្រា៣៤នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។ ក្រុមប្រឹក្សាត្រូវមានគណនេយ្យភាពចំពោះរាជរដ្ឋាភិបាលអំពីការប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ ច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ និងលិខិតបទដ្ឋាននានា (មាត្រា៣៥នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ)។

៣. គោលការណ៍គ្រឹះក្នុងនីតិអន្តរជាតិ (៣គោលការណ៍)៖

- គោលការណ៍មិនជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋបរទេស ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ព្រះរាជាណាចក្រកម្ពុជាមិនឈ្លានពានប្រទេសណាដាច់ខាត មិនជ្រៀតជ្រែកកិច្ចការផ្ទៃក្នុងនៃប្រទេសដទៃដោយផ្ទាល់ឬដោយប្រយោលទោះបីក្រោមរូបភាពណាក៏ដោយ (មាត្រា៥៣ថ្មីវាក្យខណ្ឌ២នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍នៃការគោរពសិទ្ធិមនុស្ស ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញនៃអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ (មាត្រា៣១នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍ដោះស្រាយជម្លោះដោយសន្តិវិធី ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ព្រះរាជាណាចក្រកម្ពុជាដោះស្រាយរាល់បញ្ហាដោយសន្តិវិធីនិងគោរពផលប្រយោជន៍ផងគ្នាទៅវិញទៅមក (មាត្រា៥៣ថ្មីវាក្យខណ្ឌ២នៃរដ្ឋធម្មនុញ្ញ)។

៤. គោលការណ៍គ្រឹះក្នុងនីតិអប់រំ (៣គោលការណ៍)៖

- គោលការណ៍គុណភាពនៃការអប់រំ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ មាត្រា៦៥នៃរដ្ឋធម្មនុញ្ញ រដ្ឋត្រូវការពារនិងលើកស្ទួយសិទ្ធិរបស់ប្រជាពលរដ្ឋក្នុងការទទួលការអប់រំប្រកបដោយគុណភាពនៅគ្រប់កំរិត។
- គោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ មាត្រា៦៦នៃរដ្ឋធម្មនុញ្ញ រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាពនៅទូទាំងប្រទេស ដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសិក្សាធិការនិងគោលការណ៍សមភាពក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត។

- គោលការណ៍ប្រព័ន្ធអប់រំពេញលេញនិងឯកភាព៖ រដ្ឋត្រូវរៀបចំឱ្យមានប្រព័ន្ធអប់រំពេញលេញនិងឯកភាពដែលមានការអប់រំក្នុងប្រព័ន្ធ ការអប់រំក្រៅប្រព័ន្ធ និងការអប់រំមិនផ្លូវការ។ ប្រព័ន្ធអប់រំនៅកម្ពុជារួមមានការអប់រំសាធារណៈនិងការអប់រំឯកជន។ ក្រសួងទទួលបន្ទុកវិស័យអប់រំត្រូវកំណត់ខ្លឹមសារស្តីពីប្រព័ន្ធអប់រំក្នុងលិខិតបទដ្ឋានដោយឡែក។

៥. គោលការណ៍គ្រឹះក្នុងនីតិសុខាភិបាល (២គោលការណ៍)៖

- គោលការណ៍នៃការការពារសុខភាពរបស់ប្រជាជន ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ សុខភាពរបស់ប្រជារាស្ត្រត្រូវបានធានា។ រដ្ឋយកចិត្តទុកដាក់ដល់ការការពារជំងឺនិងព្យាបាលជម្ងឺ (មាត្រា៧២នៃរដ្ឋធម្មនុញ្ញ)។

- គោលការណ៍គុណភាពនៃសេវាសុខាភិបាល ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិច្បាប់កម្ពុជាដែរ។ មាត្រា១នៃច្បាប់ស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈវិស័យសុខាភិបាលមានគោលបំណងការពារសុខភាពនិងសុវត្ថិភាពរបស់ប្រជាជន តាមរយៈការផ្តល់នូវយន្តការក្នុងការធានាថាអ្នកប្រកបវិជ្ជាជីវៈសុខាភិបាលទាំងអស់មានគុណវុឌ្ឍ សមត្ថភាពនិងសម្បទាគ្រប់គ្រាន់ក្នុងការប្រកបវិជ្ជជីវៈរបស់ខ្លួន។

៦. គោលការណ៍គ្រឹះក្នុងនីតិរបបសន្តិសុខសង្គម (១គោលការណ៍)៖

- គោលការណ៍សមធម៌សង្គម ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ រដ្ឋចាត់ចែងឱ្យមានរបបសន្តិសុខសង្គមដល់កម្មករនិងនយោជិត (មាត្រា ៧៥នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋជួយឧបត្ថម្ភជនពិការនិងដល់គ្រួសារយុទ្ធជនដែលបានបូជាជីវិតដើម្បីប្រទេសជាតិ (មាត្រា៧៤នៃរដ្ឋធម្មនុញ្ញ)។ រដ្ឋយកចិត្តទុកដាក់ចំពោះកុមារនិងមាតា។ រដ្ឋរៀបចំឱ្យមានទារកដ្ឋាននិងជួយឧបត្ថម្ភនារីដែលមានកូនច្រើនក្នុងបន្ទុកហើយឥតទីពឹង (មាត្រា៧៣នៃរដ្ឋធម្មនុញ្ញ)។ ប្រជាពលរដ្ឋទាំងពីរភេទមានសិទ្ធិទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ចដែលមានចែងក្នុងច្បាប់ (មាត្រា៣៦ វាក្យខណ្ឌ៤នៃរដ្ឋធម្មនុញ្ញ)។

៧. គោលការណ៍គ្រឹះក្នុងនីតិវប្បធម៌ (១គោលការណ៍)៖

- គោលការណ៍នៃការការពារនិងថែរក្សាវប្បធម៌ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ រដ្ឋមានកាតព្វកិច្ចថែរក្សានិងពង្រីកវប្បធម៌ជាតិ។ រដ្ឋមានកាតព្វ កិច្ចការពារនិងពង្រីកភាសាខ្មែរឱ្យសមស្របនឹងសេចក្តីត្រូវការ។ រដ្ឋមានកាតព្វកិច្ចថែរក្សានិងការពារប្រាសាទបុរាណ វត្ថុសិល្បៈបុរាណនិងកែលំអរអរមណីយដ្ឋានប្រវត្តិសាស្ត្រឡើងវិញ (មាត្រា៦៩នៃរដ្ឋធម្មនុញ្ញ)។

៨. គោលការណ៍គ្រឹះក្នុងនីតិបរិស្ថាន (១១គោលការណ៍)៖

- គោលការណ៍អភិវឌ្ឍប្រកបដោយចីរភាព៖ ការអភិវឌ្ឍត្រូវប្រកបដោយសមធម៌និងដោយនិរន្តភាពទាំងមនុស្សជំនាន់បច្ចុប្បន្នទាំងអនាគត (មាត្រា៩ នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការបញ្ចៀសការខូចខាតបរិស្ថាននិងធនធានធម្មជាតិ៖ បុគ្គលមិនត្រូវធ្វើសកម្មភាពណាមួយដែលបង្កឬអាចបង្ករការខូចខាតដល់បរិស្ថាននិងធនធានធម្មជាតិឡើយ (មាត្រា១០នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការចូលរួមជាសាធារណៈ៖ បុគ្គលដែលអាចទទួលរងផលប៉ះពាល់ដោយផ្ទាល់ឬប្រយោល ដោយសារការធ្វើសេចក្តីសម្រេចណាមួយទាក់ទងនឹងបរិស្ថានឬធនធានធម្មជាតិ មានសិទ្ធិចូលរួមផ្តល់មតិយោបល់ (មាត្រា១១នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការទទួលព័ត៌មានបរិស្ថាននិងធនធានធម្មជាតិ៖ បុគ្គលមានសិទ្ធិទទួលបានព័ត៌មានទាក់ទងនឹងបរិស្ថាននិងធនធានធម្មជាតិ (មាត្រា១២នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការទទួលខុសត្រូវរបស់បុគ្គលបំពុល៖ បុគ្គលដែលបង្កឱ្យមានការខូចខាតដល់បរិស្ថានត្រូវទទួលបន្ទុកក្នុងការចំណាយលើការជួសជុលនិងលើវិធានការទប់ស្កាត់ បញ្ចៀសនិងកាត់បន្ថយការខូចខាតបរិស្ថាន (មាត្រា១៣នៃក្រមបរិស្ថាន)។

- គោលការណ៍នៃការបង់ថ្លៃរបស់អ្នកប្រើប្រាស់៖ បុគ្គលដែលប្រើប្រាស់ធនធានធម្មជាតិត្រូវបង់ថ្លៃចំណាយសម្រាប់ការប្រើប្រាស់ធនធានធម្មជាតិ (មាត្រា១៤នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការប្រុងប្រយ័ត្នជាមុន៖ ក្នុងករណីដែលមានការព្រួយបារម្ភថាមានការខូចខាតយ៉ាងធ្ងន់ធ្ងរដល់បរិស្ថានដែលមិនអាចស្តារបាន មិនអាចយកកង្វះខាតភាពប្រាកដប្រជាផ្នែកវិទ្យាសាស្ត្រមកធ្វើជាមូលហេតុក្នុងការពន្យារពេលនៃការចាត់វិធានការដើម្បីទប់ស្កាត់ការខូចខាតបានឡើយ (មាត្រា១៥នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការកាត់បន្ថយឬទប់ស្កាត់ការខូចខាតដល់បរិស្ថាន៖ វិធានការនានានៃការកាត់បន្ថយឬទប់ស្កាត់ការខូចខាតដល់បរិស្ថានត្រូវធ្វើឡើងមុនពេលការខូចខាតនោះកើតឡើង (មាត្រា១៦នៃក្រមបរិស្ថាន)។
- គោលការណ៍នៃការធ្វើសេចក្តីសម្រេចដោយផ្អែកលើភស្តុតាង៖ ព័ត៌មានដែលមានលក្ខណៈវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ត្រូវយកមកប្រើប្រាស់ជាមូលដ្ឋានក្នុងការធ្វើសេចក្តីសម្រេចចិត្ត (មាត្រា១៧នៃក្រមបរិស្ថាន)។
- គោលការណ៍ផលប្រយោជន៍សាធារណៈ៖ ផលប្រយោជន៍សាធារណៈត្រូវមានឧត្តមភាពជាងប្រយោជន៍បុគ្គលឯកជន (មាត្រា១៨នៃក្រមបរិស្ថាន)។
- គោលការណ៍នៃសមាហរណកម្មផ្នែកបរិស្ថាន៖ កិច្ចគាំពារបរិស្ថាននិងការអភិវឌ្ឍប្រកបដោយចីរភាពត្រូវដាក់បញ្ចូលក្នុងការរៀបចំផែនការអភិវឌ្ឍនិងការធ្វើសេចក្តីសម្រេចចិត្តទាំងក្នុងដំណាក់កាលដំបូងនិងដំណាក់កាលអនុវត្តគោលនយោបាយនិងច្បាប់ (មាត្រា១៩នៃក្រមបរិស្ថាន)។

៩. គោលការណ៍គ្រឹះក្នុងនីតិសន្តិសុខ (៣គោលការណ៍)

- គោលការណ៍រក្សាការពារសណ្តាប់ធ្នាប់សាធារណៈ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ រាជរដ្ឋាភិបាលកម្ពុជាត្រូវការពារនីត្យានុកូលភាព ធានាសណ្តាប់ធ្នាប់និងសន្តិសុខសាធារណៈ (មាត្រា៥២ វាក្យខណ្ឌ១នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍នីត្យានុកូលភាព ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ការ

ចោទប្រកាន់ ការចាប់ខ្លួន ការឃាត់ខ្លួនឬការឃុំខ្លួនជនណាមួយនឹងអាចធ្វើទៅកើតលុះត្រាតែអនុវត្តត្រឹមត្រូវតាមបញ្ញត្តិច្បាប់ (មាត្រា៣៨វាក្យខណ្ឌ៣នៃរដ្ឋធម្មនុញ្ញ)។

- គោលការណ៍បង្ការនិងការពារសន្តិសុខ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិច្បាប់កម្ពុជាដែរ។ ត្រូវហាមឃាត់ ការបំពាក់ ការកាន់កាប់ ការយកតាមខ្លួន ការប្រើប្រាស់ ការទិញ ការលក់ ការធ្វើពាណិជ្ជកម្ម ការឱ្យខ្ចី ការផ្ទេរ ការចែកចាយ ការជួល ការលិត ការកែច្នៃតម្លើង ការជួសជុល ការដឹកជញ្ជូន ការនាំឆ្លងកាត់ ការនាំចូល ការនាំចេញ ការស្តុកអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទចំពោះជនស៊ីវិលក្នុងព្រះរាជាណាចក្រកម្ពុជា (មាត្រា៤នៃច្បាប់ស្តីពីការគ្រប់គ្រងអាវុធ គ្រឿងផ្ទុះនិងគ្រាប់រំសេវ)។

១០. គោលការណ៍គ្រឹះក្នុងនីតិការពារជាតិ (២គោលការណ៍)៖

- គោលការណ៍អធិបតេយ្យជាតិ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ បូរណភាពទឹកដីរបស់ព្រះរាជាណាចក្រកម្ពុជាមិនអាចរំលោភបានដាច់ខាតក្នុងព្រំដែនរបស់ខ្លួនដែលមានកំណត់ក្នុងផែនទីខ្នាត ១/១០០.០០០ ធ្វើនៅចន្លោះឆ្នាំ១៩៣៣-១៩៥៣ ហើយដែលត្រូវបានទទួលស្គាល់ជាអន្តរជាតិនៅចន្លោះឆ្នាំ១៩៦៣-១៩៦៩(មាត្រា២នៃរដ្ឋធម្មនុញ្ញ)។ ប្រជាពលរដ្ឋទាំងពីរភេទត្រូវគោរពគោលការណ៍អធិបតេយ្យជាតិ (មាត្រា៥០ នៃរដ្ឋធម្មនុញ្ញ)។ រាជរដ្ឋាភិបាលកម្ពុជាប្តេជ្ញារក្សាការពារឯករាជ្យអធិបតេយ្យបូរណភាពនៃទឹកដីព្រះរាជាណាចក្រកម្ពុជា (មាត្រា៥២ វាក្យខណ្ឌ១នៃរដ្ឋធម្មនុញ្ញ)។

- គោលការណ៍សាមគីភាពក្នុងការការពារជាតិ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ប្រជាពលរដ្ឋខ្មែរគ្រប់រូបមានកាតព្វកិច្ចចូលរួមចំណែកកសាងប្រទេសជាតិ និងការពារមាតុភូមិ (មាត្រា៤៩ថ្មី វាក្យខណ្ឌ៣នៃរដ្ឋធម្មនុញ្ញ)។ កាតព្វកិច្ចការពារមាតុភូមិត្រូវអនុវត្តតាមបញ្ញត្តិច្បាប់ (មាត្រា៤៩ថ្មី វាក្យខណ្ឌ៤នៃរដ្ឋធម្មនុញ្ញ)។

១១. គោលការណ៍គ្រឹះក្នុងនីតិព្រហ្មទណ្ឌ (១៤គោលការណ៍)៖

- គោលការណ៍សមភាពចំពោះមុខច្បាប់ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ (មាត្រា៣១នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍សន្មត់ថាគ្មានទោស៖ ជនជាប់ចោទណាក៏ដោយ ត្រូវទុកជាមនុស្សឥតទោសដរាបណាតុលាការមិនទាន់កាត់ទោសជាស្ថាពរ (មាត្រា៣៨នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍នីត្យានុកូលភាព (គ្មានបទល្មើសគ្មានទោស)៖ មានតែអំពើដែលបង្កើតជាបទល្មើសនៅពេលដែលអំពើនោះមានចែងក្នុងបទប្បញ្ញត្តិព្រហ្មទណ្ឌជាធរមានប៉ុណ្ណោះ ទើបអាចត្រូវផ្តន្ទាទោសព្រហ្មទណ្ឌបាន (មាត្រា៣នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍អនុវត្តច្បាប់ព្រហ្មទណ្ឌក្នុងពេលវេលា៖ បទប្បញ្ញត្តិថ្មីដែលលុបចោលបទល្មើសណាមួយនោះ ត្រូវអនុវត្តភ្លាម (មាត្រា៩នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍ដែនដីក្នុងការអនុវត្តច្បាប់៖ ច្បាប់កម្ពុជាត្រូវអនុវត្តទៅលើបទល្មើសទាំងឡាយណាដែលបានប្រព្រឹត្តនៅលើដែនដីកម្ពុជា (មាត្រា១២នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍ឯកត្តកម្មនៃការទទួលខុសត្រូវព្រហ្មទណ្ឌ៖ បុគ្គលម្នាក់ៗទទួលខុសត្រូវព្រហ្មទណ្ឌតែចំពោះអំពើផ្ទាល់ខ្លួនប៉ុណ្ណោះ (មាត្រា២៤នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍មិនទទួលខុសត្រូវដោយសារវិបល្លាសស្មារតី៖ មិនទទួលខុសត្រូវព្រហ្មទណ្ឌ នៅពេលរកឃើញថាចាវីមានវិបល្លាសស្មារតីនៅពេលប្រព្រឹត្តបទល្មើស (មាត្រា៣១នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍ការការពារស្របច្បាប់៖ បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌ (មាត្រា៣៣នៃក្រមព្រហ្មទណ្ឌ)។

- គោលការណ៍សច្ចធារណ៍នៃការការពារស្របច្បាប់៖ ត្រូវសន្មត់ថាជាការការពារស្របច្បាប់ក្នុងករណី ១). បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សាឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ២). បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួចឬការប្លន់ដែលអនុវត្តដោយហិង្សា (មាត្រា៣៤នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍ឯកត្តកម្មនៃទោស៖ តុលាការប្រកាសទោសដោយផ្អែកលើស្ថានទម្ងន់ទោសនិងកាលៈទេសៈនៃបទល្មើសទៅលើបុគ្គលិកលក្ខណៈនៃជនជាប់ចោទ ទៅលើសភាពផ្លូវចិត្ត ទៅលើធនធាននិងបន្ទុក ទៅលើមូលហេតុ ព្រមទាំងទៅលើកិរិយាមារយាទរបស់ជនល្មើសក្រោយពេលប្រព្រឹត្តបទល្មើសចំពោះជនរងគ្រោះ (មាត្រា៩៦នៃក្រមព្រហ្មទណ្ឌ)។
- គោលការណ៍បទល្មើសមួយមិនអាចកាត់ទោស២ដង ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិច្បាប់កម្ពុជាដែរ។ ពុំមានការចោទប្រកាន់ណាមួយអាចប្រព្រឹត្តប្រឆាំងនឹងបុគ្គលណាម្នាក់ដែលត្រូវបានជំនុំជម្រះជាស្ថាពរនៅឯបរទេសចំពោះបទល្មើសដដែល(មាត្រា២៣នៃក្រមព្រហ្មទណ្ឌ) ។
- គោលការណ៍អាជ្ញាអស់ជំនុំ៖ ជនណាដែលត្រូវបានតុលាការសម្រេចឱ្យរួចខ្លួនជាស្ថាពរហើយ ជននោះមិនអាចត្រូវចោទប្រកាន់ទៀតទេចំពោះអំពើដដែលទោះបីជាក្រោមការកំណត់ឈ្មោះបទល្មើសថ្មីផ្សេងក៏ដោយ (មាត្រា ១២នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។
- គោលការណ៍អប្រតិសកម្មនៃបទល្មើស៖ គឺជាគោលការណ៍ដែលមិនអនុវត្តច្បាប់ព្រហ្មទណ្ឌទៅលើអំពើណាដែលបានប្រព្រឹត្តមុនច្បាប់ព្រហ្មទណ្ឌចូលជាធរមាន។
- គោលការណ៍ប្រតិសកម្មនៃការអនុវត្តច្បាប់ព្រហ្មទណ្ឌដែលស្រាលជាង៖ បទប្បញ្ញត្តិថ្មីដែលបានចែងអំពីទោសដែលស្រាលជាងត្រូវអនុវត្តភ្លាម (មាត្រា ១០នៃក្រមព្រហ្មទណ្ឌ) ។

១២. គោលការណ៍គ្រឹះក្នុងនីតិរដ្ឋប្បវេណី (១៣គោលការណ៍)៖

- គោលការណ៍សិទ្ធិជាម្ចាស់កម្មសិទ្ធិ ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ជនណាក៏ដោយទោះជាបុគ្គលក្តី ជាសមូហភាពក្តី មានសិទ្ធិជាម្ចាស់កម្មសិទ្ធិ។ កម្មសិទ្ធិឯកជនស្របច្បាប់ ឋិតក្រោមការគាំពារនៃច្បាប់ (មាត្រា៤៤នៃរដ្ឋធម្មនុញ្ញ)។
- គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន៖ ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី (មាត្រា៦០នៃរដ្ឋធម្មនុញ្ញ)។ មាត្រា៣នៃក្រមរដ្ឋប្បវេណីក្រមនេះគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គល។
- គោលការណ៍ជាមូលដ្ឋាន៖ គោលការណ៍នេះសំដៅលើការធានាសេចក្តីថ្លៃធ្លៃរបស់បុគ្គល ភាពស្មើគ្នារបស់បុរសនារី និងសិទ្ធិលើទ្រព្យសម្បត្តិដែលត្រូវកំណត់នៅក្នុងរដ្ឋធម្មនុញ្ញ (មាត្រា២នៃក្រមរដ្ឋប្បវេណី)។
- គោលការណ៍នៃការហាមឃាត់មិនឲ្យប្រើប្រាស់សិទ្ធិបំពាន៖ ទោះបីជាសិទ្ធិក៏ដោយ ក៏ពុំត្រូវអនុញ្ញាតឱ្យប្រើប្រាស់ដោយបំពានឡើយ (មាត្រា៤នៃក្រមរដ្ឋប្បវេណី)។
- គោលការណ៍នៃសុចរិតភាពនិងភាពស្មោះត្រង់៖ ការប្រើសិទ្ធិនិងការអនុវត្តករណីកិច្ចត្រូវធ្វើឡើងដោយសុចរិតផ្អែកតាមភាពស្មោះត្រង់ (មាត្រា៥នៃក្រមរដ្ឋប្បវេណី)។
- គោលការណ៍សមភាពនៃសមត្ថភាពទទួលសិទ្ធិ៖ រូបវន្តបុគ្គលគ្រប់រូបមានលក្ខណសម្បត្តិអាចក្លាយជាប្រធាននៃសិទ្ធិនិងកាតព្វកិច្ចបាន (មាត្រា៦នៃក្រមរដ្ឋប្បវេណី)។
- គោលការណ៍នៃការធានាសិទ្ធិពឹងពាក់តុលាការ៖ ជនគ្រប់រូបត្រូវបានធានានូវសិទ្ធិពឹងពាក់តុលាការចំពោះវិវាទរដ្ឋប្បវេណី (មាត្រា២នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- គោលការណ៍ចំពោះមុខ៖ ភាគីណាក៏មិនអាចត្រូវបានជម្រះក្តីដោយមិនបានសាកសួរ ឬកោះហៅឡើយ។ ក្នុងករណីណាក៏ដោយ តុលាការត្រូវគោរពគោលការណ៍ចំពោះមុខ (មាត្រា៣នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

- គោលការណ៍នៃការទទួលខុសត្រូវរបស់តុលាការនិងភាគី៖ តុលាការត្រូវប្រឹងប្រែងដើម្បីរ៉ាប់រងបណ្តឹងរដ្ឋប្បវេណី ឱ្យប្រព្រឹត្តទៅដោយមានភាពយុត្តិធម៌ និងឆាប់រហ័ស ឯភាគីត្រូវអនុវត្តបណ្តឹងរដ្ឋប្បវេណី ដោយសុចរិតនិងស្មោះត្រង់ (មាត្រា៤នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- គោលការណ៍ភាសា៖ នៅក្នុងតុលាការ ត្រូវប្រើភាសាខ្មែរ ក្នុងករណីភាគីមិនអាចយល់ភាសាខ្មែរ ចាំបាច់ត្រូវមានអ្នកបកប្រែភាសាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ (មាត្រា៥នៃក្រមនីតិវិធីរដ្ឋប្បវេណី) ។
- គោលការណ៍សម្រេចសេចក្តីដោយកស្តុតាង៖ តុលាការត្រូវទទួលស្គាល់អង្គហេតុដោយផ្អែកលើកស្តុតាងជាមូលដ្ឋាន (មាត្រា១២៣នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- គោលការណ៍ជំនឿទុកចិត្តដោយសេរី៖ ក្នុងការចេញសាលក្រម តុលាការត្រូវវិនិច្ឆ័យទទួលស្គាល់ឬមិនទទួលស្គាល់ថា ការអះអាងអំពីអង្គហេតុ មានឬគ្មានការពិត ដោយគិតពិចារណាយ៉ាងហ្មត់ចត់នូវលទ្ធផលនៃការពិនិត្យកស្តុតាង និងដំណើរការនិងខ្លឹមសារនៃការទាញហេតុផលដោយផ្ទាល់មាត់តាមជំនឿទុកចិត្តដោយសេរីរបស់ខ្លួន (មាត្រា១៨៤នៃក្រមនីតិវិធីរដ្ឋប្បវេណី)។
- គោលការណ៍វិនិច្ឆ័យដោយផ្ទាល់៖ មានតែចៅក្រមដែលបានធ្វើការទាញហេតុផលដោយផ្ទាល់មាត់ដែលជាមូលដ្ឋាននៃសាលក្រមនោះប៉ុណ្ណោះទោះបីអាចចេញសាលក្រមបាន (មាត្រា១៨៥នៃក្រមនីតិវិធីរដ្ឋប្បវេណី)។

១៣. គោលការណ៍ក្រឹះក្នុងនីតិពាណិជ្ជកម្ម (៧គោលការណ៍)៖

- គោលការណ៍សេរីភាពក្នុងការប្រកួតប្រជែង ជាគោលការណ៍ដែលយកតាមលំអានបារាំង តែក៏មានរំលេចក្នុងស្មារតីនៃប្បញ្ញត្តិរដ្ឋធម្មនុញ្ញកម្ពុជាដែរ។ ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី (មាត្រា៦០នៃរដ្ឋធម្មនុញ្ញ)។ មាត្រា២នៃច្បាប់ស្តីពីការប្រកួតប្រជែងមានវិសាលភាពអនុវត្តចំពោះបុគ្គលធ្វើសកម្មភាពធុរកិច្ច ឬធ្វើសកម្មភាពគាំទ្រដល់ធុរកិច្ចពាក់ព័ន្ធនឹងការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែងគួរឱ្យកត់សម្គាល់ក្នុងទីផ្សារ។
- គោលការណ៍នៃហាមឃាត់ការរារាំង រឹតត្បិត ឬបង្ខូចដល់ការប្រកួតប្រជែង៖ ត្រូវបានហាមឃាត់ការបង្កើតនិងការអនុវត្តការព្រមព្រៀងក្នុងការកំណត់ថ្លៃ

គ្រប់គ្រងថ្លៃ រក្សាថ្លៃចំពោះទំនិញឬសេវា (មាត្រា៧នៃច្បាប់ស្តីពីការប្រកួតប្រជែង)។

- គោលការណ៍នៃការហាមប្រើសកម្មភាពបំពានដោយប្រើដំហរឧត្តមភាពលើទីផ្សារ៖ ត្រូវបានហាមឃាត់ចំពោះសកម្មភាពបំពានដោយបុគ្គលមានដំហរឧត្តមភាពលើទីផ្សារ ប្រសិនបើសកម្មភាពនោះបានធ្វើដោយបុគ្គលណាមួយដែលមានដំហរឧត្តមភាពលើទីផ្សារ ហើយដែលសកម្មភាពនោះអាចបង្ខូចដល់ការប្រកួតប្រជែង ក្នុងករណី ១). ការតម្រូវឬការបញ្ចុះបញ្ចូលឱ្យអ្នកផ្គត់ផ្គង់ឬអតិថិជនមិនឱ្យធ្វើអាជីវកម្មជាមួយគូប្រកួតប្រជែង ២). ការបដិសេធមិនព្រមផ្គត់ផ្គង់ទំនិញឬសេវាឱ្យគូប្រកួតប្រជែង ៣). ការលក់ទំនិញឬសេវាក្នុងលក្ខខណ្ឌដែលអ្នកទិញត្រូវទិញទំនិញឬសេវាផ្សេងៗដោយឡែកដែលមិនទាក់ទងនឹងកម្មវត្ថុនៃកិច្ចសន្យា ៤). ការលក់ទំនិញឬសេវាទាបជាងថ្លៃដើមផលិត និង៥). ការបដិសេធមិនឱ្យប្រកួតប្រជែងណាមួយដោយប្រើប្រាស់មធ្យោបាយចាំបាច់។

- គោលការណ៍រក្សាព័ត៌មានសម្ងាត់៖ រាល់អំពើធ្វើឱ្យបែកធ្លាយនូវព័ត៌មានដែលមានចរិតលក្ខណៈជាការសម្ងាត់ត្រូវបានហាមឃាត់ (មាត្រា២២នៃច្បាប់ស្តីពីការប្រកួតប្រជែង)។

- គោលការណ៍ស្វ័យភាពក្នុងការចុះកិច្ចសន្យា៖ មាត្រា៣នៃក្រមរដ្ឋប្បវេណីចែងពីការគោរពនូវសេរីភាពនៃឆន្ទៈរបស់បុគ្គលឯកជន។ មាត្រា៣៣៦នៃក្រមរដ្ឋប្បវេណី កិច្ចសន្យាមានអានុភាពដោយសារសំណើរនិងស្វីការត្រូវគ្នា។ សំណើ ស្វីការនិងកិច្ចសន្យាអាចធ្វើឡើងតាមមធ្យោបាយអេឡិចត្រូនិកបាន (មាត្រា១២នៃច្បាប់ស្តីពីពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិក)។ ការព្រមព្រៀង សំដៅដល់គ្រប់ទម្រង់នៃកិច្ចសន្យា កិច្ចព្រមព្រៀង ការរៀបចំឬការយល់គ្នារវាងបុគ្គលនិងបុគ្គល ហើយអាចធ្វើឡើងជាលាយលក្ខណ៍អក្សរដោយផ្ទាល់មាត់ ដោយតុណ្ហីភាព (មាត្រា៣ វាក្យខណ្ឌ២នៃច្បាប់ស្តីពីការប្រកួតប្រជែង)។

- គោលការណ៍សុចរិតក្នុងធុរកិច្ច៖ បុគ្គលទាំងឡាយដែលធ្វើធុរកិច្ចមិនត្រូវពាក់ព័ន្ធនឹងអំពើមិនសុចរិតឡើយ (មាត្រា៩នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់)។

- គោលការណ៍ទទួលបានព័ត៌មានសម្រាប់អ្នកប្រើប្រាស់៖ បុគ្គលទាំងឡាយណាដែលធ្វើធុរកិច្ចត្រូវលាត ត្រដាងព័ត៌មានអប្បបរមាដល់អ្នកប្រើប្រាស់ (មាត្រា២២នៃច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់)។

១៤. គោលការណ៍គ្រឹះក្នុងនីតិការងារ។

១៥. គោលការណ៍គ្រឹះក្នុងនីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។

គោលការណ៍ខាងលើនេះ គឺជាកម្មវត្ថុនៃការសិក្សាបន្តដើម្បីជាមូលដ្ឋាននៃការបែងចែក ឬធ្វើចំណាត់ថ្នាក់នីតិសម្រាប់ប្រទេសកម្ពុជា ដើម្បីជានាគាពច្បាស់លាស់ ឬជាក់ច្បាស់នៅក្នុងការបកស្រាយច្បាប់, ជានាសង្គតិភាព និងសមានគតិភាពនៃការអនុវត្តច្បាប់ និងជានានូវវិវាទសមត្ថកិច្ចដែលអាចកើតឡើងដោយសារតែច្បាប់មិនច្បាស់លាស់។

៣. មាគ៌ាឆ្ពោះទៅកសាងអត្តសញ្ញាណនិងមូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

ដើម្បីជានាថាការរៀបចំច្បាប់ប្រព្រឹត្តទៅ ស្ថិតនៅក្រោមប្រព័ន្ធមួយដែលមានអត្តសញ្ញាណនិងឯកសណ្ឋាន ត្រូវមានឧបករណ៍ការងារយ៉ាងតិចចំនួន ៣ គឺទី១. នីតិនិពន្ធវិទ្យា ទី២.នីតិក្រមវិទ្យា និងទី៣.ព័ត៌មានវិទ្យានីតិកម្ម។

៣.១. នីតិនិពន្ធវិទ្យា

៣.១.១. សញ្ញាណនិងការវិវត្តន៍នៃនីតិនិពន្ធវិទ្យា

នីតិនិពន្ធវិទ្យា គឺជាសិល្បៈសាស្ត្រនៃការតាក់តែងបទដ្ឋានគតិយុត្តឱ្យមានគុណភាព។ នីតិនិពន្ធវិទ្យា ក៏ត្រូវបានផ្តល់និយមន័យថាជា វិទ្យាសាស្ត្រអនុវត្ត ដែលមានគោលដៅសិក្សា កំណត់នូវឧត្តមានុវត្តន៍ និងផ្តល់អនុសាសន៍អនុវត្តសម្រាប់ការត្រៀមរៀបចំ (Conception), ការតាក់តែង, ការអនុម័ត និងការអនុវត្តបទប្បញ្ញត្តិគតិយុត្ត។

សញ្ញាណនៃនីតិនិពន្ធវិទ្យា (Légistique / Legal Drafting) បានលេចឡើងនៅអំឡុងទសវត្សរ៍ ឆ្នាំ១៩៥០ នៅបណ្តាប្រទេសលោកខាងលិចដែលមានគោលបំណងកែទម្រង់ និងលើកកម្ពស់គុណភាពបទបដ្ឋានគតិយុត្ត ដូចជាស្វីស បែលហ្សិច បារាំង អាមេរិក និងអង់គ្លេសជាដើម។ នីតិនិពន្ធវិទ្យា ចាប់ផ្តើមពី ការសិក្សាស្រាវជ្រាវក្នុងមជ្ឈដ្ឋានសិក្សាធិការពិសេសសកលវិទ្យាល័យហ្សឺណែវប្រទេសស្វីស និងសកលវិទ្យាល័យកាតូលិកបែលហ្សិក មុននឹងត្រូវយកមកបណ្តុះបណ្តាលជាមុខវិជ្ជាក្នុងសកលវិទ្យាល័យ

និងពិសេសត្រូវបានយកមកអនុវត្តជាផ្លូវការក្នុងក្របខ័ណ្ឌនៃរដ្ឋបាលសាធារណៈ ក្នុងអំឡុងទសវត្សរ៍ឆ្នាំ១៩៨០។ នៅប្រទេសបារាំង នីតិនិពន្ធវិទ្យាត្រូវបានយកមកប្រើប្រាស់ជាផ្លូវការក្នុងក្របខ័ណ្ឌនៃសារាចរ ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ១៩៨៥ ពាក់ព័ន្ធវិធាននៃការរៀបចំ ការចុះហត្ថលេខា និងការបោះផ្សាយក្នុងរដ្ឋកិច្ច ហើយដែលត្រូវបានកែសម្រួលនិងបំពេញបន្ថែមដោយសារចរពាក់ព័ន្ធផ្សេងទៀត រហូតឈានដល់ការរៀបចំមគ្គទេសក៍នីតិនិពន្ធវិទ្យា (Guide de légistique) ដោយក្រុមប្រឹក្សារដ្ឋនិងអគ្គលេខាធិការដ្ឋានរដ្ឋាភិបាល ដែលបោះពុម្ពលើកទី១ នាឆ្នាំ២០០៦ និងបច្ចុប្បន្នកម្មលើកទី៣ នាឆ្នាំ២០១៧។

ការស្រាវជ្រាវបឋមសង្កេតឃើញថា ទស្សនាទាននៃនីតិនិពន្ធវិទ្យាមានចំនួនពីរជាសារវន្ត។ ទស្សនាទានទីមួយ មានដើមកំណើតក្នុងបណ្តាប្រទេសអង់ក្លូសាក់សុង រួមមានអង់គ្លេស អាមេរិក និងនូវែលហ្សេឡង់ជាដើម នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ដំណាលគ្នានឹងនិន្នាការ "ការគ្រប់គ្រងរដ្ឋបាលសាធារណៈបែបថ្មី" (New Public Management) និងស្របពេលដែលពិភពលោកបានជួបនូវវិបត្តិជាបន្តបន្ទាប់ រួមមានវិបត្តិប្រេងនាឆ្នាំ១៩៧៣ ដោយសារសង្គ្រាមអ៊ីស្រាអែលនិងអារ៉ាប់) និងនាឆ្នាំ១៩៧៩ ដោយបដិវត្តន៍អ៊ីរ៉ង់ ព្រមទាំងវិបត្តិបំណុលសកលឆ្នាំ១៩៨២។ ទស្សនាទានទីមួយនេះ ផ្តោតលើ "កាត់បន្ថយបទប្បញ្ញត្តិគតិយុត្ត" (Deregulation) នឹងផ្តោតជាចម្បងលើទ្រឹស្តីសេដ្ឋកិច្ចទីផ្សារសេរីនិងគោលការណ៍ប្រសិទ្ធភាពសេដ្ឋកិច្ច ដែលជាកម្មវត្ថុនៃការកែទម្រង់ឆ្លើយតបនឹងវិបត្តិខាងលើ។ ដោយឡែក ទស្សនាទានទីពីរ ដែលមានដើមកំណើតដំណាលគ្នា នៅអឺរ៉ុបដែនគោក រួមមានបារាំង បែលហ្សិច និងស្វីស ផ្តោតលើ "ការកែលម្អការរៀបចំបទប្បញ្ញត្តិ" ដោយផ្តោតជាចម្បងលើការកែលម្អគុណភាពច្បាប់និងលិខិតបទដ្ឋានគតិយុត្ត។ តាមការសង្កេតនិងសន្និដ្ឋានជាក់ស្តែង ហាក់មានការព្យាយាមបង្វិតជិតគ្នារវាងទស្សនាទានទាំងពីរ ក្នុងពេលបច្ចុប្បន្នខាងលើ។ ជាក់ស្តែង មគ្គទេសក៍នីតិនិពន្ធវិទ្យាបារាំង ឆ្នាំ២០១៧ ក៏មានបញ្ចូលនូវឧបករណ៍ ឬវិធីសាស្ត្រមួយចំនួន ដែលផ្តោតលើអភិក្រមសេដ្ឋកិច្ច ហើយដែលមានដើមកំណើតពីនីតិនិពន្ធវិទ្យាអង់ក្លូសាក់សុង ដូចជាការវាយតម្លៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្ត (Regulatory Impact Assessement, RIA), ការផ្តល់អាទិភាពលើវិធានការមិនមែនគតិយុត្ត, ការអនុវត្តបទប្បញ្ញត្តិសាកល្បង (Regulatory Sandbox) និងការវាយតម្លៃប្រសិទ្ធភាពបទដ្ឋានគតិយុត្តជាដើម។ ទោះជាយ៉ាងនេះក្តី ក៏នៅមានគម្លាតច្រើនរវាងទស្សនាទាននីតិនិពន្ធវិទ្យាទាងពីរ ដែលបង្ហាញពីភាពខុសគ្នានៃផ្នត់គំនិតបណ្តាប្រទេស អង់ក្លូសាក់សុង ដែលផ្តល់អាទិភាពលើសេរីភាពទីផ្សារនិង កាត់បន្ថយបទប្បញ្ញត្តិគតិយុត្ត និងអឺរ៉ុបដែនគោក ដែល ផ្តោតលើ "គុណភាពបទប្បញ្ញត្តិ" ជាងការកាត់បន្ថយ

ចំនួនលិខិតបទដ្ឋាន។ ជាក់ស្តែងបច្ចុប្បន្ន អឺរ៉ុប មានច្បាប់គ្រប់គ្រងគ្រប់វិស័យ រួមទាំងទីផ្សារឌីជីថល (Digital Markets Act) និងបញ្ញាសិប្បនិម្មិត (EU AI Act) ជាដើម។ ទន្ទឹមនេះ តាមការពិនិត្យលើមគ្គទេសក៍នីតិនិពន្ធវិទ្យាបារាំង ឆ្នាំ២០១៧ ជាឧទាហរណ៍ជាក់ស្តែងសង្កេតឃើញ ឧបករណ៍ ឬវិធីសាស្ត្រមួយចំនួនធំពាក់ព័ន្ធការកាត់បន្ថយបទប្បញ្ញត្តិ ដែលប្រើប្រាស់ដោយបណ្តាប្រទេសអង់ក្លូសាក់សុង ហាក់ពុំត្រូវបានកំណត់ក្នុងមគ្គទេសក៍នីតិនិពន្ធវិទ្យាបារាំងឡើយ ក្នុងនោះមានជាអាទិ៍ ការតម្រូវឱ្យនិរាករបទប្បញ្ញត្តិដោយស្វ័យប្រវត្តិក្នុងរយៈមធ្យម (Sunset Clauses), បទដ្ឋានថ្មីចូល បទដ្ឋានចាស់ចេញ (One-In, One-Out Rules), ការកំណត់ពិដានចំណាយលើបទប្បញ្ញត្តិ (Regulatory Budgeting) ជាដើម។

៣.១.២. និយមន័យនិងប្រភេទនៃនីតិនិពន្ធវិទ្យា

ក្នុងមជ្ឈដ្ឋានសិក្សាធិការ នីតិនិពន្ធវិទ្យាត្រូវបានបែងចែកជាពីរប្រភេទគឺ នីតិនិពន្ធវិទ្យាទម្រង់ (Légistique formelle) និង នីតិនិពន្ធវិទ្យាសារធាតុ (Légistique matérielle)។

ផ្អែកតាមវចនានុក្រមច្បាប់នៃរដ្ឋាភិបាលកាណាដា "នីតិនិពន្ធវិទ្យាទម្រង់ ផ្តោតជាចម្បងលើវិធាននៃការតាក់តែងបទប្បញ្ញត្តិគតិយុត្ត, រចនាសម្ព័ន្ធ, រំហូរគំនិត និងទម្រង់នៃអត្ថបទគតិយុត្ត។ និតិនិពន្ធវិទ្យាទម្រង់សិក្សាអំពីវិធានទម្រង់ដែលកំណត់ការប្រើប្រាស់ភាសាគតិយុត្ត និងសោភ័ណភាពនៃខ្លឹមសារ, សមាសធាតុ និងរចនាបទគតិយុត្ត (Style législatif)។ រចនាបទនិងភាសាគតិយុត្ត គឺជាចំណុចអាទិភាពគន្លឹះនៃនីតិនិពន្ធវិទ្យាទម្រង់។ ជារួម នីតិនិពន្ធវិទ្យាទម្រង់ផ្តោតលើគោលការណ៍និងវិធីសាស្ត្រនៃបច្ចេកទេសតាក់តែង"។ ដោយឡែក ក្រុមប្រឹក្សាអឺរ៉ុប (Conseil de l'Europe) កំណត់ថានីតិនិពន្ធវិទ្យាទម្រង់ "ផ្តោតលើប្រព័ន្ធទំនាក់ទំនង (System de communication)។ វិទ្យានេះ កំណត់នូវគោលការណ៍ ដើម្បីលើកកម្ពស់ការស្វែងដឹង និងការស្វែងយល់អត្ថបទគតិយុត្ត"។ គោលការណ៍ជាសារវន្តនៃនីតិនិពន្ធវិទ្យាទម្រង់ គឺគោលការណ៍បញ្ញានុភាព (Intelligibilité) និងគោលការណ៍ពិនិត្យានុភាព (Accessibilité) ពោលគឺការតាក់តែងអត្ថបទគតិយុត្ត គប្បីច្បាស់លាស់ (ងាយយល់និងមិនស្រពេចស្រពិល), សាមញ្ញ (ខ្លី និងមានតែខ្លឹមសារគតិយុត្តភាព) និងជាក់លាក់ (ពុំធ្វើឱ្យអ្នកអានបកស្រាយច្រើនយ៉ាង)។ នីតិនិពន្ធវិទ្យាទម្រង់ត្រូវបានរៀបចំនៅតាមបណ្តាប្រទេសអឺរ៉ុបដែនគោកជាច្រើន ដោយបញ្ចូលផងដែរនូវឧត្តមានុវត្តន៍ និងឧទាហរណ៍ជាក់លាក់សម្រាប់សម្រួលដល់ការតាក់តែងអត្ថបទគតិយុត្ត ទៅតាមយថាប្រភេទនីមួយៗ ដូចជាមគ្គទេសក៍នីតិនិពន្ធវិទ្យាឆ្នាំ២០១៧ របស់បារាំងជាដើម។

ដោយឡែកសម្រាប់នីតិនិពន្ធវិទ្យាសារធាតុវិញ ត្រូវបានផ្តល់និយមន័យថា "វិធីសាស្ត្រអនុវត្តចំពោះការកសាងនិងការអនុវត្តបទដ្ឋានគតិយុត្ត ដើម្បីឱ្យបទដ្ឋានគតិយុត្តទាំងនោះកាន់តែមានប្រសិទ្ធភាព និងកាន់តែមានសង្គតិភាព"។ ផ្អែកតាមវចនានុក្រមច្បាប់នៃរដ្ឋាភិបាលកាណាដា "នីតិនិពន្ធវិទ្យាសារធាតុផ្តោតលើនីតិវិធី វិធីសាស្ត្រគតិយុត្ត ទ្រឹស្តីនៃនីតិកម្ម សង្គមវិទ្យានីតិសាស្ត្រ ពោលគឺវិទ្យាសាស្ត្រគតិយុត្ត (Science législative)។ វិទ្យានេះមានគោលដៅសិក្សាបញ្ហាផ្សេងៗ ពាក់ព័ន្ធវិធាននិងគុណតម្លៃនានាដែលបង្កើតឡើងដោយបទដ្ឋានគតិយុត្ត, ទស្សនវិជ្ជាច្បាប់ក្នុងទិដ្ឋភាពនីតិវិជ្ជមាន, ការគោរពសមត្ថកិច្ច, សុខដុមភាពជាមួយនឹងក្របខ័ណ្ឌច្បាប់ជាធរមាន, អតិផរណាបទដ្ឋានគតិយុត្ត, មូលដ្ឋានឬមូលហេតុនៃការរៀបចំបទដ្ឋានគតិយុត្ត, ការកែលម្អបទប្បញ្ញត្តិនិងនីតិក្រម, ការបកស្រាយ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់។" សម្រាប់ក្រុមប្រឹក្សាអឺរ៉ុប "នីតិនិពន្ធវិទ្យាសារធាតុ ផ្តោតលើវដ្តនៃច្បាប់។ វិទ្យានេះ វិភាគនិងកំណត់វដ្តនៃច្បាប់ជាដំណាក់កាល រួចផ្តល់អនុសាសន៍ជាវិធីសាស្ត្រដើម្បីបង្កើនប្រសិទ្ធភាពបទប្បញ្ញត្តិគតិយុត្តទៅតាមដំណាក់កាលនីមួយៗ។ ផ្អែកតាមលោកស្រី Karine Gilberg, ប្រធានការិយាល័យច្បាប់អន្តរជាតិនៃក្រសួងសេដ្ឋកិច្ចបារាំង, នីតិនិពន្ធសារធាតុ ឈានមួយជំហានបន្ថែមទៀត ពោលគឺ ការគិតគូរឱ្យបានគ្រប់ជ្រុងជ្រោយអំពីខ្លឹមសារច្បាប់ ដើម្បីធានាថាបទដ្ឋានគតិយុត្តឆ្លើយតបនឹងបរិបទជាក់ស្តែង។ ផ្អែកតាមវិធីសាស្ត្រនេះ នីតិនិពន្ធវិទូ ប្រមូលនូវទិន្នន័យពាក់ព័ន្ធបរិបទ កំណត់បញ្ហាប្រឈម និងដំណោះស្រាយដែលបទប្បញ្ញត្តិគតិយុត្តត្រូវផ្តល់ ព្រមទាំងវិភាគនូវកម្មវិបាកទាំងឡាយដែលអាចកើតមានឡើងដោយវិធានគតិយុត្តថ្មី ជាដើម។ ក្នុងក្របខ័ណ្ឌនេះ នីតិនិពន្ធសារធាតុ ផ្តល់នូវឧបករណ៍មួយចំនួនដូចជា ការសិក្សាវាយតម្លៃផលប៉ះពាល់នៃបទដ្ឋានគតិយុត្ត (Étude d'impact) ដែលត្រូវអនុវត្តមុនការរៀបចំបទដ្ឋានគតិយុត្ត និងមានគោលដៅកំណត់នូវជម្រើសដែលត្រូវធ្វើព្រមទាំងថ្លឹងថ្លែងទាំងកម្មវិបាកវិជ្ជមាននិងអវិជ្ជមាន។ ទន្ទឹមនេះ ក្នុងដំណាក់កាលអនុវត្ត នីតិនិពន្ធសារធាតុក៏ផ្តល់នូវឧបករណ៍មួយផ្សេងទៀតគឺការអនុវត្តសាកល្បងនូវបទដ្ឋានគតិយុត្ត (Expérimentation législative / Regulatory sandbox) ក្នុងវិសាលភាពមានកម្រិត ដើម្បីងាយគ្រប់គ្រងនិងសិក្សាដកពិសោធន៍ មុននឹងអនុវត្តពេញលេញ។ ក្នុងន័យនេះ លោកសាស្ត្រាចារ្យបារាំង Boris Barraud បានបញ្ជាក់ថាការកំណត់វិធីសាស្ត្រ ឬឧបករណ៍ ឬរបៀបដើម្បីកំណត់ខ្លឹមសារគតិយុត្តនេះហើយ ដែលធ្វើឱ្យនីតិនិពន្ធវិទ្យាខុសប្លែកពី គោលនយោបាយនីតិកម្ម (Politique juridique) ដែលមានកម្មវត្ថុតម្រង់ទិសការកែទម្រង់បទដ្ឋានគតិយុត្ត ឬកំណត់ខ្លឹមសារគន្លឹះនៃបទដ្ឋានគតិយុត្តណាមួយ។

៣.១.៣. ទស្សនាទានៃការកសាងបទដ្ឋានគតិយុត្ត (ការគ្រោងការរៀបចំ)

បទដ្ឋានគតិយុត្ត ត្រូវបង្កើតឡើងក្នុងករណីចាំបាច់និងសំខាន់បំផុត ដោយត្រូវធានាគតិយុត្តភាពរឹងមាំ (Juridiquement solide) និងការតាក់តែងប្រកបដោយភាពច្បាស់លាស់ (Clairement écrite)។

បទដ្ឋានគតិយុត្ត ត្រូវគ្រោងរៀបចំដោយផ្អែកតាមការចាំបាច់ ចំនួន ៣ យ៉ាងគឺ ទី១. ការកំណត់ដោយក្របខ័ណ្ឌគតិយុត្តជាធរមាន, ទី២. ទិសដៅនៃការកែទម្រង់ និងគោលនយោបាយ និងទី៣. ការវិវឌ្ឍសង្គមសេដ្ឋកិច្ច និងតម្រូវការចាំបាច់របស់រដ្ឋាភិបាល។

មូលដ្ឋានទី១. ការកំណត់ដោយក្របខ័ណ្ឌគតិយុត្តជាធរមាន៖ បទដ្ឋានគតិយុត្តនីមួយៗ ត្រូវបង្កើតឡើង ដោយអនុលោមតាមការចង្អុលបង្ហាញជាក់លាក់ ឬដោយពុំជាក់លាក់ ដោយបទដ្ឋានគតិយុត្តដែលមានឋានានុក្រមស្មើ ឬខ្ពស់ជាងខ្លួន។ ជាទូទៅច្បាប់ ឬបទដ្ឋានគតិយុត្តដែលមានឋានានុក្រមខ្ពស់តែងមានតម្រូវឱ្យរៀបចំលិខិតបទដ្ឋានគតិយុត្ត ដើម្បីអនុវត្ត។

មូលដ្ឋានទី២. ទិសដៅនៃការកែទម្រង់ និងគោលនយោបាយ៖ ក្របខ័ណ្ឌកែទម្រង់និងគោលនយោបាយ គឺជាផែនទីបង្ហាញផ្លូវសម្រាប់ដោះស្រាយនូវបញ្ហាប្រឈមនិងស្វែងរកនូវកាលានុវត្តភាពអភិវឌ្ឍសង្គម សេដ្ឋកិច្ច។ ក្នុងស្មារតីនេះ ក្របខ័ណ្ឌកែទម្រង់និងគោលនយោបាយ ពុំមានតម្លៃគតិយុត្តចាប់បង្ខំឱ្យអនុវត្តឡើយ។ ដោយឡែក ប្រសិទ្ធភាពនៃការអនុវត្តក្របខ័ណ្ឌកែទម្រង់និងគោលនយោបាយ ត្រូវធានាដោយតម្លៃចាប់បង្ខំនៃលិខិតបទដ្ឋានគតិយុត្ត ដែលត្រូវរៀបចំជាបទដ្ឋានគតិយុត្តថ្មី ឬវិសោធនកម្មបទដ្ឋានគតិយុត្តជាធរមាន។

មូលដ្ឋានទី៣. ការវិវឌ្ឍសង្គមសេដ្ឋកិច្ច និងតម្រូវការចាំបាច់របស់រដ្ឋាភិបាល៖ បទដ្ឋានគតិយុត្ត អាចត្រូវរៀបចំថ្មី បទដ្ឋានគតិយុត្តជាធរមាន ដើម្បីដោះស្រាយបញ្ហាដែលកើតឡើងនិងមិនមានកំណត់ក្នុងច្បាប់ និងក្របខ័ណ្ឌគោលនយោបាយ ជាធរមាន។ ក្នុងន័យនេះ រាជរដ្ឋាភិបាល ក៏ដូចជាក្រសួង ស្ថាប័នពាក់ព័ន្ធ អាចបង្កើតបទដ្ឋានគតិយុត្តថ្មីៗ ដើម្បីដោះស្រាយបញ្ហាចាំបាច់នានា តាមការសម្រេចរបស់ប្រមុខរាជរដ្ឋាភិបាល ឬប្រធានស្ថាប័ន និងមានកាតព្វកិច្ចកែសម្រួល ឬរៀបចំលិខិតបទដ្ឋានគតិយុត្តថ្មី ឱ្យឆ្លើយ

តបការវិវឌ្ឍរបស់សង្គមសេដ្ឋកិច្ច។ ការបង្កើតបទដ្ឋានថ្មីនេះ ត្រូវគោរពយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍សមាមាត្រ (Principe de proportionnalité)។

ការកសាង ឬការគ្រោងរៀបចំបទដ្ឋានគតិយុត្ត អាចជ្រើសរើសមូលដ្ឋានណាមួយនៃជម្រើសមូលដ្ឋានទាំង ៣ ខាងលើ ដោយត្រូវមានក្របខ័ណ្ឌសិក្សាវាយតម្លៃច្បាស់លាស់ (Susceptible étude préalable ou question préalable) គឺក្របខ័ណ្ឌនៃការសិក្សាផលប៉ះពាល់បទដ្ឋានគតិយុត្ត (Étude impact)។ លទ្ធផលចុងក្រោយនៃការសិក្សានេះ បទដ្ឋានគតិយុត្តអាចត្រូវបានរៀបចំក្រោមទម្រង់ជាច្បាប់ ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេចរាជរដ្ឋាភិបាល បទបញ្ជារាជរដ្ឋាភិបាល សារាចររាជរដ្ឋាភិបាល ប្រកាសអន្តរក្រសួង ប្រកាស សេចក្តីសម្រេចអន្តរក្រសួង សេចក្តីសម្រេចក្រសួង សារាចរអន្តរក្រសួង សារាចរក្រសួង និងសេចក្តីណែនាំក្រសួង ដោយត្រូវគោរពជាច់ខាតនូវគោលការណ៍នីត្យានុកូលភាព ឬគោលការណ៍ឋានានុក្រមគតិយុត្ត (Principe de légalité ou hiérarchie des normes)។

៣.១.៤. គោលការណ៍គ្រឹះនៃនីតិនិពន្ធវិទ្យា

នីតិនិពន្ធវិទ្យាបង្កប់នូវគោលការណ៍គ្រឹះ ដូចតទៅ៖

- **គោលការណ៍កាលានុវត្តភាព និងភាពចាំបាច់៖** ជាគោលការណ៍ ដែលតម្រូវឱ្យការរៀបចំច្បាប់ថ្មី គប្បីធ្វើឡើងតែក្នុងករណីដែលមានតម្រូវការចាំបាច់បំផុត និងមានតម្លៃបន្ថែមពិតប្រាកដ ពោលគឺមុននឹងបង្កើតច្បាប់ថ្មី ត្រូវឆានាថាច្បាប់នោះ មានមូលដ្ឋាននៃការរៀបចំជាក់លាក់ ដែលអាចជាគោលនយោបាយ ច្បាប់ ឬកាលានុវត្តន៍ភាពផ្សេងទៀត ហើយពុំមានមធ្យោបាយផ្សេងពីក្របខ័ណ្ឌច្បាប់ដែលអាចជំនួសបាន (ពន្យល់និងផ្សព្វផ្សាយ, ពង្រឹងសមត្ថភាពនិងកិច្ចសម្របសម្រួលស្ថាប័ន...)។ ជាឧត្តមានុវត្តន៍នៅបារាំង វិស័យជាសមត្ថកិច្ចនៃច្បាប់ ត្រូវបានបែងចែកចេញពីវិស័យជាសមត្ថកិច្ចនៃលិខិតបទដ្ឋានគតិយុត្តចេញដោយអង្គនីតិប្បញ្ញត្តិ។
- **គោលការណ៍នីត្យានុកូលភាព និងឋានានុក្រមគតិយុត្តោ៖** លិខិតបទដ្ឋានគតិយុត្តទាំងឡាយត្រូវតាក់តែងឡើង ដោយគោរពឋានានុក្រមនៃបទដ្ឋានគតិយុត្ត ពោលគឺបទប្បញ្ញត្តិគតិយុត្តនីមួយៗ ត្រូវអនុលោម ឬស្របតាមក្របខ័ណ្ឌគតិយុត្តដែលមានឋានានុក្រមខ្ពស់ជាង។

- **គោលការណ៍ឧត្តមភាពនៃនីតិវិសេស លើនីតិទូទៅ៖** នីតិវិសេស មានឧត្តមានុភាពលើនីតិទូទៅ សម្រាប់វិស័យ ឬស្ថានភាពជាក់លាក់ដែលកំណត់ដោយនីតិវិសេស។ គោលការណ៍នេះ ធានាសង្គតិភាពនៃវិធានគតិយុត្ត ដោយធានាថា នីតិទូទៅមិនអនុវត្តចំពោះវិស័យ ឬស្ថានភាពជាក់លាក់ដែលជាវិសាលភាពរបស់នីតិវិសេសឡើយ។ គោលការណ៍នេះ ផ្តល់ភាពបត់បែននៃច្បាប់ដោយអនុញ្ញាតឱ្យរៀបចំនូវនីតិវិសេស សម្រាប់តម្រូវ និងសម្របទៅនឹងវិស័យ ឬករណី ដែលមានលក្ខណៈជាក់លាក់ឬបច្ចេកទេស ជាងវិធានគតិយុត្តដែលអនុវត្តទូទៅ។

- **គោលការណ៍សមានគតិភាព/សង្គតិភាព** (Principe de pertinence / cohérence)**៖** លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ត្រូវតាក់តែងឡើង ដោយមានខ្លឹមសារប្រទាក់ក្រឡាគ្នា មិនប្រទាំងប្រទើសគ្នា ឬផ្ទុយគ្នា ឬស្ងួនគ្នា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងនៃលិខិតបទដ្ឋានគតិយុត្តដែលត្រូវតាក់តែង ទាំងជាមួយលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ក្នុងករណីផ្ទុយគ្នានៃបទប្បញ្ញត្តិគតិយុត្ត ត្រូវមានការបញ្ជាក់អំពីបទប្បញ្ញត្តិដែលត្រូវនិរាករ។ ទន្ទឹមនេះ អ្នកតាក់តែងច្បាប់ ត្រូវធ្វើការបន្សុី (Reconcile) ច្បាប់ ឬបច្ចេកសព្ទគតិយុត្តដែលមានប្រភពពីបរទេស ឱ្យមានចរិតលក្ខណៈជារបស់ខ្មែរ និងទស្សនវិជ្ជាច្បាប់បែបខ្មែរ។

- **គោលការណ៍បញ្ញានុភាព** (Principe d'intelligibilité)**៖** លិខិតបទដ្ឋានគតិយុត្ត ត្រូវតាក់តែងឡើង ដើម្បីឱ្យប្រជាពលរដ្ឋទូទៅ និងអ្នកអនុវត្តច្បាប់អាចយល់បាន និងបកស្រាយដូចគ្នា ពោលគឺអត្ថបទច្បាប់ ត្រូវតាក់តែងដោយមានលក្ខណៈសាមញ្ញ ច្បាស់លាស់ មិនស្រពេចស្រពិល។

- **គោលការណ៍សមាមាត្រ** (Principe de Proportionnalité)**៖** លិខិតបទដ្ឋានគតិយុត្ត ត្រូវបង្កើតឡើងតែក្នុងស្ថានភាពចាំបាច់និងសារៈសំខាន់បំផុត ដើម្បីសម្រេចគោលដៅដែលគ្រោងទុក និងពុំត្រូវដាក់កំហិតហួសហេតុដល់ការអនុវត្តសិទ្ធិនិងកាតព្វកិច្ច ឬបង្កើតគុណវិបត្តិច្រើនដល់ពលរដ្ឋនិងធុរជនជាងបញ្ហាដែលត្រូវដោះស្រាយឡើយ។

- **គោលការណ៍គតិយុត្តភាព** (Principe de normativité)**៖** បទដ្ឋានគតិយុត្តកំណត់នូវវិធានដែលបង្កើតអានុភាពគតិយុត្ត និងអាចអនុវត្តបាន ដោយ

បង្កើតសិទ្ធិ ឬកាតព្វកិច្ច ដែលមានលក្ខណៈចាប់បង្ខំ បញ្ជា ហាមឃាត់ អនុញ្ញាត ឬដាក់ទណ្ឌកម្ម ដោយពុំកំណត់នូវខ្លឹមសារជាគោលនយោបាយ ការប្តេជ្ញា ការប្រកាសជានិមិត្តរូប។

- **គោលការណ៍សុវត្ថិភាពគតិយុត្ត** (Principe de sécurité juridique)៖ បទដ្ឋានគតិយុត្ត ត្រូវតាក់តែងឡើងប្រកបដោយស្ថេរភាព អាចប្រមើលទុកបាន និងគោរពគោលការណ៍បញ្ញានុភាព ពោលគឺច្បាប់គប្បីមានស្ថិរភាព ចៀសវាងការផ្លាស់ប្តូរដោយគំហុក និងជាគោលការណ៍ពុំអនុវត្តដោយប្រតិសកម្ម។

- **គោលការណ៍សុវត្ថិភាពគតិយុត្ត** (Principe de sécurité juridique)៖ បទដ្ឋានគតិយុត្ត ដែលត្រូវបានអនុម័តនិងប្រកាសដាក់ឱ្យអនុវត្ត ត្រូវតែផ្សព្វផ្សាយ អាចស្វែងរក និងស្វែងយល់បានដោយសាធារណៈជន។

៣.២. នីតិក្រមវិទ្យា

នីតិក្រមវិទ្យា សំដៅដល់វិទ្យាសាស្ត្រអនុវត្ត ដែលសិក្សានិងកំណត់គោលការណ៍និងវិធីសាស្ត្រគតិយុត្ត ក្នុងការប្រមូលផ្តុំ និងចងក្រងនូវលិខិតបទដ្ឋានគតិយុត្ត ផ្អែកតាមចំណាត់ថ្នាក់អត្ថបទ ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិជ្ជាគតិយុត្ត ដើម្បីសម្រេចបានជាកម្រងឯកសារមួយ ដែលមានមាតិការនុក្រមរួមតែមួយ។

នីតិក្រមវិទ្យា អាចរៀបចំចេញជាឯកសារ ជា ៣ ទម្រង់ ពីកម្រិតស្រាល ដល់កម្រិតគ្រប់ជ្រុងជ្រោយ ដូចខាងក្រោម៖

- ការចងក្រង (Compilation)៖ ជាការប្រមូលផ្តុំអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តដាក់តាមលំដាប់លំដោយ ដោយរៀបចំតាមកម្មវត្ថុគតិយុត្ត និង/ឬកាលប្បវត្តិ និងផ្ទៀងផ្ទាត់ធរមានប្បញ្ញត្តិ ដោយធានាឱ្យបាននូវគោលការណ៍ បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកានុក្រម។

- សង្គមូហភាព (Consolidation)៖ ជាការប្រមូលចងក្រង និងប្រមូលផ្តុំបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយបង្ហាញនិង/ឬបញ្ចូលនូវបទដ្ឋានគតិយុត្តដែលវិសោធនកម្ម និងបទដ្ឋានគតិយុត្តនិរាករណ៍ដោយពុំកែប្រែនូវខ្លឹមសារឡើយនិងធានាឱ្យបាននូវគោលការណ៍ពិនិត្យានុភាព

(Accessibilité) ពោលគឺ ដើម្បីសម្រួលដល់ការស្វែងរកនិងស្វែងយល់លិខិតបទដ្ឋានគតិយុត្ត។

- ក្រមនីយកម្ម (Codification)៖ គឺជាការប្រមូល និងចងក្រងនូវបទប្បញ្ញត្តិគតិយុត្តជាធរមាននានា ទាំងកម្រិតច្បាប់ ទាំងកម្រិតអនុវត្ត ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមគក្តវិជ្ជាគតិយុត្តមួយច្បាស់លាស់ និងក្នុងវិស័យជាក់លាក់ ដើម្បីសម្រេចបានឯកសារមួយ ដែលមានមាតិកានុក្រមរួមតែមួយហៅថា "ក្រម"។

៣.៣. ព័ត៌មានវិទ្យានីតិកម្ម

ព័ត៌មានវិទ្យានីតិកម្ម គឺជាការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គាំទ្រដល់ការតាក់តែង ការចងក្រង និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត។

ផ្អែកតាមឧត្តមានុវត្តន៍ប្រទេសបារាំង ប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មយ៉ាងតិច ៤ ប្រភេទបាននិងកំពុងចូលរួមគាំទ្រដល់ប្រសិទ្ធភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តគឺ៖

ទី១. ប្រព័ន្ធគ្រប់គ្រងការរៀបចំនិងអនុម័តបទដ្ឋានគតិយុត្ត SOLON (Système d'organisation en ligne des opérations normatives) ដែលបាននិងកំពុងបំពេញបន្ថែមដោយប្រព័ន្ធតាក់តែងបទដ្ឋានគតិយុត្ត EDILE (Editeur légistique)។ EDILE គឺជាគម្រោងកម្មវិធីឌីជីថលូបនីយកម្មច្បាប់ ជំនួយក្នុងការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាដល់គុណភាពនិងសង្គតិភាពខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ទី២. Légifrance៖ ជាគេហទំព័រផ្លូវការនៃការផ្សព្វផ្សាយនូវច្បាប់ លិខិតបទដ្ឋានគតិយុត្ត យុត្តិសាស្ត្រ សាលក្រម សាលដីកា និងសេចក្តីសម្រេចនានារបស់តុលាការ។ គេហទំព័រនេះ គឺជាឃ្លាំងនៃព័ត៌មានច្បាប់របស់ប្រទេសបារាំងទាំងមូល ដែលរាល់ច្បាប់ជាធរមានឬច្បាប់វិជ្ជមាន ត្រូវយកមកចុះផ្សាយក្នុងគេហទំព័រនេះ រីឯច្បាប់និរាករណ៍ ឬត្រូវបានធ្វើវិសោនកម្ម ត្រូវបានយកមកចុះផ្សាយនិងរៀបចំទៅតាមវិធីសាស្ត្រគក្តវិជ្ជានៃច្បាប់យ៉ាងច្បាស់លាស់និងសាមញ្ញ។ គេហទំព័រនេះ បាននិងកំពុងបម្រើជាប្រយោជន៍យ៉ាងអតិបរមានៃការចូលរួមចំណែកពង្រឹងប្រសិទ្ធភាពនៃការយល់ដឹងច្បាប់និងការអនុវត្តច្បាប់ ជាពិសេសជាគេហទំព័រច្បាប់ បម្រើដល់ពិនិត្យានុភាពច្បាប់ ដែលជាមូលដ្ឋានគ្រឹះចម្បងក្នុងការរៀបចំឬតាក់តែងបទដ្ឋានគិតយុត្ត។

ទី៣. Vie-Publique.fr៖ ជាគេហទំព័រផ្លូវការដែលបានរៀបចំជាអត្ថបទចំណេះដឹងពាក់ព័ន្ធច្បាប់ គោលនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ដើម្បីជាគុណប្រយោជន៍ដ៏ប្រជាពលរដ្ឋទូទៅក្នុងការយល់ដឹងពីស្ថានការណ៍នៃការវិវត្តច្បាប់ សេដ្ឋកិច្ច និងសង្គមរបស់រដ្ឋ។

ទី៤. Service-public.fr៖ ជាគេហទំព័រផ្លូវការនៃការផ្តល់ព័ត៌មានសេវាសាធារណៈរបស់រដ្ឋបាលបារាំងដែលបង្កើតឡើងក្នុងគោលដៅផ្តល់ព័ត៌មាន និងឆ្លើយតបនៅការស្នើនូវបកស្រាយនានាពីសំណាក់អ្នកប្រើប្រាស់សេវា និងណែនាំពីរបៀបប្រើប្រាស់សេវាសាធារណៈដែលអនុញ្ញាតឱ្យសាធារណជនទទួលបានសិទ្ធិ និងជាជំនួយដល់ការយល់ដឹងនិងការអនុវត្តនីតិវិធីរដ្ឋបាល។ ជាក់ស្តែង ករណីជនអន្តោប្រវេសន៍ អាចស្វែងយល់សិទ្ធិរបស់ខ្លួន តាមរយៈសេវាសាធារណៈដែលផ្តល់ដោយគេហទំព័រនេះបាន។

ទន្ទឹមនេះ នៅបារាំងមានប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មជាច្រើនផ្សេងទៀតអាទិ៍ ប្រព័ន្ធបំប្លែងទិន្នន័យច្បាប់និងរដ្ឋបាល STILA (Système de traitement de l'information légale et administrative), ប្រព័ន្ធគ្រប់គ្រងទិន្នន័យច្បាប់ BDJ (Base de donné juridique) និងគម្រោងប្រព័ន្ធសមាហរណទិន្នន័យគតិយុត្តដោយបញ្ញាសម្បនិមិត្ត (Projet THEIA) ជាដើម។ ព័ត៌មានវិទ្យានីតិកម្ម នឹងលើកកម្ពស់ប្រសិទ្ធភាពនៃការផ្តល់សេវាកម្មច្បាប់ តាមរយៈការបង្កើនប្រសិទ្ធភាពនៃការគាក់តែង ការចងក្រង និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត។

បទបង្ហាញ៖ ស្តីពីប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន



មាតិកានុក្រម

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃព្រះធម្មសាស្ត្រកម្ពុជា
- ១.១. សម័យមុនអង្គរ (សម័យបុរេប្រវត្តិ ហ្វូណន និងចេនឡា)
- ១.២. សម័យអង្គរ
- ១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើប-១៨៦៣ ដល់បច្ចុប្បន្ន)
- ២.១. ទំនើបភាវូបនីយកម្មតាមបែបបារាំង
- ២.២. គុណតម្លៃទំនើបនិងគុណតម្លៃទំនៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់
- ២.៣. ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

៣. មាគ៌ាឆ្ពោះទៅកសាងអត្តសញ្ញាណនិងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា
- ៣.១. នីតិនិពន្ធវិទ្យា
- ៣.២. នីតិក្រមវិទ្យា
- ៣.៣. ព័ត៌មានវិទ្យានីតិកម្ម

៤. សំណួរ និង ពិភាក្សា
- ៤.១. ឯកសណ្ឋាន និង អត្តសញ្ញាណ នៃប្រព័ន្ធច្បាប់ខ្មែរ
- ៤.២. ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់ខ្មែរ

2

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា

១.១. សម័យមុនអង្គរ (បុរេប្រវត្តិ ហ្វូណន និងចេនឡា)

- នាសម័យបុរេប្រវត្តិ សង្គមដឹកនាំបែបកុលសម្ព័ន្ធ មេកន្ត្រាញ តាមរចនាសម្ព័ន្ធជាមជ្ឈមណ្ឌលកណ្តាល បន្ទាយគូ ភូមិមូល រីឯ ច្បាប់មានសណ្ឋានជាទំនៀមទម្លាប់ ជំនឿ ឬសាសនា។
- នៅមុនសម័យអង្គរ ការគ្រប់គ្រងទំនាក់ទំនងសង្គមប្រចាំថ្ងៃ ហាក់មានប្រភពច្បាប់ ជាទំនៀម ទម្លាប់ ជំនឿ និងសាសនា៖
  - **ខ្មែរជឿលើព្រលឹង (ជីវចលនិយម)៖** ខ្មែរជឿថាមនុស្សវត្ថុ ទីកន្លែង រុក្ខជាតិ ធម្មជាតិ សំណង់ ឬអ្វីៗទាំងអស់នៅជុំវិញខ្លួនសុទ្ធសឹងមានវិញ្ញាណ ឬព្រលឹង។ គេជឿថាមនុស្សស្លាប់ទៅមិនសាបសូន្យទេ គឺមានព្រលឹងទៅចាប់ជាតិជាថ្មីទៀត។ អ្នកតា ជាព្រលឹងនៃជនដែលស្លាប់ទៅហើយ តែនៅថែរក្សាមើលសុខទុក្ខដល់កូនចៅតទៅទៀត។ ដើម្បីគោរពអ្នកតា គេយកដុំថ្មទៅដាក់តម្កល់ ហើយគោរពជាអ្នកតា។ ម្យ៉ាងទៀតនៅបន្ទាយគូ/ភូមិមូលខ្លះ គេបានរកឃើញបង្គោលថ្មនៅចំកណ្តាលភូមិ ជាហេតុនាំឱ្យគេជឿថា បង្គោលនោះទាក់ទងទៅនឹងជំនឿលើអ្នកតាម្ចាស់ស្រុក។ ជំនឿលើអ្នកតានេះ បានបន្សល់ទុករហូតដល់សព្វថ្ងៃ។
  - **ការកំណត់អង្គហេតុនិងការស្វែករកយុត្តិធម៌ គឺផ្អែកលើជំនឿជីវចលនិយម និងសាសនា៖** តាមឯកសារចិនបាននិយាយថា "**អ្នកស្រុកហ្វូណនចូលចិត្តប្រើវិធីអស្ចារ្យដើម្បីរកសេចក្តីពិត**"។ ជាក់ស្តែងកាលណាមានបាត់របស់អ្វីមួយ គេក៏យកបាយមួយពំនូតទៅដាក់នៅចំពោះព្រះភក្ត្រទេព្តា រួចគេអង្វរសូមឱ្យព្រះអង្គជួយបង្ហាញមុខជនទុច្ចរិត។ ស្អែកឡើងគេយកបាយនោះទៅចែកឱ្យពួកខ្ញុំបម្រើនៅក្នុងផ្ទះឱ្យបរិភោគ ក្នុងមាត់ចោរនឹងមានឈាមហូរចេញយ៉ាងជាក់ស្តែង ហើយវាមិនអាចទំពារបាយផង ឯមាត់របស់ជនទៀងត្រង់បាយនោះរអិលទៅក្នុងមាត់យ៉ាងស្រួល។

3

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.១. សម័យមុនអង្គរ (បុរេប្រវត្តិ ហ្វូណន និងចេនឡា)

- **តារគ្រប់គ្រងនគរដោយផ្អែកលើច្បាប់៖**
  - កស្តុតាងឥទ្ធិពលច្បាប់ពីឥណ្ឌានៅក្នុងសង្គមខ្មែរបុរាណដែលមានចំណាស់ជាងគេ គឺមានសរសេរក្នុងសិលាចារឹកអង្គដំនឹក K.៥៣ (ស.វ. ៦៦៧) ដែលបង្ហាញពីមន្ត្រី២រូបរបស់ព្រះបាទស្រីភវវ៌ម្ម៌ទី១ (ភវវ៌ន៌ទី១) មានជំនាញខាងធម្ម៌សាស្ត្រ និងអថ៌សាស្ត្រ។
  - ការកើតនៃនគរភ្នំ នៅដើមគ្រិស្តសករាជ ជាការផ្លាស់ប្តូរដ៏ធំនៃរបបដឹកនាំនៅកម្ពុជា ពីការដឹកនាំបែបសហគមន៍ មកជារបបនយោបាយរាជាធិបតេយ្យ តាមក្បួនឥណ្ឌា "**មណ្ឌល**" (mandala)។ ផ្អែកតាមប្រព័ន្ធដឹកនាំនេះ អធិបតេយ្យភាពរបស់រដ្ឋមួយ បានមកពីសមត្ថភាពរបស់ខ្លួនក្នុងការទាក់ទាញកក្តីភាពតាមរយៈកិត្យានុភាពនៃវប្បធម៌ សេដ្ឋកិច្ច ឬយោធា ជាជាងតាមរយៈការគ្រប់គ្រងរដ្ឋបាលលើដីធ្លី ដែលមានព្រំដែនកំណត់ច្បាស់លាស់។ ប្រព័ន្ធដឹកនាំនេះ អាចរួមបញ្ចូលនូវ "មណ្ឌល" ក្រោមអាណាព្យាបាលជាច្រើន ជុំវិញ "រាជមណ្ឌល" ឬ "មជ្ឈមណ្ឌល" មួយដែលជាកន្លែងត្រួតត្រារួម និងដែលជាទីតាំងនៃរាជវាំង ឬកន្លែងដ៏ពិសិដ្ឋបំផុត។ ក្នុងបរិការណ៍នេះ គេសង្កេតឃើញសញ្ញាណនៃវិធានក្នុងការគ្រប់គ្រងរដ្ឋ ដូចតទៅ៖
    - ✓ **វិធានគ្រប់គ្រងរដ្ឋបាលកណ្តាល និងរដ្ឋបាលមូលដ្ឋាន៖** រដ្ឋដែលស្ថិតក្រោមអំណាចគ្រប់គ្រងរបស់នគរភ្នំសុទ្ធតែមានស្តេចសោយរាជ្យ ប៉ុន្តែស្តេចទាំងនោះ ត្រូវលើកសួយសារអាករមកថ្វាយមហារាជជារៀងរាល់ឆ្នាំ។
    - ✓ **វិធានពន្ធដារ៖** សម័យមុនអង្គរ ក៏មាននូវប្រព័ន្ធនិងវិធានពន្ធដារ ដោយអ្នកស្រុកមានកាតព្វកិច្ចបង់ពន្ធដារជូនរាជការជាមាស ប្រាក់ ត្បូង គុជឬគ្រឿងក្រអូបផ្សេងៗ
    - ✓ **ស្ថាប័នយុត្តធម៌៖** នៅសម័យចេនឡា គេក៏ឃើញមានសញ្ញាណនៃស្ថាប័នយុត្តិធម៌, ផ្អែកតាមឯកសារចិន នៅកណ្តាលក្រុងមានសាលប្រជុំធំមួយជាទីដែលព្រះមហាក្សត្រទ្រង់ព្រះប្រទានសវនាការ។ ក្នុង៣ថ្ងៃម្តង ព្រះរាជាតែងយាងទៅកាន់សាលប្រជុំនោះ។ មានមន្ត្រីជាន់ខ្ពស់ចំនួន ៥នាក់នៅអមព្រះមហាក្សត្រដែលក្នុងនោះមានមន្ត្រីយមរាជ (យុត្តិធម៌) ផងដែរ។ ចំណុចនេះបញ្ជាក់បានថា នាសម័យនោះមានកំណត់ទីតាំងសម្រាប់ទទួលបណ្តឹង និងធ្វើសវនាការមានរចនាសម្ព័ន្ធ និងមានព្រះមហាក្សត្រសម្រាប់ស្វែងរកយុត្តិធម៌ជូនប្រជាជនដែរ។ ព្រះមហាក្សត្រដើរតួនាទីជាអ្នកកាត់ក្តីចុងក្រោយ។

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.១. សម័យមុនអង្គរ (បុរេប្រវត្តិ ហ្វូណន និងចេនឡា)

- នៅសម័យមុនអង្គរ គេសង្កេតឃើញមានសញ្ញាណនៃគុណតម្លៃច្បាប់ខ្មែរ ជាអាទិ៍ដូចតទៅ៖
  - **គោលការណ៍មិនរើសអើងវណ្ណៈសង្គម៖** កម្ពុជាទទួលឥទ្ធិពលអរិយធម៌ឥណ្ឌាយ៉ាងខ្លាំងចំនួន២ លើក នៅដើមសតវត្សរ៍ទី១ និងដើមសតវត្សរ៍ទី៥។ ទោះជាសង្គមកម្ពុជាមានការបែងចែកវណ្ណៈជាបួន(ក្សត្រ មន្ត្រី អ្នកមាន អ្នកក្រ) ដូចសង្គមឥណ្ឌាក្តី ក៏សង្គមកម្ពុជាមិនប្រកាន់ឬរើសអើងវណ្ណៈដូចសង្គមឥណ្ឌាឡើយ។
  - **សេរីភាពសាសនា៖** នាសម័យមុនអង្គរ យើងសង្កេតឃើញថា ទោះបីព្រះមហាក្សត្របានប្រតិបត្តិព្រហ្មញ្ញសាសនាក្តី ក៏ព្រះអង្គបានបើកសិទ្ធិសេរីភាពពេញលេញដល់ប្រជាជនក្នុងការជ្រើសរើសជំនឿសាសនាដែរ។ ប្រជាជននៅប្រតិបត្តិពុទ្ធសាសនាផង និងព្រហ្មញ្ញសាសនាផង។
  - **ការបែងចែកតួនាទីបុរសនិងស្ត្រី៖** ទោះបីសង្គមកម្ពុជាមានការផ្លាស់ប្តូរពីលើកស្រីជាធំ ជាអ្នកដឹកនាំក្នុងគ្រួសារ និងសង្គមជាតិ(មេនិយម) មកឱ្យបុរសដឹកនាំវិញក្តី ក៏សង្គមកម្ពុជានៅតែផ្តល់តម្លៃដល់ស្ត្រីក្នុងការគ្រប់គ្រងចាត់ចែងទ្រព្យសម្បត្តិ និងគ្រួសារដែរ។
  - **សិទ្ធិលើការកាន់កាប់ដីធ្លី៖** នៅសម័យមុនអង្គរ មានការរៀបចំគោលនយោបាយបែងចែកដីឱ្យប្រជាជន ការទទួលស្គាល់កម្មសិទ្ធិដីធ្លីរបស់ប្រជាជន។ ដីធ្លីទាំងឡាយណាដែលគេទុកចោលមិនដាំដុះក្នុងរយៈពេលបីឆ្នាំ ក្លាយជាកម្មសិទ្ធិរបស់រដ្ឋវិញ។
  - **សេរីភាពពាណិជ្ជកម្ម៖** វិស័យពាណិជ្ជកម្មក៏មានការរីកលូតលាស់ផងដែរ។ ភស្តុតាងគេបានរកឃើញស្នាមកំពង់ផែសមុទ្រយ៉ាងធំមួយគឺកំពង់ផែអូកែវ។ គេសន្និដ្ឋានថា កំពង់ផែនេះជាកំពុងផែអន្តរជាតិ ពីព្រោះផ្អែកលើកំណាយនៅតំបន់នោះបានរកឃើញវត្ថុផ្សេងៗដែលមកពីប្រទេសឆ្ងាយៗ ដូចជា ចក្រភពរ៉ូម៉ាំង ចក្រភពអ៊ីរ៉ង់ ឥណ្ឌា។ ដូច្នេះនៅសម័យនោះ អ្នកស្រុកហ្វូណនបានធ្វើជំនួញជាមួយប្រទេសនានាដូចជាចិន ឥណ្ឌា រ៉ូម៉ាំង និងពែរ្ស។ តាមកំណត់ត្រាចិនថា នៅស្រុកនេះ ស្រីៗពូកែរកស៊ីណាស់។ ទំនិញដែលគេលក់ដូរច្រើនជាមាស ប្រាក់ សំពត់ព្រៃ គ្រឿងកែវ។

១. ទស្សនាទានជាប្រភពវិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.២. សម័យអង្គរ

ក. ទស្សនវិជ្ជាច្បាប់ខ្មែរក្នុងសម័យអង្គរ

ប្រព័ន្ធច្បាប់ខ្មែរសម័យអង្គរ គឺជាប្រព័ន្ធច្បាប់ដែលមានអរិយខ្ពស់បំផុតដោយបានធ្វើសមាហរណកម្ម និង/ឬសុខដុមនីយកម្មនៃទស្សនវិជ្ជា/ឬលទ្ធិព្រហ្មញ្ញ-ហិណ្ឌូសាសនា និងទស្សនវិជ្ជា/ឬលទ្ធិពុទ្ធសាសនា ដើម្បីធ្វើការគ្រប់គ្រង និងការអភិវឌ្ឍសង្គម សេដ្ឋកិច្ច របស់ប្រទេសជាតិ។ ប្រព័ន្ធច្បាប់ខ្មែរសម័យអង្គរ បាន***បង្កប់***នូវគុណតម្លៃនិង/ឬទស្សនវិជ្ជាច្បាប់យ៉ាងតិចចំនួន ៣ យ៉ាង ដូចខាងក្រោម៖

- **ទី១.** ច្បាប់កំពូលដែលត្រូវការពារនិងគោរពប្រតិបត្តិ
- **ទី២.** សីល្បវិសាស្ត្រនិងវិទ្យាសាស្ត្រនៃការដឹកនាំនិងគ្រប់គ្រងរដ្ឋ, និង
- **ទី៣.** សីលធម៌ និងយុត្តិធម៌សង្គម។

១. ទស្សនាទានជាប្រភពិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.២. សម័យអង្គរ

- **ទី១. ច្បាប់កំពូលដែលត្រូវការពារនិងគោរពប្រតិបត្តិ:**
  - "**ព្រះធម្មសាស្ត្រ**" គឺជាច្បាប់កំពូលខ្មែរសម័យបុរាណ ដោយព្រះមហាក្សត្របានកំណត់ទុកជាច្បាប់កំពូល សម្រាប់ដឹកនាំនិងគ្រប់គ្រងប្រទេស និងត្រូវគោរពប្រតិបត្តិទាំងមន្ត្រី ប្រជានុរាស្ត្រ និងព្រះមហាក្សត្រ ដោយតម្កល់លើព្រះសិរសារបស់ព្រះអង្គ ទើបមានគុណសម្បត្តិជាព្រះធម្មរាជា ឬព្រះរាជាទ្រង់ធម៌។
  - "**ព្រះធម្មសាស្ត្រ ទុកជាព្រះកេសារបស់ព្រះមហាក្សត្រ**" រីឯ "**គម្ពីរអថ៌សាស្ត្រ**" និងគម្ពីរដទៃទៀតដូចជាផ្នែកដទៃនៃរាងកាយ ដែលត្រូវគោរពនិងអនុលោមតាមក្រមព្រះធម្មសាស្ត្រ។
  - "**គម្ពីរអថ៌សាស្ត្រ**" ត្រូវបានប្រើជាក្បួនយុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋ រដ្ឋបាល យោធា សេដ្ឋកិច្ច និងការទូតសម្រាប់គ្រប់គ្រង និងពង្រីកនគរ។
  - ផ្អែកតាមសិលាចារឹកសម័យអង្គរ ច្បាប់ត្រូវបានប្រៀបប្រដូចជាព្រះគោ (គោឧសភរាជ) ឬជាព្រះធម្ម ឬក៏ព្រះច្បាប់ដោយត្រូវរក្សាជើងទាំង៤ឱ្យបានគង់វង្ស លុះបាត់ជើងណាមួយ នៅពេលព្រះមហាក្សត្រដែលឡើងសោយរាជ្យ ពោរពេញដោយអំណាច និងគុណធម៌តែងឧប្បត្តិកឱ្យគោមានជើងទាំង៤ឡើងវិញ អាចទ្រទ្រង់ខ្លួនបានវិញដែលប្រៀបប្រដូចនឹងការស្ថាបនាច្បាប់ឡើងវិញសម្រាប់គ្រប់គ្រងព្រះនគរ។ 7

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.២. សម័យអង្គរ

- **ទី២. សិល្ប៍សាស្ត្រនិងវិទ្យាសាស្ត្រនៃការដឹកនាំនិងគ្រប់គ្រងរដ្ឋ៖**
  - អំណាចព្រះមហាក្សត្រ ជាអំណាចកំពូល និងដឹកនាំគ្រប់គ្រងរដ្ឋលើវិស័យនានាជាអាទិ៍ នយោបាយដឹកនាំរដ្ឋ សេដ្ឋកិច្ច ការគ្រប់គ្រងដីធ្លី សាសនា តុលាការ និងយោធាជាដើម។
  - ព្រះរាជបញ្ជារបស់ព្រះមហាក្សត្រ គឺជាអំណាចរបស់ទេព ដែលជាច់ខាតអ្នកនៅក្រោមបញ្ជាត្រូវតែលុះតាមអាជ្ញានិងស្មោះត្រង់ជានិច្ច ពោលគឺជាច្បាប់ដែលត្រូវគោរពប្រតិបត្តិជាច់ខាត។
  - ការរៀបចំនិងការគ្រប់គ្រងរដ្ឋបាលក្នុងសម័យអង្គរ ត្រូវបានរៀបចំ ជារដ្ឋបាលកណ្តាល និងរដ្ឋបាលដែនដី ***ដើម្បីជានាប្រសិទ្ធភាពការគ្រប់គ្រងរដ្ឋ ការអភិវឌ្ឍសង្គម សេដ្ឋកិច្ច ជាពិសេសការអនុវត្តច្បាប់និងយុត្តិធម៌***។

8

១. ទស្សនាទានជាប្រភពិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.២. សម័យអង្គរ

- **ទី៣.សីលធម៌ និងយុត្តិធម៌សង្គម៖**
  - "**ព្រះធម្មសាស្ត្រ**" ជាក្រមច្បាប់ដែលផ្តោតលើការអប់រំផ្នែកសីលធម៌ គុណធម៌ និងកាតព្វកិច្ចសង្គមរបស់មនុស្សម្នាក់ៗ ពោលគឺការបង្កើតសង្គមមានសីលធម៌ និងសុចរិតភាពតាម "ធម៌" ដែលមានតម្លៃជាងការដាក់ទណ្ឌកម្មនៅពេលប្រព្រឹត្តកំហុស។ ច្បាប់គឺជាវិធានអប់រំសីលធម៌ក្នុងសង្គមផង និងដាក់ទណ្ឌកម្មផងដែរ។
  - "**ព្រះធម្មសាស្ត្រ**" ជាក្រមច្បាប់ធានាយុត្តិធម៌សង្គម៖
    - ព្រះមហាក្សត្រ ដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរសម័យអង្គរក្នុងការស្វែងរកនិងផ្តល់យុត្តិធម៌ ដោយកាតព្វកិច្ចរបស់ព្រះមហាក្សត្រគឺការពារប្រជារាស្ត្រ និងធានាការអនុវត្ត "ធម៌" ។
    - ការយកពន្ធដារដោយយុត្តិធម៌ និងមិនតឹងរ៉ឹងជ្រុលហួសហេតុ ដោយមានអភិក្រមចំនួន ២ គឺទី១. ឃុំបឹតផ្កា ពោលគឺបឹតលំអងផ្កាបន្តិចម្តងៗ ដោយមិនធ្វើឱ្យផ្កាខូច និងទី២ កូនគោបៅដោះ ពោលគឺបៅបន្តិចម្តងៗ ដោយមិនធ្វើឱ្យមេហត់នឿយបាត់កម្លាំង។

9

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.២. សម័យអង្គរ

ខ. អត្ថិភាព ឬឥទ្ធិពលនៃប្រព័ន្ធច្បាប់ក្នុងសម័យអង្គរ លើប្រព័ន្ធច្បាប់សម័យក្រោយអង្គរ

- នៅក្រោយសម័យអង្គរ ព្រះធម្មសាស្ត្រគឺជាកម្រងច្បាប់មួយ ដែលអាចរកឃើញក្នុងចំណោមក្រមច្បាប់ផ្សេងទៀតចាប់ពីរជ្ជកាលព្រះបាទជ័យជេដ្ឋាទី២ រហូតដល់រជ្ជកាលព្រះបាទនរោត្តម។
- ប្រព័ន្ធច្បាប់ខ្មែរក្នុងសម័យអង្គរ បានជះឥទ្ធិពលលើប្រព័ន្ធច្បាប់ក្នុងសម័យក្រោយអង្គរ ព្រមទាំងបាននិងកំពុងពួនសម្ងំនិងបន្តអត្ថិភាពរបស់ខ្លួនជាគុណតម្លៃ ឬជាទស្សវិជ្ជាច្បាប់ សម្រាប់កសាងទស្សនវិស័យនៃអត្តសញ្ញាណ និងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា បច្ចុប្បន្ន ដោយផ្អែកគុណតម្លៃនិង/ឬទស្សនវិជ្ជាច្បាប់ ដែលបានគូសរំលេចក្នុងចំណុច "ក" ខាងលើ។

គ. លទ្ធិទេវរាជ៖ បង្រួបបង្រួមជំនឿ សាសនា និង ទស្សនវិជ្ជា នៃកាជីកនាប្រទេស ៖ ប្រភព នៃការបង្កើតអំណាច រក្សាអំណាច និង ការពារទឹកដី និង ប្រជារាស្ត្រ។

- អំណាចតាំងច្បាប់ និង ជាច្បាប់សម្រាប់តាំងអំណាច
- កម្មដ្ឋាន តបធម៌ និងការបំពេញប្រាជ្ញាបារមីតា របស់ព្រះមហាក្សត្រ បំពេញព្រះពោធិសម្ភារ
- ធម្មវិជ្ជា និង ទស្សនវិជ្ជា៖ ឈានពីកម្រិតត្រិះរិះពិចារណា ដល់ កម្រិតភាវនា បំពេញឈានបារមី

10

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

ក. សញ្ញាណទូទៅ៖

- ព្រះធម្មសាស្ត្រ នៅតែជាច្បាប់កំពូល និងត្រូវបានកំណត់ទុកជាព្រះសិរសារបស់ព្រះមហាក្សត្រ
- ក្រោយសម័យអង្គរ ព្រះធម្មសាស្ត្រនិងច្បាប់បុរាណផ្សេងៗទៀត សុទ្ធតែត្រូវបានដឹកនាំតាក់តែងដោយព្រះមហាក្សត្រ និងចូលរួមតាក់តែងដោយអ្នកប្រាជ្ញ រាជបណ្ឌិត កវី មានចំណេះដឹងនិងយសសក្តិខ្ពង់ខ្ពស់ ដែលត្រូវបានព្រះមហាក្សត្រកោះអញ្ជើញឱ្យចូលរួមរៀបចំតាក់តែងច្បាប់ ឬព្រះមហាក្សត្របង្គាប់បញ្ជាឱ្យមហាមន្ត្រីណាមួយទទួលបន្ទុកតាក់តែងច្បាប់ជំនួសទ្រង់ទើបយកមកជំនុំ។
- ឯកសារច្បាប់ ជាតឹកតាងនាសម័យនេះ មានសេសសល់មួយចំនួន នាចុងសម័យកណ្តាលនេះ រួមមាន៖

11

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យគ្រោយអង្គរ (សម័យកណ្តាល)

១-ក្រឹមព្រះធម្មសាត្រ	២-ក្រឹមលក្ខណឥន្ទភាស	៣-ក្រឹមទំរុងស័ក្តិ
៤-ក្រឹមក្បដ្ឋសិក់	៥-ក្រឹមមុណ្ឌីរបាល	៦-ក្រឹមអាជ្ញាលួង
៧-ក្រឹមព្រះធម្មនុញ	៨-ក្រឹមត្រលាការ	៩-ក្រឹមសាកសីពីសោធន៍
១០-ក្រមកាត់សំនួនកាត់សាក្សី	១១-ក្រឹមទ័ទួលកាត់បន្តឹង	១២-ក្រឹមអញ្ញមញ្ញបដិភាស
១៣- ក្រឹមឧទ្ធរ៍	១៤- ក្រឹមព្រំហ្មទណ្ឌ	១៥- ក្រឹមចោរក័ម្ម
១៦-ក្រឹមព្រះរាជក្រិតសំយ៉ារី	១៧-ក្រឹមទស់ភិរីយា	១៨- ក្រឹមមរដក់
១៩-ក្រមសារពើគុណ	២០-ក្រឹមពហុលទេព្ធ	២១-ក្រឹមសែះ
២២-ក្រឹមពួក	២៣-ក្រឹមវិវាទ	២៤-ក្រឹមបៀរ
២៥-ក្រឹមបំណុល់	២៦-ល័ក្ខណៈទាសកម្មករ	២៧-ក្រឹមសួស្តីបនជូនព្រៃយ
២៨-ក្រមព្រះរាជខណ្ឌ	២៩-ច្បាប់ទុំនីមព្យីបូរ៉ាន	៣០-ច្បាប់ក្រឹមចក្រីយ៍

12

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

៣១-ព្រះធម្មសាត្រ	៣២-ច្បាប់រាជនីតិសាស្ត្រ	៣៣-ព្រះរាជក្រឹត្យ នៃមហាក្សត្រាធិរាជ
៣៤-ក្រឹត្យព្រះវររាជមាតា	៣៥-ក្រឹត្យព្រះអគ្គមហេសី	៣៦-ក្រឹត្យឧបរាជ
៣៧-ក្រឹត្យបុរោហិត	៣៨-ក្រឹត្យពលទេព	៣៩-ក្រឹត្យសារថី
៤០-ក្រឹត្យសេដ្ឋី	៤១-ក្រឹត្យឃុនឃ្លាំង	៤២-ក្រឹត្យឆ្មាំទ្វារ
៤៣- ក្រឹត្យនាងសុវណ្ណបុប្ផា	៤៤- ទសមិត្តធម៌	៤៥- លក្ខណៈអង្គាហ្លួង
៤៦-ច្បាប់ក្រមស្រុកព្រះជ័យចេស្តា	៤៧-ច្បាប់ក្រមចៅហ្វាយស្រុក	៤៨- ច្បាប់ក្រមព្រះនគរបាល
៤៩-ច្បាប់អាណាចក្រ	៥០-ក្រមសុភាធិបតី (I)	៥១-ក្រមសុភាធិបតី (II)
៥២-ច្បាប់ក្រមស្រុក ៩ ប្រការ	៥៣-ក្រមប្រដៅចៅក្រម (I)	៥៤-ក្រមប្រដៅចៅក្រម (II)
៥៥-ច្បាប់កុលបន្ទប់ សភៅវិលេខ១	៥៦-ច្បាប់កុលបន្ទប់ សភៅវិលេខ២	៥៧-ច្បាប់កុលបន្ទប់ សភៅវិលេខ៣
៥៨-ច្បាប់កុលបន្ទប់ព្រះរាជសាស្ត្រ	៥៩-ច្បាប់កុលបន្ទប់	៦០-ច្បាប់ព្រះរាជសាស្ត្រ

13

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

- ៦១-ច្បាប់សារពើគុណ
- ៦២-ច្បាប់ឃុនសាលា
- ៦៣-លក្ខណៈល្មើសព្រះរាជបញ្ញត្តិ
- ៦៤-លក្ខណៈប្តីប្រពន្ធ
- ៦៥-ច្បាប់ក្រមសួស្តីចែកពល
- ៦៦-ច្បាប់ក្រមសួស្តីប្រចាប់ពល
- ៦៧-លក្ខណៈខ្ញុំលួចទ្រព្យ ម្ចាស់ទ្រព្យ
- ៦៨-លក្ខណៈរុករានទី
- ៦៩-លក្ខណៈទទួលទិញបញ្ចាំទ្រព្យ
- ៧០-ច្បាប់ក្រមដំរី
- ៧១-ច្បាប់សំពៅ
- ៧២-ច្បាប់សារពើល្បែងភ្នាល់គ្នា
- ៧៣- លក្ខណៈកំហែង, លក្ខណៈភ្នាល់
- ៧៤- ក្រមស័ក្តិនិងលក្ខណៈវិវាទគ្នា
- ៧៥- លក្ខណៈវិវាទ
- ៧៦-លក្ខណៈវិវាទសង្ឃការី
- ៧៧-ក្បួនព្រះរាជសព្ទ
- ៧៨- ក្បួនរាជាភិសេក
- ៧៩-ច្បាប់ប្រាប្តាភិសេក
- ៨០-ច្បាប់ទ្វាទសមាស
- ៨១-ច្បាប់ធ្វើពិធីត្រុដិចង្រ្កានទ្វាទសមាស
- ៨២-ព្រះរាជក្រឹត្យគ្មានចំណងជើងនិងមិនចប់
- ៨៣-គម្ពីរត្រៃភូមិ

14

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

ទម្រង់នៃការតាក់តែងក្រម ឬច្បាប់៖ ជួនមាន ឬពុំមានបែងចែកជាមាត្រា ឬជំពូក, ជួនមាន ឬគ្មានការបែងចែកផ្នែកនៃអត្ថបទ។ ជាឧទាហរណ៍៖ ក្រំមព្រះធម្មសាត្រ ត្រូវបានតាក់តែងឡើងនៅចុល្លសករាជ ១២១៥ ត្រូវនឹង គ.ស. ១៨៥៣ ក្នុងរជ្ជកាលព្រះបាទហរិរក្សរាមាឥស្សរាធិបតី **អង្គឌួង** ដោយពុំមានបែងចែកជាមាត្រា ឬជំពូក និងបែងចែកជាបីផ្នែក គឺសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់។

ខ. ការតាក់តែងច្បាប់បុរាណ៖

❑ **គោលការណ៍គ្រឹះ៖**

- ការតាក់តែងច្បាប់ខ្មែរពីបុរាណ៖ ព្រះមហាក្សត្រដឹកនាំមន្ត្រីតាក់តែង និងដាក់ឱ្យអនុវត្តច្បាប់ ឬត្រាស់បង្គាប់ឱ្យមហាមន្ត្រីណាមួយ តាក់តែង ទើបយកមកជំនុំ ឬចម្លងព្រះរាជវិនិច្ឆ័យរបស់មហាក្សត្រមុនៗ។
- អនុលោមតាមច្បាប់កំពូល (ច្បាប់គ្រឹះ) គឺក្រមព្រះធម្មសាស្ត្រ ដែលជាស្នាព្រះហស្តរបស់ព្រះមនោសាចារិយ៍ (ព្រះបាទមនុ) ៖
  - ✓ មូលគតិ ៖ ច្បាប់គោល
  - ✓ សាខាគតិ ៖ ព្រះរាជាសាសន៍ ព្រះរាជកំណត់ ព្រះរាជបញ្ញត្តិ ដើម្បីកំចាត់ភ័យ នៃប្រជារាស្ត្រ ប្រកបដោយសិលសត្យ ប្រណិប័តន៍ធម្មដ៏ប្រសើរ បម្រុងក្រុងព្រះនគរឱ្យចំរើនបរិបូរក្សេមក្សាន្ត ជាឧត្តមប្រយោជន៍ដល់ប្រជារាស្ត្រ ដោយអនុលោមតាមព្រះធម្មសាស្ត្រ។

15

១. ទស្សនាទានជាប្រភពិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

គ. សញ្ញាណ នៃយុត្តិធម៌៖

- ក្រមនានាទាក់ទងនឹងក្រមសីលធម៌៖ ក្រមព្រះធម្មសាស្ត្រ, ក្រមត្រលាការ, ក្រមសាក្សីពិសោធន៍, ក្រមមន្ទីរបាល, ក្រំមលក្ខណឥន្ទភាស ឬក្រមលក្ខណៈឥន្ទភាស, ច្បាប់ទំនឹមពីបុរាណ, សាស្ត្រាកឹងកន្ត្រែ៖ កម្រងរឿងព្រេងខ្មែរ ចំនួន ៥៣ រឿង។
- ក្រមសីលធម៌អ្នកកាត់សេចក្តី (ចៅក្រម)
  - ✓ កុំលុះដោយអគតិធម៌៖ ឆន្ទាគតិ, ទោសាគតិ, ភយាគតិ, មោហាគតិ។ ឥស្សរិយយស និង បរិវារយស ៖ ចន្ទ ចាស់ខ្មើត និង ចាស់រនោច
  - ✓ វិរិយសម្បយុត្តដោយសុគតិយុត្តិធម៌៖ សុចរិតយុត្តធម៌, បញ្ញត្តិគារវោ, សមទណ្ឌោ, បញ្ញាវុធវិនិច្ឆ័យ។
  - ✓ វិធីសាស្ត្រកយុត្តិធម៌៖ មន្ទលេន (ទឹកហូរ) សេនបទ (ខ្លែងធាប) មណ្ឌុកដ (កង្កែបលោត) សីហលោ (បន្ទឹ សីហនាទ)។
  - ✓ គោរពប្រណិបត្តិនូវបញ្ចសីល (សីល៥) និងឧបោសថសីល (សីល៨) ព្រហ្មវិហារធម៌
  - ✓ ទសពិធរាជធម៌៖ ទាន, សីល, បរិច្ចាគ, អាជ្ជវៈ, មទ្ទវៈ, តបៈ, អក្កោធនៈ, អវិហិង្សា, ខន្តី, អវិរោធនៈ។ 16

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអន្តរ (សម័យកណ្តាល)

ឃ. សញ្ញាណ នៃបទដ្ឋានគតិយុត្ត

- ច្បាប់ទំនឹមពីបុរាណ៖ ទំនឹមទី២០. អំពើត្បកព្រះសង្ឃ ជាការប្រមាថព្រះសង្ឃ និង ព្រះពុទ្ធសាសនា ត្រូវមានទោស វាយ ១៥០ រំពាត់ រឹបអូសទ្រព្យសម្បត្តិទាំងអស់ ហើយបង្គាប់ឱ្យទូលដៃដើរតាមជើងដំរី។
  - សារពើទ្រព្យដែលបានបូជាថ្វាយព្រះរតនត្រ័យហើយ ពុំអាចយកវិញបានឡើយ
- ក្រមក្បត់សឹក៖ ជាប្រពៃណីក្សត្រ ទ្រង់ព្រះបញ្ញតចាត់ទោសដោយគួរនឹងកម្ម៖ ទោស ៣ ប្រការ តាមច្បាប់បុរាណ (ឧក្រិដ្ឋទោស គរុទោស និងលហុទោស) កែមក ៥ ប្រការវិញ (ឧក្រិដ្ឋទោស មហន្តទោស គរុទោស មជ្ឈិមទោស និងលហុទោស)
  - អំពើស្វាមីកក្តិឈ្នះអស់សង្គ្រាមត្រូវទទួលរង្វាន់ រីឯ អំពើគេចវេះពីសង្គ្រាមត្រូវសម្លាប់បង់។
- ក្រមព្រះធម្មនុញ្ញ៖ ខ្ពុំរាជការដែលគ្មានសាលាជំនុំ ពុំមែនជាចៅក្រសួងត្បូងការឡើយ (ជៀសវាងនៅផ្ទះ)។
  - បែងចែកមុខក្រសួង តាមមុខងារ និងការពិភាក្សារួមក្រសួង៖ សមត្ថកិច្ចតាមកម្មវត្ថុវិវាទ បើពាក់ព័ន្ធក្រសួងច្រើន ត្រូវរួមគ្នាពិភាក្សាវិនិច្ឆ័យសេចក្តី ៖ ក្រសួងក្រុមព្រះនគរបាល និង ក្រសួងត្រលាការសាលាហ្លួង
  - ក្នាក់ងារព្រះធម្មនុញ្ញ ត្រូវប្រថាប់ត្រាពាក្យបណ្តឹង ឱ្យត្រូវដោយធម្ម ទៅចៅក្រសួងត្បូងការ។

17

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអន្តរ (សម័យកណ្តាល)

- ដើមព្រះធម្មសាស្ត្រ ៖ ក្នុងរជ្ជកាលមុន ខ្វះការថែរក្សា និង ចម្លងកាត់ប្លែងតាមអំពើចិត្តដោយមនុស្សទុច្ចរិត ទើបតែងថ្មី ដោយហេតុទាំងពីរប្រការនេះ សម្រាប់ទុកជាមូលធម្ម ដែលព្រះមនោសារាចារ ឬព្រះមនោសារឥសី បានសម្តែងទុកជាបុរេចារឹក ៖
  - ភ្លើងរំលាយកប្ប ឆេះរាលដាលដល់ឋានព្រហ្ម ៖ ភ្លើងឆេះដល់ត្រឹមណា ទឹកលិចដល់ត្រឹមនោះ។ ឃ្លរមកខ្យល់បក់ ទឹកស្រកស្រុត ទាបចុះ ពពុះទឹកខនខាប់កើតជាផែនកែវ ប៉ុនចក្រវាឡ ជាបន្តបន្ទាប់ជាច្រើនលានយោជន៍ រហូតដល់បង្កើតបានជាផែនដី កើតធំឡើងទៅជាចក្រវាឡយើងនេះ ឈ្មោះថា មង្គលចក្រវាឡ ដ្បិតនៅសិរសាផែនដីមានឈូក ១ គុម្ព ដុះត្រង់ឡើង មានទង១ ផ្កាបែកជា ៥ ជាសញ្ញានៃការត្រាស់ដឹងរបស់ព្រះពុទ្ធ ៥ អង្គ នៅដើមកទ្រកប្បនេះ។ ព្រហ្ម ចុះមកបង្កើតជាមនុស្ស មានវិាទគ្នា ព្រះបរមពោធិសត្វ ត្រូវបានប្រជាជន តាំងជាព្រះបាទសម្តេចព្រះមហាសម្មតិរាជ។ មានមហាព្រហ្ម ១ អង្គ (ព្រហ្មទេវៈ) ចុតចុះមកក្នុងត្រកូលមហា មាត្យ ជាខ្ញុំ ព្រះបាទសម្តេចព្រះមហាសម្មតិរាជ លុះវ័យ ១៥ ឆ្នាំ តាងតំណែងបិតា ឃើញសត្វមានទុក្ខលំបាក វិាទទាស់គ្នា មានចិត្តចង់ឱ្យព្រះមហាក្សត្រ តាំងក្នុងទសពិធរាជធម៌ ក៏ឥស្សរិយយស លាទៅបួសជាតាបសឥសី

18

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ត)

១.៣. សម័យក្រោយអន្តរ (សម័យកណ្តាល)

- មានកាលភ្លៀងធំ នាងទេពគន្ធបកិណ្ណរី ទៅជ្រកសំណាក់ នៃព្រហ្មទេវៈឥសី មានចិត្តប្រតិព័ទ្ធ បានបុត្រ២អង្គ៖ ចៅភទ្ទ រកុមារ និង ចៅមនោសារកុមារ។ ទាំងពីរបួសជាឥសី សម្រេចបានអភិញ្ញាណ ៥ និងអដ្ឋសមាបត្តិ ៨
- ព្រះភទ្ទរតាបស ហៅទៅកាន់កន្តាប់ចក្រវាឡ ចម្លងគម្ពីរអាគមវេទ ថ្វាយមហាក្សត្រ ក្លាយជារាជគ្រូ
- ព្រះមនោសារតាប ជាអាមាត្យធំក្នុងទីសុភាជំនុំពិភាក្សាសេចក្តី
- គ្រានោះ បុរស ២ នាក់ធ្វើចម្ការត្រសក់ជិតខាងគ្នា ពូនដីខ្ពស់ឡើងជាព្រំចម្ការខណ្ឌកណ្តាល កុំឱ្យច្រឡំគ្នា រីឯ ត្រសក់ដុះលូតលាស់បោះទង ឆ្លងព្រំទៅមកប្រសព្វគ្នា មានផ្លែ បេះកើតវិវាទគ្នា នាំគ្នាទៅប្តឹងព្រះមនោសារអាមាត្យ
- ព្រះមនោសារអាមាត្យ៖ ចម្ការត្រសក់មានព្រំខណ្ឌកណ្តាលហើយ បើត្រសក់ផ្លែនៅក្នុងចម្ការអ្នកណា ឱ្យជារបស់អ្នកនោះ
- កាត់ក្តីមិនយុត្តិធម៌ បុរសមិនសុខចិត្តទៅប្តឹងព្រះមហាក្សត្រ ត្រាស់បង្គាប់រាជ្យអាមាត្យ១ទៀត ទៅពិចារណាមើលទងត្រសក់ ហើយទ្រង់បណ្តាំថា ឱ្យលើកទងត្រសក់នោះដាក់មកតាមគល់ ហើយបង្គាប់ឱ្យបេះផ្លែត្រសក់តាមគល់
- បុរសពេញចិត្ត សរសើរព្រះប្រាជ្ញាញាណ រីឯ ព្រះមនោសារអាមាត្យ ត្រូវត្មៃតិះដៀល ដោយល្បឿងអគតិ ៤ ប្រការមានមោហាគតិ កើតធម្មសង្វេគ ស្លុតចិត្ត ខ្មាសារស្ត្រ ទៅបួសជាឥសី ដូចដើមវិញ សម្រេចបាន អភិញ្ញាណ ៥ និងអដ្ឋសមាបត្តិ ៨ ប្រជារាស្ត្រក៏ត្រេកអរឡើងវិញ ។ មនោសារតាបស មានចិត្តចង់ឱ្យព្រះមហាក្សត្រទ្រង់ទសពិធរាជធម៌ ក៏ហោះទៅកំពែងចក្រវាឡ បានឃើញគម្ពីព្រះធម្មសាស្ត្រ តាមស្នាមលក្ខណៈអក្សរប្រាកដ មានបរិមណ្ឌលតួនីមួយៗ ប៉ុនដំរីសារ 19

១. ទស្សនាទានជាប្រវត្តិសាស្ត្រ នៃ ព្រះធម្មសាស្ត្រកម្ពុជា (ចប់)

១.៣. សម័យក្រោយអង្គរ (សម័យកណ្តាល)

- ព្រះមនោសារឥសី កំណត់កួចកត់សម្គាល់រាល់តួចាំបាន ហើយវិលត្រឡប់មកតែងឡើងជាគម្ពីរព្រះធម្មសាស្ត្រ ថ្វាយព្រះបាទសម្តេចព្រះមហាសម្មតិរាជ ដោយសច្ចធម៌។
- ព្រះបាទសម្តេចព្រះមហាសម្មតិរាជ ស្តេចសោយរាជសម្បត្តិ កំចាត់ភ័យ នៃប្រជាជន ជាសុខសោភិនី ស្តេចតាំងក្នុងធម៌ទសពិធ ១០ ប្រការ ទ្រង់នូវបញ្ចសីល ឧបោសថសីល ទ្រង់ព្រះករុណានុគុណ ដល់សត្វលោកផងមិនរើសមុខ ហើយទ្រង់ព្រះឧស្សាហ៍នមសិការ នូវគម្ពីរព្រះធម្មសាស្ត្រ ជានីតិក្នុងព្រះអង្គ ទ្រង់ប្រព្រឹត្តក្នុងធម៌ ៤ ប្រការ ៖
  - ១.ពិចារណាជ្រាបសេចក្តីខុស ត្រូវ នៃអ្នកដែលធ្វើឱ្យជាប្រយោជន៍និងមិនជាប្រយោជន៍ដល់ព្រះអង្គ
  - ២.ទំនុកបម្រុងផ្គុងផ្តើមកុលបុត្រ ដែលរក្សាសីលសត្យ
  - ៣. ប្រមូលព្រះរាជទ្រព្យក្នុងព្រះរាជធានី ត្រូវដោយគន្លងធម្ម
  - ៤. រក្សាខបខណ្ឌសីមាមហានគរ និងអាណាប្រជានុរាស្ត្រ ឱ្យសុខសប្បាយក្សេមក្សាន្ត ដោយយុត្តិធម៌។

20

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា

២.១. ទំនើបភាវូបនីយកម្មតាមបែបបារាំង

ប្រព័ន្ធច្បាប់កម្ពុជាសម័យទំនើបនេះរងឥទ្ធិលខ្លាំងពីប្រព័ន្ធច្បាប់បរទេសដែលអាចបែងចែកជាពីរដំណាក់កាលចំបង៖

១). ១៨៦៣-១៩៥៣ (សម័យអាណាព្យាបាលបារាំង)៖ ការកសាងប្រព័ន្ធច្បាប់កម្ពុជាតាមលំអានបារាំងរួមមាន៖

- ការបង្កើតគណៈកម្មការចម្រុះកម្ពុជា-បារាំងដើម្បីបង្កើតក្រមច្បាប់ខ្មែរ (១១ សីហា ១៩០១)
- ក្រមនីយកម្មតាមលំអានបារាំងត្រូវបានរៀបចំរួមមាន ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមស្តីពីការរៀបចំតុលាការ (១៩១២)
- វិធីសាស្ត្រនៃការរៀបចំក្រមរដ្ឋប្បវេណីយកតាមលំអានបារាំង៖ បង្កើតគណៈកម្មការចំនួន៥ចុះប្រមូល ពិនិត្យ និងចងក្រងរៀបចំជាក្រមរដ្ឋប្បវេណីសម័យទំនើប (១៩២០)
- ការបង្កើតស្ថាប័នតុលាការឱ្យមានជារចនាសម្ព័ន្ធរឹងនៅតាមបណ្តាខេត្ត (១៩២២)
- យន្តការនៃការដោះស្រាយជម្លោះមាន ៣ កម្រិត៖ សាលាដំបូង សាលាឃុតឬសាលាឧទ្ធរណ៍ និងសាលាវិនិច្ឆ័យឬតុលាការកំពូល។ វិវាទរដ្ឋប្បវេណី ព្រហ្មទណ្ឌ និងរដ្ឋបាលត្រូវបានបែងចែកដាច់ពីគ្នា តាមរយៈការបង្កើតសាលាឧក្រិដ្ឋ (១៩១២)និងសាលាក្រមឈុត (១៩២៣) សម្រាប់វិវាទព្រហ្មទណ្ឌ និងសាលាក្រមវិវាទ (១៩៣៣) សម្រាប់វិវាទរដ្ឋបាល។

21

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.១. ទំនើបភាវូបនីយកម្មតាមបែបបារាំង

២). ១៩៥៣ - បច្ចុប្បន្ន៖ ការព្យាយាមកសាងប្រព័ន្ធច្បាប់ខ្មែរឱ្យមានលក្ខណៈខ្មែរ ដែលយើងអាចបែងចែកជា៣ ដំណាក់កាលចម្បង៖

- សម័យសង្គមរាស្ត្រនិយម៖ កម្ពុជាទទួលបានឯករាជ្យនិងព្យាយាមកសាងប្រព័ន្ធច្បាប់របស់ខ្លួនតាមរយៈ៖
  - វិសោធនកម្មរដ្ឋធម្មនុញ្ញឆ្នាំ១៩៤៧ ឱ្យមានលក្ខណៈខ្មែរ (១៩៥៧)
  - ព្រះមហាក្សត្រ មានសិទ្ធិផ្តួចផ្តើមធ្វើច្បាប់ (មានលក្ខណៈជាខ្មែរ លទ្ធិទេវរាជ)
  - ក្រមនិងច្បាប់មួយចំនួនត្រូវបានរៀបចំឡើង៖ ក្រមព្រហ្មទណ្ឌ (១៩៥៥) ក្រមរដ្ឋប្បវេណី (១៩៦៧)។ល។
  - ការព្យាយាមពង្រឹងយន្តការដោះស្រាយជម្លោះតាមរយៈការបង្កើតក្រុមប្រឹក្សាជាន់ខ្ពស់នៃតុលាការដើម្បីធានាការគោរពក្រមសីលធម៌របស់ចៅក្រម។
- ១៩៧០-១៩៩៣៖ កម្ពុជាផុងក្នុងសង្គ្រាមស៊ីវិល ពុំមានឱកាសកសាងប្រព័ន្ធច្បាប់របស់ខ្លួន។
- ១៩៩៣-បច្ចុប្បន្ន៖ ព្រះរាជាណាចក្រកម្ពុជាទី២ត្រូវបានបង្កើតនិងមានរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣។ កម្ពុជាព្យាយាមកសាងប្រព័ន្ធច្បាប់របស់ខ្លួនឡើងវិញតាមរយៈការទទួលជំនួយពីគ្រប់ប្រព័ន្ធច្បាប់៖
  - ធនធានមនុស្ស៖ បញ្ហាវិន្តខ្លះទទួលបានការអប់រំក្នុងប្រព័ន្ធកំមិនឡ ខ្លះប្រព័ន្ធស៊ីវិលឡ បង្កើតបានជាការគិតបែប២ប្រព័ន្ធផ្សេងគ្នា

22

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.១. ទំនើបភាវូបនីយកម្មតាមបែបបារាំង

- វិធីសាស្ត្រក្នុងការរៀបចំច្បាប់៖ បង្កើតទម្រង់នៃការរៀបចំច្បាប់តាមលំអានបារាំង តែខ្លឹមសារច្បាប់មួយចំនួនមានលំអានកំមិនឡ
- ច្បាប់មួយចំនួនទទួលឥទ្ធិពលប្រព័ន្ធកំមិនឡ (ក្រមរដ្ឋប្បវេណី ក្រមនីតិវិធីរដ្ឋប្បវេណី ច្បាប់ក្នុងវិស័យពាណិជ្ជកម្ម) ច្បាប់មួយចំនួនទទួលឥទ្ធិពលប្រព័ន្ធស៊ីវិលឡ (ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ)
- យន្តការស្ថាប័ន៖ មានក្រុមប្រឹក្សាធម្មនុញ្ញតាមលំអានបារាំងក្នុងការត្រួតពិនិត្យធម្មនុញ្ញភាព
- យន្តការដោះស្រាយវិវាទ៖ ស្ថាប័នតុលាការមាន៣កម្រិតមានយុត្តាធិការរដ្ឋប្បវេណីនិងព្រហ្មទណ្ឌ តែមិនមានយុត្តាធិការរដ្ឋបាល ដែលងាកចេញបន្តិចពីប្រព័ន្ធស៊ីវិលឡ។
- ហេតុនេះទើបច្បាប់កម្ពុជាបច្ចុប្បន្នមានអត្តសញ្ញាណបែបចម្រុះពណ៌ និងច្រើនស្រទាប់ដែលលាយឡំដោយច្បាប់បែបប្រពៃណី ច្បាប់បែបទំនើបនិងទស្សនវិជ្ជាច្បាប់បែបចម្រុះដែលស្ថិតនៅឡាយលាយឡំគ្នា។

23

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.២. គុណតម្លៃទំនើប និងគុណតម្លៃទៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់

- ក. ទស្សនាទាន និងការវិវត្ត៖
  - មានទំនាក់ទំនងផ្សារភ្ជាប់ឫសគល់ទស្សនវិជ្ជានៃច្បាប់ធម្មជាតិ (Droit Naturel)៖ ប្រទេសក្រិកបុរាណ (ប្រហែលសតវត្សទី ៥-១ មុនគ.ស)ទស្សនវិទូល្បីៗ៖
    - ✓ អារីស្តូត (Aristotle)៖ ច្បាប់ជាការសំដែងមតិនៃយុត្តិធម៌ ច្បាប់របស់មនុស្សគួរតែឆ្លុះបញ្ចាំងពីហេតុផល និងប្រយោជន៍រួម។
    - ✓ ស៊ីសេរ៉ូ (Cicero)៖ ច្បាប់មានឫសគល់នៅក្នុងហេតុផលជាសកល គ្មានទីបញ្ចប់។ គុណតម្លៃនៃយុត្តិធម៌ និងសមភាពគឺជាមូលដ្ឋានគ្រឹះនៃច្បាប់។
  - ការវិវត្តទ្រឹស្តីទស្សនវិជ្ជាសម័យកណ្តាល៖ (សតវត្សទី ១១-១៥ គ.ស.)៖ ទស្សនវិទូ៖ ថូម៉ាស អាគីណាស (Thomas Aquinas)៖ ច្បាប់មានសុពលភាពប្រសិនបើវាស្របនឹងច្បាប់អាទិទេព និងច្បាប់ធម្មជាតិ។ កំណត់ភាពខុសគ្នារវាង៖
    - ✓ Lex aeterna៖ កំណត់នូវគុណតម្លៃសីលធម៌ជាសកល
    - ✓ Lex humana (ច្បាប់មនុស្ស)៖ បទដ្ឋានត្រូវបានចងក្រងដែលឆ្លុះបញ្ចាំងពីគុណតម្លៃ។

24

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.២. គុណតម្លៃទំនើប និងគុណតម្លៃទៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់

- ក. ទស្សនាទាន និងការវិតុ៖
  - ការវិតុទ្រឹស្តីទស្សនវិជ្ជាសម័យទំនើប៖ (សតវត្សទី១៧-១៩ គ.ស)៖ ទស្សនវិទូ
    - ✓ លោក Hugo Grotius (១៥៨៣–១៦៤៥)៖ ច្បាប់ធម្មជាតិដែលមិនទាក់ទងនឹងទ្រឹស្តីសាសនា និងកំណត់គុណតម្លៃសង្គមជាប្រភពនៃច្បាប់។
    - ✓ Jean-Jacques Rousseau (១៧១២–១៧៧៨)៖ ទ្រឹស្តីកិច្ចសន្យាសង្គម, ច្បាប់មានប្រភពមកពីឆន្ទៈរួម និងគុណតម្លៃសង្គម។
    - ✓ Jeremy Bentham, John Austin៖ ទ្រឹស្តី Legal positivism, បានដំទាស់នឹងយុត្តិកម្មផ្អែកលើសីលធម៌ ដោយកំណត់ថា "ច្បាប់ជាបញ្ញា មិនមែនជាគុណតម្លៃទេ"។
  - ប្រភេទធំៗ នៃគុណតម្លៃ៖
    - ✓ គុណតម្លៃជាសកល ៖ គឺជាគុណតម្លៃដែលត្រូវបានកំណត់ថាមានលក្ខណៈថេរ ដាច់ខាត និងមានសមស្របសម្រាប់គ្រប់សម័យកាល និងសង្គមមនុស្សទាំងអស់ ដោយមិនគិតពីវប្បធម៌ សម័យកាល ឬប្រព័ន្ធច្បាប់ឡើយ។ ឫសគល់ទស្សនវិជ្ជា មានឫសគល់នៅក្នុងទ្រឹស្តីច្បាប់ធម្មជាតិ (droit naturel) កំណត់នូវសច្ចភាពសីលធម៌ និងគុណតម្លៃដែល

25

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.២. គុណតម្លៃទំនើប និងគុណតម្លៃទៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់

មាននៅក្នុងធម្មជាតិ និងហេតុផលរបស់មនុស្ស។ ទស្សនវិទូ ដូចជា Aristotle, Thomas Aquinas, Immanuel Kant និង Michel Villey ចាត់ទុកគុណតម្លៃជាសកលថាជាការបង្ហាញពីយុត្តិធម៌ សេចក្តីថ្លៃថ្នូរ ឬសណ្តាប់ធ្នាប់សីលធម៌សមហេតុផល (rational moral order)។

- ✓ គុណតម្លៃតាមសម័យកាល (Valeur temporelle)៖ ជាគុណតម្លៃដែលអាស្រ័យលើបរិបទប្រវត្តិសាស្ត្រ វប្បធម៌ នយោបាយ ឬសេដ្ឋកិច្ចរបស់សង្គមណាមួយ។ គុណតម្លៃនេះវិវត្តទៅតាមពេលវេលា និងឆ្លុះបញ្ចាំងពីការផ្លាស់ប្តូរសង្គម គោលការណ៍រួមនៃសង្គម (Collective Conciousness) និងលក្ខខណ្ឌនយោបាយ។ ឫសគល់ទស្សនវិជ្ជា មានឫសទស្សនវិជ្ជា មានឫសគល់នៅក្នុង Legal Realism (Réalisme juridique) និង Legal Positivism (Positivisme juridique)។ ទស្សនវិទូ Hans Kelsen, Raymond Saleilles និង Jean Carbonnier បានទទួលស្គាល់ថា ច្បាប់ត្រូវតែសម្របខ្លួនទៅនឹងការផ្លាស់ប្តូរគុណតម្លៃរបស់សង្គម។

➢ **ខ. ដំណាក់កាលនៃការផ្លាស់ប្តូរគុណតម្លៃ ទៅបទដ្ឋានគតិយុត្ត៖** មិនមានការកំណត់ជាដំណាក់កាលច្បាស់លាស់នោះទេ និងប្រែប្រួលទៅតាមទស្សនាទានផ្សេងៗគ្នារបស់ទស្សនវិទូ។ តាមទស្សនលោក Jean-Baptiste Jacob (សៀវភៅ La valeur en droit, 2021) បានកំណត់អំពីដំណាក់កាលពី "គុណតម្លៃ → គោលការណ៍ → បទដ្ឋាន"។

26

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.២. គុណតម្លៃទំនើប និងគុណតម្លៃទៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់

- **គ. គោលការណ៍នានាដែលត្រូវបានបញ្ចូលទៅក្នុងបទដ្ឋានគតិយុត្ត៖** គោលការណ៍គ្រឹះមួយចំនួន បានឆ្លងការវិវត្តជាច្រើនសម័យកាល ចាប់តាំងពីការកកើតជាគំនិត ទ្រឹស្តីនានារបស់ទស្សនវិទូ រហូតក្លាយជាគោលការណ៍ត្រូវបានដាក់បញ្ចូលទៅក្នុងបទដ្ឋានគតិយុត្ត។ គោលការណ៍ទាំងនោះ រួមមាន៖
  - គោលការណ៍នីតិរដ្ឋ៖ នីតិ-រដ្ឋបាល (Administrative Law) និង នីតិរដ្ឋ-បាល (Rule of Law)
  - គោលការណ៍យុត្តិធម៌
  - គោលការណ៍សមភាព
  - គោលការណ៍គោរពសេចក្តីថ្លៃថ្នូររបស់មនុស្ស
  - គោលការណ៍ស្មើភាពចំពោះមុខច្បាប់
  - គោលការណ៍សេរីភាពបុគ្គល
  - គោលការណ៍នៃសិទ្ធិរស់រានមានជីវិត
  - គោលការណ៍ប្រយោជន៍សាធារណៈ...។

27

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.២. គុណតម្លៃទំនើប និងគុណតម្លៃទៀម ៖ ភាសាច្បាប់ និង ទស្សនវិជ្ជាច្បាប់

- **ឃ. សុខដុមនីយកម្ម នៃគុណតម្លៃទំនើប និង គុណតម្លៃទៀម**
  - ពិនិត្យ និងចងក្រងប្រព័ន្ធគុណតម្លៃទំនៀម ដែលនៅមានសមានគតិភាពជាមួយប្រព័ន្ធច្បាប់បច្ចុប្បន្ន
  - រៀបចំប្រព័ន្ធគុណតម្លៃបច្ចុប្បន្នកម្ម ទាំងទំនើប និង ទំនៀម ៖ គុណតម្លៃប្រវត្តិសាស្ត្រ និង គុណតម្លៃសាកល
  - ច្បាប់ធម្មជាតិ របស់អារីស្តូត និង សម្មតិសច្ច និង បរមត្ថសច្ច នៃពុទ្ធសាសនា (ហីនយាន មហាយាន វជ្រយាន)
  - គុណតម្លៃសាកល និង គុណតម្លៃសម័យកាល (Valeur universelle/ spirituelle et valeur temporelle)
  - ពីគុណតម្លៃសីលធម៌ ទៅកាន់បទដ្ឋានគតិយុត្ត (valeur morale et valeur normative) ៖ នៅក្នុងបទដ្ឋាន មានគុណតម្លៃសីលធម៌ រីឯ នៅក្នុងគុណតម្លៃសីលធម៌ មានបទដ្ឋាន ៖ បង្កើតឱ្យគ្នាទៅវិញទៅមក អាស្រ័យតាមស្ថានភាពនៃដំណើរកកើត និង ផ្លាស់ប្តូរ របស់សង្គម សេដ្ឋកិច្ច វប្បធម៌ និង ទស្សនវិជ្ជា
  - អនុវត្តច្បាប់តាមមាត្រា (សម្មតិសច្ចៈ) និងអនុវត្តច្បាប់តាមប្រាជ្ញា (បរមត្ថសច្ចៈ) ៖ បកស្រាយច្បាប់តាមពាក្យមាត្រា ឬបកស្រាយច្បាប់តាមស្មារតី នៃច្បាប់
  - តែងច្បាប់ប្រយ័ត្នជាសំណើចរាស្ត្រ (រាជបណ្តាំរបស់ព្រះវររាជមាតា ព្រះទាវ) ៖ ធម្មានុរូបភាព ធម្មានុភាព ធម្មគុណ
  - ដំណើរសុខដុមនីយកម្ម នៃច្បាប់ទំនៀម និង ច្បាប់ទំនើប ប្រៀបដូចជាដំណើរតុល្យការ នៃគុណតម្លៃសម្ភារៈ និង ស្មារតី

28

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.៣. ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

- ពីឆ្នាំ១៩៩៣-បច្ចុប្បន្ន ច្បាប់មានប្រមាណ ៦៧៥
- ច្បាប់ជាសារវ័ន្តមានចំនួន ២៤១ច្បាប់
- ការបែងចែកច្បាប់ទៅតាមនីតិនឹងក្លាយជាកត្តាគន្លឹះក្នុងការគាំទ្រគណៈកម្មការជំនាញទាំង៤



29

២. ទស្សនាទានទំនើបភាគូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)


២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

- បរិបទបារាំង នីតិបែងចែកជាសាខាធំៗចំនួន២គឺ នីតិសាធារណៈនិងនីតិឯកជន។
  - នីតិសាធារណៈ មានវិស័យចម្បងចំនួន១១រួមមាន ១). នីតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ២). នីតិរដ្ឋបាលសាធារណៈ ៣). នីតិអន្តរជាតិ ៤). នីតិអប់រំ ៥). នីតិសុខាភិបាល ៦). នីតិរបបសន្តិសុខសង្គម ៧). នីតិវប្បធម៌ ៨). នីតិបរិស្ថាន ៩). នីតិសន្តិសុខ ១០). នីតិការពារជាតិ និង១១). នីតិព្រហ្មទណ្ឌ។
  - នីតិឯកជនមានវិស័យចម្បងចំនួន៣រួមមាន ១). នីតិរដ្ឋប្បវេណី ២). នីតិពាណិជ្ជកម្ម និង៣). នីតិការងារ។
- បរិបទសកលសម័យបច្ចេកវិទ្យា៥.០ នីតិថ្មីមួយបានលេចរូបឡើងដែលអាចមិនស្ថិតក្នុងការបែងចែកនីតិបែបប្រពៃណីតាមលំអានបារាំង។ នីតិនោះ គឺនីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ។
- បរិបទកម្ពុជា៖ គួររៀបចំជា៣សាខានីតិ គឺ ១). នីតិសាធារណៈ ២). នីតិឯកជន និង ៣). នីតិបច្ចេកវិទ្យានិងវិទ្យាសាស្ត្រ និង ១៥ វិស័យនីតិ
- ផលប្រយោជន៍នៃការធ្វើចំណាត់ថ្នាក់ច្បាប់ទៅតាមសាខានីតិ និងវិស័យនីតិ គឺ៖
  - **ជាក់ច្បាស់ (Clarté)៖** ដោយសារតែច្បាប់មានចំនួនច្រើន ការធ្វើចំណាត់ថ្នាក់ច្បាប់ទៅតាមនីតិជួយចៅក្រម ព្រះរាជអាជ្ញា និងអ្នកអនុវត្តឱ្យងាយស្វែងរកច្បាប់និងងាយអនុវត្ត។
  - **សង្គតិភាពនិងសមានគតិភាព (cohérence, consistence, pertinence)៖** ការធ្វើចំណាត់ថ្នាក់ច្បាប់ទៅតាមនីតិ ងាយឱ្យការតាក់តែងសេចក្តីព្រាងច្បាប់ រៀបចំទៅតាមទម្រង់នៃសាខានៃនីតិ។
  - **វិវាទសមត្ថកិច្ច (Conflict de compétences)៖** ការធ្វើចំណាត់ថ្នាក់ច្បាប់ទៅតាមនីតិ អាចជួយឱ្យកំណត់បានពីស្ថាប័នមានសមត្ថកិច្ចក្នុងការរៀបចំ ការអនុវត្ត និងការធ្វើអធិការកិច្ច ដើម្បីបញ្ចៀសការត្រួតសមត្ថកិច្ចគ្នា។

30

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន



31


២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)
២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន
នីតិ
នីតិ សាធារណៈ
នីតិ ឯកជន
នីតិបច្ចេក វិទ្យានិងវិទ្យាសាស្ត្រ
នីតិសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
នីតិរដ្ឋបាល សាធារណៈ
នីតិ អន្តរជាតិ
នីតិអប់រំ
នីតិ សុខាភិបាល
នីតិបរិស្ថាន
នីតិសន្តិសុខ
នីតិបរិបស្ថិ សុខសង្គម
នីតិ ការពារជាតិ
នីតិ ជប្បធម៌
នីតិ ព្រហ្មទណ្ឌ
នីតិ រដ្ឋប្បវេណី
នីតិ ពាណិជ្ជកម្ម
នីតិ ការងារ
នីតិបច្ចេក វិទ្យានិងវិទ្យាសាស្ត្រ
32

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)

២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

- អ្វីជាគោលការណ៍? អ្វីជាគោលការណ៍គតិយុត្ត?
  - ឧត្តមានុវត្តន៍បារាំង គោលការណ៍គតិយុត្តសំដៅដល់វិធានគ្រឹះមានតម្លៃជាមូលដ្ឋានសម្រាប់រៀបចំច្បាប់និងបទដ្ឋានគតិយុត្តរបស់ប្រទេស។
- គោលការណ៍គតិយុត្តមានតួនាទីចម្បងចំនួន៤គឺ
  - ជាមូលដ្ឋានគ្រឹះក្នុងការរៀបចំច្បាប់និងបទដ្ឋានគតិយុត្ត
  - ជាមូលដ្ឋានគ្រឹះសម្រាប់ស្ថាប័នតុលាការក្នុងការបកស្រាយច្បាប់និងបទដ្ឋានគតិយុត្ត
  - ជាមូលដ្ឋានគ្រឹះសម្រាប់បំពេញបន្ថែមកង្វះចន្លោះនៃច្បាប់និងបទដ្ឋានគតិយុត្ត
  - សម្រាប់ការពារសិទ្ធិនិងសេរីភាពជាមូលដ្ឋានរបស់ប្រជាពលរដ្ឋ។
- បារាំងមានគោលការណ៍គតិយុត្ត២ប្រភេទគឺ
  - គោលការណ៍សរសេរដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និងច្បាប់ជាធរមាន
  - គោលការណ៍ឥតសរសេរដែលភាគច្រើនទាញចេញពីបញ្ញត្តិរដ្ឋធម្មនុញ្ញនិងបញ្ញត្តិច្បាប់ដោយតុលាការកំពូល។
- បរិបទកម្ពុជា៖ សញ្ញាណគោលការណ៍គតិយុត្តពុំមានអ្នកយល់ក្រៅពីអ្នកច្បាប់នោះទេ ហើយក៏មិនមានចែងក្នុងរដ្ឋធម្មនុញ្ញដែរ តែមានបង្កប់ក្នុងស្មារតីនៃបញ្ញត្តិរដ្ឋធម្មនុញ្ញ។ ច្បាប់មួយចំនួនមានជាគោលការណ៍ ច្បាប់ខ្លះពុំមាន តែមានបង្កប់ក្នុងស្មារតីនៃច្បាប់។ បើយើងពិនិត្យច្បាប់ទាំង ២៤១ឱ្យលម្អិត យើងអាចទាញចេញបានជាគោលការណ៍គតិយុត្តបឋមចំនួន ៧០។

33

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ត)


២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន

- នីតិសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ៖ សេរីភាពសេដ្ឋកិច្ច អន្តរាគមន៍របស់រដ្ឋក្នុងទីផ្សារ ការពារសណ្តាប់ធ្នាប់សេដ្ឋកិច្ច សមភាពនិងមិនរើសអើង ការពារប្រតិបត្តិករសេដ្ឋកិច្ច គោលការណ៍គ្រឹះនៃថវិកា (១០យ៉ាង៖ ភាពអាជ្ញា ភាពជឿទុកចិត្តបាន ឯកត្តភាព សកលភាព វិសេសភាព ចីរភាព គណនេយ្យភាព ប្រសិទ្ធភាព តម្លាភាព សមិទ្ធកម្ម)
- នីតិរដ្ឋបាលសាធារណៈ ៖ នីត្យានុកូលភាពរដ្ឋបាល តុល្យការនៃអំណាច រដ្ឋបាលឯកភាព គណនេយ្យភាព
- នីតិអន្តរជាតិ៖ មិនជ្រៀតចូលកិច្ចការផ្ទៃក្នុងរបស់រដ្ឋបរទេស ការគោរពសិទ្ធិមនុស្ស ដោះស្រាយជម្លោះដោយសន្តិវិធី
- នីតិអប់រំ៖ គុណភាពនៃការអប់រំ សេរីភាពខាងសិក្សាធិការ និងសមភាពនៃការអប់រំ ប្រព័ន្ធអប់រំពេញលេញ និងឯកភាព
- នីតិសុខាភិបាល ៖ ការពារសុខភាពរបស់ប្រជាជន គុណភាពនៃសេវាសុខាភិបាល
- នីតិរបបសន្តិសុខសង្គម៖ សមធម៌សង្គម
- នីតិវប្បធម៌ ៖ ការពារនិងថែរក្សាវប្បធម៌
- នីតិបរិស្ថាន៖ អភិវឌ្ឍប្រកបដោយចីរភាព ការបញ្ចៀសការខូចខាតបរិស្ថាននិងធនធានធម្មជាតិ ការចូលរួមជាសាធារណៈ ការទទួលព័ត៌មានបរិស្ថាន និងធនធានធម្មជាតិ ការទទួលខុសត្រូវរបស់បុគ្គលបំពុល ការបង់ថ្លៃរបស់អ្នកប្រើប្រាស់ ការប្រុងប្រយ័ត្នជាមុន កាត់បន្ថយឬទប់ស្កាត់ការខូចខាតដល់បរិស្ថាន សមាហរណកម្មផ្ទៃកបរិស្ថាន
- នីតិសន្តិសុខ៖ រក្សាការពារសណ្តាប់ធ្នាប់សាធារណៈ នីត្យានុកូលភាព បង្ការនិងការពារសន្តិសុខ
- នីតិព្រហ្មទណ្ឌ៖ សមភាពចំពោះមុខច្បាប់ សន្មតថាគ្មានទោស នីត្យានុកូលភាព អនុវត្តច្បាប់ក្នុងពេលវេលា ដែនដីនៃការអនុវត្តច្បាប់ ។ល។

34

២. ទស្សនាទានទំនើបភាវូបនីយកម្ម នៃប្រព័ន្ធច្បាប់កម្ពុជា (ចប់)

២.៣.ចំណាត់ថ្នាក់សាកល្បង នៃប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន



35

៣. មាតិកាឆ្ពោះទៅកសាងអត្តសញ្ញាណនិងបុរេភាពនៃប្រព័ន្ធច្បាប់កម្ពុជា

៣.១. នីតិនិពន្ធវិទ្យា (Legistique)

គោលបំណង និងគោលដៅ

- ប្រសិទ្ធភាពនៃនីតិរដ្ឋ ត្រូវពឹងផ្អែកលើគុណភាពច្បាប់។
- អនុក្រឹត្យលេខ ១៧០ អនក្រ.បក ឆ្នាំ២០២៤ ពាក់ព័ន្ធគោលការណ៍ណែនាំនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្ត កំណត់តែងកសណ្ឋានភាព នៃទម្រង់លិខិតបទដ្ឋានគតិយុត្ត តាមយថាប្រភេទ ដែលមិនគ្រប់គ្រាន់ឡើយ ដ្បិតបទដ្ឋានគតិយុត្តមានគុណភាពបាន ទាល់តែទាំងទម្រង់នៃខ្លឹមសារ ទាំងវិធីសាស្ត្រដើម្បីកំណត់ខ្លឹមសារបទប្បញ្ញត្តិគតិយុត្ត មានគុណភាព។
- ឯកសារទស្សនាទាននេះ មានគោលដៅសិក្សាស្វែងយល់ពីនីតិនិពន្ធវិទ្យា និងពិនិត្យលទ្ធភាពនៃការធ្វើស្តាប័នូបនីយកម្មនីតិនិពន្ធវិទ្យា ដើម្បីលើកកម្ពស់គុណភាពបទដ្ឋានគតិយុត្តកម្ពុជា ព្រមទាំងរក្សាបាននូវអត្តសញ្ញាណច្បាប់ខ្មែរ។

ការវិវត្តន៍នៃនីតិនិពន្ធវិទ្យា

- បានលេចឡើងនៅអំឡុងទសវត្សរ៍ឆ្នាំ១៩៥០ នៅលោកខាងលិច ផ្តើមពីមជ្ឈដ្ឋានសិក្សាធិការ → អនុវត្តក្នុងរដ្ឋបាលសាធារណៈទស្សវត្សរ៍ឆ្នាំ១៩៨០
- បរិបទ៖ វិបត្តិប្រេងឆ្នាំ១៩៧៣ (សង្គ្រាមអ៊ីស្រាអែលនិងអារ៉ាប់) និង១៩៧៩ (បដិវត្តន៍អ៊ីរ៉ង់) និងវិបត្តិសេដ្ឋកិច្ចសកលឆ្នាំ១៩៨២។
- អង់ក្លូសាក់សុង៖ នៅក្នុងទសវត្សរ៍ឆ្នាំ១៩៨០ ការកាត់បន្ថយបទប្បញ្ញត្តិ និង"ការគ្រប់គ្រងរដ្ឋបាលសាធារណៈបែបថ្មី" (New Public Management)
- បារាំង៖ ចាប់ផ្តើមពីសារាចរពាក់ព័ន្ធវិធាននៃការរៀបចំបទដ្ឋានគតិយុត្ត ឆ្នាំ១៩៨៥ → ឆ្នាំ២០១៧ មគ្គទេសក៍នីតិកម្ម (ទ.៧២១)
- គោលដៅលើកកម្ពស់គុណភាពបទដ្ឋានគតិយុត្ត និងកាត់បន្ថយបន្ទុកគតិយុត្ត ដើម្បីលើកកម្ពស់អភិបាលកិច្ច និងជំរុញកំណើនសេដ្ឋកិច្ច។ 36

៣. មាគ៌ាឆ្ពោះទៅកសាងអត្តសញ្ញាណនិងបុរេភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.១. នីតិនិពន្ធវិទ្យា (Legistique)

ឧស្សនាធាតុនៃនីតិនិពន្ធវិទ្យា ចំនួន ២

- ម៉ូដែលអង់ក្លូសាក់សុង
  - ✓ កាត់បន្ថយបន្ទុក ឬចំនួនបទដ្ឋាន (Deregulation) សេរីភាពទីផ្សារ និង ប្រសិទ្ធភាពសេដ្ឋកិច្ច
  - ✓ ឧបករណ៍/វិធីសាស្ត្រ (អភិក្រមសេដ្ឋកិច្ច)៖ RIA, Regulatory Budgeting, Sunset Clauses, ការវាយតម្លៃប្រសិទ្ធភាពនៃការអនុវត្ត ...
- ម៉ូដែលអឺរ៉ុបដែនគោក
  - ✓ លើកកម្ពស់គុណភាពលិខិតបទដ្ឋានគតិយុត្ត (Better Regulation)
  - ✓ ឧបករណ៍/វិធីសាស្ត្រ (វិធីសាស្ត្រគតិយុត្ត)៖ មគ្គទេសក៍នីតិនិពន្ធវិទ្យា, នីតិក្រម, គោលការណ៍និងវិធីសាស្ត្រគតិយុត្តដើម្បីធានាសង្គតិភាព ពិនិត្យានុភាព បញ្ញានុភាព និងសន្តិសុខគតិយុត្ត។
- ជារួម អភិក្រមទាំងពីរ៖ កែលម្អគុណភាពបទដ្ឋាន និង បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ច អាចគាំទ្រគ្នាទៅវិញទៅមក ច្រើនជាងការប្រទាំងប្រទើសគ្នា។
- បច្ចុប្បន្ន ហាក់មានការព្យាយាមភ្ជិតគម្លាតរវាងទស្សនាទានទាំងពីរខាងលើ ដោយមគ្គទេសក៍នីតិនិពន្ធវិទ្យាបារាំង ក៏បញ្ចូលនូវវិធីសាស្ត្រវាយតម្លៃផលប៉ះពាលបទដ្ឋានគតិយុត្ត ដែលស្រដៀងនឹងម៉ូដែលអង់ក្លូសាក់សុង រីឯ ប្រទេសដែលមិនធ្លាប់មានក្រម ក៏បានប្រមូលរៀបចំក្រមការិបនីយកម្ម សម្រាប់វិស័យរដ្ឋបាលជាដើម GAPA (General Administrative Procedure Act) ដើម្បីធានាគុណភាព ឯកភាព និងបញ្ញានុភាព នៃនីតិវិធីរដ្ឋបាល។

37

៣. មាគ៌ាឆ្ពោះទៅកសាងអត្តសញ្ញាណនិងបុរេភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.១. នីតិនិពន្ធវិទ្យា (Légistique)

និយមន័យ និងប្រភេទ

- នីតិនិពន្ធវិទ្យា គឺជាសិល្បៈសាស្ត្រនៃការតាក់តែងបទដ្ឋានគតិយុត្តឱ្យមានគុណភាព។ នីតិនិពន្ធវិទ្យា ក៏ត្រូវបានផ្តល់និយមន័យថាជា វិទ្យាសាស្ត្រអនុវត្ត ដែលមានគោលដៅសិក្សាកំណត់នូវឧត្តមានុវត្តន៍ និងផ្តល់អនុសាសន៍អនុវត្តសម្រាប់ការត្រៀមរៀបចំ (Conception), ការតាក់តែង, ការអនុម័ត និងការអនុវត្តបទប្បញ្ញត្តិគតិយុត្ត។
- នីតិនិពន្ធវិទ្យា ត្រូវបានបែងចែកជាពីរប្រភេទគឺ៖
  - ទី១. នីតិនិពន្ធវិទ្យាទម្រង់ (Légistique formelle)៖ ផ្តោតជាចម្បងលើវិធាននៃការតាក់តែងបទប្បញ្ញត្តិគតិយុត្ត, រចនាសម្ព័ន្ធ, រំហូរគំនិត និងទម្រង់នៃអត្ថបទគតិយុត្ត ព្រមទាំងកំណត់ពីវិធានទម្រង់ដែលកំណត់ការប្រើប្រាស់ភាសាគតិយុត្ត, សមាសធាតុ និងរចនាបទគតិយុត្ត (Style législatif)។ គោលការណ៍ជាសារវន្តនៃនីតិនិពន្ធវិទ្យាទម្រង់ គឺគោលការណ៍បញ្ញានុភាព (Intelligibilité) និងគោលការណ៍ពិនិត្យានុភាព (Accessibilité)។
  - ទី២. នីតិនិពន្ធវិទ្យាសារធាតុឬសម្ភារៈ (Légistique matérielle)៖ កំណត់វិធីសាស្ត្រនិងសិល្បៈសាស្ត្រដើម្បីលើកកម្ពស់គុណភាពនៃខ្លឹមសារបទដ្ឋានគតិយុត្ត។ វិទ្យានេះ មានគោលដៅសិក្សាបញ្ហាផ្សេងៗ ពាក់ព័ន្ធវិធាននិងគុណតម្លៃនានាដែលបង្កើតឡើងដោយបទដ្ឋានគតិយុត្ត, ទស្សនវិជ្ជាច្បាប់ក្នុងទិដ្ឋភាពនីតិវិជ្ជមាន, ការគោរពសមត្ថកិច្ច, សុខដុមភាពជាមួយនឹងក្របខ័ណ្ឌច្បាប់ជាធរមាន, អតិផរណាបទដ្ឋានគតិយុត្ត, មូលដ្ឋានឬមូលហេតុនៃការរៀបចំបទដ្ឋានគតិយុត្ត, ការកែលម្អបទប្បញ្ញត្តិ និងនីតិក្រម, ការបកស្រាយ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់។

38

៣. មាតិកាឆ្លោះទៅកសាងអត្តសញ្ញាណនិងបុរេភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.១. នីតិនិពន្ធវិទ្យា (Legistique)

នីតិនិពន្ធវិទ្យាបង្កប់នូវគោលការណ៍គ្រឹះ យ៉ាងតិច ៩ ដូចតទៅ៖

- **ទី១. គោលការណ៍កាលានុវត្តភាព និងភាពចាំបាច់៖** ជាគោលការណ៍ ដែលតម្រូវឱ្យការរៀបចំច្បាប់ថ្មី គប្បីធ្វើឡើងតែក្នុងករណីដែលមានតម្រូវការចាំបាច់បំផុត និងមានតម្លៃបន្ថែមពិតប្រាកដ ពោលគឺមុននឹងបង្កើតច្បាប់ថ្មី ត្រូវធានាថាច្បាប់នោះ មានមូលដ្ឋាននៃការរៀបចំជាក់លាក់ ដែលអាចជាគោលនយោបាយ ច្បាប់ ឬកាលានុវត្តន៍ភាពផ្សេងទៀត ហើយពុំមានមធ្យោបាយផ្សេងពីក្របខ័ណ្ឌច្បាប់ដែលអាចដំនួសបាន (ពន្យល់និងផ្សព្វផ្សាយ, ពង្រឹងសមត្ថភាពនិងកិច្ចសម្របសម្រួលស្ថាប័ន...)។ ជាឧត្តមានុវត្តន៍នៅបារាំង វិស័យជាសមត្ថកិច្ចនៃច្បាប់ ត្រូវបានបែងចែកចេញពីវិស័យជាសមត្ថកិច្ចនៃលិខិតបទដ្ឋានគតិយុត្តចេញដោយអង្គនីតិប្បញ្ញត្តិ។
- **ទី២. គោលការណ៍នីត្យានុកូលភាព និងឋានានុក្រមគតិយុត្តៈ** មានន័យថា លិខិតបទដ្ឋានគតិយុត្តទាំងឡាយត្រូវតាក់តែងឡើង ដោយគោរពឋានានុក្រមនៃបទដ្ឋានគតិយុត្ត ពោលគឺបទប្បញ្ញត្តិគតិយុត្តនីមួយៗ ត្រូវអនុលោម ឬស្របតាម ក្របខ័ណ្ឌគតិយុត្តដែលមានឋានានុក្រមខ្ពស់ជាង។
- **ទី៣. គោលការណ៍ឧត្តមភាពនៃនីតិវិសេស លើនីតិសាមញ្ញៈ** នីតិវិសេស មានឧត្តមានុភាពលើនីតិសាមញ្ញ សម្រាប់វិស័យ ឬស្ថានភាពជាក់លាក់ដែលកំណត់ដោយនីតិវិសេស។ គោលការណ៍នេះ ធានាសង្គតិភាពនៃវិធានគតិយុត្ត ដោយធានាថា នីតិសាមញ្ញមិនអនុវត្តចំពោះវិស័យ ឬស្ថានភាពជាក់លាក់ដែលជាវិសាលភាពរបស់នីតិវិសេសឡើយ។
- **ទី៤. គោលការណ៍សង្គតិភាព /សមានគតិភាព / (Principe de cohérence / pertinence)៖** បទដ្ឋានគតិយុត្តទាំងឡាយ ត្រូវតាក់តែងឡើង ដោយមានខ្លឹមសារប្រទាក់ក្រឡាគ្នា មិនប្រទាំងប្រទើសគ្នា ឬផ្ទុយគ្នា ឬស្ងួនគ្នា ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងនៃលិខិតបទដ្ឋានគតិយុត្តដែលត្រូវតាក់តែង ទាំងជាមួយលិខិតបទដ្ឋានគតិយុត្តជាធរមានផ្សេងទៀត។ ក្នុងករណីផ្ទុយគ្នានៃបទប្បញ្ញត្តិគតិយុត្ត ត្រូវមានការបញ្ជាក់អំពីបទប្បញ្ញត្តិដែលត្រូវនិរាករ។ 39

៣. មាគ៌ាឆ្ពោះទៅកសាងអត្តសញ្ញាណនិងបុរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.១. នីតិនិពន្ធវិទ្យា (Legistique)

- **ទី៥. គោលការណ៍បញ្ញានុភាព (Principe d'intelligibilité)៖** លិខិតបទដ្ឋានគតិយុត្ត ត្រូវតាក់តែងឡើង ដើម្បីឱ្យប្រជាពលរដ្ឋទូទៅ និងអ្នកអនុវត្តច្បាប់ អាចយល់បាន និងបកស្រាយដូចគ្នា ពោលគឺអត្ថបទច្បាប់ ត្រូវតាក់តែងដោយមានលក្ខណៈសាមញ្ញ ច្បាស់លាស់ មិនស្រពេចស្រពិល។
- **ទី៦. គោលការណ៍សមាមាត្រភាព (Principe de Proportionnalité)៖** លិខិតបទដ្ឋានគតិយុត្ត ត្រូវបង្កើតឡើងតែក្នុងស្ថានភាពចាំបាច់និងសារៈសំខាន់បំផុត ដើម្បីសម្រេចគោលដៅដែលគ្រោងទុក និងពុំត្រូវដាក់កំហិតហួសហេតុដល់ការអនុវត្តសិទ្ធិនិងកាតព្វកិច្ច ឬបង្កើតគុណវិបត្តិច្រើនដល់ពលរដ្ឋនិងធុរជន ជាងបញ្ហាដែលត្រូវដោះស្រាយឡើយ។
- **ទី៧. គោលការណ៍គតិយុត្តភាព (Principe de normativité)៖** បទដ្ឋានគតិយុត្ត កំណត់នូវវិធានដែលបង្កើតអានុភាពគតិយុត្ត និងអាចអនុវត្តបានដោយបង្កើតសិទ្ធិ ឬកាតព្វកិច្ច ដែលមានលក្ខណៈចាប់បង្ខំ បញ្ញា ហាមឃាត់ អនុញ្ញាត ឬដាក់ទណ្ឌកម្ម ដោយពុំកំណត់នូវខ្លឹមសារជាគោលនយោបាយ ការប្តេជ្ញា ការប្រកាសជានិមិត្តរូប ដែលនាំឱ្យបទដ្ឋានគតិយុត្តកាន់តែស្មុគស្មាញនិងពិបាកអនុវត្ត។
- **ទី៨. គោលការណ៍សុវត្ថិភាពគតិយុត្ត (Principe de sécurité juridique)៖** បទដ្ឋានគតិយុត្ត ត្រូវតាក់តែងឡើងប្រកបដោយស្ថេរភាព អាចប្រមើលទុកបាន និងគោរពគោលការណ៍បញ្ញានុភាព ពោលគឺច្បាប់គប្បីមានស្ថិរភាព ចៀសវាងការផ្លាស់ប្តូរដោយគំហុក និងជាគោលការណ៍ពុំអនុវត្តដោយប្រតិសកម្ម។
- **ទី៩. គោលការណ៍ពិនិត្យានុភាព៖** បទដ្ឋានគតិយុត្ត ដែលត្រូវបានអនុម័តនិងប្រកាសដាក់ឱ្យអនុវត្ត ត្រូវតែផ្សព្វផ្សាយ អាចស្វែងរក និងស្វែងយល់បានដោយសាធារណៈជន។ (ច្បាប់សម្រាប់មន្ត្រី ជាគុណតម្លៃប្រពៃណី មក ច្បាប់សម្រាប់ទាំងអស់គ្នា ជាគុណតម្លៃទំនើប)

40

៣. មាតិកាឆ្លោះទៅកសាងអត្តសញ្ញាណនិងបុរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.១. នីតិនិពន្ធវិទ្យា (Legistique)

នីតិនិពន្ធវិទ្យា មានឧបករណ៍ដើម្បីគាំទ្រ ជាសារវន្តចំនួន ៣ ដូចខាងក្រោម÷

- **ឧបករណ៍ទី១. មគ្គទេសក៍នីតិនិពន្ធវិទ្យា៖** ជាឯកសារដែលចងក្រងនូវគោលការណ៍ វិធីសាស្ត្រ និងឧត្តមានុវត្តន៍សម្រាប់គ្រប់គ្រងការតាក់តែងច្បាប់ ដែលមានគោលដៅ ជាសារវន្តយ៉ាងតិច ២ ដូចតទៅ៖
  - *ទី១.ការធ្វើស្តាប់នីយកម្មនៃការរៀបចំបទដ្ឋានគតិយុត្ត៖* ការរៀបចំបទដ្ឋានគតិយុត្តគឺជាការងារដែលស្មុគស្មាញមានលក្ខណៈនិងប្រទាក់ក្រឡាច្រើនជំនាញនិងតួអង្គ ដែលទាមទារឱ្យមានការកំណត់វិធីសាស្ត្រនិងយន្តការច្បាស់លាស់និងត្រឹមត្រូវ តាមបែបវិទ្យាសាស្ត្រ។
  - *ទី២.ការលើកកម្ពស់គុណភាពច្បាប់៖* បទដ្ឋានគតិយុត្តដែលគ្មានគុណភាព អាចមានកម្មវិបាកអវិជ្ជមាន ជាងស្ថានភាពដែលគ្មានបទប្បញ្ញត្តិគតិយុត្តគ្រប់គ្រងទៅទៀត។ បទដ្ឋានគតិយុត្ត ត្រូវមានទាំងគុណភាពទម្រង់ ដោយត្រូវមានភាពច្បាស់លាស់, សាមញ្ញងាយយល់ និងជាក់លាក់ ទាំងគុណភាពនៃខ្លឹមសារ ដោយមានប្រយោជន៍និងចំបាច់ឆ្លើយតបនិងសមស្របទៅនឹងកិច្ចប្រឈមរបស់សង្គមសេដ្ឋកិច្ច។
- គោលនយោបាយវិស័យ និង គោលនយោបាយនីតិកម្ម និង សិល្បសាស្ត្រ និងវិទ្យាសាស្ត្រនីតិនិពន្ធវិទ្យា គឺជាប្រភពនៃការពិនិត្យអំពីភាពចាំបាច់ និង កាលានុវត្តភាព នៃការតាក់តែងច្បាប់ថ្មី ។

41

៣. មាតិកាឆ្លោះទៅកសាងអត្តសញ្ញាណនិងបុរេភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ត)

៣.២. នីតិក្រមវិទ្យា (Codistique/Codification)

- **ឧបករណ៍ទី២. នីតិក្រមវិទ្យា** សំដៅដល់វិទ្យាសាស្ត្រអនុវត្ត ដែលសិក្សានិងកំណត់គោលការណ៍និងវិធីសាស្ត្រគតិយុត្ត ក្នុងការប្រមូលផ្តុំ និងចងក្រងនូវលិខិតបទដ្ឋានគតិយុត្ត ផ្អែកតាមចំណាត់ថ្នាក់អត្ថបទ ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិជ្ជាគតិយុត្ត ដើម្បីសម្រេចបានជាកម្រងឯកសារមួយ ដែលមានមាតិការនុក្រមរួមតែមួយ។នីតិក្រមវិទ្យា អាចរៀបចំចេញជាឯកសារ ជា ៣ ទម្រង់ ពីកម្រិតស្រាល ដល់កម្រិតគ្រប់ជ្រុងជ្រោយ ដូចខាងក្រោម៖
  - **ការចងក្រង (Compilation)៖** ជាការប្រមូលផ្តុំអត្ថបទច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាក់តាមលំដាប់លំដោយ ដោយរៀបចំតាមកម្មវត្ថុគតិយុត្តនិង/ឬកាលប្បវត្តិ និងផ្សៀងផ្ទាត់ធរមានប្បញ្ញត្តិ ដោយធានាឱ្យបាននូវគោលការណ៍ បូរណភាពនៃលិខិតបទដ្ឋានគតិយុត្តដែលស្ថិតនៅជាធរមាន និងសង្គតិភាពនៃការរៀបចំមាតិកានុក្រម។
  - **សង្គមូលភាព (Consolidation)៖** ជាការប្រមូលចងក្រង និងប្រមូលផ្តុំបទប្បញ្ញត្តិច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាធរមាន ដោយបង្ហាញនិង/ឬបញ្ចូលនូវបទដ្ឋានគតិយុត្តដែលវិសោធនកម្ម និងបទដ្ឋានគតិយុត្តនិរាករណ៍ ដោយពុំកែប្រែនូវខ្លឹមសារឡើយ និងធានាឱ្យបាននូវគោលការណ៍ពិនិត្យានុភាព (Accessibilité) ពោលគឺ ដើម្បីសម្រួលដល់ការស្វែងរកនិងស្វែងយល់លិខិតបទដ្ឋានគតិយុត្ត។
  - **ក្រមូបនីយកម្ម (Codification)៖** គឺជាការប្រមូល និងចងក្រងនូវបទប្បញ្ញត្តិគតិយុត្តជាធរមាននានា ទាំងកម្រិតច្បាប់ ទាំងកម្រិតអនុវត្ត ប្រកបដោយរចនាសម្ព័ន្ធជាក់លាក់ តាមតក្កវិជ្ជាគតិយុត្តមួយច្បាស់លាស់ និងក្នុងវិស័យជាក់លាក់ ដើម្បីសម្រេចបានឯកសារមួយ ដែលមានមាតិកានុក្រមរួមតែមួយ ហៅថា "ក្រម។

42

៣. មាតិកាឆ្លោះទៅកសាងអត្តសញ្ញាណនិងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា (ចប់)

៣.៣.ព័ត៌មានវិទ្យានីតិកម្ម

- **ឧបករណ៍ទី៣. ព័ត៌មានវិទ្យានីតិកម្ម** គឺជាការរៀបចំប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន គាំទ្រដល់ការតាក់តែង ការចងក្រង និងការផ្សព្វផ្សាយលិខិតបទដ្ឋានគតិយុត្ត។ ផ្អែកតាមឧត្តមានុវត្តន៍ប្រទេសបារាំង ប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មយ៉ាងតិច ៤ ប្រភេទបាននិងកំពុងចូលរួមគាំទ្រដល់ប្រសិទ្ធភាពនៃការតាក់តែងលិខិតបទដ្ឋានគតិយុត្តគឺ៖

  - **ប្រព័ន្ធគ្រប់គ្រងការរៀបចំនិងអនុម័តបទដ្ឋានគតិយុត្ត SOLON** (Système d'organisation en ligne des opérations normatives) ដែលបាននិងកំពុងបំពេញបន្ថែមដោយប្រព័ន្ធតាក់តែងបទដ្ឋានគតិយុត្ត EDILE (Editeur légistique)។ **EDILE** គឺជាគម្រោងកម្មវិធីឥឌីថលូបនីយកម្មច្បាប់ ជំនួយក្នុងការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត ដើម្បីធានាដល់គុណភាពនិងសង្គតិភាពខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

  - ប្រព័ន្ធគ្រប់គ្រងការផ្សព្វផ្សាយ៖ **Légifrance៖** ជាគេហទំព័រផ្លូវការនៃការ**ផ្សព្វផ្សាយនូវច្បាប់** លិខិតបទដ្ឋានគតិយុត្ត យុត្តិសាស្ត្រ សាលក្រម សាលដីកា និងសេចក្តីសម្រេចនានារបស់តុលាការ។ គេហទំព័រនេះ គឺជាឃ្លាំងនៃព័ត៌មានច្បាប់របស់ប្រទេសបារាំងទាំងមូល ដែលរាល់ច្បាប់ជាធរមានឬច្បាប់ដែលមាន ត្រូវយកមកចុះផ្សាយក្នុងគេហទំព័រនេះ រីឯច្បាប់និរាករណ៍ ឬត្រូវបានធ្វើវិសោធកម្ម ត្រូវបានយកមកចុះផ្សាយនិងរៀបចំទៅតាមវិធីសាស្ត្រតក្កវិជ្ជានៃច្បាប់យ៉ាងច្បាស់លាស់និងសាមញ្ញ។

  - **Vie-Publique.fr៖** ជាគេហទំព័រផ្លូវការដែលបានរៀបចំជាអត្ថបទ**ចំណេះដឹងពាក់ព័ន្ធច្បាប់** គោលនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ដើម្បីជាគុណប្រយោជន៍ដ៏ប្រជាពលរដ្ឋទូទៅក្នុងការយល់ដឹងពីស្ថានការណ៍នៃការវិវត្តច្បាប់ សេដ្ឋកិច្ច និងសង្គមរបស់រដ្ឋ។

  - **Service-public.fr៖** ជាគេហទំព័រផ្លូវការនៃការ**ផ្តល់ព័ត៌មានសេវាសាធារណៈ**របស់រដ្ឋបាលបារាំង ដែលបង្កើតឡើងក្នុងគោលដៅផ្តល់ព័ត៌មាន និងឆ្លើយតបនៅការស្នើនូវបកស្រាយនានាពីសំណាក់អ្នកប្រើប្រាស់សេវា និងណែនាំពីរបៀបប្រើប្រាស់សេវាសាធារណៈដែលអនុញ្ញាតឱ្យសាធារណជនទទួលបានសិទ្ធិ និងជាជំនួយដល់ការយល់ដឹងនិងការអនុវត្តនីតិវិធីរដ្ឋបាល។

  - ទន្ទឹមនេះ នៅបារាំងមានប្រព័ន្ធព័ត៌មានវិទ្យានីតិកម្មជាច្រើនផ្សេងទៀតអាទិ៍ ប្រព័ន្ធបំប្លែងទិន្នន័យច្បាប់និងរដ្ឋបាល STILA (Système de traitement de l'information légale et administrative), ប្រព័ន្ធគ្រប់គ្រងទិន្នន័យច្បាប់ BDJ (Base de donné juridique) និងគម្រោងប្រព័ន្ធសមាហរណទិន្នន័យគតិយុត្តដោយបញ្ញាសម្បនិមិត្ត (Projet THEIA) ជាដើម។

43

៤. សំណួរ និង ពិភាក្សា

៤.១ ឯកសណ្ឋាន និង អត្តសញ្ញាណ នៃប្រព័ន្ធច្បាប់ខ្មែរ

- តើការសិក្សាខាងលើនេះ មានលក្ខណៈជាសារវ័ន្តសម្រាប់រៀបចំជា សេចក្តីព្រាង ទស្សនាទាន នៃការកសាងឯកសណ្ឋាន និងអត្តសញ្ញាណ នៃប្រព័ន្ធច្បាប់ខ្មែរ ឬនៅ ?
- តើគួរប្រែក្លាយ ទស្សនាទាននេះជាមគ្គទេសក៍សម្រាប់ពិនិត្យនិងផ្តល់យោបល់អំពីនីត្យានុកូលភាព និងសមានគតិភាពគតិយុត្ត នៅក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សានីតិកម្ម និង អង្គភាពនីតិកម្ម នៃក្រសួង ស្ថាប័ន ដែរឬទេ?
- តើគួររៀបចំនិងអនុវត្តជាប្រព័ន្ធ និង យន្តការស្ថាប័ននីតិកម្ម ឬកែទម្រង់ច្បាប់ យ៉ាងណា ដើម្បីធានាឯកភាព ឬឯកសណ្ឋាន នៃការតាក់តែងបទដ្ឋាន ទាំងទម្រង់ច្បាប់ ទាំងគតិច្បាប់?
- តើការសិក្សានេះមានគុណប្រយោជន៍ ឬចាំបាច់ សម្រាប់បញ្ចូលទៅក្នុងកម្មវិធីសិក្សារបស់សាកលវិទ្យាល័យ/មហាវិទ្យាល័យ ច្បាប់ ដែរឬទេ?

44

៤. សំណួរ និង ពិភាក្សា (ចប់)

៤.២ ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់ខ្មែរ

- គុណតម្លៃទំនៀម/ប្រពៃណី និងគុណតម្លៃទំនើប៖ សិក្សា ចងក្រង និង រៀបចំ ពីប្រភពខាងលើ និងផ្សេងទៀត។
- កំណត់មូលដ្ឋានវិនិច្ឆ័យរួមមួយសម្រាប់ធានាសុខដុមនីយកម្ម នៃគុណតម្លៃទាំងពីរ៖ ភាសា និង ទស្សនាទាន
- ចំណាត់ថ្នាក់នៃប្រព័ន្ធច្បាប់ខ្មែរ ៖ ៣ សាខា និង ១៥ វិស័យ និង ៧០ គោលការណ៍ គប្បីពិនិត្យជាធាតុចូល សម្រាប់ធានាឯកសណ្ឋាន ឬឯកភាព នៃការបកស្រាយច្បាប់ ផ្សព្វផ្សាយនិងបណ្តុះបណ្តាលច្បាប់ ការអនុវត្តច្បាប់ សំដៅធានាសង្គតិភាព នៃការសិក្សានិងប្រតិបត្តិច្បាប់
- តួនាទីក្រុមប្រឹក្សាអ្នកច្បាប់ និង មុខងារនីតិកម្ម៖ ពិនិត្យនិងផ្តល់យោបល់អំពី ១.នីត្យានុកូលភាព ក្នុងប្រព័ន្ធច្បាប់ ដើម្បីធានាឯកភាព ឯកសណ្ឋានរបស់ប្រព័ន្ធ និង ២.សមានគតិភាពគតិយុត្ត៖ ច្បាប់ព្រាងថ្មី សមស្របនឹងប្រព័ន្ធច្បាប់បច្ចុប្បន្ន ឬតម្រូវការសង្គមបច្ចុប្បន្ន?
- សកម្មភាព/សេវារដ្ឋបាលនិងសាធារណៈ នៅតាមក្រសួងស្ថាប័ន មិនទាន់ឯកភាព អាចឈានទៅរៀបចំ **ក្រមរដ្ឋបាល** ជាស្តង់ដារួម នៃវិធាន និង នីតិវិធីរដ្ឋបាល ដើម្បីធានាឯកភាព ឯកសណ្ឋាន នៃប្រព័ន្ធរដ្ឋបាល?
- សកម្មភាពពាណិជ្ជកម្ម នៅមិនទាន់ស៊ីចង្វាក់ ប្រទាក់ក្រឡាគ្នា នៅតាមក្រសួងស្ថាប័ន អាចឈានទៅរៀបចំ **ក្រមពាណិជ្ជកម្ម** ជាស្តង់ដារប្រតិបត្តិការនៃវិធាន និង នីតិវិធីពាណិជ្ជកម្ម ដើម្បីជំរុញកំណើនសេដ្ឋកិច្ច សហគ្រិនភាព កំណើនការងារ ?

45


សូមគោរពអរគុណ
46

ប្រធានបទទី៣
ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

សម្រួបសម្រួលរួមដោយ ឯកឧត្តមបណ្ឌិតសភាចារ្យ សុក ស៊ីផាន់ណា

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធាន គ.ក.ច.

អនុប្រធានបទ
ស្តីពីការកំណត់ស្តីពីអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា

សម្របសម្រួលដោយ ឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី
អនុប្រធាន និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់

ខ្លឹមសារសង្ខេប

សង្គម ឬប្រទេសនីមួយៗនៅក្នុងពិភពលោក តែងតែត្រូវបានដឹកនាំ និងគ្រប់គ្រងដោយរបបនយោបាយមួយ ដែលមានប្រព័ន្ធច្បាប់មួយសម្រាប់ធានានូវការអនុវត្តរបបនយោបាយនោះ ស្របតាមកត្តាប្រវត្តិសាស្ត្រ កត្តាភូមិសាស្ត្រ និងទំនៀមទម្លាប់។ យោងតាមការអនុវត្តជាក់ស្តែងរបស់បណ្តាប្រទេសនានា ប្រព័ន្ធច្បាប់ត្រូវបានស្គាល់ថាជា «រចនាសម្ព័ន្ធគ្រឹះនៃវិធាន នីតិវិធី និងស្ថាប័ន ដែលប្រទេសនីមួយៗប្រើប្រាស់ ដើម្បីបកស្រាយ និងអនុវត្តច្បាប់» ពោលគឺ "ប្រទេសមួយ មានប្រព័ន្ធច្បាប់មួយ" ។

អាណាចក្រខ្មែរដ៏រុងរឿង មានក្រមព្រះធម្មសាស្ត្រ និងក្រមអចិន្ត្រៃសាស្ត្រសម្រាប់ដឹកនាំ គ្រប់គ្រងនគរ។ ទោះបីជាប្រទេសកម្ពុជា ឆ្លងកាត់អាណានិគមបារាំង និងរបបនយោបាយជាច្រើនរយៈឆ្នាំ ក៏ប៉ុន្តែរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញមានលក្ខណៈប្រជាធិបតេយ្យជឿនលឿន ដែលបានកើតចេញពីឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរគ្រប់និន្នាការនយោបាយ។ សភាធម្មនុញ្ញបានតាក់តែង រក្សាឱ្យមានមកវិញនូវគុណតម្លៃប្រពៃណីខ្មែរ គឺជាតិ សាសនា ព្រះមហាក្សត្រ អមជាមួយគុណតម្លៃធម្មនុញ្ញទំនើប ជាមូលដ្ឋានគ្រឹះ គឺប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ ដោយតាក់តែងបញ្ចូលទាំងស្រុង និងដោយលម្អិតនូវខ្លឹមសារនៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលចែងអំពីគោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា។ ក្នុងដំណើរការអនុវត្តជាក់ស្តែង ការបន្សាំបន្សីគ្នានៃគុណតម្លៃទាំងពីរបានបង្កនូវកម្លាំងសម្របសម្រួល និងជំរុញរួមគ្នា ក្នុងការដោះស្រាយបញ្ហានយោបាយ និងបញ្ហាច្បាប់ដែលបានកើតមានឡើងជាបន្តបន្ទាប់ ដោយរក្សាបាននូវភាពសុខដុមរមនាក្នុងសង្គម។

គុណតម្លៃពិសេសទាំងឡាយរបស់ខ្មែរទាំងនោះ ត្រូវបានដកស្រង់ចេញពីទស្សនវិជ្ជា នៃព្រហ្មញ្ញ សាសនា ពិសេសព្រះពុទ្ធសាសនា ហើយត្រូវបានកែច្នៃឱ្យមានលក្ខណៈខ្មែរជាបន្តបន្ទាប់ដោយបុព្វបុរសខ្មែរ និងត្រូវបានសរសេរបញ្ចូលបន្តិចម្តងៗមកក្នុងក្បួនច្បាប់ និង "ក្រម" ខ្មែរ ក្រោមទម្រង់ជាវិធានសម្រាប់គ្រប់គ្រងរដ្ឋ វិធានសម្រាប់មេដឹកនាំ

និងវិធានសម្រាប់ប្រជាជន។ ការកំណត់បាននូវ គុណតម្លៃខ្មែរ (Khmer Values) ជាកត្តាចាំបាច់ឈានទៅរកការកំណត់ អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា។ ការកំណត់បាននូវ អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា គឺជាកត្តាសត្យានុម័តក្នុងការឆ្ពោះទៅរកការកំណត់អំពីបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា។ បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា គឺស្ថានភាពរក្សាបាននូវ ឧត្តមានុវត្តន៍នៃគុណតម្លៃខ្មែរ (Khmer Values) ក្នុងសុខដុមនីយកម្មនៃការអនុវត្តប្រព័ន្ធច្បាប់កម្ពុជា។

សេចក្តីផ្តើម

ផ្អែកតាមប្រវត្តិសាស្ត្រនិងការទទួលឥទ្ធិពលពីអរិយធម៌ឥណ្ឌា បុរាណវត្ថុ និងព័ត៌មានពីសិលាចារឹក គេអាចដឹងថា ប្រទេសកម្ពុជាមានច្បាប់សម្រាប់គ្រប់គ្រង និងដឹកនាំប្រទេសជាតិ ចាប់តាំងពីសម័យហ្វូណន រហូតដល់សម័យកណ្តាល ដែលកាលនោះ ច្បាប់ក្នុងស្រុកខ្មែរប្រើប្រាស់មាននាមថា **គម្ពីរធម្មសាស្ត្រ ធម្មសាស្ត្រ ឬមនុស្រ្មឹតិ (មនស្មតិ = ច្បាប់មនុ) និងក្រោយមកហៅថា ព្រះធម្មសាស្ត្រ ឬក្រមព្រះធម្មសាស្ត្រ** ដែលមាន ឧត្តមានុភាពគ្របដណ្តប់លើសង្គមទាំងមូល។ យោងតាមសិលាចារឹកប្រាសាទព្រះខ័នកំពង់ស្វាយ K.១៦១ ព្រះបាទស្រីសូរ្យវរ្ម៉ន់ទី១(សូរ្យវរ្ម៉ន់ទី១) បានប្រដូចគម្ពីរសំខាន់ៗក្នុងព្រហ្មញ្ញសាសនាទៅនឹងសរីរាង្គរបស់មនុស្ស។ ព្រះអង្គប្រដូច គម្ពីរកាសៃដូចនឹងជើង គម្ពីរកាព្យដូចនឹងដៃ ទស៌នទាំង៦ដូចនឹងឥន្ទ្រិយគឺរូបកាយ រីឯគម្ពីរធម្មសាស្ត្រប្រដូចនឹងក្បាល (Finot, 1904)។ ក្នុងន័យនេះ គម្ពីរធម្មសាស្ត្រ ត្រូវបានលើកតម្កល់ខ្ពស់ជាងគេ ជាក្បាល ជាខួរក្បាលនៃព្រះរាជា ដើម្បីថែរក្សាព្រះរាជគុណធម៌ ជាព្រះធម្មរាជា ឬព្រះរាជាទ្រង់ធម៌។ ទំនៀមនេះ បានគូសបញ្ជាក់អំពីទស្សនវិជ្ជនយោបាយដឹកនាំប្រទេសផង និងទស្សនវិជ្ជាដឹកនាំខ្លួនតាមបែបជំនឿដ៏ចំណាស់ ឬសាសនា របស់ប្រជារាស្ត្រទូទាំងប្រទេសផង ដោយព្រះរាជវរគម្រូរបស់ព្រះមហាក្សត្រក្នុងការបដិបត្តិ ព្រះរាជធម៌ ឬទសពិធរាជធម៌ ដើម្បីជាមហាកុសល ផ្តល់សេចក្តីសុខក្សេមក្សាន្ត សម្បូរសប្បាយ រីកចម្រើនរុងរឿងដល់អាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។ ប្រព័ន្ធច្បាប់កម្ពុជាបានវិវត្តន៍ជាបន្តបន្ទាប់តាមរយៈការរួមចំណែកពីប្រភពច្បាប់ផ្សេងៗ ដោយចាប់ផ្តើមដំបូងពីបណ្តាច្បាប់ជាទំនៀមទម្លាប់ដើមរបស់អាស៊ី។ ក្រោយមកៗ ច្បាប់របស់បារាំងត្រូវបានណែនាំឱ្យប្រើប្រាស់ក្នុងកំឡុងពេលបារាំងជាប្រទេសអាណានិគម បន្ទាប់មកច្បាប់កុម្មុយនីស្ត ក៏បានជះឥទ្ធិពលទៅលើប្រព័ន្ធច្បាប់កម្ពុជាផងដែរ។ តាមរយៈការផ្លាស់ប្តូររបបនយោបាយជាបន្តបន្ទាប់ ច្បាប់អន្តរកាលរបស់អាជ្ញាធរបណ្តោះអាសន្ននៃអង្គការសហប្រជាជាតិ ចាប់ផ្តើមចាក់ចូលក្នុងប្រព័ន្ធដឹកនាំរបស់កម្ពុជា រហូតដល់សម្រេចបាននូវរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជាច្បាប់កំពូលរបស់ព្រះរាជាណាចក្រកម្ពុជា។

នីតិ គឺជាបណ្តុំនៃវិធានគតិយុត្តដែលមានចំណងសិទ្ធិ និងកាតព្វកិច្ច ដោយមានអានុភាពចាប់បង្ខំលក្ខណៈទូទៅមិនចំពោះ និងមានគោលដៅរៀបចំសណ្តាប់ធ្នាប់សាធារណៈ ឬរបៀបរៀបរយក្នុងសង្គម។ រីឯច្បាប់ក្នុងន័យចង្អៀត គឺជាបទដ្ឋានទាំងឡាយណាដែលអនុម័តដោយអង្គនីតិបញ្ញត្តិ រីឯក្នុងន័យទូលាយ ច្បាប់ជាបទដ្ឋានទាំងឡាយ

ណា ដែលចេញដោយអាជ្ញាធរសាធារណៈ ក្នុងនោះមានអង្គនីតិបញ្ញត្តិ នីតិប្រតិបត្តិ និងតុលាការ។ ក្នុងន័យនេះ ដើម្បីធ្វើការសិក្សាស្រាវជ្រាវ ជជែកវែកញែក ពិភាក្សាគ្នា ឈានទៅដល់ការឯកភាពក្នុងការគោរពប្រតិបត្តិ ទុកជាគ្រឹះនៃប្រព័ន្ធច្បាប់កម្ពុជា គប្បីសិក្សាស្វែងយល់អំពីនីតិធំៗ ចំនួនបីរួមមាន៖

នីតិសាធារណៈ គឺសំដៅទៅលើសំណុំវិធានគតិយុត្តិទាំងឡាយណា ដែលបង្កើតឡើងដើម្បីសម្របសម្រួលទំនាក់ទំនងរវាងបុគ្គលសាធារណៈនិងបុគ្គលសាធារណៈ និងរវាងរដ្ឋនិងបុគ្គលឯកជនក្នុងគោលបំណង ដើម្បីបម្រើផលប្រយោជន៍រួម។

នីតិឯកជន សំដៅដល់បណ្តុំនៃវិធាន ឬបទប្បញ្ញត្តិដែលគ្រប់គ្រងរាល់ទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជននិងបុគ្គលឯកជន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បច្ចុប្បន្នកម្ពុជាបាននឹងកំពុងអនុវត្តក្រមរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅនៃនីតិឯកជនគ្រប់ជណ្តាប់លើទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។

នីតិព្រហ្មទណ្ឌ (នីតិចម្រុះ) គឺជាវិធានដែលមានចែង ឬទទួលស្គាល់ដោយនីតិសាធារណៈ និងនីតិឯកជន។ នីតិព្រហ្មទណ្ឌ ជាមែកធាងនៃនីតិសាធារណៈ ដោយមានតួអង្គព្រះរាជអាជ្ញា ជារាជការតំណាងឱ្យរដ្ឋក្នុងការចោទប្រកាន់ទៅលើជនណាមួយ ឬបុគ្គលមួយដែលប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ។ គ្រប់បទល្មើសទាំងអស់ គឺបង្កប់នូវសំណងរដ្ឋប្បវេណីជាសាច់ប្រាក់ ដែលជាធាតុផ្សំនៃនីតិឯកជន។

ជំពូកទី១.
នីតិសាធារណៈ

ផ្នែកទី១. នីតិរដ្ឋធម្មនុញ្ញ

សិក្សាអំពី " ធម្មនុញ្ញ-ខ្មែរ-និយម "៖ សញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជា តាមលម្អានប្រវត្តិសាស្ត្រ និងវប្បធម៌

ឯកឧត្តម តាំង រតនា អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

១.១. ខ្លឹមសារសង្ខេប

របាយការណ៍សិក្សាស្រាវជ្រាវអំពី ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា ដោយផ្តោតលើករណីសិក្សាអំពី *សញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជា តាមលម្អានប្រវត្តិសា*

ស្ត្រ និងវប្បធម៌ (ធម្មនុញ្ញ-ខ្មែរ-និយម) គឺជាការសិក្សាមួយក្នុងគោលបំណងផ្តល់ធាតុចូល ជាប្រយោជន៍ដល់កិច្ចពិភាក្សាលើប្រធានបទទី៣ ផ្នែកទី១ នៃ សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា។

ករណីសិក្សាដែលបានលើកឡើងក្នុងរបាយការណ៍នេះ អាចជាចំណុចទាញការចាប់អារម្មណ៍ក្នុងចំណោមនីតិបញ្ញវន្ត និងអ្នកនិយមនីតិរដ្ឋធម្មនុញ្ញ ដ្បិតជាការសិក្សាស្រាវជ្រាវផ្នែកនីតិសាស្ត្រ តាមលម្អានប្រវត្តិសាស្ត្រនិងវប្បធម៌របស់ប្រទេសកម្ពុជា ដែលផ្តើមចេញពីការលើកនូវសម្មតិកម្ម អំពីទំនាក់ទំនងរវាងគោលការណ៍ និងទស្សនវិជ្ជាទាំងឡាយ ដែលមានក្នុងទំនៀមទម្លាប់ ប្រពៃណី ជំនឿ សាសនា នៃសង្គមខ្មែរ ផ្សាភ្ជាប់ទៅនឹងវិធានច្បាប់ ដែលកម្ពុជាបាន និងកំពុងប្រតិបត្តិ។

ការសិក្សាស្រាវជ្រាវនេះ នឹងផ្តល់នូវទិន្នន័យទាក់ទងនឹង (១) ចំណោទបញ្ហានៃគុណតម្លៃធម្មនុញ្ញ និយម (The Constitutionalism in Question) (២) ធម្មនុញ្ញនិយមតាមបរិបទ (The Constitutionalism in Context) និង(៣) ធម្មនុញ្ញនិយមក្នុងបរិបទខ្មែរ (The Constitutionalism in Cambodian Context) ដែលអាចផ្តល់នូវប្រយោជន៍ដល់ការសន្និដ្ឋានបានថា *សញ្ញាណធម្មនុញ្ញនិយម* ពិតជាមានវត្តមានក្នុងសង្គមខ្មែរ តាំងពីបុរាណកាល ដែលសញ្ញាណទាំងនោះត្រូវបានរកឃើញ ជាអាទិ៍ក្នុង ក្រមប្រតិបត្តិទសពិធរាជធម៌, ក្រមប្រតិបត្តិព្រហ្មវិហារធម៌, រួមនឹងគោលការណ៍នៃធម្មឯទៀតដែលសង្គមខ្មែរបានគោរពប្រតិបត្ត។

ទឡ្ហីករណ៍ទាំងអម្បាលដែលបានលើកឡើងក្នុងរបាយការណ៍នេះ ក៏បានឆ្លុះបញ្ចាំងអំពីសារៈសំខាន់មិនអាចខ្វះបាននៃ គុណតម្លៃខ្មែរ (Khmer Values) នៅក្នុងប្រព័ន្ធច្បាប់កម្ពុជា ដ្បិតការកំណត់បាននូវ គុណតម្លៃខ្មែរ (Khmer Values) គឺជាកត្តាចាំបាច់ឈានទៅរកការកំណត់ **អត្តសញ្ញាណប្រព័ន្ធច្បាប់. កម្ពុជា** ហើយការកំណត់បាននូវ **អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** គឺជាកត្តាសត្យានុម័តក្នុងការឆ្ពោះទៅរកការកំណត់អំពី **បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**។

១.២. សេចក្តីផ្តើម

ប្រធានបទស្តីអំពីធម្មនុញ្ញនិយម (Constitutionalism) មានការយល់ដោយច្រើនថា គឺជាទស្សនាទានរបស់ពួកបស្ចិមលោក មានខាងសហរដ្ឋអាម៉េរិក និងខាងអឺរ៉ុបជាដើម ហើយបានជះឥទ្ធិពលពេញសកលលោក តាមរយៈនិន្នាការនៃការបង្កើត **រដ្ឋធម្មនុញ្ញ** ជា

ច្បាប់កំពូលរបស់ប្រទេស។ គួរបញ្ជាក់ថា ការស្នើគំនិតសម្រាប់ការសិក្សាស្រាវជ្រាវលើប្រធានបទនេះ ពុំមែនជាបដិវត្តខាងគំនិតធម្មនុញ្ញនិយម ហើយបដិសេធចោលនូវ **គុណតម្លៃធម្មនុញ្ញនិយមទំនើប** (Modern Constitutionalism) ដែលបណ្តាប្រទេសនានាក្នុងសកលលោក បាននិងកំពុងគោរពប្រតិបត្តិនោះឡើយ ក៏ប៉ុន្តែការលើកឡើងនេះគឺជាការសាកល្បងស្វែងរកនូវចម្លើយតបនឹងចម្ងល់៖ **តើជាការពិតទេ ដែលថាប្រទេសកម្ពុជា ជាធ្លាប់ជា មហាអាណាចក្រមួយអស់កាលជាង៦០០ឆ្នាំ ពុំធ្លាប់មានគុណតម្លៃ ឬគោលការណ៍ច្បាប់ ដែលអាចចាត់ទុកថាជាសញ្ញាណនៃរដ្ឋធម្មនុញ្ញ សម្រាប់ការគ្រប់គ្រងនគរ?** ដូច្នេះការសិក្សាវិភាគខាងក្រោមនេះ គឺជាចំណុចចាប់ផ្តើមនៃការដើរ កកាយស្វែងរកនូវ *សញ្ញាណធម្មនុញ្ញនិយម* ក្នុងសង្គមខ្មែរ តាមលម្ហាននៃប្រវត្តិសាស្ត្រ និងវប្បធម៌ នៃប្រទេសកម្ពុជា។

លម្ហានដ៏សំខាន់មួយ ជ្រោមជ្រែងដល់ការពិចារណាលើប្រធានបទខាងលើ គឺមរតកគំនិតរបស់ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** អ៊ឹម ឈុនលឹម អតីតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ដែលបានផ្តួចផ្តើមគំនិតនិងដឹកនាំការសិក្សាស្រាវជ្រាវលើប្រធានបទ **ចរិតលក្ខណៈនៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា** ជានិក្ខេបបទមួយដ៏មានសារៈសំខាន់ដើម្បីធ្វើការកំណត់ឱ្យបានច្បាស់នូវគុណតម្លៃធម្មនុញ្ញ ដែលមានចារឹកទុកក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ឈានទៅរកការឯកភាពខាងស្មារតីក្នុងក្របខ័ណ្ឌជាតិ ធ្វើយ៉ាងណាឱ្យមានសុខដុមនីយកម្មទស្សនាទានគុណតម្លៃធម្មនុញ្ញ និងការលើកកម្ពស់ធម្មនុញ្ញនិយម ស្របតាមបរិបទនៃសង្គមខ្មែរ។ ដើម្បីសម្រេចបាននូវគោលបំណងខាងលើ បន្ទាប់ពីបានសិក្សាស្រាវជ្រាវ និងបានបង្កើតនូវគោលគំនិតជុំវិញប្រធានបទខាងលើ ក្នុងពិធីអបអរសាទរទិវារំលឹកខួប២៧ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាលពីខែកញ្ញា ឆ្នាំ២០២០ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិតប្រធាន** បានរៀបចំសន្និសីទមួយ[៣៤៥] ដើម្បីពិភាក្សាផ្តល់មតិយោបល់លើប្រធានបទ៖ **គុណតម្លៃទំនើប និងគុណតម្លៃខ្មែរដែលមានក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណា ចក្រកម្ពុជា**។ នៅក្នុងវេទិកានោះ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** អ៊ឹម ឈុនលឹម បានធ្វើសេចក្តីសន្និដ្ឋានជារួមមួយដើម្បីកំណត់នូវចរិតលក្ខណៈ គុណភាព និងសមត្ថភាព នៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ យ៉ាងដូច្នេះថា៖

[៣៤៥] សន្និសីទនេះ បានអញ្ជើញវាគ្មិនចំនួន១៤រូប ដែលភាគច្រើនសុទ្ធសឹងជាបញ្ញវន្តទទួលសញ្ញាបត្រជាន់ខ្ពស់ និងមាននិក្ខេបបទបណ្ឌិតពីសាកលវិទ្យាល័យធំៗនៅកម្ពុជា និងពីបណ្តាប្រទេសនានា រួមមានពីប្រទេសបារាំង, អាល្លឺម៉ង់, រុស្ស៊ី, ចិន, ជប៉ុន, សិង្ហបុរី ដើម្បីចូលរួមជជែកពិភាក្សាប្រកបដោយលក្ខណៈបច្ចេកទេស។

" រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ជារដ្ឋធម្មនុញ្ញមានលក្ខណៈប្រជាធិបតេយ្យជឿនលឿន ដែលបានកើតចេញពីឆន្ទៈរួមរបស់ប្រជារាស្ត្រខ្មែរគ្រប់និន្នាការនយោបាយ។ សកាធម្មនុញ្ញបានតាក់តែងរក្សាឱ្យមានមកវិញនូវ គុណតម្លៃប្រពៃណីខ្មែរ (គឺ ជាតិ សាសនា ព្រះមហាក្សត្រ) អមជាមួយគុណតម្លៃធម្មនុញ្ញទំនើប ជាមូលដ្ឋានគ្រឹះ (គឺ ប្រជាធិបតេយ្យ សិទ្ធិមនុស្សនីតិរដ្ឋ) ដោយតាក់តែងបញ្ចូលទាំងស្រុង និងដោយលម្អិតនូវខ្លឹមសារនៃឧបសម្ព័ន្ធទី៥ នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីសដែលចែងអំពីគោលការណ៍នៃរដ្ឋធម្មនុញ្ញថ្មីរបស់កម្ពុជា។ ក្នុងដំណើរការអនុវត្តជាក់ស្តែង ការបន្សាំបន្សុីគ្នានៃគុណតម្លៃទាំងពីរបានបង្កនូវកម្លាំងសម្របសម្រួលនិងជំរុញរួមគ្នា ក្នុងការដោះស្រាយបញ្ហានយោបាយ និងបញ្ហាច្បាប់ដែលបានកើតមានឡើងជាបន្តបន្ទាប់ ដោយរក្សាបាននូវភាពសុខដុមរមនាក្នុងសង្គម។ " [៣៤៦]

ដូច្នេះទាក់ទងនឹងការកំណត់នូវអត្តសញ្ញាណនៃរដ្ឋធម្មនុញ្ញ **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** បានគូសបញ្ជាក់ច្បាស់នូវគុណតម្លៃនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺរួមមាន៖ **គុណតម្លៃប្រពៃណីខ្មែរ (គឺ ជាតិ សាសនា ព្រះមហាក្សត្រ)** អមជាមួយ **គុណតម្លៃធម្មនុញ្ញទំនើប** ជាមូលដ្ឋានគ្រឹះ (**គឺ ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ**)។ ជាមួយគ្នានោះផងដែរ **ឯកឧត្តម កិត្តិនីតិកោសលបណ្ឌិត** អតីតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ធ្លាប់បានផ្តល់អនុសាសន៍យ៉ាងដូច្នេះថា៖ ទាក់ទងនឹងការលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា គួរមានការសិក្សាស្រាវជ្រាវសុីជម្រៅមួយរកឲ្យឃើញនូវ **គុណតម្លៃខ្មែរ** ហើយឯកភាពគ្នាកំណត់យកគុណតម្លៃទាំងនោះមកអនុវត្ត ដើម្បីជាឧត្តមប្រយោជន៍ជាតិតទៅ ដ្បិតការស្គាល់ច្បាស់អំពីគុណតម្លៃខ្មែរ មានន័យថាខ្មែរបានស្គាល់ខ្លួនឯង។ តទៅនេះ គឺជាករណីសិក្សា (Case Study) ស្តីអំពី **សញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជា តាមលម្ហានប្រវត្តិសាស្ត្រ និង**

---

[៣៤៦] សេចក្តីសន្និដ្ឋានខាងលើ គឺជាសមិទ្ធផលខាងផ្នែកទស្សនាទានធម្មនុញ្ញនិយមមួយដ៏មានតម្លៃ និងជាមរតកគំនិតមិនចេះរីងស្ងួត សម្រាប់អ្នកសិក្សាខាងនីតិរដ្ឋធម្មនុញ្ញកម្ពុជា។ មួយវិញទៀត ទស្សនាទានដែលកំណត់អំពីចរិតលក្ខណៈ គុណភាព និងសមត្ថភាព នៃរដ្ឋធម្មនុញ្ញនេះ ត្រូវបានទទួលស្គាល់ដោយថ្នាក់ដឹកនាំកំពូលរបស់ជាតិ និងគ្រប់មជ្ឈដ្ឋានក្នុងសង្គម បន្ទាប់ពីព្រះរាជាណាចក្រកម្ពុជាបានប្រារព្ធរៀបចំព្រះរាជពិធីអបអរសាទរទិវារំលឹកខួប៣០ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា កាលពីឆ្នាំ២០២៣ និងការប្រារព្ធព្រះរាជពិធីសម្ពោធនីតិបុជនីយដ្ឋាន "**វិមានរដ្ឋធម្មនុញ្ញ**" កាលពីឆ្នាំ២០២៤។ ជាការកត់សម្គាល់ ប្រកបដោយមោទនភាព ទស្សនាទាននេះ ត្រូវបាននាំយកទៅឆ្លាក់លើផ្ទាំងសិលាចារឹកនៅឯ**វិមានរដ្ឋធម្មនុញ្ញ** ទុកជាមរតកខាងគំនិត សម្រាប់កូនចៅខ្មែរតទៅ ដូច្នេះទស្សនាទាននេះ បានក្លាយជាផ្នែកមួយដ៏មានសារៈសំខាន់ក្នុងការកសាងសុខដុមនីយកម្មទស្សនាទានធម្មនុញ្ញនិយម ក្នុងបរិបទនៃសង្គមខ្មែរទាំងក្នុងពេលបច្ចុប្បន្ន និងតទៅអនាគត។

វប្បធម៌ ដែលជាចំណែកមួយ ក្នុងការសិក្សាស្វែងយល់អំពីគុណតម្លៃខ្មែរ ទាក់ទងនឹងនីតិរដ្ឋធម្មនុញ្ញ។

អនុលោមតាមគុណតម្លៃនៃរដ្ឋធម្មនុញ្ញដូចប្រារព្ធពីខាងដើម **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញជា *អគ្គនិម្មាបនករ* ផ្តួចផ្តើមគំនិតដឹកនាំការកសាង វិមានរដ្ឋធម្មនុញ្ញ បានណែនាំឲ្យរចនាប្តង់ វិមានរដ្ឋធម្មនុញ្ញ ក្នុងទិដ្ឋភាពអត្ថប្បដិរូបកម្ម ដោយនាំយកនូវទស្សនាទានធម្មនុញ្ញ ឱ្យមកមូលសង្ខេបនៅលើសំណង់ស្ថាបត្យកម្មមួយ ដែលមានសណ្ឋានជាការសំយោគរវាង *ស្ថាបត្យកម្មក្រិក-រ៉ូម៉ាំង* ជាការសម្តែងនូវនិមិត្តរូប *គុណតម្លៃធម្មនុញ្ញ ទំនើប* និង *ស្ថាបត្យកម្មខ្មែរបុរាណ* ជាការសម្តែងនូវ *គុណតម្លៃប្រពៃណីខ្មែរ* ដើម្បីញ៉ាំងឱ្យទស្សនាទានធម្មនុញ្ញ ដូចមាន សរសេរចារឹកក្នុងរដ្ឋធម្មនុញ្ញ ត្រូវបាននិមិត្តទាំងអត្ថរូប និងអត្ថន័យ ភ្ជាប់នឹងសំណង់ វិមានរដ្ឋធម្មនុញ្ញ ជាបូជនីយដ្ឋាន ស្ថិតនៅរៀងគ្នាជាមួយ វិមានឯករាជ្យ និង មណ្ឌបព្រះបរមរូប " ព្រះបរមរតនកោដ្ឋ " បង្កើតបានជា ត្រីម៉ូតិវិមាន តំណាងឱ្យបារចនា ជាតិ សាសនា ព្រះមហាក្សត្រ ជាដួងព្រលឹងនៃព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងព្រះរាជពិធីសម្ពោធវិមានរដ្ឋធម្មនុញ្ញ កាលពីថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ប្រោសប្រទានព្រះបរមរាជឱង្ការថា៖ "*វិមានរដ្ឋធម្មនុញ្ញគឺជានីតិបូជនីយដ្ឋាន ដ៏ពិសិដ្ឋតំណាងឱ្យនិមិត្តរូបនីតិរដ្ឋ ដែលមានរដ្ឋធម្មនុញ្ញជាកំពូលនៃច្បាប់ផងទាំងឡាយ នៅព្រះរាជាណាចក្រ កម្ពុជាយើង។* " ដែលតាមព្រះបរមរាជឱង្ការដ៏វិសេសវិសាលឧត្តមថ្លៃថ្លានៃព្រះអង្គ នាំឲ្យយល់បានថា វិមានរដ្ឋធម្មនុញ្ញ ជា នីតិបូជនីយដ្ឋាន ដ៏ពិសិដ្ឋ ដែលបានបង្ហាញឲ្យឃើញផងដែរ នូវរូបសណ្ឋាននៃប្រព័ន្ធច្បាប់របស់ប្រទេសកម្ពុជា។

១.៣. របកគំហើញ

១.៣.១. ចំណោទបញ្ហានៃគុណតម្លៃធម្មនុញ្ញនិយម (The Constitutionalism in Question)

ធម្មនុញ្ញនិយម (Constitutionalism) មានដំណើរដើមទងពាក់ព័ន្ធនឹងយន្តការនៃការបង្ហាញអំពីឆន្ទៈរួមរបស់ពលរដ្ឋនៅក្នុងរដ្ឋមួយ ដោយបានកំណត់អំពីឧត្តមគតិរបស់ពួកគេ ក្នុងការគ្រប់គ្រងប្រទេសជាតិ តាមរយៈការប្រមូលផ្តុំនូវបណ្តាទស្សនវិជ្ជានយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ដើម្បីប្រយោជន៍ជាតិ និងពលរដ្ឋ ព្រមទាំងដើម្បីការពារសិទ្ធិ និងសេរីភាពរបស់ពលរដ្ឋផងដែរ។ ទ្រឹស្តីនៃធម្មនុញ្ញនិយមរួមចំណែកដ៏

សំខាន់ក្នុងការផ្តល់នូវគោលគំនិត និងគុណតម្លៃជា មូលដ្ឋានក្នុងការតាក់តែងរដ្ឋធម្មនុញ្ញ របស់រដ្ឋនីមួយៗ។ ជាទូទៅ ធម្មនុញ្ញនិយមទំនើប (Modern Constitutionalism) រមែងមានរាប់បញ្ចូលនូវគុណតម្លៃ (Values) **ប្រជាធិបតេយ្យ សិទ្ធិជាមូលដ្ឋាន និងនីតិរដ្ឋ** ដែលគុណតម្លៃទាំងបី សុទ្ធសឹងតែជាគោលគំនិតនៅក្នុងការតាក់តែងច្បាប់កំពូល របស់ប្រទេស។ យ៉ាងណាមិញ មានសំណួរស្រាវជ្រាវមួយដែលចោទឡើង៖ តើធម្មនុញ្ញ និយមមានលក្ខណៈសកលដែរឬទេ ? ចម្លើយយ៉ាងខ្លីគឺ **ធម្មនុញ្ញនិយមមានលក្ខណៈសកលតាមប្រព័ន្ធ ប៉ុន្តែមិនមែនសកលតាមគុណតម្លៃនោះទេ** (The Constitutionalism is universal by its system, but not by its values) !

តោងយើងពិនិត្យមើលប្រវត្តិសាវតារនៃធម្មនុញ្ញនិយមទំនើប ដើម្បីដឹងថាតើធម្ម នុញ្ញនិយមទំនើបនេះមានប្រភពដើមពីណា។ ទោះវាមានប្រភពមកសហរដ្ឋអាម៉េរិក និង ពីបណ្តាប្រទេសនៅអឺរ៉ុបក៏ដោយ វាមិនមែនជាគំរូសកលសម្រាប់ពិភពលោកទាំងមូល នោះទេ។ ពិតណាស់ថា សហរដ្ឋអាម៉េរិកបានងើបចេញពីការត្រួតត្រារបស់អាណានិគម និយមអង់គ្លេស ដូច្នេះហើយទើបបានជារាល់ការជជែកវែកញែក និងអំណះអំណាងរបស់ ស្ថាបនិកនៃរដ្ឋធម្មនុញ្ញសហរដ្ឋ អាម៉េរិក តែងតែផ្អែកលើគំនិតបដិវត្តន៍។[៣៨៧] ចំណែកឯនៅ ប្រទេសបារាំងឯណោះវិញ សង្គមនយោបាយបានកើតមុនរដ្ឋធម្មនុញ្ញ ហើយចន្លោះឆ្នាំ ១៧៨៩ និង១៧៩៩ ការផ្ទុះឡើងនូវបដិវត្តន៍បានបែរឆ្ពោះទៅលុបបំបាត់ចោលនូវរបប រាជានិយម និងគ្រឹះសង្គមនៃរបបនេះតែម្តង។ ដោយសារតែដើមចមនេះហើយ ទើបការ សរសេររដ្ឋធម្មនុញ្ញបានក្លាយជាចំណុចដ៏សំខាន់នៅក្នុងកំណែទម្រង់ស្ថាប័ននយោបាយ បុរាណរបស់បារាំង ហើយបានក្លាយទៅជាកំណែទម្រង់ជាតិ និងរបបសាធារណរដ្ឋក្នុង ទម្រង់ថ្មី។[៣៨៨] ប្រព័ន្ធធម្មនុញ្ញនិយមបានរីកដុះដាលពាសពេញពិភពលោកតាមរយៈ អាណានិគមនិយម និងសាកលភាវូបនីយកម្ម។ ការត្រួតត្រាពីសំណាក់បណ្តាប្រទេស នៅអឺរ៉ុបមកលើប្រទេសនៅតំបន់អាស៊ី អាហ្វ្រិក និងនៅតំបន់ផ្សេងៗទៀតបានបន្សល់ ទុកនូវមរតកផ្នែកប្រព័ន្ធធម្មនុញ្ញនិយម ទាំងក្នុងប្រព័ន្ធច្បាប់រ៉ូមាំង-អាល្លឺម៉ង់ (CIVIL LAW) និងក្នុងប្រព័ន្ធច្បាប់អង់គ្លោសាក់សុង (COMMON LAW)។ ក្រោយសង្គ្រាមលោក លើកទីពីរ ចន្លោះសាកលភាវូបនីយកម្មបានដើរតួនាទីយ៉ាងសំខាន់ ក្នុងការធ្វើឱ្យប្រព័ន្ធ

---

[៣៨៧] Peter N. Stearns *វចនាធិប្បាយនៃសាកលវិទ្យាល័យអុកស្វើត (Oxford) ស្តីពីពិភពលោកសម័យទំនើប* (បោះពុម្ព ផ្សាយដោយសាកលវិទ្យាល័យអុកស្វើត ឆ្នាំ២០០៨)

[៣៨៨] Peter N. Stearns *វចនាធិប្បាយនៃសាកលវិទ្យាល័យអុកស្វើត (Oxford) ស្តីពីពិភពលោកសម័យទំនើប* (បោះពុម្ព ផ្សាយដោយសាកលវិទ្យាល័យអុកស្វើត ឆ្នាំ២០០៨)

ធម្មនុញ្ញនិយមទំនើបមានដំណើរការនៅក្នុងប្រទេសជាច្រើន ក្នុងគោលដៅជំរុញឱ្យមានការផ្តោះប្តូរគ្នាជាសកលនូវចរន្តនយោបាយ សេដ្ឋកិច្ច វប្បធម៌ និងបច្ចេកវិទ្យាព័ត៌មានវិទ្យា និង គមនាគមន៍ (ICT) ដោយហេតុថារដ្ឋធម្មនុញ្ញ ក្រៅអំពីឋានៈជាបទដ្ឋានគតិយុត្តិកំពូលរបស់រដ្ឋមួយ វាក៏ជាបទដ្ឋានកំណត់អត្តសញ្ញាណផ្លូវការ និងគោលនយោបាយរបស់រដ្ឋអធិបតេយ្យមួយ ក្នុងការធ្វើកិច្ចសហប្រតិបត្តិការសកល។ ដូច្នេះអាចនិយាយជារួមបានថា ធម្មនុញ្ញនិយម (Constitutionalism) គឺជាប្រព័ន្ធមានលក្ខណៈសកលក្នុងបរិបទនៃទំនាក់ទំនងអន្តរជាតិ នោះគឺមានន័យថា **ធម្មនុញ្ញនិយមមានលក្ខណៈសកលតាមប្រព័ន្ធ** (The Constitutionalism is universal by its system)។

ទោះជាយ៉ាងនេះក្តី សាវតារជាប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អ និងគុណតម្លៃជាមូលដ្ឋានផ្សេងទៀតរបស់ប្រទេសជាតិមួយ អាចធ្វើឱ្យការប្រតិបត្តិនូវគុណតម្លៃនៃរដ្ឋធម្មនុញ្ញរបស់ខ្លួនមានស្ថានភាពខុសប្លែកពីគ្នា (The Constitutionalism is not universal by its values)។ តួយ៉ាង ប្រទេសជប៉ុនបានប្រកាន់យកប្រជាធិបតេយ្យតាមបែបសហរដ្ឋអាម៉េរិកនៅក្នុងប្រព័ន្ធរដ្ឋធម្មនុញ្ញរបស់ខ្លួន ប៉ុន្តែនៅជប៉ុន ការអនុវត្តការបោះឆ្នោតភាគច្រើនគឺមិនដូចគ្នា ទៅនឹងអ្វីដែលគេធ្វើនៅសហរដ្ឋអាម៉េរិកនោះឡើយ។[៣៤៩] ការអនុវត្តសិទ្ធិមនុស្សនៅសិង្ហបុរី គឺមិនដូចគ្នានឹងប្រទេសប្រជាធិបតេយ្យផ្សេងទៀតឡើយ ដោយសារតែសិង្ហបុរីបានអនុវត្តដោយផ្អែកលើគោលការណ៍នីតិរដ្ឋ ជាជាងគោលការណ៍ប្រជាធិបតេយ្យ។ បណ្តាប្រទេសឥស្លាមបានអនុវត្តគោលគំនិតនៃសិទ្ធិមនុស្សសកល ប៉ុន្តែការអនុវត្តសិទ្ធិស្ត្រីត្រូវតែស្ថិតនៅក្នុងក្របខ័ណ្ឌនៃច្បាប់ឥស្លាម។ រដ្ឋសង្គមនិយម ឬកុម្មុយនីស្ត ដូចជា រុស្ស៊ី ឬចិន ប្រកាន់យកធម្មនុញ្ញនិយមទំនើប ប៉ុន្តែការអនុវត្តគុណតម្លៃទូទៅនៃធម្មនុញ្ញនិយមនេះត្រូវតែមានដែនកំណត់ និងស្របតាមនយោបាយរបស់គណបក្សកុម្មុយនីស្តរបស់ពួកគេ។ ឥណ្ឌាត្រូវបានចាត់ទុកថាជារដ្ឋប្រជាធិបតេយ្យធំជាងគេបំផុតក្នុងពិភពលោក ក៏ប៉ុន្តែការប្រតិបត្តិសាសនាត្រូវបានគេមើលឃើញថានៅមានចន្លោះប្រហោងនៅឡើយ។ សំឡេងឯកច្ឆន្ទ (ឯកមតិភាព) ត្រូវបានចាត់ទុកថាជាគុណជាតិដ៏ប្រសើរសម្រាប់កម្ពុជា ដោយសារតែប្រទេសមួយនេះ បានរងនូវការបំផ្លិចបំផ្លាញជាច្រើនទសវត្សរ៍ដោយសារតែការបែកបាក់សង្គម និងនយោបាយ ប៉ុន្តែផ្ទុយទៅវិញ នៅប្រទេសបារាំងសំឡេងឯកច្ឆន្ទនេះ ត្រូវបានគេចាត់ទុកថាជាសកម្មភាពគប់គិតគ្នា

---

[៣៤៩] លោកសាស្ត្រាចារ្យ យ៉ូស៊ីហារុ ម៉ាតស៊ូរ៉ា (Yoshiharu Matsuura) សាស្ត្រាចារ្យច្បាប់នៃសាកលវិទ្យាល័យណាហ្គោយ៉ា លើកឡើងនៅក្នុងជំនួបសន្ទនាជាមួយអ្នកនិពន្ធ តាំង រតនា កាលពីខែវិច្ឆិកា ឆ្នាំ២០២២។

នៅពេលដែលតំណាងរាស្ត្របានបោះឆ្នោតអនាមិកក្នុងរដ្ឋសភា ដោយសារគេមានបទដ្ឋានស្តីពីការពិភាក្សាដេញដោលក្នុងដំណើរការប្រជាធិបតេយ្យ។[៣៥០] ជាលទ្ធផលធម្មនុញ្ញនិយម គួរត្រូវប្រព្រឹត្តទៅតាមបរិបទ និងកាល:ទេស: (The Constitutionalism shall be discussed in the context) ។ ជាការពិតណាស់ បរិបទផ្សេងគ្នា រមែងនឹងហុចផលជាគុណតម្លៃផ្សេងគ្នា។ ហើយគុណតម្លៃផ្សេងគ្នានេះឯង ដែលនឹងបង្កើតឱ្យមានការអនុវត្តខុសគ្នា។ ការអនុវត្តខុសគ្នានៃធម្មនុញ្ញនិយមបង្កើតបាននូវពិពិធភាពនៃបទពិសោធផ្នែករដ្ឋធម្មនុញ្ញ។ យើងគួរបើកចិត្តទូលាយក្នុងការទទួលស្គាល់ថា ពិពិធភាពនៃបទពិសោធនេះ ក្លាយជាកន្លែងដែលប្រមូលបណ្តុំនៃបទពិសោធល្អៗ សម្រាប់ធ្វើការសិក្សាប្រៀបធៀបចំពោះធម្មនុញ្ញនិយម (Constitutionalism)។

១.៣.២. ធម្មនុញ្ញនិយមតាមបរិបទ (The Constitutionalism in Context)

សញ្ញាណធម្មនុញ្ញនិយមទំនើបមានដើមកំណើតនៅសហរដ្ឋអាមេរិច និងនៅអឺរ៉ុប។ ដូច្នេះ ការពន្យល់អំពីសញ្ញាណនេះនៅក្នុងសង្គមអាស៊ី មិនមែនជាកិច្ចការងាយស្រួលនោះទេ ព្រោះគេពិបាកយល់អំពីទស្សនាទានធម្មនុញ្ញ និយមរវាង *ភាពដូចគ្នាជាសកលនៃរដ្ឋធម្មនុញ្ញ* [៣៥១] និង*ភាពខុសគ្នានៃរដ្ឋធម្មនុញ្ញទៅតាមប្រទេស* ឬរវាង *ទស្សន:អឺរ៉ុបនិយម (Eurocentrism)* និង *ទស្សន:អឺរ៉ាស៊ីនិយម* (*Eurasia centrism*) ឬរវាង *ទំនើបនិយម* និង *បុរាណនិយម (Modernism and Ancienism)* ឬរវាង *សកលនិយម* និង *តំបន់និយម (Universalism and Localism)* ។ Jaclyn L. NEO និង BUI Ngoc Son បានអះអាងថា "*ផ្អែកតាមទស្សន:អឺរ៉ុបនិយម អ្នកសិក្សាស្រាវជ្រាវអំពីរដ្ឋធម្មនុញ្ញ ប្រៀបធៀបភាគច្រើនផ្តោតតែទៅលើប្រព័ន្ធរដ្ឋធម្មនុញ្ញមួយក្រុមតូចដែលមានលក្ខណ:ស្រដៀងគ្នាដូចជាការបែងចែកអំណាច សិទ្ធិសេរីភាព និងការពិនិត្យធម្មនុញ្ញភាពនៃច្បាប់*"។[៣៥២]

---

[៣៥០] ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម អតីតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ផ្តល់អនុសាសន៍ដល់អ្នកនិពន្ធ តាំងរតនា

[៣៥១] Jaclyn L. NEO និង BUI Ngoc Son បានពិភាក្សានៅក្នុងកិច្ចការសិក្សាស្រាវជ្រាវរបស់ពួកគាត់ដែលមានចំណងជើងថា "***រដ្ឋធម្មនុញ្ញពហុនិយម និងបរិបទអាស៊ីអាគ្នេយ៍***" ដែលបានបង្ហាញថា ការប្រើប្រាស់ទស្សន:ប្រព័ន្ធនិយម និងសកលនិយមនៅក្នុងការសិក្សាស្រាវជ្រាវអំពីធម្មនុញ្ញប្រៀបធៀប គឺមាននិន្នាការផ្តោតទៅលើភាពដូចគ្នាជាសកលនៃរដ្ឋធម្មនុញ្ញ។

[៣៥២] Jaclyn L. NEO និង BUI Ngoc Son ***រដ្ឋធម្មនុញ្ញពហុនិយម និងបរិបទអាស៊ីអាគ្នេយ៍*** (Hart Publishing ឆ្នាំ២០១៩)

ភាពដូចគ្នានៃធម្មនុញ្ញនិយមបង្កើតបានជាឯកសណ្ឋានភាពនៃធម្មនុញ្ញនិយម ព្រមទាំងគុណតម្លៃរួមរបស់វាផងដែរ។[៣៥៣]

ផ្អែកលើទស្សនាទាននេះ យើងគួរតែទទួលស្គាល់ថា ការបង្កើតរដ្ឋធម្មនុញ្ញគឺជាកិច្ចដ៏ប្រពៃដើម្បីលើកកម្ពស់សុខដុមនីយកម្មរវាង***អ្នកគ្រប់គ្រង*** និង***រាស្ត្រប្រជា*** ដែលការណ៍នេះ គឺស្របទៅតាមទ្រឹស្តីនៃកិច្ចសន្យាសង្គម ឬម្យ៉ាងវិញទៀត ការបង្កើតរដ្ឋធម្មនុញ្ញនេះ នឹងជួយកាត់បន្ថយគម្លាតរវាងរដ្ឋាភិបាល និងពលរដ្ឋ ដែលនេះគឺជាការកំណត់ព្រំដែននៃអំណាចរបស់រដ្ឋាភិបាល ធ្វើឱ្យមានតុល្យភាពអំណាចរបស់ពលរដ្ឋ។ ពលរដ្ឋជាអ្នកជ្រើសរើសអ្នកតំណាងរបស់ពួកគេ ដូច្នេះ អ្នកតំណាងទាំងនោះ ត្រូវការពារប្រជាពលរដ្ឋពីការរំលោភបំពានទាំងឡាយ។ រដ្ឋធម្មនុញ្ញកំណត់ព្រំដែននៃអំណាចរបស់រដ្ឋាភិបាល ហើយក៏បានផ្តល់លំហធំទូលាយសម្រាប់ពលរដ្ឋនៅក្នុងការអនុវត្តសិទ្ធិ និងសេរីភាពរបស់ពួកគេ ប៉ុន្តែការអនុវត្តសិទ្ធិទាំងនោះ ត្រូវស្ថិតនៅក្នុងរង្វង់នៃវិសាលភាពដែលកំណត់ដោយរដ្ឋធម្មនុញ្ញ។ ដូច្នេះ រដ្ឋធម្មនុញ្ញ បានក្លាយជាឧបករណ៍ដ៏សំខាន់មួយ សម្រាប់ការគ្រប់គ្រងចំណងទាក់ទងគ្នារវាងរដ្ឋាភិបាល និងប្រជាពលរដ្ឋ ក្នុងគោលដៅកសាងសុខដុមនីយកម្មសង្គមជាតិទាំងមូល (for a social harmony)។

ម្យ៉ាងវិញទៀត មានបញ្ហាវន្តផ្អែកនីតិរដ្ឋធម្មនុញ្ញជាច្រើនតែងលើកឡើងថា ចំពោះអ្នកវិទ្យាសាស្ត្រនយោបាយ និងជាពិសេសអ្នកសិក្សាផ្អែកទ្រឹស្តីទំនាក់ទំនងអន្តរជាតិ ការអនុវត្តគោលគំនិតនៃធម្មនុញ្ញនិយមគឺមិនសូវមានគេស្គាល់ និងនៅមានភាពស្រពេចស្រពិលជាច្រើននៅឡើយ។[៣៥៤] បន្ទាប់ពីការសិក្សា និងសង្កេតលើកដំបូងអំពីធម្មនុញ្ញនិយមសកលអស់មួយទសវត្សរ៍កន្លងមក ការសិក្សាទ្រឹស្តីនៅតែបង្ហាញពីកិច្ចខិតខំប្រឹងប្រែងដដែលៗ ដើម្បីផ្តល់នូវនិយមន័យ ដោយរក្សាការសិក្សាអង្កេតថា ប្រធានបទធម្មនុញ្ញនិយមនេះមានភាពស្មុគស្មាញ និងកំពុងស្ថិតក្នុងដំណាក់កាលនៃការបង្កើតនៅឡើយ។ ដោយសារវាជាគោលគំនិត ដែលមានភាពស្រពេចស្រពិលចំពោះមនុស្សមួយចំនួន ហើយបង្កើតឱ្យមាននូវមន្ទិលសង្ស័យជាច្រើន នៅក្នុងចំណោមមនុស្សជាច្រើន ដែលត្រូវការឱ្យមានការដកែវែកញែក ប្រកបដោយការស្ថាបនាផងដែរនោះ ទើបបានជាធម្មនុញ្ញនិយមសកល (Universal Constitutionalism) បានក្លាយទៅជាផ្នែកមួយនៃការ

---

[៣៥៣] -ដដែល-

[៣៥៤] Antje Wiener, Anthony F. Lang JR., James Tully, Miguel Poiares Maduro and Mattias Kumm "ធម្មនុញ្ញនិយមសកល" ដោយគ្រឹះស្ថានបោះពុម្ពសាកលវិទ្យាល័យខេមប្រ៊ីដ ឆ្នាំ២០១២, ទំព័រទី១ ដល់១៥

សិក្សាស្រាវជ្រាវ ដែលពាក់ព័ន្ធទៅនឹងចំណេះដឹងអន្តរវិស័យ។ ដូច្នេះ ធម្មនុញ្ញនិយមសកល គឺជា "**មុខវិជ្ជាសិក្សា**" ពុំមែនជា **រដ្ឋធម្មនុញ្ញ** ជាក់ស្តែងមួយនោះឡើយ។[៣៥៥]

ដោយស្របទៅនឹងគំនិតពិភាក្សាខាងលើ **ធម្មនុញ្ញនិយម** មិនគួរត្រូវបានចាត់ទុកថា ជាគោលគំនិតមានឯកសណ្ឋានភាពនោះទេ ប៉ុន្តែវាគួរណាស់តែត្រូវបានយកទៅធ្វើការពិភាក្សាក្នុងទិដ្ឋភាពពហុទស្សនៈ ទៅតាមពិពិធភាពនៃ**គុណតម្លៃ** របស់ប្រទេសនីមួយៗ។ **ធម្មនុញ្ញនិយម** ជាពាក្យទូទៅដែលអនុវត្តតែក្នុងទ្រឹស្តីប៉ុណ្ណោះ មិនមែនសម្រាប់ការ អនុវត្តជាក់ស្តែងនោះទេ។ យោងតាមការវិភាគផ្នែកភាសាវិទ្យា ពាក្យ Constitutionalism នេះអាចបំបែកចេញជាពីរផ្នែកគឺមួយផ្នែក Constitutional (**ធម្មនុញ្ញ**) និងមួយផ្នែក -ism (**និយម**) ។ តាមបែបភាសាវិទ្យា -ism (**និយម**)[៣៥៦] គឺជាបច្ឆិមបទ ដែលមិននិន្នាការទៅខាងណាមួយឡើយ ហើយដូច្នេះវាមិនមានន័យបន្ថែមដែលទាក់ទងទៅនឹងមនោគមវិជ្ជាទាំងឡាយ ដែលវាកំណត់នោះទេ។ ការកំណត់បែបនេះអាចដឹងតែតាមរយៈការយល់ឃើញរបស់សាធារណជនចំពោះមនោគមវិជ្ជាជាក់លាក់ប៉ុណ្ណោះ។ សម្រាប់គោលគំនិតស្រដៀងគ្នានេះ បើគិតតាមបែបផែនចំណង់ចំណូលចិត្តអាហាររបស់សង្គមនីមួយៗក្នុងពិភពលោកនេះ យើងមានរបៀប និងរសជាតិផ្សេងគ្នាជាច្រើន ប៉ុន្តែវាគួរតែត្រូវបានបែងចែកជាបីប្រភេទ ដែលបែបផែនរបស់យើងសំដៅលើបែបផែនជាសកល ដូចជា "**ការបរិភោគអាហារ**" ដែលជាសកម្មភាពធម្មតារបស់មនុស្សគ្រប់ៗរូប។ ទោះជាយ៉ាងណា មនុស្សក្នុងវប្បធម៌ផ្សេងគ្នា នឹងចូលចិត្តបរិភោគអាហារតាមប្រភេទ និងរសជាតិខុសគ្នា ដែលស្ថិតនៅក្នុងការបែងចែករវាង "**រសជាតិរបស់អ្នក**" (*your taste*) និង "**រសជាតិរបស់ខ្ញុំ**" (*my taste*) ។ ឧទាហរណ៍ៈ ជនជាតិជប៉ុនចូលចិត្តញ៉ាំស៊ូស៊ី, ជនជាតិអ៊ីរ៉ុបចូលចិត្តញ៉ាំ***ឈីស*** និង***ប៊ឺរ*** ខណៈដែលជនជាតិខ្មែរចូលចិត្តញ៉ាំ***ប្រហុក*** ឬ ***សម្លកកូរ***[៣៥៧]។

---

[៣៥៥] -ដដែល-

[៣៥៦] "**និយម**" គឺជាបច្ឆិមបទក្នុងពាក្យអង់គ្លេសជាច្រើន ដែលមកពីបច្ឆិមបទភាសាក្រិកបុរាណ -ισμός (-ismós) ហើយបានយកមកប្រើជាភាសាអង់គ្លេសតាមរយៈភាសាឡាតាំង -ismus និងភាសាបារាំង -isme។ វាមានន័យថា "ការផ្សៀងទៅរក" ឬ "ការធ្វើត្រាប់តាម" ហើយជាញឹកញាប់ត្រូវបានគេប្រើដើម្បីពណ៌នាអំពីទស្សនវិជ្ជា ទ្រឹស្តី សាសនាសកម្មភាពសង្គម សិល្បៈ និងអាកប្បកិរិយា ជាដើម។

[៣៥៧] **សម្លកកូរ** គឺជាសម្លប្រពៃណីខ្មែរ ដែលត្រូវបានចម្អិនពីល្បាយនៃបន្លែច្រើនមុខ សាច់ និងគ្រឿងផ្សេងៗទៀត។ គ្រឿងផ្សំសំខាន់បំផុតដែលត្រូវតែប្រើសម្រាប់សម្លនេះគឺ **អង្គរលើង**។

ដូច្នេះ ធម្មនុញ្ញនិយម (Constitutionalism)គួរតែត្រូវបានលើកឡើង សម្រាប់ការពិភាក្សាក្នុងបរិបទដែលបានប្រៀបធៀបនឹងអាហារលើកឡើងពីខាងលើនេះ។ គំរូនៃ **ធម្មនុញ្ញនិយម** មិនគួរមានទម្រង់តែមួយនោះឡើយ ប៉ុន្តែគួរតែមានច្រើនទម្រង់ ស្របទៅតាមទិដ្ឋភាព "**ធម្មនុញ្ញ-ពួកយើង-និយម**" (Constitutional-"our" ism) និង "**ធម្មនុញ្ញ-មួយណា-និយម**" (Constitutional-"anyone" ism)(ដែល "**មួយណា**" នេះអាចជំនួសដោយ "របស់ប្រទេសនីមួយៗ")។ ហេតុនេះ "**មួយណា-និយម**" (Constitutional-"anyone" ism) អាចបែងចែកជាពីរប្រភេទគឺ "**ធម្មនុញ្ញ-របស់អ្នក-និយម** " (Constitutional- "your" ism) **និង " ធម្មនុញ្ញ-របស់ខ្ញុំ-និយម**" (Constitutional-"my" ism)។ វិធីសាស្ត្រដែលបានលើកឡើងនេះ គួរអនុវត្តចំពោះធម្មនុញ្ញនិយម ដែលមានលក្ខណៈតំបន់និយម (Local Constitutionalism)ទៅតាមប្រទេសនីមួយៗរៀងៗខ្លួន ដូចជា **ធម្មនុញ្ញ-ជប៉ុន-និយម**, **ធម្មនុញ្ញ-បារាំង-និយម** និង **ធម្មនុញ្ញ-អាល្លឺម៉ង់-និយម** ជាដើម។ គំនិតផ្តួចផ្តើមនៃទស្សនៈនេះមិនមែនជាការបដិសេធចោលនូវគុណតម្លៃរួមនៃធម្មនុញ្ញនិយមទំនើប របស់លោកខាងលិចនោះទេ ប៉ុន្តែវាគ្រាន់តែជាគំនិតផ្តួចផ្តើមមួយសម្រាប់និន្នាការថ្មីមួយ ដើម្បីធ្វើការសិក្សាស្រាវជ្រាវបន្ថែមទៀតក្នុងការស្វែងរកគុណតម្លៃ (Local values) ដែលមានលក្ខណៈតំបន់និយម នៃអត្តសញ្ញាណរបស់រដ្ឋនីមួយៗ ដែលទាក់ទងទៅនឹងទស្សនាទានធម្មនុញ្ញនិយម ដើម្បីអាចធ្វើឱ្យធម្មនុញ្ញនិយម មានអត្ថិភាពប្រកបដោយសន្តិសហវិជ្ជមានទៅបាន។ ការគោរពយ៉ាងខ្ជាប់ខ្ជួន និងការយល់ដឹងយ៉ាងពិតប្រាកដអំពី "**របស់អ្នក-និយម**" ("your" ism) និង "**របស់ខ្ញុំ-និយម**" ("my" ism) នឹងបញ្ចៀសបាននូវទំនាស់ខាងគុណតម្លៃ (conflict of values) ហើយវានឹងរួមចំណែកបង្កើតឱ្យមានសុខដុមភាពនៃធម្មនុញ្ញនិយមសកល ដែលនេះគឺជាគុណតម្លៃនៃគោលគំនិត "**របស់យើង-និយម**" ("Our" ism)។

សរុបសេចក្តីមក ធម្មនុញ្ញនិយមតាមទស្សនៈខាងលើនេះ អាចប្រៀបធៀបបានទៅនឹងសួនផ្កាដ៏ស្រស់ស្អាតមួយ ដែលគេទើបតែដាក់ឈ្មោះថា **ធម្មសុខវ័ន**[៣៥៨] ដែលមានផ្ការីកដ៏ស្រស់ស្អាតចម្រុះពណ៌គួរឱ្យជាប់ចិត្ត ដែលនេះយើងអាចប្រៀបធៀបទៅនឹងគុណតម្លៃរដ្ឋធម្មនុញ្ញរបស់ប្រទេសនីមួយៗបាន។ លើសពីនេះ សម្មតិកម្មនេះ អាចជាការត្រួសត្រាយផ្លូវ សម្រាប់ការវិភាគ និងពិភាក្សា **អំពីសញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជា ឬ**

[៣៥៨] ពាក្យថ្មីដែលត្រូវបានបង្កើតឡើងនៅក្នុងអត្ថបទនេះ គឺដើម្បីកំណត់លក្ខណៈពិសេសនៃធម្មនុញ្ញនិយម។ **ធម្មសុខវ័ន** (Dhamma Sukhavana) គឺជាសមាសនាមជាភាសាបាលី ដែល**ធម៌ ឬធម្ម** មានន័យថា "**ច្បាប់" សុខ** មានន័យថា "**សុកមង្គល" វ័ន** មានន័យថា "**សួន** ឬ**ឧទ្យាន**"។ ហេតុនេះ ពាក្យនេះឆ្លុះបញ្ចាំងពីលក្ខណៈពិសេសនៃធម្មនុញ្ញនិយម។

ការសិក្សាអំពីអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ហេតុនេះយើងអាចប្រើប្រាស់វិធីសាស្ត្រ ដោយបញ្ចូលពាក្យ "**ខ្មែរ**"[៣៥៩] នៅចន្លោះពាក្យ "**ធម្មនុញ្ញ**" និងបច្ចិមបទ"**និយម**" ដើម្បីបង្កើតជាពាក្យគន្លឹះស្រាវជ្រាវថ្មីគឺ "**ធម្មនុញ្ញ-ខ្មែរ-និយម**" (Constitutional-Khmer-ism)[៣៦០]។ ជាលទ្ធផល អ្នកសិក្សាស្រាវជ្រាវ អាចធ្វើការសិក្សាឈ្វេងយល់បន្ថែមអំពីគុណតម្លៃធម្មនុញ្ញនិយមនៅកម្ពុជា។

១.៣.៣. ធម្មនុញ្ញនិយមក្នុងបរិបទខ្មែរ (The Constitutionalism in Cambodian Context)

ដើម្បីសិក្សាឈ្វេងយល់ឱ្យកាន់តែស៊ីជម្រៅលើចំណុចនេះ យើងគោងធ្វើការរំលឹកឡើងវិញអំពីការពិភាក្សាអំពីធម្មនុញ្ញនិយមតាមបរិបទ (Constitutionalism in context) ជាពិសេសនៅក្នុងបរិបទខ្មែរតែម្តង ដែលគួរហៅជាពាក្យគន្លឹះថា **ធម្មនុញ្ញ-ខ្មែរ-និយម (Constitutional-Khmer-ism)**។ ការសិក្សានេះនឹងធ្វើការឆ្លុះបញ្ចាំង អំពីការវិភាគលើសញ្ញាណធម្មនុញ្ញនិយម ដែលមានក្នុងសង្គមខ្មែរ តាមលម្ហានប្រវត្តិសាស្ត្រ និងវប្បធម៌។

ផ្អែកលើលក្ខណៈទូទៅនៃរដ្ឋធម្មនុញ្ញ ដែលគេស្គាល់ជាទូទៅ គឺ **រដ្ឋធម្មនុញ្ញ** គឺជាសំណុំវិធាននៃការគ្រប់គ្រងរដ្ឋ ឬជាច្បាប់កំពូលដែលមានឋានានុក្រមខ្ពស់ជាងគេបំផុត ហើយដែលត្រូវបានគោរពនៅក្នុងប្រទេស។ ទាក់ទងនឹងវិធាននៃការគ្រប់គ្រងរដ្ឋនៅកម្ពុជាក្នុងលំអាននៃប្រវត្តិសាស្ត្រ យើងគួរតែក្រឡេកទៅមើលពីស្ថានភាពរបស់កម្ពុជានៅមុនការ

---

[៣៥៩] ពាក្យថា **ខ្មែរ** ជាទូទៅសំដៅលើសញ្ជាតិ និងភាសារបស់ប្រជាជនកម្ពុជា។ ពាក្យ **កម្ពុជា** ជាភាសាខ្មែរ ឬ Cambodia ជាភាសាអង់គ្លេស ឬ Cambodge ជាភាសាបារាំង សុទ្ធតែសំដៅលើប្រទេសរបស់ជនជាតិខ្មែរ។ រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចែងជាលាយ- លក្ខណ៍អក្សរពីពាក្យ **ខ្មែរ** ថាជាពលរដ្ឋកម្ពុជា ជាអក្សរខ្មែរ និងជាភាសាខ្មែរ។

[៣៦០] អ្នកនិពន្ធអត្ថបទនេះ បានផ្តួចផ្តើមណែនាំគំនិតនេះជាលើកដំបូងក្នុងសិក្ខាសាលស្តីពី "**រដ្ឋធម្មនុញ្ញពហុនិយមនៅអាស៊ីអាគ្នេយ៍**" ដែលរៀបចំដោយមជ្ឈមណ្ឌលសិក្សាច្បាប់អាស៊ី (CALS) កាលពីថ្ងៃទី២៧ និង២៨ ខែកក្កដា ឆ្នាំ២០១៧ នៅមហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យជាតិសិង្ហបុរី (Bukit Timah Campus) ដឹកនាំដោយ បណ្ឌិត Jaclyn Neo (សាស្ត្រាចារ្យជំនួយនៃសាកលវិទ្យាល័យជាតិសិង្ហបុរី មហាវិទ្យាល័យច្បាប់) និងបណ្ឌិត Bui Ngoc Son (បណ្ឌិតស្រាវជ្រាវជាន់ខ្ពស់ នៃមជ្ឈមណ្ឌលសិក្សាច្បាប់អាស៊ី មហាវិទ្យាល័យច្បាប់នៃសាកលវិទ្យាល័យជាតិសិង្ហបុរី)។ សិក្ខាសាលានេះគឺជាផ្នែកមួយនៃគម្រោងស្រាវជ្រាវដែលគាំទ្រដោយ CALS។ អ្នកចូលរួមក្នុងសិក្ខាសាលានេះ បានពិភាក្សាអំពីអត្ថបទរបស់វាគ្មិននីមួយៗដែលបានធ្វើបទបង្ហាញអំពីធម្មនុញ្ញនិយមនៃប្រទេសនីមួយៗជាសមាជិកអាស៊ាន (ASEAN) ទាំងដប់ គឺ៖ ព្រុយណេ កម្ពុជា ឥណ្ឌូនេស៊ី ឡាវ ម៉ាឡេស៊ី មីយ៉ាន់ម៉ា ហ្វីលីពីន សិង្ហបុរី ថៃ និង វៀតណាម។ បន្ទាប់មក អ្នកនិពន្ធនៃអត្ថបទនេះ ថែមទាំងបាននាំយកគំនិតនេះមកពិភាក្សាម្តងទៀតនៅក្នុងសិក្ខាសាលាពិសេសនៅ CALE នៃសាកលវិទ្យាល័យណាយ៉ាង នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២០ ក្នុងពេលដែលលោកត្រូវបានអញ្ជើញជា Research Fellow នៅ CALE។ ហើយនេះក៏ជាប្រធានបទមួយក្នុងចំណោមប្រធានបទដទៃទៀតដែលលោកបានយកមកធ្វើបាឋកថា នៅជាជំបណ្ឌិត្យសភាវិជ្ជាជីវៈតុលាការ និងសាលាភូមិន្នរដ្ឋបាលនៅប្រទេសកម្ពុជា ព្រមទាំងបាឋកថានៅសាកលវិទ្យាល័យបញ្ញាសាស្ត្រកម្ពុជាផងដែរ។

ដួលរលំនៃចក្រភពអង្គរ និងមុនការមកដល់នៃអាណានិគមបារាំង ក្នុងឆ្នាំ១៨៦៣។[៣៦១] ព្រះរាជាណាចក្រកម្ពុជាធ្លាប់ជាចក្រភពជាងប្រាំមួយសតវត្សរ៍ក្នុងអំឡុងសម័យអង្គរ (គ.ស. ៨០២-១៤៣១)។[៣៦២] គេអាចធ្វើការសន្និដ្ឋានមួយបានថា ក្នុងហានៈជាចក្រភពខ្មែរដ៏អស្ចារ្យជាងប្រាំរយឆ្នាំនេះ ច្បាស់ណាស់ថាកម្ពុជាប្រាកដជាបានបង្កើតប្រព័ន្ធគ្រប់គ្រងរដ្ឋមួយដ៏រឹងមាំ រួមជាមួយនឹងសំណុំវិធានមួយដ៏មានប្រសិទ្ធភាពសម្រាប់គ្រប់គ្រងអាណាចក្ររបស់ខ្លួន ដែលគេហៅថា "រដ្ឋធម្មនុញ្ញ" នេះឯង។ ដ្បិតមិនមានភស្តុតាងជាលាយលក្ខណ៍អក្សរគ្រប់គ្រាន់ ដើម្បីបញ្ជាក់ថាកម្ពុជាក្នុងអំឡុងជាងប្រាំមួយរយឆ្នាំនៃយុគសម័យអង្គរមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងប្រព័ន្ធច្បាប់ល្អមួយនេះក៏ដោយក្តី ក៏ចម្ងល់ទាំងនេះអាចត្រូវបានពន្យល់តាមរយៈ ភស្តុតាងមួយចំនួនតាមលម្ហានប្រវត្តិសាស្ត្រ និងវប្បធម៌នៅក្នុងសង្គមខ្មែរ ជាពិសេសនៅក្នុងការប្រតិបត្តិសកម្មភាពសង្គម និងជំនឿនានា។ ជាការពិតណាស់ វាជាកិច្ចការដ៏ពិបាកមួយ នៅក្នុងការជីកកកាយរក **សញ្ញាណធម្មនុញ្ញនិយម** (the Notion of the Constitutionalism) ក្នុងទិដ្ឋភាព Localism ឬ Ancienism នៅក្នុងសង្គមខ្មែរ ដ្បិតការប្រតិបត្តិខាងសាសនា និងជំនឿនៃសង្គមខ្មែរ ត្រូវបានកប់យ៉ាងជ្រៅនៅក្នុងវប្បធម៌ និងប្រពៃណីខ្មែរ អស់រាប់ពាន់ឆ្នាំមកហើយ។ ដូច្នេះ ការស្នើគំនិតខាងក្រោមនេះ គឺជាចំណែកមួយនៃកិច្ចខិតខំប្រឹងប្រែងជីកកាយ បើកបង្ហាញនូវសញ្ញាណនៃធម្មនុញ្ញនិយម ក្នុងបរិបទខ្មែរ ដែលបានកប់ក្នុងប្រពៃណី ទំនៀមទម្លាប់ ជំនឿសាសនា តាមលម្ហាននៃប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរៈ

- **ធម៌ជាច្បាប់ក្នុងគោលគំនិតខ្មែរ**

ក្នុងភាសាខ្មែរ ប្រជាជនហៅច្បាប់កំពូលសម្រាប់គ្រប់គ្រងប្រទេសថា **រដ្ឋធម្មនុញ្ញ**។

---

[៣៦១] នៅឆ្នាំ១៨៦៣ បារាំងបានចូលមកកម្ពុជាក្នុងហានៈជាអាណាព្យាបាល តាមព្រះរាជសំណើរបស់ ព្រះបាទនរោត្តម ដែលទ្រង់បានស្នើសុំឱ្យបង្កើតអាណាព្យាបាលបារាំងលើកម្ពុជា ដើម្បីការពារប្រទេសរបស់ទ្រង់ពីប្រទេសសៀម (សព្វថ្ងៃគេស្គាល់ថាថៃ)។រហូតដល់ឆ្នាំ១៨៨៤ កម្ពុជាបានក្លាយជារដ្ឋស្ថិតក្រោមអាណានិគមរបស់បារាំងជាផ្លូវការដោយផ្អែកលើសន្ធិសញ្ញាឆ្នាំ១៨៨៤។

[៣៦២] សម័យអង្គរបានចាប់ផ្តើមឡើងក្នុងឆ្នាំ៨០២ នៃគ.ស. នៅពេលដែលព្រះបាទជ័យវរ្ម័នទី២ បានប្រកាសព្រះអង្គជា "**ស្តេចផែនដី**" និងជា "**ទេវរាជ**" ហើយបានបន្តរហូតដល់ចុងសតវត្សរ៍ទី១៤ នៅពេលអាណាចក្រនេះ បានធ្លាក់ក្រោមការគ្រប់គ្រងរបស់សៀម ជាលើកទីមួយក្នុងឆ្នាំ១៣៥១។ ការងើបបះបោររបស់ខ្មែរប្រឆាំងនឹងរដ្ឋបាលសៀមបាននាំឱ្យមានការធ្លាក់ដុនដាបអង្គរក្នុងឆ្នាំ១៤៣១ បណ្តាលឱ្យខ្មែរត្រូវផ្លាស់ប្តូររាជធានីទៅកន្លែង ផ្សេង។ រួមមានភ្នំពេញ ស្រីសន្ធរ លង្វែក ឧដុង្គ និងក្រោយមកទៀតទៅភ្នំពេញ។

រដ្ឋធម្មនុញ្ញ ជាពាក្យដែលទទួលឥទ្ធិពលពីភាសាបាលី។[៣៦៣] ពាក្យនេះត្រូវបានកំណត់និយមន័យក្នុងវចនានុក្រមខ្មែររបស់ **សម្តេចព្រះសង្ឃរាជ ជួន ណាត ជោតញ្ញាណោ** ថាជាច្បាប់បញ្ញត្តសម្រាប់ប្រទេសនីមួយៗ, ច្បាប់ទុកជាគោលចារឹកក្នុងការគ្រប់គ្រងរដ្ឋនីមួយៗ ដែលសភាបានបញ្ញត្តិតែងតាំងឡើង។[៣៦៤] ប៉ុន្តែ វាពិតជាមានការលំបាកក្នុងការរកឱ្យឃើញថាតើពាក្យនេះមានអត្ថិភាព និងត្រូវបានប្រើប្រាស់មកយូរប៉ុណ្ណា នៅក្នុងសង្គមខ្មែរ។ ទោះជាយ៉ាងណា ពាក្យថា ***ធម្ម (ធម៌)*** ដែលជាពាក្យសំខាន់នៃពាក្យផ្សំ ***រដ្ឋធម្មនុញ្ញ*** (***រដ្ឋ+ធម្ម+មនុញ្ញ***) ត្រូវបានគេស្គាល់ និងប្រើប្រាស់ជាទូទៅដោយប្រជាជនខ្មែរអស់ជាច្រើនសតវត្សមក ហើយ។ ពាក្យថា ***ធម្ម (ធម៌)*** ក៏ត្រូវបានឱ្យនិយមន័យថាជា "**ច្បាប់**" ក្នុងការប្រើប្រាស់នៃភាសាវិទ្យានៅក្នុងបរិបទប្រវត្តិសាស្ត្រ និងវប្បធម៌ខ្មែរ។

ក្នុងចំណោមសិលាចារឹកសំខាន់ៗជាច្រើននៅមុនសម័យអង្គរ និងក្នុងអំឡុងសម័យអង្គរ ក្រៅពីគោលគំនិតសាសនា ពាក្យថា ***ធម្ម (ធម៌)*** ត្រូវបានរកឃើញក្នុងទំនាក់ទំនងរវាងប្រជាជនខ្មែរ និងច្បាប់។ ឧទាហរណ៍ សិលាចារឹកសុវណ្ណភូមិ (លេខ K. ១៤១៩)[៣៦៥] ក្នុងគ.ស.៦៣៣ បានបញ្ជាក់យ៉ាងច្បាស់អំពីអត្ថិភាព និងការប្រើប្រាស់ពាក្យ **ធម្ម** (ច្បាប់)[៣៦៦] ក្នុងសង្គមខ្មែរនាសម័យកាលនោះ។ ពាក្យនេះត្រូវបានរកឃើញនៅក្នុងល្បះមួយក្នុងចំណោមល្បះជាច្រើនទៀត ដែលពណ៌នាអំពីរបស់ **ព្រៀឯត្ត** (បុគ្គលម្នាក់) ដែលបានប្រព្រឹត្តតែកុសលកម្ម (អំពើនៃការគោរព ឬការថ្វាយតង្វាយ) ក្នុងគោលបំណងលើកតម្កើងធម៌ **(ច្បាប់)** នឹងត្រូវបានគេផ្តល់ឈ្មោះថាជា **ទេវតា**។ ខាងក្រោមនេះជាល្បះដែលដកស្រង់ពីសិលាចារឹក៖

---

[៣៦៣] បាលី គឺជាភាសាឥណ្ឌូ-អារ្យែនកណ្តាល ដែលស្ថិតក្នុងក្រុមភាសាប្រាក្រឹត និងជាភាសាដើមនៅឧបទ្វីបឥណ្ឌា។ វាគឺជាភាសាស្លាប់ (dead language) ដែលត្រូវបានគេសិក្សាយ៉ាងទូលំទូលាយ ដោយសារវាជាភាសានៃគម្ពីរព្រះពុទ្ធសាសនាដ៏ចំណាស់ជាច្រើនដែលត្រូវបានរក្សាទុកក្នុងព្រះត្រៃបិដក (Pāli Canon/Tripitaka) ហើយវាក៏ជាភាសាសម្រាប់ប្រើក្នុងពិធីបុណ្យទានរបស់ព្រះពុទ្ធសាសនាថេរវាទផងដែរ។

[៣៦៤] វចនានុក្រមខ្មែររបស់ **សម្តេចសង្ឃរាជ ជួន ណាត** (ភ្នំពេញ ឆ្នាំ១៩៦៨) ទំព័រ៩៧៦

[៣៦៥] ធោម គន្ធា *សិលាចារឹកវត្តគិរីស្តេចគង់ លេខ K១៤១៩៖ ការបកស្រាយ និងការពន្យល់* ទស្សនាវដ្តីកម្ពុជសុរិយា ឆ្នាំទី ៦៦ លេខ៤ (លេខពិសេស) វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ (២០១៩)។

[៣៦៦] សិលាចារឹកនេះត្រូវបានរកឃើញនៅឆ្នាំ២០១៧ នៅក្នុងវត្តគិរីស្តេចគង់ ដែលស្ថិតនៅក្នុងខេត្តកំពង់ស្ពឺ។ សិលាចារឹកនេះបានក្លាយជាសិលាចារឹកដ៏ល្បីល្បាញដោយសារមានចារឹកពាក្យថា "**សុវណ្ណភូមិ**" (ជាពាក្យដែលប្រជាជនកម្ពុជាប្រើប្រាស់ជាទូទៅដើម្បីសម្គាល់ប្រទេសរបស់ខ្លួន។ **សុវណ្ណភូមិ**មានន័យថា **ដែនដីមាស**។ ប្រជាជននៅក្នុងតំបន់អាស៊ីអាគ្នេយ៍ផ្សេងទៀត ដូចជាប្រជាជនសៀម និងប្រជាជនភូមាបានទាមទារថាប្រទេសរបស់ពួកគេក៏ជាសុវណ្ណភូមិដែរ។) ហេតុដូច្នេះហើយ សិលាចារឹកនេះត្រូវបានគេដាក់ឈ្មោះថា **សិលាចារឹកសុវណ្ណភូមិ**។

[ស្លោក] ឯតានិ គោភូធន បូរ្វិកាណិ សវ៌្វាណិ ធម្មាត្ម ឧបាជិជតានិ
បទេ កុលានំ ស្វកុលៃកទីបោ ភ្រៅឯត្ត នាមាទិតទេវតាកុះ

យោងតាមអត្ថិភាពរបស់ ***ធម៌ (ច្បាប់)*** រួមជាមួយនឹងការកោតសរសើរ ចំពោះសកម្មភាពគោរពច្បាប់ដូចដែលបានបញ្ជាក់នៅក្នុងសិលាចារឹកខ្មែរដែលមានអាយុរាប់ពាន់ឆ្នាំខាងលើ គេអាចឃើញថា ប្រជាជនខ្មែរបានស្គាល់ និងប្រើប្រាស់ ***ធម៌ (ច្បាប់)*** មកជាច្រើនពាន់ឆ្នាំហើយ ហេតុនេះគ្មានការសង្ស័យនោះទេថា ពួកគេក៏បានបដិបត្តិធម៌ជាហូរហែរៀងមកក្នុងដំណើរជីវិតរស់នៅប្រចាំថ្ងៃរបស់ពួកគេដែរ។ ចំពោះប្រជាជនខ្មែរ ពាក្យ **ធម្ម** មានន័យលើសពីន័យក្នុងសាសនា ប៉ុន្តែវាពិតជាសំដៅលើច្បាប់នេះឯង ដែលត្រូវបានគេប្រើប្រាស់ក្នុងការណែនាំអំពីឥរិយាបថរបស់ពួកគេឆ្ពោះទៅការប្រព្រឹត្តនូវសីលធម៌ល្អ។ ជាការកត់សម្គាល់ ពាក្យ **ធម៌** ភាគច្រើនត្រូវបានភ្ជាប់ជាមួយឈ្មោះរបស់ស្ថាប័នដែលមានសមត្ថកិច្ចទទួលខុសត្រូវចំពោះច្បាប់របស់រដ្ឋ ឬច្បាប់ប្រពៃណី។ ឧទាហរណ៍ ឈ្មោះរបស់ក្រុមប្រឹក្សាធម្មនុញ្ញ, ក្រសួងយុត្តិធម៌, ក្រសួងធម្មការ និងសាសនា និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាដើម។ ក្រមផ្សេងទៀតដែលបង្រៀនអំពីសីលធម៌ និងវិន័យក៏ភ្ជាប់ពាក្យធម៌ផងដែរ ដូចជា ក្រមខ្មែរបុរាណ[៣៦៧] ទាក់ទងនឹង សីលធម៌, សុជីវធម៌, គុណធម៌, សច្ចធម៌និងក្រមសម្រាប់អ្នកដឹកនាំដែលបានមកពីធម៌ពីរប្រភេទនោះគឺ **ទសពិធរាជធម៌** និង **ព្រហ្មវិហារធម៌**។ ទាំងនេះគឺជាក្រមខ្មែរសំខាន់ៗមួយចំនួន ដែលមានជាប់ពាក់ព័ន្ធនឹងពាក្យ **ធម៌ (ច្បាប់)**។ អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា នីតិវិធីនៃការត្រួតពិនិត្យធម្មនុញ្ញភាពនៃច្បាប់ជាបច្ចាកាល គឺទាក់ទងនឹងពលរដ្ឋខ្មែរនៅក្នុងការស្វែងរកការការពារសិទ្ធិរបស់ពួកគេ តាមរយៈយន្តការនៃការពិនិត្យធម្មនុញ្ញភាពនៃច្បាប់។ ភាពស្របរដ្ឋធម្មនុញ្ញក្នុងពាក្យខ្មែរគឺ **ធម្មនុញ្ញភាព**។ ការយល់ដឹងអំពីធម៌មានអត្ថប្រយោជន៍ក្នុងការលើកកម្ពស់នីតិរដ្ឋនៅកម្ពុជា ដូច្នេះ ការសិក្សាអំពីសញ្ញាណ និងការប្រើប្រាស់ **ធម៌** ក្នុងទស្សនាទានធម្មនុញ្ញនិយម និងក្នុងបរិបទនៃ **ធម្មនុញ្ញខ្មែរនិយម** គឺពិតជាមានមានសារៈសំខាន់ខ្លាំងណាស់។

ប្រពៃណី ជំនឿ និងទស្សនវិជ្ជាសាសនារបស់ខ្មែរ ដូចជាព្រះពុទ្ធសាសនា និងហិណ្ឌូសាសនា មានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយធម្មនុញ្ញនិយម និងថែមទាំងជាមួយនីតិវិធីផ្លូវច្បាប់នានាផងដែរ។ ហេតុនេះ លម្អានប្រវត្តិសាស្ត្រ និងវប្បធម៌ នៃគុណតម្លៃខ្មែរ

[៣៦៧] ទស្សនាទាននេះត្រូវបានលើកឡើងដោយ លោក អ៊ុក រុណារស្មី ក្នុងអំឡុងពេលពិភាក្សាអំពីទំនាក់ទំនងរវាងច្បាប់ និងវប្បធម៌ខ្មែរ កាលថ្ងៃទី២៨ ខែតុលា ឆ្នាំ២០២៣។

គួរតែជាមធ្យោបាយសំខាន់ក្នុងការដឹកកកាយរកឱ្យឃើញនូវសញ្ញាណដ៏គួរឱ្យចាប់អារម្មណ៍នោះទាក់ទងនឹងធម្មនុញ្ញនិយមនៅកម្ពុជា។ អំណះអំណាងខាងលើនេះគឺស្របគ្នាទៅនឹង បណ្ឌិត Francis J. Powers, C.S.V[៣៦៨] ដែលបានចែករំលែកទស្សនៈអំពីទំនាក់ទំនងរវាងសាសនា និងច្បាប់ថា "***សាសនាពិតជាមានទំនាក់ទំនងជាមួយច្បាប់។ សាសនាគឺជាចំណុចសំខាន់នៃសរសៃឈាមច្បាប់របស់យើង។ ឥទ្ធិពលរបស់សាសនាជ្រៀតចូលពេញក្នុងវិស័យច្បាប់។ គោលគំនិតដ៏អស្ចារ្យដែលបង្កើតបានជារចនាសម្ព័ន្ធនៃច្បាប់របស់យើង ទាំងនីតិសាធារណៈ និងនីតិឯកជន គឺជាគោលគំនិតសាសនានេះឯង។ គំនិត និងឧត្តមគតិសាសនា និងសីលធម៌បង្កើតបានជាដួងព្រលឹងនៃមរតកផ្នែកច្បាប់របស់យើង [...]។ សូម្បីតែរដ្ឋធម្មនុញ្ញដំបូងរបស់ប្រទេសនេះ ក៏គេចមិនផុតពីដកស្រង់គំនិតពីសាសនានោះដែរ [...]។***"[៣៦៩] លើសពីនេះទៀត លោកបានសង្កត់ធ្ងន់ថា ធម្មនុញ្ញនិយមគឺជាគោលគំនិតផ្នែកដួងព្រលឹង។[៣៧០] លោកក៏បានមានប្រសាសន៍បន្ថែមថា ក្នុងល្បះមួយដែលបានអង្រួនព្រលឹងមនុស្សអស់រយៈពេលជាច្រើនសតវត្សរ៍ លោក Bracton បានប្រកាសគោលការណ៍រដ្ឋធម្មនុញ្ញដ៏អស្ចារ្យថា "**ព្រះមហាក្សត្រស្ថិតនៅក្រោមព្រះជាម្ចាស់ និងច្បាប់។**" ព្រះមហាក្សត្រស្ថិតនៅក្រោមព្រះជាម្ចាស់ និងច្បាប់ មានន័យថាព្រះមហាក្សត្រត្រូវបានចងភ្ជាប់ដោយច្បាប់អមតៈរបស់ព្រះជាម្ចាស់ តាម **ច្បាប់កម្មផល ច្បាប់ធម្មជាតិ** និង **តាមច្បាប់រដ្ឋ** (The King is under God and the law. The King is under God and the law means the King is bound by the eternal law of God, by the law of reason—the natural law—and by the law of the land.)។ យុត្តិសាស្ត្រអង់គ្លេសក្នុងមជ្ឈិមសម័យក៏មានចែងអំពីច្បាប់ទាំងបីនេះដែរ។[៣៧១]

ជារួម សញ្ញាណនៃពាក្យ **ធម៌** និងទស្សនាទានពាក់ព័ន្ធទាំងឡាយដូចជាគោលការណ៍**ទសពិធរាជធម៌** និង**ព្រហ្មវិហារធម៌** គឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងធម្មនុញ្ញនិយមទំនើប។ ចំពោះប្រជាពលរដ្ឋខ្មែរ ពាក្យថា**ធម៌** ក៏សំដៅដល់អំពើល្អផងដែរ។ ប្រជាជនខ្មែរប្រហែលជាស្គាល់ពាក្យ **ធម៌** ច្រើនជាងពាក្យ **ច្បាប់** ក៏សឹងថាបានហេតុដូច្នេះហើយទើបបានជាការលើកកម្ពស់ការយល់ដឹងអំពី **ធម៌** ប្រាកដជានឹងបានចូល

---

[៣៦៨] លោកធ្លាប់ជាសាស្ត្រាចារ្យនៅសាកលវិទ្យាល័យមីឈីហ្គែន (University of Michigan) ក្នុងឆ្នាំ១៩៤៥ ដែលបានសិក្សាពីទំនាក់ទំនងរវាងសាសនា និងច្បាប់។

[៣៦៩] Francis J. Powers *សាសនា និងច្បាប់* (ទស្សនាវដ្តីច្បាប់សាកលវិទ្យាល័យកាតូលិក ឆ្នាំ១៩៥១)៖ ទំព័រ១១៥-១២១។

[៣៧០] ដដែល

[៣៧១] ដដែល

រួមចំណែកក្នុងដំណើរការលើកកម្ពស់ **ប្រជាធិបតេយ្យ សិទ្ធិមនុស្ស** និង **នីតិរដ្ឋ** នៅកម្ពុជា បានដោយប្រាកដ។

- **ទសពិធរាជធម៌ គឺជាសញ្ញាណនៃគោលការណ៍នីតិរដ្ឋរបស់ខ្មែរ**

(Dasapitha Raja Dhamma —the Notion of Cambodia´ Rule of Law)

ស្របតាមសម្មតិកម្មខាងលើ ចំពោះទំនាក់ទំនងនេះក្នុងបរិបទខ្មែរតាមលម្ហានប្រវត្តិសាស្ត្រ និងវប្បធម៌ព្រះមហាក្សត្រ និងច្បាប់ គឺមិនអាចបំបែកចេញពីគ្នាបានឡើយ។ ព្រះមហាក្សត្រ ឬអ្នកដឹកនាំផ្សេងទៀតនៅកម្ពុជា យ៉ាងហោចណាស់តាំងពីរាជ្យព្រះបាទជ័យវរ្ម័នទី៧[៣៧២] ត្រូវបានគេហៅថា **ធម្មិករាជ** (**ព្រះមហាក្សត្រដែលប្រតិបត្តិតាមធម៌**) នៅពេលដែលពួកលោក បានគោរពយ៉ាងពេញលេញនូវក្រមប្រតិបត្តិដប់ប្រការសម្រាប់អ្នកដឹកនាំ (**ច្បាប់ល្អសម្រាប់អ្នកដឹកនាំ**)។[៣៧៣] **ធម្មិករាជ** មានន័យថា ព្រះមហាក្សត្រ ឬអ្នកដឹកនាំដែលប្រកាន់ខ្ជាប់យ៉ាងតឹងរ៉ឹងនូវច្បាប់ ហើយដើម្បីលើកតម្កើងការគោរពច្បាប់ ពួកលោកផ្ទាល់ត្រូវតែស្ថិតនៅក្រោមអំណាចនៃ**ច្បាប់ (ធម៌)**។ ជាការពិតណាស់ ពាក្យនេះមានន័យថា ព្រះមហាក្សត្រ និងអ្នកដឹកនាំដទៃទៀតក្នុងឋានានុក្រមរដ្ឋបាល គឺគ្មាននរណាម្នាក់អាចស្ថិតនៅពីលើច្បាប់របស់ប្រទេសបានឡើយ។ **ធម្មិករាជ** ត្រូវតែអនុវត្តតួនាទីរបស់ព្រះអង្គឱ្យបានល្អក្នុងការលើកកម្ពស់ឧត្តមប្រយោជន៍ជាតិ និងអាណាប្រជានុរាស្ត្រ ជាពិសេសលើកកម្ពស់សីលធម៌សង្គមក្នុងព្រះរាជាណាចក្រ។ ជានិមិត្តរូប **ធម្មិករាជ** ទ្រង់គង់លើព្រះរាជបល្ល័ង្កដែលតំណាងឱ្យអំណាចផ្ដាច់មុខរបស់ព្រះអង្គ លើទឹកដី និងប្រជានុរាស្ត្រ។ ប៉ុន្តែ ទាំងព្រះរាជបល្ល័ង្កនិងអង្គ **ធម្មិករាជ** ត្រូវតែស្ថិតនៅក្រោម **ព្រះមហាស្វេតច្ឆត្រ** ដែលជាឆត្ររួតពណ៌ាស មានប្រាំបួនថ្នាក់ដែលតំណាងឱ្យច្បាប់។ ព្រះមហាស្វេតច្ឆត្រ គឺជាគ្រឿងរាជសម្បត្តិមួយក្នុងចំណោម **រាជបញ្ចកកុធកណ្ឌ**[៣៧៤] ឬ **រាជកកុធ**

---

[៣៧២] **ព្រះបាទជ័យវរ្ម័នទី៧** (១១២២-១២១៨) គឺជាព្រះមហាក្សត្រនៃចក្រភពខ្មែរ។ ព្រះមហាក្សត្រដ៏អស្ចារ្យមួយអង្គនេះបានរំដោះព្រះរាជាណាចក្រពីការត្រួតត្រារបស់ចក្រភពចម្ប៉ា និងបានកសាងអារិយធម៌អង្គរដ៏រុងរឿងអស្ចារ្យ។ ព្រះអង្គបានយកព្រះទ័យទុកដាក់លើវិស័យព្រះពុទ្ធសាសនា។ ព្រះអង្គបានកសាងប្រាសាទបាយ័ន ដែលជាប្រាង្គប្រាសាទឧទ្ទិសដល់ព្រះពុទ្ធសាសនា។ ព្រះបាទជ័យវរ្ម័នទី៧ ត្រូវបានប្រវត្តិវិទូទទួលស្គាល់ជាទូទៅថាជាព្រះមហាក្សត្រខ្មែរដ៏ខ្លាំងពូកែបំផុតមួយអង្គ ក្នុងប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា។

[៣៧៣] តាំង រតនា បានលើកឡើងនៅក្នុងអត្ថបទរបស់លោកក្នុងឯកសារបោះពុម្ពដោយមូលនិធិឧនរ៉ាដអាដិនណៅអ៊ែរ (KAS)ស្តីពី "**នីតិរដ្ឋធម្មនុញ្ញកម្ពុជា**" ភ្នំពេញ (២០១៧)។

[៣៧៤] បញ្ចកកុធកណ្ឌគឺសំដៅដល់រាជកកុធកណ្ឌទាំងប្រាំសម្រាប់ព្រះមហាក្សត្រកម្ពុជា រួមមាន (១) ព្រះមហាស្វេតច្ឆត្រ (២) ព្រះមហាមកុដរាជ្យ (៣) ព្រះខ័នរាជ្យ (៤) ព្រះវាលវីជនី (ផ្ដិតធ្វើដោយរោមសត្វពណ៌សប្រាំបួនថ្នាក់) និង (៥) ព្រះសុព័ណ៌បាទុកា (ស្បែកជើងមាស)

កណ្ឌទាំងប្រាំ សម្រាប់ព្រះមហាក្សត្រខ្មែរ តាំងពីសម័យបុរាណកាលមក។ ព្រះមហាក្សត្រខ្មែរទ្រង់គ្រងរាជ្យជាផ្លូវការ ដោយប្រើប្រាស់គ្រឿងរាជកកុធកណ្ឌទាំងប្រាំនេះ។ ជាយូរយារណាស់មកហើយ ប្រជាជនខ្មែរមានជំនឿថា **ព្រះមហាស្វេតច្ឆត្រ** (ឆត្ររួតពណ៌សមានប្រាំបួនថ្នាក់ បើគិតទាំងកំពូលគឺមានដប់ថ្នាក់) ជាគ្រឿងរាជសម្បត្តិដ៏ពិសិដ្ឋមួយដែលត្រូវបានជឿថាថែរក្សាដោយអាទិទេពសំខាន់មួយព្រះអង្គ ព្រះនាម **ទេវតារក្សាស្វេតច្ឆត្រ**។ តាមន័យអត្ថប្បដិរូបកម្ម **ទេវតារក្សាស្វេតច្ឆត្រ** នេះគឺជានិមិត្តរូបនៃច្បាប់ និងក្រមប្រតិបត្តិដប់ប្រការរបស់អ្នកដឹកនាំកំពូលក្នុងព្រះនគរខ្មែរ ពោលគឺអង្គព្រះមហាក្សត្រ។ នៅកម្ពុជា **ព្រះទីនាំងទេវាវិនិច្ឆ័យ មហាប្រាសាទ**[៣៧៥] នៃព្រះបរមរាជវាំង[៣៧៦] គឺជាទីប្រតិស្ឋាននៃព្រះរាជបល្ល័ង្ក និងព្រះមហាស្វេតច្ឆត្រ។ ព្រះទីនាំងដ៏សក្តិសិទ្ធិនេះ ត្រូវបានប្រើសម្រាប់ធ្វើពិធីផ្លូវការសំខាន់ៗដូចជា ពិធីគ្រងរាជ្យសម្បត្តិ ព្រះរាជពិធីខាងផ្លូវសាសនា ព្រះរាជសវនាការ ការទូត និងពិធីសច្ចាប្រណិធានជាដើម។

អ្វីដែលគួរឱ្យចាប់អារម្មណ៍បំផុត គឺមានទេវតាជាច្រើនដែលប្រជាជនខ្មែរគោរពបូជា ប៉ុន្តែសម្រាប់រដ្ឋធម្មនុញ្ញកម្ពុជា គឺមានចារឹកតែព្រះនាមទេវតា ជាពិសេសតែមួយអង្គគត់គឺ ***ទេវតារក្សាស្វេតច្ឆត្រ*** ដែលមានចែងក្នុងឧបសម្ព័ន្ធទាំងឡាយនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣។ ការគោរពបូជាទេវតាអង្គនេះ ស្ដែងឡើងនៅក្នុងបទប្បញ្ញត្តិនៃពាក្យសច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និងសមាជិករដ្ឋសភាទាំងអស់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៥, ពាក្យសច្ចាប្រណិធានសម្រាប់នាយករដ្ឋមន្ត្រី និងសមាជិករាជរដ្ឋាភិបាលទាំងអស់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៦ និងពាក្យសច្ចាប្រណិធានសម្រាប់ប្រធាន អនុប្រធាន និងសមាជិកព្រឹទ្ធសភាទាំងអស់ ដូចមានចែងនៅក្នុងឧបសម្ព័ន្ធទី៧។ សច្ចាប្រណិធានគឺជាទម្រង់ប្រពៃណីសម្រាប់ឥស្សរជនជាន់ខ្ពស់នៅក្នុងសង្គមខ្មែរ ដែលត្រូវបានអនុវត្តមកអស់កាលរាប់ពាន់ឆ្នាំ។ មុនពេលមន្ត្រីជាន់ខ្ពស់ទាំងនោះ ចូលកាន់តំណែងជាផ្លូវការ ពួកលោកត្រូវតែធ្វើសច្ចាប្រណិធាន ជាមុនសិន ដើម្បីបញ្ជាក់ពីភាពស្របច្បាប់ និងសុចរិតភាព ក្នុងការដឹកនាំប្រទេសជាតិ។

ដូច្នេះឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានចារឹកចងនូវហ៊ាន:របស់ **ទេវតារក្សាស្វេតច្ឆត្រ** ឲ្យមាន **គុណតម្លៃរដ្ឋធម្មនុញ្ញ** ដែលឥស្សរជនខ្មែរត្រូវតែគោរពធ្វើសច្ចាប្រណិធានក្នុងដំណើរការបង្កើតស្ថាប័នព្រឹទ្ធសភា រដ្ឋសភា និងរាជរដ្ឋាភិបាល។ ប្រសិនបើឥស្សរជន

---

[៣៧៥] ជាព្រះទីនាំងដ៏ធំមួយក្នុងព្រះបរមរាជវាំង ដែលឈ្មោះប្រាសាទនេះមានន័យថា **ទីប្រជុំនៃពពួកទេព**

[៣៧៦] តាំង រតនា "**រដ្ឋធម្មនុញ្ញពហុនិយមនៅកម្ពុជា**" ដោយគ្រឹះស្ថានបោះពុម្ព Hart Publishing ឆ្នាំ២០១៧ ទំព័រ១៨២

ទាំងនោះ មិនធ្វើសច្ចាប្រណិធាននៅចំពោះមុខទេវតាអង្គនេះ រួមជាមួយព្រះកំក្រ្តព្រះមហាក្សត្រ និងព្រះកំក្រ្តសម្តេចព្រះសង្ឃរាជ ទេនោះ ឥស្សរជននៃស្តាប័នកំពូលៗរបស់ជាតិទាំងនោះ ពិតណាស់គឺមិនអាចចូលកាន់តំណែងជាផ្លូវការបានឡើយ ព្រោះបទប្បញ្ញត្តិនៃរដ្ឋធម្មនុញ្ញកម្ពុជាឆ្នាំ១៩៩៣ បានតម្រូវឱ្យឥស្សរជនទាំងអស់ធ្វើសច្ចាប្រណិធានជាមុនសិន មុនពេលចូលកាន់តំណែង ដូចដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃរដ្ឋធម្មនុញ្ញ។ ការធ្វើសច្ចាប្រណិធានចំពោះមុខ **ទេវតារក្សាស្វេតច្ឆត្រ** ពុំតម្រូវឲ្យធ្វើតែក្នុងព្រះទីនាំងទេវាវិនិច្ឆ័យនោះទេ គឺអាចធ្វើក្នុងទីដ៏សមគួរណាមួយ ប៉ុន្តែត្រូវមានកិច្ចអារាធនា យាងទេវតាអង្គនេះមកគង់ប្រថាប់ក្នុងទីធ្វើសច្ចាប្រណិធាន គឺជាការចាំបាច់។

សច្ចាប្រណិធានទាំងបី ដែលមានចែងនៅក្នុងឧបសម្ព័ន្ធទី៥ ឧបសម្ព័ន្ធទី៦ និងឧបសម្ព័ន្ធទី៧ នៃរដ្ឋធម្មនុញ្ញបច្ចុប្បន្ននៃព្រះរាជាណាចក្រកម្ពុជា គឺសុទ្ធតែចាប់ផ្តើមដោយពាក្យដូចៗគ្នា ថា "**ទូលព្រះបង្គំយើងខ្ញុំ [...] សូមធ្វើសច្ចាប្រណិធាននៅចំពោះព្រះកំក្រ្តព្រះមហាក្សត្រ ព្រះកំក្រ្តនៃសម្តេចព្រះសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រដូចតទៅ** [...]"។ ពាក្យផ្តើមនៃឧបសម្ព័ន្ធទាំងបីនេះត្រូវបានចងជាមួយគុណតម្លៃរដ្ឋធម្មនុញ្ញ ដែលឥស្សរជនជាន់ខ្ពស់ទាំងអស់ត្រូវតែប្រកាសនៅចំពោះព្រះកំក្រ្តព្រះមហាក្សត្រ ព្រះកំក្រ្តសម្តេចសង្ឃរាជ និងទេវតារក្សាស្វេតច្ឆត្រ ថាពួកលោកនឹងប្តេជ្ញាប្តូរផ្តាច់ហ៊ានបូជាជីវិតចំពោះផលប្រយោជន៍ជាតិ និងប្រជាជន [...] ។

លើសពីទស្សនាទានសាសនា **ទេវតារក្សាស្វេតច្ឆត្រ** តាមរយៈកិច្ចដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ ទេវតាអង្គនេះ គួរត្រូវបានកំណត់ថាជា **និមិត្តរូបនៃសញ្ញាណនីតិរដ្ឋ (The Symbol of Cambodia's Rule of Law) ក្នុងធម្មនុញ្ញនិយមនៅកម្ពុជា**។ សញ្ញាណនីតិរដ្ឋក្នុងន័យនេះអាចរកឃើញនៅក្នុងន័យ '**និមិត្តរូប**' ដែលតាមពិតគឺជានិមិត្តរូបនៃក្រមប្រតិបត្តិដប់ប្រការសម្រាប់ព្រះមហាក្សត្រ និងអ្នកដឹកនាំគ្រប់កម្រិតនៅក្នុងសង្គមកម្ពុជា។ ព្រះមហាក្សត្រទ្រង់ ដែលបានបដិបត្តិធម៌ (ច្បាប់) យ៉ាងខ្ជាប់ខ្ជួន ជាគុណធម៌ស្នូលសម្រាប់ព្រះមហាក្សត្រ និងអ្នកដឹកនាំផ្សេងទៀត ដែលគេហៅថា **ទសពិធរាជធម៌** មានបញ្ជាក់ជាតឹកតាងនានានៅក្នុងសិលាចារឹកក្នុងនិងក្រោយសម័យអង្គរ។ មានក្រមបុរាណដែលមានចែងអំពី**ទសពិធរាជធម៌**[៣៧៧] ដែលរួមមានក្រមប្រតិបត្តិចំនួន១០ប្រការគឺ **១- ទាន** មាន

[៣៧៧] តាំង រតនា " **ឥទ្ធិពលនៃនីតិរដ្ឋធម្មនុញ្ញលើនីតិរដ្ឋបាល៖ ឥទ្ធិពលនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលើរដ្ឋបាលនៅកម្ពុជា** " នៅក្នុងការអភិវឌ្ឍនីតិរដ្ឋបាលកម្ពុជា (ការបោះពុម្ពផ្សាយរបស់មូលនិធិខុនរ៉ាដអាដិនណាអ៊ែរឆ្នាំ២០១៣) ទំព័រ១១៩-១២០។

ន័យថាការធ្វើអំណោយ **២- សីល** មានន័យថាការប្រតិបត្តិធម៌ ឬវិន័យខ្លួនឯងឱ្យបានល្អ **៣- បរិច្ចាគ** មានន័យថាការចំណាយព្រះរាជទ្រព្យទំនុកបម្រុងប្រទេសជាតិ **៤- អាជ្ជវ** មានន័យថាសេចក្តីត្រង់ **៥- មទ្ទវ** មានន័យថាសេចក្តីទន់ភ្លន់ស្លូតសុភាពរាបសា **៦- តប** មានន័យថាការរស់នៅក្នុងជីវិតសាមញ្ញ **៧- អក្កោធន** មានន័យថាការអាណិតស្រឡាញ់ មិនក្រោធខឹង **៨- អវិហឹសា** មានន័យថាមិនបៀតបៀនដល់សត្វលោក **៩- ខន្តិ** មានន័យថាសេចក្តីអត់ធន់ និង **១០- អវិរោធនៈ** មានន័យថាមិនបំពានលើធម៌ លើច្បាប់។

ខាងក្រោមនេះ គឺជាការវិភាគលើក្រមប្រតិបត្តិទាំង១០ប្រការ នៃ**ទសពិធរាជធម៌** មានទំនាក់ទំនងទៅនឹង គុណតម្លៃនៃធម្មនុញ្ញនិយមទំនើប ដែលកំពុងអនុវត្តនាពេលបច្ចុប្បន្ន៖

១. **ទានៈ** ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃខាងសិទ្ធិមនុស្ស ក្នុងធម្មនុញ្ញនិយមទំនើបផងដែរ។ ទានៈ ដែលមានន័យថាការចែករំលែកផលប្រយោជន៍ គឺជាសិទ្ធិជាមូលដ្ឋានមួយប្រភេទរបស់មនុស្ស ជាពិសេសសិទ្ធិទទួលបានចំណីអាហារ សិទ្ធិទទួលបានការអប់រំ និងសិទ្ធិរស់រានមានជីវិត ដែលព្រះមហាក្សត្រ ឬអ្នកដឹកនាំត្រូវតែផ្តល់ជូនប្រជានុរាស្ត្រ។ ទានៈ មានច្រើនប្រភេទ ដែលបង្ហាញពីទំនាក់ទំនងរបស់វាជាមួយសិទ្ធិមនុស្ស ដូចជា **អាមិសទាន** គឺជាការបរិច្ចាគទ្រព្យសម្បត្តិ ដូចជាចំណីអាហារ ទឹក ថ្នាំពេទ្យ និងវត្ថុផ្សេងៗទៀត **ធម្មទាន** គឺជាការផ្តល់ចំណេះដឹង ឬសេរីភាពខាងអប់រំ **អភយទាន** គឺជាការធានាសុវត្ថិភាព និងសន្តិសុខចំពោះអាយុជីវិត ឬទ្រព្យសម្បត្តិ។[៣៧៨] ព្រះមហាក្សត្រខ្មែរគ្រប់អង្គតែងតែបានបំពេញការបរិច្ចាគទាន យ៉ាងជាប់លាប់ក្នុងសកម្មភាពលើកស្ទួយសិទ្ធិមនុស្ស។ ឧទាហរណ៍ ព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះមហាក្សត្រដ៏អស្ចារ្យក្នុងសម័យអង្គរ នៅចុងសតវត្សរ៍ទី១២ បានកសាងមន្ទីរពេទ្យចំនួន **១០២** កន្លែងនៅទូទាំងប្រទេស ដើម្បីព្យាបាលជំងឺជូនប្រជានុរាស្ត្រជាទីស្រឡាញ់របស់ព្រះអង្គ។[៣៧៩] សិលាចារឹកសៃហ្វុងបានកត់ត្រាថា "**ទ្រង់ទទួលរ៉ាប់រងនូវជំងឺរបស់រាស្ត្រជាងជំងឺផ្ទាល់ព្រះអង្គ ព្រោះថាទុក្ខវេទនារបស់ប្រជានុរាស្ត្រគឺជាទុក្ខ

[៣៧៨] ឥន្ទបញ្ញោភិក្ខុ ហោង មណីចិន្តា, ព្រះបាទធម្មិក, (ការបោះពុម្ពផ្សាយរបស់មូលនិធិឱុនរ៉ាដអាជិនណៅអ៊ែរ ឆ្នាំ១៩៩៤) ទំព័រ៩៩។

[៣៧៩] Michel Tranet ការគ្រប់គ្រងចក្រភពខ្មែរក្នុងយុគសម័យអង្គរ (រោងពុម្ពសាកលវិទ្យាល័យកម្ពុជា ឆ្នាំ២០០៤) ទំព័រ១០២។

វេទនារបស់ព្រះអង្គ"។[៣៨០] ដើម្បីលើកស្ទួយសុខុមាលភាពសង្គម ព្រះអង្គបានកសាងបណ្តាញផ្លូវភ្ជាប់អង្គរធំជាមួយចម្ប៉ា (វៀតណាម) និងជាមួយកិម៉ែ (ថៃ)។ តាមបណ្តោយផ្លូវទាំងនេះ ព្រះអង្គបានកសាងសាលាឆទានចំនួន ១២១កន្លែង ពោលគឺ ១៥គីឡូម៉ែត្រ មានសាលាឆទានមួយ ក្នុងនោះ ពីអង្គរធំទៅចម្ប៉ាមានសាលាឆទានចំនួន ៥៧កន្លែង ពីអង្គរធំទៅកិម៉ែមានសាលាឆទានចំនួន ១៧កន្លែង តាមផ្លូវផ្សេងៗទៀតមានសាលាឆទានចំនួន ៤៦កន្លែង និងនៅភ្នំជីសូរ្យ មានសាលាឆទានចំនួន ១កន្លែង។[៣៨១]

២. **សីលៈ** ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃទាក់ទងនឹងវិន័យសម្រាប់អ្នកដឹកនាំទាំងអស់។ មានសុភាសិតខ្មែរដ៏ល្បីមួយពោលថា "**បើអ្នកអង្គុយជិតច្បាប់ កុំយកច្បាប់មកធ្វើជាកន្លែងអង្គុយ**"។[៣៨២] សុភាសិតនេះរំឭកដល់អ្នកដឹកនាំទាំងឡាយឱ្យគោរពច្បាប់ និងមានវិន័យឱ្យបានខ្ពស់បំផុត។ អ្នកដឹកនាំទាំងឡាយត្រូវតែបំពេញករណីយកិច្ចរបស់ខ្លួនឱ្យស្របតាមច្បាប់របស់ព្រះរាជាណាចក្រ។ សញ្ញាណនេះឆ្លុះបញ្ចាំងពីនីតិរដ្ឋ និងការបែងចែកអំណាចក្នុងធម្មនុញ្ញនិយមរបស់បស្ចិមលោក។ យោងតាមសិលាចារឹកស្តុកកក់ធំ[៣៨៣] ព្រះមហាក្សត្រត្រូវតែមានចំណេះដឹងខ្ពស់ក្នុងជំនាញវិជ្ជាជាច្រើន ដូចជា វិទ្យាសាស្ត្រ ភាសាវិទ្យា ច្បាប់ យុទ្ធកោសល្យ និងជំនាញដទៃទៀតដែលអាចជួយដល់ការគ្រប់គ្រងរដ្ឋ។

---

[៣៨០] សារមន្ទីរជោតិកម្ពុជា ដែលអាចស្វែងរកមើលបានតាមរយៈ,
"https://www.cambodiamuseum.info/en_collection/stone_object/jayavaraman.html"

[៣៨១] ដដែល

[៣៨២] ឥន្ទប្បញ្ញោភិក្ខុ ហេង មណីចិន្តា, ព្រះបាទធម្មិក, (ការបោះពុម្ពផ្សាយរបស់មូលនិធិឱុនរ៉ាដអាជិនណៅអែរ ឆ្នាំ ១៩៩៤) ទំព័រ១០៦។

[៣៨៣] សិលាចារឹកស្តុកកក់ធំ (K.២៣៥) គឺជាសិលាចារឹកខ្មែរដ៏សំខាន់បំផុតមួយ ដែលមានចំនួន ៣៤០ បន្ទាត់ សរសេរជាភាសាសំស្ក្រឹត និងខ្មែរបុរាណ ដែលត្រូវបានឆ្លាក់លើថ្មកក់ខៀវកម្ពស់ ១,៥១ ម៉ែត្រ ដែលតាំងនៅជ្រុងឦសានៃប្រាសាទ។ បើរាប់តាំងពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ១០៥៣ មានរយៈពេល ២៥០ឆ្នាំហើយដែលសមាជិកអ្នកកសាងប្រាសាទបានផ្តល់ជូនតុលាការខ្មែរ ជាពិសេសជាព្រហ្មណ៍បរិស័ទចំណាស់របស់ព្រះមហាក្សត្រ។ ក្នុងការរៀបរាប់ពីតួនាទីដ៏វែងឆ្ងាយនេះ អត្ថបទនេះផ្តល់នូវទស្សនៈដ៏អស្ចារ្យ និងជាញឹកញាប់មានពាក្យសម្តី និងកំណាព្យអំពីសាសនា ខ្សែរាជវង្ស ប្រវត្តិ សាស្ត្រ និងស្ថាបត្យសង្គមនាសម័យនោះផងដែរ។

៣. **បរិច្ចាគៈ** ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃទាក់ទងនឹងការធ្វើអំពើជាប្រយោជន៍រួម។ វាជាកិច្ចដ៏សំខាន់សម្រាប់អ្នកដឹកនាំ និងប្រជាជនទាំងអស់នៅក្នុងប្រទេសមួយ។ ការគោរពគោលការណ៍នេះនឹងលើកស្ទួយសុខដុមរមនាសង្គម។ ព្រះមហាក្សត្រ និងអ្នកដឹកនាំខ្មែរគ្រប់លំដាប់ថ្នាក់ តាំងពីបុរាណកាលមក បានប្តេជ្ញាចិត្តអនុវត្តនូវគោលការណ៍បរិច្ចាគនេះ។ ក្នុងសតវត្សរ៍ទី១៩ ព្រះបាទអង្គឌួង[៣៨៤] ដែលសោយរាជ្យនៅរាជធានីឧត្តុង្គ បានយកព្រះរាជទ្រព្យរបស់ព្រះអង្គមកដោះបំណុលឱ្យទាសាទាសីទាំងអស់ដើម្បីផ្តល់សេរីភាពឱ្យពួកគេ។ ក្រោយមក ព្រះអង្គបានចាប់ផ្តើមលុបបំបាត់ចោលនូវរបបទាសភាពនៅកម្ពុជា។ នេះជាទស្សនាទានមួយទៀតដែលមានទំនាក់ទំនងជាមួយសិទ្ធិជាមូលដ្ឋានក្នុងធម្មនុញ្ញនិយមទំនើប ជាពិសេសសិទ្ធិចំពោះសេចក្តីថ្លៃថ្នូរ និងសិទ្ធិសេរីភាព។

៤. **អាជ្ញាៈ** ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃទាក់ទងនឹងការគោរពវិធានច្បាប់ និងបទបញ្ជា។ គោលការណ៍នេះគ្រប់គ្រងឥរិយាបថមនុស្សឱ្យស្របទៅតាមក្រឹត្យក្រមច្បាប់ ឬសីលធម៌។ ព្រះមហាក្សត្រ ឬអ្នកដឹកនាំដែលគោរពគោលការណ៍អាជ្ញាត្រូវបានចាត់ទុកជាបុគ្គលគំរូដ៏ល្អសម្រាប់មនុស្សគ្រប់វណ្ណៈក្នុងសង្គម។ អាជ្ញាៈមានទំនាក់ទំនងជិតស្និទ្ធជាមួយគោលការណ៍នៃការបែងចែកអំណាច និងនីតិរដ្ឋក្នុងធម្មនុញ្ញនិយម។ ទស្សនាទាននេះពាក់ព័ន្ធនឹងគោលការណ៍ផ្សេងៗទៀត ដូចជា ការគោរពតួនាទីរបស់ខ្លួន, ការគោរពតួនាទីអ្នកដទៃ, ការគោរពបុគ្គលិកលក្ខណៈរបស់អ្នកដទៃ និងការគោរពអំពើល្អ ដូចជាយុត្តិធម៌ ប្រយោជន៍សាធារណៈ និងគុណតម្លៃនានាផងដែរ។ ទស្សនាទាន នេះបង្រៀនអ្នកអនុវត្តទាំងអស់ឱ្យចាកឆ្ងាយពីអំពើពុករលួយ បក្សពួកនិយម អយុត្តិធម៌ និងការរំលោភអំណាច ដូចមានសុភាសិតមួយបានលើកឡើងថា៖ «បើអ្នកថែរក្សាច្បាប់ឱ្យបានល្អ នោះច្បាប់នឹងថែរក្សាអ្នកវិញ»។[៣៨៥]

---

[៣៨៤] **ព្រះបាទអង្គឌួង** គឺជាបុព្វការីជននៃព្រះរាជវង្សានុវង្សខ្មែរនាពេលបច្ចុប្បន្ននេះ។ ទ្រង់ជាព្រះបិតានៃ **ព្រះបាទនរោត្តម** (១៨៣៤–១៩០៤) និង**ព្រះបាទស៊ីសុវត្ថិ** (១៨៤០–១៩២៧)។ ទ្រង់ជាព្រះរាជអយ្យិកោលួតនៃ **ព្រះបាទនរោត្តម សីហនុ** (១៩២២–២០១២)។

[៣៨៥] ឥន្ទបញ្ញោភិក្ខុ ហេង មណីចិន្តា, ព្រះបាទធម្មិក, (ការបោះពុម្ពផ្សាយរបស់មូលនិធិឧនរ៉ាជអាជិនណៅអ៊ែរ ឆ្នាំ១៩៩៤) ទំព័រ១២៤។

៥. **មទ្ទវៈ** ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃទាក់ទងនឹងការលើកតម្កើងគុណតម្លៃបុគ្គល សមភាព សុភាពរាបសា និងការគោរពសិទ្ធិ។ គោលការណ៍នេះបង្រៀនព្រះមហាក្សត្រ និងអ្នកដឹកនាំឱ្យកាត់បន្ថយគម្លាតរវាងអ្នកគ្រប់គ្រង និងរាស្ត្រប្រជា។ មានន័យថា ព្រះមហាក្សត្រ និងអ្នកដឹកនាំត្រូវតែទន់ភ្លន់សុភាពរាបសា និងស្និទ្ធស្នាលជាមួយប្រជារាស្ត្រ យល់ពីតម្រូវការរបស់ប្រជារាស្ត្រ ហើយផ្តល់ដំណោះស្រាយ និងជំនួយដល់អាណាប្រជានុរាស្ត្រ។ ទស្សនាទាននេះមានទំនាក់ទំនងជាមួយសិទ្ធិជាមូលដ្ឋានក្នុងធម្មនុញ្ញនិយមទំនើប។

៦. **តបៈ, អក្កោធៈ, អវិហឹសា** និង **ខន្តិ**៖ ជាក្រមប្រតិបត្តិ ដែលមានគុណតម្លៃទាក់ទងនឹងការលុបបំបាត់អំពើអកុសលទាំងឡាយ ដូចជា **លោភៈ ទោសៈ មោហៈ** និង**ឥស្សា** ជំនួសមកវិញដោយការចេះសន្តោសប្រណី និងការគោរពច្បាប់ប្រទេសជាតិ។ ទស្សនាទាននេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយសិទ្ធិជាមូលដ្ឋាន និងនីតិរដ្ឋក្នុងធម្មនុញ្ញនិយមទំនើប។

៧. **អវិរោធនៈ** ជាក្រមប្រតិបត្តិដ៏សំខាន់បំផុតដែលពាក់ព័ន្ធនឹងគោលការណ៍នីតិរដ្ឋ។ មានន័យថាការមិនល្មើសច្បាប់។ ទស្សនាទាននេះបង្ហាញយ៉ាងច្បាស់ថា ច្បាប់របស់ប្រទេសត្រូវតែស្ថិតនៅខ្ពស់ជាងអំណាចទាំងអស់។ តួអង្គទាំងអស់ ត្រូវតែគោរពច្បាប់ជាជាច់ខាតសូម្បីតែព្រះមហាក្សត្រក៏មិនអាចល្មើសច្បាប់បានដែរ។ ទស្សនាទាននេះបង្ហាញយ៉ាងច្បាស់ពីការលើកតម្កើងគុណតម្លៃនៃការគោរពច្បាប់ក្នុងព្រះរាជាណាចក្រ ពោលគឺគោលការណ៍ **នីតិរដ្ឋ**។

ជារួម **ទសពិធរាជធម៌** ដែលជាក្រមប្រតិបត្តិដប់ប្រការសម្រាប់អ្នកដឹកនាំ ត្រូវបានចាត់ទុកថាជាគោលការណ៍មានគុណតម្លៃធម្មនុញ្ញ (Constitutional Values) នៅក្នុងសង្គមខ្មែររាប់សតវត្សរ៍មកហើយ។ ក្រមប្រតិបត្តិទាំងដប់ប្រការនេះ បានក្លាយជាក្រមសីលធម៌ដ៏សំខាន់បំផុត សម្រាប់ព្រះមហាក្សត្រ ក៏ដូចជារបស់អ្នកដឹកនាំគ្រប់ជាន់ថ្នាក់នៅកម្ពុជា ក្នុងការបំពេញតួនាទី ទៅតាមមុខងាររបស់ខ្លួន។ តាមពិតទៅ គុណតម្លៃនៃក្រមប្រតិបត្តិទាំងដប់ប្រការនេះ មិនមែនសម្រាប់តែព្រះមហាក្សត្រ ឬអ្នកដឹកនាំប៉ុណ្ណោះទេ តែក៏ចំពោះជនទាំងឡាយណា ដែលមានតួនាទីដឹកនាំគ្រប់គ្រងគ្រប់ប្រភេទ ជាអាទិ៍ការដឹកនាំសហគមន៍ផងដែរ។ ក្រៅអំពីក្រមប្រតិបត្តិទសពិធរាជធម៌ដូចបានវិភាគពីខាងលើ

នៅមាន **ទសបារមី** ដែលរួមមាន គុណជាតិ១០ប្រការ គឺ៖ **ទាន សីល នេក្ខម្ម បញ្ញា វិរិយ ខន្តិ សច្ច អធិដ្ឋាន មេត្តា និង ឧបេក្ខា** សម្រាប់ទ្រទ្រង់ ដល់អ្នកដឹកនាំនៃប្រទេសកម្ពុជា ដែលការសិក្សានៅទីនេះ ពុំបានលើកមកបង្ហាញលម្អិតនោះទេ ប៉ុន្តែគួរកត់សម្គាល់ថា គោលការណ៍ទាំង១០ ក្នុងទសបារមីនេះ គឺជាចំណែកមួយដ៏មានសារៈសំខាន់ រួមជាមួយ ក្រមប្រតិបត្តិ **ទសពិធរាជធម៌** ក្នុងការគ្រប់គ្រងកាយ វាចា ចិត្ត នៃអ្នកដឹកនាំ និងអាណាប្រជានុរាស្ត្រ ឲ្យស្ថិតក្នុងសុចរិតភាព និង ឧត្តមភាព ក្នុងក្របខ័ណ្ឌនៃការគោរពច្បាប់របស់នគរ និងការលើកកម្ពស់យុត្តិធម៌សង្គម ពោលគឺ **នីតិរដ្ឋ**។

- **ព្រហ្មវិហារធម៌ គឺជាសញ្ញាណនៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្សក្នុងសង្គមខ្មែរ** (Brahma Vihara Dhamma—The Notion of Cambodia's Democracy and Human Rights)

ក្រៅពីទស្សនាទានដែលបានរៀបរាប់ខាងលើ មានក្រមប្រតិបត្តិមួយផ្សេងទៀត នោះគឺ **ព្រហ្មវិហារធម៌** ដែលជាសញ្ញាណគួរឱ្យកត់សម្គាល់មួយនៃធម្មនុញ្ញនិយមនៅក្នុងខ្មែរ តាំងពីសម័យបុរាណកាល រហូតរៀងមក។ ក្រមប្រតិបត្តិ **ព្រហ្មវិហារធម៌** គឺជាទស្សនាទានមួយក្នុងចំណោមទស្សនាទានរបស់ព្រហ្មញ្ញសាសនា និងព្រះពុទ្ធសាសនា ដែលពាក់ព័ន្ធនឹងគោលការណ៍លើកកម្ពស់ ប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស។ សង្គមខ្មែរចាប់តាំងពីសម័យអង្គរហូតមកទល់នឹងបច្ចុប្បន្ន មិនដែលភ្លេចក្រមប្រតិបត្តិ **ព្រហ្មវិហារធម៌** នេះឡើយ ដ្បិតសង្គមខ្មែរជឿថាជាក្រមប្រតិបត្តិមួយដ៏មានសារៈសំខាន់ ដែលនាំមកនូវសេចក្តីសុខ សេចក្តីចម្រើនដល់ក្រុមគ្រួសារ និងសង្គមជាតិ ដូចមានពាក្យថា៖ **ឪពុកម្តាយត្រូវមានព្រហ្មវិហារធម៌ចំពោះកូន។ មេដឹកនាំត្រូវមានព្រហ្មវិហារធម៌ចំពោះកូនចៅក្រោមឱវាទ** ។ល។ **ព្រហ្មវិហារធម៌** ត្រូវបានប្រជាជនខ្មែរស្គាល់ដោយតំណាងព្រះកំភ្ជ្រួននៃព្រះព្រហ្ម ដែលព្រះកំភ្ជ្រទាំងបួននេះតំណាងឲ្យ៖ (១) **មេត្តា** មានន័យថាសេចក្តីរាប់អានសេចក្តីប្រណី (២) **ករុណា** មានន័យថាសេចក្តីអាណិតអាសូរ (៣) **មុទិតា** មានន័យថាសេចក្តីរីករាយទៅរកសេចក្តីសុខរបស់អ្នកដទៃ និង (៤) **ឧបេក្ខា** មានន័យថាការតាំងចិត្តជាកណ្តាលៗស្មើៗ។

ខាងក្រោមនេះជាការវិភាគ លើក្រមប្រតិបត្តិទាំងបួននៃព្រហ្មវិហារធម៌ ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងគោលការណ៍៖ ប្រជាធិបតេយ្យ សិទ្ធិជាមូលដ្ឋាន និងការបែងចែកអំណាច ក្នុងធម្មនុញ្ញនិយមទំនើប។[៣៨៦]

(**១**) **មេត្តា** សេចក្តីរាប់អាន សេចក្តីប្រណី (**២**) **ករុណា** សេចក្តីអាណិតអាសូរ និង (**៣**) **មុទិតា** សេចក្តីរីករាយទៅរកសេចក្តីសុខរបស់អ្នកដទៃ៖ ក្រមប្រតិបត្តិទាំងបីនេះសំដៅលើការប្រព្រឹត្តដោយស្មើភាពចំពោះសត្វលោកទាំងអស់ រួមទាំងមនុស្ស អមនុស្ស និងសត្វ។ ក្រមប្រតិបត្តិទាំងបីនេះពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងគោលការណ៍ទំនើបនៃប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ជាពិសេសការគោរពសិទ្ធិរស់រានមានជីវិត និងសិទ្ធិចំពោះសេចក្តីថ្លៃថ្នូរ សិទ្ធិ និងសេរីភាពផ្ទាល់ខ្លួន និងអធិបតេយ្យភាពរបស់ប្រជាជន។ នៅពេលដែលក្រមប្រតិបត្តិទាំងបីនេះ (**មេត្តា ករុណា** និង**មុទិតា**) ត្រូវបានលើកតម្កើងយ៉ាងល្អ នោះប្រជាធិបតេយ្យ និងសិទ្ធិមនុស្ស ក៏នឹងត្រូវបានគោរពយ៉ាងល្អផងដែរ។ (**៤**) **ឧបេក្ខា** ការតាំងចិត្តជាកណ្តាលៗស្មើៗ មានការពាក់ព័ន្ធយ៉ាងជិតស្និទ្ធជាមួយនឹងគោលការណ៍បែងចែកអំណាច ជាពិសេសឯករាជ្យភាពតុលាការ។ នៅពេលដែលក្រមប្រតិបត្តិ **ឧបេក្ខា** ត្រូវបានលើកតម្កើងយ៉ាងល្អ នោះអយុត្តិធម៌សង្គម និងការរំលោភអំណាចនានានឹងមិនអាចកើតមានឡើងបានឡើយ។ ជាងនេះទៅទៀត ក្រមប្រតិបត្តិនេះ ជួយលើកតម្កើងគុណតម្លៃខាងសង្គម នយោបាយ និងវប្បធម៌ផងដែរ។

អ្វីដែលគួរឱ្យចាប់អារម្មណ៍នោះគឺថា ព្រះក័ត្រទាំងបួនរបស់ព្រះព្រហ្មត្រូវបានកសាងឡើងនៅលើប្រាង្គប្រាសាទនៃស្ថាបត្យកម្មខ្មែរចាប់តាំងពីសម័យអង្គរហូតមកទល់នឹងបច្ចុប្បន្ន។ ឧទាហរណ៍ ប្រាសាទបាយ័នត្រូវបានកសាងឡើងដោយរចនាព្រះក័ត្រទាំងបួនរបស់ព្រះព្រហ្មលើប្រាង្គទាំង៤៩ និងច្រកទ្វារទាំង៥របស់ប្រាសាទ។ ព្រះបាទជ័យវរ្ម័នទី៧ ដែលជាព្រះស្ថាបនិកកសាងប្រាសាទបាយ័ននេះ បានបង្កប់គោលការណ៍ព្រហ្មវិហារធម៌នៅលើប្រាង្គ និងច្រកទ្វារទាំងអស់នៃប្រាសាទនេះ ដោយមានព្រះរាជបំណងចង់បង្ហាញថា ព្រះមហាក្សត្រ អ្នកដឹកនាំ នាម៉ឺនមន្ត្រីគ្រប់ក្រសួង និងប្រជារាស្ត្រទាំងអស់នៅក្រោមរជ្ជកាលរបស់ទ្រង់ ត្រូវតែបំពេញករណីយកិច្ចរបស់ខ្លួនស្របតាមគោលការណ៍ព្រហ្ម

---

[៣៨៦] តាំង រតនា ស្តីពី "ឥទ្ធិពលនៃនីតិរដ្ឋធម្មនុញ្ញលើនីតិរដ្ឋបាល៖ ឥទ្ធិពលនៃសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាធម្មនុញ្ញលើរដ្ឋបាលនៅកម្ពុជា" នៅក្នុងការអភិវឌ្ឍន៍នីតិរដ្ឋបាលកម្ពុជា (ការបោះពុម្ពផ្សាយរបស់មូលនិធិឌុនវ៉ាដអាជិនណៅអ៊ែរ ឆ្នាំ ២០១៣) ទំព័រ១១៩-១១៩-១២០។

វិហារធម៌ទាំងបួននេះ ដើម្បីឱ្យព្រះរាជាណាចក្រមានភាពរុងរឿងខ្លាំងពូកែ។[៣៨៧] ចំពោះព្រះទីន័ងទេវាវិនិច្ឆ័យមហាប្រាសាទនៃព្រះបរមរាជវាំង ដែលជាទីតម្កល់ព្រះរាជបល្ល័ង្ក និងជាកន្លែងទទួលព្រះរាជសវនាការ ក៏មានព្រះភ័ក្ត្រទាំងបួននៃព្រះព្រហ្ម តាំងជាកំពូលបុស្សកនៃមហាប្រាសាទ។ រីឯវិមានសំខាន់ៗរបស់រដ្ឋដែលមានតួនាទីផ្នែកច្បាប់ ដូចជាវិមានរដ្ឋសភាជាដើម ក៏ត្រូវបានតុបតែងព្រះភ័ក្ត្រទាំងបួននៃព្រះព្រហ្ម ជាស្ថាបត្យកម្មលម្អនៅលើកំពូលនៃវិមាន។ ក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រ កម្ពុជា ដែលជាស្ថាប័នមានសមត្ថកិច្ចជានាការគោរពរដ្ឋធម្មនុញ្ញ ក៏បានអនុម័តយករូបព្រះព្រហ្មជានិមិត្តសញ្ញារបស់ខ្លួន។ មិនតែប៉ុណ្ណោះ ព្រះភ័ក្ត្រទាំងបួនរបស់ព្រះព្រហ្ម ក៏ត្រូវបានគេស្ថាបនានៅលើ **ស្តម្ភរដ្ឋធម្មនុញ្ញ** (សសរស្តម្ភឆកោណ ដែលមានចារឹកបុព្វកថានៃរដ្ឋធម្មនុញ្ញកម្ពុជា ត្រូវបានដាក់តម្កល់នៅចំកណ្តាល **វិមានរដ្ឋធម្មនុញ្ញ** ឬ **កម្ពុជធម្មរាជវិមាន**)។[៣៨៨]

នៅនឹងសរសរមួយ នាជ្រុងខាងត្បូងនៃ **វិមានរដ្ឋធម្មនុញ្ញ** ក៏មានចារឹកនូវ ក្រមប្រតិបត្តិ ព្រហ្មវិហារធម៌ ជាពាក្យឧទ្ទិសក្នុងតេជានុភាពវិមានរដ្ឋធម្មនុញ្ញផងដែរ ដែលមានសេចក្តីទាំងស្រុងថា ៖ *"អធិដ្ឋានសូមឲ្យជនទាំងឡាយក្នុងរាជសីមាមហានគរ មានដំណើរ*

---

[៣៨៧] អ្នកនិពន្ធបានរៀនសូត្រអំពីទស្សនាទាននេះក្នុងឆ្នាំ២០០៣ ពីព្រះគ្រូព្រឹទ្ធាចារ្យ មហាធម្មគុរុកោសល្យ **ប្រាក់ ព្រុំ** (Bredhaja Maha Dhamma Guru Kosala **Prak Prum**) នៅវត្តលង្កាព្រះកុសុមារាម ដែលបានពន្យល់អំពីទំនាក់ទំនងរវាងទស្សនវិជ្ជាសាសនា និងស្ថាបត្យកម្ម។

[៣៨៨] ដោយយល់ឃើញថា រដ្ឋធម្មនុញ្ញបច្ចុប្បន្នមានអាយុកាលយូរអង្វែងជាងគេ ហើយកម្ពុជាបច្ចុប្បន្នសម្រេចបាននូវសមិទ្ធផលធម្មនុញ្ញជាច្រើនផងដែរនោះ ទើបបានជានៅឆ្នាំ២០១៨ ឯកឧត្តមកិត្តិនីកោសលបណ្ឌិត អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញបានផ្តួចផ្តើមគំនិតក្នុងការស្ថាបនាវិមានរដ្ឋធម្មនុញ្ញ ដើម្បីអបអរសាទរពិធីអបអរសាទរខួប លើកទី៣០ឆ្នាំ នៃការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ គម្រោងការសាងសង់វិមានរដ្ឋធម្មនុញ្ញនេះត្រូវបានទទួលការគាំទ្រពីសំណាក់រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី ដោយ **សម្តេច** បានអនុញ្ញាតឱ្យសាងសង់វិមាននេះដោយប្រើប្រាស់ថវិកាជាតិ។ វិមានរដ្ឋធម្មនុញ្ញត្រូវបានរចនាប្លង់ជាការសំយោគរវាង "**ស្ថាបត្យកម្មក្រិករ៉ូម៉ាំង**" ជាការសម្តែងនូវនិមិត្តរូប **គុណតម្លៃធម្មនុញ្ញទំនើប** នៅផ្នែកខាងក្រោម និង "**ស្ថាបត្យកម្មខ្មែរបុរាណ**" ជាការសម្តែងនូវ**គុណតម្លៃប្រពៃណីខ្មែរ** នៅផ្នែកខាងលើ។ ភាពសុខដុមរមនារវាងស្ថាបត្យកម្មបែបបស្ចិមប្រទេស និងបែបខ្មែរតំណាងឱ្យគុណតម្លៃធម្មនុញ្ញនៃរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣។ វិមាននេះត្រូវបានកសាងពីថ្មកក់ និងពីសំរឹទ្ធ បែបនេះហើយទើបនាំឱ្យយើងអាចសន្និដ្ឋានបានថា **វិមានរដ្ឋធម្មនុញ្ញ** គឺជាសិលា-លោហាប្រាសាទដ៏ធំល្អវិចិត្រទីមួយក្នុងព្រះរាជាណាចក្រកម្ពុជា។ ការប្រារព្ធពិធីក្រុងពាលីបញ្ចុះបឋមសិលាដែលជាមង្គលបឋមកិច្ចដើម្បីការកសាងវិមានរដ្ឋធម្មនុញ្ញត្រូវបានប្រារព្ធធ្វើឡើងនៅថ្ងៃទី១២ ខែមិថុនា ឆ្នាំ២០២៣ ហើយត្រូវបានស្ថាបនារួចជាស្ថាពរ នៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០២៤។ វិមាននេះស្ថិតផ្នែកខាងលិចនៃវិមានឯករាជ្យ។ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត **អ៊ឹម ឈុនលឹម** អតីតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ គឺជាអគ្គនិម្មាបនករនៃគោលគំនិតដឹកនាំឱ្យរចនាប្លង់នៃវិមាន រួមទាំងគុណតម្លៃធម្មនុញ្ញផងដែរ ហើយឯកឧត្តមក៏សម្រេចប្រគល់ភារកិច្ចជូនឯកឧត្តមអគ្គលេខាធិការក្រុមប្រឹក្សាធម្មនុញ្ញ **តាំង រតនា** ដឹកនាំការស្រាវជ្រាវ និងសហការជិតស្និទ្ធជាមួយឯកឧត្តមបណ្ឌិតស្ថាបត្យករ **លី រស្មី** ក្នុងការធ្វើអត្ថប្បដិរូបកម្មនៅលើសំណង់វិមាន។ ជារួម **វិមានរដ្ឋធម្មនុញ្ញ** នឹងក្លាយជាសំណង់ដែលត្រូវបានភ្ជាប់ទៅនឹងទស្សនាទានធម្មនុញ្ញ និងត្រូវបាននិមិត្តទាំងអត្ថរូប និងអត្ថន័យ។

*ប្រព្រឹត្តទៅត្រូវត្រង់តាមគន្លងនៃកុសលកម្មបថ។ ដោយតេជានុភាពនៃវិមានរដ្ឋធម្មនុញ្ញ ដែលបានសាងក្នុងរាជធានីភ្នំពេញ ជាក្រុងចតុម្មុខមង្គលសកលកម្ពុជាធិបតី ប្រពៃធំទូលំទូលាយរុងរឿង មានពួកជនច្រើន មានមនុស្សកុះករ ដែលចូលរួមគោរពបូជា ការពារថែទាំ អភិរក្ស វិមានរដ្ឋធម្មនុញ្ញ ជាសមិទ្ធផល (បុណ្យ) នៃប្រជាជាតិខ្មែរ សូមបុញ្ញកុសលនោះ ជួយកាត់ផ្តាច់ចំណងពៀរវេរ និងបណ្តាសាទាំងពួង ដែលមានមកតាំងពីក្នុងអតីតកាលក្តី ឬក្នុងបច្ចុប្បន្នកាលនេះក្តី ឲ្យបានដាច់ស្រឡះរួចចាកផុតរលត់សាបសូន្យទៅ ជំនួសមកវិញនូវពន្លឺនៃ **ព្រះព្រហ្មវិហារធម៌** ដ៏ក្លឹងក្លាំងត្រចះត្រចង់ គ្របដណ្តប់គ្មានសល់ចន្លោះ ក្នុងរាជសីមាមហានគរ។ មួយយអន្លើដោយតេជានុភាពនេះ សូមសត្វទាំងឡាយទាំងពួង ក្នុងទិសបូព៌ អាគ្នេយ៍ ទក្សិណ និរតី បស្ចិម ពាយ័ព្យ ឧត្តរ ឦសាន ក្រោម លើ មិនមានពៀរនឹងគ្នា សូមឲ្យមានតែសេចក្តីសុខ ប្រាសចាកទុក្ខ មិនព្យាបាទគ្នា មិនប្រេះឆាគ្នា សូមឲ្យមានអាយុយឺនយូរ ប្រាសចាករោគ សូមឲ្យបានសម្រេចដោយសម្បត្តិទាំងឡាយ សូមរក្សាខ្លួនឲ្យជាសុខ សូមសត្វទាំងឡាយទាំងពួង ដែលដល់នូវសេចក្តីទុក្ខ សូមឲ្យជាសត្វបាត់សេចក្តីទុក្ខទៅ ដែលដល់នូវភ័យ សូមឲ្យជាសត្វបាត់ភ័យទៅ ដែលដល់នូវសេចក្តីសោក សូមឲ្យជាសត្វបាត់សេចក្តីសោក ទៅហោង។* [៣៨៩]

ជារួម **ព្រហ្មវិហារធម៌** គឺជាក្រមប្រតិបត្តិមួយទៀតដ៏មានសារៈសំខាន់ ដែលគួរត្រូវបានចាត់ទុកថាជាគោលការណ៍ មានគុណតម្លៃធម្មនុញ្ញ (Constitutional Values) នៅក្នុងសង្គមខ្មែរ រួមជាមួយក្រមប្រតិបត្តិ **ទសពិធរាជធម៌** និង **ទសបារមី** ដែលគោលការណ៍ទាំងឡាយ ក្នុងក្រមប្រតិបត្តិទាំងនេះ ធ្លាប់ត្រូវបានប្រើជាមូលដ្ឋានគ្រឹះក្នុងការកសាង វិធានច្បាប់នានា និងការលើកកម្ពស់យុត្តិធម៌ ក្នុងសង្គមខ្មែរតាំងពីសម័យបុរាណកាលមក ជាពិសេសនៅក្នុងសម័យដ៏រុងរឿងនៃមហាអាណាចក្រខ្មែរ។ បច្ចុប្បន្ននេះ សញ្ញាណនៃក្រមប្រតិបត្តិទាំងនេះ មិនទាន់ទៅណាឆ្ងាយពីសង្គមខ្មែរនៅឡើយទេ ប៉ុន្តែត្រូវបានកប់ជ្រៅ ក្នុងលម្ហានប្រវត្តិសាស្ត្រ និងវប្បធម៌នៃប្រទេសកម្ពុជា។

ជាការកត់សម្គាល់ ក្រមប្រតិបត្តិទាំងនេះភាគច្រើនត្រូវបានមើលឃើញត្រឹមតែជាទ្រឹស្តីក្នុងជំនឿ/សាសនា តែបុ៉ណ្ណោះ ដែលតាមពិតទៅ ប្រសិនបើធ្វើការពិចារណាឲ្យបានល្អិតល្អន់តទៅទៀតក្រមប្រតិបត្តិទាំងនេះ សឹងមានគុណតម្លៃល្អលើសពី **គុណតម្លៃធម្មនុញ្ញទំនើប (ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ)** ក៏អាចថាបាន ដ្បិតទាំងក្រមប្រតិបត្តិ **ទស**

[៣៨៩] សម្រង់សេចក្តីចេញពីសិលាចារឹកនៅសរសេរទិសខាងត្បូងនៃ វិមានរដ្ឋធម្មនុញ្ញ

ពិធរាជធម៌ និង **ទសបារមី** ព្រមទាំងក្រមប្រតិបត្តិ **ព្រហ្មវិហារធម៌** មានគុណតម្លៃសកលធំធេង រហូតគ្របដណ្តប់**ធម្ម** ក្នុងលោកទាំងមូល ពុំដូចគុណតម្លៃធម្មនុញ្ញទំនើប ដែលមានដែនកំណត់ក្នុងការអនុវត្តនោះឡើយ។ ប្រសិនបើសង្គមខ្មែរ មានលទ្ធភាពធ្វើការចម្រាញ់ទាញយកគោលការណ៍ ដែលមានក្នុងក្រមប្រតិបត្តិទាំងនោះ មកប្រតិបត្តិនៅក្នុងជីវភាពនយោបាយ សេដ្ឋកិច្ច សង្គម និងវប្បធម៌ ប្រកបដោយភាពជោគជ័យបានវិញនោះ ពិតណាស់វាគឺជាបុណ្យកុសលមួយ ដែលនឹងជួយជ្រោមជ្រែង ផ្តត់ផ្តង់ប្រយោជន៍ឲ្យដល់ប្រទេសខ្មែរជាមហានគរ។

ដោយសង្ខេប ការសិក្សាដ៏តូចមួយនេះ គ្រាន់តែជាការផ្តួចផ្តើមនូវគំនិត ក្នុងការសិក្សាស្រាវជ្រាវ ដោយសង្ឃឹមថា ប្រាកដជានឹងមាន នីតិបញ្ញវន្តខ្មែរ ក្នុងកាលបច្ចុប្បន្ន និងក្នុងអនាគតកាល រើសយកជាគតិ បន្តធ្វើការសិក្សាស្រាវជ្រាវ វិភាគសុីជម្រៅ ឲ្យសម្រេចបានសមិទ្ធផលដ៏ធំធេងជាឧត្តមប្រយោជន៍ជាតិតទៅ។

១.៤. សេចក្តីសន្និដ្ឋាន

តាមរយៈការសិក្សាវិភាគលើសញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជា តាមលម្អានប្រវត្តិសាស្ត្រនិងវប្បធម៌ ដូចមានពីខាងដើម អាចទាញសេចក្តីសន្និដ្ឋានបានថា ជ្បឹតសង្គមខ្មែរតាំងពីសម័យបុរាណកាលមកពុំធ្លាប់បានចារឹកច្បាស់នូវច្បាប់កំពូល ហៅថា **រដ្ឋធម្មនុញ្ញ** យ៉ាងណាក៏ដោយ ប៉ុន្តែព្រះរាជាណាចក្រមួយនេះធ្លាប់បានទទួលយកនិងគោរពប្រតិបត្តិគោលការណ៍ធំៗដែលមាន **គុណតម្លៃធម្មនុញ្ញនិយម** មានជាអាទិ៍ក្រមប្រតិបត្តិ ទសពិធរាជធម៌ ទសបារមី និងព្រហ្មវិហារធម៌ រួមនិងគោលការណ៍ **"ធម្ម"** នានាដែលមានក្នុងប្រពៃណីទំនៀមទម្លាប់ល្អរបស់សង្គមខ្មែរ។ គោលការណ៍ក្នុងក្រមប្រតិបត្តិទាំងនោះ តាមការសិក្សាវិភាគ គឺពិតជាបានផ្តល់សញ្ញាណធម្មនុញ្ញនិយម ស្របនឹងគុណតម្លៃធម្មនុញ្ញទំនើប តាមបែបបស្ចិមលោក (**ប្រជាធិបតេយ្យ សិទ្ធិមនុស្ស និង នីតិរដ្ឋ**) ដែលបានផ្សាយមកកាន់ព្រះរាជាណាចក្រកម្ពុជា។

ឆ្ពើមចេញពីការសិក្សាអំពីសញ្ញាណធម្មនុញ្ញនិយមនៅកម្ពុជាដូចខាងលើ បន្ថែមលើនេះទៀតចំពោះការស្វែងយល់អំពី (១) ប្រព័ន្ធច្បាប់ធំៗលើសកលលោក ឬគ្រួសារនៃប្រព័ន្ធច្បាប់ (២) ការទទួលឥទ្ធិពលនៃប្រព័ន្ធច្បាប់ និង(៣) ប្រព័ន្ធច្បាប់របស់ប្រទេសមួយ គឺជាចំណុចសំខាន់ឈានទៅរកការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា។ ទាក់ទងនឹងចំណុចបីខាងដើមនេះ បើសួរថាតើក្នុងពិភពលោកនេះ ក្រុមគ្រួសារនៃប្រព័ន្ធច្បាប់ឬប្រព័ន្ធច្បាប់ធំៗ មានចំនួនប៉ុន្មាន? អ្នកសិក្សានីតិសាស្ត្រភាគច្រើនអាចឆ្លើយបានថា មានចំនួនបួន គឺ (១) ប្រព័ន្ធច្បាប់រ៉ូម៉ាំង/អាល្លឺម៉ង់ (២) ប្រព័ន្ធច្បាប់អង់គ្លោសាក់សុង (៣) ប្រព័ន្ធច្បាប់សង្គមនិយម និង(៤) ប្រព័ន្ធច្បាប់សាសនា។ បើសួរថាតើប្រព័ន្ធច្បាប់ប្រទេសមួយស្ថិតក្នុងក្រុមគ្រួសារនៃប្រព័ន្ធច្បាប់ណា? នោះក៏អាចឆ្លើយបានអាស្រ័យលើប្រទេសមួយនោះ ទទួលយកឥទ្ធិពលពីប្រព័ន្ធច្បាប់ណា ក្នុងចំណោមប្រព័ន្ធច្បាប់ធំៗទាំងបួន ដូចបានរៀបរាប់ពីខាងដើម តួយ៉ាងដូចជាប្រទេសកម្ពុជា គឺស្ថិតក្នុងគ្រួសារនៃប្រព័ន្ធច្បាប់រ៉ូម៉ាំង/អាល្លឺម៉ង់ និងទទួលឥទ្ធិពលចម្រុះពីប្រព័ន្ធនានាខ្លះដែរ។ ចុះបើសួរថា តើក្នុងពិភពលោកនេះមានប្រព័ន្ធច្បាប់ចំនួនប៉ុន្មាន? នោះគួរឆ្លើយដូច្នេះថា ក្នុងពិភពលោកមានប្រទេសចំនួនប៉ុន្មាន គឺប្រព័ន្ធច្បាប់មានចំនួនប៉ុណ្ណោះដែរ ដែលមានទំនងសេចក្តីថា "**ប្រទេសមួយ មានប្រព័ន្ធច្បាប់មួយ**"។ បានជាហ៊ានឆ្លើយយ៉ាងដូច្នេះ ជ្បឹតប្រទេសដែលទទួលយកឥទ្ធិពល ប្រព័ន្ធច្បាប់រ៉ូម៉ាំង/អាល្លឺម៉ង់ក្តី ឬប្រព័ន្ធច្បាប់អង់គ្លោសាក់សុងក្តី ឬប្រព័ន្ធឯទៀតក្តី តិចឬច្រើនរមែងមានចំណុចខុសប្លែកពីគ្នា អាស្រ័យដោយ

ប្រទេស ទាំងនោះមាន **អត្តសញ្ញាណរបស់ខ្លួន** ក្នុងការអនុវត្តប្រព័ន្ធច្បាប់។ អាស្រ័យហេតុនេះ ក្នុងស្មារតីរួមគិតជុំវិញប្រធានបទខាងលើនេះ អ្នកវិភាគគួរឈរលើគោលគំនិត (Concept) "**ប្រទេសមួយ មានប្រព័ន្ធច្បាប់មួយ**" ដែលប្រព័ន្ធច្បាប់មួយនោះ កើតចេញពីការបន្សាំបន្សុីរវាងគុណតម្លៃប្រព័ន្ធច្បាប់ ដែលខ្លួនទទួលរងឥទ្ធិពល រួមផ្សំនឹងគុណតម្លៃជាតិ ដែលជាអត្តសញ្ញាណរបស់ខ្លួន។

ផ្អែកលើគោលគំនិត (Concept) ខាងដើម នុ៎ះ! អាចធ្វើសេចក្តីសង្ខេបបានថា "**ប្រទេសកម្ពុជា មានប្រព័ន្ធច្បាប់របស់កម្ពុជា**" ដោយប្រព័ន្ធច្បាប់របស់កម្ពុជា កើតចេញពីការបន្សាំុបន្សុីរវាងគុណតម្លៃប្រព័ន្ធច្បាប់ទាំងឡាយ ដែលកម្ពុជាបានទទួលយក រួមផ្សំនឹង **គុណតម្លៃខ្មែរ** ជាកេតនភណ្ឌសម្គាល់អត្តសញ្ញាណជាតិខ្មែរ។ ដូច្នេះដើម្បីនឹងកំណត់នូវអត្តសញ្ញាណនៃប្រព័ន្ធច្បាប់របស់កម្ពុជា នោះកិច្ចការដា **អាទិភាព** គឺត្រូវធ្វើការសិក្សាស្រាវជ្រាវរកឲ្យឃើញនូវ គុណតម្លៃខ្មែរ (Khmer Values) ដែលមានក្នុងការអនុវត្តប្រព័ន្ធច្បាប់របស់កម្ពុជា។ ពាក្យថា **គុណតម្លៃ** (Values)គឺជាគោលការណ៍ ឬ ជាគោលគំនិត នៃបុគ្គល ឬ ក្រុមនៃបុគ្គល ដែលកំណត់ថាអ្វីមួយត្រូវឬខុស អ្វីមួយល្អឬមិនល្អ (VALUES are principles, ideas and norms that are generally accepted by particular group as important concepts of right and wrong)។ នៅក្នុងន័យនេះ **គុណតម្លៃខ្មែរ** នឹងធ្វើការកំណត់នូវអត្តសញ្ញាណនៃជាតិសាសន៍ខ្មែរ ដាច់ដោយឡែកពីជាតិសាសន៍ដទៃ ហើយ **គុណតម្លៃខ្មែរ** ដែលមានក្នុងប្រព័ន្ធច្បាប់កម្ពុជា ក៏នឹងកំណត់លក្ខណៈពិសេសដោយឡែករបស់ខ្មែរ ប្លែកពីប្រព័ន្ធច្បាប់របស់ប្រទេសទាំងឡាយក្នុងលោក។

គុណតម្លៃប្រពៃណីខ្មែរគឺ ជាតិ សាសនា ព្រះមហាក្សត្រ ដែល **ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត** អុឹម ឈុន លឹម អតីតប្រធានក្រុមប្រឹក្សាធម្មនុញ្ញ បានលើកឡើងជាគុណតម្លៃប្រពៃណីខ្មែរមានចារឹកក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាមូលដ្ឋានគ្រឹះដ៏សំខាន់ ក្នុងការសិក្សាវិភាគឈានទៅកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា ហើយក្នុងក្របខណ្ឌនៃគុណតម្លៃទាំងបីនេះ អ្វីដែលគួរត្រូវបានធ្វើការសិក្សាឲ្យបានសុីជម្រៅតទៅទៀតគឺ៖ គុណតម្លៃវប្បធម៌នយោបាយខ្មែរ, គុណតម្លៃសេដ្ឋកិច្ច/សង្គមខ្មែរ, គុណតម្លៃប្រពៃណីទំនៀមទម្លាប់ល្អ/ជំនឿ/សាសនា របស់ជាតិខ្មែរ។ល។ ដែលបានផ្សាភ្ជាប់ទំនាក់ទំនងនឹងប្រព័ន្ធច្បាប់មួយដែលកម្ពុជាបាននិងកំពុងអនុវត្ត ជាឧទាហរណ៍ *គុណតម្លៃនៃវប្បធម៌នយោបាយខ្មែរ* ប្រហែលជាអាចនិយាយបានថា អ្នកនយោបាយខ្មែរជ្រើសរើសយកការចរចា និងការសម្បទានអំណាច តាមរយៈគុណតម្លៃនេះខ្មែរបានបង្កើត **ច្បាប់ធម្មនុញ្ញបន្ថែម** កាលពីឆ្នាំ

២០០៤ ដើម្បីបញ្ចប់ភាពទាល់ច្រកផ្នែកនយោបាយ និងច្បាប់។ *គុណតម្លៃនៃសង្គមខ្មែរ* គឺ ភាពកតញ្ញុចំពោះមាតាបិតា គ្រូឧបជ្ឈាយាចារ្យ ជាដើម តាមរយៈគុណតម្លៃនេះ មាត្រា៤៧ នៃរដ្ឋធម្មនុញ្ញ បានចែងអំពីករណីយកិច្ចរបស់កូន ក្នុងការចិញ្ចឹមនិងបីបាច់ថែរក្សាមាតាបិតាចាស់ជរា។ *គុណតម្លៃប្រពៃណីទំនៀមទម្លាប់ល្អ/ជំនឿ/សាសនារបស់ខ្មែរ* គឺការគោរពព្រះពុទ្ធសាសនា និងការគោរពប្រតិបត្តិជំនឿដូនតាខ្មែរ (ព្រហ្មញ្ញសាសនា/ជំនឿអ្នកតានិយម) តាមរយៈគុណតម្លៃនេះ មាត្រា៤៣ នៃរដ្ឋធម្មនុញ្ញ បានចែងអំពីសិទ្ធិខាងជំនឿ និងតម្កល់ព្រះពុទ្ធសាសនាជាសាសនារបស់រដ្ឋ។

១.៥. អនុសាសន៍

ការកំណត់បាននូវ គុណតម្លៃខ្មែរ (Khmer Values) ជាកត្តាចាំបាច់ឈានទៅរកការកំណត់ **អត្តសញ្ញាណ ប្រព័ន្ធច្បាប់កម្ពុជា**។ ការកំណត់បាននូវ **អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** គឺជាកត្តាសត្យានុម័តក្នុងការឆ្ពោះទៅរកការកំណត់អំពី **បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**។ ប៉ុន្តែបើនិយាយអំពីបូរណភាពនៃប្រព័ន្ធច្បាប់មួយ វាហាក់ដូចជាមានន័យទូលំទូលាយ ដូច្នេះទាក់ទងនឹងប្រធានបទទី៣ គួរធ្វើដែនកំណត់មួយ (Scope and Limitation) តាមរយៈការឲ្យនិយមន័យ ទៅលើអ្វីទៅដែលហៅថា **បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**? ទាក់ទងនឹងនិយមន័យនេះ អាចមានការពិភាក្សាច្រើន ប៉ុន្តែនៅទីនេះ សូមស្នើនូវនិយមន័យមួយ ដែលគួរធ្វើការពិចារណា "**បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា គឺស្ថានភាពរក្សាបាននូវឧត្តមានុវត្តន៍នៃគុណតម្លៃខ្មែរ** (Khmer Values) **ក្នុងសុខដុមនីយកម្មនៃការអនុវត្តប្រព័ន្ធច្បាប់កម្ពុជា**។"[៣៩០]

ជាអនុសាសន៍ ប្រព័ន្ធច្បាប់កម្ពុជាក្នុងពេលបច្ចុប្បន្ន គឺជាសមិទ្ធផលនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជា ក្នុងការ អនុវត្តប្រព័ន្ធច្បាប់មួយ ស្របតាមស្ថានភាពនិងបរិបទរបស់កម្ពុជា។ ប្រព័ន្ធច្បាប់កម្ពុជាក្នុងពេលបច្ចុប្បន្ននេះ បានជ្រាបចូលក្នុងសសៃឈាមគ្រប់ផ្នែក នៃរចនាសម្ព័ន្ធសង្គមខ្មែររួចស្រេចអស់កាលយូរមកហើយ ដូច្នេះអ្វីដែលសំខាន់បំផុតគឺការចាប់ផ្តើមជជែកពិភាក្សារួមគ្នា ជីកកកាយស្វែងរក និងកំណត់ឯកភាពគ្នាអំពី **គុណតម្លៃខ្មែរ** (Khmer Values) ដែលបាននិងគួរត្រូវបាននាំយកមកធ្វើសុខដុមនីយកម្មជាមួយគុណតម្លៃនៃប្រព័ន្ធច្បាប់ ដែលកម្ពុជាបានទទួលរងឥទ្ធិពល ដើម្បីឈានទៅរកការកំណត់អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ប្រកបដោយបូរណភាព។

ជាការពិតណាស់ ការជីកគាស់កកាយក្នុងលម្ហានប្រវត្តិសាស្ត្រ និងវប្បធម៌របស់ជាតិខ្មែរ ក្នុងការរកឲ្យឃើញនូវ **គុណតម្លៃខ្មែរ** ដែលមានជាប់ទាក់ទងនឹង **ប្រព័ន្ធច្បាប់** ប្រាកដណាស់ថាត្រូវប្រើពេលវេលាយូរតទៅទៀត ដើម្បីធ្វើការសិក្សា ស្រាវជ្រាវ ជជីកវែកញែក ពិភាក្សាគ្នា ឈានទៅដល់ការឯកភាពក្នុងការគោរពប្រតិបត្តិ ទុកជាគ្រឹះនៃប្រព័ន្ធច្បាប់កម្ពុជា ប៉ុន្តែក្នុងដំណើរការនេះ ពិតជានឹងអាចនាំ **នីតិបញ្ញវន្តខ្មែរឲ្យមានឥស្សរភាព និងបូរណភាពខាងគំនិតនីតិសាស្ត្រ**។

---

[៣៩០] និយមន័យនេះ គឺជាការយល់ផ្ទាល់ខ្លួនរបស់ ឯកឧត្តម តាំង រតនា

គន្ថនិទ្ទេស

Chhom Kunthea. "Stone inscription of Wat Kiri Sdach Kong K1419: The interpretation and explanation" *Kampujasurya magazine* year 66 No 4 (special number), Buddhist Institute, Phnom Penh (2019).

Chuon Nath, *Khmer Dictionary*, (Phnom Penh,1968).

David S. Grewal & Jedediah S. Purdy, *The Original Theory of Constitutionalism*, 127 YALE L. J. 664 (2017).

IM Chhun Lim, Speech for the 30th Anniversary of the Promulgation of the Constitution of Cambodia, held on 06th October 2023.

IM Chhun Lim, Key Note Address for the 27th Anniversary of the Constitution of Cambodia, held on 24th September 2020

Jorg Menzel, "Cambodia from Civil War to a Constitution to Constitutionalism", in *Cambodian Constitutional law* (Konrad Adenauer Stiftung, 2016).

Taing Ratana, " The Influence of Constitutional law on the Administrative Law: The influence of the Constitutional Council's decisions on the Administration in Cambodia", in *The Development of Cambodian Administrative Law* (Konrad Adenauer Stiftung publication, 2014).

Taing Ratana,"The Pluralist Constitution in Cambodia", in *The Pluralist Constitution in Southeast Asia* (Hard Publishing House, 2017).

Taing Ratana, "Constitutional Change and Amendment in Cambodia", *Journal of Comparative Law*, (Wildy, Simmonds & Hill Publishing, 2019).

ឧបសម្ព័ន្ធ៖ សន្ទូបគោលគំនិតនៃអត្ថបទ

សន្ទូបគោលគំនិតនៃអត្ថបទ

ផ្អែកលើគោលគំនិត៖
ប្រទេសមួយ គឺមានប្រព័ន្ធច្បាប់មួយ

ប៉ុន្តែប្រព័ន្ធច្បាប់នោះ កើតឡើងពីការបន្សាំបន្សុីរវាងតម្លៃនៃប្រព័ន្ធច្បាប់ទាងក្រៅ និងគុណតម្លៃជាតិ

គុណតម្លៃរដ្ឋធម្មនុញ្ញកម្ពុជា

(មរតកគំនិតរបស់ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត អ៊ឹម ឈុនលឹម អតីតប្រធាន កបធ)

គុណតម្លៃទំនើប	បន្សាំបន្សុី	គុណតម្លៃប្រពៃណីខ្មែរ
- ប្រជាធិបតេយ្យ		- ជាតិ
- សិទ្ធិមនុស្ស	- Equilibre?	- សាសនា
- នីតិរដ្ឋ	- Amalgam?	- ព្រះមហាក្សត្រ
(ជាមូលដ្ឋានគ្រឹះ)		

អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា

ប្រព័ន្ធច្បាប់រ៉ូម៉ាំង-អាល្លឺម៉ង់

+

ឥទ្ធិពលនៃប្រព័ន្ធច្បាប់នានា

គុណតម្លៃខ្មែរ

- គុណតម្លៃវប្បធម៌នយោបាយខ្មែរ
- គុណតម្លៃសេដ្ឋកិច្ច/សង្គមខ្មែរ
- គុណតម្លៃប្រពៃណីទំនៀមទម្លាប់ល្អរបស់ខ្មែរ
- គុណតម្លៃ ជំនឿ សាសនា ខ្មែរ ។ល។

(គុណតម្លៃខ្មែរជាកត្តាកំណត់អត្តសញ្ញាណច្បាប់ខ្មែរ)

(អត្តសញ្ញាណនៃប្រព័ន្ធច្បាប់ខ្មែរ ជាកត្តាកំណត់បូរណភាពនៃប្រព័ន្ធច្បាប់

បូរណភាពនៃប្រព័ន្ធច្បាប់ខ្មែរ

" បូរណភាពនៃប្រព័ន្ធច្បាប់របស់កម្ពុជា គឺស្ថានភាពរក្សាបាននូវឧត្តមានុវត្តនៃគុណតម្លៃខ្មែរ (Khmer Values) ក្នុងសុខដុមនីយកម្មនៃការអនុវត្តប្រព័ន្ធច្បាប់កម្ពុជា។" (និយមន័យតាមការយល់របស់អ្នកនិពន្ធ)

ផ្នែកទី២. នីតិរដ្ឋបាល

សិក្ខាអំពី «នីតិរដ្ឋបាល»

ឧត្តមបណ្ឌិត ថេង ច័ន្ទសង្វារ រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ និងជាសមាជិក គ.ក.ច.

២.១. ខ្លឹមសារសង្ខេប

នៅអឺរ៉ុប នីតិរដ្ឋបាលត្រូវបានចាត់ទុកថាកើតក្រោយគេបន្តិច ព្រោះថាវាកើតពីបដិវត្តន៍ប្រជាជនដែលផ្តួលរំលំរបបរាជានិយមផ្តាច់ការនៅចុងសម័យយុគកណ្តាល។ ចាប់ពីពេលនោះមក រដ្ឋបាលត្រូវបានដាក់បន្តិចម្តងៗឱ្យនៅក្រោមសំណុំវិធានពិសេសមួយ (ប្រព័ន្ធច្បាប់ CIVIL LAW) ឬក្រោមសំណុំវិធាននៃច្បាប់ទូទៅដូចគេឯង (ប្រព័ន្ធច្បាប់ COMMON LAW)។ នៅកម្ពុជា យើងមានការលំបាកក្នុងការកំណត់ថ្ងៃចាប់កំណើតរបស់នីតិរដ្ឋបាលណាស់។ បើយោងតាមនិយមន័យដែលត្រូវបានកំណត់និងទទួលស្គាល់ជាទូទៅ ទាំងនៅក្នុងប្រព័ន្ធច្បាប់ CIVIL LAW ទាំងនៅក្នុងប្រព័ន្ធច្បាប់ COMMON LAW អ្នកសិក្សាមួយចំនួនហ៊ានអះអាងថានៅកម្ពុជាគ្មាននីតិរដ្ឋបាលទេ។

តែទោះជាយ៉ាងណា បើយើងពិនិត្យឱ្យបានស៊ីជម្រៅ យើងពិតជាមានការពិបាកក្នុងការប្រៀបប្រដូចរបបគ្រប់គ្រងប្រទេសដោយព្រះមហាក្សត្រខ្មែរកាលតាំងពីបុរាណកាល ជាមួយរបបរាជានិយមផ្តាច់ការដែលត្រូវបានអនុវត្តនៅប្រទេសលោកខាងលិចណាស់។ របបរាជាធិបតេយ្យខ្មែរខុសពីរាជានិយមផ្តាច់ការនៅអឺរ៉ុបត្រង់ថា ព្រះមហាក្សត្រខ្មែរគ្រប់ជំនាន់តាំងពីអតីតកាលបានរៀនសូត្រនិងទទួលឥទ្ធិពលពីសាសនាសំខាន់ចំនួនពីរដែលមានប្រភពពីប្រទេសឥណ្ឌា នោះគឺព្រហ្មញ្ញសាសនានិងព្រះពុទ្ធសាសនា ដែលបានចូលរួមកំណត់បុគ្គលិកលក្ខណៈរបស់មេដឹកនាំខ្មែរផង វិធាននៃការគ្រប់គ្រងនគរខ្មែរផង ផ្នត់គំនិតនិងជំនឿរបស់ប្រជាជនខ្មែរផង។

ទោះបីជាអាណានិគមនិយមបារាំងបានប្រើឥទ្ធិពលរបស់ខ្លួនយ៉ាងយូរមកលើសង្គមនិងប្រជាជនខ្មែរយើងក្តី យើងសង្កេតឃើញថាពុំមាននៅសល់ទស្សនវិជ្ជាអ្វីជាដុំកំភួននៅក្នុងផ្នត់គំនិត ទំនៀមទម្លាប់ និងប្រពៃណីខ្មែរឡើយ។ មនោគមវិជ្ជាម៉ាក្សនិយមដែលត្រូវបានយកមកអនុវត្តនៅស្រុកខ្មែរមួយរយៈពេល ក៏ទទួលជោគវាសនាដូចគ្នានេះដែរ។ នេះប្រហែលមកពីគុណតម្លៃរបស់ខ្មែរមានវត្តមានស្រាប់ ហើយថែមទាំងមានលក្ខណៈ

ជ្រាលជ្រៅ គ្រប់ជ្រុងជ្រោយ និងទទួលបានការគាំទ្រនិងទទួលយកពីប្រជាជនខ្មែរជាទូទៅ និងជាយូរយារណាស់មកហើយ។

គុណតម្លៃពិសេសទាំងឡាយរបស់ខ្មែរទាំងនោះ ត្រូវបានដកស្រង់ចេញពីទស្សនវិជ្ជានៃសាសនាទាំងពីរ ពិសេសព្រះពុទ្ធសាសនា ហើយត្រូវបានកែច្នៃឱ្យមានលក្ខណៈខ្មែរជាបន្តបន្ទាប់ដោយបុព្វបុរសខ្មែរ និងត្រូវបានសរសេរបញ្ចូលបន្តិចម្តងៗមកក្នុងក្បួន ច្បាប់ និង "ក្រម" ខ្មែរ ក្រោយទម្រង់ជាវិធានសម្រាប់គ្រប់គ្រងរដ្ឋ វិធានសម្រាប់មេដឹកនាំ និងវិធានសម្រាប់ប្រជាជន។ បើគេគិតថានីតិរដ្ឋបាល ត្រូវបានបង្កើតដើម្បីស្វែងរកសេចក្តីសុខរបស់រាស្ត្រប្រជា ស្ថិតក្រោមការគ្រប់គ្រងរបស់រដ្ឋបាលមួយ ទំនាក់ទំនងឪពុក-កូនបែបខ្មែរវាងរដ្ឋបាលនិងរាស្ត្រប្រជាដែលជាគុណតម្លៃស្នូលនៃនីតិខ្មែរ ពិតជាបានបំពេញគោលបំណងនេះហើយ។ ហេតុនេះនៅកម្ពុជា ការពង្រឹងនីតិរដ្ឋបាលខ្មែរ ប្រហែលជាចាំបាច់ត្រូវចាប់ផ្តើមពីការពង្រឹងទំនាក់ទំនងរដ្ឋបាលនិងរាស្ត្រប្រជាបែបឪពុក-កូននេះតទៅ។

នៅកម្ពុជា ទំនាក់ទំនងរដ្ឋបាល-រាស្ត្រប្រជា ដែលជាស្នូលនៃនីតិរដ្ឋបាល មានលក្ខណៈពិសេសដោយឡែក លើសពីទំនាក់ទំនងមេដឹកនាំ-កូនចៅ ឬទំនាក់ទំនងអ្នកគ្រប់គ្រង-អ្នកត្រូវគេគ្រប់គ្រង ប៉ុន្តែវាជាទំនាក់ទំនងឪពុក-កូនជាជាង។ កស្តុតាងប្រវត្តិសាស្ត្របង្ហាញថា ទំនាក់ទំនងឪពុក-កូននេះ កាន់តែត្រូវបានលើកតម្កើងរៀងរាល់ពេលដែលកម្ពុជាបានឆ្លងកាត់យុគសម័យរុងរឿង។ ទំនាក់ទំនងនេះឈរលើគោលការណ៍គ្រឹះចំនួន ៣ គឺទី១ មន្ត្រីរាជការត្រូវតែប្រកាន់នូវធម៌ដូចជាឪពុកមានចំពោះកូន ទី២ ការគ្រប់គ្រងរាស្ត្រប្រជាត្រូវធ្វើទៅតាមគោលការណ៍ដែលព្រះបរមគ្រូបានប្រៀនប្រដៅ និងទី៣ រាស្ត្រប្រជាត្រូវគោរពប្រតិបត្តិមន្ត្រីរាជការដូចជាកូនគោរពប្រតិបត្តិឪពុកដូច្នេះដែរ។ ការបង្រៀនទ្រឹស្តីនិងទស្សនវិជ្ជាព្រះពុទ្ធសាសនាសម្រាប់សង្គមខ្មែរ ប្រាកដជាមានភាពងាយស្រួលជាងការបង្រៀនទ្រឹស្តីនិងទស្សនវិជ្ជារបស់លោកខាងលិច ព្រោះស្រុកខ្មែរមានមូលនិធិចំណេះដឹងព្រះពុទ្ធសាសនា ស្ទើរក្នុងគ្រប់សរសៃរឈាមរបស់សង្គមស្រាប់។ ការយកទ្រឹស្តីនិងទស្សនវិជ្ជាព្រះពុទ្ធសាសនាដែលល្អៗនិងទាន់សម័យ មកធ្វើជាមូលដ្ឋាននៃតាក់តែងនិងសរសេរច្បាប់រដ្ឋបាលខ្មែរ ឬច្បាប់ដទៃទៀត ប្រាកដជាធ្វើឱ្យច្បាប់ខ្មែរងាយយល់ ងាយចងចាំទាំងពីមហាជនទូទៅ ទាំងពីមន្ត្រីរាជការ។ ការរៀបចំឱ្យកូនឈ្លោះជាមួយនឹងឪពុកតាមរយៈការជំរុញបង្កើតតុលាការរដ្ឋបាលដោយឡែក ប្រហែលមិនមែនជាជម្រើសសម្រាប់ស្រុកខ្មែរនាពេលបច្ចុប្បន្នទេ។ យើងត្រូវរង់ចាំយ៉ាងហោចឱ្យច្បាប់ខ្មែរ

វិលត្រឡប់មកផ្អែកលើមូលដ្ឋានប្រពៃណីនិងទំនៀមទម្លាប់ដើមរបស់ខ្លួន ហើយមន្ត្រីរាជការនិងប្រជាពលរដ្ឋបានស្គាល់និងយល់អំពីច្បាប់របស់ខ្លួនសិន។

២.២. សេចក្តីផ្តើម

មិនដូចនីតិដទៃទៀតភាគច្រើនដែលកកើតតាំងពីសម័យបុរាណមក នីតិរដ្ឋបាលហាក់កើតក្រោយគេបន្តិច។ នៅទ្វីបអឺរ៉ុប គេចាប់ផ្តើមនិយាយអំពីនីតិនេះ នៅក្រោយយុគសម័យបដិវត្តន៍ ព្រោះជាយុគដែលសិទ្ធិសេរីភាពរបស់ប្រជារាស្ត្រ ត្រូវបានទាមទារនិងទទួលបានពីអង្គការចាត់តាំងនៃរបបរាជានិយមផ្តាច់ការ។ ពីមុនមក វិស័យដែលស្ថិតក្រោមនីតិរដ្ឋបាលបច្ចុប្បន្ន ច្រើនតែស្ថិតក្រោមនីតិរដ្ឋធម្មនុញ្ញ ព្រោះអ្វីៗទាំងអស់តែងស្ថិតនៅក្រោមសមត្ថកិច្ចស្ថាប័នព្រះមហាក្សត្រតែមួយគត់ ដោយសារតែពុំមានការអនុវត្តគោលការណ៍បែងចែកអំណាច។ ប៉ុន្តែទោះបីជានីតិរដ្ឋបាលកើតចេញពីបដិវត្តន៍ដូចគ្នា ក៏យើងសង្កេតឃើញថានីតិរដ្ឋបាលដែលមានក្នុងប្រព័ន្ធច្បាប់ធំៗទាំងពីរ ដែលមានកំណើតនៅទ្វីបអឺរ៉ុប គឺប្រព័ន្ធច្បាប់ CIVIL LAW និងប្រព័ន្ធច្បាប់ COMMON LAW មានលក្ខណៈខុសគ្នាទាំងទ្រឹស្តី ទាំងគោលការណ៍ ទាំងការអនុវត្ត (ផ្នែកទី១)។ ដោយឡែក នីតិរដ្ឋបាលនៅក្នុងប្រព័ន្ធច្បាប់ខ្មែរ ពុំបានចាប់កំណើតពីបដិវត្តន៍ទេ ប៉ុន្តែពីបន្សំនៃធាតុក្នុងស្រុកនិងធាតុនាំចូលពីបរទេស (ផ្នែកទី២)។

២.២.១. ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law)

មិនខុសពីនីតិដទៃទៀតទេ នីតិរដ្ឋបាលនៅក្នុងប្រព័ន្ធច្បាប់ CIVIL LAW គឺជាបណ្តុំនៃវិធានដែលកើតពីប្រភពសរសេរ និងគោលការណ៍ទូទៅដែលកើតពីប្រភពយុត្តិសាស្ត្រនៃតុលាការជំនាញរដ្ឋបាល។ ចំណុចសំខាន់ ២ ដែលធ្វើឱ្យនីតិនេះមានលក្ខណៈខុសពីនីតិរដ្ឋបាលនៃប្រព័ន្ធច្បាប់ COMMON LAW គឺទី១)ទ្វិភាពនៃប្រព័ន្ធតុលាការ (មានប្រព័ន្ធតុលាការពីរ) និងទី២)លក្ខណៈស្វយ័តពីនីតិរួម (នីតិឯជន)។

ក. ប្រព័ន្ធតុលាការ

ទ្វិភាពនៃប្រព័ន្ធតុលាការ សំដៅដល់ប្រព័ន្ធមួយដែលមានអង្គការចាត់តាំងតុលាការពីរដាច់ពីគ្នាគឺអង្គការចាត់តាំងតុលាការរដ្ឋបាល ដោយឡែកពីអង្គការចាត់តាំងតុលាការរដ្ឋប្បវេណី។ ទ្វិភាពនេះកើតពីគំនិតរបស់អ្នកបដិវត្តន៍បារាំង ដែលប្រកាន់យក

គោលការណ៍បែងចែកអំណាចរវាងអង្គការនីតិប្រតិបត្តិ និងអង្គការតុលាការ[៣៩១] ក្នុងន័យថា បើគោរពគោលការណ៍បែងចែកអំណាចឱ្យបានម៉ត់ចត់ តុលាការមិនត្រូវមកត្រួតត្រាលើការងាររបស់រដ្ឋបាលដែលនៅខាងនីតិប្រតិបត្តិនោះទេ។ អំណាចនីតិប្រតិបត្តិត្រូវរៀបចំយន្តការផ្ទៃក្នុងដើម្បីសម្អាតផ្ទៃក្នុងខ្លួនឯង។ យន្តការផ្ទៃក្នុងនេះបានវិវត្តបន្តិចម្តងៗទៅជាអង្គការចាត់តាំងតុលាការរដ្ឋបាលមួយដែលមានលក្ខណៈពេញលេញនិងដែលមានចៅក្រមអាជីពបំពេញការកិច្ច[៣៩២]។ មិនខុសពីចៅក្រមរដ្ឋប្បវេណី ចៅក្រមរដ្ឋបាលមានតួនាទីសកម្មនៅការជម្រះក្តី ត្រូវដើរតួសកម្មក្នុងស្វែងរកការពិត ពោលគឺត្រូវដឹកនាំការស៊ើបអង្កេត ការប្រមូលភស្តុតាង និងក្នុងជជែកវែកញែកក្នុងសវនការ (système inquisitoire)[៣៩៣] មិនមែនគ្រាន់តែជាអាជ្ញាកណ្តាលធម្មតាប៉ុណ្ណោះទេ។ ចំណុចនេះវាឆ្លើយតបនឹងទស្សនវិជ្ជាដែលថាយុត្តិធម៌គឺជាសេវាសាធារណៈដែលមានគោលបំណងស្វែងរកការពិតជាសត្យានុម័ត។ ម្យ៉ាងទៀត វិធាននិងគោលការណ៍ដែលចៅក្រមរដ្ឋបាលប្រើសម្រាប់ជាមធ្យោបាយសម្រាប់ជម្រះក្តីរដ្ឋបាល មិនដូចជាវិធានដែលចៅក្រមរដ្ឋប្បវេណីប្រើនោះទេ។ ការណ៍នេះបានធ្វើឱ្យនីតិរដ្ឋបាលក្លាយជានីតិស្ម័យត។

ខ. នីតិស្ម័យត

លក្ខណៈស្ម័យតនៃនីតិរដ្ឋបាល (ហើយដែលធ្វើឱ្យអ្នកខ្លះហៅវាថាជានីតិស្ម័យត) បានមកពីហេតុផលថា គេអនុវត្តចំពោះប្រជាជនទូទៅនូវវិធាននិងគោលការណ៍ដោយឡែកពីនីតិរួម។ វិធាននិងគោលការណ៍ដោយឡែក (ឬពិសេសនេះ) វាមានឫសគល់យូរអង្វែងក្នុងអតីតកាលពីទស្សនវិជ្ជារ៉ូម៉ាំង ដែលថាអំណាចរដ្ឋមិនអាចត្រូវបានចាត់ទុកឱ្យនៅត្រឹមស្មើនឹងរាស្ត្របានទេ ព្រោះរដ្ឋនិងរាស្ត្រមានគោលបំណងខុសគ្នាឆ្ងាយ។ រដ្ឋធ្វើអ្វីៗគឺដើម្បីបម្រើប្រយោជន៍រួម រីឯរាស្ត្រធ្វើអ្វីៗគឺដើម្បីសម្រេចគោលបំណងសួនតួរបស់ខ្លួន។ ក្នុងន័យនេះ នៅពេលគិតគូរវាយតម្លៃអំពីនីត្យានុកូលភាពនៃរាល់ទង្វើរបស់រដ្ឋ គេត្រូវបម្រុង

---

[៣៩១] ច្បាប់ចុះថ្ងៃទី១៦-២៤ ខែសីហា ឆ្នាំ១៧៩០ ត្រង់មាត្រា១៣ បានហាមច្បាស់ៗមិនឱ្យតុលាការមកជ្រៀតជ្រែកការងាររបស់រាជការឬកោះហៅអ្នករាជការទៅឆ្លើយចំពោះមុខតុលាការឡើយ។

[៣៩២] ច្បាប់ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ១៨៧២ បានទទួលស្គាល់តួនាទីរបស់ Conseil d'Etat កាលនោះជាទីប្រឹក្សារបស់ផ្ទៅកិបាលជាតុលាការកំពូលរដ្ឋបាលជាផ្លូវការលើកដំបូង។

[៣៩៣] ប្រវត្តិនៃប្រព័ន្ធនេះបានចាប់ផ្តើមតាំងពីច្បាប់រ៉ូម៉ាំង ច្បាប់របស់វិហារកាតូលិកនាសម័យយុគកណ្តាល និងច្បាប់របស់របបរាជានិយមផ្តាច់ការបារាំងនាយុគកណ្តាល ដែលតាំងពីសម័យនោះចៅក្រមត្រូវបានតម្រូវឱ្យដឹកនាំការអង្កេតតឹងរឹងទៅតាមនីតិវិធីដើម្បីធានាស្វែងរកការពិត។

ទុកឱ្យរដ្ឋនូវសិទ្ធិពិសេសនិងផ្តាច់មុខ (ដែលគេហៅថា បុព្វសិទ្ធិ) ដែលអនុញ្ញាតឱ្យរដ្ឋ សម្រេចគោលបំណងដ៏ធំធេងនិងបេសកកម្មដ៏ធ្ងន់ធ្ងរបស់ខ្លួនបាន។

ក. គោលការណ៍គ្រឹះ

គោលការណ៍គ្រឹះសំខាន់ៗនៃនីតិរដ្ឋបាលរបស់ប្រព័ន្ធច្បាប់ CIVIL LAW នេះ មាន ៣ គឺទី១) គោលការណ៍នីត្យានុកូល (principe de légalité) ដែលតាមរយៈនេះ រដ្ឋបាលត្រូវធ្វើសកម្មភាពដោយអនុលោមតាមរាល់បញ្ញត្តិច្បាប់និងគោលការណ៍ជា ធរមានទាំងអស់[៣៩៤] បើពុំនោះទេរដ្ឋបាលនឹងត្រូវប្រជាជនចោទពីបទរំលោភអំណាច ឬ ពីបទបង្វែរអំណាច ទី២) គោលការណ៍សេវាសាធារណៈ ដែលជាគោលគំនិតដែល អនុញ្ញាតឱ្យមានវិធានពិសេស ខុសពីវិធានទូទៅ ហើយវិធាននេះជាទូទៅផ្អែកលើគោល ការណ៍មួយទៀតគឺគោលការណ៍វិសមភាព[៣៩៥] និងទី៣)គោលការណ៍សមាមាត្រ រវាង វិធានដែលរដ្ឋបាលដាក់ចេញនិងហានិភ័យដែលអាចនឹងកើតឡើង និយាយម្យ៉ាងទៀតគឺ ត្រូវមានសមាមាត្ររវាងមធ្យោបាយនិងគោលបំណង។

២.២.២. ប្រព័ន្ធច្បាប់ខមិនឡ (Common Law)

ក. នីតិសាធារណៈ:ស្ថិតក្រោមចៅក្រមរដ្ឋប្បវេណី

ខុសពីនីតិរដ្ឋបាលក្នុងប្រព័ន្ធច្បាប់ CIVIL LAW ស្រលះ នីតិរដ្ឋបាលក្នុងប្រព័ន្ធ ច្បាប់ COMMON LAW ពុំមានឯករាជភាពពីនីតិរួមទេ ផ្ទុយទៅវិញ វាជាមែកធាងមួយនៃ នីតិរដ្ឋប្បវេណី។ ហេតុផលគឺថាប្រទេសអង់គ្លេស ប្រកាន់យកគោលការណ៍អធិបតេយ្យ ភាពនៃសភា ពោលគឺអ្វីៗទូទាំងនគរត្រូវកំណត់ដោយសភា ហេតុនេះ ដោយរដ្ឋាភិបាល ចេញពីសភា រដ្ឋាភិបាលក៏ត្រូវស្ថិតនៅក្រោមច្បាប់តែមួយដូចគេឯង។ តុលាការដែលជា អ្នកបកស្រាយច្បាប់ និងបង្កើតយុត្តិសាស្ត្រ ក៏ត្រូវទទួលពិនិត្យទាំងលើទង្វើរបស់រដ្ឋបាល ផងដែរ។ និយាយយ៉ាងនេះ ពុំមានន័យថានីតិរដ្ឋបាលអង់គ្លេសឬអាមេរិកាំង ជានីតិឯក

---

[៣៩៤] រដ្ឋបាលត្រូវគោរពវិធានគតិយុត្តទាំងអស់ទៅតាមឋានានុក្រមរបស់វា រួមទាំងគោលការណ៍ទូទៅនានាដែលកើតចេញពី យុត្តិសាស្ត្ររបស់តុលាការរដ្ឋបាល (គោលការណ៍សមភាព គោលការណ៍សមាមាត្រ គោលការណ៍និរន្តរភាពនៃ សេវាសាធារណៈ។ល។)

[៣៩៥] ក្នុងប្រព័ន្ធច្បាប់ CIVIL LAW គោលការណ៍វិសមភាពគឺជាគោលការណ៍សរសេរ, ជាប្រព័ន្ធ និងមានខ្លឹមសារច្បាស់លាស់។ វាកើតពីឆន្ទៈរបស់អ្នកតាក់តែងច្បាប់។ ដោយសារគោលការណ៍នេះ រដ្ឋបាលទទួលបាននូវបុព្វសិទ្ធិនៃអំណាចសា ធារណៈ អនុញ្ញាតឱ្យរដ្ឋបាលដាក់ចេញកិច្ចរដ្ឋបាលឯកតោភាគី និងការបង្ខំឱ្យអនុវត្ត និងដែលធ្វើឱ្យរដ្ឋបាលមានវិសម ភាពជាមួយបុគ្គលដទៃ ប៉ុន្តែក្រោមហេតុផលថាខ្លួនបានបម្រើផលប្រយោជន៍ទូទៅ។

ជនទេ។ ចាប់តាំងពីពាក់កណ្តាលសតវត្សរ៍ទី២០មក តុលាការបានចេញយុត្តិសាស្ត្រជាបន្តបន្ទាប់បង្កើតបានជាសំណុំវិធាននិងគោលការណ៍ និងនីតិវិធីដោយឡែកសម្រាប់អនុវត្តតែចំពោះអង្គភាពសាធារណៈប៉ុណ្ណោះ។

ខ. ប្រព័ន្ធតុលាការ

ទោះក្នុងរឿងក្តីរដ្ឋបាលក្តី ក្នុងនាមជាចៅក្រមទូទៅ ចៅក្រមនៃប្រព័ន្ធច្បាប់ COMMON LAW ដើរតួនាទីអកម្មនៅក្នុងការជម្រះក្តី ព្រោះចៅក្រមមិនអាចផ្តួចផ្តើមឬដឹកនាំការស៊ើបអង្កេត ការប្រមូលភស្តុតាង និងការជជែកវែកញែកក្នុងសវនការបានឡើយ (système accusatoire)។ គូភាគីជាអ្នកផ្តល់ភស្តុតាង ហើយលើកលែងតែករណីមួយចំនួនតូច[៣៩៦] ចៅក្រមជម្រះក្តីផ្អែកតែលើអ្វីដែលគូភាគីស្នើឡើងអំឡុងពេលសវនការប៉ុណ្ណោះ។ អ្វីដែលចៅក្រមត្រូវយកចិត្តទុកដាក់បំផុតគឺការធានាឱ្យរដ្ឋបាលនិងប្រជាជនដែលជាភាគីវិវាទបានជជែកវែកញែកប្រកបដោយភាពស្មោះត្រង់និងសមធម៌។ ទោះបីជាមានតុលាការរដ្ឋបាលជំនាញមួយចំនួនត្រូវបានបង្កើតក៏ដោយ[៣៩៧] ក៏តុលាការទាំងនោះអនុវត្តគោលការណ៍ច្បាប់ទូទៅដូចច្បាប់ឯកជនដែរ ហើយតុលាការកំពូល ដែលជាតុលាការទោល គឺជាតុលាការដែលសម្រេចសេចក្តីចុងក្រោយបិទផ្លូវតវ៉ា។

គ. គោលការណ៍គ្រឹះ

នីតិរដ្ឋបាលក្នុងប្រព័ន្ធច្បាប់ COMMON LAW ជានីតិរួមនិងជាមែកធាងមួយនៃនីតិឯកជន ដែលប្រើគោលការណ៍គ្រឹះចំនួន ៣ គឺទី១) គោលការណ៍យុត្តិធម៌ធម្មជាតិនិងសមធម៌[៣៩៨] ទី២)គោលការណ៍នីតិរដ្ឋ (ឧត្តមានុភាពនៃច្បាប់) ពោលគឺបុគ្គលទាំងអស់, រួមទាំងរដ្ឋផងដែរ, ត្រូវស្ថិតក្រោមច្បាប់ដែលផ្អែកលើយុត្តិធម៌ធម្មជាតិនិងសមធម៌

---

[៣៩៦] ឧទាហរណ៍ពាក់ព័ន្ធនឹងសមត្ថកិច្ចចៅក្រម បញ្ហាជាគោលនយោបាយសាធារណៈ និងបញ្ហាខ្លះៗនៃនីត្យានុកូលភាពរបស់សេចក្តីសម្រេចរដ្ឋបាលមួយចំនួន។

[៣៩៧] តុលាការពិសេសទាំងនេះភាគច្រើន មានសមត្ថកិច្ចទទួលជម្រះរឿងក្តីពាក់ព័ន្ធនឹងអន្តោប្រវេសន៍ ពន្ធដារ ឬផលប្រយោជន៍នានាដែលផ្តល់ដោយរដ្ឋ។

[៣៩៨] បើប្រៀបធៀបជាមួយប្រព័ន្ធច្បាប់ CIVIL LAW សមធម៌គឺជាការបង្កើតឱ្យមានវិសមភាពទៅវិញ។ នៅក្នុងប្រវត្តិនៃប្រព័ន្ធច្បាប់ COMMON LAW សំណុំវិធាននេះច្បាប់នេះផ្អែកទូទៅលើសមភាព (យុត្តិធម៌ធម្មជាតិ) ប៉ុន្តែភាពតឹងរឹងនៃគោលការណ៍សមភាពពិបាកយកទៅអនុវត្តលើករណីជាក់ស្តែងចំពោះវិវាទនីមួយៗណាស់ ហេតុនេះសំណុំវិធានសមធម៌ត្រូវបានកើតឡើងបន្តិចម្តងៗដើម្បីបំពេញការខ្វះខាតនេះ។ ការបង្កើតវិធានសមធម៌នេះគឺជាការរំលោភលើគោលការណ៍សមភាពនេះតែម្តង ក៏ប៉ុន្តែវិសមភាពនេះមិនអាចកំណត់ជាមុនជាគោលការណ៍ទូទៅដូចក្នុងប្រព័ន្ធច្បាប់ CIVIL LAW ទេ តែចៅក្រមអាចពិចារណាទៅតាមករណីវិវាទនីមួយៗនៅពេលអនុវត្តជាក់ស្តែងក្នុងសវនការ។

នីតិវិធី និងទី៣) លទ្ធិ ultra vires ដែលមានអត្ថន័យថា **"រដ្ឋបាលមិនត្រូវប្រើអំណាចលើសពីអ្វីដែលច្បាប់ប្រគល់ឱ្យឡើយ"**។ គោលការណ៍ ultra vires និងគោលការណ៍នីត្យានុកូលនៃប្រព័ន្ធច្បាប់ CIVIL LAW មានគោលបំណងដូចគ្នាគឺធានាឱ្យរដ្ឋបាលគោរពច្បាប់ដើម្បីការពារប្រជាពលរដ្ឋពីការរំលោភបំពាន ក៏ប៉ុន្តែរបៀបគិតនិងអនុវត្តគោលការណ៍ទាំងពីរគឺខុសគ្នា។ គោលការណ៍ ultra vires កំណត់ព្រំដែនសមត្ថកិច្ចរបស់រដ្ឋបាលហើយរាល់សកម្មភាពដែលធ្វើហួសព្រំដែននោះនឹងត្រូវបានចាត់ទុកថាខុសច្បាប់ដោយតុលាការធម្មតា។ គោលការណ៍នីត្យានុកូល កំណត់ឱ្យរដ្ឋបាលធ្វើសកម្មភាពឱ្យស្របតាមបទដ្ឋានគតិយុត្តទាំងអស់ជាធរមាន បើមិនដូច្នោះទេនឹងត្រូវបានចាត់ទុកថាខុសច្បាប់ដោយតុលាការរដ្ឋបាល។ ប៉ុន្តែការវិវត្តចុងក្រោយជាមួយសញ្ញាណថ្មីៗបន្ថែមទៀត ភាពខុសគ្នារវាងគោលការណ៍ទាំងពីរកាន់តែមានភាពស្តួចស្តើងហើយ។

២.៣. បេក្ខភាពហើញ

២.៣.១. តួនាទីសាសនានៅក្នុងនីតិរដ្ឋបាលខ្មែរ

២.៣.១.១. ឥទ្ធិពលរបស់ព្រហ្មញ្ញសាសនា

ប្រជារាស្ត្រខ្មែរមិនអាចកាត់ផ្តាច់ពីរាជានិយមទេ ព្រោះអតីតព្រះមហាក្សត្រខ្មែរនេះហើយដែលបានកសាងអរិយធម៌កំពូលឱ្យនគរនិងមោទនភាពរបស់ជាតិសាសន៍ទៀតផង ។ នៅដើមគ្រឹស្តសករាជ ក្សត្រខ្មែរបាននាំព្រហ្មញ្ញសាសនាចូលមកក្នុងស្រុក ហើយធ្វើបរិវត្តសង្គមចាស់ឱ្យទៅជាសង្គមអារ្យ ដោយរក្សាឫសមូលដ្ឋានណាដែលអាចទុកជាដើមកំណើតនៃសង្គមខ្មែរ។ ការបង្កើតបានជារដ្ឋបែបសាសនាមួយ (១) បានអនុញ្ញាតឱ្យខ្មែរទទួលបាននៅក្នុងប្រវត្តិសាស្ត្ររបស់ខ្លួននូវអរិយធម៌ដ៏រុងរឿងមួយ ដោយសារតែព្រះមហាក្សត្រនិងរាស្ត្របានមានសុខដុមនីយកម្មក្រោមកិច្ចសន្យាសង្គមដោយមានជំនឿលើអាទិទេពជាមូលដ្ឋាន (២)។

ក. ការបង្កើតរដ្ឋតាមបែបព្រហ្មញ្ញសាសនា

មិនដូចប្រទេសជិតខាងយើងទេ ព្រហ្មញ្ញសាសនាមានចំណងទាក់ទងស៊ីជម្រៅជាមួយសញ្ញាណនៃរដ្ឋខ្មែរ។ អំណាចនយោបាយរបស់រដ្ឋត្រូវរៀបចំតាមវិធីសាស្ត្រជាក់លាក់មួយ។ ចំណងជិតស្និទរវាងរដ្ឋនិងសាសនាកើតឡើងដោយលក្ខណៈសាសនានៃព្រះមហាក្សត្រ។ ស្ថាបនិកអាណាចក្រអង្គរ ព្រះបាទជ័យវរ្ម័នទី២ (៨០២-៨៥០) បាននាំ

យកលទ្ធិទេវរាជមកប្រតិបត្តិ បន្ទាប់ពីបានបង្រួបបង្រួមជាតិឡើងវិញ។ តាមលទ្ធិនេះ ក្សត្រជាអាទិទេពដែលមានសិរីលីង្គជានិមិត្តរូប។

ព្រះមហាក្សត្រគឺជារដ្ឋ តែព្រះមហាក្សត្រជានិច្ចជាកាល តែងមានទីប្រឹក្សានៅជុំវិញព្រះអង្គ ជាអ្នកផ្តល់ប្រឹក្សាយោបល់និងជួយសម្រេចកិច្ចការព្រះអង្គ។ មានជំនឿថាពួកព្រាហ្មបុរោហិតទាំងនេះ បានទៅឋានលើដើម្បីរៀនគម្ពីរច្បាប់និងចំណេះដឹងសព្វទាំងពួង រួចត្រឡប់មកជួយព្រះមហាក្សត្រ។ ព្រះមហាក្សត្រចេញព្រះរាជបញ្ជាដោយព្រះរាជសារដែលត្រូវតែគោរពបូជាដាច់ខាត រហូតដល់អ្នកដែលបានប្រតិបត្តិតាមត្រឹមត្រូវនឹងបានចាប់ជាតិជាថ្មី។ នៅសម័យអង្គរ សាសនានិងច្បាប់មិនអាចកាត់ផ្តាច់ពីគ្នាទេ។ ទស្សនវិជ្ជាសាសនានិងទស្សនវិជ្ជានយោបាយក៏ដូច្នេះដែរ។ ជាលទ្ធផល អត្ថចរិកនៃវិធាននៃច្បាប់នៅសម័យនោះ មានលក្ខណៈជាក្រមសីលធម៌ដ៏ស៊ីជម្រៅមួយ។ នេះក៏ដោយសារហេតុថាជនជាតិខ្មែរតែងមានគិតគូរអំពីអនាគតជាតិផងដែរ។

អាស្រ័យដោយលទ្ធិទេវរាជ ព្រះមហាក្សត្រក្លាយជាម្ចាស់អំណាចតែមួយអង្គឯងគត់ក្នុងអាណាចក្រ ហើយមានសិទ្ធិអំណាចបញ្ជាកំពូល។ ក៏អ្វីដែលគួរឱ្យកត់សម្គាល់គឺថា ថ្វីបើអំណាចនោះជាអំណាចដាច់ខាត ប្រជារាស្ត្រខ្មែរមានទំនាក់ទំនងខ្លាំងជាមួយព្រះមហាក្សត្ររបស់ខ្លួន។ រាស្ត្រតែងរកក្សត្រនៅពេលត្រូវការ។ ព្រះមហាក្សត្រត្រូវមានលទ្ធភាពដោះស្រាយគ្រប់បញ្ហាសង្គម កុំថាឡើយត្រឹមនាំទឹកភ្លៀងសម្រាប់ធ្វើកសិកម្ម តែត្រូវខ្លាំងក្លាលើសគេឯងគ្រប់វិស័យ រួមទាំងការប្រយុទ្ធ ការរួមភេទ ការតែងកំណាព្យ ការមានទ្រព្យសម្បត្តិ ឬការរៀបចំពិធីផ្សេងៗ[៣៩៩]។

នៅក្នុងការដឹកនាំរដ្ឋ ស្ថាប័នខ្មែរដំណើរការទៅតាមការរៀបចំរបស់ពួកព្រាហ្មណ៍បុរោហិតដែលមានគម្ពីរព្រះធម្មសាស្ត្រជាក្បួនខ្នាតដែលមានប្រភពនៅឥណ្ឌា និងដែលត្រូវបាននាំចូលមកកម្ពុជាតាំងពីយូរមកហើយ។ គម្ពីរទាំងនេះច្រើនតែបរិយាយវិធានសម្រាប់ព្រះមហាក្សត្រក្នុងព្រះរាជតួនាទីជាអ្នកកាន់អំណាចនីតិប្រតិបត្តិ និងស្ទើរតែគ្មានបញ្ញត្តិពាក់ព័ន្ធនឹងអំណាចនីតិបញ្ញត្តិទេ។ មានភស្តុតាងបញ្ជាក់ថាក្សត្រចាត់ទុកព្រះធម្មសាស្ត្រដូចជាព្រះកេសាររបស់ព្រះអង្គ ពោលគឺជាច្បាប់កំពូលសម្រាប់ដឹកនាំទាំងអាណាចក្រ និងអាណាប្រជានុរាស្ត្ររបស់ព្រះអង្គ។ ក្នុងន័យនេះ ព្រះមហាក្សត្រដែលមានអំណាចស្មើអាទិ

[៣៩៩] ខ្មែរមិនចង់គិតថាព្រះមហាក្សត្ររបស់ខ្លួនត្រឹមជាគ្រប់គ្រង អ្នកបួស ឬអ្នកកាន់សីលទេ តែគឺជាវីរៈបុរស ជា hero ឬជា superman ក្នុងរឿងព្រេងនិទានទៅវិញ។

ទេព ប៉ុន្តែត្រូវជាប់នូវកាតព្វកិច្ចជាច្រើន ដើម្បីប្រយោជន៍ព្រះនគរ ប្រយោជន៍សាធារណៈ និងប្រយោជន៍ប្រជានុរាស្ត្ររបស់ព្រះអង្គ។

លក្ខណៈអធិតេយ្យនិងឯកភាពនៃអំណាច ត្រូវបានកំណត់នៅក្នុងច្បាប់អាទិទេព ដែលជាមូលដ្ឋាននៃលទ្ធិទេវរាជនៃរាជានិយមខ្មែរ សម្រាប់គាំពារនូវប្រយោជន៍នៃលទ្ធិនោះ គឺឯកភាពជាតិនិងសន្តិភាព។ ឯកភាពគឺជាបេសកកម្មសង្គ្រោះដែលជានាទីផ្តាច់មុខរបស់ព្រះមហាក្សត្រ។ ដូច្នេះព្រះអង្គជាអ្នករក្សាទុកនូវតួនាទីនេះតែម្នាក់ឯងលើលោកនេះ។ អាស្រ័យហេតុនេះ គឺត្រូវចាត់ទុកព្រះអង្គជាទេវរាជដែលមនុស្សត្រូវតែកោតខ្លាច។ ទោះបីជាស្តេចទេវៈ ព្រះអង្គមិនដែលប្រើរាជអំណាចយកទៅរំលោភលើប្រជារាស្ត្រនោះឡើយ។ ព្រះអង្គជាស្តេចល្អឥតខ្ចោះ ជាស្តេចយុត្តៈ ដោយសុក្រិតនិងអធិបតេយ្យ។ ព្រះអង្គគ្រប់គ្រងនគរដោយជាក់លាក់ដូចអាទិទេពគ្រប់គ្រងចក្រវាល ដើម្បីរក្សាសណ្តាប់ធ្នាប់លោកីយ៍និងឯកភាព។ ទោះជាយ៉ាងនេះក្តី ព្រះមហាក្សត្រខ្មែរមិនសម្រេចប្រើប្រាស់អំណាចតែអង្គឯងទេ។ ព្រះអង្គមានពពួកព្រាហ្មបុរោហិត និងមន្ត្រីសេនាបតីជាសេនាធិការ។ គេទាំងនោះច្រើនមានទំនាក់ទំនងញាតិជាមួយព្រះមហាក្សត្រទៀតផង។

ទោះជាយ៉ាងណាក្តី កង្វះនូវភស្តុតាងនិងឯកសារស្តីពីស្ថានភាពនៃការរស់នៅរបស់ប្រជារាស្ត្រខ្មែរពិតប្រាកដនាសម័យបុរាណ អ្នកស្រាវជ្រាវខ្លះក៏កើតមន្ទិលសង្ស័យលើរឿងនេះ[៤០០]។ តែមានអ្នកស្រាវជ្រាវច្រើនលើសលុបនៅតែយល់ថា យុត្តិធម៌វាស្ថិតនៅក្នុងធាតុនៃអាទិទេពទៅហើយ ព្រោះអ្នកបដិបត្តិទទួលយកថាព្រះអង្គជាអ្នកបង្កើតលោក ហើយដោយស្តេចទេវរាជជាតំណាងនៃអង្គអាទិទេពនៅលើផែនដីនៃមនុស្ស នាំឱ្យប្រជារាស្ត្រមានជំនឿដ៏មហិមា។ ភាពបរិសុទ្ធនៃអាទិទេពជាសិល្បៈដែលទាក់ទាញសទ្ធាដ៏ធំធេងរបស់មនុស្ស។ វាអាចបង្កើតជាជំនឿដ៏សែនជ្រៅ ព្រមទាំងសេចក្តីស្មោះស្ម័គ្រមេត្រីភាពរបស់ប្រជារាស្ត្រចំពោះស្តេចទេវរាជ ទោះបីនៅក្នុងលក្ខខណ្ឌបែបណាក៏ដោយ ទាំងនៅក្នុងរាជអំពើវិជ្ជមាន ទាំងអវិជ្ជមាន ព្រោះស្តេចទេវរាជមិនដែលប្រព្រឹត្តអ្វីខុសនោះ

[៤០០] រូបចម្លាក់លើផ្នាំងជញ្ជាំងនៃប្រាង្គប្រាសាទអង្គរវត្ត បង្ហាញនូវទិដ្ឋភាពអធិកអធមនៃក្បួនយោធានិងសង្គ្រាមដេដ្ឋជ័យដែលជានិមិត្តរូបនៃរាជមហិទ្ធានុភាពឆ្លាក់លើសីលា។ តើសេចក្តីប្តើងប្តើងនៃរូបភាពទាំងនោះ មានការទាក់ទងអ្វីនឹងសុភមង្គលនៃប្រជារាស្ត្រ? តើលទ្ធិទេវរាជផ្អែកលើឯកភាពជាតិនិងសន្តិភាព មានយុត្តិធម៌នៃមនុស្សលោកសម្រាប់ប្រជារាស្ត្រដែរឬទេ? តើទេវយុត្តិធម៌និងនរៈយុត្តិធម៌ ជាយុត្តិធម៌តែមួយសម្រាប់មនុស្សលោក?

ឡើយ។ ដូច្នេះព្រះអង្គមិនមែនជានីតិជន[៤០១] នោះទេ តែព្រះអង្គនិងនីតិគឺតែមួយ ព្រោះព្រះអង្គជាតំណាងនៃអាទិទេព។

ការដែលព្រះមហាក្សត្រប្រតិបត្តិសាសនាយ៉ាងតឹងរឹង បានជួយធានាឱ្យឯកភាពនៃសណ្តាប់ធ្នាប់ក្នុងលោកធាតុ ដែលព្រះអង្គអាចប្រើប្រាស់ជាគុណប្រយោជន៍សម្រាប់ក្នុងការពង្រឹងនិងពង្រីកអំណាច ដោយការសម្រេចបាននូវអធិបតេយ្យភាពសាសនាត្រួតគ្នាជាមួយអធិបតេយ្យភាពនយោបាយ នៅផ្នែកក្នុងអាណាចក្រ និងដោយការសម្រេចកសាងបាននូវលទ្ធិសាសនាជាក់លាក់មួយដែលមានព្រះអង្គជាប្រមុខ នៅផ្នែខាងក្រៅ។ ចំពោះប្រជារាស្ត្រទូទៅវិញ ការគោរពបូជាព្រហ្មសាសនាបានធ្វើឱ្យកើតមានលទ្ធិបុគ្គលនិយមនិងការជឿជាក់ថាមានមនុស្សជាអាទិទេព មិនថាបុរស ឬនារី។ សាសនានេះ ក៏បានបង្កើតឱ្យមានកម្រិតភក្តីភាពខ្ពស់បំផុតចំពោះអាទិទេព។ គោលការណ៍ភក្តីភាព គឺជាគោលការណ៍សីលធម៌ ដែលត្រូវបានលើកតម្កើងបំផុត។ ភក្តីភាពនេះហើយដែលជាប្រភពមិនចេះរីងស្ងួត ដែលជួយដល់ការកសាងជាតិ ដូចជាហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ឬកសិកម្ម និងការចូលរួមកម្លាំងប្រយុទ្ធក្នុងសង្គ្រាមជិតឆ្ងាយ។ តាមការពិត សមិទ្ធផលច្រើនណាស់កើតចេញពីការចូលរួមរបស់ប្រជារាស្ត្រ មិនថាជាកម្លាំង ឬជាទ្រព្យ។ ហើយជាមួយនឹងការរីកចម្រើននេះ ទោសទណ្ឌក៏ត្រូវបានគិតគូរចំពោះអ្នកដែលមិនមានភក្តីភាពចំពោះព្រះមហាក្សត្រផងដែរ[៤០២]។

ក្រៅពីនោះ ប្រជារាស្ត្រនៅមានកាតព្វកិច្ចបង់ពន្ធ។ ថ្វីបើច្បាប់សាសនាព្រហ្មណ៍មានឥទ្ធិពលខ្លាំងទៅលើព្រះមហាក្សត្រ តែចំពោះប្រជារាស្ត្រវិញគឺមិនដូចគ្នាទេ។ ប៉ុន្តែគឺព្រះមហាក្សត្រទៅវិញទេ ដែលមានឥទ្ធិពលទៅលើប្រជារាស្ត្ររបស់ព្រះអង្គ។ ជោគជ័យរបស់រដ្ឋកាលមួយមានការផ្សារភ្ជាប់ទៅជាចាំបាច់ទៅនឹងចរិតលក្ខណៈរបស់ប្រជារាស្ត្រចំពោះព្រះមហាក្សត្រ។ ការចូលរួមអភិវឌ្ឍនគរធ្វើឡើងតាមរយៈតាមការបង់ពន្ធ។ ច្បាប់ធម្មសាស្ត្រនៅឥណ្ឌាពីបុរាណ តម្រូវឱ្យបង់ពន្ធស្មើនឹងមួយភាគប្រាំមួយនៃភោគផលដែលប្រមូលបានទៅឃ្លាំងព្រះរាជាដែលជាម្ចាស់ទឹកដី ហើយអត្ថន័យគ្រឹះនៃប្រពៃណីនេះការចាត់ទុកការចូលរួមអភិវឌ្ឍជាតិតាមរយៈការបង់ពន្ធជាកិច្ចមួយដ៏សំខាន់បំផុត។ ការប្រមូលពន្ធគឺជាសិទ្ធិដែលមានលក្ខណៈពិសិដ្ឋរបស់ព្រះមហាក្សត្រ។ បុគ្គលដែលមិនព្រមបង់ពន្ធនឹងត្រូវទទួលទណ្ឌកម្មតាមច្បាប់ជាធរមាន។ ប្រពៃណីបង់ពន្ធរបស់ប្រជាជនខ្មែរ

[៤០១] sujet du droit

[៤០២] សម្បថជាកាតព្វកិច្ចសម្រាប់អភិជននិងមន្ត្រីជាន់ខ្ពស់។

ពីដើមគ្រឹស្តសករាជរហូតដល់សម័យអង្គរ មានប្រភពពីឥណ្ឌា និងមានការផ្សារភ្ជាប់ទៅនឹងជំនឿសាសនា។ ដោយសារព្រះមហាក្សត្រជាម្ចាស់ទឹក ម្ចាស់ដី មានអំណាចប្រៀបស្មើនឹងអាទិទេព ព្រះអង្គអាចនាំមកនូវសុភមង្គល និងវិបុលភាពសម្រាប់ប្រជារាស្ត្រទាំងអស់គ្នា។ ព្រះអង្គសោយរាជដោយព្រះធម្មឬព្រះធម៌។ ហេតុនេះបានជាជនជាតិខ្មែរជឿថាភាពចម្រុងចម្រើនរបស់សង្គមនិងការប្រមូលផលល្អ ត្រូវឆ្លងកាត់តាមការបង់ពន្ធថ្វាយព្រះមហាក្សត្រដែលជាម្ចាស់នៃភាវៈទាំងអស់លើលោក និងជាអ្នកធានាលំនឹងសុខមាលភាពរូបកាយ ផ្លូវចិត្ត និងសម្ភារៈគ្រប់យ៉ាង។

ខ. កិច្ចសន្យាសង្គម ឬកត្តាកំណត់តាពស្របច្បាប់នៃអំណាច

ខុសពីរាជានិយមផ្តាច់ការបែបអឺរ៉ុប ដែលអ្នកខ្លះយល់ថាគ្មានទេសញ្ញាណប្រយោជន៍សាធារណៈ រាជានិយមបែបព្រាហ្មនិយមនៅសម័យអង្គរប្រកាន់យកសញ្ញាណនេះជាឧត្តមគតិរាជ។ តាំងពីដើមរៀងមក ទុក្ខកង្វល់របស់ព្រះមហាក្សត្រខ្មែរ គឺការធានាស្ថិរភាពនិងអំណាចកណ្តាល។ ហើយដើម្បីទប់ទល់នឹងភាពអាណាធិបតេយ្យ លទ្ធិទេវរាជបានដើរតួរយ៉ាងមានប្រសិទ្ធភាពអស់ជាច្រើនសតវត្សរ៍។ គឺការឆ្លើយតបបានចំពោះប្រយោជន៍សាធារណៈនេះហើយ ដែលចូលរួមចំណែកធានាសណ្តាប់ធ្នាប់សាធារណៈ។ ជាងនេះទៀត ភាពជាអាទិទេពនៃព្រះមហាក្សត្រផ្អែកលើសណ្តាប់ធ្នាប់នៃចក្រវាលទាំងមូល។ ចំណុចនេះ រឹតតែអនុញ្ញាតឱ្យព្រះមហាក្សត្រ សម្រេចបានឯកភាពសាសនា និងនយោបាយរបស់អាណាចក្រ។ ព្រះអង្គមានបេសកកម្មច្រើនមុខ ដូចជាការពារជីវិតលើផែនដី ការពារសាសនា ជីវិតគ្រួសារ និងជីវិតសង្គម។ មានសិលាចារឹកច្រើនបញ្ជាក់ថាព្រះមហាក្សត្រទ្រង់ដោះស្រាយការតវ៉ារបស់រាស្ត្រដោយផ្ទាល់ព្រះអង្គ ហើយត្រូវធានាឱ្យប្រជារាស្ត្រទទួលបានការដោះស្រាយករណីក្តីក្តាំរបស់ខ្លួនជានិច្ចកាល។ សិលាចារឹកក៏បានរំលឹកថាព្រះមហាក្សត្របានសាងសង់ផ្លូវនិងសាលាសំណាក់ជាច្រើន ព្រមទាំងធ្វើដំណើរទៅគ្រប់ទីកន្លែងទូទាំងនគរដើម្បីអនុវត្តច្បាប់និងព្រះរាជបញ្ជា ដើម្បីជាប្រយោជន៍ប្រជានុរាស្ត្រ ជួយដល់ជនក្រីក្រ និងដើម្បីដាក់ទោសឧក្រិដ្ឋជន។ ព្រះអង្គក៏ទទួលខុសត្រូវលើបញ្ហាសុខភាពសាធារណៈ តាមរយៈការជំរុញសកម្មភាពកីឡា និងការពារសិល្បៈនិងអក្សរសាស្ត្រផងដែរ។ ព្រះមហាក្សត្រខ្មែរយកចិត្តទាំងជីវិតនយោបាយ សេដ្ឋកិច្ច សង្គម និងសាសនាដែលមហានគរអាស្រ័យលើ។ ព្រះអង្គត្រូវធ្វើឱ្យមានសន្តិភាព វិបុលភាព និងយុត្តិធម៌ ហើយព្រះអង្គធ្វើដោយផ្ទាល់។

សញ្ញាណប្រយោជន៍សាធារណៈក្នុងសាសនាព្រាហ្មណ៍ គឺជាកត្តាកំណត់ភាពធម្មានុរូបនៃអំណាចរបស់ព្រះមហាក្សត្រខ្មែរសម័យបុរាណ ក៏ប៉ុន្តែអំណាច **"ដាច់ខាត"** នេះ ក៏មានព្រំដែនរបស់វាផងដែរ។ ភាពធម្មានុរូបរបស់ព្រះមហាក្សត្រនៅត្រង់ថាព្រះអង្គស្វែងរកសណ្តាប់ធ្នាប់សង្គម។ ប្រជារាស្ត្រត្រូវគោរពព្រះមហាក្សត្រ។ ជាការប្តូរយកមកវិញ ព្រះមហាក្សត្រត្រូវសន្យាការពារប្រជារាស្ត្រ។ បើគ្មានព្រះមហាក្សត្រ មនុស្សជាតិនឹងត្រូវដាក់ទោសឱ្យរស់ក្នុងភាពចលាចលជាដរាប។ ការថ្វាយព្រះមហាក្សត្រនូវអំណាចកំពូលគឺជាការចាំបាច់ដើម្បីផ្តល់ភាពស្របច្បាប់ (ភាពជាធម្មានុរូប) ដល់ព្រះអង្គ ដែលមិនខុសឆ្ងាយពីសញ្ញាណកិច្ចសន្យាសង្គមក្នុងទ្រឹស្តីលោកខាងលិចឡើយ។ ព្រំដែនទី១ ដែលកំហិតទៅលើអំណាចរបស់ព្រះមហាក្សត្រគឺគុណសម្បត្តិផ្ទាល់របស់ព្រះអង្គ។ ព្រះអង្គត្រូវឈ្នះសត្រូវទាំងប្រាំមួយគឺការប្រព្រឹត្តកាមគុណ ការក្រេវក្រោធ ការលោភលន់ ការក្រអឺតក្រទម ភាពអវិជ្ជា និងការច្រណែន។ ហេតុនេះ អង្គព្រះមហាក្សត្រត្រូវតែប្រុងប្រយ័ត្នជាប់ជាប្រចាំអំពីគុណសម្បត្តិរបស់ព្រះអង្គ។ ដើម្បីទទួលបានគុណសម្បត្តិទាំងនេះ រាជទាយាទមិនត្រឹមតែត្រូវទទួលការហ្វឹកហ្វឺននិងត្រូវសិក្សាវិទ្យាសាស្ត្រនយោបាយនិងនីតិសាស្ត្រប៉ុណ្ណោះទេ តែត្រូវតែពូកែសាងសឹកទាហានទៀតផង។ ព្រំដែនទី២ ដែលកំហិតទៅលើអំណាចរបស់ព្រះមហាក្សត្រគឺមុខងាររបស់ព្រះអង្គ។ ក្នុងនាមជាម្ចាស់ព្រះនគរ ព្រះមហាក្សត្រត្រូវទទួលរ៉ាប់រងការពារទឹកដី ការដោះដូរ ការលក់ ឬប្រទានកម្មដីធ្លី ក៏ដូចជាការគ្រប់គ្រងមន្ត្រីនិងកងទ័ព និងការអភិវឌ្ឍសេដ្ឋកិច្ចផងដែរ។

ប៉ុន្តែទោះជាលទ្ធិទេវរាជធ្លាក់ចុះក្នុងទុរគតនិងសុញ្ញកាព តែឫទ្ធានុភាពនៃស្តេចទេវរាជវិញ ក៏នៅតែមានក្នុងផ្នត់គំនិតខ្មែរជានិច្ច ទោះបីមានការប្តូររបបដឹកនាំមកជារាជានិយមពុទ្ធគារវតា។ ចាប់ពីរាជកាល ព្រះបាទ ជ័យវរ្ម័នទី៧ (១១៨១-១២១៨?) របបរាជានិយមខ្មែរមានការវិវត្តទៅរកពុទ្ធគារវតា តែសាសនាព្រាហ្មណ៍នៅមានឥទ្ធិពលខ្លាំងគួរសមជានិច្ចនៅក្នុងវណ្ណៈក្សត្រនិងអភិជន[៤០៣]។ ដូច្នេះ នៅក្នុងគំនិតនៃរាជានិយមខ្មែរ រក្សាទុកព្រហ្មញ្ញសាសនាមិនគ្រាន់តែជាជំនឿសាសនា តែទុកជាគ្រឹះនៃស្ថាប័នតែម្តង[៤០៤]។ សម័យមហានគរ រយៈពេល ៦ សតវត្ស (សតវត្សទី៩ ដល់ទី១៥) គឺជាយុគសម័យដែលខ្មែរបានធ្វើការវិវត្តដ៏ឆាប់រហ័សពីទម្រង់សម័ន្ធនៃក្រុមនគរតូចៗចម្រុះរបស់ពួកកុលសម្ព័ន្ធ

[៤០៣] ដូចយ៉ាងព្រះបាទជ័យវរ្ម័នទី៧ ទោះបីព្រះអង្គជាពុទ្ធសាសនិក តែព្រះអង្គក៏នៅមានព្រហ្មណ៍បុរោហិតជាព្រះគ្រូរបស់ព្រះអង្គ។ ដូចគ្នានឹងព្រះបាទត្រសក់ផ្អែម (១៣៤០-?) ជាព្រះមហាក្សត្រពុទ្ធគារវតានិងជាអ្នកបង្កើតសន្តតិវង្សថ្មី តែព្រះអង្គក៏បានរៀបចំឡើងវិញនូវក្រុមព្រហ្មបុរោហិតស្របតាមរាជានិយម បែបនិយមព្រហ្មញ្ញសាសនា។

[៤០៤] រហូតមកដល់សព្វថ្ងៃ គ្រប់រាជពិធីសំខាន់ៗនៅក្នុងព្រះបរមរាជវាំង គឺពួកព្រហ្មណ៍បុរោហិតជាអ្នកដឹកនាំ។

មកជាការបង្រួបបង្រួមទឹកដីរៀបចំឱ្យទៅជាមហានគរដែលមានឯកភាពជាតិ ផ្អែកលើព្រហ្មញ្ញសាសនា ដែលជាវិធីសាស្ត្រគោលនៃការដឹកនាំជាតិ និងបានចាក់ឫសយ៉ាងជ្រៅទៅក្នុងសង្គមខ្មែរ។ ទោះបីព្រះមហាក្សត្របានប្តូរពីព្រហ្មញ្ញសាសនាមកកាន់សាសនាព្រះពុទ្ធវិញក្តី ក៏គេពុំកត់សម្គាល់ឃើញបដិវត្តន៍ណាមួយពិតប្រាកដនៃផ្នត់គំនិតក្នុងការដឹកនាំនគរខ្មែរឡើយ។

២.៣.១.២. ឥទ្ធិពលរបស់ព្រះពុទ្ធសាសនា

ការប្តូរជាស្តាពរពីលទ្ធិទេវរាជមកលទ្ធិពុទ្ធគារវតា គឺធ្វើតាមផ្លូវបដិវត្តន៍នៅក្នុងមជ្ឈដ្ឋាននៃពួកអ្នកដឹកនាំ។ នៅក្នុងបដិវត្តន៍នោះ មានការធ្វើឃាតព្រះមហាក្សត្រចុងក្រោយបង្អស់នៃសន្តតិវង្សអង្គរ ព្រះបាទជ័យវរ្ម័នទី៩ (១៣២៧-១៣៤០)។ តាមរាជពង្សាវតារអ្នកធ្វើឃាតគឺតាត្រសក់ផ្អែម ជាអ្នកថែសួនច្បាររបស់ព្រះមហាក្សត្រ ជាឃាតកម្មដោយឧបទ្ទវហេតុ ។ អ្នកប្រវត្តិសាស្ត្រនៅមិនទាន់ឆ្លើយបាននូវសំណួរថា តើអ្វីខ្លះជាមូលហេតុនៃបដិវត្តន៍? បើតាមទស្សនៈរបស់លោក Adhémard Leclère និង Dauphin Meunier ព្រឹត្តិការណ៍ព្រះបាទត្រសក់ផ្អែមឡើងសោយរាជ្យ គឺជាមហាបដិវត្តន៍មួយក្នុងប្រវត្តិសាស្ត្រខ្មែរ ហើយបដិវត្តន៍នោះ គឺជាបដិវត្តន៍ខាងនយោបាយនិងខាងសាសនា។

ប្រាកដណាស់ហើយថាលទ្ធិទេវរាជនៃរបបរាជានិយម ធ្វើការកសាងជាតិខ្មែរឱ្យបានដល់ភាពរុងរឿងត្រចេះត្រចង់បំផុតក្នុងប្រវត្តិសាស្ត្រខ្មែរ។ តើភាពរីកចំរើននោះសម្រាប់តែវណ្ណៈក្សត្រនិងអភិជន? ចំណែកឯរាស្ត្រសៅនៅក្នុងភាពទ័លច្រករវាងភាពក្រលំបាកគ្រប់បែបយ៉ាង ដូចយ៉ាង កំណែនយោធានិងកំណែនសំណង់ប្រាសាទ។ ទុក្ខវេទនានេះឯងដែលនាំឱ្យប្រជារាស្ត្រយកព្រះពុទ្ធសាសនា ជាជម្រកចិត្ត ដើម្បីបន្ថយនូវទុក្ខលំបាករបស់ខ្លួន។ តែមានរាជសិលាចារឹកដ៏ល្បីមួយរបស់ព្រះបាទជ័យវរ្ម័នទី៧ ចារថា «ទុក្ខនៃប្រជារាស្ត្រគឺជាទុក្ខរបស់ព្រះមហាក្សត្រ»។ ប្រយោគនេះបង្ហាញនូវគុណរបស់ព្រះមហាក្សត្រចំពោះការរងទុក្ខវេទនារបស់ប្រជារាស្ត្រ។ សួរថាតើការប្តូរលទ្ធិនោះ វាមានប្តូរទាំងស្រុងនូវអត្ថរសនៃរបបរាជានិយមដែរឬទេ?

សាសនានៃព្រះពុទ្ធនិងរបបដឹកនាំនៃព្រះនៅក្នុងដៃរបស់វណ្ណៈនៃអ្នកដឹកនាំ វាស្រដៀងគ្នាណាស់។ ព្រះពុទ្ធគឺជាអត្ថរូបនៃការទូលសុំទាននៃអ្នកសុំទាន គឺប្រជារាស្ត្រ និងការផ្តល់ទាននៃអ្នកផ្តល់ទានគឺព្រះមហាក្សត្រ។ ដូច្នេះ តើវាមានខុសគ្នាអ្វីទៅពីលទ្ធិទេវរាជ បើព្រះមហាក្សត្រនៅតែជាអ្នកផ្តល់ទានដល់ប្រជារាស្ត្រ? បើទុកការប្តូរនៃលទ្ធិនោះជាបដិវត្តន៍សម្រាប់គ្រាន់តែកែលម្អនូវអត្ថរូបនៃលទ្ធិ តែនៅតែរក្សានូវអត្ថរសនៃលទ្ធិទាំងមូល សួរថាតើ

នៅត្រង់ចំណុចណាខ្លះ ដៃរអាចទុកជាការដូរ ជាអំណោយផលចំពោះប្រជារាស្ត្រ? អត្ថរូបនៃស្តេចទេវរាជ និងស្តេចពុទ្ធគារវតានៅក្នុងអត្ថរសនៃវណ្ណៈ ជាអ្នកដឹកនាំដាច់មុខតែមួយ វាស្រដៀងគ្នាណាស់។ រាស្ត្រពុទ្ធសាសនិក និងស្តេចពុទ្ធសាសនិក វាមិនរលាយ ចូលគ្នាបាននោះឡើយ ព្រោះវាមានរបងវណ្ណៈជាខណ្ឌសីមា។ ដូចយ៉ាងនៅក្នុងបជិវត្តន៍របស់តាត្រសក់ផ្អែម ដែលគេទុកជាបជិវត្តន៍ខាងសាសនា តែអ្វីដែលតាត្រសក់ផ្អែម គាត់ស្គាល់ជាប់ជាប្រញាប់គឺអត្ថរូប និងអត្ថរសនៃរបបរាជានិយមចាស់ គឺថាគាត់រក្សាវណ្ណៈក្សត្រនិងលំដាប់នៃការដឹកនាំនៃវណ្ណៈទាំងមូល។ ដូច្នេះ ព្រះបាទត្រសក់ផ្អែម ជារាស្ត្រយកតម្រាប់វណ្ណៈក្សត្រ ដែលជាវណ្ណៈមានព្រះគុណដល់ប្រជារាស្ត្រ តាមក្បួននៃព្រះករុណាដដែល។

ទសពិធរាជធម៌ វាគ្រាន់តែជាបទដ្ឋាននៃឧត្តមគតិសម្រាប់ស្តេចពុទ្ធគារវតា តែមិនទុកជារាជកាតព្វកិច្ចមានលក្ខណៈដាច់ខាតឡើយ ដូច្នេះព្រះអង្គទ្រង់មិនមែនជាអ្នកទទួលខុសត្រូវលើអំពើនៃការដឹកនាំរបស់ព្រះអង្គនោះឡើយ។ ជាការពិត នៅក្នុងទស្សនៈនៃស្តេចពុទ្ធគារវតាបញ្ជាក់ថា ទុក្ខរបស់ប្រជារាស្ត្រ គឺជាទុក្ខរបស់ព្រះមហាក្សត្រ តែអត្ថរសនៃទុក្ខនៅក្នុងជំនឿគ្រឹះនៃពុទ្ធសាសនាគឺកើតពី «កម្មផល» ដែលជាផលានៃអំពើរបស់បុគ្គលម្នាក់ៗផ្ទាល់ គ្មានអ្នកដទៃអាចជួយសង្គ្រោះបាននោះទេ។ នៅចំពោះមុខពុទ្ធបដិមាគ្រប់រូបធាតុ រាស្ត្រពុទ្ធសាសនិកបន់ស្រន់សុំវិញ្ញាណនៃព្រះពុទ្ធ ឱ្យព្រះអង្គជួយថែរក្សានិងការពារខ្លួនក្នុងឋានៈព្រះអង្គជាអ្នកសង្គ្រោះដល់មនុស្សនៅក្នុងលោក។ តែជាប្រជារាស្ត្រនុរាស្ត្រជាពុទ្ធសាសនិក ក៏សុំព្រះមហាក្សត្រពុទ្ធគារវតា នូវសេចក្តីមេត្តា សេចក្តីអាសូរពីព្រះអង្គ ក្នុងឋានៈព្រះអង្គជាបីតានៃប្រជារាស្ត្រ៖ «*ខ្ញុំជាបថុជ្ជន ជាអ្នកគោរពព្រះពុទ្ធធម៌តតខ្ចោះ ជាអ្នករស់នៅក្រោមបារមីតែមួយនៃព្រះមហាក្សត្រ និងជាអ្នកបម្រើគ្មានលក្ខខណ្ឌ ខ្ញុំសូមឱ្យព្រះធម៌និងព្រះរាជបារមី មេត្តាផ្តល់នូវសេចក្តីសុខគ្រប់បែបយ៉ាងដល់ខ្ញុំក្នុងឋានៈព្រះទាំងពីរជាម្ចាស់នៃជីវិតលើត្បូងនិងម្ចាស់នៃវាសនានៃសត្វលោកនិងរាស្ត្រ!*»។

ទោះបីរាស្ត្រខំបន់ស្រន់យ៉ាងណាក្តី តែទុក្ខរបស់គាត់វាមិនរលត់សោះ ផ្ទុយទៅវិញ វាកាត់តែធ្ងន់ធ្ងរឡើង ព្រោះថា ការសុំតាមការបន់ស្រន់ វាមិនមែនជាដំណោះស្រាយឬមហោសថនោះទេ។ ពាហនសត្វវាហត់នឿយខ្លាំង លែងងើបដើរបាន ដូច្នេះវាដេករង់ចាំសេចក្តីស្លាប់មិនអាចបម្រើនូវសេចក្តីត្រូវការរបស់ម្ចាស់វាបានទៀតឡើយ។ រាស្ត្រមានម្ចាស់ក៏ដូចគ្នានឹងពាហនសត្វនោះដែរ បើខ្លួនមានទុក្ខ តែមិនរកដំណោះស្រាយតាមមធ្យោបាយរបស់ខ្លួនឯង។

ក. លក្ខណៈសម្បត្តិរបស់អ្នកដឹកនាំនិងរាស្ត្រប្រជាតាមព្រះពុទ្ធសាសនា

អ្នកដឹកនាំបែបព្រះពុទ្ធសាសនា ត្រូវមានព្រហ្មវិហារធម៌ ទាំង៤យ៉ាង ដែលជាធម៌ជាគ្រឿងបឹតនៅដ៏ប្រសើរ ធម៌ប្រចាំចិត្តដ៏ប្រសើរ គោលការណ៍ប្រព្រឹត្តិដ៏បរិសុទ្ធ ធម៌ដែលត្រូវមានទុកជាគោលក្នុងចិត្ត និងកាន់កាប់ការប្រព្រឹត្ត។ តាមព្រះពុទ្ធឱវាទ ដំណើរជីវិតហ្មត់ចត់និងប្រតិបត្តិខ្លួនចំពោះមនុស្ស សត្វទាំងឡាយដោយត្រូវប្រកបដោយបានដល់ *មេត្តា* (សេចក្តីស្រឡាញ់ ប្រាថ្នាល្អ ចង់ឱ្យគេមានសេចក្តីសុខ មានចិត្តមេត្រី និងគិតធ្វើប្រយោជន៍ដល់មនុស្ស សត្វទូទៅ); *ករុណា* (សេចក្តីអាណិត ជួយឱ្យរួចផុតទុក្ខ ជួយសង្គ្រោះបំបាត់ទុក្ខលំបាករបស់ពពួកសត្វ) *មុទិតា* (មានសេចក្តីត្រេកអរ ពេលឃើញអ្នកដទៃមានសក្តីសុខ មានចិត្តរីករាយសប្បាយជានិច្ច ចំពោះសត្វទាំងឡាយ អ្នកបឹតនៅក្នុងបកតិសុខ) *ឧបេក្ខា* (ការដេម្កល់ចិត្តជាកណ្តាល ដែលនឹងធ្វើឱ្យតំរង់នៅក្នុងធម៌ តាមពិចារណាឃើញដោយបញ្ញា គឺមានចិត្តរាបត្រង់ដោយធម៌ដូចជាជញ្ជីង មិនលំអៀងដោយស្រឡាញ់ដោយស្អប់ ពិចារណាឃើញកម្ម ដែលសត្វទាំងឡាយធ្វើហើយ ដ៏គួរបានទទួលផលល្អ ឬអាក្រក់ សមដល់ហេតុដែលខ្លួនបានប្រព្រឹត្ត ព្រមនឹងវិនិច្ឆ័យ និងបដិបត្តិទៅតាមធម៌ រួមទាំងចេះតាំងចិត្តជាកណ្តាលសម្លឹងមើល នៅពេលមិនមានកិច្ចដែលគួរធ្វើ ព្រោះគេទទួលខុសត្រូវបានល្អហើយ គេសមគួរទទួលខុសត្រូវដោយខ្លួនឯង ឬគេគួរបានទទួលផលដ៏សមរម្យជាមួយការទទួលខុសត្រូវរបស់ខ្លួន)។

ទាំងអ្នកនយោបាយ ទាំងមេទ័ព ក៏ត្រូវបដិបត្តិធម៌ដ៏កំពូលនេះដែរ។ ក្នុងទស្សនាទានព្រះពុទ្ធសាសនាមហាយាន ព្រះមហាក្សត្រលែងជាការអច្ឆរិយៈទៀតហើយ តែជាមនុស្សដែលសាងអំពើល្អពីជាតិមុនធ្វើឱ្យបច្ចុប្បន្នជាតិ នាំព្រះអង្គបានដល់ទីខ្ពង់ខ្ពស់ មានសមត្ថភាពគ្រប់យ៉ាង ត្រូវទទួលបន្ទុកជានាការផ្សព្វផ្សាយនិងការអនុវត្តច្បាប់របស់ព្រះពុទ្ធ។ ទោះជាយ៉ាងក្តី ភាពដាច់ខាតនៃអំណាចរបស់ព្រះមហាក្សត្រមិនបាត់បង់ឬថមថយទៅណាទេ តែព្រះមហាក្សត្រប្រែទៅជាដូចជាឪពុករបស់ប្រជារាស្ត្រទៅវិញ។ ព្រះអង្គជានាសុកមង្គលរបស់រាស្ត្រដោយជានាឱ្យមានការអនុវត្តច្បាប់។ រាជមេត្តាធម៌នេះបញ្ជាក់លើស្នាដៃរបស់ព្រះអង្គ ដូចជាករណីព្រះបាទ ជ័យវរ្ម័នទី៧ នូវសំណង់មន្ទីរពេទ្យចំនួន ១០២ សម្រាប់ព្យាបាលជំងឺនៃប្រជារាស្ត្រ និងសំណង់សាលាសំណាក់ (សាលាឆទាន) ចំនួន ១២១ សម្រាប់សម្រួលនូវផាសុកភាពដល់អ្នកធ្វើដំណើរនៅក្នុងព្រះរាជនគរនិងការកសាងប្រាសាទបាយ័ន សម្រាប់តម្កល់ពុទ្ធបដិមាអង្គុយយ៉ាងធំកម្ពស់ជិត៤ម៉ែត្រទៀតផង។

នៅសម័យក្រោយអង្គរ ព្រះពុទ្ធសាសនាបានថមថយទោះបីជាព្រះមហាក្សត្រខ្មែរភាគច្រើននៅតែជាប្រមុខសាសនានេះក៏ដោយ មិនតែប៉ុណ្ណោះ ទង្វើមួយចំនួនក៏បានចាកឆ្ងាយពីក្បួនច្បាប់ព្រះពុទ្ធសាសនាទៀតផង។ មានក្សត្រខ្លះបានប្រព្រឹត្តខុសម្តងហើយម្តងទៀតចំពោះព្រះពុទ្ធសាសនា ហើយធ្វើសង្គ្រាមជាមួយបរទេសផង មានជម្លោះផ្ទៃក្នុងក្នុងរាជវង្សានុវង្សផងដើម្បីអំណាច លែងគិតគូរដល់ប្រជារាស្ត្រសោះឡើយ។ តែទោះជាយ៉ាងណា អ្នកស្រាវជ្រាវមួយចំនួនបានរកឃើញថា ទោះជាក្នុងកាលៈទេសៈដ៏លំបាកក្តី ស្តេចខ្មែរមួយព្រះអង្គគឺព្រះអង្គឌួង (១៨៤០-១៨៥៩) បានយកក្បួនច្បាប់ព្រះពុទ្ធមកគ្រប់គ្រងស្នើរវិស័យនៃសង្គម។ ព្រះអង្គមានទុក្ខកង្វល់ជាខ្លាំងអំពីជោគវាសនានៃប្រជារាស្ត្រដែលធ្លាក់ខ្លួនទៅជាទាសករដោយសារតែបំណុល។ រាល់ច្បាប់ដែលត្រូវបានដាក់ចេញនៅរាជកាលនោះ សុទ្ធតែមានឥទ្ធិពលពីធម៌ព្រះពុទ្ធទាំងអស់។

ព្រះពុទ្ធសាសនាមិនមែនគ្រាន់តែជាទស្សនវិជ្ជាសម្រាប់តែបញ្ញវន្តទេ តែវាជាផ្លូវដើរដាក់លាក់មួយក្នុងជីវភាពប្រចាំថ្ងៃសម្រាប់ប្រជាជនខ្មែរ។ ព្រះធម៌មានព្រះឱវាទសម្បូរណ៍បែបដែលត្រូវបានចងក្រមនិងរៀបចំជា ៨៤ ០០០ ព្រះធម្មក្ខន្ធ[៤០៥] ហើយសុទ្ធតែជាឱវាទដែលតម្រង់ផ្លូវជីវិតជនជាតិខ្មែររាប់សិបសតវត្សរ៍មកហើយ។ មានបុណ្យសាសនានិងបុណ្យជាតិផ្សេងៗដែលប្រជាជនធ្វើរួមគ្នានៅវត្ត អនុញ្ញាតឱ្យពុទ្ធសាសនិកស្គាល់គ្នារាប់អានគ្នា និងគោរពគ្នា ព្រមទាំងពិភាក្សាអំពីកិច្ចការរបស់សហគមន៍របស់ខ្លួនបាន។ បើគេគិតមួយស្លែត គេអាចបារម្ភថាពុទ្ធឱវាទនឹងនាំឱ្យខ្មែរម្នាក់ៗគិតតែខ្លួនឯង តែតាមពិតមិនដូច្នេះ។ សង្គមខ្មែរមានទាំងធាតុបុគ្គល មានទាំងធាតុគ្រួសារ។ ប្រហែលជាធាតុគ្រួសារនេះហើយ ដែលជួយជំរុញឱ្យកូនប្រុសស្រីចេះរាប់អានមនុស្ស អ្នកជិតខាង ញាតិមិត្តជិតឆ្ងាយបង្កើតសាមគ្គីភាពក្នុងសហគមន៍ក្រោមឱវាទព្រះពុទ្ធសាសនា។

តែទោះជាយ៉ាងណា សាមគ្គីភាពរបស់ជនជាតិខ្មែរនៅមានកម្រិត។ មានអ្នកកត់សម្គាល់ថា ការធ្វើសហករណ៍ជាង១៤ឆ្នាំ ក្រោមការឃោសនានិងអង្គការចាត់តាំងសង្គមនិយម មិនបានផ្លាស់ប្តូរជនជាតិខ្មែរទេ។ គេយល់ឃើញថា ជនជាតិខ្មែរក្រោយសម័យសង្គមនិយមមិនជួយគ្នាទទេទេ ព្រោះយល់គ្នាខ្លួនគ្មានកាតព្វកិច្ចនឹងធ្វើ។ អ្នកខ្លះទៀតយល់ថាសាមគ្គីមានកម្រិតរបស់ជនជាតិខ្មែរ អាចបង្កឡើងដោយសារការអប់រំបែបព្រះពុទ្ធសាសនាដែរ។ ខ្មែរយល់ថា ត្រូវជួយខ្លួនឯងជាមុន រួមទាំងជួយគ្រួសារខ្លួន ញាតិមិត្តខ្លួន ចាំ

[៤០៥] ពុទ្ធឱវាទទាំងនេះត្រូវបានកត់ត្រាទុកនៅព្រះពុទ្ធសំដែងព្រះធម៌រយៈពេល ៤៥ ឆ្នាំចាប់ពីពេលដែលព្រះអង្គទ្រង់ត្រាស់ដឹង រហូតដល់ពេលដែលព្រះអង្គទ្រង់ចូលព្រះនិពានទ្ធ។

ជួយអ្នកដទៃជាក្រោយ។ ខ្មែរយើងមិនលើកទឹកចិត្តឱ្យជួយគេរហូតអស់ពីខ្លួនទេ។ នេះប្រហែលជាមេរៀននៅក្នុងពេលស្រុកទេសពិបាកបានបង្រៀនកូនខ្មែរឱ្យចេះប្រុងប្រយ័ត្ន។

ខ. ព្រះពុទ្ធសាសនានិងច្បាប់រដ្ឋបាល

ព្រះពុទ្ធសាសនាបានដើរតួនាទីសំខាន់បម្រើដល់ជនជាតិខ្មែរ ទាំងខាងស្មារតី ទាំងខាងសំការៈ។ ខាងសំការៈ តួនាទីរបស់វត្តពិតជាសំខាន់។ វត្តជាទីកន្លែងសហគមន៍ផង ធ្វើសកម្មភាពបម្រើសង្គមផង។ ខាងស្មារតី វត្តគឺជាសាលារៀនដែលផ្តល់ចំណេះដឹងទាំងលេខនិពន្ធ ទាំងព្រះធម៌។ ព្រះពុទ្ធសាសនាគឺជាកត្តាសំខាន់នៃការកំណត់សីលធម៌សង្គម។ ការសិក្សាព្រះពុទ្ធសាសនាអាចជួយទាំងអប់រំចិត្ត ជួយទាំងអភិរក្សវប្បធម៌និងអក្សរសាស្ត្រ។ ប្រពៃណីនេះបានចាក់ឫសចូលជ្រៅក្នុងសង្គមខ្មែរ រហូតមានទីកន្លែងរបស់នៅក្នុងស្ថាប័នរដ្ឋជាយូរមកហើយ។ នៅស្រុកខ្មែរ ព្រះពុទ្ធសាសនាត្រូវបានការពារដោយរដ្ឋធម្មនុញ្ញ។

អ្នកដឹកនាំត្រូវបានអប់រំឱ្យស្គាល់និងវៀរចាកនូវអគតិធម៌ទាំង ៤ ដែលជាធម៌ពុំគួរប្រព្រឹត្ត ព្រោះជាវាជាសេចក្តីលម្អៀង។ ការលុះក្នុងអគតិឬវិនិច្ឆ័យក្តីដោយអគតិរមែងនាំទៅដល់ក្តីវិនាស។ អគតិឬសេចក្តីលម្អៀងនេះមាន៤យ៉ាងគឺ ឆន្ទាគតិ (សេចក្តីលម្អៀងព្រោះស្រឡាញ់); ទោសាគតិ (សេចក្តីលម្អៀងព្រោះស្អប់); មោហាគតិ (សេចក្តីលម្អៀងព្រោះល្ងង់, ព្រោះពុំយល់ការខុសត្រូវ); ភយាគតិ (សេចក្តីលម្អៀងព្រោះខ្លាចបុណ្យខ្លាចអំណាចឬខ្លាចចិត្តគេ)។

កាន់តែសំខាន់ទៅទៀត ទាំងអ្នកដឹកនាំ ទាំងរាស្ត្រប្រជា ត្រូវគោរពបដិបត្តិត្រៃសិក្ខាទាំង ៣ មានសីល សមាធិ បញ្ញា ជាគោលការណ៍សំខាន់បីនៅក្នុងព្រះពុទ្ធសាសនា និងជាមាគ៌ាសម្រាប់អប់រំចិត្ត កាយ និងវាចា ដើម្បីឈានទៅរកការរួចផុតពីទុក្ខ។ *សីល* (Sīla) គឺជាវិន័យឬសីលធម៌ក្នុងការរស់នៅប្រចាំថ្ងៃ។ សីលជាមូលដ្ឋានគ្រឹះដំបូងគេបង្អស់សម្រាប់គ្រប់គ្រងកាយនិងវាចារបស់យើង កុំឱ្យប្រព្រឹត្តអំពើអាក្រក់។ ការរក្សាសីលធ្វើឱ្យចិត្តមានភាពស្ងប់រម្ងាប់ និងមានសន្តិភាព[៤០៦]។ សមាធិ (*Samādhi)* គឺការតម្កល់ចិត្តឱ្យនឹងនរ មិនឱ្យរាយមាយ ឬវង្វេង។ បន្ទាប់ពីយើងបានរក្សាសីលហើយ ចិត្តរបស់

[៤០៦] ឧទាហរណ៍ បញ្ចសីល៖ ជាសីលមូលដ្ឋាន ៥ យ៉ាងសម្រាប់គ្រហស្ថ (អ្នកកាន់សាសនាទូទៅ)៖ វៀរចាកការសម្លាប់សត្វ; វៀរចាកការលួចទ្រព្យសម្បត្តិអ្នកដទៃ; វៀរចាកការប្រព្រឹត្តខុសក្នុងកាម (ការផិតក្បត់); វៀរចាកការនិយាយកុហក; វៀរចាកការសេពគ្រឿងស្រវឹងនិងថ្នាំញៀន។

យើងចាប់ផ្តើមមានភាពស្ងប់ល្អ ដែលជាលក្ខខណ្ឌដ៏សមរម្យសម្រាប់ចម្រើនសមាធិ។ សមាធិជួយឱ្យយើងមានការប្រមូលអារម្មណ៍ល្អ មិនងាយធ្លាក់ក្នុងអន្ទាក់នៃតណ្ហានិងកិលេស[៤០៧]។ បញ្ញា (*Paññā*) គឺជាការយល់ដឹងច្បាស់លាស់ពីការពិតនៃជីវិតនិងធម្មជាតិ។ ពេលដែលយើងមានសីលនិងសមាធិហើយ ចិត្តរបស់យើងនឹងមានភាពស្អាតបរិសុទ្ធ និងមានថាមពលគ្រប់គ្រាន់ក្នុងការពិចារណា និងយល់ឃើញនូវការពិត។ បញ្ញាជួយឱ្យយើងមើលឃើញថាអ្វីៗទាំងអស់សុទ្ធតែមិនទៀងទាត់ មានសភាពជាទុក្ខនិងមិនមែនជាខ្លួនប្រាណ[៤០៨]។ ជារួម *សីល សមាធិ បញ្ញា* មានទំនាក់ទំនងគ្នាយ៉ាងជិតស្និទ្ធ។ សីលជាមូលដ្ឋានគ្រឹះ ដូចជាដីសម្រាប់ដាំដំណាំ។ សមាធិគឺដូចជាការស្រោចទឹកនិងថែទាំដំណាំ។ រីឯ បញ្ញាគឺដូចជាផ្លែឈើដែលយើងទទួលបានពីការដាំដុះ។ គោលការណ៍ទាំងបីនេះជួយឱ្យមនុស្សមានការអភិវឌ្ឍខ្លួនទាំងកាយ វាចា និងចិត្ត ដើម្បីសម្រេចបាននូវសេចក្តីសុខពិតប្រាកដ។

សេចក្តីសន្និដ្ឋាន

ការប្តូរពីលទ្ធិទេវរាជមកលទ្ធិពុទ្ធគារវតី វាគ្រាន់តែជាការប្តូរនៃអត្តរូបរបស់រាជានិយមខ្មែរតែប៉ុណ្ណោះ ព្រោះរបបរាជានិយមនៅរក្សាជាតុអំណាចទាំងមូលរបស់ខ្លួន គឺអំណាចផ្តាច់ការនិយម។ វាមានរូបភាពជាបដិវត្តន៍សាសនានិងនយោបាយក៏ពិតមែន តែវាគ្រាន់តែជាបដិវត្តន៍សម្រាប់លម្ហណ្ណៈនៃពួកអ្នកដឹកនាំព្រោះ គ្មានការចូលរួមពីប្រជារាស្ត្រនោះទេ ដ្បិតនៅក្នុងបដិវត្តន៍នោះ វាគ្មានមានគោលការណ៍នៃនីតិ គឺជាអធិបតីនៅក្នុងលោកនោះឡើយ។ ពីព្រះបាទជ័យវរ្ម័នទី៧ មកដល់ព្រះបាទត្រសក់ផ្អែម ស្រុកខ្មែរកំពុងរំអិលលើជម្រាលចុះ។ សិរីរុងរឿងរបស់ស្រុកខ្មែរ ដែលជាស្នាដៃរបស់ព្រះបាទជ័យវរ្ម័នទី៧ និងការស្តារនៃតម្លៃនៃរាជានិយម ដែលជាស្នាដៃរបស់ព្រះបាទត្រសក់ផ្អែមតាមការបដិវត្តន៍នៃលទ្ធិសាសនា វាមិនអាចបញ្ជ្រាសនូវជម្រាលចុះបាននោះទេ ដែលនាំឱ្យបក្សពួកទាំង

---

[៤០៧] ឧទាហរណ៍ *អានាបានសតិកម្មដ្ឋាន* គឺជាការយកចិត្តទៅគិតជាប់នឹងដង្ហើមចេញចូល ដើម្បីឱ្យចិត្តមានការប្រមូលផ្តុំ; *មេត្តាភាវនា* គឺជាការធ្វើឱ្យចិត្តពេញដោយសេចក្តីស្រឡាញ់និងការប្រណីចំពោះខ្លួនឯងនិងសព្វសត្វ។

[៤០៨] ឧទាហរណ៍ ការយល់ដឹងពីអរិយសច្ចទាំងបួន៖ សច្ច:ទី១ (*ទុក្ខអរិយសច្ច:*)៖ យល់ដឹងពីទុក្ខ; សច្ច:ទី២ (*ទុក្ខសមុទយអរិយសច្ច:*)៖ យល់ដឹងពីហេតុនៃការកើតទុក្ខ (តណ្ហា); សច្ច:ទី៣ (*ទុក្ខនិរោធអរិយសច្ច:*)៖ យល់ដឹងពីការរលត់ទុក្ខ; សច្ច:ទី៤ (*ទុក្ខនិរោធគាមិនីបដិបទាអរិយសច្ច:*)៖ យល់ដឹងពីមាគ៌ានៃការរលត់ទុក្ខ (*អរិយអដ្ឋង្គិកមគ្គ*)។

សងខាងដាក់កំហុសគ្នាទៅវិញទៅមក[៤០៩]។ តែមកដល់រជ្ជកាលរបស់ព្រះបាទ ជ័យវរ្មនទី៨ (១២៤៣-១២៩៥) មានប្រតិកម្មសិវនិយម ប្រឆាំងនឹងពុទ្ធសាសនាជាខ្លាំង។ ពួកព្រាហ្មណ៍មានឥទ្ធិពលឡើងវិញរហូតបង្គាប់ឱ្យកោសលុបរូបចម្លាក់ព្រះពុទ្ធនៅលើជញ្ជាំង និងលើសសរក្នុងប្រាសាទនានា ហើយសាងរូបចម្លាក់លិង្គព្រះឥសូរឬតាបសតាំងសីល៍ជំនួយវិញ។ ការអនុគ្រោះសាជាថ្មីដល់ពួកព្រាហ្មណ៍ គឺដោយសារព្រះបាទជ័យវរ្មនទី៨ មានមហេសីមួយរូបជាកូនព្រាហ្មណ៍បុរោហិត។ រហូតមកដល់រជ្ជកាល ព្រះបាទជ័យវរ្មនទី៩ (១៣០៧-១៣៤០) ពួកព្រាហ្មណ៍បុរោហិតនៅមានឥទ្ធិពលខ្លាំង តែពុទ្ធសាសនាថេរវាទបានរីកសុះសាយណាស់ទៅហើយនៅស្រុកខ្មែរ។ ដែលនាំឱ្យមានបដិវត្តន៍សាសនាជាថ្មីនៅក្នុងមជ្ឈដ្ឋាននៃវណ្ណៈមន្ត្រីជាថ្មី ដូច្នេះហើយបានជាកើតមានព្រឹត្តិការណ៍តាត្រសក់ផ្អែម

[៤០៩] ពួកខាងនិយមលទ្ធិទេវរាជ និន្នាថាស្រុកខ្មែរចុះអន់ថយ ដោយសារព្រះពុទ្ធសាសនា ដែលជាសាសនានាំប្រជារាស្ត្រឱ្យគិតតែស្វែងរកផ្លូវនិព្វាន ដែលនាំឱ្យជនខ្មែរទាំងឡាយបាត់អស់នូវសេចក្តីក្លៀវក្លា ជាអ្នកការពារជាតិ។ ចំណែកពួកអ្នកនិយមលទ្ធិពុទ្ធគារវតាវិញយល់ឃើញថា លទ្ធិទេវរាជគិតតែធ្វើការកសាងលិង្គព្រះឥសូរ សំរាប់គោរពបូជា ហើយកេណ្ឌប្រជារាស្ត្រធ្វើជាកម្មករសំណង់ប្រាសាទសម្រាប់អាទិទេព។ តែបក្សពួកទាំងសងខាងមិនធ្វើការទិតៀនរបៀបគ្រប់គ្រងនៃរបបរាជានិយមនោះទេ។ បក្សពួកទាំងសងខាងនោះ ជាថ្នាក់អ្នកដឹកនាំទទួលបានបុព្វសិទ្ធិគ្រប់បែបយ៉ាងពីប្រភពតែមួយ គឺតួនាទីស្តាប័នព្រះមហាក្សត្រ។ ដូច្នេះដូរលទ្ធិសាសនាមិនមានន័យថាត្រូវដូររបបដឹកនាំនោះឡើយ ហើយដូរព្រះមហាក្សត្រ ក៏មិនមានន័យថាដូរស្ថាប័នព្រះមហាក្សត្រនោះដែរ។ យើងអាចសន្មត់បានថា ដើមដម្លោះគឺជាវិវាទរវាងវណ្ណៈព្រាហ្មណ៍និងវណ្ណៈមន្ត្រី ដែលជាសម្ព័ន្ធមិត្តឯកសិទ្ធិរបស់វណ្ណៈក្សត្រ។ ត្រូវដឹងថាវណ្ណៈសេនាមន្ត្រីនាំគ្នាជ្រើសយកពុទ្ធសាសនាដើម្បីប្រឆាំងនឹងពួកព្រាហ្មបុរោហិតដែលភាគច្រើនមានដើមកំណើតបរទេស។ នេះមិនមែនជាវិវាទប្រកាន់ពូជសាសន៍ទេ។ មូលហេតុនៃជម្លោះគឺស្ថិតនៅលើការដណ្តើមគ្នាយកអំណាចដើម្បីមានឥទ្ធិពលទៅលើព្រះមហាក្សត្រ។ ពួកព្រាហ្មណ៍ព្រឹទ្ធាចារ្យនិងពួកព្រាហ្មណ៍បុរោហិត មានអារម្មណ៍ថាពួកខ្លួនមានអំណាចសាសនាទាំងមូលទៅលើស្តេចទេវរាជ ដូច្នេះហើយបានជាពួកខ្លួនស្នើរតែបង្គាប់ព្រះមហាក្សត្រ ឱ្យកសាងប្រាសាទគ្រប់បែបយ៉ាងដើម្បីថ្វាយដល់ព្រះអាទិទេពរបស់ពួកខ្លួន ដែលជាសំណង់មានតម្លៃថ្លៃដល់ថវិកាជាតិនិងជីវិតនៃប្រជារាស្ត្រ។ អំណាចប្រកបដោយគ្រោះថ្នាក់បែបនេះ ធ្វើឱ្យពួកមហាសេនាមន្ត្រីស្នើរបាត់អស់នូវអំណាចនៃឥទ្ធិពលទៅលើព្រះមហាក្សត្រ ព្រោះព្រះអង្គស្តាប់តែយោបល់ពួកព្រាហ្មណ៍បុរោហិត មិនត្រឹមតែកិច្ចការសាសនា គឺរហូតដល់កិច្ចការរាជការ ហើយទុកការទាយរបស់ព្រាហ្មណ៍រាជហោរាធិបតិ ជាទំនាយសម្តែតសច្ចៈ។ បន្តិចម្តងៗ នៅក្នុងអំឡុងច្រើនសតវត្សកំហឹងកំបាំងរបស់ពួកមហាមន្ត្រីមួយចំនួនជំជាពុទ្ធសាសនិក ចំពោះពួកព្រាហ្មណ៍បុរោហិត ក្លាយជាទំនាស់ចេញមុខនាំបង្កើតឱ្យមានវិវាទសាសនានៅក្នុងវង់នៃវណ្ណៈមន្ត្រីផង វណ្ណៈក្សត្រផង។ ព្រះបាទជ័យវរ្មនទី៧ ព្រះអង្គមានប្រផ្នូលអំពីបញ្ហានេះ ហើយទ្រង់ដោះស្រាយរកសមតា ដើម្បីកុំឱ្យគូសត្រូវទាំងសងខាងមានអារម្មណ៍ថាខ្លួនជាអ្នកចាញ់ នៅត្រង់ចំណុចនេះឯង ដែលគេទុកព្រះបាទជ័យវរ្មនទី៧ ជាព្រះមហាក្សត្រទេព។

ដែលជាអ្នកធ្វើឃាត ព្រះបាទ ជ័យវរ្មនទី៩ ហើយត្រូវពួកមហាសេនាមន្ត្រីលើកឱ្យឡើងសោយរាជ្យបន្តទៅ[៤១០]។

ការប្តូរពីលទ្ធិទេវជាតិមកលទ្ធិពុទ្ធគារវតានៃរាជានិយមខ្មែរ វាគ្រាន់តែប្តូរនូវអត្ថរូបតែអត្ថរសនៃរបបនេះវិញ វាស្ថិតនៅទាំងអស់គឺជារបបផ្តាច់ការនិយម។ របបរាជានិយមពុទ្ធគារវតាលែងទុកវណ្ណៈព្រាហ្មណ៍ជាវណ្ណៈឯកសិទ្ធិ តែក៏មិនលើកពុទ្ធសហធម្មិកជាវណ្ណៈគារវតានោះដែរ។ ស្តេចពុទ្ធសាសនិក ព្រះអង្គគ្រាន់តែជាអ្នកមានការអនុគ្រោះចំពោះព្រះពុទ្ធសាសនា ហើយទទួលយកជារាជជំនឿ តែព្រះអង្គស្ថិតនៅជាអ្នកត្រួតត្រាលើពុទ្ធសាសនាក្នុងឋានៈព្រះអង្គជាស្តេចដែលមានអំណាចជាច់ខាតនៅក្នុងព្រះមហានគរ។

២.៣.២. គុណតម្លៃទស្សនវិជ្ជានយោបាយអឺរ៉ុបនៅក្នុងនីតិរដ្ឋបាលខ្មែរ

ចាប់តាំងពីការធ្លាក់ចុះនៃសម័យអង្គរមក កម្ពុជាស្ថិតក្រោមឥទ្ធិពលនៃអំណាចបរទេសជាច្រើន។ ផ្តើមមុនគេគឺពួកសៀមនៅសតវត្សរ៍ទី១៤ និងទី១៥ ជាមួយនឹងការបោះបង់ក្រុងអង្គរ[៤១១] និងការបាត់បង់ក្រុងលង្វែក[៤១២]។ បន្ទាប់មក ពីសតវត្សរ៍ទី១៥ ដល់ទី១៩ កម្ពុជាទទួលរងការប៉ុនប៉ងលេបទឹកដីពីទាំងខាងសៀម ទាំងខាងអាណ្ណាម។ ប្រទេសជិតខាងទាំងពីរ ព្យាយាមប្រើឥទ្ធិពលមកលើព្រះមហាក្សត្រខ្មែរដើម្បីប្រយោជន៍ផ្ទាល់ខ្លួន។ តែទោះជាយ៉ាងណាគេមិនឃើញមានស្លាកស្នាមនៃក្បួនខ្នាតរបស់សៀម ឬរបស់អាណ្ណាមដែលបន្សល់ទុកនៅក្នុងរដ្ឋបាលខ្មែរច្រើនទេ ហើយនេះប្រហែលដោយសារប្រទេសទាំងនេះនៅជិតខ្មែរនិងមានទំនៀមទម្លាប់ប្រពៃណីស្រដៀងខ្មែរ។ នៅពេលបារាំងចូលមកដល់ បារាំងបានដាក់អាណាព្យាបាលលើកម្ពុជា ហើយបានធ្វើទំនើបកម្មរដ្ឋនិង

---

[៤១០] អ្នកសិក្សាខ្លះអះអាងថាព្រឹត្តិការណ៍តាត្រសក់ផ្អែម វាដូចគ្នានឹងរឿងព្រេងមួយនៅប្រទេសភូមា ហើយការលើករឿងព្រេងនោះមកប្រដូចនឹងព្រឹត្តិការណ៍នៃតាត្រសក់ផ្អែម គ្រាន់តែបញ្ជាក់ថាស្រុកខ្មែរទទួលឥទ្ធិពលក្នុងផ្នែកពុទ្ធសាសនាហីនយានឬថេរវាទីពីស្រុកភូមា។ ដូច្នេះគេសន្និដ្ឋានថាព្រឹត្តិការណ៍តាត្រសក់ផ្អែមគ្មានលក្ខណៈជាប្រវត្តិសាស្ត្រពិត តែពួកកិក្ខុសង្ឃនិយមថេរវាទីតែងតែនាំគ្នាលើករឿងតាត្រសក់ផ្អែមមកដំណាលតៗគ្នាបែបជាហេតុប្រវត្តិសាស្ត្រ ដើម្បីធ្វើស្ពានចម្លងរវាងសម័យអង្គរនិងក្រោយអង្គរសម្រាប់ផ្តល់លក្ខណៈពេញលេញដល់ព្រះរាជពង្សាវតារខ្មែរ ព្រោះចាប់ពីរជ្ជកាលព្រះបាទជ័យវរ្មនទី៩ ពួកអ្នកប្រវត្តិសាស្ត្រខ្មែរហាក់បីដូចជាមានការលំបាកក្នុងការចងក្រងពង្សាវតារជាតិ។ តែទោះបីជាយ៉ាងណា នៅក្នុងព្រះរាជពង្សាតារខ្មែរឆ្លុះការ មានការចាត់ទុកព្រឹត្តិការណ៍តាត្រសក់ផ្អែមជាប្រវត្តិសាស្ត្រជាតិពិត ហើយដាក់ព្រះបាទត្រសក់ផ្អែមជាព្រះមហាក្សត្រខ្មែរពេញសិទ្ធិ ជាអ្នកបង្កើតសន្តតិវង្សថ្មី បន្តពីព្រះបាទជ័យវរ្មនទី៩ ដោយមិនបានទុកព្រឹត្តិការណ៍ព្រះបាទត្រសក់ផ្អែមជាបដិវត្តន៍សាសនានិងនយោបាយនោះទេ។

[៤១១] ១៤៣១។

[៤១២] ១៥៩៣។

ច្បាប់ (១)។ នៅក្រោយឯករាជ កម្ពុជាទទួលបានអធិបតេយ្យភាពរហូតដល់រដ្ឋប្រហារឆ្នាំ ១៩៧០ ដែលបានរុញប្រទេសជាតិឱ្យធ្លាក់ទៅក្នុងសង្គ្រាម។ ក្រោយថ្ងៃរំដោះ ៧ មករា ១៩៧៩ កម្ពុជាបានបង្កើតរបបសាធារណរដ្ឋសង្គមនិយមមួយបែបម៉ាក្សនិយម (២)។

២.៣.២.១. ឥទ្ធិពលរបស់ប្រព័ន្ធច្បាប់បារាំង

នៅពេលបារាំងចូលមកដល់ កម្ពុជាជាប្រទេសមានរចនាសម្ព័ន្ធបែកបាក់និងទន់ខ្សោយ។ ការពង្រឹងរដ្ឋនិងរាជការឡើងវិញគឺជាការងារអាទិភាពរបស់អាណាព្យាបាល។ គោលបំណងនៅពីក្រោយនោះគឺការរៀបចំរចនាសម្ព័ន្ធសង្គមសេដ្ឋកិច្ចរបស់ប្រទេសនេះឱ្យដំណើរល្អ ដើម្បីបារាំងទាញយកប្រយោជន៍ឱ្យបានច្រើនជាអតិបរមា។ គេត្រូវបែងចែកជាពីរដំណាក់កាលមុននិងក្រោយឆ្នាំ១៨៨៤។ ដំណាក់កាលទី១ បារាំងទទួលយកតែសមត្ថកិច្ចពាក់ព័ន្ធនឹងកិច្ចការការបរទេស ដោយរក្សាសិទ្ធិសម្រេចលើកិច្ចការផ្ទៃក្នុងទុកថ្វាយព្រះមហាក្សត្រនិងរដ្ឋបាលខ្មែរដដែល[៤១៣]។ ដំណាក់កាលទី២ ព្រះមហាក្សត្រខ្មែរត្រូវទទួលយករាល់ការកែទម្រង់រដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម ដែលបារាំងយល់ថាមានសារៈសំខាន់សម្រាប់សម្រេចបាននូវបេសកកម្មរបស់អាណាព្យាបាល[៤១៤]។

នៅឆ្នាំ១៨៩១ ការកែទម្រង់របស់បារាំងកាន់តែជ្រៅ។ ឃ្លាំងប្រាក់របស់ខ្មែរត្រូវបានច្របាច់ចូលជាមួយថវិកាបារាំង។ រ៉ស៊ីដង់បារាំងអង្គុយធ្វើជាអធិបតីនៃកិច្ចប្រជុំគណៈរដ្ឋមន្ត្រី និងចុះហត្ថលេខាលើរាល់ព្រះរាជបញ្ញត្តិសម្រាប់នគរ។ បារាំងថែមទាំងប្រើឥទ្ធិពលក្នុងការជ្រើសរើសបេក្ខជនឡើងគ្រងរាជសម្បត្តិ និងលុបប្រព័ន្ធរដ្ឋបាលខេត្តនិងកម្មសិទ្ធិដីពីមុនមកទៀតផង[៤១៥]។ អាណាព្យាបាលបារាំងដែលពីមុខពុំមាននីតិបុគ្គលភាពអន្តរជាតិផងនោះ បានចូលមកស្ថិតនៅក្រោមរដ្ឋធម្មនុញ្ញបារាំងទាំងស្រុង។ ម្ល៉ោះហើយ នីតិខ្មែរទាំងនីតិសាធារណៈ ទាំងនីតិឯកជន ត្រូវចាប់យកប្រភពពីសភាបារាំង ហើយអំណាចនីតិប្រតិបត្តិត្រូវផ្ទេរទៅឱ្យអគ្គទេសាភិបាលបារាំង[៤១៦] និងប្រធានាធិបតីបារាំង។

ក. ការរៀបចំច្បាប់ទំនើបឱ្យខ្មែរ

ការទំនើបកម្មច្បាប់នៅកម្ពុជានេះមិនមែនសំដៅចំពោះតែរចនាសម្ព័ន្ធរដ្ឋាភិបាល

---

[៤១៣] សន្ធិសញ្ញាចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣។
[៤១៤] សន្ធិសញ្ញាចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤។
[៤១៥] បារាំងចាប់ផ្តើមគ្រប់គ្រងខេត្តដោយផ្ទាល់ម្តង។
[៤១៦] ដែលមានវេសនដ្ឋាននៅទីក្រុងហាណូយ។

តុលាការ និងរដ្ឋបាលរបស់ប្រទេសទេ តែក៏សំដៅដល់ការគ្រប់គ្រងទំនាក់ទំនងរវាងបុគ្គល និងបុគ្គល ដោយប្រើវិធានថ្មីស្របតាមតម្រូវការនៃសង្គមទំនើបផងដែរ។ ការកែទម្រង់ចំណុចចុងក្រោយនេះ ហាក់សកម្មជាងចំណុចទីមួយទៅទៀត។ គេសង្កេតឃើញមានការបង្កើតវិធានថ្មីៗជាច្រើនមកជំនួសវិធាននិងទំនៀមទម្លាប់ខ្មែរដែលមានតាំងពីយូរយោណាស់មកហើយ មានជាអាទិ៍ ក្រមរដ្ឋប្បវេណី[៤១៧] ក្រមនីតិវិធីរដ្ឋប្បវេណី[៤១៨] ក្រមព្រហ្មទណ្ឌ[៤១៩] បទប្បញ្ញត្តិពាណិជ្ជកម្ម[៤២០] ឬក៏របបគតិយុត្តនៃដីធ្លីជាដើម។ល។ ពាក់ព័ន្ធនឹងវិស័យតុលាការ បារាំងបានជ្រៀតចូលយ៉ាងលឿននៅក្នុងកិច្ចការយុត្តិធម៌ តាមរយៈការបង្កើតតួនាទីរបស់យុត្តាធិការបារាំងមកលើប្រព័ន្ធតុលាការកម្ពុជា ការលុបចោលតុលាការចម្រុះដែលមានសមត្ថកិច្ចជម្រះវិវាទរវាងខ្មែរនិងជនបរទេស និងការបង្កើនអំណាចតុលាការទៅឱ្យគណៈរដ្ឋមន្ត្រីដែលគ្រប់គ្រងដោយទេសាភិបាលបារាំង។

ជារួម បារាំងជាអ្នករៀបចំនិងធានាការផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងសង្គមតាមបែបទំនៀមទម្លាប់ ទៅជាប្រព័ន្ធគ្រប់គ្រងតាមច្បាប់សរសេរ។ ប៉ុន្តែការផ្លាស់ប្តូរនេះមិនមែនគ្មានបញ្ហានោះទេ។ ការចាប់យកប្រព័ន្ធច្បាប់សរសេរ ធ្វើឱ្យវិធាននៃច្បាប់កាន់តែមានភាពទូលំទូលាយ ហើយតម្រូវឱ្យឧបករណ៍គតិយុត្តទាំងឡាយត្រូវតែច្បាស់លាស់។ ច្បាប់កាន់តែស្មុគ្រស្មាញ ការអនុវត្តច្បាប់កាន់តែមានវិវាទនឹងគ្នា។ ពីមុនមក វិធានទំនៀមទម្លាប់ជាប្រភពស្នើរទាំងស្រុងនៃនីតិខ្មែរ។ ការធ្វើទំនើបកម្មនីតិខ្មែរ បានបង្កឱ្យមានភាពស្មុគ្រស្មាញ។ ការណ៍នេះបង្កលក្ខណៈឱ្យបារាំងកាន់តែមានឱកាសពង្រឹងការត្រួតពិនិត្យការអនុវត្តច្បាប់ និងពង្រីកអំណាចរបស់ខ្លួនទៅគ្រប់ដង្ហើមចេញចូលរបស់សង្គមខ្មែរ ព្រោះថាច្បាប់ទំនើបនេះមិនមែនសម្រាប់ឱ្យមនុស្សសាមញ្ញយល់ស្រួលនោះទេ។ ម្យ៉ាងទៀត ថ្វីបើច្បាប់ទំនើបរបស់បារាំងបង្កើតនូវឯកភាពនៃវិធាន តែវាបានផ្តាច់ខ្លួនពីការពិតនៃសង្គម និងបានធ្វើឱ្យខ្មែរបាត់បង់រឿងរ៉ាវក្បួនខ្នាតពីបុរាណកាលដែលខ្មែរធ្លាប់គោរពបដិបត្តិ។ វិធីសាស្ត្រដែលបារាំងកែទម្រង់ មិនបានធ្វើឱ្យមានការចូលរួមអនុវត្តទេ ព្រោះច្បាប់ថ្មីត្រូវបានចម្លងស្ទើរតែទាំងស្រុងពីច្បាប់បារាំង។ **នីតិរដ្ឋបាលគឺជាឧទាហរណ៍មួយ។**

---

[៤១៧] ១៩២០។

[៤១៨] ១៩៣៨។

[៤១៩] ១៩២៤។

[៤២០] ១៩២៦។ ការចាប់ផ្តើមតាក់តែងក្រមនៅឆ្នាំ១៩៤០ និងប្រកាសឱ្យប្រើនៅឆ្នាំ១៩៥០។

នៅឆ្នាំ១៩២៤ បារាំងបង្កើតអង្គការចាត់តាំងតុលាការរដ្ឋបាល ដោយផ្តាច់ចេញពីអង្គការចាត់តាំងតុលាការរដ្ឋប្បវេណី។ តុលាការរដ្ឋបាលមានសមត្ថកិច្ចជម្រះរឿងក្តីពាក់ព័ន្ធនឹងសិទ្ធិនិងកាតព្វកិច្ចរបស់មន្ត្រីរាជការ និងសេចក្តីសម្រេចដែលតម្រូវឱ្យប្រជារាស្ត្រសងប្រាក់ជំពាក់បុគ្គលសាធារណៈ ព្រមទាំងការទាមទារសំណងការខូចខាតបង្កឡើងដោយសកម្មភាពរដ្ឋបាលខ្មែរ[៤២១]។ ប្រព័ន្ធទ្វិភាពនេះ វាចំឡែកខ្លាំងសម្រាប់ខ្មែរជាទូទៅ។ នៅក្នុងអង្គការចាត់តាំងតុលាការរដ្ឋបាល មានតុលាការរដ្ឋបាលជាន់ទាបមួយឈ្មោះថាក្រុមវិវាទ តាំងនៅភ្នំពេញ និងមានចៅក្រមមួយរូបជាប្រធាន ហើយមានមន្ត្រីរាជការពីរូបជាចៅក្រមអម។ សមត្ថកិច្ចជម្រះបណ្តឹងឧទ្ធរណ៍ គឺជារបស់គណៈរដ្ឋមន្ត្រី លុះក្រោយមកត្រូវបានផ្ទេរ[៤២២]ទៅសភាពិសេសមួយនៃក្រុមប្រឹក្សាព្រះរាជាណាចក្រ[៤២៣] និងក្រោយមកទៀតទៅជាសាលាឧទ្ធរណ៍រដ្ឋបាលដាច់ដោយឡែកតែម្តង[៤២៤]។ សាលាឧទ្ធរណ៍នេះជម្រះដោយចៅក្រមបួនរូប ពីរូបមកពីសាលាវិនិច្ឆ័យ[៤២៥] ពីរូបទៀតជាមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រោមអធិបតីភាពប្រធានមួយរូបតែងតាំងដោយព្រះមហាក្សត្រដោយសារបទពិសោធន៍និងជំនាញផ្នែករដ្ឋបាល។ សាលាឧទ្ធរណ៍នេះក៏ដើរតួនាទីជម្រះវិវាទសមត្ថកិច្ចរវាងតុលាការរដ្ឋបាលនិងតុលាការរដ្ឋប្បវេណីផងដែរ។

តុលាការកំពូលរដ្ឋបាលត្រូវបង្កើតនៅក្រោយឯករាជ តាមគំរូ Conseil d'Etat របស់បារាំង ក៏ប៉ុន្តែមិនបានដំណើរការពិតប្រាកដទេ ដោយសារខ្វះមធ្យោបាយនិងធនធាន ហើយក៏ប្រហែលដោយសារភាពគ្មានបានការរបស់ស្ថាប័ននេះផងដែរ។ អ្នកសិក្សាច្រើនលើសលប់យល់ថា ប្រសិនបើខ្មែរហ៊ានរករឿងអាជ្ញាធរ ប្រហែលជាគាត់ត្រូវលើកសំណើផ្ទាល់ទៅព្រះប្រមុខរដ្ឋ ដែលតាមទំនៀមទម្លាប់ពីបុរាណមក ព្រះអង្គមានអំណាចស្វែងរកយុត្តិធម៌ ព្រោះមុខងារនេះមានសារៈសំខាន់ផ្នែកនយោបាយនិងរដ្ឋបាលខ្លាំងណាស់។ នោះគឺសវនការជាមួយប្រជារាស្ត្រ ដែលព្រះមហាក្សត្រឬព្រះប្រមុខរដ្ឋរៀបចំឡើង ក្នុងក្របខ័ណ្ឌដោយឡែកនៃព្រះបរមរាជវាំង។ សរុបមក ការបង្កើតយុត្តាធិការពីរផ្សេងគ្នាមិនបានបង្កលក្ខណៈងាយស្រួលដល់ប្រជារាស្ត្រទេ។

---

[៤២១] មិនមែនរដ្ឋបាលបារាំងទេ?

[៤២២] ១៩៤៨។

[៤២៣] ដូចជាព្រឹទ្ធសភាបច្ចុប្បន្ន។

[៤២៤] ច្បាប់ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៥៣។

[៤២៥] តុលាការកំពូលបច្ចុប្បន្ន។

ខ. ឧបសគ្គនៃការធ្វើទំនើបកម្មច្បាប់នៅកម្ពុជា

គ្មាននរណាម្នាក់អាចជំទាស់នឹងធ្វើទំនើបកម្មច្បាប់របស់បារាំងក្នុងអំឡុងពេលអាណាព្យាបាលទេ។ ទំនើបកម្មនេះមានឥទ្ធិពលយូរអង្វែងលើប្រព័ន្ធច្បាប់ខ្មែរ ហើយនៅតែមានឥទ្ធិពលដោយផ្ទាល់ឬដោយប្រយោលរហូតដល់ច្បាប់បច្ចុប្បន្ន។ មានអ្នកជឿថា អ្វីដែលបារាំងបានធ្វើ ផ្តល់ផលវិជ្ជមានសម្រាប់ខ្មែរ ព្រោះវាត្រូវបានរៀបចំនិងអនុវត្តដោយមានការឯកភាពនិងស្រុះស្រួលគ្នារវាងឥស្សរជននិងរដ្ឋបាលរបស់ខ្មែរ ក្រោមការដឹកនាំរបស់ព្រះរាជាខ្មែរនិងថ្នាក់ដឹកនាំបារាំង។ អ្វីដែលសំខាន់ជាងនេះទៅទៀត វាបាននាំមកឱ្យកម្ពុជានូវសន្តិភាពដែលខ្មែរបានបាត់បង់តាំងពីពេលបោះបង់ចោលអង្គរមក។ ទោះជាយ៉ាងណា គោលបំណងរបស់បារាំងក្នុងការធ្វើទំនើបកម្មច្បាប់ខ្មែរបានជួបប្រទះនឹងឧបសគ្គជាច្រើន។ ឧបសគ្គទាំងនោះមានទំនាក់ទំនងជាមួយការបដិសេធរបស់ខ្មែរផងជាមួយការប្រើប្រាស់វិធីសាស្ត្ររបស់បារាំងផង។

ទីមួយ គឺការតវ៉ារបស់ព្រះមហាក្សត្រចំពោះការកែទម្រង់ដែលស្នើឡើងដោយបារាំង។ បើប្រៀបធៀបនឹងប្រទេសដែលស្ថិតក្រោមអាណានិគមផ្សេងទៀត ខ្មែរមានលក្ខណៈដោយឡែកបីចំណុច៖ ការទប់ទល់នឹងការបង្ខំពីខាងក្រៅ ការស្រលាញ់របបរាជានិយម និងសកម្មភាពរបស់ព្រះមហាក្សត្រ។ ព្រះបាទ នរោត្តម (១៨៦០-១៩០៤) ដែលបានគ្រងរាជស្នើរតែពាក់កណ្តាលនៃរយៈពេលអាណាព្យាបាលទាំងមូល មិនដែលឈប់តវ៉ារើបម្រាស់ពីបារាំងទេ។ ពេញមួយព្រះជន្មព្រះអង្គ ព្រះអង្គតែងងើបប្រឆាំងនឹងទង្វើហួសហេតុនៃថ្នាក់ដឹកនាំរបស់របបអាណានិគម[៤២៦]។ ទីពីរ គឺការមិនទុកចិត្តរបស់សង្គមខ្មែរចំពោះពួកអាណានិគម។ ប្រជាជនកម្ពុជាចោទសួរខ្លួនឯងនូវសំណួរជាច្រើនអំពីការកែទម្រង់ទាំងនេះ ពិសេសអំពីភាពស៊ីគ្នាចង្វាក់គ្នារវាងច្បាប់បារាំងជាមួយនឹងតម្រូវការពិតនៃសង្គមខ្មែរ។ ខ្មែរងឿងឆ្ងល់ថា តើការកែទម្រង់ទាំងនេះធ្វើដើម្បីទំនើបកម្មពិតៗ ឬគ្រាន់តែជាការដកយកវិធានរបស់ពួកស្បែកស មកស្ងួងក្នុងសង្គមខ្មែរដោយគ្មានចំណងសង្គមឬវប្បធម៌អ្វីទាល់តែសោះ។ ទោះបីជាខ្មែរអាចទទួលយកគំរូរបស់បារាំងបានខ្លះ[៤២៧] វិធានខ្លះ ផ្ទុយទៅវិញ បានប៉ះទង្គិចខ្លាំងជាមួយនឹងស្មារតីជាតិនិយម ជាពិសេសការកែ

---

[៤២៦] ព្រះអង្គបានដើរព្រះរាជតួនាទីសំខាន់ក្នុងការបះបោរនៅក្រោយអនុសញ្ញាថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ដែលបានបង្ខំបារាំងឱ្យដកថយមួយជំហាន។ វិធានការអនុវត្តអនុសញ្ញានេះនៅតែមិនត្រូវបានចាត់ចែង។ ការបះបោរនេះថែមទាំងបានបង្ខំឱ្យអ្នកស្នងតំណែងរបស់លោកអគ្គទេសាភិបាល Thomson បោះបង់ចោលវិធានការទាំងនោះទៀតផង។

[៤២៧] ឧទាហរណ៍ របបអាពាហ៍ពិពាហ៍។

ទម្រង់ផ្នែកវប្បធម៌។ ការដាក់ចេញបញ្ញត្តិច្បាប់មិនត្រឹមតែដើម្បីដោះស្រាយស្ថានភាពនៃសង្គមមួយទេ ប៉ុន្តែក៏មានគោលបំណងដើម្បីធ្វើឱ្យវាវិវត្តន៍ទៅមុខផងដែរ។ ដូច្នេះកិច្ចការលំបាកបំផុតគឺការធ្វើឱ្យបញ្ញត្តិទាំងនោះត្រូវបានទទួលយក ចៀសវាងការបដិសេធ ឬការទាត់ចោលពីប្រជារាស្ត្រ។

ចំណុចចុងក្រោយនិងសំខាន់បំផុតគឺការតស៊ូផ្នែកវប្បធម៌របស់ជនជាតិខ្មែរ។ ទោះបីស្ថិតក្រោមអាណាព្យាបាល ទំនៀមទម្លាប់និងការអនុវត្តតាមស្ថាប័នជាច្រើននៅតែបន្ត ប្រឆាំងនឹងឆន្ទៈរបស់បារាំងក្នុងការកែទម្រង់។ ឧទាហរណ៍ជាក់ស្តែងគឺ "ប្រព័ន្ធយុត្តិធម៌រាជា"[៤២៨] ដែលជាទីគាប់ចិត្តរបស់ខ្មែរ។ តាពរឹងមាំនៃទំនៀមទម្លាប់រាជាធិបតេយ្យរបស់ខ្មែរនៅក្នុងវិស័យយុត្តិធម៌ បានបង្កឱ្យមានការពិបាកធ្ងន់ធ្ងរក្នុងការអនុវត្តប្រព័ន្ធយុត្តិធម៌បែបអឺរ៉ុប។ អតីតព្រះមហាក្សត្រខ្មែរនៅតែមានតួនាទីជាចៅក្រម ទោះបីជាការពិត ការថែរក្សាសណ្តាប់ធ្នាប់ក្នុងព្រះនគរ ត្រូវបានប្រគល់ទៅឱ្យអង្គការចាត់តាំងតុលាការមួយជាក់លាក់និងឯករាជក៏ដោយ។ មុខងាររបស់ព្រះមហាក្សត្រ ជាចៅក្រមកំពូលនេះមានសារៈសំខាន់ណាស់ក្នុងប្រទេសកម្ពុជា។ សូម្បីជម្លោះតូចតាចបំផុតរបស់រាស្ត្រ ក៏អាចទៅដល់ព្រះមហាក្សត្រដែរ។ ហើយនេះវាគឺជាមធ្យោបាយចុងក្រោយដែលប្រជានុរាស្ត្ររបស់ព្រះអង្គមាន។ ទំនៀមទម្លាប់រត់ទៅរកព្រះមហាក្សត្រនេះ ត្រូវបានគេអនុវត្តបន្តជាធម្មតាក្នុងសម័យបារាំង បើទោះបីជាគ្មានមូលដ្ឋានរដ្ឋធម្មនុញ្ញ ឬច្បាប់ណាមួយក៏ដោយ។

ការកែទម្រង់ដែលធ្វើឡើងដោយបារាំងត្រូវប្រឈមនឹងបញ្ហាស្វ័យភាពនៃសំណុំវិធានច្បាប់ខ្មែរ។ ច្បាប់ ដែលបង្កើតឡើងក្រោមអាណានិគមបារាំង ទោះជាមានលក្ខណៈបច្ចេកទេសខ្ពស់ប្រសើរយ៉ាងណា ក៏ត្រូវបាត់បង់គុណភាពដោយសារចំណុចខ្សោយសំខាន់មួយគឺ "យីហោបរទេស" របស់វា។ ដើម្បីទៅរួច ច្បាប់ទាំងនេះត្រូវតែធ្វើមានលក្ខណៈ "ខ្មែរ" ជាមុនសិន ជួនដោយសង្គមទទួលយកដោយស្មគ្រចិត្ត ជួនដោយសកម្មភាពប្រកបដោយឆន្ទៈនៃអំណាចជាតិពិតប្រាកដមួយ។ ផ្ទុយពីការរំពឹងរបស់ពួកបារាំង ការកែទម្រង់របស់ពួកគេជួបការលំបាកដោយសារភាពបញ្ច្រាសបណ្តាយនៃច្បាប់ដែលគេចេញនៅកម្ពុជាផង ពីហាណូយផង ពីប៉ារីសផង។ អ្នកសិក្សាខ្លះថែមទាំងមិនជឿថា ប្រព័ន្ធច្បាប់ដែលបារាំងរៀបចំឱ្យកម្ពុជាក្រោយឆ្នាំ១៨៨៤ មាននៅរស់រានរហូតនៅក្នុងសង្គមខ្មែរឡើយ។ គេពន្យល់ថាលើឆាកអន្តរជាតិ សហភាពឥណ្ឌូចិនរបស់បារាំងបានកាត់មុខកាត់មាត់ខ្មែរអស់

[៤២៨] Justice retenue។

ហើយ[៤២៩]។ នៅក្នុងស្រុកវិញ នីតិសាធារណៈនិងនីតិឯកជនរបស់ខ្មែរត្រូវយកប្រភពពីរដ្ឋមួយដែលមានអំណាចខ្ពស់ជាង។ សមត្ថកិច្ចផ្លូវច្បាប់របស់កម្ពុជាមាននៅសល់ត្រឹមមើលការខុសត្រូវលើប្រជារាស្ត្រខ្លួនឯងក្នុងវិស័យមួយចំនួនប៉ុណ្ណោះ ហើយសមត្ថកិច្ចដែលនៅបម្រុងទុកនេះ ត្រូវអនុវត្តតាមអង្គហេតុនិងអង្គច្បាប់ដោយអាជ្ញាធរអាណាព្យាបាលក្រោមការត្រួតពិនិត្យរបស់អគ្គទេសាភិបាល។

សេចក្តីសន្និដ្ឋាន

បន្ទាប់ពីទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ កម្ពុជាបានឆ្លងកាត់យុគសម័យនយោបាយនិងរដ្ឋបាលថ្មី ក្រោមព្រះបាទ នរោត្តម សីហនុ ដែលត្រូវបានលើកតម្កើងជាបិតាជាតិខ្មែរ។ មនោគមវិជ្ជាសីហនុនិយមមានទំនាក់ទំនងនឹងសញ្ញាណនៃរដ្ឋនិងប្រយោជន៍សាធារណៈ តែត្រូវបានបញ្ចប់ជាអកុសលនៅឆ្នាំ១៩៧០ ដោយរដ្ឋប្រហារគាំទ្រដោយសហរដ្ឋអាមេរិក។ នៅឆ្នាំ១៩៧៥ ខ្មែរក្រហមបានចូលទីក្រុងភ្នំពេញ ហើយបានបោសសម្អាតប្រជាជនទាំងអស់ពីទីក្រុង និងបង្កើតរបបកុម្មុយនិស្តផ្តាច់ការ ដោយបង្ខំប្រជាជនឱ្យធ្វើស្រែចម្ការនិងស្រែ។ កម្លាំងតស៊ូដឹកនាំដោយក្រុមដែលប្រឆាំងនឹងខ្មែរក្រហម និងដោយមានការគាំទ្រពីកងទ័ពស្ម័គ្រចិត្តវៀតណាមបានរុញខ្មែរក្រហមទៅជាយដែននិងទៅក្នុងព្រៃ រួចបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជា។ កម្ពុជាបានធ្លាក់ចូលទៅក្នុងសង្គ្រាមស៊ីវិលម្តងទៀត តែបានបញ្ចប់មួយអន្លើដោយសារកិច្ចព្រមព្រៀងទីក្រុងប៉ារីសក្នុងឆ្នាំ១៩៩១។ សាធារណរដ្ឋប្រជាមានិតកម្ពុជា បានធ្វើសេរីភាវូបនីយកម្មនៅឆ្នាំ១៩៨៩ ដើម្បីក្លាយជារដ្ឋកម្ពុជា។ ពីឆ្នាំ១៩៩១ ដល់ឆ្នាំ១៩៩៣ អង្គការសហប្រជាជាតិចូលមករៀបចំការបោះឆ្នោតសាកលជាលើកដំបូង។ របបសាធារណរដ្ឋខ្មែរនិងកម្ពុជាប្រជាធិបតេយ្យមានអាយុខ្លីពេក ដែលមិនអាចឱ្យយើងធ្វើការសន្និដ្ឋានអំពីគោលគំនិតនៃប្រព័ន្ធច្បាប់បាន។ របបទាំងពីរជោគជាំដោយសង្គ្រាម។ ពួកសាធារណរដ្ឋបានកាន់កាប់តែផ្នែកតូចមួយនៃទឹកដីដុំវិញរាជធានីនិងទីក្រុងធំៗមួយចំនួន។ ពួកខ្មែរក្រហមវិញបានដឹកនាំ "របបដែលគ្មានច្បាប់" និងប្រព្រឹត្តអំពើប្រល័យពូជសាសន៍ពាសពេញផ្ទៃប្រទេស។ ដូច្នេះហើយបានជាសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាកម្មវត្ថុនៃផ្នែកខាងក្រោម។

២.៣.២.២. ឥទ្ធិពលរបស់ប្រព័ន្ធច្បាប់សង្គមនិយម

សាធារណរដ្ឋប្រជាមានិតកម្ពុជាមានបួនដំណាក់កាល៖ ការកសាងឡើងវិញពីឆ្នាំ

[៤២៩] តួយ៉ាងសន្ធិសញ្ញាបារាំង-សៀម ឆ្នាំ១៩០៧ មិនមែនសន្ធិសញ្ញាខ្មែរ-សៀមទេ។

១៩៧៩ ដល់ឆ្នាំ ១៩៨២; ការបង្កើតសង្គមនិយមពីឆ្នាំ១៩៨៣ ដល់ឆ្នាំ១៩៨៦ ជាមួយនឹងចំណុចរបត់មួយនៅឆ្នាំ១៩៨៥ នៅពេលដែលមានការបើកចំហដល់វិស័យឯកជន។ ជ័យជម្នះនៃវិស័យឯកជនពីឆ្នាំ១៩៨៧ ដល់ឆ្នាំ១៩៩០; ហើយទីបំផុតការស្លាប់នៃសង្គមនិយមក្នុងឆ្នាំ១៩៩១។ ក្នុងអំឡុងពេលដប់ឆ្នាំនេះ របបនេះស្ថិតនៅក្រោម "ការគាំទ្រពីវៀតណាម" និងជាផ្នែកមួយនៃប្លុកខាងកើត[៤៣០]។ នេះជាលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់កម្ពុជា ដែលត្រូវបានគ្រប់គ្រងជាផ្លូវការតាមគោលការណ៍សង្គមនិយមដែលមានប្រភពម៉ាក្សនិយម។ រដ្ឋធម្មនុញ្ញនៃសាធារណៈរដ្ឋប្រជាមានិតកម្ពុជាមានភាពច្បាស់លាស់៖ ថ្កោលទោសវិសមភាពសង្គម និងការកេងប្រវ័ញ្ចមនុស្សដោយមនុស្សនិងការបង្កើតសង្គមភាវូបនីយកម្មនៃភាពជាម្ចាស់នៃមធ្យោបាយផលិតកម្ម។ គោលការណ៍ទាំងនេះបានបម្រើជាមូលដ្ឋានសម្រាប់រាល់សកម្មភាពរបស់រដ្ឋក្នុងការបំពេញចិត្តប្រជាជនរបស់ខ្លួន។ ថ្វីត្បិតតែសង្គមនិយមកម្ពុជាមិនទាន់ទទួលបានជោគជ័យត្រចះត្រចង់ តែកេរដំណែលរបស់វានៅតែអាចកត់សម្គាល់បានរហូតសព្វថ្ងៃ។

ក. បរាជ័យនៃម៉ាក្សនិយមក្នុងសង្គមខ្មែរ

សាធារណរដ្ឋប្រជាមានិតកម្ពុជា មានរដ្ឋបាលសាធារណៈដែលមានមជ្ឈិមភាពខ្ពស់[៤៣១]។ ទោះជាយ៉ាងនេះ មជ្ឈិមភាពរដ្ឋបាលហួសហេតុនេះ មិនអាចនាំមកនូវលទ្ធផលរំពឹងទុកទេ ហើយការប្រមូលផ្តុំមធ្យោបាយផលិតកម្មដែលជាគោលការណ៍គ្រឹះរបស់លទ្ធិសង្គមនិយមនោះ ក៏មិនទទួលបានជោគជ័យដែរ។ នៅសម័យនោះ ការបែងចែកសមត្ថកិច្ចសម្រាប់ស្ថាប័នរដ្ឋមានភាពមិនច្បាស់លាស់ច្រើន។ ស្ថាប័នដែលទទួលខុសត្រូវចំពោះការរៀបចំបច្ចេកទេសនិងការអនុវត្តគោលនយោបាយដែលកំណត់ដោយរដ្ឋាភិបាលគ្រាន់តែជាអង្គការចាត់តាំងដ៏ធំទូលាយមួយ។ យន្តការនេះមានទាំងស្ថាប័នរដ្ឋទាំងអស់ដូចជា កងទ័ព ប៉ូលីស តុលាការ ក៏ដូចជាអង្គភាពផ្សេងៗ ដូចជាអង្គការមហាជន និងគណបក្ស។ ធាតុទាំងអស់ដែលបានរួមបញ្ចូលនៅក្នុងអង្គការនេះគឺស្ថិតនៅក្រោមអំណាចតែមួយនិងប្រព័ន្ធគ្រប់គ្រងដូចគ្នា។ នេះគឺជាបញ្ហា។ ជាការពិត រដ្ឋបាលមានភាពខុសប្លែកគ្នាយ៉ាងខ្លាំងពីអង្គភាពមួយទៅអង្គភាពមួយ។ លក្ខណៈវិនិច្ឆ័យនៃការកំណត់តម្រូវការ

---

[៤៣០] មាត្រា១ នៃរដ្ឋធម្មនុញ្ញចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៨១ ចែងថាប្រទេសកម្ពុជា «កំពុងដើរមួយជំហានឆ្ពោះទៅរកសង្គមនិយម»។ មាត្រា៦ កថាខណ្ឌទី២ ចែងថាកម្ពុជា "តែងចំណងសាមគ្គីភាព និងសហប្រតិបត្តិការជាមួយវៀតណាម ឡាវ សហភាពសូវៀត និងប្រទេសសង្គមនិយមជាបងប្អូនឯទៀត"។

[៤៣១] មាត្រា៦៤ កថាខណ្ឌទី១ នៃរដ្ឋធម្មនុញ្ញថ្ងៃទី២៥ ខែមិថុនាឆ្នាំ១៩៨១ ចែងថា "ក្រុមប្រឹក្សារដ្ឋមន្ត្រីជារដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ជាអង្គការគ្រប់គ្រងសង្គមដោយផ្ទាល់ និងដឹកនាំការពង្រីកសេដ្ឋកិច្ចជាតិដោយផ្ទាល់"។

ធនធានគឺមិនដូចគ្នាសម្រាប់សេវាសាធារណៈ ដូចជា សម្រាប់អង្គការមហាជន ឬស្ថាប័នតុលាការជាដើម។ ដូច្នេះហើយ ជម្លោះសមត្ថកិច្ចរវាងរដ្ឋបាលនិងស្ថាប័នរដ្ឋដទៃទៀតតែងកើតមានជាញឹកញាប់ ជាពិសេសនៅក្នុងវិស័យសង្គមកិច្ច វប្បធម៌ និងសេវាសង្គម។

របបនេះមានមជ្ឈិមភាពផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុដែល "ពិតដូចមិនពិត"។ រដ្ឋបាលមូលដ្ឋាននៅកម្ពុជា ចន្លោះឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩២ មានបីកម្រិតដែលត្រូវគ្នានឹងរដ្ឋបាលមូលដ្ឋានបីប្រភេទ គឺខេត្ត ស្រុក និងឃុំ[៤៣២]។ ខេត្តទាំង១៩ និងក្រុងចំនួន២ ត្រូវបានបែងចែកទៅជាស្រុក[៤៣៣] ដែលជាអង្គភាពរដ្ឋបាលមូលដ្ឋាន[៤៣៤]។ នៅក្នុងរដ្ឋទោលដូចជាកម្ពុជា មន្ត្រីរដ្ឋបាលមូលដ្ឋានជាតំណាងរបស់រដ្ឋ។ ពួកគេត្រូវបានតែងតាំងដោយរដ្ឋបាលកណ្តាលតាមលក្ខណៈវិនិច្ឆ័យកំណត់ទុក។ សម្រាប់កិច្ចការបម្រើផលប្រយោជន៍ទូទៅ មន្ត្រីមូលដ្ឋានទាំងនេះគួរតែជើរតួមិនត្រឹមតែជាអ្នកតំណាងនៃអំណាចកណ្តាលនិងជាអ្នកតម្កល់អំណាចរដ្ឋនៅក្នុងស្រុកដែលពួកគេគ្រប់គ្រងប៉ុណ្ណោះទេ ប៉ុន្តែក៏ជាតំណាងអចិន្ត្រៃយ៍នៃអំណាចប្រតិបត្តិផងដែរ។ នៅកម្ពុជាកាលពីសម័យសង្គមនិយម អ្វីៗគឺខុសគ្នា។ ដូចនៅក្នុងបណ្តាប្រទេសអឺរ៉ុបខាងកើត និងប្រទេសផ្សេងទៀតដែលយកគំនិតសង្គមនិយម ដែលនៅថ្នាក់រដ្ឋបាលមូលដ្ឋាននីមួយៗមាន "គណៈកម្មាធិការប្រជាជន" ដែលបំពេញកិច្ចការដូចជារដ្ឋមួយ។ គណៈកម្មាធិការទាំងនេះតែងផ្តួចផ្តើមគនិតនៅក្នុងគ្រប់វិស័យ លើកលែងតែវិស័យយុត្តិធម៌ ការពារជាតិ និងសន្តិសុខ។ មុខងាររបស់គណៈកម្មាធិការនេះ មិនត្រូវបានកំណត់ត្រឹមការងារពាក់ព័ន្ធនឹងខេត្តឬមូលដ្ឋានរបស់ខ្លួនទេ តែក៏ពង្រីកដល់ផលប្រយោជន៍ជាតិផងដែរ។ ដូច្នេះនៅសល់ដែនកំណត់តែមួយគត់ គឺព្រំប្រទល់ភូមិសាស្ត្រដែលពួកគាត់គ្រប់គ្រងតែម្តង! ជាងនេះទៀត បើពិនិត្យមើលនីតិវិធីនៃ

[៤៣២] ក៏មានសាលាក្រុងចំនួនពីរដែរដែលការទំនួលខុសត្រូវគឺស្រដៀងនឹងខេត្តដែរ លើកលែងតែសេវាដែលខ្លួនទទួលខុសត្រូវគឺសេវាក្រុង។

[៤៣៣] សរុបចំនួន ១៧២ស្រុក។

[៤៣៤] និយាយម្យ៉ាងទៀត វាជាថ្នាក់ទាបបំផុតដែលរដ្ឋាភិបាលកណ្តាលត្រូវបានតំណាងជាផ្លូវការ។ ស្រុកនីមួយៗត្រូវបានបែងចែកទៅជាឃុំមួយចំនួន ដែលជាមណ្ឌលរដ្ឋបាល និងដែលត្រូវបានចាត់ទុកថាជាតំបន់អន្តរាគមន៍ដែលទំហំរបស់វាត្រូវគ្នាទៅនឹងវិសាលភាពនៃសេវាកម្មដែលបម្រើភូមិមួយចំនួននៅក្នុងស្រុក។ ក្រុងត្រូវបានបែងចែជា "ខណ្ឌ" នៅក្នុងកណ្តាលក្រុង និងជា "ស្រុកជាយក្រុង" នៅតំបន់ជាយក្រុង។ "ខណ្ឌ" និង "ស្រុកជាយក្រុង" ត្រូវបានបែងចែកបន្តទៅជា "សង្កាត់"។

ការតែតាំង ខេត្ត ក្រុង ពិតជាមិនស្ថិតនៅក្រោមអំណាចផ្ទាល់របស់រដ្ឋាភិបាលកណ្តាលនោះទេ[៨៣៥]។

ប្រព័ន្ធរដ្ឋបាលមូលដ្ឋានមិនដូចប្រព័ន្ធគ្រប់គ្រងបច្ចុប្បន្នទេ ហើយក៏មិនដូចជាមានប្រព័ន្ធវិមជ្ឈការឬវិសហមជ្ឈការអីដែរ។ រដ្ឋបាលមូលដ្ឋានមិនមែនជាសមូហភាពដែនដីដែលបង្កើតឡើងតាមគោលការណ៍វិមជ្ឈការ និងដែលមានមុខងារនិងអំណាចផ្ទាល់ខ្លួនដាច់ពីរដ្ឋនោះឡើយ តែអាជ្ញាធរមូលដ្ឋានបែរជាទទួលបាននូវស្វ័យភាពយ៉ាងធំក្នុងការអនុវត្ត ហើយស្វ័យភាពនេះមិនបានមកពីការផ្ទេរអំណាចពីរដ្ឋជាផ្លូវការឡើយ។ ក្នុងការអនុវត្តសេចក្តីសម្រេចរបស់អាជ្ញាធរជាតិ គណៈកម្មាធិការប្រជាជននិងប្រធានរបស់គណៈកម្មាធិការនេះ មានការទទួលខុសត្រូវដូចជាក្រសួងដែរ ដោយសម្របទៅតាមលក្ខខណ្ឌជាក់ស្តែងនៃខេត្តរៀងៗខ្លួន។ ប៉ុន្តែពួកគេក៏អាចធ្វើការសម្រេចចិត្តនិងអនុវត្តវាដោយមិនចាំបាច់ឆ្លងថ្នាក់មជ្ឈិមដែរ។ ជាងនេះទៅទៀត រដ្ឋបាលខេត្តអាចជ្រើសរើសបុគ្គលិករដ្ឋបាលនិងបច្ចេកទេសដោយផ្ទាល់ ក្នុងចំនួនកំណត់ដោយក្រសួងផែនការ គ្រាន់តែការតែងតាំងត្រូវស្ថិតនៅក្រោមការយល់ព្រមពីក្រសួងបច្ចេកទេសប៉ុណ្ណោះ។ បុគ្គលិកទាំងនេះបំពេញការងាររបស់ខ្លួនទាំងស្រុងនៅក្នុងខេត្ត ដោយមិនអាចផ្ទេរទៅខេត្តផ្សេង ឬទៅរដ្ឋបាលកណ្តាលបានទេ។ ស្វ័យភាពដ៏ធំទូលំទូលាយនេះមិនត្រូវបានកំណត់តាមផ្លូវច្បាប់ជានោះទេ។ ម្ល៉ោះហើយនៅពេលមានបញ្ហា អំណាចកណ្តាលជាអ្នកទទួលបន្ទុករ៉ាប់រងផលប៉ះពាល់នៃទង្វើរបស់មូលដ្ឋាន។ សរុបទៅ គំនិតនៃមជ្ឈិមភាពរដ្ឋបាលឬការគ្រប់គ្រងរដ្ឋបាលបែបមជ្ឈការ មិនអាចទៅរួចទេនៅស្រុកខ្មែរ។ តាមទស្សនៈបច្ចេកទេសដំណើរការបែបនេះធ្វើឱ្យអាជ្ញាធរខេត្ត ក្រុង និងស្រុក កាន់តែមានភាពសាមគ្គីគ្នាក្នុងការការពារផលប្រយោជន៍នៃមូលដ្ឋានដែលខ្លួនគ្រប់គ្រង។

សង្គមនិយមដែលជាដំណាក់កាលអន្តរកាលមុនឈានមកដល់ដំណាក់កាលកុម្មុយនិស្ត មិនមែនកំណត់ដោយសារការលុបបំបាត់ទ្រព្យសម្បត្តិឯកជនទាំងអស់នោះទេ ប៉ុន្តែដោយសារការធ្វើសង្គមភាវូបនីយកម្មនៃមធ្យោបាយផលិតកម្ម ដែលកាលម៉ាក្សហៅថា ជាការបញ្ចប់ការកេងប្រវ័ញ្ចរបស់មនុស្សលើមនុស្ស។ សង្គមនិយមនៅកម្ពុជាគេចមិន

[៨៣៥] ប្រធានគណៈកម្មាធិការប្រជាជនខេត្តត្រូវបានតែងតាំងដោយក្រុមប្រឹក្សារដ្ឋ និងមានឋានៈស្មើអនុរដ្ឋមន្ត្រី។ អនុប្រធាននិងសមាជិកនៃគណៈកម្មាធិការទាំងនេះត្រូវបានតែងតាំងដោយរដ្ឋាភិបាល។ រដ្ឋាភិបាលមិនមានអំណាចក្នុងការស្នើបេក្ខជនសម្រាប់ការតែងតាំងអ្នកតំណាងទាំងនេះនៅថ្នាក់ខេត្ត ក្រុង និងស្រុកនោះទេ តែអាចបដិសេធមិនយល់ព្រមលើការតែងតាំងជាក់លាក់មួយបាន ដូចដែលគណៈកម្មាធិការប្រជាជន អាចប្រឆាំងនឹងការតែងតាំងមន្ត្រីដែលបានចាត់តាំងនៅស្រុករបស់ខ្លួន។

ផុតពីគោលការណ៍នេះទេ។ ការកសាងសេដ្ឋកិច្ចកម្ពុជាឡើងវិញត្រូវបានធ្វើឡើងក្នុងក្របខ័ណ្ឌសង្គមនិយម ជាពិសេស ការធ្វើសហករណ៍ក្នុងវិស័យកសិកម្ម[៤៣៦] ក្នុងគោលបំណងបន្ទាន់បំផុតគឺការស្តារផលិតភាពកសិកម្មឡើងវិញ។ ជាអកុសល របបសាធារណរដ្ឋប្រជាមានិតកម្ពុជាពុំមានធនធានហិរញ្ញវត្ថុគ្រប់គ្រាន់ដើម្បីអនុវត្តគោលនយោបាយរបស់ខ្លួនទេ។ ការធ្វើសហករណ៍កសិកម្មនិងឧស្សាហកម្ម ត្រូវប្រឈមនឹងការជំទាស់របស់ប្រជាជនដែលត្រូវដោះស្រាយបញ្ហាខ្លួនឯងដោយសារគ្មានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់និងកម្លាំងពលកម្ម[៤៣៧]។ ដើម្បីដោះស្រាយបញ្ហានេះ រដ្ឋាភិបាលបានលើកទឹកចិត្តដល់កសិករក្នុងការប្រមូលផ្តុំមធ្យោបាយផលិតកម្មដែលនៅសេសសល់ដើម្បីបន្តបង្កើនផលិតភាព។ ចាប់ពីដើមឆ្នាំ១៩៧៩ ចំនួនប្រជាជនត្រូវបានរៀបចំជាបណ្តើរៗទៅជា "ក្រុមសាមគ្គីបង្កបង្កើនផល" ដែលមានគោលបំណងដាំដុះដីដែលបានបែងចែកទៅក្រុមនីមួយៗ[៤៣៨]។

មានមូលហេតុជាច្រើនដែលនៅក្រោយបរាជ័យក្នុងការធ្វើសហករណ៍ក្នុងសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា។ ទីមួយគែគឺការបែងចែកផល ទីពីរកង្វះជំនួយរបស់រដ្ឋដល់កសិករ។ ប្រព័ន្ធបែងចែកផលមិនបានលើកទឹកចិត្តកសិករឱ្យធ្វើការជាក្រុមទេ ជួនកាលធ្វើឱ្យមនុស្សខ្ជិលគេចវេសទៅវិញ ព្រោះប្រព័ន្ធនេះគិតតែពីចំនួនថ្ងៃ មិនគិតអំពីសមិទ្ធផលនៃការងារទេ។ រីឯជំនួយរបស់រដ្ឋវិញ កសិករអាចទទួលបានក្រោមទម្រង់ជាគ្រាប់ពូជដែលផ្តល់ទិន្នផលខ្ពស់ ជី ថ្នាំសម្លាប់សត្វល្អិត ម៉ាស៊ីនបូម ប្រេងឥន្ធនៈ ឬគ្រឿងបន្លាស់។ ជាអកុសល ក្រុមសាមគ្គីតិចតួចណាស់ដែលទទួលបានជំនួយនេះ។

---

[៤៣៦] រហូតដល់ឆ្នាំ១៩៨៩ ថ្នាក់ដឹកនាំនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានតស៊ូមតិការពារគោលនយោបាយសមូហភាពរូបនីយកម្មនេះ និងបានយកទៅដាក់ឱ្យអនុវត្តនៅជនបទ។ ដូច្នេះហើយមធ្យោបាយផលិតកម្មសំខាន់ពីរគឺកសិកម្មនិងឧស្សាហកម្ម ត្រូវបានដាក់ជារបស់សមូហភាព។

[៤៣៧] ការខ្វះខាតឧបករណ៍កសិកម្មជាមូលដ្ឋាន គ្រាប់ពូជស្រូវ ពូជសត្វ អ្នកបច្ចេកទេសកសិកម្ម និងកម្លាំងពលកម្ម ព្រមទាំងប្រព័ន្ធដឹកជញ្ជូននិងទូរគមនាគមន៍។

[៤៣៨] ការបង្កើតក្រុមសាមគ្គីត្រូវបានជំរុញដោយគំនិតនយោបាយនិងការគ្រប់គ្រងទិសនៃលទ្ធិសង្គមនិយម។ ការរៀបចំផលិតកម្មទៅជាក្រុមសាមគ្គីបានសម្រួលដល់ការគ្រប់គ្រងផ្នែកនយោបាយនិងយោធា។ សមាជិកត្រូវតែនៅនឹងកន្លែង ប្រសិនបើពួកគេចង់ទទួលបានចំណែកនៃការប្រមូលផលរបស់ពួកគេ នៅពេលគេបែងចែកភោគផល។ វាក៏បានជួយសម្រួលដល់ការប្រមូលទិញស្រូវរបស់រដ្ឋាភិបាលដែលចាំបាច់សម្រាប់ចិញ្ចឹមកម្មាភិបាលនិងកងទ័ពរបស់ខ្លួន។ កិច្ចការសំខាន់ៗដែលគណបក្សបានប្រគល់ជូននោះ មិនត្រឹមតែជំរុញផលិតកម្មកសិកម្ម ចិញ្ចឹមសត្វ និងសិប្បកម្មក្នុងទម្រង់សេដ្ឋកិច្ចសមូហភាព ឬគ្រួសារប៉ុណ្ណោះទេ ថែមទាំងបានប្រយុទ្ធជាមួយខ្មាំងសត្រូវបានល្អ ការពារសន្តិសុខភូមិឃុំ ការពារផលិតកម្ម និងលើកទឹកចិត្តសមាជិកឱ្យចូលរួមក្នុងជួរកងទ័ព ដើម្បីពង្រឹងកងកម្លាំងប្រដាប់អាវុធ ការពារមាតុភូមិ។ គោលការណ៍របស់បក្សនិងរដ្ឋគឺអំពាវនាវឱ្យមានកិច្ចសហការយ៉ាងសកម្មក្នុងការពង្រឹងអាជ្ញាធរនិងកសាងកម្លាំងបដិវត្តន៍ដ៏រឹងមាំ។

លើសពីនេះ រដ្ឋាភិបាលខ្វះកម្មាភិបាលដែលមានសមត្ថភាពគ្រប់គ្រងក្រុមសាមគ្គី ក៏ដូចជាកម្មាភិបាលដែលគាំទ្រដល់សហគមន៍។ មេដឹកនាំសហករណ៍ភាគច្រើនមានកម្រិតវប្បធម៌ទាប និងខ្លះមិនទាំងចេះអក្សរផង។ កម្មាភិបាលខ្លះក៏មិនសូវប្រឹងប្រែងអនុវត្តការងាររបស់ខ្លួន។ ជួនកាល រដ្ឋាភិបាលយកចិត្តទុកដាក់លើបរិមាណនៃវិភាគទានស្នេហាជាតិដែលបានបង់និងលក់ស្រូវជូនរដ្ឋ ជាជាងការខិតខំរៀបចំក្រុមសាមគ្គីឱ្យបានល្អប្រសើរ។

មានមូលហេតុបីផ្សេងទៀតនៅពីក្រោយការបរាជ័យនៃការធ្វើសហករណ៍កសិកម្ម។ ទីមួយ អ្នកជំនាញការវៀតណាមមិនមានឥទ្ធិពលខ្លាំងលើវិស័យកសិកម្ម ដូចជាលើវិស័យផ្សេងទៀត ដូចជាសន្តិសុខឬគោលនយោបាយការបរទេសទេ។ ទីពីរ រដ្ឋាភិបាលមិនប្រើគោលនយោបាយបង្ខិតបង្ខំទេ។ រដ្ឋាភិបាលមិនអាចមាន លទ្ធភាពដាក់ទណ្ឌកម្មលើក្រុមឬបុគ្គលណាបានទេ ដោយសារស្ថានការណ៍ស្រុកទេសស្ថិតក្នុងសង្គ្រាមស៊ីវិល។ ចុងក្រោយ មិនចូលរួមនិងមិនចង់ធ្វើការជាសមូហភាព ព្រោះផ្នត់គំនិតនៃការធ្វើការរួមគ្នានេះលែងមាននៅក្នុងចំណោមជនជាតិខ្មែរទៀតហើយ។ នេះជាមរតកនៃរបបកម្ពុជាប្រជាធិបតេយ្យ។

ខ្មែរក្រហមអស់អំណាចដោយបន្សល់ទុកប្រទេសមួយដែលខ្ទេចខ្ទីជាប្រព័ន្ធ។ មកដល់ឆ្នាំ១៩៧៩ ដីមិនអាចប្រើប្រាស់បានភ្លាមៗទេ។ ឧបករណ៍ភាគច្រើនសម្រាប់ការងារកសិកម្មត្រូវការជួសជុល។ ហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្មត្រូវបានបំផ្លាញ។ ផ្លូវថ្នល់ ស្ពាន ផ្លូវរថភ្លើង ហាងទំនិញ និងគ្រឿងបរិក្ខារផ្សេងទៀត រងការខូចខាតធ្ងន់ធ្ងរ។ ជាមួយនឹងកិច្ចខិតខំប្រឹងប្រែងសង្គ្រោះពីអ្នកការពាររបស់កម្ពុជា ដូចជាវៀតណាម និងជាពិសេសសហភាពសូវៀត រដ្ឋបានព្យាយាមចាប់ផ្តើមឧស្សាហកម្មមួយចំនួនឡើងវិញ។ រដ្ឋបានធ្វើឧស្សាហកម្មជាសមូហភាពដែលគ្របដណ្តប់សកម្មភាពទាំងអស់នៅក្នុងប្រទេស ហើយហាមឃាត់រាល់ឧស្សាហកម្មឯកជន។ ទោះបីជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់នៅដើមដំបូងនៃគោលនយោបាយនេះក៏ដោយ ក៏ឧស្សាហកម្មនៅសម័យនោះមិនអាចបំពេញតម្រូវការរបស់រដ្ឋនិងប្រជាជនរបស់ខ្លួនបានឡើយ។ ការដាច់ចរន្តអគ្គិសនីញឹកញាប់ធ្វើឱ្យសកម្មភាពសេដ្ឋកិច្ចនិងប្រតិបត្តិការនៃសេវាកម្មសំខាន់ៗត្រូវបានប៉ះពាល់ធ្ងន់ធ្ងរ មូលហេតុចំបងគឺបរិក្ខារហួសសម័យ ហើយអ្នកប្រើប្រាស់ឬអតិថិជនធំៗរបស់ក្រុមហ៊ុនអគ្គិសនី គឺជាភ្នាក់ងាររដ្ឋាភិបាលនិងសហគ្រាសសាធារណៈ ដែលគ្មានលទ្ធភាពបង់ថ្លៃភ្លើងបាន ធ្វើឱ្យអគ្គិសនីកម្ពុជាខ្វះថវិកាទិញប្រេងឥន្ធនៈ និងគ្រឿងបន្លាស់ចាំបាច់សម្រាប់ប្រតិបត្តិការ។ នៅពេលដែលការផ្គត់ផ្គង់ថាមពលកាន់តែយ៉ាប់ ការលួចតបណ្តាញទឹកនិងអគ្គិសនីកាន់តែកើនឡើង ដែលសហគ្រាសសេវាកកាន់តែជួបវិបត្តិហិរញ្ញវត្ថុ។

បរាជ័យនេះបានបង្ខំរដ្ឋាភិបាលបណ្តោយតាមការជាក់ស្តែង ដូចជាការបើកឱ្យមានសេដ្ឋកិច្ចលក្ខណៈគ្រួសារដើម្បីបង្កើនកម្រិតជីវភាព។ ពេលនោះ សហគ្រាសរដ្ឋក៏ចាប់ផ្តើមបាត់បង់សន្ទុះយ៉ាងលឿន។ ទោះជាយ៉ាងណាក្តី ការពង្រីកវិស័យឯកជននេះនៅមានភាពផុយស្រួយ ដោយសារសេវាសាធារណៈសំខាន់ៗមិនមានគ្រប់គ្រាន់សម្រាប់បំពេញតម្រូវការ ហើយអតុល្យភាពម៉ាក្រូសេដ្ឋកិច្ចកាន់តែជាបទៅៗ។ នៅដើមទសវត្សរ៍ឆ្នាំ៩០ សេវាសាធារណៈដែលមិនល្អស្រាប់ហើយនោះ ត្រូវបានប្រជាជនទាមទារកាន់តែខ្លាំងឡើង ដោយសារតែការធ្វើសមាហរណកម្មនៃជនភៀសខ្លួនមកពីព្រំដែន ដែលបណ្តាលឱ្យសេវាទាំងនោះស្ទើរតែគាំងទាំងស្រុង។

រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនដែលត្រូវបានទទួលស្គាល់ដោយអង្គការសហប្រជាជាតិទេ ហើយក្នុងអំឡុងពេលដប់បីឆ្នាំនៃការគ្រប់គ្រងដែនដីស្ទើរតែទាំងមូលនៃប្រទេសកម្ពុជា រាល់ជំនួយការកសាងនិងអភិវឌ្ឍត្រូវបានបដិសេធដោយមហាអំណាចលោកខាងលិចតាមរយៈការដាក់ទណ្ឌកម្មសេដ្ឋកិច្ច។ ក្នុងទស្សវត្សរ៍ឆ្នាំ៨០ រដ្ឋាភិបាលត្រូវតស៊ូដើម្បីកសាងឡើងវិញជាមួយនឹងធនធានមានកម្រិតនូវប្រទេសមួយដែលបានខូចខ្ទេចខ្ទាំពីសង្គ្រាមស៊ីវិលដប់ឆ្នាំ ការឈ្លានពានពីបរទេស ការទម្លាក់គ្រាប់បែក និងការពិសោធន៍ជ្រុលនិយមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ ប្រទេសវៀតណាមនិងបណ្តាប្រទេសប្លុកសូវៀតបានផ្តល់ជំនួយសេដ្ឋកិច្ច។ យ៉ាងណាក៏ដោយ រដ្ឋាភិបាលកម្ពុជាត្រូវបង្ខំចិត្តលះបង់ធនធានភាគច្រើនរបស់ខ្លួន ទៅនឹងការចំណាយលើវិស័យយោធា ដើម្បីប្រយុទ្ធប្រឆាំងនឹងកងទ័ពខ្មែរក្រហម និងទ័ពព្រៃមិនមែនកុម្មុយនិស្តផ្សេងទៀត។

សរុបមក គោលនយោបាយបដិវត្តន៍របស់សាធារណរដ្ឋប្រជាមានិតកម្ពុជាមានកម្រិតមធ្យមតាមទស្សនៈ សង្គមនិយម។ ជាការពិត គណបក្សប្រជាជនកម្ពុជាដែលដឹកនាំកិច្ចការនេះ ត្រូវគិតគូរពីកេរ្តិ៍ដំណែលនៃសម័យខ្មែរក្រហមនិងស្នាមរបួសរបស់ប្រជាជន។ គោលនយោបាយទាំងនេះគួរឱ្យចាប់អារម្មណ៍ ពីព្រោះសូម្បីការធ្វើសហករណ៍ត្រឹមបន្តិចបន្តួចសោះក៏បរាជ័យដែរ ព្រោះថាកសិករខ្មែរមិនចូលចិត្តប្រព័ន្ធនេះទេ។ បរាជ័យនេះអាចបណ្តាលមកពីកត្តានយោបាយនិងសេដ្ឋកិច្ច ប៉ុន្តែភាគច្រើនគឺមកពីកត្តាចិត្តសាស្ត្រនិងវប្បធម៌ ដែលមិនមែនជាកេរដំណែលនៃរបបកម្ពុជាប្រជាធិបតេយ្យតែមួយមុខនោះទេ។ គោលនយោបាយសមូហភាពបានបរាជ័យដោយសារតែកសិករមិនចូលចិត្តការងារសមូហភាពក្នុងការបម្រើសហគមន៍ និងការតបន្តឹងលើសេរីភាពបុគ្គលរបស់ពួកគេ ដែលជាកត្តាវប្បធម៌និងមនុស្ស និងដែលអ្នកតាក់តែងទ្រឹស្តីសង្គមនិយមមិនសូវផ្តល់តម្លៃ។

ខ. មរតកនៃរបបសង្គមនិយមក្នុងសង្គមខ្មែរ

របបសង្គមនិយមនៅកម្ពុជាបានបញ្ចប់ជាផ្លូវការឆ្នាំ១៩៨៩ ជាមួយការការបង្កើតរដ្ឋកម្ពុជា។ រដ្ឋធម្មនុញ្ញនៃរដ្ឋកម្ពុជាបានបង្កើតប្រព័ន្ធនយោបាយសេរីពហុបក្សទទួលស្គាល់សិទ្ធិកម្មសិទ្ធិ និងសេដ្ឋកិច្ចឯកជន។ រដ្ឋកម្ពុជាមានអាយុត្រឹមរយៈពេលខ្លី។ កិច្ចព្រមព្រៀងទីក្រុងប៉ារីសឆ្នាំ១៩៩១ បានបង្កើតរដ្ឋបាលរបស់អង្គការសហប្រជាជាតិដែលទទួលខុសត្រូវរៀបចំការបោះឆ្នោតសាកលជាលើកដំបូងនៃសម័យក្រោយសង្គ្រាម។ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាក្រោយការបោះឆ្នោត បានបង្កើតរបបរាជានិយមអាស្រ័យធម្មនុញ្ញ និងរបបប្រជាធិបតេយ្យសេរីពហុបក្ស។ ទោះយ៉ាងណាក៏ដោយ របបសង្គមនិយមកម្ពុជាមិនទាន់រលត់ទាំងស្រុងទេ។ ប្រទេសកម្ពុជានៅតែជាប្រទេសមជ្ឈការខ្លាំង និងមានលក្ខណៈមជ្ឈិមនិយមនៅឡើយ។ នេះជាប្រព័ន្ធមួយដែលជីវិតទាំងមូលនៃរដ្ឋបាលអាស្រ័យតែលើអង្គការកណ្តាលតែមួយគត់។ នៅឆ្នាំ១៩៩២ ប្រព័ន្ធគ្រប់គ្រងប្រទេសនៅសល់ឥទ្ធិពលនៃរបបសង្គមនិយមនៅឡើយ។ ចំនួនក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទនៅមានច្រើន។ វិបត្តិឬជម្លោះសមត្ថកិច្ចកើតមានញឹកញាប់។ ការបែងចែងសមត្ថកិច្ចរវាងអំណាចនីតិប្រតិបត្តិ រដ្ឋបាលសាធារណៈ និងស្ថាប័នដទៃទៀតក៏ពុំច្បាស់លាស់។

រដ្ឋបាលមូលដ្ឋានក្នុងសម័យកុម្មុយនិស្តមានស្ថិយភាពយ៉ាងទូលំទូលាយ ប៉ុន្តែគ្មានការទទួលខុសត្រូវផ្នែកស៊ីវិល រដ្ឋបាល និងហិរញ្ញវត្ថុអីទេ។ ស្ថិយភាពនេះគ្មានប្រព័ន្ធត្រួតពិនិត្យពីថ្នាក់កណ្តាលទេ ដូច្នេះហើយទើបសេវាសាធារណៈនៅថ្នាក់មូលដ្ឋាននៅមានកម្រិត និងមិនត្រូវបានបែងចែកឱ្យបានត្រឹមត្រូវរវាងរដ្ឋបាលកណ្តាលនិងរដ្ឋបាលមូលដ្ឋានឡើយ។ ភាពខ្វះខាតរបស់រដ្ឋបាលកណ្តាលនៅមូលដ្ឋានទំនងជាបានរារាំងដល់ការប្រមូលផ្តុំអំណាចសាធារណៈទាំងអស់មកវិញដើម្បីសម្រេចស្តារនិងកសាងប្រទេសឡើងវិញ[៤៣៩]។ រីឯវិសហមជ្ឈការនៅសម័យនោះក៏មិនពិតប្រាកដដែរ។ អាជ្ញាធរដែនដីខ្វះទាំងធនធានមនុស្សទាំងធនធានហិរញ្ញវត្ថុ។ រហូតដល់ខែកុម្ភៈ ឆ្នាំ២០០២ ដែលជាកាលបរិច្ឆេទនៃការបោះឆ្នោតឃុំសង្កាត់លើកដំបូង កម្ពុជាពុំធ្លាប់មានរដ្ឋបាលវិមជ្ឈការណាជាក់លាក់ឡើយ។ ការណ៍នេះធ្វើឱ្យគេសន្និដ្ឋានថាភាពមជ្ឈការរបស់រដ្ឋបាលនៃប្រទេសនេះគឺមានពិតប្រាកដ។ នៅកម្រិតនយោបាយ របបសង្គមនិយមនៃសាធារណរដ្ឋប្រជាមានិតកម្ពុជាបន្សល់ទុកនូវមរតកដ៏ធ្ងន់ធ្ងរ។ នោះគឺជាការលាយចូលគ្នារវាងរដ្ឋបាលនិងនយោបាយ។

[៤៣៩] នេះគឺជាមូលហេតុនៃការចាប់ផ្តើមការដ្ឋានកំណែទម្រង់រដ្ឋបាលចាប់ពីពាក់កណ្តាលទសវត្សរ៍ឆ្នាំ៩០មក។

សង្គមនិយមកម្ពុជាត្រូវបានគ្រប់គ្រងដោយបក្សតែមួយ។ ការសម្រេចចិត្តសំខាន់បំផុតគឺចេញពីស្ថាប័នរបស់គណបក្ស។ សភានិងរដ្ឋាភិបាលគ្រាន់តែជាស្ថាប័នអនុវត្តសេចក្តីសម្រេចប៉ុណ្ណោះ។ ដូច្នេះការសម្រេចចិត្តខាងនយោបាយ និងរដ្ឋបាលអាចលាយឡំគ្នាយ៉ាងស្រួល។ បច្ចុប្បន្ននេះ ពិភពនយោបាយគឺមានលក្ខណៈខុសប្លែកពីរដ្ឋបាលតែនៅលើក្រដាស។ តាមពិត អំណាចនយោបាយមានទៅលើរដ្ឋបាលជាទូទៅ ទាំងលើការតែងតាំងមន្ត្រីរាជការ ទាំងលើការអនុវត្តច្បាប់។

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ បានកំណត់របបសេដ្ឋកិច្ចរបស់ប្រទេស តែបានរក្សាកេរដំណែលមួយចំនួនពីរបបសង្គមនិយមក្នុងផ្នែកផែនការនិងហិរញ្ញវត្ថុ។ ប្រព័ន្ធផែនការថ្នាក់កណ្តាលត្រូវបានរក្សា តាមគម្រូមួយចំនួននៃរដ្ឋបាលសង្គមនិយមដែលបានគ្រប់គ្រងទាំងស្រុងលើគ្រប់សកម្មភាពសង្គមនិងសេដ្ឋកិច្ច[៤៤០]។ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នៅតែជាប្រព័ន្ធមជ្ឈការដ៏ជ្រាលជ្រៅមួយ។ រដ្ឋធម្មនុញ្ញមិនកំណត់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទេ តែបានប្រគល់ឱ្យច្បាប់ចាត់ចែង។ ទោះជាយ៉ាងណា ការអនុម័តច្បាប់បែបនេះទាមទារពេលវេលានិងការសិក្សា[៤៤១]។ ចំណុចចុងក្រោយគឺការចាត់ចែងសេវាសាធារណៈពីរដ្ឋបាលកណ្តាលទៅ។ ជាលទ្ធផល អាជ្ញាធរមូលដ្ឋាននៅតែបន្តអសមត្ថភាពក្នុងការគ្រប់គ្រងសេដ្ឋកិច្ចរបស់ខ្លួន[៤៤២]។

សេចក្តីសន្និដ្ឋាន

របបសាធារណរដ្ឋប្រជាមានិតកម្ពុជាមិនបន្សល់អ្វីច្រើនទេ។ បរិបទសេដ្ឋកិច្ចនិងនយោបាយពិសេសរបស់កម្ពុជាមិនអនុញ្ញាតឱ្យគំរូម៉ាក្សនិយមអាចឈរជើងនៅក្នុងប្រទេសកម្ពុជាទេ។ នៅឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានក្លាយជារាជាធិបតេយ្យអាស្រ័យរដ្ឋធម្មនុញ្ញម្តងទៀត។ ការបន្តជាមួយរបបមុនត្រូវបានធានាដោយរដ្ឋធម្មនុញ្ញថ្មី ដែលបន្សល់

---

[៤៤០] សម្រាប់ធ្វើផែនការសេដ្ឋកិច្ច ចាំបាច់ត្រូវបង្កើតនាយកដ្ឋានផែនការនិងត្រួតពិនិត្យ និងអង្គភាពប្រតិបត្តិការដែលស្ថិតនៅក្រោមក្រសួង។ អង្គភាពប្រតិបត្តិការដែលឈប់អនុវត្តមុខងារផ្តល់សេវាកម្ម ក៏លែងត្រូវបានគ្រប់គ្រងដូចសហគ្រាសដែរ។ អង្គភាពផែនការដែលនៅសេសសល់ត្រូវបានលុបចោល ហើយខ្លះទៀតត្រូវបានរៀបចំឡើងវិញនិងផ្លាស់ប្តូរទៅជាអង្គភាពស្រាវជ្រាវនិងកម្មវិធីតូចៗ។ ចំពោះសហគ្រាសដែលនៅតែស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួង ភាគច្រើននឹងចូលក្នុងបញ្ជីត្រៀមសម្រាប់ឯកជនភាវូបនីយកម្ម។

[៤៤១] ការអនុវត្តបង្ហាញថាច្បាប់ទាំងនេះទទួលឥទ្ធិពលច្រើនពីប្រព័ន្ធសង្គមនិយមនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា ហើយការកែទម្រង់ដែលបានស្នើឡើងអាចប្រឈមមុខនឹងការជំទាស់ពីមន្ត្រីជំនាញដើងចាស់នៅក្រសួងទៀតផង។

[៤៤២] ឧទាហរណ៍ ទូកដជាច្រើននៅតែបន្តគ្រប់គ្រងដោយរដ្ឋបាលកណ្តាល ពោលគឺក្រសួងសាធារណការនិងដឹកជញ្ជូន ក្នុងពេលដែលប្រតិបត្តិការទាំងនេះអាចត្រូវបានអនុវត្តនៅក្នុងមូលដ្ឋានដោយរដ្ឋបាលខេត្តមានសមត្ថកិច្ច។ ការប្រមូលសំរាមនិងសេវាផ្គត់ផ្គង់ទឹកស្អាតគឺដូចគ្នា សុទ្ធតែជាការទទួលខុសត្រូវរបស់រដ្ឋតាមអាជ្ញាធរដែនដីរបស់ខ្លួន។

ទុកជាធរមាននូវរាល់បទប្បញ្ញត្តិច្បាប់ដែលធានាទ្រព្យសម្បត្តិរដ្ឋ សិទ្ធិ សេរីភាព និងទ្រព្យសម្បត្តិស្របច្បាប់របស់បុគ្គលឯកជន និងដែលស្របនឹងផលប្រយោជន៍ជាតិ។ ប៉ុន្តែកម្ពុជាត្រូវប្រឈមមុខនឹងគម្រោងកែទម្រង់ធំៗ ហើយកំពុងស្វែងរកគំរូមួយដើម្បីដើរតាម។ បន្ទាប់ពីការបោះឆ្នោតខែឧសភា ឆ្នាំ១៩៩៣ របបរាជានិយមត្រូវបានស្ដារឡើងវិញ។ សម្តេចព្រះ នរោត្តម សីហនុ បានឡើងគ្រងរាជ្យសារជាថ្មី។ ឥទ្ធិពលរបស់ព្រះអង្គមកលើប្រជាជនកម្ពុជាហាក់នៅដដែល។ គុណធម៌របស់ព្រះអង្គនៅលើឆាកនយោបាយក៏ដូចគ្នាដែរ។ អ្នកនយោបាយយល់ព្រមចុះចូលជាមួយព្រះអង្គ។ គេនឹកឃើញដល់ពាក្យឃោសនា និងភាពរុងរឿងរបស់សង្គមរាស្ត្រនិយមដែលព្រះអង្គបង្កើតនិងដឹកនាំចាប់ពីពេលទទួលបានឯករាជ្យ រហូតដល់ឆ្នាំ១៩៧០។ ប៉ុន្តែរាជានិយមនេះ មានជីវិតថ្លៃណាស់ ព្រោះត្រូវបានប្រជាជនខ្មែរបង្កើតឡើងវិញ ក្រោយការបង្កាក់ដោយរបប សាធារណរដ្ឋមួយរយៈពេលខ្លី របបផ្តាច់ការរបស់ខ្មែរក្រហម និងវិបត្តិសង្គ្រាមស៊ីវិលប្រមាណដប់ឆ្នាំ។ នេះបង្ហាញពីភាពស៊ីជម្រៅ រចនាសម្ព័ន្ធ និងភាពពេញនិយមនៃស្ថាប័នរាជានិយមសម្រាប់សង្គមខ្មែរ។ វាជាស្រទាប់ខាងក្រោមនៃវប្បធម៌ ហើយគឺជាដែលយើងនឹងព្យាយាមយល់។

២.៣.៣. នីតិរដ្ឋបាលបែបខ្មែរ

បារាំងមកត្រួតត្រាទឹកដីនិងប្រជាជនខ្មែរក្រោមទម្រង់ជាអាណាព្យាបាល និងអាណានិគមនិយម។ ហេតុនេះ ច្បាប់និងវិធានដែលបារាំងដាក់ចេញមិនមែនដើម្បីខ្មែរទេ គឺដើម្បីផលប្រយោជន៍នៃការគ្រប់គ្រងច្រើនជាង។ ហេតុនេះ វាពិបាកនឹងនិយាយឱ្យត្រង់មាត់ថាបារាំងបានរៀបចំនិងបង្កើតច្បាប់ខ្មែរណាស់។ បើនិយាយថាបារាំងបានបង្កើតច្បាប់បារាំងនៅលើនិងសម្រាប់អនុវត្តនៅស្រុកខ្មែរ ប្រហែលសមរម្យនិងអាចទទួលយកបានជាង។ ក្នុងន័យនេះ យើងគួរនិយាយអំពីច្បាប់ខ្មែរ ឬច្បាប់កម្ពុជាតែចាប់ពីថ្ងៃឯករាជ្យឆ្នាំ១៩៥៣ មក ទើបជាការប្រសើរ ព្រោះពីនោះមក វិធាននិងគោលការណ៍ទាំងឡាយ វាបានចេញពិតប្រាកដពីឆន្ទៈខ្មែរអធិបតេយ្យ ដើម្បីគ្រប់គ្រងប្រទេសកម្ពុជា និងបម្រើផលប្រយោជន៍ប្រជាជនខ្មែរ។ ក្នុងចំណោមរបបនយោបាយដែលបានកើតឡើងក្រោយថ្ងៃឯករាជ្យជាតិ ៩ វិច្ឆិកា ១៩៥៣ មក មានតែរបបពីរប៉ុណ្ណោះដែលមានរយៈពេលយូរគ្រប់គ្រាន់ និងដែលអនុញ្ញាតឱ្យយើងស្រង់យកនូវគំរូនីតិរដ្ឋបាលមកធ្វើការសិក្សា គឺនីតិរដ្ឋបាលសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) និងនីតិរដ្ឋបាលសម័យបច្ចុប្បន្ន (១៩៩៣-បច្ចុប្បន្ន)។

២.៣.៣.១. នីតិរដ្ឋបាលសម័យសង្គមរាស្ត្រនិយម

ក្រោយឯករាជ្យ កម្ពុជានៅសល់មរតករបស់អាណានិគមនិយមបារាំងលើទិដ្ឋភាពជា

ច្រើន។ ការច្នៃប្រឌិតរបស់សម្តេចព្រះ នរោត្តម សីហនុ នៅក្នុងការស្ថាបនាសង្គមរាស្ត្រនិយម និងការស្រុះស្រួលជាតិដែលទទួលយកនូវគោលគំនិតរបស់ព្រះអង្គ គឺជាជោគជ័យរបស់របបនេះ។

២.៣.៣.១.១. ការច្នៃប្រឌិតនៃសង្គមរាស្ត្រនិយម

សង្គមរាស្ត្រនិយមប្រើវិធីសាស្ត្របី៖ ការបើកចំហផ្នែកសង្គម; ការពង្រឹងឯកភាពជាតិ; ការអនុវត្តប្រជាធិបតេយ្យនិយមដោយផ្ទាល់។ ការបើកចំហផ្នែកសង្គម គឺការធ្វើសមាហរណកម្មទំនៀមទម្លាប់រាជាធិបតេយ្យរបស់ខ្មែរទៅក្នុងក្របខ័ណ្ឌទំនើបកម្មនៃសង្គមនិយមដែលគេអនុវត្តនៅក្នុងប្រទេសក្រីក្រ។ របបសង្គមរាស្ត្រនិយមបង្កើតដោយព្រះបរមរតនកោដ្ឋ នរោត្តម សីហនុ គឺជាចលនា «សហគមន៍សង្គមនិយម» ដែលត្រូវបានរៀបចំដូចជាសមាគមមួយ។ បុគ្គលម្នាក់ៗ និងមហាជនទូទៅអាចចូលរួមបាន។ មានគណៈកម្មាធិការកណ្តាល មានក្រុមផ្សេងៗ និងមានសមាជ។ ប៉ុន្តែរចនាសម្ព័ន្ធនិងសមាជិកនៃចលនា គឺពិបាកនឹងបែងចែកឱ្យដាច់ពីភ្នាក់ងារនិងរចនាសម្ព័ន្ធរដ្ឋបាលរបស់ប្រទេសណាស់។ អភិបាលរាជធានី ខេត្ត មានតួនាទីនាំមុខនៅក្នុងក្រុមតាមរាជធានី ខេត្ត។ លើសពីនេះ ប្រមុខរដ្ឋគឺជាអ្នកបង្កើតនិងជាអ្នកដឹកនាំចលនា។ ព្រះអង្គទទួលបន្ទុកផ្ទាល់ជាប្រធានគណៈកម្មាធិការកណ្តាល។ នៅក្នុងលក្ខន្តិកៈនៃចលនានេះ មនោគមវិជ្ជាសង្គមនិយមត្រូវបានកំណត់តាមរយៈការបដិសេធប្រព័ន្ធនយោបាយពហុបក្សដែលបង្កការមិនចុះសម្រុងគ្នា។ លក្ខន្តិកៈក៏លើកទឹកចិត្តការតស៊ូមតិដើម្បីឯកភាពជាតិ គំនិតស្នេហាជាតិ ភាពស្មោះត្រង់ចំពោះប្រពៃណីខ្មែរ ឧត្តមគតិសីលធម៌ក្នុងការប្រយុទ្ធប្រឆាំងនឹងភាពអយុត្តិធម៌ អំពើពុករលួយ និងការរំលោភបំពាននានា ហើយនិងធានាការពារប្រជាជន។ សង្គមរាស្ត្រនិយមជាឧបករណ៍គ្រប់គ្រងរដ្ឋបាល និងជាមធ្យោបាយបញ្ចៀសការបង្កើតអង្គការចាត់តាំងនយោបាយដែលនាំឱ្យមហាជនប្រឈមគ្នា។ ចលនានេះរួមចំណែកបង្កើតមនោគមវិជ្ជាជាតិប្រជាជននិយម និងបានធ្វើឱ្យមាន "ការភ្ញាក់រលឹកជាតិ"។

ក. រដ្ឋបាលបែបព្រះពុទ្ធសាសនា

សង្គមរាស្ត្រនិយមមានន័យថា "សង្គមស្រលាញ់ប្រជាជន" ឬ "សង្គមចូលចិត្តប្រជាជន"។ ប៉ុន្តែពាក្យពីរគឺ "សង្គម" និង "និយម" អាចបញ្ចូលគ្នាបង្កើតជាពាក្យ "សង្គម

និយម" ដែលជាទ្រឹស្តីនយោបាយរបស់កាល់ម៉ាក្ស[៤៤៣]។ ចលនាមានគោលបំណងពីរ ទី១ គឺការបង្រួបបង្រួមនៃអ្នកស្នេហាជាតិទាំងអស់និងលុបបំបាត់ការកើនចំនួនឥតប្រយោជន៍នៃគណបក្សនយោបាយ និងទី២ គឺការធ្វើកំណែទម្រង់រដ្ឋធម្មនុញ្ញដើម្បីសង្គ្រោះរបបសភានិយម។ សម្រាប់ព្រះបរមរតនកោដ្ឋ ការបង្កើតនេះមិនត្រឹមតែឆ្លើយតបទៅនឹងភាពចាំបាច់ក្នុងការបញ្ចប់ជម្លោះនិងការប្រជែងគ្នានៃគណបក្សនយោបាយ និងក្រុមតូចៗដោយការប្រមូលផ្តុំគ្នានៅក្នុងចលនាសហព័ន្ធធំមួយនោះទេ ប៉ុន្តែកម្ពុជាត្រូវមានរបស់ខ្លួននូវមនោគមវិជ្ជានយោបាយនិងសង្គមមួយ ដែលអាចរំពឹងបាននៅក្នុងការកសាងខ្លួនទៅជាប្រទេសជាតិទំនើប។ កម្ពុជាមានមូលដ្ឋានប្រពៃណីរឹងមាំពីរគឺ៖ រាជានិយមនិងសាសនាព្រះពុទ្ធ។ សូម្បីតែព្រឹត្តិការណ៍ដែលបានអង្រួនទ្វីបអាស៊ីនៅសម័យក្រោយសង្គ្រាមក៏មិនបានធ្វើឱ្យមូលដ្ឋាននេះរង្គោះរង្គើដែរ។ វាជាមូលដ្ឋាននៃឯកភាពជាតិ ប៉ុន្តែសម្រាប់សម្តេចព្រះបរមរតនកោដ្ឋ កម្ពុជាត្រូវតែមាននូវថាម ពលថ្មីដើម្បីឱ្យប្រទេសនេះឈានទៅផ្លូវនៃទំនើបកម្មបាន។ ក្នុងន័យនេះ សង្គមរាស្ត្រនិយមត្រូវរក្សាប្រព័ន្ធមួយដែលរដ្ឋដឹកនាំសេដ្ឋកិច្ចនិងការពារប្រជាជនពីការកេងប្រវ័ញ្ចកម្លាំងពលកម្មដោយពួកមូលធន ជានានូវសេចក្តីថ្លៃថ្នូរនិងផ្តល់មធ្យោបាយសម្ភារៈដល់ប្រជាជនដើម្បីស្វែងរកសុភមង្គល។ សម្រាប់ព្រះអង្គ សង្គមនិយមនៃសង្គមរាស្ត្រនិយម មិនមែនម៉ាក្សនិយមទេ[៤៤៤]។ វាខុសពីសង្គមនិយមម៉ាក្សនិយមត្រង់ការបដិសេធការប្រមូលផ្តុំមធ្យោបាយផលិត។ បើតាមសម្តេចព្រះ នរោត្តម សីហនុ សង្គមនិយមម៉ាក្សនិយមមិនសមនឹងប្រទេសកម្ពុជាទេ។ ព្រះអង្គពន្យល់ថាកម្ពុជាមិនមានបញ្ហាកសិកម្មដែលតម្រូវឱ្យកែទម្រង់ដីធ្លីនិងសមូហភាពទេ។ ដីធ្លីធំៗនៅទីជនបទមិនមានទេ ហើយដីមានម្ចាស់តូចៗប៉ុណ្ណោះ។ កសិករដែលគ្មានដី ឬដីតូចពេក ឬដីគ្មានជីជាតិ អាចរកដីបានដោយមិនពិបាកពេកទេ។ ចំណុចចុងក្រោយ កម្មករនិយោជិតក្នុងវិស័យឧស្សាហកម្មមិនសូវសំខាន់ទេ។ កម្មករដែលធ្វើការក្នុងរោងចក្ររបស់រដ្ឋមិនស្ថិតនៅក្រោមរបបមូលធននិយមឡើយ។ ការតស៊ូវណ្ណៈរឹតតែមិនដែលកើតឡើងទៀតក្នុងសង្គមខ្មែរ។

---

[៤៤៣] ជាផ្លូវការ ចលនានេះមានឈ្មោះសម្រាយជាភាសាបារាំងថា "Communauté socialiste populaire" ដែលត្រូវបានយល់ថាជាចលនាសង្គមនិយម។

[៤៤៤] ព្រះបាទ នរោត្តម សីហនុ ធ្លាប់ពន្យល់ថា ប្រសិនបើគោលលទ្ធិនយោបាយ ទស្សនវិជ្ជា និងសេដ្ឋកិច្ច បង្កើតឡើងដោយកាលម៉ាក្សអនុវត្តទទួលបានផលចំណេញដល់ប្រជាជាតិខ្លះក្តី លក្ខខណ្ឌដោយឡែកនៃប្រទេសកម្ពុជានឹងធ្វើឱ្យការអនុវត្តលទ្ធិមិនកើត ហើយថែមទាំងមានគ្រោះថ្នាក់ដល់តុល្យភាពនិងអនាគតរបស់វាទៀតផង។ ម្យ៉ាងទៀត អរិយធម៌សីលធម៌ ទំនៀមទំម្លាប់ និងប្រពៃណីខ្មែរប្រឆាំងនឹងទស្សនៈដែលថាលទ្ធិមួយអាចមានតម្លៃលក្ខណៈសកល។

ការប្រឈមគ្នារវាងកម្លាំងផលិតកម្មនិងអង្គការសង្គមដែលផ្អែកលើ "សម្ភារៈនិយមប្រវត្តិសាស្ត្របែបម៉ាក្សនិយម" មិនធ្លាប់មានទាល់តែសោះនៅក្នុងប្រវត្តិសាស្ត្រខ្មែរ។

តាមប្រវត្តិសាស្ត្រ ព្រះមហាក្សត្រខ្មែរគឺជាធ្មាំឬជាអ្នកអភិបាលដីដែលនៅទំនេរ មិនមែនជាម្ចាស់របស់ដីនោះឡើយ។ អញ្ចឹងហើយ បានជាព្រះអង្គអាចផ្តល់កម្មសិទ្ធិពេញលេញដល់ប្រជារាស្ត្ររបស់ព្រះអង្គដែលស្នើសុំ។ ដីនោះជាកម្មសិទ្ធិរបស់ជនណាដែលកាន់កាប់និងធ្វើស្រែចម្ការ ក្រោមការគ្រប់គ្រងរបស់ព្រះមហាក្សត្រដែលជាអ្នកការពារទឹកដី។ អត្ថន័យនៃពាក្យថាទ្រព្យ តាមពិត គឺខុសពីពាក្យប្រើនៅលោកខាងលិច។ នៅស្រុកខ្មែរ ដីធ្លីគឺជារបស់អាទិទេព ស្ថិតនៅក្រោមការការពាររបស់ព្រះមហាក្សត្រ ទុកសម្រាប់ជនណាដែលត្រូវការ[៤៤៥]។ ព្រះមហាក្សត្រខ្មែរមិនត្រឹមតែជាអ្នកសាងសង់ប្រាសាទដ៏អស្ចារ្យប៉ុណ្ណោះទេ តែក៏ជាអ្នកធ្វើកិច្ចការសេដ្ឋកិច្ចនិងសង្គមដ៏អស្ចារ្យផងដែរ។ រាជានិយមសម័យអង្គរដ៏មានអំណាច បានខិតខំសម្រួលដល់ការអភិវឌ្ឍកម្មសិទ្ធិដីធ្លីរបស់កសិករតាមរយៈការងារធារាសាស្ត្រដ៏ធំសម្បើម។

គិតតាមទស្សនៈសីលធម៌និងទស្សនវិជ្ជា ព្រះពុទ្ធសាសនាគឺជាមគ្គុទ្ទេសក៍ដ៏មានតម្លៃក្នុងការបង្កើតសង្គមនិយមរបស់សង្គមរាស្ត្រនិយម ជាមួយនឹងឧត្តមគតិនៃសន្តិភាព ការអត់ឱន និងសេចក្តីមេត្តាករុណាចំពោះសត្វលោកទាំងអស់ផ្សព្វផ្សាយដោយព្រះពុទ្ធជាម្ចាស់។ ក្រោយទទួលបានឯករាជ្យនៅឆ្នាំ១៩៥៣ ព្រះពុទ្ធសាសនាបានចូលរួមចំណែកកសាងសង្គមខ្មែរ។ គោលលទ្ធិរបស់ព្រះពុទ្ធបានបង្រៀនប្រជាជនខ្មែរថា មនុស្សត្រូវពឹងផ្អែកលើកម្លាំងខ្លួនឯង ដើម្បីសម្រេចបាននូវសេចក្តីពិតនិងការរំដោះខ្លួនពីកពក្រៅទាំងអស់។ ព្រះពុទ្ធសាសនាបង្រៀនឱ្យប្រឆាំងនឹងអំពើអាក្រក់និងអយុត្តិធម៌សង្គម។ នៅក្នុងសហគមន៍កម្ពុជាឯទីជនបទ មិនថាជាការងារកសិកម្មខ្នាតធំ ការដកស្ទូងឬច្រូតកាត់ គឺគេសាមគ្គីបង្វាស់គ្នា ជួយគ្នាធ្វើ ឈរលើគោលការណ៍សមភាពនិងយុត្តិធម៌។ ការអនុវត្តនេះជ្រួតជ្រាបដល់កម្មករ កសិកររនៅតាមជនបទនិងទីក្រុង ពិសេសការជួយដល់ជនក្រីក្រ គោកយ៉ាកនិងខ្វះខាតបំផុត ការខ្វល់ខ្វាយពីប្រយោជន៍រួម និងការបដិសេធក្នុងការកេងប្រវ័ញ្ចពីទុក្ខវេទនារបស់អ្នកដទៃ។ នៅពេលនោះ សង្គមជនបទ ហាក់បីដូចជាទម្រង់មូលដ្ឋានដែលបង្កគ្រោះថ្នាក់តិចបំផុតសម្រាប់ប្រជាជនខ្មែរ។ យើងអាចយល់បានយ៉ាងច្បាស់

[៤៤៥] ព្រះអង្គយុគន្ធរបន្ទោសបារាំងថា "*នៅពេលអស់លោកបង្កើតសញ្ញាណកម្មសិទ្ធិ អស់លោកបានបង្កើតឱ្យមានអ្នកក្រ។ អស់លោកបង្ខំឱ្យខ្មែរបង់ប្រាក់ជាថ្នូរនឹងសិទ្ធិប្រើប្រាស់ដីដែលពីមុនច្បាប់របស់ព្រះមហាក្សត្រឱ្យគាត់ប្រើទេ*"!

ថា នេះជាសង្គមនិយមដែលអនុវត្តតាមធម្មជាតិ ហើយដែលស្ថាបនិករបស់វាចង់ពង្រីកឱ្យទៅដល់ទូទាំងប្រទេស។

ខ. រដ្ឋបាលបែបម៉ាក្សនិយម

សង្គមរាស្ត្រនិយមទទួលបានជោគជ័យ ដោយសាររដ្ឋទទួលបន្ទុកលើគម្រោងអភិវឌ្ឍន៍ជនបទសំខាន់ៗនិងការចូលរួមដោយផ្ទាល់ពីប្រជាពលរដ្ឋក្នុងការងារបម្រើផលប្រយោជន៍ទូទៅ។ គេថាអ្វីដែលរបបនេះរៀបចំគឺទទួលឥទ្ធិពលពីលទ្ធិម៉ាក្សនិយម ក៏ប៉ុន្តែមានការច្នៃប្រឌិតឱ្យមានលក្ខណៈខ្មែរ និងគ្មានការបង្ខិតបង្ខំ។ តួយ៉ាង ការងារសមូហភាពគឺធ្វើដោយការស្ម័គ្រចិត្តរបស់ប្រជាជន។ ប៉ុន្តែរដ្ឋមានផែនការច្បាស់លាស់និងកំណត់ខ្លួនឯងនូវការកិច្ចក្នុងការជួយប្រជាជននៅតាមជនបទ ក្នុងនោះមានការកែលម្អនិងទំនើបភាវូបនីយកម្មនៃកសិកម្ម ការជួលឧបករណ៍កសិកម្មដល់អ្នកភូមិដែលខ្វះខាត ការផ្តល់អំណោយ ដូចជាម៉ាស៊ីនបូមទឹក ត្រាក់ទ័រ និងសត្វយកទឹកដោះ ដល់សហគមន៍ខ្វះខាត ការបង្កើតរោងម៉ាស៊ីនកិនស្រូវ។ សង្គមនិយមបែបកសិកម្ម ត្រូវអនុវត្តយ៉ាងសកម្មចំពោះមធ្យោបាយផលិតនិងទីផ្សារកសិកម្ម តាមរយៈការរៀបចំសហករណ៍ផលិតកម្មនិងឥណទាន ក្រោមរូបមន្ត "ពាក់កណ្តាលសង្គមនិយម" ព្រោះថាក្រោយឯករាជភ្លាមៗ ពួកអភិជនខ្មែរគ្មានមធ្យោបាយផលិតឬដើមទុនគ្រប់គ្រាន់ដើម្បីទទួលបានដីធ្លីឬឧស្សាហកម្មធំៗនោះទេ។

នៅក្នុងវិស័យឧស្សាហកម្មវិញ សង្គមរាស្ត្រនិយមប្រើគោលការណ៍បីយ៉ាងគឺ៖ ទី ១ ប្រគល់ឱ្យរដ្ឋនូវវិស័យសំខាន់ៗនៃសេដ្ឋកិច្ចជាតិ ឬយ៉ាងហោចណាស់ក្រុមហ៊ុនដែលខ្លួនមានលទ្ធភាពគ្រប់គ្រងក្នុងវិស័យទាំងនេះ ទី២ មិនអនុញ្ញាតឱ្យបង្កើតភាពផ្តាច់មុខតែមិនហាមឃាត់គំនិតផ្តួចផ្តើមឯកជន និងទី៣ លើកទឹកចិត្តឱ្យមានការវិនិយោគបរទេសមួយចំនួននៅក្នុងក្របខ័ណ្ឌនៃក្រុមហ៊ុនដែលរដ្ឋកាន់កាប់ភាគហ៊ុនភាគច្រើន។ សរុបមក សង្គមនិយមខ្មែរក្នុងវិស័យឧស្សាហកម្ម បានអាចនាំឱ្យឧស្សាហកម្មរដ្ឋរីកចម្រើនយ៉ាងឆាប់រហ័ស ហើយបង្កើតឱ្យមានឧស្សាហកម្មពាក់កណ្តាលសាធារណៈ ពាក់កណ្តាលឯកជន (ឬសហគ្រាសចម្រុះ) ដែលអភិវឌ្ឍក្នុងស្ថានភាពល្អ។

បន្ថែមទៅលើនេះ ចលនាជាតិសំខាន់ៗក៏បានចាប់កំណើត ដូចជា ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធជាតិនិងការអភិវឌ្ឍសហករណ៍ ការបង្កើតគណៈកម្មាធិការឃុំ ស្រុក និងខណ្ឌ ដែលដឹកនាំនិងដឹកនាំកម្មវិធីអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមសំខាន់ៗ ការអនុវត្ត

ការអនុវត្តគោលនយោបាយទឹក[៤៤៦] ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្តនិងឧស្សាហកម្ម កម្មវិធីអភិវឌ្ឍន៍លំនៅឋានជនបទ ការផ្តល់អត្ថប្រយោជន៍ពីជំនួយផ្នែកយុត្តិធម៌ ពីសេវារដ្ឋបាល និងបច្ចេកទេសរបស់រដ្ឋបាល ការផ្តល់ទាំងសម្ភារៈអនាម័យដូចជា មន្ទីរពេទ្យ អណ្តូងអនាម័យ និងសម្ភារៈសង្គម ដូចជាមណ្ឌលព័ត៌មាន ឬកន្លែងកីឡាក្នុងភូមិ និងយុទ្ធនាការលុបបំបាត់អនក្ខរកម្មទាំងស្រុង ដែលជាទិដ្ឋភាពពិសេសមួយនៃប្រពៃណីព្រះពុទ្ធសាសនានៃការជួយគ្នាទៅវិញទៅមក។

យុទ្ធនាការធ្វើការងារសមូហភាពជានិមិត្តរូបខាងលើ សង្ខេបមកគឺជាយុទ្ធនាការធ្វើហត្ថពលកម្មដោយស្ម័គ្រចិត្ត ដែលតាមរយៈនេះ ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ចង់បើកទំព័រ "កម្ពុជាជួយខ្លួនឯង" និងបង្ហាញថាគ្មានអ្វីដែលមិនអាចទៅរួចសម្រាប់ប្រជាជនដែលធ្វើការដោយបេះដូងតែមួយដើម្បីកសាងប្រទេសនោះទេ។ យុទ្ធនាការនេះក៏ជាប្រតិកម្មប្រឆាំងនឹងទស្សនៈ "មន្ត្រីនិយម" ដែលកំពុងមានជាទូទៅក្នុងទ្វីបអាស៊ីទាំងអស់នៅសម័យកាលនោះ ហើយដែលនៅក្នុងទម្រង់ទំនើបរបស់វា គេហៅថា "ការិយាធិបតេយ្យ" ។ ចំពោះមន្ត្រីដែលស្អប់ខ្ពើមការងារហត្ថកម្ម "មន្ត្រីនិយម" នេះ កាន់តែធ្ងន់ធ្ងរសម្រាប់ប្រជារាស្ត្រតូចតាច។ ពីពេលនោះមក តាមរយៈការប្រមូលផ្តុំឥស្សរជនស៊ីវិលនិងយោធាជាន់ខ្ពស់ នៅក្នុងទីលានធំៗ ទាំងសិស្ស ទាំងកសិករ ទាំងទាហាន សម្តេចព្រះ នរោត្តម សីហនុ ទ្រង់ចង់រំលាយគ្រប់ស្រទាប់សង្គមរបស់ប្រទេសជាតិឱ្យរលាយចូលគ្នាតែមួយ។

សង្គមរាស្ត្រនិយមរបស់ សម្តេចព្រះ នរោត្តម សីហនុ បានផ្តល់អាទិភាពលើវិស័យកសិកម្ម។ ប៉ុន្តែផ្លូវដែលសង្គមរាស្ត្រនិយមធ្វើគឺមិនធម្មតាទេ។ កម្ពុជានាពេលនោះ គ្មាននរណាម្នាក់ស្រមៃអំពីទម្រង់នៃសមូហភាពឡើយ។ សម្តេចព្រះ នរោត្តម សីហនុ បានធ្វើឱ្យប្រជាជនជឿថា រដ្ឋាភិបាលរបស់ទ្រង់កំពុងទទួលយកដំណោះស្រាយមួយស្របតាមប្រពៃណីព្រះពុទ្ធសាសនា គឺការគោរពកម្មសិទ្ធិឯកជន និងអនុញ្ញាតឱ្យមានសេរីភាពឡើងវិញក្នុងការច្នៃប្រឌិតនិងគំនិតផ្តួចផ្តើមឯកជនក្នុងផលិតកម្ម។ រដ្ឋាភិបាលមិនលើកទឹកចិត្តការដាក់បញ្ចាំដីរបស់កសិករ ប៉ុន្តែផ្ទុយទៅវិញបានអប់រំពួកគាត់តាមរយៈការបង្កើតសហករណ៍ដើម្បីការពារពួកគេប្រឆាំងនឹងឈ្មួញកេងប្រវ័ញ្ច។ មហិច្ឆិតាដ៏អស្ចារ្យមួយនៃគោលនយោបាយ "សង្គមនិយម" នេះគឺដើម្បីរំដោះកសិករកម្ពុជាចេញពី "អាណាព្យាបាលឈ្លួយ"។ ដោយសារគោលការណ៍នេះ កសិករមិនត្រឹមតែមានសេរីភាពក្នុង "ការ

[៤៤៦] កម្មវិធីនេះបានភ្ជាប់ឡើងវិញជាមួយអតីតកាលសម័យអង្គរនិងទំនៀមទម្លាប់ដែលមានអាយុកាលពីរពាន់ឆ្នាំកន្លងមក និងដែលធ្វើឱ្យប្រជាជនខ្មែរក្លាយជា "អ្នកស្រោចស្រពដី" ដ៏អស្ចារ្យបំផុតក្នុងប្រវត្តិសាស្ត្រ។

ភ្ជួរដីដោយខ្លួនឯងតាមចិត្តចង់" "ជាំដំណាំដែលខ្លួនចូលចិត្ត" និងចុងក្រោយ "លក់ផលិតផលដោយសេរី" ប៉ុណ្ណោះទេ ថែមទាំងអាចប្រើប្រាស់សេវាកម្មរបស់អ្នកបច្ចេកទេស ឬភ្នាក់ងាររដ្ឋបាលដែលរដ្ឋបង្កើតឡើង ដើម្បីបង្កើនផលិតភាពដីរបស់ពួកគេទៀតផង។

ដើម្បីសម្រេចបាននូវគោលបំណងនៃនយោបាយរបស់ខ្លួន សង្គមរាស្ត្រនិយមបង្កើតសហករណ៍ដើម្បីជួយកសិករ។ មុនឯករាជ្យ កម្ពុជាមានតែសហករណ៍នេសាទ។ នៅឆ្នាំ១៩៥៤ សហករណ៍ស្រូវដំបូងត្រូវបានបង្កើតឡើងដោយវិស័យឯកជន។ ពួកគេបានទិញស្រូវពីកសិករ ប៉ុន្តែប្រជាជនដែលជួបការលំបាកខ្វះទុន មិនត្រូវបានអនុញ្ញាតឱ្យចូលជាមួយគេទេ។ សហករណ៍ទាំងនោះត្រូវបានគ្រប់គ្រងដោយពួកឈ្មួញ ដែលមានគោលបំណងតែមួយគត់គឺការស្វែងរកប្រាក់ចំណេញ។ ឈ្មួញក៏ជាអ្នកកំណត់តម្លៃស្រូវដែរ។ ក្រោយការបង្កើតសង្គមរាស្ត្រនិយម ការកែទម្រង់សេដ្ឋកិច្ចត្រូវបានចាប់ផ្តើម។ នៅឆ្នាំ ១៩៥៥ ក្រសួងកសិកម្មបានបង្កើតធនាគារកសិកម្ម។ ក្នុងឆ្នាំដដែលនោះ មានការគិតគូរអំពីការបង្កើតសហករណ៍។ កសិករភាគច្រើនចិញ្ចឹមជីវិតពីកសិផលបន្តិចបន្តួច ដោយសារផលិតផលទាំងនេះមានតម្លៃទាបពេក។ កសិករជាច្រើនបានខ្ចីបុលពីឈ្មួញចិនដើម្បីបន្តែមការចំណាយប្រចាំថ្ងៃ។ ឈ្មួញបានបង្ខំពួកគាត់ឱ្យលក់ដំណាំគាត់ បើមិនដូច្នេះទេពួកគាត់នឹងមិនទទួលមានកម្ចីឡើ[៤៤៧]។ ជោគជ័យនៃសហករណ៍អាស្រ័យទាំងស្រុងលើភាពស្មោះត្រង់របស់អ្នកគ្រប់គ្រងវា ដូចពាក្យចាស់ថា "បើមនុស្សល្អ ស្ថាប័នក៏ល្អដែរ" ។ សហករណ៍ជាច្រើនត្រូវបានឈ្មួញទុច្ចរិតបង្ក្រៀតខ្លួនចូល។ អ្នកដឹកនាំសហករណ៍ជាច្រើនបានទាញយកអត្ថប្រយោជន៍ពីភាពទន់ខ្សោយរបស់សហករណ៍។ នៅចុងទសវត្សរ៍ឆ្នាំ១៩៥០ មានអត្ថប្រយោជន៍ជាច្រើនពីសមាជិកសហករណ៍។ នៅឆ្នាំ១៩៦៧-១៩៦៨ រដ្ឋបានសម្រេចចិត្តបិទសហករណ៍អ្នកប្រើប្រាស់ជាច្រើន ដោយសារវាមិនបានបំពេញកាតព្វកិច្ចរបស់ពួកគេក្នុងការទូទាត់សងរដ្ឋវិញ។ រដ្ឋបានបាត់បង់ប្រាក់ច្រើនក្នុងកិច្ចការនេះបាន និងបានសម្រេចចិត្តច្របាច់បញ្ចូលសហករណ៍មួយចំនួន ដើម្បីកាត់បន្ថយការចំណាយបុគ្គលិក។

សរុបមក សង្គមរាស្ត្រនិយមពិតជាបាននាំយកគំរូមួយនៃការអភិវឌ្ឍសង្គមសម្រាប់កម្ពុជា។ របបនេះពិតជាបានធ្វើឱ្យកសិករនៅទីជនបទទទួលយក។ នៅតាមទី

---

[៤៤៧] ការប្រាក់អាចខ្ពស់រហូតដល់២០%។ OROC គឺជាការិយាល័យឥណទានដំបូងគេបំផុតតាមរយៈ "សហករណ៍ខេត្ត" របស់ខ្លួនដែលមានបំណងជំនួស "មូលនិធិឥណទានកសិកម្មឥណ្ឌូចិន" ចាស់។ តាមរយៈផ្នែក "ឥណទានអ្នកប្រើប្រាស់" របស់វា វាគ្រប់គ្រងហាងទំនិញនៅក្នុងសហករណ៍រដ្ឋ។

ក្រុងនានា ការរីកចម្រើនផ្នែកសេដ្ឋកិច្ចនិងជំនួយបរទេសពីគ្រប់ទិសទី មិនត្រឹមតែផ្តល់ផលប្រយោជន៍ដល់ក្រុមគ្រួសារដែលមានជីវភាពធូរធារប៉ុណ្ណោះទេ តែប្រជាកសិករភាគច្រើនជាទូទៅ បានជួបប្រទះនូវដំណាក់កាលដ៏រីករាយមួយ[៤៤៨]។ បរិយាកាសដ៏ប្រសើរនេះ ធ្វើឱ្យទំនាក់ទំនងរវាងរដ្ឋបាលនិងប្រជារាស្ត្រ ត្រូវបានថែរក្សាបានល្អក្នុងផ្លូវវិជ្ជាមានមួយរយៈពេលរហូតដល់ប្រទេសធ្លាក់ចូលទៅក្នុងសង្គ្រាម។

២.៣.៣.១.២. ការស្រុះស្រួលជាតិ

ក្រោយឯករាជ្យ ជាតិនិយមរបស់ សម្តេចព្រះ នរោត្តម សីហនុ បានលេចរូបរាងយ៉ាងឆាប់រហ័ស។ វាបង្កើតបានជាស្ពានមួយដែលអាចតភ្ជាប់ខ្មែរម្នាក់ទៅប្រទេសជាតិ។ បើគ្មានស្ពាននេះទេ គោលគំនិតនៃជាតិខ្មែរមិនបានស្ថិតស្ថេរដល់សព្វថ្ងៃនេះ និងគ្រាន់តែជាការស្រមើស្រមៃអរូបីប៉ុណ្ណោះ។ សម្តេចព្រះ នរោត្តម សីហនុ គឺជាស្ថាបត្យករតែមួយគត់នៃលទ្ធិជាតិនិយមនេះ និងជាអ្នកផ្សព្វផ្សាយគោលគំនិតនេះតែម្នាក់អង្គឯង។ សង្គមព្រះពុទ្ធសាសនានិងសមិទ្ធផលជាក់ស្តែងរបស់សង្គមរាស្ត្រនិយម គឺស្ថិតនៅលើផ្លូវឆ្ពោះទៅរកការកសាងជាតិ។ ចលនានៃការបង្រួបបង្រួមនេះគឺទទួលបានពីការសម្រុះសម្រួលមួយ ដែលជាលទ្ធផលនៃកត្តាពីរយ៉ាង៖ កត្តាមេដឹកនាំ និងកត្តារាស្ត្រប្រជា។

ក. កត្តាមេដឹកនាំ

ឯកភាពជាតិគឺជាមូលដ្ឋានដោគជ័យនៃគ្រប់ប្រព័ន្ធដឹកនាំទាំងអស់។ សម្រាប់សង្គមរាស្ត្រនិយម វាជាផ្នែកមួយនៃដួងព្រលឹងរបស់រាជធិបតេយ្យ។ ឯកភាពជាតិនេះបានធ្វើឱ្យមនុស្សទាំងអស់មកប្រមូលផ្តុំជុំវិញសម្តេចព្រះ នរោត្តម សីហនុ។ នៅកម្ពុជាមានភាសិតមួយថា "សាមគ្គីភាពគឺជាកម្លាំង" ឬថា "ចង្កឹះមួយបាច់កាច់មិនបាក់"។ សង្គមរាស្ត្រនិយមត្រូវបានកសាងឡើងផ្អែកលើភាសិតនេះ។ សម្តេចព្រះ នរោត្តម សីហនុ ពន្យល់ថាគម្រោងនៃការកែទម្រង់របស់ព្រះអង្គ គឺឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាជន ដែលបានបង្ហាញនៅក្នុងញត្តិជាច្រើនដែលត្រូវបានផ្ញើទៅថ្វាយព្រះមហាក្សត្រ។ ព្រះអង្គអះអាងថាគឺការបំបែកនិងការបង្កើនចំនួនគណបក្សនយោបាយ ដែលគម្រាមកំហែងដល់ឯកភាពជាតិ។ ក្រៅពីនោះ ការចំណាយខ្ពស់សម្រាប់បេក្ខជនក្នុងការបោះ

[៤៤៨] ជម្រើសនៃគំរូសង្គមបែបសង្គមរាស្ត្រនិយមដូច្នេះ មិនមែនជាមូលហេតុនៃការដួលរលំរបស់ព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ឡើយ។ ប៉ុន្តែសំណួរដែលគួរសួរថាគឺហេតុអ្វីបានជាព្រះមហាក្សត្រដែលទើបមានព្រះជន្មនៅក្មេងនៅឡើយ ទទួលបានដោគជ័យក្នុងការដាក់ឱ្យប្រើនូវ "គំរូ" របស់ព្រះអង្គជាមួយប្រជារាស្ត្រខ្មែរខ្លាំងម្ល៉េះ?

ឆ្នោត ដែលបង្ខំចិត្តពួកគេបណ្តោយខ្លួនឱ្យធ្លាក់ក្នុងឥទ្ធិពលមិនល្អ និងហ៊ានប្រើមធ្យោបាយផ្តេសផ្តាស់ដើម្បីរំដោះខ្លួនពីបំណុល។ ចំនុចមួយទៀត ប្រជាជនចោទថាអ្នកតំណាងរបស់ខ្លួន ការពារតែប្រយោជន៍របស់គណបក្សខ្លួន ហើយគោរពតែបញ្ជាថ្នាក់ដឹកនាំអង្គការចាត់តាំងនយោបាយរបស់ខ្លួន។ ប្រជាជនអ៊ូទាំនឹងការមាក់ងាយពីតំណាងរាស្ត្រ ដែលមិនដែលមកជួបពួកគាត់ មិនស្គាល់អំពីទុក្ខលំបាក ឬតម្រូវការរបស់ពួកគាត់។

ប្រជាជនទាមទារមិនឱ្យព្រះមហាក្សត្រប្រគល់រដ្ឋាភិបាលទៅឱ្យគណបក្សនយោបាយទេ ព្រោះពួកគេទុកចិត្តតែលើព្រះមហាក្សត្រតែមួយអង្គគត់ ដែលតំណាងឱ្យពួកគេ។ ការបង្រួបបង្រួមជាតិជាគន្លឹះគោលនៃរបបសីហនុនិយមទាំងមូល ហើយវាជាឆ្អឹងខ្នងនៃរាជាធិបតេយ្យដែលការពារបុគ្គលគ្រប់រូប។ អ្នកស្រាវជ្រាវខ្លះយល់ថា អ្វីដែលសម្តេចព្រះ នរោត្តម សីហនុ ធ្វើមិនដូចបទពិសោធន៍ប្រវត្តិសាស្ត្របរទេសផ្សេងទៀតដែលមិនមានមូលដ្ឋានគ្រឹះរាជានិយមប្រភេទនេះទេ។ ការបង្រួបបង្រួមជាតិរបស់ខ្មែរ មិនមែនជាឧបាយកលនយោបាយឬជាអាថ៌កំបាំងអ្វីទេ ប៉ុន្តែវាដូចជាប្រព័ន្ធជំនឿសីហនុនិយមមួយ ដែលអ្នកវិភាគខ្លះមិនទាន់អាចយល់កើត។ វាមិនមែនជាឧបករណ៍សម្រាប់លុបបំបាត់គណបក្សប្រឆាំង ហើយក៏មិនមែនសម្រាប់បំបែកឯកភាពជាតិនោះដែរ។ ប្រព័ន្ធនេះមិនអនុញ្ញាតឱ្យទំនោរនយោបាយ ចរន្តគំនិត មនោគមវិជ្ជា ឬបក្ខណាមួយ ត្រូវបានដកចេញជាដាច់ខាតពីសហគមន៍ជាតិនិងពីការសន្ទនានយោបាយឡើយ។

ការប្រឆាំងចំពោះគោលនយោបាយរបស់សម្តេចឪ និងឧបករណ៍សម្រាប់អនុវត្តសង្គមរាស្ត្រនិយម មិនមែនអត់នោះទេ។ គណបក្សប្រឆាំងបានកំណត់យកលទ្ធិប្រជាធិបតេយ្យផ្ទាល់នៃសង្គមរាស្ត្រនិយម មកធ្វើជាគោលដៅប្រឆាំង ទាំងក្នុងទិដ្ឋភាពនយោបាយការបរទេស ទិដ្ឋភាពគោលនយោបាយក្នុងស្រុក។ នៅក្នុងស្រុកមាននិន្នាការប្រឆាំងចំនួនបី។ ទីមួយ មាននិន្នាការប្រជាធិបតេយ្យអព្យាក្រឹត ដែលមិនសូវសកម្ម និងមិនមានឥទ្ធិពលផ្ទាល់ក្រៅពីស្តាប់នសេវាស៊ីវិលមួយចំនួន[៤៤៩]។ និន្នាការទីពីរគឺប្រឆាំងនឹងអព្យាក្រឹតនិយម ដែលច្រើនមានឥទ្ធិពលនៅក្នុងជួរកងទ័ព ទោះបីជាវាហាក់ដូចជានៅមានកម្រិតនៅក្នុងទសវត្សរ៍ឆ្នាំ១៩៦០។ ទីបី គឺចរន្តម៉ាក្សនិយម ដែលសប្បាយចិត្តនឹងនយោបាយការបរទេសរបស់សម្តេចឪ ប៉ុន្តែចង់ឱ្យធ្វើសង្គមនិយមផ្ទៃក្នុងកាន់តែសកម្ម[៤៥០]។

---

[៤៤៩] សមាជិកសង្គមរាស្ត្រនិយមដែលជាមន្ត្រីរាជការតែងគោរព "ភាពស្របច្បាប់" របស់ខ្លួន ហើយមតិដែលខ្លួនបញ្ចេញត្រូវចាត់ទុកថាជាគំនិតផ្ទាល់ខ្លួន។

[៤៥០] ជាទូទៅចរន្តនេះ បដិសេធមិនបញ្ចេញដំហរប្រឆាំងរាជានិយមទេ។

ក្រោមឥទ្ធិពលនៃព្រហ្មញ្ញសាសនា យើងដឹងថា "រាល់អង្គការចាត់តាំងនយោបាយ និងសង្គមនៃរបបរាជានិយមនាសម័យអង្គរគឺអាស្រ័យលើព្រះរាជា។ រដ្ឋាភិបាល រដ្ឋបាល និងសង្គមទាំងមូល ត្រូវរៀបចំឡើងនៅជុំវិញនិងក្រោមការដឹកនាំរបស់ព្រះអង្គ។ អង្គការចាត់តាំងនេះ ត្រូវបានរៀបចំស្របតាមបរិបទប្រទេសខ្មែរ ប៉ុន្តែវានៅតែរក្សាឥទ្ធិពលឥណ្ឌាខ្លះៗ។ នៅក្រោមឥទ្ធិពលនៃព្រះពុទ្ធសាសនា ព្រះមហាក្សត្រគឺជាអ្នកបម្រើនៃសណ្តាប់ធ្នាប់ចក្រវាលផង និងជាអ្នកគ្រប់គ្រងសណ្តាប់ធ្នាប់របស់មនុស្សលោកផង។ ព្រះមហាក្សត្រដែលកាន់ព្រះពុទ្ធសាសនា ទទួលអាណត្តិឱ្យមកផ្សព្វផ្សាយការប្រៀនប្រដៅរបស់ព្រះពុទ្ធ។ ព្រះមហាក្សត្របង្ហាញខ្លួនជាព្រះពុទ្ធដ៏មានឫទ្ធានុភាព ហើយស្តែងជារូបរាងនៅលើផែនដីជាព្រះពុទ្ធដ៏វិសេសវិសាលនិងអរូបី។ នៅគ្រប់កាលៈទេសៈ ព្រះមហាក្សត្រខ្មែរត្រូវបានរាស្ត្ររបស់ព្រះអង្គគោរពបូជាជាទូទៅ។ ការគោរពនេះមានលក្ខណៈពេញលេញតែក្នុងករណីមានការស្រុះស្រួលគ្នាក្នុងចំណោមប្រជាជនប៉ុណ្ណោះ។

ខ. កត្តារាស្ត្រប្រជា

ការកសាងគំរូសម្រុះសម្រួលមួយអាចធ្វើទៅកើត លុះត្រាតែរាស្ត្រប្រជា "ចុះចូល" ជាមួយគំរូនោះ។ សម្តេច ព្រះនរោត្តម សីហនុ ទទួលបានជោគជ័យក្នុងការធ្វើឱ្យមានការចុះចូលនេះ។ ពាក្យ "ចុះចូល" នៅអាស៊ី មិនមានសំនៀងដូចនៅលោកខាងលិចទេ ហើយថែមទាំងផ្ទុយគ្នាទៀតផង។ វាមិនតំណាងឱ្យភាពអាម៉ាស់ជានិច្ចកាលនោះទេ តែផ្ទុយមកវិញវាជាអាកប្បកិរិយាសមហេតុផល។ គោលដៅចុងក្រោយនៃជីវិតក្នុងភាពវេទនានៅអាស៊ីគឺធ្វើយ៉ាងណាឱ្យតែបានរស់រានមានជីវិត។ សម្រាប់មនុស្សដែលកើតមកក្នុងភាពក្រីក្រ គេត្រូវតែមេម្នាក់ដើម្បីជានាសន្តិសុខរបស់ខ្លួន។ ការចុះចូលនិងការបម្រើមេវាជាថ្នូរនឹងការផ្តល់ទីជម្រក អាហារ និងជាពិសេសការការពារ។ ចុះចូលនឹងអ្នកខ្លាំងជាង គឺជាអាកប្បកិរិយាល្អក្នុងសង្គមនិងជាទង្វើសមហេតុផល។ ការប្រឆាំងមិនចុះចូលគឺអាចមានគ្រោះថ្នាក់ដល់ជីវិត[៤៥១]។

---

[៤៥១] គេអាចប្រៀបធៀបសង្គមជាប្រពៃណីអាស៊ី ទៅនឹងថ្នាក់រៀនមួយដែលមានគ្រូបង្រៀនម្នាក់ចាំជាក់ពិន្ទុល្អៗដល់សិស្សដែលប្រព្រឹត្តត្រឹមត្រូវនិងចេះស្តាប់បង្គាប់។ នៅក្នុងសង្គមអាស៊ី មនុស្សម្នាក់មិនអាចទៅតែឯងបានទេ។ ការបែកចេញពីហ្វូងគឺស្មើនឹងភាពក្រអឺតក្រទម។ អ្នកមិនចុះចូលនឹងគេគឺជាសត្វខ្លាដែលជាសត្វសាហាវនិងមិនចូលសង្គម។ ទោះយ៉ាងណាក៏ដោយ ម្នាក់ៗគ្មានសំណាងនឹងចុះចូលអ្នកណាក៏បានតាមខ្លួនចង់នោះទេ។ ម្នាក់ៗចង់ចុះចូលជាមួយគេតែត្រូវរកមនុស្សដែលទទួលយកការចុះចូលនោះ ក្រោយពីបានកត់សម្គាល់ពីគុណសម្បត្តិរបស់គេ។ ទោះយ៉ាងណាក៏ដោយ ការចុះចូលត្រូវបានគណនាយ៉ាងមត់ចត់ អ្នកទទួលមិនចេះតែទទួល ហើយការទទួលក៏មិនអមតៈដែរ។ មេឬចៅហ្វាយត្រូវតែបង្ហាញជានិច្ចថាខ្លួនរឹងមាំ និងអាចផ្តល់ការការពារបានជានិច្ចកាល។

គោលគំនិតសង្គមរាស្ត្រនិយម នៅខុសឆ្ងាយពីលទ្ធិម៉ាក្សនិយម និងលោកខាងលិចដែលបានបង្កើតលទ្ធិនេះ។ វាជារឿងពិតដែលនិយាយថានៅអាស៊ី៖ អាស៊ីនៅតែជាអាស៊ី។ តម្លៃនៃការចុះចូលតែងតែឈ្នះលើការបះបោរ។ ការចុះចូល ឬការចុះចាញ់ ត្រូវបានលើកទឹកចិត្តប្រសិនបើអាកប្បកិរិយានេះគឺជាដំណោះស្រាយត្រឹមត្រូវ។ មនុស្សម្នាក់នឹងមិនតស៊ូដើម្បីកិត្តិយសនៃអាវុធទេ លើកលែងតែករណីសត្រូវមិនទទួលយកការចុះចូល ហើយមិនទុកជម្រើសផ្សេងទៀតទេ។ សុភាសិតដ៏ល្បីល្បាញមួយនៅតែត្រូវបានគេនិយាយជាញឹកញាប់នៅក្នុងសង្គមខ្មែរថា "ងើយស្តុក ឱនដាក់គ្រាប់" ដូនតាខ្មែរបានប្រៀបធៀបមនុស្សទៅនឹងដើមស្រូវ។ បើគ្មានគ្រាប់ទេ ដើមស្រូវនឹងឈរត្រង់ ព្រោះវាស្រាល។ ការដែលវាទន់ហើយកោង បាននំយថាវាពេញដោយគ្រាប់ ដូច្នេះហើយទើបមានផល។ យុវជនត្រូវបានគេបង្រៀនឱ្យចេះពត់ខ្លួន មិនក្រអឺតក្រទម និងចេះគោរពឱនលំទោន។ គេអប់រំមនុស្សឱ្យនៅស្ងៀម ជាជាងតវ៉ានិងឡាំប៉ា។

អំឡុងពេលសង្គមរាស្ត្រនិយម កម្ពុជាមានចំនួនមេដឹកនាំតិច មានកងទ័ពខ្សោយ និងកម្មាភិបាលពីរបីនាក់ ប៉ុន្តែអាចប្រើប្រាស់អំណាចរបស់ពួកគេយ៉ាងរឹងមាំ និងទាន់ពេលវេលាទៅលើប្រជាជនទាំងមូល។ មូលហេតុប្រហែលនៅក្នុងលទ្ធិព្រះពុទ្ធសាសនា។ ហេតុផលនៃការណ៍នេះគឺនៅក្នុងរចនាសម្ព័ន្ធប្រពៃណីនៃសង្គមខ្មែរ និងឋានៈឯកសិទ្ធិរបស់ព្រះមហាក្សត្រនៅក្នុងសង្គមនេះតែម្តង។ ប្រហែលជាការគ្មានរចនាសម្ព័ន្ធទ្រនាប់រវាងប្រជាជនជាកសិករនិងអាជ្ញាធរកំពូលបំផុត បានបើកឱកាសឱ្យអំណាចផ្តាច់ការដំណើរបានយ៉ាងស្រួល។ នៅក្នុងគោលគំនិតជាប្រពៃណី ព្រះមហាក្សត្រគឺជាអ្នកធានានូវភាពសុខដុមរមនារវាងធាតុទាំងអស់នៃលោក ពោល គឺព្រះអង្គដែលមានអំណាចនិងកាតព្វកិច្ចសោយរាជ្យ ជាអ្នករៀបចំលំហនិងជាម្ចាស់ទឹកដី។

២.៣.៣.២. នីតិរដ្ឋបាលសម័យបច្ចុប្បន្ន

ពីឆ្នាំ១៩៩៣ មក កម្ពុជាបានដើរមកដល់ដំណាក់កាលនៃការបង្រួបបង្រួមជាតិតាមរយៈបទឈប់បាញ់និងការបោះឆ្នោតសាកលលើកដំបូងក្រោមការរៀបចំរបស់អង្គការសហប្រជាជាតិ។ ទោះជាការបោះឆ្នោតនេះមិនបានបញ្ចប់សង្គ្រាមរវាងខ្មែរនិងខ្មែរជាស្ថាពរក្តី ក៏ខ្មែរបានសម្រេចឈានទៅការបញ្ចប់សង្គ្រាមស៊ីវិលដ៏ពុំរ៉ៃនៅចុងឆ្នាំ១៩៩៨ ដោយខ្លួនឯងក្រោមនយោបាយ ឈ្នះ ឈ្នះ របស់សម្តេចតេជោ ហ៊ុន សែន។ សន្តិភាពនិងស្ថិរភាពនយោបាយបានធ្វើឱ្យប្រទេសជាតិមានការអភិវឌ្ឍ ហើយរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ មានអត្ថិភាពយូរជាងគេក្នុងចំណោមរដ្ឋធម្មនុញ្ញខ្មែរដែលធ្លាប់មានទាំងអស់។ ជាមួយនឹង

ការដ្ឋានកែទម្រង់រដ្ឋជាច្រើន ការកែទម្រង់រដ្ឋបាលបានចូលរួមអភិវឌ្ឍរបបគ្រប់គ្រងរដ្ឋបាលមួយបានប្រសើរជាងមុខ ទាំងស្មារតី ទាំងសម្ភារៈ និងទាំងរចនាសម្ព័ន្ធគួរឱ្យកត់សម្គាល់។

តែទោះជាយ៉ាងណា នីតិរដ្ឋបាលកម្ពុជាបានទទួលឥទ្ធិពលពីបរទេសច្រើនលើសលុប។ គំរូច្បាប់បរទេសទាំងនេះត្រូវបាននាំចូលមកដោយក្រុមអ្នកដែលបានរៀនសូត្រទាំងខ្មែរនិងបរទេសមួយក្រុមតូច។ គំរូច្បាប់បរទេសនេះ ត្រូវបានបង្កើតនិងអភិវឌ្ឍផ្អែកលើប្រវត្តិសាស្ត្រនិងទស្សនវិជ្ជានៃប្រទេសនិងជនជាតិដទៃ ដែលប្រជាជនខ្មែរភាគច្រើនលើសលុបមិនដែលស្គាល់ មិនដែលយល់ និងមិនងាយយល់ឡើយ។ ការផ្សាំពូជច្បាប់បរទេសនេះនៅក្នុងសង្គមខ្មែរ បានចាប់ផ្តើមអស់រយៈកាលជាងមួយសតវត្សកន្លះហើយ តែវាហាក់មិនទទួលបានជោគជ័យទេ។ ក្នុងន័យនេះ យើងប្រហែលត្រូវគិតគូរបន្ថែមទៀតអំពីការតាក់តែងនិងអភិវឌ្ឍច្បាប់សម្រាប់សង្គមខ្មែរយើង។

២.៣.៣.២.១. នីតិរដ្ឋបាលក្រោមឥទ្ធិពលនៃនីតិបរទេស

សង្គ្រាមស៊ីវិលដ៏ព្រាំរ៉ែនិងការបែកបាក់ជាតិ ប្រហែលគឺជាមូលហេតុតែមួយគត់ដែលឱ្យធ្វើឱ្យខ្មែរខ្សោយ។ ក្រោយការបោះឆ្នោតសាកលបន្ទាប់ពីមានកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស បរិយាកាសមិនទុកចិត្តគ្នារវាងគូបដិបក្ខនៅក្នុងជម្លោះ នៅមានទម្ងន់នៅក្នុងរដ្ឋបាលខ្មែរនៅឡើយ។ រាប់ចាប់ពីការចរចាដើម្បីតាក់តែងមាត្រានីមួយៗនៃសេចក្តីព្រាងរដ្ឋធម្មនុញ្ញ រហូតដល់ការតាក់តែងច្បាប់ដំបូងៗនៅក្នុងនីតិកាលទី១នៃរដ្ឋសភា អ្នកនយោបាយពីគ្រប់ភាគីច្រើន តែងប្រកែកគ្នាយកឈ្នះ និងច្រើនយកទ្រឹស្តីពីលោកខាងលិចមកជាបង្អែកក្នុងការដេរដែកវែកញែកដើម្បីសរសេរច្បាប់។ ជាងនេះទៅទៀត ការហូរចូលរបស់ជំនួយបរទេសមកពីលោកខាងលិច ដើម្បីអភិវឌ្ឍប្រទេសកម្ពុជាឡើងវិញ បាននាំមកជាមួយនូវអ្នកជំនាញការបរទេស ដែលធ្វើឱ្យវិធាននៃច្បាប់ខ្មែរកាន់តែចូលស៊ុបទៅក្នុងប្រព័ន្ធបរទេស។ គេមានពាក្យពេជន៍ សញ្ញាណ ទស្សនាទាន ទ្រឹស្តី និងគោលគំនិតច្បាប់ពីលោកខាងលិចច្រើនលើសលុបត្រូវបានបញ្ចូលមកក្នុងច្បាប់រដ្ឋបាលខ្មែរ ដែលធ្វើឱ្យច្បាប់នេះពិបាកយល់ និងពិបាកអនុវត្ត។

ក. ប្រភពនៃវិធានីតិរដ្ឋបាល

រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ គឺជាប្រភពគោលនៃនីតិខ្មែរបច្ចុប្បន្ន។ ក្នុងនាមជាច្បាប់កំពូលរបស់ជាតិ រដ្ឋធម្មនុញ្ញបានកំណត់គោលការណ៍សំខាន់ៗនៃនីតិរដ្ឋបាលបច្ចុប្បន្ន ពិសេស ការធានាសិទ្ធិនិងសេរីភាពរបស់ប្រជាពលរដ្ឋ ការកំណត់

រចនាសម្ព័ន្ធអំណាចរដ្ឋ ការបែងចែកអំណាចរវាងស្ថាប័ននានា ទាំងខ្សែដេក ទាំងខ្សែឈរ។ រដ្ឋធម្មនុញ្ញកម្ពុជាគឺជារដ្ឋធម្មនុញ្ញដែលយកទម្រង់តាមប្រព័ន្ធ CIVIL LAW ប៉ុន្តែខ្លឹមសាររបស់វា មានបញ្ចូលទស្សនវិជ្ជានយោបាយសំខាន់ៗពីលោកខាងលិចស្ទើរតែទាំងអស់ រាប់ទាំងគោលការណ៍បែងចែកអំណាច គោលការណ៍សភាធិបតេយ្យ គោលការណ៍នីតិរដ្ឋ គោលការណ៍គោរពសិទ្ធិមនុស្ស គោលការណ៍សមភាព គោលការណ៍សេដ្ឋកិច្ចទីផ្សារ ការបែងចែករឿងក្តីរដ្ឋបាលពីរឿងក្តីរដ្ឋប្បវេណី។ល។និង។ល។

ច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ឆ្នាំ២០១៨ បានកំណត់រចនាសម្ព័ន្ធ សមត្ថកិច្ច និងកិច្ចដំណើរការរបស់រាជរដ្ឋាភិបាលដែលជាអង្គការនីតិប្រតិបត្តិផង ជាអាជ្ញាធររដ្ឋបាលថ្នាក់កណ្តាលផង។ ច្បាប់ជាច្រើនត្រូវបានអនុម័តដើម្បីបង្កើតក្រសួង ស្ថាប័នចំណុះរាជរដ្ឋាភិបាល និងកំណត់និងសមត្ថកិច្ច។ ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលថ្នាក់ក្រោមជាតិ (ថ្នាក់ឃុំ សង្កាត់ ឆ្នាំ២០០១ ថ្នាក់រាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឆ្នាំ២០០៨) ក៏ត្រូវបានដាក់ចេញដើម្បីរៀបចំរដ្ឋបាលវិមជ្ឈការចម្លងពីអឺរ៉ុប តែផ្តល់ស្វ័យភាពត្រឹមកម្រិតដែលកម្ពុជាទទួលយកបាន។ ក្នុងន័យនេះ ស្វ័យភាពរដ្ឋបាលនិងហិរញ្ញវត្ថុ ត្រូវបានប្រគល់ជូនរដ្ឋបាលវិមជ្ឈការចំនួនបីថ្នាក់គឺថ្នាក់រាជធានី ខេត្ត ថ្នាក់ក្រុង ស្រុក ខណ្ឌ និងថ្នាក់ឃុំ សង្កាត់ ដែលនាំឱ្យមានការទទួលស្គាល់នូវនីតិបុគ្គលភាពនៃរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ប៉ុន្តែគណៈអភិបាលដែលជាអង្គនីតិប្រតិបត្តិ និងដែលជាអង្គមួយក្នុងចំណោមអង្គទាំងពីរនៃបុគ្គលសាធារណៈទាំងនេះ[៤៥២] សុទ្ធតែត្រូវស្ថិតក្រោមហានានុក្រមផ្ទាល់របស់អំណាចកណ្តាល និងអាចត្រូវបានដកហូតដំណែងដោយរដ្ឋបាលកណ្តាលបានគ្រប់ពេល[៤៥៣]។

[៤៥២] អង្គមួយទៀតគឺក្រុមប្រឹក្សា។

[៤៥៣] លើកលែងមេឃុំ ចៅសង្កាត់ ដែលជាអង្គនីតិប្រតិបត្តិរបស់ឃុំ សង្កាត់ និងដែលមានតួនាទីជាតំណាងឱ្យរដ្ឋបាលកណ្តាលដូចរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌដែរ តែមិនអាចត្រូវបានដកហូតតំណែងដោយផ្ទាល់ដោយរដ្ឋបាលកណ្តាលឡើយ។

ច្បាប់គ្រប់គ្រងតាមវិស័យ[៤៥៤] គឺប្រភពដ៏ច្រើនបំផុតនៃវិធានរបស់នីតិរដ្ឋបាលខ្មែរបច្ចុប្បន្ន។ ច្បាប់ទាំងនេះតែងបង្កើតវិធានដើម្បីកំហិតសិទ្ធិ ឬបង្កើតកាតព្វកិច្ចសម្រាប់ប្រជាពលរដ្ឋ ព្រមទាំងដាក់លក្ខខណ្ឌដើម្បីបានទទួលសិទ្ធិធ្វើកិច្ចណាមួយនៅក្នុងវិស័យដែលពាក់ព័ន្ធ។ ជាទូទៅ ច្បាប់ក៏អនុញ្ញាតឱ្យបង្កើតទោសរដ្ឋបាលដែលអាចត្រូវបានដាក់ចំពោះប្រជាពលរដ្ឋដែលប្រព្រឹត្តល្មើសផងដែរ។ ប៉ុន្តែគេសង្កេតឃើញថា ច្បាប់កាគច្រើនលើសលុប មិនសូវបានចែងអំពីការទទួលខុសត្រូវ ឬទោសទណ្ឌសម្រាប់មន្ត្រីដែលប្រតិបត្តិការងារនៅក្នុងវិស័យទាំងនោះទេ ហើយបើមានចែង ក៏ចែងមិនច្បាស់លាស់អំពីនីតិវិធីសម្រាប់អនុវត្តដើម្បីធានាឱ្យមានការទទួលខុសត្រូវរបស់រដ្ឋបាលដែរ។

បន្ថែមទៅលើវិធាននៃច្បាប់ទាំងនោះ អង្គនីតិប្រតិបត្តិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ តែងដាក់ចេញនូវលិខិតបទដ្ឋានជាច្រើនដែលមានលក្ខណៈជាបទបញ្ជា និងមានឋានានុក្រមស្របតាមកម្រិតនិងថ្នាក់នៃរដ្ឋបាលដែលចេញ។ ច្បាប់មួយអាចតម្រូវឱ្យរៀបចំអនុក្រឹត្យអនុវត្តច្រើនជាងដប់! ហើយអនុក្រឹត្យមួយក៏រុញឱ្យក្រសួង ស្ថាប័នដាក់ចេញនូវប្រកាសឬប្រកាសអន្តរក្រសួងជាច្រើនបន្តបន្ទាប់ដែរ។ អនុក្រឹត្យច្រើនកំណត់រចនាសម្ព័ន្ធចាត់តាំងរដ្ឋបាល ធនធានមនុស្ស និងសមត្ថកិច្ច ព្រមទាំងកិច្ចដំណើររបស់ក្រសួង ស្ថាប័ន ឬអង្គភាពប្រហាក់ប្រហែល។ អនុក្រឹត្យផ្សេងទៀតដែលអនុវត្តច្បាប់តាមវិស័យ កំណត់លក្ខខណ្ឌនិងនីតិវិធីដើម្បីទទួលបានសិទ្ធិនៅក្នុងការអនុវត្តការងារឬធ្វើសកម្មភាពនៅក្នុងវិស័យនោះ។ ប្រកាស

---

[៤៥៤] សារព័ត៌មាន ឆ្នាំ១៩៩៥, បេតិកភណ្ឌ ឆ្នាំ១៩៩៦, ការងារ ឆ្នាំ១៩៩៧, សុវត្ថិភាពលើផលិតផល ទំនិញ និងសេវា ឆ្នាំ ២០០០, ភូមិបាល ឆ្នាំ២០០១, អគ្គិសនី ឆ្នាំ២០០១, ព្រៃឈើ ឆ្នាំ២០០២, រ៉ែ ឆ្នាំ២០០១ , កាតព្វកិច្ចយោធា ឆ្នាំ ២០០៦, សិប្បកម្ម ឆ្នាំ២០០៦, អប់រំ ឆ្នាំ២០០៧, ស្ពង់ដា ឆ្នាំ២០០៧, ធនធានទឹក ឆ្នាំ២០០៧, ដំណាំ ឆ្នាំ២០០៨, មាត្រាសាស្ត្រ ឆ្នាំ២០០៩, សិទ្ធិជនពិការ ឆ្នាំ២០០៩, ទេសចរណ៍ ឆ្នាំ២០០៩, សវនកម្ម ឆ្នាំ២០១០, ថ្នាំនិងជីកសិកម្ម ឆ្នាំ២០១២, ហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០១០, លទ្ធកម្មសាធារណៈ ឆ្នាំ២០១២, សហគមន៍កសិកម្ម ឆ្នាំ២០១៣, ផ្លូវថ្នល់ ឆ្នាំ២០១៤, ស្ថិតិ ឆ្នាំ២០១៥, សមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ឆ្នាំ២០១៥, ទូរគមនាគមន៍ ឆ្នាំ២០១៥, ចរាចរផ្លូវគោក ឆ្នាំ២០១៥, គ្រោះមហន្តរាយ ឆ្នាំ២០១៥, ផលិតកម្មសត្វ ឆ្នាំ២០១៦, វិជ្ជាជីវៈសុខាភិបាល ឆ្នាំ ២០១៦, សហជីព ឆ្នាំ២០១៦, សំណង់និងនគរូបនីយកម្ម ឆ្នាំ២០១៩, ប្រេងកាត ឆ្នាំ២០១៩, អធិការកិច្ច ឆ្នាំ ២០១៩, របបសន្តិសុខសង្គម ឆ្នាំ២០១៩, ទឹកស្អាត ឆ្នាំ២០២៣, បរិស្ថាននិងធនធានធម្មជាតិ ឆ្នាំ២០២៣, ការដឹកជញ្ជូនតាមផ្លូវទឹក ឆ្នាំ២០២៤, ជលផល ឆ្នាំ២០២៥។

របស់រដ្ឋមន្ត្រីច្រើនកំណត់លម្អិតអំពីបែបបទនិងបរិបថនៃការផ្តល់ការអនុញ្ញាតនិងបែបបទរដ្ឋបាល។ លិខិតបទដ្ឋានដែលមានលក្ខណៈជាបទបញ្ជា ពិតជាដើរតួនាទីសំខាន់បំផុតនៅក្នុងជីវភាពប្រចាំថ្ងៃប្រជាពលរដ្ឋ។ លិខិតបទដ្ឋានបែបនេះមានច្រើនមិនប្រាកដថាជាប្រសើរសម្រាប់ប្រជាពលរដ្ឋទេ ហើយខ្លះ វិញក៏មិនប្រាកដថាជាពរជ័យសម្រាប់ពួកគាត់ដែរ។

ប្រភពទាំងអស់ខាងលើនេះបង្កើតបានជាប្រព័ន្ធនីតិរដ្ឋបាលដ៏ពេញលេញសម្រាប់ការគ្រប់គ្រងប្រទេស ប៉ុន្តែគួរឱ្យស្តាយ ការរៀបចំនិងតាក់តែងសេចក្តីព្រាងទៅតាមវិស័យនីមួយៗប្រែប្រួលទៅតាមស្ថាប័នដែលទទួលបន្ទុក អ្នកទទួលរ៉ាប់រងការងារ និងស្ថាប័នដៃគូផ្តល់ជំនួយ។ ថ្វីបើមានទីស្តីការគណៈរដ្ឋមន្ត្រី ដែលមានក្រុមប្រឹក្សាអ្នកច្បាប់ និងក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គម និងវប្បធម៌ជាសេនាធិការ ជាអ្នកត្រួតពិនិត្យនិងសម្របសម្រួលចុងក្រោយ ក្នុងគោលបំណងធានានូវសង្គតិភាពទាំងផ្នែកទម្រង់ ទាំងផ្នែកខ្លឹមសារក្តី ការខ្វះចន្លោះតែងមានកើតឡើងដោយអន្លើ និងជាញឹកញាប់។ មូលហេតុចំបងនៃការខ្វះសង្គតិភាពនេះ ការនាំចូលគំរូតាមប្រព័ន្ធផ្សេងៗពីខាងក្រៅដោយអ្នកជំនាញខ្មែរដែលបានទៅរៀនសូត្រនៅទីនោះ ឬដោយអ្នកជំនាញការបរទេសដែលខ្វះចំណេះដឹងអំពីខ្មែរ។ គំរូវិធានដែលយកពីក្រៅមកនោះ មានប្រភពប្រវត្តិសាស្ត្រនិងទស្សនវិជ្ជាផ្សេងៗគ្នាដែរ។

ខ. ខ្លឹមសារនៃនីតិរដ្ឋបាល

នីតិរដ្ឋបាលខ្មែរមិនខុសពីនីតិរដ្ឋបាលប្រទេសដទៃឡើយ គឺមានប្រភពគោលពីរដ្ឋធម្មនុញ្ញ។ ច្បាប់កំពូលនេះកំណត់គោលការណ៍គ្រឹះនៃទំនាក់ទំនងរវាងរដ្ឋឬរដ្ឋបាលនិងប្រជាពលរដ្ឋ ក្រោមរូបមន្ត សិទ្ធិនិងសេរីភាពសាធារណៈ ដែលមានចែងជាពិសេសក្នុងជំពូកទី៣ អំពីសិទ្ធិនិងករណីយកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ ជំពូកទី៥ អំពីសេដ្ឋកិច្ច និងជំពូកទី៦ អំពីអប់រំ វប្បធម៌ និងសង្គមកិច្ច។ យោងស្មារតីនៃជំពូកទាំង៣ នេះ យើងសមនឹងស្រមៃយថា ប្រជាពលរដ្ឋកម្ពុជានឹងទទួលបាននូវរដ្ឋទេវតា (welfare state) ដែលផ្តល់ដល់ប្រជាពលរដ្ឋនូវសេវាសាធារណៈដ៏គ្រប់គ្រាន់បំផុតនិងល្អប្រសើរបំផុត យ៉ាងហោចណាស់នៅលើក្រដាស ពោលគឺនៅលើច្បាប់ដែលអនុវត្តរដ្ឋធម្មនុញ្ញ និងលិខិតបទដ្ឋានក្រោមច្បាប់ដែលអនុវត្តច្បាប់។

ផ្ទុយទៅវិញ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០២៥ របៀបសរសេរច្បាប់របស់ខ្មែរយើង មិនបានសម្រួលឬបង្កលក្ខណៈឱ្យកម្ពុជាធ្វើដំណើរនៅក្នុងផ្លូវឆ្ពោះទៅរដ្ឋទេវតាទេ។ ច្បាប់ទាំងឡាយដែលត្រូវបានអនុម័តរួច គឺជាច្បាប់ដែលបង្កជម្លោះជាមួយប្រជាពលរដ្ឋ ព្រោះវាផ្ទុកទៅដោយវិធានដែលជាក់កំហិតទៅលើរាស្ត្រប្រជា ជាជាងវិធានដែលកំហិតលើមន្ត្រីរាជការ។ នៅក្នុងច្បាប់នីមួយៗ គេពិបាកនឹងរកឃើញនូវតុល្យភាពរវាងសិទ្ធិរបស់ប្រជាពលរដ្ឋ និងសិទ្ធិរបស់មន្ត្រីរាជការដែលទទួលបានពីច្បាប់នូវអំណាចណាស់។ ជារឿយៗ ច្បាប់អនុញ្ញាតឱ្យអ្នករាជការមានសិទ្ធិជាក់ចេញចំពោះប្រជាពលរដ្ឋនូវវិធានការដែលមានវិសមភាពធ្ងន់ធ្ងរជាមួយនឹងហានិភ័យនៃគ្រោះថ្នាក់ចំពោះសណ្តាប់ធ្នាប់សាធារណៈ។ និយាយម្យ៉ាងទៀត គេរកឃើញមានច្បាប់និងបទបញ្ជាដែលហាមប្រាមប្រជាពលរដ្ឋ ឬកំហិតសិទ្ធិប្រជាពលរដ្ឋ ឥតប្រយោជន៍ច្រើន។

បន្ថែមពីលើនេះ ច្បាប់និងបទបញ្ជាអនុវត្ត មិនសូវរៀបចំបែបបទនិងនីតិវិធីឱ្យបានច្បាស់លាស់សម្រាប់ ឱ្យប្រជាពលរដ្ឋអនុវត្ត ដើម្បីទទួលបានយុត្តិធម៌ ក្នុងករណីគាត់យល់ថាសិទ្ធិរបស់ខ្លួនត្រូវបានអ្នករាជការរំលោភ។ ឃ្លាដែលគេឧស្សាហ៍ជួបប្រទះញឹកញាប់ជាងគេគឺ "មានសិទ្ធិប្តឹងទៅតុលាការតាមនីតិវិធីជាធរមាន"។ តែបញ្ហានៅត្រង់ថា នីតិវិធីជាធរមានសម្រាប់ប្តឹងជំទាស់នឹងសេចក្តីសម្រេចរដ្ឋបាលនោះ នៅមិនទាន់មាន! ដើម្បីដោះស្រាយបញ្ហា នៅពេលដែលខ្លួនមិនពេញចិត្តនឹងការសម្រេចចិត្តរបស់អាជ្ញាធររដ្ឋបាលណាមួយ ប្រជាពលរដ្ឋខ្មែរមិនពឹងអាស្រ័យលើនីតិវិធីតុលាការនោះទេ។ ពួកគាត់តែងតែងាកទៅរកយុត្តិធម៌ប្រពៃណីដែលសល់ពីដូនតាបុរេមបុរាណមក នោះគឺការសំដែងមតិនៅចំពោះមុខស្ថាប័នជាតិកំពូលៗតែម្តង ទោះបីជាគ្មានលិខិតបទដ្ឋានណាអនុញ្ញាតឱ្យពួកគាត់ធ្វើបែបនេះក៏ដោយ។

ឃ. ការអនុវត្តនីតិរដ្ឋបាល

ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០២៥ គេសង្កេតឃើញការដ្ឋានកំណែទម្រង់ជាច្រើន ទទួលបានលទ្ធផលគួរជាទីមោទនៈ ហើយបានផ្លាស់ប្តូរមុខមាត់វិស័យសាធារណៈរបស់កម្ពុជា។ មន្ត្រីរាជការកាន់តែមានសមត្ថភាពជាងមុន ក្រសួង ស្ថាប័នភាគច្រើនមានសមត្ថភាពតាក់តែងច្បាប់ដោយខ្លួនឯង ទីប្រឹក្សាបរទេសត្រូវបានកាត់បន្ថយជាបណ្តើរៗ។ កំណើនសេដ្ឋកិច្ចខ្ពស់ក្នុងរយៈពេលយូរ បានធ្វើឱ្យមានការរីកចម្រើនជាទូទៅលើគ្រប់វិស័យពិសេស បានធ្វើឱ្យមានពិពិធកម្មសេវាសាធារណៈ។ បណ្តាញហេដ្ឋារចនាសម្ព័ន្ធសាធារណៈដូចជា ផ្លូវថ្នល់ បណ្តាញអគ្គិសនី បណ្តាញទឹកស្អាត បណ្តាញអ៊ិនធឺណែត ផែ អាកាសយាន

ដ្ឋាន សេវាអប់រំ និងសេវាសុខាភិបាល ត្រូវបានអភិវឌ្ឍឥតឈប់ឈរ។ ប្រជាពលរដ្ឋទទួលយកការដឹកនាំរបស់រាជរដ្ឋាភិបាល បង្កើតបានជាដុំឯកភាពជាតិមួយប្រឆាំងទប់ទល់ជាមួយក្រុមជ្រុលនិយមមួយក្តាប់តូច។ ទោះជាយ៉ាងណាក្តី អភិបាលកិច្ចគឺជាចំណុចគន្លឹះនៃទំនាក់ទំនងល្អយូរអង្វែងរបស់រដ្ឋបាលនិងរាស្ត្រប្រជា។ អភិបាលកិច្ចល្អមានការអនុវត្តច្បាប់បានត្រឹមត្រូវជាស្នូល។

ការយល់ដឹងរបស់មន្ត្រីរាជការអំពីច្បាប់នៅមានកម្រិត ព្រោះវិធាននៃនីតិរដ្ឋបាលមានប្រភពច្រើន ខុសវិស័យគ្នា និងមិនត្រូវបានដាក់ឱ្យនៅក្នុងកន្ត្រកតែមួយ ដើម្បីងាយយល់ ងាយអនុវត្តឡើយ។ វិធានទាំងនោះច្រើនជាវិធានចម្លងពីគំរូច្បាប់បរទេស ដែលជាទូទៅពិបាកយល់ ទោះជាមានការបណ្តុះបណ្តាលក៏ដោយ ព្រោះវិធានទាំងនេះ មិនផ្អែកលើវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ និងទស្សនវិជ្ជាក្នុងស្រុកទេ។ ជាលទ្ធផល មានមន្ត្រីរាជការខ្លះ បកស្រាយច្បាប់តាមការយល់ឃើញរបស់ខ្លួន ទាំងមិនបានយល់អំពីទស្សនវិជ្ជាដើមនៃវិធានដែលនាំចូលពីក្រៅនោះទៀតផង។ ខ្លះទៀតរុញរា រារែក ព្យួរទុក មិនព្រមអនុវត្ត ពីព្រោះខ្លួនមិនយល់ឬយល់មិនច្បាស់អំពីវិធាន។ ខ្លះទៀត អនុវត្តទៅតាមតែអ្វីដែលនាំប្រយោជន៍ដល់ខ្លួន។ ទោះក្នុងករណីណាក៏ដោយ អ្នកទទួលការលំបាកគឺប្រជាពលរដ្ឋ។

ការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីច្បាប់មានតិចតួចបំផុត។ ក្រុមប្រឆាំងនិងក្រុមជ្រុលនិយម តែងយកវេទិកាក្នុងបណ្តាញសង្គមដុតឱ្យខ្លោច រោចឱ្យឆៅបន្ថែមទៀត ធ្វើឱ្យក្រុមប្រជាពលរដ្ឋខ្លះបកស្រាយច្បាប់តាមអ្វីដែលពួកចង់បាន។

ទោះបីជាខ្លួនយល់ថាបានទទួលរងនូវអយុត្តិធម៌យ៉ាងណាក្តី ការប្តឹងផ្តល់ទៅតុលាការប្រឆាំងនឹងអ្នករាជការនៅតែមិនមែនជាចំណង់ចំណូលចិត្តរបស់ជនជាតិខ្មែរ។ ផ្ទុយទៅវិញ ការសុំអន្តរាគមន៍ទៅស្ថាប័នរដ្ឋបាលឡើងវិញឬការធ្វើបណ្តឹងឧបាស្រ័យទៅស្ថាប័នកំពូលៗរបស់រដ្ឋប្រឆាំងនឹងការសម្រេចរបស់អ្នករាជការ មានច្រើនលើសលុប។ ហេតុនោះ មានបទបញ្ជាជាច្រើនដែលរៀបចំឱ្យមានយន្តការប្តឹងតវ៉ាទៅអាជ្ញាធររដ្ឋបាលតាមឋានានុក្រម។

២.៣.៣.២.២. ឆ្ពោះទៅរកនីតិរដ្ឋបាលបែបខ្មែរ

ប្រភពនាពេលពេលអនាគត និងការអនុវត្តនីតិរដ្ឋបាលនាពេលអនាគត៖

ក. ប្រភពនៃវិធានឆាពេលអនាគត

គួរប្រើប្រាស់ទស្សនវិជ្ជាព្រះពុទ្ធសាសនា ដើម្បីធ្វើជាមូលដ្ឋានក្នុងការតាក់តែងនិងអភិវឌ្ឍវិធានដែលគ្រប់គ្រងទំនាក់ទំនងរវាងរដ្ឋបាលនិងប្រជាពលរដ្ឋខ្មែរ។ ទស្សនវិជ្ជានេះជាទស្សនវិជ្ជាក្នុងស្រុក ហើយដែលសង្គមខ្មែរស្គាល់ ហើយបាននិងកំពុងទ្រទ្រង់ស្រាប់។

ព្រះពុទ្ធសាសនាមានគោលការណ៍ និងការបង្រៀនជាច្រើនដែលអាចអនុវត្តចំពោះការគ្រប់គ្រងសង្គម រួមមាន៖ ១. ការគោរពសិទ្ធិមនុស្ស និងសមភាព៖ ព្រះពុទ្ធសាសនាបង្រៀនពីសមភាពមនុស្ស ដោយគ្រប់គ្នាមានសក្តានុពលក្នុងការត្រាស់ដឹង។ ២. ការអនុវត្តធម៌ប្រាំ (សីល៥)៖ ជាគោលការណ៍សម្រាប់ជីវិតប្រចាំថ្ងៃ ដែលរួមមាន៖ មិនធ្វើអន្តរាយដល់សត្វ, មិនលួចទ្រព្យសម្បត្តិ, មិនប្រព្រឹត្តខុសក្នុងកាម, មិននិយាយពាក្យកុហក, និងមិនផឹកគ្រឿងស្រវឹង។ ៣. គោលការណ៍ធម្មាធិបតេយ្យ៖ បង្រៀនពីសារៈសំខាន់នៃការគ្រប់គ្រងដោយយុត្តិធម៌ និងតាមច្បាប់។ ៤. ការអភិវឌ្ឍខន្តីនិងមេត្តា៖ លើកទឹកចិត្តឱ្យមានការអត់ធ្មត់ ការយល់ដឹង និងការអាណិតស្រឡាញ់គ្នា។ ៥. ការចូលរួមរបស់សង្គម៖ លើកទឹកចិត្តឱ្យមានការរស់នៅដោយសាមគ្គីភាព និងការជួយគ្នាទៅវិញទៅមក។ ៦. ការគ្រប់គ្រងតាមលទ្ធិមជ្ឈិមបថបាត៖ ជាផ្លូវកណ្តាល ដែលលាតត្រដាងពីសារៈសំខាន់នៃការរក្សាតុល្យភាពក្នុងសង្គម។ គោលការណ៍ទាំងនេះអាចជាគ្រឹះសម្រាប់ការបង្កើតសង្គមមួយដែលមានសន្តិភាព យុត្តិធម៌ និងវិជ្ជមាន។

ដោយឡែកនៅក្នុងទំនាក់ទំនងរវាងរដ្ឋបាលនិងប្រជាពលរដ្ឋ ដែលជាធាតុសម្ភារៈនៃនីតិរដ្ឋបាល ព្រះពុទ្ធសាសនាមានគោលការណ៍ជាច្រើនដែលមានភាពស្រដៀងគ្នា ទោះបីជាមានប្រភពនិងវិសាលភាពខុសគ្នាក៏ដោយ។ ខាងក្រោមនេះជាគោលការណ៍សំខាន់ៗមួយចំនួនដែលអាចប្រៀបធៀបបាន៖

១. គោលការណ៍នៃសីលធម៌និងអំពើល្អ (ធម៌ក្នុងព្រះពុទ្ធសាសនា និងគោលការណ៍សុចរិតភាពក្នុងច្បាប់រដ្ឋបាល)។ ក្នុងព្រះពុទ្ធសាសនា៖ សង្កត់ធ្ងន់លើ សីល៥ (ការមិនសម្លាប់សត្វ, មិនលួចទ្រព្យសម្បត្តិ, មិនប្រព្រឹត្តិខុសក្នុងកាម, មិននិយាយពាក្យកុហក, មិនផឹកនូវទឹកស្រវឹង) ជាមូលដ្ឋានគ្រឹះនៃសីលធម៌។ អ្នកកាន់អំណាចត្រូវតែមានសុចរិតយុត្តិធម៌។ ក្នុងនីតិរដ្ឋបាល គេគួរតម្រូវឱ្យមន្ត្រីរដ្ឋបាលធ្វើការដោយសុចរិតភាព គ្មានអំពើពុករលួយ គ្មានការរើសអើង និងផ្តល់ជូនដោយត្រឹមត្រូវ។ នេះស្របគ្នានឹងការបង្គាប់សីលក្នុងព្រះពុទ្ធសាសនា។

២. គោលការណ៍នៃសិទ្ធិធម្មជាតិនិងភាពស្មើភាព (សមភាពក្នុងព្រះពុទ្ធសាសនា និងភាពស្មើគ្នាចំពោះច្បាប់)។ ក្នុងព្រះពុទ្ធសាសនា គេបង្រៀនថាមនុស្សទាំងអស់មានភាពស្មើគ្នាដោយធម្មជាតិ មិនមានវណ្ណៈ ឬឋានៈណាខ្ពស់ជាងគ្នាទេ។ "ធម៌" គឺជាច្បាប់ធម្មជាតិដែលអនុវត្តដល់មនុស្សគ្រប់គ្នាដូចគ្នា។ នៅក្នុងច្បាប់រដ្ឋបាល មាន គោលការណ៍ "សមភាពចំពោះមុខច្បាប់" (Equality before the law ឬ principe d'égalité) ដែលតម្រូវឱ្យអាជ្ញាធររដ្ឋបាលសម្រេចចិត្តក្នុងកិច្ចការទាំងអស់ដោយស្មើភាព ដោយគ្មានការរើសអើងដោយផ្អែកលើជាតិសាសន៍ សាសនា ពណ៌សម្បុរណ៍ ឬស្ថានភាពសង្គម។

៣. គោលការណ៍នៃការតបស្នង (កម្មនិងទំនួលខុសត្រូវ)។ ក្នុងព្រះពុទ្ធសាសនា ៖ ច្បាប់កម្ម (Karma) បង្រៀនថារាល់សកម្មភាពមានលទ្ធផលរបស់វា។ អំពើល្អនាំមកនូវលទ្ធផលល្អ អំពើអាក្រក់នាំមកនូវលទ្ធផលអាក្រក់។ នេះជាគោលការណ៍នៃទំនួលខុសត្រូវ។ ក្នុងនីតិរដ្ឋបាល គេតម្រូវឱ្យមន្ត្រីរាជការទទួលខុសត្រូវ (Accountability) ចំពោះសកម្មភាពនិងការសម្រេចចិត្តរបស់ពួកគេ។ ប្រសិនបើពួកគេបំពានលើច្បាប់ ឬបំពេញតួនាទីមិនត្រឹមត្រូវ ពួកគេអាចត្រូវបានផ្តន្ទាទោសឬដកតួនាទី។

៤. គោលការណ៍នៃការពិចារណាដោយហេតុផល (ប្រាជ្ញានិងហេតុផល)។ ក្នុងព្រះពុទ្ធសាសនា មានការជំរុញឱ្យមានការស្វែងយល់ដោយប្រាជ្ញា និងការពិចារណាដោយហេតុផល មុននឹងទទួលយកអ្វីមួយ (ដូចជានៅក្នុងកាលាមសូត្រ)។ ក្នុងនីតិរដ្ឋបាល គេតម្រូវឱ្យការសម្រេចចិត្តរដ្ឋបាលត្រូវមានហេតុផល (Reasonableness) និងផ្អែកលើការពិចារណានៃការពិត និងច្បាប់។ ការសម្រេចចិត្តដែលឥតហេតុផល ឬមិនសមហេតុផលអាចត្រូវបានបដិសេធដោយតុលាការ។

៥. គោលការណ៍នៃការប្រកាន់ខ្ជាប់លើនីតិវិធីសមធម៌ (នីតិវិធីស្របច្បាប់)។ ក្នុងព្រះពុទ្ធសាសនា មានវិធីសាស្ត្រដែលត្រឹមត្រូវ (សម្មាទីបិ) គឺជាផ្នែកសំខាន់នៃមាគ៌ា ៨ ដ៏ប្រសើរ។ នេះរួមមានការធ្វើអ្វីៗដោយត្រឹមត្រូវតាមវិធីសមធម៌។ ក្នុងនីតិរដ្ឋបាល គេគោរពគោលការណ៍ "នីតិវិធីសមធម៌" (Due Process) ឬសិទ្ធិការពារតាមនីតិវិធី ដែលតម្រូវឱ្យអាជ្ញាធរអនុវត្តនីតិវិធីដែលយុត្តិធម៌និងសមធម៌ ដូចជាការផ្តល់ឱ្យដោយស្តាប់ការពារខ្លួន និងការបកស្រាយច្បាស់លាស់ មុនពេលដាក់ទណ្ឌកម្មដល់ប្រជាពលរដ្ឋ។

៦. គោលការណ៍នៃការពិគ្រោះយោបល់ (សង្គាហកធម៌និងការចូលរួម)។ ក្នុងព្រះពុទ្ធសាសនា មានវិធីដែលព្រះពុទ្ធធ្វើសង្ឃកម្ម (ការប្រជុំសង្ឃ) និងណែនាំឱ្យមានការពិគ្រោះយោបល់ (សាកច្ឆា) និងសន្សំសំចៃ (សង្គាហកធម៌) ក្នុងការសម្រេចចិត្តសម្រាប់

សហគមន៍។ ក្នុងនីតិរដ្ឋបាល៖ ក្នុងដំណើរការរដ្ឋបាលជាច្រើន មានការតម្រូវឱ្យស្តាប់យោបល់ ឬអនុញ្ញាតឱ្យចូលរួមពីពលរដ្ឋឬភាគីពាក់ព័ន្ធ (Public Participation) មុនពេលអនុញ្ញាតឱ្យធ្វើគម្រោងឬការសម្រេចចិត្តធំៗ ដើម្បីធានាថាផលប៉ះពាល់ទាំងអស់ត្រូវបានពិចារណា។

៧. គោលការណ៍នៃភាពត្រឹមត្រូវ និងតម្លាភាព។ ក្នុងព្រះពុទ្ធសាសនា មានការសង្កត់ធ្ងន់លើសទ្ធាដែលផ្អែកលើការពិត និងការមិននិយាយកុហក (ការការពារក្នុងសីល)។ ក្នុងច្បាប់រដ្ឋបាល គេតម្រូវឱ្យដំណើរការសម្រេចចិត្តរដ្ឋបាលមានតម្លាភាព (Transparency) ដោយធ្វើឱ្យព័ត៌មានអាចចូលដំណើរការបាន និងអាចទាក់ទងបានចំពោះសាធារណជន ដើម្បីការពារការកេងប្រវ័ញ្ច និងធានាថាការសម្រេចចិត្តគឺត្រឹមត្រូវ។

ព្រះពុទ្ធសាសនាមានទស្សនដ៏ជ្រាលជ្រៅអំពីការរៀបចំទឹកដី ដែលមិនគ្រាន់តែជាការគ្រប់គ្រងរូបិយវត្ថុប៉ុណ្ណោះទេ ថែមទាំងជាផ្នែកមួយនៃការអភិវឌ្ឍខាងផ្លូវចិត្តផងដែរ។ ទស្សនៈនេះអាចសង្ខេបបានតាមគោលការណ៍សំខាន់ៗដូចខាងក្រោម៖

១. គោលការណ៍សំខាន់ៗក្នុងការរៀបចំទឹកដី៖ ក. អធិបតេយ្យភាពលើធម្មជាតិ៖ ព្រះពុទ្ធសាសនាយល់ឃើញថា ទឹកដី ធនធាន និងបរិស្ថានគឺជាផ្នែកមួយនៃប្រព័ន្ធអន្តរកម្មដ៏ស្មុគស្មាញ។ ការរៀបចំទឹកដីត្រូវធ្វើឡើងដោយ គោរពច្បាប់ធម្មជាតិ និងការពិត។ ខ. ការអនុវត្តគោលការណ៍ "មជ្ឈិមាបដិបទា" (Middle Way)៖ ការរៀបចំទឹកដីត្រូវរក្សាតុល្យភាពរវាង៖ ការអភិវឌ្ឍ និងការអភិរក្ស, តម្រូវការបច្ចុប្បន្ន និងផលប៉ះពាល់ពេលអនាគត, ប្រយោជន៍ផ្ទាល់ខ្លួន និងសុខុមាលភាពសាធារណៈ។ គ. ការផ្តល់តម្លៃដល់សន្តិភាពនិងបូរណភាពទឹកដី ដែលមានការរៀបចំល្អគឺជាមូលដ្ឋានគ្រឹះនៃសន្តិភាពសង្គមនិងសុភមង្គលផ្ទាល់ខ្លួន។

២. ការអនុវត្តជាក់ស្តែងក្នុងការរៀបចំទឹកដី៖ ក. ការប្រើប្រាស់ដីធ្លីដោយសមហេតុផល៖ ការបែងចែកតំបន់ដីធ្លីសម្រាប់ប្រើប្រាស់ផ្សេងៗដោយច្បាស់លាស់, ការការពារដីធ្លីសម្រាប់ផលិតកម្មកសិកម្ម ដោយយកចិត្តទុកដាក់លើការអភិរក្សដីជាតិដី។ ខ. ការអភិរក្សបរិស្ថាន៖ ការពារព្រៃឈើ និងប្រព័ន្ធអេកូឡូស៊ី និងការគ្រប់គ្រងការប្រើប្រាស់ទឹកដោយយុត្តិធម៌ និងប្រក្រតី។ គ. ការរៀបចំហេដ្ឋារចនាសម្ព័ន្ធ៖ ការសាងសង់ផ្លូវ ប្រព័ន្ធជារាសាស្ត្រ និងសំណង់សាធារណៈដែលសមរម្យជាមួយបរិស្ថាន, ការរៀបចំទីធ្លាបែបព្រះពុទ្ធសាសនា ដូចជាវត្តអារាម ជាតំបន់សម្រាប់សមាធិ និងការពិចារណាធម៌។

៣. ទស្សនីយភាពខ្ពស់ក្នុងការរៀបចំទឹកដី៖ ក. ទឹកដីជាកន្លែងសម្រាប់ការអប់រំ៖ ទឹកដីដែលមានការរៀបចំល្អអាចជាបរិស្ថានដ៏ល្អសម្រាប់ការអប់រំ និងអភិវឌ្ឍខាងផ្លូវចិត្ត។ ខ. ការបង្កើតសង្គមដែលអាស្រ័យគ្នា៖ ការរៀបចំទឹកដីគួរជំរុញឱ្យមានការរស់នៅដោយសាមគ្គីភាព និងការយោគយល់គ្នា។ គ. ការផ្តល់តម្លៃដល់សុខមាលភាព៖ ទឹកដីដែលមានការរៀបចំល្អគឺជាមូលដ្ឋានគ្រឹះនៃសុខភាពផ្លូវកាយ និងផ្លូវចិត្ត។

៤. គោលការណ៍សម្រាប់អ្នករៀបចំទឹកដី៖ អ្នកដែលទទួលខុសត្រូវចំពោះការរៀបចំទឹកដីត្រូវ៖ មានប្រាជ្ញា យល់ដឹងពីច្បាប់ធម្មជាតិ, មានមេត្តា គិតដល់ប្រយោជន៍របស់សហគមន៍, មានសីលធម៌ មិនលំអៀង និងមិនរើយ៉ែគ្គិភាព, មានភាពអត់ធ្មត់ពិចារណាលើផលប៉ះពាល់ពេលអនាគត។

ក្នុងទស្សនៈព្រះពុទ្ធសាសនា ការរៀបចំទឹកដីគឺជាសកម្មភាពដ៏ពិសិដ្ឋមួយ ដែលត្រូវធ្វើឡើងដោយប្រាជ្ញា មេត្តា និងការយល់ដឹងពីភាពអន្តរកម្មនៃធម្មជាតិទាំងមូល។ ការរៀបចំទឹកដីមិនមែនគ្រាន់តែជាការរៀបចំរូបវន្តប៉ុណ្ណោះទេ ថែមទាំងជាផ្នែកមួយនៃការអភិវឌ្ឍខាងផ្លូវចិត្តរបស់មនុស្សផងដែរ។

ជារួម គោលការណ៍ព្រះពុទ្ធសាសនាដែលស្របគ្នានឹងច្បាប់រដ្ឋបាលគឺផ្តោតលើសីលធម៌, ភាពស្មើគ្នា, ការទទួលខុសត្រូវ, ការសម្រេចចិត្តដោយហេតុផល, នីតិវិធីដែលយុត្តិធម៌, ការចូលរួម, និងភាពត្រឹមត្រូវ។ ទោះបីជាមានប្រភពខុសគ្នា (ពីសាសនានិងច្បាប់) ក៏គោលការណ៍ទាំងនេះចែករំលែកគោលបំណងរួមគ្នាក្នុងការកសាងសង្គមដែលមានយុត្តិធម៌ សុចរិតភាព និងមានស្តារភាព។ ការយល់ដឹងអំពីគោលការណ៍ទាំងនេះអាចជួយពង្រឹងសមត្ថភាពរបស់មន្ត្រីរដ្ឋបាលក្នុងការបម្រើប្រជាពលរដ្ឋដោយមានប្រសិទ្ធភាព និងសេចក្តីថ្លៃថ្នូរបានយ៉ាងពិតប្រាកដ។

ខ. ការអនុវត្តនីតិរដ្ឋបាល

ជនជាតិខ្មែរត្រូវការមន្ត្រីនិងថ្នាក់ដឹកនាំល្អ ជាជាងមានច្បាប់និងនីតិវិធីល្អសម្រាប់ប្តឹងផ្តល់គ្នានៅតុលាការ។ ហេតុនេះ សម្រាប់សង្គមខ្មែរ ប្រហែលការពារប្រសើរជាងព្យាបាល។ ការការពារគឺធ្វើឱ្យមន្ត្រីរាជការមានសីលធម៌ល្អ រដ្ឋបាលមានលក្ខណៈប្រសើរបម្រើប្រជាពលរដ្ឋបានល្អ ដើម្បីបញ្ចៀសការធ្វើដំណើរទៅរកភាពផ្តាច់ការនៃរដ្ឋបាលសាធារណៈ។ វិធីនេះអាចធ្វើឡើងតាមរយៈការបង្រៀននិងបណ្តុះបណ្តាលទស្សនវិជ្ជាព្រះពុទ្ធសាសនា ដែលជាទស្សនវិជ្ជាជាប្រពៃណីខ្មែរ ហើយដែរបានចាក់ឫសចូលយ៉ាងជ្រៅក្នុងសង្គមខ្មែររាប់រយសតវត្សមកហើយ។

ដើម្បីក្លាយជា មន្ត្រីរាជការល្អ តាមទស្សនវិជ្ជាព្រះពុទ្ធសាសនា គេត្រូវគោរពគោលការណ៍គុណធម៌ ១០ យ៉ាងរបស់អ្នកគ្រប់គ្រងឬទសពិធរាជធម៌[៤៥៥]។ តាមព្រះពុទ្ធសាសនា ប្រជាពលរដ្ឋមានសិទ្ធិទាមទារបានពីមេដឹកនាំរបស់ពួកនូវ៖ **១. សិទ្ធិទាមទារការគ្រប់គ្រងដោយយុត្តិធម៌ និងសុចរិត**៖ ភាពត្រឹមត្រូវ (អជ្ជវៈ)៖ ប្រជាពលរដ្ឋមានសិទ្ធិទាមទារឱ្យមេដឹកនាំប្រកាន់នូវភាពត្រឹមត្រូវ និងគ្មានអំពើពុករលួយ។ ភាពយុត្តិធម៌៖ ការសម្រេចចិត្ត និងការចែកចាយធនធានត្រូវតែយុត្តិធម៌ និងគ្មានភាពលំអៀង។ **២. សិទ្ធិទាមទារសុវត្ថិភាព និងសន្តិភាព៖** ការពារពីអំពើហិង្សា (អវិហិង្សា)៖ រដ្ឋាភិបាលត្រូវធានានូវសុវត្ថិភាពរបស់ប្រជាជន និងការពារពួកគេពីអំពើហិង្សា និងការបំពាន។ ការរស់នៅដោយសន្តិភាព៖ នេះគឺជាសិទ្ធិជាមូលដ្ឋានបំផុតមួយដែលប្រជាពលរដ្ឋអាចទាមទារបាន។ **៣. សិទ្ធិទាមទារការចែករំលែកធនធានដោយយុត្តិធម៌៖** ការចែករំលែក (ទាន)៖ ប្រជាពលរដ្ឋមានសិទ្ធិទាមទារឱ្យមានការចែករំលែកធនធានសាធារណៈដោយយុត្តិធម៌ជាពិសេសសម្រាប់អ្នកក្រីក្រ និងអ្នកដែលមានការខ្វះខាត។ ការទទួលបានសេវាមូលដ្ឋាន៖ ជាការបរិច្ចាគផ្នែកសាធារណៈ ប្រជាពលរដ្ឋអាចទាមទារបាននូវសេវាមូលដ្ឋានដូចជាការថែទាំសុខភាព ការអប់រំ និងហេដ្ឋារចនាសម្ព័ន្ធ។ **៤. សិទ្ធិទាមទារការគោរព និងការយល់ដឹង៖** ភាពទន់ភ្លន់ (មទ្ទវៈ) ប្រជាពលរដ្ឋអាចទាមទារឱ្យមេដឹកនាំដឹកនាំដោយការគោរព និងការយល់ដឹង មិនមែនដោយការបង្ខិតបង្ខំ ឬភាពកំណាចនោះទេ។ ការតបស្នង៖ ដោយសារពួកគេជាអ្នកជាប់ពន្ធ និងគាំទ្រអំណាច ប្រជាពលរដ្ឋអាចទាមទារការយល់ដឹងពីមេដឹកនាំ។ **៥. សិទ្ធិទាមទារការអនុវត្តដោយភាពអត់ធ្មត់៖** ភាពអត់ធ្មត់ (ខន្តី)៖ ប្រជាពលរដ្ឋអាចទាមទារឱ្យមេដឹកនាំមានភាពអត់ធ្មត់ក្នុងការដោះស្រាយបញ្ហា មិនធ្វើសកម្មភាពដោយភាពឆាប់ខឹង ឬវិនិយ័យយ៉ាងឃោរឃៅ។ **៦. សិទ្ធិទាមទារសេរីភាពក្នុងការអភិវឌ្ឍខាងផ្លូវចិត្ត៖** ការលើកទឹកចិត្តឱ្យមានសីល៖ រដ្ឋាភិបាលត្រូវបង្កើតបរិស្ថានដែលអនុញ្ញាតឱ្យប្រជាពលរដ្ឋរស់នៅដោយសុចរិត និងអភិវឌ្ឍខាងផ្លូវចិត្ត។ សេរីភាពខាងសាសនា៖ ការធានានូវសេរីភាពក្នុងការអនុវត្តតាមសាសនា ឬជំនឿដោយមិនមានការរារាំង។ **៧. សិទ្ធិទាមទារការឆ្លើយតប**៖ ការតាក់តែងដោយគ្មានការប្រឆាំង (អវិរោធន៍)៖ ប្រជាពលរដ្ឋអាចទាមទារឱ្យមេដឹកនាំគ្រប់គ្រងដោយយុត្តិធម៌ និងមិនធ្វើឱ្យអ្នកដទៃមានទុក្ខព្រួយដោយឥតប្រយោជន៍។

[៤៥៥] Dasa Raja Dhamma។

តាមព្រះពុទ្ធសាសនា ទំនាក់ទំនងរវាងមេដឹកនាំនិងប្រជាពលរដ្ឋគឺជាទំនាក់ទំនងផ្តល់និងទទួល។ មេដឹកនាំត្រូវតែបម្រើដោយការបរិច្ចាគ (ទាន) សីលធម៌ (សីល) និងការលះបង់ (បរិច្ចាគ)។ ជាអ្នកទទួលនូវទានទាំងនោះ ប្រជាពលរដ្ឋមានសិទ្ធិទាមទារប្រការទាំងនេះពីមេដឹកនាំរបស់ពួកគេ។ ទាំងនេះគឺជាសិទ្ធិដែលផ្អែកលើគោលការណ៍សមហេតុផល និងសីលធម៌ ដែលជាគ្រឹះសម្រាប់សង្គមមួយដែលមានសុភមង្គលនិងសន្តិភាព។

ក. ប្រជាពលរដ្ឋដែលយល់ចិត្ត

ព្រះពុទ្ធសាសនាមិនបានចង្អុលបង្ហាញតែបុគ្គលិកលក្ខណៈរបស់មេដឹកនាំប៉ុណ្ណោះទេ ថែមទាំងបានចង្អុលបង្ហាញយ៉ាងច្បាស់អំពីបុគ្គលិកលក្ខណៈរបស់ប្រជាពលរដ្ឋ (រាស្ត្រ) ដែលជាមូលដ្ឋានគ្រឹះសម្រាប់សង្គមមួយដែលមានសុខសន្តិភាពនិងរីកចម្រើនទៅមុខបានផងដែរ។ តាមគម្ពីរសីគាលវេទសុត្ត[៤៥៦] និងគោលការណ៍ផ្សេងទៀត រាស្ត្រល្អត្រូវតែ៖

១. ប្រតិបត្តិតាមគោលការណ៍ "ហេតុផល" ឬ "កម្ម"៖ យល់ដឹងពីច្បាប់នៃកម្ម៖ ជឿថាសកម្មភាពល្អនាំមកនូវផលល្អ សកម្មភាពអាក្រក់នាំមកនូវផលអាក្រក់។ ដូច្នេះត្រូវរស់នៅដោយសុចរិត ទទួលខុសត្រូវលើសកម្មភាពរបស់ខ្លួន។ បុគ្គលម្នាក់ៗត្រូវតែដឹងខ្លួននៅក្នុងការងារ ការចំណាយ និងការប្រព្រឹត្តទាំងអស់។

២. ប្រតិបត្តិតាមគុណធម៌ ៦ យ៉ាង (បារមី)៖ គុណធម៌ទាំងនេះមិនមែនសម្រាប់តែព្រះពោធិសត្វទេ គឺជាគុណធម៌ដែលរាស្ត្រល្អគួរបង្កើត៖ **១. ទាន (Dana)** (ការបរិច្ចាគ) សំដៅដល់ការចែករំលែក ការជួយដល់អ្នកដទៃតាមសមត្ថភាព ទាំងជាលុយកាក់ ការពិចារណា ឬការយកចិត្តទុកដាក់។ **២. សីល (Sila)** (ការរក្សាសីលធម៌) សំដៅដល់ការរក្សានូវគោលការណ៍សីលធម៌មូលដ្ឋាន ជាពិសេស សីល៥ ដែលជាមូលដ្ឋានគ្រឹះនៃសង្គមសុខសន្តិ (មិនឃាតសត្វ, មិនលួចទ្រព្យសម្បត្តិ, មិនប្រព្រឹត្តិខុសក្នុងកាម, មិននិយាយពាក្យកុហក, មិនផឹកនូវគ្រឿងស្រវឹង)។ **៣. ខន្តី (Khanti)** (ភាពអត់ធ្មត់) សំដៅដល់ការអត់ធ្មត់នឹងការលំបាក ការរិះគន់ និងស្ថានភាពដែលមិនអាចផ្លាស់ប្តូរបានភ្លាមៗ។ មិនងាយនឹងឆេវឆាវ ឬដោះសារ។ **៤. វិរិយ (Viriya)** (ភាពខ្នើយឃ្នាត) សំដៅដល់ការខិតខំប្រឹងប្រែងក្នុងការងារ ការសិក្សា និងការអភិវឌ្ឍខ្លួន។ មិនខ្ជិលច្រអូស ឬពឹងផ្អែកលើអ្នកដទៃដោយឥតប្រយោជន៍។ **៥. ឈាន (Dhyana)** (ការតម្កល់ចិត្ត) សំដៅដល់ការចេះអប់រំចិត្តឱ្យស្ងប់ មានសម្មាធិ។ នេះជួយឱ្យមានស្មារតីច្បាស់លាស់ សម្រេចចិត្ត

[៤៥៦] Sigalovada Sutta។

បានត្រឹមត្រូវ និងគ្រប់គ្រងអារម្មណ៍បានល្អ។ **៦. បញ្ញា (Prajna)** (ប្រាជ្ញា) សំដៅដល់ការចេះវិភាគ វែកញែក និងយល់ដឹងពីបញ្ហាដោយយុត្តិធម៌។ មិនងាយនឹងជឿតាមគេធ្វើឬជឿរឿងល្បែង។

៣. តួនាទីក្នុងគ្រួសារ និងសង្គម៖ រាស្ត្រល្អត្រូវចេះទំនាក់ទំនងជាមួយមនុស្សនៅក្នុងសង្គមដោយយុត្តិធម៌ ពោលគឺធ្វើជាកូនល្អ: គោរពមាតាបិតា ចាំទ្រទ្រង់ពេលចាស់ជរា រក្សាកេរ្តិ៍ឈ្មោះគ្រួសារ, ជាសិស្សល្អ: គោរពគ្រូអាចារ្យ ស្តាប់បង្គាប់ និងរៀនសូត្រដោយខ្មីឃ្មាត, ជាគ្រូល្អ: បង្រៀនដោយស្រឡាញ់ ចង្អុលបង្ហាញផ្លូវដ៏ត្រឹមត្រូវ និងជួយការពារកូនសិស្ស, ជាមិត្តល្អ: ជួយឧបត្ថម្ភមិត្តភក្តិក្នុងពេលមានគ្រោះថ្នាក់ ជួយដើមទុន ផ្តល់ដំបូន្មានល្អ និងអនុវត្តតាមពាក្យសន្យា, ជាប្តី/ប្រពន្ធល្អ: មានសន្តានចិត្តទន់ភ្លន់ គោរពជួយឧបត្ថម្ភ និងរក្សាការទុកចិត្តគ្នាទៅវិញទៅមក, ជានិយោជិតល្អ: ខិតខំប្រឹងប្រែងក្នុងការងារ មិនលួចយកទ្រព្យសម្បត្តិ និងធ្វើការដោយស្មោះត្រង់, ជានិយោជកល្អ: ផ្តល់ការងារតាមសមត្ថភាព ផ្តល់ប្រាក់ឈ្នួលដ៏យុត្តិធម៌ និងចែករំលែកផលប្រយោជន៍។

៤. បុគ្គលិកលក្ខណៈសំខាន់ៗសម្រាប់រាស្ត្រ៖ ១) មេត្តានិងករុណា៖ មានចិត្តអាណិតស្រឡាញ់ និងយកចិត្តទុកដាក់ចំពោះសហមនុស្សជាតិ និងសត្វលោកទាំងអស់។ ២)សតិ៖ មានស្មារតី ដឹងខ្លួននៅគ្រប់ពេលវេលា មិនងាយនឹងភាន់ច្រឡំ ឬធ្វេសប្រហែស។ ៣)សទ្ធា៖ មានសទ្ធាជាហេតុនាំឱ្យរស់នៅដោយសុចរិត ប៉ុន្តែមិនងាយនឹងជឿយកតាមគេធ្វើ។

តាមព្រះពុទ្ធសាសនា រាស្ត្រល្អគឺជាបុគ្គលដែលរស់នៅដោយសមហេតុផល មានសីលធម៌ ខិតខំប្រឹងប្រែងក្នុងការងារ មានសេចក្តីអត់ធ្មត់ និងមានប្រាជ្ញា។ ពួកគេចេះទំនាក់ទំនងជាមួយអ្នកដទៃដោយយុត្តិធម៌ និងជួយឧបត្ថម្ភដល់ការអភិវឌ្ឍន៍សង្គម។ រាស្ត្រដែលមានគុណធម៌បែបនេះ គឺជាមូលដ្ឋានដ៏រឹងមាំបំផុតសម្រាប់សង្គមមួយដែលសុខសាន្ត និងរីកចម្រើន។

២.៤. សេចក្តីសន្និដ្ឋាន

- អ្វីដែលនៅសល់ពីអាណានិគមនិយមបារាំង គឺរបៀបធ្វើការដោយផ្អែកប្រព័ន្ធសរសេរ
- ការសរសេរច្បាប់ខ្មែរមកទល់បច្ចុប្បន្ន ថ្វីត្បិតបើបានគិតគូរច្រើនដល់សាកលភាវូបនីយកម្ម តែហាក់បានបំភ្លេចចោលនូវគោលគំនិត ទស្សនវិជ្ជា និងគុណតម្លៃខ្មែរ
- ការសរសេរច្បាប់ដោយផ្អែកលើទស្សនវិជ្ជានិងគុណតម្លៃបរទេស ធ្វើឱ្យមានតែមនុស្សមួយក្រុមតូចដែលយល់អំពីច្បាប់ខ្មែរ ហើយធ្វើឱ្យមន្ត្រីពាក់ការខ្មែរខ្លួនឯង យល់បានតិចតួច រីឯប្រជាពលរដ្ឋខ្មែរវិញ ស្ទើរតែអត់យល់តែម្តង
- គោលគំនិត ទស្សនវិជ្ជា និងគុណតម្លៃខ្មែរមានបង្កប់ជ្រៅនៅក្នុងប្រពៃណី ទំនៀមទម្លាប់ និងវប្បធម៌ ដែលផ្អែកជាទូទៅលើសាសនាព្រាហ្មណ៍ និងសាសនាព្រះពុទ្ធ ដែលបានដើរតួនាទីយ៉ាងសំខាន់ក្នុងសង្គមខ្មែរយើងទាំងក្នុងវិស័យនយោបាយ វិស័យសេដ្ឋកិច្ច វិស័យវប្បធម៌ និងវិស័យសង្គមកិច្ច។ល។ ព្រមទាំងបានតស៊ូទប់ទល់ជាមួយឥទ្ធិពលបរទេស
- ជនជាតិខ្មែរមិនចង់និងមិនត្រូវការឈ្លោះជាមួយអ្នកដឹកនាំ តែចង់បានតែអ្នកដឹកនាំល្អប្រកបដោយទសពិធរាជធម៌។

គន្ថនិទ្ទេស

ភាសាខ្មែរ

សៅ សង្ហា, អត្ថរូបពីរយ៉ាងនៃរាជានិយមខ្មែរ, ភ្នំពេញ, ២០១៩, ១៦ទំព័រ

ហ៊ែល ចំរើន, មរតកយុត្តិធម៌ខ្មែរ, ភ្នំពេញ, ២០១០, ៥៨១ ទំព័រ

ភាសាបរទេស

BUDDHADASA Bhikkhu, Bouddhisme et Socialisme, Les Deux Océans, Paris, 1987, 134 p.

GAILLARD Maurice, Démocratie cambodgienne, la Constitution du 2 4 septembre 1993, Paris, L´Harmattan, Coll. Points sur l´Asie, 1994, 186 p.

GOUR Claude-Gilles, Institutions constitutionnelles et politiques du Cambodge, Paris, Dalloz, 1965, 448 p.

IMBERT Jean, Histoire des institutions khmères, Annales de la Faculté de Droit de Phnom-Penh, 1961, 207 p.

LECLERE Adhémard, Recherche sur le droit public des Cambodgiens, Paris 1894, 352 p.

NORODOM Ranariddh, Droit public cambodgien, Tome 1, Collection Etudes Francophones, Presses universitaires de Perpignan, 1998, 356 p.

SAY Bory, Droit administratif général, Blossom Lotus, 2e éd. 2001, 740 p.

THENG Chan-Sangvar, Le service public au Cambodge, Thèse de droit public, Université Lumière Lyon 2, 2007, 689 p.

ផ្នែកទី៣. នីតិមុខងារសាធារណៈ

សិក្ខារំពឹង «នីតិមុខងារសាធារណៈកម្ពុជា»

លោក ណុច វ៉ាម៉ូ ប្រធានលេខាធិការដ្ឋានសាលាភូមិន្នរដ្ឋបាល

៣.១. សេចក្តីសង្ខេប

របាយការណ៍សិក្សាស្រាវជ្រាវស្តីពី "នីតិមុខងារសាធារណៈកម្ពុជា" ត្រូវបានរៀបចំឡើងនៅក្នុងក្របខណ្ឌនៃក្រុមស្រាវជ្រាវទី៣ ផ្នែកទី១ស្តីពីការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជាដោយផ្សារភ្ជាប់គុណតម្លៃ ប្រវត្តិសាស្ត្រកម្ពុជា និងគុណតម្លៃសាកល។ របាយការណ៍សិក្សាស្រាវជ្រាវនេះគឺជាការសាកល្បងសិក្សាស្វែងយល់អំពីប្រព័ន្ធច្បាប់កម្ពុជាតាមជ្រុងនីតិមុខងារសាធារណៈ ដើម្បីចូលរួមចំណែកដល់សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា ឆ្នាំ២០២៥ របស់គណៈកម្មការដឹកនាំការកែទម្រង់ប្រព័ន្ធច្បាប់។ របាយការណ៍សិក្សាស្រាវជ្រាវនេះបានប្រមែប្រមូលទិន្នន័យ ទាំងឯកសារបែបសិក្សា និងបទដ្ឋានគតិយុត្តនានាដែលពាក់ព័ន្ធ ដើម្បីព្យាមស្វែងរកសញ្ញាណនៃគុណតម្លៃខ្មែរក្នុងសាវតារមុខងារសាធារណៈកម្ពុជា ព្រមទាំងគុណតម្លៃក្នុងដំណើរការនៃទំនើបកម្មរដ្ឋបាលសាធារណៈផងដែរ។ ជាលទ្ធផល របាយការណ៍សិក្សាស្រាវជ្រាវសូមស្នើនូវគុណតម្លៃសំខាន់ៗចំនួន ២ ដើម្បីកំណត់អំពីអត្តសញ្ញាណមុខងារសាធារណៈកម្ពុជា រួមមាន ទី១) "គុណតម្លៃឯកភាពរដ្ឋបាល" ក្នុងសម័យអន្តរកាលរវាងមុខងារសាធារណៈជំនាន់ចាស់ និងមុខងារសាធារណៈជំនាន់ថ្មី និងទី២) "គុណតម្លៃគុណាធិបតេយ្យ" ក្នុងសម័យកែទម្រង់រដ្ឋបាលសាធារណៈ ពិសេសការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការស៊ីវិលប្រកបដោយគុណាធិបតេយ្យ តម្លាភាព យុត្តិធម៌ បរិយាបន្ន និងប្រសិទ្ធភាព។

៣.២. សេចក្តីផ្តើម

នីតិមុខងារសាធារណៈកម្ពុជា មានប្រភពសំខាន់ចេញពីរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ត្រង់មាត្រា ៣៥, មាត្រា៣៦ និងមាត្រា៣៧ ដែលយោងតាមមាត្រាទាំងនោះ ប្រជាពលរដ្ឋខ្មែរមានសិទ្ធិចូលបំរើការងាររាជការតាមសមត្ថភាព ដោយគ្មានការរើសអើង។ លើសពីនេះ ប្រភពសំខាន់ផ្សេងទៀត គឺច្បាប់ស្តីពីសហលក្ខន្តិកៈ មន្ត្រីរាជការស៊ីវិល ឆ្នាំ ១៩៩៤ និងព្រះរាជក្រឹត្យស្តីពីគោលការណ៍រួមស្តីពីការរៀបចំមុខងារសាធារណៈរបស់រដ្ឋ

ឆ្នាំ២០១៤ ព្រមទាំងលក្ខន្តិក:ដោយឡែកប្រមាណ២០ទៀត[៤៥៧]។ វិធានគតិយុត្តទាំងនោះគ្រប់គ្រងនិងផ្តល់អត្ថប្រយោជន៍ដល់មន្ត្រីរាជការក្នុងមួយវដ្តនៃភាពជាមន្ត្រី រួមមានចាប់ពីការជ្រើសរើសការបណ្តុះបណ្តាល ការតាំងស៊ុប ការតែងតាំង ការផ្តល់បៀវត្ស រហូតដល់ការចូលនិវត្តន៍ ក្នុងគោលបំណងធានាឱ្យបានដំណើការរដ្ឋបាលសាធារណៈមួយប្រកបដោយប្រសិទ្ធភាព ហើយសេវាសាធារណៈជូនប្រជាពលរដ្ឋ ត្រូវបានរំពឹងថាកាន់តែមានគុណភាពប្រសើរ។

ពាក្យ "មុខងារសាធារណៈ" ត្រូវបានដាក់ជាឈ្មោះរបស់ក្រសួង ស្ថាប័ន ឬអង្គភាព (ក្រសួងមុខងារសាធារណៈ, អធិការកិច្ចមុខងារសាធារណៈ, វិទ្យាមុខងារសាធារណៈជាដើម)។ ដោយឡែក ក្នុងទិដ្ឋភាពសិក្សាប្រៀបធៀបពាក្យមុខងារសាធារណៈត្រូវនឹងពាក្យ «Fonction publique» ក្នុងភាសាបារាំង និង «Civil Service» ក្នុងភាសាអង់គ្លេស ដែលពាក្យបរទេសទាំងពីរមិនមានអត្ថន័យដូចគ្នាទាំងស្រុងឡើយ។ ការយល់អំពីអត្ថន័យ Fonction publique និង Civil Service អាចជួយស្វែងយល់អំពីវប្បធម៌នៃប្រព័ន្ធអាជីព (ប្រព័ន្ធបិទ) និងវប្បធម៌នៃប្រព័ន្ធនិយោជន៍ (ឬប្រព័ន្ធបើក)។ ការយល់អំពីអត្ថន័យនៃពាក្យទាំងពីរ មានសារៈសំខាន់សម្រាប់ប្រទេសដែលអនុវត្តប្រព័ន្ធមុខងារសាធារណៈចំរុះ។ ក្រៅពីឧត្តមានុវត្តន៍អន្តរជាតិ ដែនសិក្សានៃនីតិមុខងារសាធារណៈ ត្រូវបានពង្រីកទៅតាមកិច្ចការរបស់រាជរដ្ឋាភិបាល ពិសេសបរិវត្តកម្ម មុខងារសាធារណៈជាដើម។

ប្រព័ន្ធមុខងារសាធារណៈកម្ពុជានាពេលបច្ចុប្បន្ន គឺជាផលិតផលដែលបានកើតចេញពីប្រវត្តិសាស្ត្រដ៏ស្មុគស្មាញ ដោយមានការផ្លាស់ប្តូរច្រើនលើកច្រើនសារ ចាប់រាប់ពីចុងសតវត្សទី១៩រហូតដល់ដើមសតវត្សទី២១ រួមមានសម័យរាជានិយម (មុខងារសាធារណៈខ្មែរសម័យបុរាណ[៤៥៨]), សម័យអាណាព្យាបាលបារាំង, សម័យសង្គមរាស្ត្រនិយម, សម័យសាធារណៈរដ្ឋខ្មែរ, សម័យកម្ពុជាប្រជាធិបតេយ្យ, សម័យរដ្ឋកម្ពុជារហូតដល់សម័យព្រះរាជាណាចក្រកម្ពុជាទី២។ ការផ្លាស់ប្តូររបបនយោបាយពីមួយសម័យទៅមួយសម័យបានបន្សល់ទុកនូវផលវិបាកជាច្រើនដល់ប្រព័ន្ធមុខងារសាធារណៈបច្ចុប្បន្ន ដែលតម្រូវឱ្យព្យាយាមសិក្សាស្វែងរកអ្វីដែលអាចចាត់ទុកបានថាគុណតម្លៃខ្មែរ (ជំពូកទី១)។

---

[៤៥៧] នៅប្រព័ន្ធច្បាប់របស់បារាំង យើងសង្កេតឃើញមាន "ច្បាប់ស្តីពីការកែទម្រង់មុខងារសាធារណៈ", "ក្រមមុខងារសាធារណៈ" មិនត្រឹមតែឈ្មោះក្រសួង ស្ថាប័ន ឬអង្គភាពឡើយ។

[៤៥៨] ប្រព័ន្ធមុខងារសាធារណៈកម្ពុជា ចាប់តាំងពីការកកើតរដ្ឋនៅសតវត្សទី១រហូតដល់មុនចុងសតវត្សទី១៩ មុនមានការដាក់អាណាព្យាបាលបារាំង គួរជាប្រធានបទដោយឡែកមួយទៀតសម្រាប់ការសិក្សាស្រាវជ្រាវបន្ត ដែលត្រូវការពេលវេលាបន្ថែម។

ជាងនេះទៅទៀត ការកំណត់អំពីអត្តសញ្ញាណមុខងារសាធារណៈកម្ពុជា ក៏ទាមទារនូវការការផ្សារភ្ជាប់ជាចម្បងទៅនឹងការងារកែទម្រង់រដ្ឋ ពិសេសការកែទម្រង់បាលសធារណៈ។ នៅក្នុងនីតិកាលទី៧នេះ រាជរដ្ឋាភិបាលបាននិងកំពុងយកចិត្តទុកដាក់ក្នុងការកែទម្រង់សំខាន់ៗក្នុងគោលដៅបម្រើឧត្តមប្រយោជន៍ជាតិ ដោយបានដាក់ឱ្យអនុវត្តនូវយុទ្ធសាស្ត្របញ្ចកោណ ដំណាក់ការទី១ ដើម្បីកំណើន សមធម៌ ប្រសិទ្ធភាព និងចីរភាព។ នៅក្នុងក្របខណ្ឌនៃការអនុវត្តជាក់ស្តែង រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការគន្លឹះនៃការកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីសម្រេចឱ្យបាននូវការកំណត់នៅឆ្នាំ២០៥០ ដែលកម្ពុជានឹងក្លាយជាសង្គមជាតិមួយដ៏រស់រវើក រដ្ឋរឹងប៉ឹង មានអភិបាលកិច្ចល្អ និងស្ថាប័នរឹងមាំប្រកបដោយតម្លាភាព និងគណនេយ្យភាព ហើយបម្រើប្រជាជនប្រកបដោយប្រសិទ្ធភាព (ដំពូកទី២)។

៣.៣. ប្រវត្តិមុខងារសាធារណៈកម្ពុជា

នៅក្នុងដំពូកទី១នេះ របាយការណ៍សិក្សាស្រាវជ្រាវនឹងលើកឡើងនូវពីរចំណុចរួមមានសាវតានៃមុខងារសាធារណៈកម្ពុជា (**ផ្នែកទី១**) និងសាវតានៃស្ថាប័នមុខងារសាធារណៈកម្ពុជា (**ផ្នែកទី២**) ដើម្បីឈានទៅរកការកំណត់គុណតម្លៃខ្មែរក្នុងវិស័យមុខងារសាធារណៈ។

៣.៣.១. សាវតានៃមុខងារសាធារណៈកម្ពុជា

ចាប់រាប់ពីសម័យដែលមានព្រះមហាក្សត្រសោយរាជ្យមក កម្ពុជាមានមន្ត្រីបម្រើការងារនៅក្នុងរាជវាំង ហើយការគ្រប់គ្រងមន្ត្រីនាពេលនោះ មិនទាន់មានវិធានច្បាស់លាស់នោះទេ សូម្បីតែការជ្រើសរើសនិងបៀវត្ស ក៏មិនទាន់មានការកំណត់អ្វីច្បាស់លាស់នោះដែរ ពោលគឺអាស្រ័យលើព្រះមហាក្សត្រទាំងស្រុង។ នៅសម័យអាណាព្យាបាលបារាំងមកលើកម្ពុជា (ឆ្នាំ១៨៦៣-១៩៥៣) បារាំងបាននាំចូលមកនូវវិធាននិងរបៀបរបបគ្រប់គ្រងមន្ត្រីរាជការតាមបែបបស្ចឹមប្រទេសជាពិសេសក្នុងការជ្រើសរើស បណ្តុះបណ្តាល និងការបម្រើសេវាសាធារណៈចាប់ពីឆ្នាំ១៨៩៧ ហើយសូម្បីព្រះមហាក្សត្រក៏ត្រូវបានបារាំងរៀបចំបៀវត្សថ្វាយ។ ចាប់ពីពេលនោះហើយ ព្រះរាជាណាចក្រកម្ពុជាបានប្រកាន់យកមុខងារសាធារណៈតាមបែបបារាំង គឺប្រព័ន្ធ ក្របខណ្ឌវិជ្ជាជីវៈ ដែលហៅថា "ប្រព័ន្ធអាជីព" ដែលបានបន្តជះឥទ្ធិពលនៅសម័យក្រោយៗរហូតមកដល់បច្ចុប្បន្ននេះ។ ជាងនេះទៅទៀត នៅសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ប្រព័ន្ធអាជីពកាន់តែត្រូវបានមើលឃើញកាន់តែច្បាប់ តាមរយៈការប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈនៃភ្នាក់ងាររាជការក្នុង

ព្រះរាជាណាចក្រកម្ពុជា នៅឆ្នាំ១៩៥៤ ហើយស្ថាប័នមួយត្រូវបានបង្កើតឡើងតាមម៉ូឌែលបារាំង គឺ «មន្ទីរចាត់ការមុខងារសាធារណៈ» (ចំណុចនេះនឹងត្រូវបានបកស្រាយបន្ថែមនៅក្នុងផ្នែកទី២បន្ទាប់)។ នៅសម័យសាធារណៈខ្មែរ (១៩៧០-១៩៧៥) មុខងារសាធារណៈបានបន្តយកមុខងារសាធារណៈសម័យសង្គ្រាមរាស្ត្រនិយម ដោយកែប្រែ ច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរដ្ឋការនៃក្របខណ្ឌផ្សេងៗនៃរបបសាធារណៈខ្មែរ។ ចំណុចដែលខុសប្លែកពីមុខងារសាធារណៈសម័យសង្គមរាស្ត្រនិយម គឺមុខងារសាធារណៈសម័យសាធារណៈខ្មែរ មាន ការតែងតាំងមន្ត្រីរដ្ឋការមិនពឹងផ្អែករលើសមត្ថភាពរដ្ឋបាលជំនាញទាំងស្រុងទេ ព្រោះស្រុកមានសង្គ្រាម ពេលគឺជួនកាល យកគ្រូបង្រៀនបឋមសិក្សាទៅធ្វើអភិបាលស្រុក ឬដាក់នាយទាហានស័ក្តិ ៥ ទៅធ្វើអភិបាលខេត្តជាដើម។ នៅក្នុងដំនាន់កម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) មុខងារសាធារណៈតាមប្រព័ន្ធអាជីព ត្រូវបានបំផ្លាញទាំងស្រុង ដោយជំនួសវិញនូវកិច្ចការអ្វីៗទាំងអស់ស្រេចតែលើអង្គការ។ កម្មការកិបាល និងកម្មករ ដែលបំរើការងារ ត្រូវបានចាត់តាំងដោយអង្គការតាមអំពើចិត្ត។ ក្រោយរំដោះថ្ងៃ ៧មករា ឆ្នាំ១៩៧៩ ក្នុងសម័យរដ្ឋកម្ពុជាការគ្រប់គ្រងកម្មការកិបាល (មន្ត្រីរាជការ) ការងារតែងតាំងចាប់ពីថ្នាក់អនុប្រធាននាយកដ្ឋានឡើងទៅ និងការរៀបចំរចនាសម្ព័ន្ធ អង្គការលេខ ស្ថិតក្រោមការត្រួតពិនិត្យ និងសម្រេចរបស់គណៈចាត់តាំងមជ្ឈិម ដែលជាស្ថាប័នមួយរបស់គណបក្ស។ ក្នុងមុខងារសាធារណៈសម័យនោះ មានការជ្រើសរើសផ្អែករលើការស្មើគ្រចិត្តជាគោល, ប្រព័ន្ធលាភការ, ការឈប់សំរាក, ការធ្វើចូលនិវត្តន៍ និង ឥនទានបៀវត្សជាដើម។ តាមរយៈកិច្ចព្រមព្រៀងក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលបាននាំទៅដល់ការបង្កើតរបបរាជានិយមអាស្រ័យរដ្ឋធម្មនុញ្ញឡើងវិញ វិស័យមុខងារសាធារណៈត្រូវបានអនុវត្តាមសម័យសង្គមរាស្ត្រនិយម ពិសេសច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជាឆ្នាំ១៩៩៤ ហើយលេខាធិការដ្ឋានមុខងារសាធារណៈ ក៏ត្រូវបានបង្កើតឡើងដើម្បីគ្រប់គ្រងមន្ត្រីរាជការ។

៣.៣.២. ស្ថាប័នមុខងារសាធារណៈកម្ពុជា

ការកំណត់អត្តសញ្ញាណនៃប្រព័ន្ធច្បាប់គឺអាស្រ័យទៅលើការសិក្សាស្វែងយល់អំពីវិធានស្ថាប័ន[៤៥៩]។ ក្នុងន័យនេះ ការកំណត់អំពីអត្តសញ្ញាណនៃប្រព័ន្ធនីតិមុខងារសា

[៤៥៩] ប្រសាសន៍ណែនាំរបស់ឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ នៅក្នុងអង្គប្រជុំរបស់សមាជិកក្រុមសិក្សាស្រាវជ្រាវលើប្រធានបទទី៣ ផ្នែកទី១ "ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា" នៅបន្ទប់ប្រជុំក្រុមប្រឹក្សាអ្នកច្បាប់ នាថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០២៥

ធារណៈកម្ពុជា គឺអាស្រ័យទៅលើការរៀបចំស្ថាប័នមុខងារសាធារណៈផងដែរ។ ក្នុងប្រវត្តិសាស្ត្រខ្មែរ ស្ថាប័នមុខងារសាធារណៈត្រូវបានបង្កើតឡើងជាលើកដំបូង នាសម័យសង្គមរាស្ត្រនិយម (១៩៥៣-១៩៧០) ដែលនៅពេលនោះមានឈ្មោះថា "មន្ទីរចាត់ការមុខក្រសួងសាធារណៈ"[៤៦០] ស្ថិតនៅក្រោមការគ្រប់គ្រងដោយផ្ទាល់របស់នាយករដ្ឋមន្ត្រី។ ក្រោយមកពីឆ្នាំ១៩៥៧-១៩៧០ ស្ថាប័នមុខងារសាធារណៈត្រូវបានកែទម្រង់ជាអង្គភាពស្ថិតនៅក្នុងរចនាសម្ព័ន្ធនៃទីស្តីការគណៈរដ្ឋមន្ត្រី។ នៅក្នុងរបបសាធារណៈរដ្ឋខ្មែរ នាឆ្នាំ ១៩៧០-១៩៧៥ មន្ទីរចាត់ការមុខក្រសួងសាធារណៈ ស្ទើរតែពុំមានអ្វីផ្លាស់ប្តូរទេ ក៏ប៉ុន្តែមន្ទីរចាត់ការមុខក្រសួងសាធារណៈ ក៏ដូចជាក្រសួង ស្ថាប័នរដ្ឋគ្រប់វិស័យ ដ៏ទៃទៀតត្រូវបានបំផ្លិចបំផ្លាញចោលទាំងស្រុង ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយគេដាក់ជំនួសវិញនូវរចនាសម្ព័ន្ធថ្មីឈ្មោះថា "អង្គការ" ចាប់ពីឆ្នាំ១៩៧៥-១៩៧៩។ នៅក្នុងទស្សវត្សទី៨០ រដ្ឋាភិបាលនៃសាធារណរដ្ឋប្រជាមានិតកម្ពុជា បានប្រគល់កិច្ចការគ្រប់គ្រងរដ្ឋការជូនគណៈចាត់តាំងដែលជាស្ថាប័នគណបក្សនិងក្រសួងផែនការជាស្ថាប័នរដ្ឋាភិបាល។ នៅក្នុងទស្សវត្សទី៩០ រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី១ នៃរដ្ឋសភា បានសម្រេចបង្កើត "រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ"[៤៦១] ដើម្បីទទួលបេសកកម្មដឹកនាំ និងគ្រប់គ្រងមន្ត្រីរាជការស៊ីវិលក្នុងវិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា។ ដោយឡែក ការងារបៀវត្ស -ពលកម្ម នៅតាមរាជធានី ខេត្ត ត្រូវបានផ្ទេរទៅមន្ទីរផែនការរាជធានី ខេត្ត តាមរយៈប្រកាសអន្តរក្រសួងលេខ២៣១ប្រក.ផក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០០ ស្តីពីការប្រគល់ការងារបៀវត្ស-ពលកម្មជូនមន្ទីរផែនការខេត្ត-ក្រុង របស់ក្រសួងផែនការនិងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ។ រាជរដ្ឋាភិបាលកម្ពុជា ក្នុងនីតិកាលទី៥ នៃរដ្ឋសភា បានបង្កើតក្រសួងមុខងារសាធារណៈ[៤៦២] តាមរយៈការប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមុខងារសាធារណៈ ដោយបានដាក់បញ្ចូលស្ថាប័នចំនួនបី រួមមាន រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ អគ្គលេខាធិការដ្ឋាននៃក្រុមប្រឹក្សាកំណែទម្រង់រដ្ឋបាល និងសាលាភូមិន្ទរដ្ឋបាល ដែលមានមុខងារ និងបេសកកម្មសំខាន់ក្នុងការដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍវិស័យមុខងារសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា និងការងារកែទម្រង់រដ្ឋបាលសាធារណៈ។ លើសពីនេះទៅទៀត ក្នុងនីតិកាលទី៧នៃរដ្ឋសភា រាជរដ្ឋាភិបាលបានផ្តល់បេសកកម្មសំខាន់ៗបន្ថែមដល់ក្រសួងមុខងារសាធារណៈ ជា

[៤៦០] ព្រះរាជក្រមលេខ១៨៩នស ចុះថ្ងៃទី០៥ ខែមេសា ឆ្នាំ១៩៥៧

[៤៦១] ព្រះរាជក្រមលេខ នស/រកប/០១៩៦/២៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦

[៤៦២] រាជក្រមលេខ នស/រកម/១២១៣/០១៦ ចុះថ្ងៃទី៩ ខែធ្នូ ឆ្នាំ២០១៣

ពិសេសត្រូវដាលេខាធិការដ្ឋាននៃគណៈកម្មការជាតិជំរុញការអនុវត្តវិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈ ក្រោមការដឹកនាំដោយផ្ទាល់ពី សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ វិធានការគន្លឹះទាំងបីនៃការកែទម្រង់រដ្ឋបាលសាធារណៈរួមមាន ទី១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការស៊ីវិល, ទី២) ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មក្រសួង ស្ថាប័ន និងទី៣) ការលើកទឹកចិត្តគាំទ្រសមិទ្ធកម្មក្នុងរដ្ឋបាលសាធារណៈ។

៣.៤. បរិវត្តកម្មនៃមុខងារសាធារណៈកម្ពុជា

នៅក្នុងជំពូកទី២នេះ របាយការណ៍សិក្សាស្រាវជ្រាវនឹងលើកឡើងអំពីមូលហេតុដែលរាជរដ្ឋាភិបាលកម្ពុជាបានប្រកាន់យកប្រព័ន្ធអាជីពសម្រាប់មុខងារសាធារណៈ នៅឆ្នាំ១៩៩៣ (ផ្នែកទី១) ដែលប្រព័ន្ធមុខងារសាធារណៈអាជីពនេះ ក្រោយមកត្រូវបានកែបានបំពេញបន្ថែមដោយប្រព័ន្ធនិយោជន៍ ពិសេសសម្រាប់វិស័យអាទិភាពរួមមានសុខាភិបាល និងអប់រំ (ផ្នែកទី២) យោងតាមនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល (ផ្នែកទី៣)។

៣.៤.១. ប្រព័ន្ធអាជីពក្នុងមុខងារសាធារណៈកម្ពុជា

ប្រព័ន្ធអាជីពគឺជាប្រព័ន្ធបិទដែលផ្តល់មុខតំណែងក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលក្រោមជាតិ តែចំពោះមន្ត្រីរាជការក្របខណ្ឌប៉ុណ្ណោះ ពោលគឺមិនមានការបើកចំហដល់និស្សិត ឬអ្នកធ្វើការក្នុងវិស័យឯកជន ដែលជាគោលការណ៍ មិនត្រូវបានជ្រើសរើសចូលក្របខណ្ឌ តាមរយៈការប្រឡងប្រជែងដែលគ្រប់គ្រងដោយរដ្ឋនៅឡើយ។ មុខងារសាធារណៈកម្ពុជាមានមូលដ្ឋានលើប្រព័ន្ធអាជីពនេះ តាមការសម្រេចរបស់រាជរដ្ឋាភិបាល នាថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៣ ពិសេសតាមការប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៤។

ជាការពិត មូលហេតុមួយចំនួនដែលបានជះឥទ្ធិពលធ្វើឱ្យប្រទេសកម្ពុជាប្រកាន់យកប្រព័ន្ធមុខងារសាធារណៈតាមបែបអាជីពឡើងវិញរួមមានដូចខាងក្រោម៖

- ប្រទេសកម្ពុជាធ្លាប់ស្ថិតនៅក្រោមអាណានិគមនិយមបារាំងជិតមួយសតវត្ស ដែលបានធ្វើឱ្យប្រព័ន្ធអាជីព បានចាក់ឫសគល់យ៉ាងជ្រៅក្នុងការគ្រប់គ្រងរាជការរហូតមក (ឧទាហរណ៍ ធ្លាប់មានប្រពៃណី តាំងពីយូរ

ណាស់ហើយថា ពេលចូលធ្វើការមានការធានាបៀវត្ស ដល់ចាស់មានប្រាក់សោធននិវត្តន៍)

- នៅដើមទស្សវត្ស ៩០ ប្រទេសកម្ពុជាកំពុងស្ថិតក្នុងស្ថានភាពបង្រួបបង្រួមជាតិ និងកំពុងអនុវត្ត គោលនយោបាយសមហរណកម្មមន្ត្រីរាជការនៃភាគីនយោបាយនានា (១៥០.០០០នាក់)[៤៦៣] ក្នុងពេលនោះ យើងមិនអាចអនុវត្តតាមប្រព័ន្ធនិយោជន៍បានទេ
- ការជ្រើសរើសប្រព័ន្ធអាជីពនាពេលនោះគឺសមស្របតាមស្ថានភាពរបស់ប្រទេសកម្ពុជា ដែលជាប្រទេសកំពុងអភិវឌ្ឍន៍ ហើយវិស័យឯកជនក៏មិនទាន់មានការរីកចំរើន ជាពិសេសវិស័យឧស្សាហកម្ម សេវាកម្ម ពាណិជ្ជកម្ម នៅមានកម្រិតទាប រួមផ្សំចំណេះដឹង ជំនាញមន្ត្រីរាជការនៅមានកំរិតទាបនៅឡើយ។

ជាការពិត តាមរយៈបទពិសោធនៃការរៀបចំមុខងារសាធារណៈកម្ពុជាឡើងវិញនៅដើមទសវត្ស ៩០ ដោយយកជម្រើសប្រព័ន្ធអាជីពដូចសម័យសង្គមរាស្ត្រនិយម ដោយបានសម្របសម្រួលរវាងផលវិបាកនៃ មុខងារសាធារណៈជំនាន់ចាស់ (កូតានយោបាយ, ការផ្សះផ្សារជាតិជាដើម) និងការទាមទារនៃមុខងារសាធារណៈជំនាន់ថ្មី ដោយយកសមត្ថភាព (ការប្រកួតប្រជែង, លក្ខខណ្ឌឧត្តមសិក្សាជាមុន) គឺអាចអនុញ្ញាតឱ្យយើងទាញបាន "គុណតម្លៃឯកភាពរដ្ឋបាល" របស់មុខងារសាធារណៈកម្ពុជានៅសម័យអន្តរកាល[៤៦៤]។

ថ្វីត្បិតប្រព័ន្ធអាជីពមានគុណសម្បត្តិនិងសមស្របតាមស្ថានភាពប្រទេស ក៏ប៉ុន្តែប្រព័ន្ធនេះមានគុណវិបត្តិជាច្រើនផងដែរមានការជ្រើសរើសបានមន្ត្រីមានជំនាញទូទៅ មិនមានជំនាញឯកទេស មិនមានភាពបទបែន ឬការសម្របខ្លួនរបស់មន្ត្រីយឺតយ៉ាវទៅនឹង

---

[៤៦៣] យោងតាមបទឧទ្ទេសនាមរបស់ ឯកឧត្តម ប្រាក់ សុខ នៅមហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រ ជូននិស្សិតឆ្នាំទី៤ នាថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ១៩៩៦។

[៤៦៤] គុណតម្លៃ "ឯកភាពរដ្ឋបាល" នេះអាចទាញបានចេញពីប្រវត្តិរបស់សាលាកូមិន្ទរដ្ឋបាល ពិសេសការរៀបចំវគ្គបណ្តុះបណ្តាលដំបូង និងបន្ត ពោលគឺវគ្គបណ្តុះបណ្តាលបន្ត (សុក្រឹតការ ក្រោយមក វិក្រឹតការ) ត្រូវបានរៀបចំសម្រាប់មុខងារសាធារណៈជំនាន់ចាស់ ដែលមិនបានទទួលការអប់រំនៅសម័យសង្គ្រាម និងវគ្គបណ្តុះបណ្តាលដំបូង (សិស្សមន្ត្រីជាន់ខ្ពស់ និងសិស្សមន្ត្រីក្រមការ) ត្រូវបានរៀបចំឡើងសម្រាប់មុខងារសាធារណៈជំនាន់ថ្មីដែលផ្អែកលើការប្រឡងប្រជែងតាមគុណាធិបតេយ្យ។ ការសម្របសម្រួលរវាងមុខងារសាធារណៈជំនាន់ចាស់និងថ្មី គឺបានចូលរួមចំណែកដល់ការធ្វើឱ្យមានឯកភាពក្នុងរដ្ឋបាលសាធារណៈ នៅសម័យអន្តរកាល។

ការផ្លាស់ប្តូរទៅតាមការរីកចម្រើនរបស់សង្គមសេដ្ឋកិច្ច ដូចជាបដិវត្តឧស្សាហកម្ម បច្ចេកវិទ្យាថ្មីៗ ឬទីផ្សារការងារជាដើម។ គុណវិបត្តិទាំងនេះរបស់ប្រព័ន្ធអាជីព អាចត្រូវបានកែលម្អដោយគុណសម្បត្តិរបស់ប្រព័ន្ធនិយោជន៍ (ដូចជាជ្រើសរើសបានបុគ្គលិកមានជំនាញ សមត្ថភាព និងបទពិសោធការងារឆ្លើយតបតាមតម្រូវការការងារ និងភាពបទបែន)។

៣.៤.២. ប្រព័ន្ធនិយោជន៍ (មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ)

ប្រព័ន្ធនិយោជន៍ គឺជាប្រព័ន្ធបើកដល់និស្សិត ឬអ្នកធ្វើការវិស័យឯកជន ដែលអាចទទួលបានមុខតំណែងក្នុងក្រសួង ស្ថាប័ន និងរដ្ឋបាលសធារណៈ តាមរយៈកិច្ចព្រមព្រៀងការងារ (កិច្ចសន្យា)។ ការជ្រើសរើសបុគ្គលិកគឺផ្អែកតាមមុខតំណែងនីមួយៗ ដោយមានការកំណត់គុណវុឌ្ឍនៃមុខតំណែង និងការពិពណ៌នាមុខតំណែងជាដើម។ ក្នុងរាជរដ្ឋាភិបាល នីតិកាលទី៧នៃរដ្ឋសភានេះ ការធ្វើបវិត្តកម្មលើប្រព័ន្ធមុខងារសាធារណៈអាជីពដោយបន្ថែមប្រព័ន្ធនិយោជន៍ តាមរយៈការដាក់ឱ្យអនុវត្តអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ស្តីពីការជ្រើសរើសនិងគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ។ "មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ" គឺជាមន្ត្រីកម្រិតបច្ចេកទេសនិងបម្រើការងារក្នុងមុខតំណែងវិជ្ជាជីវៈនៅតាមអង្គភាពគោលដៅដែលមន្ត្រីបានជ្រើសរើស ស្របតាមកិច្ចព្រមព្រងការងារដូចជា៖

- គ្រឹះស្ថានសធារណៈ (សាលាមត្តេយ្យ, បឋម, អនុវិទ្យាល័យ វិទ្យាល័យ)
- អង្គភាពសុខាភិបាលមូលដ្ឋាន (ប៉ុស្តិ៍សុខភាព, មណ្ឌលសុខភាព, មន្ទីរពេទ្យបង្អែកកម្រិត១ និងកម្រិត២)
- អង្គភាពនៅតាមក្រសួង ស្ថាប័នដទៃទៀត ផ្អែកតាមការសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ក្រសួងមុខងារសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

មន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ ត្រូវជ្រើសរើសផ្អែកតាមគុណាធិបតេយ្យ និងគ្រប់គ្រងផ្អែកលើសមិទ្ធកម្ម ដោយមានការតាមដាននិងការវាយតម្លៃ ព្រមជាមួយអត្ថប្រយោជន៍ដូចមន្ត្រីក្របខណ្ឌ[៤៦៥]។ នេះជា ទស្សនាទានថ្មីនៃបវិត្តកម្មមុខងារសាធារណៈដែលខុសប្លែកពីប្រព័ន្ធមុខងារសាធារណៈកម្ពុជាកន្លងមក ពោលគឺការផ្លាស់ប្តូរពីគ្រប់គ្រង

[៤៦៥] សូមមើលអនុក្រឹត្យលេខ៧៨ អនក្រ.បក ចុះថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៥ស្តីពីការជ្រើសរើសនិងគ្រប់គ្រងមន្ត្រីផ្អែកលើកិច្ចព្រមព្រៀងការងារ

មុខងារសាធារណៈបែបប្រពៃណី (ប្រព័ន្ធអាជីព) ទៅកាន់ការគ្រប់គ្រងមុខងារសាធារណៈបែបនិយោជន៍។ នេះជាការផ្លាស់ប្តូរក្នុងទ្រង់ទ្រាយធំ ដែលនាំឱ្យមានការផ្លាស់ប្តូរផ្នែកគំនិតនិងឥរិយាបថរបស់មន្ត្រីរាជការខ្មែរ។ នេះជាការទម្រង់ពីរចនាសម្ព័ន្ធបែបមុខងារទៅរចនាសម្ព័ន្ធបែបប្រតិបត្តិការ តាមរយៈការបំពេញការងារគម្រោង ការបង្កើតក្រុមការងារសម្រាប់សម្រេចឱ្យបាននូវសូចនាករសមិទ្ធកម្មដែលបានកំណត់ក្នុងផែនការ សម្មភាពកម្មវិធី អនុកម្មវិធីរបស់អង្គភាព រហូតដល់ក្រសួង ស្ថាប័ន និងរដ្ឋបាលក្រោមជាតិ។

៣.៤.៣. និយាមនីតិវិធីប្រតិបត្តិសម្រាប់ការជ្រើសរើសមន្ត្រីរាជការស៊ីវិល

វិធានការគន្លឹះក្នុងការកែទម្រង់រដ្ឋបាលសាធារណៈមានចំនួន៣ រួមមាន ទី១) ការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការ, ទី២) ការពង្រឹងសមត្ថភាពនិងសមិទ្ធកម្មស្ថាប័ន និងទី៣) ការដាក់ឱ្យអនុវត្តប្រព័ន្ធលើកទឹកចិត្តគាំទ្រសមិទ្ធកម្ម។ របាយការណ៍សិក្សាស្រាវជ្រាវស្តីពីនីតិមុខងារសាធារណៈ បានផ្តោតទៅលើវិធានការគន្លឹះទី១ប៉ុណ្ណោះ ដើម្បីស្វែងរកនូវគណតម្លៃខ្មែរក្នុងវិស័យមុខងារសាធារណៈ[៤៦៦]។ វិធានការគន្លឹះទី១នៃ ការកែទម្រង់រដ្ឋបាលសធារណៈ គឺការកែលម្អជ្រើសរើសមន្ត្រីរាជការស៊ីវិល ហើយកិច្ចការនេះស្ថិតនៅក្នុងវិស័យមុខងារសាធារណៈ។ នេះអាចចាត់ទុកបានថាជាដំណាក់ការដ៏សំខាន់មួយនៃវិធាននីតិមុខងារសាធារណៈកម្ពុជានាពេលបច្ចុប្បន្ន។ នេះជាការកែទម្រង់នៃប្រព័ន្ធជ្រើសរើស ប្រកបដោយគុណាធិបតេយ្យ, តម្លាភាព, យុត្តិធម៌, បរិយាបន្ន និងប្រសិទ្ធភាព ស្របតាមអនុសាសន៍ដ៏ថ្លៃថ្លារបស់ សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី គឺ **"រើសឱ្យចំ បំពេញឱ្យត្រូវ រក្សាឱ្យនៅ"** និង **"ជាប់ដោយមោទនៈ ធ្លាក់ដោយអស់ចិត្ត"**។

ក្នុងការប្រែក្លាយប្រសាសន៍របស់ប្រមុខរាជរដ្ឋាភិបាលឱ្យក្លាយជាការពិត ឯកឧត្តម **ហ៊ុន ម៉ានី** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ បានដឹកនាំការរៀបចំការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិលចំនួន ៤២លើក ត្រូវនឹង ៩ក្រសួងស្ថាប័ន និងមានបេក្ខជនដាក់ពាក្យចំនួន ១១ម៉ឺននាក់ ផ្អែកតាមគោលការណ៍ថ្មីដែលកំណត់ក្នុងអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការដាក់

[៤៦៦] ដោយក្របខណ្ឌពេលវេលា របាយការណ៍សិក្សាស្រាវជ្រាវស្តីពី "នីតិមុខងារសាធារណៈកម្ពុជា" បានព្យាយាមស្វែងយល់អំពីវិធានការគន្លឹះទី១ស្តីពីការកែលម្អប្រព័ន្ធជ្រើសរើសមន្ត្រីរាជការស៊ីវិល ដែលស្ថិតនៅក្រោមវិសាលភាពនៃនីតិមុខងារសាធារណៈក្លាសិកតែប៉ុណ្ណោះ។ សម្រាប់ទិសដៅទៅមុខ របាយការណ៍នឹងបន្តសាកល្បងស្វែងយល់អំពីវិធានការគន្លឹះទី២ និងវិធានការគន្លឹះទី៣ នៃការកែទម្រង់រដ្ឋបាលសាធារណៈបន្ថែមទៀត។

ឱ្យអនុវត្តនិយាមនីតិវិធីប្រតិបត្តិសម្រាប់ការប្រឡងប្រជែងជ្រើសរើសមន្ត្រីរាជការស៊ីវិល។ ក្នុងការសម្រេចបេសសកម្មនេះ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី បានមានប្រសាសន៍បន្ថែមទៅកាន់បេក្ខជននិងសាធារណៈជនទូទៅថា **"មិនចាំបាច់ត្រូវស្គាល់អ្នកធំ មិនចាំបាច់ត្រូវមានខ្សែ តែត្រូវមានសមត្ថភាព"**។ ប្រសាសន៍នេះអាចឆ្លុះបញ្ចាំងអំពីការវិវត្តដ៏សំខាន់នៃប្រព័ន្ធមុខងារសាធារណៈកម្ពុជានៅក្នុងដំណាក់ការជ្រើសរើស។ ជាលទ្ធផល ការកែទម្រង់ការប្រឡងជ្រើសរើសមន្ត្រីរាជការជាងមួយឆ្នាំមកនេះ បានទទួលការសាទរពីគ្រប់មជ្ឈដ្ឋានដែលបានកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់របស់ក្រសួងមុខងារសាធារណៈ និងក្រសួង ស្ថាប័នពាក់ព័ន្ធ។ ការងារកែទម្រង់នេះបានកសាង "គុណតម្លៃគុណាធិបតេយ្យខ្មែរ" ដែលជាការបញ្ជីគ្នារវាងគុណតម្លៃគុណាធិបតេយ្យជាសកលជាមួយស្ថានភាពជាក់ស្តែងរបស់ធនធានមនុស្ស និងតម្រូវការរបស់រដ្ឋបាលសាធារណៈរបស់កម្ពុជានាពេលបច្ចុប្បន្ន។

៣.៥. សេចក្តីសន្និដ្ឋាន

បន្ទាប់ពីបានសិក្សាស្វែងយល់អំពីប្រវត្តិនិងការវិវត្តនៃមុខងារធារណៈកម្ពុជា របាយការណ៍ស្រាវជ្រាវអាចសន្និដ្ឋានបានថា រាជរដ្ឋាភិបាលដែលមានក្រសួងមុខងារសាធារណៈជាសេនាធិការ បាននិងកំពុងប្រកាន់យកប្រព័ន្ធអាជីពនិយមសម្រាប់ការគ្រប់គ្រងមន្ត្រីរាជការ ដោយកែលម្អតាមប្រព័ន្ធនិយោជន៍ ដើម្បីពង្រឹងសមិទ្ធកម្មក្រសួង ស្ថាប័ន និងសេវាសធារណៈឱ្យកាន់តែមានប្រសិទ្ធភាព និងគុណភាព។ ទោះយ៉ាងណាក៏ដោយការរៀបចំកែលម្អប្រព័ន្ធអាជីពកម្ពុជានេះត្រូវការឱ្យតម្លៃ និងការចូលរួមពីក្រសួង ស្ថាប័នមួយចំនួនទៀត ដើម្បីឱ្យកាន់តែមានសង្គតិភាពក្នុងកសាងមូលធនមនុស្សក្នុងវិស័យសាធារណៈឱ្យស្របតាមផែនការយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល តាមអភិក្រមជវភាពនៃប្រព័ន្ធតួអង្គតែមួយ។

បន្ថែមពីនេះ តាមរយៈការឆ្លុះបញ្ចាំងអំពីបទពិសោធរបស់មុខងារសាធារណៈ ជាពិសេសនៅក្នុងដើមនីតិកាលទី៧នេះ របាយការណ៍ស្រាវជ្រាវអាចស្នើបាននូវសញ្ញាណគុណតម្លៃខ្មែរក្នុងវិស័យមុខងារសាធារណៈមួយចំនួនដូចជា៖ "គុណតម្លៃឯកភាពរដ្ឋបាល" ក្នុងសម័យអន្តរកាលដែលជាការធ្វើឱ្យសុខុដុមនីយកម្មរវាងមុខងារសាធារណៈជំនាន់ចាស់ និងមុខងារសាធារណៈជំនាន់ថ្មី ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា ហើយបន្តមក **គុណតម្លៃឯកភាពរដ្ឋបាលនេះ** ត្រូវបានរក្សា និងបំពេញបន្ថែមដោយ "គុណតម្លៃគុណាធិបតេយ្យ" ក្នុងសម័យកែទម្រង់ក្នុងនីតិកាលទី៧ ដោយអ្នកដឹកនាំបន្តវេនក្រោមការដឹកនាំដ៏ស្វាហាប់របស់ សម្តេចមហាបវរធិបតី **ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

គន្ថនិទ្ទេស

ពេជ្រ ប៊ុនធិន, ស៊ន សុយន, សិក ហេងឡុង (ឆ្នាំ២០១០), ចំណេះដឹងអំពីមុខងារសាធារណៈ, ភ្នំពេញ

បណ្ឌិត សាយ បូរី (២០០៧), វិទ្យាសាស្ត្ររដ្ឋបាល, ភ្នំពេញ

ក្រសួងមុខងារសាធារណៈ (២០២៥)សៀវភៅករណីសិក្សាស្តីពីដំណើរការនៃការប្រឡងប្រជែងជ្រើសរើសក្របខណ្ឌមន្ត្រីរាជការស៊ីវិលចូលបម្រើការងារនៅតាមក្រសួង ស្ថាប័ន (កំពុងត្រៀមបោះពុម្ពផ្សាយ)

ក្រសួងមុខងារសាធារណៈ (២០២៤) ឯកសារជំនួយស្មារតីស្តីពីការជ្រើសរើស និងការគ្រប់គ្រងមន្ត្រីអប់រំ ផ្អែកលើកិច្ចព្រមព្រៀងការងារ ក្នុងវិស័យអប់រំ

សាលាភូមិន្ទរដ្ឋបាល (២០២៥), ព្រឹត្តិបត្រគោលនយោបាយនិងរដ្ឋបាលសាធារណៈ, ឆ្នាំទី២ លេខ១

Maurice Gaillard (2001), La réforme de la fonction publique au Cambodge, indicateur de la transition. In : Revue française d´administration publique, N°98, 2001

Chhiv Yiseang (2005), La fonction publique cambodgienne, Mémoire du Master en Administration publique, Université de Strasbourg- ENA

Nuch Ramo (2020), L´Ecole Royale d´Administration (ERA): quelle place dans la transformation de l´action publique cambodgienne ?, Mémoire du Master en Administration publique, Université de Strasbourg- ENA

ផ្នែកទី៤. នីតិហិរញ្ញវត្ថុសាធារណៈ

សិក្សាអំពី «នីតិហិរញ្ញវត្ថុសាធារណៈ»

លោកស្រី ឡេង ចាន់ភួង អ្នកជំនាញការច្បាប់
នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.)

៤.១. សេចក្តីសង្ខេប

សម័យបុរេប្រវត្តិ គ្មានអរិយធម៌ និងវប្បធម៌ជាតិសាសន៍ណាចូលមកលាយឡំឡើយ អ្វីៗដែលខ្មែរចេះដឹង ធ្វើកើតក្នុងសម័យនោះគឺជាគំនិតខ្មែរ ជារបស់ខ្មែរ ជាស្នាដៃខ្មែរ ពោលគឺជាខ្មែរនិយមសុទ្ធសាធដូចជាវប្បធម៌ អរិយធម៌ និងភាសាជាដើម សុទ្ធតែកើតចេញមកពីប្រភពអរិយធម៌ខ្មែរ-មន។ ខ្មែរបុរាណមានរបៀបរបបនៅក្នុងការធ្វើជំនួញ ឬដោះដូរផលិតផលទៅវិញទៅមក ដោយប្រើប្រាស់ផ្លូវដើម្បីធ្វើចរាចរណ៍លើផ្នែកសេដ្ឋកិច្ច ខណៈការធ្វើកសិកម្ម គឺសម្រាប់ជីវភាពគ្រួសារតែប៉ុណ្ណោះ ហើយចំណូលដ៏ទៃទៀត គឺកើតចេញពីការធ្វើពាណិជ្ជកម្មក្រៅស្រុកជាមួយប្រទេសធំៗដូចជាឥណ្ឌា និងចិន ជាដើម។ នៅក្នុងសម័យអង្គរការប្រមូលចំណូលរដ្ឋ ត្រូវបានលេចរូបរាងច្បាស់លាស់ តាមរយៈច្បាប់ប្រើប្រាស់ក្នុងវិស័យពន្ធដារ ដោយគោលការណ៍ពន្ធដារ ដោយកំណត់ថាការយកពន្ធអាករជាសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះមហាក្សត្រ (ក្នុងនាមជាម្ចាស់ផែនដី) ភ្ជាប់ទៅនឹងកាតព្វកិច្ចការពារប្រជារាស្ត្រពីសត្រូវផ្ទៃក្នុង និងផ្ទៃក្រៅ។ គោលការណ៍សីលធម៌ នៃការប្រមូលពន្ធតម្រូវឱ្យមានអត្រាពន្ធសមរម្យ (មិនតឹងរ៉ឹងជ្រុល) ដោយមានអត្រាខ្ពស់បំផុត ១/៦ និងទាបបំផុត ១/១២ នៃទិន្នផល (ជាពិសេស ស្រូវ និងផលិតផលកសិកម្ម)។ របបពន្ធក្នុងសម័យអង្គរគឺជាប្រព័ន្ធផ្អែកលើការទូទាត់ជាវត្ថុ មិនមែនប្រាក់កាសទេ ដោយប្រជាជនបង់ជាទំនិញឬផលិតផល (មាស ប្រាក់ ស្រូវ ក្រណាត់ ។ល។)។ ប្រភេទពន្ធសំខាន់ៗរួមមាន ពន្ធលើដីធ្លី ដីកសិកម្ម ពន្ធលើពាណិជ្ជកម្ម ឬពន្ធគយ ពន្ធលើមុខរបរ វិជ្ជាជីវៈ និងជាពិសេស គឺពន្ធកម្លាំងពលកម្ម។ រហូតមកដល់សម័យអាណានិគមនិយមបារាំង ការគ្រប់គ្រងថវិការដ្ឋ ត្រូវបានផ្លាស់ប្តូរទាំងស្រុងតាមបែបបទរបស់បារាំង ដោយបានបែងចែកការគ្រប់គ្រងជាពីរ គឺថវិការដ្ឋមជ្ឈមណ្ឌល (Budget central) ដែលស្ថិតក្រោមការត្រួតពិនិត្យរបស់អភិបាលបារាំង និងថវិការចលនាក្នុងខេត្ត (Budgets locaux) សម្រាប់គ្រប់គ្រងការចំណាយនៅតំបន់នានា តាមការអនុម័តរបស់អធិការខេត្តបារាំង។

ប្រទេសកម្ពុជាបានធ្វើដំណើរលើវិថីដ៏វែងឆ្ងាយ ក្នុងការកសាងជាតិរបស់ខ្លួនក្រោយពីបានឆ្លងកាត់ប្រវត្តិសាស្ត្រដ៏ជូរចត់ក្រោមការគ្រប់គ្រងដោយរបបប្រល័យពូជ

សាសន៍ ប៉ុល ពត នៅចុងឆ្នាំ ១៩៧០។ ក្នុងទស្សវត្សរ៍ឆ្នាំ១៩៨០ ប្រទេសកម្ពុជាបានចាប់ផ្តើមស្តារ និងអភិវឌ្ឍប្រទេសឡើងវិញពីបាតដៃទទេ។ ក្នុងកាលៈទេសៈនោះ ដៃម្ខាងត្រូវទប់ស្កាត់ការវិលត្រឡប់មកវិញនៃរបបខ្មែរក្រហម និងដៃម្ខាងទៀត ត្រូវខិតខំកសាងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងធនធានមនុស្សចាំបាច់។ ការរៀបចំការបោះឆ្នោតសកលក្នុងឆ្នាំ ១៩៩៣ បានបើកទំព័រសកវាជីវសម្រាប់ប្រទេសកម្ពុជា។ សម្រាប់នីតិកាលទី១ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ និងចាប់ផ្តើមអនុវត្តកម្មវិធីកែទម្រង់រចនាសម្ព័ន្ធសេដ្ឋកិច្ច ដែលមានរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងក្នុងការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ដែលជាពេលវេលាចាប់យកការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្អែកលើបរិការណ៍នៃការអភិវឌ្ឍកម្ពុជាជាក់ស្តែង និងបទពិសោធន៍ដែលដកស្រង់ពីឧត្តមានុវត្តន៍អន្តរជាតិ។

ការវិវត្តជាបន្តបន្ទាប់បានអនុញ្ញាតឱ្យប្រព័ន្ធច្បាប់កម្ពុជា ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានលក្ខណៈចម្រុះ ដោយម្ខាងគិតទៅលើប្រភពនៃច្បាប់ វិធាននីតិវិធី វិធានស្ថាប័ន រីឯម្ខាងទៀតពិចារណាលើខ្លឹមសារដែលមានគុណភាពក្នុងការអនុវត្តពីបណ្តាប្រទេសដៃគូអភិវឌ្ឍផង និងគិតពីភាពអាចទៅរួចនៃការអនុវត្តជាក់ស្តែងរបស់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាពលរដ្ឋក្នុងនាមជាអ្នកទទួលបានផលប្រយោជន៍រួម។

៤.២. សេចក្តីផ្តើម

ប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលនិងចំណាយរបស់រដ្ឋ គឺជាគន្លឹះក្នុងការរក្សាបាននូវវិន័យថវិកា និងរួមចំណែកដល់ការបង្កើតបរិយាកាសអំណោយផលដល់ការប្រកបអាជីវកម្ម ការរក្សាបាននូវស្តង់ដារស់នៅការលើកកម្ពស់ការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចប្រកបដោយនិរន្តភាព និងការផ្តល់ការការពារទប់ទល់នឹងវិបត្តិហិរញ្ញវត្ថុផ្សេងៗ។ រដ្ឋទទួលបានប្រាក់ចំណូលរបស់ខ្លួនពីចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធទាំងក្នុងស្រុកនិងក្រៅស្រុក រួមបញ្ចូលទាំងប្រាក់កម្ចីនិងជំនួយពីទីភ្នាក់ងារអន្តរជាតិទាំងទ្វេភាគី និងពហុភាគី ហើយរដ្ឋមានតួនាទីប្រើប្រាស់ចំណូលទាំងនោះប្រកបដោយប្រសិទ្ធ

ភាព សមធម៌ និងចីរភាព។ រីឯប្រជាពលរដ្ឋមានកាតព្វកិច្ចរួមចំណែកផ្តល់ប្រាក់ចំណូលជូនដល់រដ្ឋតាមរយៈការបង់ពន្ធ និងបង់ថ្លៃសេវាសាធារណៈផ្សេងៗ។[៤៦៧]

ជាប្រវត្តិសាស្ត្រខ្មែរក្នុងការជ្រើសរើសយកតំបន់អង្គរ ដើម្បីតាំងជារាជធានីគឺមិនមែនជាការចៃដន្យនោះទេ ពោលគឺតំបន់អង្គរជាទីប្រជុំនៃផ្លូវជំនួញទាំងផ្លូវគោក ផ្លូវទឹក ដីមានជីវជាតិសម្រាប់វិស័យកសិកម្ម បឹងទន្លេសាបសម្រាប់ការនេសាទ និងសម្បូរទៅដោយធនធានធម្មជាតិចម្រុះ។ ប្រជារាស្ត្រខ្មែរ ប្រកបរបរធ្វើកសិកម្ម នេសាទ និងសិប្បកម្ម ដើម្បីជីវភាពប្រចាំថ្ងៃ ដោយតាមរយៈសំណេររបស់លោក **ជីវតាក្វាន់** ខ្មែរនៅសម័យអង្គរអាចធ្វើស្រែបានចន្លោះពី ៣ ទៅ ៤ដងក្នុងមួយឆ្នាំ រីឯការគន់គូររបស់លោក Henri Stierlin អ្នកឯកទេសជនជាតិស្វីស បានគណនាថាក្នុងទំហំផ្ទៃដី ១០០០គីឡូម៉ែត្រក្រឡានៅតំបន់អង្គរ អាចផលិតស្រូវបានក្នុងមួយឆ្នាំ ១៥០ ០០០ តោន ដោយអាចចិញ្ចឹមប្រជាជនបាន ៨០០ ០០០នាក់ ចំណែកនៅសល់ ៤០%ទៀត អាចនាំយកទៅផ្តល់ឱ្យតំបន់ផ្សេងៗ។ តាមរយៈការសិក្សាបានបង្ហាញថា ក្នុងសម័យបុរាណមានការបង់ពន្ធជារ ១ភាគ៦ នៃសមិទ្ធផលនានាថ្វាយចំពោះព្រះមហាក្សត្រដែលទ្រង់ជាម្ចាស់ផែនដី ហើយរាល់ព្រះរាជទ្រព្យដែលបានមកពីការយកពន្ធហៅថា **"ព្រះរាជកោសរបស់រដ្ឋ"** ដែលត្រូវទុកក្នុងឃ្លាំងដែលមានពួកឆ្មាំប្រចាំការដោយមន្ត្រីជាន់ខ្ពស់តែងតាំងដោយព្រះរាជបញ្ញត្តិរបស់ព្រះមហាក្សត្រ នៅថែរក្សានិងទទួលខុសត្រូវ។ ពន្ធដែលប្រមូលបានពីប្រជារាស្ត្រជាអភ័យឯកសិទ្ធរបស់ព្រះមហាក្សត្រដែលត្រូវបានប្រើប្រាស់សម្រាប់ការកសាងបូជនីយដ្ឋានធំៗ ជាពិសេសប្រាសាទ វត្តអារាម សម្រាប់ទុកជាកន្លែងសក្ការៈបូជារបស់អាទិទេព ឬព្រះពុទ្ធអង្គ។ ក្រៅពីការយកពន្ធពីប្រជារាស្ត្រ សេដ្ឋកិច្ចនៅក្នុងសម័យបុរាណ ជាពិសេសចក្រភពអង្គរ គឺកើតឡើងតាមរយៈការធ្វើជំនួញ ដោះដូរផលិតផលជាមួយប្រទេសជាមិត្ត ដូចជាការជួញដូរអំបិល ផលនេសាទជាដើម។ ចំពោះចំណាយភាគច្រើនជាកម្លាំងពលកម្ម និងការដោះដូរទំនិញ ត្រូវបានប្រើប្រាស់ក្នុងវិស័យសំណង់ ស្ថាបនាប្រព័ន្ធធារាសាស្ត្រ កងទ័ពនិងការពារព្រំដែនអាណាចក្រ សាសនា ការអប់រំ និងសុខុមាលភាពសាធារណៈតាមរយៈការគ្រប់គ្រងចាត់ចែងដោយព្រះមហាក្សត្រ ជាអំណាចកណ្តាល[៤៦៨]។

---

[៤៦៧] សៀវភៅស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-បទពិសោធន៍កម្ពុជា, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៤

[៤៦៨] អាទិទេពក្រុងអង្គរ, LES DIEUX D'ANGKOR ជាច់ វ៉ាន់ដាត និង កែវ សុកុន

ឆ្លងកាត់ប្រវត្តិសាស្ត្រពីសម័យកណ្តាល (មជ្ឈិមសម័យ) រហូតដល់ដើមទសវត្សរ៍ឆ្នាំ១៩៩០ ប្រទេសកម្ពុជាបានផ្លាស់ប្តូរបន្តិចម្តងៗពីសេដ្ឋកិច្ចផែនការ ឆ្ពោះទៅរកសេដ្ឋកិច្ចទីផ្សារវិញ។ ប្រទេសកម្ពុជាបានបង្កើនការចូលរួមក្នុងសកម្មភាពសមាហរណកម្មក្នុងតំបន់ និងពិភពលោកតាមរយៈការចូលជាសមាជិកអាស៊ាន(ASEAN)នៅក្នុងឆ្នាំ១៩៩៩ និង សមាជិកអង្គការពាណិជ្ជកម្មពិភពលោក(WTO) ក្នុងឆ្នាំ២០០៤។ ក្នុងនោះ វិស័យឯកជនត្រូវបានចាត់ទុកជាកត្តាជំរុញចម្បងដ៏សំខាន់នៃកំណើនសេដ្ឋកិច្ចជាតិ។ សហគ្រាសសាធារណៈត្រូវបានធ្វើឯកជនភាវូបនីយកម្ម ដើម្បីកាត់បន្ថយបន្ទុកបំណុលរបស់រដ្ឋទៅលើរដ្ឋាភិបាល។ ម្យ៉ាងវិញទៀត ការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេសក៏ត្រូវបានជំរុញបន្ថែមទៀតផងដែរ ដើម្បីបង្កើតការងារក្នុងស្រុកនិងជំរុញការនាំចេញទៅក្រៅស្រុក។

បើយោងតាមរបាយការណ៍ពិនិត្យការចំណាយសាធារណៈរបស់កម្ពុជាឆ្នាំ ១៩៩៩ របស់ធនាគារពិភពលោកចាប់តាំងពីឆ្នាំ១៩៩៣ ប្រទេសកម្ពុជាមានវឌ្ឍនភាពមួយចំនួនគួរឱ្យកត់សម្គាល់ ក្នុងនោះរួមមានការរក្សាបានស្ថិរភាពសេដ្ឋកិច្ច ការស្តារកំណើនសេដ្ឋកិច្ចឡើងវិញ និងការធ្វើការកែទម្រង់គោលនយោបាយ ដែលប្រែក្លាយសេដ្ឋកិច្ចកម្ពុជាទៅជាសេដ្ឋកិច្ចទីផ្សារ។ ជាពិសេសអតិផរណាដែលជាមធ្យមប្រមាណ ១៤០% ក្នុងមួយឆ្នាំនៅអំឡុងដើមទសវត្សរ៍ឆ្នាំ១៩៩០ ត្រូវបានកាត់បន្ថយមកត្រឹមតែជាតួលេខ១ខ្ទង់ នៅឆ្នាំ១៩៩៥។ យ៉ាងណាមិញ ក្រោយឆ្នាំ១៩៩៦ ទោះបើមានការខិតខំប្រឹងប្រែងពីរាជរដ្ឋាភិបាលយ៉ាងណាក៏ដោយ ការអនុវត្តការកែទម្រង់ក្របខ័ណ្ឌសារពើពន្ធ និងរចនាសម្ព័ន្ធស្ថាប័នសំខាន់ៗបានជាប់គាំងដោយសារតែកត្តាមួយចំនួន ពិសេសកត្តាខាងក្រៅ។

នៅឆ្នាំ១៩៩៧ វិបត្តិហិរញ្ញវត្ថុនៅអាស៊ីដែលមានដើមកំណើតនៅក្នុងប្រទេសថៃបានជះឥទ្ធិពលអវិជ្ជមានយ៉ាងធ្ងន់ធ្ងរដល់សេដ្ឋកិច្ចក្នុងតំបន់។ ប្រទេសកម្ពុជាក៏បានទទួលរងផលប៉ះពាល់ផងដែរ ប៉ុន្តែផលប៉ះពាល់នោះមានទំហំតូចបើធៀបទៅនឹងបណ្តាប្រទេសផ្សេងៗទៀត ដោយសារប្រទេសកម្ពុជា ជាប្រទេសដែលប្រើប្រាស់រូបិយវត្ថុដុល្លារអាម៉េរិក ហើយម្យ៉ាងវិញទៀតវិស័យហិរញ្ញវត្ថុរបស់ប្រទេសកម្ពុជាក៏នៅមានការអភិវឌ្ឍតិចតួចនៅឡើយ។ យ៉ាងណាមិញ វិបត្តិហិរញ្ញវត្ថុពិភពលោកជាបន្តបន្ទាប់ក្នុងឆ្នាំ២០០៨ ដល់ឆ្នាំ២០០៩ បានជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរ ដល់ដំណើរការអភិវឌ្ឍសេដ្ឋកិច្ចប្រទេសកម្ពុជា។ ការជះឥទ្ធិពលអវិជ្ជមាននេះ ជាចម្បងដោយសារការធ្លាក់ចុះ នៃតម្រូវការការនាំចេញសម្លៀកបំពាក់ដែលជាការនាំចេញដ៏ធំរបស់កម្ពុជា។ ការធ្លាក់ចុះនេះ ក៏បានធ្វើឱ្យប្រជាជនបាត់បង់ការងារជាច្រើនផងដែរមុនសេដ្ឋកិច្ចមានការងើបឡើងវិញនៅឆ្នាំបន្ទាប់។

ថ្វីត្បិតតែមានវិបត្តិ និងការត្រឡប់ថយក្រោយជាបន្តបន្ទាប់ក៏ដោយ ក៏ប្រទេសកម្ពុជា នៅតែជាប្រទេសមួយដែលមានសេដ្ឋកិច្ចរីកចម្រើនយ៉ាងឆាប់រហ័សនៅលើពិភពលោក ដោយគិតចាប់ពីឆ្នាំ២០០៤មក កម្ពុជាមានកំណើនសេដ្ឋកិច្ចល្អ ក្នុងរង្វង់ ៧% ក្នុងមួយឆ្នាំ ជាមួយនឹងការរក្សាបាននូវអត្រាអតិផរណាទាប ក្នុងរង្វង់ ៣% ប្រចាំឆ្នាំ និងអត្រាប្តូរប្រាក់ទាបមានស្ថិរភាព ដែលនេះបានកើតចេញពីការកំណត់ច្បាស់លាស់នូវកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា តាមអភិក្រម កែទម្រង់ដោយបោះជំហានជាដំណាក់កាល តាមការសាកល្បង ចាប់តាំងពីដំណាក់កាលទី១ (២០០៤-២០០៨) គឺបញ្ហាកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ រហូតមកដល់ការសម្រេចបាននូវកំណើនសេដ្ឋកិច្ចដ៏រឹងមាំ និងប្រកបដោយភាពធន់ និងចីរភាពក្នុងរយៈពេលវែង។

៤.២. និតិហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

៤.២.១. ប្រវត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា

៤.២.១.១. សម័យបុរេប្រវត្តិ ហ្វូណន និងចេនឡា

នៅក្នុងសម័យបុរេប្រវត្តិសាស្ត្រ សេដ្ឋកិច្ចនិងសង្គមជីវិតរបស់ប្រជាជនខ្មែរ គឺមានលក្ខណៈសាមញ្ញ ប៉ុន្តែបែងចែកអំណាចជាវណ្ណៈលក្ខណៈទូលាយ ដោយមានវណ្ណៈកម្មករ ឬទាសករ ប្រើប្រាស់កម្លាំងដើម្បីជីវភាព ដូចជាធ្វើការជាអ្នកបម្រើ អ្នកកែច្នៃត្បាញវៃ អ្នកធ្វើក្អមឆ្នាំង ធ្វើស្រែចម្ការ បរបាញ់សត្វ នេសាទ ចិញ្ចឹមសត្វ ជាងដែក ជាងមាស ជាងស្មូន រីឯអ្នកអភិជន ធ្វើជំនួញជួញដូរ ផ្លាស់ប្តូរទំនិញ ជាពាណិជ្ជកម្ម ដូចជាអំបិល ត្រី គ្រឿងលម្អ ឧបករណ៍សិល្បៈជាដើម។ ភស្តុតាងពីរបៀបរស់នៅក្នុងស្ថានីយបន្ទាយគូនៃអរិយធម៌មេមត់ ស្នាមព្រែកជីកបរមបុរាណ និងគូទឹកនៃបន្ទាយគូ ឬភូមិមូល គឺបង្ហាញពីរបៀបនៃការរៀបចំសហគមន៍ កសាងរដ្ឋ របៀបគ្រប់គ្រងចាត់ចែងការងារបានច្បាស់លាស់ទាំងធនធានមនុស្ស និងចរន្តសេដ្ឋកិច្ចក្នុងសម័យបុរេប្រវត្តិ ឬសម័យនគរភ្នំដោយមានកំណត់ត្រាខ្លះបានបង្ហាញថាមានការយកប្រាក់ពន្ធ សង្គមត្រូវបង់ពន្ធជាប្រាក់ មាស គុជខ្យង និងឈើក្រអូបជាដើម។ រហូតមកដល់សម័យហ្វូណន សេដ្ឋកិច្ចប្រទេស ពឹងផ្អែកលើកសិកម្ម និងពាណិជ្ជកម្មតាមរយៈការអនុវត្តនយោបាយទឹក ប្រើប្រាស់វិធីជីកព្រែកជាលក្ខណៈប្រព័ន្ធស្រោចស្រព សម្រាប់បង្ហូរទឹកជំនន់ពីទន្លេមេគង្គ ទៅលាងបន្សាបជាតិអំបិលលើដីសម្រាប់យកដីល្បាប់មានជីជាតិ និងជាផ្លូវគមនាគមន៍ និងសម្រាប់ធ្វើស្រែក្នុងមួយឆ្នាំបីដង ព្រមទាំងដំណាំកសិកម្មដូចជាការដាំក្រូច ទទឹម អំពៅ ស្លា។ ជាមួយគ្នានេះ វិស័យពាណិជ្ជកម្មក៏មានការរៀបចំបានល្អប្រសើរ តាមរយៈការកសាងកំពង់ផែសមុទ្រ (កំពង់ផែ

អូកែវ) ជាកំពង់ផែអន្តរជាតិសម្រាប់ការដោះដូរទំនិញជាមួយបណ្តាប្រទេសជាច្រើនតាមរយៈកំណាយប្រវត្តិសាស្ត្រ ដូចជាសម្ភារនៃចក្រភពរ៉ូម៉ាំង ចក្រភពអ៊ីរ៉ង់ ឥណ្ឌា ចិន ជាមួយនឹងទំនិញរបស់ខ្មែរដូចជាមាស ប្រាក់ សំពត់ព្រៃ គ្រឿងកែវកង ទង់ដែក សំណបាហាំង គ្រឿងក្រអូប ភ្នុកដំរី សូត្រ ស្លកែវ។ល។ នាសម័យនោះ ព្រះមហាក្សត្រផ្តល់ព្រះរាជទ្រព្យនិងថ្វាយជាដីធ្លី ទ្រព្យសម្បត្តិផ្សេងៗ ជាខ្ញុំបម្រើ ដល់បូជនីយដ្ឋានសាសនា ការសាងសង់ផ្លូវ ការជីកស្រះទឹករួម និងជីកប្រឡាយ សម្រាប់បំរើផលប្រយោជន៍សាធារណៈ រីឯអ្នកស្រុកត្រូវបង់ពន្ធជូនរាជការជាមាស ប្រាក់ ត្បូង គុជ ឬគ្រឿងក្រអូបផ្សេងៗ តាមរយៈច្បាប់ទំនៀមក្នុងវិស័យពន្ធដារមួយច្បាស់លាស់ ដែលកំណត់អត្រាពន្ធដារ វិធីសាស្ត្រប្រមូលពន្ធ ការគ្រប់គ្រងនិងបែងចែកប្រាក់ពន្ធ និងចាត់វិធានការចំពោះអ្នកមិនព្រមបង់ពន្ធដារ (កំណត់ត្រាចិន)។ នៅក្នុងសម័យចេនឡា ចាប់ផ្តើមនៅឆ្នាំ៥៥០ នៃគ្រិស្តរាជដល់ឆ្នាំ៨០២នៃគ.ស. វិស័យសេដ្ឋកិច្ច ពាណិជ្ជកម្ម សិប្បកម្ម កសិកម្ម នៅបន្តអនុវត្តដូចសម័យហ្វូណន តាមរយៈការកសាងទីក្រុងធំៗនៅក្បែរមាត់ស្ទឹងសែន ការបង្ហូរទឹកចូលក្នុងស្រះព័ន្ធជុំវិញ កសាងអាងទឹក ដើម្បីអនុវត្តគោលនយោបាយទឹកសម្រាប់ពង្រីកការដាំដំណាំ។ សិលាចារឹកជាច្រើនបានបង្ហាញពីការបរិច្ចាកទាន និងព្រះរាជទ្រព្យ ដីធ្លី ជាទ្រព្យសម្បត្តិផ្សេងៗ ជាខ្ញុំបម្រើដល់បូជនីយដ្ឋានសាសនា សម្រាប់បម្រើជាប្រយោជន៍រួមរបស់សង្គម ហើយទីតាំងទាំងនោះក៏ត្រូវបានលើកលែងការបង់ពន្ធទាំងស្រុងផងដែរ។ ចំពោះកាតព្វកិច្ចរបស់អ្នកស្រុក គឺការបង់ពន្ធជូនរាជការ ដូចជាមាស ប្រាក់ ត្បូង គុជ គ្រឿងក្រអូបផ្សេងៗ ឬបង់ពន្ធជាកសិផល។ ច្បាប់ទំនៀម បានកំណត់អំពីអត្រាពន្ធដារ នីតិវិធីប្រមូល ការគ្រប់គ្រងនិងបែងចែក និងការចាត់វិធានការចំពោះអ្នកមិនបង់ពន្ធ។ ជារួមក្នុងសម័យចេនឡា សង្គមខ្មែរ មានច្បាប់ទំនៀមសម្រាប់គ្រងគ្រងប្រទេសជាច្រើនវិស័យ ដូចជាសញ្ញាណនៃកិច្ចការរដ្ឋបាល នគរូបនីយកម្ម កិច្ចការពន្ធដារ កិច្ចការមត៌ក កិច្ចការព្រហ្មទណ្ឌ ប៉ុន្តែជាការសោកស្តាយពុំមានឯកសារសំណេជាក់លាក់គ្រប់ជ្រុងជ្រោយនោះទេ។

៤.២.១.២. សម័យអង្គរ

នៅក្នុងសម័យអង្គរវិស័យសេដ្ឋកិច្ចមិនពឹងផ្អែកទាំងស្រុងលើលើកសិកម្មនោះទេ ពោលគឺចរន្តសេដ្ឋកិច្ចត្រូវបានរួមផ្សំគ្នារវាងកសិកម្ម សិប្បកម្ម ជាទម្រង់ឧស្សាហកម្ម ការធ្វើពាណិជ្ជកម្ម ជាមួយនឹងប្រព័ន្ធប្រមូលពន្ធដារច្បាស់លាស់។ ចក្រភពអង្គរបានអនុវត្តប្រព័ន្ធពន្ធដារ ដើម្បីធានាការគ្រប់គ្រងធនធានពីបណ្តានគរណាបចំណុះខ្លួន ដើម្បីកសាងហេដ្ឋារចនាសម្ព័ន្ធ កិច្ចការរដ្ឋបាល កិច្ចការកងទ័ព ទ្រទ្រង់អំណាចនិងភាពរុងរឿងរបស់ចក្រភព។

ទម្រង់នៃការប្រមូលពន្ធរួមមាន (១). ពន្ធលើដីធ្លី៖ ប្រជាកសិករត្រូវបង់ផលដំណាំមួយចំណែក ឬទិន្នផលកសិកម្មផ្សេងទៀតទៅឱ្យរដ្ឋ ឬមន្ត្រីមូលដ្ឋាន (២). ពន្ធលើផលិតផល៖ ប្រជាសិប្បករត្រូវបង់ផលិតផលដែលខ្លួនផលិតបានមួយចំណែកជូនរាជការ (៣). ពន្ធលើកម្លាំងពលកម្ម៖ ប្រជានុរាស្ត្រមានកាតព្វកិច្ចបម្រើការងារសាធារណៈ ដូចជាការសាងសង់ប្រាសាទ ទំនប់ទឹក ផ្លូវថ្នល់ ឬកិច្ចការផ្សេងៗទៀតសម្រាប់រដ្ឋដំនួសឱ្យការបង់ពន្ធជាប្រាក់ឬវត្ថុ និង (៤). ពន្ធលើពាណិជ្ជកម្ម៖ ពាណិជ្ជករទាំងក្នុងស្រុក និងក្រៅស្រុកត្រូវបង់ពន្ធលើទំនិញដែលពួកគេធ្វើពាណិជ្ជកម្ម ទាំងការនាំចេញ និងនាំចូល។ នៅក្នុងសម័យនោះ រាជការបានបែងចែកក្រុមមន្ត្រីត្រួតពិនិត្យពន្ធដារ ដោយដាក់នាមថា "ខ្លោញ" ដូចជា ខ្លោញស្រូវ ខ្លោញសណ្តែក ខ្លោញល្ង ខ្លោញក្រមួន ខ្លោញប្រេង ខ្លោញមុខ ខ្លោញការ្យ កំស្តេងត្រួតអំបិល (មានតួនាទីធំលើការត្រួតពិនិត្យនិងគ្រប់គ្រងការប្រមូលពន្ធអំបិល) និងឆ្មាំព្រះបញ្ជី (ទទួលបន្ទុកកត់ត្រា ចុះបញ្ជី និងគ្រប់គ្រងថែរក្សាបញ្ជីទ្រព្យរបស់ប្រាសាទ ឃ្លាំងជាដើម។

ជារួមច្បាប់អនុវត្តក្នុងវិស័យពន្ធដារបានកំណត់គោលការណ៍ច្បាស់លាស់នៅក្នុងគម្ពីរព្រះធម៌សាស្ត្រ និងអច់សាស្ត្រដោយចែងថាការយកពន្ធអាករជាសិទ្ធិដ៏ពិសិដ្ឋរបស់ព្រះមហាក្សត្រ (ក្នុងនាមជាម្ចាស់ផែនដី) ភ្ជាប់ទៅនឹងកាតព្វកិច្ចការពារប្រជារាស្ត្រពីសត្រូវផ្ទៃក្នុង និងខាងក្រៅ។ គោលការណ៍សីលធម៌ នៃការប្រមូលពន្ធតម្រូវឱ្យមានអត្រាពន្ធសមរម្យ ដោយអត្រាខ្ពស់បំផុត ១/៦ និងទាបបំផុត ១/១២ នៃទិន្នផល(ស្រូវ និងផលិតផលកសិកម្ម)។ របបពន្ធនៅក្នុងសម័យអង្គរ គឺជាប្រព័ន្ធផ្អែកលើការទូទាត់ជាវត្ថុ មិនមែនប្រាក់កាក់ទេ ដោយប្រជាជនបង់ជាទំនិញឬផលិតផល (មាស ប្រាក់ ស្រូវ ក្រណាត់ និងប្រភេទពន្ធសំខាន់ៗមួយចំនួនទៀតរួមមាន ពន្ធលើដីធ្លី ដីកសិកម្ម ពន្ធលើពាណិជ្ជកម្ម ឬពន្ធគយ ពន្ធលើមុខរបរ វិជ្ជាជីវៈ ជាពិសេសពន្ធកម្លាំងពលកម្មឬថ្វៃព្រះរាជកាយ៌្យ (បង់ឬផ្តល់កម្លាំងពលកម្មជូនរាជការ) ជាកាតព្វកិច្ចដែលប្រជាជនត្រូវផ្តល់ដល់រាជការ ដោយត្រូវប្រើប្រាស់សម្រាប់ការងារសាធារណៈការងារកងទ័ពជាដើម។

៤.២.១.៣. សម័យកណ្តាល

សម័យកណ្តាលចាប់ផ្តើមនៅឆ្នាំ១៤៣១ ដល់ឆ្នាំ១៨៦៣ ដែលជាដំណាក់កាលដ៏វឹកវរ និងជូរចត់បំផុតមួយក្នុងប្រវត្តិសាស្ត្រខ្មែរ ដោយរាជធានីខ្មែរត្រូវបានផ្លាស់ប្តូរទៅកាន់តំបន់ផ្សេងៗគ្នា ដូចជាទួលបាសាន ចតុមុខ លង្វែក ឧដុង្គ និងភ្នំពេញ-ចតុមុខ ដែលនាំឱ្យអំណាចកណ្តាលនៃរាជាធិបតេយ្យធ្លាក់ចុះ។ នៅក្នុងសម័យនេះ ការអនុវត្តច្បាប់

មានលក្ខណៈស្រដៀងគ្នានឹងសម័យអង្គរ ប៉ុន្តែមានភាពល្អប្រសើរដោយមានព្រះរាជក្រមក្បួនច្បាប់គ្រប់គ្រង។ ប្រព័ន្ធច្បាប់កម្ពុជាសម័យកណ្តាល រួមទាំងប្រព័ន្ធសេដ្ឋកិច្ច ត្រូវបានកែលម្អ បង្កើត និងដំណើរការដោយរួមបញ្ចូលគ្នារវាងច្បាប់ នយោបាយ វប្បធម៌ ទំនៀមទម្លាប់ ជំនឿ សាសនា និងឥទ្ធិពលសៀម យួន ហើយក៏បានចាប់ផ្តើមទន់ខ្សោយ និងបាត់បង់អធិបតេយ្យភាពមួយផ្នែក ទៅតាមការដឹកនាំរបស់ព្រះមហាក្សត្រនីមួយៗ។

៤.២.១.៤. សម័យទំនើប

លុះមកដល់សម័យអាណានិគមបារាំងឆ្នាំ១៨៦៣ ដល់ឆ្នាំ ១៩៥៣ កំណែទម្រង់ជាច្រើនក្នុងការគ្រប់គ្រងរដ្ឋ ត្រូវបានចាត់ចែង រៀបចំ ធ្វើទំនើបកម្ម ដោយបារាំងរួមមានវិស័យរដ្ឋបាល តុលាការ ហិរញ្ញវត្ថុ និងពាណិជ្ជកម្ម។ ដីធ្លីដែលធ្លាប់ជាកម្មសិទ្ធរបស់ព្រះមហាក្សត្រ ត្រូវបានអាជ្ញាធរបារាំងកែប្រែ រៀបចំឱ្យក្លាយជាកម្មសិទ្ធិឯកជនហើយក្នុងពេលនោះការប្រមូលពន្ធជាបញ្ហាធំបំផុតដែលជាក់សម្ពាធលើប្រជារាស្ត្រខ្មែរ រួមមានការបង្ខំយកពន្ធស្រូវ ពន្ធមនុស្ស ពន្ធដីធ្លី ពន្ធសត្វពាហនៈ ពន្ធលើយានយន្តជាដើម ដោយអាជ្ញាធរបារាំង ជាអ្នកគ្រប់គ្រងផ្ទាល់ លើក្រសួងគយ ពន្ធដារ ក្រសួងសាធារណៈការ និងក្រសួងឯទៀត។ ចំណែកឯរាល់ការចំណាយរបស់រាជការខ្មែរ និងរបស់រដ្ឋការបារាំង ជាបន្ទុករបស់រដ្ឋាភិបាលខ្មែរ រួមមានការចំណាយលើការគ្រប់គ្រងរដ្ឋបាលនិងយោធា សេវាសាធារណៈនិងសំណង់ អប់រំនិងសង្គម បំណុលនិងថ្លៃគាំទ្របារាំង(កម្ពុជាត្រូវបង់ថ្លៃសេវាដល់រដ្ឋបារាំងក្នុងនាមជាប្រទេសអាណានិគម) រីឯ ព្រះមហាក្សត្រត្រូវទទួលប្រាក់បៀវត្សដែលមានកម្រិតជាក់លាក់ និងមិនអាចខ្វីប្រាក់ដោយគ្មានការយល់ព្រមពីរដ្ឋាភិបាលបារាំងឡើយ។ ពេលវេលានោះហើយ ដែលកម្ពុជាចាប់ផ្តើមធ្វើទំនើបភាវូបនីយកម្មប្រព័ន្ធច្បាប់ ដែលបានផ្លាស់ប្តូរទាំងគុណតម្លៃ ជំនឿ សាសនា និងទស្សនវិជ្ជា ជាពិសេសការប្រតិបត្តិរបស់អ្នកដឹកនាំ និងអ្នកប្រតិបត្តិច្បាប់ ដែលធ្លាប់តែប្រកាន់យកការអប់រំចិត្តបដិបត្តិនូវសតិប្បដ្ឋាន សម្រាប់ការបណ្តុះសមាធិ ពង្រីកបញ្ញាញាណ មកជាការប្រតិបត្តិទស្សនវិជ្ជាលោកខាងលិច តាមបែបបារាំង ដែលជាការបណ្តុះគំនិត ជជែកវែកញែក និងបង្កើតនូវមហិច្ឆតាសម្ភារនិយមសម្រាប់រៀបចំការងារច្បាប់តាមរបៀប Conventional truth។ [៤៦៩]

---

៤៦៩ សៀវភៅប្រវត្តិសាស្ត្រនៃប្រទេសកម្ពុជា ពីសម័យអាណានិគមបារាំងឆ្នាំ១៨៦៣ ដល់ ១៩៩២ វ៉ាន់ឌី កាអុន

បន្ទាប់ពីទទួលបានឯករាជ្យពីប្រទេសបារាំង នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ កម្ពុជាបានឆ្លងកាត់នូវប្រវត្តិដូរចត់ ដែលបានធ្វើឱ្យមានការផ្លាស់ប្តូរភ្លាមៗនូវរបបនយោបាយ និងគោលនយោបាយសេដ្ឋកិច្ច។ ក្នុងរបបសង្គមរាស្ត្រនិយម (១៩៥៣ ដល់ ១៩៧០) រដ្ឋបានយកចិត្តទុកដាក់លើវិស័យកសិកម្ម ដោយជំរុញគោលនយោបាយបង្កើនទិន្នផលស្រូវតាមរយៈការកសាងប្រព័ន្ធធារាសាស្ត្រប្រកបដោយភាពច្នៃប្រឌិត រីឯវិស័យឧស្សាហកម្ម ទទួលបានជំនួយសេដ្ឋកិច្ចពីប្រទេសឆេកូស្លូវ៉ាគី ជប៉ុន អូស្ត្រាលី ចិន បារាំង និងសហភាពសូវៀត រួមមានវាយនភ័ណ្ឌ កញ្ចក់ សំបកកង់ កៅស៊ូ ស្ករ ជាដើម។ លើសពីនេះ ប្រាក់រៀលខ្មែរ ក៏ត្រូវបានចេញផ្សាយដំបូងនៅខែកញ្ញា ឆ្នាំ១៩៥៥ ដែលត្រូវបានគ្រប់គ្រងដោយប្រុងប្រយ័ត្នដោយធនាគារជាតិ សម្រាប់ចំណាយលើការអភិវឌ្ឍក្នុងវិស័យអប់រំ សុខាភិបាល និងហេដ្ឋារចនាសម្ព័ន្ធ។

ក្នុងរបបសាធារណៈខ្មែរ (១៩៧០ ដល់ ១៩៧៥) សេដ្ឋកិច្ចរបស់កម្ពុជា ត្រូវបានគេហៅថា "សេដ្ឋកិច្ចសម័យសង្គ្រាម" ទោះបីជារដ្ឋបានបន្តខិតខំប្រឹងប្រែងធ្វើសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងអនុវត្តកម្មវិធីកែទម្រង់គ្រប់ជ្រុងជ្រោយរក្សាគោលនយោបាយអព្យាក្រឹត្យយ៉ាងតឹងរឹងនិងបន្តយកជំនួយពីបរទេសយ៉ាងណាក៏ដោយ ក៏អស្ថិរភាពនយោបាយផ្ទៃក្នុងបាននាំឱ្យកម្ពុជាធ្លាក់ក្នុងសង្គ្រាមស៊ីវិល។

របបកម្ពុជាប្រជាធិបតេយ្យឬរបបខ្មែរក្រហម (១៩៧៥ ដល់ ១៩៧៩) ប្រព័ន្ធសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវបានបំផ្លិចបំផ្លាញទាំងស្រុង។ របបនេះបានផ្លាស់ប្តូរប្រព័ន្ធសង្គម និងសេដ្ឋកិច្ច ដោយធ្វើឱ្យកម្ពុជាមិនមានរូបិយប័ណ្ណផ្ទាល់ខ្លួន គ្មានធនាគារ គ្មានប្រតិបត្តិការរូបិយវត្ថុ និងគ្មានសាលារៀន។ របបនេះបានព្យាយាមកសាងសេដ្ឋកិច្ចរបស់ខ្លួន ដោយផ្អែកលើវិស័យកសិកម្ម គាំទ្រសហគ្រាសធុនតូច និងសិប្បកម្មក្នុងស្រុក ដោយគោលបំណងគោលនយោបាយសេដ្ឋកិច្ចគឺប្រើប្រាស់ចំណូលពីកសិកម្ម គាំទ្រដល់ការអភិវឌ្ឍវិស័យឧស្សាហកម្ម ហើយចំណូលពីវិស័យឧស្សាហកម្ម ទៅគាំទ្រវិស័យកសិកម្ម ដែលបានក្លាយជាបរាជ័យយ៉ាងដំណំ បង្កជាភាពអត់ឃ្លាន និងបណ្តាលឱ្យមនុស្សរាប់លាននាក់ស្លាប់បាត់បង់ជីវិត នៅទូទាំងប្រទេស។

ការបង្កើតសាធារណរដ្ឋប្រជាមានិតកម្ពុជានៅខែមករា ឆ្នាំ១៩៧៩ បានក្លាយជាដំណាក់កាលថ្មីមួយក្នុងការស្តារ និងកសាងប្រទេសជាតិឡើងវិញ។ ក្នុងនោះ ប្រទេសកម្ពុជាបានប្រើប្រាស់ផែនការសេដ្ឋកិច្ចតាមបែបសូវៀតពេញមួយទសវត្សរ៍ទី៨០ របស់ខ្លួន។ ប្រព័ន្ធសេដ្ឋកិច្ចនេះ ត្រូវបានបែងចែកទៅជា ៣ រួមមាន៖ (១) "**សេដ្ឋកិច្ចរដ្ឋ**" គ្របដណ្តប់ទៅលើ

ផលិតកម្មកសិកម្មទ្រង់ទ្រាយធំ ផលិតកម្មឧស្សាហកម្ម ទំនាក់ទំនង បណ្តាញដឹកជញ្ជូន និង ពាណិជ្ជកម្មបរទេសទាំងឡាយ ដែលស្ថិតនៅក្នុងបរិយាកាសប្រតិបត្តិការសេដ្ឋកិច្ច ដែលមាន ការគ្រប់គ្រង និងសម្របសម្រួលត្រឹមត្រូវ។ (២) "**សេដ្ឋកិច្ចសមូហភាព**" គ្របដណ្តប់លើការ ស្តារ និងអភិវឌ្ឍន៍កសិកម្ម ព្រៃឈើ និងសិប្បកម្ម និងការងារទាំងឡាយ ដែលទាក់ទងទៅ នឹងការទិញ និងលក់ដែលមានលក្ខណៈជាសមូហភាព។ ចុងក្រោយ (៣) "**សេដ្ឋកិច្ចបែប គ្រួសារ**" ដែលគ្របដណ្តប់លើសេដ្ឋកិច្ចតាមផ្ទះរបស់កសិករ អាជីវកម្មលក់រាយ សិប្បករ បុគ្គល ហាងជួសជុលសិប្បកម្ម និងពាណិជ្ជកម្មខ្នាតតូចជាដើម។

ជារួមចាប់តាំងពីពាក់កណ្តាលទសវត្សរ៍ទី៨០ ប្រទេសកម្ពុជាបានធ្វើការកែទម្រង់ ឆ្ពោះទៅកាន់សេដ្ឋកិច្ចទៅផ្សារ ដោយពុះពារឆ្លងកាត់កំណាត់ផ្លូវដ៏សែនលំបាកជាច្រើន គន្លាក់ និងឧបសគ្គគ្រប់បែបយ៉ាង រហូតបានឈានដល់ចំណុចរបត់ឥតថយក្រោយមួយនៅ ឆ្នាំ១៩៨៩ ហើយបានបន្តបោះជំហានទៅមុខ កាន់តែលឿនថែមទៀតក្រោយពីការបោះឆ្នោត ជាសកលលើកទី១ និងជាប្រវត្តិសាស្ត្រនៅឆ្នាំ១៩៩៣។

៤.២.២. បរិវត្តកម្មនៃហិរញ្ញវត្ថុសាធារណៈកម្ពុជា

ប្រទេសកម្ពុជា បានរៀបចំការបោះឆ្នោតសកលលើកដំបូងនៅខែឧសភា ឆ្នាំ ១៩៩៣ បន្ទាប់ពីបានបញ្ចប់កិច្ចព្រមព្រៀងទីក្រុងប៉ារីស ហើយឈានទៅដល់ការបញ្ចប់ ជម្លោះផ្ទៃក្នុងរបស់ខ្លួន ដែលមានរយៈកាលជិត២ ទសវត្សរ៍កន្លងមក។ រាជរដ្ឋាភិបាល នីតិ កាលទី១ នៃរដ្ឋសភាបានចាប់ផ្តើមរៀបចំអនុវត្តកម្មវិធីកែទម្រង់គោលនយោបាយម៉ាក្រូ សេដ្ឋកិច្ច និងកំណែទម្រង់រចនាសម្ព័ន្ធប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយទន្ទឹមនឹងការ ខិតខំយ៉ាងសកម្មលើការងារសមាហរណកម្មសេដ្ឋកិច្ចកម្ពុជាទៅក្នុងតំបន់និងសាកល លោក រហូតបានក្លាយជាសមាជិកអាស៊ាន និងសមាជិកអង្គការពាណិជ្ជកម្មពិភពលោក។ ជាបន្តបន្ទាប់ រាជរដ្ឋាភិបាលបានសម្រេចនូវលទ្ធផលជាវិជ្ជមានគួរជាទីមោទនៈក្នុងកិច្ចការ កែទម្រង់សេរីភាវូបនីយកម្ម និងស្តារភាវូបនីយកម្មសេដ្ឋកិច្ច ដែលបានធ្វើឱ្យសេដ្ឋកិច្ច ទាំងមូលមានការរីកចម្រើនយ៉ាងលឿនក្នុងអំឡុងពេលដើមទស្សវត្សឆ្នាំ៩០ ក្នុងកំណើន សេដ្ឋកិច្ចប្រចាំឆ្នាំជាមធ្យមម្រេចបានប្រមាណ៦ ទៅ៧ភាគរយ ហើយអតិផរណាក៏ត្រូវ កាត់បន្ថយ និងរក្សាឱ្យនៅកម្រិត ៥ភាគរយ។ ជាក់ស្តែង សេចក្តីព្រាងច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុ ត្រូវបានរៀបចំឡើងតាំងពីឆ្នាំ១៩៨៩ ក្នុងសម័យរដ្ឋកម្ពុជា ដូច្នេះនៅដើមនីតិ កាលទី១ នៃរដ្ឋសភា សេចក្តីព្រាងច្បាប់នេះត្រូវបានសភាពិនិត្យ និងអនុម័ត។ ក្រសួង សេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានបង្កើតឡើងតាមព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨

ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ និងបានដាក់ចេញនូវសកម្មភាពជាក់ស្តែងជាច្រើន ក្នុងគោលដៅពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសាធារណៈ និងបង្កើតឡើងនូវប្រព័ន្ធអភិបាលកិច្ចល្អដែលរួមមាន៖ វិធានការគ្រប់គ្រងយ៉ាងម៉ឺងម៉ាត់នូវក្របខ័ណ្ឌគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច វិធានការកែលម្អប្រព័ន្ធថវិកា វិធានការទំនើបភាវូបនីយកម្ម ប្រព័ន្ធសារពើពន្ធ វិធានការកែលម្អប្រព័ន្ធគណនេយ្យសាធារណៈ ការបង្កើតប្រព័ន្ធសវនកម្ម ឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ និងវិធានការពង្រឹងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋជាដើម។ នៅក្នុងនីតិកាលទី១ នៃរដ្ឋសភា សមិទ្ធផលជាច្រើនបានសម្រេចក្នុងក្របខ័ណ្ឌច្បាប់និងលិខិតបទដ្ឋានគតិយុត្តវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចជា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុឆ្នាំ១៩៩៣ រួមនិងការវិសោធនកម្មនៃច្បាប់ ច្បាប់ស្តីពីសារពើពន្ធឆ្នាំ១៩៩៧ អនុក្រឹត្យលេខ៦០ ស្តីពីការគ្រប់គ្រងលទ្ធកម្មសាធារណៈ អនុក្រឹត្យលេខ៨១ ស្តីពីការបង្កើតការត្រួតពិនិត្យហិរញ្ញវត្ថុលើចំណាយថវិការដ្ឋនៅតាមក្រសួង ខេត្ត ក្រុង និងអង្គភាពសាធារណៈរដ្ឋបាល អនុក្រឹត្យលេខ៨២ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងបណ្តាច្បាប់ និងអនុក្រឹត្យស្តីពីឯកជនភាវូបនីយកម្មជាដើម។ លើសពីនេះ ប្រព័ន្ធធនាគារត្រូវបានបង្កើតឡើងជាពីរថ្នាក់ ហើយក្រដាសប្រាក់ថ្មីត្រូវបានបំពេញឱ្យប្រើដើម្បីជំរុញបដិដុល្លារូបនីយកម្មឯគម្លាតរវាងអត្រាប្តូរប្រាក់ផ្លូវការ និងទីផ្សារក៏ត្រូវបានកាត់បន្ថយជាច្រើន។ ចំណែកឯ របាំងមិនមែនពន្ធគយត្រូវបានលុបចោល និងពង្រឹងរចនាសម្ព័ន្ធពន្ធដារឡើងវិញ ដើម្បីជំរុញវិនិយោគក្នុងប្រទេស។

នៅក្នុងនីតិកាលទី២ នៃរដ្ឋសភា រាជរដ្ឋាភិបាលបានប្រកាសដាក់ឱ្យប្រើប្រាស់យុទ្ធសាស្ត្រត្រីកោណ ដែលផ្តោតការយកចិត្តទុកដាក់លើ (១). ការធានានូវសន្តិភាព ស្ថិរភាព និងសន្តិសុខ ជូនប្រទេសជាតិ និងប្រជាពលរដ្ឋ (២). ការធ្វើសមាហរណកម្មប្រទេសកម្ពុជា ចូលក្នុងក្របខ័ណ្ឌតំបន់ និងប្រក្រតីភាវូបនីយកម្មទំនាក់ទំនងជាមួយសហគមន៍អន្តរជាតិទាំងមូល និង(៣). ការអភិវឌ្ឍប្រទេស តាមរយៈភាពអនុគ្រោះដែលបានមកពីការអនុវត្តយុទ្ធសាស្ត្រទាំងពីរខាងលើ។ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានដើរតួនាទីយ៉ាងសំខាន់ ក្នុងការអនុវត្តយុទ្ធសាស្ត្រត្រីកោណ ជាពិសេសក្នុងកិច្ចការកែទម្រង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ រួមមានការពង្រឹងអភិបាលកិច្ច ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ការពង្រឹងប្រព័ន្ធធនាគារ និងហិរញ្ញវត្ថុ ការអនុវត្តការកែទម្រង់សារពើពន្ធ ការកែលម្អការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ការបង្កើនការវិនិយោគទៅលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គមការជំរុញការអភិវឌ្ឍន៍វិស័យឯកជន និងការអភិវឌ្ឍធនធានមនុស្ស។ ចំពោះការកែ

ទម្រង់ហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បានបើកការដ្ឋានកែទម្រង់លើបួនមុខព្រួញសំខាន់ៗដូចជា (១). ការកែទម្រង់រដ្ឋបាលនិងគោលនយោបាយគយ (២). ការកែទម្រង់រដ្ឋបាល និងគោលនយោបាយពន្ធដារ (៣). ការកែទម្រង់ប្រតិបត្តិការរតនាគារជាតិ និង (៤). ការកែទម្រង់ការរៀបចំ និងប្រតិបត្តិការថវិកា។

ជាក់ស្តែងនៅថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៤ ប្រមុខរាជរដ្ឋាភិបាល បានប្រកាសយកការពង្រឹងអភិបាលកិច្ច ធ្វើជាចំណុចស្នូល និងជាបេះដូងនៃយុទ្ធសាស្ត្រកែទម្រង់សម្រាប់អភិវឌ្ឍវិស័យសេដ្ឋកិច្ចនិងសង្គមកិច្ច ដែលកើតចេញពីការបោះឆ្នោតសកលខែកក្កដា ឆ្នាំ២០០៣ ដែលកិច្ចការនេះស្របទៅនឹងផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ចឆ្នាំ ២០០១-២០០៥ យុទ្ធសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ២០០៣-២០០៥ និងយុទ្ធសាស្ត្រចតុកោណ ដើម្បីកំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជារបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នាសម័យកាលនោះ។ គោលដៅនៃការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ គឺដាក់ចេញនូវកម្រិតស្តង់ដានៃការគ្រប់គ្រង និងគណនេយ្យភាពឱ្យកាន់តែខ្ពស់ថែមទៀត ក្នុងការកៀរគររាល់ប្រភពធនធានចរន្ត និងមូលធនរបស់រាជរដ្ឋាភិបាល ព្រមទាំងការប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនូវបណ្តាធនធានក្នុងកិច្ចប្រតិបត្តិការអនុវត្តយុទ្ធសាស្ត្រកាត់បន្ថយភាពក្រីក្រ និងកម្មវិធីជាតិអាទិភាពផ្សេងៗទៀតរបស់រាជរដ្ឋាភិបាល ជាមួយនឹងទិសដៅកែប្រែប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ឱ្យក្លាយទៅជាប្រព័ន្ធមួយប្រកបដោយលក្ខណៈល្អប្រសើរ ដែលត្រូវបានទទួលស្គាល់ជាកម្រិតស្តង់ដារអន្តរជាតិ។

៤.២.៣. ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា

លោក Aaron Wildavsky (១៩៨៦) បានលើកឡើងថា ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការបែងចែកធនធានហិរញ្ញវត្ថុតាមបែបផែននយោបាយ ដើម្បីបម្រើគោលបំណងរបស់មនុស្សម្នាក់ៗ។ ដោយឡែក ប្រសិនបើមើលតាមនិយមន័យដែលបានលើកឡើងដោយលោក Matt Andrew (២០១៤) ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជានីតិវិធីមួយ ដែលរដ្ឋាភិបាលគ្រប់គ្រងធនធានសាធារណៈរបស់ខ្លួន ទាំងក្នុងរយៈពេលខ្លី និងរយៈពេលមធ្យម ដើម្បីធានាបានបច្ច័យវិជ្ជមានទៅលើសេដ្ឋកិច្ច នៃប្រទេសនោះ។ នៅក្នុងន័យទូលំទូលាយ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាការរៀបចំច្បាប់ វិន័យ អង្គភាព ប្រព័ន្ធ ដំណើរការ និងនីតិវិធីរបស់រដ្ឋាភិបាលក្នុងការការពារ និងប្រើប្រាស់ធនធានប្រកបដោយប្រសិទ្ធភាព សក្តិសិទ្ធភាព និងតម្លាភាព។ ការគ្រប់គ្រងហិរញ្ញវត្ថុសា

ធារណៈឱ្យបានត្រឹមត្រូវនិងច្បាស់លាស់ គាំទ្រឱ្យមានភាពទទួលខុសត្រូវខ្ពស់ និងទទួលបាននូវទំនុកចិត្តពីសាធារណៈជន ដើម្បីសម្រេចគោលបំណងចម្បង របស់គោលនយោបាយរបស់រដ្ឋាភិបាលនីមួយៗ។ សរុបមកប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ គឺប្រៀបបានទៅនឹងរចនាសម្ព័ន្ធប្រព័ន្ធទឹកមួយ។ ក្នុងន័យនេះ ទឹកសំដៅដល់ធនធានហិរញ្ញវត្ថុ ដែលត្រូវបាន គ្រប់គ្រង និងបែងចែកដល់រដ្ឋាភិបាលទាំងមូល។ គោលដៅចុងក្រោយ នៃការគ្រប់គ្រងនិងបែងចែកធនធានទាំងនេះ គឺដើម្បីធានាឱ្យបានបច្ច័យវិជ្ជមានដល់សេដ្ឋកិច្ច និងសង្គមជាតិទាំងមូល។

៤.២.៣.១. អំពីហិរញ្ញវត្ថុសាធារណៈកម្ពុជា

ហិរញ្ញវត្ថុសាធារណៈឬនិតិហិរញ្ញវត្ថុសាធារណៈ សំដៅដល់សកម្មភាព មធ្យោបាយ និងបណ្តុំវិធានផ្សេងៗរបស់រដ្ឋក្នុងដំណើរការកៀរគរចំណូល និងការទូទាត់ចំណាយរបស់ខ្លួន ពោលគឺការលើកកម្ពស់ប្រសិទ្ធភាពចំណូល ចំណាយ សម្រាប់ការគ្រប់គ្រងរដ្ឋកំណើនសេដ្ឋកិច្ច សេវាសាធារណៈ និងបម្រើផលប្រយោជន៍ទូទៅ។ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅរកសមិទ្ធកម្ម ទាំងលើការប្រើប្រាស់ធនធានសាធារណៈ និងការសម្រេចបានតាមគោលបំណងនៃគោលនយោបាយដើម្បីធានាផ្តល់ជាអតិបរមានូវតម្លៃនៃលុយ។ ប្រព័ន្ធគ្រប់គ្រងនេះ បែងចែកមុខងារក្នុងក្របខ័ណ្ឌច្បាប់ និងអំណាចហិរញ្ញវត្ថុសាធារណៈយ៉ាងច្បាស់លាស់សម្រាប់ថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដោយស្ថិតក្នុងប្រព័ន្ធថវិកាឯកភាពមួយដែលគ្របដណ្តប់គ្រប់ស្ថាប័ន មុខងារ កម្មវិធី និងគម្រោងរបស់រដ្ឋាភិបាល។ ការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជា ជាការដ្ឋានយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ក្នុងការអភិវឌ្ឍរយៈពេលវែង តាមរយៈការកសាងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយ ដែលមានភាពឆ្លើយតប ប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាព ក្នុងការបែងចែក និងប្រើប្រាស់ធនធានសាធារណៈ។ ក្នុងន័យនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយប្រសិទ្ធភាព និងសក្តិសិទ្ធភាព គឺជាមូលដ្ឋានគ្រឹះដ៏ចាំបាច់មិនអាចខ្វះបាន សម្រាប់ការជំរុញការអភិវឌ្ឍប្រទេសជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនពិសេសតាមរយៈកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព និងការបង្កើនប្រសិទ្ធភាពក្នុងការផ្តល់សេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ។

៤.២.៣.២. អំពីការកែទម្រង់ហិរញ្ញវត្ថុសាធារណៈកម្ពុជា

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈត្រូវបានដាក់ឱ្យអនុវត្តជាផ្លូវការដោយប្រមុខរាជរដ្ឋាភិបាលកម្ពុជា កាលថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្នុងស្មារតីប្រកាន់ខ្ជាប់

ទៅតាមអភិក្រមជាខឿន (Platform Approach) ដោយបែងចែកជាបួនខឿនឬដំណាក់កាលតាមក្របខ័ណ្ឌពេលវេលាជាក់លាក់ ដូចខាងក្រោម៖

ដំណាក់កាលទី១ "ការបង្កើនភាពជឿទុកចិត្តនៃថវិកា" ត្រូវបានអនុវត្តចាប់ពី ឆ្នាំ ២០០៤ ដល់ឆ្នាំ២០០៨ និងបានផ្តល់អាទិភាពបន្ទាន់លើវិន័យថវិកា ដែលផ្តោតលើការពង្រឹងការប្រមូលនិងគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រង សាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានកំណត់និងដាក់ចេញវិធានការជាច្រើន ដែលនាំឱ្យរាជរដ្ឋាភិបាលសម្រេច ដោះស្រាយបាននូវបញ្ហាបំណុលសាច់ប្រាក់ កង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ វិសោធនកម្ម ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងវិមជ្ឈការលទ្ធកម្មសាធារណៈ។

ដំណាក់កាលទី២ "ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ" ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥ ដែលមានគោលដៅចម្បងលើការរៀបចំការកែលម្អ ការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដាអន្តរជាតិ។ ជាលទ្ធផលគណនីទោលរតនាគារ (TSA) ត្រូវបានរៀបចំ និងអនុវត្តមូលដ្ឋានគ្រឹះនៃគណនេយ្យហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាលកម្ពុជា ត្រូវបាន រៀបចំនិងកសាងឡើងតាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ស្តង់ដាគណនេយ្យនិងប្លង់គណនីថ្មី អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមនឹងការដាក់ ឱ្យអនុវត្តប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដែលជា "ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល" ដើម្បីបង្កើនប្រសិទ្ធភាពនៃដំណើរការប្រតិបត្តិការហិរញ្ញវត្ថុ និងពិនិត្យតាមដាន កែលម្អ ចំណាត់ថ្នាក់ថវិកា វាយតម្លៃ ប្រមូលផ្តុំ និងផ្ទៀងផ្ទាត់ និងវិភាគសម្រាប់ការរៀបចំ ផែនការ ការរៀបចំថវិកា ការធ្វើសេចក្តីសម្រេចចិត្ត ការពិនិត្យតាមដាន និងការរៀបចំរបាយការណ៍។

ដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២២ ដែលចាប់ផ្តើមកែទម្រង់លើប្រព័ន្ធថវិកាផ្អែកលើធាតុចូល និងមជ្ឈការ ឆ្ពោះទៅកាន់ប្រព័ន្ធដែលផ្តោតលើលទ្ធផល សមិទ្ធកម្ម និងវិមជ្ឈការ។ ដំណាក់កាលនេះផ្តោតអាទិភាពយ៉ាងសំខាន់លើការអនុវត្តប្រព័ន្ធថវិកាកម្មវិធី ការបង្កើតអង្គភាពថវិកា និងការរៀបចំផែនការ យុទ្ធសាស្ត្រថវិកា ដែលជាគន្លឹះក្នុងការផ្សារភ្ជាប់រវាងគោលនយោបាយវិស័យ និងអនុវិស័យរបស់ក្រសួង ស្ថាប័នទៅនឹងគោលនយោបាយនៃរាជរដ្ឋាភិបាល។ ក្នុងដំណាក់កាលនេះផងដែរ ឯកសារយុទ្ធសាស្ត្រគន្លឹះមួយចំនួនត្រូវបាន

ដាក់ឱ្យអនុវត្តក្នុងគោលបំណងកំណត់អាទិភាពកែទម្រង់ជាយុទ្ធសាស្ត្រទៅតាមការដ្ឋាន កែទម្រង់សំខាន់នៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលរួមមាន៖ យុទ្ធសាស្ត កៀរគរចំណូល ២០១៩-២០២៣ យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៨-២០២៥ យុទ្ធសាស្ត្រ នៃការកែទម្រង់ប្រព័ន្ធថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ឆ្នាំ២០១៩-២០២៥ យុទ្ធសាស្ត្រនៃ ការកែទម្រង់ប្រព័ន្ធលទ្ធកម្មសាធារណៈ ឆ្នាំ២០១៩-២០២៥ និងយុទ្ធសាស្ត្រស្តីពីការកែ ទម្រង់ប្រព័ន្ធគ្រប់គ្រងការ វិនិយោគសាធារណៈ ២០១៩-២០២៥។

ដំណាក់កាលទី៤ "គណនេយ្យភាពសមិទ្ធកម្ម" ត្រូវបានអនុវត្តចាប់ពីឆ្នាំ២០២៣ មក និងគ្រោងបញ្ចប់ក្នុងឆ្នាំ២០២៧ ដែលជាដំណាក់កាលចុងក្រោយនៃកម្មវិធី កែ ទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានគោលដៅសំខាន់មួយគឺ "ការកសាង ប្រព័ន្ធគណនេយ្យភាពសមិទ្ធកម្ម" ដែលមានឧបករណ៍គាំទ្រដ៏សំខាន់នោះគឺ "ថវិកា ព័ត៌មានសមិទ្ធកម្ម"។ ជាវឌ្ឍនភាពគន្លឹះបទដ្ឋានគតិយុត្តសំខាន់ៗ និងយន្តការកសាង ប្រព័ន្ធគណនេយ្យភាពផ្សារភ្ជាប់នឹងសមិទ្ធកម្ម ត្រូវបានកសាង រួមមាន ការដាក់ឱ្យអនុវត្ត នូវច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងអនុក្រឹត្យ ស្តីពីការគ្រប់គ្រងថវិកានិង គណនេយ្យសាធារណៈ និងការអនុវត្តយន្តការកិច្ចព្រមព្រៀងសមិទ្ធកម្ម និងការត្រួតពិនិត្យ តាមដាន និងវាយតម្លៃសមិទ្ធកម្មនៅតាមក្រសួង/ស្ថាប័ន។

៤.២.៣.៣. អំពីច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈត្រូវបានប្រកាសឱ្យប្រើប្រាស់នៅថ្ងៃទី១៣ ខែ ឧសភា ឆ្នាំ ២០០៨។ ច្បាប់នេះធ្វើបច្ចុប្បន្នកម្មលើរាល់វិសោធនកម្មលើច្បាប់ស្តីប្រព័ន្ធ ហិរញ្ញវត្ថុឆ្នាំ១៩៩៣ និងមានគោលដៅកំណត់គោលការណ៍ជាមូលដ្ឋានសម្រាប់គ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈទាំងមូលនៅប្រទេសកម្ពុជា និងផ្តល់នូវគោលការណ៍ណែនាំ ដល់រាជរដ្ឋាភិបាល និងរដ្ឋសភាជាតិ ក្នុងការរៀបចំច្បាប់ថវិកា ច្បាប់ស្តីពីការកែតម្រូវថវិកា និងច្បាប់ទូទាត់ថវិកា។ ច្បាប់នេះ ផ្តល់នូវគោលការណ៍ណែនាំស្តីពីតួនាទី និងការទទួល ខុសត្រូវរបស់ស្ថាប័នដែលពាក់ព័ន្ធនៅក្នុងដំហាននីមួយៗនៃដំណើរការថវិកា ដោយរួមមាន ការរៀបចំការអនុម័ត ការអនុវត្តន៍ និងការវាយតម្លៃ។ លើសពីនេះទៀត ច្បាប់ស្តីពីប្រព័ន្ធ ហិរញ្ញវត្ថុសាធារណៈឆ្នាំ២០០៨ ក៏បង្ហាញឱ្យឃើញពីការណែនាំលើការត្រួតពិនិត្យ សកម្មភាពប្រមូល និងចំណាយថវិកា ការកំណត់តួនាទី និងការទទួលខុសត្រូវ និងផល វិបាកនៃការប្រព្រឹត្តខុសច្បាប់ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ក្រសួង ស្ថាប័ន អង្គ ភាពសាធារណៈប្រហាក់ប្រហែល និងគ្រឹះស្ថានសាធារណៈ និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

នៅក្នុងឆ្នាំ២០២២ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចាប់ផ្តើមធ្វើវិសោធនកម្ម ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បី រៀបចំនូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជា ឱ្យកាន់តែមានភាពរឹងមាំ, កាន់តែជឿទុកចិត្តបាន, មានគណនេយ្យភាព, ប្រសិទ្ធភាព និងមានតម្លាភាព ព្រមទាំងមាន "លក្ខណៈជាស្តាប៊ែន" ស្របតាមបរិការណ៍នៃកម្ពុជាផង និង ស្របតាមឧត្តមានុវត្តជាអន្តរជាតិផង ជាពិសេស ឧត្តមានុវត្តនៃសាធារណរដ្ឋបារាំង ដែលជាលំនាំគោលនៃការអនុវត្តនៅកម្ពុជា។ ទន្ទឹមនឹងនេះ ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងតែតម្រង់ឆ្ពោះទៅកាន់ការប្រើប្រាស់ នូវបច្ចេកវិទ្យាព័ត៌មាន កាន់តែស៊ីជម្រៅ និងទូលំទូលាយ ដែលផ្តល់នូវព័ត៌មានឆាប់រហ័សនិងគ្រប់ជ្រុងជ្រោយ សម្រាប់ការធ្វើ សេចក្តីសម្រេចចិត្ត ផ្នែកគោលនយោបាយសាធារណៈ ឱ្យកាន់តែមានប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពបន្ថែមទៀត។ ការរៀបចំច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈថ្មីនេះ មានលក្ខណៈជាក្របខ័ណ្ឌគតិយុត្តគោល សម្រាប់គ្រប់គ្រងថវិកា ព័ត៌មានសមិទ្ធកម្ម ដែលជាធាតុផ្សំដ៏សំខាន់នៃគណនេយ្យសមិទ្ធកម្ម ក៏ដូចជាការងារផ្សេងទៀតពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ក្នុងយុគសម័យទំនើប។ ក្នុងដំណើរនៃការរៀបចំសេចក្តីព្រាងច្បាប់នេះ មានការសិក្សាគ្រប់ជ្រុងជ្រោយ ដោយដកស្រង់នូវមេរៀន បទពិសោធន៍ និងឧត្តមានុវត្តជាអន្តរជាតិពីប្រទេសជាច្រើន ដូចជាបារាំង ថៃ ម៉ាឡេស៊ីជាដើម ហើយច្របាច់បញ្ចូលទៅនឹងប្រព័ន្ធ និងបទពិសោធន៍នៃការអនុវត្តជាក់ស្តែងរបស់កម្ពុជា ដើម្បីធ្វើឱ្យសេចក្តីព្រាងនេះ មានលក្ខណៈរស់រវើក អាចឆ្លើយតបទៅបរិការណ៍របស់កម្ពុជាផង និងពិភពលោកផង។ បន្ថែមពីនេះដើម្បីធ្វើឱ្យសេចក្តីព្រាងច្បាប់គោលដ៏មានសារៈសំខាន់នេះ កាន់តែមានភាពគ្រប់ជ្រុងជ្រោយ និងប្រទាក់ក្រឡា មានភាពបត់បែន និងងាយស្រួលក្នុងការអនុវត្ត ស្របតាមបរិការណ៍កម្ពុជាសម្រាប់រយៈពេលវែងទៅមុខ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រោមការដឹកនាំរបស់ឯកឧត្តម វង្សី វិស្សុត **អតីតប្រធានគណៈកម្មាធិការដឹកនាំការធ្វើវិសោធនកម្មច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ និងបច្ចុប្បន្នជាឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីនិងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** បានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ដើម្បីប្រមូលធាតុចូល និងមតិយោបល់បន្ថែម ដោយមានការចូលរួមពីសំណាក់លោក Jacques Pellet ឯកអគ្គរដ្ឋទូតនៃសាធារណរដ្ឋបារាំងប្រចាំការ និងលោកស្រី Carmen Moreno ឯកអគ្គរដ្ឋទូតនៃសហភាពអ៊ឺរ៉ុបប្រចាំការកម្ពុជា និងដៃគូអភិវឌ្ឍផ្សេងៗទៀត ដូចជា WB ADB IMF វិស័យឯកជន គ្រឹះស្ថានធនាគារ ស្តាប៊ែនស្រាវជ្រាវ និង អង្គការសង្គមស៊ីវិល។

ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានរដ្ឋសភាអនុម័តកាលពីថ្ងៃទី៨ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំរដ្ឋសភាជាវិសាមញ្ញ នីតិកាលទី៦ និងត្រូវបានពិនិត្យចប់សព្វគ្រប់លើទម្រង់និងគតិច្បាប់ទាំងស្រុងកាលពីថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាសម័យប្រជុំវិសាមញ្ញនីតិកាលទី៤ ដែលបានកំណត់អំពីគោលការណ៍ជាមូលដ្ឋាន សម្រាប់គ្រប់គ្រងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការរៀបចំច្បាប់ហិរញ្ញវត្ថុ ជាពិសេសដំហាននីមួយៗនៃដំណើរការរៀបចំ អនុម័ត អនុវត្ត និងការត្រួតពិនិត្យលទ្ធផលថវិកា ព្រមទាំងការកំណត់មុខងារ និងការទទួលខុសត្រូវ របស់តួអង្គពាក់ព័ន្ធ ដើម្បីសម្រេចបាននូវភាពជឿទុកចិត្តថវិកា គណនេយ្យភាពហិរញ្ញវត្ថុ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម សំដៅជានាប្រសិទ្ធភាពនិងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។[៤៧០] ច្បាប់នេះ ត្រូវបានដាក់ឱ្យប្រើប្រាស់នៅថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដោយបានកំណត់នូវគោលការណ៍ជាមូលដ្ឋាន ដើម្បីសម្រេចឱ្យបាននូវភាពជឿទុកចិត្តនៃថវិកា, គណនេយ្យភាពហិរញ្ញវត្ថុ, ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ និងគណនេយ្យភាពសមិទ្ធកម្ម ក្នុងគោលបំណងជានាប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព និងចីរភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងការទ្រទ្រង់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច កំណើនសេដ្ឋកិច្ច និងសមធម៌សង្គម។

៤.៣. ឆាតុង្សៃ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា

ក្នុងបរិបទ នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅកម្ពុជារយៈពេល ២០ឆ្នាំ បានបង្កើតនូវសមិទ្ធផលជាប្រវត្តិសាស្ត្រជាច្រើននៅកម្ពុជា ទាំងសមិទ្ធផលក្នុងការកែលម្អអភិបាលកិច្ចនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទាំងសមិទ្ធផលក្នុងទិដ្ឋភាពនៃការរីកចម្រើនផ្នែកសង្គមសេដ្ឋកិច្ច របស់កម្ពុជា ដោយកាលពីឆ្នាំ២០១៣ ចំណូលថវិកាជាតិសរុប មានប្រមាណតែ ១៨២១ប៊ីលានរៀល និង ចំណាយថវិកាជាតិមានប្រមាណ ២ ៩៩៤ ប៊ីលានរៀល លុះដល់ឆ្នាំ២០២៣ ចំណូលថវិកាជាតិមានរហូតដល់ប្រមាណ ១៣១ ២៧៦ប៊ីលានរៀល ជាមួយនឹងចំណាយថវិកាជាតិសរុប មានប្រមាណ ៣៩ ២០៦ ប៊ី លានរៀល។ សូចនាករសមិទ្ធកម្មដ៏ល្អប្រសើរ គឺជាឃ្នាស់សេដ្ឋកិច្ចដ៏សំខាន់បំផុតមួយដែលធ្វើឱ្យកម្ពុជាទទួលបានកំណើន និងបន្តស្ថិរភាពនៃកំណើន

[៤៧០] ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ២០២៣

សេដ្ឋកិច្ច ជាបន្តបន្ទាប់រហូតសម្រេចបាននូវចំណាត់ថ្នាក់ជាប្រទេសមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០១៥ និងកំពុងបោះជំហានប្រកបដោយភាពជឿជាក់ ទៅកាន់ការកសាងជាតិមួយដ៏រឹងមាំ ក្នុងស្ថានភាពដ៏លំបាកមួយ ដើម្បីកែប្រែខ្លួនទៅជាប្រទេសមានចំណូលកម្រិតខ្ពស់ នៅឆ្នាំ២០៥០។ ក្នុងន័យនេះ ដើម្បីឆ្លើយតបនឹងស្ថានភាពមិនអំណោយផល បង្កឡើងដោយវិបត្តិសេដ្ឋកិច្ច និងហិរញ្ញវត្ថុសកល ដ៏ដូចជាការឆ្លើយតបនឹងគ្រោះមហន្តរាយ គ្រោះធម្មជាតិ សង្គ្រាមឈ្លានពាន ដែលមិនអាចស្មានទុកមុនបានកន្លងមក ក៏ដូចជាទៅថ្ងៃអនាគត រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវនិយមន័យថវិកាជាតិ និងទស្សនវិស័យច្បាស់លាស់ជាមួយនឹងការដាក់ចេញគោលនយោបាយកែទម្រង់ស៊ីជម្រៅ លើធាតុផ្សំសំខាន់ៗ ក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដើម្បីធានាលទ្ធភាពគ្រប់គ្រាន់ខាងផ្នែកហិរញ្ញវត្ថុ ប្រកបដោយប្រសិទ្ធភាពខ្ពស់ និងស័ក្តិសិទ្ធភាព ក្នុងបុព្វហេតុឯករាជ្យ និងអធិបតេយ្យជាតិ ក្នុងការទទួលខុសត្រូវលើជោគវាសនារបស់ប្រទេសជាតិ។ ធាតុផ្សំ ទាំងនោះរួមមានធាតុផ្សំចម្បងគឺ ការគ្រប់គ្រងចំណូល និងការគ្រប់គ្រងចំណាយសាធារណៈ និងធាតុផ្សំធំៗ រួមមាន ការគ្រប់គ្រងការវិនិយោគសាធារណៈ ការគ្រប់គ្រងបំណុលសាធារណៈ ការគ្រប់ទ្រព្យសម្បត្តិរដ្ឋ ការគ្រប់គ្រងលទ្ធកម្មសាធារណៈ ប្រព័ន្ធគណនេយ្យសាធារណៈ ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការត្រួតពិនិត្យផ្ទៃក្នុង។

៤.៣.១. អំពីថវិកាជាតិ

យោងតាមមាត្រា១៥ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ថវិកា សំដៅដល់ផែនការហិរញ្ញវត្ថុរបស់រដ្ឋ ដែលត្រូវបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ រួមមានការគ្រោងចំណូលនិងចំណាយ ការខ្ចី និងការធ្វើហិរញ្ញប្បទានបំពេញតុល្យភាពថវិកា ដើម្បីសម្រេចសមិទ្ធកម្មដែលបានគ្រោងទុក។ ថវិកាដែលត្រូវបានអនុម័តក្នុងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ជាមូលដ្ឋានក្នុងការបញ្ជារចំណាយ។

ថវិកាគឺជាឧបករណ៍ដ៏សំខាន់បំផុតមួយរបស់រដ្ឋាភិបាលក្នុងការអនុវត្តគោលនយោបាយរបស់ខ្លួន និងមានឥទ្ធិពលលើជីវិតប្រចាំថ្ងៃ និងអនាគតរបស់សង្គមទាំងមូល។ សេចក្តីសម្រេចលើការធ្វើថវិកាមានផលប៉ះពាល់លើគ្រប់សកម្មភាព សេដ្ឋកិច្ច និងសង្គមកិច្ច រាប់តាំងពីកន្លែងដែលយើងរស់នៅ កន្លែងដែលយើងធ្វើការ មធ្យោបាយធ្វើដំណើរដែលយើងប្រើប្រាស់ ការថែទាំសុខភាព និងការអប់រំដែលយើងអាចទទួលបាន និងសុវត្ថិភាព អនាម័យ និងសេវាចាំបាច់នានាដែលយើងអាចទទួល។ នៅប្រទេសកម្ពុជា ថវិកា

ជាតិត្រូវបានរៀបចំជារៀងរាល់ឆ្នាំសម្រាប់ការអនុវត្តនៅ ក្នុងឆ្នាំប្រតិទិនបន្ទាប់ ដែលស្របពេលគ្នាជាមួយនឹងឆ្នាំសារពើពន្ធ។ ថវិកាជាតិត្រូវបានរៀបចំដោយរាជរដ្ឋាភិបាល និងចាំបាច់ត្រូវមានការអនុម័តដោយរដ្ឋសភា និងព្រឹទ្ធសភាមុនពេលអនុវត្ត។ ក្រោយពេលបានអនុម័តដោយអង្គនីតិបញ្ញត្តិ ថវិកាជាតិក្លាយទៅជាច្បាប់។

សមាសធាតុសំខាន់ៗ នៃការកែទម្រង់ថវិកាតាមរយៈច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រួមមាន៖

- ការដាក់ឱ្យអនុវត្តថវិកាព័ត៌មានសមិទ្ធកម្ម (ការភ្ជាប់ផែនការសមិទ្ធកម្មជាមួយច្បាប់ថវិកាប្រចាំឆ្នាំ និងភ្ជាប់របាយការណ៍សមិទ្ធកម្ម, កសហវ. បង្កើតប្រព័ន្ធតាមដាន និងវាយតម្លៃសមិទ្ធកម្ម
- ថវិកាកម្មវិធី (ផ្លាស់ប្តូរទម្រង់ឥណទានថវិកា ពីសមាសធាតុចំណាយទៅជាចំណាយតាមកម្មវិធី
- ទិដ្ឋភាពនៃការរៀបចំថវិការយៈពេលមធ្យម (MTFF, MTBF, BSP, ឥណទានថវិកាមូលធន ឥណទានទូទាត់ប្រចាំឆ្នាំ និងធានាចំណាយពហុឆ្នាំ)
- ការគ្រប់គ្រងការវិនិយោគសាធារណៈ (សមាហរណកម្មការវិនិយោគសាធារណៈ ទៅក្នុងរចនា- សម្ព័ន្ធថវិកាកម្មវិធី)
- ការបង្កើនស្វ័យប្រវត្តិកម្មគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (ការត្រួតពិនិត្យថវិកា និងការនិយ័តថវិកា)
- ការកែទម្រង់គណនេយ្យសាធារណៈ និងការរៀបចំរបាយការណ៍ (ផ្លាស់ប្តូរពីមូលដ្ឋានសាច់ប្រាក់ ទៅជាមូលដ្ឋានបង្គរ)
- លើកកម្ពស់តម្លាភាពថវិកា និងពិនិស្ច័យ (ការផ្សព្វផ្សាយ MTFF, MTBF, ថវិកាប្រចាំឆ្នាំ, របាយ-ការណ៍សមិទ្ធកម្មប្រចាំឆ្នាំ, របាយការណ៍ហិរញ្ញវត្ថុ, ការពិនិស្ច័យដោយសមាជិកសភា)
- ការដាក់ឱ្យអនុវត្ត FMIS (ការរៀបចំថវិកា, អនុវត្តថវិកា, គណនេយ្យ, របាយការណ៍, តាមដាន និងសវនកម្ម)
- ការកែទម្រង់ផ្សេងទៀត និងនវានុវត្តន៍ (ការត្រួតពិនិត្យផ្ទៃក្នុង, សវនកម្ម និងអធិការកិច្ចហិរញ្ញវត្ថុ, គណនីពិសេសរតនាគារ, មូលនិធិបម្រុងហិរញ្ញវត្ថុ)។

៤.៣.១.១. ការគ្រប់គ្រងចំណូលជាតិ

ចំណូលរបស់រដ្ឋសំដៅដល់ថវិកាដែលរដ្ឋប្រមូលបានពីប្រភពចំនួន២ រួមមាន៖ ប្រភពពីចំណូលសារពើពន្ធ(ពន្ធដារ និងគយ) និងប្រភពពីចំណូលមិនមែនសារពើពន្ធ (ការផ្តល់លិខិតឆ្លងដែន ការផ្តល់ទិដ្ឋាការ ការស៊ីណូ ឆ្នោត ផលទុនទេសចរណ៍ ប្រៃសណីយ៍ និងទូរគមនាគមន៍ ចំណូលពីប្រាក់ចំណេញសហគ្រាស អាជ្ញាបណ្ណក្នុងស្រុក អាកាសចរស៊ីវិល សម្បទានរ៉ែ សម្បទានប្រេងកាត ការជួលទ្រព្យសម្បត្តិរដ្ឋ និងសេវាសាធារណៈផ្សេងៗ ដែលគ្រប់គ្រងដោយប្រព័ន្ធបច្ចេកវិទ្យាពត៌មានគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ NRMIS)។ ចំណូលនិងចំណាយ គឺជាសមាសធាតុសំខាន់ដែលត្រូវរំលេចក្នុងកញ្ចប់ថវិការបស់រដ្ឋ និងជាឧបករណ៍ចម្បងសម្រាប់ប្រើប្រាស់ក្នុងការអនុវត្តគោលនយោបាយសារពើពន្ធ។ ការប្រមូលនិងគ្រប់គ្រងចំណូលមិនមានប្រសិទ្ធភាព នឹងធ្វើឱ្យរដ្ឋខ្វះថវិកាសម្រាប់ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ។

ចំណូលរបស់រាជរដ្ឋាភិបាលចែកជា២ ប្រភេទ គឺចំណូលចរន្ត និងចំណូលមូលធន។ ទំហំចំណូលចរន្តគឺជាបរិមាណដែលរាជរដ្ឋាភិបាលគ្រោងនឹងប្រមូលបានក្នុងឆ្នាំដែលត្រូវចាត់ទុកថាជាប្រភពចំណូលជាប្រចាំរបស់រដ្ឋ ដោយចំណូលចរន្ត ត្រូវបានព្យាករ និងផ្អែកលើចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ក្នុងនោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានតួនាទីភារកិច្ចក្នុងការកំណត់ទំហំចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ ដែលត្រូវប្រមូលក្នុងឆ្នាំ និងធ្វើការព្យាករទំហំចំណូលទាំងពីរនេះ ដែលអាចប្រមូលបានពីសហគ្រាសសាធារណៈរបស់រដ្ឋផងដែរ។ ចំណែកឯ ក្រសួង ស្ថាប័ន និងអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត មានកាតព្វកិច្ចផ្តល់ជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអំពីការព្យាករទំហំចំណូលរបស់ខ្លួន ដើម្បីរៀបចំផែនការប្រមូលចំណូលសម្រាប់បញ្ចូលក្នុងផែនការថវិកាប្រចាំឆ្នាំ។ ដោយឡែក ចំណូលមូលធន សំដៅដល់ចំណូលមិនជាប្រចាំ ឬមិនទៀងទាត់ ឬកើតឡើងតែម្តង ដែលអាចកើតឡើងពីប្រភពដូចជា (១). ចំណូលពីទ្រព្យសកម្មហិរញ្ញវត្ថុ បំណុល ការបង់វិភាគទានពីសហគ្រាសសាធារណៈ និងចំណូលពីការខ្ចីក្នុងទីផ្សារហិរញ្ញវត្ថុក្នុងស្រុកដោយ ក.ស.ហ.វ. មានតួនាទីភារកិច្ចក្នុងការវាយតម្លៃស្ថានភាពសេដ្ឋកិច្ច និងបោះផ្សាយមូលបត្ររដ្ឋ ឬបំណុលរដ្ឋ ដែលអាចជាមូលដ្ឋានក្នុងការប៉ាន់ស្មានចំណូលពីមូលធនក្នុងក្របខ័ណ្ឌកម្ចី(២). ហិរញ្ញប្បទានពីបរទេសក្នុងទម្រង់ជាការផ្តល់ហិរញ្ញប្បទានឥតសំណងសម្រាប់គម្រោងវិនិយោគ ត្រូវធ្វើការប៉ាន់ស្មានដោយផ្អែកលើរំហូរហិរញ្ញប្បទានស្របតាមវឌ្ឍនភាពនៃការអនុវត្តគម្រោង និង(៣). ជំនួយជាការផ្តល់ទំនិញ

ត្រូវបានគ្រោងជាចំណូលមូលធននៅក្នុងថវិកាជាតិដោយធ្វើការវាយតម្លៃជាតម្លៃទំនិញនាំចូលសម្រាប់អនុវត្តកម្មវិធីជំនួយនីមួយៗ។

យុទ្ធសាស្ត្រកៀរគរចំណូលឆ្នាំ២០១៩-២០២៣ គឺជាឧបករណ៍ពង្រឹងអភិបាលកិច្ច ក្នុងការពិនិត្យ និងកំណត់អំពីបញ្ហាប្រឈមដែលកំពុងកើតមាន។ យុទ្ធសាស្ត្រនេះនឹងបន្តធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងចំណូលតាមរយៈការដាក់ឱ្យអនុវត្តវិធានការដោះស្រាយជាក់លាក់ ដើម្បីធ្វើទំនើបកម្មប្រព័ន្ធបច្ចេកវិទ្យាព័ត៌ ការរៀបចំនិងអនុម័តដាក់ឱ្យប្រើប្រាស់គតិយុត្តចំបាច់ផ្សេងៗ និងការអភិវឌ្ឍស្តង់ដាសម្រាប់ការគ្រប់គ្រង។ អាទិភាពការងារកែទម្រង់ទាំងនេះនឹងបង្កើនការប្រមូលចំណូលមិនមែនសារពើពន្ធពីប្រភពដូចជា វិស័យអាកាសចរណ៍ស៊ីវិល វិស័យទេសចរណ៍ វិស័យរ៉ែ និងថាមពល និងចំណូលពីសកម្មភាពល្បែង។

៤.៣.១.២. ការគ្រប់គ្រងចំណាយសាធារណៈ

ការគ្រប់គ្រងចំណាយសាធារណៈ មានគោលដៅធានាឱ្យសម្រេចបានគោលការណ៍គ្រឹះ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំង៣រួមមាន ការគោរពវិន័យថវិកា ប្រសិទ្ធភាពនៃការវិភាជថវិកា និងប្រសិទ្ធភាពនៃការអនុវត្តថវិកា។ ការគោរពវិន័យថវិកាសំដៅដល់ការធានាឱ្យបាននូវសង្គតិភាពរវាងការចំណាយសាធារណៈជាមួយនឹងចំណូលប្រមូលបានសរុប ដើម្បីធានាឱ្យការចំណាយរបស់រដ្ឋមានចីរភាព ឬចំណាយមិនលើសពីចំណូលដែលរដ្ឋអាចប្រមូលបាន។ ដោយឡែកប្រសិទ្ធភាពនៃការវិភាជថវិកា សំដៅដល់សុខដុមនីយកម្មនៃការបែងចែកធនធានដោយផ្អែកលើអាទិភាពជាយុទ្ធសាស្ត្ររបស់ជាតិ ឬសំដៅដល់ការចំណាយថវិកាទៅលើការអនុវត្តសកម្មភាពជាអាទិភាព។ ប្រសិទ្ធភាពនៃការអនុវត្តថវិកា សំដៅដល់ការផ្តល់សេវាសាធារណៈដែលមានគុណភាព និងតម្លៃសមស្រប និងគោរពតាមគោលការណ៍ "តម្លៃនៃលុយ"។

ចំណាយរបស់រដ្ឋគឺផ្អែកលើតម្រូវការពិតប្រាកដបច្ចុប្បន្ន និងការវិនិយោគសម្រាប់អនាគត។ ក្នុងន័យនេះ ការចំណាយសាធារណៈ ត្រូវបានបែងចែកជា២ ប្រភេទ គឺ៖ ការចំណាយចរន្ត និងការចំណាយមូលធន។ ចំណាយចរន្ត គឺជាចំណាយប្រតិបត្តិការក្រៅពីចំណាយមូលធន ដែលមានដូចជា៖ ចំណាយលើបន្ទុកបុគ្គលិក និងក្រៅបន្ទុកបុគ្គលិកដែលជាចំណាយសម្រាប់ដំណើរការផ្សេងៗទៀត ប៉ុន្តែការអនុវត្តចំណាយចរន្តនៅមាននីតិវិធីស្មុគស្មាញនិងត្រូវការពេលវេលាយូរក្នុងការអនុវត្ត ដែលធ្វើឱ្យការអនុវត្តចំណាយពុំទាន់សម្រេចបានតាមផែនការ និងធ្វើឱ្យរាំងស្ទះដល់ការផ្តល់សេវាសាធារណៈ។

ដោយមានការគាំទ្រពីសហភាពអឺរ៉ុបក្នុងឆ្នាំ២០២០ នីតិវិធីថវិកាត្រូវបាននិងកំពុងកែទម្រង់ជាបន្តបន្ទាប់រួមមាន ការរៀបចំក្របខ័ណ្ឌពេលវេលាសម្រាប់ការរៀបចំផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង/ស្ថាប័ន ការបិរិច្ឆេទនៃការរៀបចំថវិកាប្រចាំឆ្នាំ និងការិយបរិច្ឆេទនៃការរៀបចំផែនការចំណាយមូលធនរយៈពេលមធ្យម។ ការកែទម្រង់នេះ រំពឹងថានឹងធ្វើឱ្យការអនុវត្តថវិកាបានទាន់ពេលវេលា និងកាន់តែប្រសើរឡើង។ ការកែទម្រង់ទាំងនេះជាមូលដ្ឋានសម្រាប់ដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាព័ត៌មានសមិទ្ធកម្ម ដោយផ្តោតលើកម្រិតលទ្ធផលក្នុងឆ្នាំ និងលទ្ធផលរយៈពេលមធ្យម។ ទោះបីជាសម្រេចបានវឌ្ឍនភាពជាបន្តបន្ទាប់ក៏នៅមានបញ្ហាប្រឈមមួយចំនួនត្រូវពិនិត្យដោះស្រាយបន្ថែមទៀតដើម្បីធានាថាថវិកាកម្មវិធី និងផែនការយុទ្ធសាស្ត្រ ត្រូវបានអនុវត្តពេញលេញ និងមានប្រសិទ្ធភាព។

រីឯចំណាយមូលធន ចំណាយមូលធន សំដៅដល់ថវិកា ដែលរាជរដ្ឋាភិបាលប្រើប្រាស់សម្រាប់ទិញ ឬថែទាំទ្រព្យសម្បត្តិរូបិយ ដូចជា ដីធ្លី សំណង់អគារ រោងចក្រ ឧស្សាហកម្ម បច្ចេកវិទ្យា ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ហេដ្ឋារចនាសម្ព័ន្ធទឹកស្អាត បរិក្ខា និងឧបករណ៍គ្រប់គ្រងសំណល់រឹង ។ល។

៤.៣.២. ធាតុផ្សំសំខាន់ៗ នៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ក្នុងគោលដៅនៃការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម ដែលសំដៅដល់ការទទួលខុសត្រូវផ្អែកលើលទ្ធផលតាមរយៈការកែប្រែជាសារវន្តផ្នែកគោលនយោបាយ និងយុទ្ធសាស្ត្រអាទិភាពដើម្បីពង្រឹងប្រសិទ្ធភាព គុណភាព និងការទទួលខុសត្រូវ លើការប្រើប្រាស់ថវិកាឱ្យចំគោលដៅ តម្លាភាព គណនេយ្យភាព ធានាបាននូវតម្លៃនៃលុយ ព្រមទាំងស្របតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈធាតុផ្សំសំខាន់បាននិងកំពុងកែលម្អ និងកែទម្រង់ក្នុងក្របខ័ណ្ឌនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរួមមាន៖

៤.៣.២.១. ចំណូលសាធារណៈ

បំណុលសាធារណៈ គឺជាដំណើរដែលប្រទេសមួយជំពាក់បំណុលទៅកាន់ភាគីផ្សេងដែលជាអ្នកផ្តល់ផ្តង ឬផ្តល់កម្ចី។ ភាគីដែលផ្តល់កម្ចីនោះអាចជា បុគ្គលសាធារណៈ វិស័យឯកជន និងដៃគូអភិវឌ្ឍន៍ទ្វេភាគី ឬពហុភាគី។ ការគ្រប់គ្រងបំណុលសាធារណៈគឺសំដៅដល់សកម្មភាពនានា ក្នុងការដាក់ចេញគោលការណ៍ណែនាំ គោលនយោបាយ យុទ្ធសាស្ត្រ មុខងារយន្តការគ្រប់គ្រង ជាពិសេស យន្តការស្ថាប័ន និងបទប្បញ្ញត្តិនានាដទៃទៀត ដែលត្រូវការ និងពាក់ព័ន្ធនឹងបំណុលសាធារណៈមានដូចជា ការខ្ចីប្រាក់ពីគេ ការផ្តល់ឥណទានរបស់រដ្ឋ ការបោះផ្សាយនិងដាក់លក់មូលបត្ររដ្ឋ ការបោះផ្សាយនិង

ដាក់លក់សញ្ញាប័ណ្ណរដ្ឋអធិបតេយ្យ ការធានា កាតព្វកិច្ចបំណុលជាយថាហេតុ ការទូទាត់សេវាបំណុល ការរៀបចំកែសម្រួលរចនាសម្ព័ន្ធបំណុលសាធារណៈឡើងវិញ ការគ្រប់គ្រងហានិភ័យ និងប្រតិបត្តិការផ្សេងទៀតដែលចាំបាច់។

ផ្អែកទៅលើយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ២០១៩-២០២៣ ការខ្ចីឥណទានត្រូវគោរពតាមគោលការណ៍គន្លឹះទាំង ៤ រួមមាន៖

- ខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន
- ខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់
- ខ្ចីសម្រាប់តែវិស័យទ្រទ្រង់ចីរភាព នៃកំណើនសេដ្ឋកិច្ច និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច
- ប្រើប្រាស់ឥណទានប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពខ្ពស់។

៤.៣.២.២. វិនិយោគសាធារណៈ

វិនិយោគសាធារណៈ សំដៅដល់ការចំណាយលើហេដ្ឋារចនាសម្ព័ន្ធសាធារណៈ និងចែកចេញជា ២ ប្រភេទ គឺ៖ ហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ច ដូចជាផ្លូវថ្នល់ ស្ពាន អាកាសយានដ្ឋាន កំពង់ផែ ជាដើម និងហេដ្ឋារចនាសម្ព័ន្ធសង្គម ដូចជា សាលារៀន និងមន្ទីរពេទ្យ ជាដើម។ ការវិនិយោគសាធារណៈអាចត្រូវបានហិរញ្ញប្បទានដោយថវិការបស់រដ្ឋាភិបាល ដែលបានមកពីថវិការដ្ឋ និងការខ្ចីពីក្នុងនិងក្រៅប្រទេស និងទុនវិនិយោគពីវិស័យឯកជន។ ជាមួយនឹងក្របខ័ណ្ឌ នៃការគ្រប់គ្រងវិនិយោគសាធារណៈដែលគ្រប់ជ្រុងជ្រោយ រដ្ឋាភិបាលនឹងទទួលបានធាតុចេញ និងលទ្ធផលជាអតិបរមាពីគម្រោងចំណាយវិនិយោគសាធារណៈ។ ការវិនិយោគសាធារណៈ គឺជាឧបករណ៍សម្រាប់ជំរុញកំណើនសេដ្ឋកិច្ចក្នុងរយៈពេលវែង។ ក្នុងន័យនេះ ការរៀបចំឱ្យមានប្រព័ន្ធគ្រប់គ្រងវិនិយោគសាធារណៈរឹងមាំនឹងធ្វើឱ្យសម្រេចបានគោលដៅដូចជា គាំទ្រ និងជំរុញចីរភាពនៃកំណើសេដ្ឋកិច្ច ពិពិធកម្មសេដ្ឋកិច្ច និងពង្រឹងសមត្ថភាពប្រកួតប្រជែង បំពេញតម្រូវការទុនវិនិយោគសាធារណៈ ដែលកាន់តែរីកធំឡើង ធានាការប្រើប្រាស់ធនធានវិនិយោគចំទិសដៅ និងឆ្លើយតបទៅនឹងតម្រូវការអាទិភាពពិតប្រាកដ និងឆ្លើយតបនឹងតម្រូវការសេវាសាធារណៈ និងធានាបាននូវសមធម៌សង្គម។ ក្នុងន័យនេះ ដើម្បីធានាឱ្យការគ្រប់គ្រងវិនិយោគសាធារណៈប្រកបដោយ

ជោគជ័យកម្ពុជាត្រូវរៀបចំឱ្យមានក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌគតិយុត្ត យន្តការ ស្ថាប័នរឹងមាំ នីតិវិធីប្រតិបត្តិ យន្តការគាំទ្រហិរញ្ញវត្ថុ និងការកសាងធនធានមនុស្ស។

រាជរដ្ឋាភិបាលបានដាក់ឱ្យអនុវត្តយុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈ ឆ្នាំ២០១៩-២០២៥ ក្នុងគោលបំណងបង្កើតឱ្យបានប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈរួមមួយរបស់ជាតិ សម្រាប់គ្រប់គ្រងការវិនិយោគសាធារណៈពីគ្រប់ប្រភពហិរញ្ញប្បទាន និងនៅគ្រប់កម្រិតរដ្ឋបាល។ អាទិភាពនៃយុទ្ធសាស្ត្រនេះ គឺការបង្កើតប្រព័ន្ធគ្រប់គ្រងប្រកបដោយសុខដុមនីយកម្ម សម្រាប់ការគ្រប់គ្រងវិនិយោគសាធារណៈពីដំណាក់កាលអាទិភាវូបនីយកម្ម និងផែនការនីយកម្ម សិក្សាវាយតម្លៃ និងរៀបចំសំណើគម្រោង ពិនិត្យវាយតម្លៃលើសំណើគម្រោង ជ្រើសរើសគម្រោង និងថវិកានីយកម្មគម្រោងវិនិយោគសាធារណៈតាមដាន និងត្រួតពិនិត្យការអនុវត្តគម្រោង និងវាយតម្លៃក្រោយបញ្ចប់ការអនុវត្តគម្រោង។

៤.៣.២.៣. ទ្រព្យសម្បត្តិរដ្ឋ

យោងតាមច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ទ្រព្យសម្បត្តិរដ្ឋ មានប្រភពមកពីទ្រព្យសម្បត្តិទាំងឡាយ ដែលកើតឡើងតាមធម្មជាតិ ឬបង្កើតឡើងដោយ មនុស្សជាតិ ក្រោមទម្រង់ជាចលនទ្រព្យ ឬអចលនទ្រព្យ រូបី ឬអរូបី ដែលមិនមែនជាកម្មសិទ្ធិឯកជន។ទ្រព្យសម្បត្តិរដ្ឋដោយធម្មជាតិ ជាទ្រព្យសម្បត្តិរបស់រដ្ឋ ដែលកើតឡើងតាមធម្មជាតិ មានជាអាទិ៍ ដីធ្លី ទឹក ខ្យល់ អាកាស កោះ សមុទ្រ បាតសមុទ្រ ធនធានក្រោមបាតសមុទ្រ ឆ្នេរសមុទ្រ ភ្នំ ជ្រោះភ្នំ ព្រៃឈើ ទន្លេ ព្រែក ស្ទឹង បឹង រ៉ែ គ្រប់ប្រភេទ ប្រភពទឹក ធនធានជលផល ធនធានព្រៃឈើ និងប្រភពធនធានធម្មជាតិផ្សេងៗទៀតដែលឋិតនៅ ក្នុងដី លើដី ឬក្រោមដីនៃដែនដីគោក ដែនទឹក និងដែនអាកាស ព្រមទាំងធនធានធម្មជាតិដទៃទៀត ដែលស្ថិតនៅក្រោមអធិបតេយ្យភាព និង/ឬយុត្តាធិការ នៃព្រះរាជាណាចក្រកម្ពុជា។

ទ្រព្យសម្បត្តិរដ្ឋដោយមនុស្សជាតិ ជាទ្រព្យសម្បត្តិរដ្ឋ ដែលបង្កើតឡើងដោយអំពើរបស់មនុស្ស មានជាអាទិ៍៖ (ក). ទ្រព្យសម្បត្តិដែលជាបេតិកភណ្ឌវប្បធម៌ សំណង់ប្រវត្តិសាស្ត្រ រមណីយដ្ឋានប្រវត្តិសាស្ត្រ សំណង់សាសនា សិលាចារឹក មូលដ្ឋានការពារប្រទេស និង(ខ). ទ្រព្យសម្បត្តិដែលទទួលបានតាមរយៈលទ្ធកម្មនៃកម្មសិទ្ធិ មកជាទ្រព្យសម្បត្តិរដ្ឋ ដោយប្រើប្រាស់ ឬមិន ប្រើប្រាស់ថវិការដ្ឋ មានជាអាទិ៍ ការទិញ ការដូរ អស្សាមិករណ៍ ប្រទានកម្ម អច្ចយទាន ទ្រព្យនិទាយាទ ទ្រព្យគ្មាន ម្ចាស់គ្រប់គ្រង ការរឹបអូសដោយសេចក្តីសម្រេចស្ថាពររបស់តុលាការ ព្រមទាំងទ្រព្យសម្បត្តិដែលរដ្ឋទទួលបាន

ដោយ មធ្យោបាយស្របច្បាប់ផ្សេងទៀត។ បច្ចុប្បន្នបញ្ជីសារពើកណ្តាទ្រព្យសម្បត្តិរដ្ឋ ត្រូវ បានធ្វើទំនើបកម្មការគ្រប់គ្រង តាមរយៈប្រព័ន្ធបច្ចេកវិទ្យាពត៌មានគ្រប់គ្រងបញ្ជីសារពើ កណ្តាទ្រព្យសម្បត្តិរដ្ឋ (SARMIS)។

៤.៣.២.៤. ការគ្រប់គ្រងលទ្ធកម្មសាធារណៈ

លទ្ធកម្មសាធារណៈ គឺជាយន្តការចំណាយដែលរាជរដ្ឋាភិបាលអនុវត្តដើម្បីទទួល បានទំនិញ និងសេវាកម្មពីទីផ្សារ ដើម្បីគាំទ្រគម្រោងសាធារណៈ និងសកម្មភាពប្រចាំថ្ងៃ របស់រាជរដ្ឋាភិបាល ក្នុងន័យធានាឱ្យការអនុវត្តថវិការបស់រាជរដ្ឋាភិបាលប្រកបដោយ ប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ដើម្បីសម្រេចបានតម្លៃនៃលុយ។ ធាតុសំខាន់ៗនៃលទ្ធកម្ម សាធារណៈ រួមមាន៖ ១. ការរៀបចំផែនការលទ្ធកម្ម, ២. ការអនុវត្ត (រួមទាំងការប្រគល់ និងគ្រប់គ្រងកិច្ចសន្យា និងការបើកប្រាក់ ការបញ្ចប់កិច្ចសន្យា) ៣. ការដោះស្រាយ បណ្តឹងតវ៉ា ៤. ការរៀបចំរបាយការណ៍ស្តីពីការអនុវត្តន៍លទ្ធកម្ម (ប្រចាំត្រីមាស ឆមាស និងឆ្នាំ) និង ៥. ការត្រួតពិនិត្យតាមក្រោយ។ ដើម្បីធានាឱ្យធាតុទាំងនេះ សម្រេចបាន ប្រកបដោយតម្លាភាព និងប្រសិទ្ធភាព តាមនីតិវិធីលទ្ធកម្មសាធារណៈ, ការកំណត់តួនាទី របស់និយ័តករ ប្រតិបត្តិករ និងអ្នកត្រួតពិនិត្យ គឺជាកត្តាចំបាច់ដែលត្រូវរៀបចំឱ្យបាន ច្បាស់លាស់។ ប្រព័ន្ធលទ្ធកម្មសាធារណៈរបស់កម្ពុជា ត្រូវបានវាយតម្លៃដោយប្រើប្រាស់ ក្របខ័ណ្ឌវាយតម្លៃចំណាយសាធារណៈ និងគណនេយ្យភាពហិរញ្ញវត្ថុ (PEFA) ក្នុងឆ្នាំ ២០១៥ និងឆ្នាំ២០២០ និងត្រូវបានវាយតម្លៃហានិភ័យអភិបាលកិច្ច និងផែនការ គ្រប់គ្រង ឆ្នាំ២០១៥ ដោយធនាគារអភិវឌ្ឍន៍អាស៊ី ដោយប្រើប្រាស់សូចនាករបស់អង្គ ការអភិវឌ្ឍន៍ និងសហប្រតិបត្តិការសេដ្ឋកិច្ច ដែលផ្អែកលើសរសេរស្តង់ដ្ឋសំខាន់ៗចំនួន ៤ គឺ ៖ ១. ក្របខ័ណ្ឌច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត, ២. សមត្ថភាពគ្រប់គ្រង និងក្របខ័ណ្ឌ ស្ថាប័ន, ៣. កិច្ចដំណើរការលទ្ធកម្ម និងទីផ្សារ, និង ៤. តម្លាភាព និងសូចរិតភាពក្នុង ប្រព័ន្ធលទ្ធកម្មសាធារណៈ។ លទ្ធផលនៃការវាយតម្លៃបានបង្ហាញថាប្រព័ន្ធលទ្ធកម្មសា ធារណៈ មានភាពល្អប្រសើរច្រើន ដែលបានរួមចំណែកយ៉ាងសំខាន់ក្នុងការគ្រប់គ្រងលើ ការអនុវត្ត ការចំណាយសាធារណៈកាន់តែមានប្រសិទ្ធភាព។ ទោះជាយ៉ាងក៏ដោយ មាន ធាតុគន្លឹះមួយចំនួនរបស់ប្រព័ន្ធលទ្ធកម្មសាធារណៈ ដែលត្រូវបន្តកែទម្រង់ រួមមាន ក្របខ័ណ្ឌស្ថាប័ន និងសមត្ថភាពគ្រប់គ្រង ប្រតិបត្តិការលទ្ធកម្ម និងការអនុវត្តទីផ្សារ តម្លា ភាព និងយន្តការដោះស្រាយបណ្តឹងតវ៉ា។ បន្ថែមពីនេះ ការវាយតម្លៃបានបង្ហាញថាមាន

ការបំបែកក្របខ័ណ្ឌគតិយុត្តជាផ្នែកៗ សម្រាប់ការគ្រប់គ្រងលទ្ធកម្មដោយប្រើប្រាស់ថវិកាជាតិ និងមូលនិធីជំនួយ។

៤.៣.២.៥. ប្រព័ន្ធគណនេយ្យសាធារណៈ

ប្រព័ន្ធគណនេយ្យសម្រាប់វិស័យសាធារណៈនៅកម្ពុជា គឺជាការបញ្ចូលគ្នារវាងស្តង់ដាមូលដ្ឋានសាច់ប្រាក់ និងស្តង់ដាមូលដ្ឋានបង្គរ ដែលគណនេយ្យសាធារណៈមូលដ្ឋានបង្គរ គឺត្រូវកត់ត្រាប្រតិបត្តិការជាច្រើន។ ប្លង់គណនេយ្យ គឺជាបញ្ជីលេខកូដ ដែលរាជរដ្ឋាភិបាលប្រើសម្រាប់សម្គាល់មុខសញ្ញាចំណាយនីមួយៗ ដែលយកមូលដ្ឋានតាមប្រព័ន្ធគណនេយ្យរបស់ប្រទេសបារាំង និងត្រូវបានកែសម្រួលស្របតាមបរិបទកម្ពុជា។ ប្លង់គណនេយ្យនេះ មិនត្រូវបានរៀបចំឡើងសម្រាប់តែប្រព័ន្ធគណនេយ្យស្តង់ដាមូលដ្ឋានសាច់ប្រាក់ និងមូលដ្ឋានបង្គរនោះទេ ប៉ុន្តែក៏ដើម្បីជួយសម្រួលដល់ការអនុវត្តប្រព័ន្ធផ្អែកលើមូលដ្ឋានបង្គរ ឬបង្កើតរបាយការណ៍គណនេយ្យផ្អែកលើមូលដ្ឋានបង្គរ។ ចំណាត់ថ្នាក់នៃប្លង់គណនេយ្យពីមុន មានភាពខុសគ្នាពីស្តង់ដាគណនេយ្យវិស័យសាធារណៈអន្តរជាតិ និងស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ ដែលការនេះផ្តល់ផលលំបាកដល់គណនេយ្យករ ដែលបម្រើការងារខាងក្រៅពីវិស័យសាធារណៈកម្ពុជា ក្នុងការយល់ និងប្រើប្រាស់។ លើសពីនេះ, ប្លង់គណនេយ្យនោះមានលក្ខណៈប្រមូលផ្តុំ មិនលម្អិតតាមគ្រប់មុខសញ្ញាចំណូល-ចំណាយ ដែលតម្រូវឱ្យប្រើប្រាស់ប្រាស់គណនេយ្យប្រភេទ "ផ្សេងៗ" ជាច្រើន ដែលជាហេតុធ្វើឱ្យពិបាកក្នុងការតាមដានចំណាយ ឬបំណុលជាដើម។

៤.៣.២.៦. ប្រព័ន្ធបច្ចេកវិទ្យាពត៌មានសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារ

ប្រព័ន្ធ FMIS ជាប្រព័ន្ធស្វ័យប្រវត្តិកម្ម និងសមាហរណកម្មនៃដំណើរការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ការរៀបចំផែនការថវិកា ការអនុវត្តថវិកា (ឧ. ការគ្រប់គ្រងធានាចំណាយ, ការគ្រប់គ្រងសាច់ប្រាក់, ការគ្រប់គ្រងបំណុល និងប្រតិបត្តិការរតនាគារជាតិ ជាដើម) គណនេយ្យ, របាយការណ៍, ការត្រួតពិនិត្យ និងការធ្វើសវនកម្ម។ ប្រព័ន្ធបច្ចេកវិទ្យានេះ នឹងបង្កើតនូវលទ្ធផលជាក់លាក់ជាច្រើន រួមមាន៖ របាយការណ៍ប្រតិបត្តិការ, ថវិកាមូលធន, របាយការណ៍គណនេយ្យ, ការព្យាករណ៍ហូរសាច់ប្រាក់, និងការវិភាគផ្សេងៗផ្អែកលើមូលដ្ឋានផ្សេងៗ។ ទិន្នន័យហិរញ្ញវត្ថុក្នុងប្រព័ន្ធ អាចធ្វើការវិភាគសម្រាប់គោលបំណងជាច្រើន ដូចជាការវាយតម្លៃនិន្នាការ ការវិភាគសមាមាត្រ និងគំរូហិរញ្ញវត្ថុផ្សេងៗ។ នៅពេលដែលមុខងារទាំងអស់នេះ ត្រូវបានរៀបចំឡើងនៅក្នុងប្រព័ន្ធ

តែមួយ ប្រព័ន្ធនេះត្រូវបានគេចាត់ទុកថាជាប្រព័ន្ធសមាហរណកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ(ហៅកាត់ថាប្រព័ន្ធ FMIS)។ ប្រព័ន្ធ FMIS គឺជាការធ្វើសមាហរណកម្មស្វ័យប្រវត្តិកម្មដំណើរការការងារការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបច្ចុប្បន្នកំពុងធ្វើដោយដៃ ដែលគ្របដណ្តប់ទាំងការធ្វើនីយ័តកម្មថវិកា, ការអនុវត្តថវិកា, គណនេយ្យ, របាយការណ៍, ការត្រួតពិនិត្យ, និងការធ្វើសវនកម្ម។ ប្រព័ន្ធនេះគ្របដណ្តប់លើសពីកម្មវិធីកុំព្យូទ័រ និងឧបករណ៍កុំព្យូទ័រ ដោយរាប់បញ្ចូលទាំងធនធានមនុស្ស អង្គភាព និងការគ្រប់គ្រងការផ្លាស់ប្តូរ ដែលនឹងនាំមកនូវនីតិវិធីអនុវត្តការងារថ្មីរបស់ក្រសួង ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ។

៤.៣.២.៧. ប្រព័ន្ធត្រួតពិនិត្យ

ក. សវនកម្មផ្ទៃក្នុង

សវនកម្មផ្ទៃក្នុង គឺជាសកម្មភាពពិគ្រោះយោបល់ និងការអះអាងដោយឯករាជ្យ មិនលម្អៀង ដើម្បីផ្តល់តម្លៃបន្ថែម និងកែលម្អប្រតិបត្តិការរបស់អង្គភាព ដែលជួយឱ្យអង្គភាពសម្រេចបាននូវគោលបំណងរបស់ខ្លួន ដោយប្រើប្រាស់អភិក្រមជាប្រព័ន្ធ មានជំនាញត្រឹមត្រូវ ក្នុងការវាយតម្លៃ និងបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រងហានិភ័យ ការគ្រប់គ្រងផ្ទៃក្នុង និងដំណើរការអភិបាលកិច្ចល្អ។ ក្នុងប្រទេសកម្ពុជា អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង គឺជាអង្គភាពក្រោមឱវាទ ក.ស.ហ.វ. មានមុខងារ និងការកិច្ចអនុលោមតាមអនុក្រឹត្យលេខ ៤០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃមុខងារសវនកម្មផ្ទៃក្នុងនៅតាមបណ្តាក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ។ មុខងារសំខាន់នៃសវនកម្មផ្ទៃក្នុង គឺវាយតម្លៃដោយឯករាជ្យ និងធ្វើឱ្យប្រសើរឡើងនូវប្រសិទ្ធភាពនៃការគ្រប់គ្រងហានិភ័យ ដំណើរការនៃប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនិង អភិបាលកិច្ចរបស់ក្រសួង-ស្ថាប័ន និងសហគ្រាសសាធារណៈ ដើម្បីរួមចំណែកធានាឱ្យគោលបំណង និងគោលដៅជាយុទ្ធសាស្ត្ររបស់ខ្លួនសម្រេចបានដោយជោគជ័យតាមការកំណត់។

ខ. អធិការកិច្ច

អធិការកិច្ចហិរញ្ញវត្ថុ មានបេសកកម្មត្រួតពិនិត្យលើអនុលោមភាព សមិទ្ធកម្មនៃការគ្រប់គ្រង និងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុសាធារណៈ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ដោយផ្អែកលើហានិភ័យ ករណីសង្ស័យ បណ្តឹងតវ៉ា និងបណ្តឹងបរិហារ។ គ្រប់ក្រសួង/ស្ថាប័នត្រូវរៀបចំឱ្យមានអង្គភាពអធិការកិច្ចរៀងៗ ខ្លួន ដែលដឹកនាំដោយរដ្ឋមន្ត្រី និងធ្វើរបាយការណ៍ជូនរដ្ឋមន្ត្រីក្រសួងសាមី។

ក.ស.ហ.វ. ជាសេនាធិការបច្ចេកទេស របស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចការអធិការកិច្ចហិរញ្ញវត្ថុលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងទ្រព្យសម្បត្តិរដ្ឋនៅក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលរាជធានី/ខេត្ត ក្រុង/ស្រុក/ខណ្ឌ ឃុំ/សង្កាត់ នីតិបុគ្គលសាធារណៈ និងឯកជនដែលទទួលផលប្រយោជន៍ពីហិរញ្ញវត្ថុសាធារណៈ ដោយអនុលោមតាមច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងលិខិតបទដ្ឋានគតិយុត្ត ពាក់ព័ន្ធជាធរមាន។

គ. សវនកម្មឯករាជ្យ

ស្ថាប័នសវនកម្មកំពូលឯករាជ្យ និងមានវិជ្ជាជីវៈ គឺជាកត្តាសំខាន់ នៅក្នុងខ្សែសង្វាក់គណនេយ្យភាពរបស់ប្រទេសមួយ។ ច្បាប់ស្តីពីសវនកម្ម នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០០ បានបង្កើតអាជ្ញាធរសវនកម្មជាតិ និងកំណត់ពីតួនាទី នៃសវនកម្មផ្ទៃក្នុង។ អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសាធារណៈមួយមានភាពឯករាជ្យ ហើយត្រូវធ្វើរបាយការណ៍នៃសនវកម្មជូនទៅរដ្ឋសភា, ព្រឹទ្ធសភាដោយផ្ទាល់ និងជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន។ អាជ្ញាធរសវនកម្មជាតិ មានការកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល។ អាជ្ញាធរសវនកម្មជាតិដឹកនាំដោយអគ្គសវនករមួយរូប និងមានអគ្គសវនកររងចំនួន ២រូប ។ ក្នុងការបំពេញបេសកកម្មរបស់ខ្លួន និងដើម្បីអនុវត្តច្បាប់នេះ,អាជ្ញាធរសវនកម្មជាតិមានសិទ្ធិអំណាចបំពេញសេចក្តីសម្រេច, បទបញ្ជា, សារាចរ, និងការណែនាំផ្សេងៗទៀត។

៤.៤. បេកគំហើញ

យោងតាមការស្វែងយល់អំពីប្រវត្តិសាស្ត្រជាង ២០០០ឆ្នាំ នៃអាណាចក្រខ្មែរ បានបង្ហាញថាទោះស្ថិតក្នុងកាលៈទេសៈលំបាកយ៉ាងណាក៏ដោយ ក៏ព្រះមហាក្សត្រខ្មែរគ្រប់រូប មានគោលការណ៍គ្រប់គ្រង ចាត់ចែង ប្រើប្រាស់ចំណូលរដ្ឋតាមរយៈការប្រមូលពន្ធ ការវិនិយោគជាមួយបណ្តាប្រទេសផ្សេងៗ ដើម្បីចំណាយលើការកសាងហេដ្ឋារចនាសម្ព័ន្ធ ក្នុងគោលដៅបម្រើផលប្រយោជន៍រួមជូនប្រជានុរាស្ត្រ ពង្រឹងនិងពង្រីកអាណាចក្ររបស់ព្រះអង្គ។ ក្នុងន័យនេះហិរញ្ញវត្ថុសាធារណៈ ពិតជាដើរតួនាទីយ៉ាងសំខាន់នៅក្នុងគោលនយោបាយអភិវឌ្ឍន៍ជាតិ និងជាឧបករណ៍ដ៏សក្តិសិទ្ធក្នុងការអនុវត្តកម្មវិធីកសាងជាតិរបស់រាជរដ្ឋាភិបាល តាមរយៈចក្ខុវិស័យរបស់ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធាន

ព្រឹទ្ធសភា និងជាប្រធានក្រុមឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា៖ **កែចម្រង់គឺ រស់ មិនកែចម្រង់ គឺស្លាប់** ជាមួយនឹងសមិទ្ធផលជាក់ស្តែងនៃកិច្ចការកែទម្រង់ ដើម្បីទទួលខុសត្រូវខ្ពស់ចំពោះវាសនាអនាគតជាតិ ឱ្យឈានឡើងរីកចម្រើនលូតលាស់សម្បូរបែប ជានិច្ចនិរន្តរ៍ និងប្រែក្លាយកម្ពុជា ឱ្យទៅជា កោះសន្តិភាព យ៉ាងពិតប្រាកដមួយ។

ជារួមរយៈពេល ២០ឆ្នាំមកនេះ ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាត្រូវបានបង្កើតឡើងតាមរយៈការផ្លាស់ប្តូរបន្តិចម្តងៗពីប្រព័ន្ធថវិកា ដែលផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្អែកលើធាតុចេញ ឬលទ្ធផល និងវិមជ្ឈការ។ ការវិវត្តរបស់របស់ថវិកានៅកម្ពុជា គឺចាប់ផ្តើមតាមរយៈការអនុវត្តតារាងគណនីទំនើបដោយផ្អែកលើស្តង់ដាគណនេយ្យសាធារណៈអន្តរជាតិ ការបង្កើតវិធីសាស្ត្រចាត់ថ្នាក់ថវិកាថ្មី ការបង្កើតរចនាសម្ព័ន្ធកូដប្រតិបត្តិការ និង នីតិវិធី និងវិធានគណនេយ្យ ការរៀបចំឱ្យមានការទទួលខុសត្រូវច្បាស់លាស់ តាមរយៈការបង្កើតរចនាសម្ព័ន្ធអង្គភាពថវិកាផ្សារភ្ជាប់ទៅនឹងការចាត់តាំងការងារនិងការចំណាយជាក់លាក់ ការបង្កើតរចនាសម្ព័ន្ធការរៀបចំរបាយការណ៍ឱ្យស្របទៅតាមស្តង់ដាអន្តរជាតិ និងបានបញ្ចូលការបង្កើតឧបករណ៍សម្រាប់រៀបចំកម្មវិធីរយៈពេលមធ្យម និងការដាក់ឱ្យអនុវត្តថវិកាកម្មវិធី ដែលក្នុងនោះ មានកិច្ចការមួយចំនួនតម្រូវឱ្យមានការធ្វើវិមជ្ឈការហិរញ្ញវត្ថុផងដែរក្នុងឆ្នាំ២០១៦។ ក្នុងដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយនឹងគោលដៅ "ការពង្រឹងគណនេយ្យភាពសមិទ្ធកម្ម" នេះ ដែល សំដៅទៅដល់ការទទួលខុសត្រូវផ្អែកលើលទ្ធផល ការកែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា បានឈានចូលមកដល់ដំណាក់កាលយុទ្ធសាស្ត្រកម្រិតខ្ពស់ ដែលជាគោលដៅដ៏ចម្បង របស់យើង នោះគឺការប្រែប្រួលជាសារវន្តផ្នែកគោលនយោបាយ និង យុទ្ធសាស្ត្រអាទិភាព ដែលសំដៅដល់ការពង្រឹងប្រសិទ្ធភាព គុណភាព និង ការទទួលខុសត្រូវ លើលទ្ធផលនៃការអនុវត្តរបស់ស្ថាប័នសាធារណៈ និង មន្ត្រីរាជការ ក្នុងក្របខណ្ឌរាជរដ្ឋាភិបាលទាំងមូល។ ក្នុងន័យនេះ សម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាមួយនឹងការទទួលបាននូវការផ្ទេរសិទ្ធិអំណាចក្នុងការគ្រប់គ្រងធនធានហិរញ្ញវត្ថុ

របស់ខ្លួន ក្រសួង ស្ថាប័ន នីមួយៗ នឹងត្រូវមានការទទួលខុសត្រូវខ្ពស់ លើការប្រើប្រាស់ថវិកាឱ្យបានប្រកបដោយ ប្រសិទ្ធភាព និង សក្តិសិទ្ធិភាព ព្រមទាំងចំគោលដៅកំណត់ ពោលគឺ ម្ខាងត្រូវទទួលខុសត្រូវលើការសម្រេចឱ្យបាន នូវគោលបំណងគោលនយោបាយ បេសកកម្ម និងសូចនាករ លទ្ធផលរំពឹងទុករបស់ខ្លួន អនុលោមតាមគោលការណ៍នៃ ″ការផ្សារភ្ជាប់ថវិកាទៅ នឹងគោលនយោបាយ″ និងម្ខាងទៀតត្រូវទទួលខុសត្រូវយ៉ាងម៉ឺងម៉ាត់លើការប្រើប្រាស់ថវិកាដែលត្រូវបានអនុម័តផ្តល់ជូនឱ្យបានប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ព្រមទាំងជានាបាននូវ «តម្លៃនៃលុយ» ស្របតាមបទប្បញ្ញត្តិនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាធរមាន និងឧត្តមានុវត្តន៍អន្តរជាតិ។

៤.៥. សេចក្តីសន្និដ្ឋាន

យោងតាមការសិក្សាហិរញ្ញវត្ថុរបស់រដ្ឋទាំងការប្រមូលចំណូលនិងការគ្រប់គ្រងចំណាយក្នុងសម័យអង្គរ រហូតដល់ការធ្លាក់នៅក្រោមអាណានិគមបារាំង និងការផ្លាស់ប្តូរបបនយោបាយជាច្រើនលើករច្រើនសា គឺបានបង្ហាញថាអាណាចក្រខ្មែរ ឬរដ្ឋាភិបាលខ្មែរ ឬព្រះរាជាណាចក្រកម្ពុជា គឺមាននីតិវិធីនៃការគ្រប់គ្រងសេដ្ឋកិច្ច ប្រតិបត្តិការហិរញ្ញវត្ថុជារបស់ខ្មែររួចមកហើយ គ្រាន់តែមានលក្ខណៈខុសៗគ្នា ទៅតាមសម័យកាលប៉ុណ្ណោះ។ រហូតមកដល់ក្រោយឆ្នាំ១៩៩៣ កម្ពុជាបានរៀបចំប្រព័ន្ធច្បាប់ និងរដ្ឋាភិបាលរបស់ខ្លួនឡើងវិញនៅក្រោមដំបូលនៃរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយទទួលយកជំនួយពីដៃគូអភិវឌ្ឍន៍ជាច្រើនប្រទេស ទាំងប្រទេសប្រកាន់យកប្រព័ន្ធ Civil Law និងប្រទេសប្រកាន់យកប្រព័ន្ធ Common Law ក្នុងគោលដៅចម្បងនៃសមាហរណកម្មប្រទេសឡើងវិញ ចូលនៅក្នុងនិម្មាបនកម្មតំបន់ និងសាកលលោក។ ជាក់ស្តែងចំពោះការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា គឺទទួលបានជំនួយទាំងហិរញ្ញវត្ថុ និងបច្ចេកទេសភាគច្រើនពីប្រទេសបារាំង និងដៃគូអភិវឌ្ឍន៍ (EU IMF WB ADB...) និងរួមបញ្ចូលជាមួយផ្នត់គំនិតរបស់កម្ពុជា។ បច្ចុប្បន្ន ប្រទេសកម្ពុជាបានទទួលយកបទពិសោធន៍របស់ប្រទេសបារាំងក្នុងការអនុវត្តថវិកាសមិទ្ធកម្មនេះ ពិសេស បានរៀនអំពីការកំណត់សូចនាករយុទ្ធសាស្ត្រ ស្តង់ដា នៃសូចនាករប្រសិទ្ធភាព និងភាពជឿជាក់ទុកចិត្តបាននិងស៊ីសង្វាក់នៃសូចនាករតាមពេលវេលា។

ទោះបីជាច្បាប់ ក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ នៅមានលក្ខណៈចម្រុះនៅឡើយប៉ុន្តែជារួម ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា បាននិងកំពុងធ្វើដំណើរនៅលើវិថី នៃគន្លងឆ្ពោះទៅរកស្តង់ដា និងឧត្តមានុវត្តន៍អន្តរជាតិតាមរយៈការដាក់ចេញនូវច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាបន្តបន្ទាប់ក្នុងក្របខ័ណ្ឌកែទម្រង់ ដើម្បីធានាបាននូវប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព និងគណនេយ្យភាពក្នុងបរិបទកម្ពុជា ហើយមានភាពបត់បែនខ្ពស់និងធន់ទៅនឹងការប្រែប្រួលសេដ្ឋកិច្ច សង្គម នៃសកលលោកតាមរយៈការប្រើប្រាស់ធនធានឱ្យបានត្រឹមត្រូវចំទិសដៅ (Spending Right) និងមានភាពឆ្លាតវៃក្នុងការចាយវាយ (Spending wise)[៤៧១] ជាពិសេសនឹងរួមចំណែកសម្រេចឱ្យបាននូវចក្ខុវិស័យ ឆ្នាំ២០៥០។

[៤៧១] សុន្នរកថា ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ វង្សី វិស្សុត អញ្ជើញប្រកាសផ្សព្វផ្សាយនិងដាក់ឱ្យអនុវត្ត គោលការណ៍ណែនាំស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ទីស្តីការគណៈរដ្ឋមន្ត្រី

៤.៦. អនុសាសន៍

ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ដូចជាច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ច្បាប់ស្តីពីរបបហិរញ្ញវត្ថុនិងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ច្បាប់ស្តីពីលទ្ធកម្មសាធារណៈ ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ ច្បាប់ស្តីពីការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគយ អនុក្រឹត្យស្តីពីការគ្រប់គ្រងបំណុលសាធារណៈ អនុក្រឹត្យស្តីពីការគ្រប់គ្រងការវិនិយោគសាធារណៈជាដើម មានលក្ខណៈប្រព័ន្ធច្បាប់ស៊ីវិល ដោយមូលហេតុ៖

- ប្រភពនៃច្បាប់ ជាប្រព័ន្ធច្បាប់ស៊ីវិល (ប្រទេសបារាំង)
- ច្បាប់រៀបចំតាមឋានានុក្រមនៃលិខិតបទដ្ឋានគតិយុត្ត
- ច្បាប់ មានលក្ខណៈសរសេរ
- វិធាននៃការតាក់តែងច្បាប់ដោយកំណត់ច្បាស់លាស់ពីផ្នែក ជំពូក មាត្រា
- ដំណើរការតាក់តែងនិងអនុម័តច្បាប់៖ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការជូនរាជរដ្ឋាភិបាល លើការរៀបចំសេចក្តីព្រាងច្បាប់ពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ដោយឆ្លងកិច្ចប្រជុំជាបន្តបន្ទាប់នៅទីស្តីការគណៈរដ្ឋមន្ត្រី ក្រុមប្រឹក្សាអ្នកច្បាប់ ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមនិងវប្បធម៌ កិច្ចប្រជុំអន្តរក្រសួង និងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី។ បន្ទាប់មកសេចក្តីព្រាងច្បាប់នោះបន្តបញ្ជូនទៅរដ្ឋសភា ដែលជាអ្នកបញ្ជូនបន្តទៅគណៈកម្មាធិការអចិន្ត្រៃយ៍ដើម្បីធ្វើការត្រួតពិនិត្យ និងផ្តល់យោបល់។ ពេលសន្មត់ថាចាំបាច់គណៈកម្មាធិការអចិន្ត្រៃយ៍អាចបញ្ជូនសេចក្តីព្រាងច្បាប់នេះបន្តទៅគណៈកម្មាធិការជំនាញ ដែលមានជំនាញពាក់ព័ន្ធនឹងខ្លឹមសារនៃសេចក្តីព្រាងច្បាប់នេះ ដើម្បីបន្តពិនិត្យ និងផ្តល់យោបល់ ឬក៏ដាក់បញ្ចូលផ្ទាល់ទៅសម័យប្រជុំពេញអង្គនៃរដ្ឋសភាដោយបញ្ចូលការដកដៃកដេញដោលលើសេចក្តីព្រាងច្បាប់នៅក្នុងរបៀបវារៈ។ នីតិវិធីចុងក្រោយ រដ្ឋាភិបាលត្រូវរៀបចំឯកសារគាំទ្រហើយបញ្ជូនរួមជាមួយសេចក្តីព្រាង ឬស្នើច្បាប់ដែលបានអនុម័តរួចរាល់ដោយអង្គនីតិបញ្ញត្តិ ទៅព្រះមហាក្សត្រដើម្បីប្រកាសឱ្យប្រើតាមរយៈព្រះរាជក្រម។ ច្បាប់ដែលត្រូវបានចុះហត្ថលេខាដោយព្រះ

មហាក្សត្រចូលជាធរមានហើយអាចអនុវត្តបានក្នុងរយៈពេល ១០ថ្ងៃ នៅក្នុងរដ្ឋធានី និង២០ថ្ងៃ សម្រាប់ទូទាំងប្រទេសបន្ទាប់ពីប្រកាសឱ្យប្រើ។ ច្បាប់បានប្រកាសជាបន្ទាន់ ចូលជាធរមានភ្លាមៗនៅទូទាំងប្រទេសបន្ទាប់ពីព្រះមហាក្សត្រឡាយព្រះហស្តលេខា។

- ខ្លឹមសារច្បាប់៖ ការចែងទាំងទិដ្ឋភាពទូទៅ និងទិដ្ឋភាពបច្ចេកទេស តាមគោលការណ៍អប្រតិសកម្ម មានន័យថា ច្បាប់មិនអាចអនុវត្តទៅលើសកម្មភាព ឬព្រឹត្តិការណ៍ ដែលកើតឡើងមុនពេលច្បាប់នោះ ក្នុងគោលបំណងដើម្បី **តម្លាភាព និងគណនេយ្យភាព** ៖ ប្រជាពលរដ្ឋត្រូវដឹងច្បាប់ជាមុន មុនធ្វើសកម្មភាព។ **ការពារសិទ្ធិមូលដ្ឋាន**៖ មិនអាចផ្តន្ទាទោស ឬទាមទារបុគ្គលលើសកម្មភាពដែលពេលនោះមិនទាន់ជាបទល្មើស និង**ស្ថិរភាពនៃប្រព័ន្ធច្បាប់**៖ ជៀសវាងការប្រែប្រួលថយក្រោយ។

ទោះជាយ៉ាងនេះក្តី ខ្លឹមសារច្បាប់ក្នុងប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយចំនួនខាងលើបានដកស្រង់បទពិសោធន៍នៃការអនុវត្តជាឧត្តមានុវត្តន៍អន្តរជាតិពីបណ្តាប្រទេសមួយចំនួនទាំងប្រទេសមានប្រព័ន្ធច្បាប់ Common Law និង ប្រព័ន្ធច្បាប់ស៊ីវិល ដូចជាប្រទេសបារាំង ប្រទេសអូស្ត្រាលី ប្រទេសស៊ុយអែត ប្រទេសអេស្តូនី ប្រទេសឥណ្ឌូនេស៊ី ប្រទេសម៉ាឡេស៊ី ប្រទេសហ្វីលីពីន និងប្រទេសវៀតណាមជាដើម។ ក្នុងន័យនេះប្រព័ន្ធច្បាប់កម្ពុជាគួររក្សាជាប្រព័ន្ធច្បាប់បែបចម្រុះដែលរក្សាស្តង់ដានៃការតាក់តែង បញ្ចូលខ្លឹមសារជាឧត្តមានុវត្តអន្តរជាតិដើម្បីកែលម្អប្រព័ន្ធហិរញ្ញវត្ថុសាធារណៈឱ្យកាន់តែល្អប្រសើរ និងរក្សាផ្នត់គំនិតកម្ពុជា ដែលច្បាប់ត្រូវបានតាក់តែងឡើងសម្រាប់រាជរដ្ឋាភិបាលកម្ពុជា និងប្រជាជនកម្ពុជាជាអ្នកអនុវត្តផង និងរក្សាគុណតម្លៃជាប្រវត្តិសាស្ត្ររបស់កម្ពុជាផង។

គន្ថនិទ្ទេស

សន្ធិសញ្ញារវាង ព្រះចៅអធិរាជបារាំង និង ព្រះមហាក្សត្រខ្មែរសន្ធិសញ្ញាឧត្តុង, ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៨៦៣ ដើម្បីកំណត់លក្ខខណ្ឌអាណាព្យាបាលបារាំង លើប្រទេសកម្ពុជា ; "Traité conclu à Oudon le ១១ août ១៨៦៣, réglant les conditions du Protectorat Français au Cambodge", Bulletin du Cambodge, Année ១៨៨៤ N° ១។

អនុសញ្ញារវាងបារាំងនិងកម្ពុជា, ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ; 'Convention entre la France et le Cambodge, le 9 juin 9GGG, pour régler les rapports respectifs des deux pays"។

ព្រះរាជក្រម នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ។

ព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ **ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០២០** ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់ និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ។

យុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាឆ្នាំ២០១៨-២០២៥។

យុទ្ធសាស្ត្រស្តីពីការកែទម្រង់ប្រព័ន្ធគ្រប់គ្រងការវិនិយោគសាធារណៈឆ្នាំ២០១៩-២០២៥។

យុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈ:២០១៩-២០២៣។

អាដេម៉ា ឡឺក្លែរ ២០០៥ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា បកប្រែដោយ ទេព ម៉ែង ឃាន ហៅទី ឃាឃុ ភ្នំពេញ៖ មជ្ឈមណ្ឌលឯកសារកម្ពុជា។

វង់ សុធារ៉ា (២០២១) សិលាចារឹកកម្ពុជាសម័យអង្គរ។

អាំង ជូលាន (២០២៥) ប្រវត្តិសាស្ត្រប្រទេសកម្ពុជាសម័យអង្គរ។

សៀវភៅស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ-បទពិសោធន៍កម្ពុជា, អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ចក្ខុវិស័យនិងយុទ្ធសាស្ត្រស្តីពីសុខដុមនីយកម្មកិច្ចការកែទម្រង់គន្លឹះនៃរាជរដ្ឋាភិបាល។

ផ្នែកទី៥. នីតិបរិស្ថាន

សិក្ខាអំពី «នីតិបរិស្ថាន»
លោក ម៉ិញ សុមេត្តា អ្នកជំនាញការច្បាប់
នៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.)

៥.១. សេចក្តីផ្តើម

ក្នុងឆ្នាំ២០១២ រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជាបានសម្រេចផ្តួចផ្តើមកំណែអភិបាលកិច្ចបរិស្ថាន ដើម្បីលើកកម្ពស់ចីរភាពបរិស្ថាននិងរក្សានូវការអភិវឌ្ឍសេដ្ឋកិច្ចរបស់ប្រទេស។ ជាផ្នែកមួយនៃដំណើរការកែទម្រង់នេះ កម្ពុជាបានចាប់ផ្តើមធ្វើការកែសម្រួលគួរឱ្យកត់សម្គាល់លើច្បាប់ជាច្រើនទាក់ទងនឹងបរិស្ថាន និងធនធានធម្មជាតិ។ ភាគច្រើននៃច្បាប់ទាំងនេះត្រូវបានរៀបចំតាក់តែងក្នុងទសវត្សរ៍ឆ្នាំ១៩៩០ ហើយបានបង្ហាញអំពីតម្រូវការរបស់រាជរដ្ឋាភិបាលក្នុងការលើកស្ទួយការអភិវឌ្ឍសេដ្ឋកិច្ច ក្នុងអំឡុងពេលនៃការកសាងជាតិឡើងវិញបន្ទាប់ពីការបំផ្លិចបំផ្លាញ និងការបាក់រលំនៃនីតិរដ្ឋមួយក្រោមអំណាចរបបខ្មែរក្រហមក្នុងចុងទសវត្សរ៍ឆ្នាំ១៩៧០។

ក្រមបរិស្ថាន និងធនធានធម្មជាតិ (ក្រមបរិស្ថាន) ត្រូវបានផ្តួចផ្តើមរៀបចំឡើងជាលើកដំបូងនៅឆ្នាំ២០១៥ ក្រោមការដឹកនាំរបស់ក្រសួងបរិស្ថាន ដោយមានគោលបំណងបង្កើតក្របខ័ណ្ឌច្បាប់មួយដែលមានឯកសណ្ឋានភាព និងគ្រប់ជ្រុងជ្រោយសម្រាប់អភិបាលកិច្ចបរិស្ថាន ការអភិរក្សធនធានធម្មជាតិ និងការអភិវឌ្ឍប្រកបដោយចីរភាព។ ការរៀបចំតាក់តែងក្រមបរិស្ថាននេះបង្ហាញឱ្យឃើញអំពីកំណែទម្រង់មួយនៃកំណែទម្រង់ច្បាប់ដ៏គួរឱ្យកត់សម្គាល់បំផុតក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ព្រះរាជាណាចក្រកម្ពុជា។ ក្រមនេះកំណត់អំពីវិធានទាំងឡាយដែលត្រូវគោរពនិងប្រតិបត្តិតាមក្នុងការពង្រឹង ធ្វើទំនើបកម្ម ធ្វើឱ្យមាន សង្គតិភាព និងធ្វើឱ្យប្រសើរឡើងនូវការគ្រប់គ្រងលើកិច្ចគាំពារបរិស្ថាន ការអភិរក្ស និងស្តារឡើងវិញនូវធនធានធម្មជាតិ ជីវៈចម្រុះ មុខងារប្រព័ន្ធអេកូឡូស៊ី ដើម្បីការរស់នៅនិងការអភិវឌ្ឍប្រកបដោយចីរភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា។[៤៧២]

ក្រមនេះឆ្លុះបញ្ចាំងអំពីកេរ្តិ៍ដំណែលប្រព័ន្ធច្បាប់ស៊ីវិលរបស់កម្ពុជា ខណៈពេលដែលក្រមនេះបានបញ្ចូលខ្លឹមសារមួយចំនួនពីយុត្តាធិការប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និង

[472] *Environmental and Natural Resources Code of the Kingdom of Cambodia (2023),* art. 1.

បទដ្ឋានច្បាប់បរិស្ថានអន្តរជាតិ។ ការរួមបញ្ចូលគ្នាទាំងនេះបង្ហាញអំពីការរួមចំណែកនៃច្បាប់បរិស្ថានជាសកល និងការរក្សាទំនៀមច្បាប់ជាតិក្នុងការអនុវត្តច្បាប់។

៥.២. ឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុន ទៅលើក្រមបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជា

៥.២.១. មូលដ្ឋានគ្រឹះនៃប្រព័ន្ធច្បាប់ស៊ីវិលនៅក្នុងប្រព័ន្ធច្បាប់កម្ពុជា

ប្រព័ន្ធច្បាប់របស់កម្ពុជា បានចាក់ឫសយ៉ាងរឹងមាំក្នុងប្រព័ន្ធច្បាប់ស៊ីវិល ដែលជាមរតកបន្សល់ទុកពីឥទ្ធិពលអាណាព្យាបាលបារាំង។ ជាប្រវត្តិសាស្ត្រ ក្រមនីយកម្ម (Codification) បានបម្រើជាវិធីសាស្ត្រចម្បងនៃការតាក់តែងច្បាប់ ដើម្បីធានាថាច្បាប់មានលក្ខណៈប្រព័ន្ធ មានភាពពេញលេញ និងអាចស្វែងរកបាន។ ក្រមបរិស្ថាន បានបន្តតាមប្រពៃណីនេះ ដោយទ្រង់ទ្រាយរបស់វាបានទាញយកគំរូពីក្រមបរិស្ថានបារាំង (Code de l'environnement) ដែលជាគំរូសំខាន់សម្រាប់ការរៀបចំ។ ក្រមនីយកម្មអនុញ្ញាតឱ្យមានការបង្រួបបង្រួមប្រមូលច្បាប់ដែលមានលក្ខណៈរាយប៉ាយ ស្ថិតក្រោមសមត្ថកិច្ចនៃរដ្ឋបាលផ្សេងៗ ដែលជាក់ស្តែងបណ្តាលឱ្យមានការជាន់សមត្ថកិច្ចគ្នា ឱ្យចូលជាច្បាប់តែមួយ ដើម្បីបង្ហាញពីទស្សនៈនៃប្រព័ន្ធច្បាប់ស៊ីវិលដែលផ្តោតលើអំណាចអធិបតេយ្យនៃច្បាប់ និងភាពទុកចិត្តបាន។

ដំណើរការនៃការតាក់តែងក្រមបរិស្ថាន ពឹងផ្អែកលើការងាររបស់ក្រុមការងារបច្ចេកទេសតាមវិស័យ (STWGs) ការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ននានា និងការស្រាវជ្រាវប្រៀបធៀបជាមួយយុត្តាធិការ ប្រព័ន្ធច្បាប់ស៊ីវិលនានា។ តាមការរាយការណ៍របស់លោក Baird និង Thomas ការងាររៀបចំក្រមនេះ មានបំណងកំណត់ឡើងវិញនូវកិច្ចការពារបរិស្ថាន និងការអភិរក្សធនធានធម្មជាតិនៅកម្ពុជា ស្របតាមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDGs) របស់អង្គការសហប្រជាជាតិ ដោយគ្របដណ្តប់លើគ្រប់ក្រសួង ស្ថាប័នជាមួយនឹងផលប្រយោជន៍រួមនៃការអភិវឌ្ឍន៍ប្រកបដោយចីរភាព។[៤៧៣] ឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិលនេះអាចឃើញបានច្បាស់តាមរយៈការផ្តោតលើគោលការណ៍

[473] Matthew Baird and Brendon Thomas, *"Developing an Environmental Code for Cambodia*," Chinese Journal of Environmental Law 1, no. 1 (2017): 100.

ទូទៅ រចនាសម្ព័ន្ធជាប្រព័ន្ធ និងការពឹងផ្អែកលើអនុក្រឹត្យនានាដែលមាន (សូមមើលឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះអនុក្រឹត្យផ្សេងៗរបស់ក្រសួងបរិស្ថាន)។

៥.២.២. ឥទ្ធិពលនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង

ខណៈដែលរចនាសម្ព័ន្ធនៃក្រមបរិស្ថាន ឆ្លុះបញ្ចាំងអំពីក្រមនីយកម្មនៃប្រព័ន្ធច្បាប់ស៊ីវិលក៏ដោយ ប៉ុន្តែខ្លឹមសារជាសារធាតុនៃក្រមនេះ ក៏បានដកស្រង់ពីយុត្តាធិការនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុងផងដែរ។ ដំណើរការនៃការតាក់តែងក្រមនេះ បានចាប់ផ្តើមដោយយកគំរូពីច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងអភិរក្សជីវៈចម្រុះរបស់ប្រទេសអូស្ត្រាលី ឆ្នាំ ១៩៩៩ (Environment Protection and Biodiversity Conservation Act) ដែលជាមូលដ្ឋានគ្រឹះនៃច្បាប់បរិស្ថានអូស្ត្រាលី។[៤៧៤] ច្បាប់នេះចាក់ឫសក្នុងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដែលផ្តោតលើយន្តការនិយ័តកម្មដែលមានលក្ខណៈបត់បែន ការគ្រប់គ្រងផ្អែកលើប្រព័ន្ធអេកូឡូស៊ី និងសិទ្ធិនីតិវិធីរឹងមាំក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)។[៤៧៥] ទាំងសហរដ្ឋអាមេរិក និងប្រទេសអូស្ត្រាលីគឺជាប្រទេសកាន់ប្រព័ន្ធសហព័ន្ធ ដូច្នេះច្បាប់បរិស្ថាននៅក្នុងប្រទេសទាំងនេះក៏ឆ្លុះបញ្ចាំងពីប្រព័ន្ធនយោបាយផ្សេងគ្នា និងដោះស្រាយជាមួយសិទ្ធិអំណាច និងការទទួលខុសត្រូវរបស់អាជ្ញាធរនៃសហព័ន្ធ និងរដ្ឋផ្សេងៗគ្នាដែរ។ ស្រដៀងគ្នានេះផងដែរ ច្បាប់បរិស្ថានរបស់សហរដ្ឋអាមេរិកក៏បានជះឥទ្ធិពលលើអ្នកសរសេរច្បាប់កម្ពុជា ជាពិសេសលើវិស័យនានា ដូចជាការកំណត់ស្តង់ដារបរិស្ថាន ការគ្រប់គ្រងធនធានធម្មជាតិ និងការចូលរួមជាសាធារណៈ។ ច្បាប់បរិស្ថានរបស់សហរដ្ឋអាមេរិកដែលត្រូវបានបង្កើតឡើងក្នុងបរិបទប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បានត្រួសត្រាយលិខិតូបករណ៍ ជាអាទិ៍ច្បាប់គោលនយោបាយបរិស្ថានជាតិ ដែលបង្កើតវិធានស្តាប់ឌនសម្រាប់ការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងការពិគ្រោះយោបល់ជាសាធារណៈ។[៤៧៦] កម្ងីពីគំរូច្បាប់ទាំងនេះ បានជួយប្រទេសកម្ពុជាធ្វើសមាហរណកម្មដំណើរការនៃការចូលរួមជាសាធារណៈ និងតម្លាភាពទៅក្នុងក្រមបរិស្ថាន[៤៧៧] ទោះបីជាមានការតម្រង់ទិសពីប្រព័ន្ធច្បាប់ស៊ីវិលក៏ដោយ។

[474] *Environment Protection and Biodiversity Conservation Act 1999* (Cth) (Australia).
[475] Lee Godden, "The EPBC Act and the Evolution of Australian Environmental Governance," *Environmental and Planning Law Journal* 27, no. 3 (2010): 179–196.
[476] *National Environmental Policy Act of 1969*, 42 U.S.C. § 4321 et seq.
[477] Baird and Thomas, "*Developing an Environmental Code for Cambodia*," 101.

៥.២.៣. ការប្រៀបធៀប និងការបញ្ចូលគោលការណ៍ច្បាប់អន្តរជាតិ

ក្រមបរិស្ថានក៏បានយកច្បាប់ចិនជាគំរូផងដែរ ទោះបីជាចិនជាប្រទេសប្រើប្រព័ន្ធសង្គមនិយមក៏ដោយ។ ច្បាប់បរិស្ថានចិនបញ្ចូលការគ្រប់គ្រងតាមបញ្ជារដ្ឋបាលជាមួយនឹងការអនុវត្តបត់បែនបាន។ ការយកគំរូច្បាប់ចិន ចូលរួមបង្ហាញពីការផ្សារភ្ជាប់ និងការទទួលស្គាល់ថ្នាក់តំបន់របស់កម្ពុជាអំពីបញ្ហាប្រឈមផ្នែកអភិបាលកិច្ច និងអេកូឡូស៊ីរួមគ្នា។ ថ្មីៗនេះ ប្រទេសចិនក៏បានពង្រីកតួនាទីរបស់តុលាការក្នុងការដោះស្រាយបញ្ហាប្រឈមបរិស្ថាន និងការបំពុល ដែលផ្តល់ការយល់ដឹងយ៉ាងសំខាន់ដល់អ្នកតាក់តែងច្បាប់កម្ពុជាផងដែរ។[៤៧៨] តាមការរាយការណ៍របស់លោក Baird និង Thomas ការរៀបចំក្រមបរិស្ថានបានប្រព្រឹត្តទៅក្រោមការសហការរវាងអ្នកជំនាញជាតិ និងអន្តរជាតិ ស្ថាប័នអន្តរក្រសួង ស្ថាប័នសង្គមស៊ីវិល សហគមន៍ជនជាតិដើមភាគតិច សហគមន៍មូលដ្ឋាន ជាច្រើន។[៤៧៩] វិធីសាស្ត្រប្រៀបធៀបនេះបង្ហាញពីការយកច្បាប់ល្អៗជាសកលមកបញ្ចូលក្នុងប្រព័ន្ធជាតិ និងបង្ហាញពីនិន្នាការរួមគ្នារបស់ច្បាប់បរិស្ថានទូទាំងពិភពលោក។

គួរកត់សម្គាល់ថា ក្រមបរិស្ថានកំណត់នូវគោលការណ៍ទូទៅសំខាន់ៗមួយចំនួនដែលត្រូវបានទទួលស្គាល់យ៉ាងទូលំទូលាយនៅក្នុងច្បាប់បរិស្ថានអន្តរជាតិ ជាអាទិ៍ជាគោលការណ៍នៃការអភិវឌ្ឍប្រកបដោយចីរភាព[៤៨០] ការចូលរួមជាសាធារណៈ[៤៨១] ការទទួលបានព័ត៌មានបរិស្ថាននិងធនធានធម្មជាតិ[៤៨២] ការទទួលខុសត្រូវរបស់បុគ្គលបំពុល[៤៨៣] ការប្រុងប្រយ័ត្នជាមុន[៤៨៤] ។ គោលការណ៍ទាំងនេះមានចែងនៅក្នុងគន្លឹះទី១ គោលការណ៍ទូទៅ មាតិកាទោលបទប្បញ្ញត្តិទូទៅ ជំពូកទី៣គោលការណ៍ទូទៅនៃក្រមបរិស្ថាន ដែលឆ្លុះបញ្ចាំងពីការប្តេជ្ញាចិត្តរបស់កម្ពុជា ស្របតាមបរិការណ៍ជាតិ និងបទដ្ឋានច្បាប់បរិស្ថានជាអន្តរជាតិ។

លើសពីនេះទៅទៀត មានគោលការណ៍ជាអន្តរជាតិផ្សេងទៀតដែលត្រូវធានាក្នុងក្រមបរិស្ថាន រួមមានសិទ្ធិទទួលបានព័ត៌មានបរិស្ថាន ការចូលរួមជាសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្ត និងសិទ្ធិទទួលបានយុត្តិធម៌និងដំណោះស្រាយ។ ខ្លឹមសារនៃបទ

[478] Supreme People's Court of China, *Provisions on the Establishment of Environmental Courts* (2014).
[479] Baird and Thomas, "*Developing an Environmental Code for Cambodia*," 101–102.
[480] *Environmental and Natural Resources Code of the Kingdom of Cambodia* (2023), art. 9.
[481] *Environmental and Natural Resources Code of the Kingdom of Cambodia* (2023), art. 11.
[482] *Environmental and Natural Resources Code of the Kingdom of Cambodia* (2023), art. 12.
[483] *Environmental and Natural Resources Code of the Kingdom of Cambodia* (2023), art. 13.
[484] *Environmental and Natural Resources Code of the Kingdom of Cambodia* (2023), art. 15.

ប្បញ្ញត្តិទាំងបីនេះ ក្លាយជាសសរស្តម្ភនៃលទ្ធិប្រជាធិបតេយ្យបរិស្ថាន ដូចដែលមានចែងនៅក្នុងសេចក្តីប្រកាសទីក្រុងRioស្តីពីបរិស្ថាននិងការអភិវឌ្ឍ (ឆ្នាំ១៩៩២) និងអនុសញ្ញាAarhusស្តីពីសិទ្ធិទទួលបានព័ត៌មាន ការចូលរួមសាធារណៈក្នុងការធ្វើសេចក្តីសម្រេចចិត្តនិងសិទ្ធិទទួលបានយុត្តិធម៌ក្នុងបញ្ហាបរិស្ថាន (ឆ្នាំ១៩៩៨)។[៤៨៥] ការដាក់បញ្ចូលខ្លឹមសារនៃបទប្បញ្ញត្តិទាំងនេះទៅក្នុងក្រមបរិស្ថាន បង្ហាញអំពីការអនុលោមរបស់ប្រទេសកម្ពុជាជាមួយនឹងស្តង់ដារអភិបាលកិច្ចបរិស្ថានអន្តរជាតិ ដែលកំណត់បរិបទក្នុងក្របខ័ណ្ឌច្បាប់នៃក្រមនីយកម្ម និងការពង្រឹងការអនុវត្តផ្នែករដ្ឋបាល។

[485] United Nations, Rio Declaration on Environment and Development (1992); Aarhus Convention (1998).

៥.៣. សេចក្តីសន្និដ្ឋាន

ក្រមបរិស្ថាន និងធនធានធម្មជាតិរបស់កម្ពុជា គឺជាលិខិតូបករណ៍កូនកាត់ (hybrid) ដែលផ្អែកលើរចនាសម្ព័ន្ធនៃប្រពៃណីប្រព័ន្ធច្បាប់ស៊ីវិលនៃក្រមនីយកម្ម ប៉ុន្តែត្រូវបានបញ្ចូលជាសារវន្តនូវនុវានុវត្តន៍ពីយុត្តាធិការប្រព័ន្ធច្បាប់អង់គ្លូសាក់សុង និងស្តង់ដារបរិស្ថានអន្តរជាតិ។ ក្នុងន័យនេះ ក្រមបរិស្ថានគឺជាឧទាហរណ៍អំពីរបៀបដែលច្បាប់បរិស្ថានសកលបានដាក់បញ្ចូលគ្នាកាន់តែខ្លាំងឡើងនៅក្នុងខ្លឹមសារនៃច្បាប់ជាតិ ទោះបីជាវប្បធម៌ឬផ្នត់គំនិតច្បាប់ជាតិជាអ្នកកំណត់បែបផែនឬយន្តការនៃការអនុវត្តច្បាប់ក៏ដោយ។ សម្រាប់ប្រទេសកម្ពុជា ក្រមបរិស្ថានឆ្លុះបញ្ចាំងទាំងការប្តេជ្ញាចិត្តក្នុងការអនុលោមតាមឧត្តមានុវត្តន៍អន្តរជាតិ និងការទទួលស្គាល់នូវឥទ្ធិពលនៃប្រព័ន្ធច្បាប់ស៊ីវិលក្នុងប្រទេសកម្ពុជា។ បញ្ហាប្រឈមខាងមុខមិនស្ថិតនៅលើការព្រងច្បាប់ពេញលេញនោះទេ ប៉ុន្តែក្នុងការធានាឱ្យមានការអនុវត្តប្រកបដោយប្រសិទ្ធភាពពីគ្រប់ក្រសួង ស្ថាប័ន ជាកិច្ចការដែលគួរតែសិក្សាស្វែងយល់ពីទាំងទំនៀមប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ដើម្បីជាមគ្គទេសក៍នាពេលអនាគត។

ឧបសម្ព័ន្ធ៖ បញ្ជីឈ្មោះអនុក្រឹត្យផ្សេងៗរបស់ក្រសួងបរិស្ថាន

០១ អនុក្រឹត្យលេខ២៣៨ អនក្រ.បក ស្តីពីការបង្កើតមូលនិធិបរិស្ថាន និងសង្គម ចុះថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៦

០២ អនុក្រឹត្យ លេខ ៧២ អនក្រ.បក ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩

០៣ អនុក្រឹត្យលេខ២៣៥ អនក្រ.បក ស្តីពីការគ្រប់គ្រងប្រព័ន្ធលូ និងប្រព័ន្ធប្រព្រឹត្តកម្មទឹកកខ្វក់ ចុះថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៧

០៤ អនុក្រឹត្យលេខ ១១៣ អនក្រ.បក ស្តីពីការគ្រប់គ្រងសំរាម សំណល់រឹងទីប្រជុំជន ចុះថ្ងៃទី២៧ ខែសីហា ឆ្នាំ២០១៥

០៥ អនុក្រឹត្យលេខ ១៦៨ អនក្រ.បក ស្តីពីការគ្រប់គ្រងថង់ប្លាស្ទិក ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៧

០៦ អនុក្រឹត្យលេខ៤២ អនក្រ. បក ស្តីពីការត្រួតពិនិត្យការបំពុលខ្យល់ និងការរំខានដោយសំលេង ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០០

០៧ អនុក្រឹត្យលេខ៤៧ អនក្រ.បក ស្តីពីការគ្រប់គ្រងសារធាតុបំផ្លាញស្រទាប់អូហ្សូន ចុះថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០០៥

០៨ អនុក្រឹត្យលេខ១៦ អនក្រ.បក ស្តីពីការគ្រប់គ្រងសំណល់បរិក្ខារអគ្គិសនី និងអេឡិចត្រូនិក ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៦

ផ្នែកទី៦. នីតិសិទ្ធិមនុស្ស

សិក្ខាអំពី «សិទ្ធិមនុស្សតាមបរិបទកម្ពុជា»

លោក អៀប សុធានី អនុប្រធាននាយកដ្ឋានគោលនយោបាយនិងផែនការ
នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិកំណែទម្រង់ច្បាប់ (គ.ក.ច.)

៦.១. សេចក្តីផ្តើម

នៅក្នុងន័យមនុស្សជាតិ រូបវន្តបុគ្គលម្នាក់ៗស្ថិតក្រោមការពាររបស់ច្បាប់អន្តរជាតិ ទាមទារឱ្យមានសកម្មភាពគាំពាររវាងរដ្ឋនិងរដ្ឋនៅលើឆាកអន្តរជាតិ ដែលនៅក្នុងនោះកម្មវត្ថុនៃការពារសិទ្ធិរបស់ប្រជាពលរដ្ឋនីមួយៗ គឺជាកិច្ចការដែលត្រូវធ្វើការការពារពីសំណាក់រដ្ឋទៅវិញទៅមក។ ប្រជាពលរដ្ឋគឺជាប្រធាននៃនីតិសកម្មនៅក្នុងនីតិអន្តរជាតិសាធារណៈ។ ការគាំពារពីសំណាក់រដ្ឋ គឺជាកិច្ចចាំបាច់តាមរយៈដោយត្រូវបង្កើតស្ថាប័នការពារតាមផ្លូវការទូតទៅលើប្រជាពលរដ្ឋ ដែលជាស្មារតីទទួលខុសត្រូវរួមនៅលើឆាកអន្តរជាតិ និងជាសកម្មភាពជាអាទិភាពរបស់រដ្ឋនីមួយៗក្នុងពិភពលោក។

បើនិយាយនៅក្នុងក្របខ័ណ្ឌជារួម រដ្ឋនិងប្រជាពលរដ្ឋត្រូវពឹងពាក់គ្នាទៅវិញទៅមកដើម្បីរស់ក៏ជាជាកាតព្វកិច្ចរបស់រដ្ឋនៅក្នុងការការពារស្របតាមច្បាប់អន្តរជាតិផងដែរ។ បុគ្គលម្នាក់ៗដែលជាប្រធាននៃនីតិអនុវត្តនូវបុគ្គលភាពគតិយុត្តពេញលេញរបស់ខ្លួននៅក្នុងក្របខ័ណ្ឌនៃសណ្តាប់ធ្នាប់គតិយុត្តអន្តរជាតិ តាមរយៈសកម្មភាពរបស់រដ្ឋ អង្គការអន្តរជាតិ ដោយហេតុថា ប្រធាននៃនីតិអន្តរជាតិទាំងនោះមាននូវបុគ្គលភាពគតិយុត្តនឹងត្រូវអនុវត្តសកម្មភាពការងារនៅក្របខ័ណ្ឌនៃកម្មវត្ថុរបស់ខ្លួនដូចកំណត់នៅក្នុងលក្ខន្តិកៈបង្កើត ដើម្បីការពារផលប្រយោជន៍ស្របច្បាប់របស់មនុស្សជាតិ។ ជាការពិត ការការពារតាមផ្លូវការទូតគឺជា មធ្យោបាយជាអាទិភាព ដែលប្រែប្រួល ទៅតាមទីតាំងភូមិសាស្ត្រ ប្រវត្តិសាស្ត្រ កាលៈទេសៈ និងប្រព័ន្ធគតិយុត្តជាតិរបស់រដ្ឋ ឬអង្គការអន្តរជាតិនីមួយៗ។ ដើម្បីទទួលបានការការពារក្នុងនាមជាពលរដ្ឋរបស់ប្រទេសមួយ បុគ្គលម្នាក់ៗត្រូវមានសញ្ជាតិរបស់រដ្ឋនោះ ដើម្បីទទួលបានការការពារពីប្រទេសរបស់ខ្លួន ឬប្រទេសដែលបុគ្គលនោះកំពុងមានវត្តមាន។

បន្តិចម្តងៗ បញ្ហាសិទ្ធិមនុស្ស បានក្លាយទៅជាប្រធានបទដែលត្រូវដោះស្រាយនៅលើឆាកអន្តរជាតិ និងក្លាយទៅជាទិសដៅក្នុងការការពារជាចម្បងស្របតាមច្បាប់អន្តរជាតិ តាមរយៈការបង្កើតប្រពន្ធគតិយុត្ត និងស្ថាប័នទទួលបន្ទុកផ្នែកសិទ្ធិមនុស្សអន្តរជាតិ។ សិទ្ធិ

គឺជាចំណោទបញ្ហាសំខាន់ដែលមនុស្សម្នាក់ៗត្រូវមានជាពិសេសសិទ្ធិក្នុងការតទល់ជាមួយនឹងរដ្ឋដែលខ្លួនស្ថិតនៅក្រោមការគ្រប់គ្រង ដោយហេតុថា នៅក្នុងប្រវត្តិសាស្ត្រ របស់មនុស្សជាតិ ជាពិសេសនៅមុនសង្គ្រាមលោកលើកទី២ មនុស្សភាគច្រើនរស់នៅក្នុង របបទាសភាព ហេតុនេះក្រោយការធ្វើបដិវត្ត ពិសេសក្រោយសង្គ្រាមលោកលើកទី២ មនុស្សចាប់ផ្តើមទាមទារសិទ្ធិរបស់ខ្លួន និងបានបង្កើតជាស្តង់ដារួមទាក់ទងទៅនឹងសិទ្ធិ មនុស្សអន្តរជាតិ ដូចមានកំណត់ នៅក្នុង «**សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស ក្របខ័ណ្ឌសហប្រជាជាតិ ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨**»។

ការគោរពសិទ្ធិមនុស្សរបស់ប្រទេស និងអង្គការអន្តរជាតិមានលក្ខណៈសកល និងមានលក្ខណៈ មិនច្បាស់លាស់ អាស្រ័យទៅតាមប្រព័ន្ធគតិយុត្តជាតិរបស់ប្រទេសនីមួយៗ មិនមានការកំណត់និយមន័យបានច្បាស់លាស់ទៅលើបញ្ហាសិទ្ធិមនុស្សនេះឡើយ។ ជាក់ស្តែង នៅក្នុងស្តីពីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស ចុះថ្ងៃទី១០ ខែធ្នូ ឆ្នាំ១៩៤៨ បានធ្វើការកំណត់អំពីសិទ្ធិសំខាន់ៗ និងសិទ្ធិដែលគួរទទួលបានក្នុងនាមជាមនុស្ស ដូចជា៖ សិទ្ធិរស់រានមានជីវិត សិទ្ធិរួចផុតពីការធ្វើទុក្ខបុកម្នេញ សិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ដែលសិទ្ធិទាំងនេះត្រូវផ្សារភ្ជាប់ជាមួយសិទ្ធិនយោបាយ សិទ្ធិសង្គម សិទ្ធិសេដ្ឋកិច្ច និងវប្បធម៌ដែលជាតម្រូវការរួមរបស់មនុស្សជាតិ។ រូបវន្តបុគ្គលគឺជាប្រធាននៃនីតិ ពោលគឺជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ចដែលមាននូវបុគ្គលភាពគតិយុត្ត។ នៅក្នុងអត្ថន័យជីវៈវិទ្យា រូបវន្តបុគ្គលសំដៅដល់បុគ្គលដែលមានសាច់ មានឈាម ប្រសូតចេញពីផ្ទៃម្តាយអាចរស់ និងរស់បាន។ បុគ្គលភាពគតិយុត្តគឺជាសញ្ញាណសំខាន់ដើម្បីឱ្យបុគ្គលម្នាក់ក្លាយជារូបវន្តបុគ្គល។ នៅក្នុងករណីមិនទទួលបានបុគ្គលភាពគតិយុត្ត បុគ្គលនោះមិនទទួលបានស្ថានភាពជារូបវន្តបុគ្គលឡើយ។ ឧទាហរណ៍៖ នៅក្នុងប្រវត្តិរបស់មនុស្សជាតិទាសករមិនទទួលបានបុគ្គលភាពគតិយុត្តក្នុងនាមជាប្រធាននៃនីតិឡើយ។ រូបវន្តបុគ្គលយើងអាចហៅម៉្យាងទៀតថាមនុស្សពីធម្មជាតិ។ ប៉ុន្តែ ក្រោយសេចក្តីប្រកាស ជាសកលស្តីពីសិទ្ធិមនុស្សក្របខ័ណ្ឌអង្គការសហប្រជាជាតិឆ្នាំ១៩៤៨ បង្កើតជាគោលការណ៍លុបបំបាត់របបទាសភាព ជាហេតុនាំឱ្យមនុស្សពីធម្មជាតិទាំងអស់មាននូវបុគ្គលភាពគតិយុត្ត។ ជាកត្តាសត្យានុម័ត បុគ្គលភាពគតិយុត្តនេះទទួលបានតាំងពីកំណើតរបស់មនុស្ស មានអានុភាពប្រតិសកម្មភាព តាំងពីទារកចាប់កំណើតពីផ្ទៃម្តាយ និងត្រូវបាត់បង់បុគ្គលភាពគតិយុត្តទៅវិញនៅពេលមនុស្សនោះស្លាប់បាត់ជីវិត ឬត្រូវបានសន្មត់ថាបានស្លាប់។

បុគ្គលភាពគតិយុត្តបង្កើតអានុភាពគតិយុត្ត នូវសមត្ថភាពអនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់បុគ្គល ម្នាក់ៗ ពោលគឺសិទ្ធិទាមទារឱ្យមានការអនុវត្តកាតព្វកិច្ចពីសំណាក់បុគ្គលដទៃ សិទ្ធិជាមូលដ្ឋានគ្រឹះរបស់ បុគ្គលដែលត្រូវបានធានានៅក្នុងច្បាប់ជាតិនិងច្បាប់អន្តរជាតិ សិទ្ធិក្នុងការចូលរួមសកម្មភាពការងារផ្សេងៗ នៅក្នុងសង្គមដូចជា៖ សិទ្ធិក្នុងការចុះកិច្ចសន្យា សិទ្ធិក្នុងនាមជាកម្មសិទ្ធករ ការចូលរួមផ្តល់សក្ខីកម្ម និង ការធ្វើបណ្តឹងទៅតុលាការជាដើម។ ទន្ទឹមនឹងនេះ បុគ្គលម្នាក់ៗមានកាតព្វកិច្ចនៅក្នុងការគោរពច្បាប់ជាតិ ច្បាប់អន្តរជាតិ កាតព្វកិច្ចក្នុងការគោរពសិទ្ធិរបស់បុគ្គលដទៃ និងកិច្ចសន្យាដែលបុគ្គលបានចុះបង្កើតអានុភាពគតិយុត្ត និងចងជាកាតព្វកិច្ចសម្រាប់ខ្លួន។

ក្នុងនាមជាប្រទេសប្រកាន់គោលការណ៍នីតិរដ្ឋ សិទ្ធិទាំងនេះត្រូវតែធានានៅក្នុងប្រទេសនីមួយៗ ពោលគឺ សិទ្ធិនិងសេរីភាព ដែលត្រូវតែធានានៅក្នុងក្របខ័ណ្ឌអន្តរជាតិ ប៉ុន្តែការពារសិទ្ធិទាំងចាំបាច់ត្រូវធ្វើឡើងតាមបរិបទ ចរិតលក្ខណៈប្រជាពលរដ្ឋ ស្ថានភាពជាក់ស្តែងរបស់ប្រទេសនោះ មិនអាចកំណត់ជានិយាមមួយបានឡើយ ។ និយាយដោយឡែក សម្រាប់កម្ពុជា បញ្ហាសិទ្ធិមនុស្សនេះត្រូវបានគិតគូរ និងត្រូវបានធានានៅក្នុងរដ្ឋធម្មនុញ្ញចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ ត្រង់ជំពូកទី៣ «សិទ្ធិ និងករណីកិច្ចរបស់ប្រជាពលរដ្ឋខ្មែរ» មាត្រា៣១ «*ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់និងគោរពសិទ្ធិមនុស្សដូចមានចែងក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស និងកតិកាសញ្ញាទាំងឡាយទាក់ទងទៅនិងសិទ្ធិមនុស្ស សិទ្ធិនារី និងសិទ្ធិកុមារ។ ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់មានសិទ្ធិសេរីភាពនិងករណីកិច្ចដូចគ្នាទាំងអស់ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈ សង្គមធនធានឬស្ថានភាពឯទៀតឡើយ។ ការប្រើសិទ្ធិ សេរីភាព ផ្គាល់ខ្លួនរបស់បុគ្គលម្នាក់ៗមិនត្រូវប៉ះពាល់សិទ្ធិសេរីភាពអ្នកដទៃឡើយ ។ ការប្រើប្រាស់សសិទ្ធិសេរីភាពនេះត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់។*» មាត្រា ៤៦ «*អំពើលក់ដូរមនុស្ស អំពើរអាជីវកម្មផ្នែកពេស្យាកម្ម និងអំពើរអាសអាភាស ដែលប៉ះពាល់ដល់សេចក្តីថ្លៃថ្នូររបស់នារី ត្រូវហាមឃាត់ ។ត្រូវហាមឃាត់មិនឱ្យមានការបញ្ឈប់ពីរការងារ ដោយមូលហេតុមានគភ៌ ។ នារីមានសិទ្ធិឈប់សំរាកពេលសម្រាលកូនដោយទទួលប្រាក់បៀវត្ស និងដោយមានការធានារកសាសិទ្ធិអតិតភាពក្នុងការងារ ។និងអត្ថប្រយោជន៍សង្គមផ្សេងៗទៀត ។ រដ្ឋនិងសង្គមយកចិត្តទុកដាក់បង្ការលក្ខណៈ ឲ្យនារី ជាពិសេសនារីនៅជនបទដែលគ្មានទីពឹង បានទទួលការឧបត្ថម ដើម្បីមានមុខរបរ មានលទ្ធភាពព្យាបាលជំងឺ ឱ្យកូនទៅរៀន និងមានជីវភាពរស់នៅសមរម្យ ។*»

សម្រាប់កម្ពុជាការការពារសិទ្ធិមនុស្សត្រូវបានធ្វើទំនើបកម្ម និងត្រូវបានគិតគូរតាំងពីរាជ្យព្រះមហាក្សត្រ **នរោត្តម** ពោលគឺតាំងពីមុនសេចក្តីប្រកាសសិទ្ធិមនុស្ស១០ ធ្នូ ឆ្នាំ ១៩៤៨ មកម្ល៉េះ ដោយលុបចោលទាសករ ឬខ្ញុំបម្រើ តាមរយៈព្រះរាជប្រកាស ដូចតទៅ៖

ព្រះរាជប្រកាសចុះថ្ងៃទី១៥ ខែមករា ឆ្នាំ១៨៧៧ ស្តីពីការកំណែទម្រង់នានាពាក់ព័ន្ធនឹងរដ្ឋាភិបាល និងរដ្ឋបាលនៃព្រះរាជាណាចក្រកម្ពុជា ដោយមានបញ្ញត្តិអំពី ការលុបបំបាត់របបទាសករមួយជីវិត ដើម្បីធ្វើការកាត់បំណុល

អនុសញ្ញាបារាំងខ្មែរ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ១៨៨៤ ស្តីពីកំណែទម្រង់នានានៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រង់មាត្រា៨ ចែងអំពីការប្រកាសលុបបំបាត់របបទាសភាពនៅកម្ពុជា

ព្រះរាជប្រកាសចុះថ្ងៃទី១១ ខែកក្កដា ឆ្នាំ១៨៩៧ ស្តីពីការលុបបំបាត់ទំនៀមទម្លាប់នៃការប្រើប្រាស់ពល

ព្រះរាជប្រកាសចុះថ្ងៃទី៣០ ខែកក្កដា ឆ្នាំ១៨៩៩ ស្តីពីការហាមឃាត់ការបង្ខំឱ្យធ្វើការកាត់បំណុល។

នៅក្នុងក្របខ័ណ្ឌអង្គការសហប្រជាជាតិ ការវាយតម្លៃទៅលើស្ថានភាពសិទ្ធិមនុស្សត្រូវបានធ្វើដោយផ្អែកទៅលើបទប្បញ្ញត្តិមានចែងក្នុងធម្មនុញ្ញសហប្រជាជាតិ សេចក្តីប្រកាសជាសាកលស្តីពីសិទ្ធិមនុស្ស កត្តិកាសញ្ញាស្តីពីសិទ្ធិស៊ីវិល និងសិទ្ធិនយោបាយ ក្នុងគោលដៅដើម្បីការពារសិទ្ធិ និងសេរីភាពរបស់បុគ្គលម្នាក់ៗ។ ដើម្បីធ្វើការវាយតម្លៃទៅលើស្ថានភាពសិទ្ធិមនុស្ស គណៈកម្មការសិទ្ធិមនុស្សសហប្រជាជាតិបានរៀបចំសៀវភៅ « មគ្គទេសក៍វាស់ស្ទង់ និងបំពេញបន្ថែមទៅលើស្ថានភាពសិទ្ធិមនុស្ស[៤៨៦]» ការគិត និងវិធានការវាស់ស្ទង់អំពីសិទ្ធិមនុស្សនេះ មានចរិតលក្ខណៈបែបលោកខាងលិច ដោយគិតគូរទៅលើបញ្ហា៖ ស្ថិយភាពនៃសិទ្ធិស៊ីវិល សិទ្ធិនយោបាយ សេរីភាពរបស់មនុស្ស។

៦.២. សិទ្ធិរស់រានមានជីវិត

សម្រាប់កម្ពុជា បានអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគោរពសិទ្ធិមនុស្ស តាមរយៈការរំដោះប្រទេសចេញពីរបបខ្មែរក្រហម ការបញ្ចប់សង្គ្រាមនៅក្នុងកម្ពុជាស្របតាមនយោបាយឈ្នះ-ឈ្នះ និងការដឹកនាំប្រទេសរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីត

[486] Human Rights Indicator, a guide to measurement and implementation,2012.

នាយករដ្ឋមន្ត្រី និងជាប្រធានព្រឹទ្ធសភានាពេលបច្ចុប្បន្ន ជាការធានានូវសិទ្ធិរស់រានមានជីវិតរបស់ប្រជាពលរដ្ឋខ្មែរ ការដាក់ចុះនូវនយោបាយកែទម្រង់រដ្ឋចាប់តាំងពីឆ្នាំ១៩៨៩ ជាពិសេសនយោបាយសេដ្ឋកិច្ចគឺជាការគោរព និងធានានូវសិទ្ធិមនុស្ស។ សម្រាប់កម្ពុជាគឺជាប្រទេសមានប្រវត្តិសាស្ត្រដ៏យូរលង់ មានវប្បធម៌ អរិយធម៌ និងនិយាមសង្គមដោយឡែករបស់ខ្លួន ខុសពីនិយាមសង្គមរបស់ពួកលោកខាងលិច។

៦.៣. សិទ្ធិខាងជំនឿ សាសនា ឥស្សរធម៌ ប្រពៃណី

ខ្មែរយើងមានជំនឿតាំងពីមុនពេលក្លឹង្គចូលម្ល៉េះ ដោយជឿទៅលើអារក្ស អ្នកតា ខ្មោចជូនតា ជំនឿនេះនាំឱ្យមានការរាប់រកគ្នាយ៉ាងស្មោះត្រង់នៅតាមភូមិស្រុក មានសាមគ្គីភាពគ្នា មានភាពស្និទស្នាលនៅក្នុងសង្គម នាំឱ្យមនុស្សស្គាល់បុណ្យ ស្គាល់បាប ស្គាល់សេចក្តីល្អ អាក្រក់។

ទំនៀមទម្លាប់ គឺការចូលចិត្ត ការនិយមនូវរបស់អ្វីមួយ ហើយរបស់នោះត្រូវបានឆ្កិតជាប់ទៅនឹងជីវភាពរបស់មនុស្ស ជាពិសេសជំនឿ ខ្មោច អារក្ស អ្នកតា ឬជំនឿលើធម្មជាតិ។ ឧទាហរណ៍៖ កាលណាគេឃើញផ្កាយដុះកន្ទុយគេសន្និដ្ឋានថាស្រុកពិតជាកើតកោលាហលពុំខាន ដូចជាមានសង្គ្រាម ឬទឹកជំនន់។

បើទោះបីជាមិនមានអក្សរសម្រាប់ធ្វើការកត់ត្រាក្បួនខ្នាតក៏ដោយ នៅក្នុងសម័យបុរេប្រវត្តិ តែក៏ស្តុតាងនៃការកប់សម្ភារប្រើប្រាស់ ម្ហូបអាហារក្នុងផ្នូរបង្ហាញថាខ្មែរបុរាណមានសីលធម៌ក្នុងទម្លាប់គោរពអ្នកស្លាប់ ដែលអាចសន្មត់បានថា ជាការដឹងខុស ដឹងត្រូវ ដឹងគុណ ដឹងទោស ដឹងបុណ្យ ដឹងបាប ដោយគេជឿថាអ្នកស្លាប់នឹងបានទទួលសម្ភារៈអាហារទាំងនោះសម្រាប់ប្រើប្រាស់នៅបរលោក[៤៨៧]។

ទស្សនវិជ្ជារបស់មនុស្សនាសម័យបុរេ ក៏ជាកត្តាជះឥទ្ធិពលដល់ការរស់នៅរបស់មនុស្ស និងសកម្មភាពរបស់មនុស្សនៅក្នុងសង្គមដែរ ទាក់ទងទៅនឹងការត្រិះរិះពិចារណារបស់មនុស្ស។ ទស្សនវិជ្ជារបស់មនុស្សនាសម័យនោះគឺការព្យាយាមពន្យល់មនុស្សអំពីកំណើតរបស់សត្វលោកឬមនុស្សតាមទស្សនៈរបស់ខ្លួន ភាគច្រើនទាក់ទងនឹងទេវកថានៅក្នុងរឿងព្រេងជាដើម។ ឧទាហរណ៍៖ កាលដែលបុព្វបុរសយើងកប់ខ្មោចឱ្យអង្គុយចោងហោងក្នុងក្រឡ បញ្ជាក់ថា មនុស្សដែលស្លាប់ទៅ អាចចាត់ទុកថាជាទារកនៅក្នុងផ្ទៃ

[៤៨៧] ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណេ បោះពុម្ពផ្សាយឆ្នាំ១៩៩៦ ទំព័រ១៣។

ម្តាយមុននឹងកើត។ បើគេយកខ្មោចទៅកប់ក្នុងដី ដូចទារនៅក្នុងផ្ទៃម្តាយ គេជឿថាជីវិតមិនសាបសូន្យក្រោយពេលស្លាប់ឡើយ ដោយព្រលឹងត្រូវចាប់ជាតិឡើងវិញ[៤៨៨]។

ព្រះពុទ្ធសាសនាមហាយានត្រូវបានគេសន្មត់ថា ត្រូវបានខ្មែរបុរាណគោរពប្រតិបត្តិតាំងពីសម័យមុនពេលក្លឹង្គចូលទៅទៀត ដោយហេតុថាក្រោយព្រះពុទ្ធបរិនិព្វានទៅប្រមាណ ២១៨ឆ្នាំ ព្រះរាជមួយអង្គព្រះនាមព្រះបាទធម្មសោកមហារាជ ក្រងរាជនៅក្នុងរាជធានីបាតលិបុត្តនៃមគធរដ្ឋ បានចាត់ឱ្យមានការផ្សព្វផ្សាយព្រះពុទ្ធសាសនាទៅកាន់បច្ចន្តប្បទេសនានាក្រៅពីដែនដីមធ្យមប្រទេស និងបានឧបត្ថម្ភឱ្យមានការធ្វើតតិយសង្គាយនា នៅព.ស.២៣៤ ដោយទ្រង់ហៅថា «*បើកនាំសកលលោកហើយបំភ្លឺឱ្យប្រជានិករបានស្គាល់ពុទ្ធសាសនាតាំងពីសម័យកាលនោះមក*»។ នៅក្នុងសម័យកាលនោះមានព្រះសោណត្ថេរ និងព្រះឧត្តរត្ថេរ បាននិមន្តមកកាន់ដែនដីសុវណ្ណភូមិ គេមិនអាចកំណត់ថានៅចន្លោះចិន និងឥណ្ឌាកន្លែងណាជាដែនដីសុវណ្ណភូមិ ដោយហេតុថាប្រទេសនីមួយៗនៅក្នុងតំបន់អាស៊ីអាគ្នេយ៍សុទ្ធតែចាត់ទុកព្រះថេរៈទាំងពីរអង្គ ជាប្រពៃណីបុរាណរបស់ប្រទេសរៀងៗខ្លួន[៤៨៩]។ នៅត្រង់ចំណុចនេះយើងអាចសន្មត់បានថា ព្រះពុទ្ធសាសនាមហាយានគឺត្រូវបានខ្មែរបុរាណគោរពប្រតិបត្តិ។

នៅក្នុងសម័យបុរេប្រវត្តិយើងមិនមានការបង្កើតអក្សរធ្វើការកត់ត្រា ទៅលើព្រឹត្តិការណ៍ សកម្មភាពរស់ប្រចាំថ្ងៃ ច្បាប់ ទម្លាប់របស់មនុស្សនៅក្នុងសម័យនោះឡើយ ហេតុនេះការស្វែងយល់អំពីច្បាប់ប្រពៃណីរបស់មនុស្សនៅក្នុងសម័យនោះធ្វើឡើងតាមរយៈការសិក្សាស្វែងយល់ទៅលើបុរាណវិទ្យា នៅតាមស្ថានីយ៍បុរេប្រវត្តិ និងការសិក្សាអំពីនរវិទ្យាតែប៉ុណ្ណោះ។ ការសិក្សាទៅលើចំណុចទាំងនេះ អាចឱ្យយើងស្វែងយល់អំពីរបៀបរបបក្នុងការរស់នៅ ប្រព័ន្ធរដ្ឋបាល និងការគ្រប់គ្រងរដ្ឋបាលរបស់មនុស្សនៅសម័យបុរេ។ យោងតាមសាស្ត្រាចារ្យបណ្ឌិត Louis Assier-Andrieu បណ្ឌិតផ្នែកនរវិទ្យាពីសាលាសិក្សាធិការជាន់ខ្ពស់ វិទ្យាសាស្ត្រសង្គមទីក្រុងប៉ារីសឆ្នាំ១៩៨០ និងជាបណ្ឌិតច្បាប់ពីសាកលវិទ្យា Toulouse ១ Capitole ឆ្នាំ១៩៨៥ បានលើកឡើងថា «*បាតុភូតគតិយុត្ត និងទីកន្លែងដែលជាមជ្ឈដ្ឋាននៃសង្គមមនុស្សត្រូវបានបង្ហាញតាមរយៈនរវិទ្យា*»[៤៩០]។ នីតិគឺជាសញ្ញាណមានលក្ខណៈជាសកល ហេតុធាតុផ្សំរបស់នីតិមានភាពចម្រុះអាស្រ័យទៅលើ

---

[៤៨៨] ប្រភពឯកសារដៃដែល ទំព័រ១៤។

[៤៨៩] សៀវភៅចក្ខុវិស័យព្រះពុទ្ធសាសនា២៥០០ ស្រាវជ្រាវដោយព្រះវិរិយបណ្ឌិតោ **ប៉ាង ខាត់** ផ្សព្វផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ ទំព័រទី១០។

[490] Les Droit dans la société humaine, Louis Assier-Andrieu, in 1997, P.461.

វប្បធម៌ មជ្ឈដ្ឋានសង្គម និងសម័យកាលរស់នៅរបស់មនុស្ស។ នីតិគឺជាផ្នែកមួយនៃជីវភាពរបស់នៅរបស់មនុស្ស ជាផ្នែកមួយនៃសេដ្ឋកិច្ចសង្គម «*ការរស់នៅរបស់មនុស្សនៅក្នុងសង្គមត្រូវផ្សារភ្ជាប់ទៅនឹងច្បាប់*» ។ ច្បាប់គឺជាមូលដ្ឋានគ្រឹះសម្រាប់ដឹកនាំសង្គម សម្រាប់សង្គមខ្មែរនាសម័យបុរេប្រវត្តិគឺផ្អែកទៅលើភាសា និងវប្បធម៌[៤៩១]។ ការគ្រប់គ្រងរដ្ឋបាលរបស់ខ្មែរ វប្បធម៌ និងប្រព័ន្ធច្បាប់របស់ខ្មែរបុរាណត្រូវបានអនុវត្តលាយឡំគ្នាតាមប្រព័ន្ធរបស់ឥណ្ឌានៅពេលក្លឹងចូលស្រុកនៅដើមស.វ.ទី១ នៃគ.ស.[៤៩២]។ វប្បធម៌របស់ប្រជាជាតិអាស៊ីអាគ្នេយ៍ទទួលឥទ្ធិពលពីវប្បធម៌ធំៗពីរ គឺ៖ វប្បធម៌ចិន និងវប្បធម៌ឥណ្ឌា ជាក់ស្តែងការគ្រប់គ្រងរដ្ឋ និងប្រព័ន្ធរដ្ឋបាលរបស់ខ្មែរនាសម័យបុរេប្រវត្តិ សម័យមុនអង្គរ ការគ្រប់គ្រងរដ្ឋបាលរបស់រដ្ឋត្រូវបានធ្វើតាមការគ្រប់គ្រងបែបស្តេចចក្រពត្តិ ដែលជាការគ្រប់គ្រងបែបឥណ្ឌា ផ្សំជាមួយនឹងវប្បធម៌ និងអរិយធម៌គ្រឹះរបស់ខ្មែរ ដែលនៅក្នុងនោះ វប្បធម៌ឥណ្ឌាបានហូលចូលមកដែនដីសុវណ្ណភូមិ មុនការចូលមកដល់នៃវប្បធម៌ចិននៅក្នុងសម័យហ្វូណន[៤៩៣]។

ការគ្រប់គ្រងរដ្ឋ និងច្បាប់ទម្លាប់នៅសម័យនោះការគោរពប្រតិបត្តិទៅលើច្បាប់ប្រពៃណី (customary) មូលដ្ឋាន គ្រឹះនៃការគ្រប់គ្រងរដ្ឋនៅក្នុងសម័យហ្វូណន និងនៅក្នុងសម័យចេនឡា ដែលជាសម័យកាលមុនអង្គរ ត្រូវបានគេប្រើប្រាស់ជាមូលដ្ឋានគ្រឹះក្នុងការសន្មត់ទៅលើប្រព័ន្ធនៃការគ្រប់គ្រងរដ្ឋ និងច្បាប់ទម្លាប់រស់នៅរបស់មនុស្សខ្មែរនាសម័យបុរេប្រវត្តិ។ នៅក្នុងនោះ គេបានសិក្សាទៅលើការរីកសាយភាយនៃវប្បធម៌ឥណ្ឌាទៅក្នុងឧបទ្វីបឥណ្ឌូចិន ជាពិសេស ទៅក្រុមអំបូរមនុស្សអូស្ត្រូអាស៊ីដែលរស់នៅក្នុងឧបទ្វីបឥណ្ឌូចិន ដែលការណ៍នេះបានចាប់ផ្តើមរីកសាយភាយនៅក្នុងសម័យយុគ្គថ្មរំលីងដោយប្រព័ន្ធរដ្ឋបាលនោះមេនិយម ពោលគឺស្ត្រីជាធំ (matriarchate) ព្រមទាំងមានការគោរពទៅលើសត្វដែលគេជឿថាជាបុព្វបុរសរបស់មនុស្ស (Totemic beliefs) ដែលជាសម័យកាលនៃ Pre-Aryan Inda[៤៩៤]។

អរិយធម៌ Aryan ត្រូវបានរីកសាយភាយទៅលើឧបទ្វីបឥណ្ឌូចិន តាមរយៈវប្បធម៌នៃការដាំដុះ ធ្វើស្រែ ចម្ការ ការចិញ្ចឹមសត្វ និងការប្រើប្រាស់គោក្របី ចាប់ផ្តើមចេះប្រើ

---

[491] Thèse Doctorat ‘’Culturalisme et historiographie du Cambodge ancien : a propos de la hiérarchisation des sources de l’histoire Khmère ‘’, Éric Bourdonneau, le 3 Avril, 2020, P.41.
[492] *Idem*, P. 41
[493] Idem, P.43
[494] The Indianized States of Soudest-Asia,3rd Edition G. Coedes, edited by Walter F. Vella Translated by Susan Brown Cowing in 1963, P.8

ប្រាស់លោហៈធាតុ ចំណេះដឹងប្រើប្រាស់ត្រីវិស័យ ដោយមានជំនឿសាសនាគោរពទៅលើព្រះ មានទឹក ដី ភ្លើង ខ្យល់[៤៩៥]។

៦.៤. សិទ្ធិសេដ្ឋកិច្ច

មាត្រា៣៦ នៃរដ្ឋធម្មនុញ្ញ៖ «ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិជ្រើសរើសមុខរបរសមស្របតាមសមត្ថភាពរបស់ខ្លួន តាមសេចក្តីត្រូវការរបស់សង្គម ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិទទួលប្រាក់បំណាច់ស្មើគ្នាចំពោះការងារដូចគ្នា។ ការងារមេផ្ទះមានតម្លៃស្មើគ្នានិងកម្រៃដែលបានមកពីការងារធ្វើនៅក្រៅផ្ទះ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធទទួលការធានារ៉ាប់រងសង្គម និងអត្ថប្រយោជន៍ខាងសង្គមកិច្ច ដែលមានចែងក្នុងច្បាប់ ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទ មានសិទ្ធិបង្កើតសហជីព និងចូលជាសមាជិកសហជីពនេះ ។ ការរៀបចំ និងការប្រព្រឹត្តទៅនៃសហជីព និងមានកំណត់ក្នុងច្បាប់ ។» ដើម្បីធានាបាននូវសិទ្ធិសេដ្ឋកិច្ចរបស់ប្រជាពលរដ្ឋរាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានចុះជាបន្តបន្ទាប់នូវនយោបាយសេដ្ឋកិច្ច រាប់ចាប់ពីយុទ្ធសាស្ត្រត្រីកោណ យុទ្ធសាស្ត្រចតុកោណ និងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី១ នៃរាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា។ ជាក់ស្តែងដើម្បីសម្រេចបាននូវមហិច្ឆតាក្លាយជាប្រទេសដែលមានចំណូលមធ្យមកម្រិតទាបនៅឆ្នាំ២០៣០ និងជាប្រទេសមានចំណូលខ្ពស់នៅឆ្នាំ២០៥០ ការកែទម្រង់ច្បាប់គឺជាវិស័យគន្លឹះអាទិភាព[៤៩៦]។ មាត្រា៦០ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា៖ «ពលរដ្ឋមានសិទ្ធិលក់ដូរផលិតផលរបស់ខ្លួនដោយសេរី។ ការតម្រូវឱ្យលក់ផលិតផលជូនរដ្ឋ ឬការតកោគផល ឬទ្រព្យសម្បត្តិឯកជន ទៅប្រើប្រាស់ ទោះបីមួយរយៈពេលក៏ដោយត្រូវហាមឃាត់ រៀលែងតែក្នុងករណីពិសេស ដែលមានច្បាប់អនុញ្ញាត។»

៦.៥. សិទ្ធិទទួលបានការអប់រំ

ការអប់រំគឺជាកាតព្វកិច្ចរបស់រាជរដ្ឋាភិបាល ត្រូវបានបញ្ញត្តិនៅក្នុងរដ្ឋធម្មនុញ្ញ មាត្រា៦៦ «រដ្ឋកសាងប្រព័ន្ធអប់រំមួយពេញលេញនិងឯកភាពទូទាំងប្រទេសដែលធានាឱ្យបាននូវគោលការណ៍សេរីភាពខាងសោក្សាធិការ និងគោលការណ៍សមភាព ក្នុងការអប់រំ ដើម្បីឱ្យប្រជាពលរដ្ឋគ្រប់រូបមានភ័ព្វសំណាងគ្រប់គ្រាន់ស្មើគ្នាក្នុងការកសាងជីវិត»

---

[495] *Idem,* P.9

[៤៩៦] មុំទី៤. ការលើកកម្ពស់ និងការពង្រឹង ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌, យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១, ទំព័រ៣៩។

។ តាមរយៈគោលនយោបាយចារឹកនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ៈ រាជរដ្ឋាភិបាល បានយកចិត្តទុកដាក់ដោយធ្វើការគិតគូរទៅលើការបណ្តុះបណ្តាលទាំងជំនាញទន់ និងជំនាញរឹង ការកសាងធនធានមនុស្ស ការបង្កើតមូលធនមនុស្ស ដើម្បីឆ្លើយតបទៅនឹងទីផ្សារស្របតាមបរិការណ៍កម្ពុជា និងបរិបទអន្តរជាតិ ជាពិសេសទៅលើការកសាងមូលធនឌីជីថល។ ការពង្រឹងគុណភាព និងសេវាកម្មអប់រំ ទាំងគ្រឹះស្ថានសាធារណៈ និងឯកជន ដោយមានក្រសួងអប់រំយុវជន និងកីឡា ជាសេនាធិការ។

៦.៦. សិទ្ធិនយោបាយ

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បញ្ញត្តិអំពីត្រង់មាត្រា ១ វាក្យខ័ណ្ឌទី ១ «ប្រទេសកម្ពុជាជាព្រះរាជាណាចក្រដែលព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យ សេរីពហុបក្ស»។ មាត្រា ៥ ១ ថ្មី «ព្រះរាជាណាចក្រកម្ពុជា អនុវត្តនយោបាយអធិបតេយ្យ សេរីពហុបក្ស ។ ប្រជាពលរដ្ឋខ្មែរជាម្ចាស់វាសនានៃប្រទេសជាតិរបស់ខ្លួនតាមរយៈរដ្ឋសភា ព្រឹទ្ធសភា រាជរដ្ឋាភិបាល និងសាលាជំរះក្តី។ អំណាចបែងចែកដាច់ពីគ្នា រវាងអំណាចនិតិបញ្ញត្តិ អំណាចនិតិប្រតិបត្តិ និងអំណាចតុលាការ។» ការប្រកាសរំលាយគណបក្សសង្គ្រោះជាតិ គឺជាសេចក្តីសម្រេច របស់តុលាការ ជាការអនុវត្តច្បាប់ មិនធ្វើឱ្យមានការប៉ះពាល់សិទ្ធិចូលរួម និងសិទ្ធិខាងនយោបាយរបស់ប្រជាពលរដ្ឋដូចការអះអាង និងការលើកឡើងរបស់ប្រទេសលោកខាងលិចឡើយ[៤៩៧]។ ការណ៍នេះ ធ្វើឡើងនៅក្នុងគោលបំណងដើម្បីធានានូវឯករាជ្យ អធិបតេយ្យភាពជាតិ ឯកភាពជាតិ និងសុខសន្តិភាពនៃព្រះរាជាណាចចក្រកម្ពុជា មិនមានចំណុចណាមួយផ្ទុយអំពីស្មារតីរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាឡើយ (មាត្រា ៥៥ «សន្ធិសញ្ញានិងកិច្ចព្រងព្រៀងទាំងឡាយណា ដែលមិនស្របនិងឯករាជ្យ អធិបតេយ្យ បូរណភាពទឹកដី អព្យាក្រឹតភាព និងឯករាជភាពជាតិ របស់ព្រះរាជាណាចក្រកម្ពុជា ត្រូវលុបចោល។»

ការបង្កើតច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចុះថ្ងៃទី ១២ ខែសីហា ឆ្នាំ ២ ០ ១ ៥ ធ្វើឡើងនៅក្នុងគោលបំណងការពារផលប្រយោជន៍ ស្របច្បាប់របស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ព្រមទាំងធានាបាននូវការអភិវឌ្ឍសង្គមកម្ពុជា។ យោងរបាយការណ៍ចុងក្រោយរបស់ក្រសួងមហាផ្ទៃ គិតត្រឹមខែកញ្ញា ឆ្នាំ ២ ០ ២ ៤ មានអង្គការសមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកបានចុះបញ្ជីនៅក្រសួងមហាផ្ទៃ

[៤៩៧] ច្បាប់ស្តីពីវិសោធនកម្មច្បាប់ស្តីពីគណបក្សនយោបាយ ចុះថ្ងៃទី ៧ ខែមីនា ឆ្នាំ ២ ០ ១ ៧ ត្រង់មាត្រា ៦ ថ្មី មាត្រា ១ ៨ ថ្មី។

ចំនួន ១ ៩៦១ ក្នុងនោះមានសមាគម ១ ១៣៣ និងអង្គការមិនមែនរដ្ឋាភិបាលចំនួន ៨២៨។ គ្រប់គ្រងទៅលើសមាគម និងអង្គការមិនមែនរដ្ឋាភិបាលមិនមែន ជាការរឹតត្បិតទៅលើសិទ្ធិក្នុងការចូលរួមរបស់ប្រជាពលរដ្ឋឡើយ ប៉ុន្តែដើម្បីធានាបាននូវការមិនជ្រៀតជ្រែកកិច្ចការផ្ទៃពីសំណាក់រដ្ឋបរទេស ឬអង្គការសមាគមអន្តរជាតិ តាមរយៈការផ្តល់ជំនួយហិរញ្ញវត្ថុ ឬការធ្វើសកម្មភាពប្រឆាំងរដ្ឋក្រោមទម្រង់ជាអង្គការសង្គមស៊ីវិល ការណ៍នេះក៏ត្រូវបានលើកឡើងដោយលោក J.J. Rousseau ផងដែរ សិទ្ធិសេរីភាពតាមបែបធម្មជាតិត្រូវបានកម្រិតក្នុងក្របខ័ណ្ឌច្បាប់ ជាឆន្ទៈទូទៅរបស់សង្គម។ នៅក្នុងបញ្ហានេះ លោក Kofi Annan អតីតអគ្គលេខាធិការអង្គការសហប្រជាជាតិធ្លាប់បានលើកឡើងនៅក្នុងឆ្នាំ ១ ៩ ៩ ៨ « Good Gouvernance is perhaps the most important factor in eradicating poverty and promoting development» ហេតុនេះអភិបាលកិច្ចល្អ ក៏ត្រូវមានសម្រាប់សមាគម អង្គការសង្គមស៊ីវិលផងដែរ ដើម្បីឱ្យការប្រើប្រាស់មូលនិធិ ធនធានរបស់ខ្លួនបានត្រឹមត្រូវ។

៦.៧. សេរីភាពបញ្ចេញមតិ

មនុស្សម្នាក់ៗមានសេរីភាពក្នុងការបញ្ចេញមតិ ប៉ុន្តែការអនុវត្តសេរីភាពនេះត្រូវធ្វើឡើងស្របតាមរដ្ឋធម្មនុញ្ញ និងនៅក្នុងក្របខ័ណ្ឌច្បាប់ជាធរមាន។ ការប្រយុទ្ធប្រឆាំងនឹងព័ត៌មានក្លែងក្លាយ ព័ត៌មាន មានចេតនាញុះញ៉ុង ក្នុងគោលដៅបង្កអសន្តិសុខ ប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ មិនមែនជាការរឹតត្បិតសេរីភាពក្នុងការបញ្ចេញមតិ និងសេរីភាព ខាងសារព័ត៌មាន ដូចការលើកឡើងរបស់សាធារណៈមតិជាតិ និងអន្តរជាតិមួយចំនួនឡើយ។ នៅក្នុងក្របខ័ណ្ឌអាស៊ាន ប្រទេសឥណ្ឌូនេស៊ី ជាប្រធានប្តូរវេណ បានដាក់ចុះនូវគោលការណ៍នាំស្តីពីការប្រយុទ្ធប្រឆាំងព័ត៌មានក្លែងក្លាយ នៅក្នុងឆ្នាំ២០២៣ បង្ហាញអំពីជំហររបស់អាស៊ានក្នុងការយកចិត្តទុកដាក់ទៅលើបញ្ហានេះ សម្រាប់កម្ពុជាសារព័ត៌មានក៏ត្រូវបានប្រើប្រាស់ជាឧបករណ៍នយោបាយផងដែរ។ ច្បាប់ស្តីពីរបបសារព័ត៌មាន មិនមានអនីត្យានុកូលភាពទៅនឹងខ្លឹមសារ រដ្ឋធម្មនុញ្ញ មាត្រា ៤១ «ប្រជាពលរដ្ឋខ្មែរមានសេរីភាពខាងបញ្ចេញមតិរបស់ខ្លួន សេរីភាពខាងសារព័ត៌មាន សេរីភាពខាងបោះពុម្ពផ្សាយ សេរីភាពខាងការប្រជុំ ។ ជនណាក៏ដោយមិនអាចឆ្លៀតប្រើសិទ្ធិនេះដោយរំលោភនាំឱ្យប៉ះពាល់ដល់កិត្តិយស់របស់អ្នកដ៏ទៃ ដល់ទំនៀមទម្លាប់ល្អរបស់សង្គម ដល់សណ្តាប់ធ្នាប់សាធារណៈ និងដល់សន្តិសុខជាតិបានឡើយ ។ របបសារព័ត៌មាន ត្រូវរៀបចំឡើងដោយច្បាប់ ។» ហើយស្របទៅនឹងមាត្រា១៩ និងមាត្រា២០ នៃកតិកាសញ្ញា

ស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ ដែលកម្ពុជាបានផ្តល់សច្ចាប័ននៅក្នុងឆ្នាំ១៩៩២។ កាលពីខែកញ្ញា ឆ្នាំ២០២៤ ក្រសួងព័ត៌មាន បានដាក់ចុះនូវធម្មនុញ្ញវិជ្ជាជីវៈសារព័ត៌មាន នេះគឺជាការពង្រឹងការអនុវត្តវិជ្ជាជីវៈសារព័ត៌មាន។

៦.៨. សេចក្តីសន្និដ្ឋាន

កម្ពុជាបានអនុវត្តយ៉ាងពេញលេញនូវការគោរពសិទ្ធិមនុស្ស ជាពិសេសសិទ្ធិរស់រានមានជីវិត សិទ្ធិខាងជំនឿ សាសនា វប្បធម៌ប្រពៃណី សិទ្ធិសេដ្ឋកិច្ច សិទ្ធិទទួលបានការអប់រំ សិទ្ធិនយោបាយ សិទ្ធិសេរីភាពបញ្ចេញមតិ ហើយការអនុវត្តនេះឈរលើស្មារតីនៃរដ្ឋធម្មនុញ្ញ គោលការណ៍នីតិរដ្ឋ ស្របច្បាប់ជាធរមាននៃព្រះរាជាណាចក្រកម្ពុជា និងបរិការណ៍អន្តរជាតិ។

គន្ថនិទ្ទេស

Human Rights Indicator, a guide to measurement and implementation,2012.

ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ពីបុព្វសម័យដល់ស.វ.ទី៨ ដោយបណ្ឌិត មីសែល ត្រាណោ បោះពុម្ពផ្សាយឆ្នាំ១៩៩៦។

សៀវភៅចក្ខុវិស័យព្រះពុទ្ធសាសនា២៥០០ ស្រាវជ្រាវដោយព្រះវិរិយបណ្ឌិតោ ប៉ាង ខាត់ ផ្សព្វផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនបណ្ឌិត្យ។

Les Droit dans la société humaine, Louis Assier-Andrieu, in 1997។

Thèse Doctorat ״Culturalisme et historiographie du Cambodge ancien : a propos de la hiérarchisation des sources de l׳histoire Khmère ״, Éric Bourdonneau, le 3 Avril, 2020។

The Indianized States of Soudest-Asia,3 rd Edition G. Coedes, edited by Walter F. Vella Translated by Susan Brown Cowing in 1963។

យុទ្ធសាស្ត្របញ្ចាកោណ ដំណាក់កាលទី១។

ជំពូកទី២.
នីតិឯកជន

ផ្នែកទី១. នីតិការងារ

សិក្ខាអំពី «នីតិការងារ»
ឯកឧត្តមបណ្ឌិត លឹម ស៊ុយហុង អនុរដ្ឋលេខាធិការ
ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

១.១. សេចក្តីផ្តើម

ច្បាប់មានតួនាទីសំខាន់ណាស់ក្នុងការរៀបចំការប្រព្រឹត្តទៅរបស់ស្ថាប័ន ការរស់នៅនិងការបំពេញការងាររបស់មនុស្សដែលជាសមាជិកសង្គម។ ប្រទេសកម្ពុជាដែលមានវប្បធម៌ អរិយធម៌ដ៏ចំណាស់មួយ នៅទ្វីបអាស៊ី បានបង្កើតនូវក្បួនច្បាប់សម្រាប់គ្រប់គ្រងនគររបស់ខ្លួន ហើយច្បាប់ទាំងនោះមានការប្រែប្រួលផ្លាស់ប្តូរជាបន្តបន្ទាប់ទៅតាមសម័យកាល។ នៅក្នុងបរិបទដែលសេដ្ឋកិច្ច សង្គម និងបទដ្ឋានគតិយុត្តវិវត្តទៅមុខឥតឈប់ឈរ និងដោយឆាប់រហ័ស ការសិក្សាអំពីអត្តសញ្ញាណច្បាប់ពិតជាមានសារៈសំខាន់ ដើម្បីស្គាល់ពីឫសគល់ ពីមូលដ្ឋាននៃការបង្កើតច្បាប់ ដើម្បីអាចវាយតម្លៃពីភាពស៊ីចង្វាក់ក៏ដូចជាការតម្រង់ទិសក្នុងការរៀបចំបទដ្ឋាននាពេលអនាគតឱ្យមានប្រសិទ្ធភាពសមស្របតាមភាពជាក់ស្តែងរបស់សង្គម។ ក្នុងន័យនេះ ប្រធានបទស្តីពីការស្វែងរកអត្តសញ្ញាណច្បាប់ការងារកម្ពុជានឹងសិក្សាលើអត្ថិភាព ការវិវត្តន៍ និងការវាយតម្លៃទៅលើភាពប្រែប្រួលរបស់វា ឬអាចនិយាយម្យ៉ាងទៀតថា តើច្បាប់ការងារបច្ចុប្បន្នបានរក្សានូវទំនាក់ទំនងដូចម្តេចជាមួយច្បាប់ខ្មែរបុរាណ? តើអត្តសញ្ញាណច្បាប់ការងារកម្ពុជាមានការផ្លាស់ប្តូរដូចម្តេចក្រោយទទួលរងឥទ្ធិពលពីច្បាប់បរទេស និងច្បាប់អន្តរជាតិ? តើច្បាប់វិជ្ជមានក្នុងវិស័យការងារពិតជាបានឆ្លើយតបជាវិជ្ជមានជាមួយបរិបទសង្គមដែរ ឬទេ? ការសិក្សាស្រាវជ្រាវខ្លីនេះមិនផ្តោតលើចំណុចជាក់លាក់នីមួយៗនៅក្នុងវិស័យការងារទេ ប៉ុន្តែពិនិត្យជារួមទៅលើអត្តសញ្ញាណច្បាប់ការងារកម្ពុជា ដើម្បីស្វែងរកភាពចុះសម្រុងគ្នារវាងបទដ្ឋានគតិយុត្តនិងតម្រូវការពិតរបស់សង្គម។

១.២. ការកើត និងការវិវត្តន៍ច្បាប់ខ្មែរក្នុងវិស័យការងារ

ដើម្បីភាពងាយស្រួលក្នុងការសិក្សា យើងបែងចែកជាពីរសម័យកាល ពោលគឺសម័យអង្គររហូតដល់ពេលបារាំងដាក់អាណាព្យាបាលលើកម្ពុជា ដែលពេលនោះប្រព័ន្ធ

ច្បាប់ខ្មែរមិនទាន់ទទួលរងឥទ្ធិពលពីប្រព័ន្ធច្បាប់ទំនើប ជាពិសេសប្រព័ន្ធច្បាប់ស៊ីវិល បើទោះបីជាពេលនោះអាចមានការផ្លាស់ប្តូរវប្បធម៌ផ្នែកគតិយុត្តជាមួយបណ្តាប្រទេសធំៗ ដូចជាឥណ្ឌា និងចិនក៏ដោយ និងចាប់ពីសម័យអាណាព្យាបាលបារាំងរហូតមកដល់បច្ចុប្បន្ន ដែលអត្តសញ្ញាណច្បាប់កម្ពុជាបានទទួលរងការប៉ះទង្គិចយ៉ាងច្រើនពីច្បាប់បារាំង រួមនឹងច្បាប់បរទេស ព្រមទាំងច្បាប់អន្តរជាតិផ្សេងទៀត។

១.២.១. ពីសម័យអង្គរហូតដល់មុនសម័យអាណាព្យាបាលបារាំង

ប្រទេសកម្ពុជាមានប្រវត្តិច្បាប់សរសេរយូរលង់ណាស់មកហើយក្នុងនោះគេសង្កេតឃើញមានច្បាប់ជាច្រើន ដូចជាក្រមព្រហ្មទណ្ឌ ក្រមចោរកម្ម ក្រមព្រះធម្មសាត្រ[៤៩៨] ដែលសុទ្ធសឹងជាច្បាប់ដែលត្រូវបានតាក់តែងឡើងដើម្បីគ្រប់គ្រងសង្គមនាសម័យនោះ។ ពាក់ព័ន្ធនឹងការងារវិញ យើងមិនទាន់អាចនិយាយពីវិស័យការងារតាមបែបទំនើបដែលបែងចែកច្បាស់លាស់រវាងសិទ្ធិ និងកាតព្វកិច្ច រវាងជីវិតឯកជន និងជីវិតការងារនោះទេ ដោយហេតុថានាសម័យបុរាណ ការងារផ្តោតភាគច្រើនទៅលើកសិកម្មតាមបែបគ្រួសារប្រពៃណី ឬសមូហភាព ការសាងសង់ប្រាសាទ ការចូលបំរើទ័ព ហើយរបបទាសភាពមានអត្ថិភាពផងដែរ ដែលគេបានរកឃើញដូចជាច្បាប់លំក្ខណៈទាសកំម្មករណ៍ (ក្រមទាសកម្មករ) ត្រូវបានប្រកាសឱ្យប្រើនៅចុលស័ក្ខរាជ១២៥៣។ មាត្រា ៤ នៃច្បាប់នេះចែងថា *"ម្ចាស់បានដាក់ច្រវាក់ដល់ទាសកររបស់ខ្លួន ប្រសិនបើទាសករនេះរត់គេចខ្លួនទាំងជាប់ច្រវាក់ ហើយប្រសិនបើជនណារកឃើញ ដោះច្រវាក់នោះចេញ ហើយនាំឱ្យទៅម្ចាស់វិញ ម្ចាស់ទាសករមិនត្រូវបង់ប្រាក់សំរាប់យកទាសកររបស់ខ្លួនវិញទេ ពីព្រោះថាជនណាដែលចាប់ទាសករបាន ពុំមានសិទ្ធិដោះច្រវាក់ចេញពីទាសករឡើយ។ ជនណាដែលចាប់ទាសករបាន និងនាំទៅឱ្យម្ចាស់វិញដោយមានច្រវាក់ជាប់នៅជើងដដែលនោះ អាចទាមទារប្រាក់បំណាច់ដែលមានចំនួនកាន់តែខ្ពស់ កាលណាទីកន្លែងចាប់ខ្លួនទាសករកាន់តែឆ្ងាយពីផ្ទះរបស់ម្ចាស់ទាសករ"*[៤៩៩] ។ យោងមាត្រា ៧ នៃក្រមដដែលនេះចែងថា *"បើអ្នកផង*

[៤៩៨] សូមមើល ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កម្រងច្បាប់ខ្មែរពីបុរាណ ភាគ១ និងភាគ២ បោះពុម្ពឆ្នាំ ២០១៦ និងភាគ៣ និងភាគ៤ បោះពុម្ពឆ្នាំ២០២០។

[៤៩៩] ក្រមទាសកម្មករ/ Krâm Téasa Kamokor, *នៅក្នុង* Adhémard Leclère, Les codes cambodgiens, ភាគទី១ បោះពុម្ព ដោយ Ernest Leroux ឆ្នាំ១៨៩៨ ទំព័រ ៣៨៧។ សូមមើល ហ៊ែល ចំរើន នីតិការងារ ឆ្នាំ២០០៥ បោះពុម្ពដោយ Funan ទំព័រ ៣៧។

មានខ្ញុំប្រុស ស្រីបើនៅបម្រើម្ចាស់ ហើយវាចេះឆ្លៀតជួយរកបរបស់ហើយម្ចាស់ឱ្យរំពៃបានជាមួយទៅជារបស់វាប៉ុន្មាននោះ បើវាស្លាប់ទៅ ត្រូវបរបស់នោះឯងបានទៅម្ចាស់ខ្ញុំទាំងអស់ បើរស់នៅឡើយ វាយកទ្រព្យនោះឯងទៅដូនម្ចាស់ទ្រព្យជាថ្លៃខ្លួន វានោះ ឱ្យម្ចាស់ទ្រព្យទទួលយកទ្រព្យពីវា លុមតែនឹងថ្លៃខ្លួនវាជំពាក់ បើទ្រព្យនោះសល់ប៉ុន្មានៗ ឱ្យបានទៅវាទាំងអស់ កុំឱ្យម្ចាស់ទ្រព្យយកពីវាឡើយ បើខ្ញុំណាវាពុំបាននៅបម្រើ វាដើរវេះទៅរកបរបស់ទ្រព្យ ហើយបានជារបស់ទ្រព្យយកមកជូននោះឱ្យម្ចាស់ទ្រព្យទទួលយកតែថ្លៃដើមឱ្យ ហើយឱ្យរាប់ខែឆ្នាំដែលវាពុំបាននៅបម្រើការ ឱ្យយកពីវាតាមច្បាប់ខ្ញុំប្រុសស្រីឱ្យគ្រប់ បើវាសល់ទ្រព្យប៉ុន្មាន ក៏ឱ្យបានទៅវាទាំងអស់ កុំឱ្យម្ចាស់ទ្រព្យអូសយកពីវាឡើយ បើវាមករៀបជាខ្ញុំហើយ វាមានទ្រព្យដើមវាយកមកផងនោះបើវាមានឪពុកម្តាយមានកូន នោះឱ្យៗទៅឪពុកម្តាយវា កូនវាធ្វើបុណ្យ បើពុំមានឪពុកម្តាយកូនវាទេ ឱ្យបានទ្រព្យនោះឯងទៅម្ចាស់ទ្រព្យទាំងអស់"។ តាមការពិនិត្យមើលមាត្រាទាំងពីរ ក៏ដូចជាខ្លឹមសារជារួមនៃក្រម គេអាចសន្និដ្ឋានបានថា ទាសករក្នុងបរិបទសង្គមខ្មែរសម័យនោះ មិនមែនសុទ្ធតែមានន័យជាចំខាតដូចនៅបច្ចិមប្រទេស ឬពួកសូទ្រក្នុងប្រព័ន្ធវណ្ណៈនៅឥណ្ឌានោះទេ ដែលមួយជាទាសករជាប់ថ្លៃ ជាអ្នកមានទោស ជាដើម រីឯមួយប្រភេទទៀតជាខ្ញុំបម្រើ មានសេរីភាពខ្លះក្នុងការស្វែងរកទ្រព្យដើម្បីដោះបំណុល ហើយម្ចាស់ខ្ញុំក៏ត្រូវប្រព្រឹត្តដោយមេត្តាធម៌ចំពោះខ្ញុំបម្រើទាំងនោះ ដោយមិនត្រូវលោភលន់ ទាមទារឱ្យអ្នកជំពាក់សងលើសពីថ្លៃខ្លួននោះទេ[៥០០]។ ក្រៅពីនេះ គេសង្កេតឃើញមានក្រមផ្សេងៗទៀតដូចជាក្រមគោលបន្ទាប់ និងក្រមព្រះរាជាខ័នដែលមានចែងអំពីវណ្ណៈទាសករទាំងប្រាំពីរ និងវណ្ណៈចំនួនពីរដែលមិនអាចក្លាយជាទាសករ ជាដើម[៥០១]។ ជាសរុបមក ចាប់តាំងពីសម័យអង្គរហូតមកដល់មុនសម័យអាណាព្យាបាលបារាំង ពុំឃើញមានបទប្បញ្ញត្តិចែងពីទំនាក់ទំនងគតិយុត្តផ្នែកការងារក្នុងន័យនិយោជក និងកម្មករនិយោជិតនោះទេ។ ប្រព័ន្ធច្បាប់នៅពេលនោះ ជាប្រព័ន្ធបែបបុរាណ ស្របតាមបរិបទសង្គម សេដ្ឋកិច្ច វប្បធម៌ ប្រពៃណីរបស់ខ្មែរបុរាណ

---

[៥០០] ហង្ស កក្កដារាស្សី ប្រវត្តិក្រសួងទទួលបន្ទុកវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖នីតិក្រមនៃការងារចាប់ពីសម័យអាណានិគមនិយមបារាំងរហូតមកទល់បច្ចុប្បន្ន បោះពុម្ពឆ្នាំ២០២៤ ទំព័រ ៩៨ និងបន្តបន្ទាប់។

[៥០១] យោងច្បាប់គោលបន្ទាប់ ជនណាដែលទិញទាសកររដោយទ្រព្យរបស់ខ្លួនពុំអាចរក្សាវណ្ណៈជាទាសកបន្តទៀតបានទេ៖ ទាសករទិញសម្រាប់ថ្វាយចំពោះព្រះពុទ្ធ។ ច្បាប់ព្រះរាជា (២)ទាសករទិញសម្រាប់ធ្វើជាប្រពន្ធរបស់អ្នកទិញ និង (១) ខ័នចែងអំពីពលកំលោះដែលអាចមានសេរីភាពឡើងវិញក្នុងពេលធ្វើសេកសង្គ្រាម។ សមមើល Adhémard Leclère, Les codes cambodgiens, ភាគទី២ ឆ្នាំ១៨៩៨, ទំព័រ ៤៧៩ និងទំព័រ៦៣១ *នៅក្នុង* ហ៊ែល ចំរើន នីតិការងារ ឆ្នាំ២០០៥ បោះពុម្ព ដោយ Funan ទំព័រ ៣៧។

ដែលរបបទាសភាពត្រូវបានទទួលស្គាល់ មុនពេលរបបនេះត្រូវបានលុបចោលជាផ្លូវការនៅឆ្នាំ១៨៨៤ និងរលាយបាត់ទាំងស្រុងនៅឆ្នាំ១៨៩៨[៥០២]។

១.២.២. ពីសម័យអាណាព្យាបាលបារាំងរហូតដល់បច្ចុប្បន្ន

ក្រោយពេលបារាំងបានចូលមកធ្វើជាអាណាព្យាបាលកម្ពុជាក្នុងឆ្នាំ១៨៦៣ បារាំងបានចាប់ផ្តើម ផ្ទេរ (ដោយបង្ខំ) មកឱ្យកម្ពុជានូវប្រព័ន្ធច្បាប់ទំនើបរបស់ខ្លួន ដែលនាំឱ្យមានការប្រែប្រួល និងជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រព័ន្ធច្បាប់បុរាណកម្ពុជាជាធរមាន។ បើទោះបីជារបបទាសភាពត្រូវបានលុបបំបាត់នៅចុងទស្សវត្សន៍ឆ្នាំ១៨៩០ ក៏ពិតមែន ក៏ប៉ុន្តែគេមិនទាន់អាចនិយាយពីទំនាក់ទំនងការងារនៅក្នុងន័យនៃច្បាប់ការងារនៅឡើយ ហើយស្ថានភាពសេដ្ឋកិច្ចកម្ពុជានាដើមទសវត្សន៍ទី២០ គឺពឹងផ្អែកទាំងស្រុងលើវិស័យកសិកម្ម ចំណែកឯទាសករពីមុនបានប្រែខ្លួនមកជាកម្មករធ្វើការប្រាស់ដៃ កម្មករចម្ការ ឬអ្នកបម្រើក្នុងផ្ទះ។ ថ្វីត្បិតតែលក្ខខណ្ឌរបស់ពួកគេមិនមានភាពល្អប្រសើរឡើងធៀបនឹងពេលមុនក៏ពិតមែន តែគ្រប់គ្នាមើលរាយដោយបានចាកចេញពីភាពជាខ្ញុំបម្រើដែលទទួលរងការមើលងាយ (..) សម្រាប់ពួកគេសេរីភាពមានន័យថា ជាការទទួលខុសត្រូវ និងបន្ទុក[៥០៣]។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩២០ ទើបមានក្រមរដ្ឋប្បវេណីដំបូង ហើយតាមរយៈក្រមរដ្ឋប្បវេណីនេះហើយដែលសញ្ញាណនៃនីតិការងារកម្ពុជាមានរូបរាងឡើង ក្នុងនោះយើងអាចលើកជាឧទាហរណ៍ចាប់ពីមាត្រា១១៤៥ ដល់មាត្រា១១៧៥ មានចែងពីអត្ថន័យនៃកិច្ចសន្យាការងារ រយៈពេលនៃកិច្ចសន្យាការងារ សិទ្ធិនិងកាតព្វកិច្ចរបស់គូភាគីនៃកិច្ចសន្យាការងារ ការងារកម្មករនិយោជិតវ័យក្មេង ប្រាក់ឈ្នួល ការធ្វើការងារជើម្បីដោះបំណុល ។ល។ រីឯមាត្រា ៨២៨ ដល់មាត្រា៨៣៤ មានចែងអំពីការទទួលខុសត្រូវរបស់ថៅកែនៅពេលកូនឈ្នួលមានគ្រោះថ្នាក់ការងារ។ ទោះបីជាយ៉ាងណា កម្ពុជាមិនទាន់មានច្បាប់ស្តីពីការងារមួយដែលពេញលេញនៅឡើយទេ។ បើតាមបណ្ឌិត ហ៊ែល ចំរើន ចាប់ពីឆ្នាំ ១៩២០ ដល់ឆ្នាំ ១៩៣៦ នីតិការងារត្រូវស្ថិតនៅចំណុះឱ្យនីតិរដ្ឋប្បវេណី លើកលែងតែការងារជាប់កិច្ចសន្យាដែលមានការតាំងបទបញ្ជាពិសារនាឆ្នាំ១៩២៧ ចេញ។ បានសេចក្តីថា ប្រកាសឆ្នាំ ១៩២៧ បានកំណត់អំពីលក្ខខណ្ឌនៃការជ្រើសរើស និងការ

---

[៥០២] Marcel CLAIRON សញ្ញាណសំខាន់ៗនៃច្បាប់ការងារកម្ពុជា ព្រឹត្តិបត្រ មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ ឆ្នាំ១៩៦៥ ទំព័រ២៩១។

[៥០៣] Marcel CLAIRON សញ្ញាណសំខាន់ៗនៃច្បាប់ការងារកម្ពុជា ទំព័រ ២២។ សូមមើល ហង្ស កក្កដារាស្សី ប្រវត្តិក្រសួងទទួលបន្ទុកវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖នីតិក្រមនៃការងារចាប់ពីសម័យអាណានិគមនិយមបារាំងរហូតមកទល់បច្ចុប្បន្ន ទំព័រ១៦៥ ។

សន្យាដែលកំរិតចិរវេលាធ្វើការងារនៅត្រឹម ១០ ម៉ោងក្នុងមួយថ្ងៃ កំណត់លក្ខខណ្ឌ សំការៈ នៃការរស់នៅ ចែងអំពីវិធានការសុខាភិបាល។ ការការពារកម្មករនិយោជិត និងការគោរព កាតព្វកិច្ចតាមកិច្ចសន្យាដែលធានាដោយរដ្ឋបាលត្រូវបានពង្រឹងកាន់តែខ្លាំងថែមទៀត ដោយការបង្កើតនៅក្នុងឆ្នាំដដែលនេះនូវអង្គភាពអធិការកិច្ចការងារ។ ទោះបីជាយ៉ាងនេះ ក្តី ចាប់ពីឆ្នាំ១៩៣៦ រហូតដល់កម្ពុជាទទួលបានឯករាជ្យពីបារាំងនៅឆ្នាំ១៩៥៣ មានបទ ប្បញ្ញត្តិពាក់ព័ន្ធនឹងវិស័យការងារជាបន្តបន្ទាប់ត្រូវបានប្រកាសដូចជា ក្រឹត្យ ចុះថ្ងៃទី ៣០ ធ្នូ ឆ្នាំ ១៩៣៦ អនុវត្តចំពោះជនឥណ្ឌូចិន និងជនប្រហាក់ប្រហែល ក្រឹត្យ ចុះថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ១៩៣៧ អនុវត្ត ចំពោះជនអឺរ៉ុប និងជនប្រហាក់ប្រហែល និងព្រះរាជក្រមចុះថ្ងៃ ទី ២០ ខុសភា ឆ្នាំ ១៩៣៨ ដែលពន្លាត បទប្បញ្ញត្តិថ្មី ឱ្យអនុវត្តបានចំពោះអាណិកជន កម្ពុជា ទាំងមូល។ ព្រះរាជក្រម ចុះថ្ងៃទី ៦ មករា ឆ្នាំ ១៩៣៧ បានបង្កើតសៀវភៅកម្មករ ជាប្រយោជន៍ដល់ជនរួមជាតិទាំងអស់ និងព្រះរាជក្រម ចុះថ្ងៃទី ២២ មេសា ១៩៣៧ បានដាក់ឱ្យអនុវត្តដល់ជនរួមជាតិទាំងអស់នូវអត្ថបទដែលរៀបចំការផ្សះផ្សា និងមជ្ឈត្ត ការនៅក្នុងវិវាទរវាងនិយោជក និងកម្មកនិយោជិត។ ឆ្នាំ ១៩៥១ ព្រះរាជក្រឹត្យលេខ ៦៥១-នស ចុះថ្ងៃទី ២៦ ធ្នូ ១៩៥១ បានបង្កើតក្រសួងការងារ និងសង្គមកិច្ច ដែលត្រូវ បានរៀបចំឡើងវិញនៅឆ្នាំ ១៩៥៧។ ប៉ុន្តែ នីតិកម្មការងារថ្មីនេះ គ្រប់គ្រងតែកម្មករ និយោជិត ដោយមិនគ្របដណ្តប់លើអ្នកបំរើក្នុងផ្ទះ និងកម្មកនិយោជិតខាងវិស័យ កសិកម្មឡើយ លើកលែងតែមានបទប្បញ្ញត្តិបញ្ជាក់ច្បាស់ថាត្រូវយកទៅអនុវត្ត។ បន្ទាប់ ពីបានទទួលឯករាជ្យចេញពីអាណានិគមនិយមបារាំងនាថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ មក ប្រទេសកម្ពុជាពុំទាន់មានហេដ្ឋារចនាសម្ព័ន្ធឧស្សាហកម្មនៅឡើយទេ ក្រៅពីរោងចក្របិត ស្រា និងរោងចក្រ ចំរាញ់ជីរ កៅស៊ូ។ នេះបណ្តាលមកពីប្រទេសកម្ពុជាជាប្រទេសកសិកម្ម។ នៅចន្លោះ ឆ្នាំ១៩៥៧-១៩៥៨ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមយកចិត្តទុកដាក់ និង ទទួលស្គាល់ពីភាពចាំបាច់នៃការអភិវឌ្ឍន៍ឧស្សាហកម្មសំរាប់ប្រទេសជាតិ។ ចាប់តាំងពី ពេលនោះមក ច្បាប់ការងារមួយរៀបរៀងដោយលោកមេធាវីបណ្ឌិត Marcel CLAIRON ត្រូវបានអនុម័តនៅទស្សវត្សរ៍ទី៦០[៥០៤]។ ជាមួយនឹងការផ្លាស់ប្តូរបបនយោបាយនៅឆ្នាំ ១៩៧០ ដោយរដ្ឋប្រហារពីសេនាប្រមុខ លន់ នល់ ក្រមការងារថ្មីមួយ ត្រូវបានរៀបចំ និង បានប្រកាសឱ្យប្រើនៅថ្ងៃទី១៤ ខែមករា ឆ្នាំ១៩៧២ ដោយបានបញ្ចូលគោលការណ៍សំ ខាន់ៗដែលមានមូលដ្ឋានគ្រឹះពីនីតិការងារបារាំង និងគោលការណ៍សកលមួយចំនួន

[៥០៤] ហ៊ែល ចំរើន នីតិការងារ ឆ្នាំ២០០៥ ទំព័រ ៣៩-៤០។

ទោះបីជាវាមិនទាន់ពេញលេញក៏ដោយ ជាពិសេសបទប្បញ្ញត្តិស្នូលរបស់អង្គការអន្តរជាតិខាងការងារ ដូចជាការហាមឃាត់ការងារដោយបង្ខំ ប្រភេទកិច្ចសន្យាការងារ លក្ខខណ្ឌទូទៅនៃការងារ សេរីភាពអង្គការវិជ្ជាជីវៈ ព្រមទាំងយន្តការដោះស្រាយវិវាទការងារទាំងក្នុង និងក្រៅប្រព័ន្ធតុលាការ។

ដោយសារតែសង្គ្រាមស៊ីវិលនាដើមទសវត្សឆ្នាំ១៩៧០ ក្រមការងារដែលត្រូវបានអនុម័តឡើងមិនត្រូវបានយកមកអនុវត្តឱ្យបានពេញលេញនោះទេ ហើយក្រោយមកកម្ពុជាបានធ្លាក់ចូលទៅក្នុងរបបវាលពិឃាតដែលច្បាប់នានាត្រូវបានរំលាយចោលទាំងស្រុងជំនួសមកវិញដោយការកាប់សម្លាប់ ការធ្វើទារុណកម្ម ការងារដោយបង្ខំ ។ល។ ក្រោយការដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ កម្ពុជាបានខិតខំកសាងប្រទេសឡើងវិញពីបាតដៃទទេ ហើយច្បាប់នានាក៏ត្រូវរៀបចំជាថ្មីផងដែរ។ ជាក់ស្តែង ក្រឹត្យច្បាប់លេខ ៣៨ ក្រ.ច ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យានិងការទទួលខុសត្រូវក្រៅកិច្ចសន្យាដែលទទួលឥទ្ធពលពីច្បាប់សង្គមនិយមវៀតណាម បានចែងអំពីនិយមន័យកិច្ចសន្យា សិទ្ធិកាតព្វកិច្ចរបស់ភាគី ព្រមទាំងប្រភេទផ្សេងៗនៃកិច្ចសន្យាពិសេស ក៏ប៉ុន្តែពុំមានចែងពីកិច្ចសន្យាការងារនោះទេ។ គេត្រូវរង់ចាំរហូតដល់ឆ្នាំ១៩៩២ ទើបច្បាប់ការងារថ្មីមួយទៀតត្រូវបានប្រកាសឱ្យប្រើនៅថ្ងៃទី១៣ ខែតុលា ឆ្នាំ១៩៩២ ដែលខ្លឹមសារដកស្រង់ស្ទើរតែទាំងស្រុងពីក្រមការងារឆ្នាំ១៩៧២ លើកលែងតែផ្នែកពាក់ព័ន្ធជាអាទិ៍នឹងការដោះស្រាយវិវាទការងារដោយក្រុមប្រឹក្សាអាជ្ញាកណ្តាល របបសន្តិសុខសង្គម សេវាពេទ្យការងារ ដែលមិនត្រូវបានយកមកដាក់បញ្ចូលក្នុងច្បាប់ការងារឆ្នាំ១៩៩២។

ក្រោយកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ កម្ពុជាបានរៀបចំការបោះឆ្នោតជាសកល និងមានរដ្ឋធម្មនុញ្ញ ឆ្នាំ១៩៩៣ ដែលបានទទួលយកយ៉ាងពេញលេញនូវគោលការណ៍សិទ្ធិមនុស្សសកល សិទ្ធសេរីភាពជាមូលដ្ឋានក្នុងវិស័យការងារ[៥០៥]។ ជាបន្តបន្ទាប់ ច្បាប់គោលក្នុងវិស័យការងារចំនួនបួនត្រូវបានអនុម័ត គឺច្បាប់ស្តីពីការងារឆ្នាំ

[៥០៥] មាត្រា៣១ វាក្យខណ្ឌ១ នៃរដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣ ចែងថា *"ព្រះរាជាណាចក្រកម្ពុជាទទួលស្គាល់ និងគោរពសិទ្ធិមនុស្សដូចមានចែងនៅក្នុងធម្មនុញ្ញអង្គការសហប្រជាជាតិ សេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស កតិកាសញ្ញាព្រមទាំងអនុសញ្ញាទាំងឡាយទាក់ទងទៅនឹងសិទ្ធិមនុស្ស សិទ្ធិស្ត្រី និងសិទ្ធិកុមារ"*។

១៩៩៧[៥០៦] ច្បាប់ស្តីពីសហជីពឆ្នាំ២០១៦ ច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ឆ្នាំ២០១៨ និងច្បាប់ស្តីពីរបបសន្តិសុខសង្គមឆ្នាំ២០១៩[៥០៧]។

[៥០៦] ច្បាប់ស្តីពីការងារជាច្បាប់មួយដែលរៀបចំតាក់តែងឡើងតាំងពីឆ្នាំ១៩៩៤ មក ដោយផ្អែកលើមូលដ្ឋានឯកសារសំខាន់ៗដូចជា រដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ច្បាប់ការងារឆ្នាំ១៩៩២ ឯកសារនានាដែលពាក់ព័ន្ធនឹងវិស័យការងារ និងមានការចូលរួមពីសំណាក់សហជីពជាតិជាច្រើន ជាដៃគូរបស់អង្គការជាតិខាងការងារ (ILO) ព្រមទាំងអង្គការការងារអាមេរិក (AAFLI) និងអង្គការអន្តរជាតិ បានប្រកាសឱ្យប្រើជាផ្លូវការ នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ១៩៩៧ (ដកស្រង់ពីសុន្ទរកថា ឯកឧត្តម អ៊ុំ មាន អតីតរដ្ឋលេខាធិការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ថ្លែងក្នុងសិក្ខាសាលាស្តីពី គំរប់ខួបដប់ឆ្នាំនៃច្បាប់ស្តីពីការងារកម្ពុជា ថ្ងៃទី១-២ ខែវិច្ឆិកា ឆ្នាំ២០០៧ នៅសាកលវិទ្យាសល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច)។

[៥០៧] របបសន្តិសុខសង្គមបានចាប់កំណើតនៅព្រះរាជាណាចក្រកម្ពុជាក្នុងឆ្នាំ ១៩៤០ ក្នុងទម្រង់ជាប្រព័ន្ធតារាកាលិកគ្រួសារ "ហឹបប្រាក់អន្តរវិជ្ជាជីវៈ" ក្រោយពីព្រះរាជាណាចក្រកម្ពុជាទទួលបានឯករាជ្យពីអាណានិគមបារាំង ច្បាប់ស្តីពីការបង្កើតហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ ត្រូវបានប្រកាសឱ្យប្រើដោយក្រមលេខ៣ន.ស ចុះថ្ងៃទី២៥ ខែមេសា ឆ្នាំ១៩៥៥ ស្របតាមច្បាប់នេះ "ហឹបប្រាក់អន្តរវិជ្ជាជីវៈសម្រាប់ទូទាត់វិភាជន៍គ្រួសារ" ត្រូវបានបង្កើតឡើងដោយព្រះរាជក្រឹត្យលេខ៣០៦ន.ស។ ជាអកុសល ព្រះរាជាណាចក្រកម្ពុជាបានធ្លាក់ចូលក្នុងវិនាសកម្មដ៏ខ្មៅងងឹងក្រោមរបបកម្ពុជាប្រជាធិប-តេយ្យ (របបប្រល័យពូជសាសន៍ប៉ុលពត ឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩) ដែលបានធ្វើឱ្យរបបសន្តិសុខសង្គមត្រូវបានលុបបំបាត់ចោល និងបាននាំឱ្យប្រទេសធ្លាក់ដល់ក្រោមចំណុចសូន្យ។ ក្រោយរបបកម្ពុជាប្រជាធិបតេយ្យបានដួលរលំនៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩ របបសន្តិសុខសង្គមបានចាប់ផ្តើមមានជាថ្មីផ្នែកប្រាក់សោធនរបស់មន្ត្រីសាធារណៈ និងផ្នែកប្រាក់ប៉ះពាល់សុខភាពកម្មករនិយោជិតដែលធ្វើការនៅតាមរោងចក្រសហគ្រាសរដ្ឋ ដែលអនុវត្តដោយនាយកដ្ឋានបៀវត្សពលកម្មនៃក្រសួងផែនការ។ បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ នាយកដ្ឋានសន្តិសុខសង្គមត្រូវបានបង្កើតឡើងស្ថិតក្រោមក្រសួងសង្គមកិច្ច ការងារ និងអតីតយុទ្ធជន បន្ទាប់មកចាប់ពីឆ្នាំ២០០៥ បានស្ថិតក្រោមក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីទទួលបន្ទុកក្នុងការរៀបចំកិច្ចការគតិយុត្តសម្រាប់ការអនុវត្តរបបសន្តិសុខសង្គមដល់បុគ្គលដែលធ្វើការក្នុងវិស័យឯកជន។ ក្នុងឆ្នាំ២០០២ ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារត្រូវបានអនុម័តឲ្យប្រើប្រាស់យ៉ាងទុលំទូលាយដល់កម្មករនិយោជិត រហូតដល់ឆ្នាំ២០០៧ នាយកដ្ឋានសន្តិសុខសង្គម បានប្តូរមកជារបបក្រុមជាតិរបបសន្តិសុខសង្គម ដើម្បីទទួលបន្ទុកអនុវត្តច្បាប់ខាងលើឱ្យកាន់តែមានប្រសិទ្ធភាព។ ដោយទទួលបានជោគជ័យគួរជាទីមោទកក្នុងការជាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារក្នុងឆ្នាំ២០០៨ ទើបរាជរដ្ឋាភិបាលបានបង្កើតរបបសន្តិសុខសង្គម ផ្នែកថែទាំសុខភាពក្នុងឆ្នាំ២០១៦ សម្រាប់ជនទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិ នៃច្បាប់ស្តីពីការងារ ដែលមិនធ្លាប់មានក្នុងប្រវត្តិសាស្ត្រកម្ពុជា ក្រោយអនុវត្តទទួលបានជោគជ័យលើវិស័យឯកជន រាជរដ្ឋាភិបាល បានផ្តល់សេចក្តីទុកចិត្តលើ ប.ស.ស. ដោយប្រគល់ភារកិច្ចបន្ថែមលើការអនុវត្តរបបសន្តិសុខសង្គមចំពោះបុគ្គលនៃវិស័យសាធារណៈ។ ការណ៍នេះជាកាលានុវត្តភាពឱ្យបេឡាជាតិរបបសន្តិសុខសង្គម វិវត្តខ្លួនទៅជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានឈ្មោះថា បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) និងជាប្រតិបត្តិករតែមួយគត់ដែលធ្វើប្រតិបត្តិការរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធន ផ្នែកថែទាំសុខភាព ផ្នែកហានិភ័យការងារ និងផ្នែកនិកម្មភាពការងារ ដែលបង្កើតដោយព្រះរាជក្រឹត្យលេខ នស/រកត/០៥២០/៥៨២ ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០២០។ សូមមើល https://www.nssf.gov.kh/អំពី-ប-ស-ស/ប្រវត្តិរូប/

១.៣. ការវិភាគ ទាយតម្លៃអត្តសញ្ញាណច្បាប់ក្នុងវិស័យការងារ

ការរៀបចំលិខិតបទដ្ឋានគតិយុត្តសម្រាប់អនុវត្តឱ្យមានប្រសិទ្ធភាពពុំមែនជារឿងងាយស្រួលនោះទេ ពិសេសបន្ទាប់ពីមានការប៉ះទង្គិចរវាងប្រព័ន្ធច្បាប់បុរាណជាមួយប្រព័ន្ធច្បាប់ទំនើប។ ហេតុដូច្នេះ សុខដុមនីយកម្មផ្នែកគតិយុត្តគឺមានភាពចាំបាច់ខ្លាំងណាស់ ដើម្បីបន្សុំគ្នារវាងប្រព័ន្ធច្បាប់ដែលឆ្លើយតបទៅនឹងសង្គមកម្ពុជា។

១.៣.១. ច្បាប់ដែលឧទ្ធរណ៍ឆន្ទវឥទ្ធិពលប្រព័ន្ធចម្រុះ

ទោះជាតម្លៃច្បាប់បុរាណខ្មែរដែលផ្អែកលើទំនៀមទម្លាប់ប្រពៃណី ជំនឿសាសនាបន្តមានអត្ថិភាព ក្នុងលិខិតបទដ្ឋានគតិយុត្តពិតមែន ប៉ុន្តែច្បាប់ខ្មែរបានទទួលរងនូវឥទ្ធិពលជាបន្តបន្ទាប់ពីច្បាប់នៅក្នុងតំបន់ និងពិភពលោក តាមរយៈការផ្លាស់ប្តូរពាណិជ្ជកម្ម ការគ្រប់គ្រងរបស់អាណាព្យាបាលបារាំង កិច្ចសហប្រតិបត្តិការផ្សេងៗ ព្រមទាំងកាតព្វកិច្ចជាអន្តរជាតិដែលកម្ពុជាត្រូវទទួលយកនូវបទដ្ឋានជាសារវន្តមួយចំនួន។ ឥទ្ធិពលនៃច្បាប់បរទេសដែលយើងលើកឡើងនៅទីនេះ ទាក់ទងនឹងទម្រង់ផង និងខ្លឹមសារនៃច្បាប់ផង។ ការរៀបចំជាក្រមទៅតាមវិស័យនីមួយៗ អាណាព្យាបាលបារាំងមានបំណងរៀបចំជាវិធានគតិយុត្តទៅតាមទម្រង់មួយដែលមានរចនាសម្ព័ន្ធជាក់លាក់ ដោយច្របាច់បញ្ចូលគ្នារវាងខ្លឹមសារនៃច្បាប់បុរាណ និងវិធានច្បាប់ទំនើប ធ្វើយ៉ាងណាឱ្យមានភាពប្រទាក់ក្រឡាគ្នាពីច្បាប់មួយទៅច្បាប់មួយទៀត មានសង្គតិភាព សុវត្ថិភាព និងភាពងាយស្រួលនៅក្នុងការអនុវត្ត។

ក្រឡែកមើលក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩២០ គឺត្រូវបានរៀបចំឡើងតាមទម្រង់ក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤ ឬហៅថាក្រមណាប៉ូឡេអុង ដោយការបែងចែករចនាសម្ព័ន្ធក្រមទាំងពីរប្រហាក់ប្រហែលគ្នា ក្នុងនោះ គន្ថីទី១ ចែងអំពីបុគ្គល គន្ថីទី២ ចែងអំពីទ្រព្យ និងគន្ថីទី៣ ចែងអំពីកាតព្វកិច្ច និងកិច្ចសន្យា។ ចំពោះខ្លឹមសារពាក់ព័ន្ធនឹងវិស័យការងារ យើងឃើញមានការវិវត្តន៍ជាច្រើនទាក់ទងនឹងសញ្ញាណនៃកិច្ចសន្យាការងារដែលសញ្ញាណនេះមិនទាន់មានលក្ខណៈច្បាស់លាស់នៅឡើយទេនៅក្នុងក្រមរដ្ឋប្បវេណីបារាំង ឆ្នាំ១៨០៤។ ឧទាហរណ៍ នៅក្នុងក្រមរដ្ឋប្បវេណីដំបូងរបស់បារាំងនាពេលនោះ គឺពុំមានមាត្រាច្រើនចែងពីកិច្ចសន្យាការងារ និងការទទួលខុសត្រូវដោយគ្រោះថ្នាក់ការងារ ឬជំងឺវិជ្ជាជីវៈឡើយ ម្យ៉ាងទៀត ការប្រើប្រាស់ពាក្យថាកិច្ចសន្យាការងារ ឬជួលការងារក៏ពុំសរសេរឱ្យចំៗដែរ ដោយជំនួសមកវិញនូវពាក្យកិច្ចសន្យាជួលសេវា។ ក្រោយមកទៀត

បារាំងបានអនុម័តច្បាប់ជាច្រើនដើម្បីគ្រប់គ្រងវិស័យការងារ ដូចជាច្បាប់ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៨៩៨ ស្តីពីការទទួលខុសត្រូវលើគ្រោះថ្នាក់ដែលកើតឡើងចំពោះកម្មករ ការអង្កេតគ្រោះថ្នាក់ការងារ និងអត្រាសំណងដែលនិយោជកត្រូវទទួលបន្ទុក ច្បាប់ចុះថ្ងៃទី ១២ មិថុនា ឆ្នាំ១៨៩៣ ស្តីពីអនាម័យ និងសុវត្ថិភាពការងារ (...) រហូតដល់ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩១០ ទើបក្រមការងារដំបូងរបស់បារាំងត្រូវបានប្រកាសឡើង ដែលធាតុផ្សំនៃទំនាក់ទំនងការងារកាន់តែមានរំលេចច្បាស់លាស់[៥០៨]។ ដូចគ្នានេះ មាត្រា ១១៤៥ នៃក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ ចែងថា *"ដែលហៅថា ជួលការងារនោះគឺកិច្ចសន្យាដែលជនម្នាក់ហៅថាជាង និយោជិត អ្នកការ ឬឈ្នួល សន្យាថា នឹងធ្វើការក្នុងពេលមានកំណត់ប៉ុណ្ណោះឱ្យជនម្នាក់ទៀត ហៅថានាយ ម្ចាស់ការ ឬនិយោជក ដោយយកថ្លៃតាមសមាមាត្រនៃកាលដែលបានព្រមព្រៀងគ្នា ថ្លៃនោះហៅថាប្រាក់ឈ្នួល"*។ ប្រសិនបើយើងលើកយកសញ្ញាណនៃកិច្ចសន្យាការងារ ឬកិច្ចសន្យាជួលសេវាដែលមានចែងនៅក្នុងក្រមរដ្ឋប្បវេណី ធៀបជាមួយនឹងច្បាប់ប្រទេសបារាំង យើងពិនិត្យឃើញថា ខ្លឹមសារគោលមានលក្ខណៈស្រដៀងគ្នា ពោលគឺកិច្ចសន្យាការងារ ឬកិច្ចសន្យាជួលសេវា មាននូវធាតុផ្សំដូចជា ការបំពេញការងារឱ្យនិយោជកណាមួយ ប្រាក់ឈ្នួល និងការគ្រប់គ្រងទៅលើកម្មករនិយោជិតនោះ បើទោះបីជាធាតុផ្សំទីបីនេះមិនត្រូវបានរំលេចច្បាស់ៗនៅក្នុងក្រម និងច្បាប់ពាក់ព័ន្ធនាពេលនោះក្តី។ ចំពោះការទទួលខុសត្រូវរបស់និយោជក យើងឃើញថាទាំងច្បាប់ឆ្នាំ១៨៩៨ និងក្រមរដ្ឋប្បវេណីកម្ពុជា ឆ្នាំ១៩២០ ចែងដូចគ្នាអំពីសញ្ញាណនៃការទទួលខុសត្រូវរបស់និយោជកចំពោះគ្រោះថ្នាក់ដែលកើតឡើងទៅលើកម្មករនិយោជិតរបស់ខ្លួន[៥០៩]។ ក្រោយកម្ពុជាទទួលបានឯករាជ្យ បារាំងនៅតែបន្តជួយអភិវឌ្ឍវិស័យច្បាប់តាមរយៈការផ្តល់អ្នកជំនាញការចូលរួមតាក់តែងរៀបចំសេចក្តីព្រៀងច្បាប់ផ្សេងៗ ការបណ្តុះបណ្តាលធនធានមនុស្សនៅកម្ពុជា ឬការផ្តល់អាហារូបករណ៍ទៅសិក្សានៅក្រៅប្រទេស។ ភាសាបារាំងនៅតែត្រូវបានបន្តប្រើប្រាស់យ៉ាងទូលំទូលាយក្នុងរដ្ឋបាលរបស់ប្រទេសកម្ពុជា ហើយអ្នកជំនាញការបារាំងបានមកប្រទេសនេះក្រោមក្របខណ្ឌនៃសហប្រតិបត្តិការទ្វេភាគី ឬពហុភាគីក្រោមការចាត់ចែងរបស់អង្គការអន្តរជាតិខាងការងារ។

---

[៥០៨] សូមមើលប្រវត្តិនៃច្បាប់ការងារបារាំងពីឆ្នាំ១៨៤១ ដល់បច្ចុប្បន្ននៅក្នុងគេហទំព័រ https://travail-emploi.gouv.fr/histoire-du-droit-du-travail-de-1841-nos-jours-reperes-chronologiques

[៥០៩] ច្បាប់ស្តីពីការទទួលខុសត្រូវលើគ្រោះថ្នាក់កើតឡើងចំពោះកម្មកនិយោជិត ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៨៩៨ មាន៣៤ មាត្រា រីឯក្រមរដ្ឋប្បវេណី ឆ្នាំ១៩២០ មាន៨ មាត្រា គឺមាត្រា ៨២៧ ដល់មាត្រា៨៣៤ ដែលចែងអំពីគ្រោះថ្នាក់ការងាររបស់កម្មករ និងការទទួលខុសត្រូវរបស់ថៅកែ។

តាមរយៈបទពិសោធ និងការអនុវត្តវិជ្ជាជីវៈរបស់ពួកគេ អ្នកជំនាញមួយចំនួនស្គាល់ច្បាស់ពីបទប្បញ្ញត្តិរបស់ក្រមការងារបារាំង និងក្រមការងារសម្រាប់អនុវត្តនៅដែនដីឯនាយសមុទ្រ។ ជាការគួរសបញ្ជាក់ កម្ពុជាបានចូលជាសមាជិកអង្គការអន្តរជាតិខាងការងារនៅឆ្នាំ១៩៦៩ ដែលតម្រូវឱ្យគោរពនូវគោលការណ៍គ្រឹះជាសារវន្តដូចដែល មានចែងក្នុងធម្មនុញ្ញរបស់អង្គការនេះ រួមទាំងអនុសញ្ញាផ្សេងៗដែលត្រូវបានអនុម័តឡើងក្រោមយន្តការត្រីភាគី ជាពិសេសអនុសញ្ញាដែលត្រូវបានចាត់ទុកថាជាអនុសញ្ញាស្នូលស្តីពីស្តង់ដាការងារ[៥90]។ ការពិនិត្យមើលទៅលើក្រមការងារឆ្នាំ១៩៧២ ឃើញថាក្រមនេះត្រូវបានរៀបចំតាក់តែងឡើងដោយផ្អែកមួយផ្នែកលើបទដ្ឋានគតិយុត្តទាំងឡាយដែលបារាំងបានជួយរៀបចំអំឡុងខ្លួនជាអាណាព្យាបាលកម្ពុជា។ ឧទាហរណ៍ មាត្រា១៧ នៃព្រះរាជប្រកាសលេខ៨៤ ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ១៩៣៨ ចែងថា *"កិច្ចសន្យាការងារត្រូវស្ថិតនៅក្រោមវិធានអាជ្ញាគតិ ហើយអាចនឹងធ្វើទៅតាមទម្រង់ដែលភាគីទាំងសងខាងព្រមព្រៀងគ្នា។ កិច្ចសន្យានេះអាចធ្វើជាលាយលក្ខណ៍អក្សរ ឬដោយមាត់ទទេ។ កិច្ចសន្យានេះអាចសរសេរ និងចុះហត្ថលេខាទៅតាមទម្លាប់ក្នុងស្រុក។ កិច្ចសន្យាដោយមាត់ទទេត្រូវទុកជាមានការព្រមព្រៀងរវាងនិយោជក និងកម្មករនិយោជិតស្របតាមព្រះរាជប្រកាសនេះ និងទម្លាប់ក្នុងស្រុក"*។ មាត្រា១៧ នៃព្រះរាជប្រកាសលេខ៨៤ នេះត្រូវបានដាក់បញ្ចូលទៅក្នុងមាត្រា៦២ នៃក្រមការងារឆ្នាំ១៩៧២ ដែលពាក្យពេចន៍ ខ្លឹមសារស្ទើរតែដូចគ្នាទាំងស្រុង។ ឧទាហរណ៍មួយទៀត មាត្រា២៨ នៃព្រះរាជប្រកាសដដែលចែងអំពីការិយ

---

[៥90] គិតមកទល់នឹងបច្ចុប្បន្ននេះ កម្ពុជាបានផ្តល់សច្ចាប័នលើអនុសញ្ញាអន្តរជាតិខាងការងារចំនួន ១៣ ៖ អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឆ្នាំ១៩៣0 ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (នៅជាធរមាន), អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាពសមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម ឆ្នាំ១៩៤៨ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ៩៨ ស្តីពីការអនុវត្តគោលការណ៍ស្តីអំពីសិទ្ធិនៃការបង្កើតសមាគម និងសិទ្ធិនៃការចរចាជាសមូហភាព ឆ្នាំ១៩៤៩ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ១00 ស្តីពីប្រាក់ឈ្នួលស្មើគ្នា ឆ្នាំ១៩៤៩ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ១0៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ ឆ្នាំ១៩៥១ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ១១១ ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ ឆ្នាំ១៩៥៨ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមា ឆ្នាំ១៩៧៣ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន), អនុសញ្ញាលេខ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃការងារកុមារ ឆ្នាំ១៩៩៩ ផ្តល់សច្ចាប័នថ្ងៃទី១៤ ខែមីនា ឆ្នាំ២00៦ (នៅជាធរមាន), អនុសញ្ញាលេខ៤ ស្តីពីការងារពេលយប់ (ស្ត្រី) ឆ្នាំ១៩១៩ ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (និរាករណ៍ នៅឆ្នាំ២0១៧), អនុសញ្ញាលេខ៦ ស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង ឆ្នាំ១៩១៩ ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (នៅជាធរមាន), អនុសញ្ញាលេខ១៣ ស្តីពីសំណរកាបូណាត (ថ្នាំលាប) ឆ្នាំ១៩២១ ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (នៅជាធរមាន), អនុសញ្ញាលេខ១៥0 ស្តីពីរដ្ឋបាលការងារ ឆ្នាំ១៩៧៨ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន) និងអនុសញ្ញាលេខ១២២ ស្តីពីគោលនយោបាយមុខរបរ ឆ្នាំ១៩៦៤ ផ្តល់សច្ចាប័នថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧១ (នៅជាធរមាន)។

ការី ដែលមានខ្លឹមសារប្រហាក់ប្រហែលគ្នាជាមួយនឹងមាត្រា ៤០ នៃក្រមការងារឆ្នាំ ១៩៧២។ ក្រៅពីនោះ ការបញ្ចូលនូវបទប្បញ្ញត្តិពាក់ព័ន្ធនឹងសៀវភៅការងារ កិច្ចសន្យា ហ្វឹកហ្វឺនកូនជាង លក្ខខណ្ឌទូទៅនៃការងារ គ្រោះថ្នាក់ការងារ រដ្ឋបាលការងារ និងការ ដោះស្រាយវិវាទ (...) ទៅក្នុងក្រមឆ្នាំ១៩៧២ សុទ្ធតែមានទំនាក់ទំនងជាមួយព្រះរាជ ប្រកាស អនុក្រឹត្យ ក្រឹត្យ ព្រះរាជក្រឹត្យ ជាច្រើនដែលបានចេញជាបន្តបន្ទាប់ចាប់តាំងពី មានវត្តមានអាណាព្យាបាលបារាំង រហូតដល់ក្រោយកម្ពុជាទទួលបាន ឯករាជ្យនៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣។

ក្រៅពីនេះ មួយផ្នែកធំនៃក្រមឆ្នាំ១៩៧២ ក៏បានយកតាមលំនាំក្រមការងារបារាំង ដែលអនុវត្តសម្រាប់ដែនដីឯនាយសមុទ្រផងដែរ។ បើតាមលោកស្រី Laure Ginesty ជា អ្នកជំនាញការបារាំងដែលត្រូវបានចាត់តាំងដោយអង្គការអន្តរជាតិខាងការងារឱ្យមកជួយ សិក្សា តាក់តែងច្បាប់ស្តីពីការងារកម្ពុជាឆ្នាំ១៩៩៧ បានលើកឡើងថា គំនិតនៃការបង្កើត ក្រមការងាររួមសម្រាប់អនុវត្តនៅដែនដីឯនាយសមុទ្រ បានចាប់ផ្តើមជារូបរាងនៅក្នុង សន្និសីទទីក្រុង Brazzaville នាឆ្នាំ១៩៤៤។ អត្ថបទដែលត្រូវបានអនុម័តចែងថាវានឹងត្រូវ អនុវត្តលើទឹកដីអាហ្វ្រិក ម៉ាដាហ្គាស្ការ រួមទាំងកោះនៅមហាសមុទ្រឥណ្ឌា និងមហាសមុទ្រ ប៉ាស៊ីហ្វិក ដែលស្ថិតក្រោមរដ្ឋបាលរបស់បារាំង។ នៅឆ្នាំ១៩៥២ ដែលជាឆ្នាំប្រកាសឱ្យប្រើ ក្រមរបស់ដែនដីឯនាយសមុទ្រ ប្រទេសកម្ពុជាមិនទាន់ទទួលបានឯករាជ្យរបស់ខ្លួននៅ ឡើយទេ ប៉ុន្តែអ្នកតាក់តែងច្បាប់បានដកឥណ្ឌូចិនចេញពីដែនអនុវត្ត ដោយសារពេលនោះ កម្ពុជាកំពុងតែដំណើរការឆ្លងកាត់ពីអាណាព្យាបាលទៅកាន់ឯករាជ្យភាពឡើងវិញ។ អ្នក តំណាងនានានៅឥណ្ឌូចិនមិនបានចូលរួមក្នុងសន្និសីទ Brazzaville ទេ។ ផ្ទុយទៅវិញ យើងសង្កេតឃើញថាស្មារតី និងបទប្បញ្ញត្តិដែលមាននៅក្នុងក្រមបារាំងនៃដែនដីឯនាយស មុទ្រមួយភាគធំត្រូវបានគេរកឃើញនៅក្នុងក្រមការងារកម្ពុជាឆ្នាំ១៩៩២[៥១១]។

ដូចបានបញ្ជាក់រួចហើយថា ច្បាប់ការងារឆ្នាំ១៩៩២ ដកស្រង់ស្ទើរតែទាំងស្រុង ពីក្រមការងារឆ្នាំ១៩៧២ ជាមួយគ្នានេះ បើយើងប្រៀបធៀបច្បាប់ការងារឆ្នាំ១៩៧២ ជាមួយច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ យើងរកឃើញចំណុចដូចគ្នា និងស្រដៀងគ្នាកាន់តែ

[៥១១] Laure Ginesty ការបង្ហាញប្រវត្តិនៃការតាក់តែងក្រមការងារ ស្នាដៃនៃកិច្ចសហប្រតិបត្តិការ *អត្ថបទក្នុងឯកសារបោះពុម្ព ផ្សាយពីលទ្ធផលនៃសិក្ខាសាលាស្តីពី "*គម្រប់ខួប១០ ឆ្នាំនៃក្រមការងារកម្ពុជា*"* ចងក្រងឡើងដោយការិយាល័យសហប្រតិបត្តិ ការបារាំង ប្រចាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី១-២ វិច្ឆិកា ឆ្នាំ២០០៧ រោងពុម្ព Funan ទំព័រ៣៩-៤០ ។

ច្រើន លើកលែងតែសិទ្ធិធ្វើកូដកម្ម/ឡុកអៅ[៥១២] ដែលពុំមានចែងនៅក្នុងក្រមចាស់ ប៉ុន្តែមានចែងនៅក្នុងច្បាប់ឆ្នាំ១៩៩៧។ ទាំងនេះមិនមានអ្វីចម្លែកឡើយ ដោយសារតែការបន្តមករតកគតិយុត្តពីអាណាព្យាបាលបារាំង ពីសង្គមចាស់ រួមទាំងការផ្លាស់ប្តូរបរបនយោបាយ ការបើកចំហរសេដ្ឋកិច្ចទីផ្សារសេរីផង ដែលការធ្វើបច្ចុប្បន្នភាពបន្ថែមជាការជាបាច់ ដើម្បីទាក់ទាញ និងការពារវិនិយោគិន ក៏ដូចជាការពារសិទ្ធិសេរីភាពរបស់កម្មករនិយោជិត ស្របតាមរដ្ឋធម្មនុញ្ញ និងបទដ្ឋានអន្តរជាតិខាងការងារ ។

ជាសរុបមក តាមរយៈឧទាហរណ៍មួយចំនួនបង្ហាញឱ្យឃើញនូវឥទ្ធិពលច្បាប់បរទេស និងអន្តរជាតិមកលើសង្គមខ្មែរ មានជាអាទិ៍ ការលុបបំបាត់ការងាររដោយបង្ខំ សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ សិទ្ធិធ្វើកូដកម្ម ឡុកអៅ ប្រាក់ឈ្នួលអប្បបរមា គោលគោលការណ៍សមភាពរវាងបុរស និងស្ត្រី របបសន្តិសុខសង្គម ការអនុម័តយល់ព្រមទទួលយកនូវសន្ធិសញ្ញា កតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិនានាពាក់ព័ន្ធនឹងសិទ្ធិការងារ។ សញ្ញាណទាំងនេះមិនឃើញមានក្នុងប្រព័ន្ធច្បាប់ខ្មែរបុរាណទេ ប៉ុន្តែជាការនាំចូលការបង្កើតថ្មី សម្រាប់កម្ពុជាអនុវត្តតាម។ ដោយឡែកចំពោះប្រព័ន្ធយុត្តិធម៌ ពុំមានជាទស្សនទានថ្មីឡើយ ប៉ុន្តែជាការធ្វើយ៉ាងណាឱ្យមានជាយន្តការ និងនីតិវិធីច្បាស់លាស់ រួមទាំងការបែងចែកអំណាចរវាងអង្គប្រតិបត្តិ និងតុលាការ។

១.៣.២. ការសម្របច្បាប់ទៅនឹងសង្គម ឬសម្របសង្គមឱ្យត្រូវតាមច្បាប់?

តាមទស្សនៈនីតិសាស្ត្រអន្តរវប្បធម៌ ច្បាប់ត្រូវបានមើលឃើញថាជាបាតុភូតសង្គមមួយ ដែលមានភាពបត់បែន និងអាស្រ័យទៅលើបរិបទវប្បធម៌។ ក្នុងករណីកម្ពុជា ការចូលមកនៃអាណាព្យាបាលបារាំង បាននាំឱ្យមានដំណើរការបញ្ចូលវប្បធម៌ច្បាប់ តាមរយៈការផ្ទេរ និងការនាំចូលប្រព័ន្ធច្បាប់បារាំង រួមទាំងច្បាប់ការងារទំនើបទៅក្នុងសង្គមខ្មែរ។ ការនាំចូលនេះ មិនមែនកើតឡើងម្តងបន្តិចតាមរយៈការចម្លងវប្បធម៌ គ្នាទៅវិញទៅមកនោះទេ

[៥១២] ទោះបីជាសិទ្ធិធ្វើកូដកម្មត្រូវបានចែងនៅក្នុងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ពិតមែន ប៉ុន្តែសិទ្ធិនេះមិនមែនយកលំនាំតាមច្បាប់ការងារប្រទេសបារាំងទេ ដោយសារថា ដើម្បីធ្វើកូដកម្មស្របច្បាប់ត្រូវការបោះឆ្នោតជាសម្ងាត់ និងត្រូវជូនដំណឹងជាមុនមុនពេលអាចអនុវត្តសិទ្ធិធ្វើកូដកម្មបាន។ ម្យ៉ាងវិញទៀត ត្រូវប្រើប្រាស់យន្តការដោះស្រាយដោយសន្តិវិធីអស់លទ្ធភាពសិនរួមទាំងនីតិវិធីនៅចំពោះមុខក្រុមប្រឹក្សាអាជ្ញាកណ្តាលផង។ ចំពោះកូដកម្មតាមច្បាប់បារាំងវិញ អាចអនុវត្តទៅបានដោយពុំមានការបោះឆ្នោត ដោយពុំចាំបាច់ជូនដំណឹងជាមុន និងពុំចាំបាច់រង់ចាំលទ្ធផលនៃការដោះស្រាយវិវាទការងារជាមុននោះទេ។

ប៉ុន្តែជាការប៉ះទង្គិច និងការចរចាររវាងប្រព័ន្ធច្បាប់ទំនើបបរទេស និងរបបប្រពៃណីមូលដ្ឋាន ដែលមានទស្សនៈខុសគ្នាអំពីការងារ អំណាច និងទំនួលខុសត្រូវសង្គម។

ក្នុងបរិបទនេះ សំណួរទ្រឹស្តីសំខាន់មួយត្រូវបានលើកឡើង តើច្បាប់ត្រូវសម្របខ្លួនទៅសង្គម ឬសង្គមត្រូវសម្របខ្លួនទៅតាមច្បាប់ ? ការផ្ទេរច្បាប់ការងារបារាំងមកកម្ពុជាបង្ហាញថា ចម្លើយមិនអាចមានតែមួយនោះទេ។ មួយផ្នែក ច្បាប់ការងារទំនើបបានបង្ខំឱ្យសង្គមខ្មែរ ប្រែប្រួលទស្សនៈ និងអនុវត្តការងារ ពីទំនាក់ទំនងផ្អែកលើកាតព្វកិច្ចសង្គម និងប្រពៃណី ទៅជាទំនាក់ទំនងផ្អែកលើកិច្ចសន្យា សិទ្ធិ និងកាតព្វកិច្ចផ្លូវច្បាប់។ ប៉ុន្តែមួយផ្នែកទៀត ច្បាប់បរទេសក៏ត្រូវបានកែប្រែ សម្របសម្រួល និងអនុវត្តតាមរបៀបដែលសមស្របនឹងវប្បធម៌ និងរចនាសម្ព័ន្ធសង្គមមូលដ្ឋានរបស់កម្ពុជាវិញដែរ។ ដូចនេះ តាមទស្សនៈនីតិសាស្ត្រអន្តរវប្បធម៌ វិស័យការងារមិនមែនជាដំណើរការនៃការគ្រប់គ្រងដោយច្បាប់តែម្ខាងនោះទេ ប៉ុន្តែជាដំណើរការអន្តរកម្ម ដែលច្បាប់ និងសង្គម បន្តប៉ះពាល់ និងកែប្រែគ្នាទៅវិញទៅមក។

បើតាមទស្សនវិទូ MONTESQUIEU ច្បាប់ប្រទេសមួយមិនអាចដូចគ្នាទៅនឹងប្រទេសមួយទៀតទេ វាគ្រាន់តែជាភាពចៃដន្យប៉ុណ្ណោះ ប្រសិនបើច្បាប់នៃប្រទេសមួយដូចគ្នាទៅនឹងប្រទេសមួយទៀតនោះ[៥១៣]។ ចំពោះនរវិទូ និងសង្គមវិទូ Nobert ROULAND វិញ បានលើកឡើងថា ប្រទេសនីមួយៗតែងមានច្បាប់គ្រប់គ្រងសង្គមរាងខ្លួន ប៉ុន្តែមិនប្រាកដថាវិធាននៃការដឹកនាំ គ្រប់គ្រងសង្គមនីមួយៗសុទ្ធតែមានតម្លៃដូចគ្នានោះទេ សង្គមខ្លះយកច្បាប់ជាធំនៅពេលមានបញ្ហាកើតឡើងដែលត្រូវដោះស្រាយ រីឯសង្គមខ្លះទៀត ច្បាប់ត្រូវបានយកមកប្រើតែនៅពេលដែលគ្មានមធ្យោបាយសមស្របផ្សេងទៀត ឬជាជម្រើសចុងក្រោយប៉ុណ្ណោះ[៥១៤]។ តាមលោកស្រីមេធាវីបណ្ឌិត Marion SIMONET ប្រទេសអាស៊ីជាច្រើន រួមទាំងកម្ពុជាផងដែរ ប្រកាន់យកការដោះស្រាយវិវាទតាមការចរចារ សម្រុះសម្រួលដោយសន្តិវិធីជាជាងទៅរកការចាញ់ឈ្នះនៅតុលាការ[៥១៥]។ ទ្រឹស្តីខុងជឺរបស់ចិនបុរាណក៏

---

[៥១៣] MONTESQUIEU ស្មារតីនៃច្បាប់ បោះពុម្ពដោយ Garnier Flammarion ឆ្នាំ១៩៧៩ ទំព័រ ៣៤ *នៅក្នុង* លឹម ស៊ុយហុង សមភាពក្នុងទំនាក់ទំនងការងារនៅកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យលីយ៉ុង ២ ឆ្នាំ២០០៧ ទំព័រ ១៤៤។

[៥១៤] Nobert ROULAND នរវិទ្យាគតិយុត្ត បោះពុម្ពផ្សាយដោយ P.U.F., Coll. Que sais-je? ឆ្នាំ១៩៩០ ទំព័រ ៧ ។ លោកសាស្ត្រាចារ្យ Maurice GAILLARD នៅក្នុងសៀវភៅស្នាដៃនិពន្ធរបស់គាត់ក្រោមចំណងជើង "លទ្ធិប្រជាធិបតេយ្យកម្ពុជា រដ្ឋធម្មនុញ្ញ ២៤ កញ្ញា ១៩៩៣" បោះពុម្ពផ្សាយដោយ l'Harmattan, Coll. Points sur l'Asie ទំព័រ ៨៧ បានបញ្ជាក់ថា បើចង់ឱ្យគេគោរព បន្តមានអត្ថិភាព និងមានសារៈប្រយោជន៍ដល់សង្គមជាតិនោះ ច្បាប់ត្រូវតែឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់សង្គមនោះ។

[៥១៥] Marion SIMONET ច្បាប់ និងគ្រួសារនៅកម្ពុជា ការសិក្សាអំពីនរវិទ្យាគតិយុត្ត និក្ខេបបទបណ្ឌិត សាកលវិទ្យាល័យលីយ៉ុង៣ ប្រទេសបារាំង ឆ្នាំ២០០១ ទំព័រ ២៩៥ និងបន្តបន្ទាប់។

ដូចគ្នានេះដែរ បានលើកឡើងអំពីការចេះយោគយល់គ្នា ការរស់នៅដោយសន្តិភាព ចេះអធ្យាស្រ័យគ្នាទៅវិញទៅមក ប្រសើរជាងនិយាយតែពីសិទ្ធិ ពីយុត្តិធម៌ដាច់ខាត ដែលមិនសាកសមជាពលរដ្ឋស៊ីវិល័យនៃសង្គមប្រពៃណីចិនឡើយ ប៉ុន្តែជាភាពអាម៉ាស និងការបរាជ័យទៅវិញទេដែលគ្រប់បញ្ហាត្រូវយកទៅដោះស្រាយ ហែកហួរគ្នានៅតុលាការ[៥១៦]។

តាមអ្វីដែលយើងបានសិក្សាខាងលើ ច្បាប់ការងារកម្ពុជាមិនមែនកើតឡើងដោយការតស៊ូផ្នែកសង្គមទេ ប៉ុន្តែជាច្បាប់ដែលកើតចេញពីឆន្ទៈខាងក្រៅតាមរយៈការបញ្ចូលវប្បធម៌ច្បាប់បរទេស។ ច្បាប់ដូចទៅនឹងលទ្ធិប្រជាធិបតេយ្យដែរ មិនអាចចាក់ឬសគល់រឹងមាំបានទេ ប្រសិនបើប្រទេសនោះមិនមានវប្បធម៌គតិយុត្ត ឬយន្តការនៃការគ្រប់គ្រងដូចគ្នា។ ករណីនេះជាប់ពាក់ព័ន្ធនឹងប្រវត្តិសាស្ត្រ ប្រជាជននៃប្រទេសនោះ ហើយជាទូទៅវាមិនងាយស្រួលសម្រាប់ប្រជាជននៃប្រទេសមួយទទួលយកផ្នត់គំនិត ប្រព័ន្ធគតិយុត្តនៃប្រទេសមួយទៀត (អឺរ៉ុប) ដែលខុសគ្នាខ្លាំងពេកពីប្រព័ន្ធគ្រប់គ្រងសង្គមរបស់ខ្លួននៅអាស៊ី។ ក្នុងន័យនេះ ទើបលោក លី ក្វាន់យូ បិតាស្ថាបនិកប្រទេស និងជាអតីតនាយករដ្ឋមន្ត្រីប្រទេសសិង្ហបុរីលើកឡើងអំពីទស្សនទានខុសគ្នារវាងសិទ្ធមនុស្សនៅអឺរ៉ុប និងសិទ្ធិមនុស្សនៅអាស៊ី ដោយគូសបញ្ជាក់ថា ប្រជាជននៅអាស៊ីផ្តោតសំខាន់លើគ្រួសារ លើការគោរពឱ្យតម្លៃគ្នាទៅវិញទៅមក ការគោរពអ្នកមានអំណាច និងការឱ្យតម្លៃលើការងារ[៥១៧]។

ការសម្របខ្លួនរបស់នីតិការងារទៅក្នុងសង្គមកម្ពុជាជួបប្រឈមនឹងការទទួលយកពីប្រជាជនជាទូទៅ នៅពេលដែលអត្តសញ្ញាណនៃច្បាប់នោះមិនបានឆ្លុះបញ្ចាំងការអនុវត្តនៅក្នុងសង្គមជាក់ស្តែង។ យន្តការដោះស្រាយវិវាទការងារដោយការផ្សះផ្សារក្រៅប្រព័ន្ធតុលាការ គឺពិតជាស្របតាមទំនៀមទម្លាប់ប្រពៃណីរបស់ខ្មែរ ហើយការបញ្ចូលសញ្ញាណអាជ្ញាកណ្តាលក្នុងការដោះស្រាយវិវាទការងារក្នុងក្រម ការងារឆ្នាំ១៩៧២ និងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ គឺឆ្លុះបញ្ចាំងពីតម្រូវការរបស់សង្គមពិតប្រាកដ។ និយាយម្យ៉ាងទៀត យុត្តិធម៌តាមបែបប្រពៃណីបានបន្សល់ទុកជាមរតកគតិយុត្តនៅកម្ពុជា ហើយអ្នកតាក់តែងច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ បានបញ្ចូលការដោះស្រាយវិវាទក្រៅប្រព័ន្ធ

---

[៥១៦] Élène PIQUET ប្រទេសចិននៅចំណុចនៃប្រពៃណីវប្បធម៌គតិយុត្ត បោះពុម្ពដោយ Bruyland, Bruxelles, ឆ្នាំ២០០៥ ទំព័រ៣៧។ សូមមើលផងដែរ Nobert ROULAND សេចក្តីផ្តើមប្រវត្តិនៃនីតិ បោះពុម្ពដោយ P.U.F. ឆ្នាំ១៩៩៨ ទំព័រ៤៣។

[៥១៧] Maurice GAILLARD ការកសាងប្រព័ន្ធគតិយុត្តឡើងវិញនៅកម្ពុជា៖ តើនីតិបែបណាសម្រាប់សង្គមបែបណា? *អត្ថបទក្នុងឯកសារបោះពុម្ពផ្សាយពីលទ្ធផលនៃសិក្ខាសាលាស្តីពី* "គម្រប់ខួប១០ ឆ្នាំនៃក្រមការងារកម្ពុជា" ដែលចងក្រងឡើងដោយការិយាល័យសហប្រតិបត្តិការបារាំង ប្រចាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី១-២ វិច្ឆិកា ឆ្នាំ២០០៧ រោងពុម្ព Funan ទំព័រ ៣០។

តុលាការនេះផងដែរ។ ឧទាហរណ៍មួយទៀត អ្នកបំរើនៅតាមផ្ទះ ជាវប្បធម៌ ប្រពៃណីខ្មែរពីបុរាណ ដែលពួកគាត់រស់នៅក្រោមការគ្រប់គ្រងមើលថែដូចជាកូនចៅ សមាជិកគ្រួសារដូច្នេះប្រសិនបើច្បាប់ការងារចែងពីសិទ្ធិ សេរីភាព ខ្លាំងពេកដោយពុំមានគិតពីកត្តាទាំងនេះ អាចនឹងនាំឱ្យមានផលជះអវិជ្ជមាននៅក្នុងការអនុវត្តជាក់ស្តែង។ ទោះយ៉ាងណាច្បាប់ស្តីពីការងារបច្ចុប្បន្នមិនអនុវត្តចំពោះអ្នកធ្វើការនៅតាមផ្ទះនៅឡើយទេ ប៉ុន្តែម្ចាស់ផ្ទះត្រូវបង់ធានារ៉ាប់រងផ្នែកសុខភាព ហានិភ័យការងារ និងសោធន ជូនពួកគាត់ស្របតាមច្បាប់ស្តីពីរបបសន្តិសុខសង្គម។

ផ្ទុយទៅវិញ ការបង្កើតសញ្ញាណសិទ្ធិកូដកម្ម និងសេរីភាពផ្នែកសហជីព គឺជាគោលការណ៍ដែលនាំចូលពីបរទេស ដែលទស្សនាទានបែបនេះមិនធ្លាប់មាននៅក្នុងប្រទេសកម្ពុជាពីមុន[៥១៨]។ នៅក្នុងទំនាក់ទំនងការងារ កម្មករនិយោជិតដែលជាង ៨០% ជាកម្មករនិយោជិតនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ចាត់ទុកនិយោជកដូចជាចៅហ្វាយនាយផងជាមេគ្រួសារផង។ នៅពេលមានបញ្ហាពាក់ព័ន្ធនឹងការអនុវត្តច្បាប់ស្តីពីការងារ គូភាគីតែងមានការយោគយល់គ្នា ពោលគឺមិនចង់នាំយកវិវាទបន្តទៅតុលាការនោះទេ។ ដូចគ្នានេះដែរ ទំនាក់ទំនងការងារមួយចំនួនបានកើតឡើងដោយពុំបានឆ្លងកាត់កិច្ចសន្យាការងារផ្លូវការ ការតម្រូវឱ្យគោរពលក្ខខណ្ឌការងារ លក្ខខណ្ឌសុខភាព និងសុវត្ថិភាពការងារ ព្រមទាំងកាតព្វកិច្ចផ្សេងៗគឺជាការអនុវត្តស្របតាមច្បាប់ដែលបានតាក់តែងឡើងដោយមានជំនួយបច្ចេកទេសពីអន្តរជាតិ ប៉ុន្តែច្បាប់នេះមិនប្រាកដថាកើតចេញពីការទាមទារ ពីការតស៊ូផ្នែកការងារនោះទេ ដែលនាំឱ្យការគោរព ការផ្តល់តម្លៃនៅមានកម្រិត រីឯការយល់ដឹងរបស់ដៃគូសង្គម ក៏ដូចជាភាគីពាក់ព័ន្ធខ្លះមិនទាន់បានគ្រប់ជ្រុងជ្រោយ។

---

[៥១៨] ការតស៊ូជាសមូហភាពដើម្បីទាមទារ និងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងាររបស់កម្មករនិយោជិត គឺមានប្រវត្តិយូរលង់នៅប្រទេសជឿនលឿននៅសហភាពអឺរ៉ុបដែលចាប់ផ្តើមពីអង់គ្លេសនាសតវត្សទី១៨ ហើយបានរីកសាយភាពទៅបណ្តាប្រទេសផ្សេងៗទៀត។ កម្មករនិយោជិតបានប្រមូលផ្តុំគ្នាដើម្បីប្រឆាំងនឹងការគៀបសង្កត់ ជិះជាន់ កែសលម្អច្បាប់ ទាមទារសិទ្ធិបុគ្គល និងសិទ្ធិសមូហភាព តាមរយៈការទទួលស្គាល់សិទ្ធិសហជីព និងសិទ្ធិប្រមូលផ្តុំជាដើម។ យើងមើលឃើញថាច្បាប់ប្រទេសទាំងនោះកើតចេញពីចលនា និងព្រឹត្តិការណ៍សង្គម រីឯកម្ពុជាសញ្ញាណនៃសិទ្ធិទាំងនោះ ត្រូវបានយកមកដាក់បញ្ចូលនៅក្នុងច្បាប់របស់ខ្លួនតែម្តង។ សូមមើល Jacques NÉPOTE, ចំណងគ្រួសារ និងការរៀបចំសង្គមនៅកម្ពុជា បោះពុម្ព ដោយ Olizane ឆ្នាំ១៩៩៦ ទំព័រ ២៤ *នៅក្នុង* លឹម ស៊ុយហុង សមភាពក្នុងទំនាក់ទំនងការងារនៅកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យលីយ៉ុង ២ ឆ្នាំ២០០៧ ទំព័រ ១៤៧។

១.៤. សេចក្តីសន្និដ្ឋាន

ការសិក្សាអំពីការកំណត់អត្តសញ្ញាណនៃច្បាប់ការងារនៅកម្ពុជា តាមទស្សនៈនីតិសាស្ត្រអន្តរវប្បធម៌ បង្ហាញថា ច្បាប់ការងារមិនមែនជាប្រព័ន្ធដែលកើតឡើងដោយឡែកពីសង្គមនោះទេ ប៉ុន្តែជាលទ្ធផលនៃដំណើរការប្រវត្តិសាស្ត្រ វប្បធម៌ និងសង្គម ដែលមានការប៉ះទង្គិច ការសម្របសម្រួល និងការបន្តបន្ទាប់ម្លេងជាបន្តបន្ទាប់។ ក្នុងបរិបទកម្ពុជា ច្បាប់ការងារបច្ចុប្បន្ន មិនអាចយល់បានយ៉ាងពេញលេញទេ ប្រសិនបើមិនពិនិត្យឫសគល់របស់វាឱ្យបានម៉ត់ចត់។ ការផ្ទេរច្បាប់ការងារបារាំងមកកម្ពុជា មិនមែនជាការចម្លងគំរូច្បាប់បរទេសដោយគ្មានការកែប្រែឡើយ។ ផ្ទុយទៅវិញ វាជាដំណើរការអន្តរកម្ម ដែលច្បាប់បរទេសត្រូវបានកែសម្រួល និងអនុវត្តក្នុងបរិបទសង្គមខ្មែរ ដែលមានរចនាសម្ព័ន្ធសង្គម ប្រពៃណី និងទស្សនៈអំពីការងារខុសប្លែកគ្នា។ ដំណើរការនេះ បានបង្កើតស្ថានភាពនៃពហុនីតិភាព (pluralisme juridique) ដែលច្បាប់ផ្លូវការ និងទម្លាប់សង្គម នៅតែរស់នៅ និងមានឥទ្ធិពលលើការអនុវត្តច្បាប់ការងារជាក់ស្តែង។

អត្តសញ្ញាណនៃច្បាប់ការងារកម្ពុជា មិនអាចកំណត់បានថាជាច្បាប់បរទេស ឬច្បាប់ប្រពៃណីសុទ្ធសាធនោះទេ ប៉ុន្តែជាច្បាប់ដែលកើតចេញពីការប្រសព្វគ្នារវាងគោលការណ៍ច្បាប់ទំនើប និងគុណតម្លៃវប្បធម៌មូលដ្ឋាន។ ការវិភាគតាមបែបនរវិទ្យាគតិយុត្តបង្ហាញថា ច្បាប់មិនត្រឹមតែធ្វើឲ្យសង្គមផ្លាស់ប្តូរនោះទេ ប៉ុន្តែសង្គមផងដែរ បានកែប្រែអនុវត្ត និងផ្តល់អត្ថន័យថ្មីទៅឱ្យច្បាប់។

នៅដំណាក់កាលនេះ ស្របតាមការវិវត្តន៍នៃពិភពការងារ ការរីកចម្រើនផ្នែកបច្ចេកវិទ្យា នៅក្នុងសាកលភាវូបនីយកម្មនៃសេដ្ឋកិច្ចសកល ច្បាប់ការងារមិនអាចឈប់នៅទ្រឹងបានជាដាច់ខាត ពីព្រោះនីតិការងារជានីតិដែលរស់រវើក ហើយត្រូវចេះសម្របខ្លួនដើម្បីដោះស្រាយ និងគ្រប់គ្រងបញ្ហានានាប្រកបដោយប្រសិទ្ធភាព។ មានន័យថា ការសិក្សាទៅលើអត្តសញ្ញាណច្បាប់ក្នុងវិស័យការងារមិនគ្រាន់តែជារឿងប្រវត្តិសាស្ត្រទេ ប៉ុន្តែអ្វីដែលសំខាន់នៅពេលនេះគឺការពង្រឹងវប្បធម៌អនុលោមភាពតាមច្បាប់ បញ្ជ្រាបការយល់ដឹងដល់តួអង្គអនុវត្តច្បាប់ និងភាគីពាក់ព័ន្ធ ហើយត្រូវធ្វើយ៉ាងណាឱ្យច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវបានអនុម័តឡើងដោយមានការចូលរួមពីត្រីភាគី ដែលជាមូលដ្ឋានគ្រឹះនៃសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈនៅកម្ពុជា។

ជាចុងក្រោយ ការកំណត់អត្តសញ្ញាណច្បាប់ខ្មែរជួយឱ្យយើងយល់កាន់តែច្បាស់អំពីមូលដ្ឋានគ្រឹះនៃច្បាប់កម្ពុជានៅក្នុងវិស័យការងារ អាចឱ្យយើងវាយតម្លៃបានអំពី

សមត្ថភាពរបស់វាក្នុងការឆ្លើយតបទៅនឹងចំណោទបញ្ហាពាក់ព័ន្ធនឹងយុត្តិធម៌សង្គម ការប្រកួតប្រជែងផ្នែកសេដ្ឋកិច្ច និងការគោរពសិទ្ធិការងារ ជាអាទិ៍ ព្រមទាំងអនុញ្ញាតឱ្យមានជាមូលដ្ឋានមួយរឹងមាំក្នុងការធ្វើកំណែទម្រង់ និងការកំណត់អំពីបូរណភាពនៃច្បាប់ក្នុងវិស័យការងារនាពេលខាងមុខផងដែរ។

គន្ថនិទ្ទេស

រដ្ឋធម្មនុញ្ញកម្ពុជា ឆ្នាំ១៩៩៣។

អនុសញ្ញាលេខ២៩ ស្តីពីការងារដោយបង្ខំ ឆ្នាំ១៩៣០ ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ ១៩៦៩ (នៅជាធរមាន)។

អនុសញ្ញាលេខ៨៧ ស្តីពីសេរីភាព សមាគម និងការការពារសិទ្ធិនៃការបង្កើតសមាគម ឆ្នាំ ១៩៤៨ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ៩៨ ស្តីពីការអនុវត្តគោលការណ៍ស្តីអំពីសិទ្ធិនៃការបង្កើតសមាគម និង សិទ្ធិនៃការចរចាជាសមូហភាព ឆ្នាំ១៩៤៩ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១០០ ស្តីពីប្រាក់ឈ្នួលស្មើគ្នា ឆ្នាំ១៩៤៩ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១០៥ ស្តីពីការលុបបំបាត់ការងារដោយបង្ខំ ឆ្នាំ១៩៥១ ផ្តល់សច្ចាប័នថ្ងៃទី ២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១១១ ស្តីពីការរើសអើងក្នុងការងារ និងមុខរបរ ឆ្នាំ១៩៥៨ ផ្តល់សច្ចាប័ន ថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១៣៨ ស្តីពីអាយុអប្បបរមា ឆ្នាំ១៩៧៣ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១៨២ ស្តីពីទម្រង់ធ្ងន់ធ្ងរបំផុតនៃការងារកុមារ ឆ្នាំ១៩៩៩ ផ្តល់សច្ចាប័ន ថ្ងៃទី១៤ ខែមីនា ឆ្នាំ២០០៦ (នៅជាធរមាន)។

អនុសញ្ញាលេខ៤ ស្តីពីការងារពេលយប់ (ស្ត្រី) ឆ្នាំ១៩១៩ ផ្តល់សច្ចាប័នថ្ងៃទី២៤ ខែ កុម្ភៈ ឆ្នាំ១៩៦៩ (និរាករណ៍ នៅឆ្នាំ២០១៧)។

អនុសញ្ញាលេខ៦ ស្តីពីការងារពេលយប់របស់មនុស្សវ័យក្មេង ឆ្នាំ១៩១៩ ផ្តល់សច្ចាប័នថ្ងៃ ទី២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (នៅជាធរមាន)

អនុសញ្ញាលេខ១៣ ស្តីពីសំណរកាបូណាត (ថ្នាំលាប) ឆ្នាំ១៩២១ ផ្តល់សច្ចាប័នថ្ងៃទី ២៤ ខែកុម្ភៈ ឆ្នាំ១៩៦៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១៥០ ស្តីពីរដ្ឋបាលការងារ ឆ្នាំ១៩៧៨ ផ្តល់សច្ចាប័នថ្ងៃទី២៣ ខែកញ្ញា ឆ្នាំ១៩៩៩ (នៅជាធរមាន)។

អនុសញ្ញាលេខ១២២ ស្តីពីគោលនយោបាយមុខរបរ ឆ្នាំ១៩៦៤ ផ្តល់សច្ចាប័នថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ១៩៧១ (នៅជាធរមាន)។

Laure Ginesty ការបង្ហាញប្រវត្តិនៃការតាក់តែងក្រមការងារ ស្នាដៃនៃកិច្ចសហប្រតិបត្តិការ អត្ថបទក្នុងឯកសារបោះពុម្ពផ្សាយពីលទ្ធផលនៃសិក្ខាសាលាស្តីពី "គម្រប់ខួប១០ ឆ្នាំនៃក្រមការងារកម្ពុជា" ចងក្រងឡើងដោយការិយាល័យសហប្រតិបត្តិការបារាំង ប្រចាំសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី១-២ វិច្ឆិកា ឆ្នាំ២០០៧ រោងពុម្ព Funan។

ច្បាប់ស្តីពីការងារឆ្នាំ១៩៩៧។

ច្បាប់ការងារបារាំងពីឆ្នាំ១៨៤១ ដល់បច្ចុប្បន្ននៅក្នុងគេហទំព័រ https://travail-emploi.gouv.fr/histoire-du-droit-du-travail-de-1 8 4 1 - nos-jours-reperes-chronologiques។

ច្បាប់ស្តីពីការទទួលខុសត្រូវលើគ្រោះថ្នាក់កើតឡើងចំពោះកម្មករនិយោជិត ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ១៨៩៨។

ក្រុមប្រឹក្សានីតិកម្មនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ កម្រងច្បាប់ខ្មែរពីបុរាណ ភាគ១ និងភាគ២ បោះពុម្ពឆ្នាំ២០១៦ និងភាគ៣ និងភាគ៤ បោះពុម្ពឆ្នាំ២០២០។

ក្រមទាសកម្មករ/ Krâm Téasa Kamokor, នៅក្នុង Adhémard Leclère, Les codes cambodgiens, ភាគទី១ បោះពុម្ព ដោយ Ernest Leroux ឆ្នាំ១៨៩៨។

ហ៊ែល ចំរើន នីតិការងារ ឆ្នាំ២០០៥ បោះពុម្ពដោយ Funan។

ហង្ស កក្កដារាស្សី ប្រវត្តិក្រសួងទទួលបន្ទុកវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖ នីតិក្រមនៃការងារចាប់ពីសម័យអាណានិគមនិយមបារាំងរហូតមកទល់បច្ចុប្បន្ន បោះពុម្ពឆ្នាំ២០២៤។

Adhémard Leclère, Les codes cambodgiens, ភាគទី២ ឆ្នាំ១៨៩៨, ទំព័រ ៤៧៩ និងទំព័រ៦៣១ នៅក្នុង ហ៊ែល ចំរើន នីតិការងារ ឆ្នាំ២០០៥ បោះពុម្ព ដោយ Funan។

Marcel CLAIRON សញ្ញាណសំខាន់ៗនៃច្បាប់ការងារកម្ពុជា ព្រឹត្តិបត្រ មហាវិទ្យាល័យនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចភ្នំពេញ ឆ្នាំ១៩៦៥។

Marcel CLAIRON សញ្ញាណសំខាន់ៗនៃច្បាប់ការងារកម្ពុជា។

MONTESQUIEU ស្មារតីនៃច្បាប់ បោះពុម្ពដោយ Garnier Flammarion ឆ្នាំ១៩៧៩ ទំព័រ ៣៤ នៅក្នុង លឹម ស៊ុយហុង សមភាពក្នុងទំនាក់ទំនងការងារនៅកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យលីយ៉ុង ២ ឆ្នាំ២០០៧ ទំព័រ ១៤៤។

Nobert ROULAND នរវិទ្យាគតិយុត្ត បោះពុម្ពផ្សាយដោយ P.U.F., Coll. Que sais-je? ឆ្នាំ១៩៩០ ទំព័រ ៧ ។ លោកសាស្ត្រាចារ្យ Maurice GAILLARD នៅក្នុងសៀវភៅស្នាដៃនិពន្ធរបស់គាត់ក្រោមចំណងជើង "លទ្ធិប្រជាធិបតេយ្យកម្ពុជា រដ្ឋធម្មនុញ្ញ ២៤ កញ្ញា ១៩៩៣" បោះពុម្ពផ្សាយដោយ l'Harmattan, Coll. Points sur l'Asie ទំព័រ ៨៧ បានបញ្ជាក់ថា បើចង់ឱ្យគេគោរព បន្តមានអត្ថិភាព និងមានសារៈប្រយោជន៍ដល់សង្គមជាតិនោះ ច្បាប់ត្រូវតែឆ្លើយតបទៅនឹងតម្រូវការពិតប្រាកដរបស់សង្គមនោះ។

Marion SIMONET ច្បាប់ និងគ្រួសារនៅកម្ពុជា ការសិក្សាអំពីនរវិទ្យាគតិយុត្ត និក្ខេបបទបណ្ឌិត សាកលវិទ្យាល័យលីយ៉ុង៣ ប្រទេសបារាំង ឆ្នាំ២០០១ ទំព័រ ២៩៥ និងបន្តបន្ទាប់។

Élène PIQUET ប្រទេសចិននៅចំណុចនៃប្រពៃណីវប្បធម៌គតិយុត្ត បោះពុម្ពដោយ Bruyland, Bruxelles, ឆ្នាំ២០០៥ ទំព័រ៣៧។ សូមមើលផងដែរ Nobert ROULAND សេចក្តីផ្តើមប្រវត្តិនៃនីតិ បោះពុម្ពដោយ P.U.F. ឆ្នាំ១៩៩៨ ទំព័រ ៤៣។

Maurice GAILLARD ការកសាងប្រព័ន្ធគតិយុត្តឡើងវិញនៅកម្ពុជា៖ តើនីតិបែបណាសម្រាប់សង្គមបែបណា? អត្ថបទក្នុងឯកសារបោះពុម្ពផ្សាយពីលទ្ធផលនៃសិក្ខាសាលាស្តីពី "គម្រប់ខួប១០ ឆ្នាំនៃក្រមការងារកម្ពុជា" ដែលចងក្រងឡើងដោយការិយាល័យសហប្រតិបត្តិការបារាំង ប្រចាំសាកលវិទ្យាស័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ថ្ងៃទី១-២ វិច្ឆិកា ឆ្នាំ២០០៧ រោងពុម្ព Funan ទំព័រ ៣០។

Jacques NÉPOTE, ចំណងគ្រួសារ និងការរៀបចំសង្គមនៅកម្ពុជា បោះពុម្ព ដោយ Olizane ឆ្នាំ១៩៩៦។

លឹម ស៊ុយហុង សមភាពក្នុងទំនាក់ទំនងការងារនៅកម្ពុជា និក្ខេបបទថ្នាក់បណ្ឌិត សាកលវិទ្យាល័យលីយ៉ុង។

ផ្នែកទី២. នីតិរដ្ឋប្បវេណី

សិក្សាអំពី «អត្តសញ្ញាណច្បាប់កម្ពុជាក្នុងវិស័យរដ្ឋប្បវេណី»

កញ្ញា ធីម សុភាព មេធាវី នៃក្រុមហ៊ុនមេធាវី អេស វី ភី

២.១. សេចក្តីផ្តើម

១. ច្បាប់ទាំងឡាយត្រូវបានបែងចែកជាជាពីរប្រភេទធំៗ គឺនីតិសាធារណៈ និងនីតិឯកជន។ ច្បាប់ដែល បញ្ញត្តអំពីភាពស្មើគ្នានៃបុគ្គលឯកជនក្នុងទំនាក់ទំនងគតិយុត្តរបស់ខ្លួនទៅវិញទៅមក ត្រូវចាត់ទុកជាច្បាប់នៃនីតិឯកជន។ នីតិឯកជន រួមមានជាអាទិ៍ ច្បាប់រដ្ឋប្បវេណី ច្បាប់ពាណិជ្ជកម្ម ច្បាប់ការងារ ច្បាប់ហិរញ្ញវត្ថុ។ ក្នុងរបាយការណ៍ស្រាវជ្រាវបឋមនេះ នឹងពិនិត្យតែទៅលើច្បាប់រដ្ឋប្បវេណី ដែលហៅថា ច្បាប់ស៊ីវិល ឬ Droit Civil ប៉ុណ្ណោះ។ "ប្បវេណី" មានន័យថា ប្រពៃណី ទំនៀមទំលាប់ ឬន័យទូលាយថា ជារបៀបរបបគ្រប់គ្រងសណ្តាប់ធ្នាប់ ទំនៀមទំលាប់រស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋ។

២. នីតិរដ្ឋប្បវេណី ឬ ជំនួសដោយហៅថា "នីតិឯកជន"[៥១៩] មានអត្ថន័យដូចគ្នា ដែលសំដៅដល់បណ្តុំនៃវិធាន ឬ បទប្បញ្ញត្តិដែលគ្រប់គ្រងរាល់ទំនាក់ទំនងគតិយុត្តរវាងបុគ្គលឯកជន និងបុគ្គលឯកជន ក្នុងជីវភាពរស់នៅប្រចាំថ្ងៃ។ បច្ចុប្បន្នកម្ពុជាបាន និងកំពុងអនុវត្តក្រមរដ្ឋប្បវេណី ដែលជាច្បាប់ទូទៅនៃនីតិឯកជនគ្រប់ដណ្តប់លើទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី។ ក្រមនេះ ត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/១២០៧/០៣០ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០០៧ (តទៅហៅកាត់ថា "ក្រមរដ្ឋប្បវេណី ២០០៧) និងត្រូវបានប្រកាសឱ្យអនុវត្តនៅទូទាំងព្រះរាជាណាចក្រកម្ពុជា នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១ ដោយបញ្ញត្តិនៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥១១/០០៧ ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០១១ (តទៅហៅកាត់ថា "ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី")។

៣. បទប្បញ្ញត្តិនៃក្រមរដ្ឋប្បវេណី២០០៧ ទទួលរងឥទ្ធិពលយ៉ាងជិតស្និតពីក្រមរដ្ឋប្បវេណីដំបូងរបស់កម្ពុជា ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះមហាក្សត្រ នាថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩២០ (តទៅហៅកាត់ថា "ក្រមរដ្ឋប្បវេណីសង្គមចាស់") និងត្រូវបានកែប្រែតាមរចនាសម្ព័ន្ធច្បាប់ស៊ីវិលទំនើប ក្រោមជំនួយបច្ចេកទេសរបស់ប្រទេសជប៉ុន តាមរយៈទី

[៥១៩] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១, ម.១, ទំ.១

ភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (Japan International Cooperation Agency ហៅកាត់ថា "JICA")។ បច្ចុប្បន្នក្រុមការងារ JICA នៅតែបន្តគម្រោងរបស់ខ្លួនតាមរយៈការបណ្តុះបណ្តាលច្បាប់រដ្ឋប្បវេណីដល់ចៅក្រម មេធាវី និងអ្នកច្បាប់ផ្សេងទៀត បើទោះបីជាក្រមរដ្ឋប្បវេណី ត្រូវបានអនុម័តរួចរាល់ក៏ដោយ។ ហេតុនេះហាក់ឃើញថា ក្រមរដ្ឋប្បវេណី ២០០៧ មានឥទ្ធិពលដោយផ្ទាល់ពីក្រមរដ្ឋប្បវេណីជប៉ុន ប៉ុន្តែក្រមរដ្ឋប្បវេណីជប៉ុន ក៏ទទួលរងឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំង អាល្លឺម៉ង់ ព្រមទាំងប្រទេសដែលអនុវត្តប្រព័ន្ធច្បាប់ស៊ីវិលផងដែរ[៥២០]។ ហេតុដូច្នេះអាចបង្ហាញថា ក្រមរដ្ឋប្បវេណី២០០៧ ក៏នៅតែទទួលរងឥទ្ធិពលដោយផ្ទាល់ពីប្រព័ន្ធច្បាប់ស៊ីវិលផងដែរ។ លើសពីនេះ ស្ថិតក្នុងស្ថានភាពនៃសាកលភាវូបនីយកម្ម ក្នុងគោលដៅរក្សាស្ថិរភាពគតិយុត្ត សម្រាប់វិនិយោគិនបរទេស និងប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ បទប្បញ្ញត្តិខ្លះ នៃក្រមរដ្ឋប្បវេណីក៏ទទួលរងនូវឥទ្ធិពលពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុងដែរ ជាពិសេសទៅលើបញ្ញត្តិនៃកិច្ចសន្យា ការការពារបរិស្ថាន ជាអាទិ៍។ ទោះយ៉ាងណាក៏ដោយ បទប្បញ្ញត្តិទំនៀមទំលាប់ប្រពៃណីពីបូរាណខ្មែរ និងសាសនា ក៏ត្រូវបានបញ្ចូលក្នុងក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ដែរ ជាពិសេសក្នុងទំនាក់ទំនងគ្រួសារ និងសីលធម៌រស់នៅក្នុងជីវភាពប្រចាំថ្ងៃ។ ក្រមរដ្ឋប្បវេណី២០០៧ គឺជាការរួមបញ្ចូលគ្នារវាង ច្បាប់រដ្ឋប្បវេណីនៃប្រទេសបារាំង ជប៉ុន និងទំនៀមទំលាប់ខ្មែរ ដើម្បីឲ្យសមនឹងបរិបទសង្គមប្រជាធិបតេយ្យ និងតម្រូវការបច្ចុប្បន្ន។

៤. តាមមាត្រា១ នៃក្រមរដ្ឋប្បវេណី២០០៧ បញ្ញត្តថា ក្រមនេះអនុវត្តលើទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ដែលមានទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ។ ក្រមនេះមានគោលបំណងផ្តោតសំខាន់ គោរពលើការបង្ហាញឆន្ទៈដោយឯករាជ្យរបស់បុគ្គលឯកជនលើទំនាក់ទំនងប្រចាំថ្ងៃរបស់ពួកគេ ដែលក្នុងនោះក្រមរដ្ឋប្បវេណីបានបែងចែកជា ៩ គន្លឹះធំ ដោយមាន៣ផ្នែកសំខាន់ៗរួមមាន ១. គោលការណ៍ទូទៅនៃក្រមរដ្ឋប្បវេណី ដែលមានបញ្ញត្តិ ជានានូវសិទ្ធិស្មើគ្នារបស់ប្រជាពលរដ្ឋ ការគោរពសេរីភាពឆន្ទៈបុគ្គល ការអនុវត្តកាតព្វកិច្ចដោយសុចរិតស្មោះត្រង់ និងបញ្ញត្តិពាក់ព័ន្ធនឹងសមត្ថភាពគតិយុត្តរបស់បុគ្គលឯកជន ២.ទំនាក់ទំនងទ្រព្យសម្បត្តិ ដែលមានបញ្ញត្តិពាក់ព័ន្ធនឹងសិទ្ធិប្រត្យក្ស(សិទ្ធិលើវត្ថុ) កាតព្វកិច្ចនិងកិច្ចសន្យាសំខាន់ៗ (សិទ្ធិលើបុគ្គល ឬ សិទ្ធិលើបំណុល ឬ សិទ្ធិបាតិបុគ្គល) និង៣. សិទ្ធិក្រៅបេតិកកណ្ឌ រួមមានសិទ្ធិបុគ្គល និងសិទ្ធិ

[៥២០] សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, សាស្ត្រាចារ្យ ណូមីរ៉ា តូយ៉ូហ៊ីរ៉ូ, ជំ.២-២ រចនាសម្ព័ន្ធក្រមរដ្ឋប្បវេណី, ទំ.១២-២០

គ្រួសារ ដែលក្នុងនោះមានបញ្ញត្តិពាក់ព័ន្ធនឹងការបង្កើតគ្រួសារ ទំនាក់ទំនងឪពុកម្តាយកូន និងមត៌ក។

៥. ក្រមរដ្ឋប្បវេណី២០០៧ គឺជាច្បាប់ទូទៅមួយ ដែលមានលក្ខណៈទូលំទូលាយ សម្រាប់អនុវត្តលើគ្រប់ទំនាក់ទំនងគតិយុត្តនីមួយៗរបស់បុគ្គលឯកជនតាំងពីកើតរហូតដល់ស្លាប់ ហេតុនេះរបាយការណ៍ស្រាវជ្រាវបឋមនេះ នឹងធ្វើការពិនិត្យទៅលើដំណើរវិវត្តន៍នៃក្រមរដ្ឋប្បវេណី និងសញ្ញាណគតិយុត្តផ្នែករដ្ឋប្បវេណីមួយចំនួន តាំងពីសម័យបូរាណរហូតដល់បច្ចុប្បន្ន(២.១) ដោយព្យាយាមកំណត់ថាតើបទប្បញ្ញត្តិណាខ្លះនៃក្រមរដ្ឋប្បវេណីណាខ្លះ ដែលមានឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិល ឬ ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ឬ ទំនៀមទំលាប់ប្រពៃណី និងសាសនា (២.២) ដោយយកសញ្ញាណគតិយុត្តសំខាន់ៗ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី២០០៧ជាគោលដើម្បីប្រៀបធៀបប៉ុណ្ណោះ ដោយពុំទាន់ប្រៀបធៀបលម្អិត ដល់ខ្លឹមសារដែលមានបញ្ញត្តិក្នុងច្បាប់បូរាណ និងច្បាប់ទំនើបបច្ចុប្បន្ននេះនៅឡើយទេ។

២.២. របបកត់ហើញ

២.២.១. ការវិវត្តន៍នៃច្បាប់រដ្ឋប្បវេណីកម្ពុជា

២.២.១.១. មុនសម័យអាណានិគមបារាំង

៦. ខ្មែរបូរាណ ប្រតិបត្តិខ្ជាប់ខ្ជួននូវវិន័យនានា ដែលទទួលឥទ្ធិពលពីទំនៀមទម្លាប់ ប្រពៃណី ជំនឿតាមតំបន់[៥២១] ទស្សនៈកម្មផលដែលទទួលឥទ្ធិពលពីសាសនា ជាអាទិ៍។ វិធានច្បាប់នាសម័យនោះ ត្រូវបានឆ្លុះបញ្ចាំងឱ្យឃើញតាមរយៈរឿងព្រេង អក្សរសិល្ប៍ខ្មែរ កំណាប សុភាសិតខ្មែរបូរាណ ដែលបង្ហាញពីអរិយធម៌ ប្រពៃណី ទំនៀមទំលាប់ ផ្នត់គំនិត ចាក់ឫសក្នុងទស្សនៈខ្មែរ[៥២២]។

៧. លោកបណ្ឌិត ហ៊ែល ចំរើន បានលើកឡើងក្នុងសៀវភៅមរតកយុត្តិធម៌ខ្មែរថា អត្ថបទនៃក្រមព្រះធម្មសាស្ត្រនៃសម័យអង្គរបានបាត់បង់ទាំងស្រុងទៅហើយ ការសិក្សាអំពីយុត្តិសាស្ត្រតាមគន្លងធម្មសាស្ត្រនេះ ត្រូវផ្អែកជាមូលដ្ឋានលើក្រមព្រះធម្មសាស្ត្រ និងក្រមដទៃទៀត ដែលមានអត្ថិភាពនៅសតវត្សទី១៩ ក្នុងរដ្ឋកាលព្រះបាទសម្តេចព្រះ

[៥២១] អរិយធម៌ខ្មែរ, សាស្ត្រាចារ្យ អ៊ីវ ជុង, ទំព័រ....

[៥២២] មរតកយុត្តិធម៌ខ្មែរ, បណ្ឌិត ហ៊ែល ចំរើន, កថា.២, ទំ. ៨-១០

នរោត្តម[៥២៣]។ តាមរយៈក្រមព្រះធម្មសាស្ត្រ និងក្រមបូរាណនាសតវត្សទី១៩នេះ ឃើញមានក្រមដែលពាក់ព័ន្ធនឹងច្បាប់រដ្ឋប្បវេណី រួមមាន ក្រំមព្រះរាជក្រិតសំយ៉ារី (ឬ ក្រមព្រះរាជក្រឹត្យសង្ឃរី) បញ្ញត្តអំពីលក្ខខណ្ឌនៃការរៀបអាពាហ៍ពិពាហ៍ និងទោសប្រមាថឪពុកម្តាយញាតិសន្តាន, ក្រំមទស់កិរីយ៉ា(ឬ ក្រមទោសករិយា) បញ្ញត្តពីការដាក់ទោសពាក់ព័ន្ធនឹងការសាហាយស្មន់របស់ស្ត្រីជាប្រពន្ធ និងការលែងលះដោយស្មគ្រគិត្ត, ក្រមមរដក់ (ឬក្រមមរតក) បញ្ញត្តអំពីការបែងចែកមរតករបស់ខ្មោចដែលស្លាប់ទៅ, ក្រំមពហុលទេព្វ (ឬ ក្រមពហុពលទេព) បញ្ញត្តអំពីសិទ្ធិ និងកាតព្វកិច្ចបុគ្គលជាម្ចាស់ដីស្រែ សត្វចិញ្ចឹមជាមួយនឹងអ្នកជិតខាង, ក្រំមវិវាទ (ឬ ក្រមវិវាទ) បញ្ញត្តអំពីការរស់នៅក្នុងគ្រួសារ, ក្រំមបៀរ (ឬ ក្រមបៀ), លក្ខណៈក្រំមបំណុល(ឬ លក្ខណៈក្រមបំណុល) បញ្ញត្តអំពីការខ្ចីចងការប្រាក់ និងការលក់តួ, លក្ខណៈទាសកម្មករណ៍(ឬ លក្ខណៈទាសកម្មករ) ក្រមសួស្តីបនជូនព្រៃយ(ឬ ក្រមសួស្តីបញ្ជូនព្រៃ), ក្រំមព្រះរាជខណ្ឌ (ឬ ក្រមព្រះរាជខណ្ឌ), ច្បាប់ទុំនឹមព្យីបូរ៉ាន(ឬ ច្បាប់ទំនឹមពីបុរាណ)។

២.២.១.២. អាណានិគមបារាំង (សតវត្សទី១៩-១៩៥៣)

៨. ក្នុងសម័យអាណានិគមបារាំង ប្រព័ន្ធច្បាប់កម្ពុជាត្រូវបានប្រែប្រួល ផ្លាស់ប្តូរពីការប្រតិបត្តិច្បាប់តាមបែបប្រពៃណីទំនៀមទំលាប់ មកកាន់ច្បាប់សរសេរ ដោយទទួលឥទ្ធិពលនាំចូលប្រព័ន្ធច្បាប់ស៊ីវិល ពីប្រទេសបារាំង។ **ក្រមរដ្ឋប្បវេណីឆ្នាំសង្គមចាស់** គឺជាក្រមស៊ីវិលដំបូងបង្អស់នៅកម្ពុជា ដែលត្រូវបានប្រកាសប្រើប្រាស់នៅថ្ងៃទី២៥ កុម្ភៈ ឆ្នាំ១៩២០ ដែលក្រមនេះទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីនៃប្រទេសបារាំងរួមបញ្ចូលនូវច្បាប់ទំនៀមទម្លាប់កម្ពុជាខ្លះ។ នេះជាការចាប់ផ្តើមនៃប្រព័ន្ធច្បាប់ស៊ីវិល នៅក្នុងប្រទេសកម្ពុជា។

៩. ខ្លឹមសារក្រមរដ្ឋប្បវេណីសង្គមចាស់នេះ ត្រូវបានចងក្រងតាមគំរូក្រមរដ្ឋប្បវេណីបារាំង បន្ថែមឥទ្ធិពលពីច្បាប់អាល្លឺម៉ង់ ហើយមានការបែងចែកជាបី គន្លឹះ គឺទី ១. បុគ្គល និងគ្រួសារ ដោយក្នុងនោះមានបញ្ញត្តិពាក់ព័ន្ធនឹងសញ្ជាតិ, កំដាប់ពាក្យ, ការរៀបអាពាហ៍ពិពាហ៍, ប្រពន្ធ-កូនមានខាន់ស្លា និងឥតខាន់ស្លា, ការបែងចែកមរតក ព្រមទាំងបញ្ញត្តអំពីគំហាត់ជនផងដែរ, ទី២. ទ្រព្យ ដែលក្នុងនោះរួមមានរបបកម្មសិទ្ធិ និងសិទ្ធិលើវត្ថុផ្សេងទៀត ដូចជាផលុបភោគ និងសេវភាពជាអាទិ៍, ទី៣. អំពីកាតព្វកិច្ច និងកិច្ចសន្យាសំខាន់ៗ ដោយក្នុងនោះរួមមានទាំងការធានាកាតព្វកិច្ចផង។ ទោះជាយ៉ាងណា

[៥២៣] មរតកយុត្តិធម៌ខ្មែរ, បណ្ឌិត ហ៊ែល ចំរើន, ជំ.២ ទំ.៣៥៣

ការអនុវត្តនៅក្នុងជីវិតប្រចាំថ្ងៃ មិនទូលំទូលាយទេ ពីព្រោះប្រជាពលរដ្ឋភាគច្រើននៅតែជឿទុកចិត្តលើទំនៀមទំលាប់ និងការយល់ដឹងច្បាប់សរសេរនៅតិច។

១០. ក្រោយពីកម្ពុជាទទួលបានឯករាជ្យ ក្រមរដ្ឋប្បវេណីសង្គមចាស់នៅតែបន្តប្រើប្រាស់ និងត្រូវបានវិសោធនកម្មជាបន្តបន្ទាប់ តាមការវិវត្តន៍នៃសេដ្ឋកិច្ចសង្គមខ្មែរទំនើបនាសម័យនោះ ប៉ុន្តែយើងមិនអាចដឹងថាតើ បញ្ញត្តិណាខ្លះត្រូវបានធ្វើវិសោធនកម្មទេ ព្រោះឯកសារពាក់ព័ន្ធនឹងវិសោធនកម្មក្រមរដ្ឋប្បវេណីសង្គមចាស់នោះត្រូវបានបាត់បង់[៥២៤]។

១១. រហូតដល់កម្ពុជា បានផ្លាស់ប្តូររបបមកជា របបសាធារណរដ្ឋខ្មែរ (១៩៧០-១៩៧៥) ក៏ពុំមានក្រមរដ្ឋប្បវេណីថ្មីនោះទេ ហើយរដ្ឋធម្មនុញ្ញសាធារណរដ្ឋខ្មែរ ដែលប្រកាសឱ្យប្រើនៅថ្ងៃទី១០ ខែឧសភា ឆ្នាំ១៩៧២ នៅតែគោរពសិទ្ធិសេរីភាពរបស់ប្រជាពលរដ្ឋ រួមទាំងការការពារសិទ្ធិលើទ្រព្យសម្បត្តិផងដែរ[៥២៥]។

២.២.១.៣. សម័យកម្ពុជាប្រជាធិបតេយ្យ (១៩៧៥ – ១៩៧៩)

១២. ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ចាប់ពីថ្ងៃទី១៧ មេសា ១៩៧៥ ប្រព័ន្ធច្បាប់និងតុលាការរបស់ប្រទេសកម្ពុជាត្រូវបានបំផ្លាញ និងបោះបង់ចោលស្ទើរទាំងស្រុង។ ក្នុងអំឡុងពេលនោះមិនមានក្រមរដ្ឋប្បវេណី ឬ ច្បាប់ស៊ីវិលត្រូវបានអនុវត្តឡើយ ពោលគឺមានតែធម្មនុញ្ញនៃរបបនេះតែមួយគត់ ដែលមានបញ្ញត្តិពាក់ព័ន្ធនឹងរដ្ឋប្បវេណី ដោយសិទ្ធិផ្នែករដ្ឋប្បវេណីរបស់ប្រជាពលរដ្ឋនោះ ត្រូវបានលុបបំបាត់ស្ទើរតែទាំងស្រុង ជំនួសដោយសេចក្តីបញ្ជាតាមនយោបាយបក្ស(អង្គការ)។

១៣. ធម្មនុញ្ញអង្គការខ្មែរក្រហម បានលុបបំបាត់ទ្រព្យឯកជនលើដីធ្លី មធ្យោបាយផលិតកម្ម ដោយចាត់ទុកជាទ្រព្យសមូហភាព លើកលែងរបស់របរប្រចាំថ្ងៃ[៥២៦]។ របបនេះបានលុបបំបាត់គ្រួសារបែបប្រពៃណី និងការរៀបអាពាហ៍ពិពាហ៍ត្រូវបានធ្វើឡើងជាក្រុមដោយបង្ខំតាមនយោបាយអង្គការ។ ដូច្នេះ មិនមានសិទ្ធិឯកជនលើទ្រព្យ ការធ្វើជំនួញទំនាក់ទំនងផ្លូវច្បាប់នានា កាតព្វកិច្ចក្នុងគ្រួសារ និងសិទ្ធិមរតកទៀតឡើយ។

---

[៥២៤] ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី, ម.៨២

[៥២៥] ធម្មនុញ្ញសាធារណរដ្ឋខ្មែរ១៩៧២, ជំ.២

[៥២៦] រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ, ម.២

២.២.១.៤. របបសាធារណរដ្ឋប្រជាមានិតកម្ពុជា (១៩៧៩-១៩៩៣)

១៤. បន្ទាប់ពីការបរាជ័យរបស់របបខ្មែរក្រហមនៅឆ្នាំ១៩៧៩ ប្រទេសកម្ពុជាកើតមានរដ្ឋាភិបាលថ្មី គឺ សាធារណរដ្ឋប្រជាមានិតកម្ពុជា (ក្រោយមកហៅថា សម័យរដ្ឋកម្ពុជា)។ ក្នុងអំឡុងពេលនេះ ប្រព័ន្ធច្បាប់កម្ពុជាត្រូវបានស្តារឡើងវិញយ៉ាងយឺតៗ បន្ទាប់ពីត្រូវបានបំផ្លាញស្ទើរតែទាំងស្រុងក្រោមរបបខ្មែរក្រហម។ ក្រមរដ្ឋប្បវេណីសង្គមចាស់ មិនត្រូវបានអនុវត្តទៀតឡើយ ដោយសារត្រូវបានបោះបង់ចោល ក្រោយសម័យខ្មែរក្រហម។ ក្នុងបរិបទនោះ ការអនុវត្តច្បាប់រដ្ឋប្បវេណី មានលក្ខណៈកម្រិត ដោយការខ្វះខាតច្បាប់ និងប្រព័ន្ធគ្រប់គ្រងសេដ្ឋកិច្ចបែបសង្គមនិយមនៅឡើយ។

១៥. រដ្ឋាភិបាលថ្មីបានអនុម័តបទប្បញ្ញត្តិថ្មីៗ ដែលផ្អែកលើអាទិភាពនយោបាយសង្គមនិយម និងការគ្រប់គ្រងរដ្ឋ។ ច្បាប់សំខាន់ៗមួយចំនួន ដែលជំនួសក្រមរដ្ឋប្បវេណីសង្គមចាស់គឺ ច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារ ឆ្នាំ១៩៨៩ ដែលកំណត់ទំនាក់ទំនងគ្រួសារ និងសិទ្ធិមរតក, ច្បាប់ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ឆ្នាំ១៩៨៨ ដែលកំណត់ទំនាក់ទំនងផ្នែកសិទ្ធិលើទ្រព្យ ឬកិច្ចសន្យា, ច្បាប់កូមិបាលឆ្នាំ១៩៩២ ដែលកំណត់អំពីសិទ្ធិលើអចលនវត្ថុ ជាអាទិ៍។ ប៉ុន្តែប្រជាពលរដ្ឋភាគច្រើន នៅប្រើប្រាស់ទំនៀមទំលាប់ ប្រពៃណី និងបទប្បញ្ញត្តិរដ្ឋាភិបាល ជាជំនួសក្រមស៊ីវិលពេញលេញ រហូតដល់មានក្រមរដ្ឋប្បវេណីឆ្នាំ២០០៧។

២.២.១.៥. ព្រះរាជាណាចក្រកម្ពុជា (១៩៩៣-១៩៩៣)

១៦. បន្ទាប់ពីការបោះឆ្នោតឆ្នាំ១៩៩៣ ប្រទេសកម្ពុជាបានចាប់ផ្តើមជ្រើសរើសរបបសេដ្ឋកិច្ចទីផ្សារសេរី និងស្តារឡើងវិញប្រព័ន្ធច្បាប់។ នៅដំណាក់កាលដំបូងនេះ កម្ពុជានៅបន្តការអនុវត្តច្បាប់ដែលមានក្នុងសម័យរដ្ឋកម្ពុជា និងប្រពៃណីទំនៀមទំលាប់ដដែល។ ដល់ឆ្នាំ១៩៩៩ សេចក្តីព្រាងក្រមរដ្ឋប្បវេណី ត្រូវបានបង្កើតឡើងក្រោមគម្រោងមួយរបស់ JICA សហការជាមួយនឹងក្រសួងយុត្តិធម៌កម្ពុជា ឈ្មោះថា "កម្មវិធីអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌និងច្បាប់កម្ពុជា"។ ក្រមរដ្ឋប្បវេណីថ្មី ត្រូវបានព្រះមហាក្សត្រប្រកាសឱ្យប្រើ តាមរយៈព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ នៅថ្ងៃទី០៨ ខែធ្នូឆ្នាំ២០០៧ (ក្រមរដ្ឋប្បវេណី ២០០៧) ប៉ុន្តែត្រូវអនុវត្តទូទាំងប្រទេសនៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១។

១៧. ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ ត្រូវបានបែងចែកជា ៩ គន្លឹ និងមាន ១៣០៥ មាត្រា។ គន្លឹទាំងនោះរួមមាន (១)បទប្បញ្ញត្តិទូទៅ (២)បុគ្គល (៣)សិទ្ធិប្រត្យក្ស (៤)

កាតព្វកិច្ច (៥)កិច្ចសន្យាសំខាន់ៗ និងអំពើអនីតិ្យនុកូល (៦)ការធានាកាតព្វកិច្ច (៧) ញាតិ (៨)សន្តតិកម្ម និង(៩)អវសានប្បញ្ញត្តិ។

១៨. តាមមាត្រា៧៨ និងមាត្រា៧៩ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី នៅពេលដែលកាលបរិច្ឆេទនៃការអនុវត្តក្រមរដ្ឋប្បវេណីមានអានុភាព បញ្ញត្តិមួយចំនួននៃច្បាប់(១)ច្បាប់អាពាហ៍ពិពាហ៍និងគ្រួសារ និង (២)ក្រឹត្យច្បាប់លេខ៣៨ក្រ.ច ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា នឹងត្រូវបាននិរាករណ៍។ ការនិរាករណ៍នេះក៏បានលើកលែងបញ្ញត្តិមួយចំនួននៃច្បាប់ទាំងពីរខាងលើផងដែរ ពោលគឺមានមាត្រាមួយចំនួននៅបន្តមានអានុភាព និងអាចអនុវត្តបានធម្មតា។ ក្រៅពីច្បាប់ទាំងពីរខាងលើក៏មានច្បាប់ភូមិបាលឆ្នាំ២០០១ ដែលត្រូវច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណីមាត្រា៨០បានធ្វើវិសោធនកម្មលុបចោលបញ្ញត្តិនៃមាត្រាខ្លះ ព្រមទាំងកែប្រែពាក្យពេចន៍ និងចំណងជើងឱ្យសមស្របតាមក្រមរដ្ឋប្បវេណី។

១៩. ក្រៅពីក្រមរដ្ឋប្បវេណី នៅមានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត ដែលមានតួនាទីជាច្បាប់ពិសេស ដើម្បីគ្រប់គ្រងលើទំនាក់ទំនងគតិយុត្តជាក់លាក់ក្នុងផ្នែករដ្ឋប្បវេណី ជាអាទិ៍រួមមាន ច្បាប់ស្តីពីអត្រានុកូលដ្ឋាន ស្ថិតិអត្រានុកូលដ្ឋាន និងអត្តសញ្ញាណកម្ម, ច្បាប់សញ្ជាតិ, ច្បាប់ភូមិបាល, ច្បាប់ស្តីពីការងារ, ច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម, ច្បាប់វិនិយោគ, ច្បាប់បរធនបាលកិច្ច, ច្បាប់ស្តីពីការប្រកួតប្រជែង, ច្បាប់ស្តីពីកិច្ចការពារអ្នកប្រើប្រាស់ ជាអាទិ៍។

២០. ក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ មានមុខងារ ជាមូលដ្ឋានសម្រាប់ចៅក្រមក្នុងការសម្រេចសេចក្តី និងជាមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋក្នុងការរស់នៅប្រចាំថ្ងៃផងដែរ[៥២៧]។ ក្រមនេះ បានបំពេញឲ្យប្រព័ន្ធច្បាប់កម្ពុជាមាន ស្ថេរភាព និងស្របនឹងគោលការណ៍អន្តរជាតិ ដើម្បីគាំទ្រការវិនិយោគ និងសេដ្ឋកិច្ចទីផ្សារ។ សិទ្ធិឯកជនលើទ្រព្យ ត្រូវបានទទួលស្គាល់វិញ (ក្រោយការដកហូតក្នុងរបបខ្មែរក្រហម)។ សិទ្ធិគ្រួសារ និងមរតកត្រូវបានរៀបចំជាប្រព័ន្ធច្បាស់លាស់ ផ្អែកតាមប្រព័ន្ធច្បាប់ស៊ីវិល និងទំនៀមទំលាប់ពីបូរាណ។ រីឯកិច្ចសន្យា និងកាតព្វកិច្ច ត្រូវបានគ្រប់គ្រងយ៉ាងទូលំទូលាយ សមស្របនឹងសេដ្ឋកិច្ចទីផ្សារ។

[៥២៧] សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១, ទំ.២

២.២.២. ការវាយតម្លៃសញ្ញាណច្បាប់ ក្នុងក្រមរដ្ឋប្បវេណី ២០០៧

២១. ក្រមរដ្ឋប្បវេណី២០០៧ ជាការរួមបញ្ចូលរវាង **ប្រព័ន្ធស៊ីវិលបារាំង, ជប៉ុន, អង់គ្លូសាក់សុង, ទំនៀមទំលាប់ជាតិ ច្បាប់អន្តរជាតិ និងសាសនា។ ការកំណត់ថា បញ្ញត្តិណាខ្លះត្រូវបានរងឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិល ឬ ប្រព័ន្ធអង់គ្លូសាក់ ឬ ទំនៀមទំលាប់ ឬ សាសនានោះ ជាការលំបាក ព្រោះថាប្រព័ន្ធនីមួយៗមានភាពប្រទាក់ក្រឡាគ្នា និងប្រាស្រ័យគ្នាទៅវិញទៅមក។ អត្ថបទស្រាវជ្រាវនេះនឹងបង្ហាញដោយសង្ខេបនូវបទប្បញ្ញត្តិខ្លះនៃក្រមរដ្ឋប្បវេណី ដែលអាចផ្សារភ្ជាប់នឹងឥទ្ធិពលផ្សេងៗគ្នា ដូចខាងក្រោម៖**

២.២.២.១. ឥទ្ធិពលប្រព័ន្ធច្បាប់ស៊ីវិល បារាំង ជប៉ុន

២២. ការជ្រើសរើសប្រព័ន្ធច្បាប់សរសេរ គឺជាឥទ្ធិពលមួយចេញពីប្រព័ន្ធច្បាប់ស៊ីវិល។ ក្រមរដ្ឋប្បវេណី ២០០៧ មាន ១៣០៥ រួមទាំងមាន ៨៤មាត្រាទៀត ដែលមានក្នុងច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី២០១១ គឺត្រូវបានយកមកអនុវត្តលើទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណីទាំងអស់នៅកម្ពុជា ដែលរួមមាន ទំនាក់ទំនងញាតិ និងទំនាក់ទំនងទ្រព្យសម្បត្តិ។ ក្រមរដ្ឋប្បវេណីសង្គមចាស់ មានតម្លៃប្រវត្តិសាស្ត្រយ៉ាងសំខាន់សម្រាប់កម្ពុជា ដែលជាមូលដ្ឋានសម្រាប់ការកសាងច្បាប់ស៊ីវិលនៅកម្ពុជា និងបានបង្កើតផ្លូវឱ្យក្រមថ្មីកើតមាន។ ជាក់ស្តែងបញ្ញត្តិនៃក្រមរដ្ឋប្បវេណី ២០០៧ ត្រូវបានយកលំនាំតាមក្រមរដ្ឋប្បវេណីសង្គមចាស់នេះ ស្ទើរតែទាំងស្រុង លើកលែងសញ្ញាណគតិយុត្តមួយចំនួន ដែលត្រូវបានកែសម្រួលតាមបរិបទសេដ្ឋកិច្ចសម័យទំនើប និងការធ្វើខេមរយោន្តកម្មលើបច្ចេកសព្ទគតិយុត្ត។

២៣. សញ្ញាណគតិយុត្ត ដែលទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីសង្គមចាស់ តាមលំនាំនៃច្បាប់ប្រទេសបារាំង រួមមានដូចខាងក្រោម៖

- **បញ្ញត្តិស្តីពីបុគ្គល៖** អត្រានុកូលដ្ឋាន (កើតការកប់), សមត្ថភាពនៃការទទួលសិទ្ធិរបស់រូបវន្តបុគ្គល និងរបបអាណាព្យាបាល, អត្តាធិនភាព, លំនៅដ្ឋាន និងការបាត់ខ្លួន
- **បញ្ញត្តិស្តីពីទ្រព្យ៖** របបកម្មសិទ្ធិ, កោគៈ, សិទ្ធិដំណុះលើវត្ថុ, សហកម្មសិទ្ធិ, អឌ្ឍសិទ្ធិ, សិទ្ធិប្រើប្រាស់អាស្រ័យនៅដែលមាន ផលុបភោគ, សេវភោព ជាអាទិ៍

- **បញ្ញត្តិស្តីពីកិច្ចសន្យា**៖ កាតព្វកិច្ចតាមឆន្ទៈ, កាតព្វកិច្ចតាមច្បាប់ (អំពើអនីតិ្យានុកូល, សេចក្តីចម្រើនដោយឥតហេតុ, ការគ្រប់គ្រងដោយការឈឺឆ្អាល), ការរលត់កាតព្វកិច្ច, កិច្ចសន្យាសំខាន់ៗ រួមមាន កិច្ចសន្យាលក់ទិញធម្មតា លក់បញ្ចាំ ឬហៅថាលក់ដោយមានការលោះ, កិច្ចសន្យាជួលដែលរួមមានជួលអចលនវត្ថុ ចលនវត្ថុ ជួលការងារ ជួលទុន ជាអាទិ៍, កិច្ចសន្យាខ្ចី, ប្រទានកម្ម ដែលអនុវត្តទៅលើជំនួន និងបណ្ណាការផង, កិច្ចសន្យាធានាដោយបុគ្គល បញ្ចាំ និង ហ៊ីប៉ូតែក ជាអាទិ៍។
- **បញ្ញត្តិស្តីពីអំពីញាតិ**៖ ពុំមានច្រើនមាត្រាទេ ដែលក្រមរដ្ឋប្បវេណី២០០៧ ទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីសង្គមចាស់ ព្រោះតែការប្រែប្រួលនៃការប្រកាន់យកបបប្តីមួយប្រពន្ធមួយ និងការរងឥទ្ធិពលមួយផ្នែកពាក់ព័ន្ធនឹងសិទ្ធិមនុស្សជាសកល ជាពិសេសការលុបបំបាត់ការរើសអើង។ យ៉ាងណាមិញ យើងឃើញមានសញ្ញាណគតិយុត្តខ្លះ ដែលមាននៅក្នុងក្រមរដ្ឋប្បវេណីសង្គមចាស់ ហើយនៅតែមានក្នុងក្រមរដ្ឋប្បវេណី២០០៧ រួមមាន កំជាប់ពាក្យ, ទម្រង់នៃការរៀបអាពាហ៍ពិពាហ៍ ដែលត្រូវចុះសំបុត្រអាពាហ៍ពិពាហ៍, ការលែងលះ, សន្តតិកម្មដោយគ្មានបណ្តាំ និងសារសំខាន់នៃបណ្តាំមត៌ក, អាហារកាតព្វកិច្ច ជាអាទិ៍។

២៤. ក្រៅពីលំនាំនៃក្រមរដ្ឋប្បវេណីសង្គមចាស់ខាងលើ ក្រមរដ្ឋប្បវេណី២០០៧ ក៏មានឥទ្ធិពលបន្ថែមពីក្រមរដ្ឋប្បវេណីជប៉ុន ដែលបង្ហាញឱ្យឃើញនូវស្តង់ដារច្បាប់ស៊ីវិលក្នុងសម័យទំនើប រួមមាន៖

- **បញ្ញត្តិស្តីពីសិទ្ធិប្រត្យក្ស ឬ សិទ្ធិភណ្ឌិក**៖ មានបទប្បញ្ញត្តិជាច្រើន ពាក់ព័ន្ធនឹងទំនាក់ទំនងសិទ្ធិប្រត្យក្សនេះ ដូចគ្នាទៅនឹងក្រមរដ្ឋប្បវេណីសង្គមចាស់ដែរ ប៉ុន្តែសញ្ញាណគតិយុត្តថ្មី ត្រូវបានកំណត់ក្នុងក្រមរដ្ឋប្បវេណី២០០៧ រួមមាន ទស្សនៈនៃសមាសភាគនៃវត្ថុ, សិទ្ធិលើផលនៃវត្ថុ, ទស្សនៈនៃសិទ្ធិកាន់កាប់, ឧបាទេសកម្ម, ការធ្វើលទ្ធកម្មសិទ្ធិកម្មសិទ្ធិដោយអាជ្ញាយុកាលលើអចលនវត្ថុ និងចលនវត្ថុ ជំនួសឱ្យភោគៈ ដែលត្រូវបានបញ្ចប់ការទទួលស្គាល់ដោយច្បាប់ភូមិបាលឆ្នាំ២០០១។ សញ្ញាណសេវភាព ដែលមានក្នុងក្រមរដ្ឋប្បវេណី២០០៧ សំដៅតែចំពោះសេវភាពតាមការព្រមព្រៀងប៉ុណ្ណោះ រីឯសេវភាពតាមច្បាប់កំណត់ ត្រូវបានបញ្ញត្តិដោយឡែកដោយ

ហៅថា ទំនាក់ទំនងរវាងដីជាប់គ្នា។ យ៉ាងណាមិញក្រមរដ្ឋប្បវេណី២០០៧ មិនបានចែងអំពីរបបសហកម្មសិទ្ធិ នោះទេ ពោលគឺក្រមរដ្ឋប្បវេណី ២០០៧ នៅរក្សាបញ្ញត្តិនេះក្នុងច្បាប់ភូមិបាល និងមានច្បាប់ពិសេសផ្សេងទៀត ដែលគ្រប់គ្រងនូវរបបសហកម្មសិទ្ធិនេះ។

- **បញ្ញត្តិស្តីពីកាតព្វកិច្ច ឬ ហៅថា សិទ្ធិលើបំណុល ឬ ហៅថា សិទ្ធិបាតិបុគ្គល** ៖ បញ្ញត្តិស្តីពីកាតព្វកិច្ច ក្នុងក្រមរដ្ឋប្បវេណី២០០៧ នៅមានអំពើអនីត្យានុកូល, ការគ្រប់គ្រងដោយការឈឺឆ្អាល, សេចក្តីចម្រើនដោយឥតហេតុដូចគ្នានឹងក្រមរដ្ឋប្បវេណីសង្គមចាស់ដែរ ប៉ុន្តែខុសលក្ខខណ្ឌក្នុងការអនុវត្តខ្លះ ដែលទំនោរតាមអត្ថបទច្បាប់នៃក្រមរដ្ឋប្បវេណីជប៉ុន។ យ៉ាងណាមិញ បញ្ញត្តិស្តីពីសំណងនៃអំពើអនីត្យានុកូល ក្នុងក្រមរដ្ឋប្បវេណី២០០៧ មិនត្រូវបានកំណត់លម្អិតដូចក្រមរដ្ឋប្បវេណីជប៉ុន អំពីរបៀបគិតសំណងការខូចខាតច្បាស់លាស់នោះទេ ដែលចៅក្រមត្រូវប្រើឆន្ទានុសិទ្ធិក្នុងការសម្រេច ប៉ុន្តែនៅតែមានភាពលំបាកក្នុងការវាយតម្លៃអំពីការខូចខាតនាពេលអនាគត។ ក្រៅពីបញ្ញត្តិកាតព្វកិច្ចក្រៅឆន្ទៈខាងលើ ក្រមរដ្ឋប្បវេណី ២០០៧ ក៏បញ្ញត្តិអំពីកាតព្វកិច្ចតាមការព្រមព្រៀង ហើយក្នុងនោះ យើងឃើញថាមានសញ្ញាណគតិយុត្តផ្សេងទៀតដែលទទួលឥទ្ធិពលពីប្រព័ន្ធច្បាប់ស៊ីវិលនៃប្រទេសជប៉ុន ដូចជា ទស្សនៈនៃអនុប្បទានសិទ្ធិលើបំណុល, ការទទួលកាតព្វកិច្ច, វិធានទណ្ឌកម្មនៃការមិនអនុវត្តតាមលក្ខខណ្ឌនៃកិច្ចសន្យា (មោឃភាព និងការលុបចោល), បែបផែននៃការរលត់កាតព្វកិច្ច, វិធានការនៃការសង្គ្រោះការមិនអនុវត្តកាតព្វកិច្ច រួមមានការរំលាយកិច្ចសន្យាជាដើម, ទស្សនៈនៃការសងសំណងខូចខាត។ ដោយឡែកចំពោះការធានាកាតព្វកិច្ច ក្រមរដ្ឋប្បវេណី២០០៧ បានលុបចោលសញ្ញាណនៃការធានា និងហាមឃាត់ការបញ្ចាំផ្តាច់ ប៉ុន្តែយើងឃើញមានសញ្ញាណនៃការសងដោយវត្ថុជំនួស និងកិច្ចសន្យាលក់ទិញដោយអនុវត្តសិទ្ធិលោះ ដែលអាចត្រូវបានបកស្រាយប្រដូចនឹងការបញ្ចាំផ្តាច់ផងដែរ[៥២៨] ហើយក្រៅពីនេះក៏មានទស្សនៈនៃសិទ្ធិឃាត់ទុក ឯកសិទ្ធិ រួមទាំងការបញ្ចាំសិទ្ធិ ដែល

[៥២៨] សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណីភាគ៣ ត្រង់កំណត់មាត្រា៥៦០

សំដៅលើការបញ្ចាំសិទ្ធិលើបំណុល និងសិទ្ធិទ្រព្យសម្បត្តិផ្សេងទៀតដែលមានតម្លៃសេដ្ឋកិច្ច ដូចជា សិទ្ធិកម្មសិទ្ធិបញ្ញា សិទ្ធិកាគហ៊ុន ជាដើម។

- **បញ្ញត្តិស្តីពីកិច្ចសន្យាសំខាន់ៗ៖** បច្ចេកសព្ទគតិយុត្តនៃកិច្ចសន្យាសំខាន់ៗ ត្រូវបានវិវត្តន៍ ខុសពីលំនាំនៃក្រមរដ្ឋប្បវេណីសង្គមចាស់ ជាក់ស្តែងរួមមានភតិសន្យាដែលក្រមរដ្ឋប្បវេណីសង្គមចាស់ សំដៅដល់ ការជួលអចលនវត្ថុ ប៉ុន្តែក្រមរដ្ឋប្បវេណី២០០៧ គ្របដណ្តប់ទាំងជួលចលនវត្ថុ និងអចលនវត្ថុ , រីឯ ការជួលទុន ដែលមានចែងក្នុងក្រមរដ្ឋប្បវេណីសង្គមចាស់ ត្រូវបានកែប្រែថ្មី តាមទស្សនៈច្បាប់ជប៉ុន ហៅថា កិច្ចសន្យាខ្ចីបរិភោគ, កិច្ចសន្យាជួលការងារ ត្រូវហៅថា កិច្ចសន្យាការងារ, កិច្ចសន្យាសហគ្រាស ត្រូវបានហៅថា កិច្ចសន្យាម៉ៅការ។ ក្រៅពីនេះនៅមានសញ្ញាណកិច្ចសន្យាថ្មីៗ ដូចជា កិច្ចសន្យាបញ្ចើបរិភោគ, ប្រវាស់ (ចាត់ទុកជាផ្នែកមួយនៃបញ្ញត្តិកតិសន្យា) , ធនលាភសាមយិកមួយជីវិត ជាអាទិ៍។
- **បញ្ញត្តិស្តីពីទំនាក់ទំនងញាតិ និងមរតក៖** ទស្សនៈនៃការកំណត់ទំហំញាតិ, ការសន្មត់ ឬ ការបដិសេធបិតុភាព និងការកំណត់បុត្តភាពផ្សេងទៀត, ការលុបចោលវិធានការកាត់កាលកូន, ការកម្រិតលក្ខខណ្ឌទម្រង់នៃបណ្តាំមរតក ឬហៅថា មត៌កសាសន៍ ដែលបច្ចុប្បន្ននៅមានបញ្ហាក្នុងការអនុវត្តនៅឡើយ ព្រោះចំនួនសាការីនៅមានកម្រិត, ការកំណត់លំដាប់សន្តតិជន និងការបែងចែកមត៌ក ជាអាទិ៍ ដែលមានលំនាំច្រើនពីក្រមរដ្ឋប្បវេណីជប៉ុន ព្រោះថាបញ្ញត្តិនៃមរតកនេះ ពុំបានចែងច្រើនក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ទេ ហើយបញ្ញត្តិក្នុងក្រមរដ្ឋប្បវេណីសង្គមចាស់ ក៏មិនអាចយកមកអនុវត្តបានក្នុងបរិបទនៃសង្គមទំនើបបច្ចុប្បន្ន ដែលគោរពសមភាពយែនឌ័រ និងសិទ្ធិកុមារដែរ។

យ៉ាងណាមិញសញ្ញាណគតិយុត្តមួយចំនួន ពុំទាន់ត្រូវបាន អនុវត្តដោយទូលំទូលាយនៅឡើយទេនៅកម្ពុជា ដូចជាទស្សនៈលិខិតយថាភូតចំពោះកិច្ចសន្យាអចលនវត្ថុ , ឧបាទេសកម្មសិទ្ធិលើបំណុល, ការចាប់ផ្តើមរបបអាណាព្យាបាល, ការបញ្ជាក់នត្ថិភាពនៃបុត្តភាពជាអាទិ៍។

២.២.២.២. ឥទ្ធិពលពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុច

២៥. ច្បាប់កម្ពុជា ដែលទទួលឥទ្ធិពលខ្លាំងពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុងភាគច្រើន គឺច្បាប់ពាក់ព័ន្ធនឹង វិស័យពាណិជ្ជកម្ម ដោយឡែកក្រមរដ្ឋប្បវេណី២០០៧ មានលក្ខណៈតិចតួចទេដែលទទួលរងឥទ្ធិពលខ្លះ ក្នុងគោលដៅសម្រួលដល់ប្រតិបត្តិការជំនួញរបស់បុគ្គលឯកជន។ ជាក់ស្តែង យើងឃើញមាន គោលការណ៍ស្វ័យភាពនៃបុគ្គលឯកជន និងគោលការណ៍កិច្ចសន្យាជាច្បាប់របស់គូភាគី ជាគោលការណ៍សកលក្នុងវិស័យជំនួញរបស់ភាគី ដែលមានចែងដូចគ្នានឹងច្បាប់កិច្ចសន្យាទីផ្សារសេរីដែរ។ បញ្ញត្តិនៃក្រមរដ្ឋប្បវេណី២០០៧ ជាពិសេសបញ្ញត្តិស្តីពីកាតព្វកិច្ច និងកិច្ចសន្យា ភាគច្រើនជាប្រភេទបញ្ញត្តិស្ម័គ្រចិត្ត ដែលទុកឱកាសឱ្យគូភាគី តាក់តែងដោយសេរីនូវលក្ខខណ្ឌចាំបាច់សម្រាប់ប្រតិបត្តិការជំនួញ ឬ ទំនាក់ទំនងផ្លូវច្បាប់របស់ខ្លួន។ យ៉ាងណាមិញ យើងឃើញសញ្ញាណគតិយុត្តមួយ ក្នុងគន្លឹទី៦ ស្តីពីអំពីប្រាតិកោគដោយអនុប្បទាន ដែលសញ្ញាណនេះ ស្រដៀងគ្នាខ្លាំងទៅនឹងប្រតិបត្តិការដែលមានកិច្ចធានា ដែលជារបៀបធ្វើពាណិជ្ជកម្មមួយនៃប្រទេសអឺរ៉ុប។ នៅក្នុងគន្លឹទី២ ជំពូកទី២ នៃក្រមរដ្ឋប្បវេណី២០០៧ ក៏មានបទប្បញ្ញត្តិស្តីពីនីតិបុគ្គល ដែលក្នុងនោះក៏មានបញ្ចូលនូវសញ្ញាណនីតិបុគ្គលមូលនិធិ ដែលដូចគ្នាទៅនឹងទម្រង់ក្រុមហ៊ុនពាណិជ្ជកម្ម កំណត់ក្នុងច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ដែរ ប៉ុន្តែបញ្ញត្តិនៃក្រមរដ្ឋប្បវេណី២០០៧នេះ ជាបញ្ញត្តិទូទៅប៉ុណ្ណោះ មិននិរាករណ៍ ឬ ជំនួសឱ្យបទប្បញ្ញត្តិនៃច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្មឆ្នាំ២០០៥ ដែលជាច្បាប់ពិសេសនោះទេ។

២.២.២.៣. ច្បាប់អន្តរជាតិ ជាអាទិ៍

២៦. មាត្រា២ នៃក្រមរដ្ឋប្បវេណីឆ្នាំ២០០៧ បានបញ្ញត្តិយ៉ាងច្បាស់អំពី ការធានានូវការគោរពសិទ្ធិស្មើគ្នារវាងបុរស និងស្ត្រី សិទ្ធិលើទ្រព្យសម្បត្តិ តាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។ មិនតែប៉ុណ្ណោះ មាត្រា ៧ នៃក្រមនេះ ក៏បានបញ្ញត្តិផងដែរ អំពីការទទួលស្គាល់នូវសិទ្ធិរបស់ជនបរទេស លើកលែងតែមានការកម្រិតសិទ្ធិកាន់កាប់មួយចំនួន ដែលត្រូវបានធ្វើឡើងតាមរយៈច្បាប់ ឬ សន្ធិសញ្ញា អនុសញ្ញា ណាមួយ។ រីឯមាត្រា ១០ នៃក្រមរដ្ឋប្បវេណី បានបញ្ញត្តអំពីអត្ថន័យនៃសិទ្ធិបុគ្គល និងទណ្ឌកម្មចំពោះការបំពានសិទ្ធិបុគ្គលនេះផងដែរ ពោលគឺស្របគ្នានឹងការទទួលស្គាល់ជាសកលនៃសិទ្ធិបុគ្គលឯកជន លើរូបកាយ កេរ្តិ៍ឈ្មោះ កិត្តិយស ភាពជាបុគ្គលនៃមនុស្ស ជាអាទិ៍។ ក្រៅពីនេះ ការលុបបំបាត់នូវ ទស្សនៈកូនមានខាន់ស្លា, កូនឥតខាន់ស្លា, ក៏ដូចជាការផ្តល់សិទ្ធិ

ស្មើគ្នាលើកូនស្មុំ ការកម្រិតសិទ្ធិរបស់អ្នកមានអំណាចមេបាក្នុងការអប់រំ ប្រៀនប្រដៅកូន ដោយបង្ការសកម្មភាពទាំងឡាយណាដែលមានលក្ខណៈជាអំពើហិង្សាក្នុងគ្រួសារជាអាទិ៍ គឺជា ការធានាការពារនូវឧត្តមប្រយោជន៍របស់កុមារ លុបបំបាត់ការរើសអើង ធានាការគោរពសមភាពយេនឌ័រ តាមយន្តការច្បាប់សកល។

២.២.២.៤. ទំនៀមទំលាប់ ឯិទសាសនា

២៧. បញ្ញត្តិមួយចំនួន ពាក់ព័ន្ធនឹងញាតិ និងមរតក ភាគច្រើនគោរពតាមទំនៀមទម្លាប់ ប្រពៃណីល្អផូរផង់របស់ខ្មែរ។ ជាក់ស្តែង មាត្រា ៩៣៨ នៃក្រមរដ្ឋប្បវេណី ២០០៧ បានកំណត់ទំហំញាតិ ជាបីប្រភេទ គឺញាតិលោហិតក្នុង៦ថ្នាក់ ញាតិពន្ធ៣ថ្នាក់ និងសហព័ទ្ធ(ប្តីប្រពន្ធស្របច្បាប់) ដែលនេះហាក់ផ្សារភ្ជាប់នឹង៣ក្យថា ញាតិការទាំង ៧ សន្តាន។ អានុភាពនៃទំហំញាតិនេះ នាំឱ្យទទួលបាននូវមរតក, អាហារកាតព្វកិច្ច និងត្រូវបានហាមឃាត់ចំពោះករណីអាពាហ៍ពិពាហ៍រវាងញាតិ ដែលខុសនឹងសីលធម៌ និងទំនៀមទំលាប់ខ្មែរផងដែរ។

២៨. កំជាប់ពាក្យ ជាសញ្ញាណគតិយុត្តមួយ ដែលមានចែងក្នុងក្រមរដ្ឋប្បវេណី ២០០៧ផង និងក្រមរដ្ឋប្បវេណីសង្គមចាស់ផង ដោយក្នុងនោះកំណត់លក្ខខណ្ឌ អានុភាព លុះត្រាតែបានធ្វើ ពិធីកំជាប់ពាក្យ ហើយពិធីកំជាប់ពាក្យនេះ ផ្សារភ្ជាប់យ៉ាងខ្លាំងទៅនឹងប្រពៃណីខ្មែរ ដែលមានពិធីចែចូវ ពិធីស្តីដណ្តឹង ពិធីលើកស្លា លើកជំនូនពីខាងប្រុសមកខាងស្រីតាមទំនៀមទម្លាប់ខ្មែរ ប៉ុន្តែបច្ចុប្បន្នកំឡាយត្រឹម ពិធីលើកស្លា ពាក់ជញ្ជៀន។

២៩. សញ្ញាណនៃផលុបភោគ, កិច្ចសន្យាប្រវាស់, ការគ្រប់គ្រងដោយឈឺឆ្អាល, ការទទួលបន្តនូវសិទ្ធិមរតក ដែលមានលើចេតិយ រតនសម្បត្តិ របស់គ្រួសារជាអាទិ៍ សុទ្ធតែទទួលឥទ្ធិពលដោយផ្ទាល់ពីទំនៀមទម្លាប់ខ្មែរ។ ក្រៅពីនេះ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ក៏បានចែងទទួលស្គាល់នូវសិទ្ធិសមូហភាពលើទ្រព្យសម្បត្តិរបស់វត្តអារាម ជាអាទិ៍ ដើម្បីជាប្រយោជន៍សម្រាប់ជំនឿសាសនា។

៣០. មាត្រា ១៣០ នៃក្រមរដ្ឋប្បវេណី ២០០៧ ចែងទទួលស្គាល់នូវសិទ្ធិប្រត្យក្សផ្សេងទៀត ដែលបង្កើតឡើងដោយទំនៀមទំលាប់ខ្មែរ ហើយមិនប៉ះពាល់ដល់សណ្តាប់ធ្នាប់សាធារណៈ។ ដូចគ្នាផងដែរ មាត្រា៥ នៃច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី ក៏ចែងទទួលស្គាល់នូវការយកបញ្ញត្តិស្តីពីប្រពៃណីទំនៀមទម្លាប់ មកអនុវត្ត

ដោយសមធម៌ ចំពោះទំនាក់ទំនងគតិយុត្តរវាងបុគ្គលដែលកើតមុនក្រមរដ្ឋប្បវេណី ហើយបន្តអត្ថិភាពក្រោយក្រមរដ្ឋប្បវេណីផងដែរ ក្នុងករណីដែលមិនមានច្បាប់ចែង។

៣១. ក្រៅពីនេះ គោលការណ៍ទូទៅ នៃក្រមរដ្ឋប្បវេណី ២០០៧ ដែលហាមឃាត់ការប្រើប្រាស់សិទ្ធិដោយបំពាន គោរពសិទ្ធិអ្នកដទៃ អនុវត្តកាតព្វកិច្ចដោយសុចរិត និងស្មោះត្រង់ ក៏ដូចជាការទទួលខុសត្រូវដោយសំណងក្នុងករណីមានការបំពាន ដែលខូចខាតដល់អ្នកដទៃនោះ គឺជាទស្សនៈទទួលឥទ្ធិពលពីសាសនាព្រះពុទ្ធ លើទស្សនៈកម្មផល ការប្រព្រឹត្តនូវសេចក្តីល្អ សុចរិតស្មោះត្រង់ មិនបំពានអ្នកដទៃ ជាដើម។

២.៣. សេចក្តីសន្និដ្ឋាន

ទោះបីក្រមរដ្ឋប្បវេណី២០០៧ ត្រូវបានបង្កើតឡើងក្រោមជំនួយរបស់ប្រទេសជប៉ុនក៏ពិតមែន ប៉ុន្តែក្រមរដ្ឋប្បវេណីជប៉ុនក៏ទទួលឥទ្ធិពលពីក្រមរដ្ឋប្បវេណីបារាំងដូចគ្នា ហេតុនេះហើយបានជាឃើញថា ក្រមរដ្ឋប្បវេណី២០០៧ មានលក្ខណៈស្រដៀងគ្នាខ្លាំងទៅនឹងបញ្ញត្តិនៃក្រមរដ្ឋប្បវេណីសង្គមចាស់។ ប៉ុន្តែទោះយ៉ាងណាក៏ដោយ ក្រមរដ្ឋប្បវេណី ២០០៧ មិនមែនកើតចេញពីឥទ្ធិពលនៃច្បាប់បរទេសសុទ្ធសាធនោះទេ ពោលគឺជាការរួមបញ្ចូលគ្នារវាងច្បាប់នៃប្រព័ន្ធស៊ីវិល និងទំនៀមទម្លាប់ខ្មែរ ហើយមានបញ្ញត្តិខ្លះបន្សីគ្នាទៅនឹងទស្សនៈនៃច្បាប់អង់គ្លូសាក់សុង។ ទោះបីក្រមនេះត្រូវបានផ្សព្វផ្សាយ និងដាក់ឱ្យអនុវត្ត ប្រមាណជាង១៤ឆ្នាំមកហើយក្តី ប៉ុន្តែភាពស្មុគស្មាញ នៃប្រើប្រាស់បច្ចេកសព្ទគតិយុត្ត ក៏ដូចជាសញ្ញាណគតិយុត្តថ្មីៗមួយចំនួន នាំឱ្យក្រមនេះពុំត្រូវយល់ដឹងឱ្យទូលំទូលាយ និងលំបាកក្នុងការអនុវត្ត ជាពិសេសធ្វើឱ្យមានភាពមិនចុះសម្រុងគ្នាជាមួយនឹងច្បាប់ពិសេស ដែលគ្រប់គ្រងវិស័យពាក់ព័ន្ធមួយចំនួន។

ការរក្សាទុកនូវលំនាំនៃប្រព័ន្ធច្បាប់ណាមួយ ក្នុងក្រមរដ្ឋប្បវេណី២០០៧ នឹងផ្តល់ភាពសម្បូរបែបចំពោះច្បាប់ខ្មែរសម្រាប់អនុវត្តទៅលើទំនាក់ទំនងគតិយុត្តផ្នែករដ្ឋប្បវេណី ប៉ុន្តែភាពសម្បូរបែបនេះ គប្បីត្រូវបានគ្រប់គ្រង និងកែសម្រួលឱ្យតាមលំអានច្បាប់ខ្មែរ។ ដូចបានបញ្ជាក់ក្នុងអត្ថបទខាងលើ ក្រមរដ្ឋប្បវេណី មានមុខងារជាមូលដ្ឋានសម្រាប់ចៅក្រមសម្រេចសេចក្តីផង ក៏ជាមូលដ្ឋានសម្រាប់ប្រជាពលរដ្ឋក្នុងការអនុវត្តជីវភាពរស់នៅប្រចាំថ្ងៃផង ហេតុដូច្នេះការប្រើប្រាស់បច្ចេកសព្ទគតិយុត្តតាមពាក្យសាមញ្ញ និងលក្ខខណ្ឌទំនៀមទំលាប់ច្បាស់លាស់ តែងាយយល់ សម្រាប់ប្រជាពលរដ្ឋទូទៅ គឺជាការចាំបាច់។ ការធ្វើវិសោធនកម្មក្រមរដ្ឋប្បវេណី គប្បីចូលរួមគ្រប់អង្គភាពពាក់ព័ន្ធតាមវិស័យ និងតាមផ្នែកនៃទំនាក់ទំនងគតិយុត្តដែលមានចែង ដើម្បីជាការទទួលធាតុចូលពីអង្គភាពនៃវិស័យពិសេសផង និងជាការផ្សព្វផ្សាយក្រមរដ្ឋប្បវេណីដែលជាបទប្បញ្ញត្តិទូទៅផង ក្នុងគោលដៅជៀសវាងការធ្វើច្បាប់ពិសេស ដែលមិនមានសង្គតភាពលើបច្ចេកសព្ទ ឬសញ្ញាណគតិយុត្តជាមួយនឹងច្បាប់ទូទៅ។

គន្ថនិទ្ទេស

ធម្មនុញ្ញសាធារណរដ្ឋខ្មែរ១៩៧២។

រដ្ឋធម្មនុញ្ញកម្ពុជាប្រជាធិបតេយ្យ។

ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី។

សេចក្តីពន្យល់ក្រមរដ្ឋប្បវេណីភាគ១។

សេចក្តីកំណត់មាត្រានីមួយៗនៃក្រមរដ្ឋប្បវេណី ភាគ ១។

សេចក្តីផ្តើមនីតិរដ្ឋប្បវេណី, សាស្ត្រាចារ្យ ណូមឺរ៉ា តូយ៉ូហ៊ីរ៉ូ, ជំ.២-២ រចនាសម្ព័ន្ធក្រមរដ្ឋប្បវេណី។

អរិយធម៌ខ្មែរ, សាស្ត្រាចារ្យ អ៊ឹង ថុង។

មរតកយុត្តិធម៌ខ្មែរ, បណ្ឌិត ហ៊ែល ចំរើន។

ជំពូកទី៣.
នីតិព្រហ្មទណ្ឌ

ផ្នែកទី១. នីតិវិធីព្រហ្មទណ្ឌ

សិក្ខាអំពី «នីតិវិធីព្រហ្មទណ្ឌ»

ឯកឧត្តម ពេជ អង្គ ប្រធានក្រុមការងារពាណិជ្ជកម្មនៃក្រុមប្រឹក្សាអ្នកច្បាប់

១.១. សេចក្តីផ្តើម

នីតិវិធីព្រហ្មទណ្ឌ គឺជាសំណុំនៃវិធានដែលគ្រប់គ្រងការវិនិច្ឆ័យដោយតុលាការនៃវិវាទដែលកើតឡើងរវាងបុគ្គល ឬរវាងរដ្ឋ និងបុគ្គល។ នីតិវិធីព្រហ្មទណ្ឌ គឺជាការអនុវត្តច្បាប់ព្រហ្មទណ្ឌ។ គោលបំណង គឺដើម្បីពិនិត្យបទល្មើស ប្រមូលភស្តុតាង ស្វែងរក និងវិនិច្ឆ័យជនល្មើស។ នីតិវិធីព្រហ្មទណ្ឌបង្កើតទំនាក់ទំនងរវាងបទល្មើសនិងការផ្តន្ទាទោស។ លក្ខណៈដោយឡែកនៃនីតិវិធីព្រហ្មទណ្ឌ ស្ថិតនៅក្នុងការពិតដែលថាវាត្រូវបានភ្ជាប់យ៉ាងជិតស្និទ្ធទៅនឹងការអនុវត្តច្បាប់ព្រហ្មទណ្ឌ ចំណែកឯច្បាប់រដ្ឋប្បវេណីជាញឹកញាប់បំផុតត្រូវបានអនុវត្តនៅខាងក្រៅករណីវិវាទនៅតុលាការ។ ការអនុវត្តច្បាប់ព្រហ្មទណ្ឌតម្រូវឱ្យមានការកាត់ក្តី។ នីតិវិធីព្រហ្មទណ្ឌនឹងឈានទៅឱ្យមានការកាត់ទោស និងផ្តន្ទាទោសជនល្មើស ប៉ុន្តែវាអាចបង្ហាញពីភាពគ្មានកំហុសរបស់អ្នកផ្សេងទៀតផងដែរ។ វាមានគោលបំណងការពារសង្គម ប៉ុន្តែក៏ធានាផលប្រយោជន៍របស់បុគ្គលផងដែរ។ នីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា បច្ចុប្បន្នត្រូវបានគ្រប់គ្រងដោយក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧។

១.២. លក្ខណៈនៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា ២០០៧

នីតិវិធីព្រហ្មទណ្ឌបារាំង ច្បិចយកនីតិវិធីទាំងពីរប្រភេទនេះ(ក)។ វាជារបបចម្រុះ។ នីតិវិធីព្រហ្មទណ្ឌកម្ពុជា ទទួលឥទ្ធិពលខ្លាំងពីនីតិវិធីព្រហ្មទណ្ឌបារាំង ដោយជំនាញការតាក់តែងគឺជាជនជាតិបារាំងក្រោមជំនួយបច្ចេកទេសរបស់រដ្ឋាភិបាលបារាំង(ខ)។

ក. នីតិវិធីនៃប្រភេទចម្រុះរបស់បារាំង

នេះគឺជាប្រព័ន្ធដែលត្រូវបានអនុម័តនៅក្នុងប្រទេសបារាំងចាប់តាំងពីក្រមនៃឆ្នាំ ១៨០៨។ ប្រព័ន្ធនេះតម្រូវតាមប្រពៃណីរាជាធិបតេយ្យ នៃប្រភេទស៊ើបអង្កេតផង និងគំនិតសាធារណៈរដ្ឋចង់បានប្រព័ន្ធចោទប្រកាន់មួយផង។ ប្រព័ន្ធចម្រុះធ្វើឱ្យវាអាចស្វែងរកតុល្យភាពរវាងការការពារសង្គម និងការធានាដល់បុគ្គល។ នីតិវិធីរបស់បារាំង គឺជា

ប្រភេទនៃការស៊ើបអង្កេតនៅដំណាក់កាលនៃការចាប់ផ្តើមដំណើរការនីតិវិធី៖ នេះគឺជាសិទ្ធិរបស់រដ្ឋអាជ្ញាសាធារណៈ។ ទោះយ៉ាងណាក៏ដោយ វាផ្តល់ឱ្យជនរងគ្រោះនូវលទ្ធភាពនៃការចាប់ផ្តើមដំណើរការនីតិវិធីព្រហ្មទណ្ឌតាមរយៈបណ្តឹងរដ្ឋប្បវេណី ឬដោយការកោះហៅដោយផ្ទាល់(Citation directe) ដែលជាលក្ខណៈនៃនីតិវិធីចោទប្រកាន់។

ការស៊ើបអង្កេត គឺជាលក្ខណៈនៃនីតិវិធីស៊ើបសួរ ជាពិសេសវាជាការសម្ងាត់។ ទោះជាយ៉ាងណាវាមានការតទល់ និងអនុញ្ញាតឱ្យមានការគោរពសិទ្ធិការពារក្តី។ ដំណាក់កាលជំនុំជម្រះមានលក្ខណៈនៃនីតិវិធីចោទប្រកាន់ ដោយវាត្រូវធ្វើជាសាធារណៈ ផ្ទាល់មាត់ និងចំពោះមុខ(តទល់)។

ខ. នីតិវិធីនៃប្រភេទចម្រុះរបស់កម្ពុជា ដែលទទួលឥទ្ធិពលពីក្រមនីតិវិធីបារាំង

ច្បាប់នីតិវិធីព្រហ្មទណ្ឌកម្ពុជា ពីមុនមកនិងជាពិសេសក្រមឆ្នាំ២០០៧ គឺជាច្បាប់ដែលមានលក្ខណៈចម្រុះ យកធាតុផ្សំពីប្រព័ន្ធបែបស៊ើបអង្កេតផងនិងចោទប្រកាន់ផង តាមបែបបារាំង លើកលែងតែខ្លឹមសារនៃការស្បថដែលត្រូវបានរៀបចំស្របតាមប្រពៃណីរបស់កម្ពុជា។

ទិដ្ឋភាពនៃប្រភេទប្រព័ន្ធស៊ើបអង្កេត៖

- កម្ពុជាទទួលឥទ្ធិពល**ទិដ្ឋភាពនៃប្រភេទប្រព័ន្ធស៊ើបអង្កេត** ជាពិសេសពីច្បាប់បារាំង ចាប់ពីជំនាន់អាណានិគមមកម្លេះ។
- **ចៅក្រមស៊ើបសួរ៖** ក្រមបច្ចុប្បន្នមានមាត្រា ១៤៣ ដល់មាត្រា ២៦៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលចែងអំពីចៅក្រមស៊ើបសួរ ដែលដឹកនាំការស៊ើបសួរ ការប្រមូលភស្តុតាង ការសាកសួរសាក្សី និងបញ្ជាឱ្យឃុំខ្លួន។ ចៅក្រមដើរតួនាទីស្វែងរកការពិត និងមិនមែនគ្រាន់តែជាអ្នកសម្រេចខុស/ត្រូវសម្រាប់ភាគីប៉ុណ្ណោះឡើយ។ គឺចៅក្រមដើរតួនាទីចម្បងក្នុងការស្វែងរកការពិតនៃអង្គហេតុ។
- **ការឃុំខ្លួនក្នុងដំណាក់កាលស៊ើបសួរនិងវិធានការបង្ខំ៖** ចៅក្រមអាចចេញបញ្ជាឱ្យស្រាវជ្រាវ រឹបអូស ការឃុំខ្លួនដោយមិនមានសវនាការតទល់។ មាត្រា ២០៣ អនុញ្ញាតឱ្យចៅក្រមស៊ើបសួរ ដាក់ជនស្ថិតក្រោមការពិនិត្យ ឱ្យនៅក្នុងការឃុំខ្លួនបណ្តោះអាសន្ន ដោយឈរលើភាពចាំបាច់និងមានសំអាងហេតុ។
- **ការកម្រិតតួនាទីរបស់មេធាវីការពារក្តី៖** មេធាវីការពារក្តី អាចស្នើសុំការស៊ើបអង្កេត ប៉ុន្តែមិនអាចសាកសួរសាក្សីក្នុងរយៈពេលស៊ើបសួរបានឡើយ។ នីតិ

វិធីនេះ មិនមានលក្ខណៈចំពោះមុខ និងមានបំណងកសាងសំណុំរឿងសម្រាប់តុលាការ។[៥២៩]

ទិដ្ឋភាពបែបចោទប្រកាន់នៃនីតិវិធីព្រហ្មទណ្ឌកម្ពុជា៖

- ទិដ្ឋភាពនេះ មានច្រើននៅដំណាក់កាលជំនុំជម្រះ វាមានលក្ខណៈខំមិនឡ (Common Law) និងទទួលឥទ្ធិពលពីស្តង់ដារសិទ្ធិមនុស្សអន្តរជាតិ។
- នីតិវិធីចំពោះមុខ(តទល់) មាត្រា៣០១ ដល់មាត្រា៤៤៦៖ នៅពេលដំណាក់កាល ចៅក្រមជំនុំជម្រះ អយ្យការ និងភាគីការពារក្តីបង្ហាញហេតុផល ពិនិត្យសាក្សី និងតតាំងលើកស្តុតាង។ ចៅក្រមគឺជាអាជ្ញាកណ្តាលអព្យាក្រឹត្យ ហើយបន្ទុកកស្តុតាងជាបន្ទុករបស់អយ្យការ។
- ការសន្មត់ថាគ្មានទោស៖ មាត្រា៣៨ នៃរដ្ឋធម្មនុញ្ញ និងមាត្រា៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ តម្រូវថា ជនជាប់ចោទត្រូវសន្មតថាគ្មានទោស រហូតដល់មានការសម្រេចថាមានទោស(ជាស្ថាពរ)។ ចំណុចនេះ មាននៅក្នុងប្រព័ន្ធបែបអង់ក្លូ-អាមេរិកាំង។
- សិទ្ធិមានមេធាវីនិងសវនាការសាធារណៈ៖ មាត្រា៣២១-មាត្រា៣៤៦ ជានាសិទ្ធិរបស់អ្នកការពារផ្លូវច្បាប់ និងសវនាការសាធារណៈ។ មេធាវីការពារក្តី អាចលើកអំពីបញ្ហានៃកស្តុតាង និងស្នើហៅសាក្សី ដែលជាលក្ខណៈនៃនីតិវិធីតទល់។[៥៣០]

១.៣. ទិដ្ឋភាពពិសេសនៃក្របខណ្ឌច្បាប់ និងយុត្តិសាស្ត្រនៃ អ.វ.ត.ក.

- អ.វ.ត.ក. ត្រូវបានបង្កើតឡើងដោយច្បាប់ឆ្នាំ២០០១ និងវិសោធនកម្មនៅឆ្នាំ២០០៤[៥៣១]។ ច្បាប់នេះអនុញ្ញាតឱ្យអង្គជំនុំជម្រះបង្កើតវិធានផ្ទៃក្នុងសម្រាប់ដំណើរការដំណើរការក្តីរបស់ខ្លួន[៥៣២] និងស្វែងរកការបំភ្លឺពីបញ្ហាត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌកម្ពុជា និងពីការអនុវត្តនៅតុលាការព្រហ្មទណ្ឌអន្តរជាតិនានា។
- ដោយសារតុលាការព្រហ្មទណ្ឌអន្តរជាតិ មានឥទ្ធិពលបែបខំមិនឡ (Common Law) ដូច្នេះ យុត្តិសាស្ត្រជាច្រើនរបស់ អ.វ.ត.ក. ក៏ទទួលឥទ្ធិ

[529] Langer, M. (2004). The Rise of the Adversary System in International Criminal Law. UCLA Law Review.
[530] Armenta-Deu, T. (2016). Beyond Accusatorial or Inquisitorial Systems: A Matter of Deliberation and Balance។
[531] Microsoft Word - KR Law as amended 27 Oct 2004 Kh _Combination_.doc
[532] Internal Rules - KH.pdf

ពលបែបខំមិនឡ (Common Law) មួយចំនួនដែរ។ ជាពិសេស នៅជំណាក់កាលជំនុំជម្រះក្តី។ យុត្តិសាស្ត្រទាំងនេះ ផ្តោតទាំងបញ្ហាសារធាតុ និងបញ្ហានីតិវិធី។ សូមមើលសេចក្តីពន្យល់នៃក្រមនីតិវិធីព្រហ្មទណ្ឌ (សេចក្តីពន្យល់ចំពោះករណីយុត្តិសាស្ត្រ អ.វ.ត.ក. និងអន្តរជាតិសម្រាំង)[៥៣៣] និងសៀវភៅអំពីយុត្តិសាស្ត្រ - អ.វ.ត.ក.[៥៣៤]។

- ថ្វីបើ អ.វ.ត.ក. ជាតុលាការពិសេស និងមានវិធានពិសេស ប៉ុន្តែ វិធាន យុត្តិសាស្ត្រ របៀបរបបការងារ រួមទាំងការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងឯកសារ មានចំណុចជាច្រើនដែលអាចស្រង់យកមកជាគម្រូក្នុងការអនុវត្តនៅថ្នាក់ជាតិ។

១.៤. សន្និដ្ឋាន និងជម្រើសសម្រាប់កម្ពុជា

- ដូច្នេះនីតិវិធីព្រហ្មទណ្ឌកម្ពុជា គឺជាប្រព័ន្ធបែបស៊ើបអង្កេតផង និងមានលក្ខណៈបែបចោទប្រកាន់ខ្លាំងនៅជំណាក់កាលជំនុំជម្រះ ជាពិសេសផ្តល់សិទ្ធិខ្លាំងដល់ភាគីក្នុងការការពារសិទ្ធិ ។ ទោះជាយ៉ាងណាក៏ដោយចំណុចមួយចំនួនដែលត្រូវពិនិត្យឡើងវិញដូចជា ការចូលសន្ធនា និងការអមកូនក្តីនៅពេលឃាត់ខ្លួនត្រូវមានចាប់ពីពេលដំបូងនៃការឃាត់ខ្លួន ត្រូវចាត់ទុកថាភាគីបានចូលការពារខ្លួនកាលណាបានប្តឹងទាស់ និងមានមេធាវីបានចូលការពារនៅពេលសវនាការ ជាដើម។ ក្រមព្រហ្មទណ្ឌកម្ពុជាបានយកគម្រូក្រមនីតិវិធីបារាំង ប៉ុន្តែមិនបានយកចំណុចជាច្រើនដែលបារាំងបានកែប្រែចាប់ពីឆ្នាំ២០០០មកបញ្ចូលទេ ជាអាទ៍ ច្បាប់បារាំង១៥ មិថុនា ២០០០ បានពង្រឹងការការពារការសន្មតជាមុនថាគ្មានទោស និងសិទ្ធិរបស់ជនរងគ្រោះ (La loi n° 2000-516 du 15 juin 2000 renforçant la protection de la présomption d'innocence et les droits des victimes) ។ ច្បាប់បារាំងបានធ្វើការកែប្រែជាច្រើនដើម្បីឱ្យនីតិវិធីព្រហ្មទណ្ឌបារាំងកាន់តែប្រសើរឡើង (សូមមើលអត្ថបទ Les 20 ans de la loi du 15 juin 2000 : la genèse de l'article préliminaire du Code de procédure pénale | Lexbase)

[៥៣៣] បោះពុម្ពលើកទី១ ខែមិនា ឆ្នាំ២០១៤។

[534] http://eccc.gov.kh/about/jurisprudence

- ដើម្បីឱ្យកាន់តែមានប្រសិទ្ធិភាពខ្លាំង គួរពិចារណាស្រង់យកការអនុវត្តល្អៗ ជាអន្តរជាតិ មកអនុវត្ត រួមទាំងការអនុវត្តល្អនានា និងយុត្តិសាស្ត្ររបស់ អ.វ.ត.ក. (យុត្តិសាស្ត្រ - អ.វ.ត.ក.) ផងដែរ ដែលកម្ពុជានៅមានធនធានមនុស្សដែលបានអនុវត្តនិងយល់ដឹងអំពីបញ្ហាទាំងនេះ។ សំណុំឯកសាររបស់ អ.វ.ត.ក. អាចរកបានដោយសេរីនៅ បណ្ណសារ - អ.វ.ត.ក (https://archive.eccc.gov.kh)។

គន្ថនិទ្ទេស

Langer, M. (2004). The Rise of the Adversary System in International Criminal Law. UCLA Law Review។

Armenta-Deu, T. (2016). Beyond Accusatorial or Inquisitorial Systems: A Matter of Deliberation and Balance។

Les 20 ans de la loi du 15 juin 2000 : la genèse de l'article préliminaire du Code de procédure pénale | Lexbase។

La loi n° 2000-516 du 15 juin 2000 renforçant la protection de la présomption d'innocence et les droits des victimes។

Microsoft Word - KR Law as amended 27 Oct 2004 Kh _Combination_.doc។

Internal Rules - KH.pdf។

បោះពុម្ពលើកទី១ ខែមិនា ឆ្នាំ២០១៤។

http://eccc.gov.kh/about/jurisprudence។

https://archive.eccc.gov.kh។

ជំពូកទី៤.
ការសិក្សាអំពីនីតិផ្សេងទៀត

ផ្នែកទី១. ប្រព័ន្ធនីតិកម្ពុជា

សិក្ខារំអពី «ការវិវត្តប្រព័ន្ធច្បាប់ទំនើបកម្ពុជា៖ ដំណើរវឌ្ឍន ភាពនៃការកសាងវប្បធម៌នីតិរដ្ឋ»

សាស្ត្រាចារ្យបណ្ឌិត ហោ ប៉ែង សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង

១.១. សេចក្តីផ្តើម

កម្ពុជាបច្ចុប្បន្នកំពុងឈានឡើងជារដ្ឋសុីវិល័យមួយនៅក្នុងក្របខណ្ឌតំបន់។ រដ្ឋស៊ីវិល័យគឺជារដ្ឋមានអរិយធម៌ខ្ពង់ខ្ពស់ មានការអភិវឌ្ឍរីកចម្រើនក្នុងគ្រប់វិស័យ ប្រកាន់វប្បធម៌នីតិរដ្ឋ ការគោរពច្បាប់ ស្របគ្នានឹងការបន្តរក្សាប្រតិបត្តិតាមទំនៀមទំលាប់ ប្រពៃណីថ្លៃថ្លារបស់សង្គមជាតិ។[៥៣៥] ស្របគ្នានេះ កម្ពុជាជាព្រះរាជាណាចក្រ ព្រះមហាក្សត្រទ្រង់ប្រតិបត្តិតាមរដ្ឋធម្មនុញ្ញ និងតាមលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងជារដ្ឋឯករាជ្យ អធិបតេយ្យ សន្តិភាព អព្យាក្រិត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ បើទោះបីជានៅមានបញ្ហាប្រឈមចំពោះមុខជាច្រើនទៀតក៏ដោយ។[៥៣៦]

រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៧នៃរដ្ឋសភា បានកំណត់ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល[៥៣៧] ដើម្បីរក្សាឲ្យមានប្រព័ន្ធច្បាប់ល្អ ធានារក្សាស្ថិរភាព និងចីរភាពនៃការកសាងរដ្ឋមួយដែលរឹងមាំ ឯករាជ្យ អធិបតេយ្យ ប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សមធម៌និងយុត្តិធម៌ក្នុងសង្គម វប្បធម៌ប្តុំប្តើងរុងរឿង និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សាររជឿនលឿន សុខុមាល

---

[៥៣៥] រដ្ឋខ្មែរសម័យអង្គដោរដ្ឋដែលមានអរិយធម៌ខ្ពង់ខ្ពស់ និងទទួលបានការីកចម្រើនលើគ្រប់វិស័យ ទាំងផ្លូវលោក និងផ្លូវធម៌។ កម្ពុជាបច្ចុប្បន្ន ឈានឡើងជាបណ្តើរៗនូវដំហានវឌ្ឍនភាព ស្របតាមចក្ខុវិស័យរបស់កម្ពុជា ឆ្នាំ២០៣០ និងឆ្នាំ២០៥០។ ម្យ៉ាងទៀត អរិយធម៌ខ្មែរសម័យអង្គរ បន្តរក្សាការពារ និងលើកកម្ពស់តម្លៃកម្ពុជាក្នុងក្របខណ្ឌពិភពលោក។ ក្នុងដំណើរការនៃការអភិវឌ្ឍប្រទេស សេដ្ឋកិច្ចសង្គមកម្ពុជាមានការីកចម្រើនជាបន្តបន្ទាប់ ប៉ុន្តែស្របគ្នានេះ វិបត្តិរីករាលដាលជម្ងឺឆ្លងកូវីដ១៩ (ឆ្នាំ ២០២០ ២០២២) និងសង្គ្រាមឈ្លានពានថៃលើបូរណភាពទឹកដីនៅដាយដែនកម្ពុជាថ្មីៗនេះ អាចក្លាយជាចំនុចប្រឈមមួយនៃការឈានទៅមុខ ឲ្យស្របតាមចក្ខុវិស័យរបស់កម្ពុជា នាពេលខាងមុខនេះផងដែរ។

[៥៣៦] មាត្រា១នៃរដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្នឆ្នាំ១៩៩៣ ប្រកាសធ្វើសមារណកម្មផ្អែកលើតម្លៃប្រវត្តិសាស្ត្រ និងតម្លៃសកល។

[៥៣៧] ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល (បោះពុម្ពផ្សាយ ខែមេសា ឆ្នាំ២០២៥) និងឯកសារផែនការសកម្មភាពឆ្នាំ២០២៥ ២០២៨ របស់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (២០២៥)។

ភាពពលរដ្ឋ នាយុគ្គសម័យបច្ចេកវិទ្យាទំនើប[៥៣៨] ដោយបង្កើតឲ្យមានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ បំពេញតួនាទីមុខងារ ជានិម្មាបនកររនៃប្រព័ន្ធច្បាប់ និងវប្បធម៌នីតិរដ្ឋ ផ្អែកតាមគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសកល។

នេះជាការគិតគូរដ៏ត្រឹមត្រូវ។ សង្គមមួយរឹងមាំត្រូវការមានប្រព័ន្ធច្បាប់ល្អ។ ប្រព័ន្ធច្បាប់ល្អ គឺជាគ្រឹះដ៏រឹងមាំសម្រាប់ការកសាងវប្បធម៌នីតិរដ្ឋ រក្សាការពារបានរបបប្រជាធិបតេយ្យសេរីពហុបក្ស របបសិទ្ធិមនុស្ស និងរបបសេដ្ឋកិច្ចទីផ្សារបានរឹងមាំ។ ប្រព័ន្ធច្បាប់ល្អផ្តល់ប្រយោជន៍ដល់ស្ថិរភាព សន្តិភាព សណ្តាប់ធ្នាប់ យុត្តិធម៌ ការអភិវឌ្ឍ កិច្ចការពារសិទ្ធិ និងសុខុមាលភាពរបស់ប្រជាពលរដ្ឋគ្រប់រូប និងប្រជាពលរដ្ឋមានជំនឿលើច្បាប់ ជឿលើថ្នាក់ដឹកនាំរដ្ឋ និងស្ថាប័នរដ្ឋគ្រប់លំដាប់ថ្នាក់។

ក្នុងអត្តបទស្រាវជ្រាវនេះ បានព្យាយាមពិនិត្យសិក្សាអំពីនិន្នាការវិវត្តប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្ន កំណត់អត្តសញ្ញាណ ក្របខណ្ឌទស្សនាទាន ដើម្បីចូលរួមដល់ដំណើរការកសាងវប្បធម៌នីតិរដ្ឋ។

១.២. សម័យបុរាណ និងកម្ពុជាសម័យទំនើប

ប្រទេសកម្ពុជាជារដ្ឋចំណាស់មួយនៅអាស៊ីអគ្នេយ៍។ រដ្ឋខ្មែរតំបូងបានកកើតឡើងនៅសតវត្សរ៍ទី១ មានឈ្មោះដើមជាអាណាចក្រភ្នំ (ហ្វូណាន់) សព្វថ្ងៃជាព្រះរាជាណាចក្រកម្ពុជា។ ព្រះបាទហ៊ុន ទៀន និងព្រះនាងលីវ យី ជាបុព្វវីរៈក្សត្រខ្មែរសម័យបូរាណ ដឹកនាំអាណាចក្រហ្វូណាន់ កសាងនិងការពារ និងពង្រីកអាណាចក្របន្តរាជពង្សាវតារឆ្លងកាត់ការផ្លាស់ប្តូរជាច្រើនសម័យកាល។[៥៣៩]

កម្ពុជារដ្ឋខ្មែរសម័យបូរាណ គឺជារដ្ឋមហាអំណាចធំមួយ មានឥទ្ធិពលក្នុងតំបន់លើគ្រប់វិស័យ (នយោបាយ សាសនា សេដ្ឋកិច្ច ច្បាប់ អរិយធម៌)។ អំណាចឥទ្ធិពល

[៥៣៨] បច្ចេកវិទ្យាទំនើបជាមុំយុទ្ធសាស្ត្រមួយ ក្នុងចំណោមមុំយុទ្ធសាស្ត្រទាំង៥ នៃផែនការយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាលអាណិត្តទី៧នៃរដ្ឋសភា ក្រោមការដឹកនាំរបស់សម្តេចធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។ មុំយុទ្ធសាស្ត្រទាំង៥រួមមាន មនុស្ស ទឹក ភ្លើង ផ្លូវ និងបច្ចេកវិទ្យាទំនើប។

[៥៣៩] អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (បោះពុម្ពឆ្នាំ១៩១៤, ប្រែសម្រួលភាសាខ្មែរបោះពុម្ព ឆ្នាំ២០០៥) និងសូមបន្តអានបន្ថែមស្នាអ្នកនិពន្ធជំនាន់ក្រោយៗ រួមមានជាអាទិ៍ David Chandler, A History of Cambodia (4th Edition, ២០០៨), បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក (២០១៩), បណ្ឌិតសាស្ត្រាចារ្យ ហោ ប៉េង នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប (២០២១) និង នីតិរដ្ឋធម្មនុញ្ញកម្ពុជា (២០២១) ជាដើម។

នយោបាយ មានការគ្រប់គ្រងរដ្ឋចំណុះជាច្រើននៅក្នុងតំបន់ និងមានទំនាក់ទំនងការទូតល្អជាមួយរដ្ឋធំៗ ឥណ្ឌា ចិនជាដើម។[៥៤០]

ព្រះមហាក្សត្រខ្មែរជាស្តេចផែនដីខ្លាំងពូកែក្នុងការធ្វើសឹកសង្គ្រាម មានទេពកោសល្យឆ្នើមដឹកនាំ នយោបាយគ្រប់គ្រងរដ្ឋ អាស្រ័យតាមព្រះធម៌ ឫក្បួនវេទតាមលទ្ធិព្រហ្មញ្ញសាសនា មានព្រះគ្រូជាព្រាហ្មពូកែក្នុងពិធីរាជកិច្ច មានសេនាបតីជាអ្នកមានវិជ្ជាខ្ពង់ខ្ពស់ និងមានកងទ័ពក្លាហានពូកែក្នុងសឹកសង្គ្រាម។ ជាក់ស្តែង រដ្ឋហ្វូណាន់ ចេនឡា អង្គរ មិនត្រឹមជារដ្ឋមហាណាចក្រ ប៉ុន្តែជារដ្ឋរបស់អាទិទេពនៃជំនឿសាសនានៅក្នុងតំបន់។ រដ្ឋខ្មែរបូរាណ មានអ្នកចេះដឹងច្រើន ទាំងផ្លូវលោក និងផ្លូវធម៌។ ប្រជារាស្ត្រខ្មែរជឿលើសាសនា ជឿលើអង្គព្រះមហាក្សត្រ ទុកជាទីសក្ការៈ។[៥៤១] ជាក់ស្តែង រដ្ឋធម្មនុញ្ញកម្ពុជាបច្ចុប្បន្ន បានប្រកាសថា រដ្ឋខ្មែរបូរាណ ធ្លាប់មានអារ្យធម៌ឧត្តុង្គឧត្តម ប្រទេសជាតិស្តុកស្តម្ភធំទូលាយ ប្តុំប្តើងរុងរឿង កិត្យានុភាពខ្ពង់ខ្ពស់ ភ្លឺចែងចាំងដូចពេជ្រពណ្ណរាយ។

ប៉ុន្តែកម្ពុជាក្រោយសម័យអង្គរបានក្លាយជារដ្ឋតូច បានធ្លាក់ចុះទន់ខ្សោយ។ ជារដ្ឋរងគ្រោះដោយសង្គ្រាមឈ្លានពានវាទទីពីប្រទេសជិតខាង និងក្លាយជារដ្ឋអាណានិគមនិយមបារាំងនៅចុងសតវត្សន៍ទី១៩។ កម្ពុជាបានទទួលយកគំនិតប្រព័ន្ធច្បាប់ស៊ីវិលបែបបារាំង ប៉ុន្តែការអភិវឌ្ឍប្រព័ន្ធច្បាប់នាសម័យនោះ មិនបានពេញលេញនោះទេ រចនាសម្ព័ន្ធសង្គមនៅបន្តរក្សាបែបសក្តិភូមិ។ ក្រោយចប់សង្គ្រាមលោកលើទី២ ដោយគិតពីឆ្នាំ ១៩៤៧ មកដល់ឆ្នាំ១៩៩៣ សម័យឯករាជ្យផង សង្គ្រាមផង គឺជារយៈពេលនៃការសាកល្បងមនោគមន៍វិជ្ជានយោបាយ (សម័យសង្គ្រាមត្រជាក់) និងការសើរើធ្វើបដិវត្តនសង្គមនយោបាយ និងមិនមានការវិវត្តរីកចម្រើនរឹងមាំក្នុងវិស័យច្បាប់ និងយុត្តិធម៌ទេ ទើបតែក្នុងរយៈពេល៣២ឆ្នាំចុងក្រោយនេះ ដែលប្រព័ន្ធច្បាប់ជាតិ ត្រូវបានរៀបចំការអភិវឌ្ឍ និងវិវត្តជាបន្តបន្ទាប់ ពេញលេញ ក្នុងនោះមានជាអាទិ៍ ច្បាប់ក្រមសាវន្ត ច្បាប់ក្រមនីតិវិធី ច្បាប់អង្គការ ច្បាប់ផ្តល់សច្ចាប័នលើលិខិតូបករណ៍អន្តរជាតិ ដែលពាក់ពន្ធ័កិច្ចការអំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ ប្រព្រឹត្តទៅស្របតាម

[៥៤០] ប្រវត្តិសាស្ត្រកម្ពុជា ជាកម្មវិធីសិក្សាថ្នាក់ទី៤ និងថ្នាក់ទី៦ របស់ក្រសួងអប់រំ យុវជន និងកីឡា (បោះពុម្ពផ្សព្វផ្សាយ ឆ្នាំ ២០២៥)។ សៀវភៅសិក្សានេះ បានរៀបរាប់ និងវិភាគលើចំនុចសំខាន់ៗ នៃដំណើរដ្ឋខ្មែរបូរាណនិងសម័យទំនើប។

[៥៤១] ហង់ជួន ណារ៉ុន ប្រវត្តិសាស្ត្រប្រទេសកម្ពុជា ក្នុងបរិបទសកលលោក។ ទស្សនាទាននេះក៏មានលើកនៅក្នុងកម្មវិធីសិក្សាប្រវត្តិសាស្ត្រថ្នាក់ទី៤ និងថ្នាក់ទី៦ ដែលទើបចេញថ្មីរបស់ក្រសួងអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា២០២៥។

ស្មារតី និងគោលការណ៍កំណត់ដោយរដ្ឋធម្មនុញ្ញ និងក្របខណ្ឌកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ជាបន្តបន្ទាប់ដល់បច្ចុប្បន្ន។

ប្រព័ន្ធច្បាប់កម្ពុជាបច្ចុប្បន្នមានលំនាំតាមប្រព័ន្ធច្បាប់ស៊ីវិល។ ទោះបីជាការវិវត្តប្រព័ន្ធច្បាប់កម្ពុជា ក្នុងដំណាក់ការ៣២ឆ្នាំចុងក្រោយនេះ មានការជួយជ្រុំជ្រែងពីដៃគូរអភិវឌ្ឍនានា និងបាននាំមកនូវផ្នត់គំនិត ទ្រឹស្តី យន្តការ នីតិវិធីថ្មីៗ មានភាពចម្រុះក៏ពិតមែន ប៉ុន្តែនិន្នាការវិវត្តទូទៅនៃប្រព័ន្ធច្បាប់ខ្មែរបច្ចុប្បន្ន បានបង្កើតជាអត្តសញ្ញាណខ្មែរ ជាប្រព័ន្ធច្បាប់កម្ពុជាទំនើប មានភាពជឿនលឿន និងទន់ភ្លន់ ដោយយកតាមលំនាំប្រព័ន្ធច្បាប់ស៊ីវិល ផ្អែកលើតម្លៃប្រវត្តិសាស្ត្រ និងតម្លៃសកល។

យន្តការផ្លាស់ប្តូរថ្មីនេះ បន្តរីកចម្រើននៅក្នុងដំណើរការនីតិវិធីធ្វើច្បាប់ ការអនុវត្តច្បាប់ ការជម្រះក្តី និងសាលាវិជ្ជាជីវៈច្បាប់ ស្របតាមបទដ្ឋានសណ្តាប់ធ្នាប់គតិយុត្ត គោលការណ៍បែងចែកអំណាចនិងគោលការណ៍នៃភាពជាក់លាក់គតិយុត្តិ[៥៤២] ដែលជាគោលការណ៍គ្រឹះនៅក្នុងប្រព័ន្ធច្បាប់ស៊ីវិល។ ប្រព័ន្ធច្បាប់កម្ពុជាទំនើបនេះ បាននិងកំពង់វិវត្តជាជំហានៗ តបតាមបរិបទជាក់ស្តែងរបស់សង្គមកម្ពុជា និងធានាបានប្រក្រតីភាពប្រព័ន្ធនយោបាយ ប្រព័ន្ធសេដ្ឋកិច្ច និងប្រព័ន្ធយុត្តិធម៌សង្គម ឈានឡើងជាជំហានៗ។ ជាក់ស្តែង ច្បាប់អនុម័ត និងសន្និសញ្ញាអនុសញ្ញា និងកិច្ចព្រមព្រៀងអន្តរជាតិនានា ជាច្រើនត្រូវបានអនុម័ត និងផ្តល់សច្ចាប័ន ដោយប្រកាសជាក់ឲ្យប្រើប្រាស់ដើម្បីឆ្លើយតបតាមតម្រូវការរីកចម្រើនរបស់សង្គមជាតិ និងការពារកិច្ចលើកិច្ចសហប្រតិបត្តិការអន្តរជាតិ។

១.៣. សង្គម និងការអភិវឌ្ឍច្បាប់ជាតិ

សុខុដុមនីយកម្មរវាងតម្លៃប្រវត្តិសាស្ត្រ និងតម្លៃសកលនៅក្នុងប្រព័ន្ធច្បាប់ទំនើបមានតួនាទីយ៉ាងសំខាន់ និងផ្តល់ប្រសិទ្ធិភាពក្នុងការកសាងវប្បធម៌នីតិរដ្ឋប្រកបដោយចីរភាពនៅកម្ពុជា។ តម្លៃប្រវត្តិសាស្ត្រកម្ពុជា (ជាតិ សាសនា ព្រះមហាក្សត្រ) ត្រូវបានរក្សា

---

[៥៤២] ប្រព័ន្ធច្បាប់នៅក្នុងពិភពលោកបច្ចុប្បន្ននេះ មានប្រព័ន្ធធំៗ២ ក្នុងនោះគឺប្រព័ន្ធច្បាប់ស៊ីវិល និងប្រព័ន្ធច្បាប់ខំមិនឡ។ ប្រព័ន្ធច្បាប់ស៊ីវិល (Civil Law System or Romano-Germanic Legal System) បានវិវត្តចេញពីច្បាប់រ៉ូម៉ាំងបូរាណ និងបន្តរៀបចំអភិវឌ្ឍបានពេញលេញនៅសតវត្សន៍ទី១៨ ដោយអ្នកប្រាជ្ញច្បាប់ធំៗរបស់អាឡឺម៉ង ចងក្រងជាច្បាប់ក្រមសរសេរជាក់លាក់ និងអនុម័តដាក់ឲ្យប្រើប្រាស់ជាផ្លូវការ (codification) ដោយអនុលោមតាមគោលការ ណ៍សំខាន់ៗ រួមមានគោលការណ៍សណ្តាប់ធ្នាប់គតិយុត្ត (theory of positive law baseupon principle of public order) គោលការណ៍បែងចែកអំណាច (principle of separation of powers) និងគោលការណ៍នៃភាពជាក់លាក់គតិយុត្ត (principle of legal cerntainty)។ បច្ចុប្បន្នប្រព័ន្ធច្បាប់ស៊ីវិលនេះ គឺជាប្រព័ន្ធច្បាប់ទំនើបមួយ ដែលត្រូវបានប្រទេសជាច្រើន រៀបចំអភិវឌ្ឍប្រើប្រាស់យ៉ាងទំលំទូលាយបំផុត ក្នុងនោះរួមទាំងប្រទេសកម្ពុជាផង។

បន្ត ជាបាវចនាផ្លូវការរបស់ជាតិកំណត់ដោយរដ្ឋធម្មនុញ្ញបច្ចុប្បន្ន។ ជាតិមានន័យទំលំទូលាយជាប្រលឹងរួមរបស់សង្គមខ្មែរ កំណត់ឲ្យរដ្ឋ មានករណីកិច្ចត្រូវកសាង អភិវឌ្ឍ និងរក្សាការពារ គង់វង្សជានិច្ចនិរន្តរ៍។ ជាតិជាគុណតម្លៃ ដ៏ថ្លៃថ្លារិសេសវិសាលរបស់សង្គមទាំងមូល មានតម្លៃជារូបីផង និងអរូបីផង ក្នុងនោះរួមមានជាអាទិ ភូមិសាស្ត្រទឹកដី ប្រជារាស្ត្រខ្មែរ អង្គការរដ្ឋ វប្បធម៌សីល្បៈប្រពៃណីទំនៀមទម្លាប់ ម្ហូបអាហារ ផ្ទះសំបែង ប្រាង្គប្រសាទ និងវត្ថុបូរាណជាដើម ដែលគុណតម្លៃទាំងអស់នេះ ជាធាតុផ្សំដ៏សំខាន់នៃដំណើរការរដ្ឋ កំណត់លើនិរន្តរភាពស្ថាប័នជាតិ និងភាពសុខុដុមនីយកម្មរបស់សង្គម។[៥៨៣]

ម្យ៉ាងទៀត ប្រជារាស្ត្រខ្មែរមានចរឹកស្លូតបូត ទៀងត្រង់ ប្រកបដោយស្មារតីមិត្តភាព សាមគ្គីភាព ងាយនឹងទទួលយកការសម្របខ្លួន ដោយប្រកាន់តាមធម៌ព្រះពុទ្ធសាសនា (សីល សមាធិ បញ្ញា) ដឹងខុសដឹងត្រូវ និងមានសេចក្តីព្យាយាមខ្ពស់ក្នុងការសិក្សា ធ្វើការងារ និងប្រកបមុខរបរ។ ភាពជាវិជ្ជមានរបស់ប្រជារាស្ត្រខ្មែរ បានចូលរួមគាំពារដល់ការគោរពច្បាប់ និងការកសាងវប្បធម៌នីតិរដ្ឋ។

រដ្ឋនិងសាសនាជាផ្លូវជំនឿរបស់ប្រជារាស្ត្រខ្មែរ។ ក្នុងផ្នត់ជំនឿដើមរបស់ខ្មែរ អង្គព្រះមហាក្ស ទ្រង់ជាតួអង្គដ៏ពិសេដ្ឋ តំណាងឲ្យរដ្ឋ តំណាងឲ្យជាតិ តំណាងឲ្យសាសនា តំណាងឲ្យអទិទេព តំណាងឲ្យប្រជារាស្ត្រ។ ជារួម ព្រះអង្គជាតំណាងឲ្យសភាវៈល្អរបស់សង្គម មានភារកិច្ចជាអ្នកកសាងការពារជាតិ និងសាសនា ព្រះអង្គគឺជានិមិត្តរូបស្ថិរភាពសន្តិភាព និងភាពសុខុដុមនីយកម្មរបស់សង្គមខ្មែរ។ ម្យ៉ាងវិញទៀត នៅក្នុងសម័យទំនើបកម្ពុជាបច្ចុប្បន្ន លទ្ធិប្រជាធិបតេយ្យ និងតួអង្គនាយករដ្ឋមន្ត្រី កំពុងដើរតួនាទីសំខាន់ ក្នុងដំណើរការដឹកនាំ កសាង ការពារ និងពង្រឹងសុខុដុមនីយកម្មសង្គម។

តម្លៃសកល (ប្រជាធិបតេយ្យ សិទ្ធិមនុស្ស នីតិរដ្ឋ) ក្នុងនោះរួមមាន អធិបតេយ្យ ឯករាជ្យ សន្តិភាព អព្យាក្រឹត្យ អចិន្ត្រៃយ៍ មិនចូលបក្សសម្ព័ន្ធ ប្រជាធិបតេយ្យសេរីពហុបក្ស គោរពសិទ្ធិសេរីភាព និងសេចក្តីថ្លៃថ្នូររបស់មនុស្ស សមធម៌និងយុត្តិធម៌ក្នុងសង្គម វប្បធម៌ប្តុំប្តើងរុងរឿង និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារជឿនលឿន សុខុមាលភាពពលរដ្ឋ នាយុគ្គសម័យបច្ចេកវិទ្យាទំនើប តម្លៃសកលទាំងអស់នេះ បានប្រែក្លាយជាតម្លៃរួមរបស់ជាតិ (អរូបី) ផ្សារភ្ជាប់ជាមួយតម្លៃប្រវត្តិសាស្ត្រ។

[៥៨៣] បណ្ឌិតសាស្ត្រាចារ្យ ហោ ប៉ែង នីតិរដ្ឋធម្មនុញ្ញកម្ពុជា (២០២១, ទំព័រទី៣ ដល់ ទី៦)។

១.៤. ក្របខណ្ឌកែទម្រង់ និងភាពសុខុដុមនីយកម្ម

៤.១. ក្របខណ្ឌកែទម្រង់ជួយឲ្យសង្គមរីកចម្រើនកាន់តែរឹងមាំ ពីព្រោះជាយុទ្ធសាស្ត្រដោះស្រាយបញ្ហាប្រឈមនានារបស់សង្គមស៊ីវិល័យ។ ការរៀបចំកសាងវប្បធម៌នីតិរដ្ឋ (តម្លៃសកល) ផ្អែកតាមឫសគល់របស់សង្គម (តម្លៃប្រវត្តិសាស្ត្រ) ធានាបាននូវសុខុដុមនីយកម្មសង្គម ស្ថិរភាព សន្តិភាពយូរអង្វែង។ នៅក្នុងប្រព័ន្ធច្បាប់ទំនើបកម្ពុជាបច្ចុប្បន្ន រដ្ឋធ្វើសមាហរណកម្មស្មារតីតម្លៃទាំង២នេះ ក្នុងឫទ្ធិរដ្ឋធម្មនុញ្ញ និងច្បាប់នានា ដោយអនុលោមតាមគោលការណ៍សណ្តាប់គតិយុត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល ស្របតាមស្ថានភាពជាក់ស្តែងរបស់សង្គម និងការយល់ដឹងរបស់ប្រជារាស្ត្រ។

៤.២. វិស័យច្បាប់ នយោបាយ និងសេដ្ឋកិច្ច ជាមូលដ្ឋានគ្រឹះនៃភាពរឹងមាំរបស់សង្គមស៊ីវិល័យ គឺវិស័យធំទាំង៣នេះ ត្រូវមានស្ថិរភាព និងរីកធំធាត់ជានិច្ចនិរន្តរ៍ និងមានទំនាក់ទំនងគ្នាយ៉ាងស្អិតរមួត មិនអាចបំបែកគ្នាបានទេ គឺប្រៀបបានជាសរសេរស្តេម្តទ្រទ្រង់ដល់សង្គមឲ្យដំណើរការបានទៅរលូន។ ឧទាហរណ៍ជាក់ស្តែង ប្រជាធិបតេយ្យនិងសេដ្ឋកិច្ចទីផ្សារត្រូវស្ថិតក្រោមគោលការណ៍ នីតិរដ្ឋ ពោលគឺក្រោមក្របខណ្ឌច្បាប់កំណត់ពីព្រោះក្នុងសង្គមនីតិរដ្ឋ ច្បាប់ផ្តល់កិច្ចការពារ គាំពារ និងលើកតម្កើង តម្លៃនយោបាយប្រជាធិបតេយ្យ ដែលជាតម្លៃស្នូលនៃកម្មវិធីនយោបាយរបស់រដ្ឋ និងកម្មសិទ្ធិឯកជនជាតម្លៃស្នូលនៃសេដ្ឋកិច្ចទីផ្សារ។ សេដ្ឋកិច្ចទីផ្សារជាលំហូរចរន្តឈាមចិញ្ចឹមបំប៉នប្រជាធិបតេយ្យ និងនីតិរដ្ឋឲ្យកាន់តែរឹងមាំបិតថែរ។ កម្មវិធីនយោបាយ កំណត់ចេញនូវក្របខណ្ឌសេដ្ឋកិច្ចទីផ្សារ និងក្របខណ្ឌកែទម្រង់ច្បាប់ និងយុត្តិធម៌ តាមការចាំបាច់របស់សង្គម។

៤.៣. កន្លងទៅ នៅក្នុងយន្តការអនុវត្តច្បាប់ កម្ពុជាបានប្រកាន់យកភាពបត់ប៉ែននិយម (ទន់ភ្លន់ខ្លះ រឹងត្អឹងខ្លះ) ស្របតាមនិន្នាការវិវត្តជាក់ជាក់ស្តែងរបស់សង្គមជាតិ ជាពិសេសនៅក្នុងការអនុវត្តច្បាប់ចរាចរណ៍ផ្លូវគោក ច្បាប់បង់ពន្ធ និងច្បាប់ប្រឆាំងអំពើពុករលួយ។ ដោយឡែកក្នុងដំណើរការដោះស្រាយវិវាទក្តីរដ្ឋប្បវេណី មានយន្តការប្រពៃណី (ផ្សះផ្សារ) និងយន្តការទំនើប (តុលាការ)។

ក្របខណ្ឌយុទ្ធសាស្ត្រនេះ ជាជំរើសល្អបំផុតសម្រាប់សង្គមខ្មែរ ក្បិតម្ខាងត្រូវការពេលវេលាដើម្បីផ្សព្វផ្សាយអប់រំលើកកម្ពស់ការយល់ដឹង និងការចូលរួមរបស់ប្រជារាស្ត្រ និងម្ខាងទៀត ត្រូវការពេលវេលារៀបចំកសាងសមត្ថភាពធនធានមន្ត្រីល្អ មន្ត្រីជំនាញ និងពង្រឹងពង្រីកភាពជាម្ចាស់នៃស្ថាប័នអនុវត្តច្បាប់ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងវិស័យច្បាប់និងយុត្តិធម៌។

៤.៤. ការបន្តការកសាងសមត្ថភាពស្ថាប័នអនុវត្តច្បាប់ នឹងជួយជំរុញបន្ថែមដល់ប្រសិទ្ធិភាពនៃការអនុវត្តច្បាប់កាន់តែល្អ។ ការរៀបចំកសាងធនធានមន្ត្រីក្នុងស្ថាប័នជំនាញជាមុំយុទ្ធសាស្ត្រទី១ នៅក្នុងផែនយុទ្ធសាស្ត្របញ្ចកោណរបស់រាជរដ្ឋាភិបាល អាណិត្តទី៧ នៃរដ្ឋសភា។ ការលើកស្ទួយវិស័យអប់រំធ្វើឲ្យខ្មែរខ្លាំង។[៥៤៤] ការអប់រំ និងផ្សព្វផ្សាយ ផ្នាល់ក្តី អនឡាញ់ក្តី ក្នុងប្រព័ន្ធក្តី ក្រៅប្រព័ន្ធក្តី គឺជាយុទ្ធសាស្ត្រចាំបាច់ និងគ្រប់ជ្រុងជ្រួយ ដើម្បីបង្កើតឡើងនូវស្មារតីគោរពច្បាប់។

[៥៤៤] បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ប្រវត្តិសាស្ត្រកម្ពុជា ក្នុងបរិបទសកលលោក (២០១៩) ទំព័រ៥១ ដល់៦៤។

១.៥. សេចក្តីសន្និដ្ឋាន

ប្រព័ន្ធច្បាប់កម្ពុជា ជាប្រព័ន្ធច្បាប់ទំនើបយកលំនាំតាមប្រព័ន្ធច្បាប់ស៊ីវិល។ ប្រព័ន្ធនេះកំពុងវិវត្តខ្លួនស្របតាមស្មារតីសមាហរណកម្មរវាងតម្លៃប្រវត្តិសាស្ត្ររបស់ខ្លួន និងតម្លៃសកលដែលបានទទួលយក ទោះបីជាមានបញ្ហាប្រឈមជាច្រើនក៏ដោយ។ ការវិវត្តប្រព័ន្ធច្បាប់ទំនើបកម្ពុជានេះ បង្កើតបានជាអត្តសញ្ញាណជាតិ ក្នុងយុគ្គសម័យទំនើបភាវូបណីកម្មកម្ពុជា និងធានាការពារបាននូវស្ថិរភាព សន្តិភាព និងយុត្តិសង្គមរឹងមាំមួយ។ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងផែនការសកម្មភាពនានា គឺជាយន្តការនិងក្របខ័ណ្ឌដំណោះស្រាយមួយដ៏ល្អ នឹងបង្កើតឲ្យមានមន្ត្រីល្អ ពលរដ្ឋល្អ និងប្រព័ន្ធច្បាប់ល្អ បម្រើឲ្យការរីកចម្រើនក្នុងសង្គមស៊ីវិល័យ។

គន្ថនិទ្ទេស

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់អនុម័តនានាដែលពាក់ព័ន្ធ។

ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល (មេសា ២០២៥)។

ផែនការសកម្មភាព ឆ្នាំ២០២៥ ២០២៨ របស់អគ្គលេខាធិការគណៈកម្មាធិការកែទម្រង់ច្បាប់ (មិថុនា ២០២៥)។

អាដេម៉ារ ឡឺក្លែរ ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (១៩១៧) បកប្រែជាភាសាខ្មែរ (២០០៥)។

ហង់ជួន ណារ៉ុន ប្រវត្តិសាស្ត្រប្រទេសកម្ពុជា (២០០៥)

ហោ ប៉ែង នីតិរដ្ឋធម្មនុញ្ញប្រៀបធៀប ទម្រង់ទ្រឹស្តីរដ្ឋធម្មនុញ្ញទំនើប (២០២១)

ហោ ប៉ែង នីតិរដ្ឋធម្មនុញ្ញកម្ពុជា តម្លៃធម្មនុញ្ញប្រពៃណី និងទំនើប (២០២១)។

PART II. SUPREMACY OF INTERNATIONAL LAW

QUESTION OF SUPREMACY OF INTERNATIONAL LAW: IN THE CONTEXT OF CAMBODIA'S LEGAL SYSTEM

ឯកឧត្តម ស៊ុន សួន សាស្ត្រាចារ្យនីតិសាស្ត្រ នៃសាកលវិទ្យាល័យអន្តរជាតិ ផារ៉ាហ្គន និង
ជាអតីតតំណាងអចិន្ត្រៃយ៍កម្ពុជាប្រចាំអង្គការសហប្រជាជាតិ

2.1. ABSTRACT

The paper is intentionally limited in its scope and content. Its purpose is to examine some of most essential aspects on the question of supremacy of law. In essence it sheds light on the issues of the relationship between international law and national law in a context of the Cambodian legal system. The discussion focuses on the question of supremacy of law, the normative applicability of international law into domestic legal orders involving theoretical and practical debates (Monism vs. Dualism) and practical mechanisms, with monism seeing them as one system (automatic incorporation) and dualism as separate (requiring transformation).

For this purpose, the paper analyses the spirit of the constitution in its key provisions that reflect the country 's foreign policy objectives as well as practical experience from some cases of other countries, with a focus on EU and ASEAN concerning the question of legal supremacy, their country's normative application of international law into the national law system and other legal orders solutions.

At the end, the paper comes to a conclusion with a number of recommendations regarding the practical approaches on the mix option for a country solution with respect to the normative applicability for Cambodia. The ultimate goal of the paper is to contribute to the current work of the Cambodia's Legal Reform Committee (LRC) to further archive its works ahead for strengthening the effectiveness of country's legal system and its completed integrity toward the next 25 years in compliance with the current relevant Strategic Frameworks of the Royal Government of Cambodia.

2.2. A BRIEF OVERVIEW OF CAMBODIA'S LEGAL SYSTEM: RECENT DEVELOPMENTS AND CHALLENGES

Over the past 3 decades, following the signing of Paris Peace Agreements and afterward with the departure of United Nations Transitional Authority in Cambodia (UNTAC), a new Constitution of 1993 was adopted with the restoration of the second Kingdom of Cambodia.

Since then, Cambodia has undergone a multi-phase of transformation, progressing from initial rehabilitation and reconstruction toward sustained

economic growth, social development, and the preservation of peace and stability following the political achievement of the government Win-Win policy in 1998. The Royal Government has then gone further through steady progress and achievement toward its overall goals and strategic policy programs and frameworks— (such the Triangular and Rectangular Strategic frameworks).

It is worth noting that at present further progress has been made toward sustained economic growth and development with an ongoing focus on infrastructure and modernization, among others. In line with that, the promotion of the rule of law through a comprehensive legal and judicial reform remains prioritized in the Government's agenda as one of core program frameworks. In this connection, further achievements were notable in the related areas of legal and judiciary domains, including the drafting of approximately 623 laws across various sectors.[545]Much of this progress has been made possible partly through the foreign assistance from all friendly countries and international agencies at a variety of legal and judiciary sectors.

Through the overall reform process, Cambodia legal and judiciary system is now evolving to another stage of development. Under the new dynamic and visionary leadership of Samdech Thipadei HUN Manet, Prime Minister of the Kingdom of Cambodia, the continued promotion and strengthening of respect for the rule of law, human rights, dignity, and liberal multi-party democracy remains a core priority during its 7th term of the legislature.[546]

Toward these goals, the Pentagonal Strategy-Phase I for Growth, Employment, Equity, Efficiency and Sustainability was therefore launched and adopted this year at the recent meeting presided over by the Prime Minister.[547] One of the main goals of that agenda is a strategic policy of reform aimed at further advancing the related legal and judiciary system through the enhancement of its integrity and effectiveness of law implementation. [548]

---

[545] See**,** Cambodia Launches Strategic Framework for Legal Reform Programme, See. The Strategic Framework of the Royal Government 's Legal Reform, April 2025, p. 15

[546] See, Id. ,p. 7, See also, Khmer Times 10 July 2025, https://www.khmertimeskh.com/501715188/cambodia-launches-strategic-framework-for-legal-reform-programme/

[547] See, The Pentagonal Strategy-Phase I For Growth, Employment, Equity, Efficiency and Sustainability: Building the Foundation Towards Realizing the Cambodia Vision 2050, page 7- 18, Available at : https://www.mfaic.gov.kh/files/uploads/1XK1LW4MCTK9/EN%20PENTAGONAL%20STRATEGY%20-%20PHASE%20I.pdf

[548] Khmer Times , July 10, 2025, https://www.khmertimeskh.com/501715188/cambodia- launches-strategic-framework-for-legal-reform-programme/ last 01 December 2025,

In fact, the reform of legal system is one of core components of overall reform of the RGC; and it is a long-term effort that has been prioritized in the past through the Committee of Legal and Judiciary Reform that officially started its works since 2003. [549] Now it was restructured and adopted for further implementation through new national strategies programs, especially under the Pentagonal Strategic Framework- phase I. It is one of key components of public administration and good governance reforms.[550]

In line with the restructuring of two distinct bodies (Legal Reform Committee—LRC and Judiciary Committee), the Royal Government introduced "The Strategic Framework of the Royal Government's Legal Reform Program". This Strategic Framework was launched on 10 July 2025.The ceremony was presided over by Prime Minister himself. [551] The main goals of the Framework are guided by the vision that "The LRC is the architect of the legal system and the rule of law culture, that will embrace policy approaches based on Cambodia's context combined with both elements —historical and universal values.[552] To realize this vision set for over the next 25-year period, four key strategies have been established for further implementation: namely: Accessibility of Laws, Harmonization of Laws, Uniformity of the Legal System, and Integrity of the Legal System and Continuity in the Respect for the Rule of Law.[553]

Besides the aforementioned progress, the RGC acknowledges the challenges from legal and judicial application process. And therefore, addressing the shortcomings such as legal ambiguities, inconsistencies, and loopholes is one of core objectives of the current status of the Strategic Frameworks for Cambodia to further achieve greater efficiency in this reform process.[554] It is an agenda of the top priorities for the current government aiming to harmonize its mixed legal system, to strengthen the rule of law and improve a good governance including building a public trust, tackling other issues such as addressing weak implementations and conflicting laws when they arise.

For this purpose, the paper will discuss in the next section the legal order issues and related challenges. It examines the concept of law

[549] See, The, Strategic Framework of the Royal Government Legal Reform, April 2025 page 8.
[550] See, Pentagon Strategy Phase I, page 7- 18, See also the Strategic Framework for Legal Reform Program, April 2025, page 8.
[551] See, Cambodia Launches Strategic Framework for Legal Reform Programme; Khmer Times , July 10, 2025, https://www.khmertimeskh.com/501715188/cambodia-launches-strategic-framework-for-legal-reform-programme/ last 01 December 2025,
[552] See The Strategic Framework of the Royal Government Legal Reform, April 2025, p. 23.
[553] See, Id. p 7; also see, Khmer Times 10, July 2025 ; available https://www.khmertimeskh.com/501715188/cambodia-launches-strategic-framework-for-legal-reform-programme/ last 01 December 2025.
[554] See, The Strategic Framework of the Royal Government Legal Reform, April 2025, pp. 20-25.

supremacy in the context of relationship between domestic law and international law, their normative applicability, especially through the spirit of laws mainly within the constitutional framework and foreign policy contexts.

2.3. INTERNATIONAL LAW AND THE QUESTION OF ITS SUPREMACY OVER NATIONAL LAW

A. Dilemma of Normative Application: Monism vs Dualism

The central topic of the debate revolves around the correlation between international and national law through the legal order option for country ‘s application of the two theoretical concepts: namely “monism” and “dualisms”. In legal literatures, scholars often discuss these two contrasting, but popular principles using them as analytical tools to understand as how international law and domestic law interact; especially when there is a conflict situation (between the two legal systems) and how these can be addressed in a practical reality.[555]

From a standpoint of monism, --this theory posits that international law and national law form a single, unified legal order system. For international law to have effect domestically, it generally requires a formal "transformation" or "incorporation" into national law through a law or any Act of a highest legislative body or institution action (e.g. through the Parliament). From this hierarchical structure, international law is considered superior (supremacy) to the domestic law.

As for the dualism model, this theory views international law and domestic law as two entirely separate and distinct legal systems. International law does not automatically become part of national law. In this dualist system, the supremacy of international law is not a given rule, and a later (national law) can overrule an earlier incorporated international norm (based on the principle of lex posterior derogat legi priori), which may cause the state to violate its international obligations according to the Vienna

[555] See, Shrome Gargi, Monist vs. Dualist Theory of International Law, Volume 5/Issue 2, (2023) International Journal of Legal Science and Innovation, pp.60-64 available at: https://ijlsi.com/paper/monist-vs-dualist-theory-of-international-law/ Also, see, The main differences between dualism and monism in international law, Published by lawkh on 5 Feb 2025, https://law2021.wordpress.com/2025/02/05/the-main-differences-between-dualism-and-monism-in-international-law/ ; Also see, Wilfred Mutubwa, Monism or Dualism: The Dilemma in The Application of International Agreements Under the South African Constitution, Journalofcmsd Volume 3(1), 2019, pp.27-28, https://journalofcmsd.net/wp-content/uploads/2019/06/international-law-article-MUTUBWA-May-2019.pdf

Convention on the Law of Treaties. [556] This situation may lead to the consequence as treaty when ratified by states, is considered part of national law, — meaning that it becomes one of the sources of national law, — and that may lead to a conflict of law through legal application by domestic courts.[557] Therefore, the first model (monism) favors the supremacist groups of international law through the integration or unity, while the "dualism model" places an emphasis on a separation between international law and national law.

In reality, scholars observe that in case there are conflict of law the status of country legal system may suffer a tension from inconsistencies or loopholes of legal orders application. In line with that, there is also a tendency for domestic courts to favor national legislation, thereby complicating the enforcement of international treaty obligations that may not have accurately reflected the spirit of the Constitution. And these ambiguities can be understood in different ways, — that may cause arguments, disagreement or other uncertainties, stemming from vague words, changing meanings, or context, thus requiring courts to use interpretation rules like contra proferentem (interpreting against the drafter) to find legislative intent, ultimately impacting justice and clarity.[558]

Building Force	Economic prosperity as ruler's duty	Public works, agrarian order	Infrastructure, law of commerce	Economic regulation by law	Market & innovation supported by contract law	Industrial modernization by legal reform	Economic governance under legality	Corporate & technology law	Investment & innovation-driven law	Use law as instrument for economic development & innovation (Vision 2050 alignment).
Protecting Force	Welfare, social harmony	Hierarchical welfare order	Legal protection of citizens	Social rights, environment	Human rights, welfare law	Labor & welfare law	Social state, constitutional rights	Civil rights, social programs	Safety nets, merit-based welfare	Enshrine social protection, environment, and human security in constitutional & statutory frameworks.

Dimension	Ancient India (Dharmasastra & Arthasastra)	Ancient China (Confucian & Legalist)	Roman Empire	France	England (UK)	Japan	Germany	United States	Singapore	Key Lessons for Cambodia
Unifying Force	Shared dharma and monarchy	Confucian moral order	Citizenship & Roman law unity	Republican identity	Common law heritage	National codes & civic education	Federal constitutional culture	Constitutional patriotism	Multicultural legal unity	Build national legal identity rooted in Buddhist compassion, constitutionalism, and civic duty.
Defending Force	Military ethics, sovereign defense	Strategic order, moral legitimacy	Legalized empire defense	Legal diplomacy, EU integration	Rule-bound defense	Pacifism + self-defense law	Civilian control of army	Legal supremacy in foreign policy	Legal deterrence & diplomacy	Ensure defense and diplomacy are anchored in international law & national sovereignty.

Analysis of both historical and contemporary contexts reveals three primary patterns.

1. Law as Strategic Infrastructure. In all robust states, such as Rome with its administrative law and Japan with its developmental state, law serves as the foundation for governance and national development rather than functioning solely as a set of rules. Cambodia should transition from a repetitive process of lawmaking to a comprehensive cycle of governance, emphasizing institution-building, effective legal implementation, and the cultivation of public trust to legitimize these institutions.
2. Integration of Morality and Rationality. Effective legal systems combine ethical legitimacy, such as dharma, virtue, and civic morality, with rational administrative practices. Cambodia's Buddhist and royal traditions provide significant moral capital that, if integrated with rule-of-law institutions, could establish a distinctively Cambodian jurisprudence characterized by integrity.
3. Adaptation and Localization. Nations that have achieved success have selectively adopted foreign legal models, as seen in Japan's adaptation of European systems and Singapore's adoption of British frameworks, while tailoring these models to their national identities. Cambodia should pursue a comparable strategy by adopting effective practices, adapting them to local contexts, and fostering coherence through education, professional development, and systematic codification.

This analysis demonstrates that strengthening Cambodia necessitates more than the creation of legal statutes. It requires the development of a comprehensive legal ecosystem, including institutions, stakeholders, values, and cultural norms, to collectively stabilize, unify, protect, and advance the nation. The subsequent phase of reform should connect the Strategic Framework with the Vision 2050 by implementing an updated National Legal System Integrity and Nation-Building Program, thereby establishing law as both the foundation and driving force of national transformation.

9. POLICY PROPOSAL: BUILDING THE COMPLETENESS AND INTEGRITY OF CAMBODIA'S LEGAL SYSTEM

Research indicates that Cambodia's legal system has achieved significant progress in reconstructing its institutional and normative foundation since 1993. Nevertheless, structural deficiencies, inconsistent

implementation, and limited integration with the national governance framework continue to impede its overall effectiveness. The Strategic Framework establishes a foundation through the Cycle of Law, which includes drafting, implementation, and review. However, further measures are required to address institutional, human resource, cultural, and systemic challenges. The proposed actions below are intended to supplement ongoing reforms and align the legal system with the Pentagonal Strategy and Vision 2050, thereby strengthening its role in national governance.

9.1. CONTINUE TO IMPLEMENT THE STRATEGIC FRAMEWORK OF THE LEGAL REFORM PROGRAM

While this research proposes additional measures to enhance the completeness and integrity of Cambodia's legal system, it is equally crucial to continue and consolidate the implementation of the Royal Government's Strategic Framework of the Legal Reform Program (2025–2045). The Strategic Framework remains the cornerstone of national legal reform, aligning directly with the 4th side of the Pentagonal Strategy—Growth, Employment, Equity, Efficiency, and Sustainability. It positions the LRC as the "*architect of the Cambodian legal system and the rule of law culture based on national historical and universal values*".

The framework defines a 20-year vision (2025–2045) with the mission to *lead and coordinate the reform of Cambodian laws into a system that is uniform, effective, and aligned with both the Cambodian context and international best practices*. Its core strategies—developing mechanisms for drafting, implementing, reviewing, and harmonizing laws—lay the institutional and procedural foundation for long-term legal coherence.

To achieve completeness and integrity, implementation of the Strategic Framework must be accelerated and reinforced in the following ways:

1. **Strengthen Monitoring and Evaluation (M&E):** The General Secretariat of the LRC should continue to operationalize the *monitoring, controlling, and evaluation system* envisioned in the Framework, collecting data and producing annual performance reports with actionable recommendations. This ensures real-time feedback and accountability in legal reform progress.
2. **Advance the Consolidated Work Program:** The Framework's *Consolidated Work Program*—a 20-year roadmap covering all major reform areas—should continue to guide reform sequencing, inter-ministerial prioritization, and coordination. National workshops and technical consultations

should be institutionalized to review implementation progress and adjust priorities based on new realities.

3. **Ensure Legal Continuity and Institutional Cooperation:** As the Framework emphasizes *integrity of the legal system and continuity in the respect for the rule of law*, ongoing reforms such as conflict-of-law mechanisms, legality advisory systems, and post-legislative evaluation tools must be maintained and expanded to ensure systemic stability and coherence។

4. **Integrate with Complementary Reforms:** The additional proposals in this research—such as strengthening institutional capacity, human resources, and legal culture—should not replace but *complement* the Framework's strategies. Together, they can transform the current procedural focus into a holistic system that links lawmaking, implementation, and national development.

By continuing to implement the Strategic Framework with the proposed measures from this study, Cambodia can ensure that its legal reform program evolves from procedural coordination to systemic completeness and integrity—a unified legal order that both reflects Cambodian values and supports the strategic aspirations of Vision 2050.

9.2. STRENGTHENING INSTITUTIONAL CAPACITY AND SYSTEMIC COHERENCE

The integrity and effectiveness of the legal system rely on robust institutions that translate legislation into effective governance. Strengthening these institutions necessitates moving from fragmented, ministry-specific approaches to an integrated legal governance system.

First, institutionalizing a Whole-of-Government Legal Operating Model will establish standardized procedures for drafting, implementing, and reviewing legislation across all ministries and agencies. This approach will shift lawmaking from a reactive process to a strategic governance function. Second, the LRC should be authorized to coordinate more effectively by formalizing collaboration among the Council of Jurists, Council for Administrative Reform, and relevant ministries. Third, enacting a National Framework Law on the System of Law will codify the hierarchy, validity, and lifecycle of legal norms, thereby promoting coherence, transparency, and internal consistency within the Cambodian legal system.

To enhance evidence-based policymaking, the LRC should establish a Legal System Observatory and an Integrity Index to monitor the coherence, implementation, and accessibility of legislation. Additionally, a

Post-Legislative Review Mechanism should be implemented across ministries to assess the effectiveness of laws within one to two years of enforcement. This process will support adaptability and responsiveness to social and economic changes.

These institutional reforms will enable the legal system to function as a coherent and self-correcting framework. This structure will support both stability and continuous improvement, aligning with the governance principles outlined in the Vision 2050.

9.3. LEGAL PROFESSIONALISM & COHERENCE

The quality and credibility of the legal system depend on its core professionals, including judges, prosecutors, legal drafters, regulators, and lawyers. To develop a competent and ethical legal workforce, the government should establish a National Legal Competency Framework (NLCF). The NLCF would define professional standards, qualifications, and ethical requirements for all legal professions across relevant institutions.

A National Legal Service Corps (NLSC) should be established to unify legal professionals working in ministries, courts, and sub-national administrations. The NLSC would facilitate professional mobility, standardized training, and ethical accountability. In addition, legal and judicial education should be updated to include comparative law, law and governance, ethics, international law, and policy analysis. This modernization should occur through collaboration among universities, the Royal Academy for Judicial Professions, and the BAKC.

Continuous professional development should be mandated by law. Mandatory Continuing Professional Development (CPD) and ethics certification must be required for all legal professionals to ensure ongoing competence and responsiveness to governance challenges. Furthermore, a National Legal Research and Documentation Center should be established to support legislative research, policy analysis, and jurisprudential development. This center would ensure that lawmaking is informed by evidence and comparative best practices.

These measures will contribute to the development of a skilled, ethical, and research-oriented legal workforce capable of maintaining the integrity and comprehensiveness of Cambodia's legal system.

9.4. CULTIVATING A RULE-OF-LAW CULTURE AND PUBLIC LEGAL CONSCIOUSNESS

A comprehensive legal system depends on a social and cultural context that upholds legality, justice, and civic responsibility. Advancing Cambodia's

legal culture necessitates public legal education and the reinforcement of professional ethics.

Legal literacy should be introduced at an early stage. Civic and legal education must be incorporated into school curricula and national media initiatives to inform citizens about rights, duties, and lawful conduct. At the institutional level, transparency and public participation should be established as standard procedures in the legislative process. Draft laws and sub-decrees require publication for public consultation, and all legal documents must be translated into clear and accessible Khmer.

Reinforcing professional ethics requires the harmonization of the Code of Ethics for judges, prosecutors, lawyers, and regulators. This measure would establish a common ethical framework within the legal professions, mitigate corruption risks, and enhance accountability. Furthermore, access to justice mechanisms, including community mediation and alternative dispute resolution, should be expanded and formalized by incorporating Cambodia's traditional Buddhist and peace-oriented social values.

A robust legal culture serves as the foundation for completeness and integrity in the legal system. It elevates law from a set of commands to a collective national conscience.

9.5. ESTABLISHING A CLEAR FRAMEWORK OF CAMBODIA'S LEGAL SYSTEM

Systemic coherence and sustainability in Cambodia require the establishment of a comprehensive legal framework that delineates the structure, hierarchy, and unity of the national legal order. Enactment of a Law on the System of Law is necessary to define the hierarchy of norms, clarify the status of international obligations, and standardize procedures for drafting, publication, consolidation, and repeal.

Development of a Codification Roadmap for key legal domains, including administrative procedure, land, environment, digital governance, commercial and economic regulation, is essential to simplify and harmonize existing laws and eliminate contradictions. In addition, establishing an Authoritative Law Reporting and Citation System will consolidate jurisprudence and promote uniformity in legal interpretation, as demonstrated by systems in France and Japan.

Periodic assessment of legal coherence, accessibility, and enforcement through a Legal System Observatory and Integrity Index is required, with annual reports informing policy reform and public accountability. This mechanism will position the legal system as a proactive enabler of Cambodia's national development agenda.

9.6. INTEGRATION WITH VISION 2050 AND THE PENTAGONAL STRATEGY

The Pentagonal Strategy implements the long-term objectives outlined in Vision 2050, with a focus on growth, employment, equity, efficiency, and sustainability. To achieve these objectives, the legal framework must serve as the foundational infrastructure supporting governance and national development.

Each legislative initiative must clearly demonstrate its contribution to at least one of the five strategic pillars. For instance, commercial and investment legislation should promote economic diversification and innovation. Education and professional statutes should facilitate human resource development. Environmental and land management laws should strengthen sustainability. Judicial and administrative reforms should uphold good governance and the rule of law. The LRC, the Council of Jurists, and ECOSOCC should serve as national coordinators by conducting mandatory reviews to ensure coherence between policy and legislation.

This coordinated approach will help Cambodia's legal system maintain internal consistency and integrity while advancing the country's strategic transformation toward a strong, equitable, and prosperous future.

9.7. CLASSICAL STATECRAFT FOR CONTEMPORARY REFORM (ARTHAŚĀSTRA & ANGKORIAN PRINCIPLES)

The Law Reform Committee should conduct targeted research on the Arthaśāstra and the governance principles of the Angkorian era. The research will address key domains of statecraft that were central to Angkorian administration, including kingship and public authority, civil administration, revenue and land management, public works and water systems, justice and ethics, and diplomacy within the regional mandala system.

The primary objective is to extract rights-compatible insights that inform the current reform agenda, specifically by strengthening legality, integrity, administrative coherence, and service delivery. All recommendations will align with the Constitution and Cambodia’s international obligations. The resulting findings will be presented as practical guidance for policymakers, such as policy notes, model legal provisions, and checklists for decision-makers.

9.8. CONCLUSION

The proposed actions seek to reform Cambodia’s legal system into a coherent, sustainable, and strategically aligned national framework.

Strengthening institutions, developing legal professionals, promoting legal culture, and establishing systemic unity will facilitate the creation of a comprehensive and internally consistent legal order that supports national governance.

Full implementation of these measures will enable the legal system to serve as a foundation for national development, supporting the stability, prosperity, and sovereignty outlined in Cambodia's Vision 2050.

ការសិក្សាបន្ថែមផ្សេងទៀតនៃអនុប្រធានបទស្តីពីទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

ផ្នែកទី១. កំណែទម្រង់ប្រព័ន្ធយុត្តិធម៌នៅកម្ពុជា

សិក្ខាអំពី «កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ តាមយុត្តសាស្ត្រត្រីកោណ និងយុទ្ធសាស្ត្រ ចតុកោណ ទាំង៤ ដំណាក់កាល»

ឯកឧត្តម ម៉ុង មុនីចរិយា ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ

១.១. សាវតា

ស្ថិតក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** បានប្រែក្លាយកម្ពុជាទៅជារដ្ឋអធិបតេយ្យ, ឯករាជ្យ, សន្តិភាព, នីតិរដ្ឋ និងជាពិសេស ការក សាងបាននូវស្ថិរភាពនយោបាយ និងសុខសន្តិភាពពេញលេញ ដោយឈរលើគោលការណ៍លទ្ធិប្រជាធិប តេយ្យសេរី ពហុបក្ស។ ប្រជាជនកម្ពុជារាប់លាននាក់ បានចាកផុតពីភាពក្រីក្រ និងកំពុងរស់នៅជាមួយនឹង ជីវភាពសមរម្យ, មានចំណេះដឹង និងមានសុខុមាលភាពកាន់តែប្រសើរ។ ព្រះរាជាណាចក្រកម្ពុជាសម្រេច បាននូវសុខសន្តិភាពពេញលេញ, ឯកភាពជាតិ និងឯកភាពទឹកដីទាំងស្រុង តាមរយៈនយោបាយ ឈ្នះ-ឈ្នះ របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**។ កន្លងមក រាជរដ្ឋាភិបាលកម្ពុជាតែង តែបានអនុវត្តប្រកបដោយជោគជ័យនូវយុត្តិសាស្ត្រគោលនយោបាយរបស់ខ្លួន ដែលរួមមាន យុត្តិសាស្ត្រត្រីកោណ, យុទ្ធសាស្ត្រចតុកោណទាំង៤ ដំណាក់កាល, ដោយសម្រេចបាននូវសមិទ្ធផលធំៗ ជាច្រើនលើគ្រប់ វិស័យ, ទាំងនយោបាយ, សង្គម និងសេដ្ឋកិច្ច។

ជាត្រីវិស័យក្នុងការអភិវឌ្ឍប្រទេសជាតិ **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** អតីតនាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានដាក់ចេញនូវទស្សនាទានថា «**កែទម្រង់រស់ មិនកែ ទម្រង់ស្លាប់**»។ ផ្អែកតាមទស្សនវិស័យនេះ កម្មវិធីកែទម្រង់ជាតិជាច្រើនវិស័យត្រូវបានដាក់ចេញជាបន្តបន្ទាប់ ដែលក្នុងនោះ ការកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ក៏ត្រូវបានផ្តួចផ្តើម និងដាក់ឲ្យដំណើរការដំបូងនៅឆ្នាំ ២០០៣ តាមរយៈការអនុម័តនូវ«**យុត្តិសាស្ត្រជាតិកាត់បន្ថយភាពក្រីក្រ ឆ្នាំ២០០៣-២០០៥**» ដែលបាន ចាត់ទុកកំណែទម្រង់វិស័យនេះ ជាយុត្តិសាស្ត្រអាទិភាពមួយ **ក្នុងការពង្រឹងស្ថាប័ន**

និងការធ្វើឲ្យប្រសើឡើងនូវអភិបាលកិច្ច ដែលជាសកម្មភាពអាទិភាពក្នុងការកាត់បន្ថយភាពក្រីក្រនៅកម្ពុជា។

បន្ទាប់មក **កម្មវិធីយុត្តិសាស្ត្រនៃកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ** ត្រូវបានអនុម័តជាផ្លូវការ ដោយកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រី កាលពីថ្ងៃទី ២០ ខែមិថុនា ឆ្នាំ២០០៣ ស្ថិតក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** ក្នុងចក្ខុវិស័យ «បង្កើតនូវវិស័យច្បាប់ និងតុលាការមួយ ដែលអាចទុកចិត្តបាន និងមានស្ថេរភាព សម្រាប់ទ្រទ្រង់សិទ្ធិបុគ្គល ការបែងចែកអំណាច និងនីតិរដ្ឋ នៅ ក្នុងលិទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស តាមរយៈការលើកស្ទួយការរីកចម្រើនសេដ្ឋកិច្ចជាតិ» ។

ដើម្បីសម្រេចបាននូវចក្ខុវិស័យប្រាកដនិយមរ៉ែងឆ្ងាយ និងគ្រប់ជ្រុងជ្រោយដូចខាងលើនេះ កម្មវិធី កំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ បានកំណត់ទិសដៅជាអាទិភាពចំនួន ៧ រួមមាន៖

ទី១. ការពង្រឹងការការពារសិទ្ធិ និងសេរីភាពបុគ្គល
ទី២. ការធ្វើទំនើបកម្មនៃក្រមខ័ណ្ឌច្បាប់
ទី៣. ការផ្តល់លទ្ធភាពឲ្យទទួលបានពត៌មានអំពីច្បាប់ និងតុលាការកាន់តែប្រសើឡើង
ទី៤. ការធ្វើឲ្យប្រសើឡើងនូវគុណភាពនៃដំណើរការរឿងក្តី និងសេវាកម្មពាក់ព័ន្ធ
ទី៥. ការពង្រឹងសេវាកម្មយុត្តិធម៌ រួមមានអំណាចតុលាការ និងសេវាកម្មផ្នែកអយ្យការ
ទី៦. ការបញ្ចូលយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង
ទី៧. ការពង្រឹងស្ថាប័នវិស័យច្បាប់ និងតុលាការឲ្យបំពេញអាណត្តិរបស់ខ្លួនបានសម្រេច។

ឆ្លងកាត់បទពិសោធន៍នៃការអនុវត្តកម្មវិធីកំណែទម្រង់ខាងលើ ជាពិសេស ក្នុងទិសដៅបង្កើន ល្បឿនសកម្មភាពនៃការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ជានាបាននូវភាពបត់បែន និងប្រសិទ្ធភាពការងារ រាជរដ្ឋាភិបាល ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាធិបតីតេជោ ហ៊ុន សែន** ក៏បានអនុម័តបន្ថែមនូវ «**កម្មវិធីសកម្មភាពសម្រាប់យុត្តិសាស្ត្រកំណែទម្រង់ច្បាប់ និង តុលាការ**» នៅក្នុងកិច្ចប្រជុំ

ពេញអង្គរបស់គណៈរដ្ឋមន្ត្រី នាថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥។ ចាប់តាំងពីកម្មវិធីកែទម្រង់ច្បាប់ និងប្រព័ន្ធតុលាការ ត្រូវបានដាក់ឲ្យដំណើរការ នៅក្នុងឆ្នាំ២០០៣ មក ត្រូវបានដឹកនាំ និង សម្របសម្រួលអនុវត្តដោយក្រុមប្រឹក្សាកំណែទម្រង់ច្បាប់និងប្រព័ន្ធយុត្តិធម៌ សម្រួលអចិន្ត្រៃយ៍ ជាអង្គភាពកិច្ចការរបច្ចេកទេស និងគ្រប់គ្រងគម្រោង ជាសនាធិការ ក្នុងការជួយគាំទ្រ សម្របសម្រួល និងការអនុវត្តការងារ។

លុះនៅឆ្នាំ២០១៣ ការងារកែទម្រង់ច្បាប់និងប្រព័ន្ធតុលាការ ត្រូវបានផ្ទេរឱ្យស្ថិតនៅក្រោមការ ទទួលខុសត្រូវរបស់ក្រសួងយុត្តិធម៌ និងតុលាការកំពូល តាមរយៈការបង្កើតនូវគណៈកម្មាធិការដឹកនាំការ កែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដែលមានលេខាធិការដ្ឋានអចិន្ត្រៃយ៍ ជាសេនាធិការ ក្នុងការជួយសម្រប សម្រួលការអនុវត្តបន្តនូវកម្មវិធីសកម្មភាពយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ។ តាមរយៈយន្តការនេះ កម្មវិធីកែទម្រង់ច្បាប់និងតុលាការ ទទួលបាននូវសមិទ្ធិផលធំៗជាច្រើន ដែលក្នុងនោះមាន ដូចជា ការពង្រឹងការការពារសិទ្ធិសេរីភាពបុគ្គល, ការធ្វើទំនើបកម្មក្របខ័ណ្ឌច្បាប់, ភាពប្រសើរនៃការទទួល បាននូវព័ត៌មានអំពីច្បាប់ និងតុលាការ, ការលើកកំពស់ និងការពង្រឹងគុណភាពនៃសេវាយុត្តិធម៌ ជាអាទិ៍។ ទន្ទឹមនឹងនេះ ក៏បន្តនៅមានបញ្ហាប្រឈមជាគន្លឹះមួយចំនួនផងដែរ ដែលមានភាពចាំបាច់ក្នុងការដោះស្រាយ ផ្អែកលើយុត្តិសាស្ត្រគ្រប់ជ្រុងជ្រោយ និងមានប្រសិទ្ធភាព។

១.១.១. សមិទ្ធិផលសំខាន់ៗដែលសម្រេចបាន

ក្នុងក្របខណ្ឌនៃការអនុវត្តកម្មវិធីយុទ្ធសាស្ត្រកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌រាជរដ្ឋាភិបាល សម្រេចបាននូវវឌ្ឍនភាពសំខាន់ជាច្រើន ក្នុងនោះរួមមាន៖

ក. ការកសាងច្បាប់ និងបទដ្ឋានផ្សេងៗ

ច្បាប់ចំនួន ៦១០ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្ត ដែលបង្ហាញពីភាពរឹងមាំ និងគ្រប់ជ្រុងជ្រោយ គាំទ្រការអនុវត្តលិទ្ធិប្រជាធិបតេយ្យសេរី ការគោរពសិទ្ធិសេរីភាពបុគ្គល និងនីតិរដ្ឋ ក្នុងនោះ ការដាក់ឲ្យប្រើប្រាស់ និងការធ្វើទំនើបកម្មច្បាប់ក្នុងវិស័យយុត្តិធម៌ ដែលជាស្នូលនៃយុត្តិសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌ ក៏ ត្រូវបានដាក់ឲ្យអនុវត្តផងដែរ ក្នុងនោះមានដូចជា ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ ក្រមរដ្ឋប្បវេណី និងក្រមនីតិវិធីរដ្ឋប្បវេណី, ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ, ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រមនិងព្រះរាជអាជ្ញា និងច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម រួម

ជាមួយច្បាប់និង លិខិតបទដ្ឋានគតិយុត្តិសំខាន់ៗជាច្រើនទៀត ដែលមូលដ្ឋានគាំទ្រដល់ការកែទម្រង់វិស័យផ្សេងៗរបស់រាជរដ្ឋាភិបាល។

ខ. ការកសាងធនធានមនុស្ស

ចាប់តាំងពីសាលាជម្រះក្តីត្រូវបានដាក់ឲ្យដំណើរការដំបូងនៅក្នុងឆ្នាំ ១៩៨០ មក និងថ្វីត្បិតតែមានការតែងតាំងចៅក្រមអសនៈចៅក្រមអយ្យការ ក្រឡាបញ្ជី និងមន្ត្រីពាក់ព័ន្ធត្រូវបានតែងតាំងឲ្យបំរើការផ្តល់ សេវាយុត្តិធម៌នៅតាមសាលាជម្រះគ្រប់ជាន់ថ្នាក់របស់កម្ពុជាក៏ពិតមែន ប៉ុន្តែរហូតដល់ឆ្នាំ ២០០២ នៅកម្ពុ ជាមិនទាន់បង្កើតឲ្យមានជាសាលា ឬវិទ្យាស្ថានវិជ្ជាជីវៈសម្រាប់បណ្តុះបណ្តាលមន្ត្រីយុត្តិធម៌ពាក់ព័ន្ធនោះ នៅឡើយទេ។ ការបណ្តុះបណ្តាលមន្ត្រីជំនាញផ្នែកសេវយុត្តិធម៌ គឺបានធ្វើក្នុងលក្ខណៈជា Ad Hoc ឬពេល មានភាពចាំបាច់ ដែលមានវត្តរយៈកំណត់ និងពេលខ្លះខ្លីៗសម្រាប់បណ្តុះបណ្តាលជាក់ស្តែងនៅឆ្នាំ ១៩៩៤ ក្រសួងយុត្តិធម៌បានបើកវគ្គបណ្តុះបណ្តាលចៅក្រម មានរយៈពេលពីរឆ្នាំ ដែលសិក្ខាកាមចំនួន ៤២នាក់ ត្រូវបានជ្រើសរើសពីក្នុងចំណោមអ្នកច្បាប់ដែលទទួលបានបញ្ចប់ការសិក្សា និងទទួលបានបរិញ្ញា ប័ត្រច្បាប់ពីអតីតសហភាពសូវៀត និងប្រទេសវៀតណាម និងមួយចំនួនទៀតត្រូវជ្រើរើសរើសតាមការ ប្រឡងប្រជែងពីសំណាក់មន្ត្រីក្រឡាបញ្ជី ដែលកំពុងបម្រើការងារតាមសាលាជម្រះក្តីនាពេលនោះ និងក៏មានវគ្គខ្លីៗមួយទៀតផងដែរ។ ក្នុងឆ្នាំ២០០២ សាលាភូមិន្ទចៅក្រមត្រូវបានបង្កើតឡើងតាមអនុក្រិត្យ លេខ០៩ អនក្រ.បក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០០២ ។

តាមព្រះរាជក្រិត្យលេខ នស/រកត/០៣២៣/៥២០ ចុះថ្ងៃទី២៥ ខែមីនា ឆ្នាំ ២០២៣ រាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ ត្រូវបានប្តូរឈ្មោះទៅជា បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា ជាស្ថាប័នផ្តល់ការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈច្បាប់ មានដូចជា ចៅក្រមព្រះរាជអាជ្ញា ក្រឡាបញ្ជី សារៈការី និងអាជ្ញាសាលា និងមន្ត្រីអនុវត្តច្បាប់ផងដែរ។

បណ្ឌិតសភាភូមិន្ទយុត្តិធម៌កម្ពុជា គឺជាផ្នែកមួយនៃកំណែទម្រង់ស្ថាប័នសម្រាប់បណ្តុះបណ្តាលអ្នក វិជ្ជាជីវៈច្បាប់ និងតុលាការ ដែលមានគោលដៅសំខាន់ៗ ដូចជាៈ

- ការពង្រឹងគុណភាពនៃការបណ្តុះបណ្តាលអ្នកវិជ្ជាជីវៈ និងតុលាការ ដើម្បីឲ្យមន្ត្រីពាក់ព័ន្ធមាន សមត្ថភាពគ្រប់គ្រាន់ និងប្រកបដោយសីលធម៌ ដែលជាកត្តាដ៏មានសក្តានុពលធានាបាននូវប្រសិទ្ធភាព ខ្ពស់នៃការអនុវត្តច្បាប់ និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ និងគុណភាពយុត្តិធម៌

- ពង្រីកសក្តានុពលនៃស្ថាប័ន ដែលអាចពង្រឹងសមត្ថភាពជំនាញ និងបច្ចេកទេសដល់មន្ត្រីអនុវត្ត ច្បាប់ផ្សេងទៀតដែលពាក់ព័ន្ធ
- លើកកំពស់សមត្ថភាពផ្នែកស្រាវជ្រាវ និងផ្សព្វផ្សាយនូវស្នាដៃដែលមានបរយោជន៍ដល់វិស័យច្បាប់ និងយុត្តិធម៌នៅកម្ពុជា។

គ. ការកសាង និងអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

នៅពេលចាប់ផ្តើមដំណើរការដំបូង ជាពិសេស ក្នុងឆ្នាំ១៩៨២ សាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ពិតជា ជួបប្រទះការខ្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាច្រើន ជាក់ស្តែងដូចជា សាលាដំបូងរាជធានីភ្នំពេញ និងតុលាការកំពូលកម្ពុជា មានអាគារការងារត្រឹមតែជាផ្ទះវិឡាសល់ពីសង្គមចាស់ និងស្ថិតក្នុងដីឡូត៍ រីង សាលាឧទ្ធរណ៍ភ្នំពេញវិញដែលបានដាក់ឲ្យដំណើរការដំបូងក្នុងឆ្នាំ១៩៩២ គឺអាគារការងារ នៅរួមគ្នា ជាមួយនឹងក្រសួងយុត្តិធម៌។ ទាំងបន្ទប់ការងារ និងបន្ទប់សវនាការមានភាពតូចចង្អៀត ដែលពេលត្រូវបានសាធារណជនផ្តល់ការជិះទៀនថា មិនសមរម្យជាកន្លែងផ្តល់សេវាយុត្តិធម៌ ជាអាទិ៍។ ប៉ុន្តែដោយសារកិច្ច ខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ជារួមលទ្ធផលនៃការអនុវត្តគោល នយោបាយគ្រប់តំណាក់កាល និងយុត្តិសាស្ត្រកំណែទម្រង់ជាតិ និងដោយឡែក កំណែទម្រង់ច្បាបើ និង ប្រព័ន្ធតុលាការជាបន្តបន្ទាប់ វឌ្ឍនភាពផ្នែកហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់សាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ មាន ការរីកចម្រើនគួជាទីមោទនៈ ជាពិសេស ការផ្តល់ជូនអាគារជាអតីតមន្ទីររដ្ឋសភាជាតិ ឲ្យទៅតុលាការកំពូលកម្ពុជា ដែលមានទីតាំងនៅជិតព្រះបរមរាជវាំង, សាលាយុត្តិធម៌នៃសាលាឧទ្ធរណ៍ភ្នំពេញ និងសាលា ដំបូងរាជធានីភ្នំពេញ ក៏ដូចជា ហេដ្ឋារចនាសម្ព័ន្ធថ្មីៗ របស់សាលាឧទ្ធរណ៍តំបន់ត្បូងឃ្មុំ, បាត់ដំបង និងព្រះ សីហនុ។ លើសពីនេះ ហេដ្ឋារចនាសម្ព័ន្ធរបស់សាលាដំបូងជាច្រើន ត្រូវសាងសង់ថ្មី មានដូចជា សាលាដំបូងខេត្តពោធិសាត់, ខេត្តតេនគីរី, ខេត្តមណ្ឌលគីរី ខេត្តកំពត ព្រះសីហនុ កំពត រីងសាលាដំបូងផ្សេងទៀត ក៏បានពង្រីកបន្ថែមនូវសំណង់អាគារការងាររបស់ខ្លួនផងដែរ។

ឃ. ការលើកកំពស់ប្រសិទ្ធិភាពនៃការផ្តល់សេវាយុត្តិធម៌

ចាប់តាំងពីការដាក់ឲ្យដំណើរការសាលាដម្រះក្តីគ្រប់ជាន់ថ្នាក់ រហូតដល់ឆ្នាំ ២០១៤ ទាំងសាលា ឧទ្ធរណ៍រាជធានីភ្នំពេញ ក៏ដូចជា គ្រប់សាលាដំបូងរាជធានី-ខេត្ត គឺនាយកក្រឡាបញ្ជីជាសេនាធិការឲ្យ ប្រធានសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញា នៅជាន់សាលាឧទ្ធរណ៍ និងជាសេនាធិការឲ្យប្រធាន និង ព្រះ រាជអាជ្ញា នៅជាន់សាលាដំបូង លើ

ការងាររដ្ឋបាល និងហិរញ្ញវត្ថុ ដោយឡែកនៅជាន់តុលាការកំពូល វិញ មានមន្ទីររដ្ឋបាល ជាជំនួយការលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ យោងតាម ក្រិត្យ-ច្បាប់លេខ ៣៤ ក្រ.ច ចុះ ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ១៩៨៧ ស្តីពីការចាត់តាំង និងសកម្មភាពរបស់តុលាការប្រជាជនកំពូល និងមហា អយ្យការអមតុលាការប្រជាជនកំពូល ។

នៅក្នុងឆ្នាំ ២០១៤ អង្គភាពរដ្ឋបាលតុលាការត្រូវបានបង្កើតនៅតាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដែលជាសេនាធិការជួយលើការងាររដ្ឋបាល និងហិរញ្ញវត្ថុ និងទំនាក់ទំនងសាធារណៈផ្សេងទៀត របស់ សាលាជម្រះក្តី ក្នុងគោលបំណងធានាដល់ឯករាជ្យភាពរបស់តុលាការ និងការកែលម្អសេវាទំនាក់ទនងតុ មុខ ក៏ដូចជា ការលើកកម្ពស់ការយកចិត្តទុកដាក់ក្នុងចំណាត់ការសំណុំរឿងក្តីតាមតុលាការ។ ចាមួយគ្នា នេះដែរ ការគ្រប់គ្រងរដ្ឋបាលសំណុំរឿងតាមប្រព័ន្ធបច្ចេកវិទ្យាក៏ត្រូវបានរៀបចំ និងដាក់ឱ្យដំណើរការជាប ណ្តើរៗនៅតាមសាលាជម្រះក្តីជាន់ខ្ពស់ និងសាលាដំបូងរាជធានីខេត្តមួយចំនួនផងដែរ ដែលជាសក្ខីភាព នៃការចូលរួមអនុវត្តកម្មវិធីកំណែទម្រង់ និងទំនើបកម្មស្ថាប័ន តានរយៈការជំរុញការធ្វើបរិវត្តកម្មឌីជីថល ។

១. ការបង្កើតសេវាយុត្តិធម៌ទៅកៀកប្រជាពលរដ្ឋ

កន្លងមក រហូតដល់ឆ្នាំ២០២០ នៅពេលប្រជាពលរដ្ឋជាភាគីក្តីមិនសុខចិត្តនឹងការវិនិច្ឆ័យរបស់ សាលាដំបូងរាជធានី-ខេត្ត ភាគីនោះត្រូវធ្វើឧបាស្រ័យទៅសាលាឧទ្ធរណ៍រាជធានីភ្នំពេញ។ សាលាឧទ្ធរណ៍ តែមួយ ដែលមានវិសាលភាពលើដែនដីទាំងមូលនៃព្រះរាជាណាចក្រកម្ពុជា បង្កើតជាចំណោទ បញ្ហាមួយ ចំនួនសម្រាប់ប្រជាពលរដ្ឋដែលមានតម្រូវការសេវាយុត្តិធម៌ជាន់ឧទ្ធរណ៍ មានដូចជា បន្ទុកលើចំណាយនៃ ការធ្វើដំណើរ ពេលវេលា និងទំនាក់ទំនង ជាដើម។ ហេតុដូចនេះហើយ ទើបនៅក្នុងឆ្នាំ២០២០ តាមព្រះ រាជក្រិត្យលេខ នស/រកត/១៩៨ ចុះថ្ងៃទី១៦ ខែកម្ភៈ ឆ្នាំ២០២០ សាលាឧទ្ធរណ៍ និង មហាអយ្យការអម សាលាឧទ្ធរណ៍តំបន់ចំនួន ៣ បន្ថែមទៀត ត្រូវបានការដាក់ឲ្យដំណើរការពីសាលាឧទ្ធរណ៍ និងមហា អយ្យការអមសាលាឧទ្ធរណ៍រាជធានីភ្នំពេញ ក្នុងនោះរួមមានសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលា ឧទ្ធរណ៍តំបន់ត្បូងឃ្មុំ សាលាឧទ្ធរណ៍និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់បាត់ដំបង និងសាលាឧទ្ធរណ៍ និងមហាអយ្យការអមសាលាឧទ្ធរណ៍តំបន់ព្រះសីហនុ សំដៅបង្កើតសេវាយុត្តិធម៌ឱ្យកាន់តែខិតជិត ប្រជាពលរដ្ឋ។ ជាទិសដៅអាទិភាពនាពេលខាងមុខ ក្រសួងយុត្តិធម៌មានផែនការរៀបចំតុលាការជំនាញ ចំនួន ២ បន្ថែមទៀត គឺតុលាការពាណិជ្ជកម្ម និងតុលាការការងារ សំដៅ

ជានាដល់ប្រសិទ្ធភាព និងភាព ឆាប់រហ័សនៃការផ្តល់សេវាយុត្តិធម៌ ក៏ដូចជា ឆ្លើយតប តាមតម្រូវការជាក់ស្តែងនៃការអភិវឌ្ឍន៍សង្គម។

ច. ការលើកកម្ពស់យន្តការនៃការផ្តល់សេវាជំនួយផ្នែកច្បាប់

កន្លងមក, រាជរដ្ឋាភិបាលបានយកចិត្តទុកដាក់ចំពោះប្រជាពលរដ្ឋក្រីក្រដែលមិន មានលទ្ធភាពផ្នែក ហិរញ្ញវត្ថុ ក្នុងការពឹងពាក់រកមេធាវី តាមរយៈយន្តការប្រតិភូគណៈ មេធាវីប្រចាំការនៅតាមសាលាដំបូងរាជ ធានី-ខេត្ត ក៏ដូចជា សាលាជម្រះក្តីជាន់ខ្ពស់ ដែលជាយន្តការបង្កើតឡើងដោយកិច្ចសហការរវាងក្រសួង យុត្តិធម៌ និងគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា ដើម្បីធានានូវសិទ្ធិទទួលបានយុត្តិធម៌(Access to Justice) របស់ប្រជាពលរដ្ឋក្រីក្រនៅក្នុងសង្គម។ យន្តការនេះទទួលបានកញ្ចប់ថវិកាពីរាជរដ្ឋាភិបាល ជារៀងរាល់ឆ្នាំ ហើយដែលកញ្ចប់ថវិកាប្រចាំឆ្នាំនេះកើនឡើងជាបន្តបន្ទាប់ជារៀងរាល់ឆ្នាំ ពីចំនួនទឹកប្រាក់ ២០០ លានរៀល នៅឆ្នាំ ២០០៣ រហូតដល់ចំនួនទឹកប្រាក់ ២ ៦០០ លានរៀលនៅឆ្នាំ២០២៤នេះ។ បន្ថែមពីលើយន្តការនេះ, រាជរដ្ឋាភិបាលក៏បានបង្កើតឱ្យ មាននូវយន្តការមេធាវីស្ម័គ្រចិត្តផ្សេងៗទៀត ដូចជា ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី, ក្រុម មេធាវីរាជរដ្ឋាភិបាល, ក្រុមមេធាវីស្ម័គ្រចិត្តសម្តេចតេជោសែន ព្រម ទាំងយន្តការនៃការផ្តល់ សេវាមេធាវីដោយឥតគិតកម្រៃជូនដល់ជនក្រីក្ររបស់ គណៈមេធាវីនៃព្រះរាជាណាចក្រ កម្ពុជាផងដែរ។

ឆ. ការពង្រឹងប្រសិទ្ធភាពនៃយន្តការត្រួតពិនិត្យ

«**វិរិយសម្បយុត្ត, សុចរិតយុត្តិធម៌, បញ្ញាត្តិការ៉ា, សមទណ្ឌា និងបញ្ញារុធនិច្ឆ័យ** » និង «**កុំលុះដោយៈ ឆន្ទាគតិ, ទោសាគតិ, ភយាគតិ និងមហាគតិ** » ត្រូវបានចារឹកទុក នៅលើជញ្ជាំងអាគារកណ្តាលនៃក្រសួងយុត្តិធម៌ ដែលជាអតីតសាលាវិនិច្ឆ័យរបស់កម្ពុជា ដែលបានកសាងនៅឆ្នាំ ១៩២៥។ កម្រងអក្សរទាំងពីរផ្នាំងនេះ ត្រូវបានមន្ត្រីដែលធ្លាប់ និងកំពុងបំពេញការងារវិស័យយុត្តិធម៌បា មនប្រកាន់ថា ក្រមសីលធម៌របស់ចៅក្រម ដែល ត្រូវបានប្រើប្រាសតាំងពីសម័យបុរាណមក។ សម្រាប់ បច្ចុប្បន្ននេះ ចៅក្រម និងព្រះរាជ អាជ្ញា មានក្រមសីលធម៌របស់ខ្លួន ដែលត្រូវបានព្រះមហាក្សត្រឡាយព្រះ ហស ដាក់ឲ្យ ប្រើប្រាស់កាលពីថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០០៧ ក្នុងគោលបំណងពង្រឹងនូវឯករាជភាព និងសេ ចក្តីថ្លៃថ្នូរបស់ចៅក្រមទាំងអស់ ក្នុងការអនុវត្តកិច្ចការរបស់ស្ថាប័ន ក៏ដូចជា ឥរិយា បទផ្ទាល់ខ្លួននៅក្រៅស្ថា ប័នផងដែរ។ ក្រមសីលធម៌នេះ មានប្រភពចេញពីកម្រងអក្សរ ទាំងពីរផ្នាំងដូចរៀបរាប់ខាងលើ និងក៏មាន អនុឡោមតាមគោលការណ៍នៃក្រមសីលធម៌

ចៅក្រមអន្តរជាតិផងដែរ ជាពិសេស យោងតាមក្រមសីលធម៌ចៅក្រម Bangalor ដែល ក្នុងនោះមានដូចជា «គោលការណ៍ឯករាជភាព, អនាគតិ, សុចរិតភាព, សេចក្តីថ្លៃថ្នូ និង វិរិយភាព» ។

ក៏ពីការប្រកាន់ខ្ជាប់នូវក្រមសីលធម៌វិជ្ជាជីវៈដូចខាងលើ ក្នុងគោលដៅលើកកំពស់វិន័យការងារ ក្រមសីលធម៌ និងសេចក្តីថ្លៃថ្នូរបស់ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី និង មន្ត្រីពាក់ព័ន្ធផងដែរ គឺទាមទារឲ្យ មានជាការត្រួតពិនិត្យ និងវាយតម្លៃបន្ថែមទៀតពីខាងក្រៅ ដែលអនុវត្តាតាមយន្តការអធិការ កិច្ច ជាដើម ដែលបច្ចុប្បន្នយន្តការអធិការកិច្ចទាំងផ្នែករដ្ឋបាល ក្រោមឱវាទក្រសួងយុត្តធម៌ និងយន្តការអធិការកិច្ច ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមត្រូវបានពង្រឹងជាបន្តបន្ទាប់ និងធ្វើសកម្មភាពយ៉ាងសកម្ម។

៩. ការដាក់ឲ្យដំណើរការ និងការលើកកំពស់ការដោះស្រាយវិវាទ ក្រៅប្រព័ន្ធតុលាការ

យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការក្នុងវិស័យនានា ជាពិសេសវិស័យពាណិជ្ជកម្ម, វិស័យ ការងារ, វិស័យដីធ្លី ត្រូវបានដាក់ឱ្យដំណើរការ និងទទួលបានការគាំទ្រជាបន្តបន្ទាប់។ ទន្ទឹមនេះ,អាជ្ញាធរ ជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ត្រូវបានបង្កើតឡើងកាលពីថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ដែល ជាយន្តការដោះស្រាយវិវាទថ្មីមួយបន្ថែមលើយន្តការដោះស្រាយវិវាទដែលមានស្រាប់នៅកម្ពុជាសំដៅកាត់ បន្ថយការកកស្ទះសំណុំរឿងនៅតាមតុលាការ,បង្កើតយន្តការដោះស្រាយវិវាទឱ្យកៀកប្រជាជន និងធានា បាននូវភាពសុខដុមរមនានៅក្នុងសហគមន៍ និងមូលដ្ឋាន។

ឈ. យុទ្ធនាការពន្លឿនការដោះស្រាយរឿងក្តី

ដើម្បីបង្កើនប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាយុត្តិធម៌របស់ស្ថាប័នតុលាការ និងដំរុញការ ផ្តល់សេវាយុត្តិធម៌ជូនប្រជាពលរដ្ឋឱ្យបានឆាប់រហ័ស និងត្រឹមត្រូវ គឺយុទ្ធនាការដោះស្រាយការកកស្ទះ សំណុំរឿងព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្តនៅឆ្នាំ២០២០ ទទួលបានលទ្ធផលប្រកប ដោយ ភាពជោគជ័យដ៏ត្រចះត្រចង់តាមការរំពឹងទុក ជាលទ្ធផលសរុបនៃយុទ្ធនាការនេះ សាលាដំបូងរាជធានី-ខេត្តទូទាំងប្រទេស នៅគ្រប់តំណាក់កាលនៃនីតិវិធី ដោះស្រាយសំណុំរឿងសរុបបានជាង ៣៧ ៩០០ សំណុំរឿង ស្មើនឹង ៩៦% នៃសំណុំរឿងព្រហ្មទណ្ឌដែលបានកកស្ទះសរុបជាង ៣៩ ៥០០ សំណុំរឿង និងបាន ដោះស្រាយសំណុំរឿងព្រហ្មទណ្ឌដែលចូលថ្មីចំនួនជាង ៦២ ៨០០ សំណុំរឿងស្មើនឹង ៧៨% នៃចំនួន សំណុំរឿងចូលថ្មីសរុបជាង ៨០ ៤០០សំណុំរឿង។

ស្របជាមួយគ្នានេះយុទ្ធនាការក៏បានចូលរួមចំណែក កាត់បន្ថយភាពចង្អៀតណែនអ្នកជាបឃុំ បានប្រមាណសរុប ៣៩ ៣១០នាក់។

១.១.៣. បញ្ហាប្រឈម

ទន្ទឹមនឹងសមិទ្ធផល និងជោគជ័យខាងលើ ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅជួបប្រទះ បញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលធ្វើឱ្យការពង្រឹងការអនុវត្តច្បាប់និងការផ្តល់សេវាយុត្តិធម៌ នៅមិន ទាន់ទទួលបានជំនឿទុកចិត្តទាំងស្រុងពីសំណាក់មហាជនដែលបញ្ហាប្រឈមទាំងនោះរួមមានជាអាទិ៍៖

- សមត្ថភាពស្ថាប័ននិងធនធានមនុស្សក្នុងវិស័យយុត្តិធម៌នៅមានកម្រិត ហើយមិនទាន់ឆ្លើយតបបាន ទាំងស្រុងទៅនឹងតម្រូវការការងារនិងចំនួននៃសំណុំរឿងដែលកើនឡើងជាលំដាប់ជារៀងរាល់ឆ្នាំ។
- ការយល់ដឹងអំពីច្បាប់នៅមានកម្រិតដែលធ្វើឱ្យប៉ះពាល់ដល់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងការ ចូលរួមគោរពច្បាប់ពីសាធារណជន។
- សមត្ថភាពឆ្លើយតបក្នុងការផ្តល់សេវាកម្មច្បាប់ និងជំនួយផ្នែកច្បាប់នៅមានកម្រិត,
- ការកសាងក្របខណ្ឌច្បាប់ នៅមិនទាន់គ្រប់ជ្រុងជ្រោយ ហើយក្របខណ្ឌច្បាប់ចាំបាច់មួយចំនួនលែង ឆ្លើយតបទៅនឹងស្ថានភាពវិវត្តជាក់ស្តែងរបស់សង្គម-សេដ្ឋកិច្ច និង
- ការពង្រឹងយន្តការវិនិយការងារ និងការពង្រឹងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីក្នុងការអនុវត្តច្បាប់នៅ មានកម្រិត។

១.២. ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ របស់រាជរដ្ឋាភិបាល នីតិកាលទី ៧ នៃរដ្ឋសភា

១.២.១. សាថតា

រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ «យុទ្ធសាស្ត្រ បញ្ចកោណ» ដំណាក់កាលទី១ ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច, បង្កើតការងារ, ធានាសមធម៌, បង្កើន ប្រសិទ្ធភាព និងរក្សាចីរភាព ដែលមានបាវចនា « **កំណើន, ការងារ, សមធម៌, ប្រសិទ្ធភាព និងចីរភាព** »។ ចំពោះវិស័

យច្បាប់ និងយុត្តិធម៌ រាជរដ្ឋាភិបាលនៅតែបន្តចាត់ទុក "ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" គឺ ជាសកម្មភាពដ៏សំខាសន់ និងអាទិភាពមួយដ៏សំខាន់ និងត្រូវបានរៀបចំដាក់បញ្ចូលជាមុំមួយដ៏សំខាន់ក្នុង ចំណោមមុំទាំង៥ ដែលជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅ ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌នៅកម្ពុជា។

ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានឈានដល់ដំណាក់កាល"ប្រែប្រួលថ្មី" ដែលនឹងផ្តោតការ យកចិត្តទុកដាក់ខ្ពស់លើ "ប្រសិទ្ធភាពនៃសមិទ្ធកម្ម" សំដៅពង្រឹង និងលើកកម្ពស់ទាំងគុណភាព និងប្រសិទ្ធ ភាពនៃច្បាប់, ទាំងគុណភាព និងប្រសិទ្ធភាពនៃសេវាយុត្តិធម៌ និងទាំងគុណភាពនៃយុត្តិធម៌ដើម្បីអាចឆ្លើយ តបបានប្រកបដោយប្រសិទ្ធភាពខ្ពស់ចំពោះក្តីរំពឹងទុក សេចក្តីត្រូវការ និងបំណងប្រាថ្នាដ៏ពិសិដ្ឋរបស់ប្រជាពលរដ្ឋក្នុងសង្គមនីតិរដ្ឋ និងសង្គមដែលមានសន្តិភាពពេញបរិបូរណ៌និង ម្យ៉ាងទៀតដើម្បីរួមចំណែកក្នុងការ សម្រេចឱ្យបាននូវ "ចក្ខុវិស័យកម្ពុជាឆ្នាំ ២០៥០" ក្នុងការកសាងជាតិមួយឱ្យរឹងមាំ រស់រវើក រុងរឿងនិងមាន វិបុលភាព ឱ្យក្លាយជាប្រទេសមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០។

ផ្អែកតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល, រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា នៅតែបន្តចាត់ទុក "ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ជា អាទិភាពមួយដ៏សំខាន់របស់ខ្លួន សំដៅពង្រឹង និងលើកកម្ពស់ "នីតិរដ្ឋ"នៅកម្ពុជា ដែលជាមូលដ្ឋានដ៏សំខាន់ក្នុងការធានាថែរក្សាស្ថិរភាព សង្គម សន្តិសុខនិងសណ្តាប់ធ្នាប់សាធារណៈ, ការលើកកម្ពស់ការគោរពសិទ្ធិមនុស្ស និងការពង្រឹង "យុត្តិធម៌នៅក្នុងសង្គមជាតិ" ដែលជាគ្រឹះសម្រាប់ភាពសុខសាន្តរបស់ប្រជាជន និងការអភិវឌ្ឍប្រទេសជាតិ ប្រកបដោយចីរភាព។ "ការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌" ត្រូវបានរៀបចំបញ្ចូលជាមុំមួយដ៏សំខាន់ក្នុង ចំណោមមុំទាំង៥ដែលបង្កើតបានជាស្នូលនៃយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅ "ពង្រឹង និងលើកកម្ពស់ប្រសិទ្ធភាពនៃច្បាប់ និងប្រព័ន្ធយុត្តិធម៌"នៅកម្ពុជា។ ដើម្បីសម្រេចឱ្យបាននូវ គោលដៅយុទ្ធសាស្ត្រនៃមុំទី៤ នេះ រាជរដ្ឋាភិបាលបានដាក់ចេញនូវគោលដៅជា អាទិភាពចំនួន៦ រួមមាន:

(ទី១)-ការលើកកម្ពស់សមត្ថភាពធនធានមនុស្សក្នុងវិស័យយុត្តិធម៌, ទាំងបរិមាណ និងគុណភាព, ដើម្បីបង្កើនប្រសិទ្ធភាពការងារក្នុងវិស័យយុត្តិធម៌ និង

ប្រសិទ្ធភាព និងភាពរហ័សនៃការដោះស្រាយវិវាទ ទាំង ក្នុងប្រព័ន្ធតុលាការ ទាំងក្រៅប្រព័ន្ធតុលាការ។

(ទី២)-ការលើកកម្ពស់ប្រសិទ្ធភាព, សង្គតិភាព និងអនុលោមភាពគតិយុត្តិនៃការរៀបចំច្បាប់ និង លិខិតបទដ្ឋានគតិយុត្តសំដៅធានាឆ្លើយតបបានទៅនឹងចក្ខុវិស័យ និងសេចក្តីត្រូវការនានារបស់សង្គមជាតិ។

(ទី៣)-ការលើកកម្ពស់ការគោរពច្បាប់ និងការផ្តល់សេវាជំនួយផ្នែកច្បាប់តាមរយៈការបន្តជំរុញការ អប់រំ និងផ្សព្វផ្សាយច្បាប់, ការផ្តល់ការពិគ្រោះយោបល់ផ្នែកច្បាប់ និងការផ្តល់ការការពារក្តីនៅចំពោះមុខ តុលាការ សំដៅធានាសិទ្ធិទទួលបានយុត្តិធម៌ ជាពិសេសសម្រាប់ប្រជាពលរដ្ឋ ក្រីក្រ និងជនងាយរងគ្រោះ។

(ទី៤)-ការលើកកម្ពស់ភាពត្រឹមត្រូវ និងប្រសិទ្ធភាពនៃការអនុវត្តច្បាប់ពីសំណាក់មន្ត្រីអនុវត្តច្បាប់ និងមន្ត្រីតុលាការ ជាពិសេសការពង្រឹងប្រសិទ្ធភាពនៃចំណាត់ការលើសំណុំរឿង, ការពង្រឹងភាពសុចរិត ភាព ស្អាតស្អំ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីអនុវត្តច្បាប់និងមន្ត្រីតុលាការ ព្រមទាំងការពង្រឹងយន្តការអធិការកិច្ច និងការដាក់វិន័យសំដៅ ពង្រឹងជំនឿទុកចិត្តលើការអនុវត្តច្បាប់។

(ទី៥)-ការលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធតុលាការ តាមរយៈការបន្តធ្វើទំនើបកម្ម រដ្ឋបាលតុលាការ ដើម្បីលើកកម្ពស់គុណភាពនៃការផ្តល់សេវាយុត្តិធម៌ឱ្យកាន់តែប្រសើរ និងការពង្រឹងគុណ ភាពនៃយុត្តិធម៌។

(ទី៦)-ការជំរុញរៀបចំក្របខ័ណ្ឌគតិយុត្ត និងយន្តការសម្រុះសម្រួល និងផ្សះផ្សាវិវាទ ទាំងក្នុងប្រព័ន្ធ តុលាការ ទាំងក្រៅប្រព័ន្ធតុលាការសំដៅលើកកម្ពស់ប្រសិទ្ធភាព និងភាពរហ័សនៃការដោះស្រាយវិវាទ និង បង្កើតសេវានៃការ ដោះស្រាយវិវាទឱ្យកៀកនឹងប្រជាពលរដ្ឋ។

២. ២. អំពីយន្តការនៃដឹកនាំការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តធម៌

សម្រាប់នីតិកាលទី៧ នៃរដ្ឋសភានេះដើម្បីធានានិរន្តភាព និងលើកកម្ពស់ប្រសិទ្ធភាពនៃការកែ ទម្រង់ច្បាប់ និងការកែទម្រង់ប្រព័ន្ធយុត្តិធម៌, រាជរដ្ឋាភិបាលកម្ពុជាបានសម្រេចបំបែកការងារកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ជា២ ដាច់ដោយឡែកពីគ្នាគឺ "ការកែទម្រង់ច្បាប់" និង "ការទម្រង់ប្រព័ន្ធយុត្តិធម៌" ហើយ បានរំលាយគណៈកម្មាធិការ

ដឹកនាំការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌នេះ ដោយបង្កើតជាយន្តការទទួល បន្ទុក ចំនួន២ គឺ៖

(ទី១) "គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌" ដែលដឹកនាំដោយ រដ្ឋមន្ត្រីក្រសួង យុត្តិធម៌ និងប្រធានតុលាការកំពូល ជាសហប្រធាន ដើម្បីជាយន្តការ ទទួលបន្ទុកលើ "ការទម្រង់ប្រព័ន្ធ យុត្តិធម៌" និង

(ទី២)-"គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់" ដែលដឹកនាំដោយរដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការ គណៈរដ្ឋមន្ត្រី ដើម្បីជាយន្តការទទួលបន្ទុកលើ "ការកែទម្រង់ច្បាប់" ។

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ត្រូវបានបង្កើតឡើងដោយ ព្រះរាជក្រឹត្យលេខ នស/រកត/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈកម្មាធិការ ដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ។ ដោយឡែក គ ណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវបានបង្កើត ឡើងដោយព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/១៥០ចុះថ្ងៃទី ០៣ ខែកុម្ភៈឆ្នាំ២០២៤ ស្តីពីការបង្កើតគ ណៈកម្មាធិ ការដឹកនាំការកែទម្រង់ច្បាប់ដើម្បីជាយន្តការដឹកនាំ សម្របសម្រួល និងជំរុញការអនុវត្ត ការងារ កែទម្រង់ច្បាប់ស្របតាមកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលបំណង ដើម្បីពង្រឹង និងលើក កម្ពស់គោលការណ៍នីតិរដ្ឋសន្តិសុខគតិយុត្តព្រមទាំងគុណភាព និងប្រសិទ្ធភាពនៃច្បាប់។

ក. យន្តការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តធម៌

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានចាប់ផ្តើមដំណើរការកិច្ច ប្រជុំលើកទី១ របស់ខ្លួននៅថ្ងៃទី ០៦ ខែមីនាឆ្នាំ២០២៤ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ ឯកឧត្តម កើត រិទ្ធ ឧបនាយករដ្ឋ មន្ត្រីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និង ឯកឧត្តមបណ្ឌិត ជីវ កេង ប្រធានតុលាការកំពូល ជាសហប្រធាន[៨៣៥]។ គណ កម្មាធិការនេះ គឺជាយន្តការ ដឹកនាំសម្របសម្រួល និងជំរុញការអនុវត្តការងារកែទម្រង់ប្រព័ន្ធយុត្តិធម៌ស្រប តាមកម្ម វិធីនយោបាយរបស់រាជរដ្ឋាភិបាល សំដៅពង្រឹង និងលើកកម្ពស់គោលការណ៍នីតិរដ្ឋព្រម ទាំងគុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌នៅព្រះរាជាណាចក្រកម្ពុជា។ បេសកកម្ម

[៨៣៥] ព្រះរាជក្រឹត្យលេខ នស/រកត/២៦៨២ ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២៣។

របស់គណៈកម្មាធិការ ដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌នឹងផ្តោតសំខាន់លើ"ការកែទម្រង់ច្បាប់ក្នុងវិស័យយុត្តិធម៌" និង "ការកែ ទម្រង់ប្រព័ន្ធយុត្តិធម៌"។

ខ. បេសកកម្មដឹកនាំ និងការអនុវត្តយុទ្ធសាស្ត្រកំណែទម្រង់ប្រព័ន្ធយុត្តធម៌

ទន្ទឹមនឹងការប្រកាសដាក់ឱ្យអនុវត្តយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នៅក្នុងកិច្ចប្រជុំពេញអង្គគណៈរដ្ឋមន្ត្រីលើកទី១ កាលពីថ្ងៃទី២៤ ខែសីហា ឆ្នាំ២០២៣, **សម្តេចធិបតី នាយករដ្ឋមន្ត្រី** ក៏បានប្រកាសដាក់ចេញនូវវិធានការគន្លឹះចំនួន៥ ដែលជាកិច្ចការអាទិភាពដ៏សំខាន់របស់ រាជរដ្ឋាភិបាលដែលត្រូវសម្រេចឱ្យចេញជាលទ្ធផលជាក់ស្តែងក្នុងនីតិកាលទី៧ នេះ។ ក្នុងចំណោមវិធានការ គន្លឹះទាំង៥ នេះ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានប្រកាសយក "ការពង្រឹង និងលើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃប្រព័ន្ធយុត្តិធម៌" ជាវិធានការគន្លឹះទី៥ ហើយ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** បានប្រគល់ភារកិច្ចឱ្យក្រសួងយុត្តិធម៌ ដើម្បីរៀបចំផែនការសកម្មភាពជាក់ស្តែងសំដៅធ្វើយ៉ាងណាសម្រេចឱ្យបាន នូវកិច្ចការអាទិភាពសំខាន់ចំនួន ៣ នៃវិធានការគន្លឹះទី៥ នេះ ដែលកិច្ចការអាទិភាពទាំង៣នេះ រួមមាន៖

(ទី១)-ការបង្កើតយន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ បន្ថែមលើយន្តការ ដែលមានស្រាប់ ដើម្បីជួយសម្រុះសម្រួលដោះស្រាយវិវាទឱ្យបានឆាប់រហ័សជាពិសេសវិវាទរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន។

(ទី២)-ការជំរុញ និងពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការឱ្យបានឆាប់រហ័ស សំដៅ លើកកម្ពស់គុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាយុត្តិធម៌ជូនប្រជាជន និង

(ទី៣)-ការត្រួតពិនិត្យ និងដោះស្រាយភាពមិនប្រក្រតីនៅតាមតុលាការ សំដៅជួយដោះស្រាយ រកយុត្តិធម៌ជូនប្រជាពលរដ្ឋ ក៏ដូចជាលើកកម្ពស់តម្លាភាព សុចរិតភាព និងភាពត្រឹមត្រូវនៅក្នុងការអនុវត្ត ច្បាប់ និងចំណាត់ការរឿងក្តីដោយតុលាការ។

ផ្អែកតាម "យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ និង "វិធានការគន្លឹះទី៥ ខាងលើនេះ, ជា ទិសដៅការងារទៅមុខ, ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ នឹងត្រូវប្រមូលផ្តុំការយកចិត្តទុកដាក់ទៅលើ "សសរ ស្តម្ភ" សំខាន់ចំនួន ២ គឺ៖

(សសរស្តម្ភទី១)-គឺការកែទម្រង់ប្រព័ន្ធតុលាការ សំដៅខិតខំធ្វើឱ្យប្រសើរឡើងជាលំដាប់ជាបន្ត ទៀតនូវគុណភាព និងប្រសិទ្ធភាពទាំងលើការផ្តល់ "សេវាយុត្តិធម៌"

ប្រកបដោយភាពឆាប់រហ័សទាំង លើ"គុណភាពនៃយុត្តិធម៌" ប្រកបដោយភាពសុក្រឹតនិង ភាពត្រឹមត្រូវ និង

(សសរស្តម្ភទី២)-គឺការកែទម្រង់ប្រព័ន្ធដោះស្រាយវិវាទនៅកម្ពុជា ជា តាមរយៈការបង្កើតយន្តការ សំដៅបង្ហិតសេវានៃការដោះស្រាយវិវាទដែលមានលក្ខណៈងាយ ដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ស្រួល និងសម្បូរបែបឱ្យទៅជិតប្រជាពលរដ្ឋនៅមូលដ្ឋាន , ជួយសម្រុះសម្រួល ផ្សះផ្សាដោះស្រាយបញ្ចប់វិវាទឱ្យបានឆាប់រហ័សជូនប្រជាពលរដ្ឋ ព្រមទាំងរួមចំណែកលើកកម្ពស់វប្បធម៌សន្តិភាពនិយមក្នុងសង្គម កម្ពុជា។

ការអនុវត្តជាក់ស្តែងយុត្តិសាស្ត្រកំណែទម្រង់ដោយផ្អែកលើសសរស្តម្ភទាំងពីរ ខាងលើនេះ រួមមាន សកម្មភាពដូចខាងក្រោម:

- ក្រសួងយុត្តិធម៌បានដាក់ចេញនូវយុទ្ធនាការចំនួន ២ ដែលក្នុងនោះ ទី ១. យុទ្ធនាការជំរុញ និង ពន្លឿនការដោះស្រាយរឿងក្តីនៅតាមតុលាការ និងទី២ យុទ្ធនាការត្រួតពិនិត្យ និងដោះស្រាយភាសពមិន ប្រក្រតីនៅតាមតុលាការ ។
- ការដាក់ឲ្យដំណើរការជាផ្លូវការនូវអាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ (អ.ដ.ក) តាមព្រះរាជក្រឹត្យលេខ នស/រកត/១១២៣/២៣៨១ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ២០២៣ ស្តីពីការបង្កើត ការ រៀបចំ និងកិច្ចដំណើរការរបស់អាជ្ញាធរជាតិដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ។

ការអនុវត្តយុទ្ធនាការទាំងពីរខាងលើនេះ ស្តែងឲ្យឃើញលទ្ធផល គួរជាទីមោទន: ។

គណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ បានឯកភាពគាំទ្រយ៉ាងពេញលេញចំពោះ យុទ្ធនាការសំខាន់ទាំង២ដែលត្រូវបានប្រកាសដាក់ចេញដោយក្រសួងយុត្តិធម៌ កាលពីថ្ងៃទី ៩ ខែមករា ឆ្នាំ ២០២៤ កន្លងទៅ។ ទន្ទឹមនេះ ដោយពិនិត្យឃើញថាយុទ្ធសាស្ត្រនិងកម្មវិធីសកម្មភាពជាច្រើនសម្រាប់អនុ វត្តយុទ្ធសាស្ត្រកែទម្រង់ច្បាប់ និងតុលាការ ដែលត្រូវបានដាក់ចេញតាំងពីឆ្នាំ ២០០៣ និង ២០០៥ ត្រូវ បានអនុវត្ត ប្រកបដោយជោគជ័យ ប៉ុន្តឯកសារ "ការកែទម្រង់ច្បាប់ និងតុលាការ" និងឯកសារ "កម្មវិធី សកម្មភាពសម្រាប់អនុវត្តយុទ្ធសាស្ត្រ កំណែទម្រង់ច្បាប់ និងតុលាការ" មិនធ្លាប់ត្រូវ បានធ្វើបច្ចុប្បន្នភាព ដើម្បីឆ្លុះ បញ្ចាំងពីសមិទ្ធផលការងារដែលសម្រេចបាននិងឱ្យស្រប តាមបរិការណ៍នៃតម្រូវការជាក់ ស្តែង បច្ចុប្បន្នរបស់សង្គម-សេដ្ឋកិច្ច និងបរិការណ៍នៃឱដីថលូបនីយកម្មនៅឡើយទនិងជាពិសេសដើម្បីបង្កើន ល្បឿន នៃការកទម្រងវិស័យ

យុត្តិធម៌ឱ្យកាន់តែសកម្មម៉ឺងម៉ាត់ និងមុតស្រួចឆ្លើយតបបានទៅនឹងស្ថានភាព វិវត្តផ្នែកសង្គម-សេដ្ឋកិច្ច និងបច្ចេកវិទ្យា ស្របតាមទិសដៅដែលបានកំណត់នៅក្នុងយុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល នីតិកាលទី៧ នៃរដ្ឋសភា ព្រមទាំងម្បីរួមចំណែកក្នុងការសម្រេចឱ្យ បាននូវ "ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០" ក្នុងការប្រែក្លាយខ្លួនជាប្រទេសដែលមានចំណូលខ្ពស់នៅត្រឹមឆ្នាំ ២០៥០, គណៈកម្មាធិការដឹកនាំការ កែទម្រង់ប្រព័ន្ធយុត្តិធម៌ក៏បានសម្រេចឱ្យមានការរៀបចំឡើងនូវ ផែនការយុទ្ធសាស្ត្រកែទម្រង់ប្រព័ន្ធយុត្តិធម៌រយៈពេល ១០ឆ្នាំ ដោយប្រគល់ការកិច្ចជូនអគ្គលេខាធិការនៃ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ដើម្បីដឹកនាំរៀបចំសេចក្តីព្រាង ផែនការយុទ្ធសាស្ត្រនេះ។

បទបង្ហាញ៖ ស្តីពីទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា





មាតិកា

01 សាថតា


02 ចំណោទបញ្ហា និងសំណួរស្រាវជ្រាវ

03 តាពពេញ្ញលេញ្ញនៃ ក្របខ័ណ្ឌយុទ្ធសាស្ត្រ

04 ទស្សនទានៃប្រព័ន្ធច្បាប់

05 ការវិភាគអំពីស្ថានភាពប្រព័ន្ធច្បាប់ កម្ពុជា និងការសិក្សាប្រៀបធៀប

06 ទិសដៅឆ្ពោះទៅរកបូរណភាព នៃប្រព័ន្ធច្បាប់កម្ពុជា


គណៈកម្មាធិការដឹកនាំការកែចម្រូចច្បាប់
៣
សាវតា
ចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០
យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១
ក្របខ័ណ្ឌយុទ្ធសាស្ត្រ នៃកម្មវិធីកែទម្រង់ច្បាប់ របស់រាជរដ្ឋាភិបាល
កសាងរដ្ឋមួយដែលរឹងមាំ
២០៥០
ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព
២០២៨
កសាងបូរណភាព នៃប្រព័ន្ធច្បាប់
២០៤៥
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា
3


គណៈកម្មាធិការដឹកនាំការកែចម្រូចច្បាប់
៤
ចំណោទបញ្ហា និងសំណួរស្រាវជ្រាវ
សំណួរស្រាវជ្រាវទី១
តើអ្វីជាទស្សនាទាន/ទ្រឹស្តីនៃធាតុផ្សំ របស់ប្រព័ន្ធច្បាប់?
សំណួរស្រាវជ្រាវទី២
តើប្រព័ន្ធច្បាប់អាចក្លាយជាឆ្អឹងខ្នងនៃ ការកសាងរដ្ឋដោយរបៀបណា?
ចំណោទបញ្ហា
ធ្វើយ៉ាងណាដើម្បីកសាងប្រព័ន្ធ ច្បាប់ដែលមានបូរណភាព និងជា ឆ្អឹងខ្នងនៃការកសាងរដ្ឋ?
សំណួរស្រាវជ្រាវទី៣
តើប្រព័ន្ធច្បាប់កម្ពុជាមានស្ថានភាព បែបណា?
សំណួរស្រាវជ្រាវទី៤
តើវិធានការអ្វីខ្លះចាំបាច់សម្រាប់ កសាងបូរណភាពនៃប្រព័ន្ធច្បាប់ដើម្បី សម្រេចយុទ្ធសាស្ត្របញ្ចកោណ និង ចក្ខុវិស័យកម្ពុជា ២០៥០?
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា
4

ភាពពេញលេញនៃក្របខ័ណ្ឌយុទ្ធសាស្ត្រ



រៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា

ក្របខ័ណ្ឌរៀបចំឡើងដោយផ្អែកលើវដ្តនៃច្បាប់

ប៉ុន្តែក្របខ័ណ្ឌយុទ្ធសាស្ត្រនេះពុំបានរៀបរាប់អំពីធាតុផ្សំនៃប្រព័ន្ធច្បាប់


ក្របខ័ណ្ឌយុទ្ធសាស្ត្រនេះពុំមានយន្តការផ្សាភ្ជាប់ជាមួយនឹងចក្ខុវិស័យនៃការកសាងរដ្ឋ



ទស្សនាទានទ្រឹស្តីនៃប្រព័ន្ធច្បាប់

John Austin | ១៨៣២	
អំណាចកំពូល (Sovereign)	បុគ្គលដែលមានអំណាចកំពូលនៅក្នុងសង្គម។
បទបញ្ជា (Commands)	បទបញ្ជាទូទៅដែលចេញដោយបុគ្គលដែលមានអំណាចកំពូល។
កាតព្វកិច្ច និងការប្រតិបត្តិជាប្រចាំ	សាធារណៈជនគោរពអនុវត្តតាមបទបញ្ជាជាប្រចាំ។
ទណ្ឌកម្ម (Sanctions)	យន្តការដើម្បីធានាការអនុវត្តបទបញ្ជា
ច្បាប់វិជ្ជមាន (Positive law)	ច្បាប់ គឺជាបទបញ្ជារបស់បុគ្គលមានអំណាចកំពូល ដែលមានទណ្ឌកម្មដើម្បីធានាឱ្យមានការអនុវត្តតាម។

Hans Kelsen | ១៩៣៤	
ច្បាប់ជាបណ្តុំនិយាម (Norms) មានលំដាប់ថ្នាក់	បទបញ្ជាជាន់ទាបត្រូវអនុលោមតាមបទបញ្ជាខ្ពស់ជាង។
Grundnorm (និយាមកំពូល)	ជាបទបញ្ជាដែលសន្មត់ថាជាប្រភពសុពលភាពចុងក្រោយបំផុត។
Dynamic authorization (ប្រតិភូកម្ម)	បទបញ្ជាដែលផ្តល់សមត្ថកិច្ចឱ្យអាជ្ញាធរបង្កើតច្បាប់។
Coercive order (បទបញ្ជាដែលមានលក្ខណៈបង្ខំ)	ច្បាប់រៀបចំទណ្ឌកម្មឱ្យមានរចនាសម្ព័ន្ធច្បាស់លាស់។
Efficacy condition (លក្ខខណ្ឌប្រសិទ្ធភាព)	ច្បាប់មានសុពលភាពនៅពេលច្បាប់នោះត្រូវបានអនុវត្ត។


H.L.A. Hart | ១៩៦១
វិធានគោល (Primary rules) | កំណត់អំពីកាតព្វកិច្ចរបស់ប្រជាពលរដ្ឋ។
វិធានបន្ទាប់បន្សំ (Secondary rules) | កំណត់អំពីដំណើរការប្រព្រឹត្តទៅរបស់ប្រព័ន្ធច្បាប់។
វិធាននៃការទទួលស្គាល់ (Rule of Recognition) | កំណត់អំពីសុពលភាពនៃច្បាប់។
វិធាននៃការកែប្រែ (Rule of change) | កំណត់អំពីការបង្កើតនិងវិសោធនកម្មច្បាប់។
វិធានដោះស្រាយវិវាទ (Rule of Adjudication) | កំណត់អំពីការដោះស្រាយវិវាទស្របតាមច្បាប់។
Lawrence M. Friedman | ១៩៣២
រចនាសម្ព័ន្ធគតិយុត្ត (Structure) | ស្ថាប័ន, និងបុគ្គលប្រកបវិជ្ជាជីវៈក្នុងប្រព័ន្ធច្បាប់ (តុលាការ, នគរបាល, ក្រសួង, វិជ្ជាជីវៈ)។
សារធាតុគតិយុត្ត (Substance) | វិធាន, គោលការណ៍ច្បាប់, និងសេចក្តីសម្រេច។
វប្បធម៌គោរពច្បាប់ (Culture) | ឥរិយាបទ និងជំនឿរបស់សាធារណៈជន និងអ្នកអនុវត្តច្បាប់
Joseph Raz | ១៩៧៩
រចនាសម្ព័ន្ធស្ថាប័ន (Institutional structure) | តុលាការ, អង្គនីតិបញ្ញត្តិ, អង្គនីតិប្រតិបត្តិ ដែលបង្កើត/អនុវត្តបទដ្ឋាន។
ប្រភព (Sources) | អ្វីដែលចាត់ទុកថាជាច្បាប់ អាស្រ័យលើប្រភពសង្គម (ប្រវត្តិដើម), មិនមែនគុណតម្លៃសីលធម៌ទេ។
អំណាចច្បាប់ (Claim to authority) | ច្បាប់ត្រូវបានសន្មតថាណែនាំអ្នកនៅក្រោមបង្គាប់ប្រសើជាងបុគ្គលទាំងនោះណែនាំខ្លួនឯង។
ភាពជាប្រព័ន្ធ និងឧត្តមានុភាព (Systemicity & supremacy) | ប្រព័ន្ធមួយឯកភាព ដែលមានស្ថាប័នកំពូល និងក្រោមបង្គាប់ ព្រមទាំងដៃនយុត្តាធិការ។
ប្រសិទ្ធភាព និងការទទួលយក (Efficacy & acceptance) | ប្រព័ន្ធច្បាប់មួយមានអត្ថិភាព លុះត្រាតែស្ថាប័នដំណើរការ ហើយបទដ្ឋានត្រូវបានអនុវត្តតាមយ៉ាងទូលំទូលាយ។
7


គណៈកម្មាធិការដឹកនាំការកែចម្រូចច្បាប់
៨
ឆាតុផ្សំនៃប្រព័ន្ធច្បាប់
John Austin
Hans Kelsen
H.L.A. Hart
Joseph Raz
Lawrence Friedman
រចនាសម្ព័ន្ធគតិយុត្ត (Structure)
សារធាតុគតិយុត្ត (Substance)
វប្បធម៌គោរពច្បាប់ (Culture)
Friedman យល់ឃើញថាច្បាប់ជាប្រព័ន្ធសង្គមរស់ ហើយវិធីសាស្ត្រនេះអនុញ្ញាតឱ្យវាយតម្លៃប្រព័ន្ធ ច្បាប់កម្ពុជា ដោយទូលំទូលាយ មិនត្រឹមជាសំណុំ អត្ថបទឬច្បាប់ប៉ុណ្ណោះទេ ប៉ុន្តែជាប្រព័ន្ធអេកូឡូស៊ី ដែលតភ្ជាប់ជាមួយការគ្រប់គ្រងរដ្ឋការ ការអភិវឌ្ឍន៍ និងការកសាងរដ្ឋ។
ខណៈដែល Austin, Kelsen, Hart និង Raz ផ្តោតភាគច្រើនលើតក្កវិទ្យាខាងក្នុង និងអំណាច ច្បាប់ ទ្រឹស្តីរបស់ Friedman ពិនិត្យពីរបៀបដែល ប្រព័ន្ធច្បាប់ធ្វើអន្តរកម្មជាមួយសង្គម ដែលជា ចំណុចសំខាន់សម្រាប់យល់ដឹងអំពីការវិវត្តប្រព័ន្ធ ច្បាប់កម្ពុជាពីទស្សនៈផ្នែកស្ថាប័ន និងផ្នែកអភិវឌ្ឍន៍។
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា
8


គណៈកម្មាធិការដឹកនាំការកែចម្រូចច្បាប់
៩
ធាតុផ្សំថ្មីនៃប្រព័ន្ធច្បាប់ស្មើបន្ថែមថ្មី
ជាធាតុផ្សំបន្ថែមថ្មី
ដែលជាមូលដ្ឋានកំណត់លក្ខណៈ
ធាតុផ្សំបីខាងក្រោម
មូលដ្ឋានគ្រឹះ
(Foundational Ethos)
រចនាសម្ព័ន្ធគតិយុត្ត
(Structure)
សារធាតុគតិយុត្ត
(Substance)
វប្បធម៌គោរពច្បាប់
(Culture)
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា
9



ធាតុផ្សំនៃប្រព័ន្ធច្បាប់

ធាតុផ្សំនៃប្រព័ន្ធច្បាប់រួមមាន៖

- **មូលដ្ឋានគ្រឹះ** (Foundational Ethos) សំដៅដល់គុណតម្លៃ បរិការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ព្រមទាំងគុណតម្លៃ កាតព្វកិច្ច និងឧត្តមានុវត្តន៍អន្តរជាតិ;
- **រចនាសម្ព័ន្ធគតិយុត្ត** (Structure) សំដៅដល់តួអង្គដំណើរការច្បាប់រួមមាន ស្ថាប័ន និងអ្នកប្រកបវិជ្ជាជីវៈ;
- **សារធាតុគតិយុត្ត** (Substance) សំដៅដល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងអស់; និង
- **វប្បធម៌គោរពច្បាប់** (Culture) សំដៅដល់ការផ្តល់តម្លៃដល់ការគោរពច្បាប់នៅក្នុងការប្រកបវិជ្ជាជីវៈប្រចាំថ្ងៃរបស់អ្នកអនុវត្តច្បាប់ និងការរស់នៅប្រចាំថ្ងៃរបស់សាធារណៈទូទៅ។

ការវិភាគអំពីស្ថានភាពប្រព័ន្ធច្បាប់កម្ពុជា

ធាតុផ្សំ	ចំណុចវិភាគ	របកគំហើញ	ទំនាក់ទំនងជាមួយកម្លាំងចលករទាំង៥	ស្របជាមួយចក្ខុវិស័យ ២០៥០	ស្របជាមួយយុទ្ធសាស្ត្របញ្ចកោណ	សង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រ	ការវាយតម្លៃជារួម
មូលដ្ឋានគ្រឹះ (Foundational Ethos)	គុណតម្លៃជាតិ, គោលការធម្មនុញ្ញ, វប្បធម៌នៃការគ្រប់គ្រង, និយាមអន្តរជាតិ	គុណតម្លៃត្រូវបានចែង ប៉ុន្តែការដាក់អនុវត្តនៅមានកម្រិត, កង្វះឯកភាពទស្សនៈរួមរួម	ផ្តល់ការគាំទ្រជាផ្នែកដល់កម្លាំងបង្រួបបង្រួម និងកម្លាំងគាំពារ	ស្របតាមចក្ខុវិស័យ ២០៥០ ដែលផ្តោតលើមូលធនមនុស្ស និងចីរភាពនៃមូលដ្ឋានគ្រឹះ	មិនទាន់បានអនុវត្តក្នុងប្រតិបត្តិការស្ថានប័ន	មានតែការបញ្ជាក់ដោយន័យប៉ុណ្ណោះ; ខ្វះមូលដ្ឋានគុណសីលធម៌ ឬវប្បធម៌វប្បធម៌គោរពច្បាប់	**មធ្យម; ត្រូវការភាពស៊ីសង្វាក់គ្នានៃនិយាម**
រចនាសម្ព័ន្ធគតិយុត្ត (Structure)	ការរៀបចំស្ថាប័ន ការសម្របសម្រួល សមត្ថភាពស្ថាប័ន និងភាពទទួលខុសត្រូវ	ស្ថានភាពធ្វើការដាច់ឯកឯង និងភារកិច្ចស្ងួនជាន់គ្នា; ភាពមិនស៊ីសង្វាក់គ្នាអន្តរក្រសួង	គាំទ្រដល់កម្លាំងស្ថិរកម្ម និងកម្លាំងកសាង ប៉ុន្តែខ្វះភាពធន់ទ្រាំក្នុងកម្លាំងគាំពារ	ស្របជាផ្នែកតាមចក្ខុវិស័យ ២០៥០ ជាមួយទំនើបកម្មការគ្រប់គ្រងរដ្ឋ	មានទំនាក់ទំនងខ្សោយជាមួយចំណុចគន្លឹះទាំងប្រាំ (មនុស្ស ធ្លុំ ជាដើម)	ប្រមូលផ្តុំលើ LRC ប៉ុន្តែទំនាក់ទំនងសម្រាប់ការអនុវត្តអន្តរក្រសួងនៅមានកម្រិត	**ខ្សោយទៅមធ្យម; ត្រូវការការសម្របសម្រួលជាប្រព័ន្ធ**
សារធាតុគតិយុត្ត (Substance)	គុណភាពច្បាប់ ភាពស៊ីសង្វាក់គ្នា ភាពបត់បែន និងការអនុវត្ត	មានបទប្បញ្ញត្តិសម្បូរបែប ប៉ុន្តែមានគម្លាតស្ងួនជាន់គ្នា និងការអនុវត្តមានកម្រិត	គាំទ្រដល់កម្លាំងស្ថិរកម្ម និងកម្លាំងកសាង; មិនគ្រប់គ្រាន់សម្រាប់កម្លាំងគាំពារ	គាំទ្រដល់ចក្ខុវិស័យ ២០៥០ លើសសរសេដ្ឋកិច្ច និងសង្គម	ស្របគោលបំណង ប៉ុន្តែខ្វះយន្តការធ្វើឱ្យស៊ីសង្វាក់គ្នារបស់គោលនយោបាយ	ជាចំណុចដែលបានផ្តោតសំខាន់ក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រ ប៉ុន្តែការវាយតម្លៃលើប្រសិទ្ធភាពនៅមានកម្រិត	**មធ្យម; ត្រូវការភាពស៊ីសង្វាក់គ្នានៃគោលនយោបាយ និងប្រព័ន្ធត្រួតពិនិត្យ និងវាយតម្លៃ**
វប្បធម៌គោរពច្បាប់ (Culture)	ការយល់ដឹងច្បាប់ រឿងដីរ: សីលធម៌ និងវប្បធម៌គោរពតាមច្បាប់របស់ពលរដ្ឋ	ផ្តោតលើការអនុលោមតាមច្បាប់ ជាងការផ្តែកលើគុណតម្លៃ; ការយល់ដឹងអំពីច្បាប់របស់ពលរដ្ឋនៅមានកម្រិត	ផ្តល់ការគាំទ្រក្នុងកម្រិតទាបសម្រាប់កម្លាំងស្ថិរកម្ម និងកម្លាំងគាំពារ	ស្របតាមចក្ខុវិស័យ ២០៥០ លើផ្នែកសុខដុមរមនាសង្គម ប៉ុន្តែមិនត្រូវបានអនុវត្ត	ពុំមានចែកនៅក្នុងយុទ្ធសាស្ត្របញ្ចកោណ	ការពិចារណាកម្រិតនៅក្នុងក្របខ័ណ្ឌយុត្តិសាស្ត្រ	**ខ្សោយ; ត្រូវការបណ្តុះវប្បធម៌គោរពច្បាប់ឱ្យក្លាយជាប្រព័ន្ធ**

ការវិភាគអំពីស្ថានភាពប្រព័ន្ធច្បាប់កម្ពុជា (តចប់)

ជាតុផ្សំ	ចំណុចវិភាគ	របកគំហើញ	ទំនាក់ទំនងជាមួយកម្លាំងចលករទាំង៥	ស្របជាមួយចក្ខុវិស័យ ២០៥០	ស្របជាមួយយុទ្ធសាស្ត្របញ្ចកោណ	សង្គតិភាពជាមួយក្របខ័ណ្ឌយុទ្ធសាស្ត្រ	ការវាយតម្លៃជារួម
ភាពពេញលេញ	ភាពស៊ីសង្វាក់គ្នាផ្ទៃក្នុង ភាពគ្រប់គ្រាន់ដោយខ្លួនឯងបាន និងការរួមបញ្ចូលរវាងស្ថាប័ន និងនិយាម	ប្រព័ន្ធមានទម្រង់ពេញលេញ ប៉ុន្តែមិនពេញលេញក្នុងការដំណើរការ; ខ្វះឯកសណ្ឋានភាពនៃច្បាប់	គាំទ្រដល់កម្លាំងស្ថិរកម្ម និងកម្លាំងកសាង	មិនទាន់បានបញ្ចូលក្នុងចក្ខុវិស័យយុទ្ធសាស្ត្រយៈពេលវែង	បទប្បញ្ញត្តិ និងយន្តការច្បាប់សម្រាប់វិស័យនីមួយៗ មិនស៊ីសង្វាក់គ្នា/ខ្វះការសម្របសម្រួល, មានគម្លាត ឬស្ទួនជាន់គ្នា	គ្មានលក្ខណៈនិច្ចិយ ឬសូចនាករសម្រាប់ភាពពេញលេញនៃប្រព័ន្ធច្បាប់	ខ្សោយ; ត្រូវការគំរូឯកសណ្ឋានភាពនៃប្រព័ន្ធច្បាប់
ទំនាក់ទំនងជាមួយចក្ខុវិស័យ ២០៥០	ភាពស៊ីសង្វាក់គ្នារវាងគោលនយោបាយ និងច្បាប់	ត្រូវគ្នា ប៉ុន្តែមិនមានគ្រឹះចែងជាក់លាក់	មានសក្តានុពលរួបរួម កម្លាំងចលករទាំងប្រាំឱ្យស្ថិតក្រោមចក្ខុវិស័យអភិវឌ្ឍន៍រួម	—	ស្របគ្នាលើលទ្ធផល ប៉ុន្តែមិនទាន់បានចងក្រង	ពុំមានតំណភ្ជាប់ផ្លូវការ	ខ្សោយ; ត្រូវការច្បាប់បទបញ្ញត្តិគ្រឹះ
ទំនាក់ទំនងជាមួយយុទ្ធសាស្ត្របញ្ចកោណ	តំណភ្ជាប់ប្រតិបត្តិការរវាងច្បាប់ និងការអនុវត្តតាមវិស័យ	ភាពគ្របដណ្តប់ផ្ទៃកសារធាតុពឹងមាំ; ភាពរួមបញ្ចូលខ្សោយ	គាំទ្រដល់កម្លាំងកសាង និងកម្លាំងការពារ	ស្របគ្នា ប៉ុន្តែខ្វះយន្តការអនុវត្តឆ្លងវិស័យ	—	ក្របខ័ណ្ឌយុទ្ធសាស្ត្រមិនត្រូវបានធ្វើសមកាលកម្ម	ខ្សោយ; ត្រូវការប្រព័ន្ធធានាសង្គតភាពរវាងនីតិបញ្ញត្តិ និងគោលនយោបាយ
កម្លាំងចលករទាំង៥	តក្កវិជ្ជានៃការកសាងរដ្ឋ	មានតែផ្នែកខ្លះ (ផ្តោតលើកម្លាំងស្ថិរកម្ម និងកំណើន)	—	គាំទ្រផ្នែកគំនិតចំពោះសសរសន្តិភាព និងសុភមង្គលនៃចក្ខុវិស័យ	មិនទាន់បានស្ថាបនាជាប្រព័ន្ធ	មិនត្រូវបានឆ្លុះបញ្ចាំងនៅក្នុងក្របខ័ណ្ឌយុត្តិសាស្ត្របច្ចុប្បន្ន	ខ្សោយ; ត្រូវការការសម្របសម្រួលច្បាប់ និងយុទ្ធសាស្ត្រទាំងមូល
ក្របខ័ណ្ឌយុទ្ធសាស្ត្រ	យន្តការកំណែទម្រង់ និងនិម្មាបនកម្មកំណែទម្រង់	ខ្លាំងក្នុងការព្រាងច្បាប់; ខ្សោយក្នុងការអនុវត្តច្បាប់ ភាពរួមបញ្ចូល និងការអប់រំ	គាំទ្រដល់កម្លាំងស្ថិរកម្ម និងកម្លាំងកសាង	មិនបានតភ្ជាប់ជាមួយចក្ខុវិស័យរយៈពេលវែង	ជំណើរការដោយឡែកពីការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ	—	មធ្យម; ត្រូវការបន្សាំគំរូពីការតាក់តែងច្បាប់ទៅការគ្រប់គ្រងច្បាប់



ការវិភាគប្រៀបធៀប

ទិដ្ឋភាព	ឥណ្ឌាបុរាណ ព្រះធម្មសាស្ត្រ & គម្ពីរអប៊ិសាស្ត្រ	ចិនបុរាណ (ខុង ជឺ និង Legalism)	ចក្រភពរ៉ូម៉ាំង	ប្រទេសបារាំង	ចក្រភពអង់គ្លេស	ប្រទេសជប៉ុន	ប្រទេសអាល្លឺម៉ង់	ប្រទេសសហរដ្ឋអាមេរិក	ប្រទេសសិង្ហបុរី	ចំណុចគន្លឹះសម្រាប់កម្ពុជាធ្វើការសិក្សា
មូលដ្ឋានគ្រឹះ (Foundational Ethos)	ការដឹកនាំប្រកបដោយសីលធម៌, ធម៌, យុទ្ធសាស្ត្រគ្រប់គ្រងរដ្ឋដើម្បីឱ្យមានបុល ភាព និងសណ្តាប់ធ្នាប់សង្គម	ភាពសុខដុម, ឋានានុក្រម, គុណធម៌ ផ្សារភ្ជាប់នឹងការអនុវត្ត	សណ្តាប់ធ្នាប់សាធារណៈ, សញ្ជាតិ, កាតព្វកិច្ចចំពោះច្បាប់	លទ្ធិសាធារណរដ្ឋ, សិទ្ធិ, គោលគំនិតផ្តាច់ខ្លួនរដ្ឋ និងសាសនា (Secularism), និត្យានុកូលភាពនៃសនីទានីយ	គោលការណ៍នីតិរដ្ឋ, សាលជីកា, សិទ្ធិ	លទ្ធិសន្តិភាព (Pacifism), ប្រយោជន៍សាធារណៈ, ភាពសុខដុម	នីតិរដ្ឋ (Rechtsstaat), សេដ្ឋកិច្ចទីផ្សារ, និត្យានុកូលភាព	សិទ្ធិសេរីភាពដែលធានាដោយរដ្ឋធម្មនុញ្ញ, សហព័ន្ធនិយម (federalism)	ប្រព័ន្ធផ្អែកលើសមត្ថភាព និងសមិទ្ធផល, អនុវត្តនិយម (Pragmatism), ប្រឆាំងអំពើពុករលួយ	រួមបញ្ចូលភាពសមស្រប ផ្អែកលើធម៌ (សីលធម៌ ព្រះសាសនា និងសាមគ្គីភាពសង្គម) ជាមួយភាពសមហេតុផលនៃច្បាប់ និងសិទ្ធិមនុស្ស
រចនាសម្ព័ន្ធគតិយុត្ត (Structure)	ការិយាធិបតេយ្យកណ្តាល, ក្រុមប្រឹក្សាផ្តល់យោបល់, ចៅក្រមដែលតែងតាំងដោយព្រះមហាក្សត្រ	ប្រព័ន្ធមន្ត្រីរាជការ-អ្នកប្រាជ្ញ, ប្រព័ន្ធមន្ត្រីរាជការនៃចក្រភព	រដ្ឋបាលដែលបានចងក្រងជាក្រមច្បាប់ (មានក្រមនីតិវិធីរដ្ឋបាលជាក់លាក់), មានច្បាប់ចងក្រងទំនាក់ទំនងជនស៊ីវិល	ប្រព័ន្ធតុលាការទ្វេ, ក្រុមប្រឹក្សារដ្ឋ, ឋានានុក្រមនីត្យានុកូល	ប្រព័ន្ធតុលាការអង់គ្លេសាក់សុង, អធិបតេយ្យភាពរបស់សភា	ឋានានុក្រមតុលាការ, ការិយាធិបតេយ្យរឹងមាំ, ប្រជាពលរដ្ឋដែលចូលរួមការពិភាក្សាជាមួយអង្គចៅក្រមក្នុងសវនាការ (lay-judge reform)	ក្រុមប្រឹក្សារដ្ឋធម្មនុញ្ញ, ឯកភាពគតិយុត្តសហព័ន្ធ (Federal legal unity)	ការត្រួតពិនិត្យភាពស្របច្បាប់ដោយតុលាការ (Judicial Review), ប្រព័ន្ធត្រួតពិនិត្យ និងតុល្យភាព	សេវាឯកភាព (Unified service), វដ្តនយោបាយ-ច្បាប់សមាហរណកម្ម (integrated policy-law cycle)	ពង្រឹងស្ថាប័នរដ្ឋាភិរក្ស: ឯករាជ្យភាពនៃប្រព័ន្ធតុលាការ និងការសម្របសម្រួលដ៏ស្មុគស្មាញរវាងអំណាចនីតិប្រតិបត្តិ នីតិបញ្ញត្តិ និងតុលាការ
សារជាតុគតិយុត្ត (Substance)	ព្រះធម្មសាស្ត្រ (ច្បាប់ស្តីពីសីលធម៌), គម្ពីរអប៊ិសាស្ត្រ (ច្បាប់ស្តីពីរដ្ឋបាល)	ស្តីលធម៌របស់ខុងជឺ + ក្រមព្រហ្មទណ្ឌរបស់ Legalism	ច្បាប់ស៊ីវិលនៃចក្រភពរ៉ូម៉ាំង, ច្បាប់នៃប្រជាជន (Law of Peoples)	មានក្រមច្បាប់គ្រប់ជ្រុងជ្រោយ, ក្រុមប្រឹក្សាធម្មនុញ្ញ (constitutional bloc)	ច្បាប់អង់គ្លូសាក់សុង + ច្បាប់នីតិបញ្ញត្តិ	ក្រមរដ្ឋប្បវេណី, សិទ្ធិដែលបានធានាដោយរដ្ឋធម្មនុញ្ញ (Constitutional Rights)	មានក្រមរដ្ឋបបវេណី/ក្រមព្រហ្មទណ្ឌ	រដ្ឋធម្មនុញ្ញ + ច្បាប់បង្កើតដោយសេចក្តីសម្រេចតុលាការ	ច្បាប់ដែលបានចងជាក្រម/ ច្បាប់ចែងបែបហ៊ីប្រីត (statutory hybrid)	ការចងក្រងច្បាប់ជាប្រព័ន្ធ: ការធានានូវ ភាពស៊ីសង្វាក់គ្នា ឋានានុក្រម និងភាពបត់បែន; មានបង្កប់នូវកាតព្វកិច្ចអន្តរជាតិ។



ការវិភាគប្រៀបធៀប (ត)

ទិដ្ឋភាព	គំណាំបុរាណ ព្រះធម្មសាស្ត្រ & គម្ពីរអបិសាស្ត្រ	ចិនបុរាណ (ខុង ជឺ និង Legalism)	ចក្រភពរ៉ូម៉ាំង	ប្រទេសបារាំង	ចក្រភពអង់គ្លេស	ប្រទេសជប៉ុន	ប្រទេសអាល្លឺម៉ង់	ប្រទេសសហរដ្ឋអាមេរិក	ប្រទេសសិង្ហបុរី	ចំណុចគន្លឹះសម្រាប់កម្ពុជាធ្វើការសិក្សា
វប្បធម៌គោរពច្បាប់ (Culture)	កាតព្វកិច្ច, សីលធម៌, ឋានានុក្រម	ពិធីទំនៀមទម្លាប់, ការអប់រំ និងការបណ្តុះបណ្តាលគុណធម៌	វិន័យសាធារណៈ, សិទ្ធិជាប្រជាពលរដ្ឋរ៉ូម៉ាំង	ភាពជាក់លាក់នៃគោលលទ្ធិ, ស្មារតីបម្រើរដ្ឋ	វប្បធម៌គោរពសាលក្រម តុលាការដែលបានសម្រេចកន្លងមក (Precedent Culture) និងឯកភាពជ្យភាពវិជ្ជាជីវៈ	សុខដុមភាព, ប្រសិទ្ធភាព, ទំនុកចិត្ត	ភាពសមហេតុសមផលនីតិ និងការគោរពអនុវត្តច្បាប់	វប្បធម៌ដោះស្រាយវិវាទតាមតុលាការដោយប្រើសិទ្ធិ	សណ្តាប់ធ្នាប់, ការទប់ស្កាត់, ការទទួលខុសត្រូវ	លើកទឹកចិត្តការបម្រើសាធារណៈដោយគុណធម៌ កាតព្វកិច្ចពលរដ្ឋ និងការយល់ដឹងច្បាប់ក្នុងចំណោមពលរដ្ឋ និងមន្ត្រីរាជការ
កម្លាំងស្ថិរកម្ម (Stabilizing Force)	យុត្តិធម៌តាមរយៈធម៌, ការបង្ការជម្លោះ	ការគ្រប់គ្រងដោយគុណធម៌ និងពិធីវិធាននៃសណ្តាប់ធ្នាប់	ច្បាប់ និងកងទ័ពរ៉ូម៉ាំង	នីត្យានុកូលភាពរដ្ឋបាល	អព្យាក្រឹតភាពនៃតុលាការ (Judicial Impartiality)	ភាពអាចទស្សន៍ទាយបាននៃច្បាប់ (Legal predictability)	រដ្ឋនីតិផ្នែកស្ថាប័ន	ការអនុវត្តបង្ខំដោយរដ្ឋធម្មនុញ្ញ	ការគ្រប់គ្រងផ្នែកដោយប្រើគោលការណ៍នីតិរដ្ឋ	បង្កើតយុត្តិធម៌រដ្ឋបាល នីតិវិធីច្បាស់លាស់ និងយន្តការប្រឆាំងអំពើពុករលួយ
កម្លាំងកសាង (Building Force)	វិបុលភាពនៃសេដ្ឋកិច្ច ជាកាតព្វកិច្ចរបស់អ្នកដឹកនាំ	សាធារណការ និងសណ្តាប់ធ្នាប់កសិកម្ម	ហេដ្ឋារចនាសម្ព័ន្ធ និងច្បាប់ពាណិជ្ជកម្ម	និយតកម្មសេដ្ឋកិច្ចតាមច្បាប់	ទីផ្សារ និងនវានុវត្តន៍ ដែលត្រូវបានគាំទ្រដោយច្បាប់ស្តីពីកិច្ចសន្យា	ការធ្វើឲ្យឧស្សាហកម្មទំនើបឡើងតាមរយៈការកែទម្រង់ច្បាប់	ការគ្រប់គ្រងសេដ្ឋកិច្ចក្នុងក្របខណ្ឌនៃច្បាប់	ច្បាប់ក្រុមហ៊ុន និងច្បាប់បច្ចេកវិទ្យា	ច្បាប់ស្តីពីការវិនិយោគ និងជំរុញដោយនវានុវត្តន៍	ប្រើច្បាប់ជាឧបករណ៍សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងនវានុវត្តន៍ (ស្របតាមចក្ខុវិស័យ ២០៥០)
កម្លាំងការពារ (Protecting Force)	សុខុមាលភាព និងសាមគ្គីភាពសង្គម	សណ្តាប់ធ្នាប់សន្តិសុខសង្គម ឋានានុក្រម	ការការពារប្រជាពលរដ្ឋដោយប្រើច្បាប់	សិទ្ធិសង្គម, បរិស្ថាន	សិទ្ធិមនុស្ស និងច្បាប់សន្តិសុខសង្គម	ច្បាប់ការងារ និងច្បាប់សន្តិសុខសង្គម	ជ្ជសុខុមាលភាព និងសិទ្ធិដែលធានាដោយរដ្ឋធម្មនុញ្ញ	សិទ្ធិស៊ីវិល និងកម្មវិធីសង្គម	បណ្តាញសុវត្ថិភាពសង្គម និងកម្មវិធីសន្តិសុខសង្គម ផ្អែកលើសមត្ថភាព (Safety nets, merit-based welfare)	ចែងបញ្ចាក់ការការពារសង្គម បរិស្ថាន និងសន្តិសុខមនុស្ស ក្នុងក្របខណ្ឌរដ្ឋធម្មនុញ្ញ និងច្បាប់ធម្មតា



ការវិភាគប្រៀបធៀប (តចប់)

ទិដ្ឋភាព	តំណាបុរាណ ព្រះធម្មសាស្ត្រ & គម្ពីរអឋិសាស្ត្រ	ចិនបុរាណ (ខុង ជឺ និង Legalism)	ចក្រភពរ៉ូម៉ាំង	ប្រទេសបារាំង	ចក្រភពអង់គ្លេស	ប្រទេសជប៉ុន	ប្រទេសអាល្លឺម៉ង់	ប្រទេសសហរដ្ឋអាមេរិក	ប្រទេសសិង្ហបុរី	ចំណុចគន្លឹះសម្រាប់កម្ពុជាធ្វើការសិក្សា
កម្លាំងបង្រួបបង្រួម (Unifying Force)	ធម៌មានរួម និងរាជាធិបតេយ្យ	ប្រព័ន្ធដែលគោរពក្រមសីលធម៌របស់ខុង ជឺ	ប្រជាពលរដ្ឋភាព និងឯកភាពនៃច្បាប់រ៉ូម៉ាំង	អត្តសញ្ញាណសាធារណរដ្ឋនិយម	ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង Common law heritage	ក្រមច្បាប់ជាតិ និងការអប់រំពលរដ្ឋ	គោរពការបែងចែកអំណាច និងអាទិកម្មរដ្ឋធម្មនុញ្ញលើការប្រកួតនយោបាយ (Federal constitutional culture)	ជាតិនិយមផ្អែកលើរដ្ឋធម្មនុញ្ញ	ឯកភាពក្រោមរដ្ឋធម្មនុញ្ញក្នុងសង្គមពហុវប្បធម៌ (Multicultural legal unity)	កសាងអត្តសញ្ញាណច្បាប់ជាតិដែលមានឫសគល់នៅលើមេត្តាករុណាពុទ្ធសាសនា រដ្ឋធម្មនុញ្ញនិយម និងកាតព្វកិច្ចពលរដ្ឋ
កម្លាំងគាំពារ (Defending Force)	ក្រមសីលធម៌យោធា និងការពារអធិបតេយ្យភាពជាតិ	ការរៀបចំប្រព័ន្ធយុទ្ធសាស្ត្រ, គុណធម៌គឺស្ថិតលើច្បាប់	ប្រើច្បាប់ដើម្បីការពារខ្លួន	ការទូតផ្នែកច្បាប់ និងសមាហរណកម្មជាមួយសហភាពអឺរ៉ុប (EU)	ការពារជាតិដែលខ្ជាប់ខ្ជួនតាមច្បាប់	សន្តិភាពនិយម និងច្បាប់ការពារខ្លួន	ការគ្រប់គ្រងយោធាដោយអាជ្ញាធរស៊ីវិល	ឧត្តមភាពនៃច្បាប់ក្នុងនយោបាយការបរទេស	ប្រើច្បាប់ជាមូលដ្ឋានដោះស្រាយ ឬទប់ស្កាត់ បញ្ហាភ្ជាប់ជាមួយការទូត	ជានាឲ្យការពារជាតិ និងការទូតមានមូលដ្ឋាននៅលើច្បាប់អន្តរជាតិ និងអធិបតេយ្យភាពជាតិ


គណៈកម្មាធិការដឹកនាំការកែចម្រុងច្បាប់
១៦
ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា
ដឹកនាំនិងសម្របសម្រួលចងក្រង និងផ្សព្វផ្សាយច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
បង្កើតដម្បូមណ្ឌលទិន្នន័យច្បាប់
បង្កើតប្រព័ន្ធប្រមូលទិន្នន័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (Legal Database)
បង្កើតគេហទំព័រច្បាប់ (chbab.gov.kh)
បង្កើតប្រព័ន្ធសេវាកម្មព័ត៌មានច្បាប់
រៀបចំក្រមនីយកម្មគតិយុត្តតាមវិស័យ
រៀបចំសន្ធានក្រមគតិយុត្តតាមវិស័យ
ចងក្រងនិងផ្សព្វផ្សាយសេចក្តីសម្រេចរបស់និយ័តករ
ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
រៀបចំយន្តការគ្រប់គ្រងការងារនីតិកម្មរបស់ទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័ន
រៀបចំប្រព័ន្ធនីជីថលនៃការគ្រប់គ្រងការងារនីតិកម្មរបស់គណៈរដ្ឋមន្ត្រី និងក្រសួងស្ថាប័ន
រៀបចំមគ្គុទេសក៍សិល្បៈស្ត្រនីតិកម្ម
រៀបចំប្រព័ន្ធនីជីថលសម្រាប់ការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
ដឹកនាំនិងសម្របសម្រួលពិនិត្យ និងវាយតម្លៃគុណភាព និងប្រសិទ្ធភាពនៃការតាក់តែង និងការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
រៀបចំប្រព័ន្ធនិងយន្តការនៃការពិនិត្យនិងវាយតម្លៃអំពីតម្រូវការនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
រៀបចំប្រព័ន្ធនិងយន្តការនៃការពិនិត្យនិងវាយតម្លៃអំពី គុណភាពនៃការតាក់តែងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
រៀបចំប្រព័ន្ធ និងយន្តការនៃការពិនិត្យ និងវាយតម្លៃអំពីប្រសិទ្ធភាពនៃការអនុវត្តច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត
អនុវត្តអនុសាសន៍ ក្រោយការពិនិត្យនិងវាយតម្លៃ
ដឹកនាំនិងសម្របសម្រួលរៀបចំក្របខ័ណ្ឌដោះស្រាយវិវាទគតិយុត្ត និងការពារនីត្យានុកូលភាព
ដឹកនាំនិងរៀបចំប្រព័ន្ធ និងយន្តការនៃការប្រឹក្សាយោបល់អំពីនីត្យានុកូលភាព
ដឹកនាំនិងរៀបចំប្រព័ន្ធនិងយន្តការនៃការបកស្រាយច្បាប់និងការដោះស្រាយវិវាទគតិយុទ្ធ
ដឹកនាំនិងរៀបចំប្រព័ន្ធនិងយន្តការនៃការការពារនីត្យានុកូលភាព
ដឹកនាំនិងរៀបចំប្រព័ន្ធនិងយន្តការនៃការអនុវត្តសេចក្តីសម្រេចលើវិវាទគតិយុត្តនិងដែនការការពារនីត្យានុ-កូលភាព
ដោយការណែនាំដ៏ក្រមខ័ណ្ឌយុទ្ធសាស្ត្រនៃអនុវត្តិយ៍ការកែចម្រុងច្បាប់របស់រាជរដ្ឋាភិបាល
៤ យុទ្ធសាស្ត្រគន្លឹះ ១៩ សកម្មភាព
16



គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
១៧
ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា
គណៈកម្មការជំនាញ
ទទួលបន្ទុកតាមវិស័យ
ក្រុមការងារកែទម្រង់ច្បាប់
នៅក្នុងក្រសួង ស្ថាប័ន
យន្តការស្ថាប័នអន្តរវិស័យ
យន្តការគាំទ្រទី១
យន្តការគាំទ្រទី២
យន្តការគាំទ្រទី៣
យុទ្ធសាស្ត្រគាំទ្រទី១
យុទ្ធសាស្ត្រគាំទ្រទី២
យុទ្ធសាស្ត្រគាំទ្រទី៣
យុទ្ធសាស្ត្រគាំទ្រទី៤
រៀបចំផែនការសកម្មភាពតាម
ដំណាក់កាលនីមួយៗ
រៀបចំស្តង់ដាប្រតិបត្តិ
ការងារសម្រាប់អនុវត្ត
យុទ្ធសាស្ត្រគន្លឹះទាំង៤
រៀបចំប្រព័ន្ធឌីជីថ-
លូបនីយកម្ម សម្រាប់អនុវត្ត
យុទ្ធសាស្ត្រគន្លឹះទាំង៤
រៀបចំផែនការអភិវឌ្ឍស្ថាប័ន
សម្រាប់ គ.ក.ច.
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា
17



ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

ទី១៖ បន្តអនុវត្តក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល
ទី២៖ កំណត់មូលដ្ឋានគ្រឹះ (Foundational Ethos) ឱ្យបានច្បាស់លាស់រួមមានគុណតម្លៃ បរិការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ព្រមទាំងគុណតម្លៃ កាតព្វកិច្ច និងឧត្តមានុវត្តន៍អន្តរជាតិ
ទី៣៖ ពង្រឹងសមត្ថភាព និងភាពប្រទាក់ក្រឡារបស់ស្ថាប័ន និងធនធានមនុស្សដែលបំពេញការងារក្នុងប្រព័ន្ធច្បាប់
ទី៤៖ ការធ្វើកំណែទម្រង់ប្រព័ន្ធអប់រំផ្នែកនីតិសាស្ត្រ
ទី៥៖ កសាងវប្បធម៌គោរពច្បាប់នៅក្នុងសង្គម
ទី៦៖ សិក្សាអំពីគម្ពីរអថ៌សាស្ត្រ(Arthashastra)ដែលជាគម្ពីដឹកនាំរដ្ឋនាសម័យអង្គរ
ទី៧៖ រៀបចំសេចក្តីព្រាងលិខិតបទដ្ឋានគតិយុត្ត របស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យរាល់សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវភ្ជាប់មកជាមួយការបញ្ជាក់អំពីអនុលោមភាពតាមយុទ្ធសាស្ត្របញ្ចកោណ និងចក្ខុវិស័យ២០៥០។

រូបភាពបញ្ជាស្តីពីក្របខ័ណ្ឌរួមនៃបូរណភាពប្រព័ន្ធច្បាប់កម្ពុជា




សូមគោរពអរគុណ
20

ឧបសម្ព័ន្ធទី១៖
ឯកសារទស្សនាទានសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

ឯកសារទស្សនាទាន
សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា

ថ្ងៃព្រហស្បតិ៍ ទី ២៧ - ២៨ តុលា ២០២៥

ឯកសារទស្សនាទាន
"សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា"

ទីតាំង៖ សណ្ឋាគារ Angkor Century Resort & Spa **ខេត្តសៀមរាប**

រយៈពេល ២ថ្ងៃ

ថ្ងៃចន្ទ ៦កើត - អង្គារ ៧កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩

ត្រូវនឹងថ្ងៃទី២៧ - ២៨ ខែតុលា ឆ្នាំ២០២៥

១. សេចក្តីផ្តើម

ព្រះរាជាណាចក្រកម្ពុជា បានប្រកាន់យកយ៉ាងខ្ជាប់ខ្ជួននូវគោលការណ៍នីតិរដ្ឋ ជាមូលដ្ឋានគ្រឹះដែលបានចារឹកនៅក្នុងរដ្ឋធម្មនុញ្ញឆ្នាំ១៩៩៣ ដោយឈរលើគុណតម្លៃស្នូល រួមមាន ប្រព័ន្ធនយោបាយប្រជាធិបតេយ្យសេរីពហុបក្ស ការគោរពសិទ្ធិមនុស្ស សិទ្ធិបុគ្គល និងប្រព័ន្ធសេដ្ឋកិច្ចទីផ្សារសេរី។ ក្នុងនីតិកាលទី៧ នៃរដ្ឋសភា **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានប្រកាសប្រើប្រាស់ "**ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល**" កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ ជាមួយចក្ខុវិស័យ "**គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ (គ.ក.ច.) ជានិម្មាបនករនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជានិងគុណតម្លៃសាកល**"។

តាមរយៈក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល កម្ពុជាត្រូវការជាចាំបាច់នូវប្រព័ន្ធច្បាប់មួយដែលផ្អែកលើនីតិរដ្ឋ និងឈានទៅសម្រេចឱ្យបាននូវ "**បុរាណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ**" សំដៅដល់ការកសាងអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ដោយធានាបាននូវការប្រកាន់ខ្ជាប់ជានិរន្តរ៍ នូវការគោរព ប្រតិបត្តិ និងតម្កល់ច្បាប់ជាធំ ពីសំណាក់ប្រជាពលរដ្ឋ អ្នកដឹកនាំ និងគ្រប់ក្រសួង ស្ថាប័ន ដោយស្មើភាពគ្នា និងជំនឿទុកចិត្ត។ ដើម្បីសម្រេចបានទស្សនវិស័យនេះ តម្រូវឱ្យភាគីពាក់ព័ន្ធទាំងអស់ចូលរួមជាមួយនឹងរាជរដ្ឋាភិបាលកម្ពុជា ក្នុងការសិក្សាស្រាវជ្រាវអំពីទិដ្ឋភាពទូទៅនិងការវិវត្តិនៃប្រព័ន្ធច្បាប់ធំៗលើសកលលោក ការវិវត្តនិងស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន និងការវាយតម្លៃអំពីចំណុចវិជ្ជមាន អវិជ្ជមាន និងបញ្ហាប្រឈមនានា ហើយចុងក្រោយឈានទៅកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជាជាក់លាក់មួយ ដែលផ្សារភ្ជាប់ទៅនឹងឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា។

សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា គឺជាវេទិកាពិភាក្សា ពិគ្រោះយោបល់ និងប្រមូលធាតុចូលឱ្យបានគ្រប់ជ្រុងជ្រោយពាក់ព័ន្ធនឹងប្រព័ន្ធច្បាប់ធំៗក្នុងសកលលោក ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរាណដល់បច្ចុប្បន្ន និងស្វែងរកឱ្យឃើញនូវកត្តាចម្បងនានាដែលបានជះឥទ្ធិពលមកលើប្រព័ន្ធច្បាប់កម្ពុជា ដើម្បីឈានទៅដល់ការរៀបចំសេចក្តីព្រាង "**ក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់**

កម្ពុជា" ជាមគ្គទេសក៏តម្រង់ទិសនៃការកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងជាថ្នាលសម្រាប់កិច្ចសហប្រតិបត្តិការរវាងភាគីពាក់ព័ន្ធទាំងអស់ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

សិក្ខាសាលានេះ នឹងអញ្ជើញថ្នាក់ដឹកនាំ បញ្ញវន្ត សាស្ត្រាចារ្យនិងអ្នកស្រាវជ្រាវផ្នែកនីតិសាស្ត្រ ប្រវត្តិសាស្ត្រ បុរាណវិទ្យា អារ្យធម៌ វប្បធម៌ អ្នកប្រកបវិជ្ជាជីវៈច្បាប់ និងភាគីពាក់ព័ន្ធក្នុងវិស័យច្បាប់ ទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ដោយធ្វើការបែងចែកជាក្រុមសិក្សាទៅតាមប្រធានបទស្រាវជ្រាវ។ ក្រុមនីមួយៗនឹងធ្វើការស្រាវជ្រាវ ប្រជុំពិភាក្សា រៀបចំជាអត្ថបទស្រាវជ្រាវ និងបទបង្ហាញទៅតាមចិរវេលាកំណត់ និងមុនថ្ងៃប្រារព្ធកម្មវិធីសិក្ខាសាលា ដើម្បីជាមូលដ្ឋានក្នុងការធ្វើបទបង្ហាញ ការពិភាក្សា ការផ្លាស់ប្តូរទស្សនៈ ចំណេះដឹង និងបទពិសោធទាក់ទងនឹងប្រធានបទជាក់លាក់តាមក្រុមនីមួយៗ។

២. គោលបំណង

សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា មានគោលបំណងសិក្សាអំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក សិក្សាវិភាគប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរាណដល់បច្ចុប្បន្ន ដើម្បីធ្វើការវាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន កំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងរៀបចំ**ក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា** ដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា។

៣. លទ្ធផលរំពឹងទុក

កម្មវិធីសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា នឹងត្រូវបានរៀបចំឡើងដើម្បីសម្រេចនូវលទ្ធផលដូចខាងក្រោម៖

១. ស្វែងយល់អំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក៖ ស្វែងយល់អំពី ប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ ទស្សនវិជ្ជាចិនបុរាណ ទស្សនវិជ្ជាពុទ្ធសាសនា និងច្បាប់សង្គម គុណសម្បត្តិនិងគុណវិបត្តិ និងការវិវត្តនៃប្រព័ន្ធច្បាប់នីមួយៗ ដើម្បីឈានដល់ការវិភាគនិងកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា

២. វិភាគមូលដ្ឋានគ្រឹះនៃការវិវត្តប្រព័ន្ធច្បាប់កម្ពុជា៖ វិភាគនូវឫសគល់នៃប្រព័ន្ធច្បាប់កម្ពុជាសម័យបុរាណ រួមមាន វប្បធម៌ ទំនៀមទម្លាប់ ជំនឿ សាសនា ប្រព័ន្ធរដ្ឋបាល និងការទទួលឥទ្ធិពលនៃវប្បធម៌ឥណ្ឌាក្នុងការគ្រប់គ្រងរដ្ឋ ដោយផ្តើមចេញពីសម័យបុរេប្រវត្តិ និងបន្តដល់សម័យទំនើប

៣. វាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន៖ សិក្សាអំពីការវិវត្តនៃប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន និងវាយតម្លៃអំពីចំណុចវិជ្ជមាន អវិជ្ជមាន បញ្ហាប្រឈមនានា និងផ្តល់ជាដំណោះស្រាយនិងជម្រើស

៤. កំណត់ជាតុផ្សំនៃអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា៖ សាកល្បងកំណត់នូវជាតុផ្សំនៃអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា ដែលផ្សារភ្ជាប់ទៅនឹងគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល

៥. រៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា៖ ជាលទ្ធផលនៃសិក្ខាសាលា នឹងឈានទៅរៀបចំសេចក្តីព្រាងក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា ដើម្បីដាក់ជូន

គ.ក.ច. ពិនិត្យនិងសម្រេច និងឈានឆ្ពោះទៅសម្រេចបាននូវ "**បូរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ**"។

៤. វិធីសាស្ត្រនៃការរៀបចំកម្មវិធី

៤.១. កាលបរិច្ឆេទ ទីកន្លែង ភាសា

ថ្នាក់ដឹកនាំ និងក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. បានធ្វើការសិក្សាលើពេលវេលា ទីតាំង និងភាសា ដើម្បីសម្របសម្រួលនិងផ្តល់ភាពងាយស្រួលដល់ក្រុមសិក្សាស្រាវជ្រាវ និងភាគីពាក់ព័ន្ធ ដោយបានកំណត់រៀបចំអង្គសិក្ខាសាលាដូចខាងក្រោម៖

កាលបរិច្ឆេទ ៖ ថ្ងៃទី២៧ - ២៨ ខែតុលា ឆ្នាំ២០២៥ (២ថ្ងៃ)
ចាប់ពីម៉ោង ៖ ថ្ងៃទី១ ចាប់ពីម៉ោង ០៧:៣០ ព្រឹក ដល់ ១៧:៣០ ល្ងាច
ថ្ងៃទី២ ចាប់ពីម៉ោង ០៨:០០ ព្រឹក ដល់ ១៧:០០ ល្ងាច
ទីតាំង ៖ សណ្ឋាគារ Angkor Century Resort & Spa ខេត្តសៀមរាប
ភាសា ៖ ភាសាខ្មែរ និងអង់គ្លេស

៤.២. ការបែងចែក និងប្រើប្រាស់ធនធាន

ផែនការ៖ អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ធ្វើផែនការ (Planning) រៀបចំចាត់ចែង (Organizing) ដឹកនាំ (Directing) និងតាមដានត្រួតពិនិត្យ (Monitoring) លើធនធានទាំងឡាយ និងដំណើរការទូទៅនៃកម្មវិធីសិក្ខាសាលាទាំងមូល ពោលគឺដំណាក់កាលមុនកម្មវិធី ដំណាក់កាលអំឡុងពេលកម្មវិធី និងដំណាក់កាលក្រោយកម្មវិធី។

ធនធានមនុស្ស៖ ថ្នាក់ដឹកនាំរបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ជានិម្មានករៀបចំផែនការ ដឹកនាំ និងប្រើប្រាស់អ្នកជំនាញការច្បាប់និងមន្ត្រីក្នុងនាយកដ្ឋានទាំងអស់ ជាប្រតិបត្តិករលើកិច្ចដំណើរការ សម្របសម្រួល និងការគ្រប់គ្រងនៃសិក្ខាសាលាទាំងមូល។

ធនធានហិរញ្ញវត្ថុ៖ ប្រើប្រាស់កញ្ចប់ថវិការបស់អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ដោយមាននាយកដ្ឋានរដ្ឋបាលនិងហិរញ្ញកិច្ចជាអ្នករៀបចំ សម្របសម្រួល និងគ្រប់គ្រងសម្រាប់ការចំណាយលើសិក្ខាសាលាទាំងមូល។

ធនធានសម្ភារ៖ ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. ប្រើប្រាស់ឧបករណ៍ និងសម្ភារដែលមានស្រាប់ក្នុងអង្គភាព និងដួលទៅតាមភាពចាំបាច់នៃការរៀបចំ និងកិច្ចដំណើរការកម្មវិធីសិក្ខាសាលា។

៤.៣. ប្រធានបទនៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវខាងក្រោម គឺជាមូលដ្ឋានក្នុងការរៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា។ ប្រធានបទស្រាវជ្រាវ នឹងត្រូវបានបែងចែកជាប្រធានបទស្តីពីប្រព័ន្ធ

ច្បាប់ធំៗលើសកលលោកជាទិដ្ឋភាពទូទៅ រួចបន្សឹជាមួយការវិវត្តប្រព័ន្ធច្បាប់តាមសម័យកាលក្នុងសង្គមកម្ពុជា ដើម្បីឈានទៅដល់ការវាយតម្លៃលើស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន និងសំយោគទៅរកការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងលើកជាវិធានការនិងសកម្មភាព ដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា នាពេលអនាគត ដូចខាងក្រោម៖

១. ប្រធានបទ "**ប្រព័ន្ធច្បាប់ធំៗលើសកលលោក**"៖ ប្រធានបទនេះនឹងត្រូវសិក្សាជាទិដ្ឋភាពទូទៅ សិក្សាអំពីប្រវត្តិ ប្រភព ធាតុផ្សំ ចរិតលក្ខណៈ និងការវិវត្តិនៃប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ ទស្សនវិជ្ជាចិនបុរាណ (ខុង ជឺ និង Legalism) និងទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម ។

២. ប្រធានបទ "**ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន**"៖ ប្រធានបទនេះនឹងត្រូវសិក្សាអំពីប្រវត្តិ និងឫសគល់នៃការវិវត្តប្រព័ន្ធច្បាប់ក្នុងសង្គមកម្ពុជា ចាប់ពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន និងធ្វើការសន្និដ្ឋានអំពីប្រភពនៃប្រព័ន្ធច្បាប់នានាដែលប្រព័ន្ធច្បាប់កម្ពុជាទទួលរងឥទ្ធិពលនិងបានអនុវត្ត ពោលគឺរកឱ្យឃើញថា ប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្នបានទទួលឥទ្ធិពល សំយោគនិងប្រើប្រាស់ប្រព័ន្ធច្បាប់ណាខ្លះ។

៣. ប្រធានបទ "**ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**"៖ ប្រធានបទនេះនឹងត្រូវសិក្សានិងវិភាគលើធាតុផ្សំនៃអត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា និងវាយតម្លៃលើស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន ផ្តល់ជាដំណោះស្រាយនិងជម្រើសនៃប្រព័ន្ធច្បាប់សម្រាប់កម្ពុជា និងលើកជាវិធានការនិងសកម្មភាព ដើម្បីឆ្ពោះទៅសម្រេចបាន **បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**។ កិច្ចការបន្ត ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. នឹងឈានទៅកសាងសេចក្តីព្រាង "**ក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា**" សម្រាប់ដាក់ជូន **គ.ក.ច**. ពិនិត្យនិងសម្រេច។

ដើម្បីគាំទ្រឱ្យកិច្ចពិភាក្សា និងការស្រាវជ្រាវមានភាពងាយស្រួល ស្តង់ដាតែមួយ និងឆាប់រហ័ស ក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. ត្រូវធ្វើការរៀបចំ ១. គោលការណែនាំស្តីពីរបាយការណ៍ស្រាវជ្រាវ បទបង្ហាញ និងកិច្ចពិភាក្សា ២. គំរូទម្រង់អត្ថបទស្រាវជ្រាវ ៣. គំរូទម្រង់បទបង្ហាញ និង ៤. កម្រងសំណួរ ទាំងភាសាខ្មែរ និងភាសាអង់គ្លេស ជូនដល់ក្រុមសិក្សាស្រាវជ្រាវ។

៤.៤. ការរៀបចំក្រុមសិក្សាស្រាវជ្រាវ

តំណាងពីក្រសួង ស្ថាប័ន និងបញ្ញវន្តទាំងថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ នឹងត្រូវបានអញ្ជើញចូលរួមជាវាគ្មិន និងបែងចែកជាក្រុមតាមប្រធានបទ ដោយមានរយៈពេលសិក្សាស្រាវជ្រាវ ៦ សប្តាហ៍ គិតចាប់ពីថ្ងៃទី២២ ខែសីហា ដល់ថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥ ដូចខាងក្រោម៖

ប្រធានបទទី១៖ ប្រព័ន្ធច្បាប់ធំៗលើសកលលោក សិក្សាស្រាវជ្រាវដោយវាគ្មិនចំនួន ៥រូប ដែលមានបទពិសោធន៍ធ្លាប់ធ្វើការសិក្សាស្រាវជ្រាវលើប្រធានបទនីមួយៗ និងត្រូវបានអញ្ជើញឡើងលើវេទិកាម្តងម្នាក់ដើម្បីធ្វើបទបង្ហាញ តាមលំដាប់ដូចខាងក្រោម៖

- *"ប្រព័ន្ធច្បាប់ស៊ីវិល"* ធ្វើការសិក្សា និងបទបង្ហាញដោយ វាគ្មិនទី១
- *"ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង"* ធ្វើការសិក្សា និងបទបង្ហាញដោយ វាគ្មិនទី២
- *"ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ"* ធ្វើការសិក្សា និងបទបង្ហាញដោយ វាគ្មិនទី៣
- *"ទស្សនវិជ្ជាចិនបុរាណ"* ធ្វើការសិក្សា និងបទបង្ហាញដោយ វាគ្មិនទី៤
- *"ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម"* ធ្វើការសិក្សា និងបទបង្ហាញដោយ វាគ្មិនទី៥

<u>កំណត់ចំណាំ៖</u>

- វាគ្មិន លើប្រធានបទនីមួយៗ ត្រូវបញ្ជូនអត្ថបទសង្ខេប និងបទបង្ហាញ ជូនក្រុមសម្របសម្រួល ត្រឹមថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥
- ក្រោយបទបង្ហាញបានបញ្ចប់ វាគ្មិនទាំង ៥រូប និងអ្នកសម្រសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកា សំណួរ និងចម្លើយ
- ក្រុមសម្របសម្រួលនិងបដិសណ្ឋារកិច្ចរបស់ **អ.ភ.ក.ច**. ចំនួន ២រូប ធ្វើការសម្របសម្រួលនិងផ្តល់ជាជំនួយគ្រប់ដំណាក់កាល។

ប្រធានបទទី២៖ ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន សិក្សាស្រាវជ្រាវដោក្រុមដោយមានសមាសភាពសរុប ២០រូប និងត្រូវបានរៀបចំដូចខាងក្រោម៖

- *"សម័យបុរេប្រវត្តិ សម័យហ្វូណន និងសម័យចេនឡា"* មានអ្នកសម្របសម្រួល ១រូប និងសមាជិក ៣រូប
- *"សម័យអង្គរ"* មានអ្នកសម្របសម្រួល ១រូប និងសមាជិក ៤រូប
- *"សម័យកណ្តាល (សម័យក្រោយអង្គរដល់សម័យអាណាព្យាបាលបារាំង)"* មានអ្នកសម្របសម្រួល ១រូប និងសមាជិក ២រូប
- *"សម័យទំនើប (សម័យអាណាព្យាបាលបារាំង ដល់បច្ចុប្បន្ន) និងវាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន"* មានអ្នកសម្របសម្រួល ១រូប និងសមាជិក ៥រូប

<u>កំណត់ចំណាំ៖</u>

- អ្នកសម្របសម្រួលរួម ១រូប និងជំនួយការ ១រូប ជាអ្នកសម្របសម្រួលនិងបូកសរុបលទ្ធផលកិច្ចការស្រាវជ្រាវ និងឡើងធ្វើបទបង្ហាញនៅលើវេទិកា
- ក្រោយបទបង្ហាញបានបញ្ចប់ វាគ្មិន ៥រូប ត្រូវបានអញ្ជើញឡើងលើវេទិកា សំណួរ និងចម្លើយ

- អ្នកស្រាវជ្រាវប្រធានបទនីមួយៗ បញ្ជូនរបាយការណ៍ស្រាវជ្រាវបឋម ជូនអ្នកសម្របសម្រួលរួម ត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ហើយអ្នកសម្របសម្រួលរួមធ្វើការបូកសរុបរបាយការណ៍ស្រាវជ្រាវចុងក្រោយនិងរៀបចំបទបង្ហាញ ត្រឹមថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥
- ក្រុមសម្របសម្រួលនិងបដិសណ្ឋារកិច្ចរបស់ **អ.គ.ក.ច**. ចំនួន ២រូប ធ្វើការសម្របសម្រួលនិងផ្តល់ជាជំនួយគ្រប់ដំណាក់កាល។

ប្រធានបទទី៣៖ ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា សិក្ខាស្រាវជ្រាវជាក្រុម ដោយមានសមាសភាពសរុប ៣២រូប និងត្រូវបានរៀបចំដូចខាងក្រោម៖

- ប្រធានបទ **ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** និងប្រធានបទ **ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា** នឹងត្រូវបានធ្វើការសិក្សាស្រាវជ្រាវទាំងពីរ និងធ្វើបទបង្ហាញលើប្រធានបទ **ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** រីឯប្រធានបទ **ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា** នឹងត្រូវយកមកពិភាក្សារួមក្នុងវគ្គវេទិកាពិភាក្សា

កំណត់ចំណាំ៖

- អ្នកសម្របសម្រួលរួម ១រូប ជាអ្នកសម្របសម្រួលនិងបូកសរុបលទ្ធផលកិច្ចការស្រាវជ្រាវ និងឡើងធ្វើបទបង្ហាញនៅលើវេទិកា
- ក្រោយបទបង្ហាញបានបញ្ចប់ វាគ្មិន ៧រូប ត្រូវបានអញ្ជើញឡើងលើវេទិកា សំណួរ និងចម្លើយ
- អ្នកស្រាវជ្រាវប្រធានបទនីមួយៗ បញ្ជូនរបាយការណ៍ស្រាវជ្រាវបឋម ជូនអ្នកសម្របសម្រួលរួម ត្រឹមថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២៥ ហើយអ្នកសម្របសម្រួលរួមធ្វើការបូកសរុបរបាយការណ៍ស្រាវជ្រាវចុងក្រោយនិងរៀបចំបទបង្ហាញ ត្រឹមថ្ងៃទី៦ ខែតុលា ឆ្នាំ២០២៥
- ក្រុមសម្របសម្រួលនិងបដិសណ្ឋារកិច្ចរបស់ **អ.គ.ក.ច**. ចំនួន ៣រូប ធ្វើការសម្របសម្រួលនិងផ្តល់ជាជំនួយគ្រប់ដំណាក់កាល។

ដើម្បីឱ្យក្រុមពិភាក្សានិងសិក្សាស្រាវជ្រាវដំណើរការបានដោយរលូន និងទទួលបាននូវលទ្ធផលល្អ អគ្គលេខាធិការដ្ឋាន **គ.ក.ច**. នឹងធ្វើការរៀបចំបញ្ជីឈ្មោះក្រុមសិក្សាស្រាវជ្រាវដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ ដោយមានក្រុមសម្របសម្រួលនិងបដិសណ្ឋារកិច្ចគាំទ្រដល់ដំណើរការ និងបង្កើតក្រុមតេឡេក្រាម ឬ/និងបើកកិច្ចប្រជុំពិភាក្សាដោយផ្ទាល់ ឬតាមរយៈ Zoom ដើម្បីសម្របសម្រួលដល់ក្រុមសិក្សាស្រាវជ្រាវនីមួយៗ រហូតដល់ចប់កម្មវិធីសិក្ខាសាលា។

៤.៥. គំនូសបង្ហាញរបស់ថ្នាក់ដឹកនាំ ទាក្ខិន និងអ្នកចូលរួម

សិក្ខាសាលានេះ ត្រូវបានរៀបចំជាលក្ខណាកិច្ចពិភាក្សាតុមូល និងត្រូវបានបែងចែកទៅតាមតំបន់ (Zone) ដែលបានរៀបចំដូចខាងក្រោម៖

- វេទិកា ៖ ប្លង់តុ កៅអី និងតុបទបង្ហាញ ត្រូវបានរៀបចំ និងកំណត់ប្លង់
- តំបន់ ក ៖ សម្រាប់ថ្នាក់ដឹកនាំ ស្ថិតនៅខាងមុខ និងចំកណ្តាលឆាកនៃអង្គសិក្ខាសាលា
- តំបន់ ខ ៖ សម្រាប់ក្រុមសិក្សាស្រាវជ្រាវលើប្រធានបទទី១
- តំបន់ គ ៖ សម្រាប់ក្រុមសិក្សាស្រាវជ្រាវលើប្រធានបទទី២
- តំបន់ ឃ៖ សម្រាប់ក្រុមសិក្សាស្រាវជ្រាវលើប្រធានបទទី៣
- តំបន់ ង ៖ សម្រាប់ក្រុមការងាររៀបចំកម្មវិធី

សេចក្តីលម្អិតនៃគំនូសប្លង់វេទិកា និងប្លង់តុអង្គុយរបស់ថ្នាក់ដឹកនាំ វាគ្មិន និងអ្នកចូលរួម មានភ្ជាប់ក្នុងឧបសម្ព័ន្ធទី២ នៃឯកសារទស្សនាទាននេះ។

៤.៦. កិច្ចដំណើរការកម្មវិធី

ដើម្បីធានាថាការរៀបចំកម្មវិធីសិក្ខាសាលាដំណើរការទៅដោយរលូន និងទទួលបានលទ្ធផលតាមការរំពឹងទុក កិច្ចដំណើរការកម្មវិធីត្រូវបានបែងចែកជា ៣ ដំណាក់កាល គឺ ក. ដំណាក់កាលមុនពេលកម្មវិធី ខ. ដំណាក់កាលអំឡុងពេលកម្មវិធី និង គ. ដំណាក់កាលក្រោយកម្មវិធី ដូចខាងក្រោម៖

ក. ដំណាក់កាលមុនពេលកម្មវិធី

- អគ្គលេខាធិការដ្ឋាន **គ.ក.ច**. ធ្វើការរៀបចំបែងចែកក្រុមការងារ ដើម្បីទទួលការកិច្ចរៀបចំកម្មវិធី កិច្ចការសម្របសម្រួលនិងបដិសណ្ឋារកិច្ច និងរៀបចំឯកសារពាក់ព័ន្ធ
- រៀបចំក្រុមសិក្សាស្រាវជ្រាវ ដើម្បីទទួលកិច្ចការស្រាវជ្រាវលើប្រធានបទ ឡើងធ្វើបទបង្ហាញ និងកិច្ចពិភាក្សា
- អ្នកជំនាញការច្បាប់ នៃ **គ.ក.ច**. ជាអ្នកសម្របសម្រួលដល់ក្រុមសិក្សាស្រាវជ្រាវ ហើយកិច្ចប្រជុំក្នុងក្រុមសិក្សាស្រាវជ្រាវអាចធ្វើឡើងចំនួន ៣លើក ដោយលើកទី១ ជាកិច្ចប្រជុំចាប់ផ្តើម ដម្រាបដូនអំពីគោលបំណងនិងប្រធានបទ លើកទី២ ជាកិច្ចប្រជុំពិនិត្យលើវឌ្ឍនភាពនៃកិច្ចការស្រាវជ្រាវ និងលើកទី៣ ជាកិច្ចប្រជុំសន្និដ្ឋានចុងក្រោយដើម្បីពិនិត្យលើសេចក្តីព្រាងលទ្ធផលស្រាវជ្រាវ និងបទបង្ហាញ មុននឹងដាក់ជូនអង្គសិក្ខាសាលា
- ក្រុមសិក្សាស្រាវជ្រាវនីមួយៗធ្វើការពិភាក្សានិងស្រាវជ្រាវ ដោយមានជាតុចូលពីសមាជិកក្នុងក្រុម ដើម្បីរៀបចំចងក្រងរបាយការណ៍ស្រាវជ្រាវ និងបទបង្ហាញ
- អ្នកសម្របសម្រួលរួមធ្វើការពិនិត្យបញ្ចប់ ១. របាយការណ៍ស្រាវជ្រាវ និង ២. បទបង្ហាញ និងបញ្ជូនមកអគ្គលេខាធិការដ្ឋាន **គ.ក.ច**. ឱ្យបានមុន ឬត្រឹមចិរវេលាដែលបានកំណត់ ដើម្បីក្រុមការងារនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. រៀបចំចងក្រងរបាយការណ៍ស្រាវជ្រាវ បទបង្ហាញ និងឯកសារពាក់ព័ន្ធនានា ដាក់ជូនថ្នាក់ដឹកនាំ និងត្រៀមសម្រាប់អង្គសិក្ខាសាលាទាំងមូល។

ខ. ដំណាក់កាលអំឡុងពេលកម្មវិធី

- **ពិធីពិសាភោជនីយាហារស្វាគមន៍** (Welcoming Reception)

  - មុនកម្មវិធីសិក្ខាសាលាមួយថ្ងៃ មានពិធីពិសាភោជនីយាហារស្វាគមន៍នាពេលល្ងាច

- **កម្មវិធីបើក**

  - សុន្ទរកថាបើកកម្មវិធីដោយ **ឯកឧត្តម ឥដ្ឋ ឥស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជាប្រធាន **គ.ក.ច**.
  - សុន្ទរកថាស្វាគមន៍ដោយ **ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាន និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**.
  - ថតរូបអនុស្សាវរីយ៍ និងពិសាអាហារសម្រន់

- **វគ្គធ្វើបទបង្ហាញ និងពិភាក្សា**

  ថ្ងៃទី១៖ ពេលព្រឹក

  - បទបង្ហាញស្តីពីប្រព័ន្ធច្បាប់ស៊ីវិល
  - បទបង្ហាញស្តីពីប្រព័ន្ធច្បាប់អង់គ្លូសាក់សុង
  - បទបង្ហាញស្តីពីប្រព័ន្ធច្បាប់សាសនាហិណ្ឌូ
  - បទបង្ហាញស្តីពីទស្សនវិជ្ជាចិនបុរាណ

  ថ្ងៃទី១៖ ពេលរសៀល

  - បទបង្ហាញស្តីពីទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម
  - វគ្គសំណួរ និងចម្លើយ៖ វាគ្មិន ៥រូប នៃប្រធានបទទី១ និងអ្នកសម្របសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកា
  - បទបង្ហាញស្តីពីប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន
  - វេទិកាពិភាក្សា និងសំណួរ-ចម្លើយ៖ វាគ្មិន ៤រូប និងអ្នកសម្របសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកា

  ថ្ងៃទី២៖ ពេលព្រឹក

  - បទបង្ហាញស្តីពីការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា
  - វេទិកាពិភាក្សា និងសំណួរ-ចម្លើយ៖ វាគ្មិន ៦រូប និងអ្នកសម្របសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកា

  ថ្ងៃទី២៖ ពេលរសៀល

  - វេទិកាពិភាក្សាស្តីពីទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា

- វាគ្មិន ៦រូប និងអ្នកសម្របសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកាពិភាក្សា និងសំណួរ ចម្លើយ

- **កម្មវិធីបិទ**

- សុន្ទរកថាបិទកម្មវិធីដោយ **ឯកឧត្តម ទង្សី ទិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជាប្រធាន **គ.ក.ច**.
- កម្មពិធីប្រគល់វត្ថុអនុស្សាវរីយ៍ និងលិខិតថ្លែងអំណរគុណ

គ. ដំណាក់កាលក្រោយកម្មវិធី

- ក្រោយកម្មវិធីសិក្ខាសាលាត្រូវបានបិទបញ្ចប់ អ្នកជំនាញការច្បាប់និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. សម្របសម្រួល និងជូនដំណើរត្រឡប់របស់ថ្នាក់ដឹកនាំ វាគ្មិន សមាជិកក្រុមសិក្សាស្រាវជ្រាវ និងអ្នកពាក់ព័ន្ធ
- អ្នកជំនាញការច្បាប់និងមន្ត្រីនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. រៀបចំឧបករណ៍ សម្ភារ និងធ្វើដំណើរត្រឡប់មកភ្នំពេញវិញ
- អ្នកជំនាញការច្បាប់នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. រៀបចំសេចក្តីប្រកាសព័ត៌មាន និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសិក្ខាសាលា ជូនថ្នាក់ដឹកនាំ
- អ្នកជំនាញការច្បាប់នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច**. ធ្វើការប្រមូលផ្តុំកិច្ចការស្រាវជ្រាវ របាយការណ៍លទ្ធផលនៃកិច្ចពិភាក្សា និងចងក្រងជារបាយការណ៍លទ្ធផលស្រាវជ្រាវចុងក្រោយ ជាក់ជូនថ្នាក់ដឹកនាំពិនិត្យនិងលើកទិសដៅបន្ត។

ដើម្បីញ៉ាំងឱ្យកម្មវិធី **សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា** មានដំណើរការរលូន និងទទួលបានលទ្ធផលតាមការរំពឹងទុក របៀបវារៈនៃអង្គសិក្ខាសាលាត្រូវបានរៀបចំ ដូចមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃឯកសារទស្សនាទាននេះ។

ឧបសម្ព័ន្ធទី១៖ តារាងបញ្ជីឈ្មោះក្រុមស្រាវជ្រាវ


បញ្ជីឈ្មោះក្រុមស្រាវជ្រាវ និងអ្នកសម្របសម្រួល	
ប្រធានបទទី១	**ប្រព័ន្ធច្បាប់ចំៗលើសកលលោក** ១. ប្រធានបទ **ប្រព័ន្ធច្បាប់ស៊ីវិល** សិក្សានិងធ្វើបទបង្ហាញដោយ **Dr. Vernon Valentine Palmer** សាស្ត្រាចារ្យនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ទូលឡេន (Tulane University) ២. ប្រធានបទ **ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង** សិក្សានិងធ្វើបទបង្ហាញដោយលោកស្រីចៅក្រម **Dato Mary Lim Thiam Suan** អតីតចៅក្រមនៃតុលាការកំពូល ប្រទេសម៉ាឡេស៊ី ៣. ប្រធានបទ **ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ** សិក្សានិងធ្វើបទបង្ហាញដោយសាស្ត្រាចារ្យ **Gopika Solanki** សាស្ត្រាចារ្យនីតិសាស្ត្រ នៃសាកលវិទ្យាល័យ ខាឡេតុន (Caleton University) ៤. ប្រធានបទ **ទស្សនវិជ្ជាចិនបុរាណ** សិក្សានិងធ្វើបទបង្ហាញដោយ **Dr. Yu Kam Por** សមាជិកកិត្តិយសនៃសកលវិទ្យាល័យ ហុងកុង ផូលីតិកនិក (The Hong Kong Polytechnic University) ៥. ប្រធានបទ **ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម** សិក្សានិងធ្វើបទបង្ហាញដោយលោក **ហោច មណីចិន្តា** ប្រធានអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍ ក្រុមសម្របសម្រួល និងបដិសណ្ឋារកិច្ច (**អ.ភ.ក.ច.**) - លោក **ហួរ ប៉ូពិឆាន** អ្នកជំនាញការច្បាប់ - លោក **នៅ ជានន្ទ** អ្នកជំនាញការច្បាប់
ប្រធានបទទី២	**ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន** ១. **អ្នកសម្របសម្រួលរួម៖** ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក **គ.ភ.ច.** និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម ២. ឯកឧត្តម **លី ឌុច** អនុប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សានីតិកម្ម ក.ស.ហ.វ. ផ្នែក *"សម័យបុរេប្រវត្តិ សម័យហ្វូណន និងសម័យចេនឡា"* ៣. **អ្នកសម្របសម្រួល៖** លោកបណ្ឌិត **ឃុយ ចាន់ឆួន** អនុប្រធានវិទ្យាស្ថានវប្បធម៌និងវិចិត្រសិល្បៈ នៃរាជបណ្ឌិត្យសភាកម្ពុជា ៤. ឯកឧត្តម **លឹម សុវណ្ណា** អនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ៥. ឯកឧត្តម **ស៊ីយ៉ុន សុភារិទ្ធ** អនុរដ្ឋលេខាធិការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

	ផ្នែក *"សម័យអង្គរ"* ៦. **អ្នកសម្របសម្រួលៈ** សាស្ត្រាចារ្យបណ្ឌិត **ឆង់ សុធារ៉ា** សាស្ត្រាចារ្យប្រវត្តិវិទ្យា និងជាប្រធានដេប៉ាតឺម៉ង់ប្រវត្តិវិទ្យានៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ៧. ឯកឧត្តម **ស៊ាង ផល្លា** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធានលេខាធិការដ្ឋាន ក្រុមប្រឹក្សានីតិកម្ម ៨. ឯកឧត្តមបណ្ឌិត **ហាយ ម៉ារ៉ា** ប្រធានវិទ្យាស្ថានភាសាជាតិ នៃរាជបណ្ឌិត្យសភាកម្ពុជា ៩. ឯកឧត្តម **អ៊ឹម សុខឃ្លី** ទីប្រឹក្សា ក.ស.វ. និងជាប្រធាននាយកដ្ឋានស្រាវជ្រាវ បណ្តុះបណ្តាល ផ្សព្វផ្សាយ នៃអាជ្ញាធរជោតិអប្សរា ១០. ឯកឧត្តម **ហ៊ុន ឈុនតេង** ជំនួយការសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងជាសាស្ត្រាចារ្យជំនួយនៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ផ្នែក *"សម័យកណ្តាល (សម័យក្រោយអង្គរដល់សម័យអាណាព្យាបាលបារាំង)"* ១១. **អ្នកសម្របសម្រួលៈ** ឯកឧត្តម **ពៅ សារឿន** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ ១២. ឯកឧត្តមបណ្ឌិត **សឿន សុភ័ណ** សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ១៣. ឯកឧត្តម **សួង សុខរ៉ូ** ជំនួយការសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី និងជានាយកប្រតិបត្តិនៃអង្គការផ្សព្វផ្សាយប្បេជម៌ខ្មែរ យសោធរ ផ្នែក *"សម័យទំនើប (សម័យអាណាព្យាបាលបារាំង ដល់បច្ចុប្បន្ន) និងវាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន"* ១៤. **អ្នកសម្របសម្រួលៈ** ឯកឧត្តមបណ្ឌិត **ហាស ម៉ារ៉ា** រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានកិច្ចការព្រំដែន និងជាសមាជិកគណៈកម្មាធិការដឹកនាំ ១៥. ឯកឧត្តម **ស សាម៉ីឌី** រដ្ឋលេខាធិការ ក្រសួងមុខងារសាធារណៈ ១៦. ឯកឧត្តម **លី តៃសេង** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ និងជាប្រធានគ្រប់គ្រងក្រុមហ៊ុនមេធាវី HBS ១៧. លោក **ហ៊ឹម ណារិទ្ធិ ដេវ៉ី** ប្រធានមជ្ឈមណ្ឌលជាតិមជ្ឈត្តការពាណិជ្ជកម្មកម្ពុជា ១៨. លោក **ប៊ុន ឃូឌី** នាយកគ្រប់គ្រងការិយាល័យមេធាវី ប៊ុន និងសហការី ១៩. លោក **តិន សុវត្ថិ** ប្រធានការិយាល័យមេធាវី អេស ឌី អេស ក្រុមសម្របសម្រួល និងបដិសណ្ឋារកិច្ច (**គ.ក.ច.**) - លោក **ម៉ន សុភ័ណ** អ្នកជំនាញការច្បាប់ - លោក **ហាយ សីហា** អ្នកជំនាញការច្បាប់
ប្រធានបទទី៣	**ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងចិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**

	១. **អ្នកសម្របសម្រួលរួម៖** ឯកឧត្តមបណ្ឌិតសភាចារ្យ **សុក ស៊ីផាន់ណា** ទេសរដ្ឋមន្ត្រី ទទួលបន្ទុកបេសកកម្មពិសេស និងជាអនុប្រធាន **គ.ក.ច.** **ប្រធានបទ៖ ការអំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** ២. **អ្នកសម្របសម្រួល៖** ឯកឧត្តមបណ្ឌិត **ស៊ា ម៉ៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់ ៣. ឯកឧត្តម **តាំង រតនា** អគ្គលេខាធិការនៃក្រុមប្រឹក្សាធម្មនុញ្ញ និងជាប្រធានក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៤. ឯកឧត្តមបណ្ឌិត **ថេង ច័ន្ទសង្វារ** រដ្ឋលេខាធិការ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ និងជាសមាជិក គ.ក.ច. ៥. ឯកឧត្តម **ឃក់ ប៊ុនណា** រដ្ឋលេខាធិការប្រចាំការ ក្រសួងមុខងារសាធារណៈ ៦. ឯកឧត្តម **អេង ឆ្ងួច** រដ្ឋលេខាធិការ និងជាអនុប្រធានក្រុមប្រឹក្សាអ្នកច្បាប់ ៧. ឯកឧត្តម **ប៊ុន ហុន** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាសមាជិក គ.ក.ច. ៨. ឯកឧត្តម **សួន ឥសាល** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ៩. ឯកឧត្តម **តាន់ ហ៊ាង ជាវ័ណ្ណ** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ១០. ឯកឧត្តម **សាន់ រ៉ាជា** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ១១. ឯកឧត្តមបណ្ឌិត **លឹម ស៊ុយហុង** អនុរដ្ឋលេខាធិការ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ១២. ឯកឧត្តម **អ៊ុត ស៊ីណាត** សមាជិកនិងជាអគ្គលេខាធិការរងក្រុមប្រឹក្សាអ្នកច្បាប់ ១៣. ឯកឧត្តម **ពេជ អង្គ** ប្រធានក្រុមការងារពាណិជ្ជកម្មនៃក្រុមប្រឹក្សាអ្នកច្បាប់ ១៤. សាស្ត្រាចារ្យបណ្ឌិត **អ៊ុន ណាង** ព្រឹទ្ធបុរសមហាវិទ្យាល័យសង្គមសាស្ត្រ និងមនុស្សសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញ ១៥. លោក **ណុច រ៉ាម៉ូ** ប្រធានលេខាធិការដ្ឋានសាលាភូមិន្ទរដ្ឋបាល ១៦. កញ្ញា **ចឹម សុភាព** មេធាវីនៃក្រុមហ៊ុនមេធាវី អេស វ៉ី កី ១៧. លោកស្រី KASUMI Nakagawa អ្នកស្រាវជ្រាវយេនឌ័រ និងច្បាប់ នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា **ប្រធានបទពិភាក្សា៖ ឯសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា** (សិក្សាស្រាវជ្រាវ និងមិនធ្វើបទបង្ហាញ សម្រាប់ប្រមូលធាតុចូលបន្ថែមពីវេទិកាពិភាក្សា) ១៨. **អ្នកសម្របសម្រួល៖** ឯកឧត្តម **លី ច័ន្ទតុលា** រដ្ឋលេខាធិការ អនុប្រធាន និងជាអគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ១៩. ព្រះតេជគុណបណ្ឌិត **សាន ពិសិដ្ឋ** ប្រធានផ្នែកស្រាវជ្រាវ នៃពុទ្ធិកសាកលវិទ្យាល័យព្រះសីហនុរាជ ២០. លោកជំទាវ **ជា ណង** អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល ២១. ឯកឧត្តមបណ្ឌិត **សេង ឆាង** អនុប្រធានតុលាការកំពូល

	២២. ឯកឧត្តម **ម៉ុង មុនីចរិយោ** ប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ ២៣. ឯកឧត្តមបណ្ឌិតរដ្ឋ **ឈន ព្រលឹង** ប្រធានបណ្ឌិត្យសភាភូមិន្ទយុត្តិធម៌កម្ពុជា ២៤. ឯកឧត្តមបណ្ឌិត **ឃី សុភណ្ណរតនា** រដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ២៥. ឯកឧត្តម **ជីវ សុខហាក់** រដ្ឋលេខាធិការ ក្រសួងយុត្តិធម៌ ២៦. ឯកឧត្តម **គង់ ផល្លៈ** រដ្ឋលេខាធិការ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ២៧.ឯកឧត្តម**អ៊ឹម ស៊ីថុល**រដ្ឋលេខាធិការប្រចាំការក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ២៨. ឯកឧត្តម **ប៉ែន ប៊ុនឈា** អគ្គលេខាធិការរង នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.** ២៩. ឯកឧត្តម **ហឿន សំឡេង** អគ្គលេខាធិការរងនៃអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ៣០. ឯកឧត្តមសាស្ត្រាចារ្យ **ហោ ប៉ែន** សាកលវិទ្យាធិការនៃសាកលវិទ្យាល័យជាតិគ្រប់គ្រង ៣១. ឯកឧត្តម **ស៊ីន សួន** សាស្ត្រាចារ្យនីតិសាស្ត្រ នៃសាកលវិទ្យាល័យអន្តរជាតិ ផាភ៉ាហ្គន និងជាអតីតតំណាងអចិន្ត្រៃយ៍កម្ពុជា ប្រចាំអង្គការសហប្រជាជាតិ ៣២. សាស្ត្រាចារ្យ Gavin Flood ជំនាញនីតិសាស្ត្រ ក្រុមសម្របសម្រួល និងបដិសណ្ឋារកិច្ច (**គ.ក.ច.**) - លោក **រៀប សុចានី** អនុប្រធាននាយកដ្ឋានគោលនយោបាយនិងផែនការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិកែទម្រង់ច្បាប់ (គ.ក.ច.) - លោក **ង៉ិញ សុមេត្តា** អ្នកជំនាញការច្បាប់ - លោកស្រី **ឡេង ចាន់តូច** អ្នកជំនាញការច្បាប់

ឧបសម្ព័ន្ធទី២៖ គំនូសបួនជ្រុងវេទិកា និងតុអង្គុយ



ឧបសម្ព័ន្ធទី៣៖ រៀបចារ:

ម៉ោង	កម្មវិធី	រយៈពេល
ថ្ងៃទី២៦ តុលា ២០២៥៖ មុនថ្ងៃកម្មវិធីសិក្ខាសាលា		
១៨:៣០ - ២១:៣០	ពិធីពិសាភោជនីយាហារស្វាគមន៍ (Welcoming Reception) - សុន្ទរកថាស្វាគមន៍ ដោយ **ឯកឧត្តម ឥន្ទ្រី ទិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និង **ជាប្រធានគណៈកម្មាធិការជីកណាំការកែច្នៃច្បាប់** (**គ.ក.ច.**)	១៨០ នាទី
ថ្ងៃទី២៧ តុលា ២០២៥៖ កម្មវិធីសិក្ខាសាលាថ្ងៃទី១		
០៧:៣០ - ០៨:០០	ការអញ្ជើញមកដល់ និងចុះឈ្មោះអ្នកចូលរួម	៣០ នាទី
០៨:០០ - ០៨:៣០	ការអញ្ជើញមកដល់របស់គណៈអធិបតី	៣០ នាទី
០៨:៣០ - ០៨:៤០	គោរពភ្លេងជាតិនៃព្រះរាជាណាចក្រកម្ពុជា	១០ នាទី
០៨:៤០ - ០៩:០០	សុន្ទរកថាស្វាគមន៍ដោយ **ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាន និងជាអគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋាន **គ.ក.ច.**	២០ នាទី
០៩:០០ - ០៩:២០	សុន្ទរកថាបើកកម្មវិធីដោយ **ឯកឧត្តម ឥន្ទ្រី ទិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជាប្រធាន **គ.ក.ច.**	២០ នាទី
០៩:២០ - ០៩:៤០	ថតរូបអនុស្សាវរីយ៍ និងពិសាអាហារសម្រន់	២០ នាទី
០៩:៤០ - ១០:១០	**បទបង្ហាញប្រធានបទទី១៖ ប្រព័ន្ធច្បាប់ចំៗលើសកលលោក** - បទបង្ហាញស្តីពី **ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម** ដោយលោក **ហោ ម៉ណីចិន្តា** ប្រធានអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍	៣០ នាទី
១០:១០ - ១០:៤០	- បទបង្ហាញស្តីពី **ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង** ដោយលោកស្រីចៅក្រម Dato Mary Lim Thiam Suan	៣០ នាទី
១០:៤០ - ១១:១០	- បទបង្ហាញស្តីពី **ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ** ដោយសាស្ត្រាចារ្យ Gopika Solanki	៣០ នាទី
១១:១០ - ១១:៤០	- បទបង្ហាញស្តីពី **ទស្សនវិជ្ជាចិនបុរាណ** ដោយ Dr. Yu Kam Por	៣០ នាទី
១១:៤០ - ១៤:០០	សម្រាកពិសាអាហារថ្ងៃត្រង់	១៤០ នាទី
១៤:០០ - ១៤:៣០	- បទបង្ហាញស្តីពី **ប្រព័ន្ធច្បាប់ស៊ីវិល** ដោយ Dr. Vernnon Valentine Palmer	៣០ នាទី
១៤:៣០ - ១៥:០០	**សំណួរ ឆ្លើយ៖** ក្តិន ៥រូប និងអ្នកសម្របសម្រួល ១រូប ត្រូវបានអញ្ជើញឡើងលើវេទិកា - លោក **ហ៊ឹម ណារិទ្ធ ភេស** អ្នកសម្របសម្រួល	៣០ នាទី

ម៉ោង	កម្មវិធី	រយៈពេល
	- លោក **ហេចម៉ណីចិន្តា** Dr. Vernnon Valentine Palmer លោកស្រីចៅក្រម Dato Mary Lim Thiam Suan សាស្ត្រាចារ្យ Gopika Solanki និង Dr. Yu Kam Por	
១៥:០០ - ១៥:២០	សម្រាកពិសាអាហារសម្រន់	២០ នាទី
១៥:២០ - ១៦:២០	**បទបង្ហាញប្រធានបទទី២៖ ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន** - ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក **គ.ក.ច**. និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម	៦០ នាទី
១៦:២០ - ១៧:៣០	**វេទិកាពិភាក្សា និងសំណួរ-ឆ្លើយ៖** វាគ្មិន ៧រូប ត្រូវបានអញ្ជើញឡើងលើវេទិកា - ឯកឧត្តម **ហ៊ែល ចំរើន** អ្នកសម្របសម្រួល - ឯកឧត្តមបណ្ឌិត **ហាសប៊ូរ៉ា** បណ្ឌិត **ឆាយ សុផារ៉ា** សាស្ត្រាចារ្យបណ្ឌិត **ឃុយ ចាន់ឆួន** និង ឯកឧត្តម **ភៅ សារឿន**	៧០ នាទី
១៨:៣០ - ២១:៣០	ពិសាអាហារពេលល្ងាច	១៨០ នាទី
ចប់កម្មវិធីថ្ងៃទី១		
ថ្ងៃទី២៨ តុលា ២០២៥៖ កម្មវិធីសិក្ខាសាលាថ្ងៃទី២		
០៨:០០ - ០៨:៥០	ការអញ្ជើញមកដល់ និងចុះឈ្មោះអ្នកចូលរួម	៥០ នាទី
០៨:៥០ - ០៩:០០	ការអញ្ជើញមកដល់នៃគណៈអធិបតី	១០ នាទី
០៩:០០ - ១០:០០	**បទបង្ហាញប្រធានបទទី៣៖ អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា** - ឧត្តមបណ្ឌិត **សា ម៉ៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី អនុប្រធាន និងជាអគ្គលេខាធិការក្រុមប្រឹក្សាអ្នកច្បាប់	៦០ នាទី
១០:០០ - ១០:៣០	សម្រាកពិសាអាហារសម្រន់	៣០ នាទី
១០:៣០ - ១១:៣០	**វេទិកាពិភាក្សា និងសំណួរ-ឆ្លើយ៖** វាគ្មិន ៧រូប ត្រូវបានអញ្ជើញឡើងលើវេទិកា - ឯកឧត្តមបណ្ឌិត **សា ម៉ៅ** អ្នកសម្របសម្រួល - ឯកឧត្តម **ប៊ុន ហុន** ឯកឧត្តមបណ្ឌិត **លឹម ស៊ុយហុង** ឯកឧត្តម **អ៊ុក ស៊ីណាត** ឯកឧត្តម **ពេជ អន្ត** សាស្ត្រាចារ្យបណ្ឌិត **អ៊ុន លាង** និង លោកស្រី Kasumi Nakagawa	៦០ នាទី
១១:៣០ - ១៣:៣០	សម្រាកពិសាអាហារថ្ងៃត្រង់	១២០ នាទី

ម៉ោង	កម្មវិធី	រយៈពេល
១៣:៣០ - ១៥:០០	**វេទិកាពិភាក្សា៖ ប្រធានបទស្តីពីទិសដៅឆ្ពោះទៅរកយុទ្ធសាស្ត្រនៃប្រព័ន្ធច្បាប់កម្ពុជា** - ឯកឧត្តម **លី ច័ន្ទតុលា** អ្នកសម្របសម្រួល - ឯកឧត្តមបណ្ឌិត **សេង ឆាង** ឯកឧត្តម **ម៉ុង មុនីចរិយា** ឯកឧត្តម **គង់ ផល្លៈ** ឯកឧត្តមបណ្ឌិត **ឃី សុវណ្ណរតនា** ឯកឧត្តមសាស្ត្រាចារ្យ **ហោ ប៉ែន** និង Dr. Gavin Flood - អ្នកចូលរួមទាំងអស់នៅខាងមុខវេទិកាពិភាក្សាអាចផ្តល់អនុសាសន៍ និងមតិយោបល់លើប្រធានបទ និងសួរសំណួរទៅកាន់វាគ្មិនខាងលើវេទិកាពិភាក្សា	៩០ នាទី
១៥:០០ - ១៥:៤០	សម្រាកពិសាអាហារសម្រន់	៤០ នាទី
១៥:៤០ - ១៦:៣០	សុន្ទរកថាបិទកម្មវិធីដោយ **ឯកឧត្តម ឥន្ទ្រី ទិស្សុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី** និងជាប្រធាន **គ.ក.ច.**	៥០ នាទី
១៦:៣០ - ១៧:០០	កម្មពិធីប្រគល់វត្ថុអនុស្សាវរីយ៍ និងលិខិតថ្លែងអំណរគុណ	
ចប់កម្មវិធីថ្ងៃទី២		

*** គ.ក.ច. រក្សាសិទ្ធិកែប្រែក្នុងករណីចាំបាច់។*

ឧបសម្ព័ន្ធទី៤៖ តារាងការងារអ្នកសម្របសម្រួលរបស់ អ.គ.ក.ច.

ដំណាក់កាល	ការងារ	ទទួលដោយ
ប្រធានបទទី១៖ ប្រព័ន្ធច្បាប់ធំៗលើសកលលោក		
មុនកម្មវិធី	- រៀបចំអាសយដ្ឋានសារអេឡិកត្រូនិក (Email) តំណាងអគ្គលេខាធិការដ្ឋាន ស្នើសុំលទ្ធភាពនៃការចូលរួម - រៀបចំលិខិតអញ្ជើញផ្លូវការ ចុះហត្ថលេខាដោយ ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ - រៀបចំកិច្ចប្រជុំចង្អៀតជាមួយវាគ្មិនបរទេសដឹកនាំដោយឯកឧត្តមអគ្គលេខាធិការ ឬអ្នកជំនាញការច្បាប់ - ទំនាក់ទំនងជាប់ជាប្រចាំជាមួយវាគ្មិន អំពីវឌ្ឍនភាព និងបញ្ហាផ្សេងៗ - ត្រៀមសំបុត្រយន្តហោះ កន្លែងស្នាក់នៅ ការធ្វើដំណើរក្នុងស្រុក និងជានាក់ប់រង - ស្នើសុំបទបង្ហាញ និងអត្ថបទស្រាវជ្រាវរបស់វាគ្មិន តាមថិរវេលាកំណត់ ជូនអ្នកបកសរុបលទ្ធផលរបាយការណ៍ស្រាវជ្រាវ	ហ្ស៊ូ ប៉ូពិធាន នៅ ដានន្ទ
អំឡុងពេលកម្មវិធី	- តេស្តបទបង្ហាញ ជម្រាបវាគ្មិនអំពីពិធីការ - សហការជាមួយអ្នកបកប្រែ ការពារកំហុសពីការបកប្រែឱ្យបានតិចបំផុត - ជម្រាបវាគ្មិនអំពីថិរវេលា ករណីបទបង្ហាញលើសម៉ោង - កត់ត្រាសំណួរជូនវាគ្មិន ឬបញ្ជាក់បន្ថែម ករណីវាគ្មិនទទួលសំណួរមិនច្បាស់ - ជំនួយការវាគ្មិន	
ក្រោយកម្មវិធី	- រៀបចំលិខិតថ្លែងអំណរគុណជូនវាគ្មិន ចុះហត្ថលេខាដោយឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ - សង្ខេបបទបង្ហាញ និងលទ្ធផលសំណួរចម្លើយ ជូនអ្នកបកសរុបរបាយការណ៍ - ផ្ញើលិខិតថ្លែងអំណរគុណជូនវាគ្មិនតាមរយៈ សារអេឡិកត្រូនិក និងកម្រងរូបថត ឬ Link Facebook នៃកម្មវិធីសិក្ខាសាលា	

ដំណាក់កាល	ការងារ	ទទួលដោយ
ប្រធានបទទី២៖ ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន		
មុនកម្មវិធី	- ស្នើសុំប្រធានក្រុម បង្កើតក្រុមតេលេក្រាម - រៀបចំកិច្ចប្រជុំចង្អៀតក្នុងក្រុមអាចតាមរយៈ Zoom ឬដោយផ្ទាល់ (សិក្សាទីតាំង) - រៀបចំរបាយការណ៍កិច្ចប្រជុំចង្អៀត ជូនឯកឧត្តមអគ្គលេខាធិការ - តាមដាន រាយការណ៍ បញ្ជាក់ជូនអ្នកចូលរួមនូវវឌ្ឍនភាពការងារ - លើកសំណូមពរជូនអ្នកចូលរួមករណីចាំបាច់ ឬលើកសំណើជំណោះស្រាយ សុំយោបល់ពី ឯកឧត្តមអគ្គលេខាធិការ - ស្នើសុំបទបង្ហាញ និងអត្ថបទស្រាវជ្រាវ តាមចិរវេលាដែលបានកំណត់ ជូនអ្នកបូកសរុបលទ្ធផលរបាយការណ៍ស្រាវជ្រាវ	ម៉ន សុភ័ណ មាយ សីហា
អំឡុងពេលកម្មវិធី	- សម្របសម្រួលការធ្វើបទបង្ហាញរបស់វាគ្មិន - ជម្រាបវាគ្មិនអំពីចិរវេលា ករណីបទបង្ហាញលើសម៉ោង - កត់ត្រាសំណួរ ជូនវាគ្មិន - ជំនួយការវាគ្មិន	
ក្រោយកម្មវិធី	- សង្ខេបបទបង្ហាញ និងលទ្ធផលសំណួរចម្លើយ ជូនអ្នកបូកសរុបរបាយការណ៍	
ប្រធានបទទី៣៖ បូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា		
មុនកម្មវិធី	- ស្នើសុំប្រធានក្រុម បង្កើតគ្រុបតេលេក្រាម - រៀបចំកិច្ចប្រជុំចង្អៀតក្នុងក្រុមអាចតាមរយៈ Zoom ឬដោយផ្ទាល់ (សិក្សាទីតាំង) - រៀបចំរបាយការណ៍កិច្ចប្រជុំចង្អៀត ជូនឯកឧត្តមអគ្គលេខាធិការ - តាមដាន រាយការណ៍ បញ្ជាក់ជូនអ្នកចូលរួមនូវវឌ្ឍនភាពការងារ - លើកសំណូមពរជូនអ្នកចូលរួមករណីចាំបាច់ ឬលើកសំណើជំណោះស្រាយ សុំយោបល់ពីឯកឧត្តមអគ្គលេខាធិការ - រៀបចំកម្រងសំណួរជូនប្រធានក្រុម ដឹកនាំវេទិកាពិភាក្សា - ស្នើសុំបទបង្ហាញ និងអត្ថបទស្រាវជ្រាវ តាមចិរវេលាដែលបានកំណត់ ជូនអ្នកបូកសរុបលទ្ធផលរបាយការណ៍ស្រាវជ្រាវ	អៀប សុធានី មិញ សុមេត្តា ឡេង ចាន់ភួង
អំឡុងពេលកម្មវិធី	- សម្របសម្រួលការធ្វើបទបង្ហាញរបស់វាគ្មិន - សម្របសម្រួលវេទិកាពិភាក្សា (ទីតាំងអង្គុយ មេក្រូ ក្រដាសប៊ិច ។ល។)	

ដំណាក់កាល	ការងារ	ទទួលដោយ
	- ជម្រាបវាគ្មិនអំពីថិរវេលា ករណីបទបង្ហាញ និងកិច្ចពិភាក្សាលើសម៉ោងកំណត់ - កត់ត្រាសំណួរ ជូនវាគ្មិន - ជំនួយការវាគ្មិន	
ក្រោយកម្មវិធី	សង្ខេបបទបង្ហាញ និងលទ្ធផលសំណួរចម្លើយ ជូនអ្នកបូកសរុបរបាយការណ៍	

ឧបសម្ព័ន្ធទី៥៖ បញ្ជីសកម្មភាព និងឯកសារពាក់ព័ន្ធ

តារាងកិច្ចការមុនកម្មវិធី

លរ.	តារាងកិច្ចការ	ក្របខ័ណ្ឌពេល					អ្នកទទួលបន្ទុក
		កញ្ញា W3-W4	តុលា W1-W2	តុលា W3-W4	កញ្ញា W1-W2	កញ្ញា W3-W4	
១	រៀបចំលិខិតបង្គាប់ការ (ចុះហត្ថលេខាដោយ **ឯកឧត្តមអគ្គលេខាធិការ**) ដើម្បីបង្កើតក្រុមការងាររៀបចំសិក្ខាសាលាជាផ្លូវការ និងដើម្បីប្រគល់តួនាទី និងភារកិច្ចស្របតាមបញ្ជីតាមដានសកម្មភាពនេះ	✓					ផ្ទៃបាល
២	សិក្សាទីតាំងប្រារព្ធពិធី		✓				ឱន ស៊ីដែន ច័ន្ទតារា រ៉ូម៉ែន មុិញ សុមេត្តា ផ្ទៃបាល
៣	រៀបចំគម្រោងចំណាយសម្រាប់កម្មវិធីទាំងមូល	✓					ផ្ទៃបាល និងហិរញ្ញិកិច្ច
៤	រៀបចំរបៀបវារៈសិក្ខាសាលា (ខ្មែរ និងអង់គ្លេស)	✓					ប៉ែន លីនណា ច័ន្ទតារា រ៉ូម៉ែន
៥	បញ្ជីអ្នកចូលរួម វាគ្មិន និងក្រុមពិភាក្សា	✓					គោគ សិរីរតនា ហួរ ប៉ូពិធាន នៅ ដានន្ទ
៦	ទំនាក់ទំនង និងបញ្ជាក់រួចរាល់ នៃបញ្ជីអ្នកចូលរួម		✓				គោគ សិរីរតនា ហួរ ប៉ូពិធាន នៅ ដានន្ទ
៧	សេចក្តីព្រាងទស្សនាទានចុងក្រោយ	✓					ម៉ន សុភ័ណ រួម
៨	ប័ណ្ណកម្មវិធីសិក្ខាសាលា		✓				ប៉ែន លីនណា មុិញ សុមេត្តា
៩	សេចក្តីសម្រេចស្តីពីការបង្កើតក្រុមការងារស្រាវជ្រាវ	✓					ឡេង ចាន់ភួង
១០	កំណត់តម្រូវការបន្ទប់ស្នាក់នៅ (សម្រាប់ក្រុមការងារ និង		✓				ផ្ទៃបាល

លរ.	តារាងកិច្ចការ	ក្របខ័ណ្ឌពេល					អ្នកទទួលបន្ទុក
		កក្កដា W3-W4	សីហា W1-W2	សីហា W3-W4	កញ្ញា W1-W2	កញ្ញា W3-W4	
	ក្នុងករណី ត្រូវកក់ជូនថ្នាក់ដឹកនាំ និងភ្ញៀវកិត្តិយស)						
១១	ទាក់ទងទៅកាន់សណ្ឋាគារ ដើម្បីកក់ទីតាំង និង Facilities ពាក់ព័ន្ធ (ដូចជា Projector តុ កៅអី ឆាក ផ្ការប្រព័ន្ធសម្លេង ភ្លើរខៀន អាហារសម្រន់ និងអាហារថ្ងៃត្រង់ ។ល។)			✓			ផ្ទៃបាល
១២	រៀបចំឧបករណ៍ និងសេវាបកប្រែ ខ្មែរ - អង់គ្លេស និង អង់គ្លេស - ខ្មែរ		✓				ផ្ទៃបាល
១៣	រៀបចំលិខិតអញ្ជើញទៅកាន់សមាសភាពអ្នកចូលរួម វាគ្មិន និងក្រុមពិភាក្សា និងលិខិតស្នើសុំគោលការណ៍ឯកភាពលើចំណាយអ្នកចូលរួមបរទេស		✓				ផ្ទៃបាល ហ្វរ ប៉ុពិធាន និងនៅដ្ឋានន្ទ (វាគ្មិនបរទេស)
១៤	ប្រមូលរបាយការណ៍ស្រាវជ្រាវ និងបទបង្ហាញពីក្រុមស្រាវជ្រាវ					✓	ប៉ែន លីនណា
១៥	រៀបចំកិច្ចប្រជុំចង្អៀតតាមក្រុម ដើម្បីប្រមូលធាតុចូល			✓	✓	✓	ក្រុមសម្របសម្រួល
១៦	រៀបចំរបាយការណ៍សង្ខេបស្តីពីលទ្ធផលកិច្ចការស្រាវជ្រាវ (បញ្ចូលខ្លឹមសារ)					✓	មាឃ សីហា និង ម៉ន សុភ័ណ
១៧	រៀបចំបទបង្ហាញស្តីពីកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងការប្រព្រឹត្តទៅនៃអង្គសិក្ខាសាលា សម្រាប់			✓			ឱន ស៊ីដែន

លរ.	តារាងកិច្ចការ	ក្របខ័ណ្ឌពេល					អ្នកទទួលបន្ទុក
		កក្កដា W3-W4	សីហា W1-W2	សីហា W3-W4	កញ្ញា W1-W2	កញ្ញា W3-W4	
	គោរពជូន **ឯកឧត្តមអគ្គលេខាធិការ**						
១៨	រៀបចំឯកសារជំនួយស្មារតី និងសុន្ទរកថាជូន **ឯកឧត្តមអគ្គលេខាធិការ**			✓			ឱន ស៊ីដែន
១៩	រៀបចំសុន្ទរកថាបើក និងបិទ សម្រាប់គោរពជូន**ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ**			✓			ឡេង ចាន់កូង
២០	រៀបចំឯកសារជំនួយស្មារតី សម្រាប់គោរពជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ**			✓			ឡេង ចាន់កូង
២១	រៀបចំសំណុំឯកសារពាក់ព័ន្ធ សម្រាប់អ្នកចូលរួមទាំងអស់ (QR Code)					✓	ណេង សីហា និង ហួរ ប៉ូពិធាន
២២	បោះពុម្ពសំណុំឯកសារពាក់ព័ន្ធ					✓	ក្រុមការងារផ្សព្វផ្សាយ
២៣	សេចក្តីប្រកាសព័ត៌មាន			✓	✓	✓	ណេង សីហា គោគ សិរីរតនា
២៤	រៀបចំគម្រោងចំណាយ សម្រាប់កម្មវិធីទាំងមូល	✓					រដ្ឋបាល និងហិរញ្ញកិច្ច

តារាងកិច្ចការអំឡុងពេលកម្មវិធី

លរ.	សកម្មភាព	អ្នកទទួលបន្ទុក
១	ថ្លែងមតិស្វាគមន៍ភ្ញៀវកិត្តិយស និងសម្របសម្រួលការប្រព្រឹត្តទៅនៃសិក្ខាសាលា (ពិធីករ)	ប៉ែន លីនណា ច័ន្ទតារា រ៉ូម៉ែន
២	ចុះវត្តមាន និងបដិសណ្ឋារកិច្ច (ពិធីការ)	រដ្ឋបាល
៣	អ្នកបូកសរុបលទ្ធផលនៃអង្គសិក្ខាសាលា	ឱន ស៊ីដែន
៤	ជួយកិច្ចការទូទៅ	ពេជ្រ សុវណ្ណថាវ័ត្ត
៥	សម្របសម្រួលកិច្ចដំណើរការកម្មវិធី	អ្នកសម្របសម្រួលតាមក្រុម

តារាងកិច្ចការត្រៀមពេលកម្មវិធី

ល.រ	សកម្មភាព	អ្នកចងក្រងបន្ទុក
១	រៀបចំរបាយការណ៍ស្តីពីលទ្ធផលនៃសិក្ខាសាលា	ម៉ិញ សុមេត្តា មាឃ សីហា កោគ សិរីរតនា
២	ផ្សព្វផ្សាយព័ត៌មាន	ក្រុមការងារផ្សព្វផ្សាយ
៣	ចងក្រងឯកសារ និងរក្សាទុកសម្រាប់ការសិក្សាស្រាវជ្រាវ	ប៉ែន លីនណា

ឧបសម្ព័ន្ធទី២៖
សុន្ទរកថានៃសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា



សុន្ទរកថា
ឯកឧត្តម វង្សី វិស្សុត
ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់
ថ្លែងក្នុងកម្មពិធីបើក
សិក្ខាសាលាស្តីពី "ប្រព័ន្ធច្បាប់កម្ពុជា"

ថ្ងៃចន្ទ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥
ទីតាំងសណ្ឋាគារ Angkor Century Resort and Spa

- ***ព្រះតេជគុណបណ្ឌិត ឯកឧត្តម*** ថ្នាក់ដឹកនាំក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល
- ***ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនិងសមាជិក គ.ក.ច.***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងអ្នកជំនាញជាតិ និងអន្តរជាតិ ជាទីមេត្រី!***

ខ្ញុំសូមថ្លែងអំណរគុណដល់ **ឯកឧត្តម លី ច័ន្ទតុលា** អនុប្រធាននិងអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ចំពោះរបាយការណ៍ប្រកបដោយលទ្ធផលដ៏ល្អប្រសើ និងសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែង និងទំនួលខុសត្រូវខ្ពស់ក្នុងការដឹកនាំរៀបចំ និងសម្របសម្រួលសិក្ខាសាលាទាំងមូល។

ថ្ងៃនេះ ខ្ញុំមានសេចក្តីសោមនស្សក្រៃលែង ដោយបានចូលរួមជាអធិបតីក្នុងកម្មវិធីបើកសិក្ខាសាលាស្តីពី "**ប្រព័ន្ធច្បាប់កម្ពុជា**" នៅខេត្តសៀមរាប ដែលជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រ នៅលើទឹកដីនៃអតីតរាជធានីបុរាណដែលជាអត្តសញ្ញាណនៃអរិយធម៌ខ្មែរ និងជានិមិត្តរូបនៃច្បាប់ សណ្តាប់ធ្នាប់ និងភាពសុខដុមរមនា។

ខ្ញុំសូមថ្លែងអំណរគុណដល់ **ព្រះតេជគុណបណ្ឌិត ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ បញ្ញវន្ត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវផ្នែកនីតិសាស្ត្រ ប្រវត្តិវិទ្យា បុរាណវិទ្យា អារ្យធម៌ វប្បធម៌ អ្នកប្រកបវិជ្ជាជីវៈច្បាប់ និងភាគីពាក់ព័ន្ធក្នុងវិស័យច្បាប់ ដែលបានចំណាយពេលដ៏មានតម្លៃ និងមមាញឹកដើម្បីចូលរួមសិក្សាស្រាវជ្រាវ តាក់តែងអត្ថបទ ពិភាក្សាពិគ្រោះយោបល់ និងចូលរួមសិក្ខាសាលាក្នុងរយៈពេល ២ថ្ងៃនេះ។ ខ្ញុំក៏សូមថ្លែងអំណរគុណជាពិសេស ដល់អ្នកជំនាញអន្តរជាតិដែលបានផ្តល់កិត្តិយស និងធ្វើដំណើរពីចម្ងាយដើម្បីចូលរួមជាមួយយើងខ្ញុំទាំងអស់គ្នានាថ្ងៃនេះ តបតាមការអញ្ជើញរបស់ខ្ញុំ។ ខ្ញុំក៏សូមកោតសរសើរដល់ក្រុមការងាររៀបចំសិក្ខាសាលាទាំងអស់ដែលបានប្រឹងប្រែងអស់កម្លាំងកាយចិត្តក្នុងរយៈពេលជាច្រើនខែដើម្បីសិក្ខាសាលានេះលេចចេញជារូបរាងឡើង។ កិច្ចខិតខំប្រឹងប្រែងរួមនេះ ឆ្លុះបញ្ចាំងអំពីឆន្ទៈ និងការប្តេជ្ញាចិត្តខ្ពស់ក្នុងការធ្វើកំណែទម្រង់ប្រព័ន្ធច្បាប់ និងការសិក្សាស្រាវជ្រាវអំពីច្បាប់។

សិក្ខាសាលានេះ ត្រូវបានរៀបចំឡើងនៅក្នុងដំណាក់កាលមួយដ៏សំខាន់របស់កម្ពុជា។ រាជរដ្ឋាភិបាលនីតិកាលទី៧ នៃរដ្ឋសភា ក្រោមការដឹកនាំដ៏ឈ្លាសវៃ ប្រកបដោយគតិបណ្ឌិត និងភាពប្រាកដនិយមរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** បន្តពី **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភានៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវ "**យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១**" ដើម្បីកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព កសាងមូលដ្ឋានគ្រឹះឆ្ពោះទៅសម្រេចឱ្យបាននូវចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ ក្លាយជាប្រទេសមានចំណូលខ្ពស់ និងបានបន្តយកចិត្តទុកដាក់លើកកម្ពស់ និងពង្រឹងប្រសិទ្ធភាព

ច្បាប់ជាអាទិភាពគន្លឹះមួយ ក្នុងចំណោមអាទិភាពគន្លឹះទាំង៥ នៃ **"ការកែទម្រង់និងការពង្រឹងអភិបាលកិច្ច"** របស់រាជរដ្ឋាភិបាល។ យុទ្ធសាស្ត្រនេះពុំត្រឹមតែជាឯកសារបង្ហាញផ្លូវប៉ុណ្ណោះទេ តែក៏ជាចក្ខុវិស័យវែងឆ្ងាយដើម្បីកសាងសង្គមមួយដែលរឹងមាំប្រកបដោយបរិយាបន្ន និងផ្អែកលើច្បាប់។

ស្នូលនៃយុទ្ធសាស្ត្របញ្ចកោណបានកំណត់យ៉ាងច្បាស់អំពីតួនាទីច្បាប់ និងស្ថានប័នដែលជាឆ្អឹងខ្នងនៃការអភិវឌ្ឍប្រកបដោយចីរភាព។ ប្រសិនបើប្រព័ន្ធច្បាប់មួយពុំមានភាពពេញលេញ ប្រសិទ្ធភាព និងជំនឿទុកចិត្ត នោះគោលនយោបាយក៏ដូចជាយុទ្ធសាស្ត្រនានានឹងមិនអាចអនុវត្តបាននោះទេ ចំណែកសិទ្ធិរបស់ពលរដ្ឋមិនអាចការពារបាន រីឯចក្ខុវិស័យជាតិក៏នឹងមិនអាចសម្រេចបានផងដែរ។ អាស្រ័យហេតុនេះរាជរដ្ឋាភិបាលបានកំណត់ការធ្វើកំណែទម្រង់ជាស្នូលនៃយុទ្ធសាស្ត្រដែលគាំទ្រដល់គ្រប់ផ្នែកទាំងអស់នៃការអភិវឌ្ឍជាតិ។

សិក្ខាសាលារយៈពេល២ថ្ងៃនេះ គឺជាវេទិកាមួយដែលនឹងផ្តល់ឱកាសជូនដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បញ្ញវន្តច្បាប់ ប្រវត្តិវិទ្យា បុរាណវិទ្យា អរិយធម៌ វប្បធម៌ និងរួមទាំងអ្នកជំនាញការជាតិ និងអន្តរជាតិ បានជួបជុំ ជជែក វែកញែក ពិភាក្សា ចែករំលែកគំនិត ទស្សនៈ បទពិសោធន៍ជាក់ស្តែង ផ្តល់ជាតុចូលជាមតិយោបល់ និងជាពិសេសអត្ថបទស្រាវជ្រាវ តាមប្រធានបទនីមួយៗ ពាក់ព័ន្ធនឹងទិដ្ឋភាពទូទៅ និងការវិវត្តនៃប្រព័ន្ធច្បាប់ធំៗ លើសកលលោក ដំណើរវិវត្តនិងស្ថានភាពនៃប្រព័ន្ធច្បាប់កម្ពុជា ការកំណត់អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា និងឈានឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា និងរៀបចំនិម្មាបនកម្មប្រព័ន្ធច្បាប់កម្ពុជាស្របទៅនឹងយុទ្ធសាស្ត្រទាំង៥ របស់យុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១រួមមាន៖ (១). ការអភិវឌ្ឍមូលធនមនុស្ស (២). ការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង (៣). ការអភិវឌ្ឍវិស័យឯកជន និងការងារ (៤). ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន (៥). ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល។ ប្រព័ន្ធច្បាប់មានតួនាទីយ៉ាងសំខាន់ដើម្បីសម្រេចបានយុទ្ធសាស្ត្រទាំង៥

ដូចតទៅ៖ ចំពោះការអភិវឌ្ឍមូលធនមនុស្ស ប្រព័ន្ធច្បាប់ធានាសមភាព និងគុណភាព នៃការអប់រំ ការងារ និងសុខុមាលភាព ដែលជាមូលដ្ឋានសម្រាប់កសាងពលរដ្ឋដែលមានសមត្ថភាព និងសីលធម៌។ រីឯការធ្វើពិពិធកម្មសេដ្ឋកិច្ច និងការបង្កើនភាពប្រកួតប្រជែង ប្រព័ន្ធច្បាប់ធានាស្ថិរភាព និងសមភាពក្នុងការធ្វើពាណិជ្ជកម្ម វិនិយោគ និងនវានុវត្តន៍ ដែលនឹងជម្រុញសមត្ថភាពប្រកួតប្រជែង។ ចំណែកការអភិវឌ្ឍវិស័យឯកជន និងការងារ ប្រព័ន្ធច្បាប់ការពារបុគ្គលិក និងធុរកិច្ចដែលជម្រុញដល់ការបង្កើនជំនឿទុកចិត្ត និងការងារ។ សម្រាប់ការអភិវឌ្ឍប្រកបដោយភាពធន់, ចីរភាព និងបរិយាបន្ន ប្រព័ន្ធច្បាប់ការពារបរិស្ថាន និងយុត្តិធម៌សង្គម ធានានូវការអភិវឌ្ឍប្រកបដោយតុល្យភាព និងបរិយាបន្ន។ ជាចុងក្រោយការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមឌីជីថល ប្រព័ន្ធច្បាប់ការពារស្ថិរភាព និងប្រតិបត្តិការក្នុងលំហឌីជីថល។

តាមរយៈការផ្សាភ្ជាប់ប្រព័ន្ធច្បាប់ និងយុទ្ធសាស្ត្រអភិវឌ្ឍជាតិ សិក្ខាសាលានាថ្ងៃនេះជាយន្តការក្នុងការកសាងគោលនយោបាយសម្រាប់អភិវឌ្ឍជាតិមួយផងដែរ ដែលពុំត្រឹមជាវេទិកាពិភាក្សាផ្នែកសិក្សាស្រាវជ្រាវប៉ុណ្ណោះទេ។ ក្នុងន័យនេះ ខ្ញុំយល់ឃើញថា **"ប្រទេសមួយ ត្រូវមានប្រព័ន្ធច្បាប់មួយ"** ដើម្បីដោះស្រាយបញ្ហារបស់មនុស្សនិងសង្គមដោយពុំមែនជាការបង្កើតបញ្ហាបន្ថែម ឬការបង្កើតបន្ទុកនោះទេ មានន័យថា **បើជាក់ច្បាប់នៅលើមនុស្ស ច្បាប់នោះ ត្រូវតែល្អនិងត្រូវមានប្រយោជន៍រួម ពិសេសត្រូវសំដៅសមនឹងតថភាពជាក់ស្តែងនិងត្រូវបម្រើឱ្យការការពារជាតិ ការកសាងជាតិ និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ច ក៏ដូចជាការការពារសិទ្ធិ និងសេរីភាពបុគ្គល**។

ក្នុងស្មារតីនេះ គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ហៅកាត់ថា **គ.ក.ច.** ត្រូវបានបង្កើតឡើងតាមរយៈព្រះរាជក្រឹត្យលេខនស/រកត/០២២៤/១៥០ ចុះថ្ងៃទី៣ ខែកុម្ភៈ ឆ្នាំ២០២៤ ដឹកនាំដោយទីស្តីការគណៈរដ្ឋមន្ត្រី ដែលផ្តោតលើការកែទម្រង់ច្បាប់ទាំងមូលរបស់ប្រទេស។ ជាមួយគ្នានេះ **"ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល"** ត្រូវបានអនុម័តដោយប្រមុខរាជរដ្ឋាភិបាល កាលពីថ្ងៃទី២៤ ខែមេសា ឆ្នាំ២០២៥ ជាមួយនឹងចក្ខុវិស័យ **"គ.ក.ច.ជានិម្មាបនកនៃប្រព័ន្ធច្បាប់និងវប្បធម៌នីតិរដ្ឋ**

ដោយផ្អែកលើគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល" ក្នុងបេសកកម្ម "**ដឹកនាំ និងសម្របសម្រួលការកែទម្រង់ច្បាប់កម្ពុជាឱ្យទៅជាប្រព័ន្ធច្បាប់មួយដែលមានឯកភាព ប្រសិទ្ធភាព សមានគតិភាព ឧត្តមានុភាពគតិយុត្ត និងសន្តិសុខគតិយុត្ត ស្របតាមឧត្តមានុវត្តន៍អន្តរជាតិ និងបរិការណ៍កម្ពុជា**"។ ដើម្បីសម្រេចបានចក្ខុវិស័យនេះ យុទ្ធសាស្ត្រគន្លឹះចំនួន ៤ និងកម្មវិធីការងារចំនួន ១៩ ត្រូវបានដាក់ចេញសម្រាប់អនុវត្តចំពោះមុខ។ ក្នុងន័យនេះ ដើម្បីជានាភាពពេញលេញនៃក្របខ័ណ្ឌយុទ្ធសាស្ត្រកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ក្របខ័ណ្ឌទស្សនាទានចំនួន២ ក៏នឹងត្រូវកសាងឡើង រួមមានក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា និងក្របខ័ណ្ឌទស្សនាទាននៃការកសាងវប្បធម៌នីតិរដ្ឋ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

នៅក្នុងបរិបទនៃទំនើបភាវូបនីយកម្ម និងសាកលភាវូបនីយកម្មនៃប្រព័ន្ធច្បាប់បាននាំឱ្យប្រព័ន្ធច្បាប់នាពេលបច្ចុប្បន្ន មានភាពចម្រុះ និងច្រើនស្រទាប់ដែលលាយឡំដោយច្បាប់បែបប្រពៃណីផង ច្បាប់បែបទំនើបផង ជាមួយទស្សនវិជ្ជាផ្សេងៗដែលបាននិងកំពុងស្ថិតនៅជាមួយគ្នាដោយសុខដុមនីយកម្មខ្លះ ដោយបដិវាទកម្ម/អសង្គតិភាពខ្លះ និងដោយស្រពិចស្រពិលខ្លះដោយមិនត្រូវបានយកមកអនុវត្តជ្បិតមិនឆ្លើយតបទៅនឹងស្ថានភាពជាក់ស្តែងរបស់សង្គមជាតិ។

ដូចប្រទេសជាច្រើននៅក្នុងតំបន់ ប្រព័ន្ធច្បាប់កម្ពុជាបានចាប់ផ្តើមឡើងតាមរយៈការបន្សាំពីច្បាប់បរទេសតាមរយៈឥទ្ធិពលអាណានិគម និងការកសាងប្រទេសឡើងវិញក្រោយសង្គ្រាម។ ទោះជាយ៉ាងណាក៏ដោយ កម្ពុជាបានឆ្លងផុតដំណាក់កាលនេះ ដោយឈានដល់ដំណាក់កាលថ្មីនៃប្រវត្តិសាស្ត្រជាតិ តាមរយៈការចាប់ផ្តើមបង្កើតអត្តសញ្ញាណប្រព័ន្ធច្បាប់របស់ខ្លួនដែលឆ្លុះបញ្ចាំងអំពីគុណតម្លៃ បរិការណ៍ និងចក្ខុវិស័យរបស់ជាតិ។

កាបន្សាំពីច្បាប់បរទេស គឺមានសារៈសំខាន់សម្រាប់ការកសាងស្ថានប័នឡើងវិញរួមទាំងរចនាសម្ព័ន្ធ ក៏ប៉ុន្តែដើម្បីឱ្យប្រព័ន្ធច្បាប់នោះមានបូរណភាព គឺចាំបាច់ត្រូវ

ឆ្លើយតបទៅនឹងបរិការណ៍សង្គម ដែលតម្រូវឱ្យច្បាប់បរទេសដែលបានបន្សាំទាំងនោះ មានសុខុដុមនីយកម្មជាមួយគុណតម្លៃ បរិការណ៍ និងចក្ខុវិស័យរបស់ជាតិ។

បច្ចុប្បន្ន កម្ពុជាបានចាប់ផ្តើមទំព័រថ្មីនៃប្រវត្តិសាស្ត្ររបស់ខ្លួនក្រោមម្លប់នៃសន្តិភាព និងការឯកភាពជាតិរឹងមាំ។ កិច្ចការរបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ រួមទាំងបុគ្គលពាក់ព័ន្ធទាំងអស់គឺប្រែក្លាយក្របខ័ណ្ឌច្បាប់ពីបរទេសដែលបានបន្សាំកន្លងមកឱ្យក្លាយទៅជាប្រព័ន្ធច្បាប់មួយដែលមានសុខុដុមនីកម្ម ឯកសណ្ឋានភាវូបនីយកម្ម និងឈានទៅដល់បូរណភាពនៃប្រព័ន្ធច្បាប់ទាំងមូល ដែលបញ្ជាក់អំពីអត្តសញ្ញាណច្បាស់លាស់របស់កម្ពុជាដោយពុំគ្រាន់តែចម្លងពីបរទេសនោះឡើយ។ ក្នុងន័យនេះសំដៅដល់ការរៀបចំប្រព័ន្ធច្បាប់ដោយផ្អែកទៅលើគុណតម្លៃ បរិការណ៍ និងចក្ខុវិស័យរបស់ជាតិ ព្រមទាំងគុណតម្លៃសាកល ឧត្តមានុវត្តន៍អន្តរជាតិ និងកាតព្វកិច្ចអន្តរជាតិ ដោយរក្សាអត្តសញ្ញាណវប្បធម៌ជាតិ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

គោលបំណងនៃសិក្ខាសាលារយៈពេលពីរថ្ងៃនេះ គឺដើម្បីប្រែក្លាយចំណេះដឹង និងបទពិសោធន៍របស់ថ្នាក់ដឹកនាំ និងអ្នកជំនាញជាតិ និងអន្តរជាតិទាំងអស់ទៅជាផែនទីបង្ហាញផ្លូវសម្រាប់ការកែទម្រង់ច្បាប់នៅកម្ពុជា តាមរយៈគោលដៅដូចខាងក្រោម៖

១. ស្វែងយល់អំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក៖ ប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ ទស្សនវិជ្ជាចិនបុរាណ ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម ដើម្បីកំណត់ចំណុចដែលអាចអនុវត្តន៍នៅកម្ពុជាបាន។

២. វិភាគមូលដ្ឋានគ្រឹះនៃការវិវត្តប្រព័ន្ធច្បាប់កម្ពុជា៖ ពីសម័យបុរេប្រវត្តិ សម័យអង្គរ សម័យកណ្តាល ដល់សម័យទំនើប។

៣. វាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន៖ វាយតម្លៃអំពីចំណុចវិជ្ជមាន អវិជ្ជមាន បញ្ហាប្រឈមនានា និងផ្តល់ជាដំណោះស្រាយនិងជម្រើស

៤. កំណត់ធាតុផ្សំនៃអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា៖ ដែលផ្សារភ្ជាប់ទៅនឹងគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល

៥. កំណត់ទិសដៅក្នុងការកសាងប្រព័ន្ធច្បាប់កម្ពុជា៖ ដើម្បីជាប្រទីបបង្ហាញផ្លូវក្នុងការកែទម្រង់ច្បាប់ដោយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់។

ផ្អែកតាមរបាយការណ៍ និងការរៀបរាប់អំពីដំណើរការប្រព្រឹត្តិទៅរបស់សិក្ខាសាលា ដោយ **ឯកឧត្តម លី ច័ន្ទតុលា** ខ្ញុំជឿជាក់យ៉ាងមុតមាំថាអង្គសិក្ខាសាលារយៈពេល ២ថ្ងៃនេះនឹងសម្រេចគោលបំណងខាងលើប្រកបដោយជោគជ័យ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ក្នុងកិច្ចដំណើរការកសាងរដ្ឋ ប្រព័ន្ធច្បាប់ប្រៀបបាននៅនឹងម៉ាស៊ីនដែលប្រែក្លាយគោលបំណងទៅជាលទ្ធផល ព្រោះប្រព័ន្ធច្បាប់បង្កើតភាពស្របច្បាប់នៃសកម្មភាពរបស់រដ្ឋតាមរយៈរដ្ឋធម្មនុញ្ញ, សម្របសម្រួលទំនាក់ទំនងរវាងស្ថាប័ន ទីផ្សារ និងប្រជាពលរដ្ឋតាមរយៈច្បាប់និងលិខិតបទដ្ឋានគតិយុត្តជាក់លាក់, ផ្តល់ការលើកទឹកចិត្តដល់ការអនុវត្តន៍ច្បាប់ និងផ្តន្ទាទោសដល់ការរំលោភច្បាប់, ការពារសិទ្ធិ និងការទទួលបានយុត្តិធម៌, អនុវត្តគោលនយោបាយតាមរយៈការប្រែក្លាយផែនការទៅជាកាតព្វកិច្ច។ ទាំងនេះជាកម្លាំងចលករជម្រុញល្បឿននៃការកសាងរដ្ឋ។

សិក្ខាសាលារបស់យើងបានកំណត់រួចហើយនូវប្រធានបទសម្រាប់កិច្ចពិភាក្សា ប៉ុន្តែខ្ញុំស្នើសុំអង្គសិក្ខាសាលា ពិចារណាបន្ថែមជុំវិញសេរស្តេម្តចំនួន៥ ដែលនឹងរួមចំណែកដល់ការសម្រេចនូវការអនុវត្តយុទ្ធសាស្ត្របញ្ចកោណជំណាក់កាលទី១ របស់រាជរដ្ឋាភិបាលសំដៅកសាងគ្រឹះដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០ រួមមាន៖

ទី១. កម្លាំងបង្រួបបង្រួម (Unity) សំដៅដល់ការសាមគ្គីគ្នាជាឆ្អឹងមួយ ដើម្បីជំនះឧបសគ្គធំៗ និងបញ្ហាប្រឈមថ្មីៗនាពេលអនាគត។

ទី២. កម្លាំងការពារ(Defense) សំដៅដល់ការការពារប្រទេសឱ្យមានអត្ថិភាពបូរណភាពទឹកដី អធិបតេយ្យ និង ឯករាជ្យ ព្រមទាំងការពារផលប្រយោជន៍ជាតិជាធំ។

ទី៣. កម្លាំងកសាង(Building) គឺការធ្វើឱ្យមានភាពរីកចម្រើនស្នើគ្រប់វិស័យ ដើម្បីសម្រេចបានកំណើនសេដ្ឋកិច្ចខ្ពស់ វឌ្ឍនភាពសង្គម និងការរីកដុះដាលវប្បធម៌។

ទី៤. កម្លាំងស្ថិរកម្ម (Stability) មានយន្តការប្រតិតុល្យការ យន្តការដោះស្រាយជម្លោះ និងការគ្រប់គ្រងវិបត្តិ រួមមាន៖ វិបត្តិសេដ្ឋកិច្ច នយោបាយ និងសង្គម យន្តការបង្ការ និងការអនុវត្តគោលនយោបាយស្ថិរកម្ម

ទី៥. កម្លាំងគាំពារ (Protection) សំដៅដល់គាំពារសង្គម ជំនួយសង្គម និងកិច្ចការពារបរិស្ថានធម្មជាតិ។

ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី!

ដើម្បីសម្រេចបានលទ្ធផលដូចបានរំពឹងទុកសិក្ខាសាលារយៈពេល ២ថ្ងៃនេះ ខ្ញុំសូមលើកទឹកចិត្ត **ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់** ប្រើប្រាស់ពេលវេលា និងបញ្ញាញាណឱ្យអស់សក្តានុពល ក្នុងការចែករំលែក ផ្លាស់ប្តូរ ផ្សារភ្ជាប់នូវបទពិសោធន៍ ចំណេះដឹង និង ជំនាញវិជ្ជាជីវៈនៃការបំពេញមុខងារតាមឯកទេសរៀងៗខ្លួន។ ការចូលរួមដ៏សកម្មរបស់ **ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់** នឹងជួយគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក្នុងការកសាងផែនទីបង្ហាញផ្លូវសម្រាប់អនុវត្តច្បាស់លាស់ក្នុងការកសាងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា។ លើសពីនេះ ខ្ញុំក៏សូមលើកទឹកចិត្តដល់ **ឯកឧត្តម លោកជំទាវ លោក លោកស្រីទាំងអស់** ជាពិសេសអ្នកជំនាញអន្តរជាតិ បន្តរក្សាទំនាក់ទំនងជិតស្និទ្ធ និងកិច្ចសហប្រតិបត្តិការល្អក្រោយបញ្ចប់សិក្ខាសាលានេះ។

មុននឹងបញ្ចប់ ជាថ្មីម្តងទៀតខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** ជាថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បញ្ញវន្តច្បាប់ ប្រវត្តិសាស្ត្រ រួមទាំងអ្នកជំនាញការជាតិ និងជាពិសេសសាស្ត្រាចារ្យអន្តរជាតិ ដែលបានលះបង់ពេលវេលាដ៏មានតម្លៃ រួមទាំងកម្លាំងកាយ កម្លាំងចិត្ត គំនិត ប្រាជ្ញា ចូលរួមសហការគ្នាយ៉ាងល្អ និងគាំទ្រគ្នាទៅវិញទៅមកក្នុងពេលកន្លងទៅ ប្រកបដោយវិជ្ជាជីវៈខ្ពស់ ស្មារតីភាពជាម្ចាស់ និងការ

ទទួលខុសត្រូវក្នុងការរួមចំណែកជាធាតុចូលសម្រេចបាននូវខ្លឹមសារសម្រាប់កម្មវិធីនាពេលនេះ។ ខ្ញុំក៏សូមកោតសរសើរ ចំពោះ **ឯកឧត្តម លី ច័ន្ទតុលា** អគ្គលេខាធិការ គ.ក.ច. អគ្គលេខាធិការរង **អ្នក**ជំនាញការច្បាប់ មន្ត្រី និងបុគ្គលិក នៃអគ្គលេខាធិការដ្ឋាន គ.ក.ច. ដែលបានបំពេញការងារជាសេនាធិការយ៉ាងល្អ ប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ជាមួយនឹងការប្តេជ្ញាចិត្តចំពោះការងារកែទម្រង់ច្បាប់ រហូតសម្រេចបាននូវការរៀបចំសិក្ខាសាលាដែលមានតម្លៃជាប្រវត្តិសាស្ត្រនេះ។

ជាទីបញ្ចប់ ខ្ញុំសូមប្រគេនពរ និងជូនពរ **ឯកឧត្តម លោកជំទាវ លោក លោកស្រី** និងអង្គពិធីទាំងមូល សូមសមប្រកបដោយ សុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន ព្រមជាមួយនឹងសេចក្តីសុខ និងសេចក្តីចម្រើនគ្រប់ប្រការក្រោមម្លប់នៃសុខសន្តិភាព ព្រមទាំងពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបើក សិក្ខាសាលាស្តីពី "ប្រព័ន្ធច្បាប់កម្ពុជា" ចាប់ពីពេលនេះតទៅ។

សូមអរគុណ!

សុន្ទរកថា

ឯកឧត្តម ង៉ស្សី ង៉ិសសុត

ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

ក្នុងកម្មវិធីបិទ

សិក្ខាសាលាស្តីពី "ប្រព័ន្ធច្បាប់កម្ពុជា"

ថ្ងៃចន្ទ ៦កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ពុទ្ធសករាជ ២៥៦៩
ត្រូវនឹងថ្ងៃទី២៧ ខែតុលា ឆ្នាំ២០២៥
ទីតាំងសណ្ឋាគារ Angkor Century Resort and Spa

- ***ព្រះតេជគុណបណ្ឌិត ឯកឧត្តម*** ថ្នាក់ដឹកនាំក្រសួង ស្ថាប័ននានារបស់រាជរដ្ឋាភិបាល
- ***ឯកឧត្តម លោកជំទាវ ថ្នាក់ដឹកនាំនិងសមាជិក គ.ក.ច.***
- ***ឯកឧត្តម លោកជំទាវ លោក លោកស្រី សាស្ត្រាចារ្យ និងអ្នកជំនាញជាតិ និងអន្តរជាតិ ជាទីមេត្រី!***

នាពេលនេះ សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជាបានឈានដល់ទីបញ្ចប់ ទំព័រថ្មីនៃការកែទម្រង់ច្បាប់ក៏ត្រូវបានចាប់ផ្តើម ដើម្បីសម្រេចបាននូវការកសាងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា។

ក្រោយពីបានស្តាប់ និងចូលរួមពិភាក្សាក្នុងអង្គសិក្ខាសាលាអស់រយៈពេល ២ថ្ងៃ កន្លងមកនេះ ខ្ញុំសូមថ្លែងអំណរគុណចំពោះ វាគ្មិនទាំងអស់ដែលបានធ្វើបទបង្ហាញ យ៉ាងក្បោះក្បាយ អ្នកសម្របសម្រួលវេទិកាពិភាក្សាដែលបានសម្របសម្រួលយ៉ាងប៉ិនប្រសប់ និងសូមថ្លែងអំណរគុណចំពោះសមាជិកអង្គសិក្ខាសាលាទាំងអស់ដែលបានចូលរួមយ៉ាងសកម្ម និងត្រងត្រាប់ស្តាប់យ៉ាងយកចិត្តទុកដាក់ក្នុងរយៈពេល ២ថ្ងៃនេះ។ ខ្ញុំក៏សូមវាយតម្លៃខ្ពស់ដល់ **ឯកឧត្តម លី ច័ន្ទតុលា** និងក្រុមការងាររៀបចំសិក្ខាសាលា ដែលបានខិតខំប្រឹងប្រែងរៀបចំត្រៀម និងដំណើរការសិក្ខាសាលាទាំងមូលប្រកបដោយការទទួលខុសត្រូវនិងវិជ្ជាជីវៈ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

គោលបំណងនៃសិក្ខាសាលានេះ គឺដើម្បីសិក្សាអំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក សិក្សាវិភាគប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរាណដល់បច្ចុប្បន្ន ដើម្បីធ្វើការវាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន កំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងរៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា ដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា។ តទៅនេះ ខ្ញុំនឹងធ្វើការសង្ខេបអំពីប្រធានបទដែលបានពិភាក្សារយៈពេល ២ថ្ងៃកន្លងទៅនេះ។

នៅថ្ងៃទី១ អង្គសិក្ខាសាលាបានចាប់ផ្តើមពិភាក្សាអំពីប្រព័ន្ធច្បាប់ធំៗនៅលើសាកលលោក ដើម្បីសំយោគគំនិតសំខាន់ៗសម្រាប់អនុវត្តនៅកម្ពុជា។

ក្នុងនោះ**ប្រព័ន្ធច្បាប់ស៊ីវិល** គឺជាប្រព័ន្ធច្បាប់ដែលមានវ័យចំណាស់ជាងគេ និងត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយនៅលើពិភពលោក ដោយមានឫសគល់ចេញពីច្បាប់រ៉ូម៉ាំង ទំនៀមទម្លាប់របស់ជនជាតិអាល្លឺម៉ង់ និងច្បាប់សាសនា ហើយអត្តសញ្ញាណនៃប្រព័ន្ធច្បាប់ស៊ីវិល គឺជាប្រព័ន្ធច្បាប់ដែលមានក្រមនីយកម្មជាលាយលក្ខណ៍អក្សរ ហើយច្បាប់នេះមានឧត្តមភាពកំពូលក្នុងការសម្រេចចិត្តរបស់តុលាការ ជាមួយនឹងការសង្កត់ធ្ងន់លើរចនាសម្ព័ន្ធច្បាប់ដែលមានលក្ខណៈជាប្រព័ន្ធ និងប្រកបដោយតក្កកម្ម

ដោយសារឫសគល់នៃប្រព័ន្ធច្បាប់នេះកើតចេញពីច្បាប់រ៉ូម៉ាំង និងផ្នត់គំនិតរបស់អ្នកច្បាប់អឺរ៉ុបនាសម័យ Enlightenment Rationalism។ **ចំពោះប្រព័ន្ធច្បាប់អង់គ្លូសាក់សុង** គឺជាប្រព័ន្ធច្បាប់មួយដែលមានដើមកំណើតនៅប្រទេសអង់គ្លេសនាសម័យយុគកណ្តាលដែលមានលក្ខណៈពិសេសគឺប្រភពនៃច្បាប់ធម្មនុញ្ញរបស់ប្រទេសមួយចំនួនពុំត្រូវបានចងក្រងជាអត្ថបទសរសេរតែមួយនោះទេ និងប្រទេសមួយចំនួនទៀត រដ្ឋធម្មនុញ្ញត្រូវបានចងក្រងជាអត្ថបទសរសេរតែមួយ ប៉ុន្តែខ្លឹមសារនៃរដ្ឋធម្មនុញ្ញនោះត្រូវបានបកស្រាយលម្អិតតាមរយៈសេចក្តីសម្រេចតុលាការវិញ ចំណែកចៅក្រមមានតួនាទីជាអ្នកបកស្រាយច្បាប់ផងនិងជាអ្នកបង្កើតច្បាប់ផង ដោយសារដំណោះស្រាយរបស់តុលាការលើវិវាទណាមួយ ត្រូវផ្អែកលើយុត្តិសាស្ត្រជាសេចក្តីសម្រេចរបស់តុលាការ ដែលបានសម្រេចកន្លងមក។ **រីឯ ប្រព័ន្ធច្បាប់សាសនា** គឺជាប្រព័ន្ធច្បាប់នៃការប្រតិបត្តិ និងគុណតម្លៃ ដែលផ្សារភ្ជាប់បុគ្គល ឬសហគមន៍ទៅនឹងជំនឿ ដែលក្នុងនោះ មានដូចជា ពិធីសាសនា ក្រមសីលធម៌ និងទស្សនវិជ្ជា។ អាស្រ័យហេតុនេះ សាសនាជាច្បាប់ដំបូងរបស់សង្គមដែលកំណត់នូវឥរិយាបថ និងក្រមសីលធម៌របស់ប្រជាជនទូទៅ។ ប្រព័ន្ធច្បាប់សាសនា គ្របដណ្តប់លើគ្រប់ទិដ្ឋភាពនៃបុគ្គល គ្រួសារ និងសង្គម រាប់ចាប់ពីគោលការណ៍សីលធម៌មូលដ្ឋាន ដូចជាការហាមសម្លាប់ លួច ឬកុហក រហូតដល់បញ្ហាស្មុគស្មាញផ្សេងៗ។ **ច្បាប់ហិណ្ឌូ** ជាប្រព័ន្ធនៃទំនៀមទម្លាប់ និងវិធានដែលបានសង្កេតមើលក្នុងរយៈពេលវែង ដែលបានចារឹកនៅក្នុងអត្ថបទសំស្ក្រឹតនិងហិណ្ឌូជាច្រើនដូចមានកស្តុតាងដែល ព្រះរាជា បានរក្សាទុកលិខិតបទដ្ឋានគតិយុត្តទាំងនេះដល់បច្ចុប្បន្ន។ មិនតែប៉ុណ្ណោះ **ទំនៀមនិងទស្សនវិជ្ជាច្បាប់ចិនបុរាណ** នៅតែបន្តជះឥទ្ធិពលលើរចនាសម្ព័ន្ធសង្គម និងរដ្ឋបាលរបស់ប្រទេសចិនមកដល់ពេលបច្ចុប្បន្ន។ ទស្សនវិទូជាច្រើនក្រុមនៅក្នុងរាជវង្សចូវខាងកើត (ចន្លោះពីឆ្នាំ៧៧០ ដល់ឆ្នាំ២៥៦ មុនគ.ស.) បានផ្តល់មូលដ្ឋានបញ្ញាដ៏សំបូរបែប ដែលជះឥទ្ធិពលលើច្បាប់ សីលធម៌ និងស្ថាប័នរបស់ចិន។ ក្នុងចំណោមក្រុមទាំងនោះ លទ្ធិខុងជឺ (Confucianism) និងនីតិនិយម(Legalism) បានចូលរួមចំណែកគួរឱ្យកត់សម្គាល់លើច្បាប់ ការគ្រប់គ្រង និងការដោះស្រាយវិវាទក្នុងប្រទេសចិន ដែលមានគោលការណ៍

ច្បាប់ គឺច្បាប់។ ចំពោះ**ព្រះពុទ្ធសាសនា**បានលេចឡើងនូវនិកាយទាំងពីរដែលគេហៅថា និកាយហីនយាន និងនិកាយមហាយាន ដែលសុទ្ធសឹងតែជាសាសនាបានកើតនៅឥណ្ឌា នៅសម័យដើមមុនគ្រិស្តសករាជ។ កម្ពុជា ជាប្រទេសដែលប្រជាជនភាគច្រើន កាន់ពុទ្ធ សាសនាបែបថេរវាទ។ ពុទ្ធសាសនាត្រូវបានកំណត់ជាសាសនារបស់រដ្ឋ ដោយរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ហើយសាសនាដ៏មានតម្លៃនេះបានជ្រាបចូលយ៉ាងជ្រៅក្នុង អត្តសញ្ញាណ វប្បធម៌ និងអភិបាលកិច្ចខ្មែរ ជាច្រើនជំនាន់មកហើយ។ អស់រយៈពេល ច្រើនសតវត្សកន្លងមកនេះ គោលការណ៍ពុទ្ធសាសនា បានដុះឥទ្ធិពលដល់ច្បាប់ ទំនៀមទម្លាប់ និយាមសង្គម ឥរិយាបថ ផ្នត់គំនិត ជំនឿ វិធីជីវិត។ល។

ជារួម ទាំងប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ប្រព័ន្ធច្បាប់សាសនា និងទស្សនវិជ្ជា បានដុះឥទ្ធិពលជាវិជ្ជមាន ដូចជាប្រភពនៃច្បាប់ វិធានស្ថាប័ន វិធាននីតិវិធី ជាមួយខ្លឹមសារច្បាប់ តាមឧត្តមានុវត្តន៍អន្តរជាតិ និងទស្សនវិជ្ជាពុទ្ធសាសនាដែលហៅ ថាធម្មវិន័យ សំដៅលើធម៌ និងបទប្បញ្ញត្តិនៃការប្រតិបត្តិ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ក្រោយពីបានសិក្សាអំពីប្រព័ន្ធច្បាប់ធំៗលើសាកលលោក អង្គសិក្ខាសាលាបាន បន្តសិក្សាវិភាគប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរាណដល់បច្ចុប្បន្ន ដើម្បីធ្វើការវាយតម្លៃស្ថាន ភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន។

យោងតាមប្រវត្តិសាស្ត្រខ្មែរ ប្រទេសកម្ពុជាត្រូវបានគ្រប់គ្រងដោយអង្គព្រះមហាក្សត្រ ជាសន្តតិវង្សច្រើនជំនាន់ប្រកបដោយទសពិធរាជធម៌ និងគោរពច្បាប់ ដោយទ្រង់លើក តម្កើងច្បាប់ឱ្យខ្ពង់ខ្ពស់ដាក់លើព្រះសិរសា។ ក្នុងន័យនេះ កម្ពុជាត្រូវបានគ្រប់គ្រងអនុលោម តាមច្បាប់ ឬគ្រប់គ្រងដោយច្បាប់ (Rule of Law) តាំងពីសម័យបុរាណរហូតដល់បច្ចុប្បន្ន។ នេះមានន័យថា កម្ពុជាមានប្រវត្តិច្បាប់ជាយូរលង់ ដែលស្របតាមសម័យកាលនីមួយៗ តាមសម័យកាលនៃប្រវត្តិសាស្ត្រកម្ពុជា ជាអាទិ៍ សម័យបុរេប្រវត្តិ សម័យហ្វូណន សម័យ ចេនឡា សម័យអង្គរ សម័យក្រោយអង្គរ សម័យអាណានិគមបារាំង និងសម័យ ក្រោយអាណានិគមរហូតដល់បច្ចុប្បន្ន។ តាមរយៈការពិភាក្សាលើសមាសភាគនៃ

ប្រព័ន្ធច្បាប់ រួមមានយន្តការធ្វើច្បាប់ យន្តការដោះស្រាយជម្លោះវិធាន និងនីតិវិធី យើងអាចវាយតម្លៃជាបឋមអំពីប្រព័ន្ធច្បាប់កម្ពុជាបានថា មិនទាន់មានភាពជាក់លាក់ (uniqueness) របស់ខ្លួននៅឡើយ។ ប្រព័ន្ធច្បាប់ស៊ីវិលដែលទទួលយកតាមរយៈអាណានិគមបារាំងនៅតែជាធាតុចម្បងក្នុងប្រព័ន្ធច្បាប់ខ្មែរ។ ធាតុផ្សំនៃវិធានបុរាណកាន់តែចម្ងាយ រីឯសមាសភាគថ្មីនៃប្រព័ន្ធច្បាប់អង់គ្លូសាក់សុង បានចូលក្នុងប្រព័ន្ធច្បាប់កម្ពុជា តាមរយៈការផ្តល់ជំនួយ និងការចូលរួមក្នុងយន្តការសេកលការបូនីយកម្ម ដែលបង្កជាភាពស្រពេចស្រពិល នាំឱ្យពិបាកក្នុងការអនុវត្តច្បាប់ (ខ្លឹមសារប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ក៏ប៉ុន្តែយន្តការអនុវត្តប្រព័ន្ធច្បាប់ស៊ីវិល។ល។)។ ជារួមប្រព័ន្ធច្បាប់កម្ពុជាក្នុងពេលបច្ចុប្បន្ន គឺជាសមិទ្ធផលនៃប្រវត្តិសាស្ត្ររបស់ប្រទេសកម្ពុជាក្នុងការអនុវត្តប្រព័ន្ធច្បាប់មួយ ស្របតាមស្ថានភាព និងបរិបទរបស់កម្ពុជា និងបរិការណ៍អន្តរជាតិ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

នៅថ្ងៃទី២ អង្គសិក្ខាសាលាបានបន្តមកសិក្សាលើការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា។

ការជះឥទ្ធិពលពីប្រព័ន្ធច្បាប់ធំៗ និងប្រវត្តិនៃការវិវត្តប្រព័ន្ធច្បាប់កម្ពុជាបានជ្រាបចូលក្នុងសរសៃឈាមគ្រប់ផ្នែកនៃរចនាសម្ព័ន្ធសង្គមខ្មែររួចស្រេចអស់កាលយូរមកហើយ ដូច្នេះអ្វីដែលសំខាន់បំផុតគឺការចាប់ផ្តើមជជែកពិភាក្សារួមគ្នាជីកកកាយស្វែងរក និងកំណត់ពីការឯកភាពគ្នាអំពីគុណតម្លៃខ្មែរ(Khmer Values) គួរត្រូវបាននាំយកមកធ្វើសុខដុមនីយកម្មជាមួយគុណតម្លៃនៃប្រព័ន្ធច្បាប់ ដែលកម្ពុជាបានទទួលរងឥទ្ធិពល ដើម្បីឈានទៅរកការកំណត់អត្តសញ្ញាណនៃប្រព័ន្ធច្បាប់កម្ពុជា ប្រកបដោយបូរណភាព។

ជាលទ្ធផលនៃសិក្ខាសាលារយៈពេល២ថ្ងៃនេះ អង្គសិក្ខាសាលាបានយល់ដឹងកាន់តែច្បាស់អំពីទស្សនាទាន និងផ្តល់ការឯកភាពគ្នាជារួមថា **"ប្រទេសកម្ពុជា ត្រូវតែមានប្រព័ន្ធច្បាប់របស់កម្ពុជា"** ដែលជាលក្ខណៈចម្រុះ (Mixed Legal System) កើតចេញពីការរួមផ្សំគ្នារវាងគុណតម្លៃប្រព័ន្ធច្បាប់ទាំងឡាយដែលកម្ពុជាទទួលយក រួមជាមួយនឹង

គុណតម្លៃខ្មែរជាកេតនកណ្ឌសម្គាល់អត្តសញ្ញាណជាតិខ្មែរ **ពោល គឺមានធាតុផ្សំនៃប្រព័ន្ធច្បាប់ស៊ីវិលភាគច្រើន ខ្លឹមសារតាមប្រព័ន្ធច្បាប់អង់គ្លូសាក់សុងមានមួយចំនួន និងឧត្តមានុវត្តន៍អន្តរជាតិមួយចំនួន និងគុណតម្លៃប្រវត្តិសាស្ត្រខ្មែរ ព្រមទាំងបង្កប់នូវទស្សនវិជ្ជាសាសនាផងដែរ។**

ក្រោយពីបានកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា អង្គសិក្ខាសាលាបានបន្តកំណត់ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា ដោយជាដំបូងកំណត់ធាតុផ្សំនៃប្រព័ន្ធច្បាប់រួមមាន មូលដ្ឋានគ្រឹះ (Foundational Ethos) សំដៅដល់គុណតម្លៃបរិការណ៍សង្គម សេដ្ឋកិច្ច នយោបាយ និងវប្បធម៌ ព្រមទាំងគុណតម្លៃ កាតព្វកិច្ច និងឧត្តមានុវត្តន៍អន្តរជាតិ; រចនាសម្ព័ន្ធគតិយុត្ត (Structure) សំដៅដល់តួអង្គដំណើរការច្បាប់រួមមាន ស្ថាប័ន និងអ្នកប្រកបវិជ្ជាជីវៈ; សារធាតុគតិយុត្ត (Substance) សំដៅដល់ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តទាំងអស់; និងវប្បធម៌គោរពច្បាប់ (Culture) សំដៅដល់ការផ្តល់តម្លៃដល់ការគោរពច្បាប់នៅក្នុងការប្រកបវិជ្ជាជីវៈប្រចាំថ្ងៃរបស់អ្នកអនុវត្តច្បាប់ និងការរស់នៅប្រចាំថ្ងៃរបស់សាធារណៈទូទៅ។ លើសពីនេះ ការកសាងប្រព័ន្ធច្បាប់មួយដែលពេញលេញគឺពុំគ្រប់គ្រាន់នោះទេ ពោលគឺត្រូវផ្សារភ្ជាប់ប្រព័ន្ធច្បាប់ទៅនឹងការកសាងរដ្ឋ។ ហេតុនេះទិសដៅបន្ថែមទៅលើក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់ រួមមាន កំណត់មូលដ្ឋានគ្រឹះឱ្យបានច្បាស់លាស់, ពង្រឹងសមត្ថភាព និងភាពប្រទាក់ក្រឡារបស់ស្ថាប័ន និងធនធានមនុស្សដែលបំពេញការងារក្នុងប្រព័ន្ធច្បាប់, ធ្វើកំណែទម្រង់ប្រព័ន្ធអប់រំផ្នែកនីតិសាស្ត្រ, កសាងវប្បធម៌គោរពច្បាប់នៅក្នុងសង្គម, រៀបចំក្រមច្បាប់សម្រាប់ដឹកនាំរដ្ឋដូចគម្ពីអថ៌សាស្ត្រ(Arthashastra), បញ្ញត្តិរាល់ច្បាប់និងលិខិតបទដ្ឋានគតិយុត្តិទាំងឡាយត្រូវស្របតាមចក្ខុវិស័យ និងយុទ្ធសាស្ត្ររបស់រដ្ឋ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ខ្ញុំសូមរំលឹកបន្តិចនូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន អតីតនាយករដ្ឋមន្ត្រី និងបច្ចុប្បន្នជាប្រធានព្រឹទ្ធសភា**

នៃព្រះរាជាណាចក្រកម្ពុជា គឺ "កំណែទម្រង់ គឺជាកិច្ចការស្លាប់រស់របស់កម្ពុជា បើយើងរួមគ្នាធ្វើកំណែទម្រង់នោះ ទើបយើងសង្ឃឹមថានឹងអាចរំដោះខ្លួនចេញបានពីវដ្តសង្សារនៃភាពក្រីក្រគោកយ៉ាកហើយស្តារឡើងវិញនូវភាពថ្លៃថ្នូររបស់ប្រជាជាតិមួយដែលធ្លាប់តែមានមោទនភាព និងដែលធ្លាប់ត្រូវបានគេគោរពនិងកោតសរសើរ" ជាមួយនឹងការតម្រង់ទិសបន្ថែមដ៏ខ្ពង់ខ្ពស់ពី **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ក្នុងស្មារតីមុឺងម៉ាត់ ហ្មត់ចត់ និងភាពឈ្លាសវៃ សម្រាប់ការអនុវត្តការងារកែទម្រង់គឺ "កិច្ចការកែទម្រង់ដែលជោគជ័យត្រូវតែពឹងផ្អែកលើកត្តាសំខាន់៤ ទី១.ត្រូវមានចក្ខុវិស័យច្បាស់លាស់ ទី២. ត្រូវមានការប្តេជ្ញាចិត្តខ្ពស់ ទី៣. ត្រូវមានការចូលរួមដោយភាពស្មោះត្រង់ និងទី៤.ត្រូវមានការលះបង់"។

ក្នុងន័យនេះ ដើម្បីសម្រេចបាននូវការកសាងប្រព័ន្ធច្បាប់មួយដែលមានបូរណភាព ពេញលេញ ខ្ញុំសូមផ្តល់មតិយោបល់ជាអនុសាសន៍ជូន អនុប្រធាននិងសមាជិក-សមាជិការនៃគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងតួអង្គ៣ក់ព័ន្ធ ដូចខាងក្រោម៖

ទី១.អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវរៀបចំក្របខ័ណ្ឌទស្សនាទានស្តីពីការកសាងប្រព័ន្ធច្បាប់កម្ពុជា ដោយឆ្លុះបញ្ចាំងពីកម្មវិធីសកម្មភាពដែលមានកំណត់នៅក្នុងក្របខ័ណ្ឌយុទ្ធសាស្ត្រនៃការកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល និងលទ្ធផលនៃសិក្ខាសាលានេះ ដើម្បីជាក់ជូនគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ពិនិត្យនិងសម្រេច។

ទី២. ប្រមូលចងក្រងស្នាដៃអត្ថបទស្រាវជ្រាវរបស់ថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បញ្ញវន្តច្បាប់ ប្រវត្តិសាស្ត្រ បុរាណវិទ្យា អរិយធម៌ វប្បធម៌ និងរួមទាំងអ្នកជំនាញការជាតិនិងអន្តរជាតិសម្រាប់បោះពុម្ពនិងផ្សព្វផ្សាយជាសាធារណៈ។

ទី៣. ប្រមូលចងក្រងខ្លឹមសារនៃសុន្ទរកថា បទបង្ហាញ និងវេទិកាពិភាក្សានៅក្នុងសិក្ខាសាលាទាំងមូលសម្រាប់បោះពុម្ពនិងផ្សព្វផ្សាយជាសាធារណៈ។

ទី៤. អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ត្រូវបង្កើតក្រុមការងារដើម្បីសិក្សាអំពីគម្ពីរអឋ៌សាស្ត្រ (Arthashastra)។

ទី៥. រៀបចំសេចក្តីព្រាងសារាចររបស់រាជរដ្ឋាភិបាលដែលតម្រូវឱ្យរាល់សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តត្រូវភ្ជាប់មកជាមួយការបញ្ជាក់អំពីអនុលោមភាពតាមយុទ្ធសាស្ត្របញ្ចកោណ និងចក្ខុវិស័យ២០៥០។

ឯកឧត្តម លោកជំទាវ លោក លោកស្រី

ជាថ្មីម្តងទៀត ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងក្នុងនាមជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ខ្ញុំសូមថ្លែងអំណរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ សាស្ត្រាចារ្យ បញ្ញវន្តច្បាប់ ប្រវត្តិសាស្ត្រ បុរាណវិទ្យា អរិយធម៌ វប្បធម៌ និងរួមទាំងអ្នកជំនាញការជាតិនិងអន្តរជាតិទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងកិច្ចពិភាក្សាយ៉ាងផុសផុល ផ្តល់ធាតុចូល ជាមតិយោបល់យ៉ាងក្បោះក្បាយ និងសូមលើកទឹកចិត្តឱ្យមានការចូលរួមសិក្ខាសាលាបន្តបន្ទាប់ទៀត ជាពិសេស ចូលរួមក្នុងកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល ប្រកបដោយស្មារតីសហការល្អ ការទទួលខុសត្រូវខ្ពស់ និងធ្វើឱ្យការងារកែទម្រង់ដ៏លំបាកស្មុគស្មាញនេះទទួលបាននូវផ្លែផ្កាជាវិជ្ជមានសម្រាប់អនាគតប្រទេសកម្ពុជារបស់យើង។ ការងារកែទម្រង់ច្បាប់មិនមែនជាការងារដោច់ដោយឡែករបស់គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ឬទីស្តីការគណៈរដ្ឋមន្ត្រីនោះទេ តែជាការងារកែទម្រង់ច្បាប់របស់ប្រទេសទាំងមូលដែលទាមទារឱ្យមានការចូលរួមពីគ្រប់តួអង្គក្នុងសង្គមទាំងអស់។

ខ្ញុំក៏សូមអរគុណជាពិសេសម្តងទៀត ចំពោះសាស្ត្រាចារ្យបរទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ បន្ថែមលើការងារប្រចាំថ្ងៃរបស់ខ្លួន ចូលរួមផ្តល់ជាអត្ថបទស្រាវជ្រាវ និងបានធ្វើដំណើរឆ្លងកាត់តំបន់ ឆ្លងកាត់ទ្វីប ចូលរួមដោយផ្ទាល់ក្នុងសិក្ខាសាលារបស់យើងប្រកបដោយសុច្ឆន្ទៈនិងទឹកចិត្តទូលំទូលាយ។ ខ្ញុំរំពឹងថា សាស្ត្រាចារ្យបរទេស អ្នកជំនាញការអន្តរជាតិ នឹងបន្តចូលរួមជាមួយគណៈកម្មាធិការដឹកនាំការកែទម្រង់

ច្បាប់ ដោយផ្តល់នូវជំនួយបច្ចេកទេសចាំបាច់នានាបន្ថែមទៀត ក្នុងបុព្វហេតុកែទម្រង់ប្រព័ន្ធច្បាប់កម្ពុជា ដោយរក្សានូវគុណតម្លៃប្រវត្តិសាស្ត្រ និងឧត្តមានុវត្តន៍អន្តរជាតិស្របតាមតម្រូវការជាក់ស្តែងរបស់សង្គម និងនិន្នាការជាសាកល។

ខ្ញុំក៏សូមយកឱកាសនេះវាយតម្លៃខ្ពស់ជូនដល់អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ចំពោះកិច្ចខិតខំប្រឹងប្រែង និងការលះបង់ពេលវេលា ទាំងកម្លាំងកាយចិត្តក្នុងការរៀបចំនិងសម្របសម្រួលសិក្ខាសាលាដែលមានគុណតម្លៃជាប្រវត្តិសាស្ត្រយៈពេល២ថ្ងៃនេះ ព្រមទាំងសូមលើកទឹកចិត្តឱ្យបង្កើនការប្រឹងប្រែងឱ្យកាន់តែខ្លាំងឡើងថែមទៀតក្នុងការងារកែទម្រង់ច្បាប់ដើម្បីជាឧត្តមប្រយោជន៍របស់ប្រទេសជាតិយើង។

ជាទីបញ្ចប់ ខ្ញុំសូមប្រគេនពរ និងជូនពរ ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គសិក្ខាសាលាទាំងមូល សូមប្រកបដោយ សុខភាពល្អ និងទទួលបានជោគជ័យគ្រប់ភារកិច្ចរៀងៗខ្លួន ព្រមជាមួយនឹងសេចក្តីសុខ និងសេចក្តីចម្រើនគ្រប់ប្រការក្រោមម្លប់នៃសុខសន្តិភាព ព្រមទាំងពុទ្ធពរទាំង៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ខ្ញុំសូមប្រកាសបិទសិក្ខាសាលាស្តីពី "ប្រព័ន្ធច្បាប់កម្ពុជា" ចាប់ពីពេលនេះតទៅ។

សូមអរគុណ!

សុន្ទរកថាស្វាគមន៍
ឯកឧត្តម លី ច័ន្ទតុលា
រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី និងជាអនុប្រធាននិង អគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

សណ្ឋាគារ ANGKOR CENTURY RESORT AND SPA ក្រុងសៀមរាប ខេត្តសៀមរាប

ថ្ងៃទី២៧-២៨ ខែតុលា ឆ្នាំ២០២៥

- ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ ជូនចំពោះ **ឯកឧត្តម ឥន្ទ្រី ទិសរុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់**
- សូមគោរព ព្រះតេជគុណបណ្ឌិត
- ឯកឧត្តមអនុប្រធានតុលាការកំពូល និងឯកឧត្តមប្រធានសាលាឧទ្ធរណ៍ត្បូងឃ្មុំ
- ឯកឧត្តម រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ តំណាងក្រសួង
- ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវនៅកម្ពុជា
- សាស្ត្រាចារ្យ និងអ្នកជំនាញដែលអញ្ជើញមកពី សហរដ្ឋអាមេរិក ជប៉ុន ម៉ាឡេស៊ី ចក្រភពអង់គ្លេស ហុងកុង និងកាណាដា
- លោកនាយកមជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្ម និងលោកប្រធានការិយាល័យមេធាវី
- ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូលជាទីគោរពរាប់អាន!

នៅក្នុងឱកាស ដ៏មហានក្ខត្តឫក្សនេះ ក្នុងនាមអគ្គលេខាធិការគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ និងក្នុងនាមខ្ញុំផ្ទាល់ ខ្ញុំសូមសម្តែងនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ និងកិច្ចស្វាគមន៍យ៉ាងកក់ក្តៅ ជូនចំពោះ**ឯកឧត្តម ឥន្ទ្រី ឥសរុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** ដែលបានផ្តល់កិត្តិយសជាអធិបតីក្នុងសិក្ខាសាលាស្តីពី "**ប្រព័ន្ធច្បាប់កម្ពុជា**"។ ជាមួយគ្នានេះ ខ្ញុំសូមសម្តែងនូវការស្វាគមន៍ ជូនចំពោះ ថ្នាក់ដឹកនាំគ្រប់ក្រសួងស្ថាប័ននៃរាជរដ្ឋាភិបាល និងតុលាការ អ្នកជំនាញ អ្នកស្រាវជ្រាវ ព្រមទាំងអ្នកប្រកបវិជ្ជាជីវៈ និងជាពិសេសអ្នកជំនាញអន្តរជាតិទាំងអស់ ដែលបានធ្វើដំណើរពីចម្ងាយដើម្បីចូលរួមក្នុងព្រឹត្តិការណ៍ដ៏សំខាន់នាពេលនេះ នៅទឹកដីខេត្តសៀមរាប ជាអតីតរាជធានីរបស់អាណាចក្រខ្មែរពីសម័យបុរាណ។ ការរៀបចំសិក្ខាសាលានៅក្នុងតំបន់បេតិកភណ្ឌពិភពលោក ជាមួយនឹងការចូលរួមពីសំណាក់អ្នកជំនាញអន្តរជាតិនាពេលនេះ ឆ្លុះបញ្ចាំងពីគោលបំណងរបស់សិក្ខាសាលាដើម្បីឈានទៅរកការកសាងបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា ស្របតាមគុណតម្លៃប្រវត្តិសាស្ត្រ និងបរិការណ៍របស់កម្ពុជា ជាមួយនឹងគុណតម្លៃសាកល និងឧត្តមានុវត្តន៍អន្តរជាតិ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមសម្តែងនូវការថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ **ឯកឧត្តម ឥន្ទ្រី ឥសរុត ឧបនាយករដ្ឋមន្ត្រីប្រចាំការ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងជាប្រធានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់** ដែលបានដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយក្នុងការផ្តួចផ្តើម និងដឹកនាំរៀបចំសិក្ខាសាលាជាប្រវត្តិសាស្ត្រនាពេលនេះដោយផ្ទាល់ ជាពិសេសការប្រមូលផ្តុំកិច្ចខិតខំប្រឹងប្រែង និងការកសាងថ្នាលថ្នាក់ជាតិដើម្បីធ្វើការកែទម្រង់ប្រព័ន្ធច្បាប់ទាំងមូលគ្រប់ជ្រុងជ្រោយ តាមរយៈការផ្តួចផ្តើមបង្កើតគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ក៏ដូចជារចនាសម្ព័ន្ធនិងហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ព្រមទាំងដឹកនាំតាក់តែង "ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល" រហូតត្រូវបានប្រកាសដាក់ឱ្យអនុវត្តក្រោម អធិបតីភាពដ៏ខ្ពង់ខ្ពស់របស់

សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា កាលពីថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២៥ កន្លងទៅនេះ។

លើសពីនេះទៅទៀតកិច្ចដំណើរការនៃកម្មវិធីសិក្ខាសាលានាថ្ងៃនេះ នឹងមិនអាចដំណើរបានទេដោយគ្មានការចូលរួមពីសំណាក់ ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលបានចំណាយពេលវេលាដ៏មានតម្លៃ និងមមាញឹកដើម្បីអញ្ជើញចូលរួមក្នុងកម្មវិធីសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជាលើកទី១នាពេលនេះ តាមរយៈការចូលរួមជាអត្ថបទស្រាវជ្រាវ ពិភាក្សាក្នុងកិច្ចប្រជុំត្រៀម ផ្តល់យោបល់ ជាវាគ្មិនធ្វើបទបង្ហាញ និងក្នុងវេទិកាពិភាក្សាជាដើម។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ជាកិច្ចបន្ទាប់ ខ្ញុំសូមការអនុញ្ញាតគោរពរាយការណ៍ជាសង្ខេបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងអង្គសិក្ខាសាលាទាំងមូលអំពីរបាយការណ៍នៃការរៀបចំត្រៀមសិក្ខាសាលាកន្លងមក និងកិច្ចដំណើរការនៃសិក្ខាសាលាក្នុងរយៈពេល២ថ្ងៃនេះ។

សិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជានេះត្រូវបានផ្តួចផ្តើមឡើងដោយ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងស្របតាម "ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ច្បាប់របស់រាជរដ្ឋាភិបាល" ក្នុងគោលបំណងសិក្សាអំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក សិក្សាវិភាគប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរាណដល់បច្ចុប្បន្ន ដើម្បីធ្វើការវាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន កំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងរៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា ដើម្បីសម្រេចបាននូវបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា ជាមួយនឹងលទ្ធផលពីរចំទុករួមមាន៖

១. ស្វែងយល់អំពីប្រព័ន្ធច្បាប់ធំៗលើសកលលោក៖ ស្វែងយល់អំពី ប្រព័ន្ធច្បាប់ស៊ីវិល ប្រព័ន្ធច្បាប់អង់គ្លូសាក់សុង ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ ទស្សនវិជ្ជាចិនបុរាណ

ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម គុណសម្បត្តិនិងគុណវិបត្តិ និងការវិវត្តនៃប្រព័ន្ធច្បាប់នីមួយៗ ដើម្បីឈានដល់ការវិភាគនិងកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា

២. វិភាគមូលដ្ឋានគ្រឹះនៃការវិវត្តប្រព័ន្ធច្បាប់កម្ពុជា៖ វិភាគនូវឫសគល់នៃប្រព័ន្ធច្បាប់កម្ពុជាសម័យបុពាណ រួមមាន វប្បធម៌ ទំនៀមទម្លាប់ ជំនឿ សាសនា ប្រព័ន្ធរដ្ឋបាល និងការទទួលឥទ្ធិពលនៃវប្បធម៌ឥណ្ឌាក្នុងការគ្រប់គ្រងរដ្ឋ ដោយផ្តើមចេញពីសម័យបុរេប្រវត្តិ និងបន្តដល់សម័យទំនើប

៣. វាយតម្លៃស្ថានភាពប្រព័ន្ធច្បាប់កម្ពុជានាពេលបច្ចុប្បន្ន៖ សិក្សាអំពីការវិវត្តនៃប្រព័ន្ធច្បាប់កម្ពុជា នាពេលបច្ចុប្បន្ន និងវាយតម្លៃអំពីចំណុចវិជ្ជមាន អវិជ្ជមាន បញ្ហាប្រឈមនានា និងផ្តល់ជាដំណោះស្រាយនិងជម្រើស

៤. កំណត់ធាតុផ្សំនៃអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា៖ សាកល្បងកំណត់នូវធាតុផ្សំនៃអត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា ដែលផ្សារភ្ជាប់ទៅនឹងគុណតម្លៃប្រវត្តិសាស្ត្ររបស់កម្ពុជា និងគុណតម្លៃសាកល

៥. រៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា៖ ជាលទ្ធផលនៃសិក្ខាសាលា នឹងឈានទៅរៀបចំសេចក្តីព្រាងក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា ដើម្បីដាក់ជូន គ.ក.ច. ពិនិត្យនិងសម្រេច និងឈានឆ្ពោះទៅសម្រេចបាននូវ **"បុរណភាពនៃប្រព័ន្ធច្បាប់ និងចីរភាពវប្បធម៌នីតិរដ្ឋ"**។

ដើម្បីសម្រេចបានគោលបំណង និងលទ្ធផលរំពឹងទុកខាងលើ ថ្នាក់ដឹកនាំ និងអ្នកជំនាញជាតិ និងអន្តរជាតិចំនួន ៦០រូប បានចូលរួមពីបណ្តាស្ថានប័នសំខាន់ៗរបស់រដ្ឋរួមមានស្ថានប័នរាជរដ្ឋាភិបាល តុលាការ ក្រុមប្រឹក្សាធម្មនុញ្ញ គ្រឹះស្ថានអប់រំ ស្ថានប័នវិជ្ជាជីវៈ ព្រមទាំងវិស័យឯកជន ព្រមទាំងគ្រឹះស្ថានអប់រំ និងវិជ្ជាជីវៈពីសហរដ្ឋអាមេរិក ជប៉ុន ម៉ាឡេស៊ី ចក្រភពអង់គ្លេស ហុងកុង និងកាណាដា ដោយត្រូវបានបែងចែកទៅជាក្រុមស្រាវជ្រាវលើប្រធានបទចំនួន **៣ធំៗ និង ១១អនុប្រធានបទ** រួមមាន៖

- ប្រធានបទទី១ "ប្រព័ន្ធច្បាប់ធំៗលើសកលលោក" មានចំនួន ៥អនុប្រធានបទ

- ប្រធានបទទី២ "ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន" មានចំនួន ៤ អនុប្រធានបទ
- និងប្រធានទី៣ "ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា"មានចំនួន ២អនុប្រធានបទ។

ដើម្បីធានាភាពជោគជ័យនៃសិក្ខាសាលាទាំងមូល **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** បានដឹកនាំកិច្ចប្រជុំត្រៀមជាមួយអគ្គលេខាធិការដ្ឋាន គ.ក.ច. ចំនួន **៥លើក** ដើម្បីកសាងឯកសារទស្សនាទាន និងកិច្ចការត្រៀមរៀបចំសិក្ខាសាលាទាំងមូល។ អនុវត្តតាមអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** អគ្គលេខាធិការដ្ឋាន គ.ក.ច. បានរៀបចំកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារនៃការរៀបចំសិក្ខាសាលានេះ ចំនួន **១៥លើក**។

រីឯចំពោះការស្រាវជ្រាវមុនសិក្ខាសាលា អគ្គលេខាធិការដ្ឋាន គ.ក.ច. បានរៀបចំក្រុមសម្របសម្រួលបច្ចេកទេសនិងបដិសណ្ឋារកិច្ចគាំទ្រដល់ក្រុមស្រាវជ្រាវ និងវាគ្មិនទាំងអស់ ដោយមានការបង្កើតក្រុមតេឡេក្រាម រៀបចំកិច្ចប្រជុំពិភាក្សាដោយផ្ទាល់ និងតាមរយៈ Zoom ដើម្បីកំណត់វិធីសាស្ត្រស្រាវជ្រាវ ពិនិត្យពិភាក្សាលើវឌ្ឍនភាពនៃការស្រាវជ្រាវ សរុបចំនួន **៣៦លើក**។ ជាលទ្ធផលអត្ថបទ **ចំនួន១៥** ស្មើនឹងប្រមាណជាង **៧០០ទំព័រ** ត្រូវបានតាក់តែងឡើង។

ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ, ឯកឧត្តម, លោកជំទាវ, លោក, លោកស្រី!

ជាកិច្ចបន្ទាប់ ខ្ញុំសូមគោរពអនុញ្ញាតបន្តជម្រាបជូន **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងអង្គសិក្ខាសាលាទាំងមូលអំពីកិច្ចដំណើរការរបស់សិក្ខាសាលាដូចតទៅ។

មុននឹងសិក្ខាសាលាចាប់ផ្តើម ពិធីពិសាកោជនាហារស្វាគមន៍ត្រូវបានរៀបចំឡើងកាលពីម្សិលមិញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**

ប្រចាំការ។ មុននិងក្រោយពេលបញ្ចប់ សិក្ខាសាលា ដំណើរកម្សាន្តក្នុងឧទ្យានអង្គរក៏បានរៀបចំផងដែរជូនដល់អ្នកជំនាញអន្តរជាតិ។

ចំពោះសិក្ខាសាលារយៈពេលពីរថ្ងៃនេះ នឹងប្រព្រឹត្តទៅដោយប្រើប្រាស់ភាសាខ្មែរ និងភាសាអង់គ្លេស ដោយមានអ្នកបកប្រែផ្ទាល់មាត់ជាជំនួយផងដែរ។ ក្នុងនោះផងដែរ អគ្គលេខាធិការដ្ឋាន គ.ក.ច. គោរពស្នើសុំការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងការអនុញ្ញាតពីអង្គសិក្ខាសាលាទាំងមូលដើម្បីថតជាវីឌីអូ និងធ្វើប្រតិចារឹកនូវរាល់សុន្ទរកថា បទបង្ហាញ និងវេទិកាពិភាក្សាក្នុងសិក្ខាសាលាទាំងមូល ដើម្បីរក្សាទុកជាឯកសារប្រវត្តិសាស្ត្រ ការសិក្សាស្រាវជ្រាវបន្ត និងជាពិសេសសម្រាប់ការរៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា។

បន្តមកកាន់របៀបវារៈនៃកម្មវិធីរយៈពេល ២ថ្ងៃនេះ អង្គសិក្ខាសាលានឹងត្រូវបានចាប់ផ្តើមដោយសុន្ទរកថាបើករបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ**។ រីឯបទបង្ហាញ និងវេទិកាពិភាក្សាអំពីប្រធានបទទី១ស្តីពី៖ "ប្រព័ន្ធច្បាប់ធំៗលើសកលលោក" និងបទបង្ហាញ និងវេទិកាពិភាក្សាប្រធានបទទី២ស្តីពី៖ "ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន" នឹងត្រូវរៀបចំឡើងក្នុងថ្ងៃទី១ ចំណែកបង្ហាញ និងវេទិកាពិភាក្សាប្រធានបទទី៣ស្តីពី៖ "ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា" នឹងត្រូវរៀបចំឡើងក្នុងថ្ងៃទី២។

សម្រាប់ប្រធានបទទី ១ ស្តីពី៖ "ប្រព័ន្ធច្បាប់ធំៗលើសកលលោក" បានបែងចែកជាអនុប្រធានបទចំនួន៥ ដោយមានការធ្វើបទបង្ហាញពីវាគ្មិនជាតិ និងអន្តរជាតិដូចខាងក្រោម៖

- ប្រធានបទស្តីពី៖ **"ប្រព័ន្ធច្បាប់ស៊ីវិល"** ធ្វើបទបង្ហាញដោយ Prof. Vernon Valentine Palmer បណ្ឌិតផ្នែកច្បាប់ពីសាកលវិទ្យាល័យ Oxford ប្រទេសអង់គ្លេស និងជាសាស្ត្រាចារ្យច្បាប់នៃសាកលវិទ្យាល័យ Tulane សហរដ្ឋអាមេរិក ។
- ប្រធានបទស្តីពី៖ **"ប្រព័ន្ធច្បាប់អង់គ្លូសសាក់សុង"** ធ្វើបទបង្ហាញដោយ លោកជំទាវ Dato Mary Lim Thiam Suan អតីតចៅក្រមនៃតុលាការកំពូលម៉ាឡេស៊ី និងនាយិកាមជ្ឈមណ្ឌលមជ្ឈត្តការអន្តរជាតិអាស៊ាន

- ប្រធានបទស្តីពី៖ "**ប្រព័ន្ធច្បាប់សាសនាហិណ្ឌូ**" ធ្វើបទបង្ហាញដោយ Prof. Gopika Solanki បណ្ឌិតផ្នែកច្បាប់ សង្គម និងនយោបាយពីសាកលវិទ្យាល័យ McGill ប្រទេសកាណាដា និងជាសាស្ត្រាចារ្យផ្នែកវិទ្យាសាស្ត្រនយោបាយនៃសាកលវិទ្យាល័យ Carleton ប្រទេសកាណាដា
- ប្រធានបទស្តីពី៖ "**ទស្សនវិជ្ជាចិនបុរាណ**" ធ្វើបទបង្ហាញដោយ Dr. Yu Kam Por អតីតនាយកមជ្ឈមណ្ឌលអប់រំទូទៅ នៃសាកលវិទ្យាល័យពហុបច្ចេកទេសហុងកុង
- ប្រធានបទស្តីពី៖ "**ទស្សនវិជ្ជាពុទ្ធសាសនានិងច្បាប់សង្គម**" ធ្វើបទបង្ហាញដោយ **លោក ហេង មណីចិន្តា** ប្រធានអង្គការពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍។

បន្ទាប់ពីបានសិក្សាស្វែងយល់ស៊ីជម្រៅលើប្រព័ន្ធច្បាប់ធំៗលើសកលលោក យើងនឹងបន្តពិភាក្សាលើប្រធានបទទី២ស្តីពី៖ **ប្រព័ន្ធច្បាប់កម្ពុជាពីសម័យបុរេប្រវត្តិដល់បច្ចុប្បន្ន** ដោយសិក្សាអំពីប្រវត្តិ និងឫសគល់នៃការវិវត្តប្រព័ន្ធច្បាប់ក្នុងសង្គមកម្ពុជា ចាប់ពីសម័យបុរេប្រវត្តិ ដល់បច្ចុប្បន្ន និងធ្វើការសន្និដ្ឋានអំពីប្រភពនៃប្រព័ន្ធច្បាប់នានាដែលប្រព័ន្ធច្បាប់កម្ពុជាទទួលរងឥទ្ធិពលនិងបានអនុវត្ត។ លទ្ធផលស្រាវជ្រាវក្នុងប្រធានបទទី២ នេះនឹងត្រូវបានធ្វើបទបង្ហាញនិងសម្របសម្រួលវេទិកាពិភាក្សា និងសំណួរ-ចម្លើយ ដោយ **ឯកឧត្តមបណ្ឌិត ហ៊ែល ចំរើន** រដ្ឋលេខាធិការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សមាជិក គ.ក.ច. និងជាអនុប្រធានប្រចាំការក្រុមប្រឹក្សានីតិកម្ម។

ឈរលើមូលដ្ឋានខាងលើនេះ អង្គសិក្ខាសាលានឹងបន្តពិភាក្សាលើប្រធានបទទី៣ ស្តីពី៖ **ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា និងទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា** ដែលបានបែងចែកជាវេទិការពិភាក្សាលើអនុប្រធានបទចំនួន២។ ចំពោះវេទិកាពិភាក្សាលើអនុប្រធានបទ ៣.១ ស្តីពី "**ការកំណត់អត្តសញ្ញាណប្រព័ន្ធច្បាប់កម្ពុជា**" នឹងត្រូវបានសម្របសម្រួលដោយ **ឯកឧត្តមបណ្ឌិត ស៊ា ម៉ៅ** រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី **និងជាអនុប្រធានប្រចាំការ គ.ក.ច.**។ រីឯវេទិកាពិភាក្សាលើអនុប្រធានបទ ៣.២ ស្តីពី "**ទិសដៅឆ្ពោះទៅរកបូរណភាពនៃប្រព័ន្ធច្បាប់កម្ពុជា**" នឹងត្រូវបានសម្របសម្រួលដោយខ្ញុំបាទផ្ទាល់។

ជាចុងក្រោយអង្គសិក្ខាសាលា នឹងត្រូវបិទបញ្ចប់ដោយសុន្ទកថាបិទកម្មវិធីរបស់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** ដើម្បីផ្តល់មតិដឹកនាំ និងអនុសាសន៍គន្លឹះដ៏ខ្ពង់ខ្ពស់ សម្រាប់ជាប្រទីបបំភ្លឺផ្លូវដល់អង្គសិក្ខាសាលា និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ក្នុងការបំពេញកិច្ចការនានា ក្រោយការបញ្ចប់សិក្ខាសាលាដើម្បីឈានទៅដល់ ការរៀបចំរៀបចំក្របខ័ណ្ឌទស្សនាទាននៃការកសាងប្រព័ន្ធច្បាប់កម្ពុជា។

ក្នុងនាមអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់ ខ្ញុំជឿជាក់ថាសិក្ខាសាលាស្តីពី **"ប្រព័ន្ធច្បាប់កម្ពុជា"** ជាប្រវត្តិសាស្ត្រនាពេលនេះនឹងទទួលបានលទ្ធផលតាមការរំពឹងទុក ដែលនឹងរួមចំណែកដល់ការសម្រេចបាននូវការអនុវត្តយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល សំដៅកសាងគ្រឹះដើម្បីឆ្ពោះទៅសម្រេចបានចក្ខុវិស័យកម្ពុជាឆ្នាំ២០៥០។

មុននឹងបញ្ចប់ យើងខ្ញុំសូមគោរពខន្តីអភ័យទោសពីសំណាក់ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** និងអង្គសិក្ខាសាលាទាំងមូលចំពោះកំហុងឆ្គង និងការខ្វះចន្លោះដែលបានកើតឡើងដោយអចេតនា។

ជាទីបញ្ចប់ ខ្ញុំសូមប្រគេនពរ និងគោរពជូនពរ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** ឯកឧត្តម លោកជំទាវ លោក លោកស្រី និងអង្គពិធីទាំងមូល សូមសមប្រកបដោយសុខភាពល្អ និងទទួលបានជោគជ័យគ្រប់ការកិច្ចរៀងៗខ្លួន ព្រមជាមួយពុទ្ធពរទាំង ៤ប្រការ គឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

ដោយសេចក្តីគោរពដ៏ខ្ពង់ខ្ពស់ ខ្ញុំសូមគោរពអញ្ជើញ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ** ថ្លែងសុន្ទរកថាបើកសិក្ខាសាលា ផ្តល់មតិដឹកនាំ និងអនុសាសន៍គន្លឹះដ៏ខ្ពង់ខ្ពស់ សម្រាប់ជាប្រទីបបំភ្លឺផ្លូវ ដល់សិក្ខាសាលាជាប្រវត្តិសាស្ត្រដ៏មានសារសំខាន់មួយនេះ។

សូមគោរពអញ្ជើញឯកឧត្តមឧបនាយករដ្ឋមន្ត្រីប្រចាំការ

ឧបសម្ព័ន្ធទី៣៖
កម្រងរូបភាពនៃសិក្ខាសាលាស្តីពីប្រព័ន្ធច្បាប់កម្ពុជា






The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee
SYMPOSIUM
ON CAMBODIA'S
LEGAL SYSTEM




SYMPOSIUM
ON CAMBODIA'S


The Legal Reform Committee
SYMPOSIUM
ON CAMBODIA'S
LEGAL SYSTEM


The Legal Reform Committee


គណៈកម្មាធិការជំនាញកែទម្រង់ច្បាប់
The Legal Reform Committee


គណៈកម្មាធិការជំនាញកែទម្រង់ច្បាប់
The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee
Directions Toward the Integrity of Cambodia's Legal System
SYMPOSIUM ON CAMBODIA'S LEGAL SYSTEM


The Legal Reform Committee
SYMPOSIUM ON CAMBODIA'S LEGAL SYSTEM
Identity of Cambodia's Legal System


The Legal Reform Committee
Identity of Cambodia's Legal System


The Legal Reform Committee
rity of Cambodia's Legal System
Siem Reap, 27th - 28th October 2023
H.E. Kong Phallack
Secretary of State of
Rector of


The Legal Reform Committee
Professor Dr. Un Leang
Dean of the Faculty of Social Science
at the Royal University of
Mrs. Kasumi Nakagaw
Chambers in the Courts


The Legal Reform Committee
Organized By: Legal Reform Cor
Siem Reap, 27th - 28th October


The Legal Reform Committee
Organized By: Legal Reform Comm
Siem Reap, 27th - 28th October 20


The Legal Reform Committee
POSIUM ON CAMBODIA'S LE
Organized By: Legal Reform Com
Siem Reap, 27th - 28th October


The Legal Reform Committee
POSIUM ON CAMBODIA'S LEGA
Organized By: Legal Reform Commi
Siem Reap, 27th - 28th October 202


The Legal Reform Committee
MPOSIUM ON CAMBODIA'S LEG
Organized By: Legal Reform Comm
Siem Reap, 27th - 28th October 20


The Legal Reform Committee
SYMPOSIUM ON CAMBODIA'S
Organized By: Legal Reform
Siem Reap, 27th - 28th Oct


The Legal Reform Committee
SYMPOSIUM ON CAMBODIA'S
Organized By: Legal Reform C
Siem Reap, 27th - 28th Octob


The Legal Reform Committee
SYMP IM ON BODIA'S LEGAL SYSTEM
28th October 2025






The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee


The Legal Reform Committee






The Legal Reform Committee





ទីស្តីការគណៈរដ្ឋមន្ត្រី

គណៈកម្មាធិការដឹកនាំការកែទម្រង់ច្បាប់

អគារលេខ OC-1818A វិថី OCIC សង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ

លេខទូរស័ព្ទ៖ +85511 625351 សារអេឡិកត្រូនិក៖ event@lrc.gov.kh គេហទំព័រ៖ www.lrc.gov.kh